ពន្ធបសុទិយា

ទស្សនាវិជ្ជី ផ្សាយជំណឹងទាងសាសនា នឹងអក្សរសាស្ត្រ



ឆ្នាំទី ២៩ លេខ ១ ខែមករា ព.ស. ២៤៩៩ ឧ.ស. ១៩៥៥



ទស្សនាវដ្ដី ផ្សាយដំណឹងទាងសាសនា នឹងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្ស

ផ្នែកសាសនា	បញ្ជីរៀង	ទំព័រ
– ពីណនុបដ្ឋានកថា	ព្រះភិក្ខុ ប៉ាង ទាត់	១
– ប្រហ្មលទ្ធិភប់អានឡោចបិសាច . .	យុនបណ្ណានុវ័ក្ស ប៉ូ-ប៉ូ	១០
– មាតាបិតាមានគុណមែនឬ	យុនអត្ថកោវិទ ដា-យូរ	១៩
ផ្នែកអក្សរសាស្ត្រ		
– សារិការនាងហ្សីនដាកឺ	លោក អ៊ុ-ហ៊ី . . . . ប្រែ	៣៤
– ឿងត្រីមាស	លោក សក់-ទាត់	៤១
– សុភាសិតប្រដៅដនប្រុសស្រី . . .	ព្រះយោសធម្ម ម៉ុង-សែស	៥០
– សាសនាតិស្សាមនឹងសាសនាកាតូលិក	លោក ទៀង-រិតឈុន . ប្រែ	៦៤
– ពេជ្រព្រះភដា (ពមក)	លោក ស៊ុន-ហ៊ាន . . . ប្រែ	៧១
– ឿងសាមកុក (ពមក)	ឧកញ៉ា ឆូ-កន . . . . ប្រែ	៧៨
កំណត់ប្រវត្តិការណ៍		
– វចនានុក្រមសំស្ត្រឹតខ្មែរ	វីរិយបណ្ឌិតោ ភិក្ខុ ប៉ាង-ទាត់	៩៤

មួយឆ្នាំមាន ១៤សៀវភៅ–ដំវៃឈ្មោះ ៤៣០៤០០

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique

TABLE DES MATIÉRES

PARTIE RELIGIEUSE:

-Gilanupatthanakatha . . . . . par vén. *PANG-KHAT*..1
-Les diables . . . . . par *M*. . . . *BOU-PO* ... 10
-Reconnaissance envers les parents . . . . . par *M*. *CHEA-YOU* 19

PARTIE LITTERAIRE:

-Histoire de Jeanne d'Arc (en vers) . . . . par *M*. *OUM-HY* 32
-Histoire du poisson d'or . . . . . par *M*. *SAK-KHAT* ...41
-Bons Conseils . . . . . par vén. *MŒUNG-SES* . 50
-L'Islamisme et le catholicisme traduit par *M*. *TIANG-TAY-CHHUN*. 64
-Conte "*LE DIAMANT DE RAJA*" (suite) traduit par *M*. *SIN-HEAN*. 71
-Histoire de samkok (suite) . . . . . traduit par *M*. *NOU-KAN* ... 78

NOTES ET CHRONIQUES:

-Dictionnaire Sanskrit - Khmer . . . . . par vén. *PANG-KHAT* ... 92

Prix d'abonnement annuel (comprenant 12 numéros): 230$00

ផ្នែកសាសនា

គិលានុបដ្ឋានកថា

វិរិយបណ្ឌិតោ ភិក្ខុ-ប៉ាង-ទាត់

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

អរោគា បរមា លាភា

"ការមិនមានរោគ ជាបរមលាភ"

រៀលានេះ អាត្មាភាពបានទទួលការៈមកសំដែងធម៌ទេសនា តាម
សេចក្តីនិមន្តក្រុមអភិបាលសមាគមគិលានសង្ត្រោះចំពោះព្រះសង្ឆពុទ្ធសា-
សនិក ក្នុងទិវាសបុណ្យរំលឹកថ្ងៃកំណើតមន្ទីរពេទ្យព្រះសង្ឆ ។ អាត្មាភាព
សូមលើកយកពុទ្ធភាសិតមួយបទមកសំដែង ឲ្យឈ្មោះថា **គិលានុបដ្ឋាន-**
កថា *ជូចបទបាលីថា* អរោគា បរមា លាភា *"ការមិនមានរោគ*
ជាបរមលាភ" ទុកជាទីសណ្ឋាប់ពុទ្ធបរិស័ទទាំងឡាយ ដើម្បីជាប្រយោជន៍
ក្នុងការផ្គត់ផ្គង់មន្ទីរពេទ្យព្រះសង្ឆ ជូចសេចក្តីតទៅ:—

នរជនទាំងឡាយដែលកើតមកមានរូបជាអង្គមនុស្សនេះតែងតែមាន
រោគបៀតបៀននាំឲ្យលឺចាប់ជាធម្មតា ឥតមាននរជនណាមួយគេចរៀស
ឲ្យរួចផុតពីរោគបៀតបៀននេះបានឡើយ ។ បើនរជនណាមិនសូវមាន
រោគាព្យាធិបៀតបៀនទេ នរជននោះ ឈ្មោះថាមានលាភយ៉ាងវិក្រៃលែង

សមដូចពុទ្ធភាសិត ដែលបានពោលទុកខាងដើមថា អរោគា បរមា លាភា "ការមិនមានរោគ ជាបរមលាភ" ។ អធិប្បាយសេចក្តីថា រាងកាយយើងនេះទុកដូចជា សរីរយន្ត ដូចគ្រឿងយន្តផ្សង ។ ជាទីប្រជុំនៃអាការៈ ៣៦ ប្រការ ហៅថា គោដ្ឋាសៈ, គោដ្ឋាសៈនេះមានតាទីផ្ទើ កិច្ចការទំនុកបំរុងរាងកាយឲ្យប្រព្រឹត្តទៅ បើគោដ្ឋាសៈណានីមួយវិកលឬទាស់ទំនងប្រព្រឹត្តទៅមិនស្រួល ពិការនៃរាងកាយក៏កើតមានឡើង គឺបេញអាការរញ្ជារញ្ជាញ្ជាក្តៅត្រជាក់ ស៊ីមិនបាន ដេកមិនបាន នឹងអាការផ្សង ។ ទៀតរាប់មិនអស់ នាំឲ្យឈឺចាប់ចាក់ដោត ក្តៅក្រហាយ រាលរាលរសាប់រសល់អន់ទន់ឡោយទៅជាទុព្ទលភាព ទាំងអស់នេះ លោកហៅថា រោគ ។

រោគនេះមានសមុដ្ឋានច្រើនប្រការណាស់ បើមានរោគកើតឡើងហើយ យើងនឹងប្រកបកិច្ចការអ្វី ។ ពុំបានទេ រោគនេះជាហេតុនាំឲ្យខាតលាភធំបំផុត គឺខាតរៀនសូត្រ ខាតរកទ្រព្យ ខាតរកធមិ ខាតរកប្រយោជន៍ត្រប់ប្រការ អ្វីដែលយើងត្រូវបានទាំងប៉ុន្មានក៏ខាតបង់ទាំងអស់ បើយើងមិនមានរោគទេ ឈ្មោះថាយើងមានលាភ ព្រោះរៀនសូត្រចំណេះវិជ្ជាបាន រកទ្រព្យសម្បត្តិបាន ស្វែងរកធមិបាន រកប្រយោជន៍ត្រប់ប្រការបាន អ្វីដែលយើងត្រូវបានទាំងប៉ុន្មាននឹងបានទាំងអស់ មិនខាតបង់សាបសូន្យប្រយោជន៍ទេ ហេតុនេះហើយបានជាព្រះបរមសាស្តាចារ្យនៃយើងត្រាស់ទេសនាទុកថា ការមិនមានរោគ ឈ្មោះថាជាលាភយ៉ាងក្រៃលែង ។

យើងបានឃើញកម្លាំងពេលវេលាដែរ ដែលបៀតបៀនយើងគ្រប់ ។ ត្រូវមកហើយ ខ្លួនយើងក៏ជាប់មានពេល អ្នកដទៃក្រៅពីយើងក៏ជាប់មានពេល ។ ពេលនេះ ធ្វើទុក្ខបុកម្នញសត្វលោកពាល់រូបឲ្យកើតទុក្ខវេទនាពាល់ខ្លួនពិភពត្រូ ត្រោះរូបនេះជាទីលំនៅនៃពេល ដូចមន្ទីរទេឲ្យជាទីលំនៅសម្រាប់មនុស្សឈឺដូច្នោះឯង លុះត្រាតែមិនមានរូបទើបមិនមានពេល បើយើងពិនិត្យមើលក្នុងរូបខ្លួនយើង យើងក៏ឃើញប្រត្យក្សថាខ្លួនយើងមានពេលបៀតបៀន មិនដែលបានជាសុះសៀយស្អែកល្ងាចម្តងណាទេ មានតែឈឺជាក់ជោគជាប់ជានិច្ច តែជាយថាធម៌រស់ក៏ចេះតែត្រូវខំធ្វើការទៅ ដើម្បីរឿងគ្រឿងបរិភោគបរិភោគល្មមល្មៀងដើរតែឲ្យប្រក្រឹត្តទៅ ។ មែនពិត ពេលនេះគឿងសត្វលោកទៅរកសេចក្តីស្លាប់ ដូចគោយាតក៏គឿងគោទៅកាន់ទីគោយាតដូច្នោះឯង ។ មើលចុះ! តិក្ខនេះ សាមណេរនោះ តានេះ យាយនោះ អ្នកនេះ នាងនោះ ឈឺគោះ ឈឺដៃជើង ឈឺក្បាលវិលមុខ គ្រុនកមរមាស់ ល្បែងរីឆ្ងៃរពេតពិសត្តិក្រហល់ក្រហាយ រូបពងរស្ងួតស្ងាំងស្ពាំងស្ពមថមថយកម្លាំងដើរទប់តែខ្លួនញាក់ទេទ្រើត មុខមាត់ក្រៀមក្រស់មុខតួឲ្យអាសូរពន់ពេកណាស់ ។ ស្រុកណា ភូមិណា ប្រទេសណា ក៏មានពេលដូចគ្នាពាំងអស់កើតទៅជាទុក្ខវេទនាយ៉ាំងធំសម្បើម ជាប្រស្នាធំមួយដែលសកលលោកសត្វថ្លៃកំពុងជោរស្រាយ ។

សេចក្តីទុក្ខវេទនានេះ អ្នកមានចិត្តប្រកបដោយកុសលធម៌ពន់ប្រាំនៅឈរព្រងើយមិនខាំភាក់ឡើងទេ មានតែមនុស្សចិត្តថ្លង់ទេ ដែលមិន

យកចិត្តទុកដាក់ត្រឡប់មើល ហេតុនេះ ករុណាធម៌ ជាធម៌របស់មហាបុរស ព្រោះលោកមានឥន្ទ្រិយស្រួយធំទូលាយ លោកឆន់ទ្រាំឈរនៅព្រងើយកន្តើយពុំបាន ព្រោះករុណាធម៌ ។ ករុណា ជាធម្មជាតិស្អប់ចិត្ត ដែលចូលទៅធ្វើចិត្តទ្រាំម្រើកញាប់ញ័រនៅស្ងៀមព្រងើយមិនបាន ក្នុងកាលដែលបានឃើញជនដទៃមានសេចក្តីទុក្ខលំបាកមកបៀតបៀន កាលបើមានជនណាដួយកើតទុក្ខលំបាកដោយហេតុណាមួយហើយ លោកកំកើតចិត្តអាណិតអាសូរគោរពខ្នាតទៅរក នៅស្ងៀមព្រងើយមិនទាំពាពុំបាន តែងតែអនុគ្រោះជួយរំដោះទុក្ខ ជួយទ្រូលទ្រាយជនខ្លះ ។ ឲ្យបានធូរស្រាលចាកទុក្ខ ជួយការពារសេចក្តីទុក្ខអន្តរាយជនខ្លះ ។ តាមកម្លាំងដែលខ្លួនលោកអាចជួយបាន ។ ករុណាធម៌មានការជួយបន្ថែមទ្រើទ្រួយស្រាលសេចក្តីទុក្ខលំបាក ឬ សេចក្តីអន្តរាយនៃជនដទៃជាលក្ខណៈ មានការជួយការពារខ្លួនដែលមានចិត្តជាតិលំអៀងមិនឲ្យនៅស្ងៀមបាន ក្នុងកាលដែលខ្លួនបានឃើញជនដទៃកំពុងរងទុក្ខលំបាក ឬសេចក្តីអន្តរាយផ្សេង ។ មានចិត្តខ្ញោចផ្សាអាណិតអាសូរគោរពខ្នាតទៅរកជនរងគ្រោះជាគុណសម្បត្តិ ។ ករុណាធម៌នេះ កាលបើមិនមានការបៀតបៀនដំផ្ទួចបំផ្លាញទេ ទើបចិតនៅស្ងៀមបាន ឯសេចក្តីខ្ញោចផ្សាក្នុងចិត្តក៏មិនមានកើតឡើងដែរ ព្រោះការគិតបៀតបៀនដំផ្ទួចបំផ្លាញជនដទៃជាសិក្ខាសត្រូវរបស់ករុណាធម៌ដោយចំពោះ ឯសេចក្តីខ្ញោចផ្សាចិត្ត ជាធម៌ដែលខ្លួវអមជាមួយករុណាធម៌ ។ អ្នកឯងគំនិតត្រិះរិះយល់ថា ការខ្ញោចផ្សាចិត្តក្នុងពេលដែលញាតិមិត្តបានខូលខ

សេចក្តីទុក្ខអន្តរាយ នេះជាករុណាធមិ តែដែលពិតនោះ ពុំមែនជូច្នោះ
ទេ គឺសេចក្តីទ្វាចជ្សាឈ៉ឆ្ពាលនេះឯង ជាធមិនាំបណ្តាលឲ្យករុណាធមិ
ស្ទុះចេញមកពីជួងចិត្ត បានជាព្រះអរហន្តទាំងឡាយមានព្រះសម្មាសម្ពុទ្ធ
ជាដើមទ្រង់សំដែងប្រដៅទុកថា ឲ្យបណ្តុះបណ្តាលករុណាធមិឲ្យកើតជុះ
ជាលបរិបូណិឡើងក្នុងសន្តានចិត្ត ព្រោះថាករុណាធមិជាធមិប្រសើរមួយ
ជួយសម្រាលសេចក្តីទុក្ខសត្វលោក ប្រៀបដូចជាគ្រូពេទ្យដែលទ្រទ្រង់នូវ
គុណធមិដ៏ប្រសើរ តែងរក្សាព្យាបាលមនុស្សឈ៉ឡាយឲ្យបានជាសះ
ស្បើយចាករោគដោយករុណា ព្រោះយកចិត្តប្រកបដោយករុណាជាធំ
មិនបានគិតដល់ទបការតបវិញជាប្រមាណ ។ ហេតុនេះករុណាធមិជា
គុណធមិមួយប្រសើរយ៉ាំងក្រៃលែង យើងអាចនឹងពោលបានថា បើ
មនុស្សលោកមានចិត្តប្រកបដោយករុណាធមិគ្រប់គ្នា លោកទាំងមូលនឹង
ពេញដោយសេចក្តីសុខចំរើនគ្រប់ប្រការពុំខានឡើយ ។

មនុស្សយើងនឹងរស់នៅដោយសុវត្ថិភាពបានក៏ដោយមនុស្សមានចិត្ត
ប្រកបដោយករុណា ចេះជួយគ្នាទៅវិញទៅមកតាមសមគួរដល់កិច្ចការ គឺ
មាតាបិតាជួយបុត្រធីតា បុត្រធីតាជួយមាតាបិតា ស្វាមីជួយភរិយា ភរិយា
ជួយស្វាមី ញាតិជួយញាតិ មិត្រជួយមិត្រ អ្នកស្រុកជួយអ្នកស្រុក ភិក្ខុ
សាមណេរជួយទាយកទាយិកា ទាយកទាយិកាជួយភិក្ខុសាមណេរ រដ្ឋ-
ភិបាលជួយរាស្ត្រ រាស្ត្រជួយរដ្ឋភិបាល ប្រទេសជួយប្រទេស ជួយគ្នាទៅ
វិញទៅមកយ៉ាងនេះទើបនឹងអាចធ្វើឲ្យកើតសេចក្តីចំរើនលឿនទៅមុខបាន
ទាំងប្រយោជន៍ផ្ទាល់ខ្លួននឹងប្រយោជន៍សាធារណ៍ ព្រមទាំងធ្វើឲ្យមនុស្ស

មានមេត្តាករុណារឹងតែតែប្រទៃដែមឡើងទៀតផង ។ ក្នុងការជួយគ្នាទៅវិញទៅមកនៅប្រទេសខ្មែរយើងនេះ ព្រះពុទ្ធរដ្ឋាភិបាលក៏បានជួយប្រជាជនជួលមកទៅតាមកាលសម័យខ្លះហើយ គឺបានកសាងមន្ទីរពេទ្យនៅក្រុងភ្នំពេញ នៅខេត្ត នៅស្រុក ដើម្បីជួយប្រជាជនដែលរងទុក្ខវេទនាដោយរោគាព្យាធិឲ្យបានធូរស្រាល តែប្រទេសយើងជាប្រទេសកាន់ពុទ្ធសាសនា មានតិក្ខុសាមណេរប្រើនរូប តិក្ខុសាមណេរទាំងនោះទៅព្យាបាលរោគក្នុងមន្ទីរពេទ្យសាធារណជនឃើញថា ពុំសូវល្អមើលត្រមទាំងមានការលំបាកក្នុងការប្រតិបត្តិចង្ហាន់ផ្លូវវិន័យខ្លះផង ទើបមានឧរគសប្បុរសប្រើនរូបដែលមានចិត្តគោរពព្រះធម៌ដោយកុណាធម៌ មានអធ្យាស្រ័យធំទូលាយ ក៏បានរួបរួមគ្នាបង្កើតជាសមាគមមួយឡើងឲ្យឈ្មោះថា សមាគមគិលានសង្គ្រោះបំពោះព្រះសង្ឃពុទ្ធសាសនិក ដើម្បីកសាងមន្ទីរពេទ្យព្រះសង្ឃផ្សេងដាច់ពីគេមួយ ដួចសម្រាលទុក្ខវេទនាព្រះសង្ឃឲ្យសមតិត្តិយស ជាប្រទេសកាន់ពុទ្ធសាសនា ។ មន្ទីរពេទ្យព្រះសង្ឃនេះបានកសាងរួចស្រេចហើយ ដួចព្រះករុណាព្រះមហាក្សត្រនៃយើងសោកសប្បុរសគាំទ្រយ៉ាងបានច្រើបហើយ ។ ឯមន្ទីរពេទ្យព្រះសង្ឃនេះដែលតើតច្រកផងរូបភាពដ៏ហ្មងនេះបាន ក៏កើតដោយចិត្តករុណានៃលោកសប្បុរសគាំទ្រព្រះសង្ឃគាំទ្រគ្រហស្ថទូទៅតែព្រះពុទ្ធអាណាចក្រ សំដែងឲ្យឃើញថា ប្រទេសខ្មែរយើងដែលមានចិត្តរាយជ្រួតជ្រាបដោយធម៌ក្នុងព្រះពុទ្ធសាសនាបានបង្ហាញសន្ទានបញ្ជាក់ការករុណាធម៌ឲ្យឃើញច្បាស់ មិនទន់ថយជាងប្រទេសកាន់ពុទ្ធសាសនាឯទៀតៗទេ សមគួរទើបបាន

ខ្លួលជាលាន់សង្ឃភេញចរបូណាសមតាមសេចក្តីប្រាថ្នាតុំមាន ។

មន្ទីរពេទ្យព្រះសង្ឃនេះ ស្ថាបនាឡើងដោយការសង្គ្រោះព្រះសង្ឃដែលមានពេតាភាធដែលនិមន្តមកពីទិសទាំង ៤ ដោយចេតនាជាកុសលតុំមែនដោយចេតនាប្រាថ្នាយកចំណាញដូចមន្ទីរពេទ្យឈ្មួលនោះទេ មានបំណងតែមួយ គឺជួយសង្គ្រោះព្រះសង្ឃដែលមានពេតាភាធឲ្យបានជាសះស្បើយចាកពេតាភាធ ផ្តត់ផ្តង់អាហារគោជន ទីអាស្រ័យនៅព្រមទាំងឧសថនិងភេសជ្ជៈផ្សេង ។ តុំបានគិតគូនាវៃថ្លៃទបករណ៍ឬតម្លៃអ្វីមួយឡើយដូច្នេះ ការចាយវាយកន្លងមន្ទីរពេទ្យនេះមួយវៃថ្ងៃ ។ ត្រូវចំណាយបច្ចុប្បន្នណាស់ ជាបន្ទុកមួយយ៉ាងធ្ងន់ធ្ងាក់មកលើពុទ្ធសាសនិកជនខ្លួនៗមិនរើសមុខ ។ ទាន់ព្រះពជរដ្ឋាភិបាលក៏បានលៃលកចំណាយថវិកាជាតិមកជួយខ្លះជំនួយពីបរទេសខ្លះ ប្រជាជនខ្មែរពេញព្រះពជអាណាចក្រមានសទ្ធាចំណាយទ្រព្យមកជួយជាកុសលខ្លះ ដើម្បីទបត្តម្ភមន្ទីរពេទ្យព្រះសង្ឃនេះឲ្យប្រព្រឹត្តទៅដោយប្រពៃ ។

ការបរិច្ចាគទ្រព្យចំពេញកុសលនេះ ប្រជាជនខ្មែរក្រីក្រទេ តែមានកេរ្តិ៍ឈ្មោះប្រសើរណាស់ មិនអន់ថយជាងប្រទេសកាន់ពុទ្ធសាសនានានាប្រទេសទេ ។ តាមរាល់ដូចមន្ទីរពេទ្យព្រះសង្ឃនេះជាដើម ប្រជាជនខ្មែរចំប្រឹងរៃបច្ចុប្បន្នមកទាំងសទ្ធារៀងខ្លួន មកជួយកសាងតាល់តែកើតជារូបមន្ទីរពេទ្យនេះឡើង អស់បច្ចុប្បន្នរាប់លានរៀល ប្រទេសខ្មែរមានប្រជាជនចំនួន៥លាននាក់អាចចិញ្ចឹមគ្នាកុំសាមណេរចំនួន៦៩.១៤៥អង្គបាន នេះសំដែងឲ្យឃើញថាគួរឲ្យកោតសរសើរជាបំផុត ។ ឥឡូវយើងបានបរិច្ចាគ

ទ្រព្យកសាងជាមន្ទីរពេទ្យហើយ យើងនៅមានការជួយទបត្តម្ភមន្ទីរពេទ្យ
ដោយបច្ច័យ ៤ ទៀត ឲ្យពេញឈ្មោះថាយើងជួយទំនុកបំរុងព្រះពុទ្ធសា-
សនាត្រប់បច្ច័យទាំង ៤ ។

វត្ថុណាមួយដែលជាគ្រឿងផ្តល់ជីវិតឬតជីវិត គឺចូលទៅជួយចិញ្ចឹម
ជីវិតឲ្យទ្រទ្រង់នៅតាមសមគួរបានហៅថា បច្ច័យ ។ បច្ច័យដែលមនុស្ស
លោកត្រូវការធំបំផុតនោះ គឺគ្រឿងស្វៀកពាក់ ១ អាហារគោជន ១ ទី
លំនៅ ១ ថ្នាំកែរោគ ១ ទាំង ៤ នេះជាវត្ថុចាំបាច់ គ្រឿងទបករណ៍ក្រៅពីនេះ
មិនមែនជាការចាំបាច់ប៉ុន្មានទេ បើខ្វះខាតបច្ច័យទាំង ៤ ឬណាមួយ
មនុស្សលោករស់ពុំបានទេ បើមានបច្ច័យទាំង ៤ នេះត្រប់ត្រាន់ទើប
មនុស្សរស់នៅបាន ។ ចូរពិចារណាមើលចុះ មនុស្សលោកត្រូវការ
ស្វៀកពាក់ខានពុំបាន. បើមានស្វៀកពាក់ហើយ តែខ្វះអាហារបរិភោគ
មនុស្សរស់នៅពុំបាន, បើមានស្វៀកពាក់ មានអាហារបរិភោគហើយតែខ្វះ
ទីលំនៅ ខ្វះថ្នាំកែរោគ មនុស្សក៏រស់នៅពុំកើតទៀត; ហេតុនេះបច្ច័យទាំង
៤ ប្រការនេះជាគ្រឿងទបករណ៍ជល់ជីវិតធំបំផុត ព្រោះមនុស្សជណ្តើម
រស់ត្រប់ៗគ្នា ត្រហស្ថជូចបព្វជិត បព្វជិតជូចត្រហស្ថ ត្រូវការតែបច្ច័យ ៤
នេះឯងជាធំ ដែលលោកសព្វៃថ្ងហៅថាជីវភាពខ្ពង់ខ្ពស់ ។ បើមនុស្ស
លោកមិនល្មោភលោភលន់ពន់ប្រមាណពេក រកបច្ច័យទាំង ៤ ប្រការនេះ
ឲ្យត្រាន់តែត្រប់ត្រាន់ល្មមញ៉ាំងជីវិតិន្ទ្រីយឲ្យប្រព្រឹត្តទៅបានទាំងអស់គ្នា
ហើយខំធ្វើការជាប្រយោជន៍ នោះមិនកើតមានចម្បាំងរាំងជលជល់ទៅកាប់
សម្ចាប់ជណ្តើមគ្នាស៊ីជូចយើងឃើញសព្វៃថ្ងនេះទេ ។ ក្នុងពុទ្ធសាសនា

ត្រឿងផ្តល់ជីវិតឲ្យរស់នេះ លោកមិនហៅថាជីវកាពទ្ពង់ទ្ពស់ទេ ។ លោក
ហៅថាបច្ច័យ បានដល់ចីវរបច្ច័យ ១ បិណ្ឌបាតបច្ច័យ ១ សេនាសនបច្ច័យ ១
គិលានភេជ្ជបច្ច័យ ១ បច្ច័យទាំង ៤ នេះជាការៈទាយកទាយិកាអ្នកមាន
សទ្ធាជ្រះថ្លាជួយផ្តល់ជល់ព្រះសង្ឆ ដើម្បីឲ្យព្រះសង្ឆរស់នៅបាន នឹង
ប្រព្រឹត្តព្រហ្មចរិយធម៌ ឯព្រះសង្ឆអ្នកបរិភោគនូវបច្ច័យទាំង ៤ នៃទាយក
ទាយិកាដែលគេឲ្យដោយសទ្ធាកឹត្រូវឲ្យគិតថា ចីវរជាស្បែក បិណ្ឌបាតជា
សាច់ សេនាសនៈជាមួប់ គេសជ្ជៈជាទឹកមូត្រ របស់មាតាបិតាបងប្អូនញាតិ
សន្តានរបស់ខ្លួនពិត ។ ពេលបរភោគផ្មេចភ្នែកបរិភោគ ត្រាន់តែឲ្យរស់
ដើម្បីប្រព្រឹត្តព្រហ្មរិយធម៌ រឿនសូត្រពុទ្ធវចនៈ ធ្វើការជាប្រយោជន៍
សាធារណ៍ ជាប្រយោជន៍សន្តិកាពដល់លោកសន្ទិវាស ។

ការទំនុកបម្រុងដោយបច្ច័យ ៤ ប្រការចំពោះសង្ឆ ឈ្មោះថាជួយ
ព្រះពុទ្ធសាសនាឲ្យមានជីវិតរស់ហិតហ្រមដ្ឋែងតទៅ ព្រោះថាបើមិនមាន
ការទំនុងបំរុងបច្ច័យទេ កិក្ខុសាមណេរមិនអាចនឹងទ្រទ្រង់ភេទជាបព្ចាតិ
ទៅបានឡើយ បើមិនមានព្រះសង្ឆ យើងទាំងអស់គ្នាដែលជល់នូវព្រះ
ពុទ្ធ ព្រះធម៌ ព្រះសង្ឆ ជាទីពឹងទីរលឹកនោះ នឹងរុះខាតអង្គព្រះត្រៃសរ-
ណគមន៍ ។ អំណើះឥតព្រះសម្មាសម្ពុទ្ធទៅ មានតែព្រះសង្ឆនេះហើយ
ជាអង្គតំណាងព្រះសម្មាសម្ពុទ្ធនឹងព្រះធម៌ ឯព្រះធម៌មានតែនាម ព្រះ
សង្ឆលោករក្សាទុកតៗមក តែបើឥតព្រះសង្ឆហើយ ព្រះពុទ្ធសាសនា
ក៏នឹងផុតរលត់សាបសូន្យទៅឥតសង្ឆ័យឡើយ ។

(មានត)

ប្រស្នាលន្ទិរាប់អានខ្មោចបិសាច

យុនបណ្ណានុរក្ស ប្ចិ-ប្ចី ឡៀបឡៀង

សំនួរ- អ្វីហៅថា លន្ទិ ?

ចម្លើយ - សេចក្តីដឿប្រកាន់តាមទំនៀមទម្លាប់ជាប់ជាប្រពៃណីត ។

ត្នាមក ហៅថា លន្ទិ ។

ស.- អ្វីហៅ ខ្មោចបិសាច ?

ច.- តាមយោបល់របស់មនុស្សតាតប្រើន សំដៅយករូបមនុស្ស ដែលស្លាប់ទៅហើយ ហៅថា ខ្មោច; សំដៅយកប្រេតឬអសុរកាយដែល មកស៊ីខ្មោចនោះ ហៅថា បិសាច ។

ស. ចុះពាក្យដែលគេនិយាយត្នាថា "ខ្មោចលង ខ្មោចផ្ទើមនុស្សឲ្យ ឈឺថ្កាត់ ខ្មោចចូលរូបមនុស្ស" ដូច្នេះ តើគេសំដៅយកអ្វី ?

ច. គេសំដៅយកសភាពណាដែលកើតមានប្រាកដដល់មនុស្ស នាំឲ្យមនុស្សគិតឆួល់សង្ស័យ ឬឲ្យយើញស្រពេចស្រពិល ដោយមិន យើញលក្ខណៈរូបកាងកាយច្បាស់លាស់ ឬត្រាន់តែបានឮសូរសំឡេង ប៉ុន្តែ មិនយើញខ្លួន មិនដឹងហេតុផល មិនដឹងដើមចុងថាជាយ៉ាងណា ត្រាន់តែផ្ទើឲ្យកើតសេចក្តីកោតខ្លាចស្រប់ស្រែងអស្ចារ្យ ក្នុងចិត្តទាល់តែព្រឺ ក្បាលឬព្រឺខ្លួនទាំងអស់ សភាពនោះតាមភាសាខ្មែរហៅថា ខ្មោច, តាម ភាសាបាលីហៅថា ប្រេតខ្លះ, បិសាចឬកូតខ្លះ, អមនុស្សឬសម្ពរៀសីខ្លះ ។ ប៉ុន្តែ មានអ្នកខ្លះយល់ថា រូបមនុស្សស្លាប់ទៅជាខ្មោចនោះ មិនចេះលង, មិនចេះផ្ទើមនុស្សឲ្យឈឺថ្កាត់, មិនចេះទៅចូលក្នុងរូបមនុស្សឡើយ ដែល

លង្ហុជ្ជើតេឲ្យឈឺថ្កាត់ ឬបូលក្នុងរូបមនុស្សនោះ មានតែពួកបិសាច ជ្សិតបិសាចជ្សងពីឆ្នោចមនុស្សស្លាប់ ។

ស.- ប៉ើជូហ្នោះ បិសាច លោកសំដៅយកអ្វី ?

ច.- តាមវចនានុក្រមខ្មែរប្រាប់ថា បិសាចនោះ លោកសំដៅយកអមនុស្សជាអបាយិកសត្ត គឺសត្វកើតក្នុងអបាយ ដែលនៅក្នុងមនុស្សលោក មានច្រើនពួក មានអមនុស្សដែលលិទ្ធជញ្ជក់ឈាមស្រស់ ឬដែលជញ្ជក់យករសគំរង់សាកសពជាដើម ហៅថា ពួកបិសាចឬឆ្នោចបិសាច ។

ស.- មនុស្សស្លាប់ហើយ ទៅកើតទៀតឬទេ ? ប៉ើកើតទៀតទៀងតែកើតជាមនុស្សដដែលឬជូចម្តេច ?

ច.- ទៅកើតទៀត ។ ប៉ុន្តែ មិនទៀងទេ ជួនកាលមនុស្សស្លាប់ហើយទៅកើតជាមនុស្សវិញក៏មាន ទៅកើតជាសត្វតិរច្ឆានក៏មាន ជាទេវតាក៏មាន ។ល។

ស.- ចុះអ្វីទៅកើតទៀត ?

ច.- វិញ្ញាណ (ព្រលឹង) របស់អ្នកស្លាប់នោះទៅកើតទៀត ។

ស.- ហេតុអ្វីបានជាគេដឹងថាវិញ្ញាណរបស់អ្នកស្លាប់នោះទៅកើតទៀត ?

ច.- ហេតុតែពួកមនុស្សមានលទ្ធិជឿប្រកាន់គោរពរាប់អានវិញ្ញាណរបស់អ្នកស្លាប់ទៅហើយនោះជាប់ត ។ ត្នាតាំងពីបុរាណកាលហ្ហូតមកដល់បច្ចុប្បន្នកាលនេះ ។

ច.- ចុះមនុស្សជាតិអ្វី នៅប្រទេសណា ដែលមានលទ្ធិជឿប្រកាន់

គោរពកាន់តាមវិញ្ញាណរបស់អ្នកស្លាប់ទៅហើយនោះ មុនគេ ?
បើគិតមកត្រឹម គ.ស. ១៩៥៧ ឯានរាងប៉ុន្មានឆ្នាំមកហើយ ?

ច.- ជនជាតិអស៊ីប្ត៍(១) នៅកន្លែងខ្ទឹបអាហ្វ្រិក ខាងទិសឦសាន ជាប់ទឹកខ្ទឹងអាស៊ី តាមព្រែកដីកស៊ុយអេស (Suez) ។ ជាតិអេស៊ុប្ត៍នេះ មានសេចក្តីចំរើនរុងរឿងប្រមាណជាង ៧ពាន់ឆ្នាំមកហើយ ដរាបមកដល់សម័យបច្ចុប្បន្ននេះ (គ.ស.១៩៥៧) សឹងនៅមានថាវត្ថុជាគ្រឿងសំដែងឲ្យយើងមើលយើញសេចក្តីភ្ញាក់ផ្អើលជាច្រើន ទឹងចំណេះដឹងខ្ពស់របស់ប្រជាជនជាតិអេស៊ីប្ត៍យ៉ាងក្រៃលាស់ក្នុងលោក ។

លក្ខិណៈដឿប្រការនៃជនជាតិអេស៊ីប្ត៍ចែកចេញជា ៣ ប្រការ គឺ ១- គោរពកាន់អានព្រះភូមិ, ២-គោរពកាន់អានព្រះអង្គធំ, ៣-គោរពកាន់អានអ្នកដែលចែកស្នានទៅហើយ (អ្នកស្លាប់) ។ ជាតិនេះដឿប្រការនេះថា "ជនជាតិអស៊ីប្ត៍ ដរាបវេលាស្លាប់ មិនមែនស្លាប់ទៅបាត់ភ្លាមៗទេ មានរូបកាយ ផ្សេងទៀត ដែលយើងមើលមិនឃើញ ចេញទៅពីរូបកាយដើមរបស់ខ្លួន ពាក្យនេះគេហៅថា កាយក្លែងឬវិញ្ញាណ (ព្រលឹង), ធម្មជាតិនេះនៅមានជីវិតតទៅទៀត ទម្រាំតែពាក្យដើមនោះពុករលួយរលាយអស់ទៅ" ។

---

១) ប្រវត្តិរបស់ជនជាតិអេស៊ីប្ត៍ មានសេចក្តីពិស្តារក្នុងឯកសារប្រវត្តិសាស្ត្រសាកលរបស់ហ្វូតិ-ប្រែសំរួលការ រឿងទ្រង់ ប្រទេសថៃ ដែលហ្លួងធិរាតូមន្ត្រី ញ៉ុក ថែម បានប្រែជាភាសាខ្មែរហើយ ដោយពុម្ពផ្សាយក្នុងរស្មីតាំងពី កម្ពុជសុរិយា ឆ្នាំ ១៩៤០ តាំងពីខ្សែលេខ ២ ទំព័រ ២៧... រហូតដល់ចប់ប្រវត្តិជាតិអេស៊ីប្ត៍ ។

ព្រោះតែជំនឿនេះហើយ បានជាជនជាតិអេស៊ីប្ត៉ី ចេះក្តីវិធីអប់រក្សាសពទុកឲ្យបានយូរឆ្នាំមិនឲ្យពុកផុយរលួយ ឥតាប់ ។ ឯវិញ្ញាណដែលគ្មានរូបកាន៏ត្រូវរក្សាទុកដែរ គឺតេធ្វើបន្ទប់ឥឥត សម្រាប់ជាលំនៅរបស់វិញ្ញាណនឹងជាទីដំកល់សពទុកផង ។

ជនជាតិអេស៊ីប្ត៉ីមានជំនឿថា "អ្នកដែលស្លាប់ឥហើយ នៅតែឥមកកញាតិសន្តានដែលនៅរស់" បានជាជាតិនេះយកចិត្តទុកដាក់ គោរពបូជាបុព្វបុរសដែលចែកស្ថានឥនោះដោយវិធីផ្សេងៗ ដើម្បីឲ្យបុព្វបុរសបានសុខសប្បាយ ។

ជនជាតិអេស៊ីប្ត៉ីមានជំនឿម្យ៉ាងទៀតថា "ត្រប់មនុស្សកាលដល់ពេលស្លាប់ហើយ ខ្មោចនោះត្រូវឥស្នើដល់ព្រះអូស៊ីរិសដែលទ្រង់ជម្រះទោស" ។ ហេតុនេះ បានជាគេដាក់សៀវភៅមួយ នៅក្បែរខ្លួនខ្មោច ក្នុងសៀវភៅនោះមានសរសេរសេចក្តីដែលខ្មោចត្រូវតែទន្ទេញឲ្យចាំមាត់ថា "ខ្ញុំមិនដែលពោលពាក្យកុហកដល់សាល(១)ទេ, ខ្ញុំមិនមែនជាមនុស្សឆ្លិលប្រអូស, ខ្ញុំមិនមែនជាអ្នកមានចេតនាអាក្រក់, ខ្ញុំមិនដែលប្រមាថមើលឥាយទេវរូប, ខ្ញុំមិនដែលធាបាកយកដីរបស់អ្នកដទៃ, ខ្ញុំមិនបានធ្វើឲ្យអ្នកដទៃមានសេចក្តីទោមនស្ស, ខ្ញុំមិនដែលសម្លាប់អ្នកណា, ខ្ញុំមិនដែលបិទផ្លូវក្នុងព្រៃកស្ទឹង, ខ្ញុំមិនដែលទាញដោះម្តាយចេញពីមាត់កូនឆ្លី, ខ្ញុំបរិសុទ្ធ, ខ្ញុំបរិសុទ្ធ, ខ្ញុំបរិសុទ្ធ" ។

កាលបើយើងពិចារណាមើលពាក្យអស់នេះដោយសព្វត្រប់ឥហើយ

---

១ សាលាសម្រាប់វិនិច្ឆ័យសេចក្តី ហៅថា សាល ។

ខ្ញុំឯងយើញថាជនជាតិអេស៊ីប្ដីជាមនុស្សទេ សត្វហ៊ានខ្លះទៀត តាំងប្រកបដោយ
ចរិយាមារយាទល្អផង ។

ជនជាតិអេស៊ីប្ដី មានជំនឿមួយទៀតថា "មនុស្សត្រូវបានកើត
ឡើងដោយមានលក្ខណៈសំខាន់ ៤ យ៉ាងប្រកបចូលគ្នា គឺរាងកាយ
ក្រាយ១ ចិត្ត១ វិញ្ញាណ១ រូបកាយ១ ។ ក្រោយមើលលក្ខណៈសំខាន់ ៤
យ៉ាងនេះនៅប្រជុំគ្នាដរាបណា មនុស្សនោះក៏មានជីវិតរស់នោះដរាបនោះ
បើលក្ខណៈតាំង ៤ យ៉ាងនេះ ណាមួយណែកខ្លះចេញពីគ្នាហើយ មនុស្ស
នោះក៏ត្រូវតែស្លាប់ ។ ប៉ុន្តែការស្លាប់នោះ គ្រាន់តែត្រឹមលក្ខណៈតាំង ៤
ចែកចេញពីគ្នាៗមួយគ្រាប៉ុណ្ណោះ ចិត្តរបស់អ្នកស្លាប់នោះនឹងត្រាប់ត្រឡប់
មកគង់ក្បែរវិញ ។ ចំណែកវិញ្ញាណ កាលបើចេញពីរាងកាយដើម
មកហើយ ទីនោះមកតែមានត្រកូតដូចតែមួយទៀត ប៉ុន្តែ រូបកាយ
នឹងវិលវល់នៅដដែល ។ រាងកាយដើមនោះឯង ។ ឯលក្ខណៈសំខាន់តាំង ៤
យ៉ាងមិនសាបសូន្យឆាប់ទៅឯណាឡើយ នឹងរង់ចាំកសេចក្ដីសុខឱ្យបាន
ពីកូនចៅញាតិសន្ដានជាន់ក្រោយ លុះដល់ពេលកំណត់ហើយ លក្ខណៈសំ-
ខាន់តាំង ៤ យ៉ាង ក៏នឹងវិលត្រឡប់មករួមរួបរួមគ្នាក្នុងរូបកាយក្រាយ
ហើយប្រមូលធ្មប់ជីវិតរស់នៅតទៅទៀត តាមបានព្រាងដើម" ។ ព្រោះ
ហេតុនេះ ឃើញជនជាតិអេស៊ីប្ដីមានចំណេះចេះរបស់សពរក្សាខ្មុកឱ្យគង់
នៅបានយូរអង្វែងណាស់ ដើម្បីរង់ចាំពេលវិញ្ញាណរបស់ម្ចាស់ខ្លួនត្រឡប់
ត្រឡប់ប្រមូលធ្មប់ជីវិតឡើងវិញ ។

ស.- មនុស្សប្រុសណាដែលនោះគេកាប់អាចវិញ្ញាណរបស់អ្នកស្លាប់

មានតែជនជាតិអេស៊ីប្តីមួយប៉ុណ្ណោះទេឬ ឬក៏មានមនុស្សបុកណាជាតិដទៃទៀត គោរពកាន់អាទប្រហែលជាតិអេស៊ីប្តីដែរ ?

ច.- មនុស្សបុកណាដែលគោរពកាន់អាទិញ្ញាណរបស់អ្នកស្លាប់ប្រហែលជាតិអេស៊ីប្តីមានជាច្រើនជាតិណាស់ គឺជាតិសាលដេយ៉ាំង, អស្សីរីយ៉ាង, ហេប្រ៊ូ, ហ្វូនីសាង, ប៉ែរ្ស៊ី, ក្រិក, រ៉ូម៉ាំង, ឥណ្ឌៀ, អាព៉ាប់, ចិន, ជប៉ុន ចាមដ្ឋា, កូមា, ថៃ, លាវ, ខ្មែរ, យួន, ។ល។

ស.- បើដូច្នោះ សូមប្រាប់ពីដំណឹងរបស់មនុស្សបុកណាជាតិខ្លះតែត្រង់គោលខ្លី។ ឲ្យយើញថាជាតិណាមានលទ្ធិប្រកាន់ដូចម្តេច ?

ច. ជាតិសាលដេយ៉ាំង, អស្សីរីយ៉ាង, ហេប្រ៊ូ និងជាតិហ្វូនីសាង មានលទ្ធិប្រហែលជាតិអេស៊ីប្តីដែរ គឺគេជឿប្រកាន់ថា "ក្នុងលោកនេះមានពួកមារប្តឹងសាបនៅចាំប្រទូសក៏ដូចមនុស្ស" ហេតុនេះ ឯងជាមានមនុស្សចំពួកខ្លះតែងកេងបាយបង្ហាអ្នកឯទៀបនេះ ហើយតាំងខ្លួនជាអ្នកបណ្តាញប្តឹងបំផ្លាត់ពួកមារប្តឹងសាប ដោយរំដើសេកមន្តអាគមច្រេះព្រឹកមន្ត យកស្បែសេសម្ភ័ងមកជាក់ធ្មេញក្តោងពីក ចុះលេខយន្តនឹងផ្លាំងសំពត់ ។ ជនពួកនេះមានលទ្ធិគោរពកាន់ព្រះលើស្ថានសួគ៌ និងខ្មោចបិសាចយក្សមារដែលជាប់ភាក់ពន្ធនឹងញ្ញាណរបស់មនុស្សស្លាប់ទៅហើយ ។

ជនជាតិបេរ្ស៊ី.- ជាតិប៉ែរ្ស៊ីនេះជាពួកអារ៉ីយ៉ានតែងប្រៀនប្រដៅគ្នាថា "កុំឲ្យមនុស្សម្នាក់ ។ រមែងមានទេវតានៅប្រចាំរក្សាខ្លួនជានិច្ច" ។ ក្នុងលទ្ធិសាសនា ជនជាតិប៉ែរ្ស៊ីនេះមានសំដែងថា " កាលបើមនុស្សស្លាប់ទៅបាន

ពាក្ចៃត្រូវជាប់ចោទ ត្រូវទៅលន្ទួចំពោះព្រះកក្ត្រព្រះអូរមុស្ត (ព្រះខាន
សេចក្តីល្អ) ដែលទ្រង់ជំនុំជម្រះទោសជាប់ស្រេច ។ ប្រសិនបើវ្ចាចនោះ
បានធ្វើអំពើអាក្រក់មកច្រើនជាងអំពើល្អ ព្រះអូរមុស្តកឹបញ្ជូនខ្ទួនទៅ
ឲ្យពួកមារធ្វើទោស" ។

ជនជាតិក្រិក.- ពួកក្រិកពីបុរាណ ជឿប្រកាន់ថា "មនុស្សដែល
ស្លាប់ទៅហើយ ត្រូវទៅនៅក្នុងដែនមួយដ៏ងងឹតឈឹងសូន្យខាងក្រោម
ប្រថពីដែលភាសាក្រិកហៅថា ហេដិស ទោះជាអ្នកល្អក្តី អាក្រក់ក្តី
ត្រូវទៅនៅទីនោះដូចគ្នា ។ ក្នុងដែនហេដិសនោះ មានទេពតាអ្នកគ្រប់.
គ្រងនាមថា ប៉ះលូតោ មានជាយានាមថា ប៉ែរសេឡោនី ។ ប៉ើអ្នកណា
បានសំដែងសេចក្តីក្លាហានជាវីរបុរស អ្នកនោះបានទទួលសិទ្ធិក្នុងកិច្ចការ
ណាមួយស្ថើនឹងទេពតា ឬបានទទួលអម្រិតធមិសេចក្តីមិនស្លាប់ក៏មាន ប៉ើ
គេមិនបានទទួលដូច្នោះទេ ក៏នឹងបានអនុញ្ញាតឲ្យទៅនៅសោយសុខក្នុង
ដែនតីលីសាិនជិតមហាសមុទ្រ ដ៏ជាទ្វីបបរមសុខនៅទិសខាងលិចជា
ទីឆ្ងាយក្រៃលែង ដែលគ្មានអ្នកណាធ្លាប់ទៅដល់សោះ" ។ ប៉ុន្តែ
សម័យតៗមក ពួកក្រិកកើតជំនឿថ្មីម្យ៉ាងទៀតថា "មនុស្សដែលស្លាប់ពី
លោកនេះទៅហើយ រមែងទុកដួងវិញ្ញាណ, តំនិតតិតតូរនឹងការប្រឹក្សា
ឲ្យនៅជាមួយកូនចៅដែលនៅមានជីវិត ដើម្បីចាំពិភ័ក្តិរក្សាក្នុងគ្រាកូន
ចៅមានទុក្ខលំបាក" ដោយហេតុតែជំនឿនេះ បានជាពួកក្រិកបង្កើត
ពិធីសែនព្រេននឹងសូត្រធមិអង្វរការចំពោះដួងវិញ្ញាណនៃបុព្វបុរស ។ ម្យ៉ាង
ទៀត ពួកក្រិកមានសេចក្តីគោរពរាប់អានបុព្វបុរសរបស់ខ្ទនដូចជាព្រះ

លើស្ពានសួនដែរ ដោយគេយល់ថា "បុព្វបុរសរបស់ខ្លួន កាលបើ
ស្លាប់ទៅហើយ វិញ្ញាណរបស់លោកតែងតែមកនៅរួបរួមជាមួយកូនចៅ
ហើរក្បួនការពារនិងឪពុកឲ្យកូនចៅនៅក្រោយ ។តមក" ហេតុនេះ
បានជាពួកគ្រិតខំព្យាយាមធ្វើសេចក្តីគោរពដម្រេចិត្តរបស់បុព្វបុរសណាស់
ដូចជានាំអាហារគោជនទៅសែនជល់ផ្សាទីតប់សព ហើយក្នុងគ្រួសារ
នីមួយ ។ រមែងមានទីសម្រាប់ធ្វើសក្ការបូជាជល់បុព្វបុរសរបស់ខ្លួនជា
និច្ច ។ លទ្ធិសាសនាគ្រិតប្រកាន់ថា ពួកកូនចៅត្រូវនាំយកអាហារ
ចំណីទៅបូជាសពនៅតន្លែងកប់សពតាមកាលសម័យ ដូចជាតំអេស៊ីប្ត
ដែរ ព្រោះគេជឿប្រកាន់ថា បើកូនចៅមិនធ្វើដូច្នេះទេ វិញ្ញាណរបស់
បុព្វបុរសដែលស្លាប់ទៅនោះ មុខជានឹងត្រាច់ស្រែកឃ្លានអាហារចំណី
នាំឲ្យលំបាកវេទនាច្រើន ។ ដំណើរនេះមិនមែនមានតែត្រឹមប្រជាជន
ជម្ងួតារេ សូម្បីអ្នកកាសាក៏ជឿប្រកាន់ដូចគ្នាដែរ គាល់តែមានបញ្ជាប់
បញ្ជាឲ្យឆាក់ទៅសដល់កូនចៅរបស់អ្នកស្លាប់ ដែលមិនបាននាំយកអាហារ
គោជនទៅបូជាសពក្នុងវេលាដ៏សមគួរ ។

ជំនឿជាតិពោម - ពួកពោម៉ុង មានព្រះដែលគេគោរពកាន់តាន់ច្រើន
ជាងជាតិអេស៊ីប្ត ទឹងត្រិះះទៀត ។ ពួកពោម៉ុងជឿប្រកាន់កាន់តាន់បុព្វ-
បុរសទឹងព្រះផ្សេង ដូចជាតិអេស៊ីប្តដែរ ។ នៅគ្រប់ផ្ទះពួកពោម៉ុងមាន
ទីតន្លែងបូជាបុព្វបុរសដែលគេបានអុជភ្លើងបូជាឲ្យតាំងយប់តាំងថ្ងៃ ហើយ
មានទៀបបូជ្រេង ដែលគេសន្មតថាជាអ្នកថែរក្សាផ្ទះសម្បែង (ទំនងព្រះ
គូមិបេស់ជាតិខ្មែរយើងដែរ) ។ ពួកពោម៉ុងគ្មានពាក្យប្រដៅនិយាយពី

វិញ្ញាណរបស់មនុស្សនឹងសីលធមិទេ មានតែជំនឿនឹងសេចក្តីគោតទ្ធាច ម្យ៉ាងប៉ុណ្ណោះ ហេតុនេះហើយ បានជាពួកកាមាំងមានព្រះច្រើនណាស់ ទាល់តែរាប់មិនអស់ ។

ជនជាតិឥណ្ឌា - ប្រជាជនឥណ្ឌាមាន៤ពួក គឺពួកអរិយកៈប្ម អាវ៉ន១ ពួកមិលក្ខៈ (មនុស្សត្រៃ) ១ ។ ពួកអរិយកៈសម័យបុរាណរាប់ អានវិញ្ញាណរបស់បុព្វបុរសដែលចែកស្ថានទៅហើយស្ទើនឹងទេវតាព្រោះ គេជឿប្រកាន់ថា "មនុស្សស្លាប់ហើយ មានរបស់ម្ជុយមិនស្លាប់ទៅតាម ផងទេ របស់ម្ជុយនោះគឺវិញ្ញាណ។ នេះត្រូវការបរិភោគអាហារដូចមនុស្ស នៅរស់ដែរ ។ ឆ្ជងវិញ្ញាណនោះអាចឲ្យកើតសុខទុក្ខដល់ត្រួសារបាន" ដោយមានជំនឿយ៉ាងនេះ បានជាពួកអរិយកៈមានធ្វើពិធីសែនព្រេនបូជា ដ្ជងវិញ្ញាណ ។ ពួកអរិយកៈមានជំនឿម្យ៉ាងទៀតថាមនុស្សស្លាប់ទៅហើយ នៅមានអ[illegible] [illegible] គឺរូបកាយដែលគេមើលមិនឃើញ មានទីកន្លែង សម្រាប់ នាតាស្រ័យ [illegible] [illegible]" ។ ដោយមានជំនឿយ៉ាងនេះ បានជាពួកអរិយកៈមានធ្វើពិធីទ្ធុសទក្ខិណាទានសែនព្រេនបូជាជូនចំពោះ បុព្វបុរស ។

(មានត)

មាតាបិតាមានគុណមែនឬ?

ឃុនអត្ថគោវិទ ជា.ឃូរ រៀបរៀង

មាតាបិតាមានគុណឬគ្មានគុណដល់បុត្រធីតានោះ ជាបញ្ហាមួយ យ៉ាងធំ ដែលយើងត្រូវដឹងឲ្យច្បាស់ ។

– ជនពួកខ្ចះយល់យើញថា: មាតាបិតាគ្មានគុណដល់បុត្រធីតាទេ ព្រោះចេតនារបស់លោកខាងដើមនោះ លោកគ្មានចង់បានបុត្រធីតា លោកនៅរួមសាមគ្គីនឹងគ្នា ដោយសេចក្តីសប្បាយ ។ កាលមានបុត្រធីតាហើយ លោកត្រូវធ្វើទបការៈទំនុកបំរុង ព្រោះជានាទីរបស់លោក ដែលធម្មតាបង្គាប់ឲ្យធ្វើដូច្នោះ ។ ដែលលោកមានសេចក្តីស្នហាចំពោះបុត្រធីតានោះ ក៏ព្រោះធម្មតាលោកិយតែងតែឲ្យមានដូច្នោះឯង ។ កុំថាតែមនុស្សឲ្យើយ សូម្បីតែសត្វតិរច្ឆានក៏ចេះស្រឡាញ់កូនដែរ ទាំងនេះក៏ព្រោះគតិធម្មតាតែងតែមានដូច្នោះ ។ ដោយហេតុនេះទើបគេយើញថា មាតាបិតាគ្មានគុណនិស្រ័យអ្វីទេ ។

– ជនពួកខ្ចះទៀតយល់យើញថា: មាតាបិតាមានគុណដល់បុត្រធីតា ព្រោះជាអ្នកឲ្យកំណើត និងជាអ្នកធ្វើទបការៈដល់បុត្រធីតា ។

មតិពួកជនទី ១ មានអ្នកយើញស្របតាមតិច មានអ្នកចំទាស់ច្រើន; ឯអ្នកដែលយើញស្របតាមនោះ ជាជនអកតញ្ញូ, អ្នកដែលចំទាស់ ជាជនកតញ្ញូកតវេទី ។

មតិពួកជនទី ២ មានអ្នកយើញស្របតាមច្រើនមហិមា មានអ្នកចំទាស់ តិចតួច; អ្នកដែលយើញស្របតាមនោះសុទ្ធតែជាអ្នកប្រាជ្ញកដបណ្ឌិត

ជាអ្នកកតញ្ញូកតវេទី, ចំណែកអ្នកចំពាស់ជាជនអន្ធពាល ជាជនអកតញ្ញូ ។ ជនទាំង២ ពួកនេះ មានតម្លៃថ្លៃថោកជាងគ្នា ដូចបានពោលមកនេះ ។

អំពីគុណមាតាបិតានេះ អ្នកប្រាជ្ញគ្រប់ថ្នាក់គ្រប់សម័យទាំងដែលរាប់អានសាសនាខឹងមិនរាប់អានសាសនា តែងពោលអះអាងថាមាតាបិតាមានគុណ ។ អ្នកប្រាជ្ញសម័យប្លែដែលបានសិក្សាវិស្លាំងជាន់ខ្ពស់ តាំងខ្លួនជាកណ្តាលមិនបានគាន់សាសនាណាមួយ បានតិះដៀនយកតែហេតុផលក៏តែងពោលអះអាងថាមាតាបិតាមានគុណដល់បុត្រធីតាពិតមែន ដោយហោចទៅក៏គឺជាអ្នកឲ្យកំណើតដល់បុត្រធីតាដែរ ។ ចំណែកអ្នកប្រាជ្ញដែលរាប់អានសាសនា បានពោលក៏ប់ឆើថា មាតាបិតាមានគុណដល់បុត្រធីតាយ៉ាងពិតប្រាកដ ហើយពេលណានាគុណមាតាបិតាខុតជាអនេកប្បការ ។

តួឲ្យអស្ចារ្យណាស់ ដែលពួកសាស្តានៃសាសនាធំ ។ ក្នុងលោកដូចសាសនាគ្រិស្ត សាសនាយូដាម៉ាត់ សាសនាព្រាហ្មណ៍ ឧទ្ទិសព្រះពុទ្ធសាសនា, សាស្តាទាំងនោះ តែងពោលចំពាស់ពីទៅគ្នា ដោយរឿងរ៉ាវខ្ញុំ ។ មានមតិឯកឯង តែងពោលគ្រវែគ្នាថា ម្តាយបិតាមានគុណដល់បុត្រធីតា ។ សាសនាគ្រិស្ត បានប្រដៅសិស្សឲ្យគោរពរាប់អានមាតាបិតា, ពោលដោយសេចក្តីថា "អ្នកគ្មានកតញ្ញូកតវេទីតាចំពោះមាតាបិតាខុតដូចបានចំលាយព្រះគម្ពីរបស់ព្រះជាម្ចាស់" ។ សាសនា

មហាម៉ាត់ ក៏ជាន្ប្រដៅសិស្សដូច្នោះដែរ តែផ្ទាស្ពុកាសិតដាស់តឿន
ចិត្តថា "ដើឥតាំង៤របស់មាតាបិតាជាជណ្តើរដើរឡើកាន់ថានស្ថតិ"
ដោយអធិប្បាយថា បុត្រធីតាធ្វើការគោរពប្រណិបតន៍ត្រឹមតែជាទដើឥ
មាតាបិតាប៉ុណ្ណោះ ក៏អាចឡើកាន់ថានស្ថតិជាន ។ សាសនាព្រាហ្មណ៍
ក៏ប្រដៅឲ្យធ្វើសក្ការបូជាមាតាបិតា មិនតែប៉ុណ្ណោះសោតតេធ្វើជារូបអឥ-
ជាត(អឥ្ធកំណើត)ដំកល់ទុកសំរាប់បូជា, អ្នករាប់អានសាសនាដទៃ ឃើញ
ថាការគោរពកេរ្តឺ្ទ្ធាសជាការមិនល្អ ជាការធ្វើបំជាក់មុខតួរឲ្យអ្នៀនខ្មាស
ខ្ទាំឥណាស់ តែតឥ់ទទួលរាំប់ឥជាតុណរបស់អ្នកឲ្យកំណើតមានពិត ។
ក្នុងព្រះពុទ្ធសាសនា ព្រះបរមសាស្តាទ្រង់ត្រាស់អះអាង នឹឥសរសើរ
គុណមាតាបិតាទុក្ខជាអនេកប្បការ។ ក្នុងអាតតស្ថានខ្ទះទ្រង់សំដែឥថាមាតា
មានគុណប្រើនជាឥបិតា, អាតតស្ថានខ្ទះទ្រង់សំដែឥថាបិតាមានគុណ
ប្រើនជាឥមាតា ។ ពោលដោយហានៈដែលនៅកៀកកិត ធ្វើឧបការកិច្ច
ដែលតេធ្វើជានដោយក្រ ដូចត្រូវទទួលលទ្ធផលក្នុងការនៅរួម ក្នុងការ
ទូចខាតសេចក្តីបរិសុទ្ធ ក្នុងការពពោះ ក្នុងការចិញ្ចឹមដោយទីរាទកៈតឹទឹក
ដោះ នឹឥធ្វើកិច្ចស្មើដោយជីវិត ដូចក្នុងត្រាប្រសូតបុត្រធីតា ហើយមាន
សេចក្តីស្នេហាក្នុងបុត្រធីតា ទើបទ្រង់លើកមាតាថា មានគុណូបការៈប្រើន
ក្នុងផ្នែកនេះ ព្រោះហេតុនោះព្រះជាលីទើបនិយមចុះនាមមាតាមុនបិតា
ដូចពាក្យថា មាតា បិតរោ ប្រែថា មាតាបិតា ហើយត្រាស់ថា
មាតា មិត្តំ សកេ ឃរេ "មាតាជាមិត្តក្នុងផ្ទះនៃខ្ទួន" ព្រោះធ្វើនាទី
ជាកល្យាណមិត្រ ។ បើពោលដោយហានៈ ជាអ្នកឲ្យកំណើត នឹឥជាអ្នក

ឥវឌ្ឍត្រកូល ទ្រង់លើកបិតាថាមានគុណសំខាន់ជាងមាតា ដូចទ្រង់ត្រាស់
នឹងព្រះបាទបសេនទិកោសលថា មាតុគោត្តំ នាម កឹ ករិស្សតិ
បិតុគោត្តមេវ បមាណំ ប្រែថា "គោត្រ គឺត្រកូលខាងមាតាយកជា
ប្រមាណមិនបាន គោត្រខាងបិតាទើបយកជាប្រមាណបាន" ។

ដើម្បីប្រកាសគុណដ៏សំខាន់ក្នុងផ្នែកនេះ ព្រះបាលីទើបនិយមចុះនាម
បិតាជាមុនថា ជនក ជននី ។ ជនក ប្រែថា "អ្នកឲ្យកំណើត" ជននី
ប្រែថា "អ្នកជាទីកើតនៃបុត្រធីតា" ។ ព្រោះដូច្នោះ ការប្រើនាមត្រកូល
នឹងការកាន់សែស្រឡាយទើបឲ្យកាន់យកនាមត្រកូលខាងបិតា ។ ចួនកាល
ទ្រង់លើកដំកើងថា មាតាបិតាមានគុណស្មើគ្នា ហើយទ្រង់នាំទៅប្រៀប
ធៀបនឹងលោកដ៏វិសេស ឬវត្ថុសក្តិសិទ្ធិនៃសាសនាទាំងនោះថា មាតាបិតា
ជា មហាព្រហ្ម មានគុណដល់បុត្រធីតា ដូចសម្តេចមហាព្រហ្មជាអ្នក
វិសេស ជាដើមត្រកូលនៃពួកព្រាហ្មណ៍ ព្រោះជាអ្នកសាងជាអ្នកធ្វើ
ឧបការៈ ជាអ្នកប្រកបដោយព្រហ្មវិហារធម៌ ។ ថាមាតាបិតាជា បុព្វទេព
របស់បុត្រធីតា គឺជាទេវតាអ្នកថែរក្សាបុត្រធីតាមុនទេវតាដទៃ ដែលគេ
ប្រកាន់ថា ពួកមនុស្សសុទ្ធតែមានទេវតាប្រចាំរក្សាគ្រប់ៗគ្នា ។ ថាមាតា
បិតាជា បុព្វាចារ្យ របស់បុត្រធីតា គឺជាអាចារ្យប្រៀនប្រដៅបុត្រធីតាមុន
អាចារ្យដទៃ រាប់តាំងពីបង្គាប់ឲ្យរៀនធ្វើយបាទចាសជាដើម ។ ទ្រង់លើក
ដំកើងគុណលោកទាំងពីរស្មើដោយសង្ឈរគនៈថា មាតាបិតា ឈ្មោះថា
អាហុនេយ្យា ជាអ្នកគួរដល់សក្ការៈនឹងវត្ថុដែលគេនាំមកបូជា គឺដែល

បុត្រធីតានាំយកទៅជូនដល់ទីលំនៅរបស់លោក, ឈ្មោះថា ជាហុនេយ្យា ជាអ្នកគួរដល់សក្ការៈនឹងវត្ថុដែលគេនាំមកទទួលក្បៀ គឺទេយ្យវត្ថុដែលបុត្រធីតារៀបទទួលក្នុងត្រាដែលលោកមកដល់ទីលំនៅរបស់ខ្ជួន, ឈ្មោះថា អញ្ជលិករណីយា ជាអ្នកគួរដល់ការក្រាបសំពះរបស់បុត្រធីតានឹងជាបុញ្ញខេត្ត គឺជាដីស្រែដ៏សំខាន់ សំរាប់បុត្រធីតាធ្វើបុណ្យ ។ ទ្រង់លើកដំកើងគុណរបស់លោកទាំងពីរស្មើដោយ ព្រះអរហន្ត ដោយហានៈកំណត់ទោសថា បើបុត្តធីតាសម្ទាប់មាតាបិតាត្រូវមានទោសជាអនន្ត-រិយកម្ម ដូចសម្ទាប់ព្រះអរហន្តដែលមានគុណដ៏រិសេស ។ ទ្រង់លើកដំកើងគុណលោកទាំងពីរដូចព្រះអរិយៈដោយហានៈជាក្ខើង ដូចពាក្យថា អាហុនេយ្យគ្គិ ក្ខើងគឺមាតាបិតាជាអាហុនេយ្យបុគ្គល ទក្ខិណេយ្យគ្គិ ក្ខើងគឺមាតាបិតា ជាទក្ខិណេយ្យបុគ្គល ព្រមទាំងទ្រង់លើកដំកើងលោកថាជា ទុល្លភបុគ្គល គឺបុគ្គលដែលរកបានដោយក្រក្នុងលោក ។

ពាក្យដែលថា មាតាបិតាជាអ្នកឲ្យកំណើតដល់បុត្រធីតានោះ គឺឲ្យកំណើតពិត ព្រោះលោកជាអ្នកសាងអវយវៈគ្រប់យ៉ាង, សាងសាច់ឈាមក្នុងកងកាយរបស់បុត្រធីតាដែលហៅថាខ្ជួនប្រាណ, សាច់ឈាមនេះមានបូសគល់មកពីមាតាបិតាទាំងអស់ បុត្រធីតាមិនមែនបាននាំមកពីទីណាមួយទ្បើយ, កាលលោកសាងស្រេចហើយ លោកក៏ទំនុកបំរុងចិញ្ចឹមថែរក្សាដោយមេត្តា(សេចក្តីស្នេហា)ករុណា (សេចក្តីអាណិតរំកើបចិត្ត) ទ្ទាចកូនបានទទួលទុក្ខតោកយ៉ាក, កាលកូនឈឺ លោកបានព្ធដំណឹងឬបាន

ឃើញហើយនឹងខៅស្ទើមមិនបាន, លោកមិនមើលបំណាំ សូម្បីមានកំចុ
ឆ្ងុះដូចម្តេចក៏ដោយ ក៏ត្រូវចោះបង់ ឬដាក់ចោលការងារគាំងនោះទុកសិន
ហើយមកថែរក្សាកូនដោយសេចក្តីពេញចិត្ត មិនដូចគេឲ្យឬដាថែដែល
យើងត្រូវអញ្ជើញគេឲ្យមក ជួនកាលគេក៏មក ជួនកាលក៏ខេ កាលមក
ដល់ហើយ ក៏ត្រូវឲ្យទ្រនឹបរង្គាន់ នឹងថ្លៃថ្នាំឲ្យបរិបូរណ៍ទើបសុខចិត្តជួយ
ព្យាបាល កាលព្យាបាលខៅហើយឃើញថាមិនសះជាគំចោះបង់ចោល
លែងមកមើតឆើត ចំណែកមាតាបិតាមិនដូច្នោះទេ មិនបាច់អញ្ជើញ
លោកក៏មក មិនបាច់ឲ្យទ្រនឹបរង្គាន់នឹងថ្លៃថ្នាំលោកក៏ថែរក្សា ទៅយ
ថែរក្សាដោយស្មោះអស់ពីពោះ កាលឃើញថាមិនសះជាក៏មិនចោះបង់
ចោល បើកូនអនិច្ចកម្ម ក៏ទទួលធ្វើជាម្ចាស់សព ធ្វើបុណ្យទុទ្ទិសផ្ទាល
បញ្ជូនទៅឲ្យ លោកសង្រ្តែងអោះឡោះអាល័យមានមុខដាតដាំដោយចិត
ក្អែក, កាលកូនមានទុក្ខលំបាក ទុក្ខនោះដូចតើតក្នុងខ្លួនលោក, កាលកូន
ឈឺ ខ្លួនលោកក៏ដូចឈឺដែរ មានចិត្តព្រួយបារម្ភខ្លឹងកូនជានិច្ច, ឱនបំណើ
ឆ្ងាញ់ពិសាមក ក៏នឹកដល់កូន, នឹងបរិភោគចំណីអ្វី បើកូនមិនបានបរិភោគ
ផង លេបមិនរួច, បើមានការខៅណា ត្រឡប់មកវិញ សូម្បីខ្សឹយហត់ដូច
ម្តេចក៏ដោយ តែបានឃើញមុខកូនសោយទុក្ខ ខោះប៉ស្រែកឃ្លាន ក៏ស៊ូអត់
ធ្មត់យកកូនមកបីបំពៅសិន, ចំណែកខ្លួនស៊ូអត់ត្រាំសម្រែកគំលាន, កាល
កូនចៅធំធ្លែតហើយ លោកខើបបរិភោគពេលក្រោយ ធ្វើការប្រតិបត្តិថែរក្សា
កូន ដោយសេចក្តីពេញចិត្ត មានមុខញញឹមញញែមរីករាយ ។ យើងអាច
ពោលបានពេញទ្រូងឆ្អែតថា គ្មានការសកម្មភាពណាក្នុងលោក ដែលស្រ-

ឲ្យាញ់នាយ ហើយទំធ្វើកិច្ចការឲ្យនាយ ដោយមិនគិតយកថ្លៃឈ្នួល ដូច
មាតាបិតាដែលស្រឡាញ់កូន ហើយទំថែរក្សាកូននេះឡើយ, កាលឃើញ
កូនបានសេចក្តីសុខសប្បាយ ឬបានទទួលលាភសក្ការៈ លោកក៏មានមុទិតា
ចិត្តត្រេកអរទំងឹងកូន គ្មានចិត្តឫស្សាឈ្នានិស ខ្លាចកូនបានល្អជាងខ្លួនឡើយ
មានតែសេចក្តីពេញចិត្តនឹងកូន នឹងមានទម្លេកូរដោក់ចិត្តដាក់ណាលមិន
ប្រកាន់ទោស សូម្បីកូនធ្វើខុស ក៏មិនគិតប្រទូសរ៉ាយ, កូនពោលពាក្យ
អាក្រក់តប លោកអត់សង្កត់ចិត្តមិនអាឃាតឮក្បាច, ទោះបីលោកដេរ
ពោលដោយពាក្យអាក្រក់ខ្លះ ក៏ដេរតែមាត់ ឯចិត្តលោកមិនប្រកាន់ទោស,
ហួសចិត្តណាស់ក៏សម្រក់ទឹកភ្នែកយំយែកខ្លួនឯង, កាលកូនមានសេចក្តី
ខុសនៅអាស្រ័យនឹងអ្នកដទៃមិនបាន គេបណ្តេញចោះបង់ចោល អស់ផ្លូវ
ក៏ត្រឡប់មកនៅនឹងម្តាយឪពុកវិញបាន. លោកត្រេកអរទទួលឲ្យនៅឥត
ដេរបណ្តេញឡើយ ។ មាតាបិតាប្រកបដោយព្រហ្មវិហារធម៌ ដូចបាន
ពោលមកនេះ ទើបឈ្មោះថាជាព្រហ្មរបស់បុត្រធីតា ។

ត្រង់ដែលខ្ញុំប្រៀបធៀបមាតាបិតាថាដូចភ្លើងនោះ ព្រោះលោក
មានគុណ កាលបុត្រធីតាមកគោរពប្រណិប័តន៍ដោយប្រពៃចំពោះលោក
ហើយរមែងបានបុណ្យកុសល ព្រមទាំងជាគុណសម្បត្តិដ៏គាប់ប្រសើរ
ទាំងក្នុងលោកនេះទំងឹងលោកមុខ ប្រៀបដូចបុគ្គលដែលចេះប្រើភ្លើង តែង
បានប្រយោជន៍អំពីភ្លើង ទំងឹកប់មិនបាន ដូចបន្លើនប្រើភ្លើងក្តៅតែបបួលភ្លើ
រមែងញ៉ាំងបុញ្ញាភិសំឲ្យកើតឡើងបាន, អុជធ្វើជាប្រទីប ក៏បញ្ចាំងពន្លឺភ្លឺឆ្វេ
រឿងអាចមើលឃើញសត្វតុផ្សងៗ, បន្លើនប្រើភ្លើងក្តៅតែដាំស្លូតក៏ញ៉ាំង

អាហារគ្រប់ចំណែកសម្រេចបាន, នាំគ្នាប្រើមានត្រឿងយន្តត្រឿងចក្រ ក៏ឲ្យសម្រេចលទ្ធផលគឺការមានចំណែក ។ គោលដោយទ្វីថា ក្នុងលោកនេះ បើរួមគេជាធាតុ គឺភ្លើងនេះហើយ មនុស្សសត្វនឹងរស់នៅមិនបានឡើយ លោកនេះនឹងតាំងនៅក្នុងភាពមិនបានដែរ ។ ដែលគោលពាក្យនាមកនេះដើម្បីឲ្យយើញថាភ្លើងឲ្យគុណ មានភ្លើងឲ្យទោសវិញ ក៏មានច្រើនណាស់ដែរ បើបុគ្គលមិនចេះប្រើ ក៏មិនបានទទួលប្រយោជន៍ដូចគោលមកហើយ ត្រូវប្រាប់ជាបានទទួលទោសទៅវិញ ដូចជាប់ភ្លើងត្រង់កន្លែងមិនគួរជាប់ ក៏នេះដែរ, យកភ្លើងនាំទៅប្រើក្នុងវិមិនគួរប្រើ ក៏នេះរួចខាតសព្វាវុត្ថដែលជាទីប្រថ្នា, តែត្រឹតុការណ៍ទាំងនេះ មិនមែនជាកំហុសអំពីភ្លើង ជាកំហុសអំពីអ្នកប្រើភ្លើងវិញទេ សេចក្តីទាមទារនេះដូចរម្តុចបញ្ជា សូម្បីមាតាបិតាក៏មានទាមទារយ៉ាងដូច្នោះដែរ តាលបុត្រធីតាមិនដឹងគុណលោក ហើយប្រព្រឹត្តទាស់នឹងទីន៍លោក តែងបានទទួលទោសមានត្រូវតែរហាន់ខ្លាជាដើម ដើរហូតដល់មាគុយាតបិតុយាត ក៏ត្រូវទោសអនន្តរិយកម្មជាទីបំផុត ។

ត្រង់ដែលទ្រង់លើកដំកើងមាតាបិតាជាទុក្ខកបុគ្គល (បុគ្គលដែលរកបានដោយក្រក្នុងលោក) នោះ មានសេចក្តីថា ដែលយើងកើតក្នុងលោកនេះ យើងមានមាតាតែមួយបិតាតែមួយប៉ុណ្ណោះ ហើយមានតែមួយពិតប្រាកដគឺមួយមិនមានពីរ គឺកាលលោកធ្វើកិរិយាឱ្យទៅហើយ ទីន៍រកបុគ្គលដទៃមកជំនួសលោកមិនបាន ទោះបីបុត្រធីតាមានអំណាចអាចត្រួតត្រាមនុស្សទាំងពេញទាំងក្រឡាមហាប្រថពី ក៏មិនអាចនឹងបង្កាប់អ្នកទាំងនោះឲ្យគេមកធ្វើជាមាតាបិតាបង្កើតខ្លួនបាន ឬទីន៍ប្រើកិរិយាខ្នះខ្នែងលំបាន

ក្រាបសំពះសូមឲ្យគេទាំងនោះមកធ្វើជាមាតាបិតាបង្កើតខ្លួន ក៏មិនបានដែរ ប្តូរក្រដាសមានទ្រព្យសម្បត្តិ អាចដណ្តើយកដែនដីទាំងមូលបាន ក៏មិនអាចនឹងទិញប្តូរលោះមាតាបិតា ដែលមានបំណងមួយទៅហើយនោះឲ្យរស់មកវិញបានទេ ប្តូនឹងផ្តល់អ្នកដទៃឲ្យគេមកធ្វើជាមាតាបិតាបង្កើតខ្លួន ក៏មិនបានទាំងអស់ ព្រោះមានន័យដូចពោលមកនេះ មាតាបិតាទើបឈ្មោះជាទុក្ខសុភបុគ្គល (បុគ្គលកេបានដោយក្រកន្លះលោក) ។

មានខ្លះដែរ មាតាបិតាដែលមានចិត្តអាក្រក់ មិនចង់បានកូនឬកាលមានកូនហើយ ក៏ព្យាយាមរំលូត ឬយកទៅចោលចោះបង់កន្លែងផ្សេង ។, មាតាបិតាដូច្នោះជាមនុស្សខុសវិស័យនៃជនធម្មតា, ព្រោះដូច្នោះទាន់ព្រះពុទ្ធសាសនា ទើបកំណត់គុណមាតាបិតា ដោយអង្គ ២ គឺដោយការឲ្យកំណើតប្រការ ១ ដោយការធ្វើឧបការៈប្រការ ១ ។ មាតាបិតាដែលធ្វើនាទីត្រឹមឲ្យកំណើត ឈ្មោះថាជាមាតាបិតារបស់បុត្រជាតិតាត្រឹមតាក់តណ្តាលឬកន្លះ, អ្នកធ្វើនាទីត្រឹមឧបការៈ លោកឲ្យនាមថាជាមាតាបិតាចិញ្ចឹម ព្រោះធ្វើនាទីមិនគ្រប់ទាំង ២ គឺធ្វើត្រឹមតាក់តណ្តាលឬកន្លះ, ឪពុកម្តាយដូច្នោះ អ្នកទាំង ២នោះ ឈ្មោះថាមានគុណដ៏ធ្ងន់ក្រៃលែង ព្រោះជួនបន្តជីវិតគាកឲ្យរួចរស់ ខ្មីងចំរើនវ័យវឌ្ឍនការ; បើជាមាតាបិតាដែលឲ្យកំណើតផង ជាអ្នកធ្វើឧបការៈផង ឈ្មោះថាមាតាបិតាពេញទំមិនមែនត្រឹមតាក់តណ្តាលឬកន្លះឡើយ ព្រោះបានធ្វើនាទីគាំង ២ យ៉ាងបរិបូរណ៍ ។

• បើបុត្រធីតាមិនដឹងគុណូបការៈរបស់មាតាបិតាដូចសំដែងមកហើយកន្លងទីនេះក្តី ឬដែលមិនបានទាំមកសំដែងកន្លងទីនេះក្តី ឈ្មោះថាជាមនុស្ស

អាក្រក់ជាមនុស្សអកតញ្ញូ ជាមនុស្សអន្ធពាល ព្រោះមំបាត់គុណលោក ដ៏មានគុណ; ប៉ើដឹងគុណហើយ តែមិនបានធ្វើប្រតិការៈតបស្នង ឈ្មោះ ថាជាមនុស្សល្អត្រឹមពាក់កណ្តាល ព្រោះគ្មានកតវេទី គឺមិនបានធ្វើប្រតិ-ការៈតបស្នង ទើបបាត់ជាមនុស្សល្អពេញទីមិនបាន; ដែលបាត់ជាមនុស្ស ល្អពេញទីបាននោះ លុះណាតែប្រកបដោយអង្ត ៦ ប្រការ គឺកតញ្ញូ ប្រការ ១ កតវេទីប្រការ ១ ដូចមានសាវកភាសិតថា:

និមិត្តំ សាធុរូបានំ កតញ្ញូកតវេទិតា

ប្រែថា "ភាពជាអ្នកកតញ្ញូកតវេទី ជាត្រឿងសំគាល់នៃជនល្អ" ។

ក៏ការធ្វើប្រតិការៈតបស្នងសងគុណលោកដ៏មានគុណនោះ ព្រះសម្ពុទ្ធ បានត្រាស់ទុកក្នុងសិង្គាលោវាទសូត្រថា បញ្ចហិ ខោ គហបតិបុត្ត ហិនេហិ បុត្តេន បុរត្ថិមា ទិសា មាតាបិតរោ បច្ចុប្បដ្ឋាតព្វា ប្រែថា "ម្នាលគហបតិបុត្រ មាតាបិតាលោកទុកជាទិសបូពា បុត្រធីតាត្រូវ ធ្វើប្រតិការៈតបស្នងដោយស្ថាន ៥ យ៉ាង គឺ:

១ លោកចិញ្ចឹមមកហើយ ត្រូវចិញ្ចឹមលោកវិញ

៦ ត្រូវជួយធ្វើកិច្ចការរបស់លោក

៣ ស្ថាបនាវង្សត្រកូលរបស់លោកឲ្យចិតថេរចីរកាល

៤ ប្រតិបត្តិខ្ជូនឲ្យសមគួរជាអ្នកទទួលមរដក

៥ កាលលោកអនិច្ចកម្មទៅហើយ ត្រូវធ្វើទក្ខិណាទានទ្ធិស ផលជូនលោក ។

តាមគោលនេះ បុត្រធីតាមានឧកាសធ្វើប្រតិការៈតបស្នងសងគុណ មាតាបិតាបាន ៦ គ្រាតឹ កាលលោកមានជីវិតរស់នៅ ១ គ្រា កាលលោកអនិច្ចកម្មទៅហើយ ១ គ្រា ។ បើពោលដោយលក្ខណៈការតបស្នងមាន ៦ យ៉ាងតឹ តបស្នងដោយអាមិស ដូចប្រណិបីតន៍ទំនុកបំរុងលោក ដោយជូនម្ហូបចំណីបាយទឹកសំពត់សៅអាវវស្សជាដើម ១, តបស្នងដោយធម៌ ដូចវៀរចាកទុច្ចរិត ប្រព្រឹត្តសុចរិត មានសេចក្តីសាមគ្គីរវាងបងប្អូន ប្រព្រឹត្តតាមឧវាទរបស់លោកព្យាយាមតាំងខ្ជួនឲ្យមានគោលចារឹក ជាអ្នកមានធនធានស្ពុកស្ពម្ព ១ ។ ទាំង ៦ ១ នេះអធ្យាស្រ័យរបស់មាតាបិតា តែងចូលចិត្ត ១ ទី ៦ ប្រើនជាង ១ ទី ១ ។ បើបុត្រធីតាប្រព្រឹត្តខ្ជួនឲ្យបានល្អជាងគោលដើម ដែលបានពោលមកហើយនោះ គឺធ្វើខ្ជួនឲ្យជាអ្នកមានសីល មានកល្យាណធម៌ បានឈ្មោះថា អតិជាតបុត្រ, បើប្រតិបត្តិបានត្រឹមគោលដើមឈ្មោះថា អនុជាតបុត្រ, បើប្រតិបត្តិថយជាងគោលដើមរហូតដល់ធ្លាក់ខ្ជួនជាមនុស្សថោកមនុស្សខូចឈ្មោះថា អវជាតបុត្រ ដែលមិនជាទីប្រាថ្នារបស់មាតាបិតា ដូចមានព្រះពុទ្ធកាសិតថា

អតិជាតំ អនុជាតំ បុត្តំ ឥច្ឆន្តិ បណ្ឌិតា
អវជាតំ ន ឥច្ឆន្តិ យោ ហោតិ កុលគន្ធនោ ។

ប្រែថា "មាតាបិតាជាបណ្ឌិត តែងប្រាថ្នាបុត្រ ជាអតិជាតនឹងអនុជាត តែមិនប្រាថ្នាបុត្រជាអវជាតដែលបំផ្លាញវង្សត្រកូល" ។

ការមានបុត្រ បើបានបុត្រល្អ ក៏ជាទីត្រេកអរ ជាហេតុឲ្យកើត

សេចក្តីសុខសេចក្តីចំរើន ធ្វើវង្សត្រកូលឲ្យអណ្តែតខ្ពង់ខ្ពស់ឡើង ព្រម
ទាំងធ្វើវង្សញាតិឲ្យមានមុខមាត់កេរ្តិ៍ឈ្មោះល្អ ប្រៀបដូចព្រះសម្ពុទ្ធ ដែល
ទ្រង់ទបត្តិភ្នក់សាក្យវង្សធ្វើឲ្យក្សត្រិយ៍វង្សនោះជាទីគោរពប៉ាន នៃជន
ពូ៧ រហូតដល់បរមក្សត្រិយ៍ប្រទេសដទៃ គឺសឹងគោរពគោតទាំង ។
ហេតុនោះលោកទើមសំដែង អានិសង្សនៃការមានបុត្រថា ឆន្ទតិ ប្បុត្តេ-
ហិ ប្បុត្តិមា ប្រែថា "មាតាបិតាដែលមានបុត្រ តែងត្រេកអរកើតឃ
ដោយបុត្រ តែបើបុត្រនោះជាអរជាតបុត្រ ប្រព្រឹត្តតែខុសតែ ដែលជាហេតុ
នាំមកនូវភាយនៈ ក៏ធ្វើឲ្យលោកកើតទុក្ខទោមនស្ស ព្រោះបាននូវលួច
តែការត្រេកអរនិងអំពីជនដទៃ បាននូវលួចសេចក្តីសប្បាយកើតឃខ្លះ តែ
តាលក្នុងនៅតួច តាលចំរើនឡើងហើយ មិនប្រព្រឹត្តសុចរិតប្រព្រឹត្ត
តែសេចក្តីអាក្រក់ ក៏ធ្វើឲ្យសេចក្តីស្នេហារបស់លោកអស់ទៅជាបន្តិចម្តងៗ
បន្តិច បាននូវលួចតែសេចក្តីទុក្ខគ្រាយ ធ្វើឲ្យលោកនឹកឃើញថាអាត្មាអញ
នេះចេះតែកូនល្ងង់ ដូចមានសុភាសិតថា:

ភាពជាអ្នកគ្មានកូន ១ មានហើយស្ងាប់ ១ មានហើយមិនតាំង
នៅក្នុងនូវនប្រព្រឹត្តតែសេចក្តីអាក្រក់ ១ ក្នុងបុត្រទាំង ៣ នេះ មាតាបិតា
តែងប្រាថ្នាបុត្រទី១ ទីពីរបុត្រទី២ ព្រោះមិនចាប់សោកសង្រេង ឬសោក
សង្រេងតែ១ ដង ។

បុត្រដែលមាតាបិតាបានបំពេញនូវទីរបស់ខ្លួនយ៉ាងល្អបរិបូណ៌ ឈ្មោះ-
ថា បានដោះសេចក្តីទុក្ខព្រួយរបស់មាតាបិតា ទីនេះឈ្មោះថាធ្វើឲ្យលោក
មានសេចក្តីត្រេកអរកើតឃ ព្រោះបានស្តាប់នូវត្រកូលរបស់លោក

ឲ្យថ្លៃតម្លៃចំណែកគាល ឈ្មោះថាធ្វើឲ្យលោកអស់ទុក្ខកង្វល់ ព្រោះបានជួយ
ខ្ចួលបន្ទុករបស់លោក គាំងបានឈ្មោះថាធ្វើឲ្យលោកមានសេចក្តីសង្ឃឹម
ព្រោះទឹងបានជួយលោកក្នុងគ្រាឈឺចាប់ កាលលោកអនិច្ចកម្មទៅក៏ធ្វើ
បុណ្យទុទ្ទិសផ្សាផ្សងជូនលោកតាមប្រពៃណីដោយសេចក្តីគោរពចិត្ត ធ្វើខ្លួន
ឲ្យជាទីផ្ញើទ្បោចស្រោចផ្ញើរបស់លោកបាន កាលលោកអនិច្ចកម្ម ក៏
ទឹងធ្វេចក្តែកអនិច្ចកម្មបានដោយស្រួល។ កាលបុត្រធីតាទឹកដល់លោកក៏
មានបីតិក្នុងចិត្ត ដោយគិតថាយើងបានប្រតិបត្តិនាទីរបស់យើងត្រឹមត្រូវ
គ្រប់យ៉ាងហើយ ខ្លួនតិះដៀលខ្លួនឯងមិនបាន ជាទីសរសើររបស់អ្នក
ប្រាជ្ញ ហើយការដែលធ្វើមកគាំងនោះ សុទ្ធតែជាបុណ្យជាកុសលជា
អំតើដ៏ល្អអំណោយផលជាសុខ គាំងកង្វល់លោកនេះទឹងលោកទាងមុខ ។
បើពោលតាមគោលនៃព្រះពុទ្ធសាសនាដែលជាចំណែកអានិសង្ស លោក
ប្រៀបដូចបានប្រណិបត្តិបូជាចំពោះសម្តេចមហាព្រហ្ម, បូជាចំពោះបុព្វ-
ទេវតា, បូជាចំពោះបុព្វាចារ្យ, បូជាចំពោះព្រះអរហន្ត, ព្រះអរិយៈ,
បូជាចំពោះភ្លើង ដែលពាក្យអានថាជាទូតនៃថាន់សួគ៌ ជាការបូជាដល់លោក
ដែលគួរបូជា ត្រូវតាមព្រះពុទ្ធភាសិថា

បូជាច បូជនីយានំ ឯតម្មង្គលមុត្តមំ

"ការបូជាចំពោះលោកដែលគួរបូជា ជាមង្គលដ៏ខ្ពង់ខ្ពស់" ។

មាតាបិតុគុណកថា ដែលខ្ញុំបានពណ៌នាមកនេះ ឃើញថាល្មមសម-
គួរទឹងបញ្ចប់ហើយ ហេតុនោះសូមបញ្ចប់ដោយសង្ខិត្តកថាតែប៉ុណ្ណេះ ។

សារតារាងមហ្លឹងជាតិ

លោក អ៊ុំ ហ៊ឺ តែងជាកាព្យពាក្យពិ

ខំខានមានមកគង់សម័យ ស៊ីវិល្ហៃជាន់ដើមនៅអឺរ៉ុប
ប្រទេសជាតិធំចាំធំមិនឈប់ សរុបគ្រប់ដៃខដធំតំបន់ ។
រវល់ជាន់ប្រឹងរយន្តាំហ៊ាយ រវើរវាយតស៊ូយុទ្ធស្រាកស្រាន់
រត់ញ័ខក្នុងព្រៃព្រៃភ័យភ័ន្ត ខ្លាចពលមកចាន់ផ្តន់ដ៏ក្តាំ ។
ការភ័យតិតភាំនឹងភាំនជាស់ក្បែរ ប្រុសស្រីរាំរ្វើនត្រង់អាត្មា
ក្មេងចងរក្មេងរួនក្មេងជួនតា ភាំនត្រូអាចារ្យអាពុកម្តាយ ។
ប្រាសព្រាត់ភ្លាត់គ្នាតាំយោគ្តី ខ្មៅដៅយសារគ្តីភ័យអន្តរាយ
ចោលស្រុកតុម្ភកវរបរភាំនឡាម គ្មានស្តាយឡាយជាតមិនតិតខេ ។
ប្រទេសជាតិធំចាំនឹងតន់តេក ជាតំបែកចាក់ដៃពស់អន់គ្នូស
អន់គ្នូសដណ្តើមចូនខេរ គ្មានវេគ្មានរួញគ្មានធុញថប់ ។
អន់គ្នូសហោហាវនាវនេរក្រៃ ជុតផ្លះរៃគ្រាវដ្ឋបរទ្រែសព្វ
តន្តីប៉ុប៉ាជុំលាមប្រទេសមាប់ សន្ធាប់សន្ធោហ៊ាខ្លួរខ្លារ ។
ជាប់តស៊ូជាតិតាំនដាស់ឈ្លើយ ជាន់ប្រិនគ្មានសេរីយភាតណ្តា
តក្រើតអំពើតទាំនពសុជា កន្លែដែនតាពត្រានោះនៃ ។
តៀរយកនាំចេញាំចេញលំជាក គោតយាំតកំសត់កន្លែបូរី

ប្រើច្រាសដោយពាក្យប្រមាថស្តី គ្មានត្រាប្រណីអ្វីដល់ផង ។
នគរសូន្យស្ងុតក្នុងអំណាច អ្នកស្រុកខ្វះបង្ហាចពុំអាចធូរ
នាំគ្នាដេញក្តុមុខរសៅហ្មង ចំផ្សងតាមត្រចង៉ៃសព្វយ៉ាងតិ ។
តាបាកនឹងស្មានថាបានសុខ រួចផុតបាកក្តុក្តៅមុខទៀត
ព្រោះបច្ចាមិត្តស្អិតឥតឃ្លាត នៅជុំចង្កៀតបៀតបៀរ ។
ព្រមគាំងការងាប់ការកេងការ ត្រូតត្រាចាត់ចែងតែងសេចក្តី
ត្រង់មុខក្រសួងផងទីវៃ ពន្ធទឹកពន្ធដៃត្រពន្ធដីធ្លី ។
តាប់ជួនមានហេតុដ៏អស្ចារ្យ បណ្តាលឲ្យខេវាក្នុងប្រថព្ធ
ស្តុះក្តៅម៉ៅមួតួតន្ទ្រើយ កើតទុក្ខវាតវីទីក្រឡា ។
ក្រឡេកមើលទៅត្រូវច្បាស់ពិត តំនិតអង្គឥន្ទ្រាសើចថា:
យើតុំតួរសូន្យក្នុងសីមា ដែលមានទ្វីក្លាអស្ចារ្យពេក ។
ខេវាតប្រញាប់ចាប់យាមក្បួន មកតួរនមកតួមកតិតលេខ
ឃើញត្រតែម្តេវៅថ្ងៃស្អែក ខេវាតនឹងដ្រែកទៅលោកិយ ។
ណានាំពាយួរខាងហ្នឹងជាកិ ដែលឃើញខ្នែក្លាខ្លាំងលើសស្រី
មានបុណ្យមានបុទ្ធិពេកណាស់នៃ តាបដួយបូរីឲ្យសុខា ។
ខេមរជាតិយើងតែងភ្ជាប់ដីធ្លី ភ្ជាប់ព្រលឹងឈាមសឹងរាល់រូបា
ថាខាងហ្នឹងជាកិនោះឯងណា លប្រីឈ្មោះអស្ចារ្យខាងយុទ្ធសាស្ត្រ ។
នៅក្នុងចិត្តខ្មែងស្រឡាញ់ជាតិ ឫកពារមារយាទឈ្លាសឆ្លៀវឆ្លាស
ស្រឡាញ់មាតុភូមិខ្លួនខ្លាំងណាស់ ស៊ូប្រាសព្រាត់ស្ងាប់ទៅទើបជា ។
ខាងមានឈ្មោះលប្រីក្នុងបូរី ទាំងប្រុសទាំងស្រីផងនានា

តែងឆ្នៃឈ្មោះនាងដួយភាព　　កុងគ្រានោះឯងចាកទុក្ខា　　។

ពជការដំកល់ឈ្មោះនាងទុក　　ស្អាងរូបស្អាងមុខដោយត្រូវការ

ធ្វើបុណ្យសងគុណធម៌អស្ចារ្យ　　កុងដែនសីមាមហាបុរី　　។

កាល់ឆ្នាំចាំពេលថ្ងៃអាទិត្យ　　ទី២ពន់ពីរខែជាវមី

ពជការតែងរំលឹកគុណស្ត្រី　　ធ្វើបុណ្យធំក្រៃថ្ងៃនោះឯង　　។

ដើម្បីឲ្យគង់គុណធម៌　　ដែលនាងស្មោះសរល្អជាក់ស្តែង

ឲ្យបានថិតថេរអស់កល្បជង　　ពជការសំដែងគុណនាងស្រី　　។

ប្រវត្តិនៃវត្តកែវធីតា　　ឈ្មោះហ្នឹងដាក់តែងកុងបុរី

ប្រទេសចាកចំងាយប្រាំថ្ងៃ　　ប្រាំមួយខែថ្មីនៃដើមឆ្នាំ　　។

មួយពាន់បួនរយទើងដប់ពីរ　　ភូមិដុំរមើលប្រចាំ

កំណើតស្ត្រីស្រីគ្នាខកម្ម　　កុងឆ្នាំខេះឯងស្លែងអស្ចារ្យ　　។

ត្រកូលភូជពង្សវង្សក្តិយស　　មិនខ្ពស់ទាបអាងមិនហ៊ឺហា

សមរម្យជាអ្នកស្រែចំការ　　ព្រមចាំងមាតាបិតាថ្លៃ　　។

កាលនាងអាយុ១៣ឆ្នាំ　　ទេវតាស្រែកថ្នាំដួងចរណៃ

ឲ្យទំទស្សហ៍ចាំងយប់ថ្ងៃ　　រៀនសូត្រធម៌ថ្លៃប្រពៃពិត　　។

ឲ្យនាងខំកាន់សេចក្តីខ្មៀង　　កុំបីលំអៀងតិសុចរិត

ទស្សហ៍សូត្រធម៌ទើបល្អបំផុត　　ល្អចាំងគំនិតពាក្យសំដី　　។

ក្រោយមកនាងឃើញទេពនិម្មិត　　អណ្តែតមកជិតខ្លួនស្រស់ស្រី

ជាអង្គទេវតាមានរស្មី　　ជារមិតភ្លឺភ្លាសន្ធៅ　　។

ទើបនាងក្រាបគាល់ជាបង្គំ　　ព្រះអង្គជាធំកំសៀម។ល។

ត្រាស់ថាមាសស្ងួនខ្ជួនពាលពៅ ចូរនាងត្រាច់ទៅយកអាសា ។
ផែនទឹកផែនដីបុរីអម្ប មានត្រោះយ៉ាងធំធ្ងន់អស្ចារ្យ
ចូរនាងអាណិតប្រទេសណា ជួយយកអាសាមហានគរ ។
ជ្រុតពួកអង់គ្រួសព័ទ្ធទីក្រុង អ៊ីឡអង្ស្រ ខាងក្នុងពេញដំហិរ
អ្នកស្រុកកតតយវត់ញ័រ កែវរដេរដាសំពាសប្រថពី ។
ខ្លះយំខ្លះស្រែកខ្លះតេលូន តពាក់តពូនខ្លាចរន្ធឺ
នៃបច្ចុមិត្តរំខ្ជើតេញទី រកវិលវល់អំពល់ខ្លាំង ។
ចូរនាងទៅដេញចេញឲ្យឆាប់ ប្រញាប់កុងត្រាវេលាភ្លាំង
ឲ្យទាន់កុងគេលដែលតតាំង ទើបក្រុងបាកាំងបានសុខា ។
កាលណោះនាងនាថមានរូបឆោម ពងរៀវសមល្មមល្អអស្ចារ្យ
មុខមូលកំផ្ទង់ដូចខែតា សក់ដាបដល់ស្មាសង្គាដី ។
ជន្មាអាយុដប់ប្រាំមួយ មុខស្រស់គ្មានព្រួយតិចរឿងអ្វី
ញញឹមញញែមផ្អែមសំដី សម្បុរស្អីខ្ចីខ្ចៅស្រគាំ ។
ឫកពាសុភាពតបពថសារ កញ្ញាល្អថ្លៃកចំណៃសម
គ្មានបងប្អូនណាព្រួយជាអ្នក ថៃទាំដល់ទាងដូចម្តេចឡើយ ។
នាងមានតំរេកត្រេកអរណាស់ ខែតាច្រាប់ឮសំដីរបោះហើយ
នាងមិនបង្អង់នៅកណ្តើយ ត្រាណត្រើយច្រាយច្រាប់អាពុកម្តាយ ។
ហើយនាងសុំលាចាកគេហា តែម្នាក់អាត្មាទៅស្រុកឆ្ងាយ
កំចាត់សត្រូវផងទាំងឡាយ ឲ្យបានសប្បាយក្នុងនគរ ។
អាពុកយាត់កូនមិនឲ្យទៅ សង្ឃឹយថាពៅនាងកតតរ

ជាតិស្រីត្មានល្បីយោងនគរ កុំវរមិនដឿទេកូនស្រី ! ៗ
នាងចូលបន្ទប់សញ្ជប់តិត ឡបងឡៃងតំនិតតិតពីរបី
ព្រួយពេកដេកថ្ងូរក្នុងរាត្រី អាណិតបូរីស្រីសោកយំ ៗ
ក្រោកទ្បើងអង្គុយទ្រចង្ការ នេត្រាហៀហូរដោរដោកជុំ
ដោកជល់អំពលនិម្មលមុំ ទុក្ខងំត្រាំខ្ទួនទួនពុំស្ពី ៗ
រំពឹងសញ្ជឹងតឹងទ្ធ៉ា រកអ្នកឯណាឲ្យតប្បី
នៅក្នុងស្រុកភូមិនោះឯងនៃ នឹងជួយស្ត្រីជ្រាប់ប៉ិតា ៗ
ឲ្យបានដឿជាក់ស្ម័ត្រព្រមធង បើកឲ្យនួនល្អងចរយាត្រា
ទៅដ្ទីសត្ត្រាមជួយអាសា ជល់រាជសីមាមហានគរ ៗ
ទើបនាងនឹកយើញលោកស័ក្ត៌ញ ព្រឹព្រួចហប្ចទ័យស្រីត្រេកអរ
រីករាយសប្បាយក្នុងទទរ ក្រោកឈររៀបប្ចកនាងនឹកទៅ ៗ
លោកនោះនាមឈ្មោះបូទ្រីតូ មានស័ក្ត៌ពាក់យូរត្រួតត្រានៅ
ទាហានក្នុងភូមិនោះឯងកូវ មើលការខុសត្រូវនៅតាំពារ ៗ
ជល់ហើយនាងទនក្បាលតំនាប់ តាមរបៀបច្បាប់ចាប់ដៃត្នា
លោកក៏អនុញ្ញាតឲ្យពំងារ អង្គុយនៅនាលើកៅអី ៗ
នៅមុខតុមួយមួយខាងម្នាក់ មានប្រអប់ជ្រាក់ជាក់ជ្ចារ
ទទួលក្រមុំព្រហ្មចារ ដោយនៅសេចក្ត៌មេត្រីរាប់ ៗ
លោកបូទ្រីតូសួរថានាង មានរូបមានរាងប្រសើរតាប់
អញ្ជើញជល់យើងជាមេទ័ព ហើយដែលពុំឆ្ទាប់យើញនាងមក ៗ
ចុះតើនាងមានបើហេតុអ្ហ ចូរនាងស្ត្រីស្រីពន្ទក

ពាប់រៀបធៀបប្រាប់ប្រញាប់មក　　ទីឆ្ងាយឆ្ងល់ឆកកំប្លែងការ　　។

កំប្លែងលេងគួរស្រាលតើដូចម្តេច　　ល្មមទីឆ្ងល់សម្រេចបានយ៉ាងណា

ខ្ញុំទីឆ្ងាយនាដួយដោះសារ　　តាមដោយប្រាជ្ញាណាអ្នកស្រី　　។

នារីធ្វើយថាមេត្តាពោល　　សន្តោសប្រោសប្រាណាថ្កានប្រណី

សូមកុំប្រកាន់ពាក្យសំដី　　ទុសត្រូវម្តេចក្តីសូមមេត្តា　　។

ជ្បាតថ្ងៃមុនពោះខ្ញុំឃើញពិត　　ឃើញខេតនិម្មិតខ្ញុំក្រឡា

ក្រឡាប់តាំងដែនដែនខេត្តតា　　ច្បាស់ការទីឆ្ងាយកែកឥតប្លែកអ្វី　　។

អណ្តែតក្រសែតចំកណ្តាល　　តន្ទីភ្លឺច្រាលមានរស្មី

លេចចេញគ្រប់តណិស្ស្រីវិញ　　ហើយក្រាស់ប្រាប់ស្រីឲ្យប្រញាប់　　។

ទៅជួយតតាំងឆ្ងាំឆនតរ　　ដែលកើតតែកវឲ្យបានធាប់

បើខេមុខតែទីឆ្ងល់ក្រឡាប់　　កុងនាកណ្តាប់ដៃអង់អែស　　។

ដោយហេតុនេះហើយបាននាងខ្ញុំ　　ចូលខ្ញុំនមកសុំឲ្យលោកគ្នា

ចាត់ការបញ្ជូនខ្ញុំនមាសមេ　　ព្រមចាំឆលេះហ៍ជាមួយផង　　។

ឲ្យបានដល់ទៅទីក្រុងក្រែ　　បង្គំក្សត្រថ្ងៃដ៏ច្បាស់ច្បង

អង្គាស់ដំរីតឲ្យជ្រាបផង　　រួចស្រេចឥតហ្មងសុំលាច្បាំង　　។

ឲ្យឃើញជាក់ស្តែងសំដែងខ្ញុំ　　ដេញចង្កូមិត្តឲ្យក័ន្តកាំង

កំចាត់ឲ្យស្ងាត់ព័ក្តងកាំង　　ឲ្យស្រុកបាក់ឆ្ងាយបានសុខា　　។

លោកចូរខ្ញុំតូឮដូច្នោះ　　ឆ្ងល់ណាស់ក្តងពោះឥតឧបមា

ពុំជឿថាមានអង្គខេត្តតា　　ច្រាប់នាងហ្នឹងជាកំយ៉ាងនោះឡើយ　　។

នាងខេត្តតែឧបមាអង្វរ　　លន់តួស្មោះសរពុំមានស្បើយ

ច្រើនជង់ច្រើនគ្រាឥតឈប់ឡើយ ទើបលោកថាល្អើយទៅចុះទៅ ។
លោកថាត់ពាហនច្រាំមួយនាក់ ឲ្យនាំវាលក្ខណ៍ជាក់ដល់ទៅ
ទីក្រុងស៊ុណុង ក្នុងឥឡូវ ពុំបង្អង់នៅឲ្យយឺតការ ។
រួចឲ្យជាវមួយទៅនាងទៀត កាន់យកសឹកសៀតជាប់អាត្ម
ផ្លែវែងមុខស្រួចដូចបន្លា មានក្បាច់រចនាក្លឹដូចពេជ្រ ។
ចំណែកអ្នកស្រុកដុំរមើ ជង់ថានារីនឹងបរគ្រាច់
ត្បោះទៅស៊ុណុងទីក្រុងស្តេច វៃលុយគ្នាស្រួចសម្រួចការ ។
ទិញបានសេះមួយល្អចំណាប់ ធំមាំសាច់ហាប់ខ្លាំងដូចខ្លា
ឲ្យនាងស្រីដំរះបរយោគ្រា កង់ជង់ឋកគាព្រឹក្សាសត្វ ។
មានគ្រឿងប្រដាប់សំពាប់សៀង ដបទឹកតាក់ឈៀងនាងប្រយ័ត្ន
ព្រោះព្រៃស្រីខ្លាចដល់ទីស្ងាត់ ផែលមានសត្វសត្វសាហាវខ្លាំង ។
ពុំហានឈប់ឈរសំពាកកាយ ពុំខ្លាចខ្លឹយណាយស្តាយកម្លាំង
ធ្វើដំណើរស្ទឹងបឹងត្រពាំង រហូតទាំងស្រុកផងនានា ។
នាងទំនៀនពល់ទាំងច្រាំមួយ ថារយៈទៅដួយពាជគាក
តាំងចិត្តឲ្យស្មោះទាំងអស់គ្នា កុំតិតខ្ជិឆ្ងាទៅយ៉ាំងណា ។
ឲ្យបានធាប់ដល់ទៅក្រុងក្រៃ បង្គំក្សត្រថ្ងៃព្រះបាទសារល៍
ទីប្រាព័ពិតនិទ្ទីក្ខា គ្រងរាជសម័ទាមហាប្រទេស ។
នាងធ្វើដំណើរពេញដប់ថ្ងៃ កាត់ព្រៃចូលវាលឥតមានធ្លុស
ប្រឹងលុនឲ្យលឿនទៀនដើងសេះ មិនហិនប្រហែសឲ្យយឺតយូរ ។
ទើបបានដល់ទៅមណ្ឌលដែន មនុស្សព្រាន់ម៉ឺនសែនរាប់មើលឈូ

ក្មេងចាស់ប្រុសស្រីតបទូ គោះបីនឹងគួរកំមិនអស់ ។
ដោយឃើញខួនឯងជាថ្កុំ ឬកពារមេមនៅក្មេងស្រស់
តាហ៊ានដើរតាមសុទ្ធតែខ្លោះ ដោយផ្លូវគៀនគោះបន្ទោះឆ្ងល់ ។
មើលស្តាំមើលឆ្វេងលេងកំសាន្ត តាំងច្រាំតាប្រាណាទោះឯណា
ដឹកសេះបណ្តើរស្មើអាត្មា ខ្លះស្រែកសួរថាទៅណាអើ ។
មកនេះអញ្ជើញទិញចំណី មានសព្វសុទ្ធថ្មីល្អប្រសើរ
ត្រូវការអ្វី ? សូមចូលស្នើរ កុំដេរទៅហួសខ្ញុំបង្រួសស្តាយ ។
នាងធ្វើយថាខេពុំត្រូវការ ទឹងទំនិញផ្សារផងតាំងឡាយ
សូមគាសព្រោះយើងមកតាំងយូរ បំណងចូលថ្វាយបង្គំស្តេច ។
ព្រោះមានកិច្ចការល់ផ្លូវខ្លួនប្រាណ ស្ទើរទៅពុំបានត្រូវសម្រេច
ទឹងម្ចាស់ជីវិតទើបតិតស្រេច ប៉ានជាយើងផ្តាច់ជីវិតមក ។
ផ្លូវច្នេះសុំអ្នកបង្ហាញផ្លូវ ណាមួយដែលត្រូវងាយទៅរក
ឲ្យបានដល់ធាប់ប្រញាប់មក លើកឈឺរសេចក្តីបង្គំស្តេច ។
ក្រោយមកលាខ្មៅថាស្ត្រី មានបុណ្យបារមីពេកណាស់តើ
ល្បីថាពំនាក់ជាបំរើ ខេត្តលោកប្រើឲ្យមកជ្បាន ។
ខនឹងបញ្ជូនិត្តឲ្យល្អិតល្អន ឲ្យហានឲ្យហោចឲ្យខ្លោចខ្លាំង
ដើម្បីឲ្យបានស្រុកបាក់ឆ រួចពីកម្លាំងដៃរាជ់គ្នេស ។
ប៉ុន្តែគ្មានអ្នកឯណាមួយ ឮថានាងជួយដូច្នោះទេ
កេះគ្នាសើចលេងថាមាសមេ រ៉ៃរកកិច្ចកូតក្បត្រា ។
ហើយដួតអំនួតឲ្យកោតក្រែង ឲ្យស្រែងឲ្យស្ញាចខ្លាចចេស្តា

លើសលប់ក្នុងកពពាជរដ្ឋា
ឲ្យមកបង្ក៉ាងយកជួយអាសា
ថាស្រីមានរិទ្ធិចិត្តគ្រាន់បើ
លាន់ព្រះឱដ្ឋក្នុងក្រុងក្រៃ
បង្គាប់ឲ្យនាងយាងចូលថ្វាយ
ចំណែកបែកខាងអង្គក្សត្រា
ទឹងព្រះអង្គឯងក្រែងវិលក្រឡាស់
ព្រះអង្គស្តេចទ្រង់ទូព្រះពន្លូ
ប្រឡូកប្រឡាំតែដោយផ្លូវ
រីឯនាងស្រីទេពធីតា
កិតកំយស្រីត្រួយពេកណាស់អើយ
រំឭកទឹកគុណបុណ្យថ្លាវមី
សូមជួយជូននាងយាងយាត្រា
ដ្បិតនាងមិនដែលយាងយល់សោះ
ផ្សងរួចនាងយាងចូលទៅខ្នី
ទូលថ្វាយថ្នាត់ថ្នាយល្អងថ្លាថា
អំពីទេវតាក្រឡាជ្រែក
ឲ្យនាងយាងមកបង្គំខ្ញុំ
ទៅឯទីក្រុងកំនាំនៃស្តេច

លើកខ្លួនឯងថាទេវតាប្រើ ។
ឲ្យព្រះក្សត្រាស្តេចសរសើរ
ហ៊ានធ្វើដំណើរធ្លាក់ដល់គាយ ។
ដល់ព្រះម្ចាស់ថ្ងៃដែលទ្រង់ឡាយ
ទុកាយបង្គំបរមច័ក្រ ។
បងំល្បងហ្ន៎ជាកិច្ចឃើញជាក់
ការក្លែតអួតជាក់តែអ្នកក្រៅ ។
ជាមហាតុ៌កស្រស់ហើយគង់នៅ
មិនឲ្យគាស៊ៅស្គាល់ទ្រង់ឡើយ ។
ចូលដល់កាលណានាងពុំស្បើយ
លើកដៃឡើងហើយផ្សងសព្ទ ។
អន្ទោកាសីនីទេវតា
ឲ្យចំកន្ត្រាក្សត្រដែនដី ។
ឃើញដូចគាំងអស់កំនំជ័យ
ចំព្រះចារមើតបាំបូក ។
ខូលព្រះពាក្យតុំកវែក
ក្រឡាប់ពីមេឃស្រែកផ្តាំផ្តាច់ ។
ម្ចាស់ជាកំពូលសុំបង្គ្រាប់
សព្វគ្រប់រួចស្រេចនាងសុំលា ។

(មានត)

រឿងត្រីមាស

ជារឿងព្រេង

របស់លោក សក់-ឆាត់ ក្រមការ

ក្នុងកាលពីព្រេងនាយ មានតាចាស់និងយាយចាស់ ពីរនាក់ប្តីប្រពន្ធ ជាអ្នកក្រីក្របំផុតបានសង់ទូមមួយតូចនៅទៀបមាត់សមុទ្រ អស់កាលជាយូរចំនួនញញឆ្នាំមកហើយ ។ តាចាស់នោះឯងតែងរកចិញ្ចឹមជីវិតដោយការនេសាទត្រីតឹបង់សំណាញ់ជាប្រក្រតី ។ ឯយាយចាស់ជាអ្នកប្រកបការកាប់ព្រាល កាប់ក្រៀ យកមកលក់ផ្ទូរចិញ្ចឹមជីវិតជានិច្ចកាល ។

ថ្ងៃមួយ, តានេសាទពុនសំណាញ់ទៅបង់ត្រីនៅមាត់សមុទ្រ, លុះទាញសំណាញ់មកឃើញជាប់សុទ្ធតែតក់ ។ តានេសាទក៏រលាស់ចោលហើយបង់ជាតំរាត់ពីរ, ទាញមកឃើញជាប់សុទ្ធតែសាកយ ។ តានេសាទក៏បង់សំណាញ់ទៅជាតំរប់បីទៀត, ដល់ទាញសំណាញ់មក ឃើញជាប់ត្រីសម្សុរមាសមួយ ។ រំលានោះឯង ត្រីមាសនិយាយអង្វរទៅតានេសាទនោះដោយភាសាមនុស្សថា:

– លោកតា, មេត្តាលែងទ្រុំទៅក្នុងទឹកសមុទ្រវិញទៅ, ទ្រុំនឹងជួនរបស់ដែលមានជំទ្យៃ ជាទីតាប់ចិត្តលោកតា ។

តានេសាទក៏ភាន់ភាំង ហើយទ្វាចជង ដោយនឹកថា "អញបានរកស៊ីដោយការនេសាទត្រីនេះ ចំនួនញញឆ្នាំមកហើយ មិនដែលប្រទះឃើញត្រីចេះនិយាយដូច្នេះសោះ" ។ តានេសាទក៏លែងត្រីមាសទៅ

ក្នុងសមុទ្រវិញ ហើយនិយាយនឹងត្រីថា:

– ត្រីមាស! សូមឲ្យទេតោរក្សាឯងដោយល្អចុះ, ហើយខ្ញុំកមិនត្រូវការទទួលយកវត្ថុអ្វីជាបំណាច់អំពីឯងវិញទ្បើយ ។ ចូរឯងហែលលេងក្នុងទឹកសមុទ្រតាមសប្បាយចុះ ។

តានេសាទ លុះត្រឲ្យប់មកកាន់ត្រឹហាអាត្មាវិញ កនិយាយជំ-ណាលរឿងដែលអស្ចារ្យនេះជ្រាប់ភរិយាថា:

– យាយ, ថ្ងៃនេះបងទៅបង់សំណាញ់ ជានត្រីមាសមួយ ហើយត្រីនោះមិនដូចជាត្រីធម្មតាទ្បើយ គឺវាបេះនិយាយដូចជាមនុស្សយើង ហើយត្រីនោះឯងអង្វរបង ឲ្យបងលែងវាទៅក្នុងទឹកសមុទ្រវិញ វានឹងឲ្យរបស់ដឹមានជំវ្យៃដល់បងតាមតែបងចង់ជាន តែបងខ្ចាចមិនហ៊ានទទួលយកគ្រឿងបណ្ណាការអ្វីមួយទ្បើយ ហើយបងក៏លែងត្រីនោះ ទៅក្នុងសមុទ្រវិញទៅ ។

យាយចាស់ជាភរិយា ជានញ្ចប្ជីនិយាយដូច្នោះហើយ ក៏ដេរទៅប្ជីថា

– នែតាចាស់ ល្មេញល្មើ, មឹចក៏តាឯងមិនទារយករបស់អ្វីមួយអំពីត្រី! បេទុកជាយ៉ាងណា ក៏ត្លូរតែទទួលយកថាំងឈេមួយតូត្រាន់នឹងធងទឹកចុះអេះ ព្រោះរបស់យើងវាជាក់បែកអស់ទៅហើយ ។

តានេសាទ ក៏ត្រឲ្យប់ទៅកាន់សមុទ្រវិញ ហើយចុះដើរកមើលត្រីមាសនោះ រៀលានោះទឹកសមុទ្រ កើតមានរលកយ៉ាងស្រាលៗ, ហើយតានេសាទ ក៏ស្រែកហៅទៅត្រីមាស; ឯត្រីមាសក៏ហែលមកជិត ហើយស្លូរតាត់ថា:

- លោកតា មានការអ្វីមករកខ្ញុំនេះ ?

តានេសាទក៏តបទៅកាន់ត្រីមាស ដោយសេចក្តីគោរពថា :

- ទុំអ្នកម្ចាស់ថ្លៃត្រីអើយ, ប្រពន្ធខ្ញុំឈឺធ្ងន់ខ្ញុំដោយហេតុមិនទទួលយកបេះអ្វីមួយពីអ្នក, ឥឡូវនេះគេហ៊ានឲ្យខ្ញុំមកសុំចាំងថ្មមួយសម្រាប់ពីអ្នកដើម្បីយកទៅដងទឹក ដ្បិតចាំងខ្ញុំក៏ចាក់បែកអស់ទៅហើយ ។

ត្រីមាសតបទៅតានេសាទថា :

- លោកតា កុំបារម្ភឲ្យសោះ, ចូរតាត្រឡប់ទៅផ្ទះវិញចុះ ទៅតានឹងនំទុកបម្រុងដល់តាឯង ។ នឹងបានចាំងថ្មីៗមានជាច្រើនដ ។

តានេសាទត្រឡប់មកផ្ទះវិញ ឯយាយចាស់ក៏បានចាំងថ្មមួយសម្រាប់, តែយាយចាស់មិនបានពេញចិត្តឡើយ ត្រឡប់ជាគំហកឲ្យប្តីវិញថា :

- តាចាស់ល្ងីល្ងើ តាឯងផ្តេសផ្តាសណាស់, ម៉េចក៏ទៅសុំឯចាំងឈើ, របស់នេះល្អឬ ? តាឯងចូរត្រឡប់ទៅរកត្រីម្តងទៀត ហើយសុំផ្ទះមួយវិញ ដ្បិតយើងគ្មានផ្ទះល្អទំនេរទៅទេ ។

តានេសាទក៏ត្រឡប់ទៅសមុទ្រវិញ, ទឹកសមុទ្រក៏ត្រឡប់ជាល្អក់បន្តិច ។, ហើយគាត់ស្រែកហៅទៅត្រីមាស ។ ក៏ហែលមកជិតហើយសួរថា :

- តាមករកខ្ញុំដោយមានការអ្វីទៀត ?

តានេសាទតបដោយគោរពថា :

ខ្ញុំ! អ្នកម្ចាស់ថ្លៃអើយ, ប្រពន្ធខ្ញុំក៏តែតកន់ខ្ញុំខ្លាំងឡើងទៀត, ក៏ឲ្យខ្ញុំមកសុំផ្ទះអ្នកមួយ ។

ត្រីមាសតបថា :

- តាកុំព្រួយ, ចូរតាត្រឡប់ទៅផ្ទះតាឯងវិញចុះ តានឹងបានផ្ទះមួយ តាមតាសុំជាប្រាកដ ។

តានេសាទក៏ត្រឡប់មកកាន់គេហស្ថានខ្ទួនវិញ ស្រាប់តែបាត់ឯខ្ទមនោះទៅ ឃើញឯផ្ទះមួយយ៉ាងល្អរុងរឿងផុះឡើងនៅពីមុខតាត់ មានបន្ទប់ទ្វាត់ខ្ទែងយ៉ាងធំទូលាយ មានផ្ទះបាយនឹងបន្ទប្ទ្ទារជាជួររាងរាយដែលសាងអំពីឥដ្ឋបាយអ, ឯយាយចាស់នោះអង្គុយនៅទៀបបន្ទប្ទមួយ ហើយស្រែកដេរមកតានេសាទជាប្តីវិញថា :

- នែតាចាស់តំរក់ជូចជាតិរញ្ជាន, តាឯងទៅសុំឯផ្ទះផ្តសផ្តាសយ៉ាងនេះ មិនពេញចិត្តអញទេ! តាឯងចូរត្រឡប់ទៅសុំត្រីម្តងទៀតថា: ឃើងមិនចង់ងបានភាពជាស្រីអ្នកស្រែចម្ការសាមីញ្ញជូច្នេះទេ, ឃើងចង់បានទៅជាស្រីមួយដែលប្រកបដោយរូបសម្ស្ត្ថិ មានត្រកូលស្តុកស្តម្ភវិញ ។

តានេសាទ ក៏ត្រឡប់ទៅរកត្រីមាសទៀត, ឯទឹកសមុទ្រក៏រិតតែល្អក់ក្រៃលែង តាចាស់ក៏ស្រែកហៅទៅត្រីមាសៗក៏ហែលមកជិតហើយសួរថា:

- លោកតាមកធ្វើអ្វីនៅទីនេះ ?

តាចាស់តបដោយគោរពថា :

- ឥ! អ្នកម្ចាស់ថ្លៃត្រីអើយ, សូមអ្នកអត់ទោសខ្ញុំ, ប្រពន្ធខ្ញុំគេនៅតែខឹងនឹងខ្ញុំជានិច្ច រាមិនឲ្យខ្ញុំឈប់បានមួយជង្ហីមសោះ; ឥឡូវនេះ រាថារាមិនចង់នៅជាសភាពស្រីអ្នកស្រែចម្ការជូច្នោះទេ រាចង់បានទៅជាស្រីអ្នកមានត្រកូលខ្ពង់ខ្ពស់ស្តុកស្តម្ភវិញ ។

ត្រីមាសតបថា:

- បើប៉ុណ្ណោះទេ ចូរគាកុំព្រួយ, ចូរគាត្រឡប់ទៅផ្ទះវិញចុះ ទៅគាឪនជួយគាឯងឲ្យបានសម្រេចដូចសេចក្តីប្រាថ្នា ។

គានេសាទក៏ត្រឡប់មកផ្ទះអគ្គាវិញ ស្រាប់តែឃើញប្រាសាទមួយយ៉ាងធំខ្ពស់ ឃើញយាយចាស់នោះអង្គុយក្នុងលែងប្រាសាទទាងក្រៅ ហើយមានសម្លៀកបំពាក់សុទ្ធសឹងតែពេជ្រ មានភាក់ភ្នែន ដៃលជាំរំលេចដោយពេជ្រ មានភាក់ខ្សែកពេជ្រជាច្រើនខ្សែ, ម្រាមដៃទាំងអស់សឹងភាក់ដោយចិញ្ចៀនមាសជាំពេជ្រ, ភាក់ស្បែកជើងក្រហម ។ នៅជុំវិញខ្លួនយាយចាស់នោះ មានមនុស្សនៅចាំបម្រើណែនណាន់តាន់តាប់, គាត់ឃើញគាត់ជាក់មនុស្សបម្រើទាំងអម្បាលនោះដោយឥតមេត្តា ។ គានេសាទឃើញដូច្នោះក៏និយាយទៅកាន់តាយាថា:

- ជំរាបសួរ អ្នកស្រី, ឥឡូវនេះចិត្តអ្នកស្រីយ៉ាងណា ល្មមស្កប់ស្កល់ហើយឬនៅ បើបានដល់ទីប៉ុណ្ណោះហើយ ?

យាយចាស់អប្រិយ តំហកឲ្យគានេសាទជាប្តី ហើយក៏ឲ្យគាត់ទៅធ្វើការឯពេនសេះទៅ ។

លុះកន្លងទៅបានប្រមាណតិចអង្គាស, យាយចាស់នោះមានសេចក្តីលោភកើតឡើងទៀត ទើបឲ្យបំរើទៅហៅគានេសាទមកហើយបង្គាប់ថា:

- គាអើយ, គាឯងចូរទៅកត្រីមាសម្តងទៀត ហើយសុំថា: អញមិនបានជាគាតស្រីអ្នកមានត្រកូលស្តុកស្តម្ភត្រឹមប៉ុណ្ណោះទេ, អញចង់បានទៅជាស្តេចស្រីផែលប្រកបដោយឥទ្ធានុភាពយ៉ាងល្បីល្បាញទៀត ។

ពាំងទ្វីបនោះវិញ ។

តាបាស់មានសេចក្ដីខ្ជាចហើយអង្វរថា:

- ឯ! អ្នកម្ចាស់ថ្ងៃអើយ, ចុះឯងកើតមកពីជាតិអ្វី បានជាហាស្ដ៍ និយាយឡើង ត្មានចេះខ្មាសអ្នកស្រុក អ្នកនគរបន្ទិចសោះនេះ? បាននេះ ហើយចង់បាននោះទៀតមិនចេះស្កប់ស្កល់! ។

យាយបាស់រឹងវិតតែខឹង ហើយតំរាមទៅតានសាទថា:

- តាឯងខ្ជាចអ្វី, បានជាហ៊ានមកឈ្ងោះប្រកែកតបតនឹងអញជាស្រី មានត្រកូលខ្ពង់ខ្ពស់ដូច្នេះវិញ? នែតា ចូរទៅឯសមុទ្រៀប្រញាប់, ប៉ើតាឯង មិនទៅទេ, អញនឹងបង្ខំតាឯងដោយអាជ្ញាឥឡូវនេះ ។

តានសាទកំសត់ មានសេចក្ដីខ្ជាចកវិយាអាត្មា ក៏ត្រឡប់ទៅកាន់ សមុទ្រទៀត ។ ក្នុងត្រានេះទឹកសមុទ្រ បណ្ដាលជាមានពណ៌ឆ្មៅ, តានសាទស្រែកហៅទៅត្រីមាស ៗ ក៏ហែលមកជិត ហើយស្សរថា:

- តាមករកអ្វីនៅទីនេះ?

តានសាទក៏តបទៅត្រីមាសដោយតោរពថា:

អ្នកម្ចាស់ថ្ងៃត្រីអើយ, សូមអ្នកអត់ទោសខ្ញុំចុះ ព្រោះកវិយាខ្ញុំរ៉ាវង្វង់ទៅហើយ រ៉ាថាមិនចង់បានជាកាពស្រីមានត្រកូលខ្ពស់ប៉ុណ្ណោះទេ, រ៉ាចង់ឲ្យបានទៅជាស្ដេចស្រីដ៏ធំលើសលុបគេពាំងអស់វិញ រ៉ាឲ្យខ្ញុំមកស៊ុ អ្នកទៀត ។

ត្រីមាសតបទៅតានសាទថា:

- តា កុំព្រួយ, ចូរតាត្រឡប់ទៅផូះវិញចុះ ទេវតានឹងទំនុកបម្រង

ដល់គាឲ្យបានសម្រេចដូចសេចក្តីប្រាថ្នា ។

រៀលានោះឯងយាយចាស់អប្សល័ក្ខណ៍, ប្រែកេទជាស្តេចស្រីដូចសេចក្តីប្រាថ្នា ។ ឯតានេសាទ ត្រឡប់មកដល់ផ្ទះវិញ ស្រាប់តែឃើញមានព្រះរាជរាំងផុះអំពីមុខតាត់ ឃើញយាយចាស់ទៅជាស្តេចស្រីអង្គុយនៅក្នុងព្រះរាជរាំងនោះឯង, មានបរិវារប្រុសស្រីចោមរោមតាល់ហ្វៅហើយមនុស្សទាំងនោះសឹងដឹកស្រាដែលនាំមកអំពីនានាប្រទេសយកមកថ្វាយ, ហើយស្តេចស្រីនោះបរិភោគនំបុាំងដែលប្រកបដោយគ្រឿងទេសមានរសឈ្ងុយឈ្ងប់ ។ តានេសាទនិម្មិតតែបានឃើញសភាពដូច្នោះហើយ ក៏ញ៉ាវរន្ធត់ស្ងុតក្នុងចិត្តលុតជង្គង់នៅមុខស្តេចស្រីជាកវិយាថ្វាយបង្គំហើយស្ងរថា:

-សូមថ្វាយបង្គំ ស្តេចស្រីកំណាច! ឥឡូវនេះ ព្រះនាងសព្វព្រះរាជហប្ចទ័យ នឹងសម្សត្តិប៉ុះណ្ណុះហើយឬនៅ ?

ស្តេចស្រី (យាយចាស់) ឥតរមិលមើលមកតានេសាទជាប្តីដល់តិចសោះ សូម្បីមួយប៉ប្រឹចភ្នែកក៏គ្មាន ហើយត្រឡប់ជាបណ្តោញតានេសាទនោះវិញ ។ ពួកបរិវារនឹងអមាត្យនាំគ្នាចាប់ស្មាតានេសាទប្រានចេញមកឡារខាងក្រៅ, ក្រុមរក្សាព្រះអង្គក៏ស្ទុះទៅតំរាមតាត់ មានអាការហាក់ដូចជានឹងប្រហារ ឲ្យដាច់ជាកំណាត់តូច-ធំ, ចំណែកឯបណ្តាជនក៏ចំអកផ្ទញ់ផ្ទាល់ឲ្យតានេសាទថា :

-នែតាចាស់ចោលម្សៀត, យ៉ាងនេះហើយវាសមនឹងអំពើតាឯង! តាឯងគ្មានដឹងខ្យល់អ្វី, ហ៉ានលើកខ្ជូនទៅផ្ទឹមនឹងមហាក្សត្រី នេះជាការគ្មរបស់តាឯងឬ?

តានេសាទកិតកីយណាស់ ក៏រត់ចេញអំពីនោះទៅ ។ មិនយូរប៉ុន្មានកន្ទឥទៅប្រមាណពីរតាទិត្យតមកទៀត, ស្តេចស្រីក៏កើតលោភចិត្តទ្បើឥទៀត ទើបចាត់រាជបម្រើឲ្យដើរទៅតាមរកតានេសាទជាប្តី, លុះរកឃើញហើយក៏បាននាំយកខ្ជូនតានេសាទនោះមកថ្វាយ, ឯស្តេចស្រីនោះបន្ទាប់ទៅតានេសាទថា :

-ចូរតាឯឥទៅរកត្រីនោះទៀតហើយនិយាយស៊ុំថា: អញមិនចង់បានជាស្តេចស្រីជូច្នេះទេ, អញចង់បានទៅជាស្តេចស្រីជាម្ចាស់លើសមុទ្រទិញដើម្បីទៅនៅត្រួតត្រាក្នុឥមហាសមុទ្រ ត្រាតែបានត្រីមាសនោះមកនៅបម្រើអញតាមតែសេចក្តីដែលអញត្រូវការតែម្តឥ ។

តានេសាទ មិនហ៊ានប្រកែក ក៏ទៅកាន់សមុទ្រ, ទឹកសមុទ្រវេលានោះប្រែពណិទ្មៅ មានព្យុះនឹឥរលកបោកបែកផ្តាត្រែឥ; តានេសាទស្រែកហៅទៅត្រីមាសជូចមុនទៀត ឯត្រីមាសក៏ហែលមកជិត ហើយស្ជរថា :

-នែលោកតាកំសត់, ចុះតាមករកអ្វីទៀត ?

តានេសាទ តបទៅកាន់ត្រីដោយតោរពថា :

ឧ! អ្នកម្ចាស់ទ្រីត្រីអើយ, តាមតែអ្នកអត់ទោសខ្ញុំចុះ, ខ្ជូនខ្ញុំពុំជឹឥបើនឹឥប្រព្រឹត្តទៅយ៉ាឥណាទៀតទេ, ព្រោះអកុសលរបស់ខ្ញុំហើយ, អ្នកមើលចុះ ឥឡូវស្តេចស្រីភិរិយាខ្ញុំ ក៏មិនចង់បានជាស្តេចស្រីជូច្នោះទេ, ក៏ចង់ធ្វើជាស្តេចស្រីមកសោយរាជសម្បត្តិ នៅក្នុឥមហាសមុទ្រនេះទិញដើម្បីឲ្យអ្នកបំរើក៏តាមតែក៏នឹកត្រូវការ ។

ត្រីមាសមិនបានពោលពាក្យតបទៅតានេសាទឡើយ ហើយបក់
កន្ទុយ ជាំក្បាលចុះមុជទៅក្នុងសមុទ្រជ្រៅបាត់ទៅ ។ តានេសាទក៏ចេះតែ
នៅរង់ចាំត្រីក្រែងត្រឡប់មកវិញនឹងបានទទួលពាក្យតបជូចត្រាមុនៗ, ឯត្រី
ក៏បាត់មិនឃើញមកវិញសោះ តាចាស់អស់កំឡាំងណាស់ក៏ត្រឡប់មកផ្ទះ
វិញ ។ ម្តងនេះ តានេសាទមិនបានឃើញបេស់អ្វីចំឡែកជូចជាពីកាល
មុនៗឡើយ ត្រឡប់ជាឃើញឯទ្ធមតូចកញ្ចាស់ ហើយឃើញយាយចាស់
ជាកវិយាអង្គុយនៅទៀបចាំងឈើកំបែកជូចកាលមុនវិញ ។

*
* *



កត៌របស់រឿងនេះ

រឿងនេះឯងចែងឲ្យឃើញថាជនណា
មានតណ្ហាក្រាទ្រាំងក្រែមិនចេះស្កប់
ជននោះឯងតែងបានជលផ្តល់ត្រឡប់
ជាទុក្ខលប់លើសកាលមានពីមុននោះ ។
សុភាសិតបុរាណពិតមានពោលទុក
ជាទំនុកថា "លោកពេក រាបែកពោះ"
ជាទាវទបណ្ឌិតជាតិមានសង្ត្រោះ
ហាមដោយស្មោះកុំឲ្យឃើងឡើងភ្ជួចទ្ធ ។

យូរ-អ៊ុន

សុភាសិតប្រដៅ៨ធនប្រុសស្រី

ព្រះយោសធម្ម មុំង.សែស

ចៅអធិការវត្តមហាមន្ត្រី ភ្នំ.៨៣

រៀបរៀង

៣ាកៃ្យប្រដៅស្រី

បទ៣ាកៃ្យ៣

មេះនឹងថ្វាថ្លែងចែងឆន្ទិទាន	*ខ្ញុំខ្ញានប្រុសស្រីក្នុងដីអាយ :*
នៃជនជាតិខ្មែរផងតាំងឡាយ	*ចូរស្តាប់បរិយាយអ្នកច្រាវច្រាប់* ។
ធម្មតាពួកសត្វកើតជាមនុស្ស	*ពោះស្រីពោះប្រុសត្រូវមានឮឮប់*
ប្រដៅវិញ្ញាណមានសណ្តាប់	*ឲ្យដឹងខុសគាប់អាក្រក់ល្អ* ។
ឲ្យស្គាល់លូនីចេះស្គាល់ចាបបុណ្យ	*ស្គាល់គោសស្គាល់គុណនឹងឡៅស*
ស្គាល់ទាបស្គាល់ខ្ពស់ធំមានក្រ	*បង្អាបធ្លីតចំរើនខ្លួន* ។
ជនជាតិកើតមកជាកេរស្រី	*ជាកុមារីមិនខានឆ្ងួន*
គួរវៀនវិជ្ជាគ្រប់ចំនួន	*ឲ្យចានមាំមួនគេញជាស្រី* ។
គួរចេះអក្សរសេរខនពូន្ត	*ដឹងស្រាលដឹងធ្ងន់តិចច្រើនក្តី*
ចេះមើលសាស្ត្រាសំបុត្រអ្វី	*តាំងធម៌ចាលិកិរមើលចាន* ។
ឲ្យចេះសរសេរប្រើការកើត	*ត្រឹមត្រូវល្អឆើតល្មមប្រមាណ*
ពួកជនសាមញ្ញគួរពាប់អាន	*ជាហាន កេរស្រីកបរិជ្ញ* ។
គួរចេះវិជ្ជាដណ្តាំស្ងួ	*ឲ្យស្អាតចាតល្អឆ្ងាញ់ពីសា*

ជាទីគាប់ចិត្តជនានា ជាទីស្នេហាម្ចាយអាពុក ៗ
គួរចេះចាត់ចែងធ្វើចំណី ពិសេសពិសីល្អគ្រប់មុខ
គួរសមប្រឡឹងឆ័ត្រអ្នកស្រុក គួរស៊ីគួរបុកតែត្រង់គ្នា ៗ
គួរចេះធ្វើការត្រឹងស្មៀកតាក់ ចេះដេរស្រែះចាំក់ហួលព្រៃផ្តៅ
ពូកខ្នើយកន្ទេលត្រឹងអាស្នា ក្សរក្សាច់ចនាល្អពីស៊ី ៗ
ត្រូវចេះគួរសមទឹងញាតិមិត្រ ពោះធ្វាយប្តូជិតប្រុសប្តូស្រី
ពោះពស្ត្រប្រជាប្តូមន្ត្រី មានកិច្ចការអ្វីចូរមកឆ្លុះ ៗ
ចូរនាងអើ ពីធ្វើគួរសម លើកដៃប្រណម្យប្តូសំពះ
តាមឋានតាមថ្នាក់ជាមនុស្សប្រាស់ កុំធ្វើមានះឥតសមគួរ ៗ
ចូរនាងអើ ពីដោយសំដី បន្ទោញ្ញរចិត្តលោកអកស្សរ
តាមបៃបតាមបន្ទាប់សំខួរ កុំធ្វើបុកជ្រូជាតិអប្រិយ ៗ
ឲ្យមានបៃបច្បាប់សណ្តាប់ធ្នាប់ មារយាទគួរគាប់កបសិរី
ទើបគេញុបបៀរជាជាតិស្រី ប្រុសឆងគប្តីយកជាគូ ៗ
នាងចំដុសខាត់ត្រិត្យមារយាទ កុំឲ្យឃ្លៀងឃ្លាតច្បាប់ធ្លុះ
ស្រីណាដែលល្អយកវាត្រូវ តាមច្បាប់ក្រែពីបូពណ ៗ
ចូរនាងកុំខូចកាចទឹងប្រមៈ បត់ក្តៅខូចឈ្នោះដាំសន្តាន
អាប់នុះជាគជ័យខាំងខ្លួនប្រាណ គ្មានគេកប់មានជាមគ្គិល ៗ
ចូរនាងរក្សាខ្លួនឲ្យស្អាត ដូចសំពាត់សស្អាតនិម្មល
ឥតមានមន្ទិលប្រឡាក់ដល់ អ្នកផងឃើញឃល់គួរចូលចិត្ត ៗ
បើនាងមានត្រូវត្រឹងកុមល គង់ជាន់ជួបដល់កល្យាណមិត្រ

ជាគូស្វាមីរួមផ្តេកផ្តិត អស់មួយជីវិតឥតសៅហ្មង ។
បើនាងមានប្តីស្វាមីក័ក្តិ ជាគូរួមភ័តាមគន្ធង
ប្រវៃណីច្បាប់ជាគូគ្រង ហៅជាចំណងមួយជីវិត ។
ចូរនាងស្ម័គ្រស្មោះចំពោះត្រង់ កុំវៀចវេរអង្គខ្ជិចកន្ត់ជ្រិត
គប់ប្រុសដូចខែធ្លើជាមិត្រ សហាយស្មន់ជិតជិតជាមខ្លួន ។
ចូរនាងគោរពគោតខ្ចាចប្តី តាមដោយច្បាប់ស្រីល្អសមសួន
ជាស្រីមានលក្ខណ៍ស័ក្តិធំជួន មាំមួនជាស្រីមានពូជពង្ស ។
ច្បាប់ផ្តាប់ប្រតិបត្តិតស្តាខ្លួន ថែថួរឈ្មោសវៃឥតមានល្ងង់
ពេញហៅជាស្រីអ្នកមានវង្ស មានទ្រង់មានទ្រាយល្អឥតគ្នង ។
នាងខំថែទាំផ្ទះសំបែង កន្ទែងលំនៅឲ្យហ្មត់ហ្មង
ទាំងទឹកន្ទែងរួមគូគ្រង តាមដោយគន្ធង់ចាស់បូរាណ ។
ចោសច្រាសឲ្យស្អាតជាធម្មតា នាំតើតច្រាជាក្តីសុខសាន្ត
ទាំងតើតសិរីដល់ខ្លួនជាប្រាណ ចំរើនធនធានដោយសិរី ។
ត្រូវចេះរក្សាទ្រព្យមាសប្រាក់ ខុកជាក់ឲ្យគួនដ៏ជាប្រក្រតី
បំពេញទឹកចិត្តនៃស្វាមី ជាស្រីប្រុសើរគប្បីកុណា ។
ថែទាំសំអាតកន្លែងដែលគ្រោន ទាំងចាំនឹងលាងនូវដែលជា
រៀបចំខុកជាក់ថែរក្សា កុំធ្វើខ្ជិលខ្ជាចោលរាត់រាយ ។
ទាំងភាជនក្រឡរផ្តេកត្រហុក ភាជនត្រក់ភាជនត្រាំកុំមើលងាយ
ទាំងត្រញ៉ាំគាំបិតផងទាំងឡាយ ខ្វល់ខ្វាយថែទាំឲ្យស្អាតបាត ។
ហៅស្រីផ្ទះកណ្តុយត្រហុកខ្លាញ់ ប្រុសគួរស្រឡាញ់យកជាខ្នាត

ជាគួរយោគបមាយោគ មិនឃ្លាតចោលការផ្ទះសំបែង ។
អុងអាងពាងទឹកសម្រាប់ប្រើ ប្រពន្ធអើតើរៀបតាក់តែង
ឲ្យគួរសមមមៀងយកទុកឆ្ងាយ បាត់បែងឲ្យស្អាតកុំស្មោកគ្រោក ។
នាងកុំសំគាល់ត្បាល់អង្រែ កញ្ជើចង្អើរថាខាបថោក
មនុស្សក្នុងដែនដីពិភពលោក អាស្រ័យបរិភោគតែគ្រប់គ្នា ។
បាស់ខ្ចីខ្ចានប្រដៅសព្វ ថាត្រូវសំអប់គួរកោរ្ភ
ថែទាំទុកជាក់កុំឆ្ងល់ឆ្ងា តែខ្លះកាលណាកក្ខីគេ ។
ហៅស្រីគ្មានល័ក្ខណ៍ឥតសណ្តាប់ មិនយកតម្រាប់តាមជាមេ
ទាំងគ្មានត្រែរះតិតគ្មាន់គ្នេរ សំឡឹងមើលគេដុំវិញខ្លួន ។
កន្ទេលកម្រាលខ្នើយពូកត្រាំ បាស់ថ្នូតួចធំគួរតែស្ងួន
ប្រើប្រាស់ថែទាំឲ្យមាំមួន ឲ្យជួនគ្រប់គ្រាន់កុំឲ្យខ្វះ ។
ទាំងស្រមៃអង្គរស្បៀងអាហារ គ្រប់គ្រឿងបរិក្ខារនៅកងផ្ទះ
សំចៃបរិភោគតាមពាក្យចាស់ ប្រើប្រាស់ឲ្យគួរល្មមប្រមាណ ។
ប្រើខ្លះហាលស្រូវចោលទៅដី ឲ្យជាចំណីសត្វតិរច្ឆាន
តីមាន់ទាជ្រកបាបស្រុកបាន អាហារកំសាន្តលេងឆ្កែតោះ ។
ហៅស្រីអប្រិយឥតមារយោគ មិនចេះក្សន្តខ្មាតស្តាយស្រណោះ
មុខជាខ្លះខាតបង់ក្តៅឈ្នោះ មានគ្រោះអត់ឃ្លានទៅថ្ងៃក្រោយ ។
ទាំងបុកអង្គរបម្រុងបាយ ឲ្យកំពប់ខ្ចាយភ្លាត់ពាយពេយ
ខោរបើតិចតួចការថ្នាំះធ្ងាយ បណ្តាយយូរទៅគង់ខាតច្រើន ។
អស់ទាំងកិច្ចការស្មុដណ្តាំ ស្មារតីចងចាំកុំភ្លើតភ្លើន

គួរយើងបន្តយកឬបង្កើន	ចម្រើនតាមមនុស្សនៅប្រក្រតី ។
ស្រីខ្វះដណ្តាំច្រើនហួសខ្នាត	សល់ជាយបង់ខាតពាល់ភក្តី
ស្រីនោះច្រើនខ្វះជាយចំណី	អត់ឃ្លានគប្រុយរឿងពាល់ខ្នាំ ។
ស្រីខ្វះប្រមុំគជាតិសុភ	លេងចៀជាស្ពាមើលរបាំ
ជាតិក្បត់ស្វាមីលួចបញ្ចាំ	បន្ទំលួចជាយលាក់ខឹងប្តី ។
ព្រះពុទ្ធជាគ្រូយើងពាល់គ្នា	ទ្រង់ត្រាស់ទេស្នាបទជាលី
ថាទោសសុភកន្នលោភ័យ	ប្រាំមួយឥតបីមានលើសខ្វះ ។
ទោសមួយនាំឱ្យអស់ទ្រព្យធន	ក្រៅត្រគេពកពន់គ្នានេដះ
ហិនហោចរលីងអស់ពីផ្ទះ	ពន្ធុះគ្មានសល់ក្រដុនជាប ។
ទោសមួយនាំឱ្យកើតជំលោះ	ពោលពាក្យត្រគោះពាក្យថោកគាប
វាយដេរបោះញ្ជោតគ្មានសុភាព	កើតក្តីទោសជាបប្រើនអង្វិយ ។
ទោសមួយនាំឱ្យកើតទិដ្ឋា	គេតិះដៀលថាទាំងប្រុសស្រី
សព្វហានទិសវិនាំងប្រាំបី	ឥតមានសិរីកុងខ្លួនច្រាណ ។
ទោសមួយឱ្យកើតភេតដម្ងី	ទុក្ខព្រួយជាប់ឈឺឥតស្រាកស្រាន្ត
ដេកស្វាប់ដួលស្វាប់គំសឹងមាន	ឥតជាន់ក្បែមក្បាន្តពាល់យប់ថ្ងៃ ។
ធុំក្លិនអសោចដល់គេឯង	ឥតខ្មាសឥតក្រែងអ្នកដទៃ
មមើមមើដូចសត្វព្រៃ	ទបទ្រព្យជាវង្រែដល់កូនចៅ ។
ទោសមួយស្រីនឹងក្តើរផ្តេសផ្តាស	បញ្ជោញក្តើរខ្លាសមកខាងក្រៅ
អាក្រក់ថោកទាបដល់ពូជជៅ	ឱ្យកើតហ្មងសៅញាតិសន្តាន ។
ទោសមួយប្រាជ្ញាតូចថយខ្លាំង	ស្មារតីគាន់តាំងគ្មេចវិញ្ញាណ

ភ្ញៀចកូនប្រពន្ធភ្ញៀចជនជាន ចោលឪ្កាត់ឥតមានដឹងខុសគាប់ ។
យ៉ាងនេះហៅគោសបច្ចុប្បន្ន ប្រាំមួយគ្រប់គ្រាន់ត្រូវតាមច្បាប់
ព្រះពុទ្ធសំដែងថ្លែងប្រាប់ប្រាប់ ឲ្យជនផងស្តាប់ចៀសវាងចេញ ។
រៀបចង់កុំផឹកទឹកស្ពុក ព្រោះថាផឹកហើយគ្មានចំណេញ
មានតែខ្ទះខាតមិនពោរពេញ ក្រខ្យត់ម្ហូមួយថែមទាំងថ្លាប ។
ស្រីខ្ទះជោរស្លេចលួចបន្ទុំ ទ្រព្យគេតូចធំជាដរាប
ស្រីនោះគាក្រក់គ្មានសុភាព ឃោតឆាបពូជពង្សវង្សត្រកូល ។
ស្រីមួយកុហកអួតកូតករ ប្លោកធរប្រវ័ញ្ចគៃបញ្ចូល
ប្លោកប្លាស់ប្រុសត្រើលគៀបមូល យកតាមជាស្តួលយកប្រយោជន៍ ។
ប្រុសណាធោតដោរខ្លៅងងឹត ជ្រួលជ្រួសគំនិតបងំអសោច
ខ្លួចទ្រព្យសម្បត្តិក្រត្រមោច ផ្សារខ្លួចក្តៅចិត្តជាខាងក្រោយ ។
អ្នកមានប្រាជ្ញាគួរពិនិត ប្រែប្រួងគំនិតកុំឲ្យខ្វោយ
ប្រយ័ត្នស្មាដីកុំបណ្តោយ កុំឲ្យថ្នល់ខ្លួនចាញ់ឃោកស្រី ។
ស្រីខ្ទះកៃក្រាស់ដោយតណ្ហា គ្មានឆ្អែតត្រង់ណាដោយប្រក្រតី
គោះសេពតាមគុណកល់កត្រី ឥតបីធុញទ្រាន់ឆ្អែនចិត្តា ។
ចង់ជាន់ចង់មានជនជាន់ខ្លាំង ប្រឆាំងរុកពន់ដល់កស្តា
បង្ខូសបង្ខិចហួសវាសនា បណ្តាលទៅជាឈ្លោះប្រកែក ។
ប្រកាន់ប្រចាន់ប្តីហួសខ្នាត បង្កវិវាទឈ្លោះជាដែក
លាន់ឮសំពុធឡាយផ្សាយពាន់ពេក ស្ទើរបែកត្រកៀកនៃអ្នកស្រុក ។
ដេរប្តីដោយពាក្យជូរអាក្រក់ កខ្វក់គួរខ្ពើមមិនគួរខុក

ជាពាក្យគួរយកជាក់ជាមុខ · នាំឲ្យក្ខុចម្រែជល់អាត្មា ។

ឫទ្ធពាក្យ ៨

នេះនឹងថ្លាថ្លែងវែងនូវនិទាន តាមព្រះទ្រង់ញាណពុទ្ធដីកា
ថាស្រីប្រតិបត្តិដល់តស្ថា មាន ៥ គត់ត្រូវជាមិនលើសខ្លះ ។

សុសំវិហិតកម្មន្តា ស្រីណាចាត់ចែងការនៅកន្លែង
ប្តូរភ្លាត្រូវដោយឥតកាន់មានះ ព្យាយាមមិនមានលះចោលការខ្លួន ។

សង្គហិតបរិជនា ស្រីមានក្តីជ្រះថ្លាសង្គ្រោះមួន
ចំពោះដៃបរិស័ទនឹងចិត្តបួន ឲ្យមានពីពឹងពួនជ្រកកោនបាន ។

សម្ភតំអនុរក្ខិតា ចេះថែរក្សាទ្រព្យដនជាន
ដែលបានទំរឹងប្រែងរកឲ្យមាន កុំឲ្យអន្តរធានវិនាសបង់ ។

យោសាអនតិចារិនី ជនបានជាតិជាស្រីល្អអស់អង្គ
មិនផិតក្បត់ស្វាមីស្រីមានវង្ស មានចិត្តស្លូតស្មោះត្រង់ខឹងប្តីឯង ។

កិប្ចេ ទក្ខា អនាលសា នារីណាឈ្លាសវៃប៉ិនជាក់ស្តែង
គ្មានខ្ជិលច្រអូសទាំងទំរឹងប្រែង ស្ទុះស្ទែងរកផ្គង់ផ្គាប់សព្វការគិច ។
ទំធ្វើចំណីផ្គាប់ស្វាមីភ័ក្តិ មិនឲ្យមានអន់អាក់សូម្បីតិច
ផ្គាប់ទាំងមេជុនពតដោយតស៊ូចិត ជាកិច្ចធម្មតាមនុស្សផែនដី ។

បើនារីណាអាចប្រព្រឹត្តបាន នូវហានទាំងប្រាំនេះដោយគប្បី
នារីនោះទើបបានពេញជាស្រី កើតមង្គលសិរីដល់អាត្មា ។

ហៃអស់នាងនារីផងទាំងឡាយ ចូរស្តាប់បរិយាយច្បាប់នេះណា

ចូរប្រព្រឹត្តត្រង់ត្រាប់ច្បាប់ថ្លៃថ្លា ជាច្បាប់ស្នងតម្រាព្រះធាយ ។
ទឹងបានថ្កើងរុងរឿងក្នុងលោកីយ បានឮនាមឈ្មោះជាស្រីល្អដើតធាយ
កើតរឿងឈ្មោះសំតូពីកេះត្នួងខ្ចោយ ដល់ជំងន់ដឹតធ្វាយសត្វទិសទី ។
ព្រះចោមពង្សទ្រង់មានតុន្នដីកា ប្រកេទកាយដល់នារី
ថាមានចំនួនប្រាំហើយទឹងពីរ តាមច្បាប់មេធាវីតិបុកណា ។

បទុដ្ឋបិត្តាបរវត្តា

នារីណាចិត្តក្រស្តូកក្សត់បំពាន
សេតគប់ប្រុសដទៃស្វាមីមាន រកពន្ធមើលងាយប្តីនៃអង្គា ។
ធ្វើទុក្ខភាំងបុកបុកខ្ញុំថាវ៉ែត្រវ៉ែ វែស្រែក.ហ៊ឺរដេរអំពាវដាក់ឆ្កែសា
ស្រីនោះលោកហៅឈ្មោះវែងកា ជាឈ្មោះតំយោគឆ្នើលោកីយ ។

សាមិកធម្មំ បហាត្តា

នារីណាបំផ្លាញគ្រួសស្វាមី
ដែលខំរកថ្មានមកដោយឃ្មាតខ្មី នាងនោះឈ្មោះចោរតែងយោ ។
ខុកដូចជាចោរលួចប្រក្រតី ជាស្រីអកក្រក់ហួសធម្មតា
ហៅចោរនៅគុដូនៃអង្គា គួរពេងអាកុំសាមគ្គី ។

អលសា ប មហាត្តសា បណ្ឌុទ្ទរត្តវិទិធី

ធីរុសាភិភុយ្យតារី វិត្តធី ឯសា ប អយ្យា ។
ប្រែស្រាយអធិប្បាយបទថ្លៃ សេចក្តីជាខមរកោសា :
ជនជាតិកើតជាស្រីមានតស្តា តៀបក្រាញដូច្នេះឱ្យឆ្លៃគ្រមក់ ។
ស៊ីច្រើនជាយកំច្រើនឥតឈប់ កាចកំប្រើនឥតច្បាប់ពាក្យអាក្រក់
ជាឆ្មាឆ្លៀសលើសប្តីច្រើនកុហក ជាស្រីជួសក់ឡក់រំលើប្តី ។

ស្រីនោះលោកសន្ធតឲ្យឈ្មោះថា អយ្យាកវិយាម្ចាស់ស្វាមី
លើកខ្ជូនឲ្យខ្ពង់ខ្ពស់ហួសជាងប្តី ឥតមានសិរីកីពូរាសនា ។

សទាហិតានុកម្បិនី រក្ខន្ត្ថី បតឹ បុត្តំវិ មាតា
ធនំ សម្ពតំ រក្ខតេសា ឯវិ សា មាតា ច ភរិយា

នារីណាចិត្តថ្វាសត្រ្ទោះប្តី ដោយប្រយោជន៍គប្បីសព្វៗត្រា
ថែទាំស្វាមីខ្ជូនដូចមាតា ថែទាំចាំរក្សាកូនប្រុសស្រី ។
ចេះថែទាំរក្សាទ្រព្យធនធាន ដែលកើតដែលមានរបស់ស្វាមី
ស្រីនោះជាប្រពន្ធកបស្ងស្ត្ថី ត្បូរតប្បីទុកដូចជាមាតា ។

ដេដ្ឋា កនិដ្ឋា ភតិនី សាមិកេ ឬ សគារវា
ហិរិមនា ភត្ត្ថុ វិសគា ឯវិ សា ភតិនី ច ភរិយា ។

នារីណាគោរពគ្នោះស្វាមី ដូចស្រីជាបងប្អូនរួមដ្ឋគ្នា
ចិត្តអៀនខ្មាសអស់ជនធងងធម្ងតា លុះក្នុងនាអំណាចនៃស្វាមី ។
នារីនោះលោកហៅថាកវិយា ដូចគ្នានឹងបងនឹងប្អូនស្រី
ពោះមួយបង្កើតគ្នាក្នុងលោកីយ ជាស្រីតាប់ប្រសើរត្បូរផ្រះថ្ថា ។

ទិស្ធាន បតឹ មោទន្ត្ថី សទំ សទីវិ សុមនា
សីលវិតិ បតិព្ធតា ឯវិ សា សទី ច ភរិយា ។

នារីណាយើញប្តីមកពីឆ្ងាយ ចិត្តរីករាយសប្បាយមហិមា
ត្រេកអរដូចសំឡាញ់យើញគ្នីគ្នា ស្ទុះស្ទារកបាយទឹកនំចំណី ។

កថាសិលរៀបរយេនឹងគាយក់ថា ប្រតិបត្តិតស្តាដោយមេត្រី
គោតក្រែងរំអែងដោយប្រក្រតី ហៅស្រីកំយោឈ្មោះសង្ខ ។

យោ វិធទណ្ឌតដ្ឋិតា អទុដ្ឋ អកុទ្ធា សត្តិ
ភត្តុវិសាសុវិត្តិនី ឯវំ សាទាសី ប ភរិយា ។

ជនជាតិណាកើតមកជាន់ជាស្រី មានគួស្វាមីគួរគាប់ចិត្តា
ទោះប៉ប្តីដេរក៏យកគ្រាមថា មានចិត្តអត់ក្រោធាមិនឱនតប ។
ប្រព្រឹត្តតាមអំណាចនៃតស្តា ឥតមានខ្ជិលច្រអូសឥតរបប
ហៅស្រីជាប្រពន្ធដើរក្នុងស្រុប ប្រកបដូចខ្ញុំស្រីតបសុចរិត ។
ស្រីនោះលោកអ្នកធ្រាជសន្ទតឋា ពាសីតរិយាទី ៧ ពិត
ប្រពន្ធដូចខ្ញុំស្រីដ៏ពិសិដ្ឋ រាប់កាលមួយជំតែរៀនពាល់ខ្លួន ។
ហៃមនុស្សនាងនាគ្រែប់ក្នាក់ជាន់ ចូរនាងស្រួលពន់ស្តាប់ឱ្យមាំមួន
ខ្លួនប្លាប់កំយោ ៧ ជួន ឱ្យចេះម៉ាវៀងខ្លួនប្រព្រឹត្តតាម ។
ត្រង់ណាដែលល្អនាងយកត្រង់ទុំ ត្រង់ណាដែលខូចខុសនាងចោលភ្លាម
ប្រតិបត្តិត្រង់ត្រូវកុំឆ្ងីមឆ្ងាម ខឹងបានបុខស្រួលតាមតួដីកា ។
សត្វកើតជាមនុស្សភាគច្រើនស្រី តែមានប្រពន្ធប្តីគ្រប់ៗ គ្នា
ខ្លះបានសុខខ្លួនបានទុក្ខវេទនា តាមហេតុកេរអាគ្នាធ្វើខានដើម ។
ធម្មតាជាស្រីមានមាយា កុត្តា(១)ឧឆ័ល្ហ(២)ច្រើនសម្បើម
ពាប់បានសែសិបតត់ធ្រាជគួរខ្លើម ពាលមានតែជរាធ្មើមប្លុងចិត្តពេក ។

១- កុត្តា-សព្ទ ប្រែថា ឆៀងដោយវត្ថុមានជង្គង់ជាដើម នៃស្រី។
២- ឧឆ័ល្ហ-សព្ទ ប្រែថា លំនាំយោងយាសញ្ជាញ្ជើ ក្អិកក្អាត់ ដោយងងឹលេងក្តួយនៃស្រី។

១.-អ្នកប្រទៃពីរ ពីត្តី ឆម្ងល់ជាស្រីមានតម្រេក
ដោយតាមពាក្យច្រើនពន់អនេក ពោលពាក្យដោយចិត្តត្រេកអៀនចិត្តី។
ពោលតាក្យច្រើនជ្រុលជ្រួសហួសប្រមាណ ខាំប្តីឱ្យរំខានពាល់ពាក្រ
ជួនកាលអង្គុយដំណឹងស្វាមី បញ្ជោញទឹមិត្តស្រីឱ្យអ្នកផង ។

២. វិធីប្តី មាតុគាមោ ស្រីប្រពន្ធសេះខ្លាឈ្លក់ឥតហ្មង
បញ្ជោញមិត្តតាត់ការយចិត្តបំណង ឱ្យប្រុសក្រែកអន្ទងចងចិត្តជាប់ ។

៣.-វិធម្មតិ ស្រីមច្ឆិនី ឆម្ងល់ជាស្រីប្រុសគួរគាប់
ចង់ឱ្យប្រុសយើញខ្លួនឥតរើរេទ្រឹត្យ មាយាសាំលាប់ជាប់ចំខ្មៅ ។

៤.-វិលាសតិ បិ អង្គិនា នារីប្រុសសាកតុំសួរប់ស្រៀម
កែក្រាយប្រពន្ធតាយឱ្យជាតរៀម ឱ្យប្រុសតឹតត្រុំក្រៀមចិត្តស្រឡាញ់ ។

៥.-វិលជ្ជិតិ ប វិនិតា នារីតុតមាយាខ្លួនហ្មងខ្មាញ់
ធ្វើដូចខ្លាសេតណាស់ស្មុសស្មាហ្ម ឃ្មុតខ្មាញ់ឃុកសំពត់ប៉ិចប៉ាំនខ្លួន ។
ស្មុះទៅរកតៀនភ្លាមប្តូរដណ្តើន ដោយសេចក្តីភ្លុះសព្វាំងដើម្បីពួន
ឱ្យគេដឹងជាស្រីមានភ្លុះប្តូរ លក់ខ្លួនដោយកិច្ចកលតុតមាយា ។

៦. ឆនេន ឆុំ ឃ្យជ្ជិតិ នារីឥតហ៊ានប្រុសសាកា
ផ្តាត់ក្រពតដោយគិតថា ឱ្យតាយើញតាក្នុងចិត្តភ្លាម ។

៧.- បាទិ អក្កមតិ កន្តា នារីក្រែតណ្តាក្រមតម្រាម
យកដើនជាន់លើដើនដោយចេញាយាម ចង់ឱ្យប្រុសភាក់ពាមដោយតណ្ហា ។

ក្នុងលោកច្រើនដាំដោះដាយតំរេក ត្រអាលច្រើនពន់ពេកដោយស្នេហា
បានជានារីច្រើនចេញមាយា ឲ្យប្រុសយើញអាស្នាចិត្តជាប់តាម ។

๘.-បរិវិលិខិតិ បឹ ជនជាតិកើតជាស្រីធ្វើព្យាយាម
យកឈើគូសដែនដីស្នាមរៀម បំណងទាតុត្រាមឲ្យប្រុសមើល ។

๙.-ខុលង្ឆៃតិ បិអពលា នារីធ្វើមាយាឲ្យប្រុសឆ្គើល
ចាប់ក្មេងតូចលើកខ្ពស់ឲ្យប្រុសព្រើល សំម្លឹងយើញខ្លួនថ្កើលតើលគំនិត ។

๑๐. ខុលង្ឆៃតិវា សុន្ទរី មាតុត្រាមជាទីស្នេហាពិត
ចាប់ក្មេងតូចលើកខ្ពស់ចាប់ដិត ឲ្យប្រុសយើញជាប់ជិតចិត្តត្រេកអរ ។

๑๑.-ទារកំ កីឡតិ រង្គេ ជាតិស្រីជាវិញ្ញូបូមវរ
ប្រៀនទឹងគារកដោយអំណរ បីត្រកងដើរឈរលេងតំណាន ។

๑๒.-កីឡាបេតិ បនកន្តា ញុំាងគារកឲ្យគ្រាប់ក្បែរដួងចិត្ត
ស្រែកយកសម្បាយដោយចិត្តភាព ឲ្យបំរើតួអាយបានជាន់ធំឡើង ។

๑๓.-ទារកំ ឬម្ពតិ នារី ដើរគារកញាក់ញីតាមចំនើង
ចំនៀមចៃបបរស្រីដែលថ្នុំថ្នើង ប្តេជ្ញាគាបស្មើដើងសឹងជួបគ្នា ។

๑๔.-ទារកំ ឬម្ពេរបតិ បឹ ញុំាងគារកឲ្យមើបមុខបរិញ្ញា
ខ្លួនថ្នាល់ឬមុខខ្លួនដោយស្នេហា ស្ងួនទ្រាស្ងាលមេរៀនមិនដឹមខ្លួន ។

๑๕.-ភុញ្ជតិ បន មហិហៅ ស៊ីបុកចំណីជាដោយតំណាន
ឥតមានពេលវេលាឥតស្រាកស្រាន្ត ខ្ជិះខ្ជាប់តែកឥតមានត្តិះរៀនខ្មាស ។

๑๖.-ภุญฺเชยฺเยติ ปิ กามิตึ ญาตึ ตึ ภาเรกฺขฺเยสุ ปิ ตฺวณฺ ฐาเส

ฐปฺเปตฺวา ปน ปาเรนฺโต ปาเรติ นาม ๗

๑๗.-ทุฏฺฐาติ อปิ ปมชฺชา ตึ ตึ ภาเรกฺขฺเยสุ ปิ ตฺวณฺ ฐาเส

ฐปฺเปตฺวา ปน ปาเรนฺโต ปาเรติ นาม ๗

๑๘.-อายาปตึ วิ อฺญาย ยฺเวเส ปาเรนฺเต ปาเรติ นาม

ตสฺมา ตาทิเสน ภิกฺขุนา ๗

๑๙.-กถมนฺตโรติ ปิ ตึ ตึ ภาเรกฺขฺเยสุ ปิ ตฺวณฺ ฐาเส

ฐปฺเปตฺวา ปน ปาเรนฺโต ปาเรติ นาม ๗

๒๐. ทุปฺปิ ภาสตึ ยมณึ ตึ ตึ ภาเรกฺขฺเยสุ ปิ ตฺวณฺ ฐาเส

ฐปฺเปตฺวา ปน ปาเรนฺโต ปาเรติ นาม ๗

๒๑.-ธีปิ ภาสตึ ทฺยิตา ตึ ตึ ภาเรกฺขฺเยสุ ปิ ตฺวณฺ ฐาเส

ฐปฺเปตฺวา ปน ปาเรนฺโต ปาเรติ นาม ๗

๒๒.-อาวุปิ ภาสตึ กฺฐา ตึ ตึ ภาเรกฺขฺเยสุ ปิ ตฺวณฺ ฐาเส

ฐปฺเปตฺวา ปน ปาเรนฺโต ปาเรติ นาม ๗

๒๓.-วีปิ ภาสตึ ติตฺถึ ตึ ตึ ภาเรกฺขฺเยสุ ปิ ตฺวณฺ ฐาเส

ฐปฺเปตฺวา ปน ปาเรนฺโต ปาเรติ นาม ๗

๒๔.-ฉปฺปิ ทิสา ชิกฺขตึ ปิ ตึ ตึ ภาเรกฺขฺเยสุ ปิ ตฺวณฺ ฐาเส

ฐปฺเปตฺวา ปน ปาเรนฺโต ปาเรติ นาม ๗

ជួនកាលភៀងជាសើចគ្រោះការយំ អ្នកមានខុសក្រៀមក្រំខប់ពុំបាន
ជួនកាលសើចដោះចេតាយោងយាសប្រាណ គេស្អិតស្អាងគរយប្ញាន់
សើចដែរ ។

២៥.-ប្រែក្ដីបសិមន្ធិនី ក្រឡេកមើលការអ្វីតំប្រឹនមែរ
ធ្វើកែតាមារយាខប៉ងបន្ទែរ ចាញ់ចិត្តប្រុសឲ្យរេរកបន្ទុន ។
២៦.-កំដីបាលេតិភីរុក ស្រីបះញ្ជូញមាយាដោយមាំមួន
កំរើកវេចន្លើះដោយចិត្តគួន ឲ្យប្រុសកើតក្តីសួនបាប់ចិត្តខ្ញាំង ។
២៧. គុយ្ហភណ្ឌំបាលេតិបី ញាំងអង្គជាតស្រីគួរលាត់ប៉ាំង
ឲ្យកក្រើកអំពើតញាក់ភ្ញាំគោំង ពេះប៉ជាកំប៉ាំងកំតង់ធ្វើ ។
២៨.-ខុរុំ រីរតិ កត្តា ស្រីបើកភ្លៅអាត្មាជាអំពី
ឲ្យប្រុសយើញតក់ស្លុតខ្លន់ភ្លើ សើរើបែរមើលស្លឹតែភ្លេចខ្លួន ។
២៩.-ខុរុំ បិទបតិ រិច្ឆ បើកលាត់ទូ.ទ្ធ(១)ដោយគិតគួន
ត្រឡប់ចិត្តភ្លៅញាដោយចៃដន្ទ ហាក់ដូចជាភ្ញាសមួនមាំដាំងគេ ។
៣០.-បិនំ ទុសេត្រតិ លលនា បើកបៃយះដោះអាត្មាកំលេខខេ
បង្ហាញឲ្យប្រុសយើញតិតិះរេ ឲ្យកើតសេចក្តីស្នេហ៍ត្រកត្រអាល ។
៣១.-កប្ប៉ិ ទុសេត្រតិ កាមិនី បង្ហាញខ្លៀតជាខ្លែតស្រីបស្រាល
ដល់ជនប្រុសដទៃជាជនពាល កើតក្តីក្តៅពេលកាលដោយឆន្ទា ។

(១)ប្រែថា ភ្លៅ ។

សាសនាឥស្លាមនឹងសាសនាគាតូលិក

ណោកទ្រៀង.តៃឈុន ក្រមការដើមវ្យេលេ ១

ប្រែរៀបរៀង

សាសនាឥស្លាម

សាសនាអ៊ីស្លាមបានជ្រាបចូលទៅក្នុងប្រទេសឥណ្ឌៀនៅចុងសតវត្សទី ១២ ; ដល់មកដើមឆ្នាំនៃសតវត្សទី ១៣ សាសនានេះបានជ្រាបចូលទៅក្នុងប្រទេសផ្ទា ហើយតពីនោះមកទៀតបានផ្សាយចូលមកក្នុងប្រទេសឥណ្ឌូចិន ។ ប្រជាជនចាមនៃប្រទេសចម្សា (អាណាចក្រដែលស្ថិតនៅដែនដីប្រទេសអណ្ណាមសព្វថ្ងៃនេះ) តាំងពីដើមរហូតមកដល់សម័យនោះបានកាន់សាសនាព្រាហ្មណ៍រៀងដរាបមក ក្នុងពេលដែលសាសនាព្រះពុទ្ធកំពុងមានកំឡាំងយ៉ាងខ្លាំង ; ប្រជាជនចាមបានផ្ទាស់ចោលសាសនាព្រាហ្មណ៍មកកាន់សាសនាអ៊ីស្លាមនៅក្នុងសតវត្សទី ១៥ ហើយដោយកំឡាំងអានុភាពនៃជំនឿថ្មីរបស់ខ្លួន, ចាមអាចហ៊ានទប់ទល់នូវការលុកចូលរបស់យួន ។ ដនជាតិយួនកាលបានផ្ទៃនៅសកម្មដល់អាណាចក្រចាមហើយ ក៏បែងចែកប្រទេសនេះជារដ្ឋតូច ៗ ដាក់ជាចំណុះខ្លួន ។ រីឯចាមទាំងឡាយដែលកាន់សាសនាអ៊ីស្លាមបានប្រមូលគ្នាជាកងសំខាន់ខ្លះមិនសំខាន់ខ្លះ ភៀសខ្លួនមកជ្រកក្នុងប្រទេសកម្ពុជា ។

នៅក្នុងប្រទេសខ្មែរនេះ កំឡាំងចាមខាងផ្លូវសាសនាហៀបតែនឹងឡើងរុងរឿងក្នុងមួយពេលយ៉ាងខ្លី ។ ផ្ទុយក្នុងសតវត្សទី ១៧, ព្រះមហាក្សត្រខ្មែរព្រះនាមអង្គចន្ទ ដែលសោយរាជសម្បត្តិពី គ.ស. ១៦៤២ ទៅ

ត.ស. ១៦៥៨ បានយកស្ត្រីជ្វាធ្វើជាព្រះជាយា ហើយដើម្បីសម្តែងសេចក្តីស្មោះស្ម័ត្រចំពោះចាមនឹងជ្វាដែលបានជួយខ្នះខ្នែងព្រះអង្គឲ្យដណ្តើមយកបានរាជសម្បត្តិ ព្រមទាំងជួយទប់ទល់ឲ្យមានជ័យជំនះនូវការរុករានរបស់ជនជាតិហុល្ទង់ដេស៍នៃសមាគមដែលស្ថិតនៅក្នុងប្រទេសឥណ្ឌូនាងទិសបូព៌, ព្រះអង្គបានសព្វព្រះរាជហប្ចទ័យឲ្យធ្វើពីធីកាត់ស្បែកព្រះសិទ្ធិលិង្ត ។ នៅពេលនោះ ព្រះអង្គបានប្រកាសថែមទៀតថាព្រះអង្គចូលសាសនាមហាមាត់ហើយ ព្រមទាំងទទួលយកនាមជា "ព្រះអ៊ីប្រាហ៊ីម" ផង ។ ប៉ុន្តែប្រជាកស្ត្រីខ្មែរមិនតាមព្រះអង្គទេ ហើយឲ្យឈ្មោះព្រះអង្គជាស្តេចក្រៅពុទ្ធសាសនា ។

ចាមសព្វថ្ងៃមានសញ្ញាតិជាខ្មែរ ហើយមានសិទ្ធិជាពលរដ្ឋ នឹងសិទ្ធិទាងធ្វើនយោបាយជូចជាខ្មែរសុទ្ធសាធ ។ ប៉ុន្តែជនជាតិនេះនៅតែកាន់សាសនាអ៊ីស្លាមដដែល ហើយឈ្ងក់ចិត្តសិប់នឹងជំនឿរបស់ខ្លួនខ្ចាំងណាស់ ។

អាចារ្យចាម (ម៉ាំរ៉ាប៉ូត៍= Marabouts):

ចាមហៅអាចារ្យ របស់ខ្លួនថា "ម៉ាំរ៉ាប៉ូត៍" ។ អាចារ្យអាចាមនេះឯងខ្មែរយើងសំគាល់ថាជាអ្នកមានចំណេះវិជ្ជាទាងទេពសាស្ត្រ ហើយជាអ្នកជំនួយព្រះសង្ឆចាមក្នុងពិធីសាសនាខ្លះ ។ អាចារ្យចាមស្ទៀកពាក់សហើយគោរសក់ក្សាលព្រមទាំងពាក់កន្ទឹបសផង ។ នៅថ្ងៃបុណ្យអាចារ្យចាមមានរុំព័ទ្ធឈ្នួតក្សាលធំមួយលើកន្ទឹបនោះថែមទៀត ។ នៅថ្ងៃសុក្រពួកទ្ធបាសកចាមណាដែលធ្លាប់បានធ្វើដំណើរទៅឯទីក្រុង "មេចក៍" ក៏

មានពាក់ឈ្នួតក្បាលសំដែរ ដើម្បីទៅព្រះវិហារ ។ ឯឈ្នួតក្បាលនេះ ជួនណាគេតុបតែងលំអដោយចាក់ខ្សែមាស ។

ពួក "ម៉ាក់ប៊ូត" គឺគាថារួចមកខាងនេះ តាមជម្មតាច្រើនជាសន្តតិវង្ស អំពីត្រួសារជ្វាដែលចេញចាកស្រុកបេស់ខ្លួន មកតាំងនៅប្រទេសកម្ពុជា ក្នុងសតវត្សទី ១៥ ឧធ ១៦ ។ ពួកនេះបានបង្កើតវណ្ណៈខ្ពង់ខ្ពស់ខាងសាសនាដោយឡែក ។ ក្នុងត្រួសារនោះគួនស្រីក៏កាន់សាសនាដែរ ហើយក្នុងចំណោមស្រីនេះគឺពួក «ម៉ាក់ប៊ូត» ជ្រើសរើសយកធ្វើជាភរិយារបស់ខ្លួន ។

ព្រះមហាក្សត្រនៃប្រទេសកម្ពុជាបានតែងតាំងចាមដែលកាន់សាសនាអ៊ីស្លាមបួននាក់ឲ្យធ្វើជាមេគ ។ ប្រជាខ្លះតំណាងក្នុងចំណោមអ្នកកាន់សាសនាដូចគ្នា ដូចជាមគ្គុសាវ័កបួនរូបដែលត្រូវមហាម៉ាត់ជាន តែងតាំងនោះដែរ, ប៉ុន្តែមិនអាចកាន់អំណាចន យ៉ាចុយជាមួយនឹងការណ៍យកចិត្តទាំងសាសនា ដូចជាអគ្គសាវ័កដំបូងនៃព្រះមហាម៉ាត់នោះទេ ។ មានវដ្ដលេខាធិការមួយរូបដែលជាកូនឈ្មួញជាវដ្ដមន្ត្រីក្រសួងធម្មការខ្លួលការៈដោយឡែកខាងកិច្ចការនៃអ្នកកាន់សាសនាអ៊ីស្លាម ។

• ចាសកល្អ មុខនឹងស្លាប់ ធ្វើយសារគោតខ្លួលចាបកម្មដែលខ្លួនបានប្រព្រឹត្តទាំងប៉ុន្មានដោយឯកច្ឆន្ទដោយអំពើផ្សេង ។ ហើយបើប្រសិនជាពេលនោះគាចលុបលាងនូវបាបនោះបាន ក៏លុបលាងវា ។ តាលបើត្រូវធ្វើទេ, ដង្វិលវត្ថុ ឬ សន្ទំណុលចំពោះជនទាំងឡាយដែលចាត់ចង់ទៅហើយនោះ, ត្រូវធ្វើកិច្ចទាំងនេះចំពោះអ្នកដែលមាន

សិទ្ធិខ្ពស់មកតែពីជនជាតិ, ហើយបើឥតអំពីកូនចៅនោះទៅទៀត ត្រូវធ្លើទាទោស, ចង្វិលវិញ ឬ សងចំណុលនោះចំពោះអាចារ្យដែលជាអ្នកខ្ពស់សូត្រធម៌ជំនួសម្ចាស់បំណុល ឬ ម្ចាស់វិញ ដើម្បីទុកសំរាប់ទៀ អ្នកដែលស្លាប់ទៅហើយ ។

សាសនាគ្រូលិក

ក) ចារឹកនៅស្រុកពញាឮ :

វិហារគ្រូលិកបានកើតជាដំបូងនៅប្រទេសកម្ពុជាក្នុង គ. ស. ១៥៨៥ ។ គេបានសាងវិហារនោះនៅក្នុងស្រុកពញាឮជិតស្រុកឧដុង្គ ហើយយូរមកទៀតវិហារនេះផ្លាស់ទៅជាមន្ទីរចាត់ការនៃអេវេគជ្ជន ។

ក្នុងរាជ្ជាភិសេកដ៏មហានៃសម្តេចព្រះ ន ព្រះមហាក្សត្រខ្មែរ បានជួយឧបត្ថម្ភដោយសប្បុរសធម៌ ខិតខំដោយមេត្តាចិត្ត ចំពោះបេសកជនជាតិបារាំងពីរនាក់ឡាយ ដែលបានមកផ្សាយនូវពាក្យប្រៀនប្រដៅរបស់ព្រះអាទិទេព ក្នុងប្រទេសកម្ពុជា, សិលាចារឹកឈ្មោះបេសកជនពីរនាក់នេះជាអនុស្សាវរីយ៍ហួតមកដល់សព្វថ្ងៃនេះ នៅលើបេតិយមួយក្នុងបរិវេណវត្តដ៏ធំដែលនៅខាងមុខវិហារគ្រូលិកក្នុងស្រុកពញាឮ ។ អក្សរចារឹកនេះមើលទៅគួរឲ្យរំភើបចិត្តយ៉ាងក្រៃលែង ក្នុងការស្តាប់នាដំបូងជាសាមញ្ញ ។ ក្នុងចន្លោះពីខាងមុខបេតិយនេះ គេឃើញមានព្រះពុទ្ធបដិមាជាច្រើននៅលើកំពូលក្នុងស្រុកឧដុង្គ ។

ពួកបាទីរ៍នៃសាសនាគ្រីស្តនៅស្រុកពញាឮកាលពីគ.ស.១៨៦៦

បានរងទុក្ខវេទនាជាយ៉ាងខ្លាំង អំពីការប្រព្រឹត្តិរបស់ក្រុមបះបោរដែលកើត មានឡើងក្រោមការដឹកនាំរបស់ពោកំបោ ។ នេះក្លែងខ្ជូនជាព្រះរាជនត្តានៃ ព្រះបាទអង្គចន្ទ ។ ដោយហេតុនេះហើយបានជាមន្ទីរបាត់ការនៃអេវេត-ដ្ឋាននៅប្រទេសកម្ពុជា ត្រូវគេរើយកមកសង់នៅទីក្រុងភ្នំពេញ ដែលជារាជធានីព្រះរាជអាណាចក្រ ។ អេវេតដ្ឋាននេះនៅជាប់រហូតមកដល់សព្វថ្ងៃនេះ ។

១) ភូមិកាតូលិក:

ពិតមែនតែសាសនាកាតូលិកបានបោះគោលនៅប្រទេសកម្ពុជា ប្រហែលជិតបួនសតវត្សមកហើយ, ពិតមែនតែអ្នកកាន់សាសនាកាតូលិក បានរុងរឿងនឹងលេចស្ពែងជាងគេជាប្រើនលើកប្រើនគ្រា (រាប់តែក្នុងចំណោមអ្នកដែលមានចិត្តស្មោះត្រង់ជាងគេ នៅក្នុងព្រះអាណាចក្រហើយ នឹងអ្នកដែលមានភក្តីជាងគេចំពោះស្តេច ត្រឹមត្រូវតាមច្បាប់ទាំងឡាយនៃ ព្រះរាជអាណាចក្រ) ពិតមែនតែទីបំផុត នៅក្នុងលំដាប់សក្តិមានរាប់បញ្ចូលនូវមនុស្សដែលមានបញ្ញា យ៉ាងខ្ពង់ខ្ពស់ក្រៃលែងដូចជា "មុងសេញ៉ូរពីញ៉ូដឺបេអែន" (Mgr Figneau de Béhaine) នឹង "មុងសេញ៉ូរមិស" (Mgr Miche) ឬ "មុងសេញ៉ូរអែរតុត៍ត (Mgr Hergott) នឹង "មុងសេញ៉ូរសាបាលីយេ" Mgr Chabaliér) ជាអេវេតចុងក្រោយទាំងពីរនៃប្រទេសកម្ពុជា ដែលមានចិត្តសប្បុរសប្រកបដោយសេចក្តីស្ងប់ស្ងាត់ យ៉ាងកម្ររកបាន, ប៉ុន្តែសាសនាកាតូលិកនៅប្រទេសកម្ពុជានៅតែមានឧបាសក

យ៉ាងស្តួចស្តើង តែមានប្រហែលប្រាំម៉ឺននាក់ ក្នុងចំណោមមនុស្ស ប្រហែលបួនលាននាក់ ។

ក្នុងរឿងនេះ គេមិនអាចទម្លាក់ភ្លេចលើអមិត្តភាពណាមួយនៃព្រះមហាក្សត្រីនីប្រជាជនឡើយ ។ ព្រះមហាក្សត្រីតែងតែជួយការពារបេសកជនគ្រប់ពេលហើយបានសម្តែងនូវសេចក្តីពិបាកចិត្តនឹងមិត្តភាពដែលជាតិស្តុតាងយ៉ាងខ្ជិលច្រអូសបំផុតដល់អ្នកនៅតំបន់នោះ ។ នៅឧបាសបុណ្យសព "មុនីសេញ៉ីសោចាលីយ" ក្នុងឆ្នាំ ១៩៥៩, សមាជិកគ្រួសារអស់នៃពន្លឺកំចាលខ្មែរបានអញ្ជើញទៅបម្រុងក្នុងពិធីបុណ្យនោះ ហើយក្រុមការងារក្សាព្រះអង្គបានធ្វើតាមកិច្ចនៅវេលានោះ ។ ក្រោយចម្បាំងសាកលលោកលើកទី២, ព្រះចៅខេត្តមរីហនុទ្រង់មានព្រះពុទ្ធហឫទ័យកែកយជាក្រែលែង ព្រោះព្រះអង្គបានឧតឃើញវិសាលភាពនៃវិហារមួយខ្នង ដែលគេសង់ឡើងនៅក្នុងសង្កាត់យ៉ាងល្អបំផុតនៅក្រុងភ្នំពេញដោយអស្រ័យជំនួយហិរញ្ញវត្ថុពីពុទ្ធការបាំងសែស ។

គឺនៅក្នុងរជ្ជកាលព្រះអង្គដែរ ដែលអាស្រមជួនដីមួយខាងសាសនាបានស្ថាបនាហើយនៅប្រទេសកម្ពុជា ក្នុងដំបន់ជិតខ្សែត្រកំពត គឺកែប ។ អាស្រមជួនដីនេះជាប់ពាក់ព័ន្ធខាងផ្លូវសាសនានឹងវត្ត "ពីយែរ តឺ រ៉ៀ" (pierre-Qui-Vire) ដែលស្ថិតនៅក្នុងខែត្រ "យោន" (Yonne) ។

ខែត្រកំពូលភ្នំដែលមានដើមកំណើតពីភូមិភាគភ្នំមួយចាំងឡាយនៅតញ្ញាឮ, ភ្នំពេញ, កំពង់ធំ, ចាត់ដំបង, ចុំណុំ, ក្រូចឆ្មា (ភូមិភាគភ្នំចាំងអស់ដែលមានសភាពជាភូមិខ្មែរហើយដែលសូត្រធម៌ក៏ជាខ្មែរ) មាន

ភាគច្រើន តែបណ្តាកូនចៅនៃជនជាតិអេស្បាញ៉ុលទើបតែរុះរយគេស៊ែ ដែលចូលមកប្រទេសកម្ពុជាក្នុងសតវត្សទី ១៦ ហើយបច្ចុប្បន្នមានលើចំនួនជនជាតិនេះ មានបណ្តាកូនចៅនៃជនជាតិហ្វីលីពីនទៅម៉ាទិល ដែលព្រះបាទនរោត្តមទ្រង់បានហៅឲ្យមកធ្វើជាក្រុមក្មេងរបស់ព្រះអង្គ ។

ប៉ុន្តែបាសកភាគច្រើនសុទ្ធតែយួនទើបចិន ។ ព្រះសង្ឃ, ដូនជីទើបអ្នកចេះក្នុងសាសនាគ្រឹស្ត ច្រើនតែយួន ជាអ្នកខ្វះសារៈខាងសាសន.សិក្សាធិការជាភាសាយួន នៅក្នុងភូមិភាគតូលិកនៃជនបទទើបក្រៃដែលចំណុះខ្លួន ។ រឿងនេះជាការចាំបាច់ តែមិនអាចចៀសវាងពីផលអាក្រក់បានទេ ព្រោះនាំឲ្យប្រជាការនៃប្រជារាស្ត្រខ្មែរឃ្លាតឆ្ងាយទៅ។ ពីប្រជាជនភាគតិចនេះដែលធម្មតាមិនសូវបានទទួលនូវការរាប់អានពីខ្មែរ ។ គេតែងតែប្រៀបធៀបថាអ្នកកាន់សាសនាកាតូលិក គឺយួនទើបចិន ។ យួនទើបចិនគឺភ្ជាប់ងារយៀកមិញ (កុម្មុយនិស្ត) ឬអ្នកបំបែនប្រសបខាងបន្ទិលប្រាក់យកចំណេញ ។

មានអ្នកសិក្សាសាលាជាតិខ្មែរសុទ្ធតែរឹបបីនាក់ បានទៅធ្វើការសិក្សាជាន់ខ្ពស់សព្វថ្ងៃនៅប្រទេសបារាំង ។ ដល់ត្រឡប់មកស្រុកកំណើតវិញ, ពួកទាំងនេះទើបតែជាព្រះសង្ឃជាតិមួយក្រុម ដែលគេត្រូវសង្ឃឹមថាទើបមានអ្នកដែលខ្មែរម្នាក់ចេញពីក្រុមនោះបានឆាប់ ។ នេះហើយជាការបារម្ភរបស់មុនីសេញ៉ីសាបាលីយេមុនទើបស្លាប់ ។

យើងគ្មានមន្ទិលសង្ស័យថាមហាមេឃមិនបំភ្លេចបំណងមុនីសេញ៉ីសាបាលីយេឡើយ ។

លោក សុិន - ហ៊ាន ប្រែរៀបរៀង
លោក យូរ. អ៊ុន ពិនិត្យកែសម្រួល

(តមក)

សម័យមួយ ព្រះកជាទ្រង់មានបំណងនឹងធ្វើមកុដឲ្យវិចិត្រជាយ
ការប្រជាប់ត្បូងតេជ្រឡើងវិញ ទើបឲ្យជាងកងសំណាក់ព្រះអគ្គីមកជាំ
តេជ្រ ។ ខណៈដែលជាងកំពុងធ្វើមកុដនោះចំពោះព្រះភ័ក្ត្រ, ស្វាចិញ្ចឹម
មួយរបស់ព្រះអគ្គីដែលទ្រង់ទ្រាប់ច្រោសច្រាណ ក៏ជាសត្វដែលចេះស្តាប់
ការមនុស្សច្រាន ជាគេដេរប្តូរសេរីរប្តូនឹងហៅឲ្យក៏ធ្វើអ្វី ។ ច្រានច្រែន
យ៉ាំង ព្រះអគ្គីមិនទាំងក៏ពុកដួចស្វាដទៃទេ ។ ស្វានោះចូលមកកក
ព្រះអគ្គី ព្រះកជាទ្រង់ចាប់ស្វាបអង្អែលក្បាលក៏ដោយព្រះទ័យមេត្តា ។
ខណៈនោះ ស្វាឃើញជាងធ្វើមកុដយកត្បូងតេជ្រថ្មី មកជាំនៅត្រង់
កន្ទែងត្បូងមួយគ្រាប់ដែលជ្រុះចាត់ពីពេលមុន ក៏តត់ចេញពីទីនោះទៅ ។
ព្រះកជាទ្រង់ឧតព្រះនេត្រឃើញអាការដ៏រឿងរៃរបស់ពាក៏ទ្រង់ព្រះសម្រួល។
មួយស្របក់ ស្វានោះតត់ត្រឡប់មកកេព្រះអគ្គីវិញ ហើយជាក់តេជ្រ ១
គ្រាប់ចុះនៅលើគ្នារចំពោះព្រះភ័ក្ត្រព្រះកជា ។ ទ្រង់ថ្លែកព្រះទ័យចាប់
តេជ្រនោះឡើងមកពិនិត្យមើល ព្រះអគ្គីក៏ជ្រាក់ព្រះទ័យ តង់ស្មៀមមិន
មានបន្ទូលអ្វីសោះ ។

ព្រះកជាទ្រង់ដឹងហេតុការណ៍សព្វគ្រប់ ហើយនឹកដល់ពាក្យនន្ទិអមាត្យ
ទឹងពាក្យរឹងដំហរបស់សុរពល ព្រះអង្គទ្រង់ស្តាយកងការបាត់បង់អ្នក

ឡើងត្រង់ទាំងពីរនាក់ ដោយហេតុតែស្មានខុសព្រះអង្គជ្រាបច្បាស់ថា សុរពលភ្ជាំងភ្ជាត់ក្នុងការទុកដាក់មកុដពេជ្រ ស្លានេះអែបលបឡើងឡើងដោយសេចក្តីពឹស ហើយចាប់យកពេជ្រនោះមកលេងដោយមិនមាន្ទរណាដឹង ស្លានេះកាលវាឃើញអញឲ្យដាងធ្វើមកុដពេជ្រថែមត្រាប់ថ្មី ទើបវានាំយកត្សូងពេជ្រនោះមកឲ្យអញវិញ ។ ព្រះរាជាទ្រង់ស្តាយក្នុងការភ្ជាត់ខុសរបស់ព្រះអង្គយ៉ាងធំមហ៊ាមា ដែលនាំឲ្យសេចក្តីវេទនាកើតមានដល់សុរពលនឹងអមាត្យនន្ទិ ក្នុងការដែលព្រះអង្គបានចាប់ចងឃុំឃាំងទុកអស់កាលដ៏យូរ, ទ្រង់បញ្ជាឲ្យដាងយកមកុដនោះឡើងធ្វើឯផ្ទះ ហើយទ្រង់ឡើងឡើងលើប្រាសាទ ។

ព្រះរាជាក្រុងរាជត្រឹះ ទ្រង់បានប្រជុំអមាត្យទាំងពួងក្នុងវិថ្លដាលំដាប់តមក ហើយទ្រង់មានព្រះបន្ទូលប្រាប់អំពីការឃើញពេជ្រដែលបាត់នោះ ហើយប្រឹក្សានឹងនាម៉ឹនទាំងពួងថា តើឲ្យព្រះអង្គធ្វើដូចម្តេច ? ។ នាម៉ឹនទាំងឡាយក្រាបបង្គំទូលថា ឲ្យព្រះអង្គបិទប្រកាសទូឡើងទាំងព្រះនគររាជត្រឹះ ប្រាប់អំពីការលុបលាងកំហុស របស់អមាត្យនន្ទិនឹងសុរពលថាជាអ្នកបរិសុទ្ធិតាមរឿងដែលកើតឡើង ហើយសុំឲ្យចូលមកតាល់ព្រះអង្គក្នុងពេលដែលបានដឹងរឿងវ៉ាវនេះ ។

ព្រះរាជាទ្រង់យល់ស្រមតាមយោបល់ដែលនាម៉ឹនទាំងឡាយក្រាបបង្គំទូល ។ មិនយូរប៉ុន្មាន ប្រកាសលុបលាងទោសនោះក៏បិទទូឡើងក្នុងក្រុងរាជត្រឹះ ។

ប្រកាសរបស់ព្រះរាជា ដែលភ្នាក់ងារយកឡើងត្រប់ច្រកល្ហក

ពួកអ្នកស្រុកក៏បានដឹងសេចក្តីពិតហើយនាំគ្នាត្រិះរិះពិចារណា តែថាការណ៍កន្ទងហួសទៅហើយ ដោយមិនមានរូបរាងនន្ទិអមាត្យ សូម្បីតែស្រមោលក៏មិនមកប្រាកដឲ្យឃើញទ្បើយ, ពាក្យចចាមអារាមក៏លេចឮទ្បើងថា នន្ទិអមាត្យនឹងបុត្តស្ទាប់ចាត់ទៅហើយ ហើមិនដូច្នោះទេគង់នឹងមកពុំខាន ។

ប្រកាស ១ ច្បាប់បានទៅដល់ដៃបុទ្ធិស័ត្យ គេនាំប្រកាសនោះទៅឲ្យបិតាមើល ជំរាបឪពុកថា :-

-"លោកឪពុក ! ខ្ញុំមានដំណឹងល្អនឹងជម្រាបឲ្យលោកឪពុកជ្រាប, សូមលោកឪពុកមើលប្រកាស ១ ច្បាប់នេះ" ។

-"ប្រកាសអ្វី កូន ? ប្រាប់មកឲ្យឪពុកដឹងរឿងធាប់ ។" សេដ្ឋីឃើញអាការៈរបស់បុទ្ធិស័ត្យ ក៏ចង់ដឹងរឿងធាប់ ។

បុទ្ធិស័ត្យក៏អានប្រកាសនោះឲ្យបិតាស្តាប់ទាល់តែចប់ ។

ឪពុកបុទ្ធិស័ត្យរំពឹងដោយសេចក្តីយល់ឃើញក្នុងចិត្តថា: "ពុទ្ធោ-អើយ ! នន្ទិអមាត្យមិនគួរនឹងមានគ្រោះកម្មដល់ប៉ុណ្ណោះទ្បើយ" រួចប្រាប់បុទ្ធិស័ត្យ៍ថា "ឪពុកគឹតថានន្ទិអមាត្យ កាលបើបានដឹងប្រកាសនេះហើយគង់នឹងបូលទៅគាល់ព្រះរាជាពុំខាន" ។

-"ខ្ញុំគិតដូច្នោះដែរ លោកឪពុក !" បុទ្ធិស័ត្យ៍សំដែងសេចក្តីក្រាក់ផ្អើល ទាល់តែប្រាកដបេញមកក្រៅរន្ធង់ត្នែក សំដែងបីតិបេញមកឲ្យឃើញច្បាស់ ។

-"អើកូនសំឡាញ់ ! គ្រានេះក៏ជាកិរិយាផុតទុក្ខផុតគ្រោះកម្មហើយ,

មិនយូរទេលោកនន្ទិនឹងត្រឡប់មកវិញ" លោកសំដែងសេចក្តីត្រេកអរ
ជាមួយនឹងបុទ្ធិស័ត្ស ។

សេចក្តីស្រឡាញ់ជារបស់ដែលមានអំណាចនឹងមានបុទ្ធិយ៉ាងមហិ-
មា អាចឲ្យមនុស្សធ្វើការណា ៗ បាន ដោយមិនគិតដល់សេចក្តីលំបាក
សូម្បីជីវិតខ្ជួននឹងស្ទាប់ក៏មិនគិតផង, បុទ្ធិស័ត្ស៍បានទទួលសេចក្តីលំបាកក្នុង
ការដើរតាមរកមនុស្សស្រឡាញ់ ត្រប់កន្ទែងដែលគេអាចទៅបាន អស់-
រ៉ាយូរខែ, បុទ្ធិសត្សមិនដឹងសោះថា ឥឡូវនេះ នាងកាញ្ចនាបាន
សេចក្តីសុខយ៉ាងណាតែដោយសារប្រកាសរបស់ព្រះរាជា ធ្វើឲ្យគេគិតថា
ថ្ងៃណាមួយកាញ្ចនានឹងត្រឡប់មកកាន់ក្រុងរាជត្រឹះ ជាមួយនឹងបិតារបស់
នាងវិញ, គេតាំងចិត្តរង់ចាំចួបស្រីជាសំឡាញ់ដោយសេចក្តីក្រវល់ក្រវាយ
រាល់ ៗ ថ្ងៃ បុទ្ធិសត្សតែងទៅវិលវង់នៅក្នុងថែវមុខផ្ទះរបស់ទន្ទិអមាត្ស គេមិន
បានដឹងថាការរង់ចាំនោះជាការឥតប្រយោជន៍ឡើយ, បុទ្ធិស័ត្សរង់ចាំផ្ទូវ
នាងកាញ្ចនាតែមិនឃើញនាងមកសោះ ក៏ត្រាំពុំបានទើបទៅជម្រាបបិតា
ថា: "លោកឥពុកខ្ញុំមិនមានសេចក្តីសុខទេប្រសិនបើខ្ញុំមិនបានចួបកាញ្ចនា
ខ្ញុំគិតដល់នាងណាស់ មិនដឹងថានឹងធ្វើយ៉ាងដូចម្តេចបានស្រួល បើលោក-
ឥពុកមានមធ្យោបាយយ៉ាងណាអាចជួយណែនាំខ្ញុំបាន សូមមេត្តាជួយខ្ញុំ
ផង" គេអង្វរការសេដ្ឋីដោយពាក្យគួរអាណិត ។ សេដ្ឋីបានឌ្ងកូននិយាយ
ដូច្នោះ ក៏មានសេចក្តីអាណិត ដោយនឹកដល់សេក្តីទុក្ខរបស់កូនដែល
បិតនៅក្នុងវ័យជាកំម្មោះនៅឡើយ តែមនុស្សយើងកាលបើមានឧបស័ត្ត
ដូច្នេះកិតឡើងហើយត្រូវតែរកអ្វីមកកំចាត់ឃាសសំអាតឲ្យបានទើបគិតថា

" បើពុកឲ្យឋិតិសត្យ។បុសម្ប៉ងសិន ដើម្បីឲ្យព្រះធម៌ជួសខាត់គំលេស ដ៏កក្រក់ដែលដេកគ្រាំក្នុងចិត្ត ឲ្យតាំងនៅក្នុងសភាពធម្មតាហើយ សេចក្តីទុក្ខនេះក៏នឹងជាត់ទៅឯង " ការគិតឃើញយ៉ាងនេះហើយ ទើបនិយាយទៅនឹងកូនថា :

- "ឋិតិសត្យ កូនសម្លាញ់! ឪពុកចង់ឲ្យឯងបុសម្ប៉ងជាកិច្ចកងព្រះពុទ្ធសាសនាសិន ដើម្បីនឹងបានសូបចិត្ត, ឪពុកគិតឃើញថា មានថ្ងៃណាមួយកូនសម្លាញ់ឯងនឹងត្រូវបានទទួលនូវសេចក្តីសុខសមតាមបំណង, ដឿឪពុកមួយជន្មសិនចុះកូន! ឪពុកឮបន់ទឹកបេះណា បេះដែលឪពុកនឹកស្មានទុកនោះមែនជាសេចក្តីពិតគេតឡើងតាមដែលនឹកនោះ មើលចុះ! ពេលដែលឪពុកឈឺធ្ងន់ ឪពុកគិតថា ត្រូវឯងមកវេរឪពុក ក៏ឯងមកមែន តាមសេចក្តីដែលឪពុកគិត, កូនដឹងទេ សេចក្តីទុក្ខរបស់ឪពុកពេលនោះ មិនខុសអ្វីនឹងសេចក្តីទុក្ខរបស់កូនឯង " ។

ឋិតិសត្យស្តាប់បិតានិយាយ ក៏ជាប់ចិត្តតាមបិតាក្រាម ដោយនឹកថាការបួសរបស់ខ្លួននឹងមានតានិសង្ស នាំបណ្តាលឲ្យបានជួបតាញ្ញាសមតាមបំណង ទើបដំរាបបិតាថា:

-"ខ្ញុំបាទដឿលោកឪពុក! ខ្ញុំឮប់តិតជានិច្ចមកថានឹងបុសម្ប៉ងដែរ បើដូច្នោះខ្ញុំក៏ត្រូវទៅបម្ប៉ងក្នុងក្រុងវេសាលី តាមដែលខ្ញុំបានទទួលព្រះរាជបន្ទូលនៃព្រះរាជា, សូមលោកឪពុកចាត់ចែងឲ្យខ្ញុំផង " ។

-"បានកូនសំឡាញ់! ឪពុកនឹងចាត់ចែងឲ្យ, ឯពេលវេលានឹងបុសម្ប៉ងស្រេចតែកូនឯងចុះ ពេញចិត្តនឹងបុសម្ប៉ងថ្ងៃណាក៏បាន " ។

-"ខ្ញុំចង់ហ៊ាសណាស់ឥតុក ! បើបានចេញដំណើរទៅតន់ថ្ងៃនេះឬ
ស្អែក ក៏តែតែស្រួលណាស់" ។

មិនយូរប៉ុន្មាន ក្បួនរាជរបស់សេដ្ឋីដែលមានសេដ្ឋីធីតាយោ បាន
ចេញដំណើរមកជាមួយនឹងឫទ្ធិស័ក្ស ឆ្ពោះទៅកាន់តន្តរវេសាលី ។

ឫទ្ធិស័ក្សព្យាយាមរម្ងាប់ទុក្ខវិការគឺតន្ទឹកដល់នាងកាញ្ចនា តាំងចិត្តនឹង
ឧបសម្ព័ន្ធប្រាថ្នាបុណ្យគឺអាទិសង្ឃនៃការបួសដោយដាច់ខាត គេប្រុងខ្លួន
ជាទិច្ចថា នឹងប្រតិបត្តិឲ្យល្អប្រពៃឲ្យសមជាកិត្តិភក្តីពុទ្ធសាសនាពិតៗ ហើយ
ឫទ្ធិស័ក្សនឹកដល់អមាត្យជាលិត ទើបធ្វើចុតហ្មាយឲ្យបំរើនាំទៅប្រាប់
ដំណឹងព្រមទាំងអញ្ជើញអមាត្យជាលិតមកកាន់តន្តរវេសាលី ; សេចក្តី
សំបុត្រនោះថា: សូមដំរាបលោកជាលិត ! ខ្ញុំឈ្មោះឫទ្ធិស័ក្សជាអ្នករក្សា
ភាសាស័ក្សនឹងសេចក្តីពិតចំពោះបុគ្គលម្នាក់ ដែលធ្វើឲ្យកើតសេចក្តីលំបាក
ក្នុងចិត្តហួសប្រមាណ មើលចុះដំរិតនេះមិនមានសេចក្តីសំខាន់ត្រង់ណា
ឡើយ ហេតុនេះខ្ញុំទើបតិត្ថិឧបសម្ព័ន្ធដើម្បីប្រាថ្នាផលានិសង្ស មានថ្ងៃ
ណាមួយគន់ធ្វើឲ្យខ្ញុំបានខ្ជួលខ្លួរសេចក្តីសុខ, មួយទៀតខ្ញុំមានរឿងមួយ
ដែលត្រូវដម្រាបលោកតីរឿងជាប់ខាក់ខន់ធីនឹងអមាត្យ តាំងរវាងនេះ ព្រះ-
រាជាបានឃើញពេជ្រ ១ គ្រាប់នោះហើយ ដោយទ្រង់មិនបានឹកឃើញ
សព្ទផងសោះ ព្រះអង្គឃើញត្រមត្រូវសាលាលោកខន្ធីជាអ្នកស្មោះត្រង់
បរិសុទ្ធ តាងរវាងនេះព្រះអង្គរាជាំជួបនឹងខន្ធីអមាត្យ ដោយទ្រង់ចង់សារ
សព្ទរំពឹកអំពីកំហុសរបស់ព្រះអង្គ តាំងពីខ្ញុំបានដឹងប្រកាសនោះហើយ
ខ្ញុំរង់ចាំការត្រឡប់វិញរបស់ខន្ធីអមាត្យ តែមិនឃើញលោកទៅតាល់

ព្រះរាជាសោះហេតុនេះ គ្រាបុងគ្រោយបំផុតនៃការរង់ចាំរបស់ខ្ញុំ ។ ត្រូវតែទបសម្ស៊ង ដើម្បីរម្ងាប់សេចក្តីទុក្ខព្រួយខ្ញុំ ពឹងព្រះធមិជុបជីវិតជរាបដល់ស្ងាប់ហើយ . . . . . ;

ខណៈដែលលោកអានសំបុត្រនេះ ខ្ញុំកំពុងដើរផ្ទូវទៅនគរវសាលីហើយសូមលោកមេត្តាអញ្ជើញៈទៅក្នុងការទបសម្ស៊ងរបស់ខ្ញុំផង" . . . ;

ឬទ្ធិសត្សបានបញ្ជូនមនុស្សបំរើ ឲ្យទ្បើងជិះសេះនាំសំបុត្រនោះទៅកាន់ក្រុងពារាណសី ក្នុងវេលានោះ, មិនយូរប៉ុន្មានក្សួនរទេះរបស់ឬទ្ធិសត្សក៏បានទៅដល់នគរវសាលីដោយសួស្ត្ថី, ព្រះរាជាទ្រង់ទទួលរាក់ទាក់ដោយព្រះទ័យសោមនស្ស, ឬទ្ធិសត្សនឹងបិតាមាតាបានសំណាក់នៅក្នុងក្រុងវសាលី រង់ចាំឬក្សទបសម្ស៊ងក្នុងវេលាមុនវស្សានរដូវ ដែលនឹងមកដល់តាមដំណើរប្រក្រតី ។

(មានត)

រឿងសាមកុកក

កណ្ឌ ៦៦

ឧកញ៉ាវិបុលរាជសេនា ន្ធ - កន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃធ្លាសបើបានអាន
នឹងបេះឧបាយកលបំណាន
ទាំងមានសន្ធានស្នេហាជាតិ ។

ហើយស៊ុនសេកឲ្យហៅប្អូនស្រីទាំង ៦ នាក់មកផ្តាំថា ប្អូនចូរយកចិត្តទុកដាក់ឈឺធ្មាលនឹងស៊ុនគួនជាបងផង ប្រើមានន រណាដែលជាប៉ក្សពួកសែជាមួយនឹងយើងតិតប្រទូសរ៉ាយដល់ស៊ុនគួន ចូរជួយព្ធ្រតគ្នាវិះតិតប្រើប្រាជ្ញាប្រាបប្រាមឲ្យរាបទាប កុំឲ្យអ្នកដទៃមើលងាយប្រមាថនឹងតិះដៀលនិន្ទាបាន ។ ឧណៈនោះស៊ុនគួននឹងប្អូនស្រីទាំង ៦ ទទួលស្តាប់ពាក្យបណ្តាំហើយក៏សោកាពិលាប ស៊ុនសេកក៏និយាយនឹងនាងកៀវហ្ចិយិនជាភរិយាថា " ខ្ញុនបងអស់បុណ្យវាសនាហើយនឹងស្តាប់ចោលប្អូនក្នុងគ្រានេះ ប្អូនចូរនៅឲ្យបានសេចក្តិសុខកុះ ហើយទំយកចិត្តទុកដាក់ប្រណិប៉តន៍រក្សាមាតាបេស់បងផង មួយទៀតឲ្យប្អូនជួយនិយាយរំលឹកប្អូនស្រីដែលជាភរិយាដីវយី ឲ្យទំយកចិត្តដីវយីគ្រាន់បានជាទីពឹង

ដើម្បីទឹងឲ្យដាវយើជួយចំនុកបំរុងស៊ុនគួន ហើយសូមឲ្យដាវយើមានមេត្រី
ចិត្តគិតជល់សេចក្តីស្មោះត្រង់របស់យើង ដែលធ្លាប់ធ្វើការផងគ្នារៀងពីម-
មក" ។ លុះផ្តែផ្តាំសេចក្តីសព្វគ្រប់ហើយស៊ុនសើកក៏ដាច់ខ្យល់ស្លាប់ ។

កាលស៊ុនសើកស្លាប់នោះអាយុបាន ៤៦ ឆ្នាំ មាគានឹងកវិយោនៅ
អស់វង្សគណាញាតិបងប្អូនទាំងអស់ កំសឹងខ្លាយយំដំពកសោកាល័យ
ត្រប់គ្នា ឯស៊ុនគួនោះក៏យំខាល់តែដួលសន្លប់ ទោះកំស្រោចស្រប់ណាប
រឹតតែគាល់តែដឹងខ្លួនឡើងវិញ ។ ខ្មៅរៀបរៀនិយាយលួងលោមយកចិត្តថា
វេលានេះអាណាខែត្រទាំងពួងនៅមិនទាន់កបទាប ជាប្រក្រតីនៅឡើយ
ដែលអ្នកឧទ្ទឹងមកសោកសៅដូច្នេះមិនគួរទេ សូមឲ្យអ្នករៀបចំតាក់តែង
ធ្វើបុណ្យបូជាសពស៊ុនសើកឲ្យរួចស្រេចសិនទៅ ដើម្បីទឹងបាននិងតិត
កិច្ចការពងការតោរកូស្រុកឲ្យទាំមួនតទៅ ។ ស៊ីនគួនឃល់ឃើញ
ត្រូវ ទើបផ្តួចដាក់មុខរីរៀបចំការបូជាសពនោះឲ្យស៊ុនចេងជាមាចាត់
ចែងតែងតាមទំនៀមទម្លាប់ ឯស៊ុនគួនក៏ចេញនិយាយការពងការបណ្តា
នាម៉ឺនមុខមន្ត្រីទឹងសេនាពាហនត្រប់តំណែង ចូលមកគំនាប់ព្រមគ្នា ។
ស៊ុនគួននោះជាមនុស្សមានសុកលក្ខណៈ រូបកាយស្អាតបាត មុខធំ ថ្ងាស
ធូលាយ ភ្នែកក្រហម ។

ខណៈកាលស៊ុនកៀនជាបិតារស់នៅឡើយនោះ ខ្មៅអួនជានាម៉ឺន
ធំនៅក្នុងព្រះបរមរាជវាំងតេ ចេញមកស្តីពងការស្រុកកាំងតាំង ឃើញ
កូនស៊ុនកៀនទាំង ៤ នាក់ មានរូបភាពល្អស្អាតប្រកបដោយលក្ខណៈជា
អ្នកមានបុណ្យ ខ្មៅអួនគាយមុខថា កូនគួននោះទឹងមានបុណ្យវាសនា

ច្រើនជាងបងប្អូនទាំងអស់ ទាំងអាយុក៏យឺនវែង យូរទៅស៊ុនគួននឹង
ចាន់ជាធំ ។ ដល់ត្រានេះបានសមដូចពាក្យឡេស៊ុអ្ជិនទាយទុកមែន ។

ឯជីវយ៉ ដែលស៊ុនសិកឲ្យឃុំនាំទាហានទៅរក្សាតយល្សាតនៅ
ជំបន់ចាំតីវនោះ លុះបានដឹងដំណឹងថាស៊ុនសិកត្រូវព្រួញរបួសឈឺជា
ទម្ងន់ក៏នាំទាហានស្រូតរូតមកស្រុកកាំងតាំងវិញ ដឹងថាស៊ុនសិកស្ងាប់
ក៏ប្រញាប់ចូលមកឧបសពស៊ុនសិក សោកាពិលាបរៀបរាប់ដោយ
សេចក្តីអាលោះអាល័យផ្សង ។ ។ នាងង៉ហ្ជីយិនទឹងស៊ុនគួនក៏ចេញមកជួប
ទឹងជីវយ៉ហើយពណិនាប្រាប់តាមបណ្តាំ ដែលស៊ុនសិកផ្តាំទុកសព្វត្រប់
ប្រការ ។ ជីវយ៉ធ្វើយថាៈស៊ុនសិកនោះមានគុណូបការៈចំពោះខ្ជនខ្ញុំបាទ
មកច្រើនណាស់ ខ្ញុំបាទសូមជួយទំនុកបំរុងស៊ុនគួនទៅតាមសតិបញ្ញា
ដោយការសុចរិតលុះត្រាតែអស់ជីវិតសង្ខារ ។ ស៊ុនគួនក៏ថា ខ្ជនខ្ញុំនៅ
ក្នុងសេចក្តីខ្ជិតំនិតនៅឡើយ តែថាស៊ុនសិកជាបងលើកប្រតល់ត្រា
សំរាប់ដារ ទឹងការរាជការក្នុងស្រុកឲ្យដល់ខ្ញុំហើយក៏ត្រូវទទួល តែខ្ជនអ្នក
ដែលជាអ្នកទំនុកបំរុងនឹងឲ្យខ្ញុំរក្សាស្រុកទេស ប្រការម្តេចនឹងបានសេចក្តី
សុខតទៅ ត្រូវណែនាំបំភ្ជឲ្យខ្ញុំបានដឹងស្គាល់យល់ការផង ។ ជីវយ៉ថា
ពាក្យទំនៀមបុរាណពោលទុកមកថា បើអ្នកឯណាដែលធ្វើជាមេបារក្សា
ស្រុកទេសនីមួយ ។ ឲ្យចេះបញ្ចុះបញ្ចូលល្ជ្ជងល្ជងលោមយកចិត្តអ្នកដែល
មានតម្រេះប្រាជ្ញាស្មារតី ហើយត្រូវមានមេត្រីចងចិត្តសេនាទាហានដែល
មានថ្វីដៃខ្ជាំងពូកែយកធ្វើជាគ្នាឲ្យបានច្រើន ទើបស្រុកទេសនោះនឹងបាន
សេចក្តីសុខជាប្រក្រតីតទៅ បើអ្នកឯណាលះបង់ពាក្យបុរាណដូច្នេះហើយ

ស្រុកនោះគឺធំធេងតែងតែប្រឡាសនៅសាសអន្តរាយ ដូចខ្ញុំអញ្ជើញ
ថេសស៊ីតធ្វើជាថៅហ្វាយប្រុកគ្រោះនេះ ត្រូវតែចំប្រឹងរៀនតាមរកឱ្យ
បុកណា ទើបប្រទេសបានចំរើនឡើងសេចក្តីសុខស្តាតទៅ ។ ស៊ីនដួន
ថា បងខ្ញុំបានឮគាំពុកថា ការខាងរឿបរយកូនស្រុក (ស៊ីវិល) ឲ្យតែគ្រោះ
ថ្នាក់ធំធេងជាងទៅទៀត ឯការខាងសេនាគាហានឲ្យតែគ្រោះបីក្បាលធំអញ ។

ជីវយើតក្តែងបន្ទាបខ្លួនថា ខ្ញុំរៀបរៀនគ្មានមតិបញ្ញាច្រើន
ដូចគ្រិះខាងការរឿបរយកូនស្រុកហ៊ាន ដែលប៉ុន្មានសិស្សាំឲ្យខ្ញុំជួយ
ទំនាយការខាងសេនាគា ន ដែរ ឃើញវាសនាតំណាក់ប្រុះ
ការភាហានខាងស្រីខ្លាចឆ្ងាយណាស់ ត្រូវមតិបញ្ញាខ្ញុំតែងទៅមិន
ដល់ ការគំនិតពួកគំនិតសាបរលាបខ្លួចនឹងខ្ញុំ ខ្ញុំបាប់ឃើញវាឡើងប៉ុក
នៅស្រុកតាំងឈ្មួញ មានមតិបញ្ញាកប្រែណាស់ គំនិតគ្រប់គ្រងត្រូវ
កំមានបរិបូណ៌ត្រមាំមាសសេចក្តីចម្រើន ការលក់តាងឡើងស៊ីតស្ងាប់
នោះ ឡើងប៉ុកប្រណិប័តន៍ថាក្លែងឲ្យលេងតិច្ចិ៍ ហើយមានត្រូវ
ចំណាយឱ្យមានដង់មុខស្រួលតែតិចតួចតែប៉ុណ្ណោះ ។ គាបខ្ញុំលើតម្លៃ
ពួកប្រហែល ៣០០ ទាក់ទៅនៅដំបន់ថៅឡើងនោះខ្លួលប្រមាណ ខ្ញុំដឹង
ថា ឡើងប៉ុកមានប្រហែល ២ ដង្រែក តួនមួយដង្រែក ៣០០ ចាំង ខ្ញុំទាំងឡា
ទៅប៉ុនស្មើឡើងគាហារឡើងឡើងប៉ុក ។ គឺមានអំណោះសាវឲ្យស្រួលខ្ញុំមួយ
ដង្រែក ។ លុះអំណោះតមក ឡើងប៉ុកនាំមាតាខឹងគ្រួសារទៅនៅដំបន់
ខាងប៉ុកវិ មានាឡើងស៊ីតខ្លួលអនិច្ចកម្ម ឡើងស៊ុកមានសំឡាញ់ម្នាក់
ឈ្មោះឡើងជូដឿ ដង្ហាវឡើងជូដឿនៅមួលឡើងប៉ុកប្រុះទៅនៅទីដ

តេឯចោ៎ចៅហ្វាយស្រុកចៅអ ខ្ញោស៊ុកខ្ញុំនចាន់ព្រមទៅ ហេតុនេះ
សូមឲ្យលោកចាត់ប្រើមនុស្សដែលមានសតិបញ្ញា ទៅបញ្ចុះបញ្ចូល
អញ្ជើញខ្ញោស៊ុកឯកមកកុកជាមិប្រឹក្សា ដើម្បីនឹងជួយគិតការតទៅ ។

ស៊ុនតួនបានស្តាប់ហើយក៏មានសេចក្តីក្រែកអរ និយាយនឹងដីវយើថា
"ដែលនឹងរកអ្នកឯណាឲ្យទៅនោះក៏ដូចខ្លួនអ្នក" ហើយក៏រៀបចាត់
ចែងរបស់ទ្រព្យដ៏មានជំរៃ ឲ្យដីវយើនាំយកទៅតំនាក់សមតួនឹងខ្ញោ-
ស៊ុក ។ ដីវយើក៏ដួលនាំយករបស់ទ្រព្យទាំងនោះទៅជាមួយនឹងបាត្រាវ
ដល់ដំបន់ឃ្យុក ហើយនាំចូលទៅឲ្យខ្ញោស៊ុកបួងនិយាយថា ស៊ុនតួន
បានដឹងថាអ្នកមានតម្រេកប្រាជ្ញាស្មោតី តាំងចិត្តថ្វាយគំប្រុកបដោយសេចក្តី
សុភាពរៀបរយ ទើរប្រើខ្ញុំឲ្យមកអញ្ជើញអ្នកទៅ ប្រាថ្នាឲ្យជួយ
គិតការខំនុះបំរុងស្រុកទេសឲ្យបានសេចក្តីសុខ ។ ខ្ញោស៊ុកតបថា: ខ្ញុំ
បានខួលភាស្រះឡាដៀនខុកបួចស្រេចហើយ ថាទើរទៅនៅជាមួយនឹង
តេឯចោ៎ ចៅហ្វាយស្រុកចៅអ ។

ដីវយើថា: កាលគ្រាអនឹមាំងឃ្លត់យកពាជសម្បត្តិនោះ ស្រុកទេស
ក៏ចលាចលពាស់អាទ្វើ ម៉ាម្តងដាតាហាទបានឱយាយនឹងហ៊ានកងិចូថា ដែល
ស្រុកទេសតើតចលាចលយ៉ាងនេះ ខណាដែលមានសតិបញ្ញានឹងថ្វាដែ
ខ្លាំងតូកែនោះ មិនតួនឹងព្រាងើយកន្តើយនៅស្ងៀមឲ្យអ្នកធំមករកសោះ
តួរតែពីគ្រោះក្រៃរំនេមិល បើយើញអ្នកឯណាដែលមានតម្រេកប្រាជ្ញា
ស្មោតីប្រកបដោយមេត្រីចិត្តពាក់ពាន់អ្នកតូចតួចទៅ សមតួនឹងធ្វើថា
ចៅហ្វាយនាយតេបាន ក៏ឲ្យខំតិតពានចូលទៅនៅតាំងបុណ្យអ្នកនោះ

ខ្ញុំដឹងបានជាខ្លីពីដំណឹងពាក់ព័ន្ធនៅ ឥឡូវនៃអ្នកកំដរនេះហើយថាស៊ុនគួនជាចៅហ្វាយ
នាយរបស់យើងនេះមានតម្រេះច្រើនស្មាតែប្រកបដោយមេត្រីចិត្តពប់អាន
ស្រឡាញ់សេនាជាហានដែលមានថ្នឹកដៃខ្លាំងពូកែ ខ្ញុំដឹងអ្នកដែលមានសតិ-
បញ្ញាច្រើន មួយទៀត បើមានអ្នកឯណាដែលមានសតិបញ្ញាខ្ញុំនិយាយ
ការអ្វីជាផ្លូវត្រូវ ហើយហ៊ានទៅខ្ញុំដឹងថាស់ ស៊ុនគួនក៏ប្រក្រឡាស់យល់
តាមតតប្រកែកសោះ ចិត្តរបស់ខ្ញុំដែលស្រឡាញ់ស្មោះយល់ឃើញថា បើ
អ្នកទៅនៅធ្វើការនឹងស៊ុនគួន ឈ្មោះថាប្រសើរជាងទៅនៅនឹងអ្នកដទៃ
ច្រើនភាគ ដែលខ្ញុំទុំសម្លាតមកនិយាយនឹងអ្នកទាំងពួង ដោយអំពើបុព្វហេតុ
សូមឲ្យអ្នកពិចារណាមើលតាមគួរចុះ ។

ឡោស៊ុកបានស្តាប់ដូច្នោះក៏យល់ក្តីចិត្តស៊ប់ក្នុងសន្តានចិត្តមានសោម-
នស្សប្រីតាឆ្លើយថា ខ្ញុំយល់ត្រូវតាមសំដីអ្នក ខ្ញុំ ឃើញ ៗ ពីដំណាក់
ស៊ុនគួនជាចៅហ្វាយនាយគង់ ។ ដើរយើគំនាំឡោស៊ុកចូលទៅដល់
ស្រុកតាំងតាំង ហើយក៏ចូលទៅគំនាប់ស៊ុនគួនៗក្រឡេកឃើញឡោស៊ុក
ទៅដល់ក៏ត្រេកអរពេកឃ្លេ ចេញពីកន្លែងបន្ទាយមកទទួលនាំចូលទៅនិយាយ
សាកសួរតាមសេចក្តី ហើយក៏ពិនិត្យប្រឹក្សាពីកិច្ចការសឹកសង្គ្រាម
តាំងពីព្រឹកដល់ថ្ងៃត្រង់ ។ ឡោស៊ុកក៏និយាយបន្ថែមឲ្យស៊ុនគួនភ្ញី
ចូលចិត្តស្តាប់ថាឧសភ្លក្រប់ប្រការ ។ ស៊ុនគួនមានសេចក្តីត្រេកអរជា
អនេកប្បការ ហើយឲ្យរៀបតុះដម់លៀងគោជនានាយកឡោស៊ុក ។ លុះ
វេលាយប់ស៊ុនគួនតំឡើងតាំឡោស៊ុក ឲ្យទៅដេកជាមួយគ្នាលើគ្រែដំណេក
ស៊ុនគួនក៏មានចិត្តត្រេកអរពេកឃ្លេ នាំនិយាយពីកិច្ចការនានាដ៏ ដេក

ប្រគន់តើយលើឡោស៊ុកហើយស្រដីថា សព្វថ្ងៃនេះ ព្រះចៅហ្វាខេត
សោយរាជសម្បត្តិ ផែនដីក៏កើតវិប្បរិតបលាចលផ្សេងៗ ខ្ញុំព្រះឃើញ
ថាស្រុកខេត្តរបស់យើងវេលានេះ ទឹងរៀវកេរសាបសូន្យអស់ហើយ
ដែលខ្ញុំបានកើតស្រុកជំនួសស៊ុនៈសេកជាបន្តគ្រានេះ ខ្ញុំក៏ប្រុងតែទឹងធ្វើ
ការឲ្យធំខ្លួលាយចេញទៅទៀត ឲ្យដូចគ្រាព្រះចៅដនប៉ុនកុងសោយរាជ.
សម្បត្តិនោះ ។ អាណាខែត្រភាំងកួនក៏បះបោរទាក់ទងលាបលាលអន្ទឹ
ងព្រះចៅដនប៉ុនកុងទឹងចូលទឹងកុងតាមហាឧបរាជក៏ដែរតែទឹងបំបាត់លា.
ជារ ដើរឲ្យត្រួមណ្ឌលរាជបុរីលក្ខណ៍ដំណាងភាំងស៊ុ ប្រទេស
កំពានសេចក្តីសុខស្រួមក្សត្តជាយូរ ។ ដែលខ្ញុំព្រះមកសំដែង
ឲ្យឃើញដាំលំអានដូច្នេះ តើខ្លួនម្នាស់លៃតត្រកះដូចម្តេច ?

ខ្មៅ ប៊ុតតបថា: លោកត្រកះតែតនេះ ឯការស្តួលណាស់ តែទឹង
បន្ទឹងឲ្យរហ័សធាប់ស្រួលតន់ខាន់ចិត្ត តែឲ្យបានដំណូច ដូចទំនៀម យតព្រះ
ចៅដនប៉ុនកុង ដែលចេញទឹងកុងនោះតែតនេះបានទេ ព្រោះតែដើរសព្វ
ថ្ងៃនេះកំពុងតែចលាចល ព្រះចៅហ្វាខេត្តដែលស្រួលកះជាន
តែជាវិកន្ធ្លល់តំរាស់មិនបានសុខដូច្រើតទេ ដោយខេមន្ត្រីធំតូចខ្លួនជា
មហាឧបរាជ មានព្រះភ្នាក់ស្តេចតែភាំងសេនាជាហានក៏មានខ្លួនដែរជា
ច្រើន ដែលលោកតែតទឹងរាប់បំណុងតែកសោះនោះមិនបានទេ មួយ
ទៀតអ្នកនៅក៏តំពុងតែធ្វើបតិវាប់ដែរ ដោយខ្លួនឯង ឯខ្លួនក៏ប្រែចេញ
ស្រុកតន់ណាទឹងស៊ុចរាចរៀបហ្វាយស្រុកតាំងរៀបភោះ តែជាចំនួនចាស់ នៅ
ជិតស្រុកយើង សូមឲ្យលោកនៃតតំបាត់ឲ្យរៀងស៊ុចរាចេញសិន

រួចសឹមគិតការធំតទៅទៀត ។ ស៊ុនតួនបានស្តាប់ដូច្នោះក៏ពេញចិត្តណាស់ ក្រោកឡើងសំពះឡាស៊ុកហើយក៏ដាក់ ៤ ឬយគ្នា ៧ ។ លុះត្រឹមឆ្នើស៊ុនតួនក៏បាត់ចែងមាសប្រាក់ទឹកត្រីនិងសេដ្ឋកិច្ចយ៉ាងល្អមានដំរៀបឲ្យជារង្វាន់ឡាស៊ុកជាប្រចាំ ហើយក៏បាត់ចែងទីលំនៅឲ្យឡាស៊ុក ។ ខ្លួលយកបេះសាំងអស់នោះបួលាំនតួនទៅតាន់រិលំនៅ ។

ឯផ្ទះគិនជាបងខុសបែងនោះនៅក្នុងដែនស្រុកកេងជីវ មានសតិបញ្ញាប្រិនជាសំឡាញ់គ្នានឹងឡាស៊ុក លុះដឹងដំណឹងថាឡាប៉ុកទៅនៅស្រុកគាំងតាំង ផ្ទះគិនក៏ទៅសួរដោយសេចក្តីសុខឡាស៊ុក ។ មានអំណរណាស់ពីបបួលផ្ទះគិនឲ្យចូលទៅនៅជាមួយនឹងស៊ុនតួន ។ ផ្ទះគិនក៏ព្រម ទើបឡាស៊ុកនាំខ្លួនទៅជួបនឹងស៊ុនតួន ហើយពណ៌នាប្រឹងកំប្រុងថា ផ្ទះគិននេះជាសំឡាញ់ស្និទ្ធស្នាលនឹងខ្ញុំបានមកពីដើម ឥរូវព្រមចូលមក នៅធ្វើជាការនឹងលោក ។ ស៊ុនតួនបានស្តាប់ដូច្នោះ ក៏មានចិត្តត្រេកអរទទួលយកផ្ទះគិនទុកជាទីប្រឹក្សា ហើយក៏ពិគ្រោះនឹងទីប្រឹក្សាគំនិតថា អ្នកនេះគ្រាបានឲ្យសំបុត្រមកដល់បងហើយឲ្យ ឡាកងទ័ពទៅជួយកាយកំបាត់ជួនចេញ ឥឡូវបងយើងក៏អនិច្ចកម្មទៅហើយ បើដូច្នេះតើអ្នកទាំងអស់គ្នាយល់យ៉ាងណា នឹងឲ្យយើងចូលទៅនាងអួនសៀវល្អជាងឬចូលទៅនាងជួនល្អជាង ? ផ្ទះគិនទទួលថា ដែលនឹងចូលទៅនាងអួនសៀវនោះខ្ញុំយល់ឃើញថាមិនស្រួលទេ សូមឲ្យលោកចូលទៅនាងជួនចុះ បើតាលណាយើញថាមានគុណសមនឹងលួម សឹមយកចំណាប់នោះមកវិនិតនាតាមតម្រូវ

ច្រាជ្ញាជាគ្រោយ ។ ស៊ីនគួនយល់ឃើញត្រូវតាម ទើបធ្វើ
សំបុត្រទៅកាត់ផ្ញើរមេត្រីឲ្យតាន់ជីនកាន់ត្រឡប់ទៅឲ្យអ៊ីនសៀវ ។

ឯចូនួលុះដឹងដំណឹងថាស៊ីនសេកស្លាប់ហើយ កំប្រឹក្សាទីឆ្ងល់សេនា
ពហានគាំនតួនថា ស៊ីនសេកស្លាប់ហើយ ឥឡូវស៊ីនគួនជាប្អូនបាន
ខួលធ្វើពាជការនំនួសបង យើងចង់ទីឆ្ងល់លើកកងទ័ពទៅកាយយកស្រុក
គាំងគាន់គ្រានេះតើអ្នកទាំងអស់គ្នាឯងយល់ឃើញប្រការដូចម្តេច ? ខៀវ
ហៀនវ៉ែងទុចាយ ក្តីយថា វេលានេះស៊ីនសេនកំស្លាប់ទៅហើយ ស៊ីន
គួនទីឆ្ងល់ក្រមញ៉ា បងប្អូនគាំនតួនកំទៅកំពុងវល់រៀបចំការសពស៊ីនសេក
បើលោកនឹងលើកទ័ពទៅច្បាំងយកស្រុកគាំងគាន់ក្នុងគ្រានេះ មនុស្សទាំង
តួនឆ្ងល់ឆ្ងឹងរហាងនិងា ប្រការមួយទៀត បើលោកទៅធ្វើការសង្គ្រាមនោះ
ត្រឡប់ទៅជាថ្នល់ការប្រការប្តេចទៅវិញគឺវែងតែអំប្រយោសជាច្រើន លោក
ចូរិះគិតយកចិត្តស៊ីនគួនខុកជ្នាវិញប្រសើរជាង ។ ចូនួយល់ឃើញ
ត្រូវ ក៏ចូលទៅគ្រាបបង្គំទូលព្រះបាទ ហៀនតេ ឲ្យតាំងស៊ីនគួនពេញទីជា
ចៅហ្វាយស្រុកគាំងគាន់ តាំងខៀ ហៀនជាទីបាឡាត់ ។ ព្រះចៅ
ហៀនតេក៏ទ្រង់យល់ព្រម ហើយគ្រាស់ឲ្យចូនួតែងគ្រាតាំងឲ្យខៀវហៀន
កាន់ត្រឡប់ទៅឲ្យស៊ីនគួន ឯស៊ីនគួនលុះបានខួលគ្រាតាំងហើយក៏
មានសេចក្តីក្រតអរគន់ប្រមាណ តាំងបានខៀវហៀនត្រឡប់មកវិញផង
ហើយតាំងឲ្យខៀវបៀវ ទីឆ្ងល់ខៀវហៀនជាន ម៉ឺនធំសំពាប់ចាត់ចែងការរក្សា
ស្រុកទេស ។ លុះនោះមកថ្ងៃមួយ នាះ ខៀវហៀនក៏នាំគោរយ៉ុងចូល
ទៅតំនាប់ស៊ីនគួនហើយជំរាបថា គោរយ៉ុងនេះជាមនុស្សមានសតិបញ្ញា

សុបចិតពិតត្រូវដឹងឆ្លាស់ខ្លួនមិនបោះដឹកសុកតាន់កវៃក្រែនសោះ មានចិត្តស្លាប់រស់ស្ម័គ្រចិត្តមកទៅនឹងលោក ។ ស៊ីខត្តនមានអំណរណាស់ ទើបតាំងគោះយ៉ឺង ជាភ្លាក់ដាំរោងតុលាការសំរាប់ចែចំយរសេចក្តីអាណាប្រជាខ្មុកស្ត្រីតាំងតួង ស៊ីខត្តនតែតាំងចត្តំខុកបំរុងសេនាគាហាន ទឹងថែរក្សាអាណាប្រជាជនតាមចំនៀមទម្លាប់ឲ្យនៅជាសុខស្រួមក្សត្ត បណ្តាកស្ត្រីតាំងប៉ុន្មានដែលមាននៅស្រុកចំណុះតំស្រុះស្រួលចូលចិត្តស្រឡាញ់ស៊ីខត្តនជាច្រើន ។

ឯតាន់ដំនកាលត្រូវប៉ះពាល់ប្រុកតិជាវ តំយកសំបុត្រទៅជូនអ្នកនៅសៀវហ៊ីយ៉ពណិនាសេចក្តីថា: ឥឡូវស៊ីខនសឹកស្លាប់ទៅហើយ ស៊ីខត្តនបានជាទៅហ្វាយស្រុកដំនួស ខាងបច្ចុរ៉ែតតយកចិត្តស៊ីខត្តនបានចូលស្មើឲ្យមានត្រាតាំងស៊ីខត្តនពេញទំជាទៅហ្វាយស្រុក ត្រានេះស៊ីខត្តនតំចូលចិត្តទៅខាងបច្ចុរ ។ អ្នកនៅសៀវយើញសេចក្តីសំបុត្រនឹងបានស្តាប់តតិមានពីតាន់ដំនខិយាយដូច្នោះតំនឹកចិនខ្លាំងណាស់ ទើបបង្គាប់ឲ្យកណ្តាលយោធាក្នុងស្រុកតិជាវ, ស្រុកតិរជាវ, ស្រុកសៀងជាវ, ស្រុកបេងជ; បានទាហានតាំង ៤ ស្រុក ៧០ ម៉ឺនចូយលុះទាហានជួរជុំហើយ តំរង់ចាំមើលឫក្សាពេលល្អនឹងលើកចេញទៅកាយស្រុកហ៊ូតោ ។

ខាងហែហ៊ិនខុន ដែលបច្ចុប្រើទៅតាំងទ័ពនៅជិមន់កួតរ ឮដំណឹងថាអ្នកនៅសៀនឹងលើកទ័ពមក តំយកសំបុត្របច្ចុលទៅដំកបច្ចុ ។ ឃើញសំបុត្រក្រែកមកក៏ចាត់ឲ្យស៊ីនហុកនៅថែរក្សាស្រុកក្រុង តាំងកេណ្តាទាហានទៅ

ចាន ៧ ម៉ឺន ៥ ពាន់ លើក ៧ ពេញ លើកនេះ កន្លែងមួយ ខុន ហៅ ឲ្យ
តាំង ចន្លោយ ពាយ ឈ្មោះ ប្រចាំការ តស៊ូ ន៍ ឆ្លៀវ ឆ្លាស ដៅ ត្រៃ យ ខេត្ត
ហង ហោ ។

ឯ ខ្មៀន ហ៊ុន ដែល ត្រូវ ចោទ ឆ្មោះ ក្នុង គុក នោះ ឈ្មោះ ឆ្លួត ណឹង ថា ឆ្លួន សៀវ
ខឹង លើក ចិត្ត ៧ ពាយ ស្រុក ហ្គឺ តោ កំ ច្រៀ សំបុត្រ ១ ប្តាប់ ឲ្យ យក ទៅ ឃាត់
ឆ្លួន សៀវ សេច ក្តី ថា "ធម្មតា មនុស្ស ដែល នៅ ម៉ែ ខាង មាន ទុក្ខ ភ័យ កុំ
គប្បី គិត យក ទុក្ខ ភ័យ មក ដាក់ ស្មារ ខ្លួន, ដែល លោក ឆឹង គិត លើក កង ចិត្ត
ទៅ ក្នុង គ្រានេះ ខ្ញុំ ចាស យល់ ឃើញ ថា ម៉ែ សម ស្មន ទេ ព្រោះ គ្មាន ដាច ជ័យ
ល្អ, សូម ឲ្យ លោក ពាង ប្អូន គ្រួ ន៍ តែ ការ ពារ ស្រុក ស្រែ ចំ ម្ហូ ន ស៊ន ចុះ
ព្រោះ ក្តួ ច ចិន ឆឹង ប៊ិក ឆ្ងាយ ហ៊ុ ខ្ញុ ំ ឈុប លាន ស្រុក យើ ន ចាន ទេ,
ប្រការ មួយ ទៀត ត្រូវ តែ ចាំ ស្តាប ដំណឹង ឲ្យ ន៍ ឆឹង ពស់ ការ ស៊ន បើ ឮ ថា ក្តួ
ច្នើ ស ត្រាំ ម្ភាស់ ភ្លាំ ឆឹង ខឹង អ្នក ឯ ណា សឹម ហើ ន លើក ពល យោធា ទៅ ផ្តាច ផ
ឃក ស្រុ ន ហ្គឺ តោ ឲ្យ ចាន យ៉ាំ ស្រួល, រៀល នេះ ហើ លោក ន៍ ត្រម ខ្លួ ល
ដៀ ស្តាប់ ពាក្យ ខ្ញុ ំ ចាស ទេ ទំ តែ ស ឆ្លាក លក ច័ ត ទៅ ខ្ញុ ំ ចាស យល់ ឃើញ
ថា លោក ឆឹង ដល់ ទូ វ សេច ក្តី ឋក ជ័យ ចា ញ៉ៃ ដួ ច្នួ ដា ត្រួ ត ដ" ។

ឆ្លួន សៀវ ខ្លួ ល សំបុត្រ នោះ មក ម៉ើ ល ហើ យ ក៏ ម៉ែ ចាន ថា ត្រូវ មែ ន ។
ហង តែ ដឹង សេច ក្តី ស្លាប់ ក៏ ស្រ ដ៍ ឆឹង ឆ្លួន សៀវ ថា លោក ប្រុង ឆឹង យក ឫ ក្ស
លើក ចិត្ត ទៅ ហើ យ ខ្មៀន ហង ម ន ឆឹ យ ឃាត ក្ស អ ត ម ក្តី ល ដូ ច្នេះ ម៉ែ ខ្លួ រ ទេ ។
ឆ្លួន សៀវ ត្មៅ ហង តែ ថា ដូ ច្នោះ កំ ដឹង ក្រ ជូ រ ឡើ ង ទេ ចាប ផ្តាំ ឲ្យ ទៅ យក ខ្លួ ន
ខ្មៀន ហង ម ក ស ម្ងាប់ ។ ឥ ប្រឹ ក្ស ឆឹង សេ នា ពា ហ ន ទាំ ង ពួ ង ដឹ ង ឮ ដូ ច្នោះ

កំពូលភ្នំដោយហាមឃាត់អ្នកនេសាទថា: លោកនឹងលើកកងទ័ពចេញ
ទៅធ្វើការសង្គ្រាមនឹងមកកាប់សម្លាប់មនុស្សទុសំខៀមដូច្នេះមិនគួរទេ ។
អ្នកនេសាទធ្វើយថា "បើដូច្នោះ ត្រូវឲ្យគាត់គុកខ្ញុំនហាងទុកឲ្យខ្ចាប់ បើយើង
ទៅធ្វើការមានដំយុជំនះឈ្នះវិញចូលកាលណា រួចត្រឡប់មកវិញនឹង
ឲ្យសម្លាប់កាលណោះ" ។ លុះបានឮក្សត្រជោតតេលាល្ង អ្នកនេសាទក៏លើក
ទ័ពទៅដំបន់ប៊ូអៀង ហើយឲ្យបញ្ជាក់គាហានកងទ័ពចាប់ធ្វើចម្ការយ៉ាង
ចាំមួននៅទីនោះ ។

ចស៊ីវដឹកអ្នកនេសាទថា: គាហានយើងប្រើនកំពិតរមន តែមិន
ស្មើក្លាហានចំណាន្តកងការសង្គ្រាមដូចគាហានចូនួះសោះ ឯស្បៀងអា-
ហារក្នុងកងទ័ពចូនួនោះតិចជាងយើងរមន តែលោកកុំគាលប្រញាប់ធ្វើ
ការរួសរាន់ពេក ចូរតាំរៃគិតឲ្យល្អិតល្អន់សិន ប្រសិនបើស្បៀងក្នុងកង
ទ័ពចូនួរស់កាលណា គង់តែគាហានចាំនួនោះនឹងបែកខ្ញែកទៅឯង រួច
សឹមយើងលើកកងទ័ពទៅយកចូនួ ។ ខ្ញុំថ្លៃការរបស់យើងមិនលែង ។
អ្នកនេសាទបានស្តាប់ហើយក៏ទទួលប្រឡោតឡើងថា "កាលយើងរៀបលើក
កងទ័ពចេញមក ខ្ញុំនហាងជាមនុស្សទោសហានឱយធ្វើនឹងទាស់
នឹងគំនិតយើងម្តងទៅហើយ ឥឡូវថែមមកនិយាយឲ្យរាំខានចិត្តយើងម្តង
ទៀត ដែលខ្ញុំនាំនិយាយឲ្យចង្អៀតយឺតយូរការដូច្នេះមិនជាក្បួនសឹក
សោះ" អ្នកនេសាទថាប៉ុណ្ណោះក៏បង្គាប់ឲ្យគាហានចាប់ខ្ចីនចស៊ីវយកទៅ
ជាក់គុក ហើយថា "បើសម្រេចការសង្គ្រាមវិលាណានឹងឲ្យសម្លាប់ព្រម

គ្នានឹងទៀនហង" ហើយឲ្យភាហានតាំងបន្ទាយភាយកងទ័ពរៀងគ្នាៗ
បម្រុងប្រហែល ៩០០ សិន គឺ ៣៦ គីឡូម៉ែត្រ ។

ពេលនោះ មានបំរើសេះខាងចូឆូម្នាក់ នាំយកសេចក្តីចូលទៅប្តឹង
ចូឆូ ។ ដឹងហើយក៏គិតថាភាហានអួនសៀវលើកមកគ្រានេះ ច្រើនជាង
ភាហានយើង ៩ ភាគឋ ១០ ភាគទៅទៀត ចូឆូក៏ប្រឹក្សានឹងសេនាភាហាន
តាំងពួងថា អ្នកនសៀវលើកភាហានមកច្រើនម្ល៉េះ តើអ្នកពាល់គួតិត
គតាំងឋ្វាំងដូចម្តេច ? ។ សុនហ៊ីវាឆ្លើយថា ឧឡារចង្ហុំដៃអ្នកនសៀវនោះ
ថ្វីពើយជាភាហានច្រើនយ៉ាងណា ក៏សុទ្ធតែមិនក្លៀវក្លាខ្លាំងក្លាតែប៉ុន្មាន
ភាហានយើងតិចពិតមែន តែគ្រប់ដៃវិទ្យាគារហ៊ានស្លាប់ស្លាញក្នុងការ
សង្គ្រាមខាងអស់ ទោះបីភាហានយើងតិចជាងភាហានអ្នកនសៀវនោះ ១០
ភាគក៏ដោយ បើបានតតាំងឋ្វាំងគ្នាដោយធាប់ប្រញាប់ហើយក៏មិនជា
ការអ្វី ខ្ញុំបានគិតគ្រែងតែអ្នកនសៀវខឹងបង្អង់ខុកខ្សែយូរ គេរឿងអាហារ
យើងតិច បើយូរទៅនឹងខ្វះខាត ។ ចូឆូថា "អ្នកឯងនិយាយនេះត្រូវ
ល្អណាស់ ត្រូវនឹងគំនិតរបស់យើង" ហើយចូឆូក៏គេណ្ហភាហានលើក
បញ្ជាមកពីបន្ទាយដើម្បីនឹងឋ្វាំងគ្នាខឹងអ្នកនសៀវ ។

សឹមដោយដឹងថាកងទ័ពចូឆូលើកមក ទើបជ្រុំភាហានឆ្ម ១ ម៉ឺន
ឲ្យចេញទៅតួនបង្កប់នៅក្រៅបន្ទាយសងខាងផ្លូវ ហើយដាក់គំនិតថា បើ
កាលណាបានឮសំឡេងផ្ទាំអុជជាសញ្ញាទៀង ឲ្យប្រញាប់លើកគ្នាវាយ
ខ្ជប់កងទ័ពចូឆូដែលចូលមក ។ អ្នកនសៀវឃើញសឹមដោះរៀបចំកង-
ទ័ពដូច្នោះក៏គេញចិត្តណាស់ តាំងប្រមូលភាហានលើកចេញទៅតាំង

នៅតាក្រៅបន្ទាយ លុះក្រឡេកឃើញកងទ័ពមក អ្នកនៅតែងខ្លួនពាក់គ្រោះមាសចាំងសប្បាយនឹងមាសនាំយកខៀវខាប់, គោលាំ, ហាន់បេង, អ៊ីវេង ចេញមកឈរនៅមុខតាហានធ្វើជាភ្ញៀវគ្នា ។

ឯឆ្លុះឃើញអ្នកនៅចេញមកឈរនៅមុខតាហានដូច្នោះ កំនាំទៅជួន, ខៀវលៀវ, ស៊ីហ្គុន, លីខៀន បរសេះចេញមកបញ្ជារនៅមុខតាហាន ហើយលើកសែចន្ទ្រលមុខអ្នកនៅថា តាដើមយើងបានគ្រាបទូលព្រះចៅហៀនតេឲ្យតាំងអ្នកឯងជានាម៉ឺនធំ ព្រះចៅហៀនតេក៏ទ្រង់ប្រោសព្រះរាជទាន ហេតុម្តេចបានជាអ្នកឯងប្រែចិត្តគំនិតតតក្បត់ លើកកងទ័ពមកប្រទូសព័ទ្ធក្រុងហ៊ូគោវិញ ឲ្យគាស់ព្រះទ័យព្រះចៅហៀនតេ អ្នកជាមនុស្សអកតញ្ញូឃើស ។ អ្នកនៅឮដូច្នោះក៏ធ្វើយតបថា: ខ្ញុំជាមហាឧបាជមិនមានសច្ចៈសុចរិតពិតត្រង់ តាំងធ្វើទ័ពដ៏ធំកន្ទឹក ឧកញ្ញាថាតែងដណ្តើមយកមកជាសម្បត្តិ ព្រោះសង្ឃឯកាលត្រូវអង្គុំធ្វើតាំងតុះទៅខៀត, ដែលយើងលើកកងទ័ពមកនេះ ឧឯងបានតាំងចិត្តជាក្បត់ធ្វើព្រះចៅហៀនតេក៏ឥតអន្តិមានឡើយ យើងមកនេះប្រាថ្នាតែធ្វើតំបាត់ខ្លួនឲ្យរួចនាសចេញបំពេញព្រះរាជហ្វ័យអម្ចាស់ផែនដីរបស់យើងប៉ុណ្ណោះ ព្រោះខ្លួនជាពាជសត្រូវធំ ។

x x
z

(មានត)

វចនានុក្រមសំស្ក្រឹត-ខ្មែរ

រិរ័យបណ្ឌិតោ ភិក្ខុ (ប៉ាង ខាត់)

ជំរើទនកថា

នៅប្រទេសកម្ពុជាយើង វិបុលានុក្រមសំស្ក្រឹត-ខ្មែរ តូចតាចមានទៅឡើយ គួរតែធ្វើឲ្យកើតមានឡើង ព្រោះការសិក្សាវិជ្ជាសំស្ក្រឹតនៅប្រទេសយើងចំរើនគួរសមហើយ ប៉ុន្តែតំណការនេះ៨ការៈជួនណាស់ ខ្ញុំល្បងធ្វើតាមកម្លាំងវិជ្ជារបស់ខ្ញុំលទ្ធើស ។ ខ្ញុំបានប្រគល់សំណៅនេះជូនលោកអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ សុំឲ្យលោកពិនិត្យ-វិជ្ជ កម្ពុជសុរិយោ ផ្សាយជាជំបូងក្នុង ព.ស. ២៤៩៩ ស្រាប់ ។

លោកអគ្គលេខាធិការកំពុងត្រួតត្រាដោយតែឯង ។ ខ្ញុំដឹងស្រាប់ថា ហត្ថកម្មនេះមិនវិសេសទេ តែនឹងបានជាគម្រោងផ្លូវសម្រាប់លោកអ្នកសំស្ក្រឹតទៅអនាគត បើបានកែតម្រឹមតម្រង់ហើយ មុខជានឹងបានប្រពៃពុំខាន ទុកជាប្រយោជន៍ដល់សំភ្លាតាមគ្រាន់ៗតែយើង ។

ក្នុងការនេះ ខ្ញុំបានសុំឲ្យ ត្រហ្មបណ្ឌិតោ ភិក្ខុ (អ៊ុត-អ៊ិន) សមាជិកក្រុមជំនុំប្រែព្រះត្រៃបិដក ជួយជាសហការខ្ញុំផង ព្រោះលោកពេញចិត្តក្នុងកិច្ចការនេះដែរ ។

រិរ័យតបណ្ឌិតោ ភិក្ខុ

ប.ឧ.

អ

អ៊ី ជាបច្ច័យរបស់ឈ្មោះ; និងជាគ្រាប់សេចក្តីបដិសេធថា "ទេ, មិនមែន, ពុំ, គឺ" ។ ប៉ុ. នាព្រះវិន័យ ទំនងជាពាក្យថា "នឹម" មានអក្សរ អ នៅខាងដើម (អ. ន.ម. > នឹម) ។

អ្ឫណិ៍ គុ. ដែលមិនមានចំណុល ។

អំ៉ិ ជាគុ. ចែក ។

អំ៉ិ ប៉ុ. ចំណែក, ភ្លែក ប៉ុ; ចំណែកមតិ; នាមព្រះអភិ.ឬ អំ៉ិ ចែក ។ — ភាគ ន.ប៉ុ. ការយោងទៅរួចចំណែក ។ - ភាគ្យ ស្រ., - ប្រភាគ្យ ស្រ្តី. - ប្រភាគ ន.ប៉ុ. ប្រភាគរួចចំណែក (នៃមតិ) ។ — ភាគ៍ិ គុ. ដែលមានភាពក្នុងចំណែក ឬ ក្នុងមតិ ។ - ភាគ៍ិ ក.ន. អ្នកចែករួចចំណែក ។ ភ្លែ, គុ. ដែលកើតពីចំណែក ។ - ស្ឫ ប៉ុ. ក្តួនសោ គឺមេកំណត់នៃក្តួបត្រែ (clé-notre du music) ; អំ៉ាភាគ្យ ន.ប៉ុ.. អំ៉ាភាគ្យ ប៉ុ.អវិភាគមួយចំណែក អវិភា ពាក់ព័ន្ធ, ឈ្មោះវិន្តមួយវែងគ្មានហាកវែង ។

អំ៉ិ ប៉ុ. រស្មី (នៃដើមសោម) ប្រភេទនៃសោម: ភ - ភ ន.ប៉ុ. សំពត់, ក្រឿងស្បៀងកាក់ ។ ជាល ន.ប៉ុ. បណ្តាញនៃរស្មី ។ - ជាវ ប៉ុ. "ទ្រព្រួតនូវរស្មី" ព្រះអភិ.ឬ ។ ជាវ៉ាវ ប៉ុ. ចង្កៀង, ភ្លើង ។ - ជាវ្ត ន.ប៉ុ. លោសយ្យាស្ត្រមួយបែប ។ ជាតិ ប៉ុ. "ម្ចាស់នៃរស្មី" ព្រះអភិ.ឬ ។ - ភ្ជ ប៉ុ. "អ្នកតាំងរស្មី" ព្រះអភិ.ឬ ។ មន្តិ គុ. ដែលបាត់រស្មី, ភ្លឺ ប៉ុ. ព្រះអាទិត្យ, ព្រះច័ន្ទ្រ ។ - ឋាណ ស្ត្រី. កំរងនៃរស្មី ។ - មាលិ៍ ប៉ុ. ព្រះអាទិត្យ ។ - វ័ណ "មានរស្មីជាសរ" ព្រះអាទិត្យ ។

—វិមទ ឯ. កិរិយាញ៉ាំពាំនូវរស្មី ។ — ហស្ត ឯ. "មានរស្មីដាដៃ" ព្រះអាទិត្យ ។ អត្ថាន្ត ឯ. ដាយ (សំពត់) ។

អំស ឯ. ស្មា ។ — ក្ខជ ឯ. ចង្ពួយនៃស្មា ។ — ប្ជុម្ជ ឧឯ. ដាលនៃស្មា ។ —ស្ពល ឧឯ. ពំនូកនៃស្មា, ស្មា ។

អំសល ត. ក្រអាញ, មាំ ។

អំហស៊ ឧឯ. បាប, ទោស

អកដ្ឋក ត. ដែលមិនអស់កម្ទាំត, ទ្ទាំត ។

អកណ្ឌក ត. ដែលមិនមានបន្ទាត់ការម, មិនមានសត្រូវ ឬមិនមានឧបសត្ត ។

អកណ្ឌ ត. ដែលមិនមានក, កំបុតក ។

អកទ្ទទ ត. ដែលមិនពោលមាក្រក់ ។

អកន្យា ស្ត្រី. "មិនមែនដាកញ្ញា" ភរិយា ។

អកនិម្ឋ ឯ. អកនិដ្ឋិប្រាញ ។ —ឥ ឯ. ប្រះពុទ្ធ ។ —ប ឯ. ទាម ព្រះកដាកាន់ពុទ្ធសាសនា មួយអង្ត ។

អកម្ម, អកម្ម៉ាត ត. ដែលមិនកម្រើក ។

អការ ត. ដែលមិនមានដៃ ។

អការណ ឧឯ. កិរិយាមិនត្ទ ។

អការាល ត. ដែលមិនបើកធំ ។

អការុណ ត. ដែលមិនមានការុណា ។ —ត្ថ ឧឯ. ភាវៈនៃបុគ្គល មិនមានការុណា, កំណាច ។

[illegible]

អកណ៍ គុ. ដែលមិនមានត្រចៀក; ថ្ងន់; ដែលឥតបង្ខូត, ឬ ឥតស្រៀង ។ ក, គុ. ដែលមិនមានត្រចៀក ។

អកត្រិ គុ. ដែលបុគ្គលមិនគប្បីធ្វើ ។ នបុំ. អំពើដែលបុគ្គលមិនគប្បីធ្វើ, បាបកម្ម ។

អកត្ឱ ក.ន. អ្នកមិនធ្វើ ។

អកម៌ណ្យ គុ. ដែលមិនគួរដល់កម្ម ។

អកម៌ន នបុំ. ធម្មជាតមិនមែនជាកម្ម ។ គុ. ដែលមិនមែនជាកម្ម ។ (*អកម៌*)ក គុ ដែលមិនមែនជាកម្ម (Intransitif) ។ (*អកម៌*) ក្ឱត គុ ដែលធ្វើនូវអកម្ម, ដែលមិនរស់ដើក; (*អកម៌*) ត៌ប គុ. ដែលមានអកម្មជាប្រក្រតី ។ (*អកម៌*) -ប្រាប្ត ស្ត្រី កិរិយាដល់នូវអកម្ម, កិរិយាបានទូវអកម្ម, កិរិយាបានទូវធម្មជាតមិនមែនជាត្រេតល់ណាត ។

អកម៌ន្ត គុ. ដែលមានអកម្ម, ដែលមិនមានការងារ ។

អកល គុ. ដែលមិនមែនជាបំណិត ទាំងអស់ ។

អកលង្ក គុ. ដែលមិនមានស្នៀម ។

អកលិ គុ. ដែលមិនមានជំលោះ; ដែលមិនទាស់ញា; ដែលមិនមានកំហុស ។ -ប្រសរ គុ ដែលជាដែនហួរមកនៃការមិនទាស់ទែងញា ។

អកលិត គុ. ដែលយល់មិនបាន, ដែលប្រមាណមិនបាន ។

អកលិតាត្មន គុ. (<*អកលិត+អាត្មន*) ដែលមានអាត្មន៍ប្រមាណមិនបាន ។

អកលុម គុ. ដែលមិនស្រអាប់, ភ្ជ្ជា ។

អកល្ពក គុ. ដែលមិនមានទោស; បរិសុទ្ធ ។

អកល្ពកលិត គុ. ដែលពេញដោយសេចក្តីបរិសុទ្ធិ ។

អកល្ឈ គុ. ដែលមិនត្ងរ ។

អកល្មម គុ. ដែលមិនប្រឡាក់, ស្អាត ។

អកល្យ គុ. ដែលមិនសុខ, ដែលមិនឆ្ងាំង. ឈឺ ។

អកស្មាត និ. ដោយមិនដឹងខ្លួន, ដោយមិនដឹងហេតុអ្វ ។

អកាកុ គុ. (សំឡេង) ដែលមិនឆ្ងាស់ប្លូរ ។

អកាណ្ឌ គុ. ដែលមិនមានហេតុ ។ – ឧាត បុំ. អកាណ្ឌបាត, កិរិយាធ្លាក់ដោយមិនមានហេតុ, ព្រឹត្តិការណ៍ដែលមកដល់ដោយមិនដឹងខ្លួន ។

អកាម គុ. ដែលមិនមានកាម ។ *អកាមិន* គុ. ដែលមិនមានកាម ។ –តា ស្ត្រី. ភាវៈនៃបុគ្គលមិនមានកាម; *ហត*, គុ. ដែលមិនមានកាមឡៃតបៀនហើយ, ដែលមិនមានកាម ។

អកាយស្ត បុំ. (ដិន មិនមែនដាវណ្ណៈកាយស្ត ។

អការ បុំ. អ-អក្ខរ. ។

អការក បុំ. អ្នកមិនធ្វើ ។ –ត្ត នបុំ. ភាវៈនៃបុគ្គលដាអ្នកមិនធ្វើ ។

អការណ គុ. ដែលមិនមានហេតុ ។ នបុំ. កិរិយាមិនមានហេតុ ។ –ពន្ធ បុំ. អការណេពន្ធុ; ដោតង្ស ដែលកប់រកត្ថា ។

អការុណិក គុ. ដែលមិនមានការុណា ។

អការបិណ្យ គុ. ដែលមិនអាណិត; នបុំ. កិរិយាមិនអាណិត ។

អការយិ គុ. ដែលមិនគប្បីធ្វើ ; នបុំ. កម្មតឹបុគ្គលមិនគប្បីធ្វើ.បាបកម្ម ។ - *ការណ* នបុំ.កិរិយាធ្វើនូវកម្មដែលបុគ្គលមិនគប្បីធ្វើ។ - *ការិនី* គុ. ដែលធ្វើនូវកម្ម ដែលបុគ្គលមិនគប្បីធ្វើ. ដែលធ្វើបាបកម្ម ។

អការ បុំ. ការមិនគួរ ។ - *ការ* នបុំ. ឆ្ពាតុំដ្ឋិការ។ - *ចរិយា* ស្ត្រី. កិរិយាប្រព្រឹត្តិក្នុងការមិនគួរ។ - *ឥ* ឬ *អការណ្ឌ* គុ. ដែលកើតឡសការ។ - *ម្ឋ* ឬ. អការមរណៈ, សេចក្តីស្លាប់ក្នុងការមិនគួរ ។ - *រ*ណ ស្ត្រី.អការរេណ។ - *សហ* គុ. ដែលប្រព្រឹត្តទៅក្នុងការមិនគួរ ។ - *ហ៊ីនមី* ក្រិ.វិ. ដោយឥតការគួរ, ដោយតុំមានការកំណត់ ។

អការិកមិ ក្រិ.វិ. ដោយតុំមានការកំណត់ ។

អកឺបន គុ. ដែលមិនមានកង្វល់, ក្រីក្រ ។ - *ត្ត* នបុំ. *ភាវៈ*ខៃបុគ្គលមិនមានកង្វល់, សេចក្តីក្រីក្រ ។

អកឺបិទិ និ. មិនមានអ្វី, មិនមានអ្វីមួយ ។ - *ការ* គុ. ដែលឥតធ្វើអ្វី, ដែលឥតបានប្រយោជន៍អ្វី. ឥតអំណាច ។

អកិល្ពិម **អកិល្ពិមី** គុ. ដែលឥតឡស ។

អកីតិន នបុំ. កិរិយាមិនមានគ្រឿងសំតាល់, កិរិយាមិនមានគ្រឿងសរសើរ ។

អកីតិ ស្ត្រី. កិរិយាមិនមានកិត្តិគុណ, សេចក្តីឆ្មាស ។ - *ការ* គុ. ដែលធ្វើនូវសេចក្តីឆ្មាស។

អកីតិត គុ. ដែលមិនមានគ្រឿងសំពាល់ ។

អកុក គុ. ដែលមិនអាចកាន់យកបាន ។

អកុដិល គុ. ដែលមិនរៀប, ត្រង់ ។

អកុណ្ឌ, អកុណ្ឌិត គុ. ដែលមិនសឹក, ដែលមិនរៀបរៀល, ដែលមិនតុះត់នឹត, ដែលមាំមួន, ដែលឱ្ចាំង ។

អកុតលិ នៃ. ក្នុង.....ណាទេ ។ *អកុតត្ថិទ្ធយ* គុ. ដែលតតមានភ័យក្នុងទីណាទេ; *អកុតោ-ភយ* គុ. ដែលតតភ័យក្នុងទីណាទេ ។ *អកុតោមុខ* គុ. ដែលមានមុខបែរក្រោយ ។ *អកុតោម្ឆ្ចត្ស* គុ. ដែលមិនមានម្ឆ្ចត្សក្នុងទីណាទេ ។

អកុត្របភយ គុ. ដែលតតមានភ័យពីទីណាទេ ។

អកុត្សិត គុ. ដែលតតបន្ទោស ។

អកុប្ស គុ. ដែលមិនតប្ស៊ក្រោធ ។

អកុប្ស នបុំ. លោហធាតុដែត; មាស, ប្រាក់ ។

អកុល គុ. ដែលមានត្រកូលមិនមាន, ដែលថោកទាប ។ *អកុលិនី* គុ. ដែលថោកទាប ។ — *តា* ស្ត្រី. ការៈនៃដនមានត្រកូលមិនមាន, ត្រកូលថោកទាប ។

អកុឆល គុ. អកុសល, ដែលមិនឈ្មាស ។ នបុំ. អកុសល ។

អកុសុមិត គុ. ដែលមិនផ្តា, ដែលមិនរីកផ្តា ។

អកុហ គុ. ដែលមិនកុហក ។



ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ២៩ លេខ ២ ខែកុម្ភៈ ព.ស. ២៤៩៩ គ.ស. ១៩៥៥





ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ
បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បញ្ជីរឿង	ទំព័រ
–	ជាបាដាំរឿងពុទ្ធសាសនានៅប្រទេសកម្ពុជា	លោកសេ-ញាណ ... ១០៣
–	តំណាន់បដ្ឋានកថា .. (តចប់)	ព្រះភិក្ខុ ប៉ាង-ខាត់ ... ១០៩
–	ប្រហ្មលទ្ធិកប់អានន្ទោចរិសាច (តចប់)	ឃុនបណ្ណាគុរ័ក្ស ប៊ូ-ប៉ូ .. ១១៦
ផ្នែកអក្សរសាស្ត្រ		
–	ភាសិតខ្មែរ	លោកខៀង-ថៃឈុន .. ១២២
–	សារតារនាងហ៊ុនដាកិ . (តចប់)	លោក អ៊ុំ-ហ៊ី ប្រែ .. ១២៩
–	រឿងទេវនួរបសលោតអម្រឹតឈ្មត្រ្តីម៉ុក	លោកញ៉ុក-ថែម តិនត្ថ . ១៤៤
–	សុភាសិតប្រជើជិនប្រុសស្រី (តមក)	ព្រះឃោសនន្ទ ម៉ុង-សែស . ១៥២
–	ពេជ្រព្រះភជា (តមក)	លោក ស៊ុង-ហ៊ាង ប្រែ .. ១៦៣
–	រឿងសាមកុក (តមក)	ឧកញ៉ា ន្ហូ-កន ប្រែ .. ១៦៩
កំណាត់ប្រវត្តិការណ៍		
–	តិធីបុណ្យកឋិនរបស់ទីតាំងកោះសម្តេចព្រះធម្មលិខិត ទត្តមប្រឹក្សា ល្វី-ឯម របស់សមណៈនិស្សិត	លោកឯន-ប៊ិង . ១៧៨
–	ដំណើរទៅកាន់ប្រទេសនិល្លៀនៃលោក ភ័យ-ប៊ុក	លោកភ័យ-ប៊ុក ១៨៨
–	វចនានុក្រមសំស្ក្រឹតខ្មែរ . (តមក).	រិរិយបណ្ឌិតោ ភិក្ខុ ប៉ាង-ខាត់ . ១៩៦

មួយឆ្នាំមាន ១២លៀវកៅ–ជំនៀតាវ ៣០រ៉ៀល

KAMBUJASURIYA

Revue religieuse et littéraire éditée par
l'Institut Bouddhique

TABLE DES MATIÉRES

PARTIE RELIGIEUSE:

-Causerie sur le bouddhisme au Camboge . . . par *M. SAM-NHEAN*. 103
-Gilanupatthanakatha (suite et fin) . . . . . par vén. *PANG-KHAT*.109
-Les diables (suite et fin) . . . . . par *M*. . . . *BOU-PO* . . .116

PARTIE LITTERAIRE:

-Recueils de proverbes Khmers . . . par *M. TIANG-TAY-CHHUN*. .122
-Histoire de Jeanne d'Arc (en vers) suite et fin . . . par *M. OUM-HY* . . .129
-Histoire de Devanda de *M. MOK*,
revue et corrigée . . . . . par *M. NHOC-THEM*.144
-Bons Conseils . . . . . par vén. *MŒUNG-SES* .152
-Conte "*LE DIAMANT DE RAJA*" (suite) traduit par *M. SIN-HEAN* 163
-Histoire de samkok (suite) . . . . . traduit par *M. NOU-KAN* . . 169

NOTES ET CHRONIQUES:

-Fête de reconnaissance des disciples en l'honneur
de Samdach Dhammalikhita *LOUIS-EM* . . . par *M. EN-PANG*. 178
-Voyage en Inde de *M. RAY-BUC* . . . . . par *M. RAY-BUC* . 188
-Dictionnaire Sanskrit - Khmer (suite) . . . par vén. *PANG-KHAT* . . . 196

Prix d'abonnement annuel (comprenant 12 numéros): 230$00

ថ្លែងការ

ទាបភកជារឿងពុទ្ធសាសនាទៅប្រទេសកម្ពុជា

លោក សម.ញាណ ដែលបានទៅជាអ្នកសង្កេតការណ៍ឯកជន

ក្នុងកំឡុងមុខសញ្ញាសង្គ្រាមពុទ្ធសករាជ ២៤៩៤ នៅប្រទេសវៀតណាម
បានថ្លែងព្រះធម្មទេសនានេះនៅថ្ងៃទី ៣ ខែកក្កដា ឆ្នាំ ១៩៥០ ក្នុង វិស្សាល័យធំមួយ
ក្នុងចំណោមមហាវិស្សាល័យទាំងប្រាំពីរ មានសេចក្តីដូចតទៅនេះ :-

លោកចាន់ហ្វាន ! អស់លោកជាសិស្សក្នុងសិស្សទាំងឡាយ !

ពេលនេះ ខ្ញុំមានគំនិតយ៉ាងស្លន់ ដោយបានទទួលសេចក្តីសុំអំពីអស់លោកឲ្យខ្ញុំមកថ្លែងធម្មទេសនានៅវិទ្យាល័យនេះ ។

ខ្ញុំមានអំណរយ៉ាងក្រៃលែងចំពោះលោកចាន់ហ្វាន និងអស់លោកជាសិស្សានុសិស្ស ដែលបានអញ្ជើញមកជួបជុំជាគំនិតយស ដើម្បីស្តាប់នូវធម្មទេសនារបស់ខ្ញុំនេះ ។

មុននឹងថ្លែង ខ្ញុំសូមគោរពជំរាបអំពីប្រវត្តិខ្លួនខ្ញុំសិន ខ្ញុំនេះជាន:ជាប្រធានពុទ្ធិកសមាគមកម្ពុជាផ្ទៃ ហើយជាអនុប្រធានក្រុមប្រឹក្សាព្រះពុទ្ធសាសនាចក្រនៃប្រទេសកម្ពុជាផង ប៉ុន្តែដល់ខ្ញុំធ្វើដំណើរមកកាន់មហាប្រទេសវៀតណាមនេះក្តី មកថ្លែងធម្មទេសនានេះក្តី ឥតមានតាន តាមជាន:ណាមួយឡើយនេះទេ គឺមកក្នុងជាន:ជាឯកជន ។

ខ្លួនខ្ញុំនឹងព្រះមហា.ឋេរៈ ព្រមទាំងអស់លោកដែលមិនទាន់អញ្ជើញមកជាមួយនេះ គឺជាតំណែរ ។ ជនជាតិខ្មែរនឹងជនជាតិវៀតណាមយើងគ្នាតាំង

ពីយូរណាស់មកហើយ ។ តាមពត្សាវតារបាមានក្សត្រអង្គមួយព្រះនាម
កោណ្ឌាញ្ញៈ ទ្រង់យាងចេញពីមហាប្រទេសឥណ្ឌានេះទៅកាន់ជ្រោយ
សុវណ្ណភូមិ . . . ត្រានោះព្រះអង្គមានជ័យជំនះបានសោយរាជសម្បត្តិជា
បឋមវង្សវ្ទៃ ទ្រង់ព្រះនាម ព្រះបាទកុមេរុ ខ្ទះហៅ ព្រះបោង
ព្រះអង្គនោះហើយជាមហាក្សត្រទី ១ នៃប្រទេសកម្ពុជា ។

ប្រជាជនវ្ទៃទុកជនជាតិឥណ្ឌាជារៀមច្បង ដោយព្រះមហាក្សត្រ
ទី ១របស់វ្ទៃ ទ្រង់យាងចេញពីមហាប្រទេសនេះទៅ ហើយមហាប្រទេស
នេះជាដើមកំណើតនៃពុទ្ធសាសនា ព្រោះព្រះសម្មាសម្ពុទ្ធទ្រង់បានឧបត្តិ
ឡើងក្នុងមហាប្រទេសនេះ ។

ហេតុដែលនាំឲ្យយ្ងាតការប្រាស្រ័យទាក់ទងគ្នាជាយូរអង្វែងគ្នាំ
ព្រោះមានមហាអំណាចមកសង្កត់សង្កិនប្រទេសយើងទាំងពីរ ។ ឥឡូវនេះ
ជាសម័យសករាជថ្មីនៃប្រទេសយើងបានឯករាជ្យ.រដ្ឋាភិបាលយើងទាំងពីរ
បានទាក់ទងគ្នាជាថ្មីឡើយវិញ រវាងវប្បធម៌, សេដ្ឋកិច្ច នឹង ពុទ្ធសាសនា
តាំងនៅជាអព្យាក្រិត កាន់វិន័យបញ្ចសីលាជូចគ្នា ទាំងនេះជាលទ្ធផល
យ៉ាងប្រៈសីរក្រៃលែង ចំពោះប្រទេសយើងទាំងពីរ ។

ខ្ញុំមានរាសនាល្អបានមកតោរពបុណ្យពុទ្ធជយន្តិក្នុងមហាប្រទេសនេះ,
បុណ្យនេះប្រទេសវ្ទៃ ក៏ប្រុងធ្វើនៅគ្នាំក្រោយដែរ ព្រោះប្រជាជនវ្ទៃ
និយមរាប់អានពុទ្ធសាសនាណាស់ ។

ប្រទេសវ្ទៃមានប្រជាជនតែប្រាំមួយលាននាក់ទេ ប៉ុន្តែមានតែអារាម

២.៧០០ វត្ត មានលោកសង្ឃជាង ៧ ម៉ឺនអគ្គ, វត្តចាំឆ្នាយនោះគេពុក
ដូចជាសាលារៀន ហើយលោកសង្ឃឆ្លើជាគ្រូបង្រៀនអក្សរសាស្ត្រផង។
មានលោកអគ្គខ្លះស្ទាវស្ទង់រៀនចំណេះវិជ្ជាខាងពុទ្ធសាសនា មាន
តួយ៉ាងដូច

– លោកគិក្ខុ គួច-គិ.ឡេង ចិតប្បញ្ញា មកនៅរៀនកងវិទ្យាល័យ
គិនោរីមល់នេះ;

– លោកអគ្គខ្លះនៅរៀនឯនាលន្ទា, អគ្គខ្លះនៅរៀនឯសន្តិនិកេតន៍
សព្វថ្ងៃនេះស្រាប់ ។

មានជនខ្លះដែរ គេឆ្ងល់ថាការរកប់អានពុទ្ធសាសនាដូច្នេះតើមាន
ប្រយោជន៍អ្វី ?

ខ្ញុំសូមឆ្លើយថាបានថា បើប្រតិបត្តិតាមទុកពុទ្ធសាសនា ដែលមិនតឹង
ពេក មិនធូរពេក ទីនឹងមានប្រយោជន៍នៅនាលោកិយនេះផង ទៅបរលោក
នាយផង ព្រោះទុកពុទ្ធសាសនាតែងតែខ្ជួនប្តូរសន្តឹងាំឆ្នាយ ឲ្យលះ
បង់នូវសេចក្តីទុក្ខលំបាកបាន ហើយទំនាយឃាមប្រកបកិច្ចការខ្លឹង
ព្រោះសេចក្តីទុក្ខលំបាកមានក្រក់នាំឲ្យមនុស្សយើងខ្លះអន់ចិត្តយ៉ាងធំ
បំផុត ដូចមានន័យថា:

– កាលបើទុក្ខលំបាក តើនឹងមានចំណេះ (បំណុះ) ឥណាៗ

– កាលបើគ្មានចំណេះ (សិល្បៈ) ហើយ តើនឹងរកត្រូវសម្បត្តិ
ឯណាបាន ?

– កាលបើគ្មានត្រូវសម្បត្តិហើយ ម្តេចរៀបចំរឿងការតែ

មិត្តឯណាមកវាប់អានខ្ជូន ?

· កាលបើគ្មានញ្ញាតិមិត្តហើយ តើសេចក្តីសុខនឹងមានពីណាមកដល់ខ្ជូន ? ។ល។

ការខូចប្រយោជន៍ទាំងនេះព្រោះអ្វី? ព្រោះតែខ្ជិលនេះឯង ហេតុនេះហើយ ឥវាទពុទ្ធសាសនាទូន្មានឲ្យលះបង់នូវសេចក្តីខ្ជិលចេញ ហើយឲ្យតាំងចិត្តឧស្សាហ៍រៀនចំណេះជ្សង ។ (សិល្សៈ) ។ល។ ទើបមានប្រយោជន៍នៅនាលោកកីយនេះ ។

ម្យ៉ាងទៀត ឥវាទពុទ្ធសាសនាទូន្មានឲ្យបានប្រយោជន៍ទៅខាងបរលោកនាយផង ទៅនាលោកកីយនេះផង សឹងមានន័យហ៉ាងខ្ជី ៣ គ្នាថា

១- កុំធ្វើអំពើអាក្រក់ (បាប),

២- ឲ្យធ្វើតែអំពើល្អ (បុណ្យ),

៣- ធ្វើចិត្តឲ្យស្អាតសុចរិតល្អ ។

អធិប្បាយសារុប

មនុស្សយើង ត្រូវញ្ញុំងកាយវាចាចិត្ត ឲ្យប្រកបតាមសីលធម៌ ឲ្យមានមេត្តាករុណាដល់មនុស្សនឹងសត្វទ្ជូទៅ ទើបសមនឹងថានៈខ្ជូនជាមនុស្សជាតិ ។ កាលបើយើងចង់បានសុខ ត្រូវយើងកុំបៀតបៀនគេប៉ុណ្ណេះជាដើម ។ ឥវាទពុទ្ធសាសនាយ៉ាងខ្ជីនេះ បើប្រៀបផ្ទឹមនឹងវិន័យបញ្ជាសីលា ដែលមហាប្រទេសនេះនឹងប្រទេសនានាបានប្រកាសនៅក្រុងបានឌុងនោះ មានន័យស្របគ្នា; កាលបើប្រតិបត្តិតាមហើយ សេក្តីសុខ

សន្តិភាពសឹងមានដល់សត្វលោក នៅទាំលោកិយនេះផង ទៅមុខរាលោក
នាយផងដែរដោយពិត ។

ថ្វីបើឱកាសពុទ្ធសាសនាខាងលើនេះមានដំណើរកន្លងទៅ២.៩០០ ឆ្នាំ
ហើយ ក៏នៅតែមានវេជ្ជាតិយ៉ាងប្រសើរ ជាហេតុនាំឲ្យប្រជាជនប្រើន
ប្រទេសនឹករលឹកចំពោះព្រះមហាករុណាគុណ នៃព្រះសម្មាព្រះសម្ពុទ្ធ
បាននាំគ្នាមកគោរពបុណ្យពុទ្ធជយន្តិ ដែលរដ្ឋាភិបាលមហាប្រទេសនេះ
ផ្តើមធ្វើយ៉ាងទន្ទឹកទន្ទាក់ ។

លោកចាង! លោកគង់បានជ្រាបហើយថា ពិភពលោក
សព្វថ្ងៃនេះ នៅតែធ្លុំក្តួនរំសេវ នៅតែឮ ឃ្លាំកូរឆ៍បៀតបៀនគ្នា, អំពើនេះ
កើតឡើងដោយអំណាចចិត្តមានលោភៈ ទោសៈ មោហៈ, អ្នកដែលចូល
ចិត្តធ្វើអំពើនេះ ប្រហែលមកពីមិនយល់ឱកាសពុទ្ធសាសនា ឬក៏យល់ដែរ
ប៉ុន្តែមិនព្រមប្រតិបត្តិតាម ។

ក្តីនាមជូលខ្ញុំ ។ សូមគោរព សូមពរ អំពាលោកជា
សាស្ត្រាចារ្យនាខ្មែលយ័យនេះ ព្រមទាំងអស់លោកជាសាស្ត្រាចារ្យនៅ
ខ្មែលយ័យនានាខ្លះៗ, ខ្ញុំសូមឲ្យលោកលៃលកកេងកេរ្តិ៍ឈ្មោះដ៏ថ្លៃថ្លាមកម្ម
ដែលបង្រៀនឲ្យសិស្សានុសិស្សទាំងឡាយឲ្យចេះធ្វើចិត្តឲ្យស្អាតសុចរិតល្អ
តាមឱកាសពុទ្ធសាសនាផង ។ បើបានតាមសុំនេះ សង្ឃឹមថាយូរដងយូរតី
ជាសិស្សានុសិស្សទាំងឡាយ កាលបើចេញពីសាលារៀនទៅនឹងណែនាំ
ប្រជាជាតិមិនឲ្យបៀតបៀនគ្នា កាលបើធ្វើបានដូចេះ សេចក្តីសុខ,
សន្តិភាព ក្តីពិភពលោកនឹងកើតមានដោយពិត ។

មុននឹងបញ្ចប់ខ្ញុំសូមបួងសួងចំពោះគុណព្រះរតនត្រ័យ:

-សូមឲ្យសត្វលោករស់នៅជាសុខសាន្ត!

-សូមឲ្យរដ្ឋាភិបាលនៃមហាប្រទេសឥណ្ឌ្រា ព្រមទាំងប្រជាជនជាតិ ឥណ្ឌ្រាបានប្រកបដោយនូវសេចក្តីសុខសេចក្តីចំរើន!

-សូមឲ្យអស់លោកជាសាស្ត្រាចារ្យ ហ៉ើយនឹងសិស្សានុសិស្ស ទាំងឡាយបានប្រកបដោយអាយុ: វណ្ណ: សុខ: ពល: តរៀងទៅ កុំបីឃ្លៀងឃ្លាតឡើយ !

× ×

×

បន្ទាប់ពីថ្ងៃងសុន្ទរកថាជាភាសាខ្មែរនេះចប់ហ៉ើយ, ព្រះមហាគួច-គី-ឡេង ថិតប្យញ្ញោ ជាសមណៈនិស្សិតខ្មែរដែលនៅសិក្សាក្នុងវិទ្យាល័យ តិនោរីមល់នោះ បានប្រែពីភាសាខ្មែរទៅជាភាសាអង់គ្លេស នាំឲ្យអស់ លោកជាសាស្ត្រាចារ្យ ព្រមទាំងសិស្សានុសិស្ស ទាំងឡាយទះដៃអបអរជា ច្រើនលើក ។

អិណាឧបឡាឧអមា

វិយបណ្ឌិតោ (ប៉ាង-ខាត់)

ត–ចប់

បើតតីព្រះសង្ឆហើយ ព្រះធម៌គឺពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ដែលនាំឲ្យយើងស្គាល់ទុសត្រូវ ល្អអាក្រក់ ស្គាល់គុណទោស ស្គាល់ផ្ទូវទៅរកសិវដ្ឋានក៏សាបសូន្យទៅដែរ យើងមានតែក្តីងលោភ: ទោស: មោហ: មកដឹកនាំចិត្តយើង យើងមានតែកិលេសគ្រប់គ្រងចិត្ត កើតទៅជាកិលេសគ្រប់គ្រងលោក កាលបើកិលេសគ្រប់គ្រងលោកហើយ លោកនេះនឹងទៅជាក្តីងប្រល័យកល្បធេះមិនខាន ព្រោះយើងមិនមានព្រះធម៌ គឺព្រះធម៌ដែលដឹកនាំចិត្តយើង ឬមិនមានព្រះធម៌ដែលគ្រប់គ្រងលោក ទុកជូចជាគ្មានទឹកអម្រឹតជួយរំលត់ក្តីងសោះ ។

ហេតុនេះ ការទំនុកបម្រុងបច្ច័យ ៤ ចំពោះព្រះសង្ឆដើម្បីឲ្យព្រះសង្ឆរស់នៅបាន ជាកិច្ចមួយប្រសើរណាស់ ឈ្មោះថា យើងជួយមនុស្សលោកទាំងឲ្យលោករស់នៅក្នុងសន្តិភាព ដោយទ្រព្យបន្តិចបន្ពួចរបស់យើង ។ ទ្រព្យក្នុងទីនេះមាន ៤ ប្រការ គឺទ្រព្យខាងក្រៅ ១ ទ្រព្យខាងក្នុង ១ ។

ទ្រព្យខាងក្រៅ ចែកជា ៤ ប្រការ គឺទ្រព្យចំពោះ ១ ទ្រព្យមិនចំពោះ ១, ឯទ្រព្យខាងក្នុងក៏ចែកជា ៤ ប្រការដែរ គឺ អង្គសមទ្រព្យ ១ អនុគាមិកទ្រព្យ ១ ។

ទ្រព្យបំពោះ.- ទ្រព្យណាសម្រាប់លៀងដើរតឲ្យប្រព្រឹត្តទៅ ដូចគ្រឿងស្លៀកតាក់អាហារ និវេសនៈ ថ្នាំកែរោគ ទ្រព្យនោះឈ្មោះថា ទ្រព្យបំពោះ ជាទ្រព្យចាំបាច់ធំធាន តុំបាន ។

ទ្រព្យមិនបំពោះ.- ទ្រព្យណាដែលគ្រាន់តែជាគ្រឿងឧបភោគតែលោកទិយមថាជាទ្រព្យមានតម្លៃវិសេសវិសាលបំផុត ដូចមាសប្រាក់ពេជ្រ ទិលវិន្ទា ទ្រព្យនេះលោកឲ្យឈ្មោះថាជា ទ្រព្យមិនបំពោះ ព្រោះទ្រព្យទាំងអស់នេះ មិនអាចបំបាត់ទុក្ខវេទនាដែលកើតពីស្រេកឃ្លានបានទេ យើងរឿរលែងខាតក៏បានដែរ មិនមែនជាគ្រឿងចាំបាច់លៀងដើរតឹង មានក៏មិនជាត់អត់ក៏មិនស្លុតដែរ ។

ទ្រព្យដោយចំពោះនឹងទ្រព្យមិនចំពោះទាំងពីរប្រការនេះ លោកឲ្យឈ្មោះថាជា ទ្រព្យខាងក្រៅ ព្រោះនៅខាងក្រៅពីខ្លួនយើង នឹងកើតមានបានដោយកាលស្វែរកពីខាងក្រៅ មានបានមកប៉ុន្មាន ក៏ត្រូវអស់ទៅវិញដោយកាលជាយវ័យខ្លះដោយអន្តរាយខ្លះ ដោយបាត់បែកខ្លះ ដោយហេតុផ្សេងៗខ្លះ បើទុកជារកបានមកច្រើនប៉ុន្មានក៏បានប្រើតែមួយដងតែ កាលណាយើងស្លាប់ទៅវិញទ្រព្យទាំងនោះក៏ធ្លាក់ទៅជារបស់អ្នកដទៃ ។ ទ្រព្យខាងក្រៅនេះ បើយើងចេះប្រើ ទើបទៅជាគុណ បើយើងមិនចេះប្រើ តឹប្រើក្នុងផ្លូវទុស ក៏ទៅជាទោសបំផ្លាញអ្នកម្ចាស់ទ្រព្យខ្លួនឯងវិញ ដូចជាយលេងប្រមើលស្រា បៀចោ អាកៀន កញ្ឆា

ជាដើម ឬជួនកាលក៏អាចនាំអន្តរាយមកឱ្យខ្លួនវិញដូចជាវប្ញន៍គាប់សម្លាប់អ្នកម្ចាស់ទ្រព្យជាដើម ។

ឯ ទ្រព្យខាងក្នុង ចាន់ដល់សេចក្តីល្អ ហៅតាមវោហារពុទ្ធសាសនាថាអរិយទ្រព្យ ។ អរិយទ្រព្យនេះចែកជា២ប្រការគឺ អង្គសមទ្រព្យ១ អនុត្តរិយទ្រព្យ១ ។

អង្គសមទ្រព្យ.— ទ្រព្យដែលជាចំណែកមួយស្មើដោយកាយ ចាន់ដល់ការចេះដឹងចំណេះវិជ្ជា សមត្ថភាពអធ្យាស្រ័យល្អ, សេចក្តីល្អទាំងនេះ ការបើយើងចាត់ទុកថាជាទ្រព្យកើតមានក្នុងខ្លួនយើងហើយ តែងជាប់ទៅជាមួយនឹងខ្លួនយើងរហូតដល់ស្លាប់ចាត់បង់ទៅវិញ អ្នកណាមកដណ្តើមយកមិនបានគាត់ឆ្ងាមិនបានមិនចេះរលែងលះទៅវិញ ប្រើប្រាស់ច្រើនឡើងក៏អស់តែតែចំរើនច្រើនឡើង ការបែកាយបែកធ្លាយទៅវិញក៏លះគ្នាទៅមួយអន្លើដោយដាច់តែដូចអវយវៈកាយផ្សេង ។ របស់យើងដែរ ទ្រព្យនេះ ហៅថា អង្គសមទ្រព្យ ។

អនុត្តរិយទ្រព្យ.— ទ្រព្យដែលជួនយើងទៅ គឺទ្រព្យណាមួយដែលយើងបានធ្វើឱ្យកើតមានក្នុងខ្លួនយើងហើយ ឱ្យផលមកដល់យើងក្នុងជាតិនេះនឹងជាតិទៅមុខបើពុំក្នុងជាយើងរលត់ទន្ទៅវិញ ក៏នៅតែជាប់ជិតតាមខ្លួនយើងទៅជួយឧបត្ថម្ភយើងឱ្យកើតក្នុងភពខាងមុខ បរិបូណ៌ដោយសេចក្តីសុខចំរើនគ្រប់ប្រការទៅ ចាន់ដល់គុណធម៌ដ៏ប្រសើរដូចសទ្ធា សីល បញ្ញា ទានកុសលកម្មជាដើម លោកហៅថា អនុត្តរិយទ្រព្យ ។

តរិយទ្រព្យនេះ ជាទ្រព្យសម្បត្តិយើងពិតប្រាកដព្រោះជាប់ទៅជាមួយអ្នកធ្វើ ហើយទាំងសមកឲ្យអ្នកធ្វើនោះរឿយ ។ ទៅមិនបានតាមសន្ទុកយកបាត់បង់ទៅវិញទេ បោះលួចយកមិនបាន មិនទៅជាប្រយោជន៍ដល់ខ្លួនដទៃ អ្នកណាជះណ្តើមយកមិនបាន ហើយមានតំណាចជួនយើងទៅឲ្យកើតកុសគតភពខ្ពស់ៗ បានសុខចំរើនវែមទៀត ។

មន្ទីរពេទ្យព្រះសង្ឃនេះទ្រទ្រង់ទៅបាន ក៏ដោយការអស្រ័យទ្រព្យ ៣ ប្រការ ដូចពោលមកហើយរបស់ពុទ្ធសាសនិកជនទាំងឡាយទាំងឋាវរដ៏តទាំងគ្រហស្ថ ។ លោកសប្បុរសទាំងឡាយដែលបានបរិច្ចាគធនធានទុនកបម្រុងមន្ទីរពេទ្យព្យាបាលព្រះសង្ឃនេះ ក៏ហាក់ដូចជាបានបំរើព្រះសម្មាសម្ពុទ្ធ ស្មើដូចពុទ្ធភាសិតថា:

យោ តិកិច្ឆេ ឧបដ្ឋហេយ្យ, សោ តិណាទំ ឧបដ្ឋហេយ្យ ប្រែថា "ម្នាលភិក្ខុទាំងឡាយ! អ្នកណាមួយគប្បីបំរើតថាគតយ៉ាងណា អ្នកនោះក៏គប្បីបំរើភិក្ខុឈឺយ៉ាងនោះដែរ" ។

ពុទ្ធភាសិតនេះ បានសេចក្តីថា បំរើភិក្ខុសាមណេរដែលមានពេគាពាធដោយការខំទុកបំរុងបច្ច័យទាំង ៤ ប្រការគឺ ចីវរប្បច្ច័យ បិណ្ឌបាតប្បច្ច័យ សេនាសនប្បច្ច័យ ទីឆ៌តិលានភេសជ្ជប្បច្ច័យ ទីឆ៌បានគាទិសង្ឃប្រាកដដូចបំរើព្រះសម្មាសម្ពុទ្ធយ៉ាងនោះដែរ ។ ការបំពេញកុសលកុន្តថ្ងៃនេះ មានបំណងតែមួយគឺជួយទប្តម្ភមន្ទីរពេទ្យព្យាបាលព្រះសង្ឃនេះឲ្យប្រព្រឹត្តទៅដោយប្រពៃ ដោយការស្រ័យទឹកចិត្តប្រកបដោយសទ្ធាមេត្តា ករុណា របស់លោកសប្បុរសទាំងឡាយ លោកសប្បុរសទាំង

ឡាយដែលបានបំពេញកុសលដ៏ប្រពៃ គឺបានលះបង់កម្ចាំងកាយកម្ចាំង
ចិត្ត កម្ចាំងទ្រព្យ កសាងមន្ទីរពេទ្យព្រះសង្ឆនេះក្តី បរិប្ចាគធនធាន
ទំនុកបំរុងបច្ច័យ៤រាល់ថ្ងៃ រាល់ខ្ទិ រាល់ឆ្នាំក្តី ដល់មន្ទីរពេទ្យព្រះសង្ឆនេះ
ក្តី ឈ្មោះថារួមសាមគ្គីធម៌បំពេញកុសលមួយដ៏ធំពិសេសពិសាល ជួយធ្វើ
ការជាប្រយោជន៍បំបាត់ទុក្ខវេទនាព្រះសង្ឆដែលកើតពីរោគាពាធ ឈ្មោះ
ថាឲ្យអាយុជីវិត ឲ្យអនាម័យគឺមិនមានរោគ ឲ្យពណិសម្ឆុរ ឲ្យកម្ចាំង ឲ្យ
សេចក្តីសុខ ឲ្យសេចក្តីចំរើន ឲ្យព្រះនិព្វានដល់ភិក្ខុសាមណេរទាំងឡាយ
ក្នុងពុទ្ធសាសនា ។ ភិក្ខុសាមណេរទាំងឡាយដែលបានទទួលសេចក្តី
អនុគ្រោះពីលោកសប្ឆុរសទាំងឡាយ ហើយមិនមានទុក្ខវេទនា មិនមាន
រោគ សុខសប្ឆាយ មានរាងកាយមាំមួនមានកម្ចាំង មានសុខភាពបរិបូណិ
ជាទកាសប្រពៃនឹងបំពេញព្រហ្មចរិយធម៌ រឿនសូត្រព្រះពុទ្ធវចនៈ ជា
អ្នកចេះដឹងព្រះពុទ្ធវចនៈច្រើន យល់ច្បាស់នូវធម៌ព្រះសម្មាសម្ពុទ្ធ នឹង
ប្រតិបត្តិធម្មវិន័យឲ្យពេញបរិបូណិជូចស័ន្ធដែលបុគ្គលខាត់ហើយ ដោយ
ប្រពៃជូច្នោះឯង ហើយនឹងសាបព្រួសពូជសម្មាទិដ្ឋិឲ្យផ្សាយទូទៅដល់
សត្វលោកទាំងមូល ឲ្យស្គាល់ខុសត្រូវ ស្គាល់ល្អអាក្រក់ ស្គាល់គុណ
ទោស ស្គាល់ផ្លូវទៅកាន់ឋានសួគិ ឋាននិព្វាន កើតសេចក្តីសុខ ចំរើន
កើតសន្តិភាពពេញសកលលោកដែលសត្វលោកប្រាថ្នាត្រប់គ្នា ហេតុ
នេះហើយបានជាព្រះសម្មាសម្ពុទ្ធត្រាស់ទេសនាទុកថា អរោគា បរមា
លាភា "ការមិនមានរោគ ជាបរមលាភ" ។ អ្នកដែលបានឲ្យជីវិត ឲ្យ
អនាម័យ ឲ្យសេចក្តីសុខសេចក្តីចំរើនដល់ជនដទៃ ឈ្មោះថាបានឲ្យ

របស់ប្រសើរដ៏លើស ដែលជាកំពូលសេចក្ដីប្រាថ្នាទាំងពួងដល់ជនដទៃ ហើយនឹងត្រូវបានរបស់ប្រសើរលើសមកវិញ សមដូចពុទ្ធភាសិតថា

អក្ដធាយ វរធាយ សេដ្ឋធាយ ច យោ ឧភ
ឌីឃាយុ យសវា ហោតិ យត្ថ យត្ថូបបជ្ជតិ

"នរជនណាដែលឲ្យរបស់ដ៏លើស ឲ្យរបស់ដែលគួរប្រាថ្នា ឲ្យរបស់ដែលប្រសើរ នឹងត្រូវបានរបស់ប្រសើរវិញ គឺមានអាយុវែង មានយសបរិវារក្នុងភពដែលខ្លួនកើតហើយ" ។

អក្ដតោ វ៉ បសន្នានំ អក្ដំ ធម្មំ វិជានតំ
អក្ដេ ពុទ្ធេ បសន្នានំ ឧក្ដិណោយ្យេ អនុត្តរេ
អក្ដេ ធម្មេ បសន្នានំ វិរាគូបសមេ សុខេ
អក្ដេ សង្ឆេ បសន្នានំ បុញ្ញក្ខេត្តេ អនុត្តរេ

"អ្នកចេះដឹងធមិដ៏ប្រសើរ នែងជ្រះថ្នាក្នុងវត្ថុដ៏ប្រសើរពោលគឺជ្រះថ្នាក្នុងព្រះពុទ្ធជាបុគ្គលប្រសើរលើសលប់ ជាទក្ខិណេយ្យបុគ្គលមិនមានបុគ្គលណាប្រៀបបាន, ជ្រះថ្នាក្នុងព្រះធមិដ៏ប្រសើរ ជាធមិរម្ងាប់បង់នូវរាគាទិកិលេស ជាធមិឲ្យសេចក្ដីសុខ, ជ្រះថ្នាក្នុងព្រះសង្ឆដ៏ប្រសើរ ជាស្រែបុណ្យរកស្រែបុណ្យឯទៀតក្រៃលែងជាងគ្មាន" ។ អ្នកដែលបានឲ្យទានដ៏ប្រសើរដល់បុគ្គលប្រសើរប្រាកដដូច្នេះ នែងចំរើនដោយបុណ្យដ៏ប្រសើរផង ដោយអាយុដ៏ប្រសើរផង ដោយសម្បុរកាយដ៏ប្រសើរផង ដោយកេរ្ដ៍ឈ្មោះដ៏ប្រសើរផង ដោយសេចក្ដីសុខដ៏ប្រសើរផង ដោយកម្ចាំងកាយដ៏ប្រសើរផង ។ អ្នកដែលមានប្រាជ្ញា បានដម្ពល់ខ្លួនក្នុង

ធមិដ៏ប្រសីរហើយតែងឲ្យពានដល់បុគ្គលប្រសើរយ៉ាងនេះឯង ពោះពៅ
កើតជាតិណាៗ ជាមនុស្ស ឬជាទេវតា តែងបានពៅជាបុគ្គលប្រសើរ
ហើយរីករាយសប្បាយក្នុងលោកខាងមុខឥតសង្ស័យឡើយ ។

អាត្មាកាពស៍ដែងធមិទេសនាអំពីតិលានុបជ្ជានកថា ចែកជូនលោក
សប្បុរសពំងឡាយ ក៏ល្មមដល់កាលវេលា សន្មតថាចប់ដោយប្រការ
ប៉ុណ្ណោះ ឯវ ។

ឯតេន សច្ចវជ្ជេន សុវត្ថិ ហោតុ សព្វទា
អរោគិយសុខញ្ចេវ ឥាសលញ្ច អនាមយំ

ដោយសច្ចវាចានេះ សូមសេចក្តីស្ឌស្ឌី សេចក្តីសុខដែលកើតពី
ការមិនមានរោគ នឹងអនាម័យគឺការប្រាសចាករោគាពាធ សូមមានដល់
លោកសប្បុរសពំងឡាយឲ្យបានគ្រប់កាលពៅហោង ។



ប្រស្នាលទ្ធិកប់អានឆ្មោចបិសាច

យុនបណ្ណានុវក្ស ប្ប-ប្ប៉ រៀបរៀង

(តបប់)

ជនជាតិបិន – លោកឡៅ-ស៊ឺ ជាអ្នកប្រាជ្ញជាតិបិន កើតមុន លោកអ្នកប្រាជ្ញ ខុង-ជឺ ៥៣ឆ្នាំ គឺមុន ព.ស. ៦១ឆ្នាំ ។ លោកឡៅ-ស៊ឺ បានបង្កើតលទ្ធិ តៅ អ៊ីស្ម៉ ។ លទ្ធិនេះជឿប្រកាន់ថា "មានព្រះជាធំបំផុត នៅឯស្ថានសួគ៌ មនុស្សត្រូវតែធ្វើពិធីបន់ស្រន់ប្ជងសួងអង្វរការទើបព្រះ ជាម្ចាស់ទ្រង់ប្រោសប្រាណ" ។ ចំណែរតមក លទ្ធិតៅ-អ៊ីស្ម៉ឺនេះក្លាយ ទៅជាលទ្ធិកប់អានឆ្មោចបិសាចទេពតាអ្នកតា ដែលពួកបិនជាប់កប់អាន តរហូតមកដល់សព្វថ្ងៃនេះ ។

មានអ្នកប្រាជ្ញសំខាន់របស់ជាតិបិនម្នាក់ទៀតឈ្មោះ ខុង-ជឺ កើត ក្រោយ លោក ឡៅ-ស៊ឺ ៥៣ឆ្នាំ គឺមុន ព.ស. ៨ឆ្នាំ ។ លោក ខុង-ជឺ ជាមេលទ្ធិមួយហៅថា លទ្ធិខុង-ជឺ ។ នេះ ទូន្មានប្រជាជនបិនថា "ចូរអ្នក រាល់គ្នា តោរពកប់អានឆ្មោចបិសាច ប៉ុន្តែត្រូវនៅឲ្យឆ្ងាយពីឆ្មោច" ។ ឧវាទរបស់លោក ខុង-ជឺ នេះ មានតទៅទៀតថា "ឆ្មោចអាចសំដែង ឥទ្ធិបាដិហារ្យដែលមាននៅក្នុងខ្លួនបានជាច្រើនប្រការពិតមែន ប៉ុន្តែ យើងមើលខ្លួនឆ្មោចមិនឃើញ ស្តាប់សំឡេងឆ្មោចមិនព្ន, សូម្បីយើង មើលឆ្មោចមិនឃើញ ស្តាប់សំឡេងឆ្មោចមិនព្ធជូច្នេះ ឆ្មោចក៏ចេះតែ ចូលជ្រៀតដ្រែកនៅក្នុងវត្ថុគ្រប់យ៉ាង របស់ដែលប្រាសចាកឆ្មោចនោះ ត្មានសោះ, ឆ្មោចជាហេតុនាំឲ្យប្រជាជនក្នុងអាណាចក្រត្រូវកាន់សីល

ទីដ៏លាន់ដម្រះមនុស្សសៅហ្មង ប្រជាជនត្រូវស្វែកតាក់សំពត់អាវយ៉ាងស្អាតឆើត ដើម្បីធ្វើកិច្ចគោរពបូជា, ហេតុនោះ ខ្មោចប្រៀបដូចគ្រែសែទឹកហូរ ហាក់ដូចជាមានខ្មោចនៅតាំនខាងលើផ្ទៃអាកាស នៅខាងក្នុងខាងស្តាំរបស់អ្នកធ្វើកិច្ចគោរពបូជា សូម្បីនៅឋានសួគ៌ទីឧទ្ទេសមុខគ្រកំមានខ្មោចដែរ" ។ ប្រជាជនជាតិចិនជាប់ពប់អានខ្មោចបិសាចតាមលទ្ធិ ខុង-ជឺ នេះរៀងមក ។

ជីនជាតិជប៉ុន- ជាតិជប៉ុនសម័យបុរាណគាន់លទ្ធិសាសនាជិនតោ ។ លទ្ធិសាសនានេះជាដើមកំណើតរបស់ជនជាតិជប៉ុន តាំងកើតឡើងក្នុងប្រទេសជប៉ុនតែម្តង ។ លោកសាស្តាជិនតោបានប្រៀនប្រដៅប្រជាជនជប៉ុនថា " មនុស្សយើងតាលស្លាប់ទៅហើយ ទុកដូចជាផ្ទាស់រូបកាន់ថ្មី ឬទុកដូចជាផ្ទាស់គ្រឿងសំលៀកបំពាក់ជាថ្មីប៉ុណ្ណោះ, ឯវិញ្ញាណមិនមែនសាបសូន្យបាត់ទៅតាមទេ តែឆន់ទៅចាំថែរក្សាគ្រួសារជាប់ជានិច្ច ព្រោះវិញ្ញាណជារបស់មិនចេះសាបសូន្យបាត់ទៅណា" ។ ស្រាប់តែនេះ លោកសាស្តាជិនតោបានប្រៀនប្រដៅប្រជាជនជប៉ុនឲ្យគោរពកាន់អានបូជាបុព្វបុរសរបស់ខ្លួន ។

លទ្ធិពប់អានខ្មោចបិសាចរបស់មនុស្សបុរាណដូចបានពន្យល់ឈ្មោះមកហើយដោយសង្ខេបនេះ ដើម្បីទីឆ្លងទន្ទឹលឲ្យឃើញថា ការពប់អានខ្មោចបិសាចនោះ មិនមែនទើបតែមានក្នុងសម័យថ្មីៗនេះទេ គឺប្លាប់តែមានជាប់តទ្រាំនឹងពីបុរាណកាលរៀងជាងពីរពាន់ឆ្នាំមកហើយ ។ ចំណែកមនុស្សជាតិដទៃទៀតដែលមិនបានបេះឈ្មោះ ប្តូមិនបានដំណាលឲ្យ

លទ្ធិរបស់គេក្នុងនិទានេះផង កំមានលទ្ធិពាក់ព័ន្ធខ្លាំងបំផុតដូចជាមនុស្សបុរាណដែលបានចេញឈ្មោះមកហើយនោះដែរ ប្លែកតែត្រង់តែប្រើនឬតិចតួតនឹងជាន់គ្នាប៉ុណ្ណោះ ។

ស.- អ្វីហៅថា សព?

ឧ. រូបមនុស្សស្លាប់ថ្មីៗ ហៅថា "សព" ត្រូវអានថា "សប់" ព្រោះពាក្យនេះជាភាសាបាលី-សំស្ក្រឹត ប្រែថា "ខ្មោចស្រស់, រូបបុគ្គលស្លាប់, សាកខ្មោច ឬ សាកសព" ត្រូវនឹងពាក្យខ្មែរសាមញ្ញថា "ខ្មោច" ប្រើជាពាក្យខ្ពស់ថា "សព" ប្រើជាពាក្យថ្លៃថា "ព្រះសព" ឬ ព្រះបរមសព" ។

ស.- ចុះមនុស្សត្រប់ជាតិ មានវិធីធ្វើបុណ្យសពដូចគ្នាតែមួយក្នុង ឬក៏ធ្វើប្លែកគ្នាដែរ?

ឧ. មានវិធីធ្វើបុណ្យសពប្លែកៗគ្នាជាច្រើនយ៉ាងណាស់ ធ្វើទៅតាមលទ្ធិចំណេរមនុស្សម្នាក់ៗ ទំនៀមទម្លាប់របស់ខ្លួន ទំនៀមទម្លាប់ឲ្យសពត្រប់មិនបានទេ ប៉ុន្តែ បើសំដៅយកគោលធំបំផុតក្នុងវិធីចាត់ការសពនោះ មានគោលតែត្រឹមៗ យ៉ាងគឺ វិធីកប់សព១, ដុតសព១, មិនកប់មិនដុតសព១ ។

ការកប់សព

ស.- ចុះមនុស្សជាតិណាខ្លះ ធ្វើវិធីកប់សព?

ឧ.-មានមនុស្សច្រើនជាតិច្រើនភាសា ប្រាប់ឈ្មោះមិនត្រប់ទេ សូមប្រាប់តែអំពីជនជាតិអេស៊ីប្ចីមួយ, ខ្ញុំបានដឹងដោយសារសង្កេតមើលប្រវត្តិសាស្ត្រសាកល ឃើញថា ជនជាតិអេស៊ីប្ចីធ្វើវិធីកប់សពតាមលទ្ធិជឿ

ប្រកាន់របស់ខ្ជនថា វិញ្ញាណមិនចេះស្លាប់ ។ ទីសម្រាប់ដម្ពល់សព គេធ្វើជា
អនុស្សាវរីយ៍ យ៉ាងខ្ជាប់ខ្ជួនណាស់ ហើយប្រុងប្រយ័ត្នមិនឲ្យពួកចោរឬ
មានការមើលងាយដល់សពឬដល់ទីកន្ទែងទុកសពផង ។ នៅទីដម្ពល់
សពនោះ គេធ្វើបន្ទប់ផងឹត ។ សម្រាប់ជាលំនៅរបស់វិញ្ញាណ នឹងជាទី
ទុកសពផង ។ ក្នុងបន្ទប់នេះ គេបានចាត់ដំកល់គ្រឿងប្រដាប់ផ្ទះនឹង
អាហារហើយបានសាងរូបរបស់សពទុកនៅក្បែរខាងផង ។ ទីកន្ទែង
កប់សព គេធ្វើធ្លាយពីទន្ទេនិល មិនឲ្យមានទឹកជោរដន់លិចទៅដល់
ជាទីហែងស្ងួតមិនសើម ដើម្បីទុកសពឲ្យបានយូរអង្វែងធ្នាំ ។

នៅក្នុងស្រុកអេស៊ីប្ត៉ីនីមួយ ។ មានអ្នកចិញ្ចឹមជីវិតដោយវិធីអប់សព
ដោយគ្រឿងក្រអូបសម្រាប់ទុកឲ្យបានយូរ កាលញាតិរបស់សពទៅ
និយាយជួលឲ្យគេធ្វើ ហើយប្រគល់សពឲ្យទៅគេហើយ គេក៏ចាប់យក
ឈើលាបថ្នាំចេញមកឲ្យមើល ហើយគេសួរថា អ្នកត្រូវការបែបណា? រូប
ឈើនេះមាន ៣ យ៉ាង តម្លៃផ្សេង ៗគ្នា ដែលមានតម្លៃប្រើនជាងគេនោះ
គេធ្វើជារូបដំណាងព្រះអូស៊ីរិស ។ កាលញាតិរបស់សពនិយាយថ្ងៃ
ស្រេចហើយ ក៏ត្រឡប់មកផ្ទះវិញ ។ ឯពួកអ្នកអប់សពក៏ធ្វើការនៅផ្ទះ
របស់ខ្ជន ។ សម្រាប់វិធីអប់សពយ៉ាងល្អលេខមួយនោះ មុនដំបូងគេ
ទ្ធះយកខួរក្បាលចេញដោយស៊ីកដែកទំពក់ទៅតាមរន្ធច្រមុះ ហើយលាង
ដោយបាញ់ទឹកបញ្ចូលទៅក្នុងក្បាល ហើយចោះធ្មឹងជំនីទាញយកពោះ
រៀនចេញមកលាងដោយស្រាត្នោត ប្របល់ដោយគ្រឿងក្រអូប ដែល
កិនខ្ជាជាផង់ ទើបគេញាត់ចូលទៅវិញជាមួយនឹងថ្នាំដែលធ្វើពីជ័រ

ឈើក្រអូបទំនើងគ្រឿងក្រអូបឯទៀតៗ ហើយដេរក្តឹតនៅវិញ ទើបគេយកសួតមកជាក់សពត្រាំក្នុងថ្នាំអំបិលម្យ៉ាងចំនួន ៦០ ថ្ងៃ ។

កាលគ្រប់កំណត់ ៦០ ថ្ងៃហើយ រាងកាយនោះក៏សួតក្រៀមៅ នៅសល់តែស្បែកជណ្តប់ឆ្អឹង ទើបគេយកសំពត់តូចៗស្រលក់ជ័រ ហើយរុំដោយសំពត់ដ៏ទៃទៀតជាច្រើនជាន់ ទើបយកសំពត់ជាតិរុំ១ជាន់ទៀត ។ កាលគេរៀបចំស្រេចហើយ គេយកសពនោះដាក់ក្នុងមឈូសដែលធ្វើដោយឈើជាតិរឹងជាន់ ហើយមានលក្ខណៈប្រហែលនឹងរូបមនុស្ស នៅចំណែកខាងក្បាលនោះ គេធ្វើក់ជារូបមុខរបស់សពនោះឯង ។ ការធ្វើវិធីបែបនេះ ជាហេតុរក្សាសពទុកឱ្យបានយូរអង្វែងជាវែលាច្រើនពាន់ឆ្នាំក្នុងវែលានេះមានសពសល់នៅជាចំនួនច្រើន ។

ការជ្រុតសព

មានជនជាតិ[illegible]ច្រើនជាតិឡើងដូរ[illegible] ។ ប៉ុន្តែ ក្នុងចំណោមជនជាតិទាំងនោះ ក៏មានមួយចំនួនដែរ ដែលមានទំនៀមទម្លាប់ប្លែកអំពីគេ គឺមិនកប់សពទេ តែធ្វើជុតសពវិញ ព្រោះគេប្រកាន់ឿថា ការជុតសពនឹងធ្វើឱ្យញាណរបស់អ្នកស្លាប់នោះឱ្យស្អាតហ្មត់ចត់ ហើយវិញ្ញាណនឹងអណ្តែតតាមអណ្តាតភ្លើងឡើងទៅឋានសួគ៌ ។ សូម្បីត្រឿងសំណែនរបស់វិញ្ញាណនោះ លុះធ្វើពិធីស្រេចហើយ គេក៏ជាត់ការជុតភ្លើងជូនគ្នានៅវែលានោះដែរ ព្រោះគេជឿប្រកាន់ថា ភ្លើងជាពួករបស់ស្ថានសួគ៌ដែលមានប្រចាំនៅនាស្ថានមនុស្ស ។ ចំណែកឆ្អឹងរបស់អ្នកស្លាប់នោះ គេរើសយកមកបញ្ចុះទុកក្នុងពិដីសមគួរ (ចេតិយ) ។

ការមិនកប់មិនដុតសព

ជនជាតិប៉ីរ៉ូ ជាពួកអរិយ៉ន មិនកប់មិនដុតសពទេ ព្រោះគេជឿប្រកាន់ថា សពរបស់មនុស្សមិនត្រូវដុតភ្លើង ឬកប់ក្នុងដី ឬបណ្តែតចោលក្នុងទឹកស្ទឹងទន្លេសមុទ្រទេ ព្រោះជាការធ្វើទឹកដីនឹងភ្លើងឲ្យសៅហ្មងស្មោគគ្រោក ដែលចាត់ថាជាបាបយ៉ាងធំក្រៃលែង ទើបគេធ្វើវិធីមួយឲ្យដុតពីបាប គឺគេនាំយកសពទៅទុកចោលក្នុងព្រៃឲ្យត្មាតស៊ី ។ វិធីនេះសាយកាយចូលមកប្រទេសឥណ្ឌាខ្លះដែរ នៅមានធ្វើជាប់តមកហូតដល់សព្វថ្ងៃនេះ ដូចជានៅប្រទេសបុមបៃ ។

រឿងសពនេះ រួមសេចក្តីខ្ញីថា ជាតិមនុស្សផ្សេងៗ ក្នុងលោកមានវិធីធ្វើសពពាយ៉ាងគឺ កប់សព១, ដុតសព១, មិនកប់មិនដុតសពទេគេយកសពទៅចោលក្នុងព្រៃឲ្យសត្វស៊ី១ ។ ឯរបៀបចាត់ការធ្វើបុណ្យសពនោះ មានវិធីប្លែកៗ ពីគ្នាជាច្រើនប្រការទៅទៀត តាមលទ្ធិទំនៀមទម្លាប់របស់ជាតិជននោះៗ នឹងរៀបរាប់ឲ្យសព្វគ្រប់ក្នុងទីនេះមិនបានទេ ។

រឿងលទ្ធិរាប់អានខ្មោចបិសាចសង្ឆេបប៉ុណ្ណេះ ។



ផ្នែកអក្សរសាស្ត្រ

កាសិតខ្មែរ

លោក ទៀង-តៃឈុន ក្រមការដើមខ្សែលេខ១

ប្រមូលរៀបរៀង

១- អាវែកគេសុីក្រោមត្នែក អាវែកមិនដឹងខ្ទួន ។

២- កុំទុកចិត្តមេយ, កុំទុកចិត្តផ្តាយ, កុំទុកចិត្តកូនថាគ្មានសហាយ, កុំទុកចិត្តម្តាយថាគ្មានបំណុល ។

៣- សូវស្ទាប់ចា កុំឲ្យតែស្ទាប់មេ, សូវលិចទូកកណ្ដាលទន្ទេ កុំឲ្យតែក្ងើងឆេះផ្ទះ ។

៤- គោកាសឹកតែមាត់ត្រដោក ឆ្នែតឯពោះក្រប៉ ។

៥- ឥតដំបោហៅដម្ចឹ, ដំ ចាមិនឈឺយកឈើចាក់ ។

៦- តយដេក ដាស់តយឲ្យអង្គរ ។

៧- រទេះបាក់មិនតិត ទៅតឹតតែតោលូបដាំង (លិង្ត) ។

៨- សាប់មិនបានសុី យកផ្ទឹងញ្ជរក ។

៩- ម្នៅ ៗ ទៅយកដីរត្នៅត្សៀតឈ្ទៀក ។

១០- ម្នៅ ៗ យកស្ពរទៅផ្ទើស្រមោច ។

១១- ឥតមិនឥតយកកលអន្ទាក់ ។

២១- កំប្រុកសុីផ្ទល្ទា ចំពាក់កទា ទៅផ្សារឯក្តិតឈ្ទូស ។

១៣- ឆ្នែត្រសមិនដែលខាំ, ផ្ទរលាន់រអាំ មិនដែលត្ទៀង ។

១៤- ឆ្កែទាំឲ្យកម្ចាស់, គោធ្ពើសឲ្យកនាយ ។

១៥- ចង់ធ្វាញ់ឲ្យកអន្ទក់, ចង់ស្រណុកឲ្យនឿយតី (ក្នេង) ។

១៦- ចំណីប្រើនមុខប្រើនពីសា, ក្ងនប្រើនបាប្រើនល្អ ។

១៧- គោលឿនសឹកក, ស្រីល្អសឹកគូថ ។

១៨ ប្រាជ្ញអាងប្រស្នា, រមាសអាងបន្ទា, អាងត្រៃ, ជំរីអាង
រនាម, ត្រីអាងទឹក, ទាហ៊ានអាងសឹក, ប្រមឹកអាងពែង ។

១៩- ចាស់អាងស្ទាប់, ពាលអាងកាប់, ក្នេងអាងយំ ។

២០- ទឹកហូរតាមប្រឡាយ, ទន្សាយបោលតាមប្រឡោះ ។

២១- មានប្រឡាយទើបទឹកហូរ ។

២២- ទំពក់ទៅទើបត្នៅជ្រុះ ។

២៣- ក្ងើងធេះតែពីសំរាម ។

២៤- ស្ទឹកឈើជ្រុះមិនដែលធ្វាយពីតល់ ។

២៥- ម្នកយើងតន់គ្រោះតាមរាស៊ី, ចៅក្រមកាត់ក្តីតាមពាក្យ ។

២៦- កើតជាជន្ទេនទៅទ្ពើមអីជ, ធ្វើជាមន្ត្រីទៅទ្ពើមអីប្រាក់, ធ្វើ
ជាជាងធ្វាក់ទៅទ្ពើមអីឈើ ។

២៧- ធ្វើជាក្រពើមិនដែងអកត្រូសត្រំ, ធ្វើជាចៅក្រមមិនដែង
និយាយហួស, ធ្វើជាម្នកបួសមិនដែងត្រូវតាបត្តិ ។

២៨ កើតជាម្នកចំបាំងមិនត្រូវរាសឹក, កើតជាម្នកប្រមឹកមិនត្រូវ
រាពែង ។

២៩- គោគេមិនអួត អួតតែគោឯង ។

៣០- ចិញ្ចឹមមនុស្សឲ្យមើលចិត្ត, ចិញ្ចឹមសត្វឲ្យពិនិត្យមើលចន្ទ្ពម ។

៣១- និយាយក្តីឲ្យមើលមាត្រា, និយាយការឲ្យមើលទំនង ។

៣២- មនុស្សទ្វាំងទុកជារបង, មនុស្សកាចទុកជាខ្នង, មនុស្សគោង
ទុកជាសម្រាស់, មនុស្សស្ទូតណាស់ទុកជារបាំង ។

៣៣- បើម្ជ៉ូនឹងកាច ឲ្យគេកោត, បើម្ជ៉ូនឹងឆោត ឲ្យគេអាណិត ។

៣៤- ជឹងឆ្ទើយត្រោះជង កូនឆ្គងត្រោះមេបា ។

៣៥- ផ្ទៃត្រឡាចតង់មានបណ្ណូល, មនុស្សទាំងមូលតង់មានចិត្ត ។

៣៦- អឹមជាងអៀម ស្ទៀមជាងស្រជី ។

៣៧- និយាយយប់ផ្ទប់ព្រៃ និយាយថ្ងៃព្រៃមានត្រចៀក ។

៣៨- រពឹសដៃ ផ្ទៃផ្ទៃត ។

៣៩- ឃ្ទានកុំអាលស៊ី ។

៤០- ដេកយប់កុំនិយាយនឹងស្រី ។

៤១- បង់ព្រះទៅសំពះឯបាយ៉ាប, បង់បញ្ចមហាប្រាសាទទៅនៅ
ព្រៃស្ទសាន, បង់ពាក្យសមណៈជីព្រាហ្ម្ណ៍ទៅយកឯពាក្យពាល ។

៤២- បំណាច់នឹងបាបឲ្យឆ្ទាបមាត់ ។

៤៣- លូកប្រហុកឲ្យកប់ឃ្ទៀក ។

៤៤- ជល់កំពង់លង់ទូក ។

៤៥- ពងមាន់កុំជល់នឹងថ្ម ។

៥៦- កុំរាមុខជឹង កុំទទឹងមុខសឹក ។

៤៧- ស្ទឲ្យសាប, អង្គុយឲ្យទាប ប្រាជ្ញាឲ្យដៃ សំជីឲ្យទន់ ។

๒๘- ការប់បំពង់រងទឹកភ្លៀង ។

๒๙- ញ្ចឹតផ្តរ កុំអាលចាក់ទឹកបំពង់ទោល ។

๕๐- ផ្លីស្រែឲ្យមើលស្មៅ, ទុកដាក់កូនចៅឲ្យមើលផៅសន្តាន ។

๕๑- ក្តៅរកវែក ត្រជាក់ពេកលូកនឹងដៃ ។

๕๒- ពូជសិស្សគ្រូបី, ពូជស្រីប្តីលែង, ពូជគោជ្រលែង, ពូជឆ្កែបង់ម្ហាស់ ។

๕๓- ក្របីស្នងកែក មនុស្សក្នែកឯក(๑) ក្រពើកំបុតកន្ទុយ ។

๕๒- ចូលស្ទឹងតាមបត់ ចូលទូកតាមកំពង់ ចូលស្រុកតាមប្រទេស ។

๕๔- ទូកបែកជាទូកតត់, ទូកកំបុតជាទូកង ។

๕๖- អំបែងបែក រកអំបែងណាជូច ។

๕๗- សាបមួយដៃ, ប្រៃមួយចិប ។

๕๘- រួចបាត់ថាត្រីរាស់, បានទាំងអស់ថារន្ធត ។

๕๙- ឃើញឈើពុក កុំអាលទម្លាក់ត្រពោកអង្ពុយ ។

๖๐- ហ៊ានស្សែកដាច, ទ្លាចស្សែកស្ទិត ។

๖๑- ឥក់ ៗ ពេញបំពង់, ឆុង ៗ កន្ទះឃែត ។

๖๒- រនាបបាក់ត្រាន់នឹងជួស ឹតមាត់ហួសកំពប់ប្រាក់ ។

๖๓- ជំពប់ជើងតង់ពត់ កំពប់មាត់បង់ប្រាក់ ។

๖๔- ជឹងគ្នានៅត្រាក្រ សម្ឆុរល្អនៅទៃកត្តិក ។

๖๕- មឹសៗកិះធ្នាំងបាយផ្ទុះ ។

---

๑ ន៍យទ្ទះថា មនុស្សស្រលៀងភ្នែក ។

៦៦- រហ័សតែមាត់ ត្រតាកស្ទាប់ស្ពូក ។

៦៧- មនុស្សកុំមើលឆាយមនុស្ស ។

៦៨- ប្រហែសបាត់ ប្រយ័ត្នគន់ ។

៦៩- ប្រើនបេះរបេះក្សាប់ ។

៧០- អ្នកមានកុំអរ អ្នកក្រកុំថប់ ។

៧១- មានមិនដែលបីត, ក្រមិនដែលបីជាន់ ។

៧២- ឃ្ទាកលិប អំបែងអណ្តែត ។

៧៣- ប្រាសពីដង្រែក ទៅប្អែកលើពូក ។

៧៤- ដើយស្ពក ទនជាក់ត្រាប់ ។

៧៥- ប្រាជ្ញចុះរណ្តៅ, ទ្ធៅទ្បើងស្ងួតិ ។

៧៦- បង់បេះទ្យសម្ទាប់អាចារ្ស, បង់បានផ្ទៃផ្ការទ្យយកក្វើងជុតគល ។

៧៧- សំដីសជាតិ, មារយាទសពូជ ។

៧៨- កំភ្ទាញ ស្ទាប់ព្រោះមាត់, ទ្ធែកស្ទាប់ព្រោះអាចម៍ ។

៧៩- ប្រើអនូង់ទ្យបំហុងភក់ ។

៨០- ទ៉ងទ្យអត់, ទ្យត់ទ្យរក, ទ្យប្រើនកុំយក, ទ្ធាបទ្យបូលជិត ។

៨១- គេទុសកុំអាលអរ, គសាទរកុំអាលអួត ។

៨២- ធ្ទីស្រែទាន់ក្តៅដី, បង់ស្រីទាន់ក្តៅបិត្ត ។

៨៣- លេងក្នេងអាប់យស, លេងពស់វាទាំដៃ, លេងចាស់វាបង្រៃ ។

៨៤- ស្ទាមិនបង់ប្រៀម, ស្រៀមមិនបង់ក្ឈូន, ឃ្ជូនមិនបង់ពុត,
ទ្ធៃរស៊ីតទ្រុត មិនបង់ចែចូរ ។

៨៥- អណ្ណាតជាអាទ៍កនូន បង់ទ្រព្យធនផងពីព្រោះអណ្ណាត ។

៨៦- សត្វជវង្ក្រស្ទាប់ដោយសាប្រើស ។

៨៧- ថៅហ្វាយមានបុណ្យទុនមានស័ក្តិ ថៅហ្វាយអប្បស័ក្ខណ៍ ទុនធ្វាក់អណ្ណូន ។

៨៨- កាលឈឺបង់រស់ថាថ្វាយគោ ជារស់ជ្រដោយកពងមាន់មួយ ទៅថ្វាយ ។

៨៩-កាលឈឺធ្វន់យកជ័រទៅបន់ជល់ជម្ងឺស្រន់យកពងមាន់ទៅថ្វាយ ។

៩០- កុំអរនឹងយស កុំជាទុក្ខជ្សិតថ្ងៃ ។

៩១- និរាសកុំម្ទេញ, ទុក្ខពេញកុំដឹង, ទឹងកុំទន្ទេញ, មិត្តកុំបណ្ណាញ ស្អប់កុំញាបាទ ។

៩២- ល្ងបគេធ្វាប់ដៃ ដេកថ្ងៃធ្វាប់ក្នេក ។

៩៣- អ្នកបេះដប់មិនស្មើអ្នកប្រសប់មួយ ។

៩៤- ទ្ធូនទៅបកុំគោង, ដៃទ្ធីកុំឈោង ប្រវ៉ាបក្ទំ ។

៩៥- កុំបស់សន្ធូបរំលងក្ទំ ។

៩៦- ជ័រសារស្ទាប់ទៅយកបង្អេរបាំង ។

៩៧- អូសទូកកុំឲ្យយើញជាន(*) ចាប់ត្រីបានកុំឲ្យល្អក់ទឹក ។

៩៨- ជ័រផុងព្រយុងដើមឈើ ។

៩៩- រទេះបាក់ត្រង់ណា ល្អិតស្មៅត្រង់ណោះ ។

-១០០ ចម្បាប់នឹងណោកសង្ស កុំទ្ទាបកាន់ព្រះកេស ។

---

* ន៍យទ្ធះថា អូសទូកកុំឲ្យល្អាន ចាប់ត្រីបានកុំឲ្យល្អក់ទឹក ។

១០១- ដេកផ្ទារស្ពោះលើត្រូវឯង ។

១០២- ធ្វើស្រេនឹងទឹក, ធ្វើសឹកនឹងបាយ ។

១០៣- ដឹងរង្គោះបោះដឹងបណ្តោយ ។

១០៤- ដឹងចាំងតាមសាប់ ច្បាប់កាត់តាមពាក្យ ។

១០៥- ប្រើទៅជាត្បូងចិញ្ចៀន ក្រវិចក្រវៀនជាមៀនកាំបិត ។

១០៦- គោស្គមថ្នមប្រើ ។

១០៧- ចង្អៀតចិត្តនៅមិនបាន, ចង្អៀតផ្ទះនៅបាន ។

១០៨- កុំក្តិចសង្ឆារប្រជល់ត្នា ។

១០៩- ជាងទេសុ៉ីរងកំបែក, ជាងដែកហែកនឹងមាត់ ។

១១០- ត្ងតនៅហោរ, ចោរនៅជាង ។

១១១- ធ្វើស្រេមិនបាច់ត្ថ្ងូរ រក្សាតែមួរស្រូវសុ៉ីមិនអស់ ។

១១២- មាន់ពងលើជង្រុកស្រូវ ។

១១៣- ទឹកបាក់ទៅទាប, ដីខ្ពស់កណ្តៀរពួន ។

១១៤- គោមួយកឹយប់, គោជប់កឹយប់ ។

១១៥- បង់បោយមិនមើលប្រាណ, ដាំបង្ក្រានមិនប្រមាណធ្នាំង ។

១១៦- បាយសង្សាជទៅប្រមាទកន្ទាងចំ ។

១១៧- ត្នោតបាទប្រមាទត្នោតលៃ ។

១១៨- ប្រមាត់ដីអួតបង់ទ្បើងទ្រើង ។

១១៩- មានតំនិតឥតកំណើត ។

សាវតារនាងហ្ស៉ងជាក់

ណេកអ៊ុហ៊ី តែងជាកាព្យពាក្យពៃ

(តបប់)



ទៅដេញអង់គ្លេស៍ឲ្យស្ងប់ស្ងាត់	លើកពលកំបាត់ឲ្យវេទនា	
ផ្តល់ផ្តាប់ជីវិតកុំតិតវ	បាប់បងយកជាល្ងើយបំបាំង	៣
ព្រះបាទសារល៍ទ្រាំពីរនោះ	ព្ធពាក្យជូប្ចោះពីរោះខ្ចាំង	
តែពុំស្ងូវដៀបាបេះប្យាំង	ព្រោះគ្មានកម្ចាំងដោយក្មេងកាយ	៣
ស្តេបទ្រង់បង្ផាប់ជំនុំសង្ឆ	សាកស្ងូរនោមយង់ក្នុងឧបាយ	
ពីសោធបោទនាងឲ្យដោះស្រាយ	នូវគ្រប់បរិយាយផងនានា	៣
តែនាងធ្វើយឥតមានទាល់សោះ	ធ្វើយដោះប្រស្នាអាបិគ្រប់យ្ងា	
ប្រើនលើកប្រើនដងជាប្រើនគ្រា	ទើបព្រះរាជាទ្រង់ដៀផង	៣
ដៀជាក់ថានាងកាន់សាស្នា	មែនមានប្រាជ្ញាថ្ងាកន្ងង	
ទើបប្រគល់ទ័ពឲ្យនួនល្អង	ចំនួនមួយកងរ៉ៃចម្ងី	៣
ឲ្យនាងនាំទៅយកអាសា	ក្រុងអ៊ីឲ្យអង់ណាតាមសេចក្តី-	
ប៉ុនបំងរបស់ទ្នស្ត្រី	ក្នុងគ្រានោះវៅកុំបីបាំ	៣
កាលណោះអាយុនាងទើបបាន	ប្រមាណជាដប់ប្រាំពីរឆ្នាំ	
ប្រាជ្ញាវៀងវៅស្រីគ្មានកម្ម	ចិត្តបាំបងជាប់នឹងផែនដី	៣
អស្ចារ្យក្នុងផ្ងូវយុទ្ធសាស្ត្រ	នាងឆ្ងាសប្រសប់សព្ងសេចក្តី	
ឥតមានតក់ស្ងត់ទ្ធត់ក័យ	ប្រុងប្រៀបស្មានតីស្រីពុំរា	៣

នៅថ្ងៃម្តងនឹងប្រាំបួន គាវីលដែលខ្លួនលើកចំពក្ស

កន្ត្រៃញ៉ែវហៀវហាសូរខ្លួរខ្លួរ កន្ត្រែតាសុធគ្រានោះឯង

ដោយព្រៃព្រឹក្សាបក្សាស្ងាត់ តាលច្រើនច្រកត់តាត់កន្ទែង

កន្ទុងធ្លុងផ្លែតម្រេវស្វែង តុំមានកោតក្រែងនាងថ្ងៃនិទ្ទី

មិនយូរប៉ុន្មានក៏ឃើនជល់ ទីស្ថានមណ្ឌលក្រុងក្រៃពិត

ដែលពួកអង់គ្រេស៍គេមានវិទ្ធី ព័ទ្ធដិតពីមុខអ្នកស្រុកព្រួយ

ក៏សន្ធឹបខ្លួយកយតលជាប់ ចំនួនជាងដប់ខ័ណ្ឌខ្លួយ

ចំណូលចូលថ្មីល្បីចិត្តមួយ ហ្ន៎ជាក់មិនព្រួយប្រុងអាត្ម

ទើបនាងដាក់កែកស្រែកប្រាប់តល ឲ្យប្រុងចប់ចល់តចេស្តា

កុំខ្លាចអំណាចអាមោហា ដែលមានវិទ្ធីក្លាមិនប៉ុន្មាន

យើងមកយកជ័យឲ្យល្បីឈ្មោះ ចិត្តមួលចំពោះប្លែស្ងាន

អម្ចាស់ជីវិតជាដើមជាន ត្រូវយើងប្រុងប្រាណឲ្យបានសុខ

ជីវិតត្រូវគិតរួមជាមួយ ស្មាប់រស់ត្រូវជួយគ្នាកុំធ្លុក

កុំរុញច្បាច្បាប់គាសន្ទុក្ខ ពេលនេះយើងលុកកុំទុកនៅ

គោលក្លាងនាងលើកដៃយកជ័យ បំផាយគាវនេយ្យបំបោលទៅ

កងពលវេលាគ្រាវឡូវ បង្ក្រាបសត្រូវឲ្យខ្ចាចម្តង

បង្គាប់ឲ្យទាក់យកបន្ទាយ ឲ្យខ្លួចរាយយកមួយម្តង

ឲ្យបានជួបចិត្តគំនិតប៉ង កុំឲ្យសៅហ្មងកងចិត្តា

ពលរេហ៍មានវិទ្ធីចិត្តអនេក ក៏យកបន្ទាយជាយសីមា

ចាក់គាប់ជាប់ជាន់ផ្តន់ដីវ៉ា តាមដោយប្រាជ្ញាហ្ន៎ជាក់ថ្លៃ

អង់គ្លេសតាយញ៉ាវត្រប្រសាច ចុះចាញ់អំណាចខ្លាចចរវៀណ
ខ្លះផ្ញតខឹកក្អែកស្រែកអាឡ័យ អាណិតខ្លួនក្ស័យអាឡ័យខ្លាំង ។
លុះដេញទៅដល់បន្ទាយចំ អង់គ្លេសចូលផ្តុំប្រជុំចាំង
តយុទ្ធមកវិញពេញកម្លាំង ឯពលចាក់ឆកឆន់រួញាក ។
ព្រោះបន្ទាយនោះខ្ពស់ហើយមាំ ព័ទ្ធកទៅគ្រាំគ្រងវេទនា
ចូលពុំរួចសោះអស់វិជ្ជា ខឿយណាយពស់គ្នាចង់ភរក្រាយ ។
ប៉ុន្តែនាងស្រែកខ្លាំងអនេក កុំឲ្យពលវៀកបៃតបណ្តោយ
ទើបនាងប្រញាប់ប្រាប់អ្នកក្រោយ ហុចជណ្តើរឲ្យនាងយ៉ាងឆាប់ ។
រួចនាងលើកផ្អែកទៅជញ្ជាំង ឲ្យតលទ្បើងតាំងតចំណាប់
លុកលុយប្រជុំយកចូលទៅតាប់ វាយចាក់សម្លាប់ឲ្យហិនហោច ។
ប៉ុន្តែអង់គ្លេសមិនម៉ងសៅ វាយកខឹកក្តៅមកចាក់ស្រោច
រលាករលាត់រលាយខ្មោច ស្លាប់ដូចស្រមោចស្រោចទឹកក្តៅ ។
នាងទំខឿនតលកុំឲ្យខ្លាច លុះដោយអំណាចតាចចិត្តទៅ
សង្ឃឹកសង្ឃឹញរុញតីក្រៅ ឲ្យបាស់សះទៅម្តងនេះណា ។
មិនយូរប៉ុន្មានក៏ជានថ្ងាយ ជញ្ជាំងបន្ទាយដោយចេស្តា
ជារមិនខ្ជិលដៃលេខ្ញៀវក្លា ផ្តួលផ្តាច់ដីក៏កុំខុកខៅ ។
ខ្លះបាញ់ខ្លះបុកសំរុកទ្វារ ចូលជិតតិតគ្នាពាសពេញផ្លូវ
ខ្លះស្លាប់ខ្លះសន្លប់ចុះខៅ ចាក់ដៃជើងក្តៅត្រូវត្រួបគ្នា ។
បណ្តាលលាន់ឮរន្ធឺរន្ធែរ រៃយដួចផ្តក្សេះសន្ធឹក
កំក្រើកកំរើតកក្តិតកាវ ញាប់ញ័រតសុជាជាំខ្លាំងវិក្រ ។

អង់គ្វេស់ឃើញនាងពងស្រឡះ រួតរះគ្នាសព្រួញរំពេចខ្នើ
ជាក់ស្នាលើកត្រង់ដំរង់ស្រី រួចស្រេចហើយខ្នើតសកែភ្លាម ។
ព្រួញភ្លែតត្រូវផ្ទាប់មុតជាប់ស្មា កញ្ជាឈឺអួលដួលចេញឈាម
អូហៅ! យ៉ាយ! ក្រហាយថាប់ចុកភ្លាម រើគ្គាមនាងថ្លូហូរទឹកភ្នែក ។
ពួកខ្ញុំពត្រឡប់មកមើលនាង ជួយលើកជួយលាងហើយយំស្រែក
ថ្នាក់ថ្នមបមបីព័យចំឡែក ពាល់គ្នាពរែកបែកចិត្តពីរ ។
ដោយគិតថានាងគ្មានជារមើ គ្មានវិជ្ជាអ្វីក្នុងឥន្ទ្រីយ
ចុះនៅជាត្រូវព្រួញមុតដល់ទី ផ្តល់ផ្តាច់ជីវិតាមិនខាន ។
ចំណែកបែកនាងពួកអង់គ្វេស់ លុះឃើញមាសមេត្រូវពួញច្រាណ
ត្រង់ស្មាជូរច្នះខុសលំអាន គិតស្មានថានាងរំលងខ្ញុំណ ។
នាំគ្នាស្រែកហ៊ោសូរអនេក លាន់ឮសើរបែកសំរែកលាន់
បណ្តាលឲ្យពួកជាកំងតន្ត្ត គាំងតាមស្មោសូន់គិតរួញក ។
ចង់ថយត្រឡប់ទៅវិញខ្នើ ឲ្យតែស្ត្រីម្នាក់អគ្គ
ទៅប្លាំទីកំងដលល់ទីពក តាមដោយវែកដន្ទាស្រី ។
ដៃលអួតថាមានរឹទ្ធិចំហុត ពួកគេធ្លាតធុតផុតលោកិយ
ស្រាប់តែមកដួលដេកនៅដី ភ្លាំងក្បែចស្មារតីពុំដឹងខ្លួន ។
នាងឮសំរែកអង់គ្វេស់ប្លាប់ ទឹងណាស់ក្រោកឈរពេញសំខ្លួន
ហើយស្រែកដេញតាមសន្ធាប់ផ្លូន លាន់ឮគ្រអួនរំពងព្រៃ ។
ឈាមដោរហូរចេញពេញសស្រាក់ ហៀន្ទាក់ដោកអានាងគ្មានភ័យ
គ្មានស្ងួតរន្ធត់ផុតស្មារតី ដៃលឡើងអាជនេយ្យស្រីចូលប្លាំង ។

បង្គាប់ឲ្យខំពត្រឡប់ទៅ　　កុំខ្លាចសត្រូវនៅពាក់ណ

ចូលតប្រយុទ្ធឲ្យមុតខ្លាំង　　ឲ្យខ្លាចបាក់ធ្លាំងធឹងចិត្ត ។

ពលចូលតតុកសំរុកភ្លាម　　បាញ់ស្ទាប់ស្ទាប់ឈាមពាសពេញពិត

ខ្លះចាក់ខ្លះជ្រងរងគាំបិត　　ប្រកៀកប្រកិតប្រគងគ្នា ។

ចាក់គាប់ត្រូវក្បាលកណ្តាលខ្លួន　　ស្ទុះរត់ចូលផ្ទួនឲ្យមរណា

តុំពាន់គេជាន់ចាប់ក្រុង　　ពាញផ្ទាមុកផ្ងើយចាក់ដើមទ្រូង ។

ចាក់ជើងចាក់ដៃបែកឈាមប្រាល　　បាញ់សាច់ជាច់ក្បាលដួលសន្ធឹង

សព្វធ្លុះព្រួញអង្គុញមោង　　បាញ់ផ្ងារឈោងចាប់ខ្លែលមកឃាំង ។

អូយ! អាយ! យ៉ូយ! យ៉ាយ! ស្ទើរប្រកាប់　　លេបនោមលេបអាចម៍ពាំង

ផោមខ្លាំង

សេះទាត់ភ្លាត់ស្មៀតជាត់ប្រមុំង　　ប៉ាំសត្រូវដញ្ជាំងភ័យស្ញាំងខ្លួន ។

មិនហ្មត់ប្រុំខ្លាន់ខ្ចីរន្ធែងជាតិ　　ក៏យកតាបច្ចាមិត្តសំខ្លួន

ឆ្លុះផ្លាំយបន្ទាយពាំងដង់ប្លួន　　អង់គ្រស់ថយខ្លួនរត់ពួនព្រៃ ។

ចាប់តាំងពីពេលនោះរៀងទៅ　　ល្ប៉ីឈ្មោះនោមទ្លៅពេញបូរី

ប្រទេសបាកំងពាំងប្រុសស្រី　　ស្ងប់ស្ងៀងបារមីឥតម៉ាស្មើ ។

ឮបន្ទាបអំណាចខ្ញើចស្ពាន　　ទើបឈ្មៀជាត់ថាទេតាប្រើ

ហើយនាំគ្នាស្គាល់ថាគ្រាន់ម៉ើ　　ខ្លះខ្លៀតសរសើរថាបងប្អូន ។

ខ្លះថាពួកមិត្តមកពីដើម　　ចិត្តប្លែមល្អណាស់ហៅគ្នាអូន

ឃោងមួយថាវាញ្ជាហៅតែប្អូន　　តាថាក្មេងសូត្បាត្រោះយូរយារ ។

លុះយកក្រុងនោះបានស្រេចហោង ចិត្តានាងប៉ងនាំភាជា

ទៅអតិសេកត្រងភាព ក្រុងកុងដែលជាប្ដីថ្លៃ ។
ប៉ុន្តែស្តេចពុំមានធ្លឿជាក់ ព្រះទ័យនៅសាកល់ហាក់សង្ស័យ
ថាមានទេវតារក្សាថ្លៃ មានបុណ្យតេកក្រៃទ្រង់សព្វាយខ្លួន ។
លុះត្រាតែនាងមានជំនះ ម្ដងទៀតឃើញឈ្នះច្បាស់ចំពោះ
ទៅលើនាយពលអង្គរស់នោះ នាមឈ្មោះតាល់ថូរសូរស្ងប់ស្ងៀង ។
ទើបស្តេចត្រមត្រាប់តាមស្ត្រី ទៅក្រុងកុងដ៏យឥតប៉ប្រែក្រឡ
ត្រងភជសម្បត្តិក្សត្រតម្ដង ចានសុខអង្គុងស្ងៀងរំខ្ញី ។
ដល់ថ្ងៃច្រាំប៉ីខែសេបតមប្រឹ នាងលើកទ័ពឈមដោយគ្មីរ
ក៏យកមន្ទាយមុខប៉ារីស៍, ហ៊ានហោចខេចខ្ចីគាំពីរផង ។
កាលនោះនាងត្រូវបួសខ្ចាំង ចិត្តានាងកាំងក័យកន្ធង
ដឹងច្បាស់ថាកំពូលំណាងផង អស់ត្រីមនេះហោងឥតសង្ឃា ។
សំខ្សែងដែលធ្លាប់បង្គាប់ឲ្យ ធ្វើអ្វីក៏ដោយផ្ទៃកមុខណា
ពួកពលសកលកលអាត្មា ឈប់ស្តាប់រៀហារកញ្ញាស្រី ។
មានខ្លះក្រឡះនិន្ទាថា កញ្ញាច្រើសឃ្នងមិនគប្បី
មានចិត្តគិតកាត់ស្តេចផែនដី ដោយទៅសេចក្តីអ្វីនឹមួយ ។
ពួកទ័ពត្រឡប់ទៅក្រោយអស់ មិនជឿនាងសោះដែលឲ្យជួយ
តតាំងច្បាំងខ្លៅតកុំតក្រហ៊ុយ ដល់ខ្លួននាងមួយដែលពិការ ។
សល់មានពុំបានយកប៉ារីស៍ នាងស្តាយតេញទ័ស្រុកនេត្រា
ធ្វើសោកជោកខ្លួនខ្លួនទ្វារចង្ក្រា ទឹកដល់ភ្នែកស្មារត្រងអតីត ។

លុះចូលមកដល់ដើមឆ្នាំក្រោយ មួយភាន់ប្អូនរយសាមសិបតិត
ក្នុងជំណឹងថាពួកទាំងគិតគិត លើកគ្នាមកជិតចោមកន្លែង ๗
ព័ទ្ធលុកវុកពាន់បំពានក្រួង ក់យយកមាន៏ក្នុងក្រួងគំប៉ីយែន
ឲ្យខ្លួចល្អិតល្អោចខ្លាចជាផ្សែង គ្រប់ទីកន្លែងមិនលែងដៃ ๗
នាងលើកទ័ពមកយកគាសា ក្រួងខោះខៀតណាគាំទ័យបាំថ្ម
គ្មានឲ្យើយគ្មានណាយឬស្តាយក្បាយ ឲ្យគេក្រួងក្រែរួចបរកុក្ខ ๗
សេះនាងកៀនលន់ពន់អនេក រត់ជ្រែកបៃតកផ្លូវទៅតែមុខ
ពលផងត្រសងតាមគគុក ដោយគៀនក្រឡុកក្រលៀតកុំ ๗
ក្រឡះប្បាំបន្តែកក្រឡែកទៅ ឃាន់ឃើញគាលពៅគាលចោមដុំ
រោមតែជិតខ្លួនខ្លួនក្រមុំ ហាក់ដូចសត្វឃ្មុំប្រជុំផ្កា ๗
ពលតាមចូលតាំងច្បាំងសន្ធឹក ក្រាសក្រៃពន្ធឹកកងបព្វតា
បាញ់ដៃថយពលចោលគាសា ដរណ្តើមហ្ងែនដាក់ពុំឃាន់ខេ ๗
គឺជាអគុសលអម់សំណាង សំណូមនាងសាងតិបុព្វ
ឃានជាបណ្តាក់ឲ្យមាសមេ ឆ្ងាយតិពលរេហ៍ដូច្នេះនៃ ๗
ខន់ខ្លួនខន់ប្រាភាត្មែរលើកូណ៌ រះបរិភ្លាក់តិគាជនេយ្យ
បណ្តាយឲ្យគេចាប់ចងស្រឹ តាមដោយសេចក្តីគេបំណង់ ๗
គេទាំពៅលក់ឲ្យអង់គ្លេស ឃានជំរៀរខ្លះគេកកន្ទុង
មួយម៉ុនកាក់មាសសុទ្ធតែម្ភង គ្មានប្រកែកកងនាងរួនក្រែន ๗
តាមផលទិស្សយតិអតិត នាងមិនភ័យកតិតតាវង្វែង
គ្មានវល់គំនិតគ្មានចំបែង នេរសៀមមិនលេងលសំដី ๗

លាន់ឮដំណឹងដឹងសុះសាយ　　ល្បីឈ្មោះហួសឮក្នុងបុរី
ប្រទេសថាកំឯងតាំងប្រុសស្រី　　កើតមានសេចក្តីភ័យខ្លួនឯង ។
ញ៉ាំញាប់ចំប្រាប់ត្រឡប់ថ្វាយ　　អាសូរស្រីឆ្នើមដង្ហើមផុត
ស្តាយកាយស្តាយខ្លួនខ្លួនបរិសុទ្ធ　　ស្តាយពេកដេកសុតស្វាប់អាសារ ។
នាំគ្នាយំយែកស្រែកបន់ស្រន់　　ដល់ព្រះអរហន្តបន់ទេវតា
សូមឲ្យនាងរួចរស់ជាវិញ　　វិលមកសីមាក្សត្រវិញ ។
ឈប់សូរហើយថ្វៃងតែអង់គ្រស់　　ទៀញបានមាសមេនាំចេញថ្វាត់
ទៅក្រុងអិឡេអង់តម្រង់ស្តាត់　　ពលអមចាំស្តាត់ខ្លាចបាត់ស្រី ។
ជាក់តៀបឃ្លាបខ្លោះមិនអស់ចិត្ត　　ប្រាក់រ៉ែតែតតម្រណី
ព្រានមុខព្រានក្រោយដោយសេចក្តី-　　ព្យាបាទស្តីឲ្យវេទនា ។
បង្អាប់បន្តុះបញ្ជោះដង　　បញ្ឈឺខ្លួនល្អងឲ្យគ្រាំគ្រា
តេបត្រាយលៃបាយលេងត្រាំគ្នា　　ដោយដង្វាមគាំរុក្ខាល័យ ។
រៀងពាដកបសំដៅត្រង់　　ដល់ក្រុងអិឡេអង់ដែលយកស្រី
ទៅឃាំងឃាត់ឃុំដំនុំក្តី　　ថ្ងៃដប់ប្រាំបីទៀរដេសមប្រើ ។
មួយពាន់ប្លន់យកសាមសិបជាក់　　អង់គ្រស់ចាប់ថ្នាក់ជាក់មិនថ្នម
ឃើញច្បាស់ឡាសល្អក្រហម　　លើកពលមកអមហើយចោទថា ។
ភ្លែងក្លាយកាយខ្លួនខ្លួនជាស្រី　　មានបុណ្យចារមើល្បីអស្ចារ្យ
លើសលុបក្នុងតតត្រាប់សីមា　　ដោយមានទេវតារក្សាទៅ ។
អំនួតអួតខ្លួនខ្ពស់អំណាច　　ព្រោះមានបីសាចតាចអស្រូវ
ភ្នែចព្រៃប្លុសស្រីស៊ីមិនត្រូវ　　មិនត្រូវតាមផ្លូវពាក្យស័ក្ស ។

អង់គ្លេស ច្រាជ ច្រាយ ផ្សាយ សេចក្តី យ៉ាងធ្វើមដើម្បីតែបំភ្លាត់

អ្នកស្រុកភូមិភរបរដ្ឋ ឲ្យជឿច្រោកជាសន្តតជាន ៧

ឋានន្តរកថន្តយថាអ្វីបង់កេរ្តិ ពាល់គ្នាឯងនឹងគេក្នុងភូមិស្ថាន

កុំឲ្យគេរពត្រង់ប្រមូលច្រោណ ដឿថាកលល្បាណស្រីឱ្យចរត្រ ៧

បិសាចអាស្រ័យអ្នកតាប្រើ ឋានណាយឲ្យដើរកេរក្តេតស្តី

ដូច្នេះមនុស្សម្នាទាំងប្រុសស្រី គ្រាកចិត្តទីខែពីស្រីស្ងួន ៧

ពិនិត្យអង្កេតរកអគ្គហេតុ ឥតមានអណ្តែតឲ្យមាំមួន

លេចទោសកុំហុសខុសលើខ្លួន ធ៌មនួនចំនួនបួនខែថ្លាយ ៧

ពុំដឹងជាប់ចោទជាឋានណា ប៉ើករកមាត្រាមកអធិប្បាយ

ទៅយកទោសធ្ងន់ទម្ងន់កាយ ក្នុងបទភ្លែងភ្លាយកាន់សាស្ត្រា ៧

ពុំត្រឹមពុំត្រូវផ្លូវសុចរិត តាមដោយក្រមក្រឹត្យត្រូវអាចារ្យ

មួយទៀតធ្លៀតចោទថាកញ្ញា តែឯគួរគ្នាជាបុរស ៧

ខុសកេរ្តិ៍ជាស្រ្តីពិន័យធ្ងន់ ផ្តន្ទាឲ្យជនជាតិទាំងអស់

ឃើញស្នែងក្រែងស្ទាបអំណោចស្រស់ ឥតមានសប្បុរសក្នុងដួងចៃ ៧

នាងស្រក់នេត្រាពាក្កួល ព្រមធ្វើយខ្លួលទាំងអួលដួង៖

ខ្ញុំខុសហើយសូមលោកអភ័យ កុំជាប់ប្រល័យនៃនីភ័ ៧

ខ្ញុំព្រមខ្លួលប្រតិបត្តិ គោរពបញ្ជាត្តិបពមត្រា

ហើយសូមលើកទំណាងសង្ឃ ឈប់តែឯនាគ្នាជាប្រុសទៀត ៧

គេយកនាងទៅបង្ខាំងទុក ឲ្យនៅក្នុងគុកតូចបង្អៀត

ជាក់សោស្រែកក្នុងបំរុងស្ងៀត ខ្លាចនាងស្រីកសៀតក្រៀតចេញបាន ៧

ចង្អុតចំណីឲ្យធើសាប តែគ្បាហៅធ្វើចាបង្ហាញផ្លាលត្រាណ
ជាក់ខ្មោះមិនដោះឲ្យដើរឆ្ងាន អកុសលកល្បាណច្រាណវែងនា ។
តើតខ្ពុតមុខក្រៀមស្រៀមអនេក ស្រក់តែទឹកភ្នែកផ្លែកគ្នាគ្នា
អាសូរខ្លួនស្គមត្រមេរពោ តែម្នាក់អង្គាកំព្រាក្តាត់ ។
ដល់យប់ឃុបមេល្អាតនៅម្រមាណ យាមមួយព្រួយច្រាណគ្រោះរំលត់
នាងដេកលន់លក់ស្រមុកស្មាត់ ដួចកល់រូបសត្វចាត់ស្មោតតើ ។
តេលខោះមានឡាំងរំងឹងនាក់ លួចស្ទៀកបំពាក់រលំក្ងណ៌ស្រី
ជាប្រុសខុសគេខហេតុជាប្ញ ឲ្យយើញសេចក្តីស្រើក្លែងខ្លួន ។
គ្រាន់ជាសំអាងទៅក្រាបទូល ស្តេចជាកំពូលបណ្តាលក្សួន
ឲ្យជ្រាបសេចក្តីថាស្រើសន នៅតែតែងខ្លួនជាបុរស ។
ក្រោយមកយកនាងទៅជំនុំ នៅចំណោមធំប្រជុំអស់
នាម៉ឺនកងរ៉ឹមត្រួតខ្ពស់ ដោយនៅជំពោះកត្រុក្សត្រា ។
ជំនុំជំរះច្បាស់មួយថ្ងៃ ពុំជាបសង្ស័យត្រង់បទណា
ទើបបញ្ជូនយកទាសមួយអស្ចារ្យ ហោទាស្តាស្ថាំហុក ។
ត្រូវយកនាងទៅចង់ចូជា ឲ្យក្រុយជន្មាងំរស់សុខ្ញ
ចង់ខ្សែហែហមមកដល់ទៅដុត ទើបពេញចិត្តក្នុងផ្លូវច្បាប់ ។
អនិច្ចា កញ្ញាហ្ន៎ជាកិ រង់ខ្ពុលំបាកយាកយ៉ឺនយ៉ាប់
ដួលខ្លួនខ្លួនក្រោកមកប្រញាប់ ដោយស្តាយក្រែងស្លាប់ក្នុងអគ្គី ។
ហើយខំធ្លង់ចិត្តគំនិតរឹង ធ្វើយតបពោរពឹងថានារី
សុខចិត្តខ្លួនទោសទាំងពីរ ពុំស្តាយជីវិតវិតក្សយ ។

តាមផលនៃកម្មប្រចាំជាតិ សន្ធតត្រូវឃ្លាតតាមនិស្ស័យ
ព្រោនបុណ្យសំណាងកសាងថ្ងៃ តង់ជានបច្ច័យទៅថ្ងៃមុខ ๗
រួចនាងសំយុងក្បាលឈោកដៃ ទឹកគុណគោរពប្រើមានខុក្ខ
ទោទន់ធ្ងន់ខ្លួនខ្លួនមិនសុខ ចិត្តវិតកកុកកុលខ្លាំង ๗
នៅស្ងៀមក្រៀមក្រំកុងតុក ឥតមានស្តីថាឲ្យពួកខ្លាំង
ទំរួនវិញ្ញាណគ្មានកន្តុកាំង គ្មានភ័យតិតកាំងជាត់ស្មារតី ๗
ពេលនោះពេញកនាយកូយុំ នាំគ្នាបួលជុំចាប់ស្ត្រី
ជាក់ខ្នោះជាក់ឃ្នាងនាំនាងខ្ចី ទៅតុកខុកស្រីដួចសព្វជន ๗
រត់ចាំតែដល់ថ្ងៃធ្វើតត់ ខឹងនាំទៅជុតជុតជាមួង
ពិបាកកែក្បាតោកកន្ទួង ដោយខ្លាចខ្លួនល្អងគេបង្ខូចព្រួយ ๗
ទៅថ្ងៃសាមសិបទៃរម៉ៃក្រោយ មួយតាន់បួនរយសាមសិបមួយ
ជាថ្ងៃហ្វ្រីដាកំផុតមនុស្សជួយ ស្រីស្រស់ជំនួយរលួយសុន ๗
ពាហានតង់គ្រូស៍ទ្វេតាន់ថ្មាយ ត័ន្ធទ្លោមនោមធាយចេញពីក្នុង
ឆ្ពុំត្រដាំដ្ឋាចបែកកុង ឈមមុខទៅសុំនត្រូវអូតំ ๗
ដៃលពួកកង់គ្រូស៍សង់ប៉ាធា មួយទៅកន់ផ្ទះប្រាថ្នាចង់
ប្លុជាតាវែតឯងអគ្គិ តាំងរសេទៅត្រង់កណ្តាលភ្លា ๗
មានរៀបតំនាតអុសចាប់ បំរុងរួចស្រេចខុកទៅនា
មានតួចមានធំចងរុំគ្នា ខុកនឹងប្លុជាពុំធ្លាស្រី ๗
លុះបានដល់ទៅទីប៉ាធា រួចស្រេចកាលណាខាងមិនភ័យ
ប្រុងចិត្តឥតស្ងុតមានស្មារតី ខឹកគុណគោរពនៃទេវតា ๗

តាមពាក្យសង្ឃរាជយេសូម្នាក់ វៃជាដីវាល់ក្តណ៌ជញ្ជាក់ថា:
ឲ្យនាងប្រុងប្រៀបរៀបអាត្មា កុំគិតទៅណាការនាងមិ ។
ឲ្យនាងផ្សឹងស្តាប់ចាប់តាមណ៌ ព្រះធម៌ទត្តមប្រណាមល្អ
ឲ្យស្ងៀតចិត្តក្តួចផ្តួចរតនធម៌ ទៅឯភ្នំជព្រះយេសូ ។
ថ្ងៃនីពីអ្នកស្រុកកូមំជិតឆ្ងាយ ក្មេងចាស់តាំងឡាយមកស្តាត់ឈូ
សព្វប្រកល្អកផ្លូវមិនទៅយូរ តាមមើលយេសូឲ្យធម៌ស្រី ។
ខ្លះកើតសង្វេគទឹកភ្នែកហូរ អាណិតអាសូរក្នុងហ្វូងយ
ទំអត់សង្កត់មិនចេញស្តី ខ្លាចគេជំនឹក្តីពិន័យខ្លួន ។
ពុក្តម្នាគោមេញគេញអត័ភ្ញ នាំគ្នាត្រឡប់ទៅតាំនជួន
ចើកភ្នែកក្រឡេកឃើញតែខ្លួន គោះបើដើរពួនក៏ពុំបាត់ ។
ការនាធម៌ចប់សព្វគ្រប់ហើយ ទើបបានត្រាណាត្រើយក្រោកប្រយ័ត្ន
ចើកភ្នែកក្រឡេកឃើញប្រកាត់ មនុស្សច្រើនពេកក្តាត់ពាសពេញផ្សារ ។
ដើយដើបមើលលើស្មើរជាច់ឡាល់ សំឡឹងប្តឹងដល់ទៅទេវតា
ជាក់ភ្នែកក្រឡេកមកអាត្មា ហួសទៅបា"ធាឃើញអុសតរ ។
សំឡក់ភ្នែកធំពុំចេញស្តី ស្មើរឮយឆ្ងុះដើហួសតំនរ
ទើបមានទឹកភ្នែកបែកហៀរមក ញាប់ញ័រខ្លួនខ្លាចជីវិន ។
នាងលើកដៃជ្រោងទៅទេវតា ហើយថ្លែងវាចាដោយទន់ហន់:
ស្តាយស្រុកស្តាយភូមិដែលប្រកិន្ត ស្តាយពុំបានទាន់ជួយអាសា ។
រូអង់! រូអង់! មើលមុខខ្ញុំ ថ្ងៃក្រោយអ្នកកុំកើតទុក្ខា
ឲ្យប្អាស់ទាន់ខ្ញុំនៅជីវ៉ា ចង្កិចអាត្មានឹងសូន្យហើយ ។

រួចនាងមហាណ្ណាយឱ្យគេចង ច្រើនជាន់ចំណងចងកៀកកើយ
កៀកគិតរិតខ្លួនខ្លួនគ្រាណាត្រើយ រួចស្រេចចាប់ហើយលើកយកទៅ ។
ដោតចំកណ្តាលគំនរអុស ក្រឡេកឃើញខ្ពស់ល្អាស់សន្ធៅ
សង្ឃឹមជយោសូមបរបូលទៅ បង្ហាញពាលពៅរូបព្រះអង្គ ។
ឮនាងសំឡឹងពិចារណា កុំភ្លេចអាត្មាចិត្តត្រង់
នឹកគុណយេសូគ្រីស្ទោចស្រង់ នាងក៏ប្រុងផ្តង់តម្រង់ខ្លួន ។
ភាវនាជាន់ជួមិនភ្លេចសោះ នឹកគុណគាំងអស់ពេញសំខ្លួន
សូត្រធម៌បរិសុទ្ធមិនសូន្យខ្លួន តាមដោយនៅក្បួនដំបូនព្រះ ។
ភ្លើងកាន់តែឆេះៗ ខ្ពស់ឡើង អណ្តាតផ្ទាតបើងហួសស្រឡះ
ដោយប្រែធនធ្វើឱ្យលំដាប់ណាស់ ចំហាយទៅប៉ាំសំដើងម្តងៗ ។
បណ្តាលស្រែកប្រញាប្រញាយ ឈឺផ្សាអួលណែនសែនសៅហ្មង
នាងរើមិនរួចគ្រោះចំណង ទំទាំមាត់ផ្សងតាមក់ស្នា ។
ផ្សងដឹតស្ងួតមេឃក្រឡេកទៅ ពពកខ្មួលខ្មៅក្តៅអស្ចារ្យ
ឃើញខេពហ្មុតសុទ្ធខេវតា ឯតាសាមមាប្រថពី ។
មិសៀល! មិសៀល! នាងហៅឈ្មោះ សូមជួយសង្គ្រោះដល់អញ្ជលី
មិសៀល! មិសៀល! ជួយនារី ធ្វងចេញអំពីទីនេះទៅ ។
ចំណែកឯភ្លើងឆេះឡើងខ្លាំង គេញទៅកម្ចាំងភ្លឺសន្ធៅ
ឱ្យលំបាក់បោកអុសឆេះខ្ពស់ទៅ ដល់ខ្លួនតោមទ្រៅត្រូវចំហាយ ។
ក្តៅគេកនាងស្រែកឮល្ហើយ ជាទីលោកកើយភ្លើងដល់កាយ

ឆាបដេះលៀះលៀបខ្ទាចគ្រហាយ ឃ្ប៉ូយ! យ៉ាយ! យ៉ាយ! យ៉ាយ!
ត្រៀណាស់តើ ៗ

ត្រោយមកព្ធមាត់នាងបួងសួង គុណបុណ្យតាំងពួងល្អប្រសើរ
ដល់ទៅទេវតាដែលបានប្រើ ឲ្យនាងមកស្នើធ្វើបំបាំង ៗ
នឹកគុណយេស្ប៊ីត្រូសាស្នា ជាប់ទៅទាមិនត្រូចភ្ទាំង
ដរាបជាបដល់ឲ្យល់កម្ទាំង ក្លូចទ្ទាំងបាំងចាប់ស្ទាប់ទៅហោង ៗ
ធ្វើតត់រំលត់ជុតហ្ស៊ីនជាកិ ចំជាអស្ចារ្យកាចចំបង
ឃើញស្ទាចទ្ទាចស្រែងត្រែងកន្ទង ជុតតាំងរសផងដោយចងស្រី ៗ
អង់ត្រូស៍លុះព្ធនាងស្រែកហៅ ទេវតាក្នុងត្រៅជូញ្ជោះនៃ
ផ្ទឿពិតអាណិតអាសូរស្រី កើតមានសេចក្តីភ័យអន្ទរាយ ៗ
យំសោកបោកខ្ទួនតាំងអស់ត្នា នាម៉ឹនប្រជារាស្ត្រជិតឆ្ទាយ
ពួកពលសកលផងតាំងឡាយ សោកស្តាយកាយស្រីហ៊ីយភ័យខ្ទួន ៗ
ចាយើងធ្វើតោសនោះពេញខុស ជុតស្រីតាំងរស់មិនសមស្ទួន
ជាស្រីមានធមិល្អក្នុងខ្ទួន ព្រហ្មាវិហារតាំងបួនន្ទួនកាន់ខ្ជាប់ ៗ
ដឹងខ្ទួនចាខុសហ្ជូសទៅហ៊ីយ អង់ត្រូស៍មិនសៀយដើរត្រឡប់
ទៅវិញពេញទុក្ខមុខអភ័ព្ធ ដង្ហើមធុញថប់ចំប្រប់អឺយ ៗ
ចប់ដោយសន្ទូបតែប៉ុណ្ណោះ

×

× ×

ផលនៃការអានរឿងសង្សនជាតិ

សាវតារនៃតុញ្ញ ហ្ស៉នជាតិ
ប៉ើលោកអ្នកបានអានហើយកើតទ្វាចផ្សា
ស្តាយនាវីដែលជាទីពេញចិន្តា
យកអាសាជួយផែនដីនៃបាកំង ។
រួចពីស្តាយនាំឲ្យក្ងាយចិត្តក្ងាហាន
ហ៊ានលះប្រាណចូលតយុទ្ធនឹងពួកឆ្មាំង
ដែលប៉ងមកយករដ្ឋយើងជាទាសាំង
ហ៊ានតតាំងស៊ូតែស្វាប់ជូចហ្ស៉នជាតិ ។
យកអាសានៃរដ្ឋាហើយស្វាប់ទ្ធូន
តាមក្នុងក្សួនសុកាសិតពិតដៀងជាត់ :
"រស់ក៏តាប់ ឆាប់ក៏ឆួរ ត្ងត្រប់ល៉ក្ងណ៍"
ជាតិទុកជាត់ថ្នាត់ "មហាបុរសរក្ខ" ។
ជាតិធ្វើបុណ្យរំលឹកគុណទួបរាល់ឆ្នាំ
ជាប្រចាំជូចបាកំងធ្វើប្រាកដ
"បុណ្យហ្ស៉នជាតិ" ជាទំនៀមទៀមជាដ្នត់
យើងឆ្ងរកត់យកតម្រាប់តាមទៅអឺយ!

យូរ-អ៊ុន

រឿងទេវន្ត

ពាក្យកាព្យ

លោកអម្ចាតក្សត្រី ម៉ុក រៀបរៀង

ក្នុងភាគ្យព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម

លោក ញ៉ុកថៃម ពិនិត្យ

អារម្ភកថា

រឿងទេវន្ទនេះ ជារឿងជាតកមួយ ក្នុងគម្ពីរបញ្ញាសជាតក ដែលអ្នកប្រាជ្ញបានរៀបរៀងទុកមកជាភាសាបាលី ក្នុងដែនសុវណ្ណភូមិ គឺជ្រោយទ្វីបអាស៊ី ដែលលយបេញពីតួទ្វីបទៅទិសខាងត្បូង ដែលជាទីតាំងប្រទេសនឹងប្រជាជាតិផ្សេង ៗ ជាប្រើន គឺយួន, ខ្មែរ, លាវ, ថៃ, ភូមា, ម៉ាឡាយូ តែគេមិនទាន់ដឹងប្រាកដថា គម្ពីរបញ្ញាសជាតកនេះ អ្នកប្រាជ្ញជាតិអ្វីបានតែងទុកមក ? ហើយបានតែងទុកមកក្នុងប្រទេសណាជាដំបូង ? ក្នុងព្រះពុទ្ធសករាជប៉ុន្មាន ? ។

ប៉ុន្តែតាមយោបល់យល់ស្មានរបស់យើង ថាបណ្ណាគម្ពីរជាភាសាបាលី ដែលគេបានតែងឡើងជាន់ក្រោយ ៗ មក ប្រើនតែតែងនៅប្រទេសលាវ ថៃ នឹងភូមា; ចំពោះគម្ពីរបញ្ញាសជាតកបាលី ប្រហែលជាអ្នកប្រាជ្ញជាតិលាវ ស្រុកធៀងហ្មែ ដែលនៅក្នុងអាណាចក្រថៃសព្វថ្ងៃនេះ ដោយបានរួបរួមរឿងរ៉ាវចាស់ ៗ ក្នុងស្រុកម្ចាស់ប្រទេសក្រៅ; រៀបរៀងជាភាសាបាលីឡើងរវាងសតវត្សរ៍ទី ៦០ នៃពុទ្ធសករាជ ហើយគម្ពីរនេះមានសាយកាយទៅពាសពេញក្នុងដែនសុវណ្ណភូមិ ដែលកាន់ព្រះពុទ្ធសាសនាលទ្ធិ

ហ៊ីនយាន, ក្រៅពីសុវណ្ណភូមិ ហាក់ដូចជាមិនមានគេដឹងឮពីឈ្មោះគម្ពីរ
នេះឡើយ ។

ឯរឿងព្រះកែងគម្ពីរបញ្ញាសជាតក ដែលអ្នកប្រាជ្ញបុរាណតែងតាំងប្រែ
ជានានាប្រភេទរៀបរៀងជាភាសាខ្មែរនោះ មានច្រើនរឿង ជាពាក្យកាព្យ
កំមាន ជាពាក្យឃកំមាន ដូចជា សម្តេចឃោសជាតក, សុជនជាតក,
សុជនុជាតក, រតនបជ្ជោតជាតក ទីឆ្នាំ សិរីបុល្លកិត្តិជាតក ជាដើម, ចាំឆ្នាំ
ជាតកនេះ ពុទ្ធសាសនបណ្ឌិតប្បាទបោះពុម្ពផ្សាយហើយ សុទ្ធសឹងជា
ពាក្យឃចាំងអស់, ឯជាពាក្យកាព្យនោះកំមានច្រើនរឿង ដូចជារឿង
ព្រះសុជន, សព្វសិទ្ធិ, សុកមិត្រ, វនាវន, សុវណ្ណសង្ខ, វេវង្ស, សុវង្ស,
បុញ្ញសារៈសិរីសោជាដើម ។

ចំពោះរឿងទៅទៀត ពាក្យកាព្យ ដែលរៀបរៀងជាភាសាខ្មែរនេះ
ជាស្នាដៃរបស់លោក អ្រម្រឹតក្សត្រី នាមដើម ម៉ុក កាលធ្វើជាមន្ត្រីក្នុង
សម្តេចព្រះវរាជជននី នៃព្រះករុណាព្រះចាខសម្តេចព្រះនរោត្តមព្រះសុ-
វណ្ណគោដ្ឋ លោកបានប្រែរៀបរៀងជាពាក្យកាព្យកាលពីក្នុងពុទ្ធសករាជ
២៤០២ ដូចមានពាក្យប្តេជ្ញារបស់លោកនៅខាងដើមរឿងនេះស្រាប់ ។

ប្រហែលលោកម៉ុកនេះហើយ ដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញជា
ជាងគេមួយ ក្នុងពួកព្រះករុណាព្រះចាខសម្តេចព្រះនរោត្តម តែតាម
ពាក្យសាមញ្ញច្រើនហៅថា លោកសុន្ទរម៉ុក ប្រហែលជាក្រោយមក
ទៀត ទើបបានមកធ្វើជាចាងហ្វាងកំនត់ព្រះគាល់ក្នុង នៅក្នុងព្រះបរមរាជ-

ភំង ក្រុងកំពង់ត្រាញ ទើបបានខ្លួលព្រះពរជាន់ជាវ ឧកញ៉ាសុន្ធរ
រៀហារ ។

លោកម៉ុកនេះ មានសេចក្តីដំណាលថាជាមនុស្សពិការដៃភាំងតាំងពីផង
តែក្រែងនដៃសងខាង ទើបមានពាក្យដន្ទដន្ទេញលេង ដែលឲាស់ៗ ចាំតៗ
មកថា ម៉ែងក្រងុំក ម៉ុកក្រងែង ប្រហែលជាប៉ុនតុកកំផ្លែងផង ។ មាន
សេចក្តីដំណាលថា ព្រះបុណាជាម្ចាស់ដីតែគ្រង់ប្រោសប្រាណណាស់
តែងតាមហែហមទៅគាន់តែដីតឡាយ , កាលណាគ្រង់ចង់ព្រះបណ្តាច់
ពាក្យកាព្យតែងគ្រង់មានព្រះបន្ទូល ឲ្យលោកសុន្ធរម៉ុកថ្វែងថ្វាយភ្លាម ។
ឯពាក្យកាព្យរបស់លោកនោះ មិនជាច់តិតគួរកេពាក្យបួនយូរទេ គ្រាន់
តែហាឡើង ក៏ចេញពាក្យកាព្យហូរទៅតែម្តង ។ មួយទៀត ព្រះករុណា
ជាម្ចាស់ដីតែគ្រង់ស្តាប់ស្តាលពាក់អាខលោកជាច្រើន ទើបគ្រង់ត្រាស់
ហៅថា ម៉ុក ។ ម៉ែងក្រងុំក ម៉ុកក្រងែង ដូច្នេះជារឿយៗ ។ ឯលោកសុន្ធរ
ម៉ុក ក៏មានបដិការណាកងរៃបស់ដាក់ព្រះពរជាតឲ្យស្រួយ ចេះដាច់ឲ្យប្រុង
តាមព្រះពរជាំណងគ្រប់គ្រា ។ លោកដែលគ្រង់ត្រាស់ជាមួយទឹងខ្លួន ។
ពាក្យកាព្យផ្សេង។ ដែលព្រះករុណាត្រាស់ឲ្យលោកសុន្ធរ ម៉ុក ថ្វែងថ្វាយ
ភ្លាម ។ នោះ មានច្រើនរឿងច្រើនអន្ទឹ មានកន្លែងខ្លះមានគេចាំពុកតៗ
មកដល់ឥឡូវនេះក៏មាន ដូចគ្រាមួយអស់អ្នកអស់នាងតំពុងចុះឆ្លងទឹកក្នុង
កំពង់ នៅទុកសបុណ្យចុះផែ ស្រាប់តែកំពត ១ខាំភ្លៅអ្នកមេនាងម្នាក់
អ្នកមេនាងនោះស្រែកតក់ឡើងពីទឹកមក, ព្រះករុណាគ្រង់ជ្រាបរឿងនោះ
ក៏មានព្រះបន្ទូលឲ្យសុន្ធរ ម៉ុក ថ្វែងពាក្យកាព្យថ្វាយឲ្យគ្រង់ព្រះសណ្តាប់

មួយរំពេច ។ លោកសន្ធរវៀហារកំប្លែងពាក្យកាព្យថ្វាយភ្លាមថា :

– កំពតកំពង់ចោះ ខាំបន្ទោះកន្ទៀតក្តៅ

ខាងនាជស្រែតវៀ:ស៊ី យកអំពៅព្រៃមកបិទ ។

គ្រាមួយ លោកអាត់ម៉ាល . . . . មេទ័ពជើងទឹក ជាកំងវែសស ចានចាត់ឲ្យបំរើនាំសត្វកែះពីរ ១ ឈ្មោល ១ ញី មកថ្វាយព្រះករុណាជាម្ចាស់ដ៏តែ ក្នុងព្រះបរមពាជកំង ក្រុងកុំពេញ, ក្នុងខណៈនោះទ្រង់ទឹក-ក្តកចង់ទ្រង់ព្រះសណ្តាប់ពាក្យកាព្យស្រស់របស់លោកសុន្ធរ ម៉ុក ទើបទ្រង់បង្គាញឲ្យលោក ម៉ុក មើលសត្វកំងពីរនោះ លោកម៉ុក ទូលជាពាក្យកាព្យភ្លាមក្នុងខណៈនោះថា:

– សត្វកែះកំងពីរ មួយឈ្មោលមួយញីសំបុរស្រស់

ក្បាលតូចមុខស្រួចក្រចកលស់ របស់អាត់ម៉ាលយកមកថ្វាយ ។

ក្នុងសម័យជាមួយនឹងលោកសុន្ធរ ម៉ុក នោះ មានកវីឯកម្នាក់ទៀត មានឈ្មោះស៊ីត្តិជាដំ ឬកញ្ជ្រៅរិទ្ធាធិបតី, កវីឯកនាំនិពន្ធបានបង្កើតសំដីថ្មីមាត់គ្នាជាច្រើនដង តែត្រង់ដែលមានគេចាំតៗគ្នាមកខ្លះនោះ គឺត្រង់ដែលលោកសុន្ធរម៉ុកតោលបង្អាប់លោកវង្សាធិបតីថា:

– សុន្ធរច្រាជ្រោក ច្រាជជាងលោក វង្សាធិបតី ។

លោកវង្សាធិបតីធ្វើវេបង្អាប់វិញថា:

– សុន្ធរច្រាជ្រោក ច្រាជត្រីលជាងលោក វង្សាធិបតី សរសើរខ្លួនឯង ត្រដែងដៃខ្លី បរញ្ជើសំដី ឲ្យស្រីកោតឯង ។

រឿងព័ត៌មានយ៉ាងដែលលោកសុន្ធរ ម៉ុក នៅមានច្រើនតទៅទៀត

តែដោយហេតុមិនបានកត់ត្រាទុកមកជាបែបផែន បានជាមិនមានសេស
សល់ជល់មកឥឡូវនេះប៉ុន្មានឡើយ រឿងធំ ៗ ជួចជារឿងទៅនួនេះ យើងមិន
ដែលបានប្រទះទេ ឆ្ងាប់ឃើញតែពាក្យកាព្យខ្ទី ៗ ស្នាដៃរបស់លោក គេ
បានយកទៅចុះផ្សាយក្នុងកាសែត ១ ឈ្មោះ ស្រុកខ្មែរ កាលពីជាង ១០
ឆ្នាំមុននេះ ។

តាមដែលយើងបានមើលពាក្យកាព្យផ្សង ៗ ដែលពួកចិន្តកវីបាន
តែងឡើង ក្នុងរជ្ជសម័យព្រះករុណាព្រះបរមកោដ្ឋក្តី ព្រះករុណាព្រះ
សុវណ្ណាកោដ្ឋក្តី នោះសេចក្តីចំរើនខាងរបៀបកាព្យឃ្ងាងខ្មែរ មានទំនង
ត្ងរឲ្យសរសើរជាច្រើន ទាំងលំនាំសេចក្តី ទាំងសម្ជស្សពាក្យចួន តែពាក្យ
កាព្យអស់នេះ បែរជាទាស់ត្រចៀករបស់ជនសម័យនេះខ្ងះ ចំពោះត្រង់
ដែលប្រើស័ព្ទបាលីច្រើងពេកប៉ុណ្ណោះ ប៉ុន្តែយើងមិនត្រូវបន្ទោស ពីព្រោះ
សម័យនោះភាសាបាលីជាឃ្ងាំងចំណោះវិជ្ជា ជាភាសាមានជំវិឡវិថ្ងថ្ងូរ ជា
មូលភាសានៃអក្សរសាស្ត្រខ្មែរ នឹងភាសាខ្មែរទាំងមូល បណ្តាប្រជាជន
ទូទៅទាំងជាន់ខ្ពស់ជាន់ទាប សឹងនាំគ្នាលើកជំកើងអ្នកចេះបាលីព្រះ
ត្រៃបិដកទាំងអស់ ទើបជាហេតុឲ្យអ្នកចេះបាលីមានសេចក្តីថ្ពុំថ្ពើង ទាំង
កេរ្តិឈ្មោះទាំងយសសក្តិ មានទំនងជួចសម័យសព្ទវិថ្ងនេះ ដែលរាជការ
លើកជំកើងអ្នកដែលប្រឡងជាប់សញ្ញាប័ត្រមធ្យមសិក្សា ឬទត្តមសិក្សា
ខាងវិជ្ជាបារាំងសែស ជួច្នោះដែរ ។

ចើពោលចំពោះពាក្យកាព្យរបស់លោកអម្រឹតក្សត្រី ម៉ុក ដែលបាន
តែងរឿងទៅនួនេះ យើញមានរបៀបតែងប្ងែកផ្សេងពីរបៀបរបស់ចិន្តកវី

ដទៃក្នុងសម័យជាន់ដើម ឬក្នុងជំនាន់របស់លោក គឺលោកនិយមប្រើ
ពាក្យកាព្យតែមួយបទ រហូតដល់ចប់ពុទ្ធចប់ដើម មិនប្រើច្រើនបទ ដូច
ជាចិត្តកវីឯទៀតៗឡើយ ដូចជារឿងទៅនេះ ជារឿងវែងលន្ទដ៏លន្ទៅច
គួរប្រើពាក្យកាព្យច្រើនបទ ទើបសមនឹងនៃរឿងដែលវែង តែលោក
ប្រើតែបទកាកគតិមួយ តាំងពីខាងដើមដល់ចប់រឿង ។

ក្នុងទីបំផុតនេះ យើងមានសង្ឃឹមថា រឿងទៅនេះពាក្យកាព្យរបស់លោក
អម្រឹតក្សត្រី ម៉ុក នេះ ល្មមជាគ្រឿងប្រដាប់សតិបញ្ញារបស់ជនាទុជន
ក្នុងសម័យសព្វថ្ងៃនេះបានខ្លះមិនខាន ដោយហោចទៅយើងនឹកសង្ឃឹមថា
ល្មមជាគ្រឿងបង្ហាញឲ្យយើងឃើញ ឲ្យយើងស្គាល់របៀបកាព្យឃ្លោង
ខឹងសំខួនកេហារបស់ចិត្តកវីខ្មែរយើង តាលព័ម្ភយសតវត្សក្រោយមកនេះ
ជាប្រាកដ ដែលល្មមចាប់យកជាមេគំនិតដឹកនាំឲ្យយើងតិតចន់តែផ
កាព្យឃ្លោងឡើងខ្លះ នៅទុកាសដែលប្រទេសជាតិកំពុងត្រូវការកសាង
អក្សរសាស្ត្រខ្មែរ ឲ្យបានចំរើនលូតលាស់ឡើងវិញនេះ ។

ហ្លួងនិពន្ធមន្ត្រី ញ៉ិក . ថែម

+

× +

រឿងនេះឯង

បទកាកគតិ

អហំវិត្វា អញ្ជលិយា បគ្គយ្ហា សីសបណោ ពុទ្ធេរាវិរញ្ញា-
ណរ ញ្ញាណសេដ្ឋោ ។ អហំនមា នមស្សិត្វា ធម្មគុណោ
គុណសង្ឃំ អហំនមោ នមស្សមោនោ រត្តិន្ទិវា ។

អញ្ជុំបង្គំ ក្រួញក្រាបប្រណម្យ ក្រោមព្រះបាទ ព្រះបរមសារេដ្ឋសាស្តា ព្រះអង្គជាតំណ មកុដកែវកែតវិត្រ ។ អហំអញ្ជុំ ក្រាបថ្វាយបង្គំ ព្រះធម៌ថ្លាថ្លៃ ប្រាំប៉ីហ្មឺនបួនពាន់ ធម្មខន្ធវិស័យ វិសេសក្រាសត្រៃ ត្រៃដ្រះតិស្តារ ។ អហំអញ្ជុំ ក្រាបថ្វាយបង្គំ តាំងពីបឋម(១) សាវ័កសាវក បច្ចេកពុទ្ធា ពោធិសត្តា ឥសីសង្ឃ(២)សព្វ ។ បង្គំគុណត្រូ វិញ្ញាណវិញ្ញូ តែងប្រដៅគ្រប់ អាចិតន្តបាល តម្លឹងចេះចប់ អញ្ជុំគោរព មាតាបិតា ។ នៅទេពទិសទស ខ្ជូតាំងសោឡស(៣) ន្ទូរមហាព្រហ្ម អញ្ជុំប្រតិស្ត នមស្សការ ចាតុរង្គ(៤)នៅនាលោកិយ ។ មានព្រះធតរដ្ឋ(៥) ធិពជមហាក្សត្រ ជាអធិបតី សូមរុឡ្ហីពារ ថវរសិរី សុខសាន្តសួស្តី ដូចភក្តីបំណង ។ សូមឈ្នះលោភោ ទោសោមោហោ ទុបទ្រព្យភ័យផង សូមសុខគាល់ចាន ខ្ញុំពានដូចប៉ង កុំបីមានហ្មង មារមកបំណ្ហា(៦) ។

សិរីសុភ: មង្គុរិ:(៧) វិរមង្គលា(៨) ពុទ្ធសាសនំ វិរិរិវ្ឍ(៩) វិរកាព្យា(១០) សារសព្ទសេបក្តី ។ ទ្វេសហស្សា(១១) បតុសតា(១២)ទ្វេសិរិប្បរី(១៣) ឯម្ភក(១៤)អ- ស្សុជ្ជមាសី(១៥) ព្រះហស្សតី តេតិត្តិយា(១៦) ។

១- ត្រួចមឬបឋមគឺបឋមមហាវីរ-បឋមសាវ័ក ។ ២- ពួកឥសី ។ ៣-ទូទាំងហាខសួគ៌ ១៦ជាន់ ។ ៤- ស្តេចចាតុលោកបាល ដែលស្ថិតនៅប្រចាំទិសទាំងបួន ។ ៥- ដែលឈ្មោះ ស្តេចចតុលោកបាលមួយអង្គក្នុងចំនួន៤អង្គ ។ ៦- ប្រែថា បៀតបៀន ។ ៧- សូមសិរីដ៏ ប្រសើរល្អក្រៃមាន ។ ៨-មង្គលដ៏ប្រសើរ ។ ៩- ចំប្រសើរវិសេស ។ ១០- កាព្យដ៏ ប្រសើរ ។ ១១- ពាន់ ។ ១២- រយ ។ ១៣- ខែងពីរថ្ងៃ ។ ១៤-ឆ្នាំមមែ ។ ១៥-ខែអស្សុជ ។ ១៦-ប៊ីកើត ។

សក្រាជត្រប់គ្រាន់ បួនរយពីរពាន់ ខឹងពីរសឹក្ខ គន់គិតគ្នេគ្នាន់ បច្ចុប្បន្នសាសនា មមែងឲ្យា អស្សុជ្ជមាសី ។ សុកប្បក្ខេ(១) តេតិត្តិយេ តុវ៉ារ(២) ប៊ីកើតតត់ឲ្យាស់ ប្រហស្សតិ កិរកាលអង្គិរ . សូរសេមសត្តា ។ ប្រកបព្រះក្តី ប្រាកដបឹតថេរ ជាពជមាតា លឿឲ្យាឆ្ងាយ ប្រុះប្រាយ ប្រាជ្ញា ន៊ីនេះអ្នកណា(៣) ខ្លូរស្មើហ្មាមី ។ ទ្រង់ព្រះនាមករ សម្តេចព្រះវរ ពជជនន៊ី វរៈខត្តិយោ វង្សសិរី សេដ្ឋារី វរកេតុម ។ បរម គុណ សកលមង្គល ឧត្តមបរម ប្រសើរប្រសំខ្ជឹ ចតិត្រជាអំ-ម្ចាស់ប្រសើរសេម បិតរលើសិរសៅ(៤) ។ ស្តេចទ្រង់សំលឹ ទន្តីសច្ចំ អាចអត់មេត្រី ទោសទុក្ខ សាត្វសត្វ ខុតិតក្រក្រី ប្រោសប្រាណប្រណី ដោះដោយទោសទុក្ខ ។ ទ្រង់ទូរទេសតិង ពជធម៌ក្រមក្រិត្យ(៥) រីរស្តេសោតសុខ ថ្កើងបុណ្យ រ៉ាំង្គន៍ បំបាត់ភ័យជុក ប្រេមប្រោសទោសទុក្ខ ជ្រួតជាមគា ។ ធម៌ព្រះកម្មដ្ឋាន សោតទ្រង់រៀនជាន ប្រសើរថ្លៃថ្លា តិតគុណាតេត្រៃត្រៃ តាំងចិទ្ធគ្គណ(៦) តែងទ្រង់មេត្តា ជាតែសត្វសត្វ ។ ស្តែងស្តេចមកតាំ នៅភ្នំហ៊ីយទ្រង់ សាងអង្គរសេត្ត(៧) ប្រុងស្តុបស្តែង កោតក្រែងបុណ្យ ក្តាត់ ហើយទ្រង់ចែងចាត់ ព្រះពជទ្រព្យធ្វើ ។

(មានត)

១-ខាងខ្នើត ។ ២-ថ្ងៃព្រហស្បតិ៍ ។ ៣-តើជាអ្នកឯណាមួយ ។ ៤-តាំងតែពីតក្សត្រាសម្តេចព្រះវរពជជនន៊ី... ...ប៊ីរលើសិរសៅ ជាព្រះនាមព្រះពជមាតា...សេដ្ឋារីវរកេតុម ដូច ។

៥-ទសពិធពជធម៌គឺធម៌សម្រាប់ស្តេចទេប្រការមានទានខឹងបរិភោគជាដើម ។ ៦-ឧត្តរកនខ្ពស់, ខ្ពង់ខ្ពស់ ។ ៧-អង្គិរសេត្តនេះគឺភ្នំសាងព្រះពុទ្ធរូបកំពស់១៨ហ៊ីត ដែលហៅ ព្រះអង្គិរសេ នៅភ្នំព្រះពជនៃទ្រព្យ ស្រុកខេត្តកំពង់សៀមថ្ងៃនេះ ។

សុភាស៉ិតប្រដៅជនប្រុសស្រី

ព្រះយោសធម្ម ម៉ឹង_សៃស

ចៅអធិការវត្តមហាមន្ត្រី សង្កាត់លេខ ៤ ក្រុង

ឡៃបឡៃង

(តមក)

៣២.–នាភឹ ទស្សៃតិ សុន្ទរី បន្ទាញនូវនាភីផ្ទឹតអាត្មា
ឲ្យប្រុសយើញឆ្លបកាន់ដោយស្នេហា ដោយកិច្ចកលមាយាមាតុគ្រាម ។

៣៣.–អក្ខឹ និទន្ធតិ កន្ទា នារីត្រេកកាមាផ្ទីញាយាម
យកដៃកៀសត្នែកវំពេចភ្ទាម ប៉ឹងឲ្យគេបែរតាមមើលខ្លួនជាក់ ។

៣៤.–ភមុកំ ទក្ខិបតិ ថី ធម្មជាតិជាស្រីតែងមានញាក់
នូវចិញ្ចើមនៃខ្លួនដោយចិត្តស្មឹត្រ ស្នេហារួបរួមរាក់ពេញចិន្តា ។

៣៥.–ទុដ្ឋំ បលិទតិ ឥត្ថី ជនបានជាតិជាស្រីកបតណ្ហា
យកផ្នេញបំកខាងក្រោមនៃអាត្មា ប្ជូតបបូរមាត់ថ្ទាបំកខាងលើ ។

៣៦.–ជីវ្ហំ និល្លាលេតិ នារី ស្រីកើតនាលោកីយផ្ទើអំពើ
លៀនអណ្ណាតបេញត្រែមផ្ទីងផ ឲ្យប្រុសចិត្តសើរ៉ើមើលខ្លួនលេង ។

៣៧.–ទុស្សំ មុញ្ចតិ រមណី ស្រាយសំពត់បេញពីបន្ទេះឯង
រលាស់រលាមមើលទៅស្តាំផ្ទេង នាំឲ្យប្រុសផ្សងៗកើតមេត្រី ។

៣៨. ទុស្សំ ពន្ធតិ ទយិតា ចងសំពត់អាត្មាវិលវិញថ្ម
ដោយដឹកទាញចិត្តប្រុសឲ្យបេតី មាយារបស់ស្រីបែបនេះមាន ។

៣៩.- សិរសំ មុញ្ជាតិ ពន្ធ្នា ស្រោយក្ដងសក់អាត្មាដោយគតិឥន្ទ្រាន
ទ្បៃគេមើលចំហើយត្រេកចង់ជាន តាមច្បាប់ពីបុពណាមិនខុសគ្នា ។

៤០.- សិរសំ ពន្ធតិ នារី ដនជាន់ជាតិជាស្រីកបមាយា
ស្រោយក្ដងសក់ខ្លួនជាធម្មតា ត្រឡប់ចងរំញៀជាប្រក្រតី ។
ដែលជាន់ថ្ងាថ្ងៃនៃចិកយរៀបរាប់ ជាច្បាប់មាយានៃដនជាស្រី
ចំខ្លួនសែសិបតត់តាមបាលី គុណាលជាតកស្តីថ្ងៃនៃចិតបាប់ ។
ទៃមានឆ័នារីល្អកបកល្បាណ កបដោយបញ្ញាញាណឈ្វាសវៃគ្រប់
ចូរមើលចូរស្តាប់ច្បាប់ទ្បៃជាន សព្វ ចូរតែបត្រឡប់យកត្រង់ល្អ ។
ធម្មតារបៀបស្រីដែលឆើតស្អាត មិនបំដៀតាមទ្វាតជាទ្បៃស
មិនសំដៅយកមានប្តីជាក្រ សំដៅយកត្រង់ល្អសព្វគន្ធតាយ ។
ល្អគ្រប់ទាំងកំពស់ទឹងទំហំ ក្បាលដៃដើងសក្តិសមត្រគាកសាយ
ដំណើរលំនាំមនល្អឆើតធាយ មិនធ្លាប់ប្រឹនកែក្រាយតីល្អឯង ។
ម្ខួយ ទៀតនារីល្អមានប្រាំយ៉ាំង: ល្អមាត់, សាច់ដាសំអាងឃើញជាក់ស្តែង,
ល្អឆ្អឹងទឹងសម្បុរស្រស់ឈ្លាសមែង, ល្អយែងមានអង្គន្ធវែងយូរឆ្ងាយ ។
សក់ប្រាំដូចទន្លុងនៃបក្សីភ្លុក ស្រោងចំលង់ឃើញរស្មីឆ្លុះ ស្រាយតាយ
សំយុងដល់ឆ្កងឆ្កួនចុងកន្ទុយសាយ ដ៏ឡើងបេះត្រង់ស្រាយល្អសួនាប់ ។
រមែបបួរមាត់នៃនារីណា ក្រហាមខ្មៅដូចផ្លែទន្លាប់
ត្រីវស្មើគ្នាជិតស្និទ្ធប៉ិទ្រឹមជាប់ នារីនោះមានភ័ព្វ ហាសល្អសាប់ ។
ល្អឆ្អឹងគឺធ្មេញនៃនារីណា សម្បុរសស្មើគ្នាជិតមិនដាច់
ដូចយកកេរជ្រមកដាំជាដួរក្បាច់ នារីនោះបានស្រែងហៅល្អឆ្អឹង ។

សម្បុរស្បកនៃនាងនារីទ្មៅ មិនបាច់លាបដោយម្សៅជាទីពឹង
ផ្ទរផង់ក្ងឹបឹព្រងល្អស្អាតក្ងឹង ត្ងរប្រៀបធៀបនឹងទប្សលទៀត ។
សម្បុរស្បកនៃនាងនារីស ផ្ទរផង់ហ្នត់ល្អក្ងឹស្រស់ស្រៀត
ប្រុសយើញស្រឡាញ់ស្ទើរលិទ្ធក្រលៀត ប្រុសផ្អើលមើលឧល់ឧៀតត
ត្រប់ត្នា ។

នេះហៅស្រីល្អសម្បុរស្បក តម្រាស្រីល្អឯកតាមវាសនា
ជាផលបុណ្យទានសីលភាវនា អប់រំសាងល្អជាពីព្រេងនាយ ។
ស្រីណាមានរូបល្អវ័យដំបូង សម្រាលកូនប្រាងប្រូងប្រើនរៀងវាយ
វ័យនៅតែល្អនឹងមិនវប្រក្ងាយ ស្រីនោះសោតបរិយាយហៅល្អវ័យ ។
រូបស្រីល្អជានុយបញ្ជោតពាល ឲ្យកើតត្រេកត្រអាលទាំងយប់ថ្ងៃ
ឲ្យវង្វេងភន្តកាំងបាត់ព្រះត្រៃ ល័ក្ខណ៍ដោយឥតសង្ស័យក្នុងចិន្តា ។
តឹកៃចត្រង់ធមិចាអនិច្ចំ គៃចទាំងទុក្ខំនឹងអនត្តា
ស្រវឹងវង្វេងជូចធឹកសុវា កើតទាំងលោភតណ្ហាប្រើនពេញទី ។
ឃើងបានថ្ងាថ្ងៃងចែងចរចា ចងជាពាក្យកាព្យាប្រដៅស្រី
ឲ្យស្គាល់ការខុសត្រូវកិច្ចការអ្វី សង្ខេបចប់សេចក្តីតែបុំណ្ណៈ ។

×

× ×

ពាក្យប្រដៅប្រុស

បទពាក្យ ៨

នេះនឹងថ្វាថ្ថែងបែងជាពាក្យកាព្យ ឲ្យអ្នកប្រុសបានជ្រាបសព្វសេចក្តី
តជាប់មកពីពាក្យប្រដៅស្រី ប្រុសផងគួរគប្បីទុកជាច្បាប់ ។
ជាតិមនុស្សកើតមកបានជាប្រុស កុំឲ្យមានខូចខុសទាស់ជល់ស្ទាប់
មិនសេពគប់ឲ្យត្រូវរកបំណាប់ ឲ្យទៅជាអាប់មួយជីវិត ។
គួរសេពគប់ស្និទ្ធស្នាលរកអ្នកជា អ្នកមានប្រាជ្ញាគប់សុចរិត
ដែលមានគតិល្អជាបណ្ឌិត ប្រព្រឹត្តត្រឹមត្រូវផ្ទូវទាំងប្រាំបី ។
កាលដែលខ្ជិននៅតូចខំប្រឹងរៀន អក្សរជារបៀនជំបូងថ្មី
ទាំងលេខនព្វន្តគណិតគួរអ្ចឹ ឲ្យចេះបាំមានថ្ថីដែប្រាកដ ។
ឲ្យចេះគតិធមិតតិលោក បានជាអ្នកប្រាជ្ញត្រោកត្រូវបែបបទ
ប្រដៅខ្ជិនឲ្យល្អត្រូវខ្នាតគត់ ទើបគួរបង្ហាត់ពត់អ្នកជទៃ ។
កាលដែលខ្ជិននៅតូចរក្សាខ្ជិន ឲ្យសុខល្អមាំមួនដោយប្រពៃ
កុំឲ្យបាក់ត្រេចថ្ថស់អស់ដើងដៃ ឬខូចកែ្នកសរសៃជាដើមអាទ៍ ។
កុំឲ្យមានទាស់ទែងឈ្លោះប្រកែក ប្រកាន់ពាក្យជដែកឥតមារយាទ
ឲ្យចេះជឹងគួរសមនឹងពួកញាតិ នឹងអ្នកជទៃឃ្ងាតមោះហ្មង ។
ឲ្យចេះកោតក្រែងខ្ទាចបាស់ព្រឹទ្ធា មានវ័យហួសជាអ្នករៀមច្បង
នឹងអ្នកមានសីលសុទ្ធទៀងត្រង់ផង ប្រតិបត្តិឥតឆ្គងផ្ទូវវិន័យ ។
នឹងអ្នកមានជាតិខ្ពស់ខ្ពង់ត្រកាល ជាក្សត្រីមហាសាលថ្ពើងថ្ថាថ្ថែ
កុំប្រមាថមើលងាយដូចសត្វត្រៃ ក្រែងកើតទោសចង្រៃបាបត្រោះ ។

ចូរវៀនទិយាយពាក្យសុភាសិត ឲ្យជាវិពេញចិត្តផ្អែមឥតពេះ
កុំវៀនហាត់ទិយាយពាក្យក្រគោះ ចេញសំដីបោកបោះឥតគួរសម ។
ផ្គត់ផ្គង់ឪរិយាបថវាំងបួន ដើរកន្ទិយឲ្យសមស្មួនតាមច្បាប់ក្រម
ដើរឈរទំនឹងអង្គុយតំរមទម អប់រំវាំងបួនតាមឲ្យសមល្អ ។
រៀនធ្វើខ្លួនឲ្យមានសណ្តាប់ធ្នាប់ តំរិយាគួរគាប់តាមមានក្រ
កុំធ្វើឲ្យហួសហេតុខ្លៅជាស កុំយកជាតិសំណាងធ្វើជាគ្រោក ។
ខ្លួនក្រកុំធ្វើឫកដូចសេដ្ឋី ឫកបួចមន្ត្រីអ្នកមានស័ក្តិ
កុំអួតសរសើរខ្លួនតាំងពាក្យល័ក្ខណ៍ សរសើរស្តីឲ្យគាត់ខ្លួនថាយថោក ។
បើគេមិនសួរទេកុំឆ្លើយជួន ទិយាយហួសបំណងច្រើនគរគោក
បើគេមិនហៅទេកុំទៅឈោក នាំខ្លួនឲ្យក្រោកក្រោកហិនលក្ខណា ។
បើមានសម្បត្តិច្រើនជាន់ច្រើន កុំឆ្មើងឆ្មៃព្រហើនកាចបូសា
ឲ្យមានចិត្តទោរទន់ករុណា ដាស់ជនឆន់នានាទំនងក្រ ។
កុំមើលងាយមើលថោកអ្នកក្រខ្សត់ ធ្វើឲ្យត្រូវបែបបទអ្នកចិត្តល្អ
គួរសង្គ្រោះជាក់ខានជាយសអ្វ តាមជាស់ខុតៗពីបូរាណ ។
បើបានជាអ្នកធ្វើស្រែចំការ ជាផ្លូវកសាងការទុលខាន
ចូរអ្នកទំប្រឹងប្រែងរកឲ្យមាន កើតសម្បត្តិធនធានបរិបូណ៌ ។
ក្របីគោតិតឆ្នែអ្នកស្រែ គួរចេះថ្នាក់ថ្នមថែរយាយអាសូរ
ឲ្យបានជាត់ធំទាំងរស់នោយូរ នាំឲ្យខូលយុជូរសម្បត្តិច្រើ ។
កន្ទុះប្រទេសខ្មែរសម្រាប់ចង វៀរឲ្យស្អាតហ្មត់ចត់ជាការជាប់
ខុកជាមនុស្សមានសណ្តាប់ធ្នាប់ មានព្យាយាមគួរគាប់ប្រសើរជា ។

មើនណាគេមានកូនក្រមុំ គួរផ្សំធ្វើឲ្យជាការយោ
ដោយហេតុធ្វើការមិនខ្ជិលខ្ជាយ ចេះថែទាំរក្សាទ្រព្យសម្បត្តិ ។
គេលយប់ចំពក់ក្លិនជាធម្មតា ដោយចិត្តមានមេត្តាប្រណីសត្វ
កុំឲ្យមួសសុបទាំតើតវៃតិ តើតស្តាំនឹងស្តាមពេកក្តាត់ប្រើពុំបាន ។
ថែទាំស្មៅចំណីលាងទឹកផង គេលប្រើកុំសំពងហួសប្រមាណ
ផ្តុកឲ្យល្មមកម្ទាំងបន្ទុកយាន ឲ្យមានមេត្តាត្រាប្រណីសត្វ ។
សេចក្តីកងជាលីតម្លឺវ៉ា អ្នកមានការណ៍ប្រើនពេកក្តាត់
ឲ្យផុលមិនសូវមានពេគដម្ងាត់ បៀសវាងតិរវៃតិដោយពេគធ្ងន់ ។
ធ្វើស្រែត្រូវផ្គត់ផ្គង់ដើមសំណាប ត្រូវតែតបាត់ថែងឆាបតាមដំនង់
សាបហើយថែរក្សាមើលតយគន់ ត្រែនខូចដោយទឹកដន់ឬសត្វស៊ី ។
សំខូងល្អផលល្អគ្រោះសំណាប ដែលគេបាត់ថែងឆាបកងនាពី
ជុះឡើងល្អល្អតលាស់ស្រស់ទៀទ្បី សំណាបតែងយោងជីស្រីយោងប្រុស(១) ។
ធ្វើស្រែលើកភ្លឺស្រែឲ្យត្រឹមត្រង់ កុំឲ្យរៀបកូងកូងច្រើនខូចទុស
អ្នកផងគេនឹងថាអាកំហុស បាត់ជាមនុស្សលោកបបរី ។
អ្នកលោភតសុធាច្រើនបានទុក្ខ ច្រើនខាស់ទឹងអ្នកស្រុកច្រើនកើតក្តី
បន្ទឹងតទាំងប្រាក់កាសគ្មានសល់អ្វី ជាមនុស្សជួរអប្រិយសិក្ខាន ។
ផ្ទៃស្រែត្រូវបំប្រាបឲ្យរាបស្មើ បើទឹកតិចពាបលើសត្វខំហាន

---

(១)ពាក្យបុរាណថា "សំណាបយោងដី ស្រីយោងប្រុស", បើដីនៅតែសំណាបល្អ គង់ប្រាំបើ, បើប្តីអន់ប្រពន្ធប្រាន់បើ គង់ប្រាន់បើដែរ ។

ស្រូវល្អៈស្មឹត្រប់គម្ពមិរើនគ្នាន មិរើនគ្រាប់ស្រូវបានដូចប្រាថ្នា ៗ
សំណាបចាស់ល្មមការត្រូវដកស្ទូង ចាប់តាំងពីដំបូងស្រេចកាលណា
ត្រូវយកចិត្តទុកដាក់ចាំរក្សា ក្រែងត្រៀងដន់រំលាល់ចខូចខាត ៗ
ត្រូវយើងបង្ហូរចេញទុកឲ្យល្មម ឲ្យស្ទូងលាស់ព្រមល្អល្អូកស្អាត
ប្ចមួយបាក់ភ្ជីស្រេហូរហួសខ្នាត ត្លូវខិប្រឹងសង្វាតទប់ឲ្យជាប់ ៗ
ថែទាំចាំរក្សាទាំងថ្ងៃយប់ ព្យាយាមកុំឈរឈប់ជាទំលាប់
ទំនៀមអ្នកមានស៊ីអ្នកមានទ្រព្យ ប្រឹងប្រែងធ្វើការខ្ជាប់មិនកៀចគ្រាញ ៗ
ស្រូវចេញប្រុងប្រៀបដេញចាបលលក និងសេកកុំឲ្យមកស៊ីបំផ្ទាញ
ទោះនៀយហត់យ៉ាងណាកុំធុញគ្រាញ តាមផ្ទូវអ្នកជិនាញខាងរកស៊ី ៗ
ស្រូវទុំខិប្រូតកាត់ឲ្យរួសរាន់ ខំបោកបែនបញ្ជាន់ឲ្យពេញទី
អុំរាយចោលសំដីនឹងធូលី តាមច្បាប់ប្រពៃណីពីបូរាណ ៗ
ខំដឹកដៀវដញ្ជូនដាក់ជង្រុក ឲ្យល្មមតាមបន្ទុកសម្រេចបាន
ហើយដឹកស្រេចកាលណាកើតសុខសាន្ត បានស្បើយទុក្ខរំខានព្រោះធ្វើ-
ស្រូវ ៗ
បានស្រូវហើយកុំចាយឥតសណ្តាប់ សំចៃទុកតាមច្បាប់ដែលត្រឹមត្រូវ
ក្រែងអត់ឃ្ងានខ្ទះខាតដោយរដូវ ប្រព្រឹត្តដើរតាមផ្ទូវអ្នកមានទ្រព្យ ៗ
អ្នកធ្វើស្រែត្រូវធ្វើចំការផង ដំណាំមានរបង៉ឲ្យជិតជាប់
ឲ្យមានដំណាំប្រើនជាទំលាប់ ជំនួយស្រូវគួរតាប់ក្រែងអត់ឃ្ងាន ៗ
ខំដាំបេកអំពៅគ្រាវដម្ទូង ប្ចស្បីស្រុកស្ទាជូងត្នោតឲ្យមាន
កុំឲ្យខ្ទះត្រង់ណាដោយតិតធ្យាន ឲ្យបានបរិបូណ៌ត្រប់ប្រើប្រាស ៗ

លក់ដូរយកតម្លៃកម្រៃថាយ ចរិកោគសប្បាយស្រួលពេកណាស់
ហៅអ្នកមានត្រឹងស៊ីមិនចេះខ្វះ ថ្កុំថ្កើងតាមពាក្យថាស់ថាមានស៊ី ។
អ្នកខ្វិលជាំដំណាំច្រើនតែអត់ កូនចៅឯងមើលមាត់គេមើ
សម្លឹងមើលក្អៀកៗ ដោយសម្ដី មិនចេះធ្វើចំណីឲ្យកូនចៅ ។
អ្នកធ្វើចំការស្មុគ្មុនមិនធ្វើស្រែ គេជាំសព្វបន្ទែចេកអំពៅ
ដើមល្មូតនឹងដើមកូដ្ឋស្ទាដើមញ្ចៅ សណ្ដែកសសណ្ដែកទៀកប្បាសត្រូម ។
ជាំថ្នាំតក្រូចពោតក្រហមស ធ្វើទីដីឲ្យល្អល្អិតសុខុម
ពេលរៀបជារៀបជាំដោយដុំ ជាំតាមភួកតាមក្រុមទើបចំរើន ។
ជាំគ្នីស្រេចហើយតំបែរភ្ជាំ ព្យាយាមឲ្យមួនមាំទើបបានកើន
កុំខ្ជិលច្រអូសពេកខំក្រវែក តែងបានកើតផលច្រើនចិញ្ចឹមខ្លួន ។
លក់ដូរឲ្យហែហូរឥតលំបាក ជាភាគផលកម្រៃដោយតាប់ជួន
នេះហើយហៅថាផលព្យាយាមមួន ហូបឲ្យតាមចំនួនតែកម្លាំង ។
វិធីអ្នកស្រុកស្មែងរកអាហារ ដោយធ្វើស្រែចំការដោយសម្រាំង
សម្រិតដោយសុបរិតពិតសច្ចំ វិធីញ៉ាំងអាជីពឲ្យផុរផង់ ។
បើអ្នកចង់បានកូនប្រពន្ធ សម្លឹងមើលព្រត្យជនខនឹងពូជតន្ត
សម្លឹងមើលពូជចេះប្ដូរឡើងថ្ម សម្លឹងមើលពូជត្រង់ប្ដូរពូជវៀច ។
គន់មើលព្យាយាមច្រើនឬតិចខ្លះ ច្រើនដំអក់ខំនន់ខ្វិលក្រាញក្រៀច
ជាមនុស្សស្អាតបាតឬពុតត្បៀច ដូចសក្កច្រមីខ្វៀចប្រឡាក់កក ។
ពូជខ្លះច្រើនយកប្ដីដោយចិត្តឯង គ្មានមេបាជាតំបែងអប់បំពាក់
គ្មានស្ពាប់មេស្ពាប់បាជាឥតយក ជាមនុស្សតគ្រក់ប្រុសគួរខ្ពើម ។

តូជខ្វះច្រើនប្តីលែងនៅមេម៉ាយ ឥតមានសប្បាយផុតចុងដើម
ជួនកាលយកប្តីខ្មៅតធ្លុះជង្រើម ជួនកាលខ្វក់សម្បើមជាងមុនឆង ។
តូជខ្វះសាំងនឹងប្រុសមិនចេះស្រែក ដោយចិត្តជាប់តម្រេករួមស្នេហ៍ស្នង
ស្ងិតស្ងាលភៅនឹងប្រុសជូចប្អូនបង ឥតគិតការះមោះហ្មង់ដោយក្អែកគេ ។
តូជខ្វះច្រើនលួចលាក់តែបន្ទុំ ឃើញគ្រឿងទេសនឹងយកទេ
ខ្សេមឡឺមមើលនាយអាយបែរវិះវេ រិះរកឿងគេចកែងតំយកក្លាម ។
លួចទាំងតិចឯងមានខ្មីងខ្មាំ ទាំងគ្រឿងផ្សំនានាសត្វត្រប់នាម
ច្រើនតែមានពោសខ្វក់ច្រើនភ្ញាក់ខាម ច្រើនត្រូវការគម្រាមគុកច្រវាក់ ។
តូជខ្វះច្រើនឆ្កួតប្តីមានសហាយ ដោយសេចក្តីសប្បាយការរួមរ័ក
លួចលាក់ខ្លួនសន្សឹយកលុយកាក់ ឬយកគ្រឿងមាសប្រាក់ឲ្យសហាយ ។
តូជខ្វះមិនស្រឡាញ់ការសិក្សា គេនិយាយកាលណាមិនរីករាយ
ខុកកូនចៅឲ្យស្លន់មិនខ្វល់ខ្វាយ មិនឲ្យកូនសប្បាលដោយវិជ្ជា ។
តូជខ្វះច្រើនលោភដីរបងដើរ ច្រើនតែកើតជំណើរពោសវែងឆ្ងាយ
ព្រោះដីមួយចំអាមមួយហត្ថា បង់ប្រាក់កាសអាត្មាអស់គ្មានសល់ ។
សូម្បីបងប្អូនឯងរួមផ្ទៃគ្នា កើតពាសវែងឆ្ងាយក្រៃក្លាឥតយោគយល់
ព្រោះតែដីតិចតួចនាំអំពាល នាំឲ្យកើតវិលជល់មេស្រុក ។
តូជខ្វះច្រើនអំនួតអួតកុតករ និយាយលើសគំនរហួសបន្ទុក
បន្ទន់បន្ទាបគេដូចឈើពុក គេច្រើនតែស្អប់មុខខ្ពើមសំដី ។
តូជខ្វះប្តីដើមគេស្វាត់កំបាំង ល្បែងប្បិញ្ញាច្រើនពេកទាំងជួអប្រើយ
បណ្តាលឲ្យកើតឈ្លោះប្តេជ្ញាគ្នា ច្រើនបានគេស្រដីដើមតបវិញ ។

ពួជខ្វះច្រើនជាអ្នកស្ងួតកំណាញ់ ទុកជាឃ្វានឬស្រឡាញ់មិនហ៊ានចំរើ
ស៊ូស៊ីដោយសារតែសង្គត់ធ្មេញ មិនអាចហ៊ានបង្ហូញចាយស៊ីបុក ។
ពួជខ្វះតាបយោរយៅឥតសណ្តាប់ ច្រើនឈ្លោះវាយចាក់តាប់ជាន់ក្តីទុក្ខ
ចង់ច្រាក់បង់តាសហើយថែមត្រូវគុក មនុស្សជនក្នុងស្រុកច្រើនតា ។
អ្នកប្រុសផងតាំងឡាយចូរជញ្ជឹង ចូរគិតគូរពីតែកកើយ
ឲ្យជាន់ក្តីសុខសាន្តជល់តាគ្នា ក្រែងទុក្ខវេទនាសៅថ្ងៃក្រោយ ។
យកប្រពន្ធគ្រឿងធនស្មើតាគ្នា ស្មើត្រកូលវង្សឥតមានឡើយ
មិនមានមើលងាយគ្នាគ្រប់ជ្រុងជ្រោយ ជានសុខតាមអំណោយផលរៀងខ្លួន ។
បើជានប្រពន្ធហើយចូរសង្វាត ចំប្រឹងប្រែងរកឃ្វានឲ្យមាំមួន
ស្វែងរកគ្រឿងសម្បត្តិឲ្យសមសួន កុំឲ្យជានជួបជួនធ្វើចំលក្រ ។
ប្រយ័ត្នកុំឲ្យមានឈ្លោះប្រកែក ត្រូវពាក្យជនផែកស្តីតបត
ការប្រធាំងជាស់ចែងគ្នាមិនល្អ ជាដើម ហតុបង្កឲ្យខាតគ្រឿង ។
ព្រះពុទ្ធទេសនាប្រដៅជន ប្តីសង្គ្រោះប្រពន្ធដោយគួរគប់
ជាមានច្រាំប្រការដោយរៀបរាប់ ជនណាមានបុណ្យកុំប្រព្រឹត្តតាម ។

សម្មាធនារី ធម្មិកា សរសើរកិរិយាជាប់ដិតជាម
មិនឱយអាក្រក់អាសគ្រាម ពោលតាមធម៌គឺពោលពាក្យខ្ចង់ភ្ញាល់ ។

ឥហ ប អរិអាធនា មិនមើលងាយដៀលឲ្យប្រពន្ធ
មិនពោលពាក្យចាត់ដោតជាពាក្យធ្ងន់ មិនបៀតបៀនរិះគន់ឲ្យបង្អៀត ។

អបិ វិនតិបរិយា មិនកន្ធត់ចិត្តគ្នាមានស្រើឡើត
មិនក្បត់ប្រពន្ធឯងរកស្នេហ៍ត មានឲ្យកើតសង្ឃឹតសង្ឃឹរចិត្ត ។

ឥសប្បរិយេសប្បភេសប្បគ្គោ ចិត្តស្វាមីខន្ធោវនីតអាណាតិ
លេះបង់អំណាចខ្លួនខ្មោ ផ្តុតផ្តិត ប្រតល់ទ្រព្យធនពិតឲ្យប្រពន្ធ ។
អលង្ការាទុប្បទាតំ មេត្តាមានកម្ទាំងឥតរៃគន់
សែ្នងកេរគ្រឿងប្រដាប់ស្រាលឬធ្ងន់ តាមកម្ទាំងទ្រព្យធនខៃនអាត្ម ។
ឲ្យបានមានប្រើប្រាសដូចអ្នកឯង កុំឲ្យមានសៅហ្មងចិត្តត្រង់ណា
ឲ្យកើតសប្បាយចិត្តគ្រប់វេលា ហៅសង្គ្រោះតំយោតាមថាលី ។
ការសង្គ្រោះបែបនេះជាមង្គល ជាបុណ្យកុសលកម្មវិរ
ត្រូវតាមពុទ្ធដីកាព្រះជិនស្រី ជនជឿគួរគប្បីយកតម្រាប់ ។
មនុស្សទេវតាតែងសរសើរ ជាផ្លូវដំណើរល្អគួរគាប់
គួរគតប្រព្រឹត្តតាមកាន់ឲ្យខ្ជាប់ យកពុកធ្វើជាច្បាប់ប្រពន្ធប្តី ។
ថ្ងៃមួយព្រះឥន្ទ្រសុខទេវតា ទ្រង់ព្រះនាមហៅថាព្រះកោសីយ
ទ្រង់ចុះចាកឆ្កាសាទមានសិរី ទ្រង់សំពះទិសទីតាំងជាប់តគ់ ។
គ្រានោះទេវបុត្រមាតលី ឃើញព្រះកោសីយជាក់ច្បាកជ
ក្រាបបង្គំទូលសួរតាមវែបបទ ទ្រង់មានការកំណត់សំពះអ្វី ។
ព្រះឥន្ទ្រទ្រង់ធ្វើយបតតាមពាក្យសួរ តាមការល្មមសមគួរដោយសំដី
ខន់ក្ខន់ពិតច្បាកជអាថិសេចក្តី ដល់ព្រះមាតលីបានជ្រាបច្បាស់ ។
ឧបាសកឯណា មានសីលសុទ្ធ មានកំយោបុត្រគ្រប់គ្រងផ្ទះ
ទំសាងបុណ្យកុសលមិនដែលរលះ មានបញ្ញាតេជះសូតខៀងគ្រង់ ។
ចិញ្ចឹមកូនប្រពន្ធដោយធម៌ពិត មិនដែលវិបរិតមិនលះបង់
យើងលើកដៃដង់សំពះដោយផ្តិតផ្តង់ ចិត្តចំពោះតទ្រង់អ្នកនោះឯង ។

(មានត)

លោក សុីន-ហ៊ាន ប្រែរៀបរៀង

លោក យូរ អ៊ុន ពិនិត្យកែសម្រួល

(តមក)

១០

ចំណែកាលតាំងពីព្រះធម្មបត័ពជាបានព្រះពជសុណិសា សមតាម ព្រះពជបំណងហើយ ព្រះអង្គគំទ្រង់គ្រប់គ្រងព្រះនគរឲ្យចំរើនរុងរឿង ដោយព្រះពជប្បាទ័យដែលស្វែងរកធម្មានុភាពឲ្យជ្រាកដ ក្នុងរជ្ជកាលរបស់ ព្រះអង្គ, ព្រះពជការកិច្ចបានសម្រេចទៅដោយរៀបរយជាបរៀងមក, ព្រះអង្គទ្រង់ពិចារណាឃើញនូវសេចក្តីអនិច្ចនៃព្រះពជសុណិសាដោយ សេចក្តីពៀងត្រង់តាមធម៌ ព្រះអង្គទើបទ្រង់ផ្តួតផ្តាបក្នុងការណ៍យកតំណែ តំណងដែលសុរពលបានចាត់ធ្វើទៅតាំងក្រុងធីដាយឲ្យបានសម្រេចផលល្អ គ្រប់ប្រការ, ឯសេចក្តីអនិច្ចរបស់សុរពលនោះ ពុំមានអ្នកណាដឹងសោះ មានតែខ្លួនសុរពលនឹងនូនិអមាត្យប៉ុណ្ណោះទេ ដែលអាចដឹងបាន ព្រោះការ ណាដែលក្រគេកំប្រកួតនឹងបិតា លោកអមាត្យនូនិកំជួយណែនាំកែទៅឲ្យ គិតឃើញយ៉ាងល្អិតសុខុម គេទើបប្រតិបត្តិពជការបានល្អជាច់គ, ដោយ អំណាចនៃគុណគឺសេចក្តីល្អនេះឯង ព្រះពជាទើបទ្រង់តែងតាំងឲ្យជា ទេពជរបស់ព្រះអង្គ, កាលសុរពលបានដល់នូវឋានៈជាទេពជហើយ គេ កំគ្នានភ្លើតភ្លើនក្នុងយសស័ក្តិ តាមវិស័យរបស់អ្នកដែលធ្លាប់ជួបប្រទះគ្រោះ កម្មយ៉ាងធ្ងន់មកហើយ ត្រឡប់ជាគ្រាដ្ឋានដ៏ធំនូកបំរុងព្រះពុទ្ធសាសនា ដែលត្រូវគេបោះបង់ចោលឲ្យក្រុះក្រោមត្រឡប់រុងរឿងឡើងវិញ ដោយ

ការត្រិះរិះយ៉ាងសព្វគ្រប់ត្រមរដោយផែនការណ៍ដ៏ល្អហើយ គេកំព្យាយាម
ខំទុកបំរុងសេរីភាពត្យាងឆ្ងាយ មិនយូរប៉ុន្មានក៏សម្រេចតាមបំណង
នៅសល់តែព្រះពុទ្ធជាប៉ុណ្ណោះទេ ដែលព្រះអង្គទ្រង់ស្អាក់ស្ទើរព្រះទ័យ
តែមិនយូរប៉ុន្មាន សុរត្តសក្កំណៅទាំព្រះទ័យរបស់ព្រះធម្មបតីពុទ្ធជាបាន
សម្រេច ព្រះអង្គទ្រង់បែរមកជ្រះថ្លាក្នុងព្រះពុទ្ធសាសនាបានប្រកាស
ខ្លួនជាពុទ្ធមាមក; ពុទ្ធសាសនាក៏ឧត្តរោភសីក៏រុងរឿងមិនចាញ់ប្រៀប
ព្រះពុទ្ធសាសនាខាងក្រុងពុទ្ធគ្រឹះឡើយ; ទៅជាប្រទេសមួយមានការ
សិក្សាធម្មវិន័យខាងព្រះពុទ្ធសាសនា ជាហេតុញ៉ាំងការចូលចិត្តធម៌វិន័យ
ឲ្យកើតឡើង ដល់អាណាប្រជាពរស្ត្រ ។

ឧបាសុរត្តសក្ក ការបានឧទ្ទិសសេចក្តីសុខដោយយសទ្ធិសម្បត្តិ
ប៉ុណ្ណោះហើយ ក៏តែតែមានសេចក្តីភក់អាងអមាត្យចាស់តែដែលជាអ្នកខំទុក
បំរុងខ្លួនតែមក ដូចជាមាតាបីតារបស់គេម្ចាស់ក៏ថាបាន ចំណែកអមាត្យ
ចាស់តមានសេចក្តីគោតខ្លាចឧបាសុរត្តសក្កផ្លូវភាពការ ហើយប្រតិបត្តិ
តាមពាក្យសុរត្តដោយរៀបរយ តែកាលដល់វេលាក្រៅការភាពការ
ឧបាសុរត្តសក្កត្រឡប់ជាបុរត្តវិញ លោកអមាត្យចាស់
ទើបចូលចិត្តមកសន្ទនា ជាមួយនឹងឧបាសុរត្តរឿយៗ, រឿងសន្ទនា
គ្នានោះ តែរឿងជាប់ពាក់ព័ន្ធបុគ្គលិកនាគាញនា; ថ្ងៃមួយកាល
នៅជួបជុំមុខគ្នា អមាត្យចាស់តក៏និយាយអំពីបុគ្គលិកថា:

– ខ្ញុំប្រែមនុស្សនាំចុតហ្នាយមកញ៉ាក់សេចក្តីប្រព្រឹត្តរបស់ឧបាសុរត្តនឹង
គ្រួសារហើយ ហេតុអ្វីទើបយើតយូរស្រឹមស្ងាត់មិនមានដំណឹងអ្វី? ។

សុវត្ថិភាពមានកង្វល់ណាស់ជាធំលោកចាស់តអមាត្យ ដើរតម
តាមសេចក្តីយល់ឃើញថា:

- ខ្ញុំគិតថាមិនប៉ុន្មានថ្ងៃទេ យើងគង់ចាំបានដំណឹងខ្វះពុំខាន ព្រោះការ
ដើរផ្លូវហើយ យ៉ាងណាស់ក៏ដោយដែរ ប្រហែលអ្នកនាំសំបុត្រ
ទើបនឹងត្រាច់ដើរផ្លូវត្រឡប់មកពីក្រុងភនគ្រឹះវិញក៏ថាបាន ឬខ្ញុំស័ត្យ
កាលដឹងរឿងហើយ គេក៏មិនត្រូវនើយកន្តើយដែរ ។

- "មិនមែនដូច្នោះទេដឹង?" លោកចាស់តនិយាយទៀង "ខ្ញុំដឹង
ច្បាស់ថាសេដ្ឋីជាបិតារបស់ឫទ្ធិស័ត្យជាអ្នកប្រកាន់ខ្លួនខ្លះដែរ ដូចគាល
ចំពោះរឿងព័ទ្ធជាប់នឹងការចូលទៅរកអ្នកមានបុណ្យស័ក្តិ គាត់មិនត្រម
ពឹងពាក់អាស្រ័យអ្នកណាទេ គាត់គាចយល់ឃើញថាឥឡូវនេះសុវត្ថិ
ភាពជាទុកដូហើយ គង់នឹងមានចិត្តថ្មើមឃ្លាតឆ្ងាយពីគាត់ក៏ថាបាន ខ្ញុំស្គាល់
ច្បាស់នូវនិស្ស័យរបស់លោកម្ចាស់នេះណាស់ សូម្បីព្រះកថាហ្នឹងឯង សេដ្ឋ
នឹងចូលគាល់ក៏ចំពោះតាលមានព្រះកដិច្ចជាចាំបាច់ តាលបើដូច្នេះខ្ញុំយល់
ឃើញថាជាការបំបាក់បេក ខ្ញុំអាណិតតែបុត្តនឹងធីតារបស់គាត់ប៉ុណ្ណោះ,
ផែនដីភាំងពីរឃ្លាតឆ្ងាយពីគ្នាណាស់ ដូចម្តេចនឹងដឹងហេតុការណ៍របស់គ្នា
ឲ្យត្រាក់ត្រូវបាន" និយាយហើយលោកចាស់តក៏ដកដង្ហើមធំ ។

"ប្រហែលមិនជាអ្វីទេដឹងលោក! ចិត្តរបស់ឫទ្ធិស័ត្យនឹងនួនណាស់
ហើយឫទ្ធិស័ត្យគ្មាប់និយាយប្រាប់ខ្ញុំថា សេដ្ឋីមានសេចក្តីគោរមនសក្ការៈនូវ
លោកជាច្រើន តាលណានឹងពឹងពាក់អាស្រ័យលោកពុំបាន ប៉ែនឹងប្រកាន់
ខ្លួនខ្លះត្រឹមតែបន្តិចបន្តួចប៉ុណ្ណោះមិនជាច្រើនប៉ុន្មានទេ, ខ្ញុំចង់ដឹងតែត្រឹមថា

តើសព្វថ្ងៃនេះ ឬទ្ធិស័ត្យបិតនៅក្នុងក្រុងរាជគ្រឹះឬទេ?" សុរពលនិយាយ
ដោះសារជំនួសសេដ្ឋីជាបិតារបស់ឬទ្ធិស័ត្យដោយសេចក្តីសុភាព ។

ខណៈដែលកំពុងសនួនាគ្នានោះ មនុស្សបំរើបានចូលមកប្រាប់ថា
មានអ្នកត្រូវការជួបនឹងលោកបាលិត ។ ទើបឲ្យអញ្ជើញចូលមក ។

មួយស្របក់ទៀត, ក៏មានបុរសពីរនាក់ស្ពាយដាវដើរចូលមកជា
មួយនឹងមនុស្សបំរើ ហើយសួរថា "លោកបាលិតគឺអ្នកណា? ខ្ញុំជាមនុស្ស
បំរើរបស់ឬទ្ធិស័ត្យជានាយឲ្យនាំសំបុត្រមកជូនលោក" ។

-"យើងហ្នឹងហើយ" និយាយហើយអមាត្យបាលិតក៏ដើរចូលទៅ
រកមនុស្សទាំងពីរនាក់ដោយទឹកមុខស្រស់ស្រាយ ។

មនុស្សបំរើដែលកាន់សំបុត្ររបស់ឬទ្ធិស័ត្យជូនសំបុត្រនោះទៅ
លោកបាលិតដោយអាការគោរព ។

លោកបាលិតទទួលសំបុត្រហើយ អានសំបុត្រនោះរួចជូនឲ្យ ទៅ
ទបរាជសុរពលនឹង លាកនន្ធិមើលទៀត ហើយនិយាយថា:

លោកយើញទេ ខ្ញុំជំរាប់ហើយថាឬទ្ធិស័ត្យ មានសេចក្តីនឹងនួន
ណាស់ អញ្ជើញលោកអានសំបុត្រ១ច្បាប់នេះចុះ ហើយសូមប្រុងប្រៀប
រៀបខ្ជូនដើរផ្ទូវទៅជាមួយនឹងខ្ញុំឥឡូវនេះ ។

នាងកាញ្ចានាដែលអង្គុយនៅក្នុងទីនោះដែរ លុះបានឮមនុស្សបំរើ
របស់ឬទ្ធិស័ត្យ ពោលដូច្នោះ នាងត្រេកអរក្រៃលែង ។ អមាត្យបាលិតជូន
សំបុត្រឲ្យសុរពល។ ក៏អានខ្ទាំង។ ។ សេចក្តីក្នុងសំបុត្រដែលឬទ្ធិស័ត្យ
បរិយាយប្រឹងរាំវដ្សង ។ ក្នុងរវាងដែលគេនៅក្នុងនគរាជគ្រឹះតាំងអំពីដើម

ជាបដល់បង ជាការផ្ទាស់អារម្មណ៍ ដែលល្អក់កករហើយបើកផ្សាយទូ
ការស្មោះត្រង់ក្នុងចិត្ត ដោយពាក្យដែលបានស្តាប់នាំឲ្យកើតសេចក្តី
អាណិតយ៉ាងខ្លោចចិត្ត ។

កូនស្រីលោកនន្ទូមិនអាចនឹងខប់ទឹកភ្នែកបាន ដោយទឹកគួចចិត្តចំពោះ
កាលវេលា ដែលបិទបាំងយាំងខុតមិនឲ្យផ្តួចនឹងប្តូរទិស្តមកជាវេលាយូរ
ណាស់ហើយ ។

នន្ទូអមាត្យនឹងសុរតេស កាលដឹងថា "ព្រះរាជានៃក្រុងរាជគ្រឹះ
ទ្រង់ជ្រាបសេក្តីបរិសុទ្ធិរបស់ខ្លួនហើយ ព្រមទាំងអនុញ្ញាតឲ្យត្រឡប់ចូល
មកកាន់នគរវិញដូច្នេះហើយ, នាំឲ្យមានការកន្ទុះពក្នុងចិត្តតាន់ពេក ។
សេចក្តីទឹកលើកដល់ព្រះកុណាធិគុណ អំពីដាន់មុនមិនទាន់សុបរលាយ
បាត់ទៅពីក្នុងចិត្តនៅឡើយ តែមិនអាចនឹងប្រតិបត្តិតាមព្រះរាជបំណង
បានទេ ចាំថ្ងៃណាមួយនឹងទៅគាល់ព្រះអង្គ ថ្វាយសេចក្តីស្រឡាញ់កក្តី
ឲ្យព្រះអង្គទ្រង់ជ្រាបថា នន្ទូអមាត្យនឹងបុត្តមានសេចក្តីអាឡោះអាល័យ
ព្រះអង្គខ្លាំងឡើយ ដែលគិតដូច្នេះជាធម្មតារបស់បុគ្គលដែលធ្លាប់មាន
សេចក្តីស្រឡាញ់កក្តីប៉ុណ្ណោះ បើជាបុគ្គលដែលជ្រាសជាកតញ្ញូគុណធម៌មុខ
តែស្អប់ខ្ពើមព្រះរាជា ហើយកេឱកាសនឹងតបស្នងវិញពុំខាន, អមាត្យ
នន្ទូនិយាយនឹងសុរតេសដោយសំឡេងញ័រ ។ ថា:

- កូនសម្លាញ់! ថ្ងៃដែលយើងរង់ចាំ ថាយើងនឹងត្រូវបរិសុទ្ធ
បានមកដល់ហើយ ឪពុកនឹកថា កូនគង់តែដូចឪពុកដែរ កូនកុំចង
ចិត្តតាមនស្សស្អប់ខ្ពើមចំពោះព្រះរាជាឡើយ ។

– កុំបារម្ភឡពុក! ខ្ញុំមានសេចក្តីស្រឡាញ់តក្តីចំពោះព្រះអង្គនៅ
ឡើយ តែថាការត្រឡប់ចូលទៅកាន់នគររាជត្រឹះវិញនោះយើញថា ជា
ការលំបាកពេក" សុរពលនិយាយដោយសេចក្តីជឹងខ្ជួនជូចបិតាហើយ
ក៏អង្គុយស្ងៀម ។

ខាងក្រោយពីការអង្គុយស្ងៀមមួយស្របក់ អមាត្យបាលិតទើប
អញ្ជើញបបួលសុរពលនឹងនន្ធិអមាត្យ:

–" សូមលោកទបរាជ លោកនន្ធិនឹងបុត្រីរបស់លោក ត្រូវទៅជាមួយ
នឹងខ្ញុំផង ឬទ្ធិស័ត្យតង់នឹងត្រេកអរណាស់ កាលបើបានជួបលោកហើយ,
ចំពោះកាញ្ជនាត្រូវតែទៅកុំខាន" និយាយហើយលោកបាលិតក៏បែរទៅ
ខាងកូនស្រីនៃលោកនន្ធិ ។

នាងកាញ្ជនា សូម្បីមានសេចក្តីត្រេកអរយ៉ាងណា នាងក៏មិនសំដែង
អាការឲ្យយើញប្រាកដឡើយ តាមវិស័យរបស់ស្ត្រី ដែលស្រឡាញ់កេរ្តឺ-
ឈ្មោះ ក៏វិយារបស់នាងជាទីរីករាយរបស់មនុស្សក្នុងទីនោះវិក្រេពេក ។

ក្នុងទីបំផុត ជនទាំងនេះ ក៏ព្រមព្រៀងគ្នានឹងបេញដំណើរទៅកាន់
នគរវសាលីក្នុងរាងធាប់ ។ ខាងក្រោយដែលបានក្រាបបង្គំទូលលា
ព្រះរាជាហើយ ។

(មានត)

+

+ +

រឿងសាមកុក

ទកញ្ញាវិបុលរាជិសេនា ឆ្ន.កង ប្រែរៀបរៀង

(ពមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃធ្លាសបើបានអាន
នឹងបេះឧបាយកលបំណាន
ទាំងមានសន្ទានស្នេហាជាតិ ។

កណ្ឌទី ២៣

តាំងពីចូធូប្រើទៀវលៀវឲ្យបេញតយុទ្ធនឹងអ្ជិនសៀវ ៗ ប្រើទៀវទាប់បេញតទល់ រហូតដល់ចូធូចាប់បានសំបុត្រនាយទាហានរបស់ខ្ជូនដែលប្រៃបិត្តទៅចូលនឹងអ្ជិនសៀវ ។

ចូធូបានពុប្សាស់ក៏ខឹងទ្វាំងណាស់ ទើបចាត់ទៀវលៀវឲ្យលើកទាហានបេញទៅប្លាំងនឹងអ្ជិនសៀវ ។ យើញដូច្នោះក៏ចាត់ប្រើឲ្យទៀវទាប់លើកទាហានបេញមកតនឹងទៀវលៀវបាន ៥០ ក្វេង នៅមិនទាន់ចាញ់ឈ្នះគ្នា ។ ចូធូយើញទៀវទាប់ក្ងាហានណាស់ ក៏សរសើរថា: "ទៀវទាប់មានថ្ងៃដែបំណានក្នុងការសង្ត្រាមណាស់" ទើបប្រើទៅជូឲ្យបេញទៅជួយទៀវលៀវ ។ អ្ជិនសៀវយើញដូច្នោះក៏ប្រើគោលាំបេញទៅជួយទៀវទាប់ ។ នាយទាហានទាំង ៤ នាក់នោះក៏ប្រយុទ្ធគ្នាទៅវិញទៅមកដោយគុនអាវុធដ៏ហ៊ាសហ៊ីជូចគោមវិល ។ ចូធូចាត់ឲ្យវៃហ៊ីទុនឹងចោហាងលើកទាហានម្នាក់ ៣.០០០ បេញទៅជួយវាយទ្ជប់កងទ័ពអ្ជិនសៀវកុំឲ្យ

ដ៏ធំខ្លួនខាន់ ។ សឹមដោយឃើញថាហានចូលមកដោយខ្លួនឯងដូច្នោះក៏ឲ្យដុតជាវាជាសញ្ញាឡើង, ពួកហាននៅសល់ចន្លងបង្កប់តាំង ៤ ចំហៀកក៏ស្រែកវាត់ចូលមក ។ ហែហ្ហិខុនធីនិងចាហាន់ចម់មិនបាន កំច្រាស់ខាំហានថយវាត់ទៅក្រោយ ។ អ្នកនៅសៀវបានចំណាប់កំលើកទ័ពដេញបណ្តោយទៅតាប់ចាត់ត្រូវពលហានចូធ្លួចួសពីការស្លាប់ជាច្រើន ទ័ពចូធ្លួកំបែកត្រាត់ត្រាយ ចូធ្លួឃើញហួសលើសកំឡាំងនឹងចម់តុំឈ្នះ ក៏ថយទ័ពត្រឡប់ទៅតាំងបន្ទាយនៅទីកុំតួតរ ។

អ្នកនៅសៀវកំលើកទ័ពតាមទៅ តាំងបន្ទាយជាប់ជិតគ្នានឹងបន្ទាយចូធ្លួ ។ សឹមដោយនិយាយនឹងអ្នកនៅសៀវថា នៅជំបន់តួតរនេះជាទីបង្ក្រឹតស្រួលណាស់ បើរៃគិតប្រើតំនិតបន្លំឆ្លាក់យកបន្ទាយតួតរបានហើយស្រុកហ្ហិគោកំនឹងក៏យកបានដោយងាយ សូមឲ្យលោកចាត់ពាហានខ្មុកវក្បាចន្ទាយតែ ១០ ម៉ឺនចុះ លើសពីនោះចាត់ឲ្យជញ្ជូនយកគាចម៌ដ៏មកតរជាកំតែងចម់ឲ្យខ្ពស់ឡើងជាងសើនបន្ទាយចូធ្លួដោយដុំវិញ រួចឲ្យពាហានចាញ់ធ្វើចម្រុះចូលទៅកន់បន្ទាយចូធ្លួ មុខជាចូធ្លួនឹងការពារពុំឈ្នះច្រាសបែកទៅឯង បើយើងបានជំបន់តួតរហើយក៏ជួបជាមួយនក្រុងហ្ហិគោដែរ ។ អ្នកនៅសៀវយល់ឃើញពេញចិត្តក៏ឲ្យធ្វើតាមតំនិតដែលសឹមដោយគិតនោះ, ពាហានអ្នកនៅសៀវតាំងតែដកយកអាចម៌ដ៏ ហាសិកនឹងជញ្ជូនមកចាក់តរជាច្រូលច្របល់ ។

ចូធ្លួក្រឡេកទៅឃើញកំដឹងថា អ្នកនៅសៀវឲ្យជញ្ជូនគាចម៌ដ៏មកចាក់ឲ្យខ្ពស់ឡើង ប្រយោជន៍នឹងឲ្យចាញ់ធ្វើចម្រុះទៅកន់បន្ទាយនៃខ្លួន, ចូធ្លួ

កំបង្គាប់ថា ហានឲ្យលើកទៅវាយបំបែកខ្ទមអ្នកនៅ ដែលកំពុងដឹកជញ្ជូនគាថម៌ដ៏នោះកុំឲ្យធ្វើការបាន, ថាហានបន្ទូលកំលើកចេញទៅធ្វើតាមបង្គាប់ ។ សំមេវាយតតបារម្ភណ៍ខ្លាចក្រែងបន្ទូលប្រើថា ហានមកកំចាត់កំចាយមិនឲ្យធ្វើការបាន ក៏បែងចែកថា ហានឲ្យនៅរក្សាបន្ទាយ ៥ ម៉ឺន សុទ្ធតែកាន់ធ្នូបុំរុងចាំបាញ់មិនឲ្យថា ហានបន្ទូលើកចេញពីកងបន្ទាយ ។ ពួកថា ហានអ្នកនៅដែលដឹកជញ្ជូនគាថម៌ដ៏នោះ ប្រហែល ១០ ថ្ងៃមកហើយ ចំនួនដ៏កំចើនខ្ពស់ឡើងជុំវិញបន្ទាយបន្ទូលបាន ៩០ អន្លើ ដឹកបន្ទាយបន្ទូលប្រហែល ៥ ញាម (គឺ ១០ ម៉ែត្រ) អ្នកនៅក៏ផ្ទុំថា ហានឲ្យឡើងទៅនៅលើចំនប់ដីគ្រប់កន្លែង ហើយបង្គាប់ទុកថា "បើឮសំឡេងជាវាក់ឲ្យព្រមគ្នាបាញ់ធ្នូបម្រុះទៅកងបន្ទាយបន្ទូល" ថាហ៊ានតាំងពួងនោះកំតាមបង្គាប់អ្នកនៅ ។

ឯថា ហានបន្ទូលដែលនៅកងបន្ទាយនោះ លុះឃើញថា ហានអ្នកនៅបាញ់ធ្នូបម្រុះមកជុំវិញបន្ទាយ ក៏នាំគ្នាយកសែ្បកសេះទឹងពាងបាំងកំងខ្លួនខ្លះ គេចវេះពួនជ្រកនៅកងរណ្តៅលុងកងបន្ទាយខ្លះ ។ ថាហានអ្នកនៅឃើញដូច្នោះ ក៏ចូលគ្នាខ្លះដៃស៊ើចចំអកឲ្យកឲ្យយបញ្ជឹបគ្នា ។ បន្ទូលឃើញថា ហានតាំងពួងបែកខ្ញែកគ្នា ក៏ប្រឹក្សាទឹងនាយថា ហានតាំងអស់ថា អ្នកនៅធ្វើៗចាយយ៉ាងនេះ នរណាទឹងតតំនែងកែខ្ញុំបម្ដេចបាន ? ។ ខ្លៅហ៊ានធ្វើយថា ឥឡូវនេះថា ហានអ្នកនៅនៅលើខ្ពស់ បើទឹងលើកកងខ្ទមយើងឡើងទៅវាយចំណាយចេញ ថា ហានវាងយើងមិញក៏តិចជាងគេណាស់ បើដូច្នេះសូមឲ្យធ្វើចក្រយន្ត

នាំរនេះផ្ទុកថ្មសិលាទុក្ខាទៅឲ្យលុមផុតបន្ទាយដីតទំនប់ដីនោះឲ្យបាន៤ទំសរួចឲ្យតាញខ្សែយន្តឲ្យចក្របក់តាត់ដុំថ្មនោះឲ្យខ្ជាតឡើង មុខជាត្រូវតាហានអ្នកនៅខ្ចាត់ខ្ចាយពីលើទំនប់ដីនោះមិនលែង ។ ចូរឆ្លួយល់ឃើញស្រុកកំឲ្យឡើងហ៊ូធ្វើចក្រយន្តហើយយកនេះសឹង្ហ ២០០ មកផ្ទុកថ្មសិលាឲ្យពេញរនេះមួយ។ ។ រួចយកចក្រនោះដាក់កន្លែរនេះត្រឹមខ្ទុកឲ្យត្រមក្នុងពេលកណ្តាលយប់ស្ងាត់ លុះព្រឹកឡើងឃើញតាហានអ្នកនៅខ្ចាត់ខ្ចាយពីលើទំនប់ដី ចូរឆ្លូកំឲ្យតាហានរុញរនេះដែលផ្ទុកដុំថ្មនោះ ១ទំស ៩០ រនេះ ចេញទៅផុតបន្ទាយដីតគំនរដីប្រហែល ៣ ព្យួរមក្ងាយ ហើយឲ្យកន្ត្រាក់ខ្សែយន្តឡើងត្រមគ្នា ចក្រយន្តនោះក៏បក់តាត់ដុំថ្មនោះខ្ជាតឡើងទៅលើគំនរដី ត្រូវតាហានអ្នកនៅខ្ចាត់ខ្ចាយចូលសព៌ការស្ងាប់អស់ជាច្រើន ណាដែលរស់នៅក៏មិនតាចនឹងនៅក្នុងទីនោះបាន សឹងតែថយរត់ចុះទៅលើគំនរដីនោះអស់តមានសល់ម្នាក់ឡើយ ។

អ្នកនៅខ្ចាត់ខ្ចាយឃើញដូច្នោះ ក៏ពីគ្រោះនឹងសឹមរៀងយថា តាហានយើងដែលឡើងទៅនៅលើទំនប់ដីនោះ ក៏ធ្វើអន្តរាយចូរមិនបាន ត្រូវបន្តរត់ចុះមកអស់ដូច្នេះ តើអ្នកនឹងគិតប្រការម្តេចខ្លៅ ? ។ សឹមរៀងឆ្លើយថា កាលបើយខ្ញុំបាទនៅមានមួយយ៉ាងខ្លៅ សូមឲ្យលោកប្រមូលតាហានរកដីតមកឲ្យគ្រប់ចំនួនចូលទៅកន្លែបន្ទាយចូរ កាលណាបានសម្រេចហើយដល់ពេលកណ្តាលយប់ស្ងាត់ ត្រូវបញ្ជូលតាហានឲ្យចូលទៅតាមប្រហោងមុខ ហើយចំលុះឡើងទៅឲ្យចំកណ្តាលបន្ទាយចូរ ដេញតាប់សម្លាប់តាហានចូរក្នុងបន្ទាយឲ្យវិនាសខ្ចាត់ខ្ចាយទៅ មុខជាតាហាន

ក្នុងបន្ទាយមិនដឹងខ្លួនទេ ។ អ្នកនៅយល់ឃើញត្រូវ កំឡុងប្រមូលថាហានមកជីកទម្លុងក្រៅបន្ទាយជិតគំនរដី ។ ថាហានចូលឃើញដូច្នោះក៏ទៅដំណឹងប្រាប់ថា ឥឡូវអ្នកនៅឲ្យថាហានជីកដីលុះនៅក្រោយគំនរដីជាច្រើនណាស់ ធំដែរធ្វើប្រការម្តេចបើមិនច្បាស់ ? ចូធូឮដូច្នោះក៏ទឹកចិត្តសង្ស័យ ទើបសួរទៅឡៅហ៊ូថា តើលោកអ្នកនៅឲ្យធ្វើការដូច្នោះអ្នកយល់ឃើញដូចម្តេច ? ឡៅហ៊ូថា អ្នកនៅឲ្យធំធ្ងន់ធ្វើការយកជ័យជំនះយើងតាំងពីដំបូងតើ ឃើញជាមិនបានហើយ បានជាធ្វើកលឲ្យថាហានជីកដី ប្រាថ្នាដើរផ្លូវទម្លុងចូលមកធ្វើអន្តរាយបន្ទាយយើង បើដូច្នោះសូមឲ្យលោកប្រមូលថាហានមកជីកសុំឲ្យផ្លាស់ពីក្រៅបន្ទាយ មុនជាថាហានអ្នកនៅឲ្យធ្វើការមកមិនរួចបាន ។ ចូធូយល់ត្រូវផង លុះវេលាយប់ស្ងាត់ក៏ប្រមូលថាហានមកជីកសុំឆ្លងតាមការឡៅហ៊ូថា ។

ឯថាហានអ្នកនៅនោះ លុះជីកទម្លុងមកដល់ជិតជើងបន្ទាយចូធូ ក៏ការទៅលើសុំឆ្លងដែលចូធូឲ្យជីកស្ងាត់ពុកនោះ ធំធ្ងន់ជីកចុះចេញទៅខ្មៅតក៏ពុំបាន ព្រោះសុំឆ្លងធំជ្រៅតន្ទឹកណាស់ ទើបនាំគ្នាទៅជំពាក់អ្នកនៅវិញ ។ អ្នកនៅបានឮថាហានប្តឹងដូច្នោះ ក៏មិនដឹងម៉េនធំនតែធ្វើដូចម្តេចតទៅទៀត ក៏ឲ្យថយទ័ពត្រឡប់ទៅតាំងបន្ទាយឆ្ងាយអំពីដំបន់គួរ ចម្ងាយប្រហែល ៣០០សិន (គឺ ១២ គីឡូម៉ែត្រ) ។

ឯចំណែកចូធូតាំងតែពីរកបង្ខ័ងក៏ទ័ពមិនចេញតតាំងប្តឹងធំនអ្នកនៅតាំងពីខែតន្ទូបទរហូតដល់ខែអស្សុជ ក៏មិនឃើញអ្នកនៅចេញប្តឹងធំ

គិតទឹងថយទៅវិញ ទើលស៊ីហ៊ុនកន្ត្រៃលាប់ពាហាន
អ៊ួនសៀវចុនម្នាក់ កំនាំខ្លួនទៅជូនបួនួ ។ សួរពាហានយកការថាអ៊ួនសៀវ
ប្រើម្នាងឯងឲ្យទៅណាមកណាចូលច្រាប់យើងតាមត្រង់ បើឯងគួតតរកុហក
យើងឲ្យគាត់ក្បាលចេញឥឡូវនេះ ។ ពាហាននោះខ្លាចក៏ធ្វើយច្រាប់តាម
ត្រង់ថា ខ្ញុំបាទជាបាវហ៊ានបេង អ៊ួនសៀវប្រើហ៊ានបេងឲ្យដាក់ឲ្យនេសៀងមក
ឲ្យកន្ត្រៃទៅត្រឡប់មកដីតទឹងដល់ទីបន្ទាយហើយ ហ៊ានបេងប្រើឲ្យខ្ញុំបាទ
ស្រែតមកស៊ើបការជាមុន ។

ស៊ុនហ៊ីវាត្អូរថ្លុះ ក៏ដំរកបបួនួថា ហ៊ានបេងនេះជាមនុស្សមានថ្លៃ
ដៃខ្លាំងពូកែកំពិតមែន តែគ្មានដម្រះប្រាជ្ញាទេ, ប្រសិនបើលោកបាត់ការ
ឲ្យពាហានឯករលើកពលយោធាតែ ៣០០០ ទៅចាំស្លាក់ដណ្តើមយក
សៀងអ៊ួនសៀវ មុខជាទឹងបានដោយងាយ អ៊ួនសៀវតែងតែទឹងបែកខ្ញុក
ខ្លួចសៀងអាហារអស់ ។ បួនួថា បុះយើងទឹងឲ្យពាហានណាទៅស្លាក់
ធ្វើការនេះបាន? ស៊ុនហ៊ីវាថា ត្រឹមតែថ្លៃដៃស៊ីហ៊ុនកំលុមតស៊ូទឹងហ៊ានបេង
បានហើយ ។ បួនួក៏យល់ឃើញត្រមផង ទើបបាត់ពាហាន៣០០០ ឲ្យ
ស៊ីហ៊ុន ទឹងស៊ូហួនកាន់កាប់ទៅផង ឲ្យលើកកងទ័ពទៅតាំងចាំស្លាក់
នៅត្រង់ដងខ្នោះផ្លូវច្រកភ្នំ ដែលហ៊ានបេងទឹងនាំសៀងមកនោះ ហើយប្រើ
ទៀវសៀវទឹងរៀងខ្លួនឲ្យលើកពាហាន ៥០០០ ទៅតាមក្រោយ ពាហានចាំង
នោះក៏លើកទៅតាមបួនួមង្គាប់ ។ លុះវេលាកណ្តាលអធ្រាត្រយប់ស្លាត់
ហ៊ានបេងក៏នាំរនេះសៀងប្រមាណ ២០៦ មកដល់ច្រកភ្នំនោះ ស្រាប់តែក្រឡែក
ទៅឃើញស៊ីហ៊ុនបាវរសេះ នៅខទឹងផ្លូវពីមុខ ហ៊ានបេងកំបរសេះបង្រុះ

ចូលទៅប្រយុទ្ធនឹងស៊ីហ្វុងតាំងអំណាច ទៅមិនបានចាញ់ឈ្នះ ស៊ូហ៊ិន
ឃើញដូច្នោះក៏លើកទាហានចូលទៅព្រួតតាក្រោយថែមទៀត សម្លាប់
ទាហានហ៊ានបេងស្លាប់អស់ជាច្រើន ហើយឲ្យទាហានយកក្បាលដុតរេះ
សឹ្បនោះអស់ ។ ហ៊ានបេងឃើញស៊ូហ៊ិនដេញចាប់ទាហានចូលមក
ឃើញថាលប់លើសកំឡាំង ខប់ខល់ពុំឈ្នះក៏បរសេះរត់ត្រឡប់ទៅក្រោយ
វិញ ទាហានក៏ចាត់ចែងបណ្តាយទៅបែកខ្ញែកខ្ចាត់ខ្ចាយអស់ ។

ឯអ្នឧសៀវទៅកន្លងបន្តាយ ឃើញតន្ទឺក្លៀងឆេះឡើងខាងទិសឯលិច
ក៏នឹកសង្ស័យណាស់ ខលួចទាហានដែលបែកចែងនោះរត់ទៅដល់ ប្តឹង
សេចក្តីឲ្យអ្នឧសៀវដឹង អ្នឧសៀវកំភ័យស្ទុតចិត្ត ទើបប្រើទៀវទាប់ទឹង
គោលាំទាំទាហានលើកទៅជួយ ស្ថាត់ពយាយំចូលទូដែលដុតរេះ
សឹ្បនោះ ទៀវទាប់ទឹងគោលាំក៏លាអ្នឧសៀវទាំទាហានកងចែងទៅ
ចាំស្ថាត់កណ្តាលផ្លូវ ។

ឯស៊ីហ្វុងនឹងស៊ូហ៊ិន លុះដុតរេះសឹ្បនេះអស់ហើយ ក៏លើកចែង
ត្រឡប់មកតាមផ្លូវ ខលួចប្រទះនឹងទៀវទាប់, គោលាំ ទៅចាំស្ថាត់
កណ្តាលផ្លូវនោះ ក៏ចូលប្រយុទ្ធគ្នាជាពន្ទឺក ខលួចទៀវលៀវទៅធ្លុះលើក
ចែងទៅជួបប្រទះគ្នាទៀត តំបន់ពេលចូលប្រយុទ្ធគ្នាជាប្រឡំបល់ គោលាំ
នឹងទៀវទាប់តខល់ពុំឈ្នះកច្រាសបែកចែងទៅ ស៊ីហ្វុង, ទៅជួ, ស៊ូហ៊ិន
ក៏ដេញតាប់កងចែងអ្នឧសៀវស្ទាប់នោសច្រើនណាស់ ហើយក៏លើក
ត្រឡប់ទៅបន្តាយតួតវិញ ចូលទៅជំរកបចូឆ្ង ។ ក៏មានរំណោរណាស់
ឬបំណាច់ផ្តាច់ដល់ស៊ីហ្វុងនឹងសេនាទាហានតាំនពួនជាច្រើន ។

ឯហ៍នបេនរត់ទៅដល់បន្ទាយ ក៏នាំយកសេចក្តីនោះទៅជំរាបអ្ជិន
សៀវ ។ ទ្រឹនណាស់ ទើបបន្ទាប់ឲ្យចាប់ទ្ជួនហ៍នបេនយកទៅប្រហារជីវិត ។
ទីប្រឹក្សានឹនសេនាតាហានតាំនពួនក៏នាំគ្នាអន្ទរសួមទោស ។ សឹមផោយ
ជំរាបអ្ជិនសៀវថា: ឯការធ្វើសឹកសន្ត្រាមនេះអាស្រ៍យនឹនមានស្សៀន
អាហារជាកំឡាំន ឥឡូវបើស្សៀនអាហារយើនដែលលាក់ទុកនៅដំបន់
អ្ជិលៅនោះ ទ្ទាចក្រែនចូធូដឹននឹនលើកទ៍ពទៅដណ្តើមយកបានយើនក៏នឹន
ទ្ទះទាតស្សៀនអាហារ យើញថានឹនធ្វើការសន្ត្រាមតទៅឲ្យរហូតពុំបាន
ហេតុនេះ សួមលោកចាត់តាហានដែលមានថ្ទីដែទៅរក្សាដំបន់អ្ជិលៅ
ទុកឲ្យមាំមួន ទើបយើនឹនបានអាស្រ៍យអាហារជាកំឡាំនតទៅ ។
អ្ជិនសៀវថា ការត្រន់ណោះអ្នកកុំវិតក្តញ្ជូយឡើយ ឯដំបន់អ្ជិលៅនោះ
យើនបានចាត់ចែនជាមាំមួនទុកស្រេចហើយ ឲ្យអ្នកស្រូតទៅស្រុក
ដៀបកុនដែលជាស្រុកចុះឡើនស្តាប់បន្ទាប់យើន ឲ្យស្រូតរូតបញ្ជូន
ស្សៀនអាហារមកឲ្យកនទ៍ពជាប្រញាប់កុំឲ្យទ្ទះទាតតាន់ ។ សឹមផោយ
ក៏លាអ្ជិនសៀវទៅកាន់ស្រុកដៀបកុន លុះសឹមផោយទៅផុតហើយ
អ្ជិនសៀវក៏ចាត់អីទេនជានាយតាហានទ៍ពធំ នឹនកុយន្ជួន,ជិនហ៍ន,តីជូ,
លីអ្ជិយហន,ទៀវយ៉ូយ ឲ្យលើកតាហាន ៤ ម្ជឹនទៅនៅរក្សាដំបន់អ្ជិលៅ ។
ទណៈកាលអីទេនទៅនៅដំបន់អ្ជិលៅហើយ ក៏មិនបានយកចិត្តទុកជាក់
ក្នុនកិច្ចការរាជការផែនដីអ្ជីសោះ តិតតែពីនាំពួកគៀនផឹកស្រាស្រវឹនជា
និច្ច ទោះបីបើអ្នកឯណានិយាយទទឹនតាស់ក៏ត្រឲ្យប់នៅជាគ្រោធទឹនវិញ
ហើយពោលពាក្យទ្រគោះមើលនាយជាច្រើន តាហានតាំនពនក៏សឹនតែ

គោតឆ្វាបអ៊ីរៃឆមិនអាចហាមឃាត់ឬរំលឹកបានឡើយ ។

ឯចូធូដែលតាំឆឥតៅដំបន់ឆ្ងតរនោះ ស្ស្យៀឆអាហារក៏កាន់តែ ស្ពួបស្ពើឆណាស់ ចូធូក៏ប្រើតាហានកាន់សំបុត្រៅឲ្យស៊ិនហុកឯស្រុក ហ្ចិតោ, សេចក្ពីសំបុត្រនោះថា "ក្នុឆកឆឥតយើឆមានការឆ្ងះឆាតស្ស្យៀឆ អាហារប្រើនណាស់ហើយ ឲ្យស៊ិនហុកឆំរិះឆិតចាត់ឲ្យនាំស្ស្យៀឆៅជា ប្រញាប់កុំឲ្យឆ្ងះឆាតតាន់" ។ តាហានឥឲ្ជលសំបុត្រហើយក៏លាចូធូៅ ចេញពីបន្ទាយចម្ងាយប្រវហល ៣០០ សិន (១០ឆីឡូម៉ែត្រ) ពួកតាហាន កឆក្រវៃលអ្ជិនសៀវ ក៏ចាប់ឆ្ងួនបានហើយនាំយកៅឲ្យៅហ៊ីវដែល ជាឥប្រឹក្សាធំរបស់អ្ជិនសៀវ ។

ៅហ៊ីវនេះ កាលនៅពីកំឡោះនៅឡើយនោះ ជាគឿនសំឡាញ់ នឹឆចូធូ លុះចូធូវបកចាកៅធ្វើរាជការក្នុឆស្រុកហ្ចិតោ ៅហ៊ីវក៏ចូល មកនៅធ្វើរាជការនឹឆអ្ជិនសៀវ, កាលនាយកឆក្រវៃលចាប់តាហានចូធូ មកឲ្យ ៅហ៊ីវឲ្យមនុស្សត្រួតមើលយើញសំបុត្រដែលចូធូឲ្យៅជល់ ស៊ិនហុក ៅហ៊ីវក៏នាំយកសំបុត្រនោះៅជំរាបអ្ជិនសៀវហើយថា ចូធូតាំឆរាឥតនឹឆយើឆក៏យូរអឆ្ជឆណាស់មកហើយ តាល់តែអស់ស្ស្យៀឆ អាហារ, ស្រុកហ្ចិតោក៏នៅឥំនេរឆ្នាឆនរណាការពារជាមាំមួន សូម ឲ្យលោកបៃឆតាហានលើកៅក្រលុកវាយយកស្រុកហ្ចិតោ ប៊ើជាបាន ស្រុកហ្ចិតោហើយ ចូធូក៏នៅក្នុឆកណ្ពាប់ដៃយើឆតែម្ពឆ ។

(មានត)

កំណត់ធំធ្ងប្រវត្តិការណ៍

ពិធីបុណ្យកតញ្ញូកតវេទី

ចំពោះសម្តេចព្រះធម្មលិទិតឧត្តមប្រឹក្សា ល្វី-ឯម

របស្ថ់សមណៈនិស្សិតពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត

សោក ឯត-ប៉ង ប្រមូលរួបរួម

ថ្ងៃសៅរ៍ទី ១៥ ធ្នូ ១៩៥៦ វេលាម៉ោង ៧ យប់ ក្នុងបរិវេណ
វត្តលង្កា សង្កាត់លេ ១ ៦ ក្រុងភ្នំពេញ មានធ្វើពិធីបុណ្យកតញ្ញូកតវេទី
ចំពោះសម្តេចព្រះធម្មលិទិតឧត្តមប្រឹក្សាតណៈមហានិកាយ ក្រោមការចាត់
ចែងនៃសមណៈនិស្សិតពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ។

ក្នុងឧកាសនោះ យើងសង្កេតឃើញ នូវពួកពុទ្ធបរិស័ទ្យដែលបាន
អញ្ជើញទៅជួបជុំគឺ លោក ម៉ម-ឃើម ប្រធានតណៈកម្មការវត្ត, លោក
ប-យាន, លោក ល-គឺមស៊ា, លោក ឃឹម-ស៊ុម ព្រមទាំងពុទ្ធបរិស័ទ
ទាំងស្រីទាំងប្រុសជាច្រើននាក់ ដែលយើងសូមអភយទោសដោយមិន
បានរាប់នាមក្នុងទីនេះ ។ ចំណែកព្រះសង្ឆមានព្រះតេជព្រះគុណព្រះ
មហាព្រហ្មមុនី ទេព-អ៊ូ, ព្រះតេជព្រះគុណព្រះញាណវីរិយៈ រ៉ណ្ណ-សាខ្ពុំ
ជាដើម បាននិមន្តទៅជួបជុំក្នុងទីនោះ ។

នៅម៉ោង ៨, ១០ នាទី សម្តេចព្រះមហាសុមេធាធិបតី ជួន-ណាត
សង្ឆនាយកតណៈមហានិកាយ បាននិមន្តមកដល់ទីនោះ ដោយមាន

សមណៈនិស្សិតពុទ្ធិកវិទ្យាល័យព្រះសុកម្រឹត ឈរគោរពហូបហែតាំងពីខ្នើងទ្វារហួតដល់ចាំកាំទៅមុខហោង្រៃ ។ សម្តេចបានឈប់បន្តិចសំណេះសំណាលនឹងក្រុមសមណៈនិស្សិតទាំងឡាយមួយស្របក់ រួចនិមន្តឡើងទៅថ្វាយបង្គំសម្តេចព្រះធម្មលិខិត លុះសួរអំពីអាការពេតសម្តេចហើយក៏និមន្តទៅឯព្រះវិហារ ។

ក្រោយដែលបានជួបជុំក្រុមនិស្សិតជាសមណៈនឹងពុទ្ធបរិស័ទទាំងឡាយហើយ ព្រះអាចារ្យ ស៊ុន-សារឿម និស្សិតពុទ្ធិកវិទ្យាល័យព្រះសុកម្រឹតថ្នាក់ទី ៤ ថ្វាយសុន្ទរកថារៀបរាប់អំពីទុបការគុណនៃសម្តេចព្រះធម្មលិខិតជាសង្ឃបិតា ។ បន្ទាប់មក ព្រះតេជព្រះគុណព្រះពុទ្ធវង្ស កៅ-សឹម ថ្វាយសុន្ទរកថាតបវិញ ។

លុះចប់សុន្ទរកថាហើយ សម្តេចព្រះមហាសុមេធាធិបតីបានសំដែងធម៌យ៉ាងពីពោះអស្ចារ្យ នាំឲ្យក្រុមសមណៈនិស្សិតនឹងពុទ្ធបរិស័ទទាំងឡាយជ្រះថ្លារីករាយជាខ្លាំង ។

ថ្ងៃអាទិត្យទី ១៦ ធ្នូ ១៩៥៦ វេលាព្រឹកម៉ោង ៩, ១៥ នាទី បាននិមន្តព្រះសង្ឃ ១៥០ អង្គ ទទួលបណ្តាន់បិណ្ឌបាត ។

ដល់ម៉ោង៧ឆប់ នមន្តព្រះសង្ឃចំរើនព្រះបរិត្តមួយលើកទៀត រួចនិមន្តព្រះអាចារ្យ ខៀវ-ដុំ សំដែងធម៌; មុនឡើងសំដែង ព្រះអាចារ្យ ស៊ុន-សារឿម ថ្វាយសង្កថាមួយកន្លងនាមមៃក្រុមនិស្សិតទាំងអស់យ៉ាងក្បោះក្បាយ ។

ពិធីបុណ្យនេះចប់នៅម៉ោង ១២, ៣០ នាទី ។

× × ×

រីសុន្ទរកថា នឹងសង្ក្ថាព្រះអាចារ្យ សុិន-សារៀម ព្រមទាំងសុន្ទរកថា ព្រះតេជព្រះគុណព្រះពុទ្ធវង្ស គៅ-សុិម យើងនឹងស្រង់យកមកចុះជូនអ្នក អាន ដូចតទៅនេះ ៖

សុន្ទរកថាព្រះអាចារ្យ សុិន-សារៀម

ថ្ងៃងក្នុងនាមនៃនិស្សិតពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត

សូមគោរព

– សម្តេចព្រះធម្មលិខិតឧត្តមប្រឹក្សាគណៈមហានិកាយ ,

– សម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយ ,

– ព្រះថេរានុត្តរៈទាំងឡាយ ,

សូមជំរាបអស់លោក-អ្នកជាពុទ្ធបរិស័ទ្យទាំងឡាយ !

ខ្ញុំព្រះករុណា អាត្មាភាព សូមថ្ងៃងក្នុងនាមនៃនិស្សិតពុទ្ធិកវិទ្យាល័យ ព្រះសុរាម្រិត នូវសេចក្តីសោមនស្សរីករាយដ៏ក្រៃលែង ចំពោះសម្តេច, ព្រះតេជព្រះគុណក្រុមជំនុំព្រះត្រៃបិដក ដែលមានព្រះតេជព្រះគុណ រ័ណ្ណ-សាឌុំ ជាដើម, ព្រះតេជព្រះគុណ សាស្ត្រាចារ្យពុទ្ធិកវិទ្យាល័យ ព្រះសុរាម្រិត មានព្រះតេជព្រះគុណ ព្រះមហាព្រហ្មុនី ទេព-អ្ជិ ជាដើម, អស់លោកនៅក្រសួងធម្មការ នឹងអស់លោក-អ្នកសប្បុរសជើងវត្តលង្ក្ឥ ជាដើម ដែលបានទិមន្តបានអញ្ជើញមកក្នុងពិធីបុណ្យនេះ ។

ខ្ញុំព្រះករុណា ទាំងឡាយជាក្រុមសិស្សពុទ្ធិកវិទ្យាល័យ នឹងជាសិស្ស នៃពុទ្ធិកបឋមសិក្សាខ្ទះ ជាចៅសិស្សរបស់សម្តេច មានសេចក្តីរំភើបញាប់-

ញ៉ាតគក់ស្ងុតរន្ធត់ក្នុងចិត្តក្រៃពេក ចំពោះសម្តេចជាអយ្យកាចារ្យក្នុងវេលាដែលសម្តេចមានជរាពាធប្រចាំព្រះកាយ ព្រោះខ្ញុំព្រះករុណាតាំងឡាយ ទោះបីពុំមែនជាសិស្សផ្ទាល់តាំងអស់ត្នាក៏ដោយ, ប៉ុន្តែជាអ្នកបានទទួលមរតកដ៏បរិសុទ្ធ៏ ពោលគឺចំណេះវិជ្ជាខាងផ្លូវព្រះពុទ្ធសាសនាតពីសម្តេចមកដែរ ។ ខ្ញុំព្រះករុណាតាំងឡាយបានកើតឡើងក្នុងសម័យដែលសាលាបាលីរង, សាលាបាលីជាន់ខ្ពស់ នឹងពុទ្ធសាសនបណ្ឌិត្យមានសេចក្តីចំរើនហើយក៏ពិតមែន, ប៉ុន្តែខ្ញុំព្រះករុណាតាំងឡាយបានដឹងប្រវត្តិខ្ទះតាមរាចានៃត្រូអាចារ្យតមកថា ៖

— ក្នុងអតីតកាលប្រទេសកម្ពុជា ពុំមានសាលាសម្រាប់សិក្សានូវសាស្ត្រាបាលីនឹងធម្មវិន័យទេ ព្រមទាំងពុំមានអ្នកប្រាជ្ញណាមួយអាចចាត់ការបង្រៀនឲ្យមានរបៀបរៀបរយបានឡើយ ។ ដល់មកឆ្នាំ ១៩១៦ ទើបអ្នកប្រាជ្ញទាំងឡាយមានសម្តេចព្រះធម្មលិខិតទត្តមប្រឹក្សាព្រះនាម ល្ខ-ឯមនេះ នឹងសម្តេចព្រះមហាសុមេធាធិបតី ជួន-ណាត ដែលគង់នៅចំពោះមុខខ្ញុំព្រះករុណាតាំងអស់នេះជាដើម បានសុំឲ្យព្រះរាជរដ្ឋាភិបាលបង្កើតសាលាបាលីជាន់ខ្ពស់ឡើង បានចាត់ការបង្រៀនដល់សមណៈនិស្សិតទាំងឡាយ ឲ្យរៀនបេះដឹងដោយងាយរហូតមកដល់សម័យនេះ ។

— តាំងពីសាលាបាលីជាន់ខ្ពស់កើតឡើង អធិការណ៍ធំ ។ ខាងផ្លូវពុទ្ធសាសនា ជូចជាសង្ត្រាមសាសនាមួយកើតឡើងក្នុងប្រទេសកម្ពុជា សម្តេចទាំងពីរព្រះអង្គនេះជាធម្មសេនាបតីព្រមទាំងព្រះសង្ឆជាសហការីឯទៀតផង បានកំចាត់អធិការណ៍នោះឲ្យរលត់រលាយទៅ ។

វីវត្តលង្ការនេះសោតក៏ហាក់ដូចសមរភូមិមួយយ៉ាងធំក្នុងប្រទេសកម្ពុជាដែរ, ដែសម្តេចបានសាងអារុធគឺសៀវភៅធម្មវិន័យជាប្រើនច្បាប់ សរសេរ ជោះពុម្ពដែកជាធម្មទានប្រើនឡើង ។ ទីវត្តនេះក្លាយទៅជាវិជ្ជាស្ថានមួយ ដ៏ទត្តមយ៉ាងក្រៃដែង ។

– ក្នុងឆ្នាំ ១៩៦៥ សម្តេចបានហានៈជាក្រុមប្រឹក្សាក្នុងការបង្កើតព្រះ រាជបណ្ណាល័យ ក្នុងឆ្នាំ ១៩៦៩ សម្តេចបានទទួលហានៈជាអធិបតីក្រុមជំនុំ ព្រះត្រៃបិដកដែលជាថ្ងៃមប្រមាត់នៃព្រះពុទ្ធសាសនា, ក្នុងឆ្នាំ ១៩៣០ សម្តេចបានជាក្រុមប្រឹក្សាក្នុងការបង្កើតពុទ្ធសាសនបណ្ឌិត្យ ក្នុងប្រទេស កម្ពុជា ។

– សម្តេចបានបង្កើតសាលាបាលីរង ក្នុងវត្តលង្ការមុនវត្តឯទៀត ទាំងអស់ក្នុងប្រទេសកម្ពុជា, ទោះបីសាលានេះនៅក្រោផ្ទូវការក៏ដោយ សម្តេចក៏ទំនុកបំរុងឲ្យបានសេចក្តីចំរើនដូចជាសាលាក្នុងផ្ទូវការដែរ, មាន សិស្សរាប់រយរូប រៀនក្នុងមួយឆ្នាំ ។ ក្នុងសម័យនោះ ។ សាលាបាលីរង វត្តលង្ការនេះឯង ជាគំរូមួយឲ្យវត្តឯទៀតក្នុងព្រះរាជអាណាចក្រ មានវត្ត ពោធ៏អណ្តែតក្នុងខេត្រកំពង់ឆ្នាំងជាដើមយកតម្រាប់តាម ។

– វត្តឯទៀតបានបង្កើតសាលាបាលីរងបាន ២-៣ វត្តហើយសម្តេច ក៏បានប្រជុំពិគ្រោះជាមួយនឹងសហការីទាំងឡាយ មានសម្តេចព្រះមហា សុមេធាធិបតីជួន-ណាតដែលតង់នៅនេះជាដើម បានសម្រេចមូលមតិ ថាគួរតែបង្កើតសាលាបាលីរងគ្រប់ទីរួមខេត្រទាំង ១៦ ឲ្យមានក្របខ័ណ្ឌ ដូចសាលាបឋមសិក្សា បាវាំង-ខ្មែរ, ប៉ុន្តែការនេះពុំបានសម្រេចគ្រប់ខេត្រ

ដូចបំណងឡើយ ជានត្រឹមតែសាលាបាលីរង៉ែងឲ្យមានក្នុងវត្តមួយ ។ ដែលលោកគ្រូចៅអធិការវត្តសព្វព្រះទ័យឲ្យតាំង ។

– តាំងពីឆ្នាំ ១៩៣៣ ដែលសាលាបាលីរង៉ែងវត្តនេះកើតឡើងជានថ្មលក្នុងផ្លូវការហើយ កុលបុត្រអ្នកសិក្សាក៏តែងតែកើនចំនួនឡើងរាប់ពាន់រាប់ម៉ឺនរូបគឺតាំងខ្ញុំព្រះករុណាគ្រប់គ្នានេះផង តាំងសិក្ខាកាមកុលបុត្រឯទៀតដែលពុំជានមកកក្នុងទីនេះផង ក៏សុទ្ធតែជានចំណេះវិជ្ជាដុះជាលអំពីសាលាបាលីរង៉ែងនោះទាំងអស់ ។

ឥឡូវនេះ ខ្ញុំព្រះករុណាតាំងអស់គ្នាជានិស្សិតពុទ្ធកវិទ្យាល័យព្រះសុកម្រឹតនឹងនិស្សិតពុទ្ធកបឋមសិក្សាខ្លះ ទោះបីពុំជានរៀនផ្ទាល់ក្នុងសំណាក់សម្តេចក៏មែន ប៉ុន្តែឈ្មោះថាជានទទួលមតិកដ៏បវរសុទ្ធតមកអំពីសម្តេច ។

ចំណែកសម្តេច ទោះបីឥឡូវនេះពុំជានទទួលកាន់តាប់សាលាតាំងនោះក៏មែនពិតហើយ, ប៉ុន្តែសម្តេចទៅតែមានមេត្តាចិត្តផ្សាយក្រាលទៅលើសាលាតាំងនោះ ដូចជាទឹកអម្រឹតរសស្រោចស្រប់លើខ្ញុំព្រះករុណាគ្រប់គ្នាឲ្យដុះដាលពុំមានអាក់ខានឡើយ ។

ចតិត្រសម្តេច ?

សម្តេចជាសន្ធឹមតាមួយព្រះអង្គឃ៉ាំងខ្នែម, សម្តេចមានព្រះទ័យដ៏បវរសុទ្ធិទំព្រើនក្រៃលែងព្រះពុទ្ធសាសនា ក្នុងពេលដែលអន់ថយទន់ខ្សោយយ៉ាងខ្លាំង គឺខ្សោយទាំងការប្រតិបត្តិទាំងការសិក្សា ជាពិសេសលើកុលបុត្រ ប្រតិបត្តិសិក្សាគេភ្ញាក់ខ្លួនរឿងក្នុងប្រទេសកម្ពុជា ។

ព្រះគុណដ៏ធំអស្ចារ្យ ដូចជានពាណិនារៀបរាប់ទាំងលើតាំងអស់នេះ

ហើយ ដែលបណ្តាលឲ្យខ្ញុំព្រះករុណាជាសមណៈសិស្សតាំងអស់គោរព ព្រមទាំងទឹកភ្នែក ។

ក្នុងបច្ចុប្បន្ននេះ សម្តេចត្រូវដកចូលមកញ៉ាំញីព្រះកាយឲ្យខ្ទុះ-ខ្ទ្រេមស្តាំនស្តមហួសប្រមាណ ហើយជរាពាធនោះបានសំដែងអាការដ៏ក្រៀវក្រាំសំបើម ។ ប៉ុន្តែក្នុងខណៈនោះ ព្រះករុណាជាអម្ចាស់ជីវិតទាំងពីរព្រះអង្គនឹងសម្តេចព្រះទេបយុវាជ ទ្រង់មានព្រះរាជបញ្ជាឲ្យគ្រូពេទ្យយាងដំនាក់ យកទុសថវិសេសមកព្យាបាលព្រះកាយសម្តេច, ជរាពាធនោះក៏បានធូរថយស្រាយបន្តិច ។ ដំណើរនេះនាំឲ្យខ្ញុំព្រះករុណាតាំងខ្លួនជាសមណៈសិស្ស មានសេចក្តីរំភើបតក់ស្លុតរន្ធត់ជាខ្លាំង ទើបរួមកំលាំងគ្នាធ្វើបុណ្យនេះ ដោយផ្តងចិត្តខ្ញុំសកុសលប្រគេនសម្តេច ដើម្បីឲ្យគាទុកភាពបុណ្យនេះ ជួយសម្តេចឲ្យស្រាស្រ័យជរាពាធហើយមានព្រះជន្មយឺនយូតអង្វែងតទៅ ។ ដូច្នេះ ទូលសម្តេចមេត្តាចាំទទួលកុសលដែលយើងខ្ញុំទុទ្ធិសប្រគេនតទៅនេះ ៖

បពិត្រសម្តេច !

កុសលតាំងខ្លួយគោះជាសច្ចវាចាក្តី គោះជាធម្មទានក្តី គោះការនិមន្តព្រះសង្ឃមកស្វាធ្យាយព្រះបរិត្តក្តី ព្រមទាំងអាមិសទានបរិស្ការមានបុទ្គលបរិសេក្តី ខ្ញុំព្រះករុណាតាំងខ្លួយជាក្រុមនិស្សិតនៃពុទ្ធិកវិទ្យាល័យព្រះសុគម្រិត សូមតាំងប្រណិធានដោយមនោសញ្ចេតនាដ៏បរិសុទ្ធិ លើកស្ទួយនូវបុណ្យកុសលនេះប្រគេនចំពោះសម្តេច, សូមសម្តេចតាំងព្រះទ័យអនុមោទនា ទទួលដោយសោមនស្ស !

សូមអំណាចអានុភាពនៃបុណ្យកុសលនេះ ញ្យាបាលសម្តេចឲ្យបានជាស្រឡះសះស្បើយចាកព្រះរោគ, សូមជ្រោមជ្រែងសម្តេចឲ្យមានព្រះកាយរឹងប៉ុងមាំមួនជាស្ថាពរឡើងវិញ, សូមជួយឧបត្ថម្ភសម្តេចឲ្យមានព្រះជន្មាយុយឺនយូរតទៅ ដើម្បីនឹងបានជាម្ចប់ត្រជាក់សម្រាប់ជាទីជ្រកកោននៃខ្ញុំព្រះករុណាទាំងឡាយជាក្រុមនិស្សិត ។

ទីបំផុតនេះ ខ្ញុំព្រះករុណាអាត្មាភាពទាំងឡាយ សូមឧទ្ទិសផ្សាយផលនៃកុសលនេះដល់ព្រះថេរានុត្តេរៈ នវកកិក្ខុ សាមណេរ ព្រមទាំងឧបាសកឧបាសិកា ជាពុទ្ធបរិស័ទដែលបានទិមន្តនឹងអញ្ជើញមកក្នុងពិធីបុណ្យនេះ សូមឲ្យបានសម្រេចនូវឥដ្ឋមនុញ្ញផលគ្រប់ៗគ្នាកុំបីខានឡើយ ។

+ × +

សុន្ទរកថា ព្រះពុទ្ធរង្សកោសុិម

ថ្វៃងក្នុងនាមនៃសម្តេចព្រះធម្មលិខិត ល្ឃ-ឯម ទត្តមប្រឹក្សាតណៈមហានិកាយ

តបសមណៈនិស្សិតពុទ្ធិកវិទ្យាល័យព្រះសុកម្រិត

អស់លោកសមណៈនិស្សិតទាំងឡាយ! សម្តេចខ្ញុំ សូមឧកាសបន្តិច ដើម្បីថ្វៃងសេចក្តីទទួលអំណរយាំងក្រៃលែង អំពីអស់លោកជាសមណៈនិស្សិត ដែលមានឧស្សន្នកុសលចេតនាផុះផុលឡើងក្នុងខន្ធសន្តាន ហើយបានមូលមកិរួមតំនិតគ្នាធ្វើបុណ្យកតញ្ញុតានេះ ឧទ្ទិសចំពោះរូបខ្ញុំ, ទាំងបានអញ្ជើញអស់លោក អ្នកសប្បុរសប្រុស ស្រីទាំងឡាយ ឲ្យចូលមកជួយពង្រីកបុណ្យនេះ ឲ្យមានវិសាលភាពធំទូលាយឡើងទៀត ។

អស់លោកសមណៈនិស្សិតទាំងឡាយ! សម្តេចខ្ញុំ មានសេចក្តីត្រេក
អរជ្រះថ្ងាជាកិយ្យាភាព ចំពោះបុណ្យកតញ្ញុតានេះដោយសុទ្ធចិត្ត ហើយ
បានធ្វើមនសិការៈប្រកបដោយមនោសញ្ចេតនា សំដែងអាការជាបដិគ្គហ-
ភាពទទួលអំណរបុណ្យ ដែលអស់លោកទាំងឡាយ បានធ្វើបដិការតប
ដោយអាទរភាពចំពោះខ្ញុំ ដែលកំពុងតែរងសេចក្តីទុក្ខវេទនា ដោយ
រោគាពាធជិះជាន់ត្របសង្កត់ជាប់តែរាល់ថ្ងៃ មិនដឹងជានឹងបានថ្នាំអ្វីមក
បន្សាបរម្ងាប់រោគនេះ ឲ្យបានជាសះស្បើយទៅឡើយ, ឯថ្នាំសម្រាប់បន្សាប
រម្ងាប់រោគនេះនឹងលោកត្រូពេទ្យ ដែលពួកែអស្ចារ្យមកព្យាបាលតែរាល់ថ្ងៃ
ជាបច្ចុយឲ្យខ្ញុំបានធូរស្រាលត្រាន់ទប់ទល់អត្តភាពនេះ ឲ្យប្រព្រឹត្តបាន
បន្តិច ៗ ចាត់ថាប្រសើរវិសេសណាស់ហើយ ៗ

ពេលនេះ ក្នុងសរីរាងកាយរបស់ខ្ញុំ បានធូរស្រាលអំពីការឈឺចាប់
បន្តិច ដោយបានទទួលបុណ្យកុសលរបស់អស់លោកជាសមណៈនិស្សិត
ដែលឧទ្ទិសប្រគេនចំពោះខ្ញុំ ៗ មហាកុសលនេះដែលកើតឡើង
ប្រហែលជាកើតដោយតំនិតអស់លោកដែលបាននឹកឃើញថា: "ខ្ញុំជា
មនុស្សមួយគួរជាទីស្នេហា គួរជាទីជ្រះថ្ងា ស្រឡាញ់ពេញចិត្ត គួរជាទី
គោរពរបស់អស់លោកទាំងឡាយ ក្នុងជីវលោកសម័យសព្វថ្ងៃនេះ" ៗ
សម្តេចខ្ញុំ មានសេចក្តីពេញចិត្តណាស់ ដែលបានឃើញអស់លោក
ជាសមណៈនិស្សិតទាំងឡាយមានសាមគ្គី បាននាំគ្នាសស្រោកសស្រាញ
មកធ្វើបុណ្យ ឧទ្ទិសប្រគេនខ្ញុំ ដើម្បីឲ្យខ្ញុំមានអាយុវឌ្ឍនភាពចំរើនឡើង
ជាអង្វែងទៅ ៗ ក្នុងកិច្ចនេះ សម្តេចខ្ញុំ ពុំបានធ្វើបដិសណ្ឋារៈផ្ទាល់ចំពោះ

លោកជាសមណៈនិស្សិត ឲ្យបានសមមម្យគេញគ្រប់គ្រាន់ដួនល្មមនឹង
បដិការៈនោះ។ ដូចអស់លោកដឹងស្រាប់ហើយ ។

អស់លោកសមណៈនិស្សិតទាំងឡាយ! សម្តេចខ្ញុំ មានយោបល់
ប្រកបដោយ "ធម្មវិចារណ៍" បានពិចារណា ត្រៃរ៉ៃតើងមើលចំពោះកេរដ-
តាយរបស់ខ្ញុំជារាល់ថ្ងៃហើយ ឃើញថាគ្មានផ្លូវណាមួយល្មមឲ្យសង្ឃឹមនឹង
តអាយុសង្ខារ ឲ្យជឿនលឿនវែងទៅ គ្រាន់តែបានជាទីពឹងពាក់សំណាក់
អាស្រ័យរបស់អស់លោកជាសមណៈនិស្សិតយូរប៉ុន្មានឡើយ ខ្ញុំសូមផ្តាំ
ទុកជាមុនថា "ខ្ញុំសូមលាលោកទាំងអស់ហើយ សូមលោកសង់នៅជាខាង
ក្រោយ គួរខំប្រឹងរៀនសូត្រឲ្យបានចេះដឹងពិតប្រាកដក្នុងធម្មវិនយ ហើយ
ប្រុងប្រដិបត្តិឲ្យបានម៉ឺងម៉ាត់បំបែរសុទ្ធកុងព្រះពុទ្ធសាសនាកុំបីឲ្យឃ្លៀងឃ្លាត "
ព្រោះបើរំណាមធម៌ ធម៌សម្រាប់ធ្វើរូបកាយរបស់មនុស្សសត្វឲ្យប្រែប្រួល
ទៅជានិច្ច តើដូចនឹងមរណៈដែលយើងបានឃើញជាក់ផ្ទាល់ភ្នែក ចេះតែ
សង្កើញចូលមកដិតកិតណាស់ហើយ បានធ្វើឲ្យបែត្តិដល់ការខៀងខាត់
គឺឲ្យបាត់មុខមានឃើញមុខគ្នាទៅវិញទៅមក មិនដឹងជាវេលាថ្ងៃណាមួយ
ប្តុះប៉ើតរំលួចសត្វសុទ្ធតែយ៉ាងនេះហើយ តើធ្វើដូចម្តេចហ្ន៎! ទឹងបាន
សេចក្តីសុខចំរើន?

(មានត)

ដំណើរនៅកាន់ប្រទេសឥណ្ឌា

ក្នុងឧកាសបុណ្យពុទ្ធជយន្តិ ព.ស.២៥០០ គ.ស.១៩៥៦

នៃលោក ភ៉យ-ប៉ុក ក្រមការដើមទ្យៃ

នាយផ្នែកការផ្សាយសៀវភៅនៃក្រុមពុទ្ធសាសនបណ្ឌិត្យ

ប្រធានសមាគមមិត្តពុទ្ធិកវិទ្យាល័យភ្នំពេញ

លោក ភ៉យ-ប៉ុក រៀបរៀង

ដោយបានទទួលសេចក្តីអញ្ជើញរបស់ប្រធានគណៈកម្មាធិការប្រតិ-បត្តិការនៃពិធីបុណ្យ ព.ស. ២៥០០ នៅទីក្រុងញូវដែល្ហីប្រទេសឥណ្ឌា ពិទៃកក្តដា ១៩៥៦, ខ្ញុំ (ភ៉យ-ប៉ុក) តាងនាមសមាគមមិត្តពុទ្ធិកវិទ្យាល័យ បានបេញដំណើរតាមអាកាសយានពីក្រុងភ្នំពេញ នៅថ្ងៃអង្គារទី ២០ វិច្ឆិកា ១៩៥៦ មោ៉ង ៨,៣០ នាទី ទៅដល់ទីក្រុងញូវដែល្ហី នៅថ្ងៃសៅរ៍ទី ២៤ វិច្ឆិកា ១៩៥៦ ពេលមោ៉ង ១៧,២០ នាទី ។ រដ្ឋាភិបាលឥណ្ឌាបានចាត់តំណាងម្នាក់ និងអ្នកប្រែភាសាបាកំងអង់គ្លេសម្នាក់ យករថយន្តមកទទួលខ្ញុំនៅបំណតអាកាសយាន "បាលាំ" ។ រថយន្តក៏បាននាំខ្ញុំទៅសំណាក់នៅភោជនាគារ "អសោក" ដែលជាគ្រិះស្ថានខ្ពស់ជាងគេបំផុតនៅទីក្រុងញូវដែល្ហី (៧ជាន់) ។ ភោជនាគារនេះជាទីសំណាក់នៃពួកគណៈប្រតិភូទាំងសែសឹបប្រទេស ដែលនិមន្តនឹងអញ្ជើញមកប្រជុំក្នុងពិធីបុណ្យនេះ ។

សូមជ្រាបថា: ពិធីបុណ្យពុទ្ធជយន្តិប្រទេសឥណ្ឌាគេចាប់ផ្តើតាំងពីថ្ងៃសៅរ៍ទី ២៤ វិច្ឆិកា ១៩៥៦ រហូតដល់ថ្ងៃពុធទី ១២ ធ្នូ ១៩៥៦ ។

ពិធីបុណ្យនេះបែងចែកជាពីរកាល:

កាលទី ១ ពិធីបុណ្យនៅទីក្រុងញូវដែលហ្ហីចាប់ពីថ្ងៃទី ២៤ វិច្ឆិកា ទៅដល់ថ្ងៃទី ២ ធ្នូ ១៩៥៦ ;

កាលទី ២ ការទស្សនាពុទ្ធបូជនិយដ្ឋានពីទីក្រុងញូវដែលហ្ហី ទៅដល់ទីក្រុងកាលកត្តា តាមអយស្ម៉យយានពិសេស ចាប់ពីថ្ងៃទី ២ ធ្នូ ទៅដល់ថ្ងៃទី ១២ ធ្នូ ១៩៥៦ ។

ពិធីបុណ្យនៅទីក្រុងញូវដែលហ្ហី

ថ្ងៃសៅរ៍ទី ២៤ វិច្ឆិកា ១៩៥៦ ពិធីសម្ពោធបុណ្យពុទ្ធជយន្តិ ឥណ្ឌៀបានធ្វើនៅថ្ងៃទី ២៤ វិច្ឆិកា ពេលមោ៉ង ១៧ នៅតំបន់ពមលិឡាត្រុន ក្រោមអធិបតីកាពលោកវដ្ឋាត្រឹស្ឋន់ អនុប្រធានាធិបតីប្រទេសឥណ្ឌៀ, ប្រធាននៃគណៈកម្មាធិការប្រតិបត្តិការបុណ្យនេះ ។

ឥស្សរជនដែលបានទៅរួមក្នុងពិធីបុណ្យនេះគឺ

១- លោកបណ្ឌិតនេហ៍រូ នាយករដ្ឋមន្ត្រីប្រទេសឥណ្ឌៀ ប្រធានកិត្តិយសនៃគណៈកម្មាធិការប្រតិបត្តិការ ;

២- លោកអ៊ូ-នូ នាយករដ្ឋមន្ត្រីប្រទេសភូមា ,

៣- លោកសាស្ត្រាចារ្យ ត.រ៉ីតាមី ,

៤- ព្រះកិត្ទុស្ហ៉ីរុប ជ៉តសូ ,

៥- លោកត្រីស្តស្ម៉ស ហំហ្ស៉ីស៍ ,

៦- លោកជ៉យវ៉ៃក៉ គុរុព្ទ ,

ព្រមទាំងឥស្សរជនឯទៀតជាច្រើននាក់ ។

ជំបូងលោករដ្ឋាត្រិស្នង់ បានថ្វែងសុន្ទរកថាទទួលអំណរចំពោះគណៈប្រតិកូនានាប្រទេស ដែលអញ្ជើញមកកាន់សន្ទិបាតនោះ ហើយលោកបានបញ្ចប់សុន្ទរកថាដោយពាក្យថា: "បុណ្យពុទ្ធជយន្តិនេះជាស្ពរទូងឲ្យទបាសកទបាសិកាបានត្រាប់ៗគ្នាថា ការណីយកិច្ចនៃពួកពុទ្ធសាសនិកជនទាំងអស់ ត្រូវតែព្រួតគ្នាតស៊ូនឹងអយុត្តិធម៌ ព្រមទាំងអំពើកាចសាហាវ ដែលនាំមនុស្សលោកឲ្យធ្លាក់ទៅក្នុងមហាសង្ត្រាមសាកលលោកទីពាទៀត" ។

លំដាប់ពីនោះមក បណ្ឌិតនេហ៍រូ បានថ្វែងសារលិខិតមួយយ៉ាងក្សោះក្សាយ ។ សេចក្តីសង្ខេបនៃសារលិខិតនោះថា "ត្រូវតែពុទ្ធសាសនិកជនទាំងឡាយ ទោះជាមហាយានក្តី ហីនយានក្តី ត្រូវតែរួបរួមកាន់ដៃគ្នាដោយមេត្រីកាព នឹងកាតរកាព ដើរឆ្ពោះទៅរកសន្តិសុខព្រោះថាជាអ្នកដឿកាន់តាមឥវាទនៃព្រះសម្មាសម្ពុទ្ធតែមួយព្រះអង្គ, ការដែលយើងមានយោបល់ផ្សេងគ្នា មានគំនិតវិទូងគ្នា ជាហេតុធ្វើឲ្យព្រះពុទ្ធសាសនាទុព្ទលភាពជាលំដាប់" ។

ពិធីបុណ្យនេះ, បានបញ្ចប់ដោយមានមនុស្សផ្ទុំខ្ទុយឲ្យស៍ពួសាធុការពរ ចំពោះគណៈប្រតិកូទាំងអស់ ។

ថ្ងៃអាទិត្យទី ២៥ វិច្ឆិកា ម៉ោង ៦ ល្ងាច លោកអ្ចិ-នូរដ្ឋមន្ត្រីប្រទេសកូមា បានថ្វែងសន្ទិសិទក្នុងនាមនៃគណៈប្រតិកូកូមានៅមន្ទីរសន្ទិសិទក្រុងឈ្មោះវិញ្ញាណកវ៉ន អំពីរឿងថា: យ៉ាងដូចម្តេចដែល

ហៅថា.ព្រះពុទ្ធសាសនា ? លោក អ៊ូ-នូ បានពណ៌នាអំពីឧរាទរបស់ព្រះសម្មាសម្ពុទ្ធ ៣ យ៉ាងគឺ ការមិនធ្វើបាបអកុសល ១, ការធ្វើកុសលឲ្យកើតមាន ១, ការធ្វើចិត្តរបស់ខ្លួនឲ្យផ្លូវផង់ ១, បទ្ចាប់មកលោកពណ៌នាអំពីអដ្ឋង្គិកមគ្គ ។

សន្ទិសិទនេះ បានបញ្ចប់នៅម៉ោង ៨ ល្ងាច ។ លោក អ៊ូ-នូ បានធ្វើអំណោយជាសារវត្ថុផ្សេង ។ ក្នុងនាមនៃគណៈប្រតិភូភូមា ចំពោះវដ្ឋាភិបាលប្រទេសឥណ្ឌា ។

ថ្ងៃប៉ន្ទ ទី ២៦ វិច្ឆិកា ម៉ោង ៩. ១០ នាទី មានការថតរូបនៅមុខមន្ទីរសន្ទិសិទ វិញ្ញាណភវ៉ន ដែលមានលោកបណ្ឌិតនេហ៍រូ នាយកដ្ឋមន្ត្រីប្រទេសឥណ្ឌា ចាន អញ្ជើញទៅថតជាមួយ ។

លុះដល់ម៉ោង ៩, ៣០ នាទី មានពិធីបើកសន្ទិសិទនៅមន្ទីរសន្ទិសិទក្រុង វិញ្ញាណភវ៉ន នៅក្រោមអធិបតីភាពលោក បណ្ឌិតនេហ៍រូ ដោយលោកវដ្ឋាត្រិស្ទ៉ង់ ប្រធានគណៈកម្មាធិការប្រតិបត្តិការ មានទុក្ខជាទម្ងន់ ដោយកិរិយារបស់លោកទើបនឹងទទួលអនិច្ចកម្ម ។

សន្ទិសិទនេះពាក្យអង់គ្លេសថា symposium ប្រែថា "ការសួរដេញដោលឲ្យអស់សង្ស័យ ។ ទីសម្រាប់សន្ទិសិទខាងលើនេះមានវេទិកា ១ សម្រាប់គណៈកម្មការបុប្ជាវិសជ្ជនា, មានប្រធាន ១ អនុប្រធាន ១ លេខាធិការ ១ អ្នកវ៉ាត្ថិនដែលត្រូវថ្វែងអត្ថបទមួយអំពីរឿងសិល្សៈ ព្រះពុទ្ធ-សាសនា ១ ។

អត្ថបទទាំងនេះគេធ្វើជាភាសាអង់គ្លេស, មានបោះពុម្ពជាស្រេច ។

ខ្ញុំបានសួរថាអត្ថបទនេះគេធ្វើពីកាលណាមក ? លោកដុកទ័រម្នាក់ឆ្លើយ
ឡើងថា អត្ថបទនេះរង្គាត់ចាស់ណាស់ហើយ ប៉ុន្តែបានបន្តិចបន្តួចទៅតណៈប្រតិភូគ្រប់ប្រទេស
ឲ្យនិពន្ធតាំងពីមុនធ្វើពិធីបុណ្យ ហើយគេបញ្ជូនអត្ថបទនេះទៅតណៈ
កម្មការពិនិត្យ ។ យល់ថាសមគួរហើយ ក៏ឲ្យចុះពុម្ពផ្សាយ ។ ដល់មក
ក្នុងពេលនេះ បុគ្គលណាដែលជាអ្នកតែងនៃអត្ថបទនេះ ត្រូវយកអត្ថបទ
នោះទៅសូត្រ ជាក់ៗគ្នាសន្ទសព្ទ ដែលស្ថិតនៅខាងស្តាំតណៈកម្មការ
ប្តូរវិសជ្ជនា, បើកាលណាគាន់ប្តូរហើយ ប្រធានតណៈកម្មការបានគ្រាក
ឈរឡើង ប្រកាសសួរទៅតណៈប្រតិភូនានាប្រទេសដែលអង្គុយចាំស្តាប់
នៅខាងក្រោម មានតុំណៅអីស្តាបនាជាវង់មូលធំថា តើលោកអ្នកយល់ថាស
យ៉ាំងណាខ្លះទេ ? បើមានតណៈប្រតិភូម្នាក់យល់ថាស់ពីកថាខ័ណ្ឌណា
តណៈប្រតិភូនេះត្រូវឡើងទៅកាន់វេទិកា ដើម្បីថ្លែងពន្យល់តាមៗគ្នា-
សន្ទសព្ទទំនងឲ្យយោបល់ ។ បើអ្នកពាក់ព័ន្ធនោះមិនសុខចិត្ត ក៏ចូលទៅ
ថ្លែងដោះស្រាយ លុះត្រាតែយោបល់ស្រុះគ្នា ។ បើពុងក្រោយមាន
អ្នកពាក់ព័ន្ធពីរនាក់ថាស់យោបល់គ្នា, ត្រូវលោកប្រធានតណៈកម្មការសំដែង
ហេតុផលហើយសម្រេច ។

លុះដល់ម៉ោង ១២ ទើបចប់ន្តវិការប្តូរវិសជ្ជនាមួយលើក ។ ម៉ោង
១៣ មានការលៀងភោជនាហារជាទូទៅ នៅមហាវិសណ្ឋាគារនៃ
លោកថណ្ឌិតនេហ៊ូ ។

លុះដល់ម៉ោង ៣,៣០ នាទីរសៀល មានការប្តូរវិសជ្ជនានៅមន្ទីរ

ទិញ្ញាណកវ៉ន ១ លើកទៀត ដែលមានឯកឧត្តម សម-សារី ជាប្រធានគណៈកម្មការ ។

ឯកឧត្តម សម-សារី ប្រធានគណៈប្រតិកូប្រទេសកម្ពុជាជាប្រធានគណៈកម្មការបុច្ចារិសជ្ជនា ជានថ្ងៃសន្ទិសិទមួយអំពីរឿងព្រះពុទ្ធសាសនា, លំដាប់តមក, មានពួកវ៉ាន្ទិននៃគណៈប្រតិកូនានាប្រទេស ថ្ងៃនជាលំដាប់រហូតដល់ម៉ោង៥ ល្ងាច ។

ម៉ោង៥,៣០នាទី ខ្ញុំនឹងលោកសាដាស៊ីវ៉នជាអ្នកប្រែកាសារបស់ខ្ញុំ ជានទៅទស្សនាពិពណិអន្តរជាតិនៃសិល្បៈព្រះពុទ្ធសាសនា ។

ពិពណិអន្តរជាតិនេះ គឺធ្វើដោយការរួបរួមនឹងអង្គការសហប្រជាជាតិនៃការសិក្សា, នូវវិទ្យាសាស្ត្រនឹងវប្បធម៌ ដើម្បីនឹងផ្សាយនូវសិល្បៈ, អក្សរសាស្ត្រ,ទស្សនវិជ្ជានៃព្រះពុទ្ធសាសនា ។ មានប្រទេសជាច្រើនជានមកតាំងសិល្បៈព្រះពុទ្ធសាសនានៅទីនោះគឺ ប្រទេសឥណ្ឌៀ, ប៉ាគិស្តង់, ថៃឡង់, ភូមា, ជាវ៉ាង, សហរដ្ឋអាមេរិក, ប្រទេសកម្ពុជា, រដ្ឋសីគ្គិម, ប្រទេសចិនប្រជាមានិត, នេជ៉ាល; ហុងគ្រី, ឡាក្រង់ប្រឹតាញ់ជាដើម ។

ថ្ងៃអង្ហារទី ២៣ វិច្ឆិកា ពេលម៉ោង១១, ខ្ញុំនឹងលោក សាដាស៊ីវ៉ណ្ណ(អ្នកប្រែកាសារបស់ខ្ញុំ)ជានទៅកាន់វិហារឥណ្ឌូមួយឈ្មោះ វិហារលក្ឆ្មីនារ៉ង ។ ទៅដល់ទីនោះ នាយទ្វារជាលជានបង្គាប់ឲ្យយើងទាំងពីរនាក់ដោះស្បែកជើង ហើយឲ្យពាក់ស្បែកជើងផ្ទាត់ដែលមានទៅទីនោះ ទើបចូលទៅក្នុងវត្តនោះជាន ។ ខ្ញុំមានសេចក្តីធូល់ថា ស្បែកជើងយ្ងុបនឹងស្បែកជើងផ្ទាត់តើខុសគ្នាយ៉ាងណា ? ខ្ញុំតិតមិនយល់សោះ ។ ក្នុង

ពេលនោះ ខ្ញុំបានលស្បែកដើងផ្ទាត់ណាក៏មិនត្រូវដើង, ខ្ញុំក៏ដើរដើងទទេ ឡើងទៅលើវិហារនោះទៅ ។

វិហារនេះបណ្ណោយប្រវែហល ៣០០ ម៉ែត្រ ទទឹងប្រវែហល ៤០០ ម៉ែត្រ, លោកបិរល៉ាជាអ្នកកសាង ។ នៅតាមសាលា, ព្រះវិហារ សើន . . . . ល . . មានរូបព្រះនាងល្ងក្ស, ព្រះអគ្គមហេសីព្រះគ្រឹស្ទ: ។

លំដាប់តមក, យើងបានទៅទស្សនាព្រះវិហារមួយដែលហៅថា "ព្រះវិហារព្រះពុទ្ធ" ដែលលោកបិរល៉ាកសាងដែរ ។ ព្រះវិហារនេះគឺសាងនៅជិតព្រះវិហារហិណ្ឌូ ។ ខ្ញុំបានស្លូរលោកសាដាស្ប៉ីវ៉ណ្ណថា លោកបិរល៉ានេះជាអ្វី ? លោកជាអ្នកកាន់ព្រះពុទ្ធសាសនា ឬព្រហ្មញ្ញ-សាសនា ? លោកសាដាស្ប៉ីវ៉ណ ឆ្លើយតបមកខ្ញុំវិញថា លោកបិរល៉ានេះជាមហាសប្ប្សរស លោកមិនប្រកាន់លទ្ធិណា សាសនាណាទេ, ឲ្យតែកិច្ចការនោះជាប្រយោជន៍សាធារណ: លោកចេះតែសាង ព្រោះលោកមានធនធានត្រប់ត្រាន់ល្មមធ្វើបាន ។ ព្រះវិហារព្រះពុទ្ធនេះមានបណ្ណោយប្រវែហល ១៥០ម. ទទឹងប្រវែហល ១០០ម. ។

លុះដល់ម៉ោង ១៧-៣០ នាទី យើងបានទៅកាន់ទីមហាពោធិសមាគមនៅញូវដែល្ហី, ជំបន់ក៉ាវិងក្ខ៉ត ដោយមានពិធីទទួលនៅទីនោះ ។ ពិធីនេះគេធ្វើនៅក្រោមអធិបតីភាពនៃលោកដុកទ័រ ក.ន. ក៉តជូ រដ្ឋមន្ត្រីក្រសួងការពារប្រទេស ។

ម៉ោង ៤០ យើងបានទទួលការដប់លៀងភោជនាហារនៅភោជនាគារអសោក ដោយលោកបណ្ឌិតនេហ៍រូ នាយករដ្ឋមន្ត្រីប្រទេសឥណ្ឌៀជាអ្នក

អញ្ជើញ ។ ម៉ោង ៦១,៣០ នាទីយើងបានទៅទស្សនាល្ខោនវណ្ណូ លេងរឿងជីវភាពព្រះសិទ្ធត្ថកុមារ ដោយសេចក្តីអញ្ជើញពីសមាជិកម្នាក់ នៃគណៈកម្មាធិការប្រតិបត្តិការបុណ្យពុទ្ធជយន្ត៌, នៅតំបន់ទល-មិល្ស.ហ្ស៉ត ។

ល្ខោនវណ្ណូ ជាសិល្បៈមួយដ៏ចំទ្យែក ហើយចេះផ្សំទិដ្ឋភាពធម្មជាតិមេឃ, ផ្កាយ, ពពកដោយពន្ធឹអត្ថិសិនីត្រប់ពិណ, នឹងតាប្ចូតំនូរផ្សេងៗ ឲ្យទៅជាស្ថានទីមួយដ៏ល្អអស្ចារ្យ ឆ្លូរឲ្យមើលណាស់របៀបកំ ប្រៀង, កាយវិការផ្សេងៗ នៃល្ខោននោះវិសេសវិសាលពន់ពេក ។

ថ្ងៃពុធទី ៤៨ វិច្ជិកា ម៉ោង ៩,៥០ នាទី, មានការផ្ទើសន្ទិសិទបុច្ចាវិសជ្ជនានៅមន្ទីរវិញ្ញាណកវ៉ន ។ ម៉ោង ១៦,៣០ នាទី មានផ្ទើសន្ទិសិទអំពីសិល្បៈ ព្រះពុទ្ធសាសនា នៅកន្ទែងសន្ទិសិទជដែល, ជល់ម៉ោង ១៩, ៣០ នាទី, មានការលេងល្ខោនវណ្ណៀអំពីរឿងពុទ្ធប្រវត្តិ ។ ក្នុងពេលនោះលោក ជូ-អេន-ឡាយ នាយកវដ្ឋមន្ត្រីប្រទេសចិនប្រជាមានិត ក៏បានអញ្ជើញទៅទស្សនាដែរ ។

ថ្ងៃព្រហស្សតិ៍ទី ៤៩ វិច្ជិកា ម៉ោង ៩,៣០ នាទី, មានផ្ទើសន្ទិសិទបុច្ចាវិសជ្ជនានៅកន្ទែងសន្ទិសិទក្រុង ។ ម៉ោង ១៦,៣០ នាទី, សន្ទិសិទក៏ផ្ទើមតទៅទៀត រហូតជល់ម៉ោង ១៧ ៖

ម៉ោង ១៨,៣០ នាទី លោករាជន្ទ្រូប្រាសាទ ប្រធានាធិបតីសាធារណរដ្ឋវណ្ណៀ បានអញ្ជើញគណៈប្រតិភូនានាប្រទេសទៅជប់លៀងនំទឹកតែ នៅវិមានរបស់លោក ។

(មានត)

អកុហន គុ. ដែលមានការបំភាន់ដំនៀមិនមាន; ដែលមិនបំភាន់,ដែលមិនកុហក ។

អកូដ គុ. ដែលមិនលាន់ឧ,ត;–ន គុ. (កង់) ដែលមិនលាន់សំឡេង ។ នបុំ. កិរិយាស្ងៀម ។

អកូបារ បុំ. សមុទ្រ; មេអណ្តើក ។

អកូប្ប្រ គុ. ដែលមិនលំបាក ។

អកូត គុ. ដែលមិនធ្វើហើយ; នបុំ. កម្មដឹបុគ្គលមិនធ្វើហើយ; អកូតា ស្ត្រី. កុមារិកាដែលមិនទាន់ពេញក្បាប់; អកូតិន៊ គុ. ដែលមានប្រយោជន៍មិនទាន់ធ្វើហើយ ។ – ចូឌ គុ. ដែលមានពិធីចូឌ: (ការសក់) មិនទាន់ធ្វើហើយ ។ – ជ្ញ គុ. ដែលមិនដឹងឈបការគុណដែលគេបានធ្វើហើយ; – ជ្ញតា ស្ត្រី. ភាវៈនៃបុគ្គលមិនដឹងឈបការគុណដែលគេបានធ្វើហើយ ។ – ចូវ៍ គុ. ដែលមានបុពូកិច្ចមិនទាន់ធ្វើហើយ ។ – ប្រជ្ញ គុ. ដែលមានប្រាជ្ញាមិនទាន់ធ្វើហើយ, លូង់ឡៅ ។ – ពុទ្ធិ គុ. ដែលមានពុទ្ធិមិនទាន់ធ្វើហើយ (ដែលមានកិរិយាត្រាស់ដឹងមិនទាន់ធ្វើហើយ); – ពុទ្ធិត្ត នបុំ. ភាវៈនៃបុគ្គលមានពុទ្ធិមិនទាន់ធ្វើហើយ ។ – រៃវ៉ គុ. ដែលមានពៀរមិនទាន់ធ្វើហើយ ។ – ប្រណ បុំ. នាមនៃត្រាហ្មណ៍ម្នាក់ ។ – សំជ្ញ គុ. ដែលមានការសិក្សាមិនទាន់ធ្វើហើយ ។ អកូតាតស៊ (< អកូត + អាតស៊) គុ. ដែលមានទោសមិនទាន់ធ្វើហើយ ។ អកូតាត្មន៊. (< អកូត + អាត្មន៊) គុ. ដែលមានអាត្មន៍មិនទាន់ធ្វើហើយ ។ អកូតាថ៊ (< អកូត + អថ៍) គុ. ដែលមានអាថ៊ិមិនទាន់ធ្វើហើយ ។ អកូតាស្ត្រ (< អកូត + អស្ត្រ) គុ. ដែលមាន

អស្ត្រ (អាវុធ) មិនទាន់ធ្វើហើយ ។ *អកតាហ្និក* (<*អកត* + *អហ្និក*) គុ. ដែលមានពិធីតែមិនទាន់ធ្វើហើយ ។

អកត្តព្វ គុ. ដែលបុគ្គលមិនគប្បីធ្វើ; នបុ. កម្មគឺបុគ្គលមិនគប្បីធ្វើ, បទន្រឹង្ឍ ។ —*ការិន* គុ. ដែលធ្វើនូវកម្មដែលបុគ្គលមិនគប្បីធ្វើ, មនុស្សត្រូវទោសបទន្រឹត ។

អកត្តិ គុ. ដែលបុគ្គលមិនកាត់ហើយ ។

អកត្តិម គុ. ដែលមិនក្លែង, ដែលជាធម្មជាតិ ។

អកត្តុ គុ. ដែលមិនពេញលេញ។ —*វិទ* គុ. ដែលមានវិជ្ជាពេញលេញមិនមាន។

អកត្តុប គុ. ដែលមិនអាណិត; —*ណ* គុ. ដែលមិនក្រឹក្រ, ដែលស្តុកស្តម្ភ ។

អកត្តូ គុ. ដែលមិនស្តួម, ធាត់; —*លក្ខ្ម* គុ. ដែលមានលក្ខ្ម(ទ្រព្យ, សេចក្តីចំរើន) មិនសូវតិចឡើយ, ដែលមានលក្ខ្មពេញបរិបូណ៌ ។ *អកត្តានេកកណ្ណក* (<*អកត្ត* + *អនេក* + *កណ្ណក*) គុ. ដែលមានបន្ទាអនេកមិនមាន, ដែលរួចពីបន្ទា ។

អកត្ថ គុ. ដែលមិនក្តួរហើយ, ដែលមិនដឹកហើយ; ដែលមិនគាំហើយ, ដែលដុះដោយខ្លួនឯង ។ — *អភិនិ* គុ. ដែលដុះដោយមិនចាប់គាំ, ដែលដុះដោយខ្លួនឯង ។

អកេតិន គុ. ដែលមានសំនៅមិនមាន ។

អកេដ គុ. ដែលមានសក់មិនមាន, ដែលទំពែក ។

អកេសិ គុ. ដែលមិនមែនដែកសែ, ដែលមិនមែនវ៉ែ្ក, ដែលមិនមានសក់ ។

អកោប បុ. សេចក្តីមិនក្រោធ, នាមរួមនៃព្រះឱទនសាទិ ។

អកោបន គុ. ដែលមិនក្រោធ ។

អកោវិទ គុ. ដែលមិនឈ្លាស, ឆ្ងៅ ។

អកោដ គុ. ដែលមិនមានស្រោម ។

អក្ក ស្ត្រី. ម្តាយ; មេអណ្តើក ។

អក្ត គុ. (អ៊ត) ដែលនាំទៅហើយ ។

អក្ត គុ. (អ៊ញ្ជ) ដែលណាបលនហើយ។

អក្ត្រា ស្ត្រី. យប់ ។

អក្ត្ថុ បុំ. ពណ៌, ពន្ធ; ពណ៌ឆ្មៅ; ឯឯត, យប់ ។

អក្ឋាបន គុ. ដែលមិនលើម ។

អក្ត្រ (<អ+ក្ត្រ) ដែលមិនកម្រើក, ដែលនឹងឋ្កល់ ។

អក្ត្រ បុំ. ទង់; ប្រាកា; រកំពែង ។

អក្ត្រត្ថុ គុ. ដែលមានបំណង់មិនមាន ។

អក្ត្រម គុ. ដែលឥតក្រម, ដែលមានលំដាប់មិនមាន, ដែលរាត់រាយ ។

អក្ត្រវិបាស្ត គុ. ដែលមានដែប្រឡាក់ឈាមមិនមាន ។

អក្ត្រវ្យាទ គុ. ដែលមិនស៊ីសាច់ ។

អក្ត្រាន្ត គុ. ដែលមិនទៅ, ដែលមិនកន្ទង ដែលឃកមិនបាន ។

អក្ត្រិយា ស្ត្រី. អក្ត្រិយា, ការមិនមានអំពើ ។

អក្ត្រូរ គុ. ដែលមិនកាច, ស្ទូត; ដែលមិនរឹង. ទង់ ។ បុំ. នាមក្រុរបាទយោទៀ ។

អក្រោធ គុ. ដែងមានក្រោធមិនមាន; ឬ. សេចក្តីមិនក្រោធ ។

អក្លម គុ. ដែលមិនអស់កម្ចាំត, ម៉ុងម៉ាត់, មាំទាំ ។

អក្លិម្ត គុ. ដែលមិនសៅហ្មង, វិសេស ។ -ការិន៊ី, ដែលធ្វើការមិនសៅហ្មង ។ -ការ៉ ឬ. អក្ខិម្ទភាព, ការៈ ខៃបុគ្គលមិនសៅហ្មង ។ -ត្រ៉ គុ. ដែលមានត្រាតមិនសៅហ្មង ។

អក្លេទ្យ គុ. ដែលមិនគប្បីធ្វើឲ្យសៅហ្មង ។

អក្លេត ឬ. កិរិយាមិនលំបាក, ការមិនមានទុក្ខ ។ អក្លេតាត៊, អស់ព្យាយាម ។

អក្ស ឬ. ល្បែងបាសក, ត្រៀងលេង; ឈ្មោះដើមឈើ ។ -កិតវ ឬ. អ្នកលេងបាសក ។ -ក្ខជ ឧ ឬ. កលល្បាចនៃល្បែងបាសក; ការកោងនៃល្បែងបាសក ។ -ក្សបណ ឬ. ឈ្មោះនៃអ្នកលេងបាសកម្នាក់ ។ -ត្ថហ ឬ. ការដើរនៃល្បែងបាសក, ការអុកនៃល្បែងបាសក ។ -ទេវិត្ថ ក.ន., -ទេវិន៊ ឬ.; -ធូត៊ ឬ. អ្នកលេងបាសក ។ -ទ្យូត ឧ ឬ. ល្បែងនៃបាសក ។ -ភូមិ ស្ត្រី. ភូមិនៃល្បែងបាសក, ទីហានលេងនៃល្បែងបាសក ។ -មទ. ឬ. កិរិយាញៀននៃល្បែងបាសក ។ -មាលា ស្ត្រី. កម្រងនៃអក្ស, ផ្តាំ (ដែលធ្វើពីត្រាច់ឈើអក្ស); ផ្តាយអរុន្ធត៊; -មាលិកា ស្ត្រី. ផ្តាំ; -មាលិន៊ ឬ. (ដន) អ្នកមានផ្តាំ, ត្រៈសិរៈ ។ -វលយ ឧ ឬ. កងនៃអក្ស, ផ្តាំ; -វលយិន៊ គុ. ដែលមានកងអក្ស, ដែលមានផ្តាំ ។ -សូត្រ ឧ ឬ. ខ្សែនៃអក្ស, ផ្តាំ ។ -ហ្ថុទយ ឧ ឬ. ហ្ថុទ័យនៃបាសក, ល្បាចនៃបាសក ។ អក្សាតិវាប (<អក្ស+អតិវាប) ឬ. អ្នកយាមនៃល្បែងបាសក ។ អក្សាវលី (<អក្ស+អាវលី) ស្ត្រី. កម្រងនៃផ្តាំ, ផ្តាំ ។

អក្ស ប៉ុ. ភ្នៅ (រទេះ); ក្រឡា; ឈ្មោះមនុស្ស ។

អក្ស (*មើលអក្ស*) ប៉ុ. ឧប៉ុ. អន្តារយៈ ។

អក្សណិក គុ. ដែលប្រយ័ត្ន ។

អក្សត គុ. ដែលមិនអស់ទៅ, ដែលមិនអន្តពយ; ប៉ុ. ពហុ. ឬ ឧប៉ុ. ឯក. ត្រាប់ស្រូវ (ដែលបកសម្បកហើយ) សម្រាប់ពិធីបូជា ។

អក្សត្រ, អក្សត្រិយ គុ. ដែលមិនមែនក្សត្រ; ដែលមិនមានក្សត្រ ។

អក្សន មើល អក្ស ។

អក្សម គុ. ដែលមិនមានសមត្ថភាព, ដែលមិនត្ទះដល់; ដែលមិនចង់, ដែលមិនរកកល ។ *អក្សមា* ស្ត្រី. សេចក្តីប្រាថ្នា, បំណង; សេចក្តីខ្ជាញ់ ។ *អក្សមាវន្ត* គុ. ដែលមានបំណង; ដែលខ្ជាញ់ ។

អក្សមិន គុ. ដែលមិនអាណិត ។

អក្សយ គុ. ដែលមិនអស់ទៅ, ដែលបិតថេរ ។ *-ត្ថ* ឧប៉ុ. ភាពអក្ស័យ, ភាពមិនអស់ទៅ ។

អក្សរ គុ. ដែលមិនសឹក, ដែលមិនរីចរិល; ឧប៉ុ. ពាក្ស, សំដី; ព្យាង្ត, ព្យាង្តថា "ទម"; អក្សរ, សំឡេងភាសា; ប៉ើជាពហុ. ឯកសារដែលសរសេរហើយ; ទេវតាជាន់ខ្ពស់; នាមនៃទេវតាផ្សេង ៗ ។ *-ក៏រ* ប៉ុ. សមាធិចិត្តមួយបែប ។ *-ចញ្ចុ ឬ -ចុញ្ចុ ពុំនោះ -ចណ ឬ-ចន* ប៉ុ. "អ្នកឈ្វាសសរសេរ" អ្នកនិពន្ធ ។ *-ប្ឋកក* ឧប៉ុ. កិរិយាប្ឋុតនៃព្យាង្ត (ល្បែង) ។ *- ធន្ធស* ប៉ុ. ធន្ធនៃអក្សរ ។

(មានត)

ទម្ពមសុនិយា

ទស្សនាវិជ្ជី ផ្សាយជំណឹងទាងសាសនា នឹងអក្សរសាស្ត្រ

INSTITUT BOUDDHIQUE



ឆ្នាំទី ២៩ លេខ ៣ ខែមីនា ព.ស. ២៤៩៩ គ.ស. ១៩៥៥



ធម្មសន្ទេយ្យា

ទស្សនាវដ្តី ផ្សាយជំណឹងខាងសាសនា និងអក្សរសាស្ត្រ

ពោះពុទ្ធផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បញ្ជីរឿង	ទំព័រ
–	អប្បមាទកថា . . . . . ព្រះទេពសង្គា កែម – ទូរ. .	២៨៣
–	ប្រស្នាធម៌និងវិន័យ . . . . . ឃុនបណ្ណាគុរ័ក្ស ប៊ូ-ប៉ូ . .	២៩១
ផ្នែកអក្សរសាស្ត្រ		
–	សុភាសិតខ្មែរ . . . . . (តចប់) . . . . . លោកខៀង-គៃឈុន . .	២៨១
–	ដើមកំណើតទីក្រុងភ្នំពេញក្នុងសតវត្សទី ១៥ . . . . . អ្នកស្រីសារិះយ៉ាន . .	២៨៩
–	រឿងទៅនូវរបស់អម្រឹតឈ្មត្រែម៉ុក . . . (តមក) . លោកញ៉ុក-ខែម ពិនិត្យ .	២៣៧
–	សុភាសិតប្រៀបជាជនប្រុសស្រី (តមក) . . . . ព្រះយោសធម្ម ម៉ុង-សែស .	២៤៥
–	តេជ្រព្រះភជា (តមក) . . . . . លោក សុខ-ភោគ ប្រែ . .	២៥៥
–	រឿងសាមកុក (តមក) . . . . . ឧកញ៉ា ន្នូ-ធន ប្រែ . .	២៦៥
–	រឿងហ្សាតិត . . . . . លោកភ័យ - ប៊ុក ប្រែ . .	២៧៧
កំណាត់ធំប្រវត្តិការណ៍		
–	ពិធីបុណ្យកឋិនតេទិតាចំពោះសម្តេចព្រះធម្មលិខិត	
	ឧត្តមប្រើក្សា ល្វី-ឯម របស់សមណៈនិស្សិត (តចប់) លោកឯន-ប៊ិង.	២៨១
–	ដំណើរទៅកាន់ប្រទេសតវ៉ាន់ណៃលោក ភ័យ-ប៊ុក (តមក) . លោកភ័យ-ប៊ុក	២៨៨
–	វចនានុក្រមសំស្ក្រឹតខ្មែរ . (តមក). . . . . ព្រះ ភិក្ខុ ប៉ាង-ខាត់ . .	១៧៧

មួយឆ្នាំមាន ១២សៀវភៅ–តំលៃឆ្នាំវ៉ា ២៣០ខែ០

KAMBUJASURIYA

Revue religieuse et littéraire éditée par
l'Institut Bouddhique

TABLE DES MATIÈRES

PARTIE RELIGIEUSE:

-Appamadakatha . . . . . par vén. KEM-TO 203
-Prasna Dharma-Vinaya . . . . . par M. BOU-PO 211

PARTIE LITTERAIRE:

-Recueils de proverbes Khmers (suite et fin) . . .
par M. TIANG-TAY-CHHUN. 221
-Fondation de la ville de Phnom-penh au 15ème siècle
. . . . . traduit par ME. SARIS-YANN 229
-Histoire de Devanda de M. MOK,
revue et corrigée (suite) . par M. NHOC-THEM. 237
-Bons Conseils (suite) . . . . . par vén. MŒUNG-SES . 245
-Conte "LE DIAMANT DE RAJA" (suite) traduit par M. SIN-HEAN 255
-Histoire de Samkok (suite) . . . . . traduit par M. NOU-KAN . . 265
-Histoire de Zadig . . . . . traduit . par M. RAY-BUC . . . 277

NOTES ET CHRONIQUES:

-Fête de reconnaissance des disciples en l'honneur de Samdach
Dhammalikhita LOUIS-EM. (suite et fin) par M. EN-PANG. 281
-Voyage en Inde de M. RAY-BUC (suite). . par M. RAY-BUC . 288
-Dictionnaire Sanskrit - Khmer (suite) . . . par vén. PANG-KHAT . . . 297

Prix d'abonnement annuel (comprenant 12 numéros): 230$00

ផ្នែកសាសនា

អប្បមាទកថា

ព្រះពុទ្ធសង្គ កិម.ត្ថូវ រៀបរៀង

សូមនមស្សការចំពោះព្រះរត្នត្រ័យគឺព្រះពុទ្ធ

ព្រះធម៌ ព្រះសង្ឃ ដោយសេចក្តីគោរព ។

ទុកាសនេះ អាត្មាភាពសូមស្រង់យកពុទ្ធភាសិតមួយបទដែលមាន
ក្នុងគម្ពីរធម្មបទខុទ្ទកនិកាយ ត្រង់អប្បមាទវគ្គមកសំដែងដូចតទៅនេះ ៖

ពុទ្ធភាសិតនោះគឺ **អប្បមាទញ្ច មេធាវី ធនំ សេដ្ឋំវ រក្ខតិ**
"*អ្នកប្រាជ្ញរមែងរក្សាសេចក្តីមិនប្រមាទទុក ដូចរក្សាទ្រព្យដ៏ប្រសើរ*" ។

ពាក្យថា **អ្នកប្រាជ្ញ** *ក្នុងន័យនេះបានដល់បុគ្គលអ្នកមានប្រាជ្ញា ។*

ពាក្យថា **រមែងរក្សាសេចក្តីមិនប្រមាទទុក** *នោះបានដល់ការ*
មិនចណ្តោយសតិ គឺយ៉ុត្រង់ស្មារតីទុក ឬតាំងស្មារតីឲ្យមាំខ្ជាប់ត្រង់អារម្ម-
ណៈ៤ មិនឲ្យភ្លេចមាយាទៅផ្សេង ។

ពាក្យថា **ទ្រព្យដ៏ប្រសើរ** *បានដល់កែវតាំង៧ប្រការ មានដំរីកែវ*
សេះកែវជាដើម ដែលមនុស្សលោកទាំងឡាយនិយមកាន់យកទុកថាជាទ្រព្យ
ប្រសើរបំផុត ។ រួមសេចក្តីថា បុគ្គលអ្នកមានប្រាជ្ញារមែងយ៉ុត្រង់ ឬដំកល់
ស្មារតីរបស់ខ្លួនទុកឲ្យមាំត្រង់អារម្មណៈ៤ ដូចបុគ្គលរក្សាកែវតាំង ៧
ប្រការ មិនឲ្យវិនាសទៅដោយអន្តរាយផ្សេង ។ មានន័យដូចជាដើម ។

ឥឡូវនេះ ខ្ញុំនឹងអធិប្បាយកំចាយសេចក្តីនៃសុភាសិតនេះឲ្យបានពិស្តារបន្តិច ដើម្បីឲ្យបានជាផ្លូវប្រតិបត្តិនៃអស់លោកជាពុទ្ធសាសនិកជនដូចតទៅនេះ ៖

ពាក្យថា "សេចក្តីមិនប្រមាទ" ក្នុងពុទ្ធភាសិតនេះជាពាក្យផ្ទុយទៅនឹងពាក្យថា "សេចក្តីប្រមាទ" ។

ពាក្យថា "សេចក្តីមិនប្រមាទ" នេះ បើតាមព្យញ្ជនៈ បានដល់សេចក្តីមិនស្រេវឹង គឺមិនស្រេវឹង ក្នុងលាភ ក្នុងយសស័ក្តិ ក្នុងសេចក្តីសរសើរ ក្នុងសេចក្តីសុខ ក្នុងវ័យ ក្នុងភាពមិនមានរោគ ទើបក្នុងជីវិត ។ បើតាមអត្ថ បានដល់ការមិនច្រាសចាកសតិ គឺមិនបណ្តោយស្មារតីឲ្យពាយមាយរសាត់អណ្តែតទៅក្នុងអារម្មណ៍ផ្សេងៗ ។

សេចក្តីមិនប្រមាទនេះ ជាឫសគល់ ឬជាកំពូលនៃកុសលធម៌ទាំងអស់ សូម្បីពុទ្ធវចនៈគឺធម្មក្ខន្ធទាំង៨,៤០០០ធម្មក្ខន្ធ ដែលមានក្នុងបិដកទាំង៣ ក៏គង់រួមបុះមកនៅក្នុងសេចក្តីមិនប្រមាទនេះតែម្យ៉ាង ។ ព្រោះហេតុនោះ ទ្រង់ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា បណ្តាស្នាមជើងនៃពួកសត្វដែលសញ្ចរត្រាច់ទៅលើផែនដី, ស្នាមជើងដំរីធំជាងគេ ព្រោះស្នាមជើងនៃពួកសត្វទាំងអស់នោះ សុទ្ធតែតូច។ ប្រជុំរួមបុះក្នុងរង្វង់នៃស្នាមជើងដំរីទាំងអស់, ដំរីជាសត្វមានជើងធំជាងសត្វទាំងពួងយ៉ាងណាមិញ បណ្តាធម៌ជាកុសលទាំងអស់, ធម៌គឺសេចក្តីមិនប្រមាទជាឫសគល់នៃកុសលធម៌ទាំងពួង ។ ប្រជុំបុះក្នុងសេចក្តីមិនប្រមាទតែម្យ៉ាង ព្រោះសេចក្តីមិនប្រមាទជាកំពូលលើកុសលធម៌ទាំងអស់ ក៏យ៉ាងនោះដែរ ។

ម្យ៉ាងទៀត សេចក្តីមិនប្រមាទនេះ ជាធម៌មានទបការៈយ៉ាង ដ្នើមបំផុតក្នុងកិច្ចការទាំងពួង ទាំងតាងលោកទាំងតាងធម៌ ។ ទាង តាងលោក បុគ្គលដែលបានទទួលឥដ្ឋផលដែលខ្ជូនត្រូវការប្រាថ្នា ដូច ទ្រព្យសម្បត្តិនឹងយសស័ក្តិជាដើម តឺថាបានទ្បើងទៅជាអ្នកមានទ្រព្យ សម្បត្តិដ៏ស្ពុកស្ពម្ភ ឬបានទ្បើងទៅជាអ្នកមានចំណេះចេះដឹងផ្ទូវលោកនឹង ផ្ទូវធម៌ក្តី មានហានន្ទរស័ក្តិដ៏ខ្ពង់ខ្ពស់ ទាងអាណាចក្រឬទាងពុទ្ធចក្រក្តី ក៏អាស្រ័យមកតែអំពីសេចក្តីមិនប្រមាទក្នុងនាទីរបស់ខ្ជូន ឬក្នុងមុខក្រសួង ដែលខ្ជូនត្រូវធ្វើត្រូវប្រព្រឹត្តតែម្យ៉ាង ។ ដើម្បីឲ្យយល់ច្បាស់សេចក្តីនេះ សូម ទាញទទាហរណ៍ជាបុគ្គលាធិដ្ឋាន លើកត្រដាងបង្ហាញ អំពីវីរបុរសទាង ត្រហស្ថនឹងបព្វជិតខ្ទះ ដែលមានក្នុងប្រទេសយើងនេះ តែមិនបាច់ចេញ នាមរបស់វីរបុរសនោះ ។ ទេ ត្រាន់តែលើកប្រវត្តិមកជំណាលខ្ទី ។ ក៏តង់ អស់លោកអ្នកស្តាប់យល់សេចក្តីបាន ។

ដែលហៅថា វីរបុរស សំដៅយកបណ្ឌិតអ្នកមានប្រាជ្ញានឹងសមត្ថកាព ត្រប់ត្រាន់ក្នុងការជួយជាតិជួយប្រទេសនឹងសាសនា ប្រកបដោយសេចក្តី ព្យាយាមព្រមទាំងសេចក្តីក្ទៀវក្ទាអង់អាចមោះមុត មិនតក់ស្ទុត មិនញ-ញើតរួញា ក្នុងកិច្ចការដែលជានាទីរបស់ខ្ជូនត្រូវធ្វើ,បើទុកជាមានទបស័ត្ត មករាវាំងយ៉ាងណា ក៏អាចទំលុះទំលាយពុះពារទបស័ត្តនោះ ។ ទៅបាន យ៉ាងនេះហៅថា វីរបុរស ។ បណ្ណាវីរបុរសបែកទាងត្រហស្ថ វីរបុរសខ្ទះ កើតក្នុងត្រកូលខ្សត់ទ្បាយក៏មាន ខ្ទះកើតក្នុងត្រកូលស្ពុកស្ពម្ភក៏មាន បើទុកជាយ៉ាងណាក៏ដោយ កាលបើមានវ័យចំរើនទ្បើងហើយ ក៏ខំប្រឹង

ប្រែនស្វែនរករៀនចំណេះវិជ្ជានឹនទ្រព្យសម្បត្តិ យូរទៅក៏បានឡើនទៅ
ជាអ្នកមានភោគសម្បូទបរិវារសម្បូទដឹស្ពុកស្ពម្ព ត្រមទាំនមានកិត្តិស៍ពូ
កេរ្ត៏ឈ្មោះល្បីល្បាញទូទៅក្នុនប្រទេស មិនតែប៉ុណ្ណោះ បានឡើនហាន
ន្ពរស៍ក្តិជាមន្ត្រីកិត្តិយសក្រៅដំណែន ។

វីរបុរសខ្ញុះ កាលបើមានវ៍យល្មមរៀនវិជ្ជាហើយ ក៏ខំប្រឹនប្រែន
រៀនដោយយកចិត្តទុកដាក់ ឥតមានសេចក្តីខ្ជិលច្រអូសធុញត្រាន់ក្នុន
ការរៀនវិជ្ជាផ្សេន ។ មានអក្សរសាស្ត្រជាដើមខាន់ផ្ទូវលោក ខ្ញុះនៅ
រៀនតែក្នុនប្រទេសរបស់ខ្ញុន ខ្ញុះបានចេញទៅរៀននៅប្រទេសដទៃ
មិនយូរប៉ុន្មានក៏បានទៅជាមនុស្សមានចំណេះចេះដឹន ជាអ្នកជ្រាជ្ជអាច
ដោះអាថិប្រស្នាផ្ទូវលោកឥតទើសទាល់ មានកេរ្ត៏ឈ្មោះល្បីល្បាញផ្សាយ
ទៅក្នុនប្រទេសតូចធំ មានគេទទួលស្គាល់គោរពរាប់អានស្ទើរតែគ្រប់ត្នា
ថមទាំនបានឡើនជាមន្ត្រីមានយសស៍ក្តិដឹខ្ពន់ខ្ពស់ក្នុនតំណែនទៀត ។
បុគ្គលដែលកន្ទន់ថ្នាក់ទាបឡើនមកកាន់ថ្នាក់ខ្ពស់យ៉ាំននេះ ក៏តាស្រ៍យ
មកតែអំពីសេចក្តីមិនប្រមាទ គឺមិនធ្វេសប្រហែសក្នុនមុខនាទីរបស់ខ្ញុន ។

បណ្ណាវីរបុរសបែកខាន់បព្វជិត វីរបុរសខ្ញុះតាំនពីចូលមកបព្វជា
ប្ជុទបសម្បទាហើយ មិនមានសេចក្តីធ្វេសប្រហែសក្នុនការរៀនខាន
លទ្ធិពុទ្ធសាសនា ដែលជាសាសនាមានខ្ពឹមសារជាន់សាសនាដទៃ ។ ។
ការខំប្រឹនរៀនរបស់លោក បើទុកជាមានទបស៍ត្តចូលមកកាំនយ៉ាំន
ណាក៏ដោយ លោកក៏មិនដាក់ធុរៈទំលាក់ចោល ខំព្យាយាមប្រឹនរៀន
ដរាបទាល់តែបានសម្រេចការចេះដឹនខាន់ផ្ទូវសាសនា បានទៅជាបណ្ឌិត

ជាន់ខ្ពស់មានចំណេះចេះដឹងច្រើនគ្រប់គ្រាន់អាចដោះអាថ៌ប្រស្នា ឥតទើសខាល់ បានតាំងតែងសៀវភៅច្រើនវគ្គ ជាស្រេចតែចិត្តម្ចាស់ផ្ទះ។ សុខ្លួតែជាពាក្យប្រៀនប្រដៅពន្យល់អំពីផ្លូវលោកនឹងផ្លូវធម៌ ខុកជាតំរូវប្តូជាក្តីដំណែលសម្រាប់សិក្សារៀនសូត្រ នៃកុលបុត្រជាន់ក្រោយជាកបដល់សព្វថ្ងៃនេះ, ពីរបុរសខ្លះបានទំប្រឹងបង្ហាត់បង្រៀនកុលបុត្រឲ្យចេះដឹងតៗគ្នា នឹងទេសនាប្រាប់ពន្យល់ជាស់គឿនដល់ចរិតឲ្យកើតសតិបញ្ញា ស្គាល់ខុសនឹងត្រូវ តាំងមានកិត្តិស័ព្ទកេរ្តិ៍ឈ្មោះល្បីរន្ទឺពួនខ្ចរខ្ចាយផ្សាយខ្ទរទៅក្នុងប្រទេសរបស់ខ្លួនទឹងនានាប្រទេស មានគេខ្លួលស្គាល់កាន់តាមជាគោរពកោតក្រែងលើកដំកើងទៅជាអ្នកមានសមណសក្តិដ៏ខ្ពង់ខ្ពស់ ។

ម្យ៉ាងទៀត បើបុរសដែលមិនមានសេចក្តីប្រមាទនោះ បើខុកជាស្លាប់ចាត់បង់ជីវិតទៅហើយ ក៏ឈ្មោះថាមិនស្លាប់ ព្រោះហេតុអ្វី? ព្រោះបុគ្គលមិនមានសេចក្តីប្រមាទ កាលមានជីវិតកំពុងរស់នៅ បានធ្វើប្រយោជន៍នឹងធ្វើសេចក្តីល្អឲ្យកើតឡើងដល់ខ្លួនឯងផង ដល់អ្នកដទៃផង ដែលជាហេតុឲ្យអ្នកដទៃស្រឡាញ់គោរពកាន់តាន បើខុកជាបែកស្លាប់ចាត់បង់ទៅហើយក៏ពិតមែន ប៉ុន្តែសារប្រយោជន៍យ៉ាងសំខាន់ ។ ដូចជាក្បួនច្បាប់អក្សរសាស្ត្រផ្សេង ។ ដែលសំដែងអំពីតតិលោកនឹងតតិធម៌ជាដើម កើតឡើងដោយសារស្នាដៃរបស់លោក ខុកជាក្តីដំណែលឲ្យយើងសិក្សារៀនសូត្រសព្វថ្ងៃនេះ តាំងក្តីឈ្មោះយសស័ក្តិរបស់លោកឥតមានលុបបាត់បង់ទៅណាឡើយ គឺគេតែងបង់តាំងផ់ទៅក្នុងចិត្តជានិច្ចកាល អស្រ័យហេតុនេះឯង បើខុកជាបុរសនោះស្លាប់ហើយ

ក៏ទុកដូចជាមិនស្ងាប់ សមនឹងពុទ្ធភាសិតក្នុងខេត្តសំយុត្តថា រ្បុំ ជីវតិ មប្ជាំ តាមគោត្តំ ន ជីវតិ សេចក្តីថា "រូបតតាងកាយរបស់សត្វទាំងឡាយតែងរលុបរលាយឆាប់ជាងសូន្យទៅ តែឯបកតតាមនឹងគោត្តនាម ព្រមទាំងតតាងរបស់សត្វទាំងឡាយ ឥតរលុបរលាយឆាប់ជាងសូន្យទៅឡើយ" ។

ន័យមួយទៀត ជនអ្នកមិនមានសេចក្តីប្រមាទអាចរៀសវាងនូវផុតអំពីគ្រោះថ្នាក់តតាមនូវកាយរបស់ខ្លួនឬចំពោះទ្រព្យសម្បត្តិរបស់ខ្លួន តួយ៉ាងដូចពេតផ្សេង។ មានបុរសបរកមរមាស់ជាដើម ពេតទាំងនេះអ្នកដែលមិនមានសេចក្តីធ្វេសប្រហែសគេអាចការពារបំបាត់មិនឲ្យកើតឡើងបានដោយប្រើវិធី ២ យ៉ាងគឺ មានថ្នាំប្រើនបៃបសម្រាប់ព្យាបាលខុកប្រចាំនៅជានិច្ច១, មានការសំអាតកងកាយនឹងសំអាតគ្រឿងប្រើប្រាស់ផ្សេង។ មានប្រដាប់សម្រាប់ស្ងៀតពាក់ជាដើម ១ ។ ចំណែកទ្រព្យសម្បត្តិសោតទៀត ជនអ្នកមិនមានសេចក្តីប្រមាទ គេអាចរកៗបាយការពារអន្តរាយផ្សេង។ មានចោរលួចចោរឆ្ងន់ជាដើម មិនឲ្យសត្រូវទាំងនោះចូលមកបៀតបៀន ញាំញីដល់ទ្រព្យសម្បត្តិបានឡើយ ។ សមដូចសុភាសិតខ្មែរបុរាណបានចងទុកមកថា "ប្រហែសបាត់ប្រយ័ត្នគង់" ។ មានមនុស្សខ្លះឆ្លាយតំនិតដឿកអ្នផលជ្រុលហួសពេកពាល់តែបានសេចក្តីវិនាសក៏មាន ដូចសត្វបើដេកមិនភ្ញាក់ខ្លួន ចោរបានឱកាសចូលលួចយកទ្រព្យសម្បត្តិអស់រលីង បៃរៅ

បន្ទោសកម្មផលថា ធ្វើម្តេចខ្ជូនឯងសាងអាក្រក់ពីជាតិមុនមក បានជា
អន្តរាយយ៉ាងនេះ ត្រង់ខ្ជូនឯងធ្វេសតំនិតក្រូចបិទទ្វារមិនតិតបទ្ចោស ហៃ
ជាទៅបន្ទោសផលកម្មវិញ នេះជាតំនិតខុសស្រឡះ ។ មានមនុស្សខ្ជះទៀត
ធ្វើការអ្វីមិនប្រយ័ត្ន ឬមិនប្រយ័ត្នក្នុងពេល ដើរ ឈរ អង្គុយ ដេក
កាលបើប្រើតវិយាបថណាទៅហើយ មានប៉ះទង្គិចជល់នឹងវត្ថុនេះវត្ថុនោះ
ជល់ថ្នាក់របួសត្រាំត្រាវាងកាយបានសេចក្តីទុក្ខលំបាក ហៃរទៅជាថាផល
កម្មចាស់ពីជាតិមុនទៅវិញ ត្រង់ផលកម្មថ្មីដែលខ្ជូនឯងធ្វេសប្រហៃស
មិនតិតជល់សោះ ។

ហេតុនោះ អស់លោកជាពុទ្ធសាសនិកជន បើនឹងប្រារព្ធធ្វើកិច្ចការ
អ្វីទោះជាផ្ទូវលោកក្តីផ្ទូវធម៌ក្តី ត្រូវមានអប្បមាទៈ តឹសេចក្តីមិនធ្វេស
ប្រហៃសតាំងនៅខ្ជាប់ក្នុងសន្តានជានិច្ច ចំពោះកិច្ចការជាមុខក្រសួងរបស់
ខ្ជូន ទើបកិច្ចការនោះ ផុតចាកអន្តរាយផ្សេង ។ ។

តតិធម៌វិញ សេចក្តីមិនប្រមាទនេះ ជាហេតុឲ្យកើតឬឲ្យចំរើនកុសល
ជាលោកិយនឹងលោកកុត្តរ ។ បុគ្គលដែលត្រូវបំពេញកុសលណាមួយ
ឲ្យកើតចំរើនមាំមួនឡើង តាំងអំពីបវិច្ចាតទានរក្សាសីលចំរើនកាវនា ជា
ដើម ដរាបដល់បានសម្រេចមគ្គនឹងផល ក៏ត្រូវអាស្រ័យសេចក្តីមិនប្រមាទ
នេះជាទីតាំងដែរ ។

ន៏យមួយវិញទៀត ដំណើរបស់សត្វដែលត្រាច់រង្គាត់ទៅក្នុង
សង្សារវដ្តមានទៅដរាបណា សេចក្តីវិលកើតវិលស្លាប់របស់សត្វក៏មាន
ទៅដរាបនោះ ។ ធម៌ដែលធ្វើសត្វឲ្យផុតចាកសេចក្តីកើតសេចក្តីស្លាប់

មានតែព្រះនិព្វានទេបញ្ចាំងសត្វឲ្យដល់នូវចំបុតនៃសង្សារវដ្ត; ព្រះនិព្វាន នោះដែលសត្វគប្បីបាន ក៏ព្រោះអាស្រ័យសេចក្តីមិនប្រមាទជាខ័ណ្ឌដែរ ព្រោះហេតុនោះ ឋានជាព្រះដ៏មានព្រះភាគទ្រង់សំដែងថា បុគ្គលអ្នកមានប្រាជ្ញារមែងរក្សាសេចក្តីមិនប្រមាទ ទុកដូចរក្សាទ្រព្យដ៏ប្រសើរ ។

សេចក្តីបរិយាយអំពីសេចក្តីមិនប្រមាទក្នុងពុទ្ធកាសិតនេះ ក៏ល្មមបញ្ចប់ដោយសេចក្តីសង្ខេបត្រឹមប៉ុណ្ណេះ ។

តទៅនេះ សូមអស់លោកជាពុទ្ធបរិស័ទ្យចាំទទួលពរ:

ទុក្ខប្បត្តា ច និទ្ទុក្ខា ភយប្បត្តា ច និព្ភយា
សោកប្បត្តា ច និស្សោកា ហោន្តុ សព្ពេបិ បាណិនោ

សត្វសត្វដែលជួលហើយនូវទុក្ខ សូមឲ្យជាសត្វចាត់ទុក្ខទៅ!
ដែលជួលហើយនូវភ័យ សូមឲ្យជាសត្វចាត់ភ័យទៅ!
ដែលជួលហើយនូវសោក សូមឲ្យជាសត្វចាត់សោកទៅ!

ធម្មទេសនាវិសេន កម្ពោជរដ្ឋវាសិនោ
វុឌ្ឍិំ វិរូឡ្ហិំ បប្បោន្តុ សន្តិភាវញ្ច នាញ្ញថា

ដោយអំណាចនៃព្រះធម៌ទេសនា (នេះ) សូមឲ្យប្រជាជនទាំងឡាយអ្នកនៅក្នុងនគរកម្ពុជរដ្ឋ ជួលនូវការលូតលាស់ចំរើនទំនឹងសន្តិភាព កុំបីឃ្លាតឡើយទៅជាប្រការផ្សេងឡើយ!

ប្រស្នាធម៌និងវិន័យ(១)

ឃុនបណ្ណានុរក្ស ប៊ូ ប៉ុ រៀមរៀង

ផ្នែកប្រស្នាធម៌

១- សំនួរ- *សង្ខារ និងវិសង្ខារ ប្រែយ៉ាងណា ? មានអាការ ផ្សែងគ្នាដូចម្តេច ?*

ចម្លើយ- *ប្រែយ៉ាងនេះ គឺ សង្ខារ-សំស្ក្រឹត កាលបើប្រែតាមព្យញ្ជនៈ ថា "ធម៌ដែលបច្ច័យប្រជុំធ្វើ" បើប្រែតាមអត្ថថា "របស់ដែលសភាវធម៌ តាក់តែងឡើងជារូបជានាម ឬនដល់របស់ដែលធម្មតាផ្សំឡុំមកអំពីធាតុ ឥដ្ឋ ទឹក ភ្លើង ខ្យល់ ដូចខន្ធ ៥ គឺ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ដែលមានកន្លះកាយ របស់មនុស្ស អមនុស្ស សត្វតិរច្ឆានក៏ ទឹងដើម ឈើក្តី របស់ផ្សែងផ្សំមកអំពីសម្ភារៈដូចថ-ផ្ទះជាដើមក្តី ឈ្មោះថាសង្ខារ។ ខោះ លោកចាត់ទុកជាប្រើនយ៉ាង ផ្សែង។ គ្នា គឺ* ឧបាទិន្នកសង្ខារ *សង្ខារដែលមានចិត្តគ្រប់គ្រង, អនុបាទិន្នកសង្ខារ សង្ខារដែលគ្មានចិត្ត គ្រប់គ្រង ទំង* បុញ្ញាភិសង្ខារ *គឺកុសលចេតសិក, អបុញ្ញាភិសង្ខារ គឺអកុសលចេតសិក, អានេញ្ជាភិសង្ខារ គឺអញ្ញាសមានចេតសិក ទំង* កាយសង្ខារ *សភាពតាក់តែងកាយ,* វចីសង្ខារ *សភាពតាក់តែងវាចា,* មនោសង្ខារ *សភាពតាក់តែងចិត្ត ទាំងនេះចាត់ជាសង្ខតធម៌ គឺធម៌ ដែលបច្ច័យតាក់តែងឡើង សុទ្ធតែជាក់នៅកន្លះកាយ។ ក្នុងលក្ខណៈទាំង ៣ គឺ*

---

១) ប្រែចាកក្បាម៉ូធម្មបស្ស ព.ស. ២៤៧៣ ។

๑-អនិច្ចតា សេចក្តីមិនទៀន ដូចក្នុងបាលីថា អនិច្ចា វិត សង្ខារា សង្ខារទាំងឡាយមិនទៀងទេតើ ឧប្បាទវិយធម្មិនោ មានសេចក្តីកើតឡើងនឹងការសាបសូន្យទៅជាធម្មតា ឧប្បជ្ជិត្វា និរុជ្ឈនិ មិនរើសថាជាសង្ខារបែបណាទេ ល្អក៏ដោយ អាក្រក់ក៏ដោយ តែកើតឡើងហើយរមែងលត់ទៅវិញ ។

๒-ទុក្ខតា សេចក្តីជាទុក្ខ ដូចក្នុងបាលីថា សង្ខារា បរមា ទុក្ខា សង្ខារទាំងឡាយជាទុក្ខយាំងក្រៃលែង ។

๓-អនត្តតា សេចក្តីជារបស់មិនមែនខ្លួនប្រាណ គឺថា មិននៅក្នុងអំណាចបង្គាប់បញ្ជារបស់អ្នកណា ។ ជាសភាពទទេគ្មានម្ចាស់ ដូចក្នុងអនត្តលក្ខណសូត្រថា នេតំ មម ន៉ុះមិនមែនរបស់យើង នេសោ ហមស្មិ ន៉ុះមិនមែនយើង ន មេ សោ អត្តា ន៉ុះមិនមែនខ្លួនប្រាណរបស់យើង, ទាំងអស់នេះចាត់ជាសង្ខារ ឈ្មោះថា នៅមានអវិជ្ជា តណ្ហា ឧបាទានកម្ម, កាល បីពួកសត្វនៅមានកិលេសទាំងនេះហើយ ជាតិ ជរា ព្យាធិ មរណៈ សោក ទុក្ខ ក៏រមែងមាននៅដែរ មិនអស់មិនរលត់ទេ គឺចេះតែនៅក្តៅរោលរាលដោយភ្លើងកិលេស ដូចប្រទីបដែលនៅមានប្រេងនឹងប្រេងភ្លើងក៏នៅតែឆេះរហូតទៅមិនចេះរលត់ដូចម្តេច សង្ខារក៏ដូច្នោះដែរ ។

ចំណែកវិសង្ខារនោះ បើប្រែតាមព្យញ្ជនៈថា "ធមិដែលបច្ច័យប្រជុំធ្វើទៅប្រាសហើយ" ប្រែតាមអត្ថថា "ប្រាសចាកសង្ខារ គឺគ្មានសង្ខារ

ឬមាត្មានត្រឿងតាត់តែង ត្មានឲន្ទតំង៥ ត្រាន់តែជាសការ: ឬជាជាតុ ទ្រទ្រង់ទុកប៉ុណ្ណោះ, ជានដល់ អសង្ខតធម៌ គឺធម៌ដែលបច្ច័យមិនជានតាត់តែង គឺព្រះនិព្វាន ដ៏រលត់សង្ខារ រលត់រាគ: ទោស: មោហ: នឹង រលត់កិលេសតូចធំ រលត់អវិជ្ជា តណ្ហា ឧជាទាន កម្ម ទាំងអស់ មិនត្រូវវិលស្ទាប់វិលកើតក្នុងវដ្តសង្សារតទៅទៀត គឺត្មាន ជាតិ ជរា ព្យាធិ មរណ: សោក ទុក្ខ តទៅទៀតទេ រលត់សូន្យទាំងអស់ ។ ហេតុនោះ វិសង្ខារ គឺព្រះនិព្វាន ទើបជារបស់ដែលនៅស្ងិតស្ងៀ មិនប្រែប្រួល មិនប្រកបដោយទុក្ខ ប៉ុន្តែចាត់ជាអនត្តាដូចត្មា ព្រោះមិនជានៅក្នុងអំណាចបង្គាប់បញ្ជារបស់អ្នកណា ។ ។ បើនឹងបង្គាប់ថា ព្រះនិព្វានចូរ មិនទៀង ចូរជាទុក្ខ ចូរជាអត្តាក៏បង្គាប់មិនជាន ។ ព្រះនិព្វាននេះប្រៀបដូចប្រទីបដែលអស់សម្ការ: គឺប្រេងនឹងប្រធេះហើយ មិនអាចឲ្យភ្លើងធេះជានទេ ។ កាលបើភ្លើងរលត់អស់ហើយក៏ជារបស់ត្រជាក់ ដូចម្តេចព្រះនិព្វានក៏ដូច្នោះដែរ ។ ពាក្យថា "វិសង្ខារ" នេះ ត្បូនឹងសំដៅយកចំពោះតែអនុជាទិសេសនិព្វាន(๑) រលត់កិលេស ត្មានបញ្ចក្ខន្ធនៅសេសសល់ គឺព្រះអរិយ: អ្នកជានសម្រេចឧជាទិសេសនិព្វាន នៅមានបញ្ចក្ខន្ធ កាលលោកអស់ជីវិតហើយ ទើបនឹងចាត់ជាវិសង្ខារជាន ។

កាលបើនិយាយដោយបំប្រួញ សង្ខារ នឹង វិសង្ខារ មានអាការផ្សេងត្មាតែត្រង់ថា សង្ខារ ចាត់ជាសង្ខតធម៌ ជារបស់មិនទៀង ប្រកបទៅដោយទុក្ខសោក ។ វិសង្ខារ ចាត់ជាអសង្ខតធម៌ ជារបស់ទៀងចាត់ស្ងិតស្ងៀ

---

๑) អនុជាទិសេសនិព្វាន ព្រះជាលីមិនជានស់ ជាយកអស់ជីវិតទេ ។

ជ្រាសចាកទុក្ខសោក ប៉ុន្តែមានសេចក្តីថាជាអនត្តាដូចគ្នា ត្រូវតាមព្រះ
ចាលីថា សព្ពេ ធម្មា អនត្តា ធម្មិតំនាងជាអនត្តា ។ ពាក្យថា "ធម្មិ"
ក្នុងទីនេះ សំដៅយកតំនសន្ធតធម្មិតំនអសន្ធតធម្មិ ។

មួយទៀត អ្នកដែលបានសម្រេច វិសន្ធារ គឺព្រះនិព្វាន ត្រូវរលត់
សន្ធារដែលមាន អវិជ្ជា តណ្ហា ឧបាទាន កម្ម ជាមុន ដោយប្រើយោ-
និសោមនិការពិចារណាឃើញដោយបញ្ញាថា សន្ធារតំនាងមិនទៀន
ជាទុក្ខ ជាអនត្តា ក៏រមែងនឿយណាយក្នុងទុក្ខក្ខន្ធ មិនត្រូតត្រូនជ្រុលជ្រប់
ក្នុងសន្ធារដែលដឹកនាំចិត្តឲ្យកើតសេចក្តីស្រឡាញ់ ដូចព្រះពុទ្ធកាសិតក្នុង
ធម្មបទ ត្រង់មត្តវត្តថា "កាលណាឃើញដោយបញ្ញាថា សន្ធារតំនឡាយ
តំនាងមិនទៀន ជាទុក្ខ ធម្មិតំនឡាយតំនាងជាអនត្តា (យ៉ាងនេះ
ហើយ) កាលនោះរមែងនឿយណាយក្នុងទុក្ខ ន៉ុះឯងជាផ្លូវនៃសេចក្តី
បរិសុទ្ធិ, ការស្ទប់រម្ងាប់ទូវសន្ធារតំនានោះឯងជាសុខ ។ សេចក្តីសុខ
ក្នុងទីនេះ ក៏គឺព្រះនិព្វានដែលគ្មានសន្ធារ ជាសុខដឹស្អាត ជ្រាសចាក
អាមិស គ្មានគ្រឿងប្រលោមល្បងលោមនឹងគ្រឿងជន្ទចិត្តទេ ជាសុខដឹ
ក្សេមក្សាន្តជ្រាសចាកយោតធម្មិតំន ៤ គឺ កាម ១ ភព ១ អវិជ្ជា ១ ទិដ្ឋិ ១
ជាសុខដែលនឹងរកសុខដទៃមកប្រៀបផ្ទឹមឲ្យត្រឹមស្មើមិនបានឡើយ ។

៤- ស- អសញ្ញីសត្ត វៀរចាកអាហារតំនអស់ តំនគ្មាន
ផស្ស: វេទនា សញ្ញា ចេតនា នឹងចិត្តទេ ចុះដល់វេលាប្យុត គើអ្វីនាំទៅ
ចាប់បដិសន្ធិទៀត? ហើយអ្វីជាតួបដិសន្ធិនោះ? ធម្មិតំនានោះកើតមាន
ឡើងដូចម្តេច ?

ប.. ដើម្បីនឹងឲ្យចូលបិត្តច្បាស់លាស់អំពីរឿងកំរបស់អសញ្ញីសត្ត
នោះ, ខ្ញុំនឹងស្រង់យកបំពោះសេចក្តីប្រៀពីបាលីធម្មហទយវិភង្ត ក្នុង
អភិធម្មបិដកដូចតទៅនេះ ៖

"ក្នុងខណៈដែលកើតឡើងជ្រាកដនៃទេវតាជាអសញ្ញីសត្ត ខន្ធ ១ រមែង
ជ្រាដក គឺរូបក្ខន្ធ, អាយតនៈ ៤ រមែងជ្រាដក គឺរូបាយតនៈ នឹងធម្មាយត-
នៈ, ធាតុ ៤ រមែងជ្រាដក គឺរូបធាតុ នឹងធម្មធាតុ, សច្ចៈ ១ រមែងជ្រាកដ
គឺទុក្ខសច្ច, ឥន្ទ្រីយ៍ ១ រមែងជ្រាកដ គឺរូបជីវិតិន្ទ្រីយ៍, អសញ្ញីសត្ត ទាំង
ឡាយ រមែងជ្រាដកជាអ្នកមិនមានហេតុ មិនមានអាហារ មិនមានផស្សៈ
មិនមានវេទនា មិនមានសញ្ញា មិនមានចេតនា មិនមានចិត្ត" ។

អសញ្ញីសត្ត នេះ ក្នុងវេលាចុតិ កម្មជាតួនាំទៅឲ្យបដិសន្ធិដូចមាន
ទីអាងក្នុងដីកាអភិធម្មត្ថវិភាវិនីថា "កម្មដែលធ្វើទុកក្នុងភពដទៃ (មុនដែល
កើតជាអសញ្ញីសត្ត) ឯណា គប្បីបានឱកាស កម្មនោះរមែងជាហេតុ
នៃបដិសន្ធិ" ។ ចំណែកពាក្យដែលស្ងរដល់តួបដិសន្ធិនោះ ក៏ត្រាន់
តែថាកម្មនឹងនាំទៅបដិសន្ធិក្នុងភពដូចម្តេច ព្រោះបដិសន្ធិមានដល់ ៤ គឺ
អបាយបដិសន្ធិ ១ កាមសុគតិបដិសន្ធិ ១ រូបាវចរបដិសន្ធិ ១ អរូបាវចរ
បដិសន្ធិ ១ លើកតួយ៉ាងដូចមនុស្សស្លាប់ហើយ ខន្ធ ៤ បែកធ្លាយរលត់អស់
ប៉ុន្តែ កម្មនាំឲ្យទៅកើតជាអសញ្ញីសត្ត ត្រង់នេះមានគោលអាងថាអសញ្ញី-
សត្ត នោះមានរូបជាតួបដិសន្ធិ ។ ប៉ើនឹងស្ងរឲ្យខ្ញីថា រូបដែលជាតួបដិសន្ធិ
របស់អសញ្ញីសត្ត នោះយកជាប់មកអំពីភពមុនឬអ្វី ? មុខជាលោកធ្វើយថា
មិនមែនទេ ព្រោះការពិត រូបនោះមានឡើងថ្មីជាតួបដិសន្ធិក្នុងអសញ្ញីសត្ត

នោះឯង មិនបានយកទៅអំពីទីណាទេ កាលបើដូច្នេះ អ្នកដែលចុតិបាក អសញ្ញីភពក៏ដូចគ្នា នឹងយកអ្វីជាប់ទៅតាមផងមិនបានទ្បើយ កាលកម្មនាំ ទៅបដិសន្ធិក្នុងភពដូចម្តេច តួបដិសន្ធិក៏ប្រព្រឹត្តទៅតាមហានៈរបស់ភព នោះ ។ ដូចជាកម្មនាំទៅកើតក្នុងអបាយភូមិ តួបដិសន្ធិក្នុងអបាយភូមិ ក៏ គឺសន្ធីរណៈដឹសហគតៈដោយទបេក្ខា មានអកុសលជាវិបាក បើនាំទៅ កើតក្នុងកាមសុគតិ ក៏មានសន្ធីរណៈដឹសហគតៈដោយទបេក្ខាមានកុសល ជាវិបាក ជាតួបដិសន្ធិ ។ ទោះយ៉ាងណាក៏ដោយ រឿងរ៉ាវទាំងនេះ ជារឿងដែលក្ខឹច្បាស់លាស់ចំពោះតែលោកអ្នកត្រាស់ដឹង មានញាណ ឃើញច្បាស់ទូវការទៅកើតមកកើតប៉ុណ្ណោះ ឯអ្នកធ្វើយប្រស្នានេះមិនមែន ជាអ្នកយល់ចូលចិត្តជាក់ច្បាស់ច្រើនជាងក្បួនច្បាប់ ដែលបានស្រាវជ្រាវ យកមកពិនិត្យមើលនោះទេ ។

*

* *

ផ្នែកប្រស្នាវិន័យព្រះសង្ឆ(๑)

๑-សំនួរ- ព្រះវិន័យមានអ្វីជាអានិសង្ស? គួរប្រតិបត្តិដូចម្តេច ទើបនឹងបានអានិសង្សនោះ?

ចម្លើយ- មានសេចក្តីមិនក្តៅក្រហាយចិត្ត ដែលហៅអវិប្បដិសារៈ ជាអានិសង្ស ។ គួរប្រតិបត្តិឲ្យល្អប្រវិតតាមផ្ទូវមជ្ឈមាបដិបទា គឺមិនឲ្យ

---

๑) ប្រែបាកធម្មចក្ខុ ព.ស.๒๕๓๓ ។

ឥឡូត នឹងមិនឲ្យធ្លូរពេក ទើបនឹងបានអានិសង្ស ។

๒- ស. ភិក្ខុមានបិត្តកាបអាក្រក់ ក្នុងព្រះវិន័យកម្រិតទោសយ៉ាងធ្ងន់ បំផុតត្រឹមណា? មានសិក្ខាបទអ្វីជាគោលអាង? សេចក្តីដូចម្តេច? ចូរឆ្លើយមក!

ច. កម្រឹតទោសត្រឹមដាប់ចាកភិក្ខុភាព ឥត្រូវទោសដល់បារាជិកជាយ៉ាងធ្ងន់បំផុត, មានបារាជិកសិក្ខាបទទី ៣ ជាគោលអាង, សេចក្តីថា ភិក្ខុវៃភ្ងសម្ងាប់មនុស្សឲ្យស្ងាប់ ត្រូវបារាជិក ។

៣- ស ភិក្ខុព្យាយាមដើម្បីទម្ងាយសង្ឆឲ្យបែកគ្នា សង្ឆបែកគ្នាតាមបំណង ១ យ៉ាង មិនបែកគ្នាតាមបំណង ១ យ៉ាង តើភិក្ខុនោះត្រូវអាបត្តិសង្ឆាទិសេសតែម្យ៉ាងដូចគ្នាឬទេ?

ច- មិនទាន់ត្រូវអាបត្តិសង្ឆាទិសេសទាំង ២ យ៉ាងទេ ព្រោះសង្ឆមិនបានសូត្រកម្ម លុះសង្ឆសូត្រកម្មចប់ ៣ ដងហើយ បើភិក្ខុនៅតែប្រព្រឹត្តដូច្នោះទៀត ទោះសង្ឆបែកគ្នាឬមិនបែកគ្នាក៏ដោយ ភិក្ខុនោះត្រូវអាបត្តិសង្ឆាទិសេស ។

๔-ស- ក្នុងនិស្សគ្គិយបាចិត្តិយ មានសិក្ខាបទដែលជាប់ទាក់ទងជាមួយនាងភិក្ខុនីប៉ុន្មានសិក្ខាបទ ឥអ្វីខ្ទះ?

ច- មានពាសិក្ខាបទ ឥសិក្ខាបទទី ៤ ទី ៥ នៃចីវរវត្ត នឹងសិក្ខាបទទី ៧ នៃកោសិយវត្ត ។

៥-ស- ភិក្ខុចូលបិត្តនិយាយញុះញង់ភិក្ខុដទៃដោយពាក្យកុហក ប៉ុន្តែអ្នកស្តាប់មិនបានជឿតាមទេ នឹងឲ្យភិក្ខុនោះត្រូវអាបត្តិបាចិត្តិយបានឬទេ?

ប៉ើបាន តើត្រូវអាបត្តិនោះព្រោះនិយាយញុះញង់ឬក៏ព្រោះនិយាយ
កុហក? ដោយហេតុអ្វី?

ប- ទោះគេជឿក្តីមិនជឿក្តី គង់តែឲ្យត្រូវអាបត្តិបាចិត្តិយបាន ព្រោះ
និយាយញុះញង់ មិនមែនព្រោះនិយាយកុហកទេ, ដោយហេតុដែលកិក្ខុ
នោះមានបេតនាញុះញង់ ។

៦-ស- សេចិយវត្តពួកសារូប ៣ទី១១ ១៦ មានសេចក្តីដូចម្តេច?
ដើម្បីប្រាថ្នាអ្វី បានជាលោកហាមប្រាមដូច្នោះ?

ប- មានសេចក្តីថា កិក្ខុគប្បីធ្វើសេចក្តីសិក្សាថាអញនឹងមិនសើច
ទ្ចាំង ដើទៅឬអង្ពុយនៅក្នុងចន្ទោះជួះ ។ បានជាលោកហាមប្រាមយ៉ាង
នេះ ដើម្បីប្រាថ្នានឹងមិនឲ្យខូចសមណាចរិយា ឲ្យមានសតិរលឹកបាន
នឹងឲ្យតាំងនៅក្នុងសមណាសញ្ញាជានិច្ច ។

៧-ស-កិក្ខុ៦រូប ឈ្លោះប្រកកគ្នាពីរឿងចីវរ, មួយរូបថា ចីវរ
អម្បោះល្អជាងចីវរសូត្រ, មួយរូបទៀតថា ចីវរសូត្រល្អជាងចីវរអម្បោះ
យ៉ាងនេះនឹងចាត់ជាវិវាទាធិករណ៍បានឬទេ? ព្រោះហេតុអ្វី ។

ប- មិនចាត់ជាវិវាទាធិករណ៍ទេ ព្រោះឈ្លោះប្រកកគ្នាក្រៅ
រឿងវ៉ាវ មិនបានប្រារព្ធធម៌ឬវិន័យជាហេតុ ។

* *

*

ផ្នែកប្រស្នារំដែយគ្រហស្ថ

១ - សំនួរ- សេចក្តីចរិសុទ្ធិ នឹងសេចក្តីសៅហ្មង ទាំង២នេះ តើអ្នកស្រឡាញ់ណា? បើជាគ្រហស្ថ នឹងប្រតិបត្តិដូចម្តេច ទើបនឹងបាន តាមសេចក្តីស្រឡាញ់នោះ?

ច- ខ្ញុំស្រឡាញ់សេចក្តីចរិសុទ្ធិ ។ បើជាគ្រហស្ថកាលស្រឡាញ់ បង់បានសេចក្តីចរិសុទ្ធិហើយ ត្រូវតែប្រតិបត្តិយ៉ាងនេះ គឺជាអ្នកមានមេត្តាករុណា មិនសម្លាប់គេ មិនបៀតបៀនគេ ជួយទុក្ខធុរៈគេដោយកម្លាំងកាយ នឹងកម្លាំងតំនិតតាមការណ៍អាចធ្វើកើត រៀបចាកការលួចគេ ឆបោកគេ នឹងជាអ្នកមានអធ្យាស្រ័យចូលាយចែកចាយធនធានដល់អ្នកដែលគួរចែក ចាយ មិនធ្វើទុសអាក្រក់ក្នុងកូនប្រពន្ធគេ គ្រកអរតែក្នុងកិរិយាបស់ខ្លួន មិននិយាយកុហក និយាយតែពាក្យសត្យ ប្រតិបត្តិយ៉ាងនេះ ទើបពាប់ថា ជាអ្នកចរិសុទ្ធិបាន ។

២- ស- គ្រកូលអ្នកមានសម្បត្តិសុកស្តម្ភ តែគាំងនៅយូរមិនបាន តើរោយហេតុអ្វី?

ច ដោយហេតុមិនចំរែងនឹកគ្រឹត្យដែលបាត់បង់ទៅ មិនជួសជុល របស់ដែលចាស់គ្រាំគ្រាបាក់បែក មិនដឹងប្រមាណក្នុងការបរិភោគសម្បត្តិ នឹងគាំងស្ត្រីប្តីបុរសក្រុស្តសីលធ្វើជាមេផ្ទះ ។

៣- ស- តបាសកមានវិធីរកចំញឹមដ៏វៃតតំនរុំផ្ទាំងមនុស្សសាម័ញ ដូចម្តេច?

ច ឧបាសក មិនជ្ជញ្ញេគ្រឿប្រហារ មិនជ្ជញ្ញមនុស្ស មិនជ្ជញ្ញសត្វរស់ និងសាច់សត្វដលនេសម្ចាប់ដើម្បីជាអាហារ មិនជ្ជញ្ញទឹកស្រវឹង មិនជ្ជញ្ញថ្នាំពិស ។ វិធីរកចិញ្ចឹមជីវិតរបស់ឧបាសកតឹងរ៉ឹងជាងមនុស្សសាមីញ្ញយ៉ាងនេះ ។

៤- ស- អាចារ្យនឹងសិស្សគួរប្រតិបត្តិទៅវិញទៅមករកគ្នាជូចម្តេចទើបនឹងបានត្រឹមត្រូវតាមគន្ធងធមិ ?

ច-អាចារ្យគួរអនុគ្រោះសិស្សដោយអាការវណនាំល្អ ឲ្យរៀនសូត្រល្អ ប្រាប់សិល្បវិទ្យាឲ្យអស់ដើងមិនលាក់លាម លើកដំកើងឲ្យប្រាកដក្នុងក្រុមមិត្ត ផ្ទើសេចក្តីការពារក្នុងទិសទាំងឡាយ ។ សិស្សគួរទំនុកបំរុងអាចារ្យវិញដោយអាការក្រោកឈរទទួល ចូលទៅនៅចាំបំរើ ដៀស្តាប់ពាក្យប្រដៅរបស់លោក រៀនសិល្បវិទ្យាដោយគោរព ។

អាចារ្យនឹងសិស្សប្រតិបត្តិរកគ្នាយ៉ាងនេះ ទើបបានត្រឹមត្រូវតាមគន្ធងធមិ ។

ចង់ចំណេញត្រូវសង

ហើចំពាក់ដោយចងការម្ចុទ្ធីបុល
ត្រូវប្រឹងរុលសងគេវិញទើបចំណេញ,
ចំពាក់គុណត្រូវសងគុណទៅគេវិញ
ទើបចំណេញកើតមង្គលដល់ខ្ងួនអឹយ !

យូរ អ៊ុន

ផ្នែកអក្សរសាស្ត្រ

សុភាសិតខ្មែរ

ណេក ទៀង-តៃឈុន ក្រមការដើមខ្សែលេខ១

ប្រមូលរៀបរៀង

(ត-ចប)

១២០- ចិត្តល្អក្រខ្ជូន ។

១២១- ពិសារក្រែណានឹងឃ្ងាន, អាក្រក់ប៉ុន្មានក្រែណានឹងចិត្ត ។

១២២- ដប់នាក់អន្សមខ្ចោច, ត្នាដូចស្រមោចអន្សមដៅ ។

១២៣- លើកស្នារំអារក្អែក ។

១២៤- ត្ងររូបខ្ចាបដ្អើលគោ ។ (ត្ងររូបខ្ចាឲ្យគោខ្ចាប)

១២៥- ប៉ើដុះបាច់អីដាំ, ខ្ចាខាំបាច់អីចូលព្រៃ ។

១២៦- ស៊ីសាច់ដាច់មេត្តា, សេពសុភត្មានពាក្យទៀង ។

១២៧- បាយកកក៏បាយ, មេម៉ាយក៏ស្រី ។

១២៨- គាប់នឹងស្រា, ដានឹងបាយ ។

១២៩- ចង់ចេះឲ្យធ្វើដាល្ងង់ ។

១៣០- បានមាសក្រងក្រដាសខ្ចប់ ។

១៣១- ចោលសាច់ស្រវ៉ាធ្អឹង ទំពារទៅរ៏ងភាវរកសាច់ ។

១៣២- គិតប្រើនវ៉ាឃ្ងាត ដេកប្រើនវ៉ាកើតព្យាធ៏ ។

១៣៣-ប៉ើមិនជួយបែរ កុំតែយកដើងរាងឹក ។

១៣៤-ដេកមិនលក់កុំខំដេក ។

១៣៥-ពុតគ្រូកុំគ្រាប់, ប្បាប់គ្រូឲ្យយក ។

១៣៦-ចោលអង្ក្ររយកអង្ក្រាម ។

១៣៧ មនុស្សខឹងកុំឲ្យលាងចាន, មនុស្សឃ្ងានកុំឲ្យដាំបាយ ។

១៣៨-ស្អប់កុំឲ្យបាញ់, ស្រឡាញ់កុំឲ្យខ្ជី ។

៦៣៩-ខ្ជនរស់របស់គង់, ខ្ជនស្ងាប់បង់ទ្រព្យលាញ ។

១៤០-នៅផ្ទះម្ពាយឡីទៃ, នៅព្រៃម្ពាយជាមួយ ។

១៤១-ជ្ងន់នៅថ្ម, ក្រនៅក្តី ។

១៤២ ខ្មាសគ្រូគ្មានប្រាជ្ញា, ខ្មាសកិយាគ្មានកូន ។

១៤៣-ឬស្សីមួយដើមគង់ផ្សេងប្ចាំង បងប្អូនត្រឡាំងគង់ផ្សេងចិត្ត ។

១៤៤-ចេះប្បាប់មិនខ្ជាបក្តី ចេះវិន័យមិនខ្ជាបសង្ឈ ។

១៤៥-អ្នកឡើងបានតែបេះ អ្នកប្រលេះមិនបានស៊ី អ្នកនៅទទេ
បានស៊ីផ្អែត ។

១៤៦-សូវបែកក្បាលកុំឲ្យបែកធ្នាំង សូវជាប់ចង្ក្រាជាំង កុំឲ្យស្រី
ម៉ើលងាយ ។

១៤៧-ស្រឡាញ់ពេញប្រាស ស្អប់ចំពប់ថើ ។

១៤៨ សមូមិនធ្ងាញ់ឲ្យតែក្តៅ ប្រពន្ធឆ្មៅឲ្យតែក្មេង ។

១៤៩-បានពីក្អែក ចែកតាវៅ ។

១៥០-សូវកាប់កុំឲ្យជន្ធ សូវដេរ"មេដកទងចោរ"កុំឲ្យថា"នែអើ" ។

๑๕๑-សូវឲ្យក្រពើលេប កុំឲ្យចង្ហ៉ាប្របិច ។

๑๕๒-នឹងហារវាស្ហាក់ នឹងឆ្ងាក់វាសែ្ហង នឹងលែងវាពុំបាន ។

๑๕๓-យល់ញាតិយ្ហាតច្បាប់ ។

๑๕๔ ចេះមកពីរៀន បានមកពីរក ។

๑๕๕-ប្ជសដោយវត្ត ចិត្តដោយខ្ជូន ។

๑๕๖ ស្រើបតាមផ្ទរ អរតាមក្ទៀង ។

๑๕๗-បុណ្យបាត់ជ្យិតបាប លាភបាត់ជ្យិតយោរ ។

๑๕๘ ផ្ទុករទេះតាមចំណុះ ។

๑๕๙-កុំដៀងដោយខ្យល់ កុំឡនពាក្យពល កុំខ្ជល់ដោយស្រី ។

๑๖๐-ចង់បុណ្យបានបាប ។

๑๖๑-ចចើងចង់លាភ រែងបាត់ធនទៅ ។

๑๖๒-តិចទ្រព្យអាប់ប្រាជ្ញា ។

๑๖๓-មានះបាត់មិត្រឥតអ្នកជាដៅ ក្រេវក្រោធយោរយៅរមែង-
បាត់អង្ត ។

๑๖๔- ត្រុកៗ អ្នកស្រុកមើលងាយ រលាស់តូចឆ្ជាយមានឡតមាន
ភាន់ ។

๑๖๕- ស្ហូតស្ហាប់ រៀចវេរមានភ័ពអាយុយឺនយូរ ។

๑๖๖- គោដំបៅខ្នង កែ្អកហ៉ីរវិលង រំសាយកន្ធុយ ។

๑๖๗- ស្ហាប់ជូចពស់ រស់ជូចកង្កែប ។

๑๖๘- កុំស៊ីបាយនឹងមនុស្សធ្ជូត កុំកាច់ទសប្រកួតនឹងជំរ ។

๑๖๙- ស៊ីបាយនឹងពន្ធឹទៀន និយាយនឹងមនុស្សមានរបៀន សប្បាយស្តាប់; ស៊ីបាយនឹងពន្ធឹតល់ និយាយនឹងមនុស្សកំហល់ ប៉ុនតេ យកអវ៉ង្របុសដើមទ្រូង ។

๑๗๐- ទ្ធាក្រាបកុំថាទ្ធាសំពះ ។

๑๗๑- ប្រាជ្ញមិនស្មើប្រប បំរើស្ទឹកត្រចៀកទ្ធបមិនស្មើអាទ្យេមទ្យឹម

๑๗๒- ប្រាជ្ញពុំស្មើពុត បំរើលំអុតពុំស្មើក្តីតាប់ មានគុណពុំស្មើ អ្នកដ៏មានបុណ្យកឹត្ធ ។

๑๗๓- កុំយកមេយទ្រាប់អង្ពុយ ។

๑๗๔- ចំណីធ្ធាញ់កុំទុកវស្អក ប្រពន្ធតាប់ក្នែកកុំទ្យដើរក្រោយ ។

๑๗๕- ជ្ជញជិតជាជាងជ្ជញធ្ធាយ ជ្ជញវក្សររៀងអាយរក្សាប្ជូនស្រី ។

๑๗๖- រាយពស់ទ្យវក្អកស៊ី ។

๑๗๗- ត្ថសូរផ្ជរទៅយកឯសំពត់ជ្រលក់ទឹក ។

๑๗๘- ទឹកត្រជាក់ត្រីកុំ ។

๑๗๙- ដេកលើត្នៅ ទៅបៅដោះអ្នកដទៃ ។

๑๘๐- អណ្តើកនៅដើងចាំអីរកវ៉ត្ត ។

๑๘๑- ទ្ពីមលាមកជិះជំរី ទ្ពីមក្តីទ្យើងចុងឈើ ។

๑๘๒- សំដីជាឯក លេខជាទោ ។

๑๘๓- ពេទ្យ គោលូន, មេមត់ ស្ទាប់កូន, សភា ចាញ់ក្តី ។

๑๘๔- ធ្ងីគុណមួយរយសំពៅ ទោសមួយចូលទៅ រលាយបាត់ ប្រាណ ។

๑๘๔- សូវបង់ប្រាក់មួយថង់ កុំឲ្យតែបង់ពាក្យសត្យ ។

๑๘๖- កាន់កពស់ឲ្យឆ្ពាប់ ក្រែងក្រឡាប់ទាំងប្រាណ ។

๑๘๗- បានស្វាយណាយក្រូច, បានតូចណាយធំ, បានក្រមុំ
ណាយចាស់ ។

๑๘๘- ឡៅវែងស្អប់ចេះ, ឧត់ឥតចំណេះ ស្អប់អ្នកមានទ្រព្យ ។

๑๘๙- អ្នកមានរក្សាឧត់ ជូចសំពត់ព័ទ្ធពីក្រៅ, អ្នកប្រាជ្ញរក្សា
ឡៅ ជូចសំពៅនឹងសំបាន ។

๑๙๐-ពារស្ពុកពារស្ពាអ្នកមានប្រាជ្ញា ក្រែណានៅមានបុណ្យក័ព្ទ ។

๑๙๑- ព្ទផ្ពរឲ្យមើលឧល់, ក្ពិពុំយល់កុំអាលក្រោធ ។

๑๙๒- កុំឈ្ងោះនឹងស្រី, កុំជួញនឹងមន្ត្រី, កុំក្ពីនឹងគ្នា ។

๑๙๓-មានទុក្ខមហាក្យត្រិយ៍,មានទុក្ខចៅវត្ត,មានទុក្ខស្រីមានរូប ។

๑๙๔- នំមិនដែលធំជាងនាឡិ ។

๑๐๕- បររទេះត្រិកៗដល់ផ្ទះ តូងតាងដេកផ្ទូវ ។

๑๙๖- ស្វែងរៀនរកច្បាប់ពុំស្ញើចិត្តជា ។

๑๙๗- យល់តូចកុំអាលទំ ទោះយល់ធំកុំអាលស្រាយ ។

๑๙๘- ដើរឲ្យមានបី ស្រដីឲ្យមានបួន ។

๑๙๙- ត្រឡាចវារទៅ ឈ្ពៅវារមក ។

๒๐๐- ឆ្នាមិននៅ កណ្ពុរឡើងរាជ្យ ។

๒๐๑- តិតរួចសឹមតូរ ។

๒๐๒- ឆ្មាយមិនក្រែនឹងបាន មានមិនក្រែនឹងអ្នកដឹបានសុ១ ចេះក្តី មិនក្រែនឹងអម្ចាស់ស្រុក ។

๒๐๓- មានទុក្ខសឹងនឹកវកញ្ញាតិ ដល់ទុក្ខឃ្ងាត បាត់នឹកឈឹង ។

๒๐๒- ដើរឲ្យរំពៃ អង្គុយឲ្យរំពឹង ដេកឲ្យជញ្ជឹង ទឹងឲ្យពិចារណា ។

๒๐๕- ចូលព្រៃសត្ងសាហាវ វកអំពាវគ្នាមកជុំ ដល់បានស្ពរទឹកឃ្ចុំ ញ្ជនក្នុងផ្ទះស៊ីម្នាក់ឯង ។

๒๐๖- ឈើផ្ងចាញ់សន្ទឹក ត្រីប្រើនទឹកល្អក់ពុំជា ទ្រព្យប្រើនព្ជ្ជយរក្សា ទ្រព្យតិចណាព្ជ្ជយរិះគិត ។

๒๐๗- មាន់ព្រៃកំចាយមាន់ស្រុក ។

๒๐๘- ចម្ងងដល់ត្រើយ សើយតូចឲ្យ ។

๒๐๙- អ្នកមុនកំសោយ អ្នកក្រោយមានលាភ ។

๒๑๐- មាន់តែយក កតែកាច់ ។

๒๑๑- សូវស្ពួបកុំឲ្យដាច់, គិតការពុំទាន់ស្រេច កុំអាលរន្ទាន់ ។

๒๑๒- កាលលួបគេវាត្រាន់ តែគេទាន់វាក្រែល ។

๒๑๓- ឆ្ងាមិនឆ្ងាច ទៅឆ្ងាចឯអាចម៍ឆ្ងា ។

๒๑๒- ដូចឆ្ងាក់បានដៃ ។

๒๑๕- ដូចក្រពើវង្ងងបឹង ។

๒๑๖- ដូចគេចិញ្ចឹមកូនឆ្ងា ។

๒๑๗- អាស្ងាមិនទាន់ស្គាល់ព្រនង់ ។

๒๑๘- កុំយកផ្ទះធ្ងីក្តី កុំយកស្រីធ្ងីគ្រូ ។

៦១៩- ត្រីមួយត្រកតែសម្ពុយមួយសម្ពុយ ពំនអស់ ។

៦៦០- ពាក្យត្រូវរនឹន ថ្នាំវេនស្រឹន ពុំដែលពិសា ពាក្យពិតវេន
ស្ទេន ពុំពីរោះថា ។

៦៦១- ជានមិនកើតបន្ទោសឯដែក ។

៦៦៦- ធ្មឹនស្រែក ស្យែកហៅ ។

៦៦៣- មាន់ណាក្តត មាន់នោះពន ។

៦៦៤- ស្រឡាញ់កុំឲ្យទៅញ៉ឹកា ជល់ពួកសឹមទៅម្ពន ។ ។

៦៦៥_ ថោកអីនូវដៃ ថ្ងូអីនូវមាត់ ជូបកន់ត្រាបកន់ធ្នន់ ។

៦៦៦- នានតីស្ទាតាន ស៊ីរះសនទាន មិនឲ្យអន់ចិត្ត ។

៦៦៧- ចំណេះជិះកឯន ។

៦៦៨- ចាប់ប្រវាសំឡឹនជ្រោយ ។

៦៦៩- ទូកទៅ កំពន់ទៅ ។

៦៣០- ចែកមិត្រកុំឲ្យជាមិត្រ ។

៦៣១- ចិត្តជាប់ទៅស្រី ។

៦៣៦- ចានមួយរាវលែនអីនឹនណ្តាំត្នា ។

៦៣៣- ឬកជាតាក្រៃណានឹនទន្សាកំណើត ។

៦៣៤- ស៊ីប្រើនាជុះ លេនប្រើនាឈ្ងោះ ដេកប្រើនាឆ្ងិល ។

៦៣៥- សំណាបយោនជី ស្រីយោនប្រុស ។

៦៣៦- ឆ្ងាវំពឹនត្រៃ ត្រៃវំពឹនឆ្ងា ។

៦៣៧- ជឹកស្រាក្ងាសំជី ។

๒๓๘- មិនដឿពាក្យស្រី អស់ស្រូវពូជ ។

๒๓๙- ប៉ើស៊ីត្រន់ណា កុំជុះត្រន់ណោះ ។

๒๔๐- ក្តីក្រកុំតិតឡាយ ការសំទាយជាកំរោល សិន្សិមកុំបំបោល ក្រែងពុំជល់ជូចប្រាថ្នា ។

๒๔๑- មនុស្សជា គេថាធោត, មនុស្សស្ងូត គេថាល្ងង់, ចេះគេថាកាច ប្រាជ្ញគេថាត្រើល ។

๒๔๒- ចេះមិនដែលចាញ់ ។

๒๔๓- ហេតុមិនស្រឡាញ់សឹងថាឆ្ងាយ ទូកបែកសំពៅឆ្ងាយ សាត់ជល់លង្ការនាយ ស្រឡាញ់ហើយទើបឥបាន ។

๒๔๔- មេម៉ាយកូនមួយជូចត្រហ្ម្ចាវី មេម៉ាយកូនបីជូចស្រីសាវកែ ។

๒๔๕- ជាក់ទ្រូឲ្យស្រះបន្ទា ការសាច់ជូនឆ្ងា ទើបនៅស្រុកបាន ។

๒๔๖- កំឡោះធុំទ្ងិនក្រមុំជូចផ្ការ មានប្តីកាលណាជូចរន្ធកេ ។

๒๔๗- ឥឥតគេរក . មកឥតគេហៅ ។

๒๔๘- និយាយប្រើនពាក្យ គេពុំស្តាប់អាប់ប្រាជ្ញា ។

๒๔๙- ដេកផ្សំជួល រមួលផ្សំគ្រេច ។

๒๕๐- ហុចអំបោះ មិនឲ្យស្រណោះដៃ ។

๒๕๑- ផ្ទូវវៀចកុំបាបង់ ផ្ទូវណាត្រន់កុំដើរហោង ដើរដោយផ្ទូវតន្ទង តម្រាយអ្នកចាស់បូរាណ ។

ដើមកំណើតដីក្រុងកុំពេញ

ក្នុងសតវត្ស ដី ១៥

អ្នកស្រី ពេជ្រ-សល់ ហៅ សារិះយ៉ាន អ្នកស្រាវជ្រាវ

តាមសំណុំរឿងរបស់ក្រុមដំនុំទំនៀមទម្លាប់ខ្មែរ

ក្នុងសតវត្ស ទី ១៥ កាលដែលព្រះបាទពញាយ៉ាតបោះបង់ចោលព្រះរាជវាំងអង្គរ ស្តេចមករកទីកន្លែងសាងដំណាក់ថ្មី ឲ្យឲ្យាយអំពីបឹងទន្លេសាប ដើម្បីកុំឲ្យសៀមចូលមកលុកលុយបាននោះ ព្រះអង្គបានយាងទៅតាំងទីក្រុងឯស្រុកស្រីសុន្ទរជាដំបូង ហើយទ្រង់ឲ្យសង់ប្រាសាទនៅបាសានដែលជាស្រុកមួយក្នុងតំបន់នោះ នៅក្បែរពាមផ្តាយម្រេច ។

ប៉ុន្តែលុះបានសាងប្រាសាទស្រេចហើយ ដល់រដូវក្តៀងធ្លាក់ ទឹកក្តៀងកឹជន់លិចទីក្រុងថ្មីនោះ ។ ព្រះបាទពញាយ៉ាតទ្រង់ព្រះតម្រិះថានឹងស្តេចបេញចោលទីក្រុងទឹកលិចនោះ មកតាំងទីក្រុងនៅទន្លេបួនមុខវិញ ។ តាមប្រវត្តិថា ព្រះអង្គមកតាំងក្រុងថ្មីនៅទន្លេបួនមុខនេះ ក្នុងរវាងគ.ស. ១៤០០-១៤៥០ ប៉ុន្តែគេមិនបានប្រាប់ថា កាលមុនសម័យនោះព្រះអង្គធ្លាប់យាងមកក្រសាលនៅទីទន្លេបួនមុខជារឿយ ។ ដែរឬទេ? កាលទ្រង់ស្តេចមកតាំងក្រុងកុំពេញគ្រាដំបូង គឺក្នុងសតវត្ស ទី ១៩ ។

តាមសេចក្តីតំណាលរបស់សម្តេចចក្រីប៉ុន កាលលោកធ្លីរដ្ឋមន្ត្រីក្រសួងសិក្សាធិការជាតិថា កុំដែលគេឲ្យឈ្មោះដល់ទីក្រុងយើងសព្វវិថ្ងនេះបានកើតឡើងមុនព្រះបរមរាជវាំង ផ្ទាយមានរឿងដំណាលថា ៖

"កាលនោះមានស្រីចាស់ម្នាក់ឈ្មោះ ពេញ ជាអ្នកមានកោតសម្បត្តិបរិបូរ មានទីលំនៅ ។ ក្បែរមាត់ហ្រាំងទន្លេបួនមុខនេះឯង ។ ផ្ទះគាត់សង់

នៅលើទួលមួយតូចនៅទាងកើតភ្នំតូចមួយ ។ ក្នុងថ្ងៃមួយ មានភ្ជៀង
ធ្លាក់ខ្លាំងពេក ទឹកទន្ទេកឹជន់លិចរហាចរហ៊ម ជូនពេញចុះទៅកំពង់ទឹក
ស្រាប់តែឃើញដើមតគីរមួយធំអណ្តែតមកកន្សរច្រាំង, ហើយដោយ
អំណាចទឹកតួចខ្លាំងពេក ដើមតគីរនោះចេះតែអណ្តែតវិលវល់ ៗនៅកន្សរ
ទាងច្រាំង ។ ជូនពេញលុះឃើញជូច្នោះក៏រត់យ៉ាងប្រញាប់ទៅអំពាវនាវ
ហៅអ្នកជិតទាងឲ្យមកជួយទាញយកដើមតគីរនោះ ។ អ្នកជិតទាងទាំង
នោះក៏នាំគ្នាយកពួរទៅចង ហើយអូសរំកិលបន្តិចម្តង ៗ ទាល់តែជល់មក
លើមាត់ច្រាំង ។ យាយពេញយកកំណាត់ឈើទៅកោសកៀរសំអាត
កក់ចេញពេបនោះស្រាប់តែតាត់ឃើញមានប្រហោងមួយក្នុងតល់ឈើតគីរ
នោះ ។ ក្នុងប្រហោងនោះមានព្រះពុទ្ធរូប ៤ ព្រះអង្គតូច ៗ ធ្វើអំពីសំរិទ្ធ
នឹងព្រះពុទ្ធរូបមួយព្រះអង្គទៀតធ្វើអំពីថ្ម ។ ព្រះពុទ្ធរូបដែលធ្វើអំពីថ្ម មាន
រាងជាព្រះពុទ្ធអង្គទ្រង់ឈរ ព្រះហស្តម្ខាងទ្រង់តំបង ព្រះហស្តម្ខាងទៀត
ទ្រង់ស័ង្ខ ហើយព្រះពុទ្ធរូបនោះមានព្រះកេសាជួងជូចជាយួន ។ ជូន
ពេញនឹងអ្នកជិតទាងដែលទៅជួយមានសេចក្តីត្រេកអរណាស់ ដោយទ្ធ
រឹសបានរបស់ដែលជាទីគោរព ក៏នាំគ្នាជង្រៃព្រះពុទ្ធរូបទាំង ៤ អង្គនោះ
មកជល់ផ្ទះជូនពេញ ហើយជូនពេញបាត់សង់ទ្ធមមួយតូច ដើម្បីដំកល់
ព្រះបដិមាករទាំងនោះជាបណ្តោះអាសន្នសិន ។ ថ្ងៃក្រោយមក យាយ
ពេញ អំពាវនាវឲ្យអ្នកជិតទាងជួយលើកដីពួនភ្នំដែលនៅទាងលិចផ្ទះតាត់
នោះឲ្យទៅជាភ្នំធំមែនទ្រង ។ បន្ទាប់ពីនោះមក តាត់បង្គាប់ឲ្យគេអារ
ឈើតគីរនោះធ្វើជាសរសរវិហារដែលតាត់បម្រុងនឹងសង់នៅលើភ្នំនោះ ។

ក្នុង គ.ស.១៣៧២ ជូនពេញនឹងអ្នកស្រុកជាច្រើននាក់ស្រុះស្រួលបបួលគ្នាសាងព្រះវិហារមួយខ្នង ប្រក់ស្បូវក្តាំងនៅលើកំពូលភ្នំ ។ សង់ស្រេចហើយដង្ហែព្រះពុទ្ធរូបចំនួន៤ព្រះអង្គទៅដំកល់ទុកក្នុងព្រះវិហារ ។ ចំណែកព្រះពុទ្ធរូបថ្ម ១ អង្គ គាត់ដង្ហែទៅដំកល់ទុកក្នុងគាសនៈមួយនៅជើងភ្នំខាងកើត ហើយដោយគាត់យល់ឃើញថា ព្រះពុទ្ធរូបនេះអណ្តែតទឹកសោត់មកតាំងពីស្រុកលាវ នឹងមានបែបដែនដូចជាលាវ គាត់ក៏ជាន់ថ្វាយព្រះនាមថា អ្នកតាព្រះបៅ ជាប់មកដល់សព្វថ្ងៃនេះ ។

លុះដល់សាងព្រះវិហាររួចស្រេចហើយ គេនិមន្តព្រះសង្ឃឲ្យមកគង់នៅជើងភ្នំនោះក្នុងទំសាងលិច ទើបកើតមាននាមឈ្មោះ ហៅថា វត្តភ្នំជ្រុនពេញ ជាប់រៀងមក (សព្វថ្ងៃនេះគេហៅកាត់ខ្លីថា ភ្នំពេញ ។ ចាប់ពីពេលនោះមកព្រះពុទ្ធរូបចំនួនព្រះអង្គនឹងអ្នកតាព្រះបៅ ជាន បញ្ចេញឲ្យឃើញឥទ្ធិឫទ្ធិតូចតែសំខ្លឹងណាស់ ដូរតថាបើអ្នកណាទៅបន់អ្វី ។ ក៏ជានសម្រេចដូចសេចក្តីប្រាថ្នាតាមរបស់អ្នកនោះ (នេះជាជំនឿរបស់អ្នកស្រុក) ។ នេះហើយជារឿងភ្នំពេញ ដែលកន្លងរាងន ៥០ ឆ្នាំក្រោយមកជានកើតទៅជាទីក្រុងរបស់ស្តេចខ្មែរយ៉ាងស្តុកស្តម្ភ ។

អំពីទីក្រុងភ្នំពេញវិញ ក្នុងប្រវត្តិជានឲ្យការថា កាលនោះព្រះបរមរាជាធិរាជ កមាធិបតី ព្រះស្រីសុរិយោពណ៌ (នេះជាព្រះនាមនៃព្រះចៅ ពញាយ៉ាត នៅវេលាដែលទ្រង់ឡើងសោយរាជសម្បត្តិ) ទ្រង់សម្រេចព្រះហឫទ័យថា នឹងយាងមកសាងទីក្រុងនៅភ្នំជ្រុនពេញនេះវិញ

ដោយហេតុទីទួលបាសាននោះមានទឹកជន់លិច មិនសមនឹងធ្វើជាទីក្រុង
ស្តេចទេ ។ ទ្រង់ព្រះចិន្តាស្រេចហើយព្រះអង្គ ក៏ទ្រង់ត្រាស់បង្គាប់
ចៅពញាកែ នឹងលោក ឧកញ៉ាហោភធិបតី ទៀរ ព្រមទាំងនាមុឹន
សព្វមុខមន្ត្រីខ្លះ ដែលជំនាញខាងវិជ្ជាហោរចេះមើលជី មើលទីជយ-
ភូមិកន្ទែងល្អសំរាប់សាងព្រះបរមរាជរាំងថ្មី នៅក្សេរភ្នំជូនពេញនោះ ។
ពួកនាមុឹនទទួលព្រះរាជឧន្ទាវហើយក៏នាំគ្នាមកមើលទីកន្ទែង ឃើញថា
កន្ទែងខាងត្បូងឈៀងខាងកើតភ្នំជាទីជយភូមិប្រសើរណាស់ ហើយក៏ធ្វើ
សារតាមសេចក្តីយល់ឃើញនោះ ឲ្យនាំទៅក្រាបទូលស្នើរព្រះមហា-
ក្សត្រ ។ ទ្រង់ត្រាស់បង្គាប់ឲ្យពួកចៅហ្វាយខេត្រគ្រប់ខេត្រកេណ្ឌមនុស្ស
មកជួយសង់កំពែង សង់ព្រះរាជដំណាក់ធំតូចឲ្យហើយយាំងប្រញាប់
រួសរាន់ ។

- ការសាងព្រះរាជរាំងថ្មីក៏បានហើយធាប់ជូចព្រះរាជបំណង ទើបព្រះ
អង្គចាត់ឲ្យរៀបដំណើរស្តេចចេញពីក្រុងបាសាន ដើម្បីមកគង់នៅទីក្រុងថ្មី
នៅវិថ្ងៃ ៩ កើតខែពិសាខឆ្នាំខាល ឆស័ក ត្រូវនឹង គ.ស. ១៤៣៤ ព្រះអង្គ
បានគង់នៅស្រុកបាសានតែមួយឆ្នាំគត់ប៉ុណ្ណោះទេ ។ ទ្រង់យាងមកក្រុង
ភ្នំពេញដោយទូកសំពៅ ព្រមទាំងសេនាយោធាហែហមព្រះអង្គមកផង ។

- ការលព្រះអង្គបានមកគង់នៅទីភ្នំពេញនោះហើយ ទ្រង់ត្រាស់ប្រើឲ្យ
លោក ឧកញ៉ាតេជោស្រី ដែលជាចៅហ្វាយខេត្រសំរោងទង ឲ្យកេណ្ឌ
មនុស្សបានការទាំងឡាយមកជញ្ជូនដី ចាក់បំពេញផ្ទូរជំហុកខ្លះដែលនៅ
ទិសខាងត្បូងនឹងខាងកើតភ្នំឲ្យ ទៅជាផែនដីរាបទាបស្មើល្អ តាំងពីជើងភ្នំ

រហូតដល់ខាងក្នុងព្រះបរមរាជកំផែង ។ ចាប់ដើមតាំងពីនោះមក គេហៅកំពង់នោះថា ពីរីបឹកំពង់រាប ។ នៅទីកលន្ទ្រៀដែលគេដឹកជញ្ជូនដីយកទៅលុបចុងកំហុកនោះ កំភ្លាយទៅជាបឹងមួយធំហៅថា បឹងតេជោ(១) ។

ក្រោយមកទៀត ព្រះមហាក្សត្រទ្រង់គ្រាស់បង្គាប់ឲ្យលោកឧកញ៉ាប្ដុង ទៅហ្វាយខេត្តចាត់ឲ្យកេណ្ឌមនុស្សដឹកព្រៃកមួយបន្ទុះទឹកតាទន្លេបួនមុខចូលទៅក្នុងកំផែងដើម្បីឲ្យបណ្ដាជនប្រើប្រាស់ជាប្រក្រតី ។ ប៉ុន្តែទ្រង់មិនឲ្យដឹកព្រៃកនោះចុកចំហរខាងលើទេ ឲ្យធ្លុះធ្លង់ក្នុងដីបង្គន់ទឹកបញ្ចូលស្រះក្នុងកំផែង(២) ព្រៃកដឹកនោះហៅថា ព្រៃកឧកញ៉ាប្ដុង ជាប់រៀងមក(៣) ។

បន្ទាប់មក ព្រះមហាក្សត្រទ្រង់បង្គាប់ឲ្យដឹកព្រៃកទៅទំលាខាងត្បូងកំផែងមួយទៀត ហើយឲ្យលើកជាកំពែងតូចដុំវិញក្រុង ។ ព្រៃកនៅខាងស្ដាំនោះឲ្យឈ្មោះថា ព្រៃកតាកែវ(៤) មានអូរមួយនៅខាងលិច(៥) ហៅ

១– បឹងតេជោ ចាប់តាំងពីខាងលិចមហាវិថី ព្រះបាទភេត្តម រហូតទៅទល់នឹងខាងត្បូងផ្ទៃក់ពតសព្វថ្ងៃនេះ ។

២– ព្រះរាជកំផែងកាលណោះនៅត្រង់កន្លែងជិតសណ្ឋាគារក្រុង ធនាគារឥណ្ឌូចិនហើយនឹងដ្ឋានធំថ្មី ។

៣– ព្រៃកនោះនៅកន្លែងសួនច្បារមុខស្ថានីយ៍ឡានដែលមានផ្ទះព្រះមហាក្សត្រីយានី នឹងផ្ទះឧកញ៉ាប្ដុង នៅអមសងខាង ។

៤– ព្រៃកនោះនៅកន្លែងខាងត្បូងវត្ត ពាកែវ (វត្តកែវព្រះភ្លើង) ។

៥– អូរនេះនៅខាងកើតវង់បរសេះ សន្ធឹងពីត្បូងទៅជើង ។

អ្នកគ្រូ ។ ខាងព្រែកមួយទៅខាងជើងហៅថា ព្រែកពុំពាយ(១) ប៉ុន្តែ
ដោយហេតុត្រង់កន្លែងនោះកន្លងចំនង់ធ្វើផក ទើបព្រែកពុំពាយក៏ក្លាយឈ្មោះ
ទៅជា ព្រែកបិតជំពែក ទៅវិញ(២) ។ ទៅតាមមាត់ទន្លេ ព្រះមហាក្សត្រ
ទ្រង់បង្គាប់ឲ្យលើកដីជាកំពែងដើម្បីការពារទឹកទន្លេកុំឲ្យឡើងលិចក្រុង ។
ទៅក្នុងកំពែងដែលជារបងនៃទីក្រុងថ្មីនេះ ពួកអ្នកភជការនិងអ្នកស្រុកសង់
ផ្ទះសម្បែងបានតាមចិត្ត តែចំណែកភូមិភាគខាងលិចទីក្រុងនោះសុទ្ធតែ
វាលស្រែ ។

លុះរៀបចំទីក្រុងស្រេចហើយ ព្រះបាទស្រីសុរិយោពណ៌ក៏ទ្រង់
ប្រទានឈ្មោះក្រុងថ្មីនេះថា ក្រុងបតុមុខមង្គល សុទ្ធាកម្ពុជាធិបតី
សិរីសុន្ទរបវរតិន្ទបត្តមួរិន្ទរាជសីមាមហានគរ ។ ចំណែកទន្លេដែល
ទៅពីខាងមុខព្រះបរមភជកំនត់ ហើយដែលពីមុនមកមានឈ្មោះហៅថា
ទន្លេប្រាបឈាម នោះទ្រង់បញ្ញត្តឲ្យហៅថា ទន្លេបតុមុខ វិញ ។

បួនឆ្នាំក្រោយមក ព្រះនរាយណ៍រាជា ជាព្រះភជបុត្រច្បងនៃព្រះ
ស្រីសុរិយោពណ៌ បានត្រូវតាំងជាព្រះឧបភជ ហើយទៅសាងគ្រាសាទ
តន់ទៅឯក្រោយវិញ ។ កន្លងពេលជាមួយបន្តិចនោះ ព្រះស្រីរាជា ជា
ព្រះភជបុត្រមច្ចាប់នៃព្រះស្រីសុរិយោពណ៌ ទៅតន់ទៅទីខាងលិចភ្នំគូរ
ទៅលើខ្នងមួយដែលគេតែងហៅថា ខ្នងព្រះស្រី (កន្លងយូរមក ទី

---

១ ២- ព្រែកនៅខាងត្បូងផ្ទះលោកដីជាតំណាងសព្វថ្ងៃ ព្រែកនេះប្រហែលជាតាមពាក្យឈ្មោះ
ព្រែកពោងពាយទេ ប៉ុន្តែភាសាអ្នកស្រុកចេះតែហៅថ្លាយទៅ ។ ។

កន្ទេងនោះទៅជាកន្ទេងកប់ខ្មោចចិនវិញ) ។

ខាងក្រោយមកទៀត វិហាររបស់ជូនពេញក៏ចាក់បែកខ្ទេចខ្ទេចស្ទើរតែលំ ព្រះមហាក្សត្រទ្រង់សព្វព្រះទ័យនឹងរុះរើធ្វើជាថ្មីឡើងវិញ ហើយទ្រង់ក៏ធ្វើតយកទីតាសនោះទីនឹងផ្ទាស់បែបផែនឲ្យបានល្អវិសេសជាងមុន ទើបព្រះអង្គបង្គាប់ឲ្យលើកដីពូនកុំនោះឲ្យបានធំហើយខ្ពស់ជាងមុន រួចទ្រង់ឲ្យចាក់ថ្មក្រាលលើកុំនោះ ឲ្យសង់ចេតីយធំ ๑ អង្គ ។ កុនចេតីយធំនោះ មានធ្វើជាហាន៣ថ្នាក់ ហានខាងក្រោមធ្វើទ្វារគ្រប់ទាំង ๔ ទិស ។ កុនពេលជាមួយគ្នានោះ ព្រះមហាក្សត្រឲ្យកសាងវត្តជាប្រើនទៅកុនទីក្រុង គឺវត្តពីរនៅខាងកើតកុំ វត្តមួយនៅខាងត្បូងព្រែកចិនដំដែក វត្តមួយទៀតនៅកែ្សរមាត់ទន្លេ ត្រង់ពាមព្រែកឧកញ៉ាប៉ុន វត្តមួយទៀតនៅត្រង់ចេតីយវត្តទុណ្ណាលោម ហើយនឹងវត្តមួយក្រោយបង្អស់នៅខ្ពបតាយ៉ង(๑) ។

ព្រះមហាក្សត្រប្រើឲ្យទៅដង្ហែព្រះពុទ្ធរូបខ្លះ នឹងយករូបសង្ហឹគោខ្លះមកពីតំបន់តវត្ត មានក្បួនហែហមយ៉ាងទន្លាក់ យកមកដំកល់ទុកលើកុំដូនពេញនោះ ។ តំណើរដង្ហែធ្វើអស់ពីរៈយៈថ្ងៃ ព្រះពុទ្ធរូបទាំង ๔ អង្គដែលដូនពេញរើសបាននោះ គេយកទៅប្រតិស្ឋានកុនចេតីយហានខាងលើ ។ ព្រះពុទ្ធរូបដែលយកមកអំពីនតវត្តដំកល់កុនព្រះចេតីយធំនោះដែរ តែនៅហានខាងក្រោម ។

បំណែរក្រោយមកទៀត ព្រះមហាក្សត្រធ្វើបុណ្យតាមទំនៀមប្បូ

๑- ដែលជាវត្តបុទុមវតីពាធិរកាមសព្វថ្ងៃនេះ ។

ស្រុកហើយ ទ្រង់បញ្ជាឲ្យឈ្មោះវត្តដែលសាងថ្មីៗ ពាន់នោះ គឺវត្តនៅលើភ្នំឲ្យឈ្មោះថា វត្តព្រះបេតិយបព៌ត ប៉ុន្តែអ្នកស្រុកចេះតែនាំគ្នាហៅថា វត្តភ្នំ ។ រហូតមកដល់សព្វថ្ងៃនេះ ។ ចំណែកវត្តពីរនៅខាងកើតភ្នំនោះ វត្តមួយនៅខាងត្បូងហៅ វត្តកោះ វត្តមួយនៅខាងជើងហៅ វត្តលង្កា នៅកន្លែងវត្តលង្កានេះហើយដែលគេជំនាស់តម្រាផ្សេងៗ។ វត្តមួយនៅខាងត្បូងព្រៃកចន្ទដែកហៅថា វត្តពុទ្ធយោសា ។ វត្តដែលនៅមាត់ទន្លេក្បែរព្រៃត ទុកញ៉ាប្ញ័ង ហៅ វត្តពាមប្ញ័ង ។ ឯព្រះពុទ្ធរូបដែលប្រតិស្ថានក្នុងព្រះវិហារនោះហៅថា ព្រះស្រែការលេញ ។ វត្តឧណ្ណាលោម គេច្រើនហៅតាមពាក្យ "ឧណ្ណាលោម" ប្រែថា "រោមប្រជុំចិញ្ចើម" ឈ្មោះវត្តឧណ្ណាលោម(๑) ជាវត្តធំមួយក្នុងក្រុងភ្នំពេញ, មានចេតិយបុរាណធំមួយនៅខាងក្រោយឧបោសថាគារ មានចេតិយធំបន្ទាប់ ๔ ព័ទ្ធជុំវិញ តស្លាប់ទីឆ៍ចេតិយធំ ។ ក្នុងចេតិយធំនោះ តាមសេចក្តីតំណាលថា គេបញ្ចុះរោមប្រជុំចិញ្ចើមនៃព្រះមហាវរមួយអង្គមានឈ្មោះពុំច្បាស់... ។ លុះដល់មកពុទ្ធសករាជ ๒๔๒๓ សម្តេចព្រះមហាសង្ឃរាជព្រះនាម ទៀង ជាន់បញ្ចុះព្រះបរមសារីរិកធាតុនៃព្រះសក្យមុនីសម្មាសម្ពុទ្ធមួយព្រះអង្គគួបក្នុងចេតិយធំក ណ្តាល; ព្រះបរមធាតុនោះព្រះសារីសុមង្គលាចារ្យ ជាសង្ឃនាយកនៅលង្កាទ្វីប ជាន់ចាត់មហាវរមួយរូបឈ្មោះ ឥសិវរិយៈ ឲ្យនាំមកថ្វាយ(តាមអក្សរចារឹកនៅលើមាត់ថ្ងាររចតិយពាន់គួខាងមុខចេតិយធំ)។

---

(๑) ស្រង់ពីឯកសារនៃក្រសួងវប្បធម៌ ភាគទី ๒ ទំព័រ ๑๖๔ ។

រឿងនេវន្ត

ពាក្យកាព្យ

លោកអម្ចូតក្សត្រី ម៉ុក រៀបរៀង

ក្នុងរាជ្យព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម

លោក ញ៉ុក ថៃម ពិនិត្យ

(តមក)

ទិហារដែលមាន នៅក្នុំប៉ុន្មាន ទាំងគ្រោមទាំងលើ សឹងក្សឿងឥដ្ឋថ្ម
បាយអរប្រោសប្រើ ជួលទ្មែរបិនធ្វើ សោតសឹងស្រេចស្រាប់ ។
សព្វព្រះទ័យពន់ រឿងព្រះទៅន្ត ប្រសើរមហាតាប់ ដ្សិតឥតអាចារ្យ
ពិស្តារសារស័ព្ទ សំដែងសណ្តាប់ តំណាតទុក ។ ប្រោសប្រើខ្ញុំជា
ខ្ញុំល្អងបាទ ដើមនាមឈ្មោះ ម៉ុក ឲ្យតែងបេញពី បាលីតាំងទុក
តំណាទៅមុខ តំណាងសាសនា ។ មេត្តាប្រោសប្រាណ ប្រោស
ព្រះរាជទាន ទៃនាមខ្ញុំជា អម្ចូតក្សត្រី ដោយក្តីករុណា ខ្ញុំនឹងពណ៌នា
ជាកាព្យបែងចង ។ ប្រោសឲ្យ ហៅពញា សុន្ធរអក្ខរា កែកុន
តិតធង ជាអ្នកស្មៀនស្មេរ សរសេរចម្ងង ដោយនូវទំនង ដំណើរ
សេចក្តី ។ ក្រែងខ្ញុំលាកលះ ពាក្យពេចន៍ទាតខ្ងះ ចួនធ្តាំធ្តងក្តី
អ្នកណោប្រាជ្ញប្រុះ ធ្ងាតធ្ងុះកុំបី ដៀលតិះប្រណ៌ តម្រង់ឲ្យទាន ។

សត្ថវិហោ(១) សត្ថនាយកោ(២) កាលព្រះទ្រង់ញាណ

---

១ ទ្រង់ទាំពួកសត្វពឹចម្ងងសត្វទៅកាន់ហានព្រះនិព្វាន ។ ២ ទ្រង់ជានាយកនៃពួក
សត្ថរោក ។

គន់គន់ដេតពន សុតន្តវេយ្យមក្សាន្ត សម្រាកសម្រាន្ត ចាំព្រះវេស្សា ។ អស្រ័យសាវត្ថី បិណ្ឌបាតប្រក្រតី តែងទ្រន់ទេសនា ប្រោសសត្វសព្វ ហាន ខ្លះបានសកិទា-គាមិស្រោតា អនាគាមីអរហត្ត ។ ថ្ងៃមួយព្រះអង្គ លីលាឡើងគង់ លើអាស្នាត្តុំ ជុំវិញសង្ឃមហាជន អរហន្តបរិសុទ្ធ ព្រមព្រះមហាសាវក តិក្ខនិតិក្ខសច្ច ។ សំដែងអាថិអាថ៌ កាលព្រះយេកជាតិ ជាពោធិវង្ស នាមព្រះទេវទូត អានន្ទត្តេរទ្រង់ ចាំជាក់ព្រះអង្គ រៃរៀងនិយាយ ។ លង់តែវគ្រែភ្លាត់ វគ្រែតេជបង់ចាក់ ទ្រង់ចាកែជាបទបាទចាស៎ សំដីលង្កា ខុកតសាស្នា ព្រះសម្ពុទ្ធោ ។ អតីតេកាលេ(១) ពារាណសិយេ(២) ឯកពាជោ(៣) រាជជាយោ(៤) រមែលានាមេ(៥) គន្ធិប្បុត្តោ(៦) ឫត្តិវិរ្យោ(៧) ។ កិរកាលកតព័ន្ធ៍ គតផុតទាំងខ័ណ្ឌ កំចាំងចាត់ជា លង្កែកតវែងឆ្ងាយ ពីប្រេងខាយណា មានពាជរដ្ឋ ឈ្មោះពាកណាសី ។ មានឯកអង្គក្សត្រ នាមព្រះព្រហ្មទត្ត រែគ្គ-មហេសី នាមទាធិរមណា បរិពារសោស្រី ជម្រើប្រក្រតី មួយហ្មឺនហុកសាន់ ។ វត្រែនគរ ប្រសើរចំប្លែក ដូចសត្តបរិស័ណ្ឌ ជង្ហែជុំវិញ ប្រាំពីរជុំជាន់ ជាំនាំវែងទាំងខ័ណ្ឌ ឆេងធំខ្លួសាយ ។ រៀបដោយទ្វារគ្រប់ សឹងមានមណ្ឌប ប្រសើរឆើតឆាយ គួគោកទាំងខ័ណ្ឌ គ្រប់ជាន់បន្ទាយ ចាក់ចម្រុងពយ រៀបរូបបមនៅ ។ ប្រាសាទសួស្តីសល់ ប្រសើរយេងយល់ រុងរឿងដំខន្ធៅ ភ្លឺផ្កែកភាវគោ សន្ធោសន្ធៅ សន្ធឹក

---

១ ក្នុងសារត្ថទីបនីហើយ ។ ២ ក្នុងព្រហ្មណារណស ។ ៣ មានស្តេច ១ ព្រះអង្គ ។ ៤ ជាតកហេសិរបស់ស្តេច ។ ៥ ឧហេសិព្រះនាមទាធិរមណា ។ ៦ ជាតព្រះពាធិប្បុត្រ ។ ៧ ឫត្តិដំប្រសើរ (កំណាន) ។

ចំខ្លៅ ចំខ្លាក់មាសមាន ។ ប្រសើរសល់ថ្ងៃធ ចំញាចចំញែងធ ជញ្ជាំងបើកបាន ត្រដែតត្រដាង ស្ទៅស្ទាបរូហាន(១) ហាក់ច្រោសាខ ហាន ព្រះឥន្ទ្រស្តេចគន់ ។ ចូលជុំសម្តេច ត្រាវឆ្ងាស្តេច មន្ត្រីចតុ-រង្គ(២) តន់ត្រែអស្សាហ៍ សេនាពលពន្ធ ក្សត្រាយឯកអគ្គ ចំណុះបក្រើ ។ ស្តេចសោយសម្បត្តិ សម្បូរពេញស្រុងជ្ជ ឯកអគ្គមហេសី ខ្ញុំស្ទាំរៀង បរិវារសោរស្រី អាងតបុត្រី ខ្ញុំពាងបុត្រា ។ ស្តែងស្តេចគន់តិត ឱអង្គអញ្ជតិត បុត្រ៌ច័តា ឱនតព្ធដតន្ស៍ រីក្រែងរង្គោ ហើតតក្សត្រា សមសូន្យបែកបង់ ។ តិតស្រេចចក្រី ត្រាស់ទឹនមហេសី ហៃប្អូនវរន្ស៍ យើងតបុត្រា បុត្រីមួយគង្គ ប្អូនអើយអម្ចង់ អំណើះយើងទៅ ។ សមស្រុកនឹងក្រសួ ខេះខឹនវិខាស ឧសាវេតសៅ អាសូរអស់ពស្តេ ចូរមាសមិត្រទៅ រៃលែងរៃញៅ តិតកាន់សិលា ។ ឲ្យបាន បរិសុទ្ធ ថ្លាថ្នាសូមបុ. ត្រីនូវបុត្រា មួយប្អូនប្រសើរ ច្រាប់ប្រើស្រីគ្នារ តាំងអស់ពល់គ្នា ឲ្យកាន់សីលធង ។ ក្រែងចួនបានបង់ បុត្រដូចបំណាន់ អំណាចប៉ុនប៉ង នាងក្រាបលុតលា ក្សត្រាបង្គាស់ឲ្យធ ច្រាបក្រាមស្នំផង ជូបព្រះឧត្តារ ។ ឲ្យស្រែកំណាន់ មួយហ្មឺនហុកតាន់ ឲ្យកាន់សីលា អស់ស្នំស្រុះស្រួល ខ្ញុលត្រប់គ្នា សឹងរៀបភ័ក្ត្រា ខ្ញុំរៀនធ្លុបផង ។ នោងបវរ ទ្រង់សុទ្ធសឹងស បញ្ជាសីលផ្តត់ផ្តង(៣) អដ្ឋង្គោសថ(៤) ស្រេតត់ម័ត់ហ្មង សង្រ្គមត្រប់ត្រង ជាន់ចិត្តប្រក្រតី ។ ចែកពាយជនជាន

---

១ ពាក្យប្ញវណប្រែថា ប៊ិន្ទិច ។ ២ ចតុរង្គ : មានអង្គ ៤ គឺកងរំពៃ ៤ កង ក្នុងសម័យបុរាណ : ពលថ្មើរដើរ,ពលដំរី, ពលសេះ, ពលរទេះ ។ ៣ បញ្ជាសីល គឺសីល៥ ។ ៤ អដ្ឋង្គោសថ : ឧបោសថមាន៨ប្រការសីល៨ ។

ផែដលឲ្យទាន សូមស្ទុំប្រុសស្រី ទទ្ធិសប្រាថ្នា បុត្រាបុត្រី ឲ្យបាន
ដូចក្តី បំណងប្រាថ្នា ។ ហេតុតែបារមី វរាជក្សត្រី រក្សាសីលា
សីលបរិសុទ្ធសល់ ក្តៅដល់អាស្នា សម្តេចឥន្ទ្រា ព្រះអង្គទ្រង់ឥត ។
ហេតុម្តេចអាស្នា អង្គអញអស្ចារ្យ កើតជានិម្មិត ដូចនូវប្រេះប្រាយ
ធ្ងុះធ្ងាយល្អោចល្អិត អ្នកណាតន់ឥត ប្រាថ្នាក័ស្តុរ្យ ។ ស្រេចព្រះ
អង្គឥន្ទ្រ បើកទិព្វចក្ខិន ទ្រើសទ្រង់បារមី ទតទៅសាយសព្ទ ភូមិ
ភពដែនដី យល់តែក្សត្រី រក្សាសីលា ។ សទ្ធាបរិសុទ្ធ ប្រាថ្នា
សូមបុត្រ អង្គឡរសា ព្រះឥន្ទព្រះអង្គ ស្តេចទ្រង់ចិន្តា សុះសព្ទស្ងតា
ទិព្វទេពទេវបុត្រ ។ យល់តែពង្សពោ- ធិសត្វទត្តមោ វិសេសវិសុទ្ធិ
ចួបចួនកំណត់ ប្រាកដពង្សពុទ្ធ អ្នកនឹងឃ្យត ចុះចាកស្ងតា ។ សោ-
មនស្សាសល់ ហិចហោះទៅដល់ មណ្ឌលប្រាង្គប្រា- សាទស្ងតិទិព្វ
តន់ ទេវិន្ទទូលថា បពិត្រព្រះមហា បុរសវ៉ត្នថ្ងៃ ។ ខ្ញុំសូមនិមន្ត
អ្នកទៅបដិស- ន្ធិនៅនាផ្ទៃ សម្តេចវិមលា ជាយាជេស្ឋជ័យ ឥសូរ
អង្គព្ធ ពាវាណសី ។ មួយអ្នកនឹងបាន បំពេញសីលទាន បន្ទំបារមី
វិសេសវិសុទ្ធ៏ ជាម្ពុជភពត្រី នឹងបានដូចក្តី បំណងប្រាថ្នា ។ ពង្សពុទ្ធង្ក្ខល
ព្រើសព្រមទទួល បើកបន្ទូលថា បើខ្ញុំក្រីក្រ កម្រម្តេចម្តា សូមស្តេចមេត្តា
ចរចុះជ្រងជួយ ។ ព្រះឥន្ទ្រស្តេចស្តាប់ ព្រះអង្គប្រាយប្រាប់ ថាកុំអ្នកព្ជួយ
ទោះបីអ្នកក្រ កម្រនីមួយ ខ្ញុំឯងនឹងជួយ ពិតពុំហ៊ានខាន ។ ព្រះឥន្ទ្រ
សញ្ញា ស្រេចស្រាប់លីលា វិលរឹងវិមាន ព្រះពោធិសត្ត បុរសវ៉ត្នថ្ពើង
ថ្ពាន ឃ្យុតចាកហាន ដែនតុសិតា ។ បដិសន្ធិក្នុង ទទរវរអង្គ សម្តេច

រមណា វិសេសវិសាល ត្រកាលដូចជា វដ្ដីរត្ន(១)ថ្លៃថ្លា ពិតពេញទទេរ ។

ថ្ងៃកាលសម្ដេច បរមសារៈឥដ្ឋ លើសលោកាសារ តន្ទុកតន្ត្រ ពុទ្ធ ច្បុតចាកចរ ចូលចាប់ទទេរ សម្ដេចរមណា ។ នាងនាដង្ខំស្ដាប់ ស្ដាប់កើតយង់យល់ សម្ដីសុចិនថា ហាក់មានទេវបុត្រ វិសុទ្ធសោភា សុភាពហត្ថា កាន់កែវវដ្ដីរ ។ សន្ធោសន្ធៅ ភ្ញីផ្ទៃកន្ធៅ ចាំងទេសទិសទី ជាក់ដល់ហត្ថា នាងនាថទៅ ទទួលយកពី ទេពៈទេវបុត្រជាន ។ មានទេវបុត្រម្នាក់ នេត្រនោះសោតខ្លាក់ ចាំងពីរហៅវហាន ចូលក្នុងនគរ បវរពេជដ្ឋាន បៀតបិណ្ឌាជាន ប្រជាជនផង ។ កែវវដ្ដីរត្ន លោនៃនាស ជាត់ នាងនារីរង ទុក្ខកោមនស្ស សោកាតន្ទង កន្ទង់សៅហ្មង ស្ដាយកែវវដ្ដីរ ។ ហាក់យូរបន្តិច យង់យល់បែរគេច មកមានវិញ្ញី សម្ងាប់ទេវបុត្រ លេត់ដីរី ពដរត្នវដ្ដីរ នោះនៅនឹងនាង ។ នាងពដ(២)រីលក្ខ ប្រែប្រាណត្រាក់ លង់លុះព្រឹកព្រាង សុរិយាអរុណោ-ទ័យរះស្រេចស្រាង ទើបតើនសំអាង អង្គអវតថ្លៃង ។ បរចូលជាក់ ដោម សិរីសោភ្ញាបក្រោម ព្រះបាទគម្ដែង ត្រកាលត្រកូល ក្រាប់ទូលចារចែង បរចាសំដែង សណ្ដាប់ស្ដាម ។ ដោយដំណើរនោះ សម្ដីសួរ សាយសុះ សាយសព្វសេចក្ដី ស្ដែងស្ដេចស្ដែងស្ដាប់ សារស័ព្ទមហេសី ទ្រង់ត្រេកអរតបី ថ្លៃងថ្លឹងទបមា ។ ត្រាស់ហៅហោរជាស់ ខែនទិព្វ មណ្ឌល ចាយចែងចរចា ច្រាយច្រាប់រៀបរាប់ ហោរក្រាបទូលថា បពិត្រស្ដ្រា ដោយទំនាយនោះ ។ ជាស្ដេចនឹងបាន បុត្រាកល្យាណ

---

១ វដ្ដីរៈរត្ន : ឈ្មួងពេជ្រ ។ ២ រីលក្ខ : ស្រីមានបុណ្យធំប្រសើរ ។

ប្រសើរឥតមោះ ប្រកបជាមេ លាភាលាភសព្វសុះ តែជាព្រះគ្រោះ
ព្រះពាជបុត្រមាន ។ រីឯបុត្រខ្លាត់ ជាទីងមានយក្ស ជួចារសោមាន្យ
ចូលបៀតបំណាំ ប្រជាសត្វច្រាណ ពាជបុត្រតស្បាណ ទីនច្រាស
ព្រះអង្គ ។ ទៅ(๑)ខ្លះវែនឡាយ ប្រើសច្រនំសិស្យសាយ រៃរឹងក្រៃក្រូន
ផ្តិលផ្តាច់ជន្មា យក្សាឆ្ងិចឆ្ងូង ដោយតេជប្រើសច្រនំ ជុណ្យជាមេមាន ។
ទីនស្បែតេជដល់ ខសទិសាសល់ ជម្ពូទ្វីបហាន បរិបូណ៌ជាតិបប ខ្ចប់ខ្ចាប
ព្រួញច្រាណ មែនមិនអាចហាន ពារតុះប៉ះបុណ្យ ។ ស្តេចស្តាប់រំនាយ
ហោរាខូលទាយ សោមនស្សាសុន ស្តែងស្តេចប្រជាប់ អស់ទ្រព្យ
ជានជន ប្រទានតបគុណ ហោរាច្រាជ្រាយ ។ លុះថ្ងៃពីរបើ រៃរត្នក្សត្រី
ជ្រាបក្នុងព្រះកាយ នាងច្រនំតកិបុត្រ រិសុទ្ធិ៍ពោមពាយ បរចូលថ្វាត់ថ្វាយ
បង្គំខូលក្សត្រ ។ ស្តែងស្តេចជ្រាបថា ពាជបុត្រស្នេហា ប្រសើរទប្បត្តិ
រើសរកស្រីស្នំ តួចធំចែងចាត់ ច្រាប់ប្រើប្រាស់ត្នូ ប្រយោជន៍រកូ ។
លង់លុះខែដប់ នាងទីងសម្ភព ប្រសូតបុត្រកូ ហេតុព្រះចាមេ ពោធិ-
សម្ភារ បណ្តាលអស្ចារ្យ តើតតួរស្ងែងស្ងប់ ។ អ័ព្ភអស់មេឃោ ជាល
ជាបបង្អែរ ភ្លៀងស្រិតលើសឃប់ រន្ទះពោនពី ខសទិសាសព្វ ផ្គរបន្ទោរ
ខប់ ច្រកត់វេហាស៍ ។ ខ្សល់ព្យុះពោរមហាក់ ចោកបក់បែកចាក់ ឈើ
ព្រៃព្រឹក្សា លង់លុះត្រឹកត្រាង ស្រេចស្រាន់រមេយ សែងសុរិយោយ-
ត្រាត្រាច់ចេរចរ ។ អស្ចារ្យទាំងឡាយ រៃនាសអន្តរាយ ពេលពេលាស្អ
ព្វជតន្ត្រីតុគ្គា ថ្ងៃថ្ងាបវែរ ចេញចាកទ្វារ រៃរាជមាគា ។ ក្រោងព្រះស្នំ

---

๑ ទ្វារ : ប្រែថា ឆ្ងាយ តំឃ្លាតច្រាត់ទៅទីឆ្ងាយ ។

មែនមានសួស្តី ត្រចះសោតា ដូចមាសនពគុណ ខំភ្ញតន់ថ្ងៃថ្លា ខំភ្ញខេត
លេខា រូបវេទនាធ្លើ ។ ព្រះជាទ្រហ្មទត្ត ធំពាជមហាក្សត្រ យល់បុត្រ
ប្រសើរ លើសលោកាកវ ទ្រង់អវតរបើ ស្តេចប្រាយប្រាប់ប្រើ មន្ត្រី
ភ្លូចធំ ។ ឲ្យចេញទៅជ្រើស រួតរត់រកើស មេនាងមេទំ សឹងតូចព្រះ
វង្ស ។តុង្គ្គតុគ្គម រូបពងស័ក្តិសម ឲ្យបំបៅបុត្រ ។ ហើយក្សត្រធំពាជ
ឲ្យហៅព្រាហ្មណ៍ទ្រាជ្ញ ចេះទាយនាប់ឆុត ព្រាហ្មណ៍មកដល់ហើយ
ទូនអង្គលំទុត ក្សត្រថ្លៃបង្គំ បើកបន្ទូលថា ។ ចូរព្រាហ្មណ៍
ប្រាជ្ញប្រាយ មកមើលខៀងទាយ នៃនរសុណា ឬក្សត្រជបុត្រស្តេច
តើក្សូនតម្រា តម្រិះព្រាហ្មណ៍ទ្រា-កជកើតម្តេចទៅ ។ ព្រាហ្មណ៍
ប្រាជ្ញសិល្បសត្ថ គន់គួរគ្រាន់គ្រប់ អស់ឥតហ្មងសៅ ទើបទូលបពិត្រ
មហាក្សត្រចមចៅ ពាជបុត្រនេះហើ គ្រប់ល័ក្ខណ៍ប្រសើរ ។ ទាំង
សាមសិបពីរ ពិតតេញធរណី ទំរង់អ្នកណាស្មើ រៃសសរសុទ្ធ ជាម្តុជ
លើសលើ លោកជនជំណើរ ទំនាយដូច្នេះ ។ ព្រះមហាក្សត្រ
ត្រេកទ្រង់ត្រាស់ថា ចូរចៅព្រាហ្មណ៍នេះ ព្រាហ្មណ៍ស្រែកនាម តាំង
តាមចំណេះ ចំណាំចំបេះ ដូចម្តេចទើបសម ។ ព្រាហ្មណ៍ទ្រាជ្ញ
ហោព ស្តាប់មហាក្សត្រា ទូនអង្គបង្គំ ទូលថាបពិត្រ មហាក្សត្រ
ទុតម ទុរសាសម ទ្រង់នាមទេវន្ទ ។ តាមហេតុសម្ភព សំការស្មែង
ស្ទាប់ អស្ចារ្យតេកតន់ ស្តេចស្តាប់ទ្រាជ្ញព្រាហ្មណ៍ តាំងនាមបុត្រតន់
ទ្រង់ត្រេកតេកតន់ ពិតតេញព្រះទ័យ ។ ប្រធានព្យាករ ទ្រព្យធន
សឹងស្អុ ដល់ព្រាហ្មណ៍ច្រើនកៃក្រ ស្តេចធ្វើមង្គលា ជយោជោគជ័យ

តាំងនាមបុត្រថ្លៃ ចំរើនពាក ។ ហៅព្រះខេមាខ្ញុ សុភាពសោភ័ន ប្រសើរថ្លៃថ្លា រើសក្មេងស្រីប្រុស ស្រឡៃស្រស់សោភា សឹងកូនសេនា ប្រមាននាជាប្រុត្រ ។

លុះពុទ្ធន្តរ(១) ខែនរបះជើរដួល នាងនាងវិសុទ្ធ ទ្រង់គភ៌គ្រាន់ គ្រប់ ខែដប់ចំហុត ប្រែប្រមូតបុ ត្រទ្រង់រូបា ។ នោមនាយសោ-ភ័ន កូនក្មែបដូចចំនួន ប្រកបកាយា ដូចមាសស្អាងស្អាត ហើយ រចនាការ ធរីជ្រះថ្លា រិសេសវិសុទ្ធ ។ ប៉ុព្វេសាកោ- ងាគមនៅ នាគាលព្រះពុទ្ធ នាមកោនាគម បរមរ៉ៅ-ឡ្លីជាចំហុត បរចូលនិព្វាន ។ ព្រោះស្រាណាសត្វ និត្យនៅកព្រះដ្ឋ សង្ឃរសេពូជ្រាណ កាលព្រះ បេរបរ ទ្រង់ប្រតិស្ថាន សាស្នាខ្ញុន្នាន ដូចកាលប្រក្រតី ។ កាល ណោះធីតា នោះនាងកើតជា កូនមហាសេដ្ឋី រក្សាសីលំ បញ្ចអដ្ឋមី(៣) វិសុទ្ធប្រក្រតី ប្រកបសទ្ធា ។ ហើយកូនសេដ្ឋី សាងព្រះចេតីយ៍ តូចមួយរចនា នៃនឹងទ្វីមច័ន្ទច័ន្ទ សោភន៍ថ្លៃថ្លា ឃកមាសធ្វើជា ពុទ្ធរូបមួយអង្គ ។ ជាក់កងចេតីយ៍ ហើយកូនសេដ្ឋី និមន្តភិក្ខុសង្ឃ រួសរៀបរណ្តាប់ សម្រាប់ផ្ទះអង្គរំ ពិត្តចាប់ត្រេកត្រអំ ប្លូជាបុណ្យធ្ងន ។ ហេតុសាងព្រះពុទ្ធ ធរីសោតសុទ្ធ មាសមែតហ្មត ព្រះកាយពីរោះ តន្តរស្អប់ស្អង ព្រោះដោយផលផង ឋានសាងចេតីយ៍ ។

(នៅមានត)

---

១ ពុទ្ធន្តរ: បណ្តាលនៃព្រះពុទ្ធ គឺថាពួងពន្សរបស់ព្រះពុទ្ធជាអ្វស ។ ២ បរមរ៉ៅឡ្លី: ទ្រង់ចំរើនយ៉ាងប្រសើរក្រៃលែង ។ ៣ បញ្ចអដ្ឋមី: សំដៅយកសីល ៥ និងសីល ៨ ។

សុកាសិតប្រដៅជនប្រុសស្រី

ព្រះឃោសធម្ម ម៉ឹង សែស

ចៅអធិការវត្តមហាមន្ត្រី សង្កាត់លេ ១ ៨ ក្រុង

រៀបរៀង

(តមក)

ត្រានោះទេវបុត្រមាតលី ចានស្តាប់ព្រះកោសីយស្តេចទ្រង់ថ្វៃន
កើតក្តីសោមនស្សយល់ច្បាស់ទ្រង ទ្រីបក្រាបទូលសំដែងដូចតទៅ ។
ព្រះអង្គសំពះបុត្តលណា អ្នកប្រសើរថ្ងៃថ្ងាតតហ្នងសៅ
ទ្ចុំព្រះអង្គយល់ស្របតាមព្រះចៅ សូមសំពះសំដៅអ្នកនោះដែរ ។
ការសង្ត្រោះកូនកំដាមង្គល រឿងនេះនឹងពន្យល់ជាពាក្យទ្ចរ
ស្រង់ពីពាក្យចាលីលៃបំបែរ ពប់រៀបល្មមឲ្យតែចានសេចក្តី ។
កិច្ចនោះសឹងមានថមិនលើសទ្ចះ មានមកប្រាកដច្បាស់ក្នុងចាលី
ការសង្ត្រោះដល់កូនកើតសិរី តាមពាក្យព្រះជិនស្រីទ្រង់ត្រាស់ថា ។
បាបានិ និវារេន្តិ បុត្តេ ម្តាយអាពុកជាចាមេយាត់ទាំងទា
មិនឲ្យកូនធ្វើចាបពៀរវេត អំពើជនពាលាជួហ្នងសៅ ។
កល្យាណេ និវេសេន្តិ ភ ញ្ញាំងកូននៃអាត្មាឲ្យបិតនៅ
ក្នុងធមិជាកុសលល្អធ្មិនធ្មៅ មិនឲ្យកាចយោរយៅជួកប្រីយ ។
សិប្បំ សិក្ខាបេន្តិ តថា ឲ្យកូនទំសិក្សារៀនអ្ចី ។
អស់វិជ្ជាសិល្បសាស្ត្រលើផនដី ឲ្យចេះដឹងតប្បីទ្ចីពឹងទ្ចួន ។
ទារេន សំយោជេន្តិ រៃ អាពុកម្តាយចាមេចិត្តឆ្ជាប់ទ្ចួន
រៀបចំកូនប្រុសស្រីដោយមាំមួន ប្រពន្ធប្តីសមសួនដោយគួរសម ។

ល្មមដោយត្រកូលវង្សគោតទ្រព្យ មារយាទល្អតួរតាប់រូបទត្តម
បានរុងរឿងចុះបែបអ្នកតូចធំ បានថ្ពំថ្ពើងប្រទ្ឋំនឹងអ្នកស្រុក ។

ទាយជ្ជំ ធិយ្យាទេត្តិ ភ មាតានឹងបិតាបៀបជាក់ទុក
ចែកបាយទ្រព្យសម្បត្តិប្រើនត្រប់មុខ ឲ្យកូនបានក្តីសុខតួរតាមកាល ។
យ៉ាងនេះលោកហោះថាសង្ត្រោះកូន ជាផ្ទូវច្បាប់មិនសាបសូន្យផ្ទូវកណ្តាល
ត្រូវតាមធម៌ព្រះពុទ្ធល្អវិសាល ជាច្បាប់លោកបាលមង្គលតាប់ ។

ប៉ើអ្នកស្រុកចង់រកស៊ុជំនួញ ចង់ធ្វើជាអ្នកជ្ជញ៉ាស្វែងរកទ្រព្យ
តួរខំរៀនចំណេះរកចំណាប់ កុំឲ្យជួអតីព្ទបង់ខាតទុន ។
ផ្ទូវជំនួញជាផ្ទូវធំក្នុងលោក គេធ្វើប្រើនតរតោកគេដើរមុន
យើងក៏បានយើញសព្ទត្រប់បែបធុន គេចំរើនទ្ធតុណាកប់មិនអស់ ។
សិប្បៈបូសតល់ទៃជំនួញ ចំរើនមិនករួញដើរឥតខ្ជោះ
សិប្បៈតែងហុចឲ្យឥតចន្ទោះ ឥតមានរើសចំពោះថាមុខណា ។
តសំពោកបាំល់នឹងរថយន្ត យន្តហោះជាទម្ទន់មហ៊ាមា
សិប្បៈធំជុំលើពសុធា អ្នកប្រទេសនានានិយមប្រើ ។ ល ។
រហូតដល់ពែងបាំន់ចានកន្ទោ ប្រណាកអកកំបោរឆ្នាំងកញ្ជើ
សុទ្ធតែសម្រេចមកពីការធ្វើ សិល្បៈជាវិជ្ជាលើតពីផែនដី ។
ចេញមកជាជំនួញសព្ទនិតម ស្រុកតូចស្រុកធំលោកសិរី
តួររៀនទ្ធូវសិល្បៈឲ្យមានល្បី ប្រកបការរកធីលៀងជីវិត ។

សិល្បៈប្រែថា ការឈ្ទាសរាងវៃ ប៉ុនប្រសប់ដោយដៃជាការពិត
ថាតប្បីសិក្សាដោយពិនិត្យ តួរអ្នកផងរិះតិតរៀនត្រប់ត្នា ។

បើសម្រេចចេះស្ងួតប្រាកដហើយ ឲ្យដល់តុំលែងឡើយដូចប្រាថ្នា
កើតមានទ្រព្យសម្បត្តិខ្ពើងថ្ងៃថ្ងា មានមិត្រភ័ក្តិស្ងួនភ្ងាកើតសុខសាន្ត ។
ដំណាំដែលគេដាំត្រូវប្រការ សុទ្ធតែមានទឹមសារលក់ដូរបាន
បេញ្ញាដាជំនួញកើតធនធាន ឲ្យកើតជាអ្នកមានទ្រព្យសម្បត្តិ ។
ទុជាសកក្នុងព្រះពុទ្ធសាសនា កាន់យកសីលសិក្ខាមានពាក្យសត្យ
ត្រូវរៀងជំនួញដោយទៀងទាត់ ជាផ្លូវលះរៀងកាត់ជំនួញខុស ។
សត្តវណិជ្ជា ជំនួញសត្វ យកសេចក្តីតាមអត្ថតែមនុស្ស
ចាប់លក់ប្តូរដូញលក់ស្រីប្តីប្រុស យកចំណេញស៊ីជុះឥតមេត្តា ។
មំសវណិជ្ជា ជំនួញសត្វ ដែលគេត្រូវបំបាត់ជីវិតវា
យកសាច់លក់ដូរប្តូរជាកក្ខ មានត្រីធំធ្ងន់ជ្រុកគាជាដើមអាទិ៍ ។
សត្ថវណិជ្ជា ជំនួញតាល អាវុធគ្រឿងប្រហារទំងំតិយោជ
សព្វសត្វមានជីវិតឲ្យបាត់ឃ្លាត គឺស្ងាប់បង់សុទ្ធសាធឬថាខុសគ្នា ។
វិសវណិជ្ជា ជំនួញពុល ថ្នាំបំពុលមនុស្សសត្វគ្រប់មុខ
ឲ្យបង់ខាតជីវិតប្តូរគ្នានសុខ លក់ដូរឲ្យអ្នកស្រុកតាមប្រាថ្នា ។
មជ្ជវណិជ្ជា ជំនួញទឹក ស្រាទំងដល់អ្នកផឹកគឺសុភ
មេរ៉ៃនាំចរត្រដល់អាត្មា ព្រមទាំងជននានាច្រើនអនេក ។
ជំនួញទាំងប្រាំនេះឬលកជាពៀរ ទុជាសកត្រូវរៀចគ្នាកុំត្រេក
ព្រោះជាផ្លូវឃ្លាងឆ្ងាយឥតធម៌គេក គួរគេគួរលែកដើរផ្លូវត្រូវ ។
ប្រទេសគេធំៗជំនួញធំ ច្រើនអ្នកមានសុភសុគ្គតិឥតឡើយ

វិជ្ជានឹងជំនួញនាំបើកផ្លូវ ដើរបានគ្រប់រដូវឥតខើសទាល់ ។
អ្នកទាំងឡាយចូរគិតឲ្យយល់ជាក់ កុំឲ្យមានជំពាក់មិនដឹងស្គាល់
មានឧបស័ត្តអ្វីមកប៉ះពាល់ បានជាខ្ទះវិជ្ជាវៀងរាល់គ្រប់ៗគ្នា ។
ខ្ទះយើងខ្ទះវិជ្ជាវិក្រឹលងខ្ទះ ខ្ទះប្រើនវិក្រពេកណាស់ឥតគណនា
មកពីយើងបាក់ឃកស្រាំប្រេះធា បានជាគ្មានវិជ្ជាជូចស្រុកគេ ។
ទទួលបានជួបជួនអ្នកបាវាំង គេមកនៅតែងតាំងធ្វើជាមេ
គេឲ្យវៀនសូត្រដែរមិនទទេ គ្រាន់តែធ្វើស្មៀនស្មេរគេប៉ុណ្ណោះ ។
គេឲ្យវៀនធ្វើពេទ្យថែជម្ងឺ រក្សាមនុស្សឈឺគេឲ្យឈ្មោះ
ជាគ្រូពេទ្យគ្រាន់តែចិញ្ចឹមពោះ គ្មានចេះផ្សំថ្នាំសោះតើចេះអ្វី ។
គ្រាន់តែចេះមើលដឹងសំបុត្រថ្នាំ វិធីប្រើឲ្យចាំដោយស្មារតី
ចេះវះកាត់លាបថ្នាំរុំសំឡី ចាក់ថ្នាំបុទិញថ្នាំអីក៏ទិញបាន ។
ចេះសរសេរសំបុត្រផ្ញើទៅទិញ យកសព្វមុខទំនិញដែលគេមាន
នៅឯស្រុកបាវាំងទាំងប៉ុន្មាន នាំចំរើនធនធានស្រុកបាវាំង ។
ឯងចេះតែរៀនទិញមិនរៀនធ្វើ ហាក់ជូចឥតអំពើគ្មានកម្ចាំង
ជួយស្រុករបស់ខ្លួនឲ្យម៉ាំងទាំង ស្រុកនៅតែស្គមស្គាំងគ្មានធំធាត់ ។
បើរៀនបានចេះដឹងគួរគប្បី គេឲ្យធ្វើមន្ត្រីមានមុខមាត់
មានកេរ្តឹ៍ឈ្មោះគ្រាន់បើទាំងសម្បត្តិ មិនសូវមានខ្ចាយខ្ចាត់ដល់កូនចៅ ។
ម្ចោ៉ះហើយគេមើលឃើញជាស្ពុកស្ពម្ព គេនាំគ្នាប្រឹងទំបោលសំដៅ
ទៅចូលសាលារៀនយកទាន់ទៅ ប្រើនជ្រើមជ្ជួលខ្ទួលទ្មៅពេញដែនដី ។

កំឆ័ដួនក្រហោមដៀបចក្រ៉ប៉ុន[1] ឧឆ័ណលោកយោមពាជឈុនធ្វើកុនលី
ចេះបាកំឆ័មុខគេ មុនធ្លើថី បកប្រែភាសាស្តីបាកំឆ័ខ្មែរ ។
បានថ្កុំថ្កើងរុងរឿងមាំឆ័ក្លួនចៅ អស់តាំងពួកពន្យល់គ្រាន់ចេះដែរ
នាំឲ្យដួនកាំឆ័ឡាយងាកវេរបែរ រៀនបាកំឆ័បាវែរស្ទើរមិនសល់ ។
ព្រោះឃើញនរណាមិនចេះបាកំឆ័ មិនសម្បូរទុំបាំឆ័ឧឆ័ណឆ្លួចផ្តល់
ឧឆ័ណថាយពាយស៊ីពុកឲ្យឆ្អែតឆ្អល់ អ្មោ៎ះខំប្រឹងខ្វាយខ្វល់ឲ្យបានន់គេ ។
នរណាចេះតែខ្មែរថៅកថយ ណាស់ ដូចឈើពុកស្រឡះសោះខ្លេ
ពុំនោះសោតប្រៀបដូចជាសត្វកេ ឃ្លាតឆ្ងាយបីឆ័ខ្នេគ្នានត្រីស៊ី ។
អ្នកមានតែចៅរៀនស្រុកបាកំឆ័ គេសម្ងឆ័ឧឆ័ណឃ្លាំឆ័ខ្មែរមេ
គេនឹកថាអញមុខជាពេញចិ អស់តាំងពួកស្រីញាតិអញមិនខ្វះ ។
មិនគិតថាប្រាក់ឃ្លាំឆ័មកពីណា បានពីទៅគាថ្នពីព្រះ
ឬបានពីព្រះឥន្ទមានតេជះ បង្ហាវឲ្យគ្រប់ដួងយកមកជាក់ ។
ប្រាក់ឃ្លាំឆ័បានពីអ្នកចំការស្រែ បានពីអ្នកជួញប្រែរកលុយកាក់
ពីអ្នកលក់កម្លាំឆ័ញើសសស្រាក់ គេប្រមូលយកប្រាក់ទៅខុកចាយ ។
សម្រាប់ជួលមនុស្សឲ្យរក្សា ថៃតាំអស់គ្នាឲ្យសប្បាយ
កុំឲ្យចោរលួចប្លន់អន្តរាយ ឲ្យបានក្តីកេរយកតាំឆ័អស់គ្នា ។
ប្រាក់អ្នកស្រុកតាំឆ័អស់មានន័យស្មោ អ្នកនៅចាំសរសេរចាំកត់ត្រា
ឲ្យដឹឆ័តាមចំនួនថៃរក្សា បើត្រូវជួលអ្នកណាឲ្យអ្នកនោះ ។
កន្ទែឆ័ខុកប្រាក់ហ្នឹឆ័គេហៅឃ្លាំឆ័ គេរើសដនសំកំឆ័មានក្តីឈ្មោះ

---

១ សម្តេចចៅហ្វាកំឆ័ងដួន, លោកក្រឡាហោមព្រះតាមធឿប, សម្តេចចក្រីព្រះតាមប៉ុន ។

ជាមនុស្សអ្នកល្អចិត្តត្រង់ស្មោះ គេជាក់ឲ្យចំពោះថែរក្សា ។
ប្រៀបដូចភូមិធំមួយជនកុះករ មនុស្សច្រើនតែល្អមានប្រាជ្ញា
តែមានចោរល្ងចប្ងន់ច្រើនក្រៃណា ហ៊ានហោចទ្រព្យត្រប់ត្នាត្រាំពុំបាន ។
បប្ងលត្នាវៃប្រាក់យកត្រប់ផ្ទះ យកទាំងក្មេងទាំងចាស់ទាំងក្រមាន
ប្រមូលទុកឲ្យមូលផ្ទុំធនធាន ទុកផ្ទលអ្នកក្ងាហានឲ្យយាមល្សាត ។
ថែទាំផ្ទះសម្បែងសព្វទ្រព្យធន កុំឲ្យចោរល្ងចប្ងន់បង់ខូចខាត
រាល់យប់ថ្ងៃទ្នាំមិនយ្ងៀងយ្ងាត ឲ្យថ្ងៃឈ្នួលតាមខ្នាតខសន្យា ។
យូរ ៗ ទៅប្រាក់ហ៊ុនចេះតែកើន ចេះតែឡើងចំរើនរាល់មាសា
អ្នកស្រុកមានក្តីសុខដូចប្រាជ្ញា ចំរើនទ្រព្យធនត្រប់ត្នាឥតមោះមៃ ។
ក្រុមហ៊ុនទាំងអស់នោះប្រឹក្សាគ្នា គិតពង្រីកបញ្ហារកកម្រៃ
ចង់សាងផ្ទះពេទ្យមួយទុកសំបៃ ក្រែងមានទុក្ខរោគកំយត្រូវត្រប់ត្នា ។
ចង់ឲ្យកូនចៅខ្ជនបានចេះដឹង គិតខ្នះខ្នែងខំប្រឹងសាងសាលា
ឲ្យកូនចៅរៀនសូត្រកើតបញ្ញា ស្វះស្វែងរកវិជ្ជាឲ្យបួនមាំ ។
ក្រោយនោះមេធាវីមានប្រាជ្ញា ជាជនចាស់ព្រឹទ្ធាយឺនយូរធ្នាំ
ផ្ទើយដោះស្រាយបញ្ហាតាមចំណាំ ឲ្យជនផងចង់ចាំដូចតទៅ : ។
ផ្ទះពេទ្យសាលារៀនអ្វីក៏ដោយ ជាបញ្ហាខាងក្រោយទេណាចៅ
បញ្ហាធំសំខាន់ចោរគ្នុងក្រៅ សព្វថ្ងៃនេះយើងនៅទន់ខ្សោយទេ ។
យើងដោះស្រាយចោរកម្ម ឲ្យរួចមុនមួនមាំសុខដូចគេ
ឲ្យបានទុកចិត្តសិនសិមរិះរ រកបញ្ហាដោះកែតទៅមុខ ។
ចោរគេចេះសាងកើតបានច្រើនយ៉ាង កើតមានទាំងខ្នោះយ្នាងច្រវាក់តុក

គាំក្តៅធ្ងន់ជាវិលវែងគាំបិតសុក សោកាទោំងនេះកុងធំនរបង់ ។
ពួកចោរតែងបំផ្លាញទ្រព្យអ្នកស្រុក នាំឲ្យកើតអុកឡុកជិះជាន់ផង
គាប់សម្លាប់អ្នកស្រុកដោយបំណង នាំឲ្យកើតសៅហ្មងឥតស្រាកស្រាន្ត ។
អ្នកស្រុកច្រើនក្រីក្រព្រោះតែចោរ ក៏តែងនាំគ្នាគោរហួសប្រមាណ
ក៏បំផ្ទិចបំផ្លាញអស់ធនធាន គេក្រៃបីសេះយានគ្មានឲ្យសល់ ។
បើយើងបំបាត់ចោរបានកាលណា សិមយើងដឹកនាំគ្នាតាមយោបល់
បង់សាងអ្វីក៏បានតាមយើងយល់ ឥតមានការអំពល់ដោយកិតភ័យ ។
កូមិមួយប្រៀបដូចគ្នានឹងរដ្ឋមួយ តែងតែមានទុក្ខព្រួយខ្លាំងពេកក្រៃ
បានជានាំគ្នាគិតអង្គាសរៃ យកប្រាក់ទុកសំច័យឲ្យឈ្នួលល្បាត ។
ប្រាក់ឃ្លាំងពិតជាប្រាក់ពស្ត្រអ្នកស្រុក គេប្រមូលមកទុកជាដើមគាំទ
សម្រាប់ការពារពស្ត្រដោយសុទ្ធសាធ មិនត្រូវដណ្តើមយកប្រាក់ឃ្លាំង
ឡើយ ។
ប្រាក់ឃ្លាំងត្រូវធ្វើការប្រយោជន៍ពស្ត្រ មិនត្រូវចាយផ្តេសផ្តាសសោះអង្គើយ
គ្មានទឹកនាម្ចាស់ប្រាក់ធ្វើកន្តើយ ធ្វើដូចជាព្រងើយមិនដឹងអ្វី ។
មានព្រះឥន្ទ្រឯណាចង្អុលប្រាប់ ឲ្យខ្លួនចាយស្រាប់មិនរកស៊ី
ទោះគេខឿយលំបាកហត់វៃវី តាមច្បាប់ប្រពៃណីពស្ត្រទាំងឡាយ ។
មានខ្លះហ៊ានរំលោភប្រើអាជ្ញា ប្រៀបដូចសត្វខ្លានឹងខន្ធាយ
ខ្លាមួយមានចង្កឹមក្រចកកាយ ទោះមួយសែនខន្ធាយក៏ចាញ់ខ្លា ។
ចំការស្រែសត្រូវនឹងគេពិត ឃ្លាំងប្រាក់ទើបជាមិត្រគេពល់គ្នា
ជានជាគេទំប្រឹងរកផ្លែ ជានជាមិត្រសួនភ្លាំងឃ្លាំងប្រាក់ ។

ប្រាក់នេះពិតជាប្រាក់ស្តៅក្រហាយ បើអ្នកបានមកបាយតែឲ្យជាក់
បានមកពីឈាមញើសហូរសស្រាក់ គេខាយកមកជាក់ទុកក្នុងឃ្លាំង ។
យើងខាន់តាំងពីព្រះនេរកត្តម ខ្ញុំសោយភក្ស្យជាធំបុណ្យបូកាំង
គេរៀបចំស្រុកខ្មែរមានកម្លាំង រៀបផ្លូវថ្នល់គ្រប់តាំងពីសម្រាំម ។
តាតមួយខាងប្រាំរៀលហុកសិបសេន មានតាំងត្រូវកំណែនកែនដីតដី
មានពន្ធស្រូវពន្ធគ្នាតម្រេចដីផ្ទី នៅពន្ធគោក្របីពុំខាន់មាន ។
ខាងតែខ្មែដំបូងជល់ជាប់ធ្នាំ អ្នកក្រីក្រឯកម្មច្រើនអត់ហ្មាន
គេខាងអស់មួយឆ្នាំរកមិនបាន លំបាកស្ទើរផុតប្រាណតែពាល់ធ្នាំ ។
ខ្លះមានគោក្លូចតាចលក់ឲ្យគេ នៅសល់តែគោមេពុកថែតាំ
ខ្លះ យកកូមិប្តូរស្រែជាក់បញ្ចាំ យកបង់ពន្ធតាមកម្មខ្លួនក្រក្រ ។
បើប្រាក់ឃ្លាំងមុនខាងយល់ថាធ្ងាញ់ អ្នកជនច្រើនស្រឡាញ់យល់ថាល្អ
មិនដឹងជាថ្នាំពុលស្អាប់ធ្ងន់ស នាំនានាសតាមិនចេះចប់ ។
ដូចគ្នានឹងអ្នកបួសក្នុងសាសនា បើមិនតាន់សិក្ខាឲ្យសព្វគ្រប់
ប្រព្រឹត្តអនាចារគ្មានឈប់ឈរ ខុសពាល់ថ្លៃពាល់យប់មិនធ្វើល្អ ។
ត្រង់ឃុំព្រៃចាំរនៃអ្នកស្រុក បរិភោគគ្រប់មុខបាយសម្ល
ជារបស់អ្នកមានធនឯអ្នកក្រ ច្រើនតែនាំបង្កប្រមូលលាភ ។
ឥតគិតពិចារណាជុំវិញខ្លួន អាស្រ័យបច្ច័យបួនគេជាប
ប្រព្រឹត្តអនាចារដូចោកខាប មុខជានឹងបានជាបទៅអបាយ ។
ដូចអ្នកពាសាស្ទើរប្រាក់ឃ្លាំង គ្មានស្មារតីប្រុងតាំងគិតវែងឆ្ងាយ
ឯងចេះតែរកចុះអើញអ្នកបាយ ព្រះឥសូរលោកបាយខុកឲ្យអញ ។

ព្រោះអញជាអ្នកមានបុណ្យស័ក្តិយស ជាពូជអ្នកថ្កើងឮសំជាងសាមញ្ញ
តាមតែយកប៉ុន្មានតាមស្រឡាញ់ កេរ្តិ៍តតគ្នាន់គ្នេរគាញ់ថាប្រាក់ពស្ត្រ ។
មានប្រាក់ខែចាំងកូនចាំងប្រពន្ធ ធ្ងន់នេះហៅសែនធ្ងន់គ្មានទុកាស
គាន់ស្លៀកបាកំដរផ្លើផ្តេសផ្តាស គេយកខ្មែរធ្វើទាសចាំងដែនដី ។
មិនមែនបាកំដរជាខេវគា អស់ខ្មែរធនានាជាក្របី
ជាតិមនុស្សដូចគ្នាចាំងប្រុសស្រី អ្នកប្រុសគួរគេប្តីតឲ្យឡាយ ។
អ្នកនៅឡាយពីខ្ញុំប្រជុំជន សុទ្ធតែបានបង់ពន្ធគ្រប់រូបកាយ
មិនបានលាំមួយគ្រាប់ដប់ឆ្នាំថ្លាយ អ្នកជិតគេសប្បាយដោយថ្នាំពេទ្យ ។
មនុស្សយើងឥឡូវវៀរធ្វើធ្ងន់ចាំង នាំគ្នាប្រឹងប្រណាំងគ្រប់ស្រុកខែត្រ
មិនបង់ខ្ទើយហត់សោះហើយបានឆ្អែត លើកខ្លួនឲ្យអណ្តែតដោយប្រាក់
ខែ ។

យកប្រាក់ចាំងតាន់ហ្មឺនមកសូកទិញ ហាក់ដូចជាចំនិញអ្នកជួញប្រៃ
នាំឲ្យក្រីក្រឡត់ឥតមែន ជួនខ្លួចប្រាក់ខែអត់បានការ ។
សំណួកមានគ្រប់ប្រកគ្រប់ដំបន់ ជាចោរលួចចោរប្លន់យកមុខងារ
លួចប្លន់យកបុណ្យស័ក្តិនឹកតែការ លួចដណ្តើមតាមតែយកទីខ្ពស់ ។
បើបំបាត់សំណួកមិនបាត់ទេ មិនខុនរឿងដូចគេបង់កេរ្តិ៍ឈ្មោះ
ចោកភាឋសាបសូន្យគ្មានកិត្តិយស សត្វសូរមិនព្រមអង្គុយ ។
ខែរយើងនៅតាល់ប្រក.ក្រីនកន្ទុង ខ្លះចំណេះចាត់ចែងធ្វើដោយដៃ
ទាងជំនួញក៏នៅមិនឈ្លាសវៃ បានជារកដម្លៃទឹងគេគ្មាន ។
នាំគ្នាចូលរៀនតែអក្សរសោស្ត្រ ដើម្បីកេប្រាក់មាសទ្រព្យធនធាន

សំឡឹងតែឃ្លាំងប្រាក់ធ្វើស្ពាន ពាំងប្រុសស្រីរាប់លានគ្មានប្រកផ្ទូវ ។
អក្សរនោះទៀតរៀនអក្សរគេ អក្សរឯងនៅទទេដូចសត្រូវ
បើមើលប្ដសរសេរមុខក្រញូវ ព្រោះតែខ្ជូនមិនសូវបានហាត់រៀន ។
រៀនបាវាំងប្រហែលម្ពៃឆ្នាំ ទើបបានចេះបានចាំបានធ្វើស្មៀន
ប្ដធ្វើគ្រូប្រដៅបង្ហាត់ប្រៀន ប្ដមន្ត្រីកោះគៀនពារប្រាក់ពន្ធ ។
យើងពាល់ប្រកផ្ទូវមកយូរណាស់ហើយ ជាតិវ្ទ្ធរពាំងឡាយអើយចូរគិតគន់
រៀនវិជ្ជាគ្រប់មុខកុំទម្រន់ ព្រោះយើងនៅខ្សោយទន់ពន់ពេកណាស់ ។
រៀនធ្វើស្ទាបប៉ាកកាគ្រឿងសរសេរ ធ្វើម្ជុលសម្រាប់ដេរនឹងម្ជុលខ្ទាស់
ពាំងរៀនធ្វើសព្ទគ្រប់គ្រឿងប្រើប្រាស់ កុំឲ្យមាននៅខ្ទះគ្មានមុខណា ។
វិជ្ជាអស់នោះនាំឲ្យថ្ពំថ្ពើង នាំឲ្យចំរើនឡើងមហិមា
ដូចដាំអស់ដំណាំកើតវផ្ទផ្ការ ចំរើនស្រុកថ្ងៃថ្ងាមិនខ្ទះខាត ។
ពិភពលោកសព្ទថ្ងៃគេបង្ហើន វិជ្ជាឲ្យចំរើនខ្ទាំងហ្ជសខ្មាត
បើយើងមិនខំទេឃើញថាឃ្ងាត ជ្ងាក់ចុះដុនដាបជាតិគ្មានរស្មី ។
ជាតិវ្ទ្ធរច្រើនស្រឡាញ់តែយសស័ក្តិ ចូលចិត្តតែហ៊ុកហ៊ាកធ្វើមន្ត្រី
ចង់ឲ្យមានអំណាចលើផែនដី ជនផងពាំងប្រុសស្រីទនលុតគ្រាប ។
ខ្ទះបានយសស័ក្តិហើយប្រពន្ធច្រើន ចេះតែចង់បង្ហើនប្រាក់ដរាប
គ្មានមេត្តាដល់ពស្ត្រអ្នកទន់ពាប អ្នកក្រីក្រដុនដាបរងទុក្ខត័យ ។
ប្រពន្ធច្រើនជាហេតុវិនាសធំ ឲ្យខូចស្រុកនិគមនាំចវ្រៃ
បាត់ផ្ទូវសុចរិតខូចដម្ងៃ វង្វេងពាល់យប់ថ្ងៃកន្ត័ប្រឡំ ។

(មានត)

លោកសុិន - ហ៊ាន ប្រែរៀបរៀង
លោកយូរ - អ៊ុន ពិនិត្យកែសម្រួល

(តមក)

-១១-

វស្សានរដូវចូលមកជិតណាស់ហើយ ។ ពួកកសិករអ្នកភ្ជួរកស់រន់ចាំ
ទឹកភ្លៀងប្រុងប្រៀបទ្ចូនទឹងភ្ជួរកស់ នូវដីស្រែចម្ការដើម្បីសាបព្រោះពូជ ។
ឡល់ភ្លៀងបក់មកបន្តិច ។ ជាការដាស់តឿនចិត្តពួកកសិករឲ្យដឹងថា
វស្សានរដូវជារដូវមានទឹកភ្លៀងធ្លាក់ចុះ នឹងមកក្នុងពេលឆាប់ ។ ។ ក្នុង
ព្រះពុទ្ធសាសនាមានប្រពៃណីនិយមថា ព្រះភិក្ខុសង្ឆនឹងមិនត្រូវសញ្ចរទៅ
កាន់ទីណា ។ អស់វស្សានរដូវ, ព្រោះប្រពៃណីនេះឯង ទើបមានភិក្ខុសង្ឆ
ដែលអាស្រ័យនៅក្នុងព្រៃកាន់ធុតង្ត ដើម្បីស្វែងរកមោក្ខធម៌ជាផ្លូវផុត
ចាកកិលេស លោកត្រឡប់ចូលមកកាន់អារាមជាជំនួនច្រើន ។ ពិធី
ឧបសម្បទពុទ្ធមាមិកកុលបុត្ត មានអាយុត្រប់ ២០ ឆ្នាំ បរិបូណិកើតមានឡើង
ក្នុងទាងដើមវស្សានរដូវនេះ ដោយមានពុទ្ធប្បញ្ញត្តិទ្រង់អនុញ្ញាតចំពោះ
បុត្តលអ្នកមានអាយុត្រប់ ២០ ឆ្នាំបរិបូណិហើយ ទើបនឹងឧបសម្បទបាន
ប៉ើអាយុមិនទាន់ត្រប់ ២០ ឆ្នាំទេ នឹងបួសបានត្រឹមតែសាមណេរប៉ុណ្ណោះ ។

ក្សួនរទេះរបស់លោកអមាត្យបាលិតធ្វើដំណើរដាច់ស្រយាលមកក្នុង
ចន្ទោះផ្លូវទៅទាន់ក្រុងវេសាលីនោះយ៉ាងលំបាក ព្រោះដ្ឋដីក្រហេង
ក្រហូងដោយទឹកហូរប្រោះជាទ្ចាំង, រទេះត្រូវតែបរបៀសដីក្រហេងក្រហូង

នោះ ជាហេតុធ្វើឲ្យខ្ញុចវេលាក្នុងការដើរផ្លូវទៅប្រើនថ្ងៃ ។ ទំនៀងគ្រឿងដក់ជាកជាំនៅដីក្នុងព្រៃ នាំឲ្យត្រជាក់ដល់មនុស្សសត្វដែលដើរកាត់ព្រៃនោះ ។ ពេលដែលគួរខ្លាចណាស់ គឺពេលគ្រុនចាញ់ ។ តែគ្រុនចាញ់នេះមិនចាន់កើតច្រាកដល់ឡើងដល់ខ្នាណានៅឡើយ ។ ឧបាយសុរពលក្បាយាមជាស់គឿនឲ្យប្រញាប់តែរះឡើង ហើយប្រយ័ត្នក្នុងការឈប់ស្នាក់ក្នុងពេលយប់ មិនឲ្យស្នាក់ក្នុងជន្លៀត្រជ្រៅដែលជាទីត្រជាក់ខ្លាំង ព្រោះជម្ងឺគ្រុនទំនឹងកើតមានឡើងក្នុងទីនោះឯង ។ ការដើរផ្លូវគាន់តែជិតដល់ខ្នាតវេសាលី តែតែជួបជន្លៀត្រជុំប្រើនណាស់ឡើង។ ក្នុងមួយថ្ងៃក្បួនរនេះមិនអាចនឹងធ្វើឆ្ងាត់ជន្លៀត្រនោះបានឡើយ ក្នុងវេលាជិតព្រលប់ត្រូវឈប់ស្នាក់ក្នុងជន្លៀត្រនោះ ។ អមាត្យបាលិតជាស់គឿនឲ្យតាហានទាំងមនុស្សត្រប់គ្នាប្រយ័ត្នខ្លួន ហើយឲ្យអាស្រ័យជំណេកជិតតំនរក្តើងដែលគេជុតពុកជាប្រើន ដើម្បីឲ្យបានកក់ក្តៅជួយការពារនូវសេចក្តីត្រជាក់ ។

ក្នុងរយៈវេលានៃការដើរផ្លូវ នាងកាញ្ចនាបានបន់ស្រន់សុំឲ្យការដើរផ្លូវត្រានេះប្រព្រឹត្តទៅដោយសួស្តី ។ ស្ត្រីក្រមុំមិនធ្លាប់ធ្វើទុក្ខវេទនាដោយការដើរផ្លូវយូរថ្ងៃ ហើយមានក្តៀងជូរច្នេះឡើយ ។ នាងដឹងខ្លួនថាក្រៅពីសេចក្តីភេយស្រពន់ក្នុងកាយហើយ សូម្បីពេលឈឺចាប់ផ្សេង។ ក៏ពុំមានឡើយ តែក្នុងវេលាយប់នាងហាក់ដូចមានជម្ងឺគ្រុនកើតឡើង ខាំនស្រេងស្រេងៗចង្រៃខ្លាចដោយវិស័យរបស់ស្ត្រីក្រមុំ ចំពោះបភាពកណ្តាលព្រៃធំ ធ្វើឲ្យនាងអាស្រ័យជំណេកមិនលក់, ក្នុងពេលយប់

ម្ដង ។ ឡើង នាងឮតែសំឡេងសង្ឃឹងឮសត្វសាហាវផ្សេង ។ យំកងរំពង
ជាហេតុធ្វើឲ្យនាងខ្លាចពន់ពេក យប់ណាក៏ដូចជាយប់ណា ។ ស្ដ្រីក្រមុំ
អាស្រ័យដំណេកនៅជិតគំនរក្ដីង មិនអាចនឹងលក់បាន នាងក្រោក
ឡើងចាប់យកទុសដាក់ទៅក្នុងគំនរក្ដីង ហើយអាស្រ័យដំណេកសម្ងំង
មើលតាមមែកឈើដ៏ក្រាស់ធ្លុះទៅក្នុងផ្ទៃមេឃ, ក្នុងពេលនាងរពេចប្រាស
ចាកពន្លឺព្រះចន្ទ មានតែពន្លឺផ្កាយព្រាងព្រាតនៅលើផ្ទៃមេឃ ហាក់
ដូចជាជាស់តឿនស្មារតីនៃស្ដ្រីក្រមុំឲ្យទឹកភ្នែកជល់តួស្មូហ, ឃ្យូ ។ មាន
ឮសម្ងំឮក្ដាន់រមាំងយំស្រែក ហាក់ដូចជាជាស់តឿនឲ្យដឹងថាវេលាយប់
ជ្រៅជិតមកដល់ហើយ, ខ្មែរផ្ដេមចុះជាប់នៅស្លឹកឈើ មិនយូរ
ប៉ុន្មានក៏ស្រក់ចុះមកលើផែនដីនឹងគំនរក្ដីង, នាងអាស្រ័យដំណេកស្ដាប់
តន្ត្រីពាំនេះ ហើយក៏លក់យល់សប្ដឃើញនូវវេលាលីនឹងប្ដីសឹក
ទាំងកណ្ដាលអង្គាត នាងភ្ញាក់ឡើងដោយអាការៈតក់ស្លុតញាប់ញ័រ
អស់ទាំងសព៌ាង្គកាយ នាងដឹងខ្លួនថាជម្ងឺគ្រុនចាញ់មានពិសដ៏ពន្លឹក
ជ្រៀតជ្រែកចូលមកកន្លងកាយហើយ ។ ខណៈដែលនាងអាស្រ័យ
ដំណេកលក់បានយល់សប្ដឃើញថា “ផ្កាយមួយមានពន្លឺរុងរឿង
អណ្ដែតចូលមកជិត, នាងលូកដៃទៅចាប់ផ្កាយនោះ ។ ក៏ចេះតែអណ្ដែត
ឃ្លាតចេញទៅមិនឲ្យនាងចាប់បានឡើយ, នាងទើបចេញទៅតាម
ផ្កាយនោះ មិនយូរប៉ុន្មានក៏ទៅជាន់នៅមាត់ទឹកមួយកន្លែង ផ្កាយនោះ
ធ្លាក់ចុះទៅក្នុងទឹក នាងសម្ងំឃើញទឹកនោះពក់ ផ្កាយក៏នៅតែ
បញ្ចេញពន្លឺយ៉ាងរុងរឿងដដែល, ស្ដ្រីក្រមុំគាត់ចិត្តដោយចង់បាន

ពេកក៏ចុះទៅកន្លែងទឹក ទឹកនោះក៏ស្តើងដូចជាកូនឆ្មា, ការចង់ចាន់ឆ្អាយ
នោះធ្វើឲ្យនាងយំដោយសេចក្តីស្រើបស្រាលខ្លាច នាងទំដើរត្រឡប់មកកាន់ទី
ស្នាក់វិញ តែមិនអាចនឹងដើរទៅបាន មួយរំពេចនោះនាងក៏ដួលសន្លប់
ទៅ" នាងទើបក្រាក់ស្មារតីដឹងខ្លួនថា មិនអាចនឹងប្រែប្រួលកាយឬទ័ត
ចុះទ័តឡើងបាន សូម្បីតែបន្តិចបន្តួច នាងហៅបងប្រុសកន្លះខណៈដែល
នាងក្រាក់ឡើង ។ សុរពលគាលបានឮសម្លេងហៅ ទើបទៅជិតនាង ។

នាងនិយាយប្រាប់ដោយសម្លេងស្អកស្អៈ "បង! គាញ់ត្រូនហើយ
សូមទឹកខ្លួលខានបន្តិច បង!" ។

សុរពលកិតក័យជាខ្លាំង ក៏ប្រញាប់ប្រញាល់រត់ទៅរកទឹកមកឲ្យ
ហើយសួរថា :

-ដូចម្តេច គាញ់ ? ប្អូនប្រសើរទឹកហើយឬនៅបន្តិចទៅ, សុរពល
និយាយបានប៉ុណ្ណោះ ហើយក៏រត់ទៅជាស់អមាត្យនន្ទិនីអមាត្យចាលិត ។

ស្ត្រីក្រមុំដេកសន្ធឹមមិនដឹងខ្លួនប្រាណ, នន្ទិអមាត្យអង្គុយនៅជិតនាង
មាត់ស្រែកហៅបុត្រី, អាការត្រូនជាខ្លាំងមន់របស់នាងបេះតែខ្លាំងឡើងគ្រប់
ខណៈ ។ លុះដឹងស្មានគាញ្ជានាទើបបើកភ្នែងឡើងម្តង នាងហៅឪពុក
ហៅបងឲ្យចូលមកជិតនាង ។ មនុស្សគ្រប់គ្នាមិនដឹងថាខិបផុតនៃជីវិត
របស់ស្ត្រីក្រមុំជិតដល់ហើយឡើយ នាងមានស្មារតីកន្លែងបំផុតម្តងទៀត
តែមិនអាចនឹងនិយាយឲ្យបានឮច្បាស់ប្រាជ្ញាទេ នាងរំលើកយថា: "ឪពុក
ស័ត្យ! គាញ់ចាំបាន, មានគេប្រាប់ឲ្យខ្ញុំអត់ធន់បំពេះសេចក្តីទុក្ខដែល
កើតឡើង សេចក្តីទុក្ខនោះ វាមិនធ្វើឲ្យខ្ញុំកើតទុក្ខទេ ខ្ញុំកើតទុក្ខខ្លួនឯង,

បងប្អូនិសត្វ ជាទីពឹងរបស់គាត់, ឥតុក!....បង!" ។

មនុស្សទាំងអស់សម្លឹងមើលមុខគ្នា, កងកាយរបស់ស្ត្រីក្រមុំកំរើកបានបន្តិច ។ ម៉ែកក្អែកសម្លឹងមើលឥតុកនឹងបង, បបូរមាត់ឡើងទើបកាលនាងសម្លឹងមើលទៅចំមុខឥតុកនឹងបង ក៏បន្ទឹកភ្នែកជាទីបំផុតដែលគ្មានអ្នកណាស្តាប់ឮបាន ហើយក្អែកទាំងពីរក៏មិនដឹងទៅវិញ ។

អមាត្យចាស់តឃើញសុរាលរបរស្មៀមចិត្តមាត់ជិត ស្រក់ទឹកភ្នែកលោកមិនអាចនឹងអត់ទ្រាំនៅមើលសភាពយ៉ាងនោះបាន ទើបក្រោកឡើងចាកទីនោះ ប្រញាប់ដើរស្រួតគេចចេញទៅតែម្នាក់ឯង ស្រាប់តែឃើញផ្កាយមួយធ្លាក់ចុះពីលើមេឃ ហើយចាំងចាត់ទៅក្នុងព្រៃ ។

សេចក្តីមិនទៀងទាត់នៃជីវិតជារបស់ពិតក្នុងទីបំផុត, មច្ចុរាជឈ្លៀតឱកាសឆក់យកជីវិតសត្វលោក គឺសេចក្តីចាស់ សេចក្តីឈឺមិនរើសរើយរបស់បុគ្គល ឬបុគ្គលជាទីស្រឡាញ់របស់អ្នកណា មិនថាអ្នកនោះកំពុងប្រកបគុណាគឺសេចក្តីល្អឲ្យដល់លោកទេ, សេចក្តីមិនទៀងទាត់របស់ជីវិតតែងប្រព្រឹត្តទៅយ៉ាងនេះ ។

វេលាថ្ងៃ ព្រះអាទិត្យគោចរឡើងផុតជើងមេឃបញ្ចាំងរស្មីភ្លឺចែងចាំលើប្រហប៊ី, ក្បួនរទេះរបស់អមាត្យចាស់តចេញផុតពីជង្រៃទៅដល់ព្រលឹមមួយ ចោលជង្រៃឆ្ងាយនៅពីខាងក្រោយ, កងកាយរបស់ស្ត្រីក្រមុំជេកស្ទប់ស្ទាត់នៅខាងក្នុងរទេះហើយវិញ្ញាណរបស់នាងបានអណ្តែតឡើងទៅបិតនៅលើផ្ទៃមេឃដែនសុខាតែហើយ ។

ចុងភៅសុរាលដឹកសេះចេញផុតពីជង្រៃ ហើយក៏ដឹះសេះតាមក្បួន

ទេះទៅ; មនុស្សត្រប់ត្នាមិនអាចលះបង់នូវសេចក្តីសោកសៅសោះឡើយ
មិនយូរប៉ុន្ទានក៏បានដល់ទៅនគរវសាលី ។

* * *

-๑๒-

ឬទ្ធិស័ត្យមានសេចក្តីត្រេកអរណាស់ កាលបើបានឃើញអមាត្យ
បាលិតមកដល់, អមាត្យបាលិតមិនចង់ឲ្យឬទ្ធិស័ត្យដឹងរឿងរាំវរបស់ស្ត្រី
ក្រមុំទើបចូលមកតែម្នាក់ឯង ឲ្យទបរាជសុរពលនឹងអមាត្យនន្ទិនៅទាងក្រៅ
ព្រះនគរ, អាការស្រងូតស្រងាត់របស់អមាត្យបាលិត ជាហេតុឲ្យឬទ្ធិស័ត្យ
សង្ស័យជាខ្លាំង ព្រោះអាការដូច្នេះឬទ្ធិស័ត្យមិនធ្លាប់ជួបប្រទះសោះ ។
ថ្ងៃមួយឬទ្ធិស័ត្យអត់ទ្រាំស្ងៀមមិនបាន ទើបស្ងរអមាត្យបាលិតថា :

– សូមជំរាបលោកជាទីស្រឡាញ់! ខ្ញុំដឹងថាខ្លួនខ្ញុំជាអ្នកមានទុក្ខ
ហើយចូលចិត្តថា ត្នានអ្នកណាមានទុក្ខផូចខ្ញុំ តែខ្ញុំបានឃើញលោកក្នុង
ត្រានេះហាក់ដូចជាមានទុក្ខជាងខ្ញុំទៅ តើលោកមិនសប្បាយចិត្តព្រោះអ្វី?
ប្រាប់ខ្ញុំឲ្យដឹងផង ។

សំនួរដ៏ស្មោះត្រង់នេះជាហេតុឲ្យលោកបាលិតមានទឹកមុខស្លេកស្លាំ
លោកបាលិតចង់ប្រាប់ឬទ្ធិស័ត្យថា កុំអាឡោះអាល័យនូវស្ត្រី ដែលជាទី
ស្រឡាញ់នោះឡើយ, ឥឡូវនេះនាងកាញ្ចនា ដែលធ្លាប់នឹកធ្លាប់គិតមក
នោះអស់ជីវិតទៅហើយ តែលោកបាលិតមិនអាចនឹងប្រាប់បាន, លោក
មានសេចក្តីអាណិតអាសូរឬទ្ធិស័ត្យនោះឯងដោយឡែក គឺលោកកើតទុក្ខ
ដោយឃើញសេចក្តីស្មោះត្រង់របស់ឬទ្ធិស័ត្យដែលទំរង់ចាំជួបត្នា លោក

ទ័បត្រីសីស:បដិសេធថា: ខ្ញុំសុខសប្បាយទេឬទ្ធិស័ត្យ! ក្រែងលោការ
ឱនដែលមានទុក្ខ? ខ្ញុំដឹងច្បាស់ថាលោកកើតទុក្ខខ្លាំង ។

-បាទ, ខ្ញុំបាទកើតទុក្ខមែន ខ្ញុំបាទគោតលោកណាស់ ដែលស្គាល់
ចិត្តខ្ញុំថាមានទុក្ខ, នែលោកជាទីស្រឡាញ់! សេចក្តីទុក្ខរបស់ខ្ញុំ
នេះ ជាប់ពាក់ព័ន្ធនឹងសេចក្តីស្រឡាញ់ដែលជាផលកើតមកអំពីខ្ញុំបាន
ឃើញកន្លែងបរិនិព្វានរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ដែលមានមនុស្ស
ទៅថ្វាយបង្គំជាច្រើន ក្នុងខណៈដែលខ្ញុំទៅឃើញនោះ ខ្ញុំមិនទាន់កើត
មានគំនិតជាទុក្ខនេះទៅឡើយ លុះដល់ខ្ញុំគិតនឹកដល់នាងកាញ្ចនាពេកទៅ
ទើបខ្ញុំកើតមានទុក្ខនេះឡើង ខ្ញុំខំព្យាយាមរកផ្លូវនឹងធ្វើសេចក្តីទុក្ខនេះឲ្យ
រលត់រលាយអស់ទៅ តំកើតមានសេចក្តីដឹងខ្លួនថា សេចក្តីស្រឡាញ់ជា
ទុក្ខអាចនឹងខំសាយខ្លួនដើរតែបាន ព្រោះមិនបានប្រសព្វផល គឺសេចក្តី
ស្រឡាញ់ សេចក្តីស្រឡាញ់រមែងផ្តាច់ផ្តិលជីវិតរបស់មនុស្ស បានម្តងៗ
បន្តិចៗ ដូចសុភាសិតរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ថា "សេចក្តីសោក
កើតអំពីសេចក្តីស្រឡាញ់, សេចក្តីស្រឡាញ់មានទីណា ទុក្ខមានទៅ
ទីនោះ" ; ឯព្រះពុទ្ធជាម្ចាស់ទ្រង់លះបង់សេចក្តីស្រឡាញ់កាត់អាល័យ
បានត្រង់ឃ្លាំង មិនមានរបស់អ្វីមកញាំញីឲ្យព្រះអង្គកើតទុក្ខទេ អាត្ម
អញមិនអាចកាត់បង់បានដូចព្រះអង្គ ប្រស្នានេះធ្វើដូចម្តេចនឹងអស់ផុតទុក្ខ
បាន", កាលខ្ញុំគិតឃើញដូច្នេះ ក៏ដឹងច្បាស់ថា មានតែសេចក្តី
ស្លាប់ប៉ុណ្ណោះឯងដែលនឹងធ្វើឲ្យអស់ផុតទុក្ខទៅបាន ។

អមាត្យថាលិតស្តាប់ឫទ្ធិស័ត្យនិយាយមកដល់ត្រឹមនេះ ក៏មាន

សេចក្តីតានតឹងក្នុងចិត្ត ទើបតបថា: ខ្ញុំយល់ថាសេចក្តីស្វាប់ធ្វើឲ្យមនុស្ស
កើតទុក្ខ ហេតុអ្វីលោកទើបថា សេចក្តីស្វាប់នឹងធ្វើឲ្យអស់ទុក្ខបាន ? ។

ឬទ្ធិស័ត្យញាក់មុខ :

– ត្រូវរបស់លោកហើយ ដែលថាសេចក្តីស្វាប់ធ្វើឲ្យកើតទុក្ខនោះ,
តែចំពោះមនុស្សអ្នកដែលមានហេតុផល យាំងខ្ញុំនឹងមិនកើតទុក្ខទ្បើយ
ព្រោះហេតុអ្វី ? លោកដឿទេ ? ដែលខ្ញុំយល់ឃើញថា សេចក្តីស្វាប់
ជារបស់ទៀងទាត់ពិតប្រាកដជាងរបស់អ្វីៗ ក្នុងលោក តាំងអំពីមុនដែល
ខ្ញុំតិតជូច្នេះ ខ្ញុំបានប្រាប់លោកហើយថា ព្រះសាស្តារបស់យើង ព្រះ-
អង្គតង់បរិនិព្វាន ផ្សងអំពីសេចក្តីស្វាប់របស់មនុស្សដែលមានកិលេស
តែប្រហែលនឹងស្វាប់ជួចគ្នាដែរ ទោះបីយាំងណាក៏ដោយ មនុស្សគ្រប់
គ្នានឹងរស់នៅក្នុងលោកទៅមិនរហូត ហេតុនេះ, ខ្ញុំមិនកើតទុក្ខទេលោក!
សុំតែឲ្យបានដឹងប្រាកដថា មនុស្សដែលខ្ញុំស្រឡាញ់នោះរស់ឬ ស្វាប់ចាត់
បង់ទៅហើយ ប្រសិនបើស្វាប់មែន អ្នករស់នៅទោះបីសោសោកជូចម្តេច
មនុស្សដែលខ្ញុំស្រឡាញ់នោះ ក៏មិនអាចមានជីវិតរស់ទ្បើងវិញបាន តែ
ការណ៍នេះខ្ញុំមិនបានដំណឹងអ្វីទាំងអស់ សូម្បីតែដំណឹងល្ហាក់ល្ហៀងអំពី
មនុស្សណាម្នាក់ក៏គ្មាន ព្រោះសហេតុនេះខ្ញុំទើបមានទុក្ខនៅក្នុងចិត្តជានិច្ចៗ

អមាត្យបាលិតយល់ឃើញថាបានឧកាសល្មមនឹងឲ្យឬទ្ធិស័ត្យដឹងនូវ
សេចក្តីពិតហើយ ដើម្បីជាការជួយសម្រាលទុក្ខរបស់គេផង ទើបប្រាប់ថា
ឬទិស័ត្យ!ដែលលោកនិយាយជូច្នោះ តើលោកដឹងប្រាកដក្នុងចិត្តហើយឬ?

ឬទ្ធិស័ត្យស្ងរដោយបើកភ្នែកយាំងធំថា ចុះលោកមិនដឿខ្ញុំទេឬ ? ។

– មិនមែនខ្ញុំមិនជឿទេ...តែខ្ញុំសួរលោកនេះ ដើម្បីឲ្យស្តាល់ចិត្ត លោកបុំណ្ណោះ ។

ឬទ្ធិស័ត្យសើចចំពោះការណ៍ដែលលោកបាលិតជំរិតសួរយកការពិតប្រាកដ រួចតបថា ដែលខ្ញុំនិយាយនេះ ខ្ញុំក៏ហ៉ានប្រាប់លោកថា និយាយដោយសេចក្តីដឹងខ្ជួនពិតប្រាកដ ។

– ប្រវៃពហើយឬទ្ធិស័ត្យ ! បើដូច្នោះសុំឲ្យលោកស្តប់ចិត្តនឹកដល់ពាក្យរបស់លោក ដែលនិយាយរួចហើយនោះ ហើយស្តាប់ខ្ញុំ ។ ប្រាថ្នានឹងឲ្យសេចក្តីទុក្ខរបស់លោក លែងញ៉ាំញ៉ីលោកតទៅទៀត សុំឲ្យសេចក្តីដឹងខ្ជួនរបស់លោក ជាប្រយោជន៍ដល់លោកចុះ ។

ឬទ្ធិស័ត្យ ស្តាប់ពាក្យអមាត្យបាលិតដោយស្ងប់ស្ងៀម ។

អមាត្យបាលិតនិយាយដោយសំឡេងច្បាស់ហើយរន្ទើល ។ ក្នែកសម្ងឹងមើលមុខឬទ្ធិស័ត្យ៍ថា "ឬទ្ធិស័ត្យ ! បុត្រីក្រមុំរបស់លោកនន្ទិ អនិច្ចកម្មទៅហើយ គាលពីក្នុងរាត្រីដែលនន្ទិអមាត្យនឹងសុរពលស្នាក់នៅក្នុងដងព្រៃ ដែលជុតវិស័យអ្នកណានឹងជួយនាងបាន, ឯសេចក្តីស្ងាប់របស់នាងនេះរហ័សពេក មិនមានអ្នកណាតិតស្មានបានឡើយ នាងឈឺត្រឹមតែមួយយប់ក៏អនិច្ចកម្មទៅភ្ងាម" ។

អមាត្យបាលិតនិយាយចប់ ក្នែកនៅតែសម្ងឹងមើលអាកប្យរិកិយារបស់ឬទ្ធិស័ត្យ៍ដែលជាអ្នកបាននិយាយអះអាង ថាបើគេបានដឹងនូវសេចក្តីស្ងាប់របស់មនុស្សជាទីស្រឡាញ់ហើយគេនឹងមិនកើតទុក្ខទេ ។

ឬទ្ធិស័ត្យសួរបញ្ជាក់ថា :

-មិនដឿទេ, លោកកុំនិយាយដូច្នេះ, ដែលលោកថានេះ តើមា
គោលចារឹកអ្វីមកអះអាង? ។

អមាត្យបាលិតកិតក៉យកាលបើឃើញបុទ្ធិស៉ត្យផ្ទាស់ប្តូរអាការដែល
ស្ងប់ស្ងៀម ទៅជាមានអាការតក់ស្ងុតរន្ធត់ចិត្តទៅវិញ ។

-លោកយកអ្វីមកនិយាយ? បុទ្ធិស៉ត្យ និយាយដោយសំឡេងទ្ងាំ
ជាងពីដើម ហើយគ្រោកដើរចូលទៅជិតបាលិតអមាត្យ ។

គ្រាយដែលនឹងកើតរឿងឡើង សេដ្ឋីបិតារបស់បុទ្ធិស៉ត្យដើរចូ
ទៅក្នុងបន្ទប់ ហើយចាប់ដៃបុទ្ធិស៉ត្យស្ងរថា:

-អ្វីទៅ កូនសម្ងាញ់! ហេតុដូចម្តេចកូនឯងធ្វើកិរិយាដូច្នេះទៅ
លោកបាលិត ? ។

បុទ្ធិស៉ត្យត្រឡប់ជាបានជឹងខ្ជួន ងាកបែរមករកបិតាហើយជ្រប់មុខចុះ:

-បុទ្ធិស៉ត្យ! ឥពុកអាស្រ៉យដំណោកនៅទាងគ្រៅបានញ្ជឯងសន្ទន
នឹងលោកបាលិតសព្ទត្រប់រឿងហ៉ាវ, ហេតុអ្វីកូនឯងទើបមិនរក្សាន្ទូវសំ
-របស់ខ្ជួន, កូនសម្ងាញ់ចូរស្ងរលោកបាលិតឲ្យបានជឹងពិតប្រាកដជាមុ
ឥពុកនេះចង់ជួបលោកនន្ទិណាស់ ហើយឯងកុំទោមនស្សឡើយ ព្រោ
សេចក្តីស្ងាប់ជារបស់ធម្មតាដែលនឹងត្រូវមានពិតប្រាកដក្នុងទីបំផុតជីវិ
ឥពុកបានញ្ជកូនឯងនិយាយពំប់រងនឹងលោកបាលិតយ៉ាងជាក់លាក់ណាស
តែចិត្តរបស់កូនឯងត្រឡប់ជាផ្ទាស់ប្តូរខុសពីសំដីរបស់ខ្ជួនទៅវិញដោយ
ធាប់ហ៉ាស, កូនឯងចូរតាំងស្មាតីជាថ្មីវិញទៅ ។

(នៅមានត)

រឿងសាមកុកា

កណ្ឌទី ៦៧

ឧកញ៉ាវិបុលរាជសេនា ន្ធ.កន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃធ្លាសបើបានអាន
នឹងបេះឧបាយកលបំណាន
ទាំងមានសន្ធានស្នេហាជាតិ

អ្ជិនសៀវថា ចូធូនោះជាមនុស្សមានល្បិចប្រាជ្ញាណាស់ អ្នកកុំ
គាលមើលងាយ, ដែលចូធូធ្វើសំបុត្រឲ្យទាហានកាន់យកទៅឲ្យដល់ស៊ុន
ហុកនោះ ជាកលឧបាយដើម្បីឲ្យយើងបែងទាហានទៅវាយស្រុកហ្ជិតោក៏
សឹងបាន, បើកាលណាយើងធ្វើការជ្រុលហ្ជសទៅហើយ ចូធូនឹងត្រឡប់
លើកកងទ័ពទៅវាយយកស្រុកយើងវិញក៏មិនដឹង ។ ទៅហ៊ុវថា កាល
សង្ត្រាមបានចំណាប់ជូច្នេះហើយ លោកមិនធ្វើតាមពាក្យខ្ញុំបាទថាទេ យូ
ទៅអន្ធកយមុខជានឹងមានដល់ខ្ជូនលោកមិនខាន ។ កាលកំពុងនិយាយ
ត្នានោះ ស្រាប់តែមានទាហានជាបំវើម្នាក់នាំសំបុត្រមកពីសឹមដោយដែល
ទៅជញ្ជូនស្បៀងពីស្រុកដៀបកុននោះមកឲ្យអ្ជិនសៀវ ។ អ្ជិនសៀវទទ្ជល
លាមើលយើញសេចក្តីក្នុងសំបុត្រនោះថា ខ្ញុំបាទសឹមដោយបានចាត់ចែង
ស្បៀងក្នុងស្រុកដៀបកុននោះជាស្រេចអស់ហើយ តែឥឡូវនេះមានតេ
ប្តឹងខ្ញុំបាទថា ទៅហ៊ុវកាលនៅក្នុងស្រុកតីជីវនោះ ធ្វើការអាក្រក់ឲ្យ

បណ្ណាវស្ត្រអ្នកស្រុកបានសេចក្តីក្តៅក្រហាយជាច្រើន ហើយប្រើកូនក្មួយរបស់ខ្ញុនទៅបោកធវស្ត្រ ទារយករបៃរៃជាក់ពីបណ្ណាវស្ត្រក្នុងស្រុកបៀងកុន ខ្ញុំបាទក៏បានយកខ្ញុនកូនក្មួយទៅហ៊ុវមកស្ងរ រ៉ាធ្វើយទទួលសារភាពជូចពាក្យតេប្ពឹង ឥឡូវខ្ញុំបាទឲ្យយកខ្ញុនទៅឃុំទុកក្នុងតុកហើយ ។

អ្ជិនសៀវយើញសំបុត្រជូច្នោះក៏ខឹងណាស់ និយាយនឹងទៅហ៊ុវថាខ្ញុនឯងជាមនុស្សបោកកុហកអាក្រក់ណាស់ នៅខំឈមមុខចូលមកប្រឹក្សាការសង្ត្រាមនឹងអញធ្វើអ្វីទៀត អញជឹងថាឯងជាពួកគ្រឿនសំឡាញ់នឹងចូធូមកពីដើម ឥឡូវចូធូឲ្យសំណូកឯង បានជាឯងរិះគិតឲ្យកូនក្មួយឯងទៅធ្វើការផ្តេសផ្តាសជូច្នោះ ប្រាថ្នានឹងឲ្យបណ្ណាវស្ត្រក្រាក់ផ្អើលច្រួលច្របល់, ឯក្សាលឯងនេះអញបានផ្ញើទុកនឹងខ្ញុនឯងពីដើម ពីថ្ងៃនេះទៅមុខ ឯងកុំចូលមកឲ្យអញយើញមុខទៀតឡើយ ។ ទៅហ៊ុវបានឌ្ងសំដីអ្ជិនសៀវស្ត្រីទ្រគោះជូច្នោះ ក៏ដើរដកដង្ហើមធំចេញទៅ ហើយនិយាយថា "ខ្ញុនអញមានសេចក្តីស័ត្យពិតត្រង់ជាប្រាកដណាស់ តែនិយាយអ្វី អ្ជិនសៀវក៏មិនជឿស្តាប់ ។ តែពាក្យមនុស្សញុះញង់រៀបអាក្រក់ ឥឡូវសឹមផោយក្ងែងបងអាឃាតយករឿងអាក្រក់មកជាក់លើយើង ទាល់តែកូនក្មួយរបស់យើងទទួលទុក្ខ ដែលយើងនឹងឈមមុខត្រឡប់ទៅយើញស្រុកតីជីវិញក៏នឹងបានសេចក្តីអាប់យសជល់មនុស្សទាំងពួង" ហើយទៅហ៊ុវក៏ហូតក្រប៉ីឡើងនឹងអារកឲ្យស្ងាប់ ។

ពេលនោះ មានទាហានម្នាក់ជាសម្ងាញ់ស្និទ្ធស្នាលរបស់ទៅហ៊ុវក្រឡេកយើញជូច្នោះក៏ស្ទុះទៅដណ្ដើមយកក្រប៉ីចេញបាន ហើយនិយាយ

លួងលោមអង្វរហាមឃាត់ទៅហ៊ុំថា ខ្ញុំនឹងលោកមានជម្រះប្រាជ្ញាស្មោតគ្រោនសូម្បីមានរឿងតែប៉ុណ្ណោះនឹងមកសម្លាប់ខ្ញុំនឯងនឹងបញ្ញា មុនឈឺនោះមិនគួរទេបើអ្នកនឹងសៀវមិនដឿ ស្តាប់ពាក្យលោកហើយ ត្រូវតែតតាំងខ្ញុំឲ្យរួចទៅល្អជាង ។បមាជួបនៅក្នុងទីធំធាត់អន្ធការ ត្រូវតែទុស្សាហ៍ស្វែងរកពីដែលភ្លឺស្វាង ប្រការមួយទៀត ចូរនូនឹងលោកក៏ជាកឿនសំឡាញ់រាប់អានគ្នាមកពីដើម បើប្រសិនជាលោកនឹងប្រែផ្លាស់វេះគេចទៅរក យ៉ាំងម្តេចក៏តនិ៍តែចូរនូនឹងខ្ញុំលេងំនុកបំរុងផ្តុងផ្តើមលោកមិនមាន ប្រហែលជាកើនខ្ញុំជាជាងនៅនឹងអ្នកនឹងសៀវទៅទៀតផង ។

ទៅហ៊ុំបានស្តាប់ពាក្យតាហាននោះ ក៏ឲ្យផ្ទុះស្មោតគ្រោនតយើញតាមក្លាម លុះវេលាយប់ក៏នាំប័ក្តពួកដែលស្មុំខ្ញុំស្មោលនោះ លមចូលទៅក្នុងបន្ទាយចូរ ហើយតាហានចូរដែលជាកងក្រវែលនោះ ឃើញទៅហ៊ុំនាំពួកកឿនចូលមកកំព្រតចាប់ខ្ញុំនឃុំខុក ហើយសួរតាំចាណាថា: ដែលអ្នកឯងនាំគ្នាមកនេះនឹងប្រាថ្នាការអ្វី? ។ ទៅហ៊ុំវាឆ្លើយថា ខ្ញុំនយើងនេះបានស្គាល់ច្បាស់មហាឧបាជមកពីដើម បានជាយើងនាំគ្នាមករកដោយសេចក្តីពុញចាល់ អ្នកចូរនាំខ្ញុំនយើងចូលទៅឲ្យជួបនឹងមហាឧបាជចុះ ។ តាហានកងក្រវែលក៏ចូលទៅជំរាបចូរថា ឥឡូវទៅហ៊ុំវានៅស្រុកលាំហ៊ុំនមានការមករកលោក ។

ខណៈនោះ ចូរកំពុងដេកវិតតានឹងធ្វើសង្គ្រាម លុះបានឮតាហានប្រាប់ពតិមានដូច្នោះ ក៏មានសេចក្តីត្រេកអរណាស់ ក្រោកឡើងខ្ញុំនទេមិនបានពាក់អាវ ចេញទៅដល់មាត់ទ្វារបន្ទាយ ឃើញទៅហ៊ុំក៏

ស្គាល់ច្បាស់ ។ បងធូរក៏ខះដៃខ្លួនតំនាម់ដោយអំណរ ទៅហ៊ុំរយើញដូច្នោះ
ក៏ឆ្ងល់ក្នុងចិត្ត ទើបចាប់ដៃបងធូរហើយថា ខ្លួនលោកជាមហាឧបាសមិនគួរ
មកបន្ទាបអំណាចនឹងតំនាម់ខ្ញុំបាទទេ ។ បងធូរតបថា "ខ្លួនអ្នកនឹងយើងជា
មិត្រសំឡាញ់កប់អាននឹងមកពីដើម ទោះបីយើងនឹងមានវាសនាលើស
ជាងអ្នកក៏ពិតមែន តែចិត្តយើងនៅស្មើដូចពីដើម" ហើយបងធូរតំនាំទៅហ៊ុំរ
ចូលទៅក្នុងបន្ទាយ ។ ទៅហ៊ុំរនិយាយថា ខ្លួនខ្ញុំបាទដែលក្លាត់ទៅនៅ
នឹងអ្នកនៅរនោះ ព្រោះគិតថានឹងផ្តើខ្លួនឲ្យបានតែសេចក្តីសុខមួយគ្រា
ទៅចុះ បានតាំងចិត្តសុចរិតពិតត្រង់ជួយការអ្នកនៅរ ។ ក៏មិនមានដឹង
ស្តាប់ក់ថាដំល់ម្តងនោះ ថែមទាំងមើលងាយប្រមាខ្លួនខ្ញុំបាទថែមទៀត
បានជាខ្ញុំបាទចង្អៀតចិត្តគិតរំខានខ្លាំងណាស់ ព្រោះយើញថាអស់តើងឹង
នឹងនៅផ្តើខ្លួនតទៅទៀតហើយ ទើបវេលានេះថែរមុខបងលមកសួរនៅ
ជ្រកនឹងលោក ដោយបំណងប្រាថ្នាថានឹងជួយធ្វើពការលោកតាម
តែលោកនឹងប្រើប្រាស តាមសតិកំឡាំងទៅចុះ ទំកំតែអស់ជីវិត ខ្ញុំបាទ
លែងគិតនឹងទៅខើពីងអ្នកជាខទៀតហើយ ។ បងធូរតបថា ដែលអ្នក
ផ្តាប់ចិត្តគិតមកនៅនឹងយើង ។ ក៏មានអំណរក្នុងចិត្តពិតណាស់ ការ
របស់យើងគាំងប៉ុន្មាន បើនឹងបានសំរេចតទៅក៏ដោយសារតំនិតអ្នក
ជួយបំភ្លឺពន្យល់ យើងក៏ត្រូវសំគាល់ធ្វើតាម ជាប្រយោជន៍នឹងបានតំបាត់
អ្នកនៅរចេញ ។ ទៅហ៊ុំរថា ការគាំងនេះជាក្នាក់ងារខ្ញុំបាទនឹងជួយ
រិះគិតធ្វើការតបស្នងសងគុណលោក តាមដម្រេះប្រាជ្ញានឹងថ្វីដៃគាល់
ខ្ញុំបាទនៅនឹងអ្នកនៅរនោះខ្ញុំបាទក៏បានថា តែឥឡូវនេះលោកលើកកង

ទ័តមកតតាំងប្បាំនឹងអ្នកស្រែ នឹងកេអ្នកឯណាខ្លាំងពូកែនៅកណ្តាស្រុក
កំគ្មាន សូមឲ្យអ្នកស្រែវៃបងគាហាន លើកត្រឡប់ទៅវាយខ្ជប់យកស្រុក
ហ្នឹងគោយើញថានឹងបានដោយងាយ អ្នកស្រែក៏មិនស្តាប់ត្រឡប់ទឹងមក
ខ្ញុំបាទវិញ ។ ចូរធ្លុបានស្តាប់ដូច្នោះក៏នឹងភ័យខ្លាំងណាស់ ធ្វើយថាបើប្រសិន
ជាអ្នកស្រែវៃធ្វើតាមពាក្យអ្នកឥន្ទ្រលែមេន ខ្ញុំក៏នឹងឋូស់ការជាក្រាកជ ។

ទៅហ៊ុំវាក៏សួរចូរធ្លុថា ស្រួវអង្គរសៀងអាហារក្នុងកងទ័ពលោក
នេះនៅមានប៉ុន្មានច្រើនឬតិច ? ចូរធ្លុយល់យើញថា ទៅហ៊ុំវានិយាយ
សួរនោះជាល្បិចល្បន ក៏ភ្លែងធ្វើយថា ឯស្បៀងអាហារបស់យើងនោះមិន
សូវជានឹងខ្វះខាតប៉ុន្មានទេ ល្មមនឹងប្រើការចំញឹមសេនាពាហានបានមួយ
ឆ្នាំទៀត ។ ទៅហ៊ុំវាឮដូច្នោះក៏អស់សំណើចហើយថា លោកមានប្រសាសន៍
នេះលើសហួសពេកមិនសមរសោះ ។ ចូរធ្លុថា យើងនិយាយដោយពិត
វិញ តែស្បៀងអាហារបស់យើងនៅល្មមប្រើបានតទ្វេរឆ្នាំទៀត ។ ទៅ
ហ៊ុំវាយើញចូរធ្លុនិយាយអំព្រាងកុហកដូច្នោះក៏នឹកខឹងណាស់ ទើបក្រោក
ឡើងហើយថា ខ្ញុំបាទមកសូមនៅនឹងមហាឧបាជនេះ ប្រយោជន៍នឹង
តាំងចិត្តគិតធ្វើការជំនួញដ៏តបស្នងសងគុណលោក ដោយសុចរិតត្រង់
ឥឡូវលោកមិនជាន់ជឿខ្ញុំតចិត្តខ្ញុំបាទជាក្រាកជហើយ ខ្ញុំបាទក៏សូម
លាលោកទៅកេទីពឹងវិញទៀត លុះត្រាតែបាននៅចក្តីសុខ ។

ចូរធ្លុយើញអាការកំរើយាទៅហ៊ុំវាដូច្នោះ ក៏ចរចាជាយអាវៃទៅហ៊ុំវាឲ្យ
អង្គុយហើយថា អ្នកកុំអាបខឹងនឹងយើងគិតលាទៅកេទីពឹងនៅទៀត
ឡើយ យើងដឹងចិត្តអ្នកហើយ យើងនឹងប្រាប់អ្នកឲ្យត្រង់ទៅចុះ ស្បៀង

អាហារយើងនៅតិចណាស់ ប្រហែលប្រើការបានតែ៣របីខែទៀតអស់ហើយ ។ ទៅហ៊ីវក៏អស់សំណើចហើយថា កិត្តិសព្ទល្បីថា មហាឧបរាជនឹងនិយាយការអ្វីរមែងជាកិច្ចកលឧបាយមិនដាយនឹងជឿស្តាប់សោះ ឥឡូវក៏ឃើញសមប្រកបជូចពាក្យគេថាមែនពំងអស់ ។ ចូធូបានឮទៅហ៊ីវស្តីដល់ដូច្នោះក៏មិនបានខឹង ធ្វើជាអស់សំណើចហើយថា "អ្នកមឹនដឹងទេឬ ? ឯការសង្ត្រាមនេះដែលនឹងមានជ័យជំនះបាន ក៏អាស្រ័យដោយតបះកំឡាំងសតិបញ្ញាកលឧបាយជាប្រធាន" ហើយធ្វើជាឧនឱ្យិបប្រាប់ទៅហ៊ីវថា ស្បៀងអាហារយើងនៅតែ ១ ខែទៀតអស់ហើយ ។ ទៅហ៊ីវក៏ស្រែកតំហកឲ្យចូធូហើយថា នៅតែនិយាយកុហកខ្ញុំបាទដល់ណាទៅទៀត ខ្ញុំបាទដឹងអស់ហើយ គឺស្បៀងក្នុងកងទ័ពលោកអស់រលីងហើយ ។ ចូធូក៏យណាស់ ទើបស្ងរទៅហ៊ីវថា ហេតុម្តេចបានជាអ្នកដឹង ។

ទៅហ៊ីវក៏ដកសំបុត្រហុចទៅឲ្យចូធូមើល គឺសំបុត្រដែលចូធូផ្ញើទៅឲ្យស៊ិនហុកនោះ ។ ចូធូឃើញសំបុត្រនោះហើយក៏ស្ងរថា នរណាយកសំបុត្រនេះទៅឲ្យអ្នក ? ទៅហ៊ីវក៏ពណិនារឿងរាំវដែលចាប់បានអ្នកកាន់សំបុត្រនោះឲ្យចូធូស្តាប់ត្រប់ប្រការ ។ ចូធូយល់ឃើញថាទៅហ៊ីវដឹងការសព្វត្រប់ដូច្នោះ ក៏ខ្ទាចក្រែងបែកការខ្ទាយខ្ទរទ្បើង ក៏ហាមប្រាមថា អ្នកកុំបីនិយាយសេចក្តីពំងអស់នេះឲ្យនរណាដឹងឮទ្បើយ ចូរជួយគ្នាតិតកំចាត់អ៊ិនសៀវចេញឲ្យបាន ។ ទៅហ៊ីវក៏ទទួលពាក្យហើយថា លោកធ្វើសង្ត្រាមនឹងអ៊ិនសៀវវេលានេះ ពាហានអ៊ិនសៀវច្រើនលើសលប់ណាស់ សូមឲ្យលោកស្រួតប្រញាប់ធ្វើការទើបបានជ័យជំនះ បើនឹងបង្អង់ឲ្យយឺត

ឃ្លះតទៅក្រែងនឹងថ្លៃសំការដោយខ្លាចអ្នកនៅសៀវភៅគ្រាកដ ។ ចុងភ្លូធ្វើយថា អ្នកនិយាយនេះត្រូវហើយ, ចុះតំនិតរបស់អ្នកនឹងគិតដូចម្តេចខ្លះ ទើបនឹងឲ្យអ្នកនៅសៀវភៅកខ្វះទៅដោយឆាប់ហ៊ានបាន ? ទៅហ៊ុំវាធ្វើយថា ខ្ញុំបាទគិតធ្វើ១ថ្ងៃកសួមួយយ៉ាង ប្រសិនបើលោកធ្វើតាមខ្ញុំបាទហើយ មុខជាអ្នកនៅនឹងសេនាភាគច្រើនបែកខ្លះទៅក្នុងរវាង ៣ ថ្ងៃនេះ។ ចុងភ្លូសួរថា ១ថ្ងៃយកលរបស់អ្នកនោះដូចម្តេច ? ។ ទៅហ៊ុំវាធ្វើយថា អ្នកនៅសៀវភៅមកធ្វើការគ្រានេះ បានប្រមូលស្រូវអង្គរជាស្បៀងអាហារមកខុកនៅដំបន់អ្នកទៅ ឲ្យអ៊ីខេងនៅថែរក្សា ឯអ៊ីខេងនោះក៏មិនបានយកចិត្តខុកជាក់សោះ ធឹកតែស្រាស្រឹងជាន់ច្រ ភាគច្រើនក៏បែកខ្ញែកអស់ជាច្រើន សូមឲ្យលោកចាត់ប្រើភាគច្រើនឲ្យលើកកងខ្លះចូលទៅបន្ថែមជាពួកភាគច្រើនអ្នកនៅសៀវ លើកអោយតំរួបន្ថយអ្នកនៅសៀវចេញទៅដុំបន់អ្នកទៅ បើមាននរណាសាកសួរឲ្យធ្វើយថាជាភាគច្រើនជៀវគឺ ដែលជានាយកងស្បៀងអ្នកនៅសៀវ ឧទ្ធទៅបង្ខំការយកស្បៀងពីដំបន់អ្នកទៅ បើទៅដល់ដំបន់អ្នកទៅហើយ ឲ្យលបចូលទៅតំរួចក់យបន្ថយហើយដុតស្បៀងអាហារអ្នកនៅសៀវនៅទីនោះឲ្យអស់ បើអ្នកនៅសៀវខូចស្បៀងអាហារអស់ហើយក៏ឧទ្ធឹងបែកខ្ញែកជាច្រើនដ ។

ចុងភ្លូបានស្តាប់ហើយក៏មានអំណរណាស់ ទើបប្រើមនុស្សឲ្យរៀបតុលៀងភោជនាហារទៅហ៊ុំវា ហើយអញ្ជើញឲ្យចូលទៅនៅក្នុងបន្ទាយលុះវេលាព្រឹកឡើងចុងភ្លូក៏ចាត់ប្រើភាគច្រើន ១.១០០ ឲ្យលើកទៅដំបន់អ្នកទៅ ។ ខៀវលៀវក៏លបទៅនិយាយនឹងចុងភ្លូថា អ្នកនៅសៀវក៏នៅ

មានដម្រេះច្រើនជាងដែរ បើប្រសិនជាពុកស្បៀងអាហារនៅដំបន់អ្នកទៅបានខោះ ក៏គង់មានតាហានទៅគ្រប់គ្រងរក្សាជាមិនខាន ដែលលោកមកស្រាលតំនិតគិតដឿតាក្យសំដីទៅហ៊ីវនោះ ខ្ញុំបាទមិនចាន់យល់ឃើញផងទេ ក្រែងជាកលៗបាយអ្នកស្បៀវទេដឹង ឲ្យលោកត្រេះរិះមើលតាមគួរសិនចុះ។ បពិត្រធ្វើយថា អ្នកកុំសង្ស័យឡើយ ដែលទៅហ៊ីវនឹងបញ្ជោតយើងនោះមិនមែនទេ បើសិនណាជាទៅហ៊ីវមកធ្វើជាកលសឹកមែន ក៏មិនអាចហ៊ានចូលមកដល់យើងដូច្នេះទេ តាមរយៈយើងឃើញថាអ្នកស្បៀវអស់កំលាំងហើយ ប្រហែលជាទឹងដល់សេចក្តីស្លាយផងក៏មិនដឹង បានជាបណ្តាលឲ្យគិតធ្វើការខុស។ ទៅ តាល់តែយើងដឹងសេចក្តីសព្វគ្រប់ យើងក៏បានចំណាប់ហើយ បើទឹងបង្អង់ពុកមិនធ្វើតាមពាក្យទៅហ៊ីវថាទេ ស្បៀងអាហារខាងយើងក៏ខ្វះខាត យូរទៅយើងទឹងថ្វល់ការរបស់អ្នកស្បៀវវិញ។ ទៀវស្បៀវធ្វើយថា ដែលមហាបពិត្រជាតិនេះក៏ត្រូវហើយ តែខ្ញុំបាទក្រែងអ្នកស្បៀវដឹងថាលោកលើកទ័ពទៅជំបន់អ្នកទៅ អ្នកស្បៀវនឹងលើកទ័ពមកវាយយកបន្ទាយខាងណោះវិញ សូមឲ្យលោកត្រេះតិតឲ្យមិនខានចុះ។ បពិត្រថា អ្នកកុំរវៃក្តរឿងរក្សាបន្ទាយនោះឡើយ យើងក៏បានតិតពុកជាស្រេចហើយ។

បពិត្រកំពត់ប្រើស៊ុនហ៊ី, តាសឿង, ចោហង, ឧទ្ធរទៅហ៊ី, តាំង ៤ នាក់នេះជានាយក្រុមឲ្យនៅរក្សាបន្ទាយ ឲ្យហែហ្វូងទឹងហែហ្វូងអៀនលើកតាហានជាកងទ័ពទៅបង្ក្រាបនៅពីក្រៅបន្ទាយខាងស្តាំ ឲ្យលីវឿនឧទ្ធរចាយនលើកតាហានជាកងទ័ពទៅបង្ក្រាបពីក្រៅបន្ទាយខាងឆ្វេងហើយទើបបង្គាប់ថា បើប្រសិនជាអ្នកស្បៀវឧទ្ធរលើកកងសេនាតាហានមកវាយ

យកបន្ទាយក៏ឲ្យដួយគ្មាការពារក្បាលកុំឲ្យអន្តរាយបាន" ហើយចូលទូក ប្រើទៅធូ, ខៀវលៀវ, ស៊ីហ៊ុន នឹងអ៊ីគាំមឲ្យលើកទាហានសរុប ៩.០០០ នាក់ ទៅដល់ភ្នំជាទាហានអ៊ូនសៀវ ហើយយកខន់ដ័យដែលមានឥណាដូច ខន់ដ័យអ៊ូនសៀវលើកចេញទៅ ឲ្យយកចាប់អុសនឹងចំបើងដែលប្រុងនឹងដុតដំបន់អ៊ូទៅនោះដូករខេះទៅផង ខ្លាចក្រែងទៅមុខនឹងរកមិនទាន់ការ ហើយបង្គាប់ថា "បើការណានឹងលើកទ័ពទៅនោះ កុំឲ្យនរណានិយាយគ្នាឲ្យលាន់ឮសំឡេងជាខ្លាំង" លុះដល់ពេលយប់ចូលក៏លើកទ័ពចេញពីបន្ទាយនឹងទៅវាយយកដំបន់អ៊ូទៅ ។

ឯចស៊ីវ៉ែដែលអ៊ូនសៀវឲ្យជាក់គុកពុកនោះ លុះមកពេលយប់មួយ ឃើញមេយក្ខីស្វាងក៏ទឹកធ្លាក់ក្នុងចិត្តណាស់ ទើបឲ្យនាយកូឃុំដោះក្តី ហើយក្រោកចេញទៅខាងក្រៅលួងគង់ទ័ព ក៏ឆើយមើលទៅលើមេយ រើញផ្កាយវិប្បរិតក៏ទឹកក័យថាមច្បាស់ ទើបគិតថា "អន្តរាយនឹងមានដល់នាយទៅហ្ន៎យរបស់យើងក្នុងគ្រានេះហើយ បើយើងនឹងនៅស្ងៀមការខ្ជិយឃើញជាមិនគួរ" ចស៊ីវ៉ែក៏ឲ្យនាយកូឃុំនាំខ្លួនចូលទៅជួបនឹងអ៊ូនសៀវ ។ ខណៈនោះអ៊ូនសៀវកំពុងដឹកស្រាស្រវឹងដេកលក់ ខ្លួលទាហានចូលទៅដំណឹងថា ចស៊ីវ៉ែចូលមកប្តឹងពីការពេជគារអ៊ូនសៀវ ។ ក៏ឲ្យចស៊ីវ៉ែចូលទៅហើយសួរថា ខ្លួនចូលមករកយើងដោយកិច្ចធុរៈអ្វី ? ចស៊ីវ៉ែដំណឹងថា ពេលយប់នេះមានផ្កាយវិប្បរិត ខ្ញុំបាទពិគ្រោះពិចារណាមើលទៅឃើញថាលោកនឹងមានសេចក្តីព្រួយលំបាក ព្រោះមានគេលបទៅវាយយកដំបន់អ៊ូទៅ សូមឲ្យលោកចាត់ប្រើទាហានទៅចាំស្កាត់ដើមផ្លូវខ្លួនឲ្យមាំកុំឲ្យ

សត្រូវលើកចូលទៅបាន ។

អ្ជិនសៀវបានស្តាប់ហើយក៏ខឹងប្រឡោត ដេរចស៊ីវថា "ខ្ជនឯងជាមនុស្សទោស ហេតុម្តេចមកអាចហ៊ានចរចាអ្ជតចេះដឹងដូច្នេះ" ហើយនិយាយនឹងនាយកូយុំថា "ចស៊ីវជាមនុស្សទោស យើងឲ្យយកខ្ជនទៅយុំទុកក្នុងតុក ហេតុម្តេចក៏ខ្ជនបណ្តោយឲ្យវាចេញមករកយើង ?" ហើយបង្គាប់ឲ្យយកខ្ជននាយកូយុំនោះទៅសម្ងាប់ ហើយក៏ចាត់ទាហានឯទៀតឲ្យនាំខ្ជនចស៊ីវទៅដាក់តុកវិញ ។ វេលានោះចស៊ីវអង្គុយដកដង្ហើមធំហើយថា "អ្នករាល់គ្នានឹងដល់នូវសេចក្តីស្ងាប់ក្នុងវិថ្ងត្រឹកវស្អកនេះហើយ នឹងយកសាកសពទៅតទុកនៅដំបន់ឯណាក៏មិនដឹងទេ" និយាយហើយចស៊ីវអង្គុយយំ ។

ឯចូធូកាលលើកទ័ពកាត់រំលងបន្ទាយអ្ជិនសៀវទៅ ទាហានកងក្រវែលអ្ជិនសៀវក្រឡេកឃើញក៏ស្រែកស្ងរថា កងទ័ពនរណាលើកទៅណា ? ទាហានចូធូធ្វើយថា អ្ជិនសៀវប្រើជៀវតីឲ្យយុំនាំទាហានលើកទៅយកស្សៀងឯដំបន់អ្ជិចៅជាប្រញាប់ ។ ទាហានកងក្រវែលបានស្តាប់ក៏ក្រឡេកមើលតាមទៅឃើញទង់ជ័យសម្រាប់ទ័ពអ្ជិនសៀវ ក៏សំគាល់ថាមែនពិតឥតមានសង្ស័យអ្ជីសោះ ។ កាលចូធូលើកកងទ័ពទៅក្នុងពេលយប់នោះ ក៏ប្រទះនឹងទាហានអ្ជិនសៀវស្ងរដេញដោលរាល់អន្ទើ ទាហានចូធូក៏ធ្វើយវតសំដីមួយដូចកាលមុន ។ ពួកទាហានកងក្រវែលអ្ជិនសៀវទាំងនោះ ក៏មិនមានវិមុត្តិសង្ស័យឡើយ លុះដល់ពេលយាម ៦ ឋាយ ចូធូក៏បានទៅដល់ដំបន់អ្ជិចៅ ទើបឲ្យទាហានទាំងអស់ចងបាច់អុសនឹងបាច់ចំបើង

ជុតក្តីឆ្យេធេះឡើងព្រមគ្នាជុំវិញបង្រុកស្រូវ ក្តីឆធេះរាលទៅជល់បង្រុក
នោះជុំវិញ ពហានពំននោះក៏ស្រែកហោកញ្ជ្រៀវតិកកងលើកគ្នាចូល
ទៅបោមពីឧអ៊ីរេឆ ។

ឯអ៊ីរេឆនោះ តាំងពីពេលព្រលប់ជឹកស្រាស្រវឹងពុំដឹងស្មារតីដេក
លក់នៅក្នុងជំណេក លុះបានព្ធសំឡេងអឺងកងក៏បានស្មារតីដឹងខ្ជនក្រាក់
ឡើង រត់ចេញទៅមើលឃើញកងឧីពចូធូលើកមកបោមរោមរាយកាប់ចាក់
ពហានហើយចូលទៅចាប់ខ្ជនអ៊ីរេឆបាន ។ ឯតុយអ្ជិនជិនន៏ងឡៃ-យ៉ូយ
ដែលអ៊ីរេឆប្រើឲ្យនាំពហានទៅយកស្សៀងអាហារមកឲ្យកងឧីពអ្ជិន
ស្សៀវនោះ លុះត្រឡប់ទៅជិតជល់ជំបន់អ្ជិបៅ ទទួលក្រឡេកមើលទៅ
ឃើញពន្ធឹក្តីឆ ត្រង់ជង្រុកស្រូវកំពុងតែធេះឡើងសន្ធោ ក៏លើកពហាន
ទន្ទ្រានចូលទៅជួយ ។

ខណៈនោះពហានចូធូក្រឡេកទៅឃើញកងឧីពលើកមកពីក្រោយ
ច្រើនណាស់ ចូធូស្រែកឡើងថាកុំឲ្យគ្នាយើងកិតកីយ ឲ្យតាំងចិត្តខំប្រឹង
តែធ្វើការទៅខាងមុខទៀតចុះ ដែលកងឧីពលើកមកពីក្រោយនោះជាក្នាក់
ដាររបស់យើងន៏ងការពារតែវិទហើយ ។ ពហានពំនពួងបានព្ធដូច្នោះ ក៏
បន្ទំជុតក្តីឆពំនអស់គ្នា ហើយចូលទៅដេញកាប់សម្ងាប់ពហានអ៊ីរេឆ
ស្ងាប់អស់ជាច្រើនណាស់ ។ លុះតុយអ្ជិនជិនន៏ងឡៃ-យ៉ូយលើកឧីពរាយពី
ក្រោយចូលទៅ ចូធូក៏ដេញពហានដែលរក្សាខ្ជនឲ្យត្រឡប់មុខមករាត
តាំងប្សាំងគ្នាជាពន្ធឹក ។ ពហានចូធូយកទួនចាក់ត្រូវតុយអ្ជិនជិនន៏ងឡៃ-
យ៉ូយជ្ជាក់ពីលើសេះស្ងាប់ ។

ឯតាហានអ្ជិនសៀវដែលលើកឡើកឆ្នាងពេលយប់នោះ ឃើញពន្ធឹក្ខើង
ធេះឡើងខាងទិសទត្តរកឹទំស្រូតឡើបាប់អ្ជនសៀវ ។ ទណៈនោះអ្ជិនសៀវ
កំពុងដេកលក់ ក៏ភ័យភ្ញាក់ឡើងគ្រោកឡើមើលឃើញក្ខើងធេះភ្ជឹចំទិសទត្តរ
ក៏ដឹងថាជាកងទ័ពចូធ្ជូលើកឡើជុតចង្រុកស្រូវនៅជំបន់អ្ជិនចៅអស់ ទើបឲ្យ
ហៅសេនាតាហានតំងអស់មកប្រឹក្សាថានឹងលើកទ័ពឡើជួយ ។ ទៀវ-
ខាប់ធ្ជើយថា ខ្ញំបាទនឹងគោឡ្លាំសុំយកអាសាលើកតាហានឡើជួយការពារ
ស្សៀងឲ្យបាន ។ ត្ជូតៅជំរាបថាដែលទៀវខាប់នឹងគោឡ្លាំថានឹងយកអាសា
លើកទ័ពឡើនោះពិតជាមិនបានទេ ព្រោះចូធ្ជូលើកទ័ពមកធ្ជើការដោយ
ខ្ជួនឯង សូមឲ្យលោកស្រូតលើកទ័ពឡើរាយបន្ទាយចូធ្ជូខាងណោះវិញ
បើចូធ្ជូដឹងនឹងរាមកជួយដណ្តើមយកបន្ទាយទុក ការដែលយើងធ្ជើក៏នឹង
បានសំរេចដោយងាយ ។ ទៀវខាប់តបថា តំនិតរបស់ចូធ្ជូនោះជ្រៅនឹង
ចំណានស្ទាត់ក្នុងការសង្ត្រាមណាស់ បើប្រសិនចូធ្ជូនឹងលើកឡើការខាង
ណោះ ក៏គង់បានទុកសេនាតាហានដែលមានថ្ជីដែឲ្យនៅរក្សាបន្ទាយខាង
ណោះជាមាំមួនមិនឲ្យមានអន្តរាយបានឡើយ ដែលលោកនឹងឲ្យលើទ័ព
ឡើរាយបន្ទាយចូធ្ជូមិនងាយនឹងបានទេ ក្រែងមានថ្ជស់ការ ប្រការមួយ
ទៀត បើនឹងលើកឡើជួយអ៊ីខេងខាងណោះសោត ទោះបីអាក្រក់ល្អ
ប្រហែលជាកូធ្ជូនឹងចាប់អ៊ីខេងបានហើយដឹង ការដែលលោកនឹងប្រឹងតិត
ត្រានេះឃើញថាមុខជាថ្ជស់ការតំងសងខាងមិនលែងទេ ។

(មានត)

លោក វ៉ុលតែរ ធិពន្ធ

លោក រ៉ាយ.ប៊ុក ប្រែរៀបរៀង

វគ្គទី ១

រឿងមនុស្សខ្វាក់ភ្នែកម្ខាង

នៅនគរបាប៊ីឡូន ក្នុងរជ្ជកាលព្រះបាទមូអាប់ដារ មានបុរសកំឡោះម្នាក់ឈ្មោះ ប៊ែរ្ទីឌីគ មានរូបឆោមល្អ, មានប្រាជ្ញាច្រើន ។ ពិតមែនតែលោកហ្នឹងគេនេះមានភោគទ្រព្យច្រើន ហើយស្ថិតនៅក្នុងឋានៈជាអ្នកមានចិត្តសន្តោសតាមគន្លងច្បាប់ លោកមិនដណ្តើមត្រូវតែម្នាក់ឯងទេ ហើយចេះគោរពមនុស្សពុតូលភាព ។

មានគេឆ្ងល់ថា: បើលោកមានប្រាជ្ញាច្រើន ហេតុម្តេចក៏លោកមិនពោលពាក្យអាក្រក់ ឬពាក្យចំអកឡកឡឺយ ចំពោះអ្នកដទៃដែលនិយាយពាក្យមិនច្បាស់លាស់, ពាក្យមិនពិត, ពាក្យមិនគប្បី, ពាក្យតិះដៀនកថា ដែលគេហៅថា "ការសន្ទនាទៅវិញ-មក" នៅទីក្រុងបាប៊ីឡូន? ។

លោកបានសិក្សារៀនសូត្រតាមសៀវភៅបណ្ឌិតហ្សាពិស្តូថា: សក្កាយទិដ្ឋិ (ការប្រកាន់ខ្លួន) ជាចាល់ឫស្សីភៅស៊ូចោទដោយសារឡើងហើយបញ្ចេញនូវព្យុះសង្ឃាត បើគាស់ណាគេយកម្ជុលទៅចាក់ចាល់ឫស្សីនោះ ។ លោកហ្នឹងគិតមិនដែលអួតខ្លួនថា ខ្លួនប្រសើរមើលងាយស្តីហើយចង់ធ្វើឲ្យស្តីស្តាប់បង្គាប់ខ្លួនសោះឡើយ ។ លោកមានចិត្ត

សប្បុរស លោកមិនខ្វាចខ្លួនពួកជនជាអកតញ្ញូទេ, ដោយលោកបាន
សិក្សារៀនសូត្រខ្ជាប់ខ្ជួនពីបណ្ដិតហ្សាកឹស្ដែថា: បើយើងបរិភោគអាហារ
ណា ត្រូវឲ្យអាហារនោះមកផ្ដែបរិភោគវិញ,ទោះបីផ្ដែនោះក៏ខាំកំដោយ ។
ដោយការសេពគប់ជាមួយពួកបណ្ដិតបានជាលោកមានប្រាជ្ញាច្រើន ។

លោកបានសិក្សាខ្ជាប់ខ្ជួនពីជនជាតិគាល់ដេអឿងសម័យបុរាណ
តែលោកមិនមែនមិនចេះខ្ជាប់ខ្ជួលក្នុងគោលបំណងឡើយ ធម្មជាតដែលគេបានដឹង
ក្នុងពេលនោះត្រង់ៗគ្នាទេ លោកចេះបរមត្ថវិជ្ជា ហើយលោកជឿជាក់ថា
ក្នុងមួយឆ្នាំមាន ៣៦៥ ថ្ងៃ ហើយព្រះអាទិត្យស្ថិតនៅចំកណ្ដាលពិភព
លោក ។ បើកាលណាពួកម៉ាសបានពោលជាពាក្យអសប្បុរសមក
កេលោក។ នៅស្ងៀមមិនតបមនស្សខ្លីយ ។

លោកហ្សាឌីតជាគហបតីមានកោតខ្ពង្សច្រើន មានមិត្តសំឡាញ់
ច្រើន លោកបរិបូណ៌ដោយសុខភាព មានចិត្តមុខស្រស់ស្រាយ ជាអ្នក
ប្រព្រឹត្តសុចរិត លោកគិតថាខ្លួនលោកមុខជាបានសុខក្នុងអនាគត ។
លោកមានចំណង់ចង់រៀបមង្គលការជាមួយ នាង "សេមីរ" ជាស្ត្រីមាន
រូបឆោមស្រស់ប្រិមប្រិយ, មានកោតខ្ពង្សបរិបូណ៌, មានត្រកូលដ៏
ឧត្តម ។ លោកមានចិត្តប្រតិព័ទ្ធជាខ្លាំងចំពោះនាង។ ក៏មានចិត្តស្នេហា
ជាខ្លាំងចំពោះលោកដែរ ។

ជិតដល់ពេលរៀបមង្គលជាមួយនាងសេមីរហើយ លោក
បានដើរលេងជាមួយនាង សេមីរ តម្រង់ទៅកាន់ច្រាំងក្រុង បាច់ខ្លាន
ក្រោមដើមត្នោតដែលដុះជាជួរតាមមាត់ទន្លេឡើរហ្វាត, កំស្រាប់តែ

យើញមនុស្សកាន់ជាវនើធព្រញមកដល់ ។ មនុស្សនេះជាពួកសេនា
លោកអ្នកធំ ជាខ្នងរដ្ឋមន្ត្រីមួយរូប ។ លោកអ្នកធំនេះ គ្មានគុណ
សម្បត្តិដូចលោកហ្សាងគេ, តែលោកអ្នកធំចង់សំដែងអាការៈថាខ្លួន
មានចិត្តស្នេហាចំពោះនាងសេម៉ីដែរ ហើយមានបំណងចាប់យកនាង
នេះធ្វើអំណាច ។

ពួកសេនាលោកអ្នកធំ ចាប់ភាញនាងដោយចិត្តយោរយៅ ធ្វើ
ឲ្យនាងមានបួសចេញឈាម ។ ពួកសេនានេះមិនសមបើធ្វើយ៉ាងដូច្នេះទេ,
សូម្បីតែខ្លាខ្មៅកុំ អ៊ីម៉ូសុ គ្រាន់តែក្រឡេកយើញនាងក៏គង់មានចិត្តអាណិត
អាសូរនាងដែរ ។ នាងស្រែកថ្ងូថា "ឧស្សាម៉ាធីពេញចិត្តខ្ញុំអើយ,
គេចាប់អូសកន្ត្រាក់ខ្ញុំចេញឃ្លាតពីអ្នកជាគូរសង្សារហើយ" ។ នាងមិន
ចាន់តិតដល់គ្រោះថ្នាក់របស់នាងឡើយ នាងគឺតតែលោកហ្សាងគង់ជាស្នាម
ដែលជាទីស្នេហារបស់នាង ។ តែនាងនេះមានគេការពារដោយកំឡាំង
ទឹកចិត្តដែលកប់នៅលោកហ្សាងក តែលោកហ្សាងគមានឥស្សាពីនៅក់
ឥស្សានោះចាន់តែមកជួយនាង, ពួកសេនាលោកអ្នកធំក៏ចាន់តែបកចាក់
ខ្ចាត់ខ្ចាយអស់ ។ ឥស្សាលោកហ្សាងគនាំនាងសេម៉ីដែលសន្ធប់ចាត់ស្មារតី
មានឈាមប្រឡាក់មកដល់គេហដ្ឋាន ។ នាងសេម៉ីបើកភ្នែកក្រឡេក
ទៅយើញអ្នកជួយការពារ នាងក៏ពោលថា: "ឧហ្សាងគ, ខ្ញុំស្រឡាញ់
បងក្រៃប្រៀបគ្មាន ព្រោះបងចាន់ជួយជីវិតខ្ញុំ" ។ តាំងពីពេលនោះមកនាង
សេម៉ីក៏មានចិត្តប្រតិព័ទ្ធស្និទ្ធស្នេហាលោកហ្សាងគតែតែខ្លាំងឡើង... ។

នាងសេម៉ីមានបួសស្រាលធាប់ជាសះស្បើយ ។ ឯលោកហ្សាងគ

របួសខ្ទាំងដោយត្រូវព្រួញមួយមុតជិតក្នែក ហើយរបួសនោះជ្រៅណាស់, នាងសេមីរបានបន់ស្រន់សូមទេវតាចាជួយស្វាមីឲ្យជាសះស្បើយរោគ ទៅ ។ ក្នែកនាងដោរជន់ដោយទឹកក្នែកទាំងយប់ទាំងថ្ងៃមិនដាច់, នាងរង់ចាំ រៀលាដែលលោកហ្សាឌិតជាក្នែក ឲ្យអាចមើលឃើញនាងដោយសប្បាយ ចិត្តបាន តែត្រង់កន្ទែងរបួសនោះទៅជាមានបូសតំខ្ទុស, ត្បូរឲ្យស្ទុត រន្ធត់ចិត្ត..... ។

គេបានទៅនាំយកត្រូពេទ្យឈ្មោះ ហែរមែស ដែលនៅក្នុងទីក្រុង ម៉ាកិស ។ ពេទ្យហែរមែសបានមកដល់ក្រុងបាប៊ីឡោនដោយមានមនុស្ស ហែហមជាប្រើន ។ លោកហែរមែសក៏បានពិនិត្យក្នែកនោះ ហើយប្រាប់ ថា លោកហ្សាឌិតនឹងទូចក្នែកម្ទាង ។ ត្រូពេទ្យបានកំណត់ន្ទូវថ្ងៃនឹង ម៉ោងពេលដែលក្នែកនោះត្រូវទ្ទាក់ រួចប្រាប់ថា "ប៉ើក្នែកស្ពាំ, ខ្ញុំអាចមើល ជាបាន, តែតំបៅនៅក្នែកឆ្ទេង មើលកម្រនឹងជាណាស់" ។

ប្រជាជនទាំងអស់នៅទីក្រុងបាប៊ីឡោនក៏ឆ្ពួញត្រេរអំពីដោគរាសនា នៃលោកហ្សាឌិត, មានចិត្តស្រប់ស្រេងចំពោះវេជ្ជសាស្ត្រនៃលោកត្រូពេទ្យ ហែរមែស ។

ពីរថ្ងៃក្រោយមក បូសនោះឆ្ទាយហើយលោកហ្សាឌិតក៏ជាសះស្បើយ ទៅ ។ លោកហែរមែសបានសរសេរសៀវភៅមួយបញ្ជាក់ ថាក្នែកនោះមិន អាចជាបានទេ តែហ្សាឌិតមិនបានអានសៀវភៅនោះឡើយ ។ លុះដល់ អាពាធជាសះស្ប្រួលបួលហើយ លោកចង់ទៅជួបនឹងស្ត្រីដែលជាទី ស្រឡាញ់របស់លោក ។

គំណត់នឹងប្រវត្តិការណ៍

ពិធីបុណ្យកតញ្ញូកតវេទិតា

ចំពោះសម្តេចព្រះធម្មលិទិតឧត្តមប្រឹក្សា ល្វី-ឯម

របស់សមណៈធិស្សិតពុទ្ធិកវិទ្យាល័យព្រះសុកម្រឹត

លោក ឯន-ប៉ង់ ប្រមូលរួបរួម

(តបប់)

ការរាវរកសេចក្តីសុខសេចក្តីបំរើនោះ មិនងាយនឹងរកបានដោយស្រួលទេ លុះណាតែស្វែងរកហេតុនឹងបច្ច័យរបស់នាមនឹងរូបឲ្យឃើញជាសការៈអ្វីហ្នឹ! ដែលជាហេតុប្បច្ច័យរបស់នាមនឹងរូបនោះ ហើយរំលត់ធមិដែលជាហេតុជាបច្ច័យនោះឲ្យបានរលត់សូន្យទៅ ទើបរកទៅប្រទះនូវសេចក្តីសុខសេចក្តីបំរើនមែន ។ ទាំងរាតាញាធិឈឺពើតចុកចាប់ ក៏បានសូប់ម្ចាប់ទៅឯង ។ ដូចជាត្រូតេទ្យបានឃើញរាតាពាធផ្សេង ។ ហើយបានស្វែងរកសមុដ្ឋានវិនរាតាពាធ ឲ្យឃើញពិតប្រាកដ ទើបផ្សំថ្នាំតម្រូវនឹងរាតនោះ ឲ្យត្រូវតាមហេតុប្បច្ច័យរបស់រាត ធ្វើឲ្យរាតនោះ។សូប់ម្ចាប់ទៅបាន ។

អស់លោកសមណនិស្សិតទាំងឡាយ!

បុណ្យកតញ្ញុតា របស់អស់លោកដែលបានធ្វើនេះ គឺបុណ្យកើតពីការនិមន្តសម្តេចព្រះមហាសុមេធាធិបតីសង្ឆនាយក - គណៈមហានិកាយ

មកសំដែងព្រះធម៌ទេសនាក្ត៉ន៌មន្តព្រះសង្ឆមកចំរើនព្រះបរិត្តក្ត៉ ន៌មន្តព្រះ
សង្ឆ ១៥០ អង្គមកទទួលចង្ហាន់បិណ្ឌបាតក្ត៉ ន៌មន្តលោកអាចារ្យ ទៀ-ជុំ
មកសំដែងធម៌ទេសនាបង្ហើយបុណ្យនេះក្ត៉ សម្តេចខ្ញុំ សូមធ្វើសច្ចកិរិយា
ទទួលកូមិបុណ្យកតញ្ញុតារបស់អស់លោក ជាសមណនិស្សិតទាំងឡាយ
ដែលបានធ្វើដោយពលវសទ្ធាដែលសម្ឆយុត្តដោយវិបស្សនាចិត្តជាកម្ចាំង
ហើយបានទទួលប្រគេនចំពោះខ្ញុំ ដោយនិយ្យាទនវាចាជាសច្ចៈ អម្សាញ់
មិញនេះ ជាសុទ្ធចិត្តដ៏ស្អាតរបស់អស់លោក ។

អស់លោកសមណនិស្សិត! សម្តេចខ្ញុំ បានធ្វើមនសិការៈ ចែមទៀត
ដើម្បីអធិដ្ឋានចិត្តថា: "បុណ្យកតញ្ញូកតវេទិតា ដែលក្រុមលោក
សមណនិស្សិតនៃពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ដែលបានធ្វើក្នុងពេល
នេះ ឆ្លរចាត់ទុកជាទិដ្ឋានុគតិដល់ពុទ្ធសាសនិកជន ដែលតែងនិយមរាប់
អានពោលសរសើរគ្រប់គ្នាថាជាបុណ្យមានទត្តមប្រយោជន៍ ហើយបាន
នាំគ្នាជ្រះថ្លាធ្វើទទួលជូនចំពោះ "បុព្វការី" ទាំងឡាយគ្រប់ ៗ គ្នា ជាប់
ជាទំនៀមទម្ងាប់ហូរហែមកដល់សម័យនេះ តាមគម្ពីរក្សួនច្បាប់សាសនា
ប្រដៅថា: "ត្រូវតែធ្វើកុំខាន នឹងបានជលានិសង្សប្រើនជាអនេកគឺបាន
រួចចាកទុក្ខភ័យទុបទ្រពចនៃត្រគ្រប់យាំងនាបច្ចុប្បន្ននេះជាដើម" ។

ដោយហេតុបុំណ្ណេះហើយ សម្តេចខ្ញុំ មានការនឹកសង្ឆឹមចំពោះ
លោកសមណនិស្សិតទាំងឡាយ ដែលបានសិក្សាចេះដឹងវិជ្ជា ក្នុងផ្ទូវ
ព្រះពុទ្ធសាសនា ហើយបានប្រព្រឹត្តប្រដិបត្តិតាមធម៌វិន័យពុំមានខ្ចោះ

មុខជានឹងបានការចម្រុងចំរើនរុងរឿងដោយវឌ្ឍនធម៌ទៅមានសម័យ ដូច
ជាប្រទេសដទៃមិនខាន, ពួកប្រជានិកវដែលជាពុទ្ធសាសនិកអ្នកប្រុង
ក្រែបដញ្ជក់ បីតយកជាតិខ្លះជារសរបស់ពុទ្ធសាសនានឹងសព្វថ្ងៃគ្រប់យ៉ាង
ដែលជាសភាវៈសម្រាប់បំភ្លឺផ្លូវលោកខ្លួនមិនឲ្យស្គាល់ទុក្ខស្រួ តើនឹងទៅ
ក្រែបដញ្ជក់យកជាតិខ្លះជារសនោះទៀតឬ ឲ្យបានមកអំពី នរណា! បើគ្មានអ្នក
សម្រាំងចិត្តគំនិតប្រឹងសិក្សាប្រដិបត្តិឲ្យមានចំណេះយល់ថ្លៃថ្នូរឡើងទេ ធ្វើដូច
ម្តេចហ្ន៎! ព្រះពុទ្ធសាសនានឹងមានដំណើរគឿនលឿនទៅរួច នឹងទៅ
ជាសាសនាមានដំណើរតើម ។ ដូចអណ្តើកវាតាមផ្លូវទៅហើយឬ ? ។
ដូច្នេះ ការដែលបានដុះគឿនក្រើនរំលឹកដោយទុក្ខភាពដ្ឋានចិត្តរបស់ខ្ញុំមក
ប៉ុណ្ណេះ ដោយសេចក្តីជ្រះថ្លាចំពោះលោក ដើម្បីនឹងដឹកនាំលោកទៅរក
សេចក្តីគោរពព្រះពុទ្ធសាសនា ដែលមានទុក្ខាទុសាសនីប្រជាពុទ្ធជាប្រ-
មុខនៃសាសនាគ្រប់គ្រាន់ គួរបើងនាំគ្នាប្រតិបត្តិឲ្យបានជាសុក្រិត្យ ដោយ
យកចិត្តទុកជាក់ធ្វើសេចក្តីសង្រួម ដោយការមិនប្រមាទធ្វេសប្រហែស
ស្មារតី ក្នុងការណ៍យកចិត្តរបស់ខ្លួនទីមួយ ។ ដើម្បីជ្រោមជ្រែងជ្រោង
ព្រះពុទ្ធសាសនា ឲ្យបានអណ្តែតត្រសែតឡើងក្នុងលោកនេះឲ្យទៅជា
អគ្គសាសនៈដ៏ប្រសើរ ដោយសារការឈ្លាសវៃប៉ុនប្រសព្វរបស់អស់លោក
ជាបរមណានិសង្សតាំងពីឥឡូយ ដែលខ្ញុំបានធ្វើមនសិការៈអធិដ្ឋានចិត្ត
សង្រឹមទុកមកនេះរួចហើយ ឲ្យបានសមប្រកបតរៀងទៅ ។

ទីបំផុតនៃការខ្ជួលអំណរចំពោះបុណ្យកតញ្ញូតានេះ សម្តេចខ្ញុំបាន
តាំរិចិត្តប្រកបដោយមេត្តាករុណា បួងសួងសូមឲ្យអស់លោកដែលជា

សមណានិស្សិតពំនឡាយ បានប្រកបដោយពរ ៥ ប្រការ គឺអាយុ ១ វណ្ណ: ១ សុខ ១ ពល: ១ បដិភាណ: ១, ពរពំន ៥ ប្រការនេះ សូមឲ្យបានសម្រេចដល់សមណានិស្សិតពំនឡាយ គួរតាមសេចក្តីប្រាថ្នា គួរតាមបំណង បើសេចក្តីប្រាថ្នានៃអស់លោកយ៉ាងណាៗក៏សូមឲ្យបានសម្រេចយ៉ាងនោះៗ កុំបីឃ្ងៀងឃ្ងាតឡើយ ពំនសូមឲ្យលោកពំនឡាយមានសាមគ្គីរសរាប់រកគ្នា ស្រឡាញ់គ្នា កុំបៀតបៀនគ្នា កុំឲ្យមានរោគាព្យាធិគ្រប់យ៉ាងចូរឲ្យជាអ្នកមានទ្រព្យគឺវិជ្ជាសម្បទ ដែលជាគុណកំចាត់នូវសេចក្តីល្ងង់ខ្លៅ ឲ្យបាត់ទៅអំពីខន្ធសន្តាន ដរាបដល់បានទៅជាអគ្គបណ្ឌិតដ៏ប្រសើរក្នុងលោកនេះ ដោយតេជានុភាពនៃបុណ្យកតញ្ញូតានេះកុំបីខានឡើយ ។

* * *

សង្ពហ្ជាព្រះអាចារ្យ សុក-សាធៀម

ថ្វៃងក្នុងតាមនៃនិស្សិតពុទ្ធិកវិទ្យាល័យព្រះសុភម្រឹត

សូមគោរព

– សម្តេចព្រះធម្មលិខិតគ្តមប្រឹក្សា !

= ព្រះថេរានុត្តរពំនឡាយ !

សូមគោស

– អស់លោក-អ្នកសប្បុរសពំនឡាយ!

ខ្ញុំព្រះករុណា អាត្មាភាពពំនឡាយ មានសេចក្តីសោមនស្សរីករាយជាភិយ្យោភាព ចំពោះព្រះតេជព្រះគុណក្រុមជំនុំព្រះត្រៃបិដក, ព្រះតេជ

ព្រះគុណ សាស្ត្រាចារ្យពុទ្ធិកវិទ្យាល័យព្រះសុកម្រឹត ទាំងគ្រហស្ថទាំង
បព្វជិត មានព្រះតេជព្រះគុណចាន់ ហ្វាន់ វ៉ន់ជាប្រមុខនឹងអស់លោកជា
បុគ្គលិកក្រសួងធម្មការជាដើម ដែលទំមន្ទឹងនឹងអញ្ជើញមកជាកត្តិយស ក្នុង
ពិធីបុណ្យនេះ នឹងអស់លោក-អ្នកសប្បុរសជើងវត្តលង្កា ព្រមទាំង
ព្រះថេរានុត្ថេរៈកន្លងវត្តនេះជាដើម ។

ខ្ញុំព្រះករុណា អាត្មាភាពទាំងឡាយ សូមពិតខ្លួនឹងជំពប់ជា
លើកទី ២ អំពីប្រវត្តិហេតុនៃបុណ្យដ៏ទុឡភកៈ ដូចតទៅនេះ ៖

បុណ្យដែលបានកើតឡើងក្នុងពេលល្ងាចមុន នឹងពេលល្ងាចនេះជា
តំបន់ពីរ គឺកើតឡើងដោយខ្ញុំព្រះករុណាទាំងឡាយ ជាសិស្សពុទ្ធិក-
វិទ្យាល័យព្រះសុកម្រឹតនឹងសិស្សពុទ្ធិកឋបមសិក្សាខ្លះ ត្រង់អាចារ្យក្នុងគ្រួង
បានរួបរួមគ្នាផ្តួចផ្តើមប្រារព្ធធ្វើឡើង ដោយមានអស់លោក-អ្នកជួយទំនុក
បំរុងចង្អាន់ចំណីបានផង ដើម្បីប្រមូលកុសលដ៏ទុឡភកប្រគេនសម្តេច
ដែលកំពុងតែមានពេគាព្យាធិជាតុណា ចូលមករុកពន្ធទ្រានញាំញីដ៏
ជាន់ធ្ងន់ឲ្យព្រះកាយពលដល់ខ្លួវពុំឮលកាត ។

ខ្ញុំព្រះករុណាទាំងឡាយជាសមណសិស្ស, តាំងពីពេលដែលដឹងថា
សម្តេចមានជពាពធជាទម្ងន់ មានចិត្តកិតក័យព្រឺព្រួចជាកំយោកាត,
ព្រោះនឹកឃើញថា តុហ្ន! អ្នកថ្លាដ្ឋចំណាន ។ ដែលថ្ងាច់មានថ្លៃដែ
ក្នុងការរៀបចំព្រះពុទ្ធសាសនាឲ្យមានលេស្សីនៅកាន់វង្សនភាព ចេះតែ
មានឧបសគ្គ តែពេគាព្យាធិមកបៀតបៀន ធ្វើឲ្យលំបាកក្នុងព្រះទ័យ
ព្រោះការឈឺចាប់កន្ត្រាក់ក្នុងអង្គខ្លាំងពេក ។ យើងខ្ញុំព្រះករុណាជឹងពិត

ប្រាកដថា: ព្រះទ័យសម្តេចនៅជាប់ជំពាក់ខ្លឹងការរៀបចំព្រះពុទ្ធសាសនា ជាខ្លាំងបំផុត ដោយហេតុព្រះពុទ្ធសាសនាក្នុងប្រទេសយើងពុំទាន់ចាន រៀបរយនៅឡើយ សូម្បីពេលដែលសម្តេចអាពាធធ្ងន់ណាស់ហើយ ក៏នៅតែមានថេរដីកាខ្លឹងសិស្សគណ:ដែលនៅបំរើផ្ទាល់ អំពីការរៀប ចំព្រះពុទ្ធសាសនាឲ្យចាន់រុងរឿងតទៅអនាគតដែរ ។

ចំពោះដកពាធដ៏គារុណានៃសម្តេចសព្វថ្ងៃនេះ យើងមិនមានភ័យ ភ័យខ្លាចប៉ុន្មានទេ ថែមទាំងមិនអង្វរការលន់ខ្លួនទៀត ព្រោះយើងដឹង ច្រមទាំងចាំចាន់យ៉ាងច្បាស់ថា:ការចាស់ជរា, ការឈឺចាប់នេះ ជាការ ធម្មតារបស់លោក, តែងមានពាល់រូបមនុស្សសត្វ ទេព្តា មារព្រហ្មក្នុង ត្រៃភព ។ ប៉ុន្តែ យើងសូមអង្វរការ បន់ស្រន់បួងសួងចំពោះកុសលកស៊ី ដែលយើងចាន់ធ្វើពីល្អចមុនខ្លឹងល្អចនេះ ខុកជាទេវថដ៏ពិសិដ្ឋ ជួយ ច្រទ្រង់ទ្រមន្តគ្គតាំទ្រសម្តេចឲ្យមានព្រះជន្មាយុយឺនយូរ ទាំងពេតាពាធ ដែលចូលមកយាយីក្នុងព្រះអង្គ ក៏សូមឲ្យអំណាចកុសលនេះ ជួយកំចាត់ បង់កុំបីសេសសល់ឡើយ !

បពិត្រសម្តេច !:

ខ្ញុំព្រះករុណា ទាំងឡាយដែលនៅវត្តឆ្ងាយក្តី ក្នុងវត្តលង្កានេះក្តី មាន សេចក្តីស្តាយពន់ពេក ដោយពុំចានមកតាល់បំរើដកដល់ចំពោះសម្តេច ត្រប់ទំពក្រឹ ។ រឿងនេះខុកជាការធ្ងាំធ្ងន ឬជាកំហុសចំពោះ ខ្ញុំព្រះករុណា ទាំងឡាយ ។ ម្យ៉ាងទៀត, ក្រែងជួនជាខ្ញុំព្រះករុណា ទាំងឡាយ ចានប្រព្រឹត្តធ្ងាំធ្ងន់ពុំគួរគប្បីចំពោះសម្តេចដោយកាយ-វាចា-

ចិត្ត ។ ការលើសធ្នាំធ្ងន់ទាំងអស់នេះ សូមសម្ពេចមេត្តាប្រោសលោះ
លាត្រាប្រណីអភ័យទោស ដល់ខ្ញុំព្រះកុណាទាំងអស់គ្នា ក្នុងអវសាននេះ
ខ្ញុំព្រះកុណាមិនមានវត្ថុអ្វីវិសេសក្រៅពីបុណ្យកុសល ដែលខ្ញុំព្រះកុណា
បានធ្វើនេះទេ ដូច្នេះ បុណ្យនេះ ខ្ញុំព្រះកុណាសូមលើកប្រគេនសម្ពេច
ដោយទឹកចិត្តដ៏បរិសុទ្ធ ។

ជាពិសេស, សូមទ្ធិសព្រះរាជកុសលនេះ ថ្វាយព្រះកុណាជា
ម្ចាស់ជីវិតទាំងពីរព្រះអង្គនឹងសម្ពេចព្រះទបយុវរាជ សូមព្រះអង្គគង់នៅក្នុង
សិរីរាជសម្បត្តិជាសុខចំរើនតទៅ ទាំងពួកពលរដ្ឋទួទៅក្នុងប្រទេស ក៏សូម
ឲ្យបានសេចក្តីសុខ សេចក្តីចំរើន កុំបីឃ្ជ៉ងឃ្ជាតទ្បើយ ។

ដំណើរទៅកាន់ប្រទេសឥណ្ឌា

ក្នុងទិវាសបុណ្យពុទ្ធជយន្តី ព.ស. ២៥០០ គ.ស. ១៩៥៦

នៃលោក រ៉ាយ.ប៊ុក ក្រមការជើមខ្សែ

តាយន្តែកការផ្សាយសៀវភៅនៃក្រុមពុទ្ធសាសនបណ្ឌិតសួ,

ប្រធានសមាគមមិត្តពុទ្ធិកវិទ្យាល័យភ្នំពេញ

លោក រ៉ាយ.ប៊ុក រៀបរៀង

(តទៅ)

ថ្ងៃសុក្រទី ៣០ វិច្ឆិកា ម៉ោង ៩, ៣០ នាទី លោកអាចារ្យស្រី ពុលស៊ីភ័ដ ស្វាមីភេក៏ឋន្ទី កាន់លទ្ធិជេន បានអញ្ជើញគណៈប្រតិភូទៅរួមប្រជុំក្នុងមហាសភានៅតំបន់មស្ជីហាល ។

ក្នុងពេលនោះ អាចារ្យនឹងសាវ័កចាំងអស់យកសំពត់សរុំមាត់ ។ ខ្ញុំបានសួរអ្នកប្រែភាសាថា ហេតុម្តេចក៏ពួកកាន់លទ្ធិជេនយកសំពត់សរុំមាត់? អ្នកប្រែភាសាបានតបមកខ្ញុំវិញថា "ពួកជេនកាន់លទ្ធិអហឹសា, (ការមិនបៀតបៀនសត្វជាដរាប) បានជាឃុំមាត់ព្រោះខ្លាចក្រែងសត្វក្រពូចល្អិតហើរចូលមាត់ ។

ក្រោយលោកអាចារ្យថ្លែងសុន្ទរកថារៀបចប់អំពីលទ្ធិ "ជេន" ហើងចាំងអស់គ្នាក៏លែងត្រឡប់មកកាន់កោដនាគារវិញ ។

ម៉ោង ១០, ឯកឧត្តម សម-សារី ប្រធានគណៈប្រតិភូប្រចាំសកម្ពុជា, ព្រះតេជព្រះគុណព្រះវិនេវគន្ធ អ៊ីវ ពួត មេគណវត្តចាត់ដំបង, ព្រះតេជព្រះគុណធម្មវិត្រលោកាចារ្យ "កេត.តោ" វត្តបទុមវតី ជាសមាជិក នឹង

ខ្ញុំជាកៀវកែត្តិយសក៏បានទៅគោរពថ្វាយបង្គំនិងលោកមហាត្មគន្ធី ហើយបានទៅជួប "កជយាជ" នៅត្រើយខាងស្តាំទន្លេយមុនា ជាទីតាំងដ៏ធ្លាប់ដែលគេបានថ្វាយសពលោកមហាត្មគន្ធី ក្រោយដែលមានបុគ្គលបានធ្វើមនុស្សឃាជ ។

កជយាជជាទីធំទូលាយពន់ពេក មើលជាច់កន្ទុយភ្នែក ។ យើងទៅជួបគ្នាមក៏នាំគ្នាដោះស្បែកជើង, ទើបយកកម្រងផ្កាទៅដាក់លើថ្វាយបង្គំនិមន្តព្រះភិក្ខុចាំងពីរូបសូត្រព្រះសត្តុបកណាភិធម្ម ។

ម៉ោង ១១ ខ្ញុំនិងអ្នកប្រែភាសា, ភិក្ខុ ភ័ - យ៉ាវ សមណនិស្សិតជាតិខ្មែរ ដែលសមាគមមិត្តភាពខ្ញុំកៀវលើយបញ្ជូនឲ្យទៅរៀននៅវិទ្យាល័យនាលន្ទាបានទាំងគ្នាទៅទស្សនាវដ្តសតា ។ វដ្តសតានេះ ស្ថិតនៅក្នុងព្រៃធំមួលធំសម្បើម ហើយខាងក្នុងមានវត្ថុកាន់និងទីតាំងខ្លួនជាវត្ថុមួលសម្រាប់តំណាងភក្ត្រអង្គុយជំនុំ ។

ម៉ោង ១៧,៣០នាទី, លោក ជូ-អេនឡាយ នាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស នៃប្រទេសចិនប្រជាមានិត, បានរៀបពិធីទទួលភ្ញៀវតណៈប្រតិភូនានាប្រទេសនៅតំបន់កំលាំងឡាត្រូន ។ នៅទីនោះ, លោក ជូ-អេនឡាយបានថ្លែងសុន្ទរកថាជាភាសាចិន, មានចិនម្នាក់ជាអ្នកប្រែភាសាចិនមកជាភាសាអង់គ្លេស ។ លំដាប់តមក, លោកបណ្ឌិត នេហ៍រូ បានសូត្រសុន្ទរកថាមួយតបនឹងលោក ជូ- អេនឡាយវិញ ។ តមក, មានការលៀងទំពីតែ ជាកិច្ចបញ្ចប់ ។

ថ្ងៃសៅរ៍ ទី១ធ្នូ ម៉ោង ៤ រសៀល, ខ្ញុំនិងអ្នកប្រែភាសាត្រម-

តាំងតំកុ ភ៌-យ៉ាវ ជានៅកាន់មន្ទីរស្តីការនាយករដ្ឋមន្ត្រី ដើម្បីជួបនឹង លោកបណ្ឌិត នេហ៊ូ ។ ខ្ញុំបានថ្លែងសុន្ទរកថានៅទីនោះជាភាសាចិន រៀបរាប់អំពីរឿងប្រវត្តិសាស្ត្រប្រទេសឥណ្ឌា ដោយសង្ខេប ។ ខ្ញុំបានបញ្ចប់សុន្ទរកថានោះដោយពាក្យថា "ប្រទេសកម្ពុជានិងអព្យាក្រឹតដូចប្រទេសឥណ្ឌាជានិងប្រតិបត្តិតាមគោលប្រាំ ។ ដូច្នេះប្រទេសកម្ពុជានិងប្រទេសឥណ្ឌា ត្រូវគាំទ្រដៃគ្នាដោយមេត្រីភាព, ភាតរភាព ដើម្បីនិងធ្វើអព្យាក្រឹតរបស់យើងឲ្យមានសភាពរឹងប៉ឹងទៅអនាគត ព្រមទាំងរក្សាសន្តិភាពលោក ដោយប្រើមធ្យោបាយដ៏ប្រពៃ" ។

លុះថ្លែងសុន្ទរកថាចប់ហើយ ខ្ញុំក៏បានជូនដល់លោកនេហ៊ូ នូវសំពត់ហូលដែលជាំក់រូបគំនូរពុទ្ធប្រវត្តិមួយផ្ទាំង ព្រមទាំងបានកែអក្សរថា: "អំណោយសមាគមមិត្តពុទ្ធិកវិទ្យាល័យ ចំពោះបុណ្យពុទ្ធជយន្តីប្រទេសឥណ្ឌា" ១, ព្រះពុទ្ធរូបក្នុងដែលសមាគមជូនចំពោះលោកនេហ៊ូ ១, និងរូបថតលោកនេហ៊ូកាលលោកអញ្ជើញមកទស្សនាប្រទេសកម្ពុជា ១ ។ បណ្ឌិត នេហ៊ូ ក៏បានទទួលវត្ថុទាំងនោះដោយចិត្តសោមនស្សជាយ៉ាងក្រៃលែង ។

ថ្ងៃអង្គារទី៣ទី ២ ធ្នូ ម៉ោង ១០, សម្តេចជាវ្ឈ្ឈាមា៉ នឹងសម្តេចបញ្ចឈ្ឈាមា៉ក៏បានទៅព្រះកុដិសង្ឃនាយនៅអសោកាភម ដោយមានគណៈប្រតិភូនានាប្រទេសបានអញ្ជើញទៅរួមប្រជុំជាមួយផង ។ សម្តេចជាវ្ឈ្ឈាមា៉នឹងសម្តេចបញ្ចឈ្ឈាមា៉បានមានព្រះបន្ទូលមួយអង្គម្នាក់ ។ រួចក៏ប្រគេនចង្ហាន់ចំពោះព្រះកុដិសង្ឃ ។

យោបល់របស់ខ្ញុំ:

ទីក្រុងដែលហ្គាស់ មានកំពែងលាបថ្នាំពណ៌ក្រហម, កំពែងនេះ ជាកន្លែងនៃការថ្កោលទោសរបស់ពួកសន្តតាវ៉ូ មោគោល ។ នៅខាងក្នុងកំពែង មានព្រះបរមរាជវាំងនៃស្តេចព្រះនាមជហាំ មានទីសម្រាប់ប្រជុំពីរដែលមានសសរសរសួន, មានជញ្ជាំងខ្ពស់ជាងគេជាងគេ នាំឲ្យពួកទេសចរមានចិត្តរំភើបជាខ្លាំង ។ នៅលើជញ្ជាំងខាងក្នុង មានចារឹកជាវចនាប៉ែរ្សថា: បើមានស្ថានសួគ៌នៅលើផែនដីនេះ ស្ថានសួគ៌នោះគឺនៅទីនេះឯង" ។ សិលាគ្រឹះ ឯទៀតដែលនៅកងកំពែងនោះគឺ វិមានម៉ាហាល, ក្រុងសាខាម៉ាម, វិហារមហាម៉តតជាង, វិមានមុមតាសម៉ាហាល ដែលមានពិពិធភណ្ឌ ស្ថានដំកល់ទុកសាវតារនៃសន្តតាវ៉ូ មោគោល ។

ចន្លោះពីកំពែង ទៅវិហារមហាម៉តហ្គាតេហ៍ម្ចាស់ មានតំបន់មួយហៅថា បណ្ណាល័យ ជាមជ្ឈដ្ឋានលក់តេនវត្ថុ គ្រឿងមាសប្រាក់គ្រប់យ៉ាង ។ នៅខាងស្តាំ មានវិហារមហាម៉តមួយនាមថា ជមាមស្ជីដ ដែលជាវិមានល្អបំផុតក្នុងចំណោមវិមានទាំងអស់ មានជណ្តើរបេតាជាំចំត្រ ចូលទៅដល់ទីលានជាំស្មើដែលមានទំហំ ៤១ ម៉ែត្រទទួលណា ។ ទីលាននោះគ្រាលដោយថ្មថ្ងាយក្រឹមហើយបញ្ចាំងថ្លែវ ។

ខាងស្តាំចំនួនខាងស្តាំឈៀងខាងលិច មានថូបដ្ឋានហ៊ុយម៉ាយុន,

វិមានថ្មបាយក្រៀមតណាកុឡាបមង្គុះថ្មកែវលាយចម្រុះល្អណាស់ ។ ក្រៅពីនេះ នៅមានប្រាសាទខ្នងឡាកាបាជ ទីធ្លាកំពែងជាល្អវិចិត្រ ព្រមទាំងថ្មបង្គន់នៃអ្នកកសាងប្រាសាទនេះ ។ ល្បើនិយាយឈ្មោះអ្នកម្ចាស់ណា ជាវិមានធ្វើពីថ្មបាយក្រៀមតាំងពីសតវត្សទី ១៦ នៃគ្រិស្តសករាជ ។

នៅជិតនោះ មានសសរជែកមួយមិនចេះប្រែជែលសាងតាំងពីសតវត្សទី ៨ នៃគ.ស. ។

ទីក្រុងជែល្បីថ្មី គឺក្រុង ញ្វាវជែល្បីនោះឯង, ក្រុងនេះមានសិលាសង់ជាគ្រែជួរស្មើ មានថែងធំៗភ្នាក់ខ្វែង មានក្បូជាតិផ្សេងៗដាំជាជួរតាមផ្លូវ ព្រមទាំងមានទ្វារធំៗ ។ វង្សសាស្ត្រនៅកន្លែងវិមានជែលមានសណ្ឋានមួលធំ ហើយមានទីអង្គុលសាធិការស្ថិតនៅកណ្តាលនៃថ្នល់តែមែ ជែលជាផ្លូវទៅកាន់មហាសណ្ឋាគារនៃប្រជានាធិបតី ។ ក្រៅពីនេះ មានព្រះវិហារលក្ខ្មីនាកយន៍ធីកជាជាជែលគេបូជាលោកមហាក្សត្រ ។

ក្នុងទីនោះ នៅមានគោញ៉ី(ព្រះគោ)ជែលគេយកទៅប្រសិទ្ធដោយទឹកអគ្គិបំពង់ខ្លួនៃលិង្គព្រះឥសូរធនិយោនាធ មាគោតវតែ អប់ដោយក្លិនបុប្ផាផ្សេងៗ ស្រោចស្រង់លើគោនោះ ហើយលែងឲ្យដើរតាមចិត្តក្នុងវិថីមុខគេហដ្ឋាន, តាណាំដ្ឋាន ព្រមទាំងមានស្នូមយាចកជាច្រើនឥតគណនា ។ ស្ត្រីពាក់សារីស្តើង មានពណ៌ស្រស់យ៉ាង, ប្រុសស្លៀកសំពត់សចងក្បិន ដណ្តប់ក្រមាំ ជូតក្បាលសំពោង ។

ថ្ងៃបន្ទ ទី៣ ធ្នូ ម៉ោង៨,៣០នាទី មានអាយស្មុយ

យានពាសេសមួយជូនគណៈប្រតិភូនានាប្រទេស ចេញពីទីក្រុងដែលល្ហៅទៅ
កាន់ទីក្រុងអង្គរៈ ។

ទីក្រុងអង្គរៈនេះ នៅលើស្នូនយមុនាជាកជនាតីពីអតីតកាល ។
ព្រះបាទបាបាវជាស្តេចគាត់ចាប់បានកំយុវណ្ហៀយកពីជនាតីនេះបានពីឆ.ស
១៩៦៦ ហើយយកបានតេជ្រគោហ៍ណ្ហរ ជារតនវត្ថុមានតម្លៃ ។ ព្រះបាទ
អត្តបាវជាព្រះពជបុត្រព្រះបាទបាបាវបានស្ថាបនាពជនាតីរបស់ព្រះអង្គនៅ
ទីនេះ ព្រនិបានតសាងកំពែងអង្គរៈឡើង ។

ដល់ម៉ោង១៣,៣០នាទី, យើងទាំងអស់គ្នាបានទៅដល់ទីក្រុង
អង្គរៈ ។ មានរថយន្តធំៗជូនគណៈប្រតិភូទៅកាន់ប្រាសាទតាហ៍ម៉ាហាល
ដែលស្តេចសាសព្រះនាម ជ ហាន់ បានសាងសម្រាប់ថ្វាយជាន់ព្រះអគ្គ-
មហេសីព្រះនាមមុមតាហ៍ ម៉ាហាល ។ ប្រាសាទនេះធ្វើពីថ្មកៃវែង ដោយ
កម្មករ២០.០០០នាក់, សាង៦៦ឆ្នាំទើបប្រួចស្រេច ។ ដល់ស្តេចសាស
ជហាន់សោយព្រះទិវង្គត គេយកសពនោះទៅដាក់ជាព្រះអគ្គមហេសី
ព្រះនាមមុមតាហ៍ម៉ាហាល ។ ថ្វាយជាន់នេះ, មានជញ្ជាំងគេថាក្តុរតនវត្ថុត្រង់យ៉ាង ដែលពួកអង់គ្លេសបានក់យចំណែកតាស់យកអស់គ្មានសល់ ។
លំដាប់តមក យើងបានទៅទស្សនាថ្វាយជាន់ព្រះបាទអ័ម៉ាជអ៊ុត·ដោ
លាហ៍ ជាឪពុកនៃព្រះអគ្គមហេសីព្រះនាងមុមតាហ៍ម៉ាហាល ។

ថ្ងៃអង្គារទី ៤ ធ្នូ ម៉ោង ៩·៣០ នាទី, មានរថយន្តធំៗ បាន
ជូនពួកគណៈប្រតិភូទៅទស្សនាប្រាសាទហ្គាគេហ៍ថូរស៊ីត្រ ។ នៅក្នុង
ប្រាសាទនេះ មានសាងថ្វាយជាន់លោក ម៉ហាម៉ាជ អលីយ៉ែម ស៊ីស្ត្រី ជា

មហាតុរំនៃស្តេចអគ្គវារ ។ ថ្ងៃបង្ហាននេះធ្វើពីថ្មកែវសៃ មានបញ្ចុះតជ
ង្ឍនភ្លឺច្រកត់តួរឡៃទស្សនា ។

ម៉ោង ១៤-៤០ នាទី, ពួកគណៈប្រតិភូនានាប្រទេសបាន៧៣
ទស្សនាថ្ងៃបង្ហាននស្តេចអគ្គបារដែរបើធ្វើពីថ្មកែវសដាំតជង្ឍនត្រមពាំងបញ្ចុះ
ត្បូងកែវ, តិចួរឬស្ងាំកាននផ្សែង ។ ។

ម៉ោង ១៦, យើងបាននធ្វើដំណើរទៅកាន់កំពែងអគ្គ: ។ ទៅទី
នោះគេបាននយើញព្រះបរមកដ្ឋាងស្តេចអគ្គបារ ។

ម៉ោង ៦៣, អយស្មើយយាននពិសេសបាននចេញពីទីក្រុងអគ្គ:ទៅ
កាន់ទីក្រុងសញ្ជៃ ។

ថ្ងៃពុធ ទី ៥ ធ្នូ ម៉ោង ៩-៩០ នាទី គណៈប្រតិភូបាននទៅដល់
ទីក្រុងសញ្ជៃ ។ មាននអស្សរជនជាច្រើននាក់មកទទួលគណៈប្រតិភូពុទ្ធ-
ជយន្តិ ។ បណ្តាអស្សរជនទាំងនោះ គេឃើញព្រះបញ្ញាទិសថេរៈអ្នក
ទទួលការៈចាត់ការខាងមហាតោធិសមាគមនៅសញ្ជៃ,ដុកទ័របត្តាតីសីតាភ័
មាំយ៉ាំ តំណាងថៅហ្វាយខែត្រមរ្យៈប្រទេស ដុកទ័រពាំលីស៊ូញ៉ាអគ្គលេខា-
ធិការមហាតោធិសមាគម ព្រមទាំងមហាជនប្រុសស្រីជាច្រើន ។

ក្រោយដែលបាននលៀងតែនំចំណី គណៈប្រតិភូខាងប្រទេសក៏បាន
ទៅរួមប្រជុំដើម្បីបញ្ចុះបថមសិលាឫក្សមហាតោធិសងឺវៃសៈ ។ ក្រោយ
ដែលបាននទទួលបញ្ចូសីល គណៈប្រតិភូទំនីទីប្រជុំក៏បានចាត់ព្រះអគ្គមហា
ធនីនីពីគណៈប្រតិភូប្រទេសថៃឡង់ ឲ្យថ្លែងសុន្ទរកថាបើកសម័យប្រជុំ ។

លុះដល់ម៉ោង ១១, ៧ នាទីព្រះអគ្គមហាសង្ឃធនីនីពីគក៏យកថ្មមួយដុំ ទៅ

ចញ្ចុះជាបឋមហើយច្រៀបព្រំស្រោចទឹកអបបុជ្ជា ជាមង្គលសិរីសួស្តី ។

ដល់ម៉ោង ១៤, ៤៩, មានការប្រជុំនៅមហាវិហារសញ្ជិ រួចគណៈប្រតិភូកំសូត្រសារលើទឹតមួងម្នាក់; ម៉ោង ១៧, មានការដង្ហែព្រះសារីរិកធាតុព្រះបរមសម្ពុទ្ធ នឹងព្រះធាតុនៃព្រះមោគ្គល្លាន ។ កន្លងពេលនោះព្រះបញ្ញាទិសវោះ: បានយកព្រះបរមសារីរិកធាតុមកជាក់លើក្បាលខ្ញុំ ដង្ហែយកមកដំកល់ទុក ក្នុងមហាវិហារ។

សញ្ជិ កន្លែងបញ្ចុះព្រះធាតុព្រះសារីបុត្រ នឹងព្រះមោគ្គល្លានស្ថិតនៅ ៤០ គីឡូម៉ែត្រពីទិសត្រកោចាល តាមផ្លូវអាយស្មុយយានពីបុមថៃ ៧ ខ្សែក្រុងដែលហ្គី ។ ស្តូបធំលើ ធ្វើពីថ្មប្រផេះ មានជាមវិជ្ជមាត្រ ៤៤ម.កំពស់ ១៣ម. ។ នៅជុំវិញទាំងក្រោម មានផ្លូវដើងក្រាលឥដ្ឋ មានរបាំងព័ទ្ធជុំវិញធ្វើពីថ្ម មានក្លោងទ្វារបួន ។ ក្លោងទ្វារនីមួយៗព្រមទាំងជញ្ជាំងមានក្បាច់ចំលាក់នឹងមានសិលាចារឹកខ្លះ ប្រើអក្សរគាំងពីសតវត្សទី ១-២ មុនគ.ស. ។ ក្លោងទ្វារគាំង ៤ ទិសនេះ មានសភាពវិសេសវិសាលណាស់ ព្រោះមានក្បាច់សិល្បៈថ្មដ៏រឿងពុទ្ធប្រវត្តិ នឹងរឿងព្រះបាទអសោក, សាងតាំងពី ២៥០ គ.ស ៤ ក ៣.ស. ។

ម៉ោង ១៩, គណៈប្រតិភូនៃបុណ្យពុទ្ធជយន្តិប្រទេសឥណ្ឌាបានបញ្ចប់ពីក្រុងសញ្ជិតាមអាយស្មុយយានពិសេស ។

ថ្ងៃព្រហស្បត្តិ៍ទី ៦ ធ្នូ ម៉ោង ១៣,៤០នាទី, យើងបានមកដល់ប្រជុំក្រុងបេណារេស(ពារាណសី)។ យើងចាំងអស់គ្នាបានឡើងរថយន្តដែលស្ថានកុងស៊ុលឧត្តរប្រទេសបានចាត់ទុកសម្រាប់តួកគ្រឿកគ្រឿយស តម្រង់ទៅ

ការន់ទីក្រុងសារណាត (ឥសីបត្នៈមិគ្គទាយវ៉ន) ។ នៅតាមផ្លូវពីក្រុង
ពារាណសី ទៅទីក្រុងសារណាត,យើងបានឃើញស្ពូបមួយហៅថាឱនឯ
ស្ពូបទីនេះហើយ ដែលព្រះបរមសម្ពុទ្ធជាម្ចាស់ ទ្រង់ស្តេចយាងមកជួបនឹង
បញ្ចវគ្គិយភិក្ខុ ។

មោឹង ១៨,១០ នាទី, យើងបានទស្សនាពិពិធកណ្ឌ ស្ថាននៅសារ-
ណាតដែលមានតាំងបុរាណវត្ថុផ្សេង ។ ព្រះពុទ្ធរូប, សរសរព្រះបាទ
អសោក, ទេវរូប, ព្រះវិស្ណុ, ព្រះឥសូរ, ព្រះក្រិស្ណៈជាដើម ។

មោឹង ១៨,៣០ នាទី,យើងបានទៅដល់មូលគន្ធកុដិវិហារ ។ ក្រោយ
ដែលបានដោះវិស្សកដើង, យើងទាំងអស់គ្នាក៏បានចូលទៅក្នុងវិហារ ។
ព្រះសង្ឆរតនៈក៏បានយកព្រះបរមសារីរិកធាតុមកជំកល់ពីមុខយើង, យើង
ទាំងអស់គ្នាក៏នមស្សការព្រះរតនត្រ៉យ ទទួលបញ្ចសីល ។ អ្នកកសាង
ព្រះវិហារនេះព្រះនាមអនាគារិក ធម្មបាលៈ។ លំដាប់តមក, យើងបានមក
ទស្សនាស្ពូបធម្មមេយ, ទីដែលព្រះសម្មាសម្ពុទ្ធបរមត្រូបានសំដែងធម្ម-
ចក្កប្បវត្តនសូត្រ ប្រោសបញ្ចវគ្គិយភិក្ខុ ។ ក្រៅពីនោះ មានស្ពូបធម្មរទិកៈ,
សសរដែលព្រះបាទអសោកកសាង ធម្មចក្រជិនវិហារ, ហិមចក្រជិន
វិហារជាដើម ដែលបាក់បែកទ្ធេចទ្ធីអស់ ។ បើតាមអ្នកឲ្យការម្នាក់ថាៈ ពី
ព.ស.១១៩៦ ឬ គ.ស.១៧៣៧, ទីក្រុងសារណាតនេះ ត្រូវមេទ័ព
មោគលឃ្មោះគុត្ស-ឧជ-ឯន ដែលមកធ្វើសង្ត្រាមនៅទីនេះបានវាយបាក់
បែកទ្ធេចទ្ធីអស់ ។

–ជនន៊ "ស្ត្រី.ការបង្កើតអក្សរ" ឥតបាកកា ។–ជ៉វក ឬ– ជ៉វិក ឬ–ជ៉វិន៊ "ប៉ុ. ឥនរស់នៅ" "គោយការសរសេរ", អ្នកនិពន្ធ ។–ត្ថូលិកា ស្ត្រី. ឥក់សម្រាប់សរសេរអក្សរ, ស្ទាបបាកកា ។ –ន្យាស ប៉ុ. របៀបព្យាត្ត, របៀបអក្សរ ។–មុ១ ប៉ុ. "ឥនមានមាត់ពេញហើយ គោយអក្សរ" សិស្ស, អ្នករៀន ។ –មុម្ធិកា ស្ត្រី. វិធីរៀបអក្សរគោយម្រាមដៃ (វិធីមួយបែបក្នុង ៦៤ កណសិ) ។ –វ៉ជ៊ិត , ត. ដែលមានអក្សររៀរហើយ, ដែលមិនបេះអក្សរ ។ –វិន្យាស ប៉ុ. របៀបអក្សរ ។ –ឥិក្យា ស្ត្រី. អក្សរវិធី ។ –សំស្ថាន ឧប៉ុ. ការសរសេរ, និពន្ធ៍ ។ –សមាំន្យាយ ប៉ុ. អក្សរ, វិណ្ណ: ។ –អក្សរាក្សរ ប៉ុ. សមាធ៊ ។

អក្សរា ស្ត្រី. សព្ទ, ពាក្យនិពន្ធ ។

អក្សរលាវិន ឧប៉ុ. អាហារមិនឆ្ងមិនប្រៃ ។

អក្សិ ឧប៉ុ. ភ្នែក ។ –ក្ខ, ប៉ុ. ថ្ងាស ។ –ឥត ត. ដែលពាំងនៅបំពោះភ្នែក ។ –ភោល ប៉ុ. ប្រស្រីនៃភ្នែក ។ –ជាហ, ឧប៉ុ. ឬសនៃភ្នែក ។ –តាភ, ស្ត្រី. បក្ខុតាភ ក្ខនក្រមុំនៃភ្នែក ។ –និកាណ៉ាម៊ ក្រិ. វិ. គោយការបិទពាក់ កណ្តាលនៃភ្នែក ។ –និរមម ប៉ុ. ក៉ិរ៉យាប្រប្រិបនៃភ្នែក; ស្របក ។ –បក្ស្ម៊ន ឧប៉ុ. ភេមនៃភ្នែក ។–បជល ឧប៉ុ. ត្របកនៃភ្នែក ។ –ជាត ប៉ុ. ក៉ិរ៉យារណកនៃភ្នែក ។ –ភេមជ ឧប៉ុ. ភេសឆ្ងដើម្បីភ្នែក ។ –ក្រុវ ឧប៉ុ. ភ្នែកនំងភេមបិត្ចើម ។ –មត, ត. ដែលមានភ្នែក ។ –ភោមន៊ ឧប៉ុ. ភេមនៃភ្នែក ។ –វិក្ខណ៉ាត, ឧប៉ុ. ក៉ិរ៉យា

ប្រឡេកគោយភ្នែកបន្ទាប់ពីកណ្តាល ។ -សំតដិន ន.ប. ឈ្មោះអក្សរក្នុងរឿងព្រេង ។ *អក្ស្រាមយ* ប. ដង្ហើមនៃភ្នែក ។ *អក្ស្រាមយិន* គុ. ដែលមានដង្ហើមនៃភ្នែក ។

អក្ស្រឹត គុ. ដែលមិនអស់ទៅ ។

អក្ស្រឹតិ ស្ត្រី, កិរិយាមិនអស់ទៅ ។

អក្ស្រឹណា គុ. ដែលមិនបាត់ ដែលមិនអស់ទៅ; ប. ក្មួនខែវិច្ឆិកា ត្រ ។ *តុខ្ញុ* គុ. ដែលមានទ្រាប់ជាមិនអស់ទៅ ។

អក្ស្ប៊ុណ្ណា គុ. ដែលមិនបែកបាក់; ដែលមិនដាច់; ថ្ម ។ -*ភា* ស្ត្រី. ភាវៈ កិរិយាមិនបែកបាក់ ។

អក្ស្ប៊ុទ្ធ គុ. ដែលមិនក្តួច; ដែលមិនសាធារណៈ ។

អក្ស្បែត្រ គុ. ដែលមិនមែនជាស្រែ; *អក្ស្ត្រែ* គុ. ដែលមិនមានស្រែ ។

អក្ស្បែម ន.ប. "ការមិនក្បែម" សេចក្តីទុក្ខ ។

អក្ស្បែជ ឬ **អក្ស្បែ**, ប. ឈ្មោះដើមឈើ ។

អក្ស្បែភ គុ. ដែលមិនញាប់ញ័រ, ដែលមិនកម្រើក ។ ប. ទីក្បែមក្បត្តមិនមានចលាចល, ទីមានចលាចលមិនមាន; ទីចងអំរ ។ *អក្ស្បក្ស*, គុ. ដែលមិនតឿកម្រើក; ប. តាមព្រះពុទ្ធ (ក្នុងសទ្ទិមភោយាន) ។

អក្ស្បែហិណាំ ស្ត្រី. អក្ខោភិនី, កងទ័ពដែលមាន ១០ អនីកិនី ឬ មានអំរ ២១.៨៧០, រថ ២១.៨៧០, សេះ ៦៥,៦១០, ទាហានថ្មើរជើង ១០៩.៣៥០ ។

អក្ស្ប ន.ប. ទ្វីបអាស្ន ។ *អក្ស្ណយាក្ខ្ញុត* គុ. ដែលធ្វើទុស; *អក្ស្ណយាទុស* ប. ប្រទេសដែលតាំងនៅជាប់ពីកណ្តាល; *អក្ស្ណយាទ្រុហ* គុ. ដែលទ្រុះទុស; *អក្ស្ណយាវង្ស*

ស្ត្រី. ឆ្មៃពុះកណ្តាល ។ *អក្ឈ្ណ* (ត្ឆ្ឌឌ្ឍ) ដោយទទឹង ។

អទណ្ឌ គុ. ដែលមិនបែក, ដែលមិនទ៍ណ្ឌ; ទាំងមូល, ទាំងដុល ។ *-ភល* គុ. (ព្រះប៉ន្ទ) ដែលពេញវង់ ។

អទណ្ឌិត គុ. ដែលមិនទ៍ណ្ឌ; ដែលមិនអន្តរាយ; ដែលមិនវិកវរ ។

អទរិ គុ. ដែលមិនតូច សំទាន់ ។

អទល ប៉ុ. (មនុស្ស) ដែលស៊ីធឹកហូសកំរិត ដែលហូសមាត្រា ។

អទាត គុ. ដែលមិនកបំក្នុងដី ។

អទាឡ គុ. ដែលមិនតប្ប៉ស៊ី ។

អទិន្ត គុ. ដែលមិនអស់កម្ចាំង ។

អទិល គុ. ទាំងអស់, ទាំងដុល ។ *-លោកនាថ*, ប៉ុ. "អ្នកទីពឹងនៃលោកទាំងមូល" ព្រះវិម្ណុ ។ *អទលាត្ថនិ* ប៉ុ. "អ្នកមានអាត្ថ៍ទទាំងអស់" ព្រះព្រហ្ម ។

អទេទ ប៉ុ. ការមិនអស់កម្ចាំង ។

អទ្យាត គុ. ដែលមិនល្ប៉, ដែលមិនស្គាល់ ។

អគ ប៉ុ. ឈើ, ភ្នំ; ចំនួន "ឧ" ។ *-ជ* គុ. ដែលកើតពីឈើ ឬ ពីភ្នំ, អរញ្ញវាសី; អគា ស្ត្រី, នាមព្រះបវិតី ដាស៉ក្តិព្រះដស្សរ, ដាធិតានៃភ្នំហិមាល៉យ ។

អគណ គុ. ដែលមិនមែនដាគណៈ ។

អគណិត គុ. ដែលមិនរាប់; ដែលមិនពោលដល់ ។ *-ប្រតិយាត* គុ. ដែលត្រឡប់វិលវិញព្រោះគេមិនរាប់រក ។ *-លជ្ជ* គុ. ដែលអៀនព្រោះគេមិនរាប់រក ។

អគណ្យ គុ. ដែលមិនគប្បីរាប់, ប្រើន ។

អគត គុ. ដែលមិនទៅ ។

អគតិ ស្ត្រី. អគតិ, ការទៅមិនដល់, ដំណើរវៀកវេ, ដំណើរល់អៀង ។ – *គា*, ស្ត្រី. ភាវនៃសេចក្តីល់អៀង ។

អគតិក គុ. ដែលអស់ចំណេះ, ដែលផុតវិស័យ ។

អគតីក គុ. (ផ្ទូវ) ដែលប្រើប្រាសមិនបាន ។

អគទ ឃុំ. ការមានជម្ងឺមិនមាន, សុខភាព; ញ្ជាំកែរោត; គុ. ដែលសុទស្រួល ។ – *អគទំការ* ឃុំ. ពេទ្យ; *អគទវេទ*, ឃុំ. វេទ្យសាស្ត្រ ។

អគម គុ. ដែលមិនកំរើក, ដែលកំរើកមិនបាន; ភ្ជំ.ដើមឈើ ។

អគម្ម គុ. ដែលបុគ្គលមិនគប្បទៅ, ដែលបុគ្គលមិនគប្បីគប់; ដែលបុគ្គលគប្បីយល់បាន ។ – *គា* ស្ត្រី. ស្ត្រីគឺបុរសមិនគប្បីគប់ ។ – *រូប* គុ. ដែលមានរូបគឺបុគ្គលគប់មិនបាន ។ – *អគម្យាគមន*, នឃុំ. កិរិយាគប់ម្ចយអន្ធើដោយស្ត្រីគឺបុគ្គលមិនគប្បគប់ ។

អគហ៊ិត គុ. ដែលបុគ្គលគេះដៀលមិនបាន ។

អគស្ត្យ ឃុំ. នាមឬសិដាបុត្រនៃមិត្រនឹងវរុណ, នាមព្រះសិវ ។ – *គីតា* ស្ត្រី. គីតាសម្រាប់ព្រះអគស្ត្យ ដែលកើតទៅដាឈ្មោះតម្ពីរឈ្មោះអាទិភាហបុរាណ ។ – *ចារ* ឃុំ. ផ្ទូវនៃព្រះអគស្ត្យ ។ – *តីថិ* ឃុំ. នាមហនសក្តិសិទ្ធិ ។ – *មាតិ* ឃុំ. ផ្ទូវនៃព្រះអគស្ត្យ ។ – *សំហិតា*, ស្ត្រី. នាមគម្ពីរទាងលទ្ធិតន្ត្រៈ ។ – *វដ* ឃុំ. នាមហនសក្តិសិទ្ធិ ។ – *ឆាស្ត*, គុ. ដែលត្រប់ត្រងដោយព្រះអគស្ត្យ ទាងទក្សិណ ។ *អគស្ត្យាទយ*, ឃុំ. កិរិយារះឡើងនៃព្រះអគស្ត្យ; ថ្ងៃទី ៣ នៃពាក់កណ្តាលទីពីរនៃព្រះភាទ្រៈ ។

(មានត)

ពន្ធុលសុទិយា

ទស្សនាវិដ្ឋី ផ្សាយជំណឹងទាងសាសនា នឹងអក្សរសាស្ត្រ



ឆ្នាំទី ២៩ លេខ ៤ ខែមេសា ព.ស. ២៥០០ គ.ស. ១៩៥៦



ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បញ្ជីរឿង	ទំព័រ
– ជីវកថា	ព្រះមហា ភ.ឃ័រ	. . ៣៤៣
– មនុស្ស-៤ពួក	ឃុនបណ្ណានុរក្ស ប៊ូ-ប៊ូ	. . ៣០៧
ផ្នែកអក្សរសាស្ត្រ		
– រឿងទេវនែរបស់អម្រឹតសូត្រម៉ឺក . . . . (តមក) .	លោកញ៉ឹក-ថែម ពិនិត្យ	. ៣៤២
– សុភាសិតប្រៀបធៀបប្រុសស្រី (តចប់)	ព្រះយោសធម្ម ម៉ឺង-សៃស	. ៣២៤
– ពេទ្យព្រះរាជា (តចប)	លោក ស៊ុន-ហ៊ែន ប្រែ	. . ៣៣៤
– រឿងសាមកុក (តមក)	ឯកញ៉ា ទួ-កន ប្រែ	. . ៣៤៣
– រឿងហ្សាតិត	លោកវ័យ - ប៊ុក ប្រែ	. . ៣៥២
កំណត់ទំនឹកប្រវត្តិការណ៍		
– ដំណើរទៅកាន់ប្រទេសតិណ្ឌៀនៃលោក វ័យ-ប៊ុក (តមក) .	លោកវ័យ-ប៊ុក	៣៥៨
– ព្រឹត្តិការបុណ្យ ព.ស. ២៥១០	ក្រសួងធម្មការ	៣៦៦
– កម្មវិធីបុណ្យ ព.ស. ២៥១០	ក្រសួងធម្មការ	៣៧២
– វចនានុក្រមសំស្ក្រឹត-ខ្មែរ . (តមក).	ព្រះ ភិក្ខុ ប៉ាង-ខាត់	. . ៤០០

មួយឆ្នាំមាន ១២សៀវភៅ–តំលៃជាវ ៤៣០រៀល

KAMBUJASURIYA

Revue religieuse et littéraire éditée par
l'Institut Bouddhique

TABLE DES MATIÉRES

PARTIE RELIGIEUSE:

-Jayakatha . . . . . par vén. VAR-YAO. 303
-Les quatre catégorie d'hommes. . . . . par M. BOU-PO 307

PARTIE LITTERAIRE:

-Histoire de Devanda de M. MOK,
revue et corrigée (suite et fin) . par M. NHOC-THEM. 312
-Bons Conseils (suite et fin) . . . . . par vén. MŒUNG-SES . 324
-Conte "LE DIAMANT DE RAJA" (suite) traduit par M. SIN-HEAN 334
-Histoire de Samkok (suite) . . . . . traduit par M. NOU-KAN .. 343
-Histoire de Zadig . (suite) . . . . . traduit . par M. RAY-BUC ... 352

NOTES ET CHRONIQUES:

-Voyage en Inde de M. RAY-BUC (suite) . . par M. RAY-BUC . 358
-Plan de la Fête de 2.500 ans de l'Ere Boudhique . Ministère des Cultes 366
-Programme de la Fête de 2.500 ans de l'Ere Bouddhique.
Ministère des Cultes 382
-Dictionnaire Sanskrit - Khmer (suite) . . . par vén. PANG-KHAT . . . 400

Prix d'abonnement annuel (comprenant 12 numéros): 230$00

ផ្នែកសាសនា

ជយកថា

ដោយ ព្រះមហាវ៉ា-យ៉ាវ សមណៈនិស្សិត

នៅវិទ្យាល័យនាលន្ទា ប្រទេសតណ្ឌៀ

សូមនមស្សការចំពោះព្រះសម្ពុទ្ធជាបរមត្រូ ដែលជាត្រូវនៃទេវតានឹងមនុស្សទាំងឡាយ ព្រះអង្គប្រកបដោយធម្មណ្ណរង្សី ទ្រង់ត្មានមន្ទិលសៅហ្មង ព្រោះព្រះអង្គបានខ្ជាក់ចោលហើយនូវធមិដឹលាមក ព្រះអង្គមានសេចក្តីអាណិតអាសូរដល់ពួកសត្វនិកមិនបានរើសមុខ, បានជួយស្រោចស្រង់សត្វដែលលិចចុះទៅក្នុងអន្ទង់អកុសល ។

បន្ទាប់ពីនេះ ខ្ញុំនឹងដកស្រង់យកតាថាអំពីមហាសាតរសូត្រ ដែលជាធមិអាចនាំសត្វទៅកាន់ជោគជ័យ ដូចតទៅនេះ:

១- សេចក្តីមិនប្រមាទ, សទ្ធា, ព្យាយាម, ចិត្តនឹងនួន, ការប្រតិបត្តិតាមពុទ្ធាវាទ, ការសេពគប់នឹងសប្ប្សរស, ធមិទាំង ៦ នេះ ជាធមិនាំសត្វទៅកាន់ជោគជ័យ ។

២- ទាន, វិន័យ, ការឈ្នះខ្ជូនឯង, ខន្តី, សប្ប្សរិសធមិ, អហឹសា, មេត្តា, សុខ, ការលះបង់កំណាញ់ នេះជាមធ្យាបាយសម្រាប់ទៅកាន់ជោគជ័យ ។

៣- ចំណងពាលចម្រើនជានិរន្តរ៍, ចំណែកបណ្ឌិតដែលប្រព្រឹត្ត

ធ្វើកម្មកុសលដោយកាយវាចាចិត្ត មុខជានឹងបានដោតជ័យ ។

៦- បើបានពិចារណានូវផលនៃអប្បមាទធម៌ ហើយធ្វើចិត្ត ឲ្យប្រព្រឹត្តតាមអប្បមាទធម៌នោះ នឹងបានដោតជ័យ ។

៥- អ្នកណាបានធ្វើទាន, រក្សាវិន័យដ៏ហ្មត់ចត់ ហើយមាន ព្រហ្មវិហារធម៌ចំពោះសត្វលោកទាំងអស់, អ្នកនោះនឹងបានដោតជ័យ ។

៦- បុគ្គលដែលបានប្រព្រឹត្តសប្បុរិសធម៌ នឹងព្រហ្មវិហារធម៌, បានសម្ចាប់នូវតណ្ហាហើយជួយសង្រ្គ្រោះអ្នកដទៃ, ការធ្វើដំណើរទៅកាន់ដោតជ័យនៃបុគ្គលនោះ នឹងអាចសម្រេចបានដោយធាប់រហ័ស ។

៧- អ្នកដែលមានចិត្តសន្តោសហើយមានអប្បមាទធម៌, អ្នកដែល មានចិត្តអាណិតអាសូរដល់សត្វលោកទាំងអស់, អ្នកដែលរលាស់ខ្ជនចេញចាកវាតាទិកិលេស; ការធ្វើដំណើរទៅកាន់ដោតជ័យនៃអ្នកនោះ នឹងអាចសម្រេចបានដោយធាប់រហ័ស ។

៨- ជនណាដែលគ្មានសត្រូវ, គ្មានចិត្តអាក្រក់ ជាអ្នកប្រឹងរលាស់ ខ្ជនចេញចាកវាលវដ្តសង្សារ; ដំណើរទៅកាន់ដោតជ័យនៃអ្នកនោះ នឹង អាចសម្រេចបានដោយធាប់រហ័ស ។

៩- ជនណាដែលមានចិត្តនឹងនួន, ដែលស្រឡាញ់ត្រេះធម៌នឹង ការឲ្យទាន, ដែលដោះខ្ជនរួចពីកណ្តាប់ដៃនៃលោភៈ នឹងសេចក្តីប្រណែន, ជននោះឯងនឹងបានសម្រេចដោតជ័យដោយធាប់រហ័ស ។

១០- ជនណាដែលរឹតត្បិតខ្ជនឯង, ដែលសុខស្រួល, ដែល ពេញចិត្តគោរពនូវរៀមច្បង, ដែលស្គាល់វិធានការត្រូវធ្វើនឹងមិនត្រូវ

ធ្វើ, ការពាន់ជោគជ័យនៃជននោះ នឹងសម្រេចដោយធាប់ហ័ស ។

១១-ជនណា មានចិត្តស្មោះត្រង់, ចេះគោរព, មានវាចាស្រទន់ផ្អែម ស្ហែម, ជាអ្នកបំពេញវិបស្សនាធុរៈនឹងគន្ធធុរៈ, ការពាន់ជោគជ័យនៃ ជននោះ នឹងសម្រេចដោយធាប់ហ័ស ។

១២- ជនណា ដែលចេះលៃពេលនឹងទិកន្ទៃងដ៏សមគួរ ដើម្បីប្រកប ការកុសល, ដែលស្គាល់ច្បាស់ទូវរបស់គួរធ្វើនឹងមិនគួរធ្វើ ហើយដឹងខ្ជួន ចាខ្ជួនមានសមត្ថភាពប្ដត្មាន; ការពាន់ជោគជ័យនៃជននោះនឹង សម្រេចដោយធាប់ហ័ស ។

១៣- ការខឹងត្រូវសម្ងាប់ដោយការមិនខឹង, ការកាចត្រូវតស្ងិ ដោយខន្ត៊ី, ទុច្ចរិតត្រូវតយុទ្ធដោយសុចរិត, ឆន្ទឹតត្រូវបំផ្ទាញដោយពន្ធឹ ។

១៤- កុហកត្រូវផ្ទាញ់ដោយសច្ចធមិ, ការពោលពាក្យផរុសវាទ ត្រូវ តស្ងិដោយការសង្ស្ងមឥន្ត្រិយ, ពាក្យអាសត្រាមត្រូវបំបាត់ដោយចិត្តស្ងូត ត្រង់, ចំណងត្រូវកាត់ផ្តាច់ដោយការត្មានចំណង ។

១៥- ការប្រមាទជល់ជីវិតសត្ងលោក ត្រូវធ្វើឲ្យវិនាសដោយចិត្ត សប្ជុរស, សេចក្តីកំណាញ់ត្រូវផ្ទាញ់ដោយការឲ្យទាន, ការប្រុងប្រយ័ត្ន អាយតនៈខាងក្រៅ ត្រូវតស្ងិដោយការប្រុងប្រយ័ត្នអាយតនៈខាងក្នុង ។

១៦- អវិជ្ជាត្រូវផ្ទាញ់ដោយវិជ្ជា ជូចជាស្រមោលត្រូវយកថ្ងៃពៅ ផ្ទាញ់ជូប្ទោះ, ប្ដថ្ងៃ ១៥ រោច ត្រូវយកថ្ងៃ១៥កើតពៅផ្ទាញ់ ។

១៧- តណ្ហាត្រូវយកប្រាជ្ញាពៅផ្ទាញ់; ឆៅក្នុងជ្ជូវអាក្រក់ ត្រូវយក អជ្ឌង្គិកមត្តពៅផ្ទាញ់ ។

១៨- ការមិនអស់អាចត្រូវផ្ទាញ់ដោយការក្ខាហាន; សេចក្តីក្ខេចក្ខាំន ត្រូវផ្ទាញ់ដោយខំចងស្មារតី ។

១៩- បុគ្គលដែលលស់លិចទៅក្នុងអកុសល ត្រូវផ្ទាញ់ដោយ បំពេញបុណ្យកុសល ប្រៀបដូចជាភ្នំ មានព្រៃជាក្សាំងម្ពុជ ត្រូវយក ភ្នំព្រះសុមេរុមកផ្ទាញ់ ។

២០- ចិត្តឃ្ងងឃ្ងាង ត្រូវយកចិត្តនឹងន្ធនមកផ្ទាញ់, សេចក្តីក្រ ខ្សត់ទ្រព្យត្រូវយកញ្ញាយាមរកទ្រព្យសម្បត្តិមកផ្ទាញ់, សេចក្តីកាចត្រូវយក សេចក្តីស្ងូតមកផ្ទាញ់, សេចក្តីខុសភាន់ប្រលំត្រូវយកសច្ចធមិមកផ្ទាញ់ ។

២១- សេចក្តីមិនពិត ត្រូវផ្ទាញ់ដោយធមិពិត, ដូចជាអុសតែងតែ ភ្លើងឆេះ; ដូចការស្រេកត្រូវផ្ទាញ់ដោយទឹក, ការឃ្ងានត្រូវផ្ទាញ់ដោយ អាហារ ។

២២- ការអាណិតអាស្សរជាធមិដ៏ប្រសើរ; ការមិនអាណិតអាស្សរ មិនមានអ្នកណាសរសើរឡើយ; ហាមភាពមានដោតជ័យជានិរន្តរ៍, ការទន់ ខ្សោយនាំឲ្យចម្រើនន្ធូវមោហ: ។

២៣- បុគ្គលដែលមានសកម្មភាពកាចសាហាវ, ហើយប្រើនភូតភ- កុហកត្រូវផ្ទាញ់ដោយ ប្រាជ្ញា ។

២៤- បុគ្គលដែលជាមិច្ឆាទិដ្ឋិមានពាក្យសំដីអសប្បុរសត្រតោះបោក ប្រាះ ត្រូវផ្ទាញ់ដោយព្រះសម្មាសម្ពុទ្ធ, ដូចជាញ្ជកអសុរាត្រូវផ្ទាញ់ដោយ ព្រះអាទិទេព, នេះជាបទបញ្ញត្តិសម្រាប់ទៅកាន់ដោតជ័យ ។

មនុស្ស ៤ ពួក

យុនបណ្ណៈនុវក្ស ប៊ូ-ប៉ូ

ប្រៀបរៀត

ក្នុងដីកាមាលេយ្យសូត្រមានសំដែងថាមនុស្សក្នុងលោកនេះ ចែកជា ៤ ពួកគឺ

១- មនុស្សប្រេត	(មនុស្សបេតោ)
២- មនុស្សតិរច្ឆាន	(មនុស្សតិរច្ឆានោ)
៣- មនុស្សនរក	(មនុស្សនេរយិកោ)
៤- មនុស្សមែនទែន	(មនុស្សគូតោ) ។

អធិប្បាយ: មនុស្សដែលមានរូបកងកាយពិកលពិការ តែងដើរសូមទានតេស៊ី អត់ឃ្ងានលំបាកវេទនា មានអាការដូចប្រេតហៅថា មនុស្ស-ប្រេត ។ មនុស្សអនាថាឥតមានចំណេះវិជ្ជានឹងទ្រព្យសម្បត្តិជាទីពឹងអាស្រ័យបិញ្ជឹមជីវិតតែដោយសារតេ មានអាការដូចសត្វតិរច្ឆានហៅថា មនុស្សតិរច្ឆាន ។ មនុស្សមានចិត្តកាចអាក្រក់វាយកាប់សម្ងាប់គេ ល្មួចប្ងន់គេ ត្រូវរាជការធ្វើទោសជាក់គុកច្រវាក់រងទុក្ខវេទនាដូចជាសត្វនរកហៅថា មនុស្សនរក ។ មនុស្សប្រព្រឹត្តល្អ មានចិត្តស្ងូតបូតសប្បុរសព្យាយាមឲ្យទានរក្សាសីល ចំរើនភាវនា មិនប្រមាទ ហៅថា មនុស្ស-មែនទែន ។ គាថារ្យទ្ធះពោលថា អ្នកដែលមានសេចក្តីអៀនខ្មាស់អំពើអាក្រក់ ហៅថា មនុស្សទេវតា (មនុស្សទេវៅ) ។

បន្ទាប់អំពីនេះទៅ ខ្ញុំសូមនាំរឿងមនុស្សនរកនឹងមនុស្សទេវតាមកចុះក្នុងទីនេះ ដើម្បីជាផ្ទូវពិចារណានៃសាធុជនជូចតទៅនេះ ៖

រឿងមនុស្សនរក

កាលពីព្រេងនាយ មានពួកចោរជាច្រើនសំណាក់នៅក្នុងដងព្រៃមួយជិតស្រុកបច្ចន្តគ្រាម ក្នុងដែនរបស់ព្រះបាទពារាណសី ។ ព្រះមហាក្សត្រទ្រង់តាំងអមាត្យម្នាក់ឲ្យនៅក្សរដងព្រៃនោះ ដើម្បីនឹងកំចាត់ចោរផងជួយនាំផ្ទូវជូនអ្នកដំណើរកាត់ព្រៃផង ។ រាជអមាត្យនោះតែងជូនអ្នកដំណើរឲ្យឆ្ងងព្រៃទៅមកឲ្យផុតដងព្រៃនោះ ។

ត្រានោះ មានបុរសម្នាក់នាំប្រពន្ធរូបល្អស្រស់ជិះរទេះតូចមួយបរទៅដល់កន្ទងនោះ ។ រាជអមាត្យបានឃើញប្រពន្ធរបស់បុរសនោះល្អ ក៏កើតចិត្តប្រតិព័ទ្ធស្នេហា ។ កាលបុរសអ្នកដំណើរនិយាយអង្វរឲ្យជូនទៅ រាជអមាត្យប្រកែកថា ទេ ហួសពេលហើយ ព្រឹកសឹមខ្ញុំជូនអ្នកទៅ ។ បុរសដំណើរចេះតែទទូចអង្វរថា សូមលោកអាណិតមេត្តាជូនខ្ញុំទៅមួយភ្ងៃតចុះ ។ រាជអមាត្យល្បួងថា អ្នកឯងប្រញាប់អ្វីម្ទេះ អ្នកឯងទៅដេកនៅផ្ទះខ្ញុំមួយយប់សិន បាយចំណីក៏មានស្រាប់ ។ បុសនោះមិនព្រមទៅសោះ ។ ស្រាប់តែរាជអមាត្យប្រើមនុស្សឲ្យអូសរទេះយកទៅដាក់ក្សរមាត់ទ្វារផ្ទះខ្ទួន ហើយរៀបកន្ទងឲ្យដេក ឲ្យបាយបរិភោគ ។ ឯក្នុងផ្ទះរាជអមាត្យនោះមានកែវមណីមួយ ។ រាជអមាត្យឲ្យមនុស្សយកកែវមណីនោះទៅដាក់ក្នុងរទេះបុរសនោះ លុះជិតភ្ងឹក៏ស្រែកធោទ្បោថា ចោរចូលលួចក្នុងផ្ទះ ។ មនុស្សម្នាក់ទៅដំរាបរាជអមាត្យថាឥឡូវនេះ ចោរលួច

យកកែវមណីចាត់ហើយ ។ ពួកអមាត្យប្រាប់ថា ចូរអ្នកពាល់គ្នាទៅចាំស្តាត់ត្រង់ទ្វារស្រុក ហើយឃ្លាំមើលមនុស្សដែលចេញពីស្រុកនេះទៅ ។ ឯបុរសអ្នកជំណើរនោះ លុះព្រឹកឡើងក៏បាត់ទៅ ។ ពួកអ្នកយាមល្បាតរកនេះបុរសនោះមើល ក៏បានឃើញកែវមណីហើយតម្រាមចោទប្រកាន់ថាជាចោរចាប់យកទៅ ។ ពួកអមាត្យក៏នាំលើកមើលកកាយថា អានេះឯងអ្នកមាលក្បាយ តាលក់ទើបមកដល់ អញឲ្យកន្ទែងដេក ឲ្យបាយស៊ីលុះក្រឡប់ទៅវិញ ក៏ហ៊ានលួចយកកែវមណីអញទៅទៀត ទើបកំហែងខ្លាក់ទោសទ្រីដ្ឋចាត់ការឲ្យនាំបុរសនោះទៅសម្លាប់ចោលបង់ ហើយយកប្រពន្ធបុរសនោះទៅ ។ ពួកអមាត្យលុះអស់អាយុសង្ខារស្លាប់ទៅ ក៏ទៅនេះនៅក្នុងនរកអស់កាលជាយូរអង្វែង លុះច្យុតពីនរកមកកើតជាមនុស្សក្រៃគេសម្លាប់អស់មួយរយជាតិ ។

មនុស្សដែលប្រព្រឹត្តអាក្រក់ដូចជាអមាត្យនេះ លោកហៅថាមនុស្សនរក ។

(ស្រង់ចាកធម្មបទដ្ឋកថា ភាគទី ៦ ត្រង់រឿងមហាកប្បិនឋេរ)

× × ×

រឿងមន្ទុស្សទេវតា

មានស្រីម្នាក់ឈ្មោះនាងទត្តព ជាអ្នកមានសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនាណាស់ ប៉ុន្តែបានប្តីជាមនុស្សមិច្ឆាទិដ្ឋិ ។ ប្តីនោះឃាត់ប្រពន្ធមិនឲ្យធ្វើបុណ្យទានអ្វីសោះ ។ ប្រពន្ធមិនសុខចិត្តនឹងអាក់ខានធ្វើបុណ្យ ក៏ជួលស្រីភ្លាមាសម្នាក់ឈ្មោះ សិរិមា ដែលមានរូបឆោមល្អឆើតជាប់គេឲ្យមក

បំរើប្តីបំនួន១៥ថ្ងៃ ក្នុងមួយថ្ងៃឲ្យថ្ងៃឈ្នួលមួយពាន់រៀល ។ ប្តីយើញ
ស្រីផ្ការមាសនោះ ក៏ស្រឡាញ់ពេញចិត្តណាស់ព្រមឲ្យប្រពន្ធធ្វើបុណ្យ
ទាន ។ ឯនាងសិរិមាស្រីផ្ការមាសបាននៅរួមជាមួយនឹងប្តីនាងទត្តរា
រៀងរាល់ថ្ងៃមក ។ ចំណែកនាងទត្តរា ក៏ធ្វើរោងមួយធំក្សរផ្ទះសម្រាប់ស្ន
ជណ្តាំធ្វើបង្ហាន់ប្រគេនព្រះសង្ឆរាល់ព្រឹក ។ មានមួយថ្ងៃ ប្តីអើតតាម
បង្អួចសំឡឹងមើលទៅប្រពន្ធយើញកំពុងតែចាត់ការឲ្យគេស្ងជណ្តាំប្រឡាក់
ផេះខ្ទះផ្សូងខ្ទះ ក៏នឹកថា "ឧនាងនេះល្ងង់ណាស់ សម្ឆត្តិមានស៊ីឥតខ្ទះ
មិនគួរបើទៅធ្វើឲ្យនៀយហត់ខ្ទួនព្រោះតែស្រមណ៍កំណោរ" គិតយ៉ាង
នេះហើយក៏ញញឹមដើរចញទៅ ។ នាងសិរិមាយើញបុរសនោះមើល
ទៅនាងទត្តរាហើយញញឹមជូច្នោះក៏កើតចិត្តប្រច័ណ្ឌថា អ្នកនេះមុខជា
ធ្វើសេវនកិច្ចនឹងនាងនោះជាប្រាកដបានជាយើញមុខគ្នាសិច នឹកខឹង
ខ្ទាំងតែចខ្ទួនថាជាខ្ចុំដែលគេជួលឲ្យមកបំរើប្តីគេ ក៏ត្រឲ្យប់ជាសំគាល់ខ្ទួន
ជាម្ចាស់គេវិញ ក៏ចុះទៅជួសខ្ទាញ់កំពុងពុះក្នុងខ្ទះស្រោចលើក្បាលនាង
ទត្តរា ។ ឯពួកស្រីៗអ្នកដាំស្ងព្រួតគ្នាវាយនាងសិរិមា ។ នាងទត្តរា
ខំស្ទុះទៅជួយយាត់ខាំងត្រោបពីលើនាងសិរិមា ដើម្បីកុំឲ្យគេវាយត្រូវ
ហើយនិយាយយាត់អង្ងរគេថា ចូរឯងរាល់គ្នាកុំវាយនាងសិរិមានេះ ដ្បិត
នាងនេះ មានគុណូបការលើអញធំណាស់ដោយបានមកស៊ីឈ្នួលបំរើប្តី
អញ ឲ្យអញបានមកធ្វើបុណ្យយ៉ាងនេះ ។ តាំងពីថ្ងៃនោះមក នាងសិរិមា
លែងខឹងនឹងនាងទត្តរា ស៊ុធ្វើជាសំឡាញ់នឹងគ្នាត្រឲ្យប់ជាស្រីមានសទ្ធា
ជ្រះថ្ងាក្នុងព្រះពុទ្ធសាសនាទៅវិញ លុះគ្រប់កំណត់១៥ថ្ងៃហើយក៏រិលទៅ

លំនៅខ្ជនដដែល ។ ឯនាងទត្តកនឹងប្តីក៏នៅរួមសុខទុក្ខជាមួយត្នារហូតមក ។

មនុស្សដែលមានអាការកិរិយាមារយាទនឹងចិត្តថ្វើមល្អដូចជានាង

ទត្តកនេះ លោកហៅថា មនុស្សទេវតា ។

(ស្រង់ចាកធម្មបទដ្ឋកថា ភាគ៦ ត្រង់រឿងនាងទត្តកទាសិកា)

ប្រុសស្រីក្នុងលោកមាន៤ផ្នែក

លោកចាត់ដោយឡែកខុសពីត្នា

អ្នកខ្ទះដូចប្រេតរងរវទនា

អ្នកខ្ទះដូចជាសត្វតិរច្ឆាន ។

អ្នកខ្ទះដូចជាសត្វនរក

ធ្វើកម្មលាមកឥតលោះខាន

អ្នកខ្ទះដូចទេវតានោស្ថាន

ស្ថិតិសុខសម្រាន្តមានមេត្តា ។

ហេតុនេះយើងត្រូវទំសង្វាត

ធ្វើតាមក្ឈនខ្នាតមនុស្សទេវតា

កុំទ្យាខ្ចបងំក៉ព្ទវាស្នា

ទើបបានឈ្មោះថាជួយស្រុកទេស ។

ចប់

រឿងនេវន្ត

ពាក្យកាព្យ

លោកអម្ចូតក្សត្រី ម៉ុក រៀបរៀង

ក្នុងកាឡ្យព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម

លោក ញ៉ុកវៃម ពិនិត្យ

(ភមក)

ព្រះបាទកូមី យង់យល់បុត្រនី- មិលមានស្លស្ត៊ ស្តែងស្តេចស្រឡាញ់ ពេកពេញបេតី ត្រាស់ប្រើមន្ត្រី ឲ្យរើសមនំ ។ សឹងកូនសេនី សេនាបតី នាហ្នឹងតូចធំ ប្រទានបុត្រវ៉ត្ត ហើយក្សត្រទត្តម តាំងនាមស៉ក្តិសម ហៅនាងចន្ទា ។ កាលណោះមហាក្សត្រ ទរនាថព្រហ្មទត្ត ជាព្រះបិតា ហេតុកម្មក្សត្រថ្ថ ទឹងរ៉ូយជន្មា ចង់ចរយាត្រា ទៅលេងព្រឹក្សព្រៃ ។ ទ្រង់ត្រាស់ប្រើប្រុង រៀបរាជចតុរង្ត ត្រប់ប្រាំពីរថ្ថ រួចជូចអាជ្ញ៉ ព្រះមហាក្សត្រថ្ថ ទ្រង់ត្រេកអរក្រៃ ត្រាស់ផ្តាំពនិតា(១) ។ ប្អូនអើយចូរនៅ បងអ្នកនឹងទៅ លេងព្រៃព្រឹក្ស៉ ដេញអស់សត្វតែង បន្ទែងយោធា ចូរប្អូនរក្ស៉ ទាំងពីរបុត្រវ៉ត្ត ។ នាងទូលវឹងស្នង អញ្ជើញស្តេចហោង ខ្ញុំពុំទាំងយាត់ តែសូមស្តេចធាប់ ប្រញ៉ាប់វិលថ្ថាត់ ក្រែងក្រជ្ឆិតក្សត្រ ពុំតង់ត្រប់ត្រង ។ មួយខ្ញុំតិតក្សត្រ ត្រាច់ព្រៃសឹងសត្វ ពន្ធឹកយង់ឃ្នង ស្តេចធ្ងើយវឹងថា ស្ទួនក្ងាស្នេហ៍ស្នង កុំបារម្ភបង បងធាប់យាត្រា ។ ត្រាស់ស្រេចថើបថ្ថ ប៉ីបុត្រទាំងទ្វ ថាហៃស្ទួនក្ង

១-ពនិតា : ប្រពន្ធ ។

អាពុកណាស៎ ទឹងទៅព្រឹក្សា ទុស្ខនឹកំ ទឹងយកទៅផង ។ គ្រាស់
ស្រេចក្តៅខាង ទ្រង់គ្រឿងប្រពាត ប្រដៃតតហ្មង ទ្រង់ខាន់ជ័យថ្កើង
ផែលឡើងលើខ្នង អស្សរាហ៍ពុំផ្សង មន្ត្រីជិតដោយ ។ ពួកពលយោធា
ហៅហ្លួណា(១) ដើរនាំមុខក្រោយ ខតព្រៃព្រឹក្ស អធិកដុះដោយ
ជ្រោះប្រកជ្រុងជ្រោយ ប្រកបដណា ។ រចោយពោយពុះ សត្វសត្វក្រៀវ
ក្រុស្ត ជណ្តើមកោក្តា ស្តែងស្តេចក្តកទឹក រលឹកពន់តា បុត្រីបុត្រា
ព្រះស្ងួសម្រាប់ ។ អស់ពាំងពាលផង សើចលេងអីងកង ក្រហឹងអឹងអាប់
អេះប្រតំ ភ្លេងផ្ទុំសង្ខ័សព្ទ សូរសោតឮលាប់ ពន្ធឹកខ្ទាំងក្តាត់ ។ អស់
ពាំងសត្វម្រឹគ កំគកយ័ក្លាំងក្លឹក រត្តេរត់ពួនព័ទ្ធ ពួនពឹងដោយព្រៃ
ក្សត្រៃថ្លុចក្រវែត្តិ ឲ្យបរសេះស្តាត់ រកដេញម្រឹគា ។ ពុំមានពុំបាន
ហើយស្តេចឈប់ខាន សង់ព្រះពន្ធា សម្រាកសម្រាន្ត តាហ៊ានយោធា
ចាំដេញម្រឹគា សំណាក់ដេកកា ។

រីមឹងថ្ងៃឆៅ យក្សមួយនាមហ៊ៅ ក្រុងនន្ទិយក្ស យក្សយង់
ហោរហៅ តែងនៅសំណាក់ វេស្សវ័ណសិទ្ធិស័ក្តិ បម្រើក្សត្រថ្ងៃ ។
ស្តេចត្រាស់សុំណា ឲ្យទីហ៊ានថា ចូរចៅនៅព្រៃ មួយនោះជាហ៊ាន
កុំមានសង្ស័យ តីតាស្រ័យ អង្គអញឲ្យបា ។ តែមួយយោជន៍យល់
នូវអ្នកដើរដល់ ប្លែកបាប្តូរ សួរមូលធម្មៀ បើគេឯណា ចេះដឹងកុំបា
បរិភោគអ្នកនោះ ។ បើអ្នកឯណា ខ្លៅដួចាន ចំណីចៅចុះ ត្រាតី
អាស្រ័យ កុំប៉ះបាល់ ចៅលោកឲ្យីយនោះ ទឹងមានទោសស្ងួយ ។

๑- ហ្លួណា: ប្រមុខ, មេកង, មេក្រុម, តាយក ។

យក្សរៀនធម្មា សូរវេចក្រាបលា មកនៅដើមព្រៃ តែងតែរាជញ្ញាស្អាត់
សព្វសត្វក្នុងព្រៃ សាកសួរធម៌ថ្មៃ ហើយស៊ីសត្វជន ។ ថ្ងៃនោះយក្ស
រុករកម្រឹគា សព្វព្រៃត្រាំក្បូងង ឃ្លានខ្លាំងពុំបាន ដួចក្តានបំណង ឃើញ
ក្សត្រប្បាស់ច្បង ខ្លួរពលយោធា ។ ត្រេកអរគិតយល់ ទុបាយកំចួកល់
ចាប់ស្តេចកោក្តា ស្រេចសូត្រព្រះមន្ត ទិព្វគន់ដៃជ្ញា ប្រែក្លាយកាយជា
អម្រឹតវិលាស ។ មៀងមូលសូរង ផ្លៀងផ្លងដូចខន ខៃលតាមាស ខេត្រ
ស្រស់ស្រិល ឡៅនិលទុកាស ដូចនិលក្តងាស ដាំកូនខេត្រនោះ ។
រុងរឿងយល់ច្បាស់ ដូចផ្កាយព្រហ-ស្បតិ៍ពីរភ្លោះ ស្នែងស្ថិតសមល្មម
ព្រែកត្រមស្បែក្បោះ ច្រូងច្រាងស្មើស្មោះ ដូចវត្តរោង ។ ផ្ទៅធ្លាត់ស្មៃប
ក្លាយ ដាំតួងព្រោងព្រាយ ខ្លួរត្នោចខា ច្រូងច្រង់ល្មមល្មៃ ប្រកៃសោភា
សោភាតកត្រា កត្តីស្រស់ស្រាប់ ។ ល្អល្អះធាយធ្លេត ដូចធម្មជាតកើត
ប្លែវត្នចំណាប់ រូហានពិស្ដារ រចនាប្រជាប់ ប្រជាផ្លូវផ្កាប់ ខ្លួវត្នធា
ធាយ ។ ដាំមណីមុក្តា មើលម្ដង់ដូចជា ពពិលវត្នាយ ដូចសូរគានគាស
ឆ្ពុះធ្លាសត្រោងព្រាយ ម្ដងដូចតិកាយ តិខ្សែនពរត្ន ។ កោមលមាសមាន
រស្មីរូហាន ខ្ចីមមារកដ ខៅត្រីប្តូរប្តូរ តិខ្សែខុមរត្ន ខុមពាគកាលកាត់
កាលកៃមបវរ ។ លៀនលំខ្ចាត ឃាងឃាសយាត្រា ការខ្លួងធើយង
ចេរចរត្រាច់ត្រង់ ចតុរង្គិនិការ ខៀបព្រះភូធរ រឹងអំពើក្លាត់ ។ ធើបធើយ
ឆាំបំឆាំ រឹនវ្ញែកមួយសា ដូចឥន្ទ្រនិមិត្រ ប្រសើរឥតមោះ ពុំនោះតិចិត្រ
ដូចព្រះអាទិត្យ ទុយផ្ទុះផុត ។ ពណ្ណរាយយល់ថ្លើង ក្រៃក្រចការធើង
ដូចមហាមារកដ ស្រែលស្រស់ស្អាតស្អំ ស័ក្តិសមដើមបខ ដូចផ្ទើលដូចរត់

ចេរចេរយោគ្រា ។ ចូលជ្រកសម្ងំ ក្នុងព្រៃស៊ុំខ្មែរ មុខគុម្ពតន្ទា ត្រហ្មុខត្ត
ស្តេចយល់ អាសេរមហិមា ពុំជ្រាបជាក់ជា យក្សយេងប្រែក្លាយ ។
ស្តេចគិតចាប់ទៅ ឲ្យបុត្រចមទៅ មើលសេនសព្វាយ ជ្រាប់អស់សេនា
យោធាទាំងឡាយ ចូរចាត់ចែងចាយ គ្នីគ្នាឲ្យធាប់ ។ អម្រឹតមាសមួយ
ចូលតួនចូរឲ្យ ចែកចោមឲ្យខ្លាប់ សេនាតលពង្ស ចតុរង្គស្តេងស្តាប់
ខ្នួលបង្គាប់ ចែកចោមខ្លាយខ្នួល ។ ស្តេចគង់សេះចេញ ប៉ុនប៉ងនឹងឆ
ដេញ កណ្តាលតួកតល ឯអម្រឹតយក្ស យល់ជាក់អាសេរ ក្លែងក្លាយ
ដោយកល់ មាយាយក្ស ។ រត់រេចៅមក ប្រយោជន៍នាំយក ស្តេចចៅ
គោក្តា ពួកតលស្រែកស្រុះ ស្ងាស្ងុះបំពា ចេញចំកក្តា រត់រួចចេរចេរ ។
រេហ៍តលឈប់ចៅ ងើបងើយនឹស្មៅ លស្លងគូរ ស្តេចឡាស់យោធា
សេនាឱកា តឹងតឿនអស្ត្រគរ ដេញតាមម្រឹគា ។ ធ្លើហាក់ភ័យកិត
ឈរឈប់លឿនលិទ្ធ អស់អគ្គីអាត្មា ស្តេចចៅខៀបខាន់ ធ្លើស្ងន់រេក
រេរត់ខាំមហា ក្សត្រាយកចៅ ។ លុះដល់ដើមត្រែ ប្រែប្រាណាលែវែ
ជាយក្សយោរយៅ លាក់កាយតន្ត្រើយ ក្នុងទីលំនៅ រីព្រៃចមចៅ
ខ្លូវសេះមង្គល ។ តាមប្រើសមាសមៃ ចុតំនាដើមត្រែ រកជានពុំយល់
ព្រះអង្គឆ្ងល់ឆ្ងាយ អស់កាយតល ឈប់ក្រោមមណ្ឌល ព្រះ
ត្រែចំតូចី ។ ទើបតែនឹងយោធ វៃព្រះបាទមូធ ទម្លាក់ដល់ដី
ក្រុងយក្សស្រែវស្រែក សម្រែកហាក់ឆ្ងី ចាប់ព្រះបក្រី ព្រមទាំង
មនោម័យ ។ យក្សយសស្ងាប់ ដណ្តើងឲ្យច្រាប់ ខ្លូវមួលធម៌ថ្លៃ
ក្សត្រាវៃឲ្យ ស្តេចទ្រង់តិតភ័យ សូន់សូតស្មារតី ពុំអាចធ្លើយថា ។

ស្វៀមស្វាត់នៅនោះ យក្សយល់ជូរ្ជាះ ក់ក់យកោក្តា រួចរៀបទៅធ
ពាជីទៀតណា ពាជីតិតថា អង្គអញនឹងស្លាប់ ។ រ៉ីហេតុនេះនឹង ត្មានព្ធដំ
ណឹង ជំណួចតួរតាប់ តួរតិតស្រេជ កុំបីឲ្យស្លាប់ យូរទៅសឹមប្រាប់ កុមារ
រត្នៃថ្ថ ។ តិតស្រេចស្តីថា ហៃអ្នកជឹមហា ពន្ធឹកវិទ្ធ៍ក្រៃ ប៉ើបវិកោតត៉ក្ស
ខ្ញុំអ្នកឆ្អែតផ្ទៃ បានតែមួយថ្ថ ថ្ថៃស្អែកព្ញួយរក៍ ។ ប៉ើអ្នកក្ខែងជា ព្រះមហា
ក្សត្រា ជិះខ្ញុំចរចរ ទៅសោយរាជ្យជា នៅនានតរ អ្នកនឹងបានបវិ-បូណិ
បុណ្យឆ្អែតឆ្អន់ ។ ស្តេចមានពនិតា ឈ្មោះនាងវិមលា បុត្រឈ្មោះទេវន្ធ
បុត្រីនាមា ចន្ធាសោភ៉ណ អស់ស្រីកំណាន់ ប្រើនក្រៃមហិមា ។
សេះប្រាប់ដោយពិត កំណត់តំនិត តំនុំយក្សា យក្សស្តាប់សេះថ្ថ
អរឯងមហិមា ក្ខែងក្ខាយកាយជា ក្សត្រាសុទ្ធសាត ។

លីលាចេរចរ ទ្បើងជិះអស្សតរ នានាំខ្ចីឃ្មាត ជល់ទ៉ីពន្ធា សេនា
អមាត្ស សឹងថ្ថាយអភិវាទ យក្សប្រាយប្រាប់ទៅ ។ អញដេញម្រឹតា
ពិតពុំទាន់ក់ បាត់ក្ខុងត្រៃជ្រៅ នាំយើងលីលា យាត្រាមកនៅ យូរហ៉ីយ
ល្មមទៅ បូរ៉ីរដ្ឋា ។ ត្រាស់ស្រេចតង់រថ លើកពលបវិសឲ្យ ចូលកាន់
ភារា អស់ស្រីខុនណាង នូវនាងវិមលា បុត្រីបុត្រា ស្មានជាចក្រ៉ ។
យក្សឋិតសុខា រួមនឹងវិមលា ជាតិជាមហេស៉ ប្រជាជនជាត អមាត្សមន្ត្រ
ស្មានព្រះនរបតី(១)តង់ព្រះជន្ធា ។ រ៉ីយក្សអប្រ៉ីយ រ៉ែងរង់រាត្រ៉ ចេញចាប់
មនុស្សម្ទា ស៊ីជានិរន្ត៍ មួយមន្ត្រ៉ីណា ទោសតិចតួចវ៉ ពុំមានប្រណ៉ ។
តែងឲ្យយកទៅ ដោតជាក់ទុកនៅ លង់លុះរាត្រ៉ យកទៅកោក្តា ជាប់

១- នរបតី : ជាម្ចាស់នៃនរជន ជីក្សត្រជែនដ៉ ។

ជាប្រក្រតី លង់ទៅអស្ចារ្យ រំពឹងត្រេកត្រអែ ។ រីឯហេតុអំពើ អង្គអញមកធ្វើ
ពីនោះដល់ម្ល៉េះ ទីអ្នកណាដឹង ដំណឹងតែសេះ យូរក្រែងអានេះ
ច្រាប់អ្នកដទៃ ។ ទឹងជ្រួតជ្រាបដល់ វេស្សវ័ណថ្កើងថ្កល់ សមអង្គ
អញក្សត្រិយ បើខុកអស្សយាន ទឹងមានទោសភ័យ គួរតែតឡែក្សត្រិយ
ទើបបានសុខសាន្ត ។ តែតម្រេចត្រាស់ថា ហៃអស់សេនា
សេនីតាហាន ចូរអស់មន្ត្រី សេនីត្រប់ប្រាណ ដាក់ទ្រូងអស្សយាន
បង្អត់ឡែក្សត្រិយ ។ ដ្បិតកាលអញចេញ លេងព្រៃតាមដេញ អម្រឹតមាស
មៃ វាមិនទំាចាល សត្វចោលឆ្ងាយក្រៃ ចាស់សត្វវះរៃ វះវាងបាត់ភ្នែ ។
តាហានបានស្តាប់ ខ្ចួលបង្គាប់ បង្គំចមចៅ ចាប់សេះដាក់ទ្រូង បង
បង្អត់ស្មៅ ឡែមនុស្សចាំនៅ រក្សាប្រក្រតី ។ សេះវង្គុក្ខញ្ញ៉ា តន់តែត
ជាអញ ឥតមានទោសអ្វី នេះច្រាកដជា ឃក្សតិ៍ឡើយ ក្រែងអញស្រដី
ច្រាប់មនុស្សចាំងឡាយ ។ ទុហេតុតំនិត បំណាច់អញតែត អញ
កុំគួរស្តាយ ម៉ៃទឹងក្សិណក្ស័យ បានស្តីនិយាយ ដំណើរច្រាប់ច្រាយ
កុមារតែចាំ ។ ទុហេតុបុណ្យខ្ញុំ បានសាងសន្សំ តិតពីបឋម សូម
ទេពគ្រប់ឋាន ច្រោសច្រាណមេត្តា ចណ្តាលកុមារ ឡែមករកខ្ញុំ ។
សេះងើវេខា រងំចាំកុមារ រួតទុត្តម លង់ប្លួនទៅជ្រាយ ស្តុមកាយស្ទើរពុំ
រួចសំហេតុសំ. ណាងនោះមហិមា ។ រីឯអង្គយក្ស ជួងាតិអបលក្ខណ៍
ស្មានជាអស្សព្រាហ៍ នោះលុះដល់ក្ស័យ ប្រល័យជន្មា តែងសេពសុខា
ជានិច្ចប្រក្រតី ។ ដេកលើច្រាង្គច្រា. សាខសុខសុវណ្ណា សត្វរកត្រី
តែងដើរគេងំតែ ដោយកែវប៉ារី ជួនបួបចោរក្តី ប្តមនុស្សឯណា ។ អាច

ចរស្ទះស្ទែង ភ្លាំងភ្លាត់ឯកឯង កណ្តាលអភ្ញា មួយមុខមន្ត្រី ខុសអ្វីក្តីណា
តុំពិភាក្សា ហេតុចិត្តតិរ្ថ្យ ។ មោហាក្រែវក្រោធ ឲ្យយកទៅដោត
ខុកដល់ពក្រ្តី មើលឃល់ស្ងាត់ល្អ ចេញចរឃ្លោនខ្មី ទៅជាប្រក្រតី
មនុស្សស្ងាប់ប្រែខក្តាត់ ។

អស់មុខមន្ត្រី ខ្លះអ្នកបូរី ឃល់មនុស្សតែងចាត់ មួយអស់កូនចៅ
ដែលទៅភ្លាំងភ្លាត់ តិចរួតែងចាត់ ជាទិច្ចសព្វថៃ្ង ។ ជំនុំគ្នាថា តាដើម
ក្សត្រា ច្រែងព្រះធម៌ថៃ្ង តាំងតីចេញចរ ទៅប្រភាតព្រៃ រៃលវិញ
ព្រះទ័យ ដូចយក្សមោហា ។ ឲ្យសម្លាប់សេះ ប្តូមួយស្តេចនេះ
ជាយក្សកាឡ កិតតិយក្រែងខ្លាច រត្នេពជអស្សតាហ៍ ច្រាប់យើង
កល់គ្នា ដោយខ្លួរដំណឹង ។ ខ្ញុំថប់ណាស់ណា តុំមែនក្សត្រា
នៃយើងទេដឹង ខ្លះខ្លែយថាអើ ថាបើចន់ដឹង ជំណើរយើងហ្នឹង
នាំគ្នាស្រើបស្រុះ ។ ទៅគាល់តិនិត្យ ស្ងាកស្នាមចរិត នៃអង្គ
ស្តេចនោះ អស់តាំងមន្ត្រី សេនីតិតច្នោះ សោតសឹងស្រើបស្រុះ
ចូលគាល់លំទត ។ តនអង្គអសុរាជ សាក់សាតមិនអាច ថាស្តេច
ព្រោះសុទ្ធ គាល់តន់ប្រក្រតី ជាន់បីខែតត់ ស្ងាកស្នាមមានមុត មាន
មិនទីថៃ ។ សេះត្រូវខ្លែងជា ប្រាំពីរមាសា តែតុំស្ងាំណស្ងួយ
ហេតុដោយសំការ ចេស្តាក្រាស់ក្រៃ ជាតិនាំងនៃ គោធិចមទៅ ។
គាល់ណោះទេវនួ- កុមារនោងច - ន្លាដាប្តូនពោ ពិតតុំធ្លុសធ្លើ បម្រើ
គាល់ហ្មៅ យក្សយន់យោរយៅ ស្មោះស្មានបិតា ។ សម័យមួយ
ទៅ តន់គាល់លើក្តៅ នៃអង្គយក្ស យក្សនុបថើបសរ តាំងខ្លួ

កុមារ ធ្វើហាក់ដូចជា កូនកើតសៀយ ។ ស្រេចចង្គិលា យាងយាសហេត្រា ចេញចាកពេងជ័យ រុងរឿងបវិបូណ៌ ដូចសុរិយោជ័យ រឿងរះឯព្ធ បូណ៌មិតេញ្ញវង់ ។ ហេតុជាអំបូរ ក្សត្រក្សាន្តឥស្សរ ពន្ធុក ពុទ្ធពង្ស បវរបូលកាន់ពេង ដែលចង្អអស្សពង្ស តុំយល់នៅចុង ពេងក្តួ ដែលចង ។ យង់យល់ក្នុងគុក ក្រៀមក្រំកើតទុក្ខ ត្រូវទ្រូងដែកផង ច្រវ៉ាក់ដែកជាក់ ពាញពាក់ជើងចង ស្តាំងស្តមសៅហ្មង អង្គអត់ចំណី ។ សួរថាហៃបង ត្រូវទ្រូងចំណង កើតមានទោសអ្វី សេះសោតធ្វើយ ឆ្លាស់ ថាអម្ចាស់ថ្លៃ ចង់ដឹងសេចក្តី ចូលដំតមកអាយ ។ ទ្រង់ចូលតំបហើយ សេះថាម្ចាសអើយ ប៉ុណ្ណោះនៅឆ្ងាយ ហេតុនេះក្រីក្រ កម្រដោះស្រាយ ខ្ញុំទីនិយាយ តំបទើបបាន ។ កុមារវរលក្ខណ៍ ទ្រង់ជ្រាបដឿងជាក់ ពាក្យពីអស្សយាន ទនអង្គផ្សឿងផ្តាប់ សេះច្រាប់ដោយជាន ដោយដំណើរមាន មកពីដើមថា ។

បិតាអ្នកថ្លៃ បវរចេញទៅព្រៃ យក្សនេះក្លែងជា ច្រណាប្រើស មាសមែ ក្សត្រថ្លៃដេញក់ ក៏ចាប់កោត្តា កូនព្រៃស្នាន ។ យក្សយង់ប៉ុនបីន បរិកោគខ្ញុំផង ខ្ញុំតន់តតឆ្ងាន ក្រែងក្រាយសួរសោះ ហេតុនេះមិនបាន ព្រះលេចតតិមាន ដល់ម្ចាស់ពន្ធុក ។ បានជាខ្ញុំថា ឲ្យយក្សកាឡា ឈើជំនិះខ្ញុំមក យក្សគិតកយា បានដាឲ្យយក អង្គអញខ្ញុំមក ដាក់ក្តីឲ្យស្លាប់ ។ យក្សគិតក័យក្រែង អញខ្ញុំសំដែង សំដីច្រាយច្រាប់ អស់មនុស្សពាំងឡាង ខ្លះខ្លាយសារសំពុះ តន់តតសម្លាប់ ឲ្យខ្ញុំក្បាណក្ស័យ ។ ហេតុនេះសុខុម ដឹងតែម្ចាក់ខ្ញុំ កុំម្ចាស់

សង្ឃ័យ ពុំពិតជាតិជា បិតាថ្លាថ្លៃ គាត់នេះយកព្រៃ ជួរចារមោ
ហា ។ ម៉េពុំជ្រាបហេតុ ខតតែនយ័នេត្រ មិនមានតែវាថា ដូចមនុស្ស
ប្រក្រតី ប្រុសស្រីនេត្រា ពុំមានដូចជា អស់ទាំងមនុស្សយើង ។
មួយឯនន្ទ្ធា ហើបហារគាលណា យល់សុទ្ធសឹងភ្លើង ផ្សំផ្សែងផ្សាផ្សប់
ត្រឡប់ឡប់ឡើង ពុំដូចមនុស្សយើង គ្រប់គ្នូទាំង ។ កុមារស្តែង
ស្តាប់ ដំណើរភរាសព្ទ ពាក្យពីគាជានេយ្យ រៀបរឹងទៅដល់ មណ្ឌល
ពិភ្ជាថ្លៃ ឡូនគ្នាន់សង្ឃ័យ ជាព្រះបិតា ។ ថាហៃប្អូនភៅ មកយើង
ដេកភៅ ព្រឹកព្រាងកាលណា សមយើងមើលល្បង ដូចបងសេះថា
លួងលោមអនុជា ផ្ទំផ្ទមលក់ភៅ ។ លុះព្រឹកព្រាងស្រេច ពីរពង្ស
សម្តេច កុមារសំដៅ កាន់ភេនវត្តមម្យ បង្គំខៀងភៅ តង់តាល់លើភ្លៅ
ដូចដែលសត្វគ្រា ។ គន់មើលនេត្រយក្ស យល់ច្បាកដជាក់ ដូច
ពាក្យសេះថា ខំលួលបង្គំ ហើយសូមកាកស្មា ប្រយោជន៍ច្រាំ ឧត
ចង់យើញជាក់ ។ បពិត្របិតា សូមច្រង់មេត្តា ឲ្យពានកញ្ជាក់ ស្មា
ដែលសោយនោះ ក្បាលនោះស្តេចយក្ស តនហារខ្ជាក់ជាក់ ដល់ដៃ
បុត្រា ។ កុមារយល់ភ្លើង ផ្សែងផ្សាផ្សប់ឡើង ដូចដោយពាក្យតា-
ជីតឿលចំត្តុ តយ័តតក្តមា ប្រែប្រាណាលាកលា ចរចេញឆៀង
ធាប់ ។ ទៅកាន់សេះហើយ ត្រាស់ថាបងអើយ ពិតដូចបងច្រាប់
មើច្នេះទឹងគិត តំនិតម្តេចតាប់ សេះសោតស្តែងស្តាប់ កុមារត្នួថ្លៃ ។
ឱលថាបពិត្រ កុមាររឿងវិទ្ធ កុំព្រួយព្រះទ័យ ហេតុនេះយល់ល្អ
កម្រក្រៃក្រៃ ខនិម្នាកដទៃ ណាទឹងដឹងឡើយ ។ តំនិតតំនាប់ ខ្ញុំពុំ

ទាន់ប្រាប់ អម្ចាស់គ្រាណាត្រើយ បើអម្ចាស់សុំ អញឲ្យបានហើយ
ធឹងក្រអីឡើយ កុំព្រួយព្រះទ័យ ។ ម្ចាស់ទៅតាន់រ៉ា ហើយម្ចាស់
ទូលថា បពិត្រដែស្តេចយ័ក កាលដើមស្តេចថា អង្គអាជានេយ្យ ស្មោះ
ស្មើព្រះទ័យ ប្រទានអញឲ្យ ។ ឥឡូវហេតុអ្វី ស្តេចឲ្យដាក់ក្តី សេះ
សោតពិតពុំ មានមេត្តាទេស ប្រាណាប្រាសអង្គអ- ម្ចាស់ចោល
បែរចំ-ពោតពុំប្រាកដ ។

កុមារលើកូណ៍ ចង់ចាំដៀងជាក់ ពាក្យពាដីស្លុត រំលើងយាគ្រា
ទៅប្រាសាទត្នេ លុះលុតបាទបទ បង្គំយក្ស ។ កំលោយចូលទៅ តង់.
តាល់លើភ្លៅ ចាយចែងចាចា ដូចសេះបង្គាប់ យក្សស្តាប់ឆ្លើយថា កូន
អើយគ្រោយគ្រា អាពុកទៅព្រៃ ។ ឃើញប្រើសមាសមក ចិត្តចង់ចាប់
យក អម្រឹតមាសមែ ក៏មិនទំចោល សត្វចោលឆ្ងាយព្រៃ ក៏ផវះបាត់ឮ
ព្រៃព្រឹក្សាសាន្ត ។ ហេតុនេះអាពុក ឲ្យធ្វើទេសទុក្ខ កុំកូនចង់បាន
ដង្វៃសឹងស្ល មិនក្រសឹងមាន ចង់បានប៉ុន្មាន ចូលយកតាមចិត្ត ។ កុមារ
ទូលថា បពិត្របិតា ឯកជន្រ្ទធ៌ទ្វៃ ប៉ុន្មានក្តីខ្ញុំ ពិតពុំចូលចិត្ត សេះមួយ
នេះដ្បិត ស្តេចឲ្យខានទ ។ បើយើងខ្ញុំនេះ ធំនឹងឲ្យសេះ ជិះលេងកំសាន្ត
ឥឡូវធំហើយ ម្តេចឡើយក្យត្រក្យាន្ត ព្រះអង្គប្រទាន បន្ទូលដូច្នោះ ។
យក្សតន់តិតខ្លាយ បើអញមិនឲ្យ សេះដូចពាក្យខោះ សមសង្ឃឹយពិត
យក្សតិតតែម្ន៉ោះ ឆ្លើយថាបើឮ្នោះ យកចុះស្នូនអើយ ។ តែកុំប៉ាទៅ បេះបេ
ទៅក្រៅ ទៅលេងឆ្ងាយឡើយ លេងតែនៅអាយ ប្រុងកាយកូនអើយ
ក្រែងក្លាត់ខ្លាក់ហើយ ចាក់ជើងចាក់ដៃ ។

កុមារត្រេកអរ បង្គំចេញចរ ចេញចាកភេនដ័យ ចរចូលកាន់ភេន
ដែលចនមនោមយ ទ្រេមទុស្សនាប់រៃ ស្រាយស្រែចថ្ងាយថ្ងាត់ ។
ហើយទ្រេចោចស្មៅ ទ្រេស៊ីចនៅ នាក្នុងភេនរក្ខ ទ្រេមទុស្សដែលចាំ
ថែទាំប្រដាត់ ដុះលាងជូតខាត់ លុះធាត់ដូចដែល ។ ប្រឿនពីរកុមារ
ទ្រេជិះគាគ្នា ដើរដោយបរិវារ ដើរថ្នមតិច ។ ដ្បិតស្តេចមិនដែល សេះ
យល់ប្រហែល ចេះដើរខ្លាប់ខ្លួន ។ ចោលខ្លាំនតិចទ្បើន តែតើតស់ដើន
យល់ជាមាំមួន ចេះគេចចេះគាច ខ្លួសាបប្រែខ្លួន ប៉ុនចៅមួនខ្លួន ល្មម
ទៅធ្វើយបាន ។ ហើយសេះក្រុលថា បពិត្រកុមារ ពីដើមខ្ញុំមាន កំឡាំន
ខ្លាំនក្រៃ ទៅមួយថ្ងៃបាន រាប់រិះប្រមាណ មួយរយយោជន៍តត់ ។ យក្ស
ជាក់ក្តីខ្ញុំ កំឡាំនថយពុំ នៅដូចកំណាត់ ឥឡូវខ្ញុំមាន រូបច្រាណធំជាក់
បង្ហាត់ទ្រេស្អាត់ ដូចដើមទ្បើយបាន ។ ចូរម្ចាស់យាត្រា ទៅលាយក្សថា
ទៅលេនទេវាន យើនឥតចំណាំ ទ្រេចាំសព្វហាន សព្វទីដែនជាន់
ច្រកល្អកបត់ត ។ យើនយកបាយក្រៀម ទៅកប់ទុកស្ងៀម ដោយព្រៃ
ក្រែនតត់ បានច្រើនសន្សឹម យើនទាំគ្នារត់ ទៅកាន់ជនបទ ប្រទេស
ដទៃ ។ កុមារបានស្តាប់ ពាក្យសេះបង្គាប់ ចុះចាកមនោម័យ ចរចូល
ទៅដល់ មណ្ឌលទីភ្លូថ្ងៃ ន្ងុលត់ពុះថ្ងៃ ម្ហូបទៀតចូលថ្លាន ។ យក្ស
ហើយបង្គំ ទូលថាអញ្ជើ ខាំនពីរសូមទាន លុតលាស្តេចស្តែន ទៅ
លេនទេវាន នឹនសេះទ្បើក្បាន ល្ងាចនឹនវិលមក ។ យក្សទុបអង្រួន
តន្ត្រែដ៏ថាស្ងួន កូនកែវពន្លក ទៅចុះតាមចិត្ត ល្ងាចមិត្តមាសមក ចូរវិលជួរក
ទីលំនៅណា ។ កុមារពីរពុំ លង់លុតបង្គំ ចូលលាមាតា បពិត្រអញ្ជើ

សូមសុំបាយជា កញ្ចប់សូមលា ទៅលេងឧទ្យាន ។ សុំទាំងអាហារ
ក្រៀមទៅបង្ការ ក្រែងល្ងាចទៅឃ្ងាន ទៅតែពីរពង្ស និងអស្សយាន
យើងខ្ញុំពុំបាន យកមនុស្សទៅទេ ។ នាងស្តាប់បុត្រវត្ត ពុំអាចទាំងយាត់
ហេតុដោយក្តីស្នេ- ហាហើយត្រាស់ហៃ ស្ងួនថ្ងៃមាសមេ មាស
មកឧនឯ អាយឲ្យម្តាយថើប ។ នាងថើបបុត្រហើយ ផ្តាំថាកូនអើយ
ប្អូននៅតូចទើប តែទៅលេងម្តង មើលជងកុស្រើប ក្រែងពារពះពើប
សត្ងពាលពាជា ។ ម្ងយមាសមើលប្អូន តូចណាស់កុំកូន ឲ្យឃ្ងាតពីបា
រសៀលទន់តិច ទៃលគេចទៃញណា កុំរង់រៅលា ជល់យប់អជ្រាត្រ ។
ហើយនាងផ្ទង់ផ្ទត់ ទ្ធប់បាយថ្ងាយបុត្រ រាជបុត្រអកិវាទ កិវនួលានាង
ឃាសយាងព្រះបាទ ចុះបាកជ្រាសាទ ប្រសើរកិរម្ស ។ លីលាទ្បើងគង់
លើអង្គអស្សពង្ស ល្អល្អះឧត្តម ត្រចះត្រចង់ រូអង្គជ្រាណត្រហ្ម គង់សេះ
សសម អណុជនៃបនៅ ។ ព្រះកវកៃកាន់ ដើមជងព្រះទ័ន ទន់ក្ងន់
ល្ហក់ល្ហៅ សេះនាំដោយជង ជ្រលងត្រៃជ្រៅ ក្សេមក្សាន្តដោយនៅ
ព្រះត្រៃត្រឹត្សា ។ កុមារទៃសាល កណ្តៃងកណ្តាល ទូរគមអជ្ងា ទត
អស់ត្រឹក្សត្រៃ ឈើឃៃសាទា ជុះដោយជួរជា សង្ការត់រៀងរាយ ។

(មានត)

សុកាស៊ិតប្រដៅជនប្រុសស្រ

ព្រះយោសធម្ម ម៉ឹង.សែស

ចៅអធិការវត្តមហាមន្ត្រី សង្កាត់លេខ ៥ ក្រុង

រៀបរៀង

(តបប់)

នាំឲ្យលោកប្រាក់កាសមាសពេជ្រនិល នាំឲ្យបាត់ទានសីលធម៌ទត្តម
នាំឲ្យស៊ីសំណូកនៃបន្ទំ នាំឲ្យទុសច្បាប់ក្រមប្រវេណី ។
នាំឲ្យទូចយសស៊ីក្តិធ្នាក់ជុនជាប ត្រឲ្យប់ជាថោកទាបអស់សិរី
ក្នុងពេលគេឃើញគេសមិនតប្បី ជួនកាលក៏ជាប់ក្តីតុកច្រវាក់ ។
ស្រីច្រើនរូបដេកចាំចាយប្រាក់ស្រាប់ មិនតិតរកចំណាប់ត្បាញដេរបាំក់
មិនព្រមធ្វើការងាវរកលុយកាក់ ប្រុងចាំចាយនៃប្រាក់ពីស្វាមី ។
ប្តីទ្ធនតើបានប្រាក់មកពីណា បានមកពីទេញ្ញប្ដពីអ្វី
ប្ដបានមកពីរាស្ត្រដែលកើតក្តី ប្ដបានពីមន្ត្រីដែលតូចតាច ។
ប្ដបានមកពីពួកអ្នកជំនួញ គេអ្នករកស៊ីជួញគេមានប្រាជ្ញ
ឲ្យនៃបានចំណេញគេមិនទ្ទាច គេហ៊ានបោះបាចសាចយកមកជូន ។
ប្ដបានពីរិបជាន់ប្ទន់អ្នកស្រុក ធ្វើឲ្យគេបានទុក្ខក្តីសាបសូន្យ
យកទ្រព្យប្ដចាប់ទ្ធនប្រពន្ធកូន លបយកប្រាក់វារលូនមកឲ្យទ្ធន ។
ប្ដពីអ្នកប្រឲ្យងយកមុខងារ ឲ្យបានចូលធ្វើការពេញមាំមួន
គេឲ្យប្រាក់សំណូកតាមចំនួន រកស៊ីតាមវិបបក្ឈនទុច្ចរិត ។
ក្របីត្រោសធំមួយញ៉ីមួយហ្ទូន មានកូនកើតច្រាងច្រូងច្រើនប្រកិត
ក្របីត្រោសត្រេកអរសប្បាយចិត្ត ដើរតាមហ្ទូនប្រកិតមិនឃ្ទាតឆ្ទាយ ។

ក្រមើគ្រោសនោះឯងវៃលំខាំង ដោយការពារកំនញ៉ាំងឡាយ
តែចិត្តក្រមើនោះសែនសប្បាយ សែនត្រេកអរកែកយូលំវែងវី ។
លុះមានស្មារតូចគាចក់ជ្រៀតជ្រែក ដោយធ្វើការដំរេកនឹងមេញ៉ី
អាគ្រោសទំប្រើងប្រែងមើលសំតី ប្រច័ណ្ឌចិត្តពេញទីខប់តុំបាន ។
ដេញក់ត់អាស្មារៀវត់ខ្លាត់ខ្លាយ រត់ទៅតាន់ទីឆ្ងាយហួសប្រមាណ
ចោលពួកចោលហ្វូងខ្លួនគ្មានសុខសាន្ត ព្រោះតណ្ហាជាយានយ៉ាងនេះឯង ។

អាគ្រោសទំប្រើងប្រែងការពារញ៉ី ប្រើងទៀយហត់រត់រវីសត្វកន្ទែង
សត្វថ្លៃប្រើងតែសំរួចស្នែង មកាញឹកខ្លាចក្រែងគ្រោសឯទៀត ។
បើមានគ្រោសជាខែចូលមកជល់ ប្រទះគ្នាត្រូវជល់ប្រើងអស់ស្មៀត
កម្លាំងតិចជាងគេប្រើងប្រែងជ្រៀត ចំឡាក់ឆ្កៀតយោងណាគង់ចាញ់គេ ។
បើចាញ់គេរាជេញាក់ត់ស្ទើរស្ទាប់ ខ្លួនត្រូវភ្លាត់ចំណាប់តេ់ចោលមេ
ស្រងាកចិត្តខ្លាំងក្រៃខ្លួនខេ រិះរកលាក់ខ្លួនពួនសម្ងំ ។
អាគ្រោសយំសោកស្តាយរៀងកល់ថ្ម ដោយអាណោះអាល័យចិត្ត

ក្រៀមក្រំ

តើតគួបចិត្តធ្លឹតទ្រូងជាន់ក្តុំ តិតគួរកែសន្សំកម្លាំងកាយ ។
• ភាហរណ៍ក្រមើបមា ជួបមនុស្សនានាជនតាំនឡាយ
បើមានប្រពន្ធច្រើនគេសប្បាយ ប៉ុន្តែតនឹង្រៃភ្លាយទៅជាទុក្ខ ។
កិច្ចនេះជាបែបនៃកុដុម្ពី មានបរាគេស៊ីច្រើនគ្រប់មុខ
មានទ្រព្យពីដូនតាម្តាយឪពុក ទ្រព្យច្រើនមានទំនុកបម៉ែនគោដីរ

គេបង់បានបុំន្ទានគេយកទៅ ត្នានរណាក្ពួលក្ពៅពោលបាក់ដោត
ត្នានរណារុកវានហ៉ានពោលបោទ ថែមទាំងគេមិនធោតបំផ្ទាញទ្រព្យ ។
ចំណែកខ្លួនត្នានទ្រព្យពីណាសោះ ហុតឈាមគេទាំងស្រស់មិនគួរតាប់
រិបដាន់បំភាន់យកដោយឥតច្បាប់ គេក្រឲ្យត់ស្ទើរស្ទាប់ត្នានមេត្តា ។
អ្នកផ្ទើមន្ត្រីត្រូវមានសណ្តាប់ ត្រូវកាន់តាមច្បាប់មានមាត្រា
មិនត្រូវរំលងច្បាប់ដោយតណ្ហា អាណិតរាស្ត្រប្រជាស្ទូតទៀងត្រង់ ។
សណ្តាប់នោះចូលមើលប្រទេសតំ គេផ្ទើបូកវំទំរេស៊ីជង្ស
មានតែប្រពន្ធមួយទំផ្ទិតផ្ទង់ ជំរង់អស់បូកពារមិនឲ្យធ្ជង ។
គេរើសទាំងរូបរាងទាំងទំហំ ទាំងវិជ្ជាស្ពុកស្ពម្ភឈ្ទាសវៃផង
មារយាទកឹតួរតាប់ឥតសៅហ្មង ល្មមជាអ្នកត្រប់ត្រងប្រជាបាន ។
កុំបង់បានសម្បត្តិព្រោះមន្ត្រី គួរបង់បានសិរីសុខក្យមក្សាន្ត
គួរបង់បានកេរ្ត៍ឈ្មោះជាប្រមាណ ថ្ពំថ្ពឹងញាតិសន្ធានតវៃងធ្ទាយ ។
ទុកជាពូជខ្ទួនឲ្យល្អប្រសើរជាង ត្រកូលទាំងពីរខាងមុខរីករាយ
ជួយយិតជួយយោងត្នាឲ្យសាយភាយ ឲ្យបានសុខសប្បាយតវៃងទៅ ។
កុំបង់បានពូជបោរទុកឲ្យកូន ខូបកេរ្ត៍ឈ្មោះបងប្អូនទៅជល់ចៅ
បង្រៀនឲ្យធ្ទើបោរទាំងពូជផៅ យកប្រាក់ពីហោប៉ៅគេរាល់ត្នា ។
មន្ត្រីស្រឡាញ់ធមិសុចរិត មានកិច្ចការប្រព្រឹត្តិតាមមាត្រា
បានថ្ពំថ្ពើងរុងរឿងូបទេព្តា អស់ទាំងរាស្ត្រប្រជាបានសុខសាន្ត ។
ធមិមានប្រាំពីរឲ្យចំរើនយស ជាធមិដឹខ្ពង់ខ្ពស់គួររាប់អាន
ជាហេតុនាំមនុស្សឲ្យថ្ពើងថ្ពាន ថ្ងៃថ្ងាឥតបីមានក្តីមោះហ្មង ។

១. ឧដ្ឋានំ ញាយាមសុរេក្រោកទៀង ធ្វើការដោះថ្កុំថ្កើងត្រូវតន្ទឹង
ចិត្តស្មោះត្រង់នឹងការឥតឆ្គាំឆ្គង មិនច្រអូសយឺតយូនឯលក្បៀតក្រាញ ។
ធ្វើអ្វីទំប្រឹងធ្វើត្រាតែបាន មិនបង្អង់អាក់ខានមិននាំសាញ
មុះមុតនឹងការដោះគ្មានស្មុកស្មាញ មិនមានការបំផ្លាញប្រយោជន៍ខ្លួន ។
២. សតិ ស្មារតីចាំមិនភ្លាំងភ្លេច ឧកេរឃើញមួយរំពេចចាំខ្ជាប់ខ្ជួន
តិតនឹកនូវការម្មណ៍ឃើញមាំមួន ភ្លេចហើយតង់ជួបជួនឧកេរឃើញបាន ។
៣.សុបិកម្មំ ធ្វើការល្អស្អាត ត្រឹមត្រូវល្អតាមខ្នាតល្មមប្រមាណ
ត្រឹមត្រូវតាមពេលម៉ោងមិនអាក់ខាន ត្រូវតាមច្បាប់បូកណាច្បាប់បញ្ញត្តិ ។
បើធ្វើដាមន្ត្រីមានសណ្តាប់ ធ្វើការត្រូវតាមច្បាប់មិនបំបាត់
មិនលោភស៊ីសំណូកកន្ធឹងស្ងាត់ សុចរិតខៀងចាត់មិនលំអៀង ។
៤. ធិសម្មកវណិតបា ទោះធ្វើកិច្ចការណាប្រឹងផ្គាត់ផ្គង់
តិចារណាមុនស្រេចទើបរៀបរៀង ទើបធ្វើមិនឲ្យឃ្លៀងឃ្លាតពីច្បាប់ ។
៥. សញ្ញមោ ប្រុងកាយវាចាចិត្ត សង្រួមឲ្យល្អពិតត្រូវចំណាប់
ឲ្យល្អស្អាតបាតត្រូវតាមសណ្តាប់ មារយាទល្អគួរគាប់មិនធ្លាំធ្លង់ ។
៦. ធម្មជីវីធំប្រែស្រាយថា ចិញ្ចឹមជីវិតជាតាមតន្ទឹង
តាមធម៌ត្រូវតាមច្បាប់មិនមោះហ្មង មិនគួរដល់អ្នកផងតិះដៀលបាន ។
៧. អប្បមាទោមិនប្រហែសធ្វេស មិនខុកចិត្តបរិវេសភ្លេតរិះបាន
ដែលមានចង្កឹមពិសស្នែងជាក់ច្បាន ឱដ៏ជនពាលសាមានឲ្យជួអប្រិយ ។
មិនប្រហែសធ្វេសក្នុងការកុសល មិនវង្វែងវង្វក់ខ្វល់នឹងស្រាស្រី

មិនជ្រុលជ្រប់ធំណែនស៊ីសងក្តី ចាំងមិត្តភក្តិមិនសេពគប់ ។
មិនស្ងើចស្មោលនឹងស្តីបន្ទិចទេ ធ្វើឯកូនប្រពន្ធគេចាំងថ្ងៃយប់
មិនស្ងើចស្មោលនឹងកេតជម្រើតប់ មិនស្ងើចស្មោលសម្តីពាក្យកូល ។
អប្បមាទជាធម៌មានគុណច្រើន ចូរខំប្រឹងក្រើនកុំបញ្ចូល
អប្បមាទធម៌ជាកំពូល ជាមួលនៃពួកធម៌ជាកុសល ។

ធម៌ប្រាំពីរនេះនាំចំរើនយស ព្រះសម្ពុទ្ធដំណែលប្រទានពរ
បើប្រតិបត្តិបានឆាប់កើតផល ឆាប់ដល់ទូរគ្រោយដូចក្តីប្រាថ្នា ។
ពាក្យថាយសគឺសំដៅដំណាប អ្នកផងតែងគោរពទាំងប្តូរចេស្តា
ឆាប់ព្រឿងសម្បត្តិច្រើនខ្ពស់ថ្លៃថ្លា ជាតិដនផងនានាគេរាប់អាន ។
សេចក្តីសរសើរស្អកមានត្រម ក្លេរឈ្មោះល្អសមល្មមសព្វទីហាន
ជាមនុស្សរុងរឿងថ្ងៃថ្លៃឆ្ងាន ឥតមានមោះមៃតយឆឹងសត្រូវ ។

× × ×

នេះឆឹងថ្ងាថ្ងៃឆ្នាំចរចា ខ្ញុំប្រយោជន៍ថ្ងៃថ្ងាក្នុងបច្ចុប្បន្ន
ដែលកើតដែលមានឡើងដល់ពួកជន មានបួនដោយតតិតណាតាមចំនួន ។
បឋមម្ចាស់ឆ្នាំ ទីមួយគឺទស្សាហ៍ដោយចាំមួន
ថ្ងៃនឹងកន្ត្រៃសម្បត្តិប្រយោជន៍ខ្លួន ត្រាតែបានជួបជួនព្រៃមាសច្រាក់ ។
ឥតមានខ្ជិលច្រអូសនឹងការងារ ខំប្រឹងប្រែងពុះពារញើសស្រក់
មិនអើពើនឹងក្តៅឬត្រជាក់ ត្រាតែមានលុយកាក់ដូចបំណង ។
ថ្ងៃនឹងកន្ត្រៃតាមផ្លូវសុចរិត ខៀងចាត់ច្រាកដតិតឥតសៅហ្មង

មានទ្រព្យចរបូណាដូចប៉ុនបំផុត អស់មហាជនជនគោតស្ងប់សែនៗ

ទុតិយោ វគ្គសម្បទា

ទំពីការការពារដួងសំរែង

រកទ្រព្យសម្បត្តិដោយខ្នះខ្នែង ចាត់ចែងគ្រឿងការពារការពារមាំៗ

បើមានគោក្របីជំរីសេះ នៃធនៃបះការពារបះថែទាំ

ឲ្យល្អឲ្យគង់វង់តាមលំនាំ តាមចាស់ពុំផ្តែផ្តាំប្រឿនប្រដៅៗ

មិនឲ្យចោរលួចនាំយកទៅបាន ខូចខាតទ្រព្យដែលមានកើតសុបសៅ

ខូចប្រយោជន៍នៃខ្លួនចិត្តក្តួលក្តៅ មកពីខ្លួនល្ងង់ខ្លៅឬប្រហែសៗ

ធ្វើក្រាលរបងឃ្នងឲ្យមួនមាំ ការពារថែទាំពុំមានធ្វេស

ការពារប្រយោជន៍ខ្លួនយ៉ាងវិសេស ឲ្យគង់តាមប្រទេសកាលយ៉ាងណាៗ

តេជ្រចិលកែវតែចូរឬម្ចាស់ប្រាក់ សំពត់គ្រឿងស្លៀកពាក់ហូលព្រៃផ្តាំ

គង់វង់ដោយរបាងព្រោះរក្សា ដោយខុបាយបញ្ញាអ្នកម្ចាស់ទ្រព្យៗ

ការពារក្សាជាកិច្ចធំបង្អស់ អ្នកជាន់តាមជាន់ខ្ពស់ដូចគាំងសព្វ

បើគ្មានរក្សាទេនឹងអស់ព្វ ឈ្មោះថាមនុស្សឆ្កាំបន្ទាស្មោតតើៗ

ដួចប្រទេសនានាពាក់ពន្ធលោក អ្នករក្សាជ្រោកជ្រោកគ្មានសំរិ

គ្មានចិត្តស្លូតស្មោះត្រង់សាមគ្គី ខូចអស់ព្រះធរណីឃុំស្រុកទៃត្រៃៗ

ដូចជាទៃត្រចាសាក់ព្រះត្រៃតាំង ក្រមួនសន្ធឹងទ្រាំងយើញក្រវៃឡៃ

ចាណាមមាត់ជ្រូកក្បែរគោះអណ្តែត ដីជិតស្រុកប៉ែតប៉ែតកុំជនធំកែៗ

ហេតុនេះមកពីខ្នះការពារក្សា ខ្នះខុបាយបញ្ញាប្រុសឯក

មានតែអ្នកលិញលួញនាំប៉ែបបែក មានតែតាមចំណែកយកអំណាចៗ

ចាន់ជាធ្លាក់ទៅនៅតែណាប់ដៃ នៃជនជាតិជាទៃអ្នកគោនគាច

គេយើញយើងខន់ខ្លាយគេមិនភូច គេកតតក្សាតជាបសាចដុំវិញជែន ។
ជាតវៃទ្រពាំនឹខ្លាយចូរពិចារណា ត្រិះរែះដោយបញ្ញាវាងវៃខ្លួន
ចូរការពារប្រយោជន៍ឲ្យមែនទែន ឲ្យត្រូវតាមបែបផែនក្បួនតម្រា ។
ការរក្សាការពារជាប្រយោជន៍ ដូចជាសត្វស្រមោចនឹងសង្កា
ខេះការពារពាំពនរបស់ក មនុស្សជនានាគួរយល់ជាក់ ។

ឥតិយោ កល្យាណមិត្តតា ទីបីគឺបញ្ញាសេតមិត្រភ័ក្តិ

ជាមនុស្សត្រឹមត្រូវល្អសមស័ក្តិ មិនដឹតជាមប្រឡាក់ដោយទោសជាប ។
សេតគប់មនុស្សល្អជាបណ្ឌិត ប៉ាន់សុទ្ធចំរើនពិតជាជាប
តែងបានវិជ្ជានឹងបុញ្ញាលាភ ចៀសអំពើថោកគាបបានដោយងាយ ។
ការសេពគប់អ្នកជាកើតមង្គល កើតមានពុណ្យកុសលក្តីរីករាយ
កើតមានក្តីសរសើរក្តីសប្បាយ ចៀសភ័យអន្តរាយកើតពីចិត្ត ។
ការសេពគប់អ្នកជួជាតិអប្រិយ ឥតមង្គលស្ងួស្តីដល់ខ្លួនពិត
នាំឲ្យដើរផ្លូវឃ្លាងមួយជីវិត នាំឲ្យលិចនិងឥតច្រាជ្យ ។
ព្រោះហេតុជួបប្រទះឯងអ្នកពាំនាំខ្លាយ ចូលអ្នកខំខ្វល់ខ្វាយរកអ្នកជា
យកជាមិត្រមេត្រីភ័ក្តិសន្ធក្យ ជាប្រយោជន៍កន្លងនាលោកភ័យអើយ ។

បត្តិ្តា សមជីវិតា ទីបួនគឺបញ្ញាដែលត្រូវធ្វើយ

ការចំណាយជីវិតមិនជ្រួលច្បើយ ល្មមខ្រួតដែលមានហើយពាំនាំប៉ុន្មាន ។
មិនចាយឲ្យជ្រុលជ្រួសហួសសម្បត្តិ ស្មារតីប្រុងប្រយ័ត្នមិនធ្វេសប្រាណ
មានតិចចាយតាមតិចឥតរំខាន ចាយតិចច្រើនតាមបានតាមមានល្មម ។

នេះឯងហើយហៅថាចេះលំអិត　　ចេះចាយទាំងចេះរកសព្វគ្រប់គ្រាន់
ចេះលើកទាំងចេះជាក់ចេះថ្នាក់ថ្នម　　ចេះបីទាំងចេះបម្រុងថ្នមបញ្ចុក　　៦
នេះហៅថាប្រយោជន៍ក្នុងលោកនេះ　　ព្រះពៃញ្ញអ្នកចេះបានថ្លៃធំខ្ពស់
ជាផ្លូវប្រតិបត្តិនៃអ្នកស្រុក　　ទីឯបានជ័យជាសុខក្នុងបច្ចុប្បន្ន　　៧
ចំណែកប្រយោជន៍ខាងបរលោក　　ព្រះសម្ពុទ្ធទ្រង់ជ្រាបគុណអនន្ត
ទ្រង់សំដែងក្រោសប្រាប់ជានិរន្តរ៍　　ដល់ពួកប្រជាជនថាមានបួន　　៨
១. ស្ទឹង្គ តិដ្ឋន្តេកាវេជ្ជិ ចាំ　　ចំពោះអំពើកម្មរបស់ខ្លួន
កើតដោយតាយក់ចាចិត្តមាំមួន　　សមស្មួនតាមចំនួនចេតនា　　៩
កម្មនោះជាកុសលអកុសល　　តែងតែឲ្យផលប្រសើរជា
ទីឯជួអាក្រក់ជាធម្មតា　　អ្នកមានជួនបញ្ញាតួរចងចាំ　　១០
ការវេជ្ជិត្រង់ថាកតីសុខទុក្ខ　　ល្អអាក្រក់ត្រូវតាមចំណាំ
ហៅថាវេជ្ជិត្រង់ផលរបស់កម្ម　　នេះជាពាក្យបណ្តាំព្រះសាស្តា　　១១
ការវេជ្ជិថាពួកសត្វកើតក្នុងលោក　　ធ្វើកម្មច្រើនតរៀងត្រូវលៀ
កម្មនោះជារបស់នៃគាត្មា　　ហៅថាសត្វមានកម្មរបស់ខ្លួន　　១២
ការវេជ្ជិថាសត្វមានកម្មជាញាតិ　　ជាកំណើតមិនឃ្លាតដាច់តាំមួន
មានកម្មជាដៅតស្បៃពួតដន្លាប់ខ្លួន　　មានកម្មជាច័ពួនជ្រកកាស្រ័យ　　១៣
សត្វធ្វើកម្មឯណាជាកុសល　　ឬជាកម្មវៃកលថាបបន្ត្រៃ
ទទួលផលកម្មនោះជាបច្ច័យ　　ច្រាកដឥតសង្ស័យជាធម្មតា　　១៤
ការវេជ្ជិតោងញ្ញាណព្រះសម្ពុទ្ធ　　ជាម្ចាស់ត្រៃលោកជាសាស្តា
ត្រាស់ដឹងពិតច្រាកដដោយបញ្ញា　　អស់កិលេសវាសនាគឺប្រយោគ　　១៥

ត្រាស់ដឹងព្រោះធម៌ដោយត្រូវពិត ឥតមានរបៀតកូនក្រៃលោក
ឥតខើសពាល់បញ្ហាអ្នកប្រាជ្ញព្រោក រួចផុតចេញពីភេតគតីក្តីលង់ ។
ការជឿយ៉ាងដូច្នេះហៅសទ្ធា ជាប្រយោជន៍មហិមាវែងឆ្ងាយណាស់
ជូនទៅលោកខាងមុខឱ្យមានទ្រង់ ជាផលនិសង្សសុខក្សេមក្សាន្ត ។
២. សីលំ ការសង្រួមកាយវាចា ឱ្យស្អាតបាតថ្លៃថ្លាដោយខ្នាន
គឺសីលប្រុំប្រាំបីជាប្រធាន ជាកុសលកើតបានផលជាសុខ ។
៣. ភាវនា ការលះបង់ក្តីកំណាញ់ លះឲ្យជាសំឡាញ់មិនលាក់ខុក
ធ្វើទានយកភាគផលទៅខាងមុខ មិនធ្វើសុកត្រលុកក្រៅតម្រា ។
៤. បញ្ញា គឺការដឹងយល់ខួរក្បាល សព្វត្រង់ចាំតែកូនក្រៅស្អាតភ្លឺថ្លា
ជាដួងវែកវៃតួមប្រសើរជា ជាឲ្យតាប់ចិត្តាជនចាំនឹងឲ្យយ ។
ធម៌ចួនប្រការនេះហៅឲ្យធំ ជាប្រយោជន៍ស្អកស្តួមមិនខ្ចាត់ខ្ចាយ
នាំជនដើរទៅកាន់បរលោកនាយ ឋានក្តីសុខសប្បាយឥតមានហ្មង ។

+

× ×

យើងខ្ញុំបានឮ យោសធម្ម រៀនចាំលើមុតមាំត្រូវចំនង
សាសនាព្រះពុទ្ធតាមតន្ត្រង លោកអ្នកប្រាជ្ញរៀមច្បងពីបុរាណ ។
នាមដើមខ្ញុំឈ្មោះសៃសុ ជាមហា ជាអ្នកមានប្រាជ្ញាស្មារតីបាន
តាក់តែងជាច្បាប់ស្នួនពាក្យខ្ញុំខ្ញាន ឱ្យបានដល់មនុស្សពាំនឹងប្រុសស្រី ។
ខ្ញុំធ្វើជាមេវត្តនាម៉ក្រុង ភ្នំពេញជាកំពង់រាជបូរី
នាមវត្តហៅថា ម៉ហាមន្ត្រី ប្រកបដោយសិរីដ៏ឆមង្គល ។

ចៃចៃត្រេដើមឆ្នាំវកអដ្ឋស័ក ព្រះនិព្វានជាងជាក់ពីរពាន់ដល់
នឹងបួនរយកៅសិបបានជួបដល់ នឹងប្រាំបួនឆ្នាំសល់នៅខាងបុង ។
អង្គារប្រាំបួនកើតចៃចៃត្រេនោះ និពន្ធស្រេចបំពោះទុកបម្រុង
ជាប្បាប់សម្រាប់អានទុកខាងក្នុង បំផ្ទុងបំភ្ទឹអស់ជនប្រុសស្រី ។
ខ្ញុំបានថ្ទាថ្ទែងចែងអធិប្បាយ ជាពាក្យមរិយាយសង្ខេបខ្ទី
ជាកាព្យពាក្យប្រាំពីរនឹងប្រាំបី ចែងចប់អស់សេចក្តីប៉ុណ្ណះឯង ។

ថ្ងៃ ៣ ៥ ឆ្នាំវកនៅក្នុងសប្តស័ក ព.ស. ២៤៩៩

ត្រូវនឹងថ្ងៃទី ២០ ខែមីនាឆ្នាំ ១៩៥៦

ព្រះយោសធម្ម ម៉ឹង សៃស

ដោយសេចក្តីអាសោះអាល័យគាណិតគាសូរប្ញទ្ធិស័ត្យណាស់ សេដ្ឋីទើបចូលទៅសុំទោសលោកថាលិតថា:

–កូនប្រុសរបស់ខ្ញុំមិនខុសពីមនុស្សកូចខ្ចីនេះ ជាអ្នកមិនស្គាល់ប្រមាណកម្លាំងចិត្តរបស់ខ្លួនថាមានត្រឹមណា, កម្លាំងចិត្តរបស់ខ្លួនឯងនៅមិនទាន់ធ្ងន់ធ្ងល់មុនឹងប្រព្រឹត្តទៅតាមគំនិតដែលបានគិតខុកមកនេះ លុះបានឮលោកឱ្យដំណឹងក៏គិតថា កំឡាំងចិត្តរបស់ខ្លួនឯងបានតែត្រឹមប៉ុណ្ណេះ ជាខ្លាំងមិនបានទៀត ។

អមាត្យថាលិតបានស្តាប់សំដីសេដ្ឋីកំលែងប្រកាន់ទោស ប្រញាប់ពាក្យប្ញទ្ធិស័ត្យឱ្យក្រោកឡើង រួចនិយាយថា:

–ខ្ញុំបានតាំងចិត្តថានឹងមិនទាំដំណឹងនេះមកប្រាប់លោកនេះតែដោយសេចក្តីគាណិតក្រែងលោកនឹងកើតទុក្ខខ្លាំងទៅទៀត លុះខ្ញុំបានឮពាក្យក៏ប់រងើយដ៏ជាក់ប្លាស់ហើយមានហេតុផលផង ខ្ញុំប្រាថ្នាឱ្យលោកផុតទុក្ខទើបប្រាប់រឿងនេះឱ្យលោកដឹង, សូមលោកនឹកដល់ពាក្យដែលលោកប្រាប់ខ្ញុំឱ្យមែនទែនឡើង ហើយកុំគិតអ្វីទៅទៀត, ចូរប្រុងប្រៀបខ្លួនទៅផ្គួបលោកនឹងនឹងសុរពលចុះ ទើបនឹងបានដឹងរឿងដ៏វិសេសជាងដែល

ស្ងរ្ងុំ៖ៅ៖ៀត" ។

ក្នុងរយៈ៖ៅលាមិនយូរប៉ុន្មាន សេដ្ឋីនឹងបុត្ត្រិស៍ត្យ ក៏ចេញ៖ៅផ្ទបនន្ទិ អមាត្យឯ៖ក្រៅ៖ក្រុងរ៖សាលី ។ លោកនន្ទិនឹងសុរពលសំដែងសេចក្តីសោម-នស្សចំពោះបុត្ត្រិស៍ត្យនឹងសេដ្ឋីដែលពណិនាប្រាប់រឿងផ្សេង ៗ ដែលកន្ទងមកហើយក្នុងក្រុងរាជគ្រឹះ ដរាបដល់អមាត្យបាលិតបានទទួលដំណឹងអំពីឧបសម្សត៖ ទើបបបួលគ្នាដើរផ្ទូរមក តែសេចក្តីមិនទៀងរបស់ជីវិត មិនមានអ្នកណាស្មានបាន,សេចក្តីស្ទាប់របស់នាងកាញ្ចនា ទើបកើតឡើងក្នុងរ៖លានោះ ។ នន្ទិអមាត្យលុះពណិនារឿងរ៉ាវផ្សេង ៗ ដែលកន្ទងមកហើយ រួចបានសរសើរបុត្ត្រិស៍ត្យជាច្រើន ។

កាលបើបានសាកស្ងរសុទទុក្ខគ្នាហើយ សេដ្ឋីទើបបរួលនន្ទិអមាត្យនឹងសុរពលចូលទៅស្នាក់ក្នុងនគរ៖សាលីក្នុងវិថ្ងនោះ ។

*
* *

- ១៣ -

បុណ្យសាសនា

សេចក្តីស្ទាប់ជារបស់ទៀង សម្រាប់ជីវិតមនុស្ស មិនចំពោះតែបុគ្គលណាមួយដែលមានគូស្នេហាក្នុងលោកនេះទេ សូម្បីបុគ្គលដែលគ្មានគូស្នេហា សេចក្តីស្ទាប់ក៏ចេះតែរុករាន ឥតគោតញ្ញាញ្ញើតដូចគ្នា ។ មួយទៀត, សេចក្តីស្ទាប់កាលកើតឡើងដល់បុគ្គលណាម្នាក់ហើយ អាច

នាំសេចក្តីទុក្ខមកឲ្យដល់អ្នកដទៃច្រើនណាស់ជាន់ខ្លាំងណាស់ ។ ឯបុគ្គលម្នាក់ដែលជាប់ជួបប្រទះនូវសេចក្តីក្រាន់ក្រៃ ដោយសេចក្តីស្លាប់របស់បុគ្គលជាទីស្រឡាញ់ ឧន្តរ្តូវមានសេចក្តីទុក្ខ ព្រោះការក្រាន់ក្រៃជាធំធៃក្រៃលែង ។ បើប្រសិនជាអ្នកដទៃមិនមែនឯប្តូរិស័ត្យវិញទេ គេក៏មិនអាចនឹងហាមឃាត់នូវសេចក្តីទុក្ខនេះបានឡើយ ។ ឥឡូវនេះ ប្តូរិស័ត្យបានទទួលជាកិច្ចកង្វល់ព្រះពុទ្ធសាសនារួចស្រេច ហើយត្រឡប់ឃើញមកជាគ្រហស្តវិញ ជាអ្នកបរិសុទ្ធដោយការជម្រះចិត្តឲ្យផុតចាកសេចក្តីសៅហ្មង អស់រយៈវេលា ៤ ខែ ។

កិច្ចជាដំបូងដែលគេនឹងចូលទៅកាន់តេទជាកិច្ច តម្រូវការសាក់ឲ្យរលើង ហើយស្បែកដណ្តប់នូវសំពត់ជ្រលក់ដោយទឹកអម្ចត់ ចូលទៅក្នុងព្រះវិហារ បន្ទឹកថាសូមទទួលសម្តែចំពោះលោកសង្ឃទ្រង់សីលដែលជាប្រធានក្នុងពួកសង្ឃ, លុះព្រះសង្ឃអនុញ្ញាតឲ្យជាកិច្ចបានហើយ តពីនោះទៅកិច្ចដែលត្រូវចំពេញគឺអត់អាហារពេលល្ងាច មិនមានការខ្វល់ខ្វាយក្នុងការស្វះស្វែងរកជោគលាភដទៃទៀតឡើយ ។ វេលាព្រឹកចេញបិណ្ឌបាតទទួលអាហារបិណ្ឌបាតពីអ្នកស្រុកមកបរិភោគ ធ្វើជីវិតឲ្យរស់នៅដោយអ្នកស្រុកចិញ្ចឹម មិនមានកង្វល់ដោយកិច្ចដទៃទៀតឡើយ ទិតទំទួលយកពាក្យប្រៀនប្រដៅអំពីទេវធម្មយ៉ា អាចារ្យមកអប់រំខ្លួន ឲ្យស្គាល់ច្បាស់នូវលោកផ្សេងៗជាដំបូង, ទោះបីសេចក្តីមិនទៀងទាត់ជាពិតប្រាកដរបស់សត្វក្នុងលោក ចាត់ថាជាទុក្ខកង្វល់អំពីកើត

ជាតាកេមក ភាពជាតាកត្រូវបានទទួលការចិញ្ចឹមបីបាច់ថែទាំអំពីអ្នកជាម្ចាស់ មានមាតាបិតាបង្កើតខ្លួនជាដើម, គឺពោះទៅរយៈពេលដែលមានការឈឺចាប់ការស្លាប់ត្រូវមានជាពុំខាន, ក្នុងការពិចារណានេះខ្លួនត្រូវដាស់តឿនខ្លួនឯងឲ្យដឹងថា ជីវិតដែលកន្លងទៅ ។ តើបានធ្វើកុំខ្លះហើយ ដែលអាចញ៉ាំងជីវិតឲ្យប្រព្រឹត្តទៅក្នុងព្រះពុទ្ធសាសនា ឬក្នុងសីល្យជាកុលបុត្រមួយរូប ដែលធ្វើខ្លួនឲ្យបរិសុទ្ធមានចិត្តម៉ាត់ចត់ស្អាតបានដោយប្រការដូច្នេះឯង ។

នគរវៀសាលីក្នុងសម័យនេះ ជានគរយ៉ាំងធម៌មួយក្នុងជម្ពូទ្វីប, ព្រះរាជាទ្រង់គ្រប់គ្រងនគរណាប្រជាកស្ត្រ ឲ្យត្រជាក់ត្រជុំជាសុខស្ថាពរដោយធម៌ អាចញ៉ាំងប្រជាជនឲ្យមានសេចក្តីស្រឡាញ់កត្តញ្ញូដោយស័ព្ទសាធុការពរខ្លួនៅគ្រប់ទិសានុទិស តាំងអំពីបុគ្គលសីល្យបានទទួលសមមន្ត្រីខ័ណ្ឌសីមេចញ្ជើមកវិញ ។ ព្រះអង្គទ្រង់សំគាល់ក្នុងព្រះទ័យជានិច្ចថាបុគ្គលសីល្យបានធ្វើគុណដល់ព្រះអង្គដ៏ធំក្រៃពេក គឺមិនឲ្យព្រះអង្គធ្វើពិធីបូជាយ័ញ្ញជាពុំណាកម្មយ៉ាំងយោរយៅ ណែនាំព្រះអង្គឲ្យចូលកាន់ព្រះពុទ្ធសាសនាព្រមទាំងបានតាំងចូលទទួលជ័តាវបស់ព្រះអង្គ ឲ្យបានសរជាពាកព្រះពេតមានជន្មាយុជាបឋមកដល់សព្វថ្ងៃនេះ ។ ព្រះអង្គមានជន្មាយុ ៦០ ព្រះវស្សាដោយបរិបូណ៌ សន្មត់ថាដកកាតទាំងណាស់ទៅហើយ មានព្រះទ័យចំណាន់ធំដើរកិច្ចការបស្ថានគុណចំពោះបុគ្គលសីល្យ គឺព្រះពេជ្ឈានព្រះធាតុឲ្យ លុះទ្រង់តម្រិះក្នុងព្រះហឫទ័យដូច្នេះ ទើបមានព្រះបន្ទូលឲ្យទៅហៅបុគ្គលសីល្យទាំងបីតាបូលមកគាល់ ។

សេដ្ឋីនឹងបុត្ថិស័ត្យកំពុងប្រឹក្សាគ្នាអំពីការដើរផ្ទូវត្រឡប់ទៅកាន់ក្រុងរាជគ្រឹះ, ជួនជាមហាតលិកទៅដល់ជំរាបថាព្រះរាជាទ្រង់មានព្រះបន្ទូលហៅឲ្យចូលទៅតាល់ ក៏ប្រញាប់ប្រញាល់ចូលទៅតាល់ភ្លាម ។ ព្រះរាជាទ្រង់ឃើញហើយក៏មានព្រះបន្ទូលសួរថា លោកនឹងនៅក្នុងនគរយើងតទៅទៀតបានបុទេ?"

សេដ្ឋីដោយមិនបានតិតទុកមកពីមុនសោះ ក៏តិតក័យហើយក្រាបបង្គំទូលថា:

-សូមព្រះតេជះដំកល់លើត្បូង! ខ្ញុំព្រះអង្គនឹងនៅស្នងព្រះតេជះព្រះគុណបានយ៉ាងដូចម្តេចកើត បើខ្ញុំព្រះអង្គមានជរាភាពណាស់ហើយ។ មិនអាចប្រតិបត្តិនូវព្រះរាជកិច្ចស្នងព្រះអង្គបានផង ។

ព្រះរាជាទ្រង់ត្រសម្ដ្រូលៈ រួចត្រាស់ថា:

-ការណ៍នោះលោកមិនត្រូវនឹកដល់ទេ ការដែលខ្ញុំសួរលោកនេះ ក៏ដោយខ្ញុំមានបំណងម្យ៉ាង តែមិនដឹងជាលោកត្រេកអរដែរបុទេ ។ សេដ្ឋីមិនដឹងនូវព្រះរាជបំណងក៏ដើងឆ្ងល់ក្នុងចិត្តរិតតែខ្ជាំងឡើង ហើយក្រាបបង្គំទូលថា:

-សូមឲ្យព្រះតេជះដំកល់លើត្បូង! បើព្រះអង្គមានព្រះរាជបំណងដូចម្តេច សូមទ្រង់មានព្រះរាជបន្ទូលចុះ ខ្ញុំព្រះអង្គនឹងត្រេកអរស្នងនូវព្រះរាជបំណងនោះ ។ ព្រះរាជាទ្រង់គង់នៅស្ងៀម ដោយទ្រង់នឹកសង្ឃឹមថា បើព្រះអង្គកាត់ព្រះទ័យថ្ថងរឿងដែលជាការណ៍ស្លាត់កំបាំងរបស់ព្រះអង្គទៅ ប្រហែលជាបានសម្រេចដូចបំណង, ក្នុងទីបំផុតក៏ទ្រង់

កាត់ព្រះទ័យមានព្រះពរជបទូលដោយព្រះសូរសៀងញ័រ ។ ថាៈលោកបាន
យើញជរាកាតរបស់យើងឬទេ? សត្វទៃថ្ងៃដ៏តែយើងដូចឈើដុះដិតជ្រាំង
បាក់ទឹងជល់ខ្យល់សេចក្តីសាបសូន្យក្នុងពេលមិនយូរប៉ុន្មានទេ ឯកូនស្រី
របស់យើងទៅមិនគាន់មានបន្តិចសោះឡើយ យើងប្រាថ្នាទឹងឲ្យកូនស្រី
យើងមានតួត្រង់តាមប្រពៃណី យើងនឹកយើញថាប្តូរិស័ត្យមានគុណ
បំណាច់ទឹងយើងច្រើនណាស់ ល្មមតែយើងនឹងតបស្នងគុណនោះវិញ
ដូច្នេះ យើងនឹងលើកយកព្រះធីតាយើងនេះឲ្យប្តូរិស័ត្យដើម្បីជាតិប្តូសង
គុណដ៏ធំក្រៃលែងរបស់ប្តូរិស័ត្យ ដូច្នេះហើយយើងទើបហៅៈលោកមាន
ពីរមក ។ ទ្រង់មានព្រះបន្ទូលហើយតន់ឆាកព្រះកំក្រៀមមានព្រះបញ្ជា
(បង្ហូប) រនាំចាំស្តាប់សំដីឥស្សរជនទាំងពីរនាក់នេះ ដោយព្រះគាការ
ស្ងប់ស្ងៀម ។

សេដ្ឋីមិនអាចនឹងខ្លួលព្រះពជាក្សាមបាន លោកសម្លឹងមើលមុខ
ប្តូរិស័ត្យខ្លះឆាកដូចជាចង់ស្ងួរចិត្ត តើស្តេចចិត្តខ្លួលតាមព្រះបន្ទូល
ឬទេ? ចំណែកប្តូរិស័ត្យអង្គុយស្ងៀមស្ងាត់មួយស្របក់ ។ ព្រះពជាទ្រង់
បែរព្រះភ័ក្ត្រត្រឡប់ដួងព្រះនេត្រត្រង់មកចំមុខប្តូរិស័ត្យវិញ ។ ប្តូរិស័ត្យ
ប្រញាប់ថ្វាយបង្គំខ្លួលថាៈ សូមព្រះតេជះដ៏តស់លើសួន! ខ្ញុំព្រះអង្គជាអ្នក
ដំណើរ ប្រៀបដូចមនុស្សពាន្ទេចរចេញចាកទីដាច់ មិនមានកិត្តិយសអ្វី
ដ៏សមគួរល្មមជាតូនៃព្រះជាតាបានទេ សូមព្រះអង្គទ្រង់ព្រះតម្រិះដោយ
ព្រះប្រាជ្ញាដ៏សុខុមជាមុនសិន មួយទៀតខ្ញុំព្រះអង្គខ្វាយក្រែងបំពានព្រះ
អង្គមិនយល់ស្របតាមព្រះអង្គជនកំជាហេតុឲ្យអាប់ព្រះកិត្តិយសព្រះអង្គ ។

ព្រះរាជាទ្រង់មានព្រះរាជបន្ទូលថា អ្នកឯងមិនមែនមិនសមនឹងកូន
ស្រីយើងទេ យើងកាត់សេចក្តីឆ្មាស់ហ៊ានស្ទរចិត្តអ្នកឯងនេះ ដោយ
យើងយល់ច្បាស់ថា ត្មានឥស្សរជនណាមិនយល់ស្របតាមយើងទ្បើយ
យើងនឹងប្រឹក្សានាម៉ឺនសព្វមុខមន្ត្រីអមាត្យតាំងឡាយមើល បើមិនមាន
នរណាទទឹងតាស់ទេ គើឯងនឹងព្រមទទួលប្ដូទេ?" ។

ឬទ្ធិស័ត្យមិនតាន់ទូលតបភ្ជាមទេ ក្នុងចិត្តគេគិតថា ពិតមែនតែព្រះ
ធីតានេះជាព្រះធីតានៃព្រះរាជា តែព្រះទ័យព្រះធីតាអាចមិនស្របនឹងព្រះ
បិតាក៏ថាបាន បើដូច្នោះ គេនឹងព្រមទទួលព្រះរាជតានពុំតាន់បាន គិត
ដូច្នេះហើយក៏ថ្វាយបន្ទំគ្រោយទូលថា: សូមព្រះគេជះដំកល់លើត្សូង, នៅ
មានមួយទេទ្រឹតដែលខ្ញុំព្រះអង្គសង្ស័យ គឺខ្ញុំព្រះអង្គមិនតាន់ដឹងព្រះទ័យ
ព្រះធីតា បើរូបទូលព្រះបន្ទំនេះមិនមានការតាស់ព្រះទ័យនៃព្រះធីតាទេ
ខ្ញុំព្រះអង្គក៏ព្រមតាមព្រះតម្រាស់ត្រប់ប្រការ ។

ព្រះរាជាទ្រង់ព្រះសណ្ឋាប់ហើយក៏សោមនស្សនៃក្រពេក ព្រោះព្រះ
អង្គទ្រង់ជ្រាបច្បាស់ថាតាំងអំពីឬទ្ធិស័ត្យ បានរក្សាអាការប្រឈូនរបស់
ព្រះអង្គម្ចាស់ក្សត្រីឲ្យសះជាហើយ ព្រះអង្គម្ចាស់ក្សត្រីបានលើកដំកើង
គុណរបស់ឬទ្ធិស័ត្យ ទូលព្រះអង្គជារឿយៗ ធ្វើឲ្យព្រះរាជាជឿថា ម្ចាស់
ស្ត្រីតង់នឹងប្រតិព័ទ្ធចំពោះឬទ្ធិស័ត្យជាប្រាកដ ។

កាលទ្រង់ព្រះបិន្ទាយើញច្បាស់ដូច្នោះហើយ ទើបទ្រង់អនុញ្ញាតឲ្យ
មនុស្សតាំងពីរត្រឡប់ទៅតាន់ទីស្នាក់វិញ ។

ហេតុការណ៍ដែលមិនឆ្ងាប់គិតនឹក រមែងកើតមានដល់មនុស្សត្រប់

ឆ្នា ហើយហេតុការណ៍ទាំងនោះ រមែងមានមកអំពីហេតុនៃការធ្វើទាំង
អស់ ។ ឬទ្ធិសីត្យជាអ្នកប្រកបដោយគុណគឺសេចក្តីល្អ បានជួបប្រទះ
នឹងជលដែលកើតឡើងដោយមិនបានគិតនឹកទុកជាមុន ។ ព្រះរាជា
បានប្រឹក្សានឹងអមាត្យទាំងពួង, បណ្តាអមាត្យទាំងឡាយមិនមានអ្នកណា
ជំទាស់ សឹងសំដែងកិរិយាត្រេកអរវីកកាយចំពោះព្រះយោបស់របស់ព្រះ
អង្គត្រប់ ៗ ឆ្នា ។ ព្រះរាជាកាលសំដែងព្រះរាជបំណងដោយស្មោះត្រង់
ប្រាប់ពួកអមាត្យជូវ្នោះហើយ ទ្រង់ក៏ចង់ជ្រាបព្រះទ័យព្រះរាជធីតា ទើប
ទ្រង់ហៅព្រះរាជធីតាមកសួរ ព្រះធីតាបានទូលតបមិនទទឹងទាស់នឹងព្រះ
រាជបំណង ។ ព្រះរាជាទ្រង់សោមនស្សជាយ៉ាងក្រៃលែង ទើបទ្រង់
ត្រាស់បញ្ជាក់ឲ្យឬទ្ធិសីត្យដឹងត្រប់ប្រការ ហើយទ្រង់ឲ្យផ្សាយដំណឹងដល់
បណ្តាប្រជាជនទូទៅទាំងព្រះនគរឲ្យបានដឹងថា ទ្រង់នឹងអភិសេកឬទ្ធិសីត្យ
នឹងព្រះរាជធីតា ក្នុងថ្ងៃ ..... ខែ ..... ដែលមានបុក្សយាមល្អ ។

ក្នុងពេលរសៀលថ្ងៃមួយ, ឬទ្ធិសីត្យនឹងព្រះរាជធីតាបានជិះសេះ
មួយម្នាក់ចេញចាកព្រះនគរវេសាលី តម្រង់ចូលទៅកាន់ដងព្រៃជ្រៅ
ហើយជិះសេះតាមផ្ទូវកាត់រៀង ៗទៅ មិនយូរប៉ុន្មានក៏បានទៅដល់កន្ទែង
មួយដែលមានពួនដីក្រោមដើមឈើមានផ្តាះស្រាបទាំងដើម ជាទីត្រជាក់
សប្បាយ ឬទ្ធិសីត្យក៏បានពណ៌នាអំពីរឿងរាំជាអតីតរវាងទ្ទូនគេនឹងនាង
កាញ្ចានា ដែលគេកប់រូបក្រោមដើមឈើមានផ្តា ឲ្យព្រះធីតាជ្រាប ហើយ
គេមានសេចក្តីរត្មកនឹកដល់គុណរបស់នាងជានិច្ច សូម្បីនាងនោះអនិច្ចកម្ម
បាត់ទៅហើយ គុណគឺសេចក្តីល្អនោះអាចជាស់គឿនចិត្តគេឲ្យនឹកឃើញ

មិនគ្រូបសោះ ហើយបបួលព្រះរាជធីតាឲ្យមកមើលផ្នូរកប់សពនាង, ឬទ្ធិស័ត្យ៍បាននឹកដល់អានិសង្សនឹងផលបុណ្យទាំងឡាយ ដែលបានធ្វើមកហើយក្នុងជាតិនេះ ឧទ្ធិសឲ្យដល់នាងកាញ្ចនា ដើម្បីឲ្យបានសម្រេចសម្បត្តិសុគតិហើយបបួលព្រះរាជធីតាធ្វើសេចក្តីគោរព រួចនាំគ្នាឡើងជិះសេះត្រឡប់ចូលទៅកាន់ព្រះនគរវសាលីវិញ ។

កម្មទាំងពួងដែលខ្ជនធ្វើអំពីមុន
ជាកម្មទុនញ្ញាំងជាតិនេះឲ្យបានផល
ព្រោះពួជល្អម្ហអាក្រក់តែងតែផ្តល់
គឺឲ្យផលល្អអាក្រក់ដល់ខ្ជនអឺយ ! ។

ចប់

រឿងសាមកុក

កណ្ឌ ៦៧

ឧកញ៉ាវិបុលរាជសេនា ន្ធ-កន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃធ្លាសបើបានអាន
នឹងបេះឧបាយកលបំណាន
ទាំងមានសន្ទានស្នេហាជាតិ

ត្បូតៅធ្វើយទ្បើងថា ខ្ញុំបាទសូមអង្វរលោក ព្រោះបូធ្ធូលើកទ័ពទៅនោះ មុខជាមានតែកូនទាហានទៅរក្សាបន្ទាយទេ សូមឲ្យលោកលើកទ័ពទៅតាមពាក្យខ្ញុំបាទចុះ ។ អ្ជិនសៀវកឹយល់ឃើញត្រូវជង ទើបចាត់ទៀវ-ទាប់នឹងគោឡាំឲ្យលើកទាហាន ៥០០០ ទៅវាយយកបន្ទាយបូធ្ធ ហើយឲ្យជៀវតីលើកទាហាន ១០.០០០ ទៅជួយអីទេងទៅជំបន់អ្ជិចៅ ។ នាយទាហានទាំង ៦ កង ក៏លើកទៅតាមពាក្យអ្ជិនសៀវបង្គាប់ក្នុងពេលកណ្តាលយប់នោះ ។

ឯកងទាហានបូធ្ធូនោះ លុះវាយយកបានជំបន់អ្ជិចៅហើយ ក៏រើជញ្ជូនយកបស់ទ្រព្យ គឺគ្រោះនឹងគ្រឿងសាស្ត្រាវុធទៅជ័យជារបស់អីទេងច្រើនណាស់ ហើយទាហានដែលចាប់អីទេងបាន ក៏នាំយកខ្ជូនទឹងគ្រឿងប្រដាប់ទៅជូនបូធ្ធ ។ ក៏ឲ្យកាត់ម្រាមដៃ, មាត់, ប្រមុះ, នឹងត្រចៀក

អ៊ីខេងចេញអស់ ហើយឲ្យបងឆ្កួលរួចលែងទៀ។ ចូរកុំឲ្យតាហានគាំងពួង
យកគ្រោះទីងទង់ជ័យដែលរើសបានខោះ ឲ្យតាហានស្លៀកពាក់បន្ទំជា
តាហានអ៊ីខេង ឲ្យទៅជួនទីងលៀវលើកចេញទៅជាមុន ហើយបង្គាប់
ថា " បើប្រទះទីងតាហានអ្នួនសៀវគាលណាឲ្យធ្វើអាការច្រាប់ថាជា
តាហានអ៊ីខេងបែកពីទ័ពចូរត់ចេញមក" លុះចាត់បងស្រេចហើយកំ
លើកគ្រឡប់ទៅដល់ច្រកភ្នំមួយ កំប្រទះទីងទ័ពជ្រៃតែ។ កំស្រែកសួរថា
នរណាលើកទ័ពទៅណា? លៀវលៀវទីងទៅជួកំបង្គាប់តាហានឲ្យធ្វើយថា
យើងជាតាហានអ៊ីខេងបែកគេមក។ ឆ្កែតែបានស្តាប់ហើយកំមិនសង្ស័យ
ឡើយ ទំនែស្រួតដេញតាហានរបស់ខ្លួនឲ្យប្រញាប់ៗលឿនទៅ។ លៀវ-
លៀវទីងទៅជួយើញជ្រៃតែបរសេះមកជិត កំស្រែកកំហែកថា ឯងលើក
តាហានទៅណា? ឆ្កែតែកំជ្រុលទៅទៅក្នុងចំណោមសេនាតាហានចូរ
លុះឮដូច្នោះកំភ័យណាស់ទីងតទល់ច្បាំងកំងាកំមិនបាន់។ លៀវលៀវកំ
លើកខ្លួនឡើងបាក់ត្រូវឆ្កែតែធ្លាក់ពីលើសេះស្ទាប់មួយរំពេចខោះ ហើយ
ដេញកាប់ពលតាហានគាំងពួង ស្ទាប់មិរដេរដាសថែមទៀត។

ខណៈខោះ លៀវលៀវកំឲ្យតាហានដែលស្លៀកពាក់បន្ទំជាតាហានអ្នួន
សៀវនោះ ឲ្យទំស្រួតទៅខាងមុខ ស្រែកប្រកាសដល់ពួកតាហានអ្នួនសៀវ
ថា ឥឡូវឆ្កែតែលើកទ័ពទៅសម្លាប់តាហានចូរឆ្ង ស្ទាប់អស់ជាច្រើនណាស់
សំឡេងនោះកំឮគ។ ទៅដល់អ្នួនសៀវ។ មិនដឹងកលល្បិចយ៉ាងកំតែងមាន
សេចក្តីត្រេកអរ មិនភ្លេចប្រមូលតាហានបញ្ជូនទៅជួយឆ្កែតែ អ្នួនសៀវ
កំបញ្ជូនតាហានទៅជួយលៀវទាប់ទីងគោឡាំ ដែលទៅបន្ទប់បន្ទា ចូរ

នោះវិញ ។

ឯខៀវមាប់ទីនឹងកោឡាំ លុះលើកទ័ពទៅដល់ច្រកលំនឹងបន្ទាយចូរ ហើយកំពុងតាហានចូលវាយលំសាយយកបន្ទាយចូរ ឯពោធិវដែលនៅក្នុងបន្ទាយនោះក៏លើកតាហានចេញទៅតទល់ច្បាំងគ្នាជាពន្លឹក ។ ហៃហ្គីខុន ទីនិ ហៃហ្គីអៀន, ពោយិន, លីខៀន ដែលជាកងទ័ពបន្តប់តាំងនៅខ្នង.ស្តាំ ក៏លើកទ័ពវាយរុចប់មកតាំងសងខាង សម្លាប់តាហានអ្នកនៅស្រុកស្លាប់អស់ជាច្រើន ខៀវមាប់ទីនឹងកោឡាំតទល់ពុំឈ្នះ ក៏ថយតាហានមកក្រោយជួបប្រទះនឹងតាហាន ដែលអ្នកនៅស្រុកបញ្ជូនទៅឲ្យជួយនោះ ពោធិនឹងកងទ័ពដែលបង្កប់តាំង ៤ ក្រុម ក៏លើកគ្នាវាយរុចប់ខៀវមាប់ទីនឹងកោឡាំដុំវិញតាំង ៣ ទិស ។

ចំណែកចូរលើកកងទ័ពមកឃើញដូច្នោះ ដេញតាហានឲ្យចូលទៅវាយប្រសប់ពីក្រោយតាហានអ្នកនៅស្រុកគ្រប់តាំង ៤ ទិស ។ ខៀវមាប់ទីនឹងកោឡាំចប់ទៅពុំឈ្នះ ក៏នាំតាហានតារំលាយតែចេញទៅវិញ ។ ឯអ៊ីខេង ដែលចូរធ្វើខោសងនឹងលែនឡុង បានមកជួបនឹងពួកតាហានដែលបែកទ័ព ក៏នាំគ្នាទៅកអ្នកនៅស្រុកក្នុងបន្ទាយ ។ អ្នកនៅស្រុកឡើងទៅឃើញអ៊ីខេងមានរបួសឈឺចាប់ជាខ្លាំងណាស់ ក៏សួរថា ហេតុម្តេចទើបថ្ងៃស៊ីតាដូច្នោះ ។ តាហានដែលបែកមកជាមួយនោះ ក៏ជំរាបអ្នកនៅស្រុកថា តាលអ៊ីខេងទៅនៅក្បាលដំបន់អ្នកទៅនោះ មិនបានយកចិត្តទុកដាក់ត្រួតត្រាក្បួនស្បៀងតាហារសោះ បេះតែផឹកស្រាស្រវឹងគ្រប់វេលាជានិច្ច លុះចូរលើកទ័ពទៅវាយ ក៏ចាប់អ៊ីខេងបាន

ហើយក៏ឲ្យកាត់ម្រាមដៃ មាត់ច្រមុះ ទំនត្រចៀកចេញសែនមក ។ អ្នកនេសៀវ
ឃាតស្តាប់ដូច្នោះក៏ក្រោធខ្លាំង ទើបចាប់ក្រហ៊ុមមកចាក់សម្លាប់អ៊ីវេង ។

ខណៈនោះគួរតែកាលឃាតដំណឹងថា ខៀវមាប់ទឹងគោឡាំចាញ់
ទ័ពចូនដូច្នោះក៏គិតថា "ប្រសែលជាអ្នកនេសៀវប្រើឲ្យខៀវមាប់ទឹងគោឡាំ
ចាំង ៤ នាក់ទៅធ្វើការនោះ តាមពាក្យដែលអញពន្យល់ ឥឡូវ
ខៀវមាប់ទឹងគោឡាំចូលការហើយ មុខជាអ្នកនេសៀវទឹងកេរឿងទឹង
ទឹងអញមិនខាន ម៉ើដូច្នោះអញចាំតែរកឧបាយចូលទៅនិយាយញុះ
ញែអ្នកនេសៀវក្រឡប់ទឹងទឹងខៀវមាប់ទឹងគោឡាំវិញ ខ្លួនអញក៏ទឹងរួចពី
ទោសនោះ" លុះគិតហើយក៏ចូលទៅជំរាបអ្នកនេសៀវថា ឥឡូវខៀវមាប់
ទឹងគោឡាំ ដែលទៅចូនប្អូនថ្លាយចូនូនោះដឹងដំណឹងថា លោកចូលស្បៀង
អាហារអស់ហើយ ក៏មានចិត្តត្រេកអរ ។ អ្នកនេសៀវក៏សួរថា ហេតុ
ម្តេចបានជាអ្នកឯងដឹងថាខៀវមាប់ទឹងគោឡាំមានសេចក្តីត្រេកអរដូច្នោះ ។
គួរតែវាឆ្លើយថា ខ្ញុំដឹងជាច្រើនដឹងថាខៀវមាប់ទឹងគោឡាំនោះមានចិត្តគំនិត
មិនពិតត្រង់ទឹងលោកមកយូរហើយ តែតែប្រែចិត្តចេញតែមិនទាន់មាន
ឱកាស លុះលោកប្រើទៅចូនបន្ទាយគ្រានោះ ក៏មិនមែនតាំងចិត្ត
ទឹងធ្វើការជាច្រើនដ តែក្លែងធ្វើជាចាញ់ចូនូ ។ អ្នកនេសៀវឃាតឮដូច្នោះ
ក៏ជឿថាពិត មានចិត្តនោះទឹងគំនុំខុកជាខ្លាំងណាស់ ទើបប្រើឃាតន
ឲ្យទៅហៅខ្លួនខៀវមាប់ទឹងគោឡាំឲ្យចូលមកធ្វើទោស ឃាតនឮលួស
ពាក្យអ្នកនេសៀវហើយក៏លាចេញទៅ ។

គួរតៅយើញអ្នឧនសៀវដៅស្តាប់តាក្យខ្លួនហើយ កំត្រឡប់មកវិញ ទើបប្រើមនុស្សស្ងួនស្មាលម្នាក់ ឲ្យស្រួតទៅប្រាប់ខៀវទាប់ឧនកោឡាំជាមុនថា អញឲ្យអ្នឧនសៀវនឹងព្រោះទៅធ្វើការឲ្យថ្នល់ការ ដែលឲ្យហៅខ្លួនមកនេះដើម្បីប្រហារដើរតែ ។ ចំរើតួរតៅក៏ស្រួតតៅទៅប្រាប់សេចក្តីដល់ខៀវទាប់ឧនកោឡាំត្រប់ប្រការ ខៀវទាប់កោឡាំដឹងដូច្នោះក៏រិះគិតគ្នា ។ ខណួលមានតាហានអ្នឧនសៀវទៅប្រាប់ថា អ្នឧនសៀវឲ្យហៅទៅជួប ។ ខៀវទាប់ កោឡាំសួរថា ដែលអ្នឧនសៀវឲ្យមកហៅយើងទៅនោះមានការអ្វី? ខ្លួនដឹងឬទេ? តាហាននោះប្រាប់ថាមិនដឹងមានការអ្វីទេ ។ កោឡាំក៏ឲ្យឧនហូតគ្រប៉ីឡើងសម្ងាប់តាហាននោះស្លាប់ទៅ ។

ខៀវទាប់យើញដូច្នោះក៏ភ័យស្ងុតចិត្ត ទើបសួរទៅកោឡាំថា ហេតុម្តេចបានជាអ្នកសម្ងាប់បំរើអ្នឧនសៀវចញដូច្នេះ? ។ កោឡាំថា ឯចិត្តអ្នឧនសៀវនោះមិនមែនជាអ្នកចិត្តល្អមមនុស្សខៀងត្រង់ដោយប្រក្រតីទេ វាមែនធ្វើស្តាប់តែតាក្យមនុស្សញុះញ៉ង់ ដែលឲ្យមកហៅយើងតាំង ២ នាក់ទៅវេលានេះ ប្រាថ្នាឧនសម្ងាប់យើងដូចបំរើតួរតៅមកប្រាប់មែនទោះបីយើងរួចជីវិតក្នុងគ្រានេះ យូរទៅក៏តង់តែឧនស្លាប់ដោយថ្លើដែតាហានឧនដម្រេះប្រាជ្ញាចូធ្លូមិនខាន បើដូច្នេះត្រូវតែយើងបបួលគ្នាទៅនៅឧនចូធ្លូ សូមធ្វើការយកអាសាចូធ្លូវិញ ទើបឧនឯងបានសេចក្តីសុខតទៅ ។ ខៀវទាប់យល់ឃើញត្រូវផង ក៏នាំតាហានតាំង៣ឧនចូលទៅកន្លែបន្ទាយចូធ្លូហើយប្រាប់តាហានចូធ្លូថា យើងនេះឈ្មោះខៀវទាប់ឧនកោឡាំតាំង ២ នាក់ ស្តេចចូលមកសូមធ្វើការឧនឯងមហាឧបាជ តាហាននោះក៏នាំសេចក្តី

ទៅជំរាបចូផ្ទ ។

ឯហែហ្ជិទុនបានញ្ជូរឲ្នាះកឹជំរាបចូផ្ទូថា ទៀវទាប់នឹងកោឡ្យាំនោះ ជាតាហានឯកវបស់អ្ជិនសៀវ ឥឡ្យូវនេះ លោកនឹងអ្ជិនសៀវកំពុងតែធ្វើ សង្ត្រាមជាប់ដែគ្នា ដែលទៀវទាប់នឹងកោឡ្យាំស្ម៉ត្រចូលមកធ្វើរាជការនឹង លោកនេះ ខ្ញុំបាទក្រែងជាកលទ្ធបាយទេដឹង ? សូមឲ្យលោកវិះគិត ពិនិត្យមើលកុំអាលដៀទុកចិត្ត ។ ចូផ្ទូតបថា "អ្នកឯងនិយាយនេះត្រូវ ហើយ ដែលកោឡ្យាំនឹងទៀវទាប់ចូលមកធ្វើកលទ្ធបាយសឹកប្រការម្តេច យើងកឹល្មមដឹងបាន នឹងទ្ធាចអ្ជីត្រឹមប្រាជ្ញាឈ្មោះតាំងពីរនេះ បើនៅនឹង យើងដោយសុចរិតពិតត្រង់ យើងកឹទទួលចិញ្ជឹមដោយប្រក្រតី" ហើយ កឹឲ្យតាហានចេញទៅហៅខ្ជូនទៀវទាប់នឹងកោឡ្យាំចូលមក ។ ទៀវ ទាប់នឹងកោឡ្យាំតំនាប់ចូផ្ទូហើយកឹពណិនារៀងរាំវពីដើមដល់ចប់ ដែល បាននៅនឹងអ្ជិនសៀវនោះឲ្យចូផ្ទស្តាប់ត្រប់ប្រការ រួចជំរាបចូផ្ទូថា ឥឡ្យូ នេះខ្ញុំបាទនឹងនៅតទៅទៀតពុំបាន ទើបនាំគ្នាមកសូមនៅធ្វើជាតាហាន របស់លោកនេះ ។

ចូផ្ទូបានស្តាប់កឹកូងលើកសរសើរទៀវទាប់-កោឡ្យាំថា "ឯអ្ជិន សៀវនោះមានសេនាតាហានឯកកឹច្រើន បើប្រសិនជាស្តាប់ពាក្យអ្នក ឯងតាំង ៦ នាក់កឹនឹងមិនទូចទាតស្ស្យៀងអាហារ សូម្យ៉ាកិច្ជការតាំងតួន កឹតង់បានសំរេចដោយងាយ នេះហាក់តែបុណ្យរបស់យើងច្រើន ទើប ឃណ្ណាលឲ្យអ្ជិនសៀវមិនដៀស្តាប់ពាក្យអ្នក ដែលយើងបានអ្នកមកទុក តាំង ៦ នេះ អ្នកកឹចូរយកចិត្តទុកជាក់ជួយធ្វើរាជការសឹកដើម្យ៉ាំចាត់អ្ជិន

សៀវឲ្យបរាជ័យចាញ់ដោយសតិបញ្ញានឹងថ្វីដៃរបស់អ្នកទាំង ៤ យើងក៏
សូមសង្ឃឹមទុកចិត្តនឹងតំនិតប្រាជ្ញារបស់អ្នកដោយអស់ពីចិត្ត" ហើយចូធូ
ក៏តាំងឲ្យទៀវទាប់នឹងកោឡាំធ្វើជានាយទាហាន ។ ទៀវទាប់នឹងកោឡាំ
យើញចូធូទទួលរាប់អានដោយស្មោះអស់ពីចិត្ត ក៏រឹតតែមានសេចក្តី
ត្រេកអរសោមនស្សជាប្រើន ហើយជំរាបចូធូថា បើលោកនឹងលើកទ័ព
ទៅចាំងនឹងអ្ជិនសៀវវេលាណា ខ្ញុំបាទសូមយកអាសាបេញាទៅជាទ័ពមុខ
ជាជរាម ។ ខណៈនោះទាហានក្នុងកងទ័ពអ្ជិនសៀវដឹងថា ទៅហ៊ុ៉វ ទៀវ-
ទាប់នឹងកោឡាំរត់ទៅនៅទាងចូធូអស់ហើយ ទាំងស្សៀងអាហារនៅជំបន់
អ្ជិបៅនោះក្ងើងក៏ធេះវិនាសអស់ ទាហានទាំងនោះក៏នឹកតូចចិត្តទៅមនស្ស
តិតដោះយកតែខ្ជនខ្ជះ ក៏កើតទុក្ខព្រួយរំទាងពុំបានយកចិត្តទុកដាក់ធ្វើការ
រាជការទ្បើយ ។

ចំណែកទៅហ៊ុ៉វជំរាបចូធូថា ត្រានេះសង្ត្រាមបានកល់ការជា
ចំណាប់អស់ហើយ សូមឲ្យលោកលើកកងទ័ពទៅវាយចាំងនឹងអ្ជិនសៀវ
ជាប្រញាប់តុំបន្ថន ។ ចូធូក៏យល់យើញត្រូវដន ទើបកណ្ជាទាហានឲ្យ
ទៀវទាប់នឹងកោឡាំលើកទៅចូន់មនាយអ្ជិនសៀវ ។ ក៏ឲ្យទាហានបេញ
តចាំងជាទ្វាំងតន្ទឹក ទៀវទាប់នឹងកោឡាំក៏កាប់សម្ទាន់ទាហានអ្ជិនសៀវ
ស្ទាប់អស់ជាប្រើនណាស់ លុះពេលព្រឹកទ្បើងទៀវទាប់នឹងកោឡាំក៏នាំ
កងទ័ពត្រឡប់មកប្តឹងឲ្យដំណឹងចូធូ តាមដែលបានទៅធ្វើការមានជ័យជំនះ
សព្វត្រប់ប្រការ ចូធូក៏មានសេចក្តីត្រេកអរជាអនេក ។

ស៊ុនហុកជំរាបចូធូថា ទាហានក្នុងកងទ័ពអ្ជិនសៀវនោះយើញ

ថាទន់ថយកំឡាំងនឹងស្ពួចស្ពើងអស់ហើយ សូមឲ្យលោកចាត់ទាហាន
យើងឲ្យទៅនិយាយការជាពាក្យ៦ចាយថា វេលានេះលោកឲ្យលើកទ័ព
ទៅវាយស្រុកនៃបកុន ដែលបញ្ជូនស្បៀងអាហារមកឲ្យអ្ជិនសៀវ ១ កង
ទៅវាយទ័ពដែលតាំងស្ពាត់ផ្ទូវ នៅដំបន់លីយ៉ុង ១ កង, ទៅវាយទ័ព
ដែលតាំងនៅដើមផ្ទូវនឹងទៅស្រុកតីជីវ ១ កង ហើដំណឹងនេះបានឮដល់
អ្ជិនសៀវវេលាណា អ្ជិនសៀវក៏នឹងបែងទាហានទៅជួយឯស្រុកនៃបកុន
១ កង, ទៅវាយទ័ពដែលស្ពាត់ដើមផ្ទូវ ១ កង, កាលណាបែងរំលែកទៅ
ជាប្រើនកងជូច្នេះហើយ ទាហានកងទ័ពធំរបស់អ្ជិនសៀវក៏មានតែថយចុះ
ស្ពួចស្ពើងទៅ រួចសូមឲ្យលោកលើកទ័ពទៅវាយយកបន្ទាយអ្ជិនសៀវ
ឃើញថានឹងបែកបានដោយងាយ ។ ចូធូយល់ឃើញត្រូវផងក៏ចាត់ប្រើ
ទាហានឲ្យដើរទៅនិយាយបរិហារ ដល់ពួកអ្នកស្រុកគ្រប់ដំបន់តាមពាក្យ
ដែលស៊ុនហុកនិយាយនោះ ។

ឯទាហានអ្ជិនសៀវលុះបានដឹងថា ចូធូលើកកងទ័ពទៅគ្រប់ដំបន់
ត៏នាំយកសេចក្តីនោះទៅប្រាប់អ្ជិនសៀវ។ ដឹងជូច្នោះក៏ភ័យខ្ទាំងណាស់
ទើបចាត់អ្ជិនសុងជាបុត្រឲ្យឃុំនាំទាហាន ៥ម៉ឺនទៅជួយរក្សាការពារស្រុក
នៃបកុនកុំឲ្យខូចស្បៀងអាហារបាន ហើយឲ្យស៊ុនបេងលើកទាហាន ៥
ម៉ឺនទៅចាំវាយកងទ័ពដែលលើកទៅស្ទាក់ផ្ទូវនៅដំបន់លីយ៉ុង អ្ជិនសុង
នឹងស៊ុនបេងក៏លើកទាហានម្នាក់ ៥ ម៉ឺនម្នាក់ចេញទៅតែរៀងខ្លួន ។

ចូធូឮដំណឹងជូច្នោះ ក៏ចាត់ចែងទាហានលើកញែកចេញជា ៨កងចូល
ទៅវាយបន្ទាយអ្ជិនសៀវ ឯពួកទាហ៊ានអ្ជិនសៀវនោះសឹងតែកោត

ញ្ញើតមិនអាចនឹងចេញចាំងព្រោះខ្លាចអំណាចបូធូតាំងអស់គ្នា ។ អ្នក-
សៀវឃើញថាហានបែរមុខរួចប្រែចិត្តក៏តែតតែយខ្លាច មិនទាន់ពាក់ព្រះ
វេនាំអ្នកចាំជាបុត្រនឹងថាហានប្រហែល ៨០០ ថ្ងៃយចេញចោលបន្ទាយ
នឹងត្រាស់ពាប់ជារន្ធវាត្រូវបែរមុខតាំងអស់ ហើយកំពារំលាយកងទ័ព
ចេញរួចធ្វើនេះហាន ហោ ។

ក្នុងខណៈនោះ ថាហានបូធូកំពាប់សម្លាប់ទ័ពអ្នកសៀវស្លាប់អស់ជា
ច្រើន ឯទៀវសៀវ,ទៅធូ,អ៊ីតិម នឹងស៊ីហ្គូនកំបរសេះលើកថាហានដេញ
ទៅ អ្នកសៀវទៅដល់ត្រើយមាត់ទន្លេហាន ហោ លុះឃើញអ្នកសៀវធ្វើន
ហួសក៏នាំគ្នាត្រឡប់មកវិញ ទើបបូលទៅដេញយកបែរមុខត្រូវអ្នក-
សៀវក្នុងបន្ទាយមកឲ្យបូធូ ។ កំយកមាសប្រាក់នឹងគ្រឿងសម្លៀកបំពាក់
នោះចែកឲ្យពួកហានតាមសមគួរ, ឯនាយពួកហាន ១០ នាក់យកសំបុត្រ
ដែលបានមកពីបន្ទាយអ្នកសៀវនោះទៅឲ្យបូធូ ។ ខ្លួលយកសំបុត្រនោះ
មកមើលឃើញសេចក្តីថា " ខ្ញុំបាទជាមាយពួកហានច្រើនទាក់ដែលមក
ទៅក្នុងកងទ័ពបូធូនោះ សូមដំរាបមកដល់អ្នកសៀវ បើបូធូបាជ័យចាញ់ដៃ
វៀលណាខ្ញុំបាទពាល់គ្នានឹងស៊ុំតែជីវិតពុក នឹងបូលមកសាពិភ័ក្តិទ័ពីនឹងលោក
តទៅ" ។ ទ័ប្រឹក្សានឹងសេនាពួកហានតាំងពួងជាងសេចក្តីក្នុងសំបុត្រនោះ
ជូរបាះ ហើយក៏ដំរាបបូធូថា សូមឲ្យលោកពិចារណាកន្លងមនុស្សដែល
លបប្រព្រឹត្តបន្ទុច្ចរិតនឹងលោក ហើយលបផ្ញើសំបុត្រទៅដល់អ្នកសៀវឲ្យ
យើញកុំឲ្យខាន ។

រឿងហ្សាឌីត

លោកវ៉ុលតែរ ជាអ្នកនិពន្ធ

លោកវ៉ាយ ប៉ុក ប្រែរៀបរៀង

(ពមក)

នាងសេមីរទៅស្រុកស្រែប្រហែលបីថ្ងៃ ហ៊ាយ ។ លោកហ្សាឌីតបានជឹងដំណឹងតាមផ្លូវថា ស្ត្រីល្អនោះបានប្រកាសខ្ចាំងៗ ថាខ្លួនវស្អប់ខ្ពើមនូវបុគ្គលខ្ចាក់ត្នែកម្ចាង ហ៊ាយនាងនេះក៏រៀបវិវាហមង្គលការជាមួយលោកអ្ចរកង់ពីយប់មេញទៅហ៊ាយ ។ លោកហ្សាឌីតបានឌ្ចដំណឹងនេះក៏ជួលសន្ទប់បាត់ស្មារតី តែគ្រោយមក លោកមានវិចារណញ្ញាណបាត់ព្រួយវិញ ។ លោកហ្សាឌិតគិតថា: "ប៉ើអញចាញ់ប្រាកនាវិនេះ អញនឹងរៀបវិវាហមង្គលការនឹងស្ត្រីអ្នកក្រុងម្នាក់វិញ" ។ លោកបានជ្រើសរើសយកនាងអាហ្សូវ៉ាជ្ជីជាកវិយា ហ៊ាយនៅជាមួយគ្នាជាងមួយខែដោយសេចក្តីត្រេកត្រអាលវ៉ែកកយពន់ពេក ។ លោកបានពិនិត្យចំពោះនាងអាហ្សូវ៉ាយ៉ើញថានាងចិត្តទន់ ហ៊ាយនាងពេញចិត្តនឹងបុរសកំឡោះ ដែលមានរូបល្អស្អាតជាជាងបុរសកំឡោះដែលមានគុណធម៌នឹងមានប្រាជ្ញា ។

× × ×

វគ្គទី ២

រឿងកាត់បុងប្រមុះ

មានកាលមួយថ្ងៃ, នាងអាហ្សូវ៉ាបានវិលត្រឡប់ពីដើរលេងកំសាន្ត,

នាងមានចិត្តខ្មេមខ្មាំងខ្លាំងហើយ ភ្លេចភ្លាំងសម្រែកលាន់ឮពន់ពេក ។ លោកហ្សាឌីតក៏សួរនាងអាហ្សាក់ថា: "តើនាងមានរឿងអ្វី? តើអ្នកណាធ្វើឲ្យនាងខ្មេមខ្មាំងនេះ? នាងអាហ្សាក់ក៏តបទៅស្វាមីវិញថា: "អ្នកបងមុខជាធ្វើដូចខ្ញុំ បើអ្នកបងបានឃើញទស្សនីយភាពអម្បាញ់មេញនេះ។ ខ្ញុំបានទៅសួរនាងមេម៉ាយម្ចាស់ឈ្មោះកូស្រ្តូ នាងនេះទើបនឹងស្អាងថូបដ្ឋានមួយ សម្រាប់តំកល់សពស្វាមីនាងអស់រយៈពេលពីរថ្ងៃហើយ ថូបដ្ឋាននោះស្ថិតនៅជិតស្ទឹងមាត់ភ្លុ ។ នាងបានសន្យាទឹងខ្លួនតាំងអម្បាលម៉ាណ ក្នុងពេលដែលនាងមានសេចក្តីទុក្ខថា ជាបណ្តាទឹកស្ទឹងនៅមាត់ថូបដ្ឋាននៅតែគេញ ជាបនោះនាងនឹងស្ថិតនៅជិតថូបដ្ឋានមិនឲ្យឃ្លាងឃ្លាតសោះឡើយ" ។

លោកហ្សាឌីតក៏ពោលថា: "នោះហ្ន៎! ស្ត្រីដែលស្នេហាស្មោះស្ម័គ្រចំពោះស្វាមីបែបនេះ ខ្ញុំ" ។ នាងអាហ្សាក់ក៏សួរទៅស្វាមីថា: "បើអ្នកបងជ្រាប តើនាងមេម៉ាយនេះប្រព្រឹត្តបែបណា កាលដែលខ្ញុំទៅសួរនាងនោះ" ។ លោកហ្សាឌីតក៏សួរនាងអាហ្សាក់វិញថា: "តើនាងមេម៉ាយនោះធ្វើអ្វី? នាងអាហ្សាក់ក៏តបវិញថា: "នាងមេម៉ាយបានព្យាយាមបង្វែរទឹកស្ទឹងនោះកុំឲ្យហូរទៅប្របថូបដ្ឋាន ដែលជាទីតំកល់សពស្វាមីនាង" ហើយនាងអាហ្សាក់ក៏ពោលពាក្យគួរសប្បុរសជាច្រើនប្រការ មានពាក្យដេរប្រទេចផ្តាសាជាដើមចំពោះនាងមេម៉ាយនោះ ពាល់តែលោកហ្សាឌីតធុញគ្រាន់ ។

លោកហ្សាឌីតមានមិត្តភក្តិម្នាក់ឈ្មោះ គាជូ ជាបុរសជំទង់ ក៏យោលោក

ពុកប៉ុរសនេះថាជាអ្នកមានធម៌សុចរិតនឹងគុណធម៌ច្រើនជាងអ្នកឯទៀត ។ លោកហ្សុនគឺចង់ពិសោធន៍ចិត្តកវីយោ តើជាស្រឡាញ់លោកពិតឬយ៉ាងណា ក៏ប្រាប់លោកគាជូវដែលជាកល្យាណមិត្តរបស់លោកអំពីរឿងនេះសព្វគ្រប់ លោកបានសំដែងសេចក្តីស្មោះស្ម័គ្រចំពោះលោកគាជូវថា "លោកមិនមានការប្រកាន់ចំពោះរឿងនេះទេ" ហើយលោកធ្វើអំណោយនូវគោគ្រឿងជាច្រើនដល់លោកគាជូវ ។

នាងអាហ្សាក៏បានទៅលេងកំសាន្តជាមួយនឹងស្រីម្នាក់ជាមិត្តអស់រយៈវេលាពីរថ្ងៃ, ដល់ថ្ងៃទីបីក៏រៀបត្រឡប់មកកាន់គេហដ្ឋានវិញ ។ មានពួកទាសាទាសីយំខ្លួញស្រែកថា: " លោកហ្សុនស្វាមីនាងខ្លួលអន់ចិត្តមកម្ចាស់មេញៅហើយ, យើងគ្មានពេលនឹងជូនដំណឹងដំខ្លាចផ្សារនេះឲ្យនាងបានជ្រាបក្នុងមួយរំពេចនេះ ឥឡូវ យើងខ្ញុំទាំងអស់គ្នាបានសែងយកសពលោកហ្សុនគឺទៅកប់ហើយនៅថ្ងបង្គន់អាពុកឯណោះ ឯចុងបញ្ចប់ដំណាំ ។

នាងអាហ្សាក៏ សោកសង្រេងជាខ្លាំង, ដកសក់ហើយស្រែកថាចង់ស្លាប់ស្លាចនេះ ។ លោកគាជូវបានអង្វរនាង សូមនាងយកចិត្តចិត្ត, ហើយអ្នកទាំងពីរក៏យំសោកស្តាយអាឡោះអាល័យ ចំពោះសពលោកហ្សុនគឺ, ដល់ថ្ងៃស្អែកអ្នកទាំងពីរនៅយំ ហើយបរិភោគជាយស្លាចជាមួយគ្នា ។ ក្នុងពេលបរិភោគនេះ លោកគាជូវបានប្រាប់នាងអាហ្សាក៏ថា មិត្តរបស់លោក កាលខ្លួលមរណភាពនៅបានទុកកេរ្តិ៍មរតកច្រើនជូនលោក ហើយលោកមានប្រសាសន៍ថា លោកនឹងយកទ្រព្យទាំងនេះបំណាយ

ដើម្បីសុភមង្គលយើងទាំងពីរនាក់ ។ ដំបូងនាងអាហ្វ្រង់យំៗ ទឹងផង, បន្តាប់មកលែងយំ ។ ការជប់លាងនេះអស់រយៈវេលាដ៏យូរ ដោយមានការចោទគ្នាបណ្តើរបរិភោគបណ្តើរ ។ អ្នកទាំងពីរពោលតាក្យសំដីគាន់តែរស់ពាយ គាន់តែដឹងស្ថិទ្ធជាងមុន នាងអាហ្វ្រង់ថានសរសើរចំពោះសព តែនាងបានបញ្ជាក់ថា សពនោះមានគុណវិបត្តិខ្លះដែលលោកគាជូរគ្មាន . . . . .

កំពុងតែបរិភោគ ស្រាប់តែលោកគាជូរស្រែកថ្ងូរថា លោកឈឺក្បាលខ្លាំង ។ នាងអាហ្វ្រង់ក៏ឲ្យយកប្រដាប់ប្រដាមកលាបសព្វសាង្គីកាយឲ្យពេគនោះជាសះស្បើយ ។

នាងអាហ្វ្រង់មានចិត្តអាណិតគាសូរលោកគាជូរពន់ពេក ក៏សួរថា: "លោកជ្ងាប់កើតពេគបែបនេះឬ?" ។ លោកគាជូរក៏តបទៅនាងវិញថា: "ខ្ញុំជ្ងាប់កើតពេគនេះ; បើគាលណាកើតមន្តង។ ធ្វើឲ្យខ្ញុំឈឺចាប់ដល់តមរណៈ ខានតែទុសថមួយយ៉ាងដែលអាចធ្វើឲ្យពេគនេះជាសះស្បើយទៅបាន គឺយកប្រមុះបុគ្គលដែលអនិច្ចកម្មព័ម្បីលមិញមកបំពន្លឹងដំនីខ្ញុំ។ នាងអាហ្វ្រង់ក៏សួរបញ្ជាក់ថា: នេះប្រាកដជាទុសថមែនឬ? "..... ពិតមែន ។

នាងអាហ្វ្រង់ក៏ប្តេជ្ញាក្នុងចិត្តថា ខឹងរកទុសថនេះឲ្យ ហើយនាងពោលថា: "ស្វាមីខ្ញុំចេញបាកពិកពលោកនេះគាលពីថ្ងៃម្បិលមេញ ទៅគាន់បរលោកនាយ, ដល់សពនោះគ្រាច់ទៅដល់ស្ថានជីនីក៏ ទេវតាអ៊ីស្រាអែលប្រហែលជាមិនដំទាស់ក្នុងការធ្វើដំណើរនេះទេ ព្រោះស្វាមីខ្ញុំមានប្រមុះខ្លីកន្ទុយដីគាតពីរ, បើប្រៀបធៀបទឹងដីគាតមួយ . . . ។

នាងអាហ្វ្រ៉ាកំពុងតាំងចិត្តគោរមួយគ្រាប់ៗតាន់ថូបដ្ឋានស្វាមី, យំសោកជាច្រើន, ហើយចូលទៅជិតដើម្បីនឹងកាត់ចុងច្រមុះសត្វនោះ ។ លោកហ្គ្យឺតក៏ក្រោកឡើងយកដៃមួយចាប់ចុងច្រមុះខ្លួន, ដៃមួយទៀតចាប់តាំងចិត្តគោរជាប់, ហើយពោលថា:" នាង, កុំឲ្យនាងស្រែកធ្វើអ្វីចំពោះនាងមេម៉ាយកើយបុរសកំឡោះក្មេងស្រី, បំណងនាងចង់កាត់ចុងច្រមុះបងដូចគ្នានឹងនាងមេម៉ាយ ដែលបំណងបង្ខែរខ្ទឹកស្ទឹងកុំឲ្យហូរទៅកៀនថូបដ្ឋានសត្វស្វាមី ។

×

× ‹

វគ្គទី ๓

ទិវាងពីផ្លែឪឯសេះ

លោកហ្គ្យឺត មានមនោសញ្ចេតនាច្រើនក្នុងធ្វើរឿងហេតុនឹងសាកល្បងខ្លួនមួយ ព្រោះជាខ្លែមានព្រះបន្ទូលភ្ញាក់ដោយទឹកឃ្មុំ តែជាឧកាសសុខស្រួលសប្បាយដែរដូចទឹកឃ្មុំ, ឯចំណែកខ្លែពីរ ព្រះបន្ទូលស្រែកអាប់ស្មៅ តែជាពេលដ៏ក្តុកបំបាកគ្រប់យ៉ាង ដូចបានសំដែងកន្លងមក "ហ្សូន" ។ លោកហ្គ្យឺតមិនយូរប៉ុន្មានក៏លែងនាងអាហ្វ្រ៉ា ដោយនាងនេះលំបាកនឹងរស់នៅជាមួយគ្នាតទៅ ។ រួចលោកក៏បានសែងរកសុភមង្គល ដោយការព្យាយាមសិក្សាខាងធម្មជាតិទៅវិញ ។

លោកហ្គ្យឺតពោលថា: "ក្នុងលោកនេះមិនមានអ្នកណាសប្បាយជាងអ្នកចេះស្រឡាញ់ខ្លួនឯង ដែលបានអានសៀវភៅធំ ដែលព្រះអាទិទេពបាន

ត្រង់ឯបង្ហាញយើងចំពោះមំសចក្ខុ សច្ចធម៌ដែលអ្នកខស្បូនខ្ញុំបានសែង រកយើញខ្មៅក្នុងសៀវភៅធំនោះ ជារបស់ឥតប្រាកដ លោកហ្សាឌីតបាន យកសច្ចធម៌នោះមកអប់រំដើរតែឲ្យមានសភាពដ៏ទុក្ខិទុក្ខម លោកស្រី នៅជាសុខស្រួល, លោកមិនខ្វាចចំពោះមនុស្សភាំងឡាយមកប្រមាថ តាជដន្នលោកសោះឡើយ ។

ដោយលោកបានអប់រំខ្លួនបែបនេះ, លោកហ្សាឌិតក៏បានជួបនៅនៅ ឯគេហដ្ឋានស្រុកស្រែ, នៅលើមាត់ទន្លេអ៊ីហ្វាតនៅទីនោះ, លោក មិនបានគិតថា តើទឹកដែលហូរក្រោមស្ពានទោះជំរៅចំនួនប៉ុន្មានមេដៃ? (ផ្ទៅសបួកណាត្រូវគ្នានឹង $\frac{1}{12}$ ជើង=ត្រូវជា ០ម.០២៧) តើមានទឹកភ្លៀង ធ្លាក់នៅខែកណ្តុរប៉ុន្មានម៉ែត្រត្រីគុណ លើសពីខែដៃម? លោកមិនបាន តិចារណាយកសរសៃពីនពាងមកធ្វើជាខ្សែត្រ ឬយកអំបែងដបមកធ្វើ ជាដុំស្បីលែន ។ លោកទំនិកភ្នែតអំពីលក្ខណៈរបស់ភ្នែតនៅក្នុងទឹកជាតិ ហើយលោកក៏មានក្រោជាមួយបែប ដោយលោកបានឃើញសភាព ផ្សេងៗ ដែលអ្នកភាំងអស់ឃើញថាដូចគ្នា ។

មានមួយថ្ងៃ លោកបានដើរលេងកំសាន្តនៅក្នុងព្រៃរះជាមួយ, លោកបានឃើញនាហ្គីនកំរៀវម្នាក់របស់ព្រះអគ្គមហេសី រត់តម្រង់មកចំ លោក មានន័យថាហានជាច្រើនរត់តាមគ្រោយ ហើយអ្នកភាំងអស់ មានអាការព្រួយបារម្ភជាខ្លាំង ។ អ្នកភាំងអស់តែងតែជួបមនុស្សវង្វេង ដែលស្វែងរកវត្ថុអ្វីមួយដ៏សំខាន់ ។

នាម៉ឺនកំរៀវកំស្រែកសួរលោកថា: លោកបានឃើញសុនខព្រះ អគ្គមហេសីឬទេ ? ។

(មានត)

កំណាត់ដឹងប្រវត្តិការណ៍

ដំណើរទៅកាន់ប្រទេសឥណ្ឌា

ក្នុងឱកាសបុណ្យពុទ្ធជយន្តិ ព.ស. ២៥០០ ត.ស. ១៩៥៦

ដៃលោក រ៉ាយ-ប៊ុក ក្រមការជើមឱ្យ

នាយផ្នែកការផ្សាយសៀវភៅនៃក្រុមពុទ្ធសាសនបណ្ឌិត្យ,

ប្រធានសមាគមមិត្តពុទ្ធិកវិទ្យាល័យភ្នំពេញ

លោក រ៉ាយ-ប៊ុក ឈៀបឈៀង

(គមក)

ម៉ោង ២១,៣០ នាទី យើងទាំងអស់គ្នាវិលត្រឡប់មកកាន់ស្ពានីយ៍ អយស្ម័យយានពាហណស័វិញ ។

ថ្ងៃសុក្រទី ៣ ធ្នូ ម៉ោង ៩,៤៥, យើងឡើងរថយន្តទៅកាន់កំពង់ទឹកទន្លេគង្គា ។ នៅទីនោះមានទូកជាប្រើនសម្រាប់ឲ្យគណៈប្រតិភូជិះតាមមាត់ទន្លេគង្គាតាំងពីកំពង់ រហូតដល់ស្ពានមួយធ្ងងកាត់ទន្លេនេះ ។ នៅទីនោះ មានជនជាតិឥណ្ឌូជាប្រើនទៅមុជទឹកលាងបាប, មានខ្ទះយកធាតុនៃសពដែលទើបនឹងដុតយកទៅបោះចោលក្នុងទឹក ។ គេបានយើញជណ្តើរបុះពីមាត់ប្រាំងទៅក្នុងទឹកប្រវែហលៈ ៤ ជណ្តើរ ហើយមានដែសម្រាប់ងូតទឹក ។ បើតាមពាក្យអ្នកឲ្យការម្នាក់ថា: "ក្នេងអាយុ ៣ ឆ្នាំ, មនុស្សដែលកើតរោគអុត, រោគឃ្ងង់ និងមនុស្សដែលលាបផេះដេកហាល

ថ្ងៃ ដល់មរណៈ៧ គេមិនយកៗដុតទេ, គេយកសពនោះ៧ឯកំពង់ទឹកទន្ទេតឆ្ពា,មានទូកមួយដាក់សពនោះ យកថ្មមួយដុំចងក, ដល់ទូកៗ ដល់ពាក់កណ្តាលទន្ទេ គេក៏ប្រានសពនោះទំលាក់ៗ ក្នុងទឹកៗ ។

មោ៉ង ១៩ យើងទាំងអស់គ្នាក៏បានៗ ទស្សនាវិហារវិស្ទាណាតដែលមហាសប្បុរសប៊ីរល៉ាជាអ្នកបង្កើត រួចៗ ម៉ើលមហាវិទ្យាល័យពាពណស៊ីដែលលោកបណ្ឌិតម៉ាដាំង-មហ៉ន-ម៉ាល៉ាវិយ៉ា ជាអ្នកកសាង ។ មហាវិទ្យា-ល័យនេះធំណាស់ មានសាលារៀនតាំងពីបឋមកូមិ រហូតដល់ថ្នាក់ខ្ពស់បំផុត មហាវិទ្យាល័យនេះសាងចំរុះនៅលើដីជាមួយគ្នា ។

ថ្ងៃសៅរ ទឹ ៣ ធ្នូ មោ៉ង ៧,៤០ នាទី គណៈប្រតិកូទាំងអស់បានជិះអយស្ម័យយានពិសេសៗ ដល់ស្ពានីយ៍គោរៈកប៉ុរ: ។ យើងបានចេញពីស្ពានីយ៍នេះ ៗ ឡើងរថយន្តដែលចតខាងមុខ ។ មានអ្នកស្រុកនៅទីនោះទាំងប្រុសស្រីក្មេងចាស់យកផ្ការៗ ជាចជាប្រើន ហើយស្រែកថា "ជយោ ពុទ្ធជយន្ត៉" ។ ក្នុងពេលនោះ មាននារី៤នាក់យកកម្រងផ្ការមកបំពាក់ត្រប់គណៈប្រតិកូ, មាននារី៤នាក់ទៀត យកជ័រហឹងតុលមឺនដឹងជាលាយអ្ទ៉ ស្ទុះមកលាបត្រង់ប្រជុំចិញ្ចើមយើង ដើម្បីជ័យមង្គលនឹងសិរីស្ទស្ត៉ ហើយមាននារី៤នាក់ទៀត ច្រៀងឲ្យពរស័ព្ទសាធុការ ។

លំដាប់តមក, យើងបានៗ ដល់ក្រុងកុសិនាព មោ៉ង ១៦ បានៗ ទស្សនាព្រះវិហារនិព្ទាន ។ គឺនៅទីនេះហើយ ដែលព្រះសម្ពុទ្ធទ្រង់ចូលកាន់ព្រះបរមនិព្ទាន នៅក្រោមដើមសាលព្រឹក្សទាំងគូ ។ នៅទីនេះ គេយើញមានប្រាសាទនឹងព្រះស្ពូបជាប្រើន ។ មានព្រះស្ពូប

មហាបរិនិព្វាន នឹងមហារវិហារមួយដែលមានព្រះពុទ្ធរូបព្រះអង្គទ្រង់ផ្ទំចូល
កាន់បរិនិព្វាន ។

ម៉ោង ១៤,១០ នាទី, យើងបានទៅកាន់មកុដពន្ធនចេតិយ, សព្វថ្ងៃ
អ្នកស្រុកហៅ ភមាភារស្តូប គឺជាទីដែលបូជាព្រះសពនៃព្រះសម្មាសម្ពុទ្ធ
ក្រោយដែលព្រះអង្គទ្រង់បរិនិព្វាន ។

ម៉ោង ១៨, យើងក៏វិលត្រឡប់មកស្ថានីយ៍គោរះកបុរះវិញ, រួចឡើង
ជិះអយស្ម៉ុយយានវិលត្រឡប់មកក្រុងពាភណសី ។

ថ្ងៃអាទិត្យ ទី ៩ ធ្នូ ម៉ោង ៩ ព្រឹក គណៈប្រតិភូទាំងអស់
បានចេញពីទីក្រុងពាភណសីទៅកាន់គយា ។ ម៉ោង ១៤,១៥ នាទី យើង
ឡើងជិះរថយន្តអូតូប៊ីសទៅដល់ពុទ្ធគយា ។

ក្រោយដែលមានពិធីបាចផ្កា, ដាក់កម្រងផ្កានៅក, ប្រជាជនទាំង
ប្រុសស្រីក៏ជង្ហែគណៈប្រតិភូទាំងអស់ ទៅកាន់មហាពោធិវិហារ ជា
កន្ទែងដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ, នៅ
ខាងក្រោយមហាវិហារ មានព្រះពោធិព្រឹក្សមួយដើម ។ ក្រោយដែល
បាននមស្សការព្រះពោធិព្រឹក្សហើយ យើងទាំងអស់ត្នាក៏ទៀទស្សនា
ស្រះមុចូលិន្ទ, រតនចង្ក្រម, ប្រាសាទឯទ្រ៍តនឹងព្រះស្តូប, ដែលកសាង
នៅជុំវិញមហាវិហារ ។ មហាពោធិវិហារ មានកំពស់ ៤៨០ មែត្រហើយ
មានសើនជុំវិញ; នៅខាងក្នុងមហាវិហារ មានព្រះពុទ្ធរូបអង្គធំលាបលន
ទឹកមាសទ្រង់ចង្អុល នាងតង្ហីងព្រះធរណី ជាសាក្សីក្នុងកិច្ចដែលព្រះអង្គ

បានត្រាស់ជឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ។ នៅជិតនោះ មានក្នំតូចមួយហៅមរបហរ: ដែលព្រះអង្គទ្រង់ជ្ជាប់ឡើងទៅធ្វើសមាធិ ។ នៅទាងជើងមហាវិហារមានយ៉ាមួយធ្វើពីឥដ្ឋ កំពស់ពីដីមួយម៉ែត្រ ហៅ រតនចង្ក្រម, បណ្តោយ ១៥ ម៉ែត្រ ។ នៅទីនេះ ទ្រង់បានតង់ឈសបាត្តហ៍, ហើយត្រង់កន្ទែងដែលព្រះអង្គយាងចង្ក្រម នឹងត្រង់ព្រះបាទាឈានផ្ទាល់ដែនដីគេមានសាងក្សាប់ចំឡាក់ជាផ្ការឈូកវីកក្រោមព្រះបាទា ។

នៅជុំវិញព្រះវិហារ មានស្តូបជាច្រើន ប្រាសាទក៏មានច្រើនដែរ ។

ពុទ្ធតយានេះស្ថិតនៅចម្ងាយ ៦៩៦ម៉ែពីទីក្រុងកំលតុត្តា, ចម្ងាយ ៧ម៉ែពីស្ថានីយ៍អយស្ម៍យយានតយា ។

ម៉ោង ៦០ យើងវិលត្រឡប់មកស្ថានីយ៍អយស្ម៍យយានតយាវិញ ។

ថ្ងៃប៉ង្ហូទី ១០ ធ្នូ ម៉ោង ៧ ព្រឹក គណៈប្រតិភូបានឡើងរថយន្តទៅកាន់ក្រុងរាជគ្រឹះ ។ នៅទីនេះ យើងបានទៅទស្សនាបូជនិយដ្ឋានសត្តបន្នីដែលស្ថិតនៅលើក្នំតូច ឈ្មោះ វៀភារ: ជាកន្ទែងដែលធ្វើសង្គាយនាព្រះពុទ្ធសាសនាលើកទី ១ ។

ក្រៅពីនេះ យើងបានទៅទស្សនា សត្តធារ: (ប្រភពទឹកប្រាំពីរ) ដែលមានទឹកហូរក្តៅចេញពីរូងក្នំ គេហៅថាស្ទឹង តបោទា រួចទៅមើលក្នំតិជ្ឈកូដ; ក្នំនេះមិនខ្ពស់ប៉ុន្មានទេ ក្នំនេះហើយជាទីដែលព្រះទៅទត្តប្រមៀលថ្មមួយជុំធំមកលើព្រះអង្គ ។ យកព្រះបាទាទ្រទប់ថ្មនោះ ។ យើងទាំងអស់គ្នាបានទៅពិនិត្យគុកដែលព្រះបាទអជាតសត្តុរាជយុំទាំងព្រះបាទពិម្ពិសារនឹងកន្ទែងជទៃទៀត ។

លំដាប់តមក, យើងបានទៅមើលក្រុងនាលន្ទា ។ ក្រុងនាលន្ទា ពីអតីតកាល ជាមហាវិទ្យាល័យពុទ្ធសាសនា តាំងពីសតវត្សទី ៥ ហើយជាមជ្ឈដ្ឋានវប្បធម៌ក្នុងរយៈ រៀល ៧០០ ឆ្នាំ ។ លោកហ្ជុនសាំង អ្នកដំណើរជាតិចិនម្នាក់បានចូលរៀនទៅមហាវិទ្យាល័យនេះ ក្នុងសតវត្សទី ៧ ហើយបានទុកឯកសារអំពីរឿងរ៉ាវនេះជាអនេកបរិយាយ ។ មានពួកនិស្សិតមកអំពីភូមិភាគប្រទេសឥណ្ឌៀត្រប់កន្ទែង, អាស៊ីប៉ែកអគ្នេយ៍នឹងប្រទេសចិនជាច្រើនតាក់ចូលមកសិក្សារៀនសូត្រទៅទីនេះ ។

នាលន្ទាជាស្រុកកំណើតអរិយសាវ័កទាំងពីរព្រះអង្គ គឺព្រះសារីបុត្រនឹងព្រះមោគ្គល្ទាន ។ យើងបានបន្ទុដំណើរតាមរថយន្ទទៅកាន់ទីក្រុងបាតៈណា (បាតលីបុត្រ) ។

តាមផ្ទូវថ្នល់ពីនាលន្ទារហូតដល់បាតលីបុត្រ, មានកូនសិស្សប្រុសស្រីឈរតាមសង្កាត់ភូមិ, និតម, ជនបទ, ខែត្រ, ស្រុក ស្រែក "ជយោពុទ្ធជយន្ទិ" ហើយបាចផ្កាមកក្នុងរថយន្ទយើង ។

លុះទៅដល់ស្ពានីយ៍បង្ក៉ីបុរៈ មោ៉ង ១៨, ៣០ នាទី, យើងក៏បានឃើញអយស្ម័យយានពិសេសសំចតទៅទីនោះ ។ បន្ទិចទៀត, មានអ្នកតំណាងនៃទៅហ្ទាយខែត្រក្រុងបាតលីបុត្រ បានមកអញ្ជើញគណៈប្រតិភូពុទ្ធជយន្ទិទាំងអស់ទៅកាន់ទីបុណ្យមួយ ។ ទៅទីនោះ មានបាវាប្រកបដោយភ្ទើងអគ្គិសីនីត្រប់ពណ៌ បានចងជារំយោលបុប្ជាភ្ទឹសន្ទោសន្ទៅ

កណ្តាលយប់ ហើយចាំងភ្លើងតាលីយប្រៀបដូចជាស្ថានសួគ៌នៅលើផែនដី ។

ក្រោយដែលបានបំពាក់ប្លង់, ឡែតសេតូសហាធុការ យើងទាំងអស់គ្នាក៏អង្គុយមើលល្ខោននៅទីនោះ ។ មានពួកបុរសស្ត្រីចេញមកកំដរច្រើនបែប ។ បុរសកំរជ្ញាមួយបែបដែលហៅថា "រជ្ញាំកថាកលី" ។ រជ្ញាំនេះគេលេងលាយចំរុះរជ្ញាំបួកណានឹងរជ្ញាំសម័យថ្មី ។ សិល្បៈបុរាណនឹងសិល្បៈសម័យថ្មីបានលាយចំរុះគ្នា ហើយការចលនានៃរូបកាយ, កាយវិការ, អកប្បកិរិយា, ទឹកមុខ,ក្បាច់កំ, ចម្រៀង ទៅតាមក្បាច់កំនឹងក្លេងប្រមូលទៅជារជ្ញាំមួយគួរឲ្យទស្សនាពន់ពេក ។

ស្ត្រីកំរជ្ញាំមួយបែប ហៅថា "រជ្ញាំកថាក" ។ រជ្ញាំនេះគេបានយកសិល្បៈមហាម័ត មកលាយចំរុះគ្នានឹងសិល្បៈហិណ្ឌូ ទៅជារជ្ញាំមួយបែបដែលច្រើនប្រើពាក្យពោល ទឹងបញ្ចេញមនោសញ្ចេតនាហើយនឹងក្លួនបច្ចុកទេសតាមនាដសាស្ត្រ ។

លុះដល់ម៉ោង ១២,៣០ នាទី យើងទាំងអស់គ្នាក៏ចេញពីស្ថានីយ៍បន្តិចបុរះទៅកាន់ទីក្រុងកំលគុត្តាតាមអយស្ទ័យយានពិសេស ។

ថ្ងៃអង្គារ ទី ១១ ធ្នូ ម៉ោង ១២,៤០ នាទី យើងទាំងអស់គ្នាក៏បានទៅដល់ទីក្រុងកំលគុត្តា ។

ទីក្រុងកំលគុត្តាពីសតវត្សទី ១៧ ជាទីក្រុងតូចមួយ, តែឥឡូវនេះទៅជាទីក្រុងមួយធំសម្បើមអស្ចារ្យក្នុងពិភពលោក ហើយជាទីកំពង់សមុទ្រ

ធំមួយនៅខាងបូពាប្រទេស ដែលជាផ្សារធំនាំទំនិញចេញចូលសម្រាប់ រដ្ឋបង្ការលនឹងរដ្ឋឯទៀតៗ ក្នុងប្រទេសឥណ្ឌៀទាំងមូល ។ ទីក្រុងនេះ មានជាំដើមឆ្មៃជាច្រើន ។ នៅតាមមាត់ទន្ទេហូគ្ទី មានរោងจស្សាហ-កម្មធ្វើក្រដាស, ប្រេង, ដែក, ស្សែក និងរោងពុម្ពជាច្រើន ។

នៅកណ្ណាលក្រុង មានจទ្សានមួយ ជាំផ្ការគ្រប់យ៉ាង ដែលគេ ហៅ "จទ្សានមែជ័ន" ហើយនៅទីនេះមានសង់កំពែង ហៅថា "កំពែង រិលិយ៉ាម"របស់ប្រទេសអង់គ្លេស ។ នៅជិតจទ្សានមែជ័ន និងតាមមាត់ ទន្ទេហូគ្ទី មានស្ថាបនានូវអនុស្សាវរិយ៍ព្រះនាងវិកតូរីយ៉ាអតីតអគ្គមហេសី នៃមហាក្សត្រិយ៍ប្រទេសឡាក្រង់ប្រឹតាញ ដែលមានជំកល់វត្ថុក្នុងរដ្ឋកាល ព្រះរាជិនីវិកតូរិយ៉ា ។ ខាងកើតจទ្សានមែជ័ន, មានពាណិជ្ជស្ថានជាច្រើន ត្ទិប, ភោជនាគារ . . . ល . . នៅខាងជើងจទ្សានមែជ័ន, មានវិមាន ចៅហ្វាយក្រុងក័លគុត្តា ។ ក្រៅពីនេះ នៅមានសួនសត្វនឹងសួនរុក្ខជាតិ គ្រប់យ៉ាង និងថូបដ្ឋានសំខាន់ៗ, ព្រមទាំងមានអនុស្សាវរីយ៍ជាច្រើន ។

ថ្ងៃអាទិត្យទី ១៦ ធ្នូ ១៩៥៦ ម៉ោង ២៤ ខ្ញុំបានចេញពីទី ក្រុងក័លគុត្តាតាមអាកាសយាន មកដល់ទីក្រុងគ្នំពេញ នៅថ្ងៃព្រហស្សតី ២០ ធ្នូ ១៩៥៦ ម៉ោង ១៧,៣០ នាទី ។

+

× ×

ប្រទេសឥណ្ឌៀ មានសភាកណ្ណាលនៅទីក្រុងដែល្ហី និងសភាទៃត្រ នៅរដ្ឋទាំង ១៦ ។ ក្នុងរដ្ឋនីមួយៗ មានរដ្ឋាភិបាលកាន់នីតិប្រតិបត្តិទទួល

ការខុសត្រូវចំពោះសកាវៃត្រ ។ សកាកណ្ណាលមានសិទ្ធិត្រួតត្រាទួលៅ
ត្រប់រដ្ឋទាំងអស់ ។ គេហដ្ឋានប្រជាពស្ត្រច្រើនជាគៀម សង់ផ្ទាល់នឹង
ដី,ពុំសូវមានសួនច្បារដំណាំបន្ទៃបុប្ជាទេ; នៅទីក្រុងប្ដស្រុកស្រែគ្មានចិន
តាំងលក់ដូរទេ, កន្ទៃងលក់ស្រាពុំសូវមាន ។ ពល់តែថ្ងៃអង្គារ រដ្ឋាកិបាល
ហាមមិនឲ្យលក់ត្រឿងស្រវឹង សូម្បីតែបីយៃក៏គ្មានដែរ ។ នៅទីណាក៏
មានប្រុសស្រីដេកផ្ទាល់នឹងដីហាលថ្ងៃ មានស្មូមយាចកច្រើន ។ កាសា
ដែលជ្រាស្រ៉ៃយគ្នាត្រប់ទ៉ីតំបន់ គឺកាសាអង់គ្លេស; នឹងកាសាហិណ្ឌី ។

ប្រទេសឥណ្ឌៀដែលបានឯកពដដោយស្នាដៃរបស់លោកមហត្មៈគន្ធី
នឹងលោកបណ្ឌិតនេហ៍រូ ។ លោកនេហ៍រូបានរចនាប្រទេសនេះទៅជា
ប្រទេសអព្យាក្រិត,ប្រតិបត្តិតាមគោលទាំង៥គឺ

១-ត្រូវទទួលស្គាល់នូវអធិបតេយ្យ, ឯកពដ្យនឹងបូរណកាពនៃ
ប្រទេសដទៃ ទៅវិញទៅមក;

២-មិនត្រូវបៀតបៀនគ្នាទៅវិញទៅមក;

៣-ត្រូវរក្សាឲ្យមានសមភាពនឹងគារវកាពនឹងគ្នាទៅវិញទៅមក;

៤-មិនត្រូវជ្រៀតបៀតនឹងកិច្ចការកូនប្រទេសទៅវិញទៅមក;

៥ ត្រូវរក្សាថាន: នឹងលក្ខណសម្បត្តិ ដើម្បីតំរង់ជីវកាពរស់
នៅជាមួយគ្នាដោយសន្តិសុខកូនសាកលលោកតទៅ ។

តពីនេះ យើងនឹងស្រង់យកសុន្ទរកថានឹងសារលិខិត មកចុះជូន
ជាលំដាប់តទៅ ៖

(មានត)

ក្រោងការបុណ្យ ព. ស. ២៥០០

របស់ប្រទេសកម្ពុជា

ក្រសួងធម្មការ

១- ការកំណត់កាលបរិច្ឆេទបុណ្យ:

ពិធីបុណ្យនេះកំណត់ធ្វើ ៧ ថ្ងៃ ៧ យប់, ចូលបុណ្យនៅថ្ងៃអាទិត្យ ១៤ កើតខែពិសាខ គឺ ១២ឧសភា ១៩៥៧, បន្ទាយបុណ្យនៅថ្ងៃសៅរ៍ ៥ កេីតខែពិសាខ គឺ ១៨ឧសភា ១៩៥៧ ។ ក្នុងឧកាសបុណ្យទាំង ៧ ថ្ងៃនេះ ត្រូវឲ្យមានបូជនីយេសកិច្ច ៣ ថ្ងៃផង នៅឯសៀមកប (អង្គវត្ត) សម្រាប់ប្រតិភូបរទេសទាំងឡាយ ដោយកម្មវិធីពិសេសដោយឡែក ។

២- អំពីទីកន្លែងសម្រាប់ធ្វើបុណ្យ:

ត្រូវយកទីត្រង់មុខស្ថានីយ៍អយស្ទ័យយាន ចាប់ពីទាត់កេីតព្រះសក្យមុនីចេតិយតទៅ ។

៣- អំពីការស្ថាបនាកន្លែងបុណ្យ:

ក- ធ្វើបុស្បកមួយ ខ្នាតតូច កំពស់ ២ ម, ២០ ទទឹងបណ្តាយ ៣ ម៉ែត្រ ៤ ជ្រុង ចំពីមុខព្រះសក្យមុនីចេតិយទៅទាត់កេីតចម្ងាយ ៥០ ម៉ែត្រ សម្រាប់តម្កល់ព្រះបរមសារីរិកធាតុឲ្យប្រជាជនធ្វើនមស្ការបូជា ។

ខ- ស្ថាបនាវេទិកា ២ ខ្នង : មួយខ្នងទាន់ស្តាំ មួយខ្នងទាន់ឆ្វេងនៃបុស្បក ; វេទិកាទាន់ស្តាំ សម្រាប់ព្រះមហាក្សត្រនឹងវរជនជាត្រហស្ថក្នុងប្រទេសនឹងក្រៅប្រទេស, វេទិកាទាន់ឆ្វេងសម្រាប់ព្រះសង្ឃ

នាយកទាំងពីរគណៈនឹងមម្ត្រីសង្ឆក្នុងប្រទេសនឹងក្រៅប្រទេស ។ ឯវេទិកា
ទាំងពីរនេះ ក្នុងវេទិកានីមួយ ។ ផ្ទើឲ្យបានចំណុះមនុស្ស ៣០០ នាក់
ដោយអង្គុយកៅអី ។

ត - សង់វេទិកាពិសេសមួយទ្នងទៀត មានជណ្តើរ មានកង់អាចរុញ
ចុះរុញឡើងបាន ផ្ទើឲ្យទ្ពស់សម្រាប់ថ្ងៃងកថាផ្សេង ។ ឲ្យគេមើលពីចម្ងាយ
មកឃើញលោកអ្នកថ្ងៃងការណ៍នោះយ៉ាងច្បាស់ ។ វេទិកានេះត្រូវដាក់ឲ្យ
ថ្ងៃងការណ៍ត្រង់ចន្ទោះព្រះចតិយនឹងបុស្សុក ។

យ - ពីខាងកើតបុស្សុក ចម្ងាយ ៣០ ម៉ែត្រ សង់បាពំពិធីមួយ
ទទឹង ៣៥ ម៉ែត្រ បណ្តោយ ១០០ ម៉ែត្រ ឲ្យបានចំណុះមនុស្ស ១ ម៉ឺន
នាក់យ៉ាងតិច ត្រូវផ្ទើឲ្យគត់ត្រៀងផង ផ្ទៃក្រោមក្រាលក្តារឲ្យទ្ពស់ស្ទើនឹង
បង្គុយកៅអី ដែលរៀបហើយប្រេចក្នុងវេទិកាដែលមានចែងត្រង់វគ្គអក្សរ
ទ ខាងលើ ។ បាពំនេះត្រូវចែកជាពីរសង្ឆាត់ : សង្ឆាត់ខាងមុខសម្រាប់ព្រះ-
សង្ឆ, ខាងក្រោយសម្រាប់ប្រជាជនទូទៅ ចូលប្រជុំផ្ទើសក្តារបូជា, ត្រូវ
ពាសជាពិតានដោយសំពត់សជង ក្រាលកន្ទេលក្រហម ដោយសុំអំពាវ
នាវដល់ពួកពុទ្ធបរិស័ទ អ្នកមានសទ្ធាចូលជួយតាមខ្នាតដែលនឹងកំណត់
ឲ្យ ។ សង្ឆាត់សម្រាប់ប្រជាជន ត្រូវឲ្យមានស្ទែងធំបានចំណុះប្រើនជាង
សង្ឆាត់សម្រាប់ព្រះសង្ឆ ។

ង - ខាងជើងនឹងខាងត្បូងនៃបាពំវែង មានផ្ទើះពងតាំងតុ ២ សម្រាប់
ព្រះសង្ឆនាយកទាំងពីរគណៈ គឺ ខាងត្បូងសម្រាប់ព្រះសង្ឆនាយកគណៈ
មហានិកាយ, ខាងជើងសម្រាប់ព្រះសង្ឆនាយកគណៈធម្មយុត្តិ ត្រូវផ្ទើឲ្យ

ចំភាគកណ្ណាលនៃបាវាពិធី ហើយឲ្យមានខ្នាតប៉ុនគ្នាផង ។

ច- បន្ទាប់ពីរោងព្រះសង្ឆនាយកទាំងពីរគណៈមកខាងកើត មានធ្វើរោងពីរទៀត គឺខាងជើងមួយ ខាងត្បូងមួយ, ក្នុងរោងមួយ ៗ ចែកជា ៧ ល្វែង សម្រាប់ចៅហ្វាយខែត្រៃរួបរួមជាមួយលោកគ្រូមេគណ-អនុគណ តាំងតុមួយរួមគ្នា មួយខែត្រតុមួយ ។

ឆ- តពីរោងតាំងតុរបស់ចៅហ្វាយខែត្រ-មេគណ-អនុគណមក ខាងកើតទុកឧកាសឲ្យពួកពុទ្ធបរិស័ទតាំងវត្ថុផ្សេង ៗ ដែលទាក់ទងខាងព្រះពុទ្ធសាសនា មានពុទ្ធប្រវត្តិជាដើម ជាគូជាគូទល់មុខគ្នាតាមជួររោងតាំងរបស់ចៅហ្វាយខែត្រ ។ ឯរោងតាំងត្រឿងទាំងនេះ ត្រូវពុទ្ធបរិស័ទអ្នកស៊ុំតាំងធ្វើផ្ទាល់ខ្លួន តាមខ្នាតដែលគណៈកម្មការកំណត់ឲ្យ ។

ជ- តួព្រះសក្យមុនីចេតិយមានការតាក់តែងដោយប្រទីបជ្វាលា ទង់ជាតិ ទង់សាសនានឹងផ្ការកម្រងផ្សេង ៗ ។

ឈ- នៅមុខបុស្សុក មានធ្វើរានមួយសម្រាប់តម្កល់ផ្ការក្ងីនឹងទៀនធូបផ្សេង ៗ ល្អវិសេស ដែលប្រជាជននាំមកធ្វើសក្ការៈបូជាចំពោះព្រះបរមសារីរិកធាតុ ។ ឯទីសម្រាប់ជុតបូជាទៀនធូបនឹងធ្វើកន្ទែងដោយឡែក ។

ញ- នៅជុំវិញបុស្សុក ត្រូវធ្វើតូបយាម ៤ សម្រាប់ទាហានយាមថែរក្សាព្រះបរមសារីរិកធាតុ ។

ដ- ធ្វើរោងតាំងមួយទៀតជាពិសេស ដោយឡែក នៅខាងត្បូងវត្តគ្នំ សម្រាប់ឲ្យក្រសួងសិក្សាធិការ "សាលារបនា" នាំយកនូវបុរាណវត្ថុផ្សេង ៗ មានព្រះពុទ្ធរូប ប្ដរូបថត ប្ដគំនូរដែលទាក់ទងខាងព្រះពុទ្ធសាសនា

ដើម្បីពន្យល់ប្រជាជនឲ្យឡើងពីពតិមាននៃវត្ថុនោះ ។ ។

៤- អំពីការស្ថាបនាមន្ទីរទាំងឡាយជារណបនៃបុណ្យនេះ

ក- ធ្វើរោងមួយសម្រាប់មន្ទីរពេទ្យដើម្បីថែទាំប្រជាជនដែលមកកាន់ពិធីបុណ្យនេះ ។

ខ- ធ្វើប៉ុស្តិ៍ប៉ូលិសមួយសម្រាប់ការពារសុខទុក្ខ និងសេចក្តីរៀបរយដែលបណ្តាលមកពីហេតុផ្សេង ។ ។

គ- ធ្វើរោងមួយសម្រាប់ជាក់ការិយាល័យគណៈកម្មាធិការនាយកប្ចគណៈកម្មាធិការប្រតិបត្តិការចាត់រិធានការបុណ្យគ្រប់យ៉ាង ។ ក្នុងរោងនេះ ត្រូវមានប្រជាប់ទគ្សាសនស័ព្ទ និងឲ្យស័ព្ទមួយគ្រឿងសម្រាប់ប្រាស្រ័យកិច្ចការផ្សេង ។ ក្នុងពិធីបុណ្យនេះជុានដោយស្ថួល ។

ឃ- ធ្វើរោងមួយសម្រាប់ជាក់ភ្ជងពិណពាឲ្យនិងភ្ជងវិទ្នរបូរាណ ។

ង- ធ្វើបង្ជន់មួយសម្រាប់ព្រះសង្ឆនិងប្រជាជនឲ្យឡើ ។

៥- សុំឲ្យមានបញ្ជាផ្សាយជំណឹងឡើងគ្រប់ទីស្ថាន ផ្ទះរាជការនិងផ្ទះឯកជន ព្រមទាំងវត្តអារាមទាំងអស់ក្នុងកម្ពុជរដ្ឋ ឲ្យរៀបពិធីបុណ្យនេះគ្រប់ទាំង ៧ ថ្ងៃដោយគ្រឿងសក្ការៈបូជាមានដោតទង់ជាតិ-ទង់សាសនាជាដើម តាមយថានុរូប ព្រមទាំងយានជំនិះគ្រប់ប្រភេទទាំងដើងទឹកដើងគោកក៏ត្រូវឲ្យដោតទង់ជាតិ និងទង់សាសនាដែរ ។

មួយទៀត បើវត្តណានៅជិតផ្ទូវរាជការ ត្រូវលើកទង់ក្រៅវត្តកែ្សរផ្ទូវនោះផង ។ គ្រប់ផ្ទះពុទ្ធបរិស័ទទាំងអស់នៅខែត្រក្រៅ ក៏ត្រូវលើកទង់ជាតិ ទង់សាសនាព្រមទាំងរៀបចំគ្រឿងសក្ការបូជាដែរ ។ ប្រជាជន

អាចប្រជុំគ្នា ធ្វើពិធីបុណ្យ ព.ស. ២៥០០ ខែនេះតាមផ្ទះ តាមភូមិកំពុង ប្រសិនបើខែក្រោយពីវត្តអាវាស ។

៦- ត្រូវប្រកាសផ្សាយដំណឹង ពាល់ពុទ្ធបរិស័ទឱ្យដឹងទូទៅថា កឋិនទានបុណ្យតាំងពីថ្ងៃនោះ ត្រូវឱ្យពុទ្ធបរិស័ទសមាទានសីល ៥ តាំងអស់គ្នា ខែវិថ្ងៃ ១៤ ទឹង ១៥ កើតខែភិសាខ គួរពាល់ឱ្យសមាទានខ្មោសថសីល ឱ្យបានច្រើនគ្នាជាងប្រក្រតី ។ បើគ្រហស្ថដែលមានសទ្ធា ចង់កាន់សីល ១០ ឱ្យត្រង់តាំងពី ៧ ថ្ងៃ តំណាការប្រពៃណាស់ ប៉ុន្តែត្រូវប្រើសុទ្ធតែសំលៀកបំពាក់ពណ៌ស ពោះបើស្លៀកសំឡីយក្តី ខោដើងវែងក្តី ។ អ្នកកាន់សីល ១០ ត្រូវគោរពស្តាប់ ពុកមាត់ ពុកចង្កា កាត់ក្រចកតាមពុទ្ធប្បញ្ញត្តិ ។

៧- គួរពាល់ណែនាំ ព្រមតាំងប្រកាសក្រឹងដំណឹងឱ្យពុលបុត្រ ពោះអ្នកពាក់ការត្រង់តំណែងតាំងតាមានតាំងស៊ុំលែក្តី ពោះសិស្សសាលាក្តី បើត្រូវការចង់ឃ្លួស ព្រះពាដរដ្ឋាតិបាលទ្រង់អនុញ្ញាតឱ្យឃ្លួសត្រឹម ៧ ថ្ងៃ ឯនក្រៅពីសិស្សសាលា ទ្រង់អ្នកពាក់ការមិនមានកំណត់ពេលឱ្យសឹកទេ, ឯការឃ្លួសនេះត្រូវឱ្យឃ្លួសនៅថ្ងៃចូលបុណ្យតំថ្ងៃ ១៤ កើតខែភិសាខ សឹកនៅថ្ងៃបន្ទាប់ក្រោយថ្ងៃបវេណីបុណ្យ ។ ចំណែកខាងគ្រឿងបរិក្ខារសម្រាប់ឃ្លួសជាការៈលើសាម៉ីខ្លួន តែបើដនណាមួយមានសទ្ធាត្រូវការឃ្លួសពុលបុត្រ ដែលមានសេចក្តីត្រូវថ្លៃចង់ចំរើនតាញ្ញុបដែរ តែខ្លាលក្រកំអាចឃ្លួសបានដោយសេរី ។ តថ្ងៃដែលឃ្លួសនឹងខ្លីសំណាក់អាស្រ័យនៃអ្នកឃ្លួសនោះសុំឱ្យលៃលកតាមសាម៉ីរបស់ត្រូ សុំឱ្យឃ្លួសតែតង់ថ្ងៃមួយជាមួយ

គ្នាប៉ុណ្ណោះ ។ ដំណឹងនេះចាប់ផ្តើមឃើញតាំងពីឆ្នាំ ๒๕๐๗ ។

๘- ប្រការសង្ឃឹមដំណឹងឲ្យតុលាការបរិច្ចេទ្ធ្វើទានជាកំណត់ត្រដាប់ព្រះសង្ឃ ๒๕๐๐ គង្គីយ៉ានតិច រៀនកន្លងបុណ្យតាំង ๗ ថ្ងៃ ក្នុងទីប្រជុំធ្វើបុណ្យ បើតុលាការណាមានសទ្ធា គាបនិមន្តតិក្ខុសង្ឃអគ្គណាទៅធាន់ប្តូ ស្មាក់ឯគេហដ្ឋានរបស់ខ្លួនកំណាន ។

៩- ចាត់ឲ្យបោះពុម្ពសាសនាសញ្ញា មានសណ្តានដូចជាមេដាយជាអនុស្សាវរីយ៍ដល់តំណពូបុណ្យ ព.ស. ๒๕๐๐ សម្រាប់ថ្វាយព្រះគុណជាអម្ចាស់វត្តលើស្ទួង ព្រមទាំងវេនក្នុងប្រទេសទីផ្សេងប្រទេស ដែលបានមកគាំពារពីពូបុណ្យនេះ ។ ឯសញ្ញានេះ មានការបញ្ជាក់ប្រើនបែបនឹងតម្លៃផ្សេង ๆ គ្នា តាមការសំរេចរបៀបគណៈកម្មការ ។

๑๐- ចាត់ឲ្យធ្វើតែមប្រើប្រាស់ណាយ៍មានតម្លៃផ្សេង ๆ ពុកជាទីរលឹកក្នុងពិធីបុណ្យនេះសម្រាប់ចែកជាដំណាលប្រជាជនទូទៅ ។

๑๑- ចាត់ការអញ្ជើញប្រតិភូប្រទេសនានា ដែលគាំទ្រព្រះពុទ្ធសាសនាទីប្រទេសជាមិត្តដ៏ឥតខាន ព្រមទាំងអគ្គការសមាគមនៃពុទ្ធសាសនា ដោយការចាត់ឲ្យអញ្ជើញតាំងពីឆ្នាំនេះទៅ ដើម្បីឲ្យគេមានឱកាសធ្វើយនឹងឱកាសឲ្យគេប្រជុំប្រៀបរៀបចំពិធីការរបស់គេ មានសារលិខិតជាដើម ព្រមទាំងសុំឲ្យគេធ្វើសារលិខិតនាំយកមកជាមួយផង បើប្រសិនជាគេមិនបានអញ្ជើញមកផ្ទាល់ខ្លួនក៏ដោយ ។

๑๒ ក្នុងថ្ងៃទី ๑๓ ខែកក តែថ្ងៃ ๑๕ កើតខែពិសាខ ព.ស. ๒๕๐๐ ជាថ្ងៃសៅរ៍បូជា វេលាម៉ោង ๕ ព្រឹក ត្រូវចាត់ឲ្យរាយតង់ជួនតាំង

ទូងគេវ៉ ទាញអាណត្តិសញ្ញា (ស៊ីវ៉ែន) ឲ្យលាន់ញ្ជកងរំពងទូទៅក្នុង ព្រះរាជអាណាចក្រ ឲ្យមានការបាញ់កាំភ្លើង ៦៥ ណាត់ផង ។ រួចហើយ មានការធ្វើពិធីសម្ពោធក្រោមព្រះបរមរាជាធិបតីភាព នៃព្រះករុណាជា អម្ចាស់ជីវិតលើត្បូង, សម្តេចព្រះមហាក្សត្រិយានី, សម្តេចព្រះទបយុវរាជ ដោយជួបជុំព្រះសង្ឆនាយកទាំងពីរគណៈ ព្រមទាំងមន្ត្រីសង្ឆក្នុង ប្រទេស ក្រៅប្រទេស និងវរជនក្នុងប្រទេស ក្រៅប្រទេស ថ្វែងកថា ផ្សេងៗលើវេទិការពិសេសដែលមានចែងក្នុងកម្មវិធី ។

៦៣- ត្រូវចាត់ឲ្យមានការសមាទានទបោសថសីលដោយមានព្រះ សង្ឆឲ្យសីល និងចំរើនព្រះបរិត្តតាមទគ្ឆោសនស័ព្ទ ព្រមទាំងប្រកាស ផ្សាយមេត្តាដោយទគ្ឆោសនស័ព្ទ ហើយចាត់ឲ្យមានអាកាសយានហោះ បាចផ្តា ព្រមទាំងក្រដាសបោះពុម្ពធមិផ្សេងៗក្នុងព្រះរាជធានីផង ។

៦៤- ក្នុងពិធីបុណ្យនេះ មានការសមាទានសីល៥ចំរើនព្រះបរិត្ត សំដែងធមិទេសនារៀងរាល់ថ្ងៃ រួចហើយត្រូវក្រុមទាហានដើងគោក-ដើងទឹក-អាកាស-ប៉ូលិស បុគ្គលិករាជការពួកនិស្សិតសូត្រធមិតាមកំណត់ ពេលវេលា ដែលនឹងមានបែងចែកពេលតាមលំដាប់ក្រុម-ពួក ដោយមាន មេចាត់នាំទៅតាមពួកតាមក្រុម ។ ឯធមិដែលត្រូវសូត្រនោះនឹងមានបោះ ពុម្ពចែក ទោះបីមិនបេះពីមុនមកក៏ដោយ អាចឲ្យសូត្រជាមួយគ្នាបាន ។

៦៥- នៅវេលាចប់ធម៌ម្ពងៗសុំឲ្យពុទ្ធបរិស័ទបញ្ជាញសទូសញ្ញា ថា សាធុ ៣ ដងឲ្យញ្ជឱ្ទាំងៗ ប៉ុន្តែឲ្យត្រម ៗ គ្នា គឺឲ្យមានសូរសំឡេង ស្មើគ្នាតែមួយ កុំឲ្យមានអ្នកខ្ទះស្រែកញ្ជឱ្ទាំងពេកជាងគេ ជួបជាគេស្រែក

លេង ជ្យាតការបញ្ចេញសូរស័ព្ទ ៣ ដងនេះជាប្រវេណីមួយមានតាំងពី
ក្នុងពុទ្ធកាលរៀងមក ។

មួយវិញទៀត បន្ទាប់ពីសាធុ ៣ ដងនោះមក ត្រូវឲ្យបញ្ចេញវាចា
ព្រមគ្នាថា "សូមឲ្យព្រះពុទ្ធសាសនារុងរឿងចំរើន ! សូមឲ្យព្រះពុទ្ធ-
សាសនាផ្សាយទូទៅពេញសកលលោក ! សូមឲ្យលោកទាំងមូលបាន
ប្រកបដោយសន្តិភាព ! ព្រះសក្យមុនីសម្ពុទ្ធទ្រង់ត្រាស់ថា "នត្ថិ សន្តិ
បរំ សុខំ" ពុំមានសេចក្តីសុខដទៃក្រៅពីសេចក្តីស្ងប់ទ្បើយ! ។ ទាងវាចា
នេះត្រូវបោះពុម្ពដោយក្រដាសមួយទំព័រតូចសម្រាប់ចែកឲ្យមានរាល់គ្នា ។
វាចានេះគាចបញ្ចេញឲ្យលាន់ព្ធគឺកកងរំពងម្ពង ។ ក្នុងពេលដដ្ឋព្របរម-
សារីរិកធាតុផង ។ ទាងវាចាទាំងនេះឲ្យមានមេដឹកនាំឲ្យថាតាម ។

១៦-ប្រកាសផ្សាយដំណឹងដល់ពួកពុទ្ធបរិស័ទដែលមានសទ្ធា ឲ្យ
ធ្វើបដា..ដោយសំពត់ពណ៌ស ឬពណ៌លឿង ដោយការសរសេរពាក្យ
ស្លោកបែបខាងលើនេះ ដាក់លើវិថីនានា ឬដាក់បញ្ឆរឲ្យព្រោងព្រាត
នៅមុខផ្ទះ ត្រប់វិថីនានាក៏បាន តាមសេចក្តីស្ម័ត្រ ។ ឯគណៈកម្មការ
ក៏ត្រូវចាត់ការធ្វើបដាបងលើវិថីនានាតាមការណ៍លែលក ។

១៧- សុំឲ្យមានការដោះលែងមនុស្សទោស នឹងការបន្ធយទោស
ទ្ធះចំពោះអ្នកមានទោសធ្ងន់ ។

១៨-ក្នុងទ្ធកាសបុណ្យទាំង ៧ ថ្ងៃនេះ មានប្រកាសច្បាប់បញ្ញត្តិឲ្យ
អត័យដល់សត្វព្រៃ ដើម្បីឲ្យសត្វទាំងឡាយនោះ បានរស់រួចជីវិត សូម្បី
ការប្រើប្រាស់សត្វពាហណៈក្នុងកំឡុងទាំង ៧ ថ្ងៃនេះ មានទឹមរទេះសេះ

ជាដើម ក៏ឲ្យមានការត្រាប្រណី ឧសពីថ្ងៃប្រក្រតីដែរ ។

១៩ - បញ្ឈប់មិនឲ្យមានការលក់នឹងការសេពសុរា មើរយ ក្នុងថ្ងៃ
បុណ្យតាំង ៧ ថ្ងៃនេះ សូម្បីប្បាប់អនុញ្ញាតជាពិសេស ក៏ពុំត្រូវអនុញ្ញាត
ឲ្យក្នុងថ្ងៃតាំង ៧ នេះដែរ ។

២០ ក្នុងឧកាសបុណ្យតាំង ៧ ថ្ងៃនេះ ព្រះរាជរដ្ឋាភិបាលតប្បីចាត់
វិធានការទាងតមនាតមន៍ ដូចជាអយស្ម័យយាន រថយន្តប្រចាំផ្ទូវ នាវ
ប្រចាំផ្ទូវទឹក និងរថយន្តឈ្នួលត្រប់ប្រភេទ ព្រមទាំងផ្ទះឈ្នួលដក ក៏
បញ្ញត្តកុំឲ្យរឡើងថ្ងៃលើសធម្មតា តែចំណែកទាងអយស្ម័យយាន សុំឲ្យ
បន្ទយថ្ងៃឈ្នួលមួយក្នុងភាគបី ។

២១- សុំឲ្យរាជការមុខក្រសួង ចាត់វិធានការដល់អ្នកលក់ផ្តា ទ្រឿន
ធូប ឲ្យលក់ថ្ងៃថោកគួរសម កុំឲ្យរឡើងថ្ងៃតាមអំពើចិត្ត ទាំងតម្លៃម្ហូប
អាហារនៅភោជនីយដ្ឋានទាទា ក៏កុំឲ្យរឡើងថ្ងៃលើសពីធម្មតាដែរ ។

២២ - ក្នុងឧកាសបុណ្យតាំង ៧ ថ្ងៃនេះ ត្រូវឲ្យមានភ្ជុងតូរ្យតន្ត្រី
និងរបាំផ្សេងៗ ឲ្យលេងរឿងដែលទាក់ទងនឹងពុទ្ធប្រវត្តិជាដើម ។
រឿងនោះ ត្រូវឲ្យមានគណៈកម្មការមួយក្រុមធ្វើការទាក់ទងជាមួយក្រុម
ល្ខោនជាតិ ព្រមទាំងសូមព្រះបរមរាជានុញ្ញាត ឲ្យល្ខោនព្រះរាជទ្រព្យ
លេងជូនភ្ជ្រៀវបរទេសមើលក្នុងថ្ងៃណាមួយ ។ ក្នុងការនេះ ត្រូវលៃ
លករកវ៉ៃឈ្ងភាពយន្តរឿងពុទ្ធប្រវត្តិ យកមកបញ្ចាំងក្នុងឧកាសបុណ្យនោះ
ផង ជាការប្រពៃណាស់ បើអាចលៃលកបាន ។ ឯរឿងភាពយន្តពុទ្ធ-
ប្រវត្តិនេះ គណៈកម្មាធិការនាយក សុំឲ្យព្រះរាជរដ្ឋាភិបាលប្រាស្រ័យ

ពាក់ខ្លួនទឹងស្តាខ្លួតឥណ្ណៀ សុំឲ្យដួយកេខ្ចី-កេដួលឲ្យ ។ ឯទី
កន្លែងលេង គណៈកម្មការទឹងលែលកទៅថ្ងៃក្រោយ ។

២៣ - មានការដង្ហែព្រះបរមសារីរិកធាតុ ចេញពីព្រះបរមកដកំពង
ដោយក្បួនដើងគោក ។

- ក្បួននេះ កំណត់ហៅនៅថ្ងៃទី ១៦ ខែឧសភា ១៩៥៧ ដើម្បី
និមន្តព្រះបរមសារីរិកធាតុ ទៅប្រតិស្ឋាននៅមហាបុស្សកខាងមុខព្រះ
សក្យមុនីចេតិយ ។

ក្នុងឧកាសដង្ហែក្បួននេះ មានអាកាសយានហោះពីលើបោះបាច់ផ្កា
ក្រដាសទឹងប័ណ្ណប្រសិទ្ធិពរជន ទឹងមានកម្មវិធីពិសេសដោយឡែក ។

២៤ - មានពួកកុមារជាង ១០០ នាក់ កុមារីជាង ១០០ នាក់ ស្លៀក
ពាក់ជាឯកសណ្ឋាន ទៅសូត្របទសកេញ្ញាសរសើរគុណព្រះពុទ្ធនៅ
បុស្សក នៅពេលដែលក្បួនហែទៅដល់ ។ ឯពួកកុមារ កុមារីនេះ ត្រូវ
យកសិស្សវិទ្យាល័យស៊ីសុវត្ថិ គរុវិជ្ជាទឹងអនុវិទ្យាល័យនារី ដោយជ្រើស
រើសឲ្យមានសំឡេងល្អផង ។

២៥ - សាលារៀនគ្រប់ប្រភេទ ព្រមទាំងអ្នកពាក់ការគ្រប់តំណែង
ទាំងពាហនទាំងស៊ីវិល ត្រូវបានឈប់សម្រាកក្នុងឧកាសបុណ្យនេះ គឺ

- អ្នកពាក់ការខាងសាលារៀន ត្រូវឲ្យឈប់គ្រប់ទាំង ៧ ថ្ងៃ

- អ្នកពាក់ការគ្រប់តំណែង ទាំងពាហនទឹងស៊ីវិល ត្រូវឲ្យឈប់
នៅថ្ងៃទី ១៣-១៦ ទឹងខែ ឧសភា ១៩៥៧ ដើម្បីទឹងបានទៅដង្ហែព្រះបរម
សារីរិកធាតុ, ក្នុងឧកាសឈប់សម្រាកនេះ ត្រូវចាក្រសួងទឹងមួយៗ មាន

បញ្ជាទៅបុគ្គលិកក្នុងក្រសួង នឹងគ្រប់ក្រុមទាំងអស់ដែលបិតនៅក្រោម
បង្គាប់ឲ្យទៅដង្ហែគ្រប់គ្នា ដោយមានមេបាត់ការក្នុងក្រសួងនីមួយ ៗ នឹង
ក្រុមនីមួយ ៗ នាំបុគ្គលិកទាំងអស់នោះឲ្យទៅរង់ចាំហែដោយពួកដោយ
ក្រុម ឬមួយកឹណាត់ទីកន្ទែងនឹងកាលបរិច្ចេទនឹងពេលមោំងឲ្យពួកបុគ្គលិក
ទៅជួបជុំតែម្តងក៏បាន ដើម្បីនឹងហែក្នុងក្សួននេះ រៀរលែងតែអ្នករាជការ
ដែលតម្រូវឲ្យទៅកាន់មុខការផ្សេង ៗ ក្នុងក្សួនហែ ។

ឯអ្នករាជការដែលទៅហែនេះ ត្រូវមានសំលៀកបំពាក់ជាឯក-
សណ្ឋាន គឺខោ-អាវស ក្រវ៉ាត់ខ្មៅ ស្បែកជើងខ្មៅ ។

៦៦- នៅទីក្រុងភ្នំពេញ មានការប្រកាសផ្សាយឲ្យប្រជាជន នឹង
វត្តអារាមនានាលាបថ្នាំសំអាងជាថ្មីនូវគេហដ្ឋាន នឹងកុដិ រិហារ សាលាជា
ដើម ព្រមទាំងយានជំនិះគ្រប់ប្រភេទ ក៏ត្លូវឲ្យលាបលនជាថ្មីដែរ ដើម្បី
លំអដល់ក្រុងក្នុងឱកាសបុណ្យ ។

៦៧- ការរៀបចំទូលនឹងការរៀបចំក្សួនហែព្រះបរមសារីរិកធាតុ
ត្រូវប្រគល់ការៈឲ្យក្រសួងការពារប្រទេស ជាប្រធានរៀបចំតាក់តែងផ្ទើ
ប្រាស្រ័យទាក់ទងជាមួយអ្នកតំណាងក្រសួងព្រះបរមរាជវាំង, ពុទ្ធិក
សមាគមកម្ពុជរដ្ឋ, សមាគមមិត្តពុទ្ធិកវិទ្យាល័យ, សមាគមតិលានសង្ត្រោះ,
តំណាងក្រសួងនានា ហើយនឹងសាលាក្រុង ។

៦៨- សូមព្រះបរមរាជានុញ្ញាត ហើកទ្វារវិហារព្រះកែវមរកត
មណ្ឌបព្រះបាទ ឲ្យជនបរទេសដែលយើងអញ្ជើញជាភ្ញៀវចូលនមស្ការ
បូជាក្នុងវិថ្ងណាមួយ ដោយមានកម្មវិធីពិសេសដោយឡែក ។ ឯជន

ជាតិយើងនឹងអនុញ្ញាតឲ្យថ្វាយបង្គំពីរបៀងទាងក្រៅព្រះវិហារ ។

៦៩- នៅព្រះបរមរាជវាំងមានអុចប្រទីបជ្ជាលាឲ្យភ្ជឹកាត្រាតជ្ជបបុណ្យតាំងតុអុំទូកដែរ ដើម្បីបង្ហាញឲ្យយើញសេចក្តីរុងរឿងរបស់ប្រទេសដែលមានព្រះមហាក្សត្រជាទីគោរព ។

៣០- ក្នុងវិថ្ជដង្ហព្រះបរមសារីរិកធាតុ: រយៈក្ស្ជនហត្រូវឈប់នៅទីវត្តណាមួយ ឲ្យមានពួកកុមារាកុមារី សូត្រឯទសរកញ្ញសរសើរគុណព្រះពុទ្ធបរមត្រូ ត្រប់រយៈក្ស្ជនហដែលត្រូវឈប់ "ជាការៈលើចៅអធិការវត្តត្រិះរិះរក" ។

៣១ អំពីការតាំងតុរបស់ព្រះសង្ឆនាយកទាំងពីរគណ: ត្រូវតាំងអំពីរឿងបូជនីយទស្សនីយដ្ឋាន ៤ កន្ទែង គឺព្រះអង្គទ្រង់ប្រសូត ជាន ត្រាស់ដឹង-សំដែងធម្មចក្កប្បវត្តនសូត្រ នឹងបរិនិព្វាន ត្រូវតាំងដោយរូបភាពដែលជាំន់ជារូបពិត ។ តាមដំណើរដ្ជរឿង ឲ្យក្រឡេកមើលទៅយើញហាក់ដូចជារូបមនុស្សមែន ។ ។ នេះជាការចាំជាច់ ។

៣៦- ប្រកាសផ្សាយដំណឹងអំពាវនាវពីឥឡូវនេះតទៅ ឲ្យប្រជាជនជ្រាបថា នរជនណា បើមានរតនវត្ថុផ្សេង ។ ហើយជ្រាថ្នានឹងយកទៅដំកល់ក្នុងទូមូលព្ធដ៏ដ្ជក្នុងនៃព្រះសក្យមុនីបេតិយថ្នាក់ក្រោម ទុកជាគ្រឿងសក្តារៈបូជានៃព្រះបរមសារីរិកធាតុនោះ សុំឲ្យយកទៅដំកល់ក្នុងទីនោះតាមសទ្ធា ។ .

៣៣- បុណ្យនេះគណៈកម្មាធិការនាយក ជានកំណត់ឲ្យឈ្មោះថា "បុណ្យព.ស.៦៥០០" ។

(fête de l'an 2500 de l'Ere Bouddhique)

๓๔ ក - ក្នុងឧកាសបុណ្យចាំដណ្តប់ថ្ងៃនេះ ត្រូវចាត់ការផ្សាយដំណឹងឲ្យពួកពុទ្ធសាសនិកជាត្រហស្ថ ដែលចូលមកកាន់តំបន់ធ្លាបុណ្យទៅក្រុងភ្នំពេញ ឲ្យស្គាល់ពាក់ព័ន្ធសម្គាល់គ្នា ប៉ុន្តែមើពុំអាចនេ ទំនងប្រើសំលៀកបំពាក់ពណ៌ផ្សេងក៏បាន ក្រៅពីលែងតែពណ៌ខ្មៅ ។ ឯពួកពុទ្ធសាសនិកដែលប្រជុំធ្វើបុណ្យនេះ ទាំងខែត្រក្រៅ បើអាចប្រគំបត្តិបាននាមរបៀបខាងលើនេះ ក៏ជាការប្រពៃណាស់ តែត្រង់អាវឡុកហាមផ្តាច់មិនឲ្យប្រើសោះ ។

ខ - មួយវិញទៀត គួរបញ្ជូនដល់ពួកអ្នកធាក់ស៊ីគូ ឲ្យមានសំលៀកបំពាក់ជាឯកសណ្ឋានផង ។

๓๕ - ត្រូវប្រកាសផ្សាយដំណឹងពីឥឡូវនេះតទៅ សុំឲ្យឈ្មោះបណ្តាអ្នកគ្រោះ ចោរបក្ខជិត ត្រហស្ថ បុរសស្ត្រីក្តី បើមានសមត្ថភាពអាចតែងឬរៀបរៀងអត្ថបទធម្មវិន័យណាមួយ ដែលយល់ថាគួរចោះពុម្ពចែកផ្សាយខ្លះ ឬជាវខ្លះក៏បាន យ៉ាងតិចត្រឹមមួយទំព័រពីរទំព័រឡើងទៅ ត្រូវរៀបចំតាំងពីឥឡូវនេះទៅ ឯតម្លៃចោះពុម្ពជាបន្ទុកលើសាមីខ្លួន ឬលើអ្នកមានសទ្ធាជួយជ្រះថ្លាតំណឹង ប៉ុន្តែអត្ថបទត្រូវមានសេចក្តីអធិប្បាយមែអត្ថបទគាំងនោះត្រូវឲ្យមានអាគតដ្ឋានអាងដល់គម្ពីរព្រះត្រៃបិដក ឬអដ្ឋកថាដីកាដែលជាពុទ្ធសាសនាពិត ។ ទោះបីទឹកឃើញចេញពីយោបល់ខ្លួន ក៏ត្រូវកុំឲ្យស្មើនឹងស្មើនយ៉ាងអំពីសេចក្តីក្នុងគម្ពីរដែលជាព្រះពុទ្ធសាសនាពិត ។ ទោះវែងខ្លីយកជាការបាន ។ ហាមផ្តាច់មិនឲ្យតែងសេចក្តីបូលក្នុងទង្វើនយោបាយ ទំនងសេចក្តីក្រៅព័ន្ធព្រះពុទ្ធសាសនា ទោះបីមានអាងគម្ពីរឬ

ក្នុងតម្រាអ្វីកំដោយ តាលេបើមានសេចក្តីខុសឥតប្រែតុទ្ធសាសនា មិនបើកទុកាសឲ្យបរសេរចមួង ប្តែងរៀបរៀងបោះពុម្ពផ្សាយក្នុងតិនដបុណ្យនេះឡើយ ។ ត្រូវតែក្នុងត្រះពុទ្ធសាសនាចក្រ ត្រូវតាំងឲ្យមានគណៈកម្មការមួយក្រុមសម្រាប់ខ្លួនតិនិត្យអត្ថបទនេះ ដោយខ្លួលខុសត្រូវពេញទី បើវត្តណាតូបនិងអាចតាំងគណៈកម្មការបាន ក៏សុំឲ្យយកអត្ថបទនោះទៅឲ្យវត្តណាដែលមានគណៈកម្មការតិនិត្យឲ្យ ។ ឯចំណែកគ្រូហស្ថបើបានតែងអត្ថបទនេះដែរ ក៏សុំឲ្យយកទៅប្រគេនគណៈកម្មការនៃវត្តដែលខ្លួនត្រូវរៀង ប្តែវត្តណាមួយដែលនោងជិតតាមស្តួត្រេបស់ខ្លួន ។ ឯអ្នកតែងអត្ថបទថ្មរៀបរៀងអត្ថបទតាំងនោះ ត្រូវយកទៅប្រគល់ឲ្យគណៈកម្មការដូចគោលខាងលើនោះតិនិត្យជាមុន ទើបមានសិទ្ធិបោះបាន ។

๓๖ - ប្រការសព្វ ឯជំណឹងតិនឡូវនេះទៅ ឲ្យពួកជាន់តំខ្ពស់ ជាន់ខ្ពាក់ជាន់ស្តួត ជាន់ប៉ាន់-ជាន់សូនបូ ប្រឹក្សាក្នុងប្រតិ តាមតែត្រង់ណាកំបានតាំងតិព្រាពុទ្ធត្រង់ប្រសូត រហូតដល់បរិនិព្វាន ប្តែបើអាចចាំប្រវត្តិត្រាតុទ្ធសាសនា ដែលព្យាយចូលមកប្រទេសកម្ពុជានេះ ដោយតិតក្រាកដ កំអាចឲ្យធ្លើបាន ។ ប្តែបើពុំខានសោតនឹងរបនាត្រង់រឿងដែលត្រះសោណត្ថេនឹងត្តវត្តបានមកត្រួត ពុទ្ធសាសនាមកប្រតិស្ថានតៅសុវណ្ណភូមិក្នុងកាលពុទ្ធសតវត្សទី ៣ តំនុង បើចាំរឿងនេះជោកល្អាស់, បើពុំនោះសោតនឹងធ្លើជាប្រទេនតវត្តិ មានប្រសង្ឃពុទ្ធសាសនិកនៅជិតផងកំបាន ដោយសព្វគារៀងខ្លួន ឲ្យយកមកតាំងត្រង់ទីដែលគណៈកម្មការកំណត់ឲ្យរួចទីមួយ ។ បើអាចធ្លើប្រទេនសម្រាប់ជាដែលអ្នកត្រូវការយកទៅពុកជាទី

រលឹកផងក៏បាន ។ មួយទៀតរូបភាពនេះនឹងមានការដាក់ឲ្យប្រឡងប្រ
ជែងយករង្វាន់ផង ដោយមានគណៈកម្មការមួយក្រុមពិនិត្យឲ្យរង្វាន់ ។

៣៧- ក្នុងវេលាថ្ងៃបុណ្យទាំង ៧ នេះ មានការអុចកាំជ្រួចរន្ធាភ្ជ-
ទៀនផងដាពុទ្ធបូជា ។

៣៨= ប្រាក់ចំណាយក្នុងពិធីបុណ្យនេះ មានការចំណាយប្រាក់
ថវិកាជាតិនឹងការវៃអង្គាសពីប្រជាជនត្រប់ជាន់ថ្នាក់តាមសទ្ធា, ដោយ
មធ្យោបាយនៃគណៈកម្មការមានក្រសួងហិរញ្ញវត្ថុជាប្រធាន ។

៣៩= មានការសុំអនុញ្ញាតពីព្រះរាជរដ្ឋាភិបាល អង្គាសប្រាក់កាស
ពីប្រជាជនទូទៅ ដើម្បីយកមកចាត់ការបុណ្យពីពេលនេះតទៅហើយមាន
ការសុំអនុញ្ញាតជាពិសេសទៀតដល់ព្រះរាជរដ្ឋាភិបាល ដើម្បីចាយវាយ
ប្រាក់នោះឲ្យស្រួល ហើយទាន់ពេលវេលាផង, ដោយការបង្កើតគណៈ
កម្មការមួយក្រុមសម្រាប់ពិនិត្យមុខចំណាយ គឺចាសុំឲ្យមានសិទ្ធិក្នុងការ
ចំណាយប្រាក់នេះសម្រេចថាគួរចាយមុខនេះ មុខនោះ ថ្ងៃប៉ុណ្ណេះ
ថ្ងៃប៉ុណ្ណោះ គួរចាយឬមិនគួរឲ្យចាយ ។

៤០- ប៉ើប្រាក់អង្គាសពីប្រជាជនពុំទាន់បានមកដល់ត្រប់ត្រាន់នឹង
មុខចំណាយទេ គួរសុំខ្ចីថវិកាជាតិមកប្រើប្រាស់មុន ដើម្បីឲ្យទាន់ការ ។

៤១- បង្កើតគណៈកម្មការមួយក្រុម សម្រាប់រៀបចំកម្មវិធីបុណ្យ
ទាំងមូល មានសម្តេចព្រះសង្ឆនាយកគណៈមហានិកាយជាប្រធាន ព្រះ
សង្ឆនាយកគណៈធម្មយុត្តិជាអនុប្រធាន សមាតមទាំង ៣ ជាសមាជិក ។

ត្រោងការទាំង ៤១ ខ ដែលបានចែកមកនេះ គណៈកម្មាធិការ

នាយកមានសមាជិក ២០ រូប ដែលតែងតាំងតាមប្រកាសក្រសួងនាយក
រដ្ឋមន្ត្រី លេខ ១១៨ ចុះថ្ងៃទី ១៨ មករា ១៩៥៧ ជាន់ដំខុំពិភាក្សាដេញ
ដោលប្តូរយោបល់គ្នាទៅវិញទៅមក អស់ចំនួន ៣ ថ្ងៃ យល់ឃើញថា
ប្រពៃហើយ ក៏ជានអនុម័តជាឯកច្ឆន្ទតាមគ្រោងការនេះគ្រប់ចំនុចអស់
ព្រោះឃើញថាមហាកុសលដែលប្រទេសកម្ពុជាធ្វើបុណ្យ ព.ស.២៥០០
នេះ ជាការសមរម្យតាមហាន:ជាវេលាកកជ្យហើយ ។ គណៈកម្មាធិការ
នាយកក៏ជានចាត់តាំងគណៈកម្មាធិការប្រតិបត្តិការ ឧទ្ទិសគណកម្ម:ការរដ
ប្រើនក្រុមតទៅទៀត ឲ្យទទួលបន្ទុកចាត់ការបុណ្យនេះឲ្យជានសម្រេច
តាមគ្រោងការដែលជានចែករំលែកមុខការឲ្យប្រតិបត្តិរៀង ។ ខ្លួន ឲ្យ
ជានរុងរឿងតាមព្រះយោបល់នៃព្រះករុណាជាអម្ចាស់ដ៏វិតលើក្បួន
សម្តេចព្រះមហាក្សត្រិយានី សម្តេចព្រះនរយុវកង វដែលព្រះអង្គ
មានព្រះមនោសញ្ចេតនា ប្រកបដោយមហាកុសល ច្រានគ្នាបុណ្យនេះឲ្យ
ជានរុងរឿងសមដល់កិត្តិគុណនៃប្រទេសរបស់ព្រះអង្គ ។

ភ្នំពេញថ្ងៃទី ៧ កុម្ភ:ត.ស.១៩៥៧

ជានពិនិត្យឃើញហើយយល់ព្រម
តាមគ្រោងការនេះទាំងអស់
រដ្ឋមន្ត្រីទី ១
ហត្ថលេខា: សាន-យុន

ប្រធានគណៈកម្មាធិការនាយក
ហត្ថលេខា: ឈួន-មនុលពេជ្រ

ជានចម្លងតាមដើមត្រឹមត្រូវហើយ
លេខាធិការនៃគណៈកម្មាធិការនាយក
ម៉ៅ-ការុន

កម្មវិធីបុណ្យ ព. ស. ២៥០០

ថ្ងៃទី ១

ថ្ងៃអាទិត្យ ១៤ កើតខែពិសាខ ព.ស. ២៥០០ (១២-៥-៥៧)

ជាថ្ងៃដង្ហែព្រះបរមសារីរិកធាតុទៅប្រជាប់លើបុស្ស្យក

ពេលព្រឹក

ម៉ោង ៦-០០: បើកពេលបុណ្យក្នុងព្រះរាជអាណាចក្រទាំងមូល ។

ម៉ោង ៦-៤០: ពិធីទទួលព្រះបរមសារីរិកធាតុ អំពីសម្តេចព្រះឧប-
យុវរាជ ក្នុងព្រះទីនាំងទេវាវិនិច្ឆ័យ ។

- សង្កថានៃសម្តេចព្រះសង្ឆនាយកទាំងពីរគណៈ ។

ម៉ោង ៧-៤០: ពិធីដង្ហែព្រះបរមសារីរិកធាតុទៅកាន់ទីកន្ធែងបុណ្យ ។

ម៉ោង ៩-៥០: ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង, សម្តេចព្រះមហា-
ក្សត្រិយានី, សម្តេចព្រះឧបយុវរាជ ស្តេចយាងដល់ ។

ម៉ោង ១០-០០ ក្ឆួនដង្ហែព្រះបរមសារីរិកធាតុមកដល់ទីកន្ធែងបុណ្យ ។

- ពិធីបង្ហូតទង់ជាតិ ទង់សាសនា ។
- ចំរៀងបទនគរាជ ។
- ពិធីនិមន្តព្រះបរមសារីរិកធាតុប្រជាប់លើបុស្ស្យក ។
- ថ្វាយបទសរភញ្ញ ។
- ព្រះរាជសុន្ទរកថានៃព្រះរាជា បើកពិធីបុណ្យ ។
- សុន្ទរកថា នៃសម្តេចព្រះសង្ឆនាយក គណៈ
មហានិកាយ ។

- សុនូរកថានៃសម្តេចព្រះសង្ឆនាយក ឆណ: ធម្មយុត្តិ ។

ម៉ោង ១០-៤០: ព្រះករុណាជាអម្ចាស់ជីវិតលើត្ឆូង សម្តេចព្រះមហាក្សត្រិយានី នឹង សម្តេចព្រះទបយុវរាជ ស្តេចយាងត្រឡប់ ។

សំលៀតបំពាក់
ចើមានឯកសណ្ឋាន : កីឡិយសធំ
ចើឆ្មានឯកសណ្ឋាន : ថ្ងៃថ្ងូរ
សូមមើលរបៀបសំលៀកបំពាក់នៅទាងចុង

ពេលរសៀល

ម៉ោង ១៨-៤៨: សម្តេចបៅហ្ហ៉ាកំងវរះវៀងជ័យអធិបតីស្រឹង្ការ ព្រឹទ្ធ-សមាជិកទត្តមប្រឹក្សាព្រះរាជាអគ្គនាយកក្រសួងនានាក្នុងព្រះបរមរាជវាំង ជាព្រះរាជតំណាងនៃព្រះករុណាជាម្ចាស់ជីវិតលើត្ឆូងអញ្ជើញជល់ ។

- សេចក្តីថ្វៃងការណ៍ជាបដិសណ្ឋារកិច្ចនៃព្រះរាជតំណាង ចំពោះព្រះបរមសាវ៉រកជាតុ ។

ម៉ោង ១៦-០០: ព្រះសង្ឆបួសថ្មី ៦៥០០អង្គ នឹងអ្នកកាន់សីល ១០ នមស្ការព្រះរត្នត្រ័យ ។

- ទាំទានុសាសនីនៃសម្តេចព្រះសង្ឆនាយកទាំងពីរឆណ: ។

- ប្រគេនទេយ្យទានដល់ព្រះសង្ឆបួសថ្មី ព្រម
ទាំងជូនទេយ្យវត្ថុដល់អ្នកកាន់សីល ១០ តាមគួរ ។

ម៉ោង ១៣ – ៣០: ព្រះរាជតំណាងត្រឡប់វិញ ។

សំលៀតបំពាក់
សំលៀកបំពាក់ក៉ត្តិយសគូច
មានឯកសណ្ឋាន : ក៉ត្តិយសគូច
ឆ្មានឯកសណ្ឋាន : ថ្ងៃថ្នូរ

ពេលយប់

ម៉ោង ១៨–០០: ពិធីប្រចាំពេលយប់ (នមស្ការព្រះរត្នត្រ័យ ចំរើន
ព្រះបវិត្ត ធម្មទេសនា)

ម៉ោង ១៩–០០: បូជាប្រទីបជ្ជាលាត្រប់វត្តអារាមគេហស្ថានរាជការ
និងពុទ្ធបរិស័ទទូទៅ ក្នុងព្រះរាជអាណាចក្រ ។

ម៉ោង ២០–៣០: បូជាកាំជ្ជួច រន្ធា ភ្ជីទៀន ។

ម៉ោង ២២–០០: រាំរឿងពុទ្ធប្រវត្តិដោយល្ខោនព្រះរាជទ្រព្យ រួបរួម
ជាមួយនឹងល្ខោនជាតិ ។

ម៉ោង ២០ដិល់ ២៤ : មហោស្រពលេងនៅបរិវេណវត្តក្នុំជូនពេញ
សម្រាប់ប្រជាជន ។

សំលៀតបំពាក់
ធម្មតា

× × ×

ផ្ទៃទី ២

ថ្ងៃបន្ទ ១៥ កើត ខែពិសាខ ព.ស,២៥០០(១៣-៥-៥៧)

ជាថ្ងៃវិសាខបូជា

ពេលព្រឹក

ម៉ោង ៨-០០: ព្រះករុណា ទាំង ២ ព្រះអង្គ នឹងសម្តេចព្រះឧបយុវរាជ ស្តេចយាងមកដល់ ។

- ទ្រង់បូជាកូងផ្ការ ។
- ថ្វាយបទសរភញ ។
- ពិធីសមាទានសីល ៨ ជាឧឡារិក ។
- ចំរើនពុទ្ធជយមង្គលគាថា ។
- ព្រះរាជសុនូរកថា នៃសម្តេចព្រះឧបយុវរាជ ។
- សារលិខិតនៃរដ្ឋាភិបាលបរទេស (ថ្ងៃន ៥ នាទីម្មាក់) ។

ម៉ោង ១០-០០: ពិធីដាក់បាត្រព្រះសង្ឆ ២៥០០ អង្គ ដោយមាន ព្រះករុណា ទាំង ២ ព្រះអង្គ ទ្រង់ជាប្រមុខ ។

ម៉ោង ១៤-៣០: ព្រះករុណា ទាំង ២ ព្រះអង្គ នឹងសម្តេចព្រះឧបយុវ-រាជ ស្តេចយាងត្រឡប់ ។

សំលៀកបំពាក់
ផ្ទបថ្ងៃទី ១ ពេលព្រឹក

ពេលរសៀល

ម៉ោង ១៦-០០: ឯ.ឧ.ទីប្រឹក្សាក្រសួងមហាផ្ទៃអញ្ជើញមកដល់ ។

- សុន្ទរកថា នៃ ឯ.ឧ. ទីប្រឹក្សាចំពោះព្រះបរម
  សារីរិកធាតុ ។
- សាលិទិតអ្នកតំណាងសមាគមពុទ្ធសាសនា
  បរទេស (ថនាទីម្នាក់) ។
- សុន្ទរកថា នៃពុទ្ធិកសមាគមពិភពលោកមជ្ឈ-
  មណ្ឌលភូមិភាគកម្ពុជរដ្ឋ ។
- សុន្ទរកថា នៃសមាគមតិលានសង្រ្គោះចំពោះ
  ព្រះសង្ឆ ។
- សុន្ទរកថា នៃសមាគមមិត្តពុទ្ធិកវិទ្យាល័យព្រះ
  សុរាម្រឹត ។
- ប្រគេនទេយ្យទានដល់ព្រះសង្ឆបរទេស ។

ម៉ោង ១៧-៣០- ឯ.ឧ. ទីប្រឹក្សាអញ្ជើញត្រឡប់ទៅវិញ ។

សំលៀតបំពាក់
ដូចថ្ងៃទី ១ រសៀល

ពេលយប់

ម៉ោង ១៩-០០: បូជាប្រទីបជ្ជាលា ដូចថ្ងៃទី ១ ។

ម៉ោង ២០-០០: ព្រះករុណាទាំង ២ ព្រះអង្គនឹងសម្តេចព្រះទបយុវរាជ

សេចយាងមកដល់ សេចគង់ប្រថាប់នឹងសេចយាងត្រឡប់ទៀតាមព្រះរាជអធ្យាស្រ័យ ។

ម៉ោង ២០-១៥: ក្ឌួនវៀហកើងបូជាព្រះរត្នត្រ័យប្រទក្សិណមណ្ឌលបុណ្យ ។

- ពិធីវៀហប្រទក្សិណថ្វាយគ្រឿងសក្ការបូជា ។
- ប្រកាសទៀសាខបូជា ។
- សូត្រទៀសាខបូជា ។
- ធម្មទេសនាទៃសម្តេចព្រះសង្ឆនាយក គណៈមហានិកាយ ។

ម៉ោង ២៣-០០: ពិធីថ្វាយកម្រងផ្កាដោយយុវនារី (ជ្រើសរើសនារីម្នាក់ជានិមិត្តរូបនៃនាង សុជាតា នឹងនារីកិត្តិយសធ្វេង-ស្តាំ) ។

(នាង សុជាតា ត្រូវទទួលកិត្តិយសបើកពិធីរំលឹកពេលព្រះពុទ្ធបានត្រាស់)

- ប្រកួតប្រជែងសូត្រធម៌បទផ្សេងៗ ដោយមានពួកនារីសម្រុងឯក រហូតដល់ម៉ោង ៥ ភ្លឺ ។

ម៉ោង ៤-៣០ភ្លឺ: ព្រះករុណាទាំង ៦ ព្រះអង្គនឹងសម្តេចព្រះទបយុវរាជសេចយាងដល់ ។

- ពិធីនមស្ការព្រះរត្នត្រ័យដោយព្រះសង្ឆ ទបាសក-សិកា ។

ម៉ោង ៥.ភ្ជ. ពិធីរំលឹកដល់ពេលដែលព្រះអង្គបានត្រាស់ដឹងនូវ
សម្ពោធិញ្ញាណដោយកាំជ្រួចបញ្ចេញពន្ធឹធព្ទ-
ណ្ណរង្ស៉ ។ កាំជ្រួចពិសេសបញ្ចេញរូបភាពនៃ
ព្រះពុទ្ធបិតនៅលើអាកាស ។

- សូត្រថ្វាយព្រះពរជ័យ ។

- ព្រះសង្ឆស្វាធ្យាយបដិច្ចសមុប្បាទធម៌ - អនេក
ជាតិសំសារំ ។

ម៉ោង ៦-០០: ព្រះករុណាទាំង ៦ ព្រះអង្គ នឹងសម្តេចព្រះទបយុវ-
រាជទ្រង់យាងត្រឡប់ ។

សំលៀតបំពាក់
ឆ្លងថ្ងៃទី ១ ពេលរសៀល

× × ×

ថ្ងៃទី ៣

ថ្ងៃអង្គារ ១ រោបខែពិសាខ ព.ស. ២៥០០(១៤.៥.៥៦)

"ដូនត្រៀវបរទេសទៅទស្សនាប្រាសាទនគរវត្តរហូតដល់ថ្ងៃទី ១៦
ពេលព្រឹកត្រឡប់មកវិញ"

ពេលព្រឹក

ម៉ោង ៩,០០: លោកប្រធានរដ្ឋសភាអញ្ជើញមកដល់ ។

-សេចក្តីថ្វៃនការណ៍ជាបដិសណ្ឋារកិច្ចនៃលោក
ប្រធាន ចំពោះព្រះបរមសារីរិកធាតុ ។

-ពិធីសមាទានសីល ៥ ជាទឡ្ហរិក ។

-ពិធីដាក់ចាត្រព្រះសង្ឆ ២៥០០ អង្គ ។

ម៉ោង ១០,៣០: លោកប្រធានរដ្ឋសភាអញ្ជើញត្រឡប់ទៅវិញ ។

ពេលរសៀល

ម៉ោង ១៦,០០ ប្រធានក្រុមប្រឹក្សាព្រះរាជអាណាចក្រអញ្ជើញមក
ដល់ ។

-សេចក្តីថ្វៃនការណ៍ជាបដិសណ្ឋារកិច្ចនៃលោក
ប្រធាន ចំពោះព្រះបរបសារីរិកធាតុ ។

-នមស្ការជាទឡ្ហរិកតាមក្រុម ។

-ពិធីសមាទានសីល ៥ ជាទឡ្ហរិក ។

ម៉ោង ១៧-៣០: លោកប្រធានអញ្ជើញត្រឡប់ទៅវិញ ។

សំលៀកបំពាក់ធាំនៃពេល
ផ្ទាចថ្ងៃទី ១ ពេលរសៀល

ពេលយប់

ម៉ោង ១៩-០០: បូជាប្រទីបជ្វាលា ដូចថ្ងៃទី ១ ។

ម៉ោង ១៩-៣០០ បូជាកាំជ្ជួបរន្ធាក្ងីទៀនដូចថ្ងៃទី ១ ។

ម៉ោង ២០-០០ ប្រកាសវិសាខបូជានៃគណៈធម្មយុត្តិ ។

- សូត្រវិសាខបូជា ។

- ធម្មទេសនានៃសម្តេចព្រះសង្ឆនាយកគណៈធម្មយុត្តិ ។

- ធម្មទេសនានៃព្រះធម្មកថិកពីររូប ។

ម៉ោង ២០ទៅ ២៤: ពិធីប្រចាំពេលយប់នឹងមហោស្រពនៅបរិវេណវត្ត

ភ្នំ ដូចថ្ងៃទី ១ ។



សំលៀកបំពាក់
ធម្មតា

× × ×

ថ្ងៃទី ៤

ថ្ងៃពុធ ២ ភេបខែពិសាខ ព.ស. ២៥០០ (១៥-៥-៥៣)

ជាថ្ងៃរំលឹកដល់ព្រះពុទ្ធអង្គទ្រង់សំដែងធម្មបក្រ

ពេលព្រឹក

ម៉ោង ៣,៥៥: លោកទេសរដ្ឋមន្ត្រីក្រសួងធម្មការនឹងសន្តិសុខជាតិ

អញ្ជើញមកដល់ ។

- សេចក្តីថ្វែងការណ៍ជាបដិសណ្ឋារកិច្ចនៃលោក

ទេសរដ្ឋមន្ត្រី ចំពោះព្រះបរមសារីរិកធាតុ ។

- ពិធីសមាទានសីល ៥ ជាទឡារិក ។

ម៉ោង ៩-០០ ពិធីតាវកិច្ចនៃកងតម្រួត_កងជីវពលនឹងនាវីក្ងាហាន
ចំពោះព្រះបរមសារីរិកធាតុ (ការហែក្បួន) ។
- ពិធីជាក់ចាត្រព្រះសង្ឆ ២៥០០ អង្គ ។

ម៉ោង ១០-៣០: លោកទេសរដ្ឋមន្ត្រីអញ្ជើញត្រឡប់វិញ ។

ពេលរសៀល

ម៉ោង ១៦-០០: លោករដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចជាតិអញ្ជើញមកដល់ ។
- សេចក្តីថ្វាយការណ៍ជាបដិសណ្ឋារកិច្ចនៃលោក
រដ្ឋមន្ត្រី ចំពោះព្រះបរមសារីរិកធាតុ ។
- នមស្ការជាទឡាវិកតាមក្រុម ។
- ពិធីសមាទានសីល ៥ ជាទឡាវិក ។

ម៉ោង ១៧-៣០: លោករដ្ឋមន្ត្រីអញ្ជើញត្រឡប់វិញ ។

សំលៀតបំពាក់ឆាំង ២ ពេល
ផ្ទុចថ្ងៃទី ១ រសៀល

ពេលយប់

ម៉ោង ១៩-០០: បូជាប្រទីបជ្ជាលា ផ្ទុចថ្ងៃទី ១ ។

ម៉ោង ១៩-៣០: បូជាកាំជ្រួច រន្ទា ក្ងីទៀន ផ្ទុចថ្ងៃទី ១ ។

ម៉ោង ២២-០០: ប្រកួតប្រជែងអត្ថបទស្តីអំពីពុទ្ធទាទជាសាវន្ត ។

ម៉ោង ២០ដល់២៤: ពិធីប្រចាំពេលយប់នឹងមហោស្រពនៅវត្តកុំ ផ្ទុច
ថ្ងៃទី ១ ។

សំលៀកបំពាក់
ធម្មពា

× × ×

ឆ្ងៃធី ៤

ថ្ងៃព្រហស្សត៍ពាភាបខែពិសាខ ព.ស.២៥០០ (១៦-៥ ៥៣)
ជាថ្ងៃរំលឹកដល់ព្រះពុទ្ធអង្គសំដែងធម៌ប្រោសព្រះពុទ្ធមាតា

ពេលព្រឹក

ម៉ោង ៣-៥៥; លោករដ្ឋមន្ត្រីក្រសួងការពារប្រទេសនឹងឃោសនាការ
អញ្ជើញដល់ ។

- សេចក្តីថ្វាងការណ៍ជាបដិសណ្ឋារកិច្ចនៃលោករដ្ឋមន្ត្រី
ចំពោះព្រះបរមសារីរិកធាតុ ។

- ពិធីសមាទានសីល ៥ ជាឧឡារិក ។

ម៉ោង ៧-០០: ពិធីតារវកិច្ចនៃកងឃោធពលទេមរភូមិន្ទចំពោះព្រះបរម
សារីរិកធាតុ (ការហែក្បួន) ។

- ពិធីដាក់បាត្រព្រះសង្ឆ ២៥០០ អង្គ ។

ម៉ោង ១០-៣០: លោករដ្ឋមន្ត្រីអញ្ជើញត្រឡប់ទៅវិញ ។

សំលៀកបំពាក់

ដូចថ្ងៃទី ១ រសៀល

ពេលរសៀល

ម៉ោង ១៤-០០: ការប្រកួតប្រជែងរថយន្តមាលាវិចិត្រ របនាតាមដ្ឋ
រឿងពុទ្ធប្រវត្តិ ។

- ពិធីដង្ហែក្ឈូនរថយន្តមាលាវិចិត្រប្រទក្សិណ មណ្ឌលបុណ្យ ។

ពេលយប់

ម៉ោង ១៩.០០: បូជាប្រទីបជ្រាលា ដូចថ្ងៃទី ១ ។

ម៉ោង ១៩-៣០: បូជាកាំជ្ជួប រន្ធា ក្ងីទៀន ដូចថ្ងៃទី ១ ។

- ពិធីរំលឹកព្រះពុទ្ធអង្គយាងចុះពីស្ថានត្រៃត្រឹង្ស ។

ម៉ោង ២០ដល់ ២៤: ពិធីប្រចាំពេលយប់ទឹងមហោស្រព នៅវត្តក្នុំ ដូចថ្ងៃទី ១ ។

ម៉ោង ២១,៣០: ល្ខោនព្រះរាជទ្រព្យជូនក្ងៀវបរទេសមើលក្នុងព្រះ
បរមរាជវាំង ។

សំលៀកបំពាក់

ធម្មតា

× × ×

ថ្ងៃទី ៦

ថ្ងៃសុក្រ ៤ រោបវៃពិសាខ ព.ស.២៥០០ (១៣-៥ ៥៣)

ជាថ្ងៃរំលឹកដល់ព្រះពុទ្ធអង្គទ្រង់ប្ចូលព្រះបរិនិព្ធាន

ពេលព្រឹក

ម៉ោង ៣-៥៤: លោករដ្ឋមន្ត្រីក្រសួងសាធារណសិក្សាធិការអញ្ជើញ
មកដល់ ។

- សេចក្តីថ្វែងការណ៍ជាបដិសណ្ឋារកិច្ចនៃលោក
រដ្ឋមន្ត្រី បំពោះព្រះបរមសារីរិកធាតុ ។

- ពិធីសមាទានសីល ៥ ជាទឡ្ហរិក ។

ម៉ោង ៧-១០: ពិធីគារវកិច្ចនៃនិស្សិតវិទ្យាល័យនឹងអនុវិទ្យាល័យ
ទាំងឡាយ ព្រមទាំងក្រុមការយវិទ្ធិ ។

- ពិធីដាក់ចាត្រព្រះសង្ឆ ២៥០០ អង្គ ។

ម៉ោ ១០-៣០: លោករដ្ឋមន្ត្រីអញ្ជើញត្រឡប់ ។

ពេលរសៀល

ម៉ោង ១៦-០៧: លោករដ្ឋមន្ត្រីក្រសួងយុត្តិធម៌អញ្ជើញមកដល់ ។

- ពិធីដោះលែងមនុស្សទោសដោយទរាទនៃលោក
រដ្ឋមន្ត្រី ។

- ពិធីសមាទានសីល ៥ ជាទឡ្ហរិក ។

- នមស្ការព្រះរត្នត្រ័យ តាមក្រុម ។

ម៉ោង ១៦-៣០: ក្រៀវបរទេសចូលនមស្ការបូជាស្ថានវិហារព្រះកែវមរកត

នឹងមណ្ឌបព្រះបាទ ។

ម៉ោង ១៧-៣០ - លោករដ្ឋមន្ត្រីអញ្ជើញត្រឡប់វិញ ។

សំលៀតបំពាត់
ដូចថ្ងៃទី ១ សៀល

ពេលយប់

ម៉ោង ១៩.០០: បូជាប្រទីបជ្ឋាលា ដូចថ្ងៃទី ១ ។

- បូជាកំជ្ជុបរនូ ក្រីទៀន ។

ម៉ោង ២០ដល់ ២៤: ពិធីប្រចាំពេលយប់ នឹងមហោស្រព ដូចថ្ងៃទី ១ ។

ម៉ោង ២២.០០: ពិធីសំដែងសេចក្តីសោកស្តាយព្រះពុទ្ធអង្ត ។

សំលៀតបំពាត់
ធម្មតា

× × ×

ថ្ងៃ ឌី ៧

ថ្ងៃសៅរ ៥ រោចខែពិសាខ ព.ស. ២៥០០ (១៨-៥-៥៧)

ជាថ្ងៃប្រតិស្ឋានព្រះបរមសារីរិកធាតុក្នុងព្រះសក្យមុនីបេតិយ

ពេលព្រឹក

ម៉ោង ៧.០០: ព្រះករុណា ទាំង ៦ អង្ត នឹងសម្តេចព្រះទបយុវកជ

ស្តេចយាងដល់ ។

- ពិធីនមស្ការ ។

- ពិធីសមាទានសីល ៥ ជាទឡ្ហិក ។

- ពិធីប្រតិស្ឋានព្រះបរមសារីរិកធាតុ ។

ម៉ោង ៩.០០: ព្រះករុណាទាំង ២ ព្រះអង្គនឹងសម្តេចព្រះទបយុវរាជ ទ្រង់យាងត្រឡប់ ។

ម៉ោង ៩.៣០: ពិធីដាក់បាត្រជូចថ្ងៃទី ១ ។

សំលៀកបំពាក់ ជូចថ្ងៃទី ១ ព្រឹកឆែរ តែបើទ្រង់ព្រះពស្ត្រ-ស្លៀកសំពត់ពណិត្នៅ

ពេលរសៀល

ម៉ោង ១៥-០០: ពិធីសង្គាយនា ។

- ព្រះករុណាទាំង ២ ព្រះអង្គនឹងសម្តេចព្រះទបយុវ-រាជស្តេចយាងដល់ ។

- សេចក្តីរាយការណ៍នៃសម្តេចព្រះទបយុវរាជនា-យកវដ្ឋមន្ត្រីអំពីពិធីបុណ្យថ្វាយព្រះករុណាជា អម្ចាស់ជីវិតលើត្សូង ។

- ព្រះរាជាទ្រង់តបវិញដោយផ្សាយបុញ្ញរាសីដល់ ពុទ្ធបរិស័ទទូទៅក្នុងព្រះរាជអាណាចក្រ ។ រួចហើយ ព្រះអង្គទ្រង់បិទពិធីបុណ្យ ។

- ទាញអាណត្តិសញ្ញា - ចាញ់គាំភ្នើន ៦៩ ណាត់

ជាសញ្ញាបិទពិធីបុណ្យ ។

សំលៀកបំពាក់

ដ្ឋិចថ្ងៃទី ១ ពេលព្រឹក

ផ្នើនៅក្រសួងធម្មការថ្ងៃទី ៤ ខែមេសា ១៩៩៧

	សម្តេចព្រះមហាសុមេធាធិបតី
គណៈកម្មាធិការនាយកបានអនុមតិយល់ព្រមហើយ	សង្ឆនាយកគណៈមហានិកាយ
ទេសរដ្ឋមន្ត្រីទទួលបន្ទុកទាងក្រសួងធម្មការ	ប្រធានគណៈកម្មការរៀបចំកម្មវិធី
ប្រធានគណៈកម្មាធិការនាយក	ហត្ថលេខា: ជ្ឋិន-ណាត
ហត្ថលេខា: ឈួន-មជុលពេជ្រ	

បានយើញហើយយល់ព្រមដង

សម្តេចព្រះសុធម្មាធិបតី	សម្តេចព្រះមហាសុមេធាធិបតី
សង្ឆនាយកគណៈធម្មយុត្តិ	សង្ឆនាយកគណៈមហានិកាយ
ហត្ថលេខា: ភុល-ទេស	ហត្ថលេខា: ជ្ឋិន-ណាត

	បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
ទ្រង់មានព្រះភជយោមល់យល់ដង	សូមព្រះរាជទានឡាយព្រះហស្តលេខា
សម្តេចឧបយុវរាជនាយកៈដ្ឋមន្ត្រី	ទេសៈដ្ឋមន្ត្រីទទួលបន្ទុកទាងក្រសួងធម្មការ
ព្រះហស្តលេខា: ន. សីហនុ	ប្រធានគណៈកម្មាធិការនាយក
	ហត្ថលេខា: ឈួន-មជុលពេជ្រ

ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង

ទ្រង់បានព្រះបរមរាជានុញ្ញាត

ព្រះហស្តលេខា: ន-សុរាម្រឹត

× × ×

របៀបសំលៀកបំពាក់សម្រាប់ពិធីបុណ្យ

មាន៤យ៉ាងគឺ:

១- សំលៀកបំពាក់កិត្តិយសធំ:-

ក្សត្រី-ស្ត្រី ព្រះពស្ត្រ-សំពត់ ពណិតាមថ្ងៃ បងក្សិន

ព្រះភូសា-អាវ ស

ព្រះសុក៉ត ឥាហ៊ុម ស៊ីនួនឌ្ឌី

ក្សត្រា-មន្ត្រី មានឯកសណ្ឋាន:

ព្រះពស្ត្រ-សំពត់ ពណិតាមថ្ងៃ

ព្រះភូសា-អាវ ស សក្តិពញ្ញយសគ្រឿងឥស្សរិយ-

យសព្យូរ សុព៉ណិបាទ - ស្បែកជើង - ស្រោមខ្មៅ

(សេនាទាហាន ក្សត្រានឹងមន្ត្រីមានឯកសណ្ឋាន

ដែលមានការត្រូវស្តេចយាងឬដើរហ អាចទ្រង់

ស្លៀកខោជំនួសសំពត់បាន)

មន្ត្រីសង្ស ហានានុក្រម មានផ្ទីតសម្រាប់ងារ ។

២:- សំលៀកបំពាក់កិត្តិយសតូច:-

ដូចកិត្តិយសធំដែរ ប៉ុន្តែមានតែសក្តិស្មា នឹងគ្រឿង

ឥស្សរិយយសបន្ទះ (បាវ៉ែត)

មន្ត្រីសង្ស ហានានុក្រមមានផ្ទឹតសម្រាប់ងារ

៣: សំលៀកបំពាក់ជ្លៃជ្ជុរ:-

ឈ្មត្រី-ស្ត្រ ព្រះពស្ត្រ សំពត់ ចងក្សិន ព័ណិ

ព្រះភូសា-អាវ ស

ព្រះសុភ័ត-ក្រមា ពណិ ឬផ្ការ

ឈ្មត្រា-បុរស: ព្រះពស្ត្រ-សំពត់ពណិ ព្រះភូសា-អាវកុតបិទក ស

ឬព្រះពស្ត្រ-ទោ ស អាវបើកក ស ក្រវាត់ឡៅ

សុព័ណិបាទ-ស្បែកជើង-ស្រោមជើងឡៅ

មន្ត្រីសង្ស ហានានុក្រម ឆ្នានជ្ជិត ។

៤: សំលៀកបំពាក់ធម្មតា:-

ឈ្មត្រី-ឈ្មត្រា ស្ត្រី-បុរស :

សំលៀកបំពាក់តាមធម្មតា តែត្រូវមានត្រប់ប្រដាប់ ។

× × ×

អគាត្ម ពុំ. អ្នកគ្រៀងមិនពីភេះ ។

អគាធ គុ. ដែលស្ងួងមិនបាន, ជ្រៅណាស់, ជ្រៅន ។ - នាមភ្លើងអួយក្នុងភ្លើងទាំងប្រាំនៅស្ថានការ, (ហ វម្ស) ។ - ជល នពុំ. ទឹកជ្រៅ ។ - ពុទ្ធិ គុ.ដែលមានប្រាជ្ញាជ្រៅន ។ - វុដ្ឋិ នពុំ. ឈាមជ្រៅន, ឈាមតាសពេញ ។

អគារ ពុំ. នពុំ. អាគារ, ផ្ទះ ។ - ទាហន ពុំ. ភ្លើងឆេះផ្ទះ ។

អគិរ ពុំ. ព្រះអាទិត្យ; ភ្លើង ។

អគុណ ពុំ. អគុណ, ការមិនមានគុណ, ទោស; គុ. ដែលឥតគុណ; - វន្ត, គុ. ដែលមិនមានគុណ, អាក្រក់ ។ - ជ្ញ, គុ. (ជន) មិនដឹងគុណ ។ - ភាវ, គុ.ដែលមិនពោលនូវគុណ ។ - ភីរុ, គុ. ដែលមិនមានគុណជាប្រក្រតី ។

អគ្ឃ ពុំ. ជនមិនមែនជាតុរ្យ ។ គុ. ដែលច្រើនស្រួល; ពុំ. នពុំ. ឈើអគ្ឃ ។

អគ្ឃវន គុ. ដែលមិនក្រៃ, ដែលចំហ ។ -ភន្ធ, នពុំ. ឈ្មោះឈើ ។ - ភាវ, ពុំ. ភាវនៃ . . . មិនចំទាំង, ភាវនៃ . . . ដែលតើលឃើញ ។

អគោបរ គុ. ដែលមិនមែនជាទីគោចរ, ដែលក្នុលទៅមិនបាន; ពុំ. ព្រហ្ម - គ ស្ត្រី. ភាវនៃ . . . មិនមែនជាទីគោចរ ។

អគោឃាល គុ. ដែលមិនមែនជាគោឃាល ។

អគ្គិ ពុំ. អគ្គិ, ភ្លើង ទេវតាភ្លើង; ពហុ. ជនតាជនដែលព្រះអគ្គិ; - ភីត ទ្វិបជាភ្លើង; - ស្ថាន ដុំរភ្លើង ។ - កន ពុំ. "បំណែកដែលភ្លើង" ផ្កាភ្លើង ។

ឥន្ទសុទិយា

ទស្សនាវិជ្ជី ផ្សាយជំណឹងទាងសាសនា នឹងអក្សរសាស្ត្រ

លេខពិសេស

ពិធីបុណ្យ



ឆ្នាំទី ២៩ លេខ ៥ ខែទុសភា ព.ស. ២៥០០ គ.ស. ១៩៥៦



ធម្ពបស្ទិយា

លេខពិសេស

ពិធីបុណ្យ

ពុទ្ធសាសនា ២៥០០



ឆ្នាំទី ២៩ លេខ ៥ ខែទុសភា ព.ស. ២៥០០ គ.ស. ១៩៥៦

អារម្ភកថា

ព្រះពុទ្ធសាសនា ជាសាសនាមានពុទ្ធន្តរកប្រជៅតាំងផ្លូវលោក ផ្លូវធម៌ គឺប្រជៅតាំងពីប្រយោជន៍បច្ចុប្បន្ន, ប្រយោជន៍បរលោក, រហូតដល់ប្រយោជន៍ផុតចាកលោកគឺព្រះនិព្វាន ជម្រះលទ្ធកន់ខៅជ្រៅបំផុតជួចមហាសមុទ្រដែលមានផ្ទៃទាំពាក់ខៅជ្រៅ ជាបដល់ជ្រៅឥតគណនា ហើយកន្លងបណ្តាពុទ្ធន្តរកប្តាំងកត់តាំងជ្រៅនោះ សុទ្ធតែប្រជៅឲ្យលះទុច្ចរិត កាន់សុចរិតតាំងអស់ ជាពុទ្ធន្តរមានរសតែមួយ គឺវិមុត្តិរស (ការរួចស្រឡះចាកកិលេស) ហើយជាសាសនាសម្បូរដោយបទនាយកធម៌ធំ ៗ មានអហឹសា (ការមិនបៀតបៀនគ្នា) ជាដើម ហៅថា " សាសនាទឹកអម្រឹត " អាចស្រោចស្រប់បន្ទានចិត្តនៃជនដែលក្តៅដោយភ្លើងទុក្ខ ភ្លើងកិលេសឲ្យត្រជាក់ត្រជំជាបរមសុខបាន តាមទិស្សយដ្ឋកប្រតិបត្តិ ។

ដោយហេតុព្រះពុទ្ធសាសនាមានគុណធម៌ដ៏ឧត្តម ដូចពណ៌នាមកនេះទើបបានទទួលកិត្តិឃោស (សេចក្តីលើកដំកើង) អំពីសកលលោកថាជាសាសនាខ្ពស់បំផុតខាងបទដឹកនាំពិភពលោកឲ្យបានសន្តិភាព ។

កាលព្រះសក្យមុនីសម្ពុទ្ធគ្រប់ព្រះជន្មខៅឡើយ សាសនារបស់ព្រះអង្គរុះថ្លើងរឿងតែក្នុងប្រទេសឥណ្ឌា, លុះព្រះអង្គបរិនិព្វានខៅជាង ២០០ ឆ្នាំ ទើបផ្សាយមកថ្លើងរុះរឿងដល់នានាប្រទេស តែមិនការសពេញពិភពលោកទាំងមូលដូចសព្វថ្ងៃនេះទេ ដោយពេលនោះផ្លូវគមនាគមន៍ពុំទាន់មានបរិបូណ៌ មនុស្សលោកធ្វើដំណើរខៅមកកន្លែងមិនងាយ

ចាន, ដល់មកពុទ្ធសករាជគ្រប់ ២.៥០០ ឆ្នាំគេមនាគមន៍ដុំវិញលោក
ទាំងដើងទឹកដើងគោកដើងអាកាសបរិបូណ៌ខ្លើង មនុស្សលោកធ្វើដំ-
ណើរទៅមករកគ្នាចានហ៊ាសស្រួលផង តិកពលោកកំពុងតែភ្ជាដោយភ្លើង
សង្គ្រាមសម័យថ្មី មនុស្សលោកស្រេកឃ្លានសទ្ធិកាតកំពុងតែទឹកភ្លៀក
មធ្យាបាយដើម្បីរំលត់ភ្លើងសង្គ្រាមនោះឆង, ដំណឹងព្រះពុទ្ធសាសនា
ក៏អណ្តែតត្រសែតខ្លើង បង្ហាញមនុស្សក្នុងពិភពលោកឲ្យដឹងច្បាស់ថែស្តង
ស្គាល់ច្បាស់ថា ជាសាសនាទឹកអម្រឹតទីពឹរិសេស មានមធ្យោ-
បាយសន្តិភាព សម្រាប់ជួយរំលត់ភ្លើងទុក្ខសកលលោកឲ្យរលត់ឲ្យបាន
សេចក្តីសុខពិត ដោយសុភនិមិត្តដែលប្រទេសពុទ្ធសាសនិកទាំងពួងមាន
ប្រទេសតណ្ហៀ លង្កា ភូមា ថៃ លាវ ជប៉ុន យួន ចិន ជាដើមបាន
នាំគ្នាធ្វើបុណ្យជាទន្ទឹកំលើកពុទ្ធសករាជគ្រប់ ២.៥០០ ហៅថា
"បុណ្យពុទ្ធជយន្តី" ជាបុណ្យធ្ងន់អាយុព្រះពុទ្ធសាសនា, វេលាធ្វើ
គេបានអញ្ជើញប្រតិភូអំពីប្រទេសពុទ្ធសាសនិកនៅទ្វីបអាស៊ី រហូតដល់
ប្រទេសខ្លះនៅទ្វីបឧរ៉ុប ទឹងទ្វីបអាមេរិកទៅរួមប្រជុំផង ហើយគេឃ្លាយ
ដំណឹងតាមសារពត៌មាន គ្រប់ជាតិគ្រប់ភាសាពេញលោកទាំងមូល ឲ្យ
ប្រជាពលលោកបានដឹងឮស្គាល់គ្រប់គ្នាគ្រប់ៗគ្នា ។

ប្រទេសកម្ពុជាក៏បានចាត់ការធ្វើបុណ្យនេះ ដូចប្រទេសទាំងពួង
សន្មត់នាមថា "បុណ្យ ព.ស.២.៥០០" ។

បុណ្យ ព.ស.២.៥០០ នៃប្រទេសកម្ពុជា ពិធីចាប់

គឺពីថ្ងៃអាទិត្យ ១៤ កើត ដល់ថ្ងៃសៅរ៍ ៥ រោច ខែពិសាខ ឆ្នាំរកាធឫស័ក ព.ស. ២,៥០០ (១២ ដល់ ១៨ ឧសភា គ.ស.១ ៩៥៦) ។

បុណ្យនេះ ជាបុណ្យថ្វាយការបស់កម្ពុជរដ្ឋ, ព្រះពុទ្ធរដ្ឋាភិបាលត្រួមទាំងប្រជាជាតិកម្ពុជាក្នុងព្រះពុទ្ធអាណាចក្រទាំងមូល បានចាត់ចែងធ្វើក្នុងព្រះបរមនាម នឹងព្រះបរមពុទ្ធបដិមាក្នុងព្រះកុណាជាអម្ចាស់ដ៏តេជៈលើស្ងួន, សម្តេចព្រះមហាក្សត្រិយានី, សម្តេចព្រះទេពយុវតី នឹងសេចក្តីថ្លែងនៃសម្តេចព្រះសង្ឃនាយកទាំង ២ គណៈ ។

បុណ្យ ព.ស. ២,៥០០ មានបុណ្យធ្វើព្រះសក្យមុនីចេតិយប្រតិស្ឋានព្រះបរមសារីកធាតុរួមជាមួយផង ។ បុណ្យនេះប្រព្រឹត្តិទៅនៅលានព្រះសក្យមុនីចេតិយ ត្រង់មុខស្ថានីយពុទ្ធអឃស្ទ័យយោង ព្រះពុទ្ធទាយីក្នុងភ្នំពេញ ព្រមទាំងមានធ្វើទូទៅគ្រប់វត្តអារាមនៅក្នុងព្រះពុទ្ធអាណាចក្រទាំងមូល ។

ព្រះចេតិយនេះ បានជាមានន័យថា "ព្រះសក្យមុនីចេតិយ" ព្រោះតុដ្ឋបរិស័ទសាធុកជាទីរលឹកដល់ថ្ងៃដែលព្រះបរមសារីកធាតុនៃព្រះសក្យមុនីសម្ពុទ្ធ នឹងព្រះធាតុនៃព្រះសារីបុត្រ ព្រះមោគ្គល្លាន ជាអគ្គសាវ័កនិមន្តពីប្រទេសឥណ្ឌាមកប្រថាប់នៅក្រុងភ្នំពេញ ៧ ថ្ងៃ ៧ យប់ គឺមកពីថ្ងៃអាទិត្យទី ៥ ដល់ថ្ងៃសៅរ៍ទី ១១ តុលា ព.ស. ២៤៩៥ គ.ស. ១៩៥២ និមន្តទៅវិញ, ដែលវេលានោះភ្នំពុទ្ធបរិស័ទទាំងព្រះពុទ្ធប្រជាពុទ្ធស្ត្រ

នៅប្រទេសកម្ពុជា ជ្រះថ្លាមហិមានាំគ្នាប្រើនម៉ឺនសែនរូបមកនមស្ការបូជា ឆ្លាវ:ដោយមហោឡារសក្តាវ:មានមាសប្រាក់ជាដើម, ចំណែកប្រាក់បាន ១.៦៦៧.៣០៩រ,៦១ គណ:កម្មការបានចែកជាចំណែកផ្សេង ៗ ជាអាទិ គឺ១ ចំណែកចំនួន២០០.០០០រ០០ យកមកសាងព្រះចេតិយនេះ ដោយបេតុងអារមេ៉ ទំហំ ៣ ម៉ែត្រ កំពស់ ១៥ ម៉ែត្រ, រួមទាំងប្រាក់រៃពីពុទ្ធបរិស័ទថែមទៀតផង អស់ចំនួន ៧៦០.៦៦៧រ០០ ៗ

រៀលាធ្វើបុណ្យធ្វងព្រះចេតិយនេះ ជាមួយនឹងបុណ្យ ព.ស. ២៥០០ មានប្រតិស្ឋានព្រះបរមសារីរិកធាតុខ្នាតកណ្ណាល ១ ព្រះអង្គ ដែលប្រទេសសិរីលង្កាថ្វាយមកសម្តេចព្រះ នរោត្តម-សីហនុ ឧបយុវរាជ ក្នុងពេលដែលស្តេចទ្រង់យាងទៅជាព្រះរាជប្រតិភូតំណាងព្រះរាជា នៅរៀលាបុណ្យ ព.ស. ២.៥០០ នៃប្រទេសនោះ ៗ ការប្រតិស្ឋាននោះ គឺជំកល់ព្រះបរមសារីរិកធាតុក្នុងកាញ្ចនកោដ្ឋ (កោដ្ឋមាស) ជំកល់កោដ្ឋមាសនោះក្នុងព្រះសក្យមុនីស្ពូបរ័ត្ន (ស្ពូបសម្រឹទ្ធ) ជំកល់ព្រះស្ពូបសម្រឹទ្ធក្នុងព្រះសក្យមុនីចេតិយ ៗ

របៀបចាត់ចែងកិច្ចការនៃមហាពិធីបុណ្យ ព.ស. ២.៥០០ នឹងបុណ្យធ្វងព្រះសក្យមុនីចេតិយនេះ មានគណ:កម្មការប្រើនផ្នែកប្រើនក្រុមទាំងព្រះសង្ឃទាំងគ្រហស្ថ, គណ:កម្មការទាំងនេះសុទ្ធតែយកព្រះទ័យយកចិត្តទុកដាក់ខ្នះខ្នែងរៀបចំតាមមុខការរៀងអង្គរៀងខ្លួនហ៉ាងម៉ឺងម៉ាត់ ដោយនៀយហត់យ៉ាងខ្ចាំង ៗ តាមដែលសង្កេតមើលគ្រប់ជំណើរការនៃមហាពិធីបុណ្យនេះ គេឃើញថាសម្តេចព្រះមហាសុមេធាធិបតី ជួន.ណាត

សង្ឆនាយកគណៈមហានិកាយទំនុះវឿនដាបំផុត ទៀយហត់ព្រះកាយ ពលក្រៃពេក តាំងពីមុនពេលបុណ្យជាយូរថ្ងៃទមកហើយ ទាំងក្នុងឧកាសបុណ្យ៧ថ្ងៃ៧ យប់ទៀត ក៏សម្តេចរ៉ាតវតទៀយព្រះអង្គណាស់ ។ ការទំនុះវឿននៃគណៈកម្មការទាំងនេះ នាំឲ្យពិធីបុណ្យបានរុងរឿងអស្ចារ្យ ឲ្យពុទ្ធបរ៉ិស៉ទទាំងប្រទេសមានសេចក្តីជ្រះថ្លា នឹងសេចក្តីស្វើច-សរស៉ើរ យ៉ាងក្រៃលែង ។

ក្រុមពុទ្ធសាសនបណ្ឌិត្យមានអំណរមហិមា ដោយបានទទួលកិត្តិយសជាគណៈកម្មការប្រតិបត្តិការរង ទាងពិធីទាក់ទងដោយព្រះសង្ឆក្នុងឧកាសបុណ្យ ព.ស.២.៥០០ នឹងបុណ្យធ្វងព្រះសក្យមុនីចេតិយ ប្រតិស្ថានព្រះបរមសារ៉ីរិកធាតុនេះ ហើយបានទំបំពេញមុខងារនាទីរបស់ខ្លួនដោយយកចិត្តទុកយ៉ាងពេញទំហឹង ។

ដើម្បីជាតស្ពុតាងនៃអំណរ នឹងដើម្បីជាទីរលឹកដល់មហាកិលក្ខិត-កាលដ៏អស្ចារ្យទាំង ២ ផ្នែក ក្រុមពុទ្ធសាសនបណ្ឌិត្យបានរៀបរៀងអត្ថបទស្តីពីមហាពិធីបុណ្យនេះ ដោយរៀបរាប់សព្វគ្រប់ចុះក្នុងទស្សនាវដ្តីកម្ពុជ-សុរិយាលេខពិសេសនេះឡើង ទុកជាអនុស្សាវរីយតទៅ ។

ពុទ្ធសាសនបណ្ឌិត្យ

ពិធីបុណ្យ ២៥០០ វស្សា

នៃព្រះពុទ្ធសាសនា នៅប្រទេសកម្ពុជា

ពិធីបុណ្យ ព.ស.២៥០០ បានធ្វើនៅខាងកើតស្ពានីយ៍ពជអយស្វ៍យ យាន ក្នុងក្រុងភ្នំពេញ មានរបៀបដូចរៀបរាប់តទៅនេះ:

១_ទីកន្លែង_អគារផ្សេង ៗ :

នៅខាងត្បូងព្រះសក្យមុនីចេតិយ មានអគារនៃក្រសួងសិក្សាធិការ ជាតិ នឹងវ្វែរកម្ពុជាក្រោម, ខាងលិច: អគារនៃពួកពុទ្ធសាសនិក មហាយាន, ខាងជើង: អគារនៃសមាគមតិលានសង្ត្រោះព្រះសង្ឆវ្វែរ, ពុទ្ធិកសមាគម. សមាគមមិត្តពុទ្ធិកវិទ្យាល៍យ ។

ខាងកើតព្រះសក្យមុនីចេតិយ មានបុស្ស្យកតំកល់ព្រះបរមសារីរិក-ធាតុ ដែលសម្តេចព្រះទបយុរាជទ្រង់បានយកមកពីក្រុងកណ្ឌី (ប្រទេស សិរីលង្ក), ខាងត្បូងបុស្ស្យក មានព្រះពន្ធាកិត្តិយសសម្រាប់ព្រះករុណា ជាអម្ចាស់ជីវិតលើត្បូង សម្តេចព្រះមហាក្សត្រិយានី សម្តេចព្រះទបយុវ-រាជ សម្តេចក្រុមព្រះស៊ីសុវត្ថ-មុនីរៃត សម្តេចព្រះរាជកនិដ្ឋារស្មីសោភ៍ណ សម្តេចចៅហ្វាកំងវរៈវៀងជ៍យ សមាជិកទត្តមប្រឹក្សាព្រះរាជា សមាជិក រាជរដ្ឋាភិបាល មន្ត្រីធំ-តូច, ខាងជើងបុស្ស្យក មានពន្ធាព្រះសង្ឆមួយ សម្រាប់សម្តេចព្រះសង្ឆនាយកទាំងពីរគណៈ,រាជាគណៈ:ហានាទុក្រម, មេ គណ,អនុគណ,ចៅអធិការ, ភិក្ខុ-សាមណេរ,ខាងកើតបុស្ស្យក មានអគារ ធំមួយ (ហៅមហាកេង) សម្រាប់ធ្វើកិច្ចក្នុងពិធីបុណ្យមានស៊ុំស៊ីល, ចំរើន ព្រះបរិត្តជាដើម ។ មហាកេងនេះ អាចក្ទាយទៅជាអគារមហោស្រព

មានស្នាព្រះពុទ្ធរូបតូចធំរាប់រយអង្គ ប្រមាណជាមួយស្នាដៃ, ប្រឡងប្រ-
ជែងនាំគ្នាកែញាស ប្រកួតប្រជែងធម៌បទផ្សេងៗជាដើម; ក្នុងពេលកំពុងមាន
វេទិកាមួយធំមានកន្លែងរុញច្រានបាន គេរុញចូលតាមទ្វារ មកស្ថិតនៅត្រង់ស្លែង
ខាងកើតនៃមហាពេធ ។ នៅជុំវិញបុស្សក មានតូបឆាហានត្រង់ជ្រុងទាំង
៤ សម្រាប់ឆាហានយាមថែរក្សាព្រះបរមសារីរិកធាតុ ។ នៅចំពីខាង
កើតបុស្សកមានវេទិកាពិសេស ១ មានកន្លែងរុញទៅមកបាន មានគ្រឿង
ឧត្តុង្គសន្ទះសម្រាប់ព្រះករុណាជាអម្ចាស់ដំរីតេលីស្ងួន, សម្តេចព្រះ
ឧបយុវរាជ, សម្តេចព្រះសង្ឃនាយកគាំពីរគណៈ, គណៈប្រតិភូនានា
ប្រទេស, សមាជិកពលរដ្ឋកិត្តិយស និងនាយកសមាគមព្រះពុទ្ធសាសនា
ក្នុងប្រទេសក្រៅប្រទេស ឡើងថ្លែងសេចក្តី ថ្លែងការណ៍ សារលិខិត
គ្រប់យ៉ាង ។ ខាងស្តាំមហាពេធ មានអគារគាំងតុំនៃសម្តេចព្រះមហាសុ-
មេធាធិបតីសង្ឃនាយកគណៈមហានិកាយ, ខាងដើមមហាពេធ មាន
អគារគាំងតុំនៃសម្តេចព្រះសុធម្មាធិបតីសង្ឃនាយកគណៈធម្មយុត្ត មាន
ព្រះពុទ្ធរូបលង់ហិនធំកំពស់ ២ ម៉ែត្រគាំងនៅទីនោះផង ។

ខាងកើតមហាពេធ មានដីធំនេរមួយធំ, ខាងស្តាំដីធំនេរនោះ
មានអគារគាំងតុំមេគណខែត្រចាត់តំបន់, តាកែវ, កំពត, ស្វាយរៀង,
សៀមរាប; ខាងដើង មានអគារគាំងតុំមេគណខែត្រក្រចេះ, ពោធិ៍សាត់
កំពង់ឆ្នាំង, កំពង់ស្ពឺ, កំពង់ធំ, ព្រៃវែង, កណ្តាល ។

ខាងកើតអគារមេគណខែត្រខាងលើនេះ មានដីធំនេរធំមួយទៀត,
ខាងដើងទីធ្លាខាងស្តាំដីធំនេរធំនេះ មានពេធជាក់ម៉ាស៊ុនទឹក ២ ខាងស្តាំ

១ ទាងដើង១ សម្រាប់មហាជនទួលៅប្រើប្រាស់; តពីរោងម៉ាស៊ីនទឹកនេះ ៅរហូតៅដល់តិរវិថីព្រះបាទស៊ីសុវត្ថ៍ មានរោងជាប្រើនសន្ធាត់ទៀត ធ្វើរាងជាបន្ទាជាក់ក្តារជាដើងម៉ាបំកណ្ណាល សម្រាប់ឲ្យពុទ្ធសាសនិកជន ជាក់បាត្រព្រះសង្ឆបំនួន ៤.៥០០ អង្ត ។

អគារទាំងឡាយជូបរាយឈ្មោះដោយសង្ខេបទាងលើនេះ សុទ្ធតែ ធ្វើដោយគ្រឿងឈើប្រក់ហ្ទីប្រូស៊ីម៉ង់លាបថ្នាំព័ណ៌ខៀវលឿង ពាស ពិតានទេសឯកស ហើយសុទ្ធតែស្ថាបនាឡើងដោយសិល្ឆៈខ្មែរសុទ្ធ មាននាគជហ្ទាជងក្តារ ហោជាង គាងឃ្ទាយ ប្រកបដោយក្សាច់រចនា សារពើសូត្រ បិទមាសលាបថ្នាំព័ណ៌ខៀវសលឿងក្រហមប្រាលរន្ទាល ឆ្និនផ្នៅ ប្រូងប្រាងស្អាងស្អាតព្រាតព្រាង ហើយលំអដោយគ្រឿង សក្តារៈទាំងឡាយមានទង់ជាតិ ទង់សាសនា ទង់រលក នឹងប្រទីប ជ្ទាលាជាដើម ត្ទូរឲ្យជ្រះថ្ទាក្រៃពេក ។

២ - ពិធីបុណ្ឈ ព.ស. ២៥០០ នៅប្រទេសកម្ពុជា:

ចាប់ផ្តើមធ្វើពីថ្ងៃអាទិត្យទី ១២ ឧសភា ១៩៥៧ រហូតៅដល់ថ្ងៃ សៅរ៍ទី ១៨ ឧសភា ១៩៥៧ មានកម្មវិធីជូបតៅនេះ :

ថ្ងៃទី ១

គឺថ្ងៃអាទិត្យ ១៤ កើត ខែពិសាខ ឆ្នាំរកានពូស័ក ព.ស. ២៥០០ គឺថ្ងៃទី ១២ ឧសភា ១៩៥៧

ជាថ្ងៃជង្ហែព្រះបរមសារីរិកធាតុ

ម៉ោង ៦ គត់ មានពួកសូរសៅពួកវែញយ៉ាងវែង។, ពេលនោះហើយជា
ពេលបើកពិធីបុណ្យ ព.ស.២៥០០ ក្នុងព្រះពុទ្ធអាណាចក្រកំពង់មួល ។

ពួកពុទ្ធសាសនិកជនគ្រប់ជាតិ គ្រប់គ្រហស្ថ ក៏ប្រុងប្រៀបខ្លួន
គ្រប់គ្នាចូលទៅរួបរួមក្នុងពិធីបុណ្យនេះ ។

ក្រោយពីសូរសៅវែងនោះមក, មានស្ត្រីបុរស គ្រហស្ថ, បព្វជិត,
ពហាន, សុំវិល, ឈរតាមវិថីក្នុងក្រុងរង់ចាំស្វាគមន៍ព្រះបរមសារីរិក-
ធាតុ ពួកសូរសព្វតិកកងរំពងពេញព្រះពុទ្ធានី ។

ពួកព្រះពុទ្ធវង្សាទ្យាវ, ពួកសមាជិកក្រុមប្រឹក្សាឯកជនអមព្រះអង្គ,
ពួកសមាជិកពុទ្ធរដ្ឋាភិបាល, ពួកនាម៉ឺនសព្វមុខមន្ត្រី ទ្រង់ស្តេចយាង
អញ្ជើញទៅកាន់ព្រះវិហារទេវាវិទិប្ចិយក្នុងព្រះបរមពុទ្ធកំពង់,ចំណែកសម្តេច
ព្រះសង្ឃនាយកនាំពីរគណៈ ទីព្រះសង្ឃពាំគណៈហានុត្រួម២៥អង្គ
គង់លើអាសនៈមួយនៅលើឆទានស្ទួង នៃព្រះវិហារទេវាវិទិប្ចិយ ។

ម៉ោង ៦-៣០ សម្តេចព្រះទេបយុវពុទ្ធ ទ្រង់ស្តេចយាងមកដល់
ទ្រង់ប្រទានថ្វាយព្រះពុទ្ធសង្ឃថាដូចតាងក្រោមនេះ :

សម្តេចព្រះសង្ឃនាយក,

ព្រះថេរានុត្ថេរៈ,

ទ្រង់,

ឯកទុត្តម,

អស់លោក,

ខ្ញុំព្រះករុណា ខ្ញុំ មានហ្វូងយ៉ាងកៀបយ៉ាងខ្លាំងរកគណនាពុំបានអំពី

តិត្តិយសដ៏ថ្លៃថ្លាដែលខ្ញុំព្រះករុណា ខ្ញុំ បានខិតខំលះបង់ក្នុងថ្ងៃមហាឧត្តមឫក្សនេះ ដោយបំពេញកិច្ច ១ គួរចារឹកជាអក្ខរៈមាសទុកក្នុងប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា ។ គឺការរៀបចំនាំនឹងឡាកែចំពោះប្រជាជាតិខ្ញុំព្រះសារីរិកធាតុនៃព្រះសក្យមុនីគោតមបរមគ្រូ ដែលបានត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ ជាសាស្តាចារ្យនៃទេវតានឹងមនុស្សទាំងឡាយ ហើយដែលជាទីគោរពនឹងបូជារបស់ប្រទេសយើងជាអនេ្តងតាលមកហើយ ។

ចំនួនជាងបីខែមកហើយ ខ្ញុំព្រះករុណា ខ្ញុំ បានប្រទះនឹងព័ត៌មានមួយយ៉ាងត្រកាលឯក ដោយបានទទួលនូវព្រះសារីរិកធាតុនេះផ្ទាល់អំពីលោកអ្នកថែរក្សាព្រះបរមសារីរិកធាតុនៃព្រះពុទ្ធជាអម្ចាស់ នៅក្រុងកណ្ឌីប្រទេសសិរីលង្កា ដែលបានផ្សាយនូវព្រះសទ្ធម្ម តាំងក្បួនប្រៀនប្រដៅរបស់ព្រះ សព្វញ្ញូសម្មាសម្ពុទ្ធ ឲ្យបានសាយសព្វនូវទីក្នុងសកលលោកនេះ ។

ខ្ញុំព្រះករុណា ខ្ញុំ គិតឃើញថា ដោយខ្ញុំព្រះករុណា ខ្ញុំ ជាបុត្រនៃកម្ពុជវង្សត្រកូលតែខ្ញុំព្រះករុណា ខ្ញុំ ពែកវិលកន្លងព័ត៌មានដ៏ឧត្តមនេះជូនជនរួមជាតិទាំងអស់ ដែលជាទីស្រឡាញ់រស់ពីដួងហឫទ័យរបស់ខ្ញុំព្រះករុណា ខ្ញុំ ព័ត៌មានបែបនេះមានមនុស្សលោកតិចណាស់ដែលបានតើបប្រទះ ។ ហេតុនេះខ្ញុំព្រះករុណា ខ្ញុំ សូមបង្អោនកាយវាចាចិត្ត លើកព្រះសារីរិកធាតុនៃព្រះ គោតមបរមសម្មាសម្ពុទ្ធ ដែលយើងតែងតែស្មោះ ខ្ជិន

ឧោរពបូជាទាំងអស់គ្នា ជូនចំពោះប្រជាជាតិទាំងមូល ។ យើងត្រូវជំកល់ព្រះបរមសារីរិកធាតុនេះជូចជាព្រះ ភគវន្ត មុនីសាស្តា មកប្រតិស្ឋានតង់នៅប្រទេសកម្ពុជាជាទីឧោរពរបស់បុព្វបុរសយើង ដែលលោកតែងមានសេចក្តីជ្រះថ្លាកាន់ព្រះពុទ្ធសាសនាយ៉ាងខ្ជាប់ខ្ជួន ។ យើងដែលស្គាល់ច្បាស់នូវ កម្មវិបាក គឺផលរបស់កម្មទាំងឡាយត្រូវសំគាល់ថា សេចក្តីឧោរពនឹងសេចក្តីជ្រះថ្លាចំពោះព្រះពុទ្ធសាសនារបស់បុព្វបុរសរបស់យើង នាំផលយ៉ាងល្អសំខាន់មកកាន់រដ្ឋកម្ពុជាដោយបានព្រះបរម-សារីរិកធាតុរបស់ព្រះ លោកនាថ មកប្រតិស្ឋានក្នុងមាតុប្រទេសតាំងតែពីវេលានេះទៅ ។

ពិតមែនតែព្រះបរមសារីរិកធាតុនឹងព្រះពុទ្ធប្បដិមា មិនអាចបំបាត់នូវអវិជ្ជាឲ្យជ្រះស្រឡះចេញអំពីខន្ធសន្តានយើងបាន តែបូជនីយវត្ថុដ៏ប្រសើរទាំងនេះ នាំឲ្យយើងឈ្វេងយល់ដល់អនិច្ចតាធម៌ គឺសេចក្តីមិនទៀង ហើយនឹងដល់ផលល្អនានា ដែលពញ្ជកបណ្ឌិតបានទទួលហើយ ។ ក្នុងតម្ពីរមហាបរិនិព្វានសូត្រ ព្រះដ៏មានបុណ្យបានសំដែងថា ការយកអដ្ឋិធាតុមកពិចារណា នាំឲ្យយើងរំលឹកដល់ជីវប្រវត្តិនឹងតុណធម៌របស់មហាបុរសទាំងឡាយ នាំឲ្យយើងប្រាថ្នាចង់យកតម្រាប់តាមព្រមទាំងឲ្យចិត្តបានស្ងប់ស្ងាត់នឹងរីករាយផង ។

ព្រះសារីរិកធាតុដ៏ថ្លៃថ្លានេះ នឹងជួយទ្រទ្រង់ទបត្ថម្ភមាតុប្រទេសយើង ប៉ីជូចជា ព្រះសម្ពុទ្ធវិសុទ្ធិគុណអនន្តញ្ញាណ ទ្រង់ព្រះធរមាន

នៅឡើយ ដោយយើងនឹករលឹកចំពោះព្រះអង្គ ព្រមទាំងប្រព្រឹត្តតាម ព្រះបរិយត្តិធម៌ នឹង ព្រះនព្វលោកុត្តរធម៌ ដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សំដែងហើយ ។

សូមអានុភាពនៃព្រះបរមសារីរិកធាតុរបស់ព្រះសក្យមុនីគោត្តមបរម-ត្រូជាម្ចាស់នៃត្រៃលោក ជួយជនរួមជាតិយើងទាំងអស់ឲ្យឈប់ទាស់ទែងទ្វេងតំនិតគ្នា ឲ្យចេះធ្វើការរួបរួមគ្នាដោយជិតស្និទ្ធ ឲ្យលះបង់នូវសេចក្តីលោភ: ជ៏ហៅទាប ដែលនាំឲ្យឃ្ងាតចេញឆ្ងាយអំពីមាគ៌ារបស់ជាតិ អំពីកាតរភាពនឹងអំពីការស្រុះស្រួលគ្នា ។ មានតែមាគ៌ាទាងលើនេះទេ ដែលអាចនាំឲ្យយើងប្រទះនឹងសម័យសុភមង្គលឡើងវិញបាន ។ ប្រជាជាតិណាបានយកព្រះសទ្ធម្ម ជាទីពឹងទីរលឹក ប្រជាជាតិនោះរមែងតែបានទទួលជានិច្ចនូវសុភមង្គល គឺសេចក្តីសុខ សេចក្តីចំរើនយ៉ាងសំខាន់តាំងតែពី អតីតកាល មក ។

បងប្អូនរួមជាតិទាំងឡាយ! ដោយខ្ញុំមានចិត្តគិតតែអំពីសេចក្តីថ្កុំថ្កើងរបស់មាតុប្រទេស នឹងតែអំពីសេចក្តីចំរើនរបស់ប្រជាពលរដ្ឋទ្វេរ ខ្ញុំសូមឲ្យយើងកល់គ្នា យោគយល់គ្នាទៅវិញទៅមក ដោយស្មោះចំពោះដើម្បីធ្វើសាមគ្គីធម៌ ដែលយើងធ្លាប់កសាងបានក្នុងអតីតកាលថ្មីៗនោះ ឲ្យកើតឡើងវិញ ។

សាមគ្គីធម៌ទាងលើនេះហើយ ដែលនាំឲ្យប្រទេសយើងបានឯក-រាជ្យបរិបូណ៌ដោយ សន្តិវិធី ដោយ អហឹង្សា ។

វេលានេះជាឧត្តមសម្ផស្សដ៏ល្អណាស់ ដែលយើងគួរធ្វើអំពើថ្លៃថ្លា
មានកិត្តិស័ព្ទដែលត្រូវបានកើតក្នុងនាមជាប្រវត្តិរបស់យើងនឹងរបស់ប្រជាជាតិ ។
យើងគាចនឹងបានកុសលច្រើន បើសិនណាជាក្នុងថ្ងៃនេះយើងនាំគ្នា
សន្យាថា ដែងចាណ្តាយឲ្យសេចក្តីលោភមកបំបែកបំផ្លាស់សាមគ្គីធម៌
របស់យើងតទៅទៀតហើយ ។ សេចក្តីលោភកើតមកអំពីសេចក្តីមោហៈ
គឺវង្វេង ។ ហាមយោគ គឺសេចក្តីប្រកបក្នុងកិលេសតាមនឹងវត្ថុកាម
បើមានកើតនៅក្នុងរូបបុគ្គលណាហើយ បុគ្គលនោះនឹងក្លេចដល់សេចក្តី
ត្រូវការរបស់ដនដទៃហើយពុំបានចំរើនឃ្លាតទៀតផង ។

ព្រះពុទ្ធសំដែងថា ផលនៃកុសលនឹងអកុសលតែងមានដាប់ជានិច្ច
គ្មានដនណាឬទេវតាណាកែប្រែបានឡើយ ។ បុគ្គលប្រព្រឹត្តអំពើអកុសល
នឹងបានទទួលផលអាក្រក់ ហើយបើនៅតែប្រព្រឹត្តបែបនេះឲ្យច្រើនតទៅទៀត បុគ្គលនោះនឹងបានទទួលទុក្ខនឹងទោសជាដរាប ។

សូមបងប្អូនលើកវិញ្ញាណនឹងចិត្តឲ្យខ្ពស់អណ្តែតឡើង!
ព្រះបរមសារីរិកធាតុដែលមក ប្រតិស្ឋាន នៅទីនេះ ហាក់ដូចជាទិម្ពុ
មកសុំឲ្យយើងតាំងអស់គ្នាកាន់មេត្តាធម៌ឲ្យខ្ជាប់ខ្ជួន ពីព្រោះធម៌នេះជាធម៌
របស់ព្រះដ៏មានព្រះភាគ ព្រះអង្គបានឃើញទុក្ខវង្វេងនៅកាន់សេចក្តីចំរើន
នឹងសេចក្តីសុខ ហើយព្រះអង្គបានបង្ហាញមាគ៌ានេះ ឲ្យយើងដើរតាម
តាំងអស់គ្នា ។

សុខិ រុំប្បឺ បប្បោន្តុ សន្តិតារេញ្ច នាញ្ញហ

សូមសេចក្តីសុខ សេចក្តីចំរើន មានដល់សត្វលោកទាំងអស់ កុំបីឃ្ងាតក្ងាយឡើជាបការៈដទៃឡើយ !

សាសនំ សត្ថុ អម្ហាកំ ចីរំ ទិប្បតុ តាទិនោ

សូមឲ្យសាសនានៃព្រះបរមសាស្តារបស់យើងទាំងឡាយ ដែលជាសាសនាប្រកបដោយ **តាទិគុណ** មានសេចក្តីរុងរឿងអស់កាលជាយូរអង្វែងតទៅហោង !



\+

\+ \+

លំដាប់អំពីព្រះរាជសង្ឆថា នៃសម្តេចព្រះឧបយុវរាជមក, សម្តេចព្រះមហាសុមេធាធិបតីសង្ឆនាយក ជួន-ណាត(ដោតញ្ញាណោ) គណៈមហានិកាយបានថ្វែងនូវសង្ឆថាមួយ ដោយព្រះឧស្ឆទទេអំពីរឿងព្រះបរមសារីរិកធាតុរំព្ងកដល់គុណូបការៈព្រះបរមសម្ចាសម្ពុទ្ធជាម្ចាស់ ដែលទ្រង់តែងតែបំពេញនូវពុទ្ធកិច្ចទាំងឡាយ ព្រមទាំងស្រោចស្រង់សត្វលោកឲ្យជុតចាកសេចក្តីទុក្ខទាំងពួង ។

រួចបានសម្តេចព្រះឧបយុវរាជទ្រង់និមន្តព្រះបរមសារីរិកធាតុចុះមកប្រគេនសម្តេចព្រះមហាសុមេធាធិបតី ។ បីទ្រនិមន្តបេញតាមទ្វារកណ្ណាលដោយមានសម្តេចព្រះសុធម្ចាធិបតីសង្ឆនាយកគណៈធម្ចយុត្ត និងសម្តេចព្រះឧបយុវរាជ និមន្ត, យាងហែតាមក្រោយ ព្រមទាំងនាមុីនសព្ងមុខមន្ត្រីនឹងពុទ្ធបរិស័ទហែតាមដង ។ សម្តេចព្រះមហាសុមេធាធិបតីនិមន្តព្រះបរមសារីរិកធាតុទៅតំកល់នៅលើរថយន្តបុស្ឈុក ដែលរង់ចាំដង្ហែនៅមុខព្រះបរមរាជវាំង ។

មោង ៧.៦០ ក្សួនដវង្ហ្ព្រះបរមសារីរិកធាតុ ក៏តាំងចាប់ផ្តើមហ
ចេញពីមុខព្រះបរមរាជវាំងឆ្ពោះទៅកាន់ទីកន្ទែងបុណ្យ ។

មោង ១០-០០ ព្រះករុណាជាអម្ចាស់ជីវិតលើត្សួង, សម្តេចព្រះ
មហាក្សត្រិយានី, សម្តេចព្រះទបយុវរាជ ទ្រង់ស្តេចយាងដល់មណ្ឌល
បុណ្យ ព្រមទាំងសម្តេច ប៉ែន នុត ព្រឹទ្ធាចារ្យ នៃក្រុមប្រឹក្សាឯកជនអម
ព្រះអង្គ, សមាជិកព្រះរាជវង្ផាភិបាល, នាមឹនសព្ទមុខមន្ត្រីធំតូចជាបរិវារ ។

កាលក្សួនដវង្ហ្ព្រះសារីរិកធាតុដល់ហើយ លោកឈួន ម្ជុលពេជ្ត
ទេសរដ្ឋមន្ត្រីក្រសួងធម្មការ ប្រធានគណៈកម្មាធិការនាយកនៃពិធីបុណ្យ
ព.ស. ៦៥០០ បានលើកព្រះបរមសារីរិកធាតុថ្វាយព្រះករុណាជា
អម្ចាស់ជីវិតលើត្សួង ។ ទ្រង់ទទួលព្រះបរមសារីរិកធាតុនេះទៅតំកល់
នៅបុស្សក រួចមាននាងកញ្ញានៃអនុវិទ្យាល័យនរោត្តម ៦ នាក់ ថ្វាយភួង
បុប្ផាចំពោះព្រះករុណាជាអម្ចាស់ជីវិតលើត្សួង ព្រមទាំងសម្តេចព្រះមហា
ក្សត្រីយានី ទ្រង់ទទួលយកភួងបុប្ផានោះស្តេចឡើងទៅកាន់បុស្សកថ្វាយ
ព្រះបរមសារីរិកធាតុ ។ ដល់ស្តេចយាងមកកាន់ព្រះពន្ធាកិត្តិយសវិញ
មានពិធីលើកទង់ជាតិ ទង់សាសនា មានពួកយុវនារីពាក់អាវស ស្ទ្រ
សំពត់សម្ទុយពណ៌ប៉ៃតង នឹងពួកនិស្សិតសាលាគរុវិជ្ជាដែលឈរខាងកើត
បុស្សកច្រៀងបទនគរាជថ្វាយព្រះពរជ័យព្រះករុណាទាំងពីរព្រះអង្គ ។
បន្ទាប់ពីចំរៀងបទនគនរាជមក មានពួកសិស្សប្រុសស្រីសូត្របទសរ-
ភញ្ញថ្វាយបង្គំព្រះបរមសារីរិកធាតុ ។

លំដាប់តមក, ព្រះករុណាជាអម្ចាស់ជីវិតលើត្សួង ទ្រង់ស្តេចយាង

ទៅថ្ងៃនូវព្រះរាជសុន្ទរកថាបើកពិធីបុណ្យ ៤.៥០០ មានសេចក្តីជូចខាងក្រោមនេះ :

សូមពិតពុទ្ធដីកាព្រះថេរានុត្តេរ:

សូមទូលទ្រង់

ជំរាប ឯកទត្តម លោក-អ្នកតំណាងប្រទេសជាមិត្ត នឹងអស់លោក-អ្នកសប្បុរសទាំងឡាយ

ក្នុងឱកាសបើកសម័យបុណ្យនេះ ខ្ញុំមានសេចក្តីរីករាយយ៉ាងក្រៃលែងសុំថ្ងៃងអំណរជ៏ជ្រាលជ្រៅប្រគេនចំពោះព្រះថេរានុត្តេរ: ចំពោះទ្រង់គណ:ប្រតិភូបរទេសនៃប្រទេសជាមិត្ត នឹងពុទ្ធបរិស័ទទាំងឡាយដែលមានសោមនស្សចេតនាបានន៌មន្ត យាង អញ្ជើញមកចូលរួមក្នុងមហាពិធីបុណ្យតំរប់ ២៥០០ ព្រះវស្សា នៃព្រះពុទ្ធសាសនា ក្នុងព្រះរាជធានីភ្នំពេញនេះ ។

មុនដំបូង ខ្ញុំពណិនាអំពីហេតុ ដែលនាំឲ្យយើងជ្រះថ្លានាំគ្នាធ្វើមហាពិធីបុណ្យនេះ ។

ព្រះសម្មាសម្ពុទ្ធបរមគ្រូទ្រង់ជាអគ្គមហាបុរសដ៏ធ្នើមក្នុងលោក ព្រះអង្គមានព្រះហ្ជ្ជ៉ទ័យប្រកបដោយព្រះមហាករុណាទិគុណយ៉ាងធំអនេក ចំពោះសត្វលោកគឺព្រះអង្គស្តេចយាង-ទៅសូះសែ្ងងរកមោក្ខធម៌ ឥតគិតដល់ការនៀយព្ជ្ជយព្រះកាយពល ។ លុះបានត្រាស់ធឹងមោក្ខធម៌ហើយ ព្រះអង្គទ្រង់យកព្រះធម៌ដ៏សុខុមនោះមកទេសនាប្រដៅពន្យល់ ដឹកនាំសត្វលោកដែលត្រូវការគ្រប់គ្នា ។

ប្រជារាស្ត្រខ្មែរទាំងមូល សុទ្ធសឹងជាអ្នកកាន់ព្រះពុទ្ធសាសនា ។

ឋានជាប្រជាវស្ត្រីឲ្ទរពេញចិត្តយ៉ាងខ្ចាំង ចំពោះព្រះពុទ្ធសាសនា ព្រោះ
ជាសាសនាអព្យាក្រិត គឺថាជាសាសនាប្រដៅឲ្យមានការអត់ទនឲ្យធ្វើ
សេចក្តីល្អ មិនចំពោះតែជនរួមឈាមរបស់ខ្ជួនប៉ុណ្ណោះទេ ត្រូវធ្វើចំពោះ
សត្វទាំងអស់ ក្នុងសាកលលោក ព្រោះគេត្រូវការរស់ ត្រូវការសេរីភាព
ដូចយើងដែរ ។

ប្រទេសកម្ពុជាសព្វថ្ងៃដែលប្រកាន់នយោបាយអព្យាក្រិត គឺប្រព្រឹត្ត
អនុលោមតាមព្រះពុទ្ធសាសនា ដែលជាសាសនាឯកក្នុងលោក ជាសាសនា
ប្រដៅឲ្យមានសាមគ្គីភាព ភាតរភាពនឹងសមភាព រវាងមនុស្សនានាជា
ការចាំបាច់ ដើម្បីឲ្យកើតសន្តិភាពនឹងសន្តិសុខក្នុងលោកព្រមទាំងប្រដៅ
ឲ្យមានការសន្តោសចំពោះមនុស្សផងគ្នា ឲ្យមានការគោរពទ្រព្យសម្បត្តិ
នឹងសិទ្ធិអ្នកដទៃ ឲ្យវៀចាកការប្រព្រឹត្តិរំលោកជិះជាន់ជនដទៃ ។ ផ្សិតព្រ
សម្ចាសម្ពុទ្ធបរមត្រូ ទ្រង់ជ្រាបច្បាស់នូវហេតុនៃសេចក្តីទុក្ខ នឹងហេតុនៃ
សេចក្តីសុខ យើងធ្វើឲ្យគេបានទុក្ខលំបាក យើងមុខជានឹងត្រូវទទួលនូ
សេចក្តីទុក្ខលំបាកវិញ ក្នុងថ្ងៃណាជាមិនខាន យើងធ្វើឲ្យគេបានសុ
យើងនឹងត្រូវតែទទួលនូវសេចក្តីសុខវិញជាប្រាកដ ។ សមដូចពុទ្ធកាសិ
សំដែងថា:

យាទិសំ វប្បតេ ពីជំ តាទិសំ វប្បតេ ផលំ
កាល្យាណាការី កាល្យាណំ ចាបការី ច ចាបកាំ

ប្រែថា ជនណាសាបព្រោះនូវពូជដំណាំអ្វី ជននោះត្រូវទទួលនូ
ផលនៃដំណាំនោះ ជនអ្នកធ្វើនូវកុសលតែងបាននូវសេចក្តីសុខ ជនអ្ន

ធ្វើនូវអំពើបាបតែងបានទទួលនូវសេចក្តីទុក្ខ ។

ដូច្នេះ ថ្ងៃនេះជាអភិលក្ខិតកាល ប្រកបដោយសិរីសួស្តីជ័យមង្គលគំរប់ ២៥០០ព្រះវស្សានៃព្រះពុទ្ធសាសនា ចាប់តាំងពីថ្ងៃបរិនិព្វាននៃព្រះសម្ពុទ្ធ បរមគ្រូមក យើងខ្ញុំព្រះអង្គសូមធ្វើមហាពិធីបុណ្យដ៏ទឡ្លាវិកអស្ចារ្យ ពិសេសនេះ បូជាដោយគោរពចំពោះព្រះអង្គ និងចំពោះព្រះទរាទនៃព្រះ អង្គដែលជានិយ្យានិកធម៌ គឺធម៌សំរាប់ដឹកនាំសត្វលោកឡើរកសេចក្តី សុខចំរើន ។

ជយោព្រះពុទ្ធសាសនា !

×

× ×

ប៉ើតាមកម្មវិធីនៃពិធីបុណ្យនេះ ក្រោយដែលព្រះនរបតីទ្រង់ថ្ងៃន ព្រះរាជសុន្ទរកថាចប់, ត្រូវសម្តេចព្រះមហាសុមេធាធិបតីសង្ឆនាយក គណៈមហានិកាយថ្ងៃនសុន្ទរកថាជាលំដាប់តមក រួចបានត្រូវសម្តេចព្រះ សុធម្មាធិបតីសង្ឆនាយកគណៈធម្មយុត្តថ្ងៃនជាខាងក្រោយ តែដោយ ពេលព្រះសង្ឆនាន់ជិតដល់ហើយ ក៏អាក់ខានមិនបានថ្ងៃនឡើរិញ ។ ហេតុនេះយើងសូមយកសុន្ទរកថាទាំងពីរមកចុះទាំងស្រុងនោទីនេះផង ។

សុន្ទរកថា នៃសម្តេចព្រះមហាសុមេធាធីបតី

ជួន.ណាត (ជោតញ្ញាណោ)

សង្ឆនាយកគណៈមហានិកាយ

សូមព្រះរាជទានព្រះរាជវរោកាស,

អាត្មាភាព សូមថ្លែងសេចក្តីដោយសង្ខេប តាមប្រព្រឹត្តិការណ៍នៃព្រះពុទ្ធសាសនា ដែលបានដំណើរយូរមកក្នុងកប្បជាតុ ដូចតទៅនេះ :

ព្រះគោតម: អរហន្តសម្មាសម្ពុទ្ធ ទ្រង់មានព្រះជាតិជាក្សត្រិយ៍សាក្យៈ ក្នុងសកវង្ស ដែលកន្លងសម័យនេះ ហៅថា ប្រទេសនេប៉ាល, ទ្រង់ចាត្រាស់ជាព្រះបច្ចេកពុទ្ធ ស្ថិតនៅអស់រយៈកាល៤៥ឆ្នាំ ទ្រង់ចរនិព្វានទៅ ឯជម្ពូទ្វីប គឺប្រទេសឥណ្ឌាឯណោះសោះទេ, ចុះហេតុអ្វីបានជាបុព្វបុរសខាងឆ្វាយរបស់ជនជាតិខ្មែរ រហូតដល់មកបច្ចាជនអ្នកកម្ពុជវង្សតូចថ្ងៃនេះ ត្រមង់ទួលយកសាសនារបស់ព្រះសក្យមុនីសម្ពុទ្ធអង្គនោះមកប្រតិបត្តិតាន់តាម? ជនជាតិខ្មែរដែលមានព្រះមហាក្សត្រិយ៍ជាប្រមុខរដ្ឋរៀងមកតុំដែលជាប់ ដកចេញដល់បច្ចុប្បន្នសម័យបំបែរដំនឿមកកេព្រះពុទ្ធសាសនា មិនអាល័យសាសនាចាស់ដែលធ្លាប់តាន់តាំងតាំពីព្រេងនាយមកហើយនោះប៉ុន្មានឡើយ តើមកពីយល់ឃើញដូចម្តេច? មកពីការណ៍ភ័ន្តច្រឡំ ឬយ៉ាងណាទេដឹង?

បញ្ហានេះបើពណ៌នាតាមប្រវត្តិសាស្ត្រ មានសេចក្តីពិស្តារវែងឆ្ងាយណាស់, តាលបើសរុបសេចក្តីឲ្យខ្លីបុះមក នៅត្រឹមតែថា មនុស្សក្នុងពិភពលោកតាំងមូល សុទ្ធតែមានដំនឿជាប្រមុខរបស់ចិត្ត រមស់កិច្ចការផ្សេង ។, ដំនឿនោះមានពិតខ្លះ ពុំពិតខ្លះ, ព្រះសក្យមុនីគោតម: ទ្រង់ណែនាំមនុស្សឲ្យឃើញ ឲ្យឮ តាមការណ៍ពិត ដូចយ៉ាងទ្រង់ពន្យល់អំពីអរិយសច្ច៤ ជាដើមដែលជាសេចក្តីកំចាំងជិតស្ទុង ឥតមានអ្នកណាមួយនិយាយប្រាប់គ្នាកើត មានតែព្រះពុទ្ធត្រាស់ព្រះអង្គឯង

អាចរកអរិយសច្ចនោះឃើញច្បាស់ ឥតមានស្រវាក់ស្រវាន់ក៉ន្ធប្រឡំ
ឡើយ, ព្រះសម្មាសម្ពុទ្ធទ្រង់ជ្រាបច្បាស់នូវទុក្ខ: សមុទយ: និរោធ:
មគ្គ: គឺទ្រង់ជ្រាបថា សេចក្តីទុក្ខ កើតមកពីតណ្ហា, ទបាយសម្រាប់
រំលត់តណ្ហានោះមាន ពុំមែនគ្មានទេ, កាលបើតណ្ហារលត់ហើយ
សេចក្តីទុក្ខក៏រលត់ ។ លុះព្រះអង្គបានជ្រាបអរិយសច្ចនេះជាក់ច្បាស់ហើយ
ទ្រង់ ប្រាសប្រទានឲ្យវេនេយ្យសត្វបានដឹងដោយសារព្រះអង្គផង ។ មួយ
ទៀតទ្រង់ជ្រាបថា សត្វលោកទាំងអស់សុទ្ធតែមានកម្ម គឺអំពើដែលធ្វើជា
របស់ខ្ជូនរាល់រូប, អំពើល្អឲ្យផលល្អ អំពើអាក្រក់ឲ្យផលអាក្រក់, អំពើ
របស់បុគ្គលណា បុគ្គលនោះនឹងបានទទួលផលល្អអាក្រក់សុទទុក្ខតាមពួជ
ដើមរបស់កម្ម, ទាំងព្រះអង្គដែលបានត្រាស់ជាព្រះពុទ្ធ ក៏មានកម្មជារបស់
ព្រះអង្គដែរ ។ ព្រះអង្គទ្រង់បញ្ជាក់ថា អ្នកប្រាប់ផ្ជូវប្ដប្រាប់ទិសទីដល់អ្នក
ដែលពុំស្គាល់ផ្ជូវប្ដដល់អ្នកវង្វេងទិសទី, អ្នកប្រាប់នោះគ្រាន់តែដឹងច្បាស់
ហើយប្រាប់ប៉ុណ្ណោះ ពុំមែនដើរជំនួសអ្នកមិនស្គាល់ផ្ជូវប្ដអ្នកវង្វេងទិសទីទេ
យ៉ាងណាមិញ, ព្រះពុទ្ធក៏យ៉ាងនោះដែរ គឺព្រះអង្គគ្រាន់តែជ្រាបច្បាស់
ហើយប្រាប់ប៉ុណ្ណោះ ពុំមែនព្រះអង្គប្រតិបត្តិប្រព្រឹត្តកាន់ជំនួសបុគ្គលណា
មួយ ឬទទួលទោសកំហុសជំនួសបុគ្គលណាមួយទេ ដ្យតអំពើដែលអ្នក
ណាធ្វើ នឹងប្រតល់ផលផ្តល់សុទទុក្ខល្អអាក្រក់ដល់អ្នកនោះវិញ ។ និយាយ
ដោយសរុបទ្វីទៅថា ប្រាសាទពិមានទឹងសារពើវត្ថុល្អ ។ ផ្សង ។ កើត
អំពីកុសលកម្ម, ពន្ធនវត្ថុ គឺគ្រឿងចាប់ចងយុំទាំងគុកតារាងទ្នោះយ្នាង
កើតអំពីអកុសលកម្ម, និយាយយ៉ាងរាក់ ។ ទៅទៀតថា ពួកកម្រាលទ្នល់

ខ្ញុំយល្អ ។ ជាដើម កើតអំពីបុញ្ញកម្ម, គ្រឿងការពារកូមស្រុកផ្លូវលំនៅ កើតអំពើជាបកម្មវបស់ពួកចោរ, សុចរិតបង្កើតវបស់ល្អ ទុច្ចរិតបង្កើតវបស់អាក្រក់, តុំមែនព្រះពុទ្ធបង្កើតវត្ថុទាំងនោះទេ ព្រះអង្គគ្រាន់តែត្រាស់ដឹងច្បាប់ ហើយប្រាប់តាមការណ៍ពិតប៉ុណ្ណោះ ។ល។

ដោយយល់ឃើញថា ព្រះសម្មាសម្ពុទ្ធទ្រង់ប្រកាសព្រះធម៌តាមការណ៍ពិតដូច្នេះ ជាជនជាតិខ្មែរលេះដំខ្មៅចាស់ចោលបែរជាងាកមកជឿតាមព្រះពុទ្ធសាសនា ដោយយល់ថាជាសាសនាឯកកន្ត លោក ទាំងជនជាតិដទៃដែលជឿព្រះពុទ្ធសាសនា ក៏សុទ្ធសឹងតែមានយោបល់ដូចគ្នាទាំងអស់ខ្មែរដែរ ។ ខ្មែរជឿស៊ប់ថាព្រះពុទ្ធសាសនាប្រដៅឲ្យមានសន្តិភាពទាំងសន្តិសុខ, ប្រសិនបើអ្នកកាន់សាសនាជាន់ប្រព្រឹត្តប្រតិបត្តិតាមតាម;ដោយហេតុនេះទើបជាន់លើកព្រះពុទ្ធសាសនាថាជាសាសនាវបស់កម្ពុជវដ្ត ។

ព្រះចេតិយថ្មីនេះ មានឈ្មោះថា "ព្រះសក្យមុនីចេតិយ" ព្រោះប្រជាជនពលរដ្ឋខ្មែរជាន់រួបរួមគ្នាកសាង ក្នុងព្រះបរមពជូបត្ថម្ភ សម្រាប់តំកល់ព្រះបរមសារីរិកធាតុនៃព្រះសក្យមុនីសម្ពុទ្ធបរមគ្រូ ដើម្បីជាស្ថានសក្ខិសិទ្ធិជាទីគោរពបូជាតរៀងទៅ ។

ឧកាសដ៏ឧត្តមនេះជារយៈកាលនៃបុណ្យ ព.ស.២៥០០ ឬ ពុទ្ធសតវត្សរ៍ទី ២៥ ជាពិធីចំរើនពុទ្ធសាសនាយុកាលប្រតិស្ឋអធិស្ឋានសូមឲ្យព្រះពុទ្ធសាសនារុងរឿងដូចក្នុងពុទ្ធសម័យ ។

រដ្ឋាភិបាលនៃសិរីសង្ឃ័ធ្វើប ជាន់ថ្វាយព្រះបរមសារីរិកធាតុខ្ញុំតកណ្ដាលមួយព្រះអង្គ ចំពោះសម្តេចព្រះនរោត្តម សីហនុ ទេបយុវៈជ

ព្រះបិតាឯកភាពនៃកម្ពុជរដ្ឋ ក្នុងកាលដែលស្តេចយាងទៅគាន់លង្កាខ្លួន
ជាតំណាងព្រះករុណាជាម្ចាស់ដ៏វិត ដោយរដ្ឋគិចាលសិរីលង្កាបានគ្រោង
បង្ហិនូលសូមស្តេចទៅជាប្រមុខ នៃការមើតពិធីបុណ្យពុទ្ធជយន្តីចំរើនពុទ្ធ-
សាសនាយុកាលគំរប់ ๒๕๐๐ ពីកន្លងមកយូរលង់ណាស់ក្នុងអតីតកាលមុននេះ ជួបជា
ពិធីបុណ្យនៃប្រទេសកម្ពុជាក្នុងវេលានេះដែរ ។ សម្តេចព្រះទេបយុវរាជទ្រង់
មានព្រះរាជប្បាទយ័ប្រកបដោយសោមនស្សជ្រះថ្លាជាគំរប្យាកាត ទ្រង់
ព្រះមេត្តាប្រោសឲ្យមានពិធីដង្ហែព្រះបរមសារីរិកធាតុនោះ មកប្រតិស្ថាន
ក្នុងពិធីបុណ្យ ព.ស. ๒๕๐๐ នេះ ហើយនឹងតំកល់ទុកក្នុងព្រះសក្យមុនី
ចេតិយជាទីគោរពនមស្ការបូជាតរៀងទៅ, ដោយព្រះករុណាជាអម្ចាស់
ដ៏វិតទ្រង់ព្រះមេត្តាប្រោសព្រះរាជទានព្រះបរមរាជានុញ្ញាត ។

បពិត្រព្រះសក្យមុនីសម្ពុទ្ធបរមគ្រូ, ព្រះអង្គទ្រង់បំនិទ្ធានទៅអស់
កាលយូរ ជាង ๒๕๐๐ ឆ្នាំហើយ ប៉ុន្តែព្រះពុទ្ធសាសនាជាឱវាទរបស់
ព្រះអង្គ, ព្រះបរមសារីរិកធាតុជាព្រះសរីរកាយដ៏សេសសល់របស់ព្រះអង្គ
ទំនឹងព្រះពុទ្ធរូបជាទេ្ធសិកចេតិយស្មឹងព្រះអង្គព្រមទាំងព្រះគុណរបស់ព្រះ
អង្គ ស្ថិតនៅតុំពាន់ជាត់ទៅណានៅឡើយ, យើងខ្ញុំព្រះអង្គ, ដោយមាន
ព្រះមហាករុណាគុណពុទ្ធសាសនិកជាប្រមុខនៃកម្ពុជរដ្ឋ, សូមថ្វាយគ្រឿង
សក្ការបូជាចំពោះព្រះអង្គ ដើម្បីឲ្យកម្ពុជរដ្ឋនឹងសកលលោកប្រកបដោយ
សេចក្តីសុខ - ចំរើនជានិច្ចនិរន្តរ៍អស់កាលយូរអង្វែងតរៀងទៅ ! ដោយ
គេជាទុកាពនៃពុទ្ធគុណ, សូមពិភពលោកទាំងមូលសូមប់ ត្រជាក់ត្រដំ
ដោយមេត្តា ករុណា មុទិតា ឧបេក្ខា នឹងសីលធម៌ទាំងពួង, សូមកុំបី
ប្រែក្លាយទៅជាប្រការៈដទៃក្រៅពីនេះឡើយ !

សុន្ទរកថា

សម្តេចព្រះសុធម្មាធិបតី សង្ឆនាយក

គណៈធម្មយុត្តិកនិកាយ

ក្នុងព្រះរាជអាណាចក្រកម្ពុជា

ថ្ងៃ

នៅទ្ធកាសបុណ្យ ព.ស. ២៥០០

សូមថ្វាយព្រះពរព្រះបរមបពិត្រ ព្រះករុណាជាអម្ចាស់ជីវិតទាំង ២ ព្រះអង្គ ទឹង សម្តេចព្រះទបយុវរាជ,

សូមប្រគេនពរ - ចំរើនពរ - ព្រះថេរានុត្តរៈ - ទ្រង់ - ឯកទត្តម ទឹង អស់លោក - អ្នក ដែលជាពុទ្ធសាសនិក ទឹងជាប្រតិភូនៃរដ្ឋពុទ្ធសាសនិក ទាំងឡាយ

សូមទ្រង់ជ្រាប សូមជ្រាប ។

ក្នុងទ្ធកាសមហាសន្ទិបាតបុណ្យអាយុព្រះពុទ្ធសាសនា គំរប់ ២៥០០ ព្រះវស្សានេះ, អាត្មាភាព - ខ្ញុំព្រះករុណា មានកិត្តិយសថ្ងៃងសុន្ទរកថា ក្នុងនាមពុទ្ធសាសនិក ខាងគណៈធម្មយុត្តិកនិកាយ ដូចមានសេចក្តីតទៅនេះ ៖

បពិត្រព្រះរាជសម្ភារ - ព្រះថេរានុត្តរៈ - ទ្រង់ - ឯកទត្តម ទឹង អស់លោក-អ្នកទាំងឡាយ ! ក្នុងថិរៈវលាជាប្រើនពុទ្ធសតវត្សណាស់មកហើយ, ប្រទេសយើងជាពុទ្ធសាសនិកទាំងឡាយ ពុំអាចជ្ជប

ប្រស្រ័យគ្នាទៅវិញទៅមកដោយសេរីបាន ព្រោះព្រឹត្តិការណ៍សាកល
លោកកំពុងយើង គ្រាតែយើងអស់សង្ឃឹមថា ធំធំបានធ្លាប់ច្នេះកើត ។
ដំណើរនេះហើយដែលធ្វើឲ្យសាសនធម៌នៃព្រះបរមសាស្តាយើងអាប់អន់
ស្មើ ដកបញ្ចាំងប្រទេសខ្លះដែលធ្លាប់ជាតុទ្ធសាសនិក ឲ្យទៅជាពាហិរ.
សាសនិកវិញ ។ តែក៏ពុំសំណាងព្រះពុទ្ធសាសនា ដែលជាសច្ច.
វ៉ាថា ប្រកបដោយហេតុ-ផលគួរដល់វិចារណញ្ញាណ ក៏នៅតែមាន
អានុភាពអាចដះចាំងស្មើ ផ្សាយទៅកាន់នានាប្រទេសក្នុងពិភពលោក
ដែលមិនធ្លាប់ប្រាកដក្នុងប្រវត្តិសាស្ត្រថាបានផ្សាយទៅដល់សោះ ដូចជា
ប្រទេសអឺរ៉ុបជាដើម ដែលជាប្រទេសសម្បូរដោយអ្នកប្រាជ្ញខ្លាំងវិជ្ជា
ធំធាងវិទ្យាសាស្ត្រ ។ ប្រៀបបានដូចព្រះអាទិត្យ ដែលរះឡើង
ពីបុព្វទិស ហើយអាចផ្សាយរស្មីដល់អ្នកស្រុកបច្ចិមទិស ទោះបីមាន
រស្មីអាប់អន់ទៅក្តីគ្រាខ្លះ ដោយមេឃបុះអ័ព្ទ ឬដោយសូរ្យគ្រាសជាដើម
ក៏ដោយ ការនេះនាំឲ្យយើងដែលធ្លាប់ឮថ្ងៃថ្ងាមកហើយ មានសេចក្តី
ត្រេកអរក្តីអកឧបមា, ហើយដឿថាបើលោកសន្ទិដ្ឋសាសនេះ សម្បូរដោយ
អ្នកប្រាជ្ញដែលប្រកបដោយវិចារណញ្ញាណ ធ្លាប់មានការពិសោធន៍ពិត
សេចក្តីពិតហើយ នោះព្រះពុទ្ធសាសនាមុខជាមានអាយុយឺនយូរហើយ
រុងរឿងដោយសារការរះរកសច្ចធម៌ នៃអ្នកប្រាជ្ញទាំងនេះពុំខានឡើយ ។

ឯប្រទេសកម្ពុជានេះ កន្លងបុពណសម័យ ក៏ធ្លាប់សម្បូរដោយអ្នក
ប្រាជ្ញបែបនេះដែរ ទើបប្រទេសនេះអាចចំឡងយកវប្បធម៌ពុទ្ធសាសនា
ដែលដុះលូតលាស់ឡើងក្នុងមជ្ឈមប្រទេស (ឥណ្ឌា) មកបណ្តុះជាំឲ្យលូត

លាស់ពាសពេញ ត្រាតែក្លាយទៅជាប្រទេសពុទ្ធសាសនិកដរាបមកដល់
សព្វថ្ងៃនេះ ។

សម័យនេះ ឆ្លរទុកជាសម័យប្រកបដោយសុភមង្គលយ៉ាងខ្ពស់ឯក
មួយរបស់ព្រះពុទ្ធសាសនា នឹងរបស់ពួកយើងជាពុទ្ធសាសនិកទាំងអស់
ព្រោះចាប់តាំងពីមហាសង្ត្រាមទី ៦ រលត់ទៅ សាកលលោកតែងមាន
ព្រឹត្តិការណ៍សមរម្យ ឆ្លរជាភាជនៈ ត្រងរងព្រះពុទ្ធសាសនាបាន ។
រដ្ឋបុរសឯក ។ ទាំងឡាយរបស់ប្រទេសនានា តែងនាំគ្នាចរចេញពី
ប្រទេសមួយទៅប្រទេសមួយទៀត ធ្វើសន្ទិសិទ ពិគ្រោះរកមធ្យា-
បាយសន្តិភាព ដោយស្មើបន្ទើមខ្ទាចសង្ត្រាម មិនចង់ឲ្យមានសង្ត្រាម
ចែបនោះ, ទាំងមិនចង់ឲ្យមានសង្ត្រាមប្រល័យលោកទៅមុខទៀតឡើយ
ដូចព្រះពុទ្ធជាអម្ចាស់ ដែលទ្រង់បានឃើញនូវ អវិជ្ជា-តណ្ហា ជាមូល
នៃជាតិ ជរា ព្យាធិ មរណៈ ហើយទ្រង់ក៏ប្រកាសធម្មតេរ៉ ដាស់សត្ត
ឲ្យភ្ជាក់ដឹងខ្ទួនឃើញដូចព្រះអង្គធង ។

សូម្បីសម្តេចព្រះឧបយុវរាជ ដែលជារដ្ឋបុរសឯករបស់ប្រទេស
កម្ពុជា ក៏ទ្រង់បានបំពេញព្រះរាជការណ៍យកិច្ច ដូចរដ្ឋបុរសនោះ ។ ដែរ
រហូតដល់ទៅទ្រង់រក្សាទុកនូវព្រះនយោបាយអព្យាក្រឹត ដឹកនាំប្រទេស
ទ្រង់មិនឲ្យជ្ជាក់ចូលក្នុងប័ក្ខសម្ពន្ធសង្ត្រាមណា ។ ឡើយ ។ ទាំងប្រទេស
ពុទ្ធសាសនិកទាំងឡាយ ដែលជាអាណានិគម ឬនៅក្នុងអាណាព្យាបាល
នៃបរទេសយូរណាស់មកហើយ ដូចប្រទេសឥណ្ឌៀ-សិរីលង្ក-ភូមា
នឹងប្រទេសកម្ពុជាជាដើម, ក៏ត្រឲ្យប់បានជាប្រទេសឯករាជ្យ មាន

អធិបតេយ្យបរិបូណ៌វិញ ទាំងអស់ បានទាំងបង្កើតពុទ្ធិកសមាគមក្នុង ប្រទេសរៀងខ្លួន ដើម្បីឲ្យមានការប្រស្រ៉ីយទាក់ទងទៅវិញទៅមក រវាងប្រទេសជាពុទ្ធសាសនិកផងគ្នាតទៅទៀតផង, ដើម្បីចម្ងងចំណេះ វិជ្ជា ព្រមទាំងទម្លាប់ទំនៀមដែលល្អពិសេស ៗ ផង, ដើម្បីរួមកំឡាំងគ្នា ដោយសាមគ្គីធម៌ ក្នុងការទបត្ថម្ភព្រះពុទ្ធសាសនាឲ្យមានជំហររឹងប៉ុង ហើយផ្សាយទៅកាន់ប្រទេសនានាផង ។

ក្នុងកាលឥឡូវនេះ ក៏បានប្រារព្ធធ្វើបុណ្យសម្ពោធអាយុព្រះពុទ្ធ-សាសនាគំរប់ ៦៥០០ ព្រះវស្សា, ព្រមទាំងធ្វើបុណ្យធ្ងងជាមួយនេះ នូវ ព្រះសក្យមុនីចេតិយ ដែលសាងទុកជាអនុស្សាវរីយ៍ដល់ព្រះជំណើរមក ដោយប្រវិតនៃព្រះបរមសារីរិកធាតុ និងព្រះអហន្តធាតុអំពីប្រទេស ឥណ្ឌៀផង បានទាំងបញ្ចុះក្នុងព្រះចេតិយនេះ នូវព្រះបរមសារីរិកធាតុ ដែលសម្តេចព្រះបិតាឯកវាជ្ស ទ្រង់បានទទួលមកពីប្រទេសសិរី-លង្ការផង ។

អស់លោកពុទ្ធសាសនិកទាំងឡាយ! ប្រទេសកម្ពុជា ជ្ងាប់ជា ប្រទេសពុទ្ធសាសនិក ហើយមានព្រះមហាក្សត្រជាព្រះអគ្គសាសនូបត្ថ-ម្ភក៍ តាំងពីបុរាណកាល ។ លុះមកដល់ឥឡូវនេះ ក៏បានជួបនូវជោគ វាសនាយ៉ាងប្រសើរ គឺបានឯកវាជ្សដែលមានអធិបតេយ្យបរិបូណ៌ផង, បានព្រះមហាក្សត្រ, ព្រះមហាក្សត្រិយានី និងសម្តេចព្រះទបយុវរាជ ដែលជាព្រះអគ្គសាសនូបត្ថម្ភក៍ផង, បានជួបប្រស្រ៉ីយដោយសុ ៗ សាមគ្គីកាព ជាមួយប្រទេសដែលជាពុទសាសនិកជូចគ្នាផង, បានធ្វើ

បុណ្យសម្ពោធអាយុព្រះពុទ្ធសាសនា ដោយអាម័សបូជាទឹងបដិបត្តិបូជា ដើម្បីសំដែងគតញ្ញូធម៌ ទឹងដើម្បីលើកដំកើងគុណព្រះរតនត្រ័យ ឬ ព្រះពុទ្ធសាសនាជាឧឡារិកផង ។

ពួកយើងជាពុទ្ធសាសនិក តែងនឹកសង្ឃឹមថា "ប្រទេសណា ក្នុងពិភពលោក ដែលស្អប់ខ្ពើមសង្គ្រាម ហើយជាប្រទេសមានរដ្ឋបុរសប្រកបដោយវិចារណញ្ញាណ ជាអ្នកដឹកនាំ, ដូចប្រទេសកម្ពុជានេះ; ប្រជាជនក្នុងប្រទេសនោះ ។ មុខជានឹងនាំគ្នាធ្វើពុទ្ធបូជាដោយសេចក្តីប្រតិបត្តិ យ៉ាងហោចត្រឹមរក្សាសីល ៥ ឲ្យបរិសុទ្ធត្រឹមត្រូវតាមពុទ្ធបំណង, កាលប្រទេសនានាធ្វើបានដូច្នេះ ពិភពលោកនឹងដល់នូវសន្តិភាពដែលជាមូលនៃសេចក្តីសុខពិតពុំខានឡើយ ។

ក្នុងអវសានេះ អាត្មាភាព-ខ្ញុំព្រះករុណា សូមថ្វាយអំណរគុណដ៏ជ្រាលជ្រៅក្នុងនាមនៃធម្មយុត្តិកនិកាយ ចំពោះពុទ្ធសាសនិកចាំងឡាយដែលបានស្តេចយាង - និមន្ត - អញ្ជើញមករួមប្រជុំ ក្បាំងពិធីបុណ្យរបស់យើង ឲ្យមានលំអរុងរឿងជាឧឡារិកក្នុងវេលានេះ ។

ពីតោ ជេន សុប្បញ្ញេន សោត្តិ ហោតុ សទាបិនោ
សាសនំ សត្ត អម្ហាកំ បិរំ ទិប្បតុ តាទិនោ

ដោយមហាបុញ្ញកុសល ដែលកើតអំពីការសម្ពោធអាយុគំរប់ ២៥០០ ព្រះវស្សានៃព្រះពុទ្ធសាសនានេះ សូមសួស្តីកើតមានដល់យើងទាំងឡាយជាពុទ្ធសាសនិកគ្រប់កាល, សូមសាសនាព្រះពុទ្ធ ទ្រង់ប្រកប

ដោយតាទិតុណាដែលជាបរមសាស្តារបស់យើងទាំងឡាយ រុងរឿងអស់
កាលជាអង្វែងតទៅ ។

សូមសន្តិភាព កើតមានក្នុងសាកលលោកសព្វ ៗ កាលកុំបីខានឡើយ ។

ថ្ងៃនៅថ្ងៃទី ១៦ ឧសភា ៤៩០០/១៩៤៧

សម្តេចព្រះសុធម្មាធិបតីសង្ឆនាយកគណៈធម្មយុត្តិ

ឥន្ទញាណោ កុល-ធេស

× × ×

ម៉ោង ១១-០០ ព្រះករុណាជាអម្ចាស់ជីវិតលើត្សូង, សម្តេចព្រះ
មហាក្សត្រិយានី នឹងសម្តេចព្រះទបយុវរាជស្តេចយាងត្រឡប់ទៅកាន់
ព្រះបរមរាជវាំងវិញ ។

ម៉ោង ១៥.៤៥ សម្តេចហ្វាវាំងវរៈវ៉ៀងជីយ អធិបតីស្រឹង្គារ
ព្រឹទ្ធសមាជិកទត្តមប្រឹក្សាព្រះរាជា អគ្គនាយកក្រសួងនានាក្នុងព្រះបរម
រាជវាំង ជាព្រះរាជតំណាងនៃព្រះករុណាជាអម្ចាស់ជីវិតលើត្សូង បាន
អញ្ជើញមកជល់មណ្ឌលបុណ្យ រួចបានយកកូងបុប្ជាដែលកញ្ញាម្នាក់យក
មកជូនទៅបូជាព្រះបរមសារីរិកធាតុនៅក្នុងបុស្សុក ។ លំដាប់តមក, សម្តេច
បានអញ្ជើញទៅអានន្ទូវសេចក្តីថ្វែងមួយ គោរពព្រះសម្មាសម្ពុទ្ធជាអម្ចាស់
ជូចខាងក្រោមនេះ:

សូមថ្វាយបង្គំព្រះសម្ពុទ្ធជាម្ចាស់,

ក្នុងទកាសពិធីបុណ្យពុទ្ធសករាជ ៦៥០០ ព្រះវស្សានេះ យើងខ្ញុំ
ព្រះអង្គទាំងឡាយ សូមបង្ហោនកាយវាចាចិត្តគោរពជាទឡារិកចំពោះព្រះ
បរមសារីរិកធាតុនៃព្រះអង្គ ។

តាធីបុណ្យដ៏ធំអស្ចារ្យនេះ យើងខ្ញុំព្រះអង្គធ្វើឡើង ជាការតបស្នងសងព្រះគុណសម្បត្តិ ๓ យ៉ាងរបស់ព្រះអង្គ ដែលផ្សាយគ្របដណ្តប់ស្រោយស្រង់មកលើយើងខ្ញុំគ្រាំងឡាយ ក្នុងកម្ពុជវដ្តនេះ ។

ព្រះគុណសម្បត្តិ ๓ ប្រការនោះគឺ :

๑- ព្រះបញ្ញាគុណ គុណត្រង់ដែលព្រះអង្គត្រាស់ដឹងនូវធម៌ពិតប្លែកប្រការមុនសាស្តាគាំងអស់កន្លងលោក ហើយប្រកាសប្រាប់សត្វឲ្យដឹងផងគឺព្រះអង្គត្រាស់ដឹងនូវ:

ក- ទុក្ខសច្ច: សេចក្តីទុក្ខជារបស់ពិត,

ខ- សមុទយសច្ច: ហេតុនាំឲ្យកើតទុក្ខជារបស់ពិត,

គ- និរោធសច្ច: ការរំលត់ទុក្ខជារបស់ពិត,

ឃ- មគ្គសច្ច: ផ្លូវនៃសេចក្តីប្រតិបត្តិ ដើម្បីរំលត់ទុក្ខ ជារបស់ពិត ។

๒- ព្រះវិសុទ្ធិគុណ គុណត្រង់ដែលព្រះអង្គបរិសុទ្ធស្អាត គ្មានកិលេសជាគ្រឿងមន្ទិលសៅហ្មងក្នុងព្រះទ័យ ចាត់ជាព្រះអរិយបុគ្គលជាន់ខ្ពស់បំផុតដែលពួកសត្វលោកគួរយកតម្រាប់តាមព្រះអង្គ ។

๓- ព្រះករុណាគុណ គុណត្រង់ដែលព្រះអង្គមានព្រះទ័យមេត្តាករុណាចំពោះសព្វសត្វឥតរើសមុខ ។ ដោយហេតុព្រះអង្គ មានព្រះករុណាគុណនេះហើយ ទើបកាលព្រះអង្គគង់នៅ ទ្រង់ស្វះស្វែងប្រោសសត្វឥតតិតដល់ការលំបាកព្រះអង្គ ព្រមទាំងប្រតិស្ឋានសាសនាទុកតមកដល់វេលានេះ ។

បពិត្រព្រះសម្មាសម្ពុទ្ធជាបរមគ្រូ,

យើងខ្ញុំព្រះអង្គ ដោយបានរលឹកឃើញនូវមហាគុណ តាំងបីនេះហើយ ត្រាំពុំបានទើបថ្ងៃនូវសេចក្តីគោរពចំពោះព្រះអង្គ ដោយបន្ទឹរាបាដ៏លាន់ ញ្ជឧរឧារយ៉ាងនេះ ។

ព្រះគុណសម្បត្តិតាំង ៣ នោះ យើងខ្ញុំបានដឹងច្បាស់ថា ព្រះអង្គ បានសម្រេច ដោយសារសេចក្តីព្យាយាម ជាបញ្ញាធិក កាលអំពីអតីត ជាតិ ដែលមានសេចក្តីលំបាកជាយ៉ាងក្រៃលែង រាប់ដោយកប្បអស់ ៤ អសំខេយ្យមួយសែនកប្ប ។ រាល់តែព្រះជាតិ ព្រះអង្គយកព្រះទ័យប្តូរ នឹងព្រះសម្ពោធិញ្ញាណមិនមានរួញរា គឺព្រះជាតិខ្ទះ ហ៉ានលះរាជសម្បត្តិ ទៅទ្រង់ផ្ទួសជាតាបស, ព្រះជាតិខ្ទះ លះបុត្តកវិយាឲ្យជាទានដល់ស្មូម យាចក, ព្រះជាតិខ្ទះ ហ៉ានពុះទ្រូងយកថ្ងើមជាក់ទានដល់អ្នកត្រូវការ សុំឲ្យតែសម្រេចពោធិញ្ញាណ ដល់មកបច្ចិមជាតិ ព្រះអង្គលះសម្បត្តិ ស្តេចចក្រដែលនៅ ៧ ថ្ងៃទៀតនឹងបាន មិនមានព្រះទ័យស្តាយ ទ្រង់ ចេញបោលរាជរាំងទៅទ្រង់ព្រះផ្ទួស ហើយធ្វើទុក្ករកិរិយា រហូតទាល់ តែផ្ទួលលើដែនដី ហើយប្រែផ្ទាស់ព្រះទ័យមកចំរើនអានាបាណស្សតិ កម្មដ្ឋាន ក៏បានសម្រេចព្រះពោធិញ្ញាណ ។ តមកទ្រង់មិននៅស្ងៀម ទ្រង់ ស្តេចនិមន្តទេសន៍ទូន្មានដឹកនាំសត្វឲ្យបានសម្បត្តិ ៣ ប្រការ គឺសុខក្នុង មនុស្សលោក ១ ក្នុងបរលោក ១ ក្នុងព្រះនិព្វាន ១ ។

បពិត្រព្រះសក្យមុនីគោត្តម

អាស្រ័យហេតុដែលព្រះអង្គមានមហាឧបការគុណដ៏ធ្ងន់ ចំពោះ

ចរិសទ័ដូចថ្ងៃនេះ ទើបយើងខ្ញុំធ្វើនូវបុណ្យដ៏ធំៗក្រៃកនេះ ដើម្បីសំដែងនូវកតញ្ញូកតវេទិតាធម៌ចំពោះព្រះអង្គ ។

ដោយអំណាចបុញ្ញាភាពនេះ សូមពួកទេវតាដែលមានទីគ្នាទុកភាពនឹងសូមឲ្យតេជៈតិ្តសិទ្ធិកង់សកលលោក ជួយអភិបាលប្រជាជាតិខ្មែរនឹងប្រទេសខ្មែរ ឲ្យបានជួបប្រសប់នូវបុណ្យសុខ ឲ្យបាននូវការថ្កើងរុងរឿងជួបសម័យអង្គរ កុំបីអាក់ខាន ។

មួយទៀត សូមជួយអភិបាលសម្រួលការគាន់តឹងកង់សាកលលោក ឲ្យបានធូរស្បើយចាកទុក្ខនឹងភ័យខាំងឡាយ កុំបីមកបៀតបៀនឡើយ !

❀ ❀ ❀

ក្រោយដែលសម្តេចចៅហ្វាអានសេចក្តីថ្លែងការណ៍ចប់ ព្រះសង្ឃបួសថ្មី ២៩០ អង្គ នឹងអ្នកកាន់សីល ១០ ក៏បានឧបសម្ផាព្រះរតនត្រ័យ ។

លំដាប់តមក, សម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយ បានប្រគានទុក់ថានុសាសនី សរសើរនូវកិច្ចសំណាងយើងទាំងអស់គ្នាបានថាន់ព្រះពុទ្ធទុក់ ថាន់ព្រះពុទ្ធប្បដិមាករ ព្រះពោធិព្រឹក្ស ព្រះបរមសារីរិកធាតុរបស់ព្រះគតវន្តមុនីជាម្ចាស់ ពុកជួបជាថាន់ព្រះអង្គគាលទ្រង់តម្កល់ព្រះធរមាននៅឡើយ ។ ក្រោយដែលមានព្រះពុទ្ធដីកាអំពីពុទ្ធប្រវត្តិ សម្តេចជាស់គ្រឿនក្រើនរំលឹកពួកពុទ្ធសាសនិកជនឲ្យខំប្រតិបត្តិតាមព្រះពុទ្ធទុក់ខានការគាន់សីល ៥, សីល ៨, សីល ១០, បព្វជ្ជាជាសាមណេរ ឬឧបសម្បទាជាភិក្ខុជាដើម ។

សម្តេចបានបញ្ចប់នូវទុក់ថានុសាសនី ដោយប្រមូលកុសលពលសី

ថ្វាយជាព្រះរាជកុសលចំពោះព្រះករុណាជាអម្ចាស់ជីវិត, សម្តេចព្រះមហា-ក្សត្រិយានី នឹងសម្តេចព្រះទបយុវរាជ សូមទ្រង់គង់ជាសុខប្រកបដោយសុវត្ថិជ័យមង្គលគ្រប់យ៉ាង ។

លំដាប់តមក សម្តេចព្រះសុធម្មាធិបតីសង្ឆនាយកគណៈធម្មយុត្តិកនិកាយ ថ្វែងនូវទរាទានសាសនីថា

សច្ចរាចា ប្រកបដោយហេតុផលគួរដល់វិចារណេញ្ញាណ ក៏នៅតែមានអានុភាពអាចជះចាំងរស្មី ផ្សាយទៅកាន់នានាប្រទេសក្នុងពិភពលោកដែលមិនធ្លាប់មានក្នុងប្រវតិសាស្ត្រថាបានផ្សាយដល់សោះ ដូចជាប្រទេសអើរ៉ូបជាដើម ដែលជាប្រទេសសម្បូណិដោយអ្នកប្រាជ្ញទស្សនវិជ្ជានឹងខាងវិទ្យាសាស្ត្រ ។

សម័យនេះគួរទុកជាសម័យប្រកបដោយសុភមង្គលយ៉ាងខ្ពស់ឯកម្ជយរបស់ព្រះពុទ្ធសាសនា នឹងរបស់ពួកយើងជាពុទ្ធសាសនិកទាំងអស់ ព្រោះចាប់តាំងពីមហាសង្ត្រាមទី ២ រលត់ទៅ សកលលោក តែងមានព្រឹត្តិការណ៍សមរម្យ គួរជាភាជនៈត្រងរងព្រះពុទ្ធសាសនាបាន ។

សូម្បីសម្តេចព្រះទបយុវរាជ ដែលជារដ្ឋបុរសឯកបស់ប្រទេសកម្ពុជាក៏ទ្រង់បានបំពេញព្រះរាជករណ៉ីយកិច្ច ដូចរដ្ឋបុរសនោះ។ ដែរ រហូតដល់ទៅទ្រង់រក្សាទុកនូវព្រះនយោបាយអព្យាក្រឹត ដឹកនាំប្រទេសទ្រង់មិនឲ្យធ្លាក់ចូលក្នុងប័ក្ខសម្ពន្ធសង្ត្រាមណា។ ឡើយ ។

ក្នុងកាលឥឡូវនេះ ប្រទេសកម្ពុជា បានប្រារព្ធធ្វើបុណ្យសម្ពោធអាយុព្រះពុទ្ធសាសនា គំរប់ ២៥០០ ព្រះវស្សា ព្រមទាំងធ្វើបុណ្យ

ឆ្នូនជាមួយនេះទូរព្រះសក្យមុនីចេតិយ ដែលសាងទុកជាអនុស្សាវរីយ៍ដល់ព្រះដំណើរមកដោយប្រពៃនៃព្រះបរមសារីរិកធាតុ ទឹនព្រះអរហន្តធាតុអំពីប្រទេសឥណ្ឌា ជាន់ជាបញ្ចុះក្នុងព្រះចេតិយនេះ ទូរព្រះបរមសារីរិក-ធាតុដែលសម្តេចព្រះបិតាឯកពាស្ស ប្រទានឲ្យមកពីប្រទេសសេរីលង្កានេះ ។

លំដាប់តមក មានការប្រគេនខេត្តទាន ដល់ព្រះសង្ឃប្លួសថ្មី ទឹនជូនខេត្តវត្តិ ដល់អ្នកគាន់សីល១០ ។

ក្នុងពេលរសៀលថ្ងៃនេះ វេលាម៉ោង ១៥, គណៈប្រតិភូនាប្រទេស ភ្ញៀវកិត្តិយសរបស់យើង ជានឲ្យលេចក្តីអញ្ជើញពីភជវង្គ-កិច្ចាលឲ្យទៅទស្សនាពិពិធកណ្ឌស្ថានជាតិ, សាលាសាធីវ:ខ្មែរ, មន្ទីរពេទ្យព្រះសង្ឃ ។ ភ្ញៀវកិត្តិយសទាំងនោះ ជានមានឧកាសទស្សនាទូរពិពិធកណ្ឌស្ថានជាតិ ដែលជានរៀបចំអង្គការ ជាយ៉ាងម៉ឺងម៉ាត់ មានបុពណវត្ថុដាក់ប្រែនប្រកបដោយក្បាច់ចនាដ៏វិចិត្រ, មានព្រះពុទ្ធរូបសម័យបុពណ, សម័យអង្គរ, សម័យទំនើប, សម័យបច្ចុប្បន្ន, ទេវរូប, រូបគំនូរជារូបប្រែនបែប-យ៉ាង, អក្សរចារឹកបុពណជាដើម ។ នៅសាលាសាធីវ:ខ្មែរ, ភ្ញៀវកិត្តិយស ជានសរសើរអំពីក្រុមតួកជាងសិល្បៈជាងគំនូរ, ជាងឆ្លាក់, ជាងតម្បាញ . . . . ល . . . . . ដែលកំពុងធ្វើកិច្ចការទាំងស្មាយ, ព្រមទាំងការអប់រំដែលមានចំណងចង់រក្សាទុកនូវរបៀបរបស់ខ្លួន ដោយបញ្ចេញកំសួលថ្មី ឲ្យចូលមកកន្លងសន្តានចិត្តអ្នកនិស្សិត គឺថាសាយចម្រុះប្រពៃណីបុពណ ទឹនប្រពៃណីថ្មីដែលកើតជា

ប្រៃពណ៌មួយដ៏ប្រសើរ ប្រកបដោយចរិតនិស្ស័យទៅតាមសោភណ្ឌភាពដ៏ប្រៃព ។

ពេលយប់ម៉ោង ១៨ មានដ្ឋីពិធីនមស្ការព្រះរតនត្រ័យ សមាទានសីល ៥ នឹងចម្រើនព្រះបរិត្ត ទេសនា ។

រំលាដ្ឋីពិធីទាំងនោះ មានអាចារ្យគណៈមហានិកាយ ១ នាក់ទៅប្រចាំការសម្រាប់នាំដ្ឋីទៅមហាវាង; ព្រះសង្ឆគណៈមហានិកាយ ២០០០ អង្គ ធម្មយុត្ត ៥០០ អង្គ ចំរើនសត្តបរិត្ត ។ បន្ទាប់មក មានធម្មទេសនា ២ លើក, ក្នុង ១ លើកចំនួនកន្ទះម៉ោង :

លើកទី ១ ម៉ោង ១៩, ព្រះពោធិវ័ង្ស ហួត-តាត គណៈមហានិកាយ វត្តទណ្ណាលោម សំដែងរឿងពុទ្ធប្រវត្តិ ត្រង់តុសិតបរិច្ចេទ ទី ៣ គព្ភាកិនិក្ខមនបរិច្ចេទទី ៤ លក្ខណបរិត្តហណបរិច្ចេទទី ៥ ។

លើកទី ២ ម៉ោង ១៩, ៣០, ព្រះអមរាភិរក្ខិត ឡុង-ណាវ វត្តបទុមវតី គណៈធម្មយុត្តិសំដែងរឿងរាជាភិសេកបរិច្ចេទទី ៦ មហាភិនិក្ខមនបរិច្ចេទទី ៧ ។

ក្រោយពីការបូជាកាំជ្រូច, ពេលម៉ោង ២២, មានល្ខោនព្រះរាជទ្រព្យ ពំរឿងពុទ្ធប្រវត្តិរួមជាមួយល្ខោនជាតិ ។

សម្តេចព្រះទបយុវរាជ, សម្តេចវៅហ្ទាកំងវរៈរឿងជ័យ អធិបតីស្រឹង្គារព្រឹទ្ធសមាជិកទត្តមប្រឹក្សាព្រះរាជា, សមាជិកនៃរាជរដ្ឋាភិបាល, សមាជិកការទូត, មន្ត្រីធំ,តូច បានស្តេចយាងអញ្ជើញទៅទស្សនាល្ខោននេះដោយសោមនស្សរីករាយយ៉ាងក្រៃលែង ។

ល្ខោននេះបានពំរឿងតាំងពីព្រះសម្មាសម្ពុទ្ធទ្រង់ប្រសូត, ហោរា

ភាយ, និម្មិតទាំងបួន(ចាស់,ឈឺ,ស្លាប់,ព្រះសង្ឃ), ទ្រង់សាងផ្នួស,ទ្រង់ត្រាស់ទូវេសម្មាសម្ពោធិញ្ញាណ ។ សំលៀកបំពាក់ពួកស្នំនភ្នំប្រាសផ្តៅ ប្រកបដោយពណ៌សម្បុរស្រស់ពន់ពេក, រូបគំនូរមានក្រមខ័ណ្ឌ, មានសភាពគួរឲ្យពេចពិលរមិលមើល ។

អាកប្បកិរិយា, កាយវិការអ្នកគួរស្នាន ទាំងបុរសស្ត្រីប្រកបដោយក្សាច់សិល្បៈ គួរឲ្យពេញចិត្តណាស់, ទង្គភាពនៃកេងទាំងមូលក៏ចាលវស្ត្រក្រហមខៀវលឿងលាយចំរុះនឹងរូបគំនូរ ទឹងស្ទឹកឈើខៀវខ្ចី ព្រមទាំងពពក, មេឃ, តាព, ព្រះចន្ទ រចនាវត្ថុទាំងអស់នោះឲ្យមានលំអវិស្ស័យហាន់សួតិ ។

ទិដ្ឋភាពនៃរាជធានីភ្នំពេញ

នៅតាមគេហដ្ឋាននៃរាជធានីភ្នំពេញ; មានទង់ជាតិ, ទង់សាសនាដោតនៅមុខផ្ទះ ។ ឯទង់សាសនាបានបញ្ចេញភាពណាទាំងប្រាំ គឺខៀវ ផ្លែមេឃ, លឿង, ក្រហម, ស, ហាន្សបាទ ដំមានលំអគួរទស្សនា ។ នៅគេហដ្ឋានខ្លះមានបាសសំអាតរៀបចំទ័កខ្ពែង ដាក់តុមួយក្រាលកម្រាលហើយតាំងព្រះពុទ្ធរូបព្រមទាំងគ្រឿងសក្ការបូជាទាំងឡាយ មានខៀនធូបកំភ្លើងជាដើម; យប់មានអុជគោមបង្កើងអគ្គិសនីគ្រប់ពណ៌ថ្វាយព្រះបរមសមុទ្ធដែលព្រះអង្គបរិនិព្វានហើយគ្រប់២៥០០ព្រះវស្សា ។ មានគេហដ្ឋានខ្លះបានយកផ្កាក្រដាសគ្រប់ពណ៌ក្រដាងចងនៅខាងកន្លែងមានគ្រឿងសក្ការបូជា ។

មានទុបាសក ទុបាសិកា បព្វជិតគ្រហស្ថក្នុងថាស់កប់សែននាក់បានចូលទៅកន្លែងមណ្ឌលពិធីបុណ្យ ព្រះសង្ឃសូរកន្លំពែងជាន់ន្តែ ។ មាន

ព្រះសង្ឆ, ឧបាសក ឧបាសិកា អ្នកកាន់សីល ១០ គង់អង្គុយក្នុងរោងធំ ដែលគេក្រឡេកឡេកឃើញជូចសមុទ្រលឿងនឹងសមុទ្រសតបន្ទាប់គ្នា មានខ្ទះកាន់ធូបឡៃនៅអុជបូជាព្រះបរមសារីរិកធាតុ, ខ្ទះដើរទស្សនាអគារផ្សេងៗ ខ្ទះឈរទស្សនាទិដ្ឋិកាពវិនមណ្ឌលពិធីបុណ្យដែលមានអគារផ្សេងៗ ប្រៀបជូចជាប្រាសាទវិមានថ្មីៗ មានទង់រលកទង់សាសនា បក់រវិបឡេតាមព្រះពាយដែលគួរឲ្យរីករាយវិក្រេពេក ។ មានមាំស៊ីនបាញ់ទឹកចេញទឹកពីព្រះធរណីខាងមុខនឹងខាងក្រោយបុស្សុក ហើយទទួលមានរស្មីព្រះសុរិយាបញ្ចាំងមក មើលឡេជូចជាឥនូធនូចុះធឹកទឹក ។

រាជធានីទាំងមូលគឹកកងរំពង ដោយមនុស្សដើរនឹងជិះរថយន្ត ទោចក្រយាន ប្រញ៉ាបប្រញាប់ឡេកាន់មណ្ឌលបុណ្យ ។

ព្រះសុរិយារៀបរះ មានសភាពញញឹមស្រស់បានដាស់មនុស្សទាំងឡាយឲ្យភ្រាក់ឡើង ដើម្បីស្វៀកខោពាក់អាវ ផ្ទើម្ហូបអាហារឡេកាន់មណ្ឌលបុណ្យ ។

ពេលនេះ, ភិក្ខុសាមណេរនឹងឧបាសកឧបាសិកាអ្នកកាន់សីល ១០ ក៏ បាននិមន្ត, បានអញ្ជើញមកកាន់មណ្ឌលបុណ្យដោយរៀបរយ ។ តាមសេចក្តីឲ្យការណ៍ក្នុងទីប្រជុំបុណ្យថា គណៈកម្មការចាត់ការបុណ្យដ្នកខាងទេយ្យទាន បានអំពាវនាវសុំទេយ្យវត្ថុពីសប្ឆុរសជនសម្រាប់យកឡេប្រគេនព្រះសង្ឆបួសថ្មី, ព្រះសង្ឆបរទេស, ជូនឧបាសកឧបាសិកាអ្នកកាន់សីល ១០ ជូចខាងក្រោម :

១ - ខាងព្រះសង្ឆបួសថ្មី ប្រមាណ ៦៥០០ អង្គ គេបែងចែកឲ្យ

សមាគមទាំង ៣ ជួយអំពាវនាវ គឺ

ក) - ពុទ្ធិកសមាគមកម្ពុជរដ្ឋ : ១០០០ អង្ក ;

ខ) - សមាគមមិត្តពុទ្ធិកវិទ្យាល័យ : ៧៥០ អង្ក ;

គ) - គិលានសង្រ្គោះព្រះសង្ឃខ្មែរ : ៧៥០ អង្ក ;

២ - ខាងអ្នកកាន់សីល ១០ប្រមាណ ៥០០ នាក់ គេបែងចែកឲ្យសមាគម ទាំង ៣ ជួយអំពាវនាវ គឺ

ក) - ពុទ្ធិកសមាគមកម្ពុជរដ្ឋ : ២០០ នាក់;

ខ - សមាគមមិត្តពុទ្ធិកវិទ្យាល័យ : ២០០ នាក់;

គ - គិលានសង្រ្គោះព្រះសង្ឃខ្មែរ : ១០០ នាក់;

៣ - ខាងព្រះសង្ឃបរទេស ប្រមាណ ១០ អង្ក គេបែងចែកជូចេះគឺ

ក) - ពុទ្ធិកសមាគមកម្ពុជរដ្ឋ : ៤ អង្ក;

ខ) - សមាគមមិត្តពុទ្ធិកវិទ្យាល័យ : ៣ អង្ក ;

គ) គិលានសង្រ្គោះព្រះសង្ឃខ្មែរ : ៣ អង្ក ។

ទេយ្យទានដែលសមាគមទាំងបី បានអំពាវនាវ ចំពោះពួកពុទ្ធ-សាសនិកជន បានអណ្តាប់ដល់ទៅជាងមួយម៉ឺនកញ្ចប់, តែតិកូសាមណេរ ជួសថ្មី មានត្រឹមតែ ៦.៨៨០ អង្ក; ឧបាសក-ឧបាសិកាអ្នកកាន់អតិរេកសីល មានជាង ១០.០០០ នាក់ ។ ការណ៍នេះនាំឲ្យយល់ថាពួកពុទ្ធសាសនិកជន មានសទ្ធាជ្រះថ្លាជាយ៉ាងវិក្រលែង ចំពោះពិធីបុណ្យ ព.ស.២.៥០០, បានជាចំនួនកញ្ចប់ទេយ្យទានច្រើនលើសលុប ។

× × ×

ថ្ងៃទី ២

គឺថ្ងៃបន្ទ ១៥កើត ខែពិសាខ ព.ស.២៥០០

គឺថ្ងៃទី ១៣.៥-៥៧ ជាថ្ងៃវិសាខបូជា

ថ្ងៃនេះ ជាថ្ងៃសំខាន់ជាងគេ ព្រោះជាថ្ងៃត្រូវធ្វើបុណ្យវិសាខបូជា គឺថ្ងៃដែលព្រះអង្គប្រសូត ថ្ងៃដែលព្រះអង្គត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ, ថ្ងៃដែលព្រះអង្គចូលកាន់បរិនិព្វាន, ជាអតិលក្ខិតសម័យដែលពួកពុទ្ធសាសនិកជនគ្រប់ទាំងបុរសស្ត្រីត្រូវប្រជុំធ្វើបុណ្យវិសាខបូជារៀងរាល់ឆ្នាំ ដើម្បីសំដែងគារវកាតញ្ញូតាចំពោះព្រះគុណនៃមុនីបវរមសម្ពុទ្ធជាម្ចាស់ ។

ពេលព្រឹក ម៉ោង ៨ ព្រះគុណជាអម្ចាស់ដ៏វិសេសលើសត្វលោក ទីឯសម្តេចព្រះមហាក្សត្រិយានី ព្រមទាំងសម្តេចព្រះទេពរៀងៗខ្លួន ស្តេចយាងមកដល់, សម្តេចចៅហ្វាក៏ទទួលរៀងរាយ សមាជិកផ្នែកតុបាល, សមាជិកការទូត, មន្ត្រីជំនិតជួប ទ្រង់ស្តេចយាងអញ្ជើញចូលទៅគង់អង្គុយក្នុងព្រះពុទ្ធាភិត្តិយស ។

ព្រះគុណជាអម្ចាស់ដ៏វិសេសលើសត្វលោក, សម្តេចព្រះមហាក្សត្រិយានី សម្តេចព្រះទេពរៀងៗខ្លួន ទ្រង់ស្តេចយាងទៅគាល់បុស្បកថ្វាយក្តួងបុប្ផាំងគោរពព្រះបរមសារីរិកធាតុ; លំដាប់តមក, ពួកសិស្សសាលានៃវិជ្ជាទីឥន្ទវិទ្យាល័យនៃកត្តម ដែលឈរតម្រៀបជាជួរខាងកើតបុស្បកថាន បន្ទ

ទ្រង់បន្ទូលតបវិញ ដើម្បីបញ្ជាក់ឲ្យបានច្បាស់ថា ព្រះអង្គជាអ្នកមានសទ្ធាជ្រះថ្លាចំពោះព្រះរតនត្រ័យ ។

ក្រោយមកទៀត ព្រះសង្ឃនាយកគណៈមហានិកាយបានប្រគេនសីល ៨ ជាច្រើនដង ចំពោះពួកពុទ្ធសាសនិកជនភាំងឡាយ ព្រមទាំងនមស្ការព្រះបរមសារីរិកធាតុ ហើយព្រះសង្ឃថ្វាយពុទ្ធដីកាមង្គលគាថា ជាអាសាន ។

លំដាប់តមក, សម្តេចព្រះមហាឧបយុវរាជទ្រង់ថ្វាយនូវព្រះពរជាសុន្ទរកថាមួយ បើកតាមដីបុណ្យក្រដាបមានសេចក្តីតទៅនេះ ៖

សូមតាតពុទ្ធដីកា,

សម្តេចព្រះសង្ឃនាយក,

ព្រះថេរានុត្ថេរៈ,

សូមជំពាក់ចិត្តលោកតំណាងប្រទេសនានា ទាំងមិត្តរួមជាតិភាំងឡាយ !

នៅវេលាចាប់ផ្តើមធ្វើបុណ្យពុទ្ធសករាជ ២៥០០ ដែលបណ្តាពិភពលោកនៅក្នុងប្រទេសកម្ពុជា មានសទ្ធាជ្រះថ្លាទាំងសាមគ្គីសព្វបែបនាយ៉ាងក្រៃលែង នោះខ្ញុំព្រះករុណា សុំថ្វាយសេចក្តីកត្តញ្ញូដោយគោរពចំពោះសម្តេច, ខ្ញុំសុំថ្វាយនូវអំណរគុណដោយស្មោះអស់ពីដួងហឫទ័យ ដល់អ្នកតំណាងនៃរដ្ឋនានា ដែលបានអញ្ជើញមកចូលរួមជាមួយនឹងយើង ដើម្បីធ្វើអភិវន្ទនាការ ចំពោះព្រះបរមសាស្តាជាទីគោរពនឹងមនុស្សភាំងឡាយ។ ខ្ញុំព្រះករុណា ខ្ញុំ សុំថ្វាយសេចក្តីគោរពប្រកបដោយភក្តីចំពោះព្រះសង្ឃទាំងអស់រួមជាអ្នកយើង ដែលបានចំណាយអញ្ជើញមកគង់នៅក្នុងព្រះពុទ្ធជាន ដើម្បីសម្តែងនូវហឫទ័យជ្រះថ្លាចំពោះ ព្រះសម្មាសម្ពុទ្ធ វិសុទ្ធិគុណ អនន្តញ្ញាណ ដែលព្រះអង្គបានត្រាស់ដឹងនូវ ញេយ្យធម៌

ទាំងពួងដោយប្រពៃ ជាបច្ច័យនៃសេចក្តីសុខ សេចក្តីចំរើនដល់ពួកសត្វលោក ។

កាលបើយើងបានឃើញអស់លោកអ្នកតំណាងប្រទេសជាមិត្តទាំងឡាយ ចំឡូលខ្លាយអញ្ជើញមកបំពេញ បុញ្ញកម្ម នេះ ជាមួយព្រះមហាករុណាធិគុណ ទើបជនរួមជាតិយើង ដើម្បីនឹករលឹកចំពោះព្រះមហាករុណាធិគុណនៃ ព្រះសព្វញ្ញុសម្មាសម្ពុទ្ធ នោះយើងមានចិត្តរីករាយជាមហិមា ព្រោះយើងទុកការរួបរួមបែបនេះ ជាសេចក្តីប្រឿនប្រជុំមួយយ៉ាងខ្លាំងត្រូវជាចិត្ត ។

លុះព្រះអង្គបានត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណរួចហើយ ព្រះដ៏មានព្រះភាគបានសម្តែងនូវព្រះសុធម្មប្រោសមនុស្សទាំងពួង ធ្វើឲ្យសត្វលោកប្រាសចាកពីទុក្ខវេទនា ជៀងនាំសេចក្តីសុខ សេចក្តីសាមគ្គីទាំងភាវភាព ។

ពួកអស់លោកតំណាងប្រទេសជាមិត្តជាបងប្អូនរួមលោហិត ដែលបានអញ្ជើញមកកាន់ពិធីនេះបង្ហាញឲ្យយើងឃើញបានថា សាសនាបេះសម្តេចព្រះជិនស្រីសម្មាសម្ពុទ្ធ ទេសនាញាណ បានជ្រួតជ្រាបសុះសាយទៅក្នុងទ្វីបអាស៊ីទាំងទ្វីបដទៃទៀតផង ។ ពួកប្រទេសដែលគាំទ្រព្រះពុទ្ធសាសនា គ្មានបៀតបៀន គ្មានប្រណាំងប្រណាំងគ្នាឡើយ ណាទេ ព្រោះប្រទេសទាំងនោះគ្មានសេចក្តីលោភ គ្មានសេចក្តីស្អប់ខ្ពើមគេឡើយ ។ កំឡាំងរបស់ប្រទេសទាំងនោះ គឺកំឡាំងចិត្តដែលគោរពភក្តីដោយនូវមនុស្សធម៌-សប្បុរសធម៌ និងមេត្តាធម៌ ។

ប្រជាពស្ត្រៃទ្មានចិត្តដឿជាក់ដល់ព្រះសុធម្មដែលជាទីពឹង ទីពំ-
នាក់របស់ខ្លួន ទោះក្នុងការត្រិះរិះក្តី ទោះប្រកបកិច្ចការក្តី ឬសំដែងអាកប្ប-
កិរិយាចំពោះប្រទេសនានាក្តី ក៏តែងប្រព្រឹត្តតាមគន្ធងធម៌ជានិច្ច ។ រីឯ
នយោបាយទ្លាឡរបស់ប្រទេសកម្ពុជាសព្វៃថ្ងៃនេះ ដែបនិយមតាមលទ្ធិ
ប្រជាធិបតេយ្យ សហជីវកាពនឹងសន្តិកាពក៏តម្រូវតាមព្រះពុទ្ធោវាទទាំង
អស់ ។ ទត្តមគតិរបស់យើងទាំងអស់នេះ ពុំមែនយើងទើបតែនឹងមាន
តាមតេក្នុងបច្ចុប្បន្នកាលសម័យថ្មីនេះទេ ។ ទត្តមគតិនេះស្ថិតនៅជាប់
ក្នុងសន្តានចិត្តនឹងអាកប្បកិរិយារបស់យើង របស់មគ្គុទ្ទេសក៍នៃប្រជាជាតិ
មកជាជរាបយូរយារណាស់មកហើយ គឺតាំងពីបុរាណកាល ។ ព្រោះ
ព្រះពុទ្ធសាសនាប្រដៅយើងឲ្យស្គាល់ទូវសមភាព ។ មនុស្សលោក
មិនថាអ្នកធំ ឬ អ្នកតូច រមែងមានសមភាពនៅចំពោះមុខនៃទុក្ខដូចគ្នារៀង
រាល់រូប ហើយខុសគ្នាតែត្រង់កុសលដែលបានកសាងរួចមកហើយនោះ
ឬដែលខ្លួនកសាងច្រើន ឬតិច ។

ព្រះពុទ្ធសាសនា ប្រដៅទាំងព្រះមហាក្សត្រិយ៍ ទាំងប្រជាពស្ត្រ
ឲ្យស្គាល់ទូវចរិយាសុភាពនឹងការទុនលំទោន ចំពោះសត្វទ្លាឡ ។ ជន
ណាដែលប្រទេសជាតិលើកតម្កើងទៅជាក់ក្នុងហានដ៏ខ្ពង់ខ្ពស់ជននោះត្រូវ
តែបានបំពេញនឹងចេះបំពេញករណីយកិច្ចនឹងពលីកម្ម ឲ្យសមរម្យនឹង
ហានៈដែលខ្លួនឡើងទៅកាន់នោះ ។ ព្រះពុទ្ធសាសនាប្រដៅយើងឲ្យចេះ
អត់ទុនគ្នា កុំឲ្យបៀតបៀនជីវិតសិទ្ធិ នឹងកោតទ្រព្យ របស់អ្នកដទៃ
ជាស់តឿនឲ្យយើងមានសាមគ្គី ចូលចិត្តយកអាសាគេ មានចិត្តសប្បុរស

ឧស្សាហ៍ធ្វើបុណ្យទានផង ។

ព្រះមានព្រះភាគនៅវេលាដែលព្រះអង្គបានត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ ព្រះអង្គបានជ្រាបច្បាស់នូវផ្លូវដែលនាំទៅកាន់សេចក្តីសុខ មានព្រះនិព្វានជាទីបំផុត ។ ព្រះអង្គបានសម្ពែងអំពីដំណើរសៅហ្មងទាំងឡាយដែលនាំឲ្យកើតសេចក្តីទុក្ខ ។ ប៉ើចង់បានសេចក្តីសុខសេចក្តីចំរើនត្រូវតែទំបំបាត់នូវ អាសវៈ ទាំងនោះឲ្យអស់ពីខន្ធសន្ពានចេញ ។

សម្ពេចព្រះលោកនាថសាស្តា បានសំដែងថា

សចេ ហ្វំ ហ្វេន ពន្ធតិ

ឥុតោ ហ្វេស្ស អន្ទោ ឥាវិស្ស្សតិ

ប៉ើគេតបពៀរដោយពៀរ កាលណាទៅ នឹងបានជល់ទីបំផុតនៃពៀរ?

អក្កោច្ឆិ មំ អវធិ មំ អជិនិ មំ អហាសិ មេ

យេ ច តំ ឧបនយ្ហន្តិ តេសំ ហ្វំ ន សម្មតិ ។

ន ហិ ហ្វេន ហ្វាន៉ិ សមន្តីធ ឥុធាចនំ

អហ្វេន ច សម្មន្តិ ឯស ធម្មោ សនន្តនោ ។

អ្នកឯនោះ បានដេរយើង បានវាយយើង បានផ្ទាញ់យើង អ្នកណាមានគំនិត ចងពៀរជូចេ ពៀរនៃអ្នកនោះ មិនស្ងប់ទេ ព្រោះតាំងពីកាលណា ។ មក ពៀរមិនដែលរម្ងាប់បាន ដោយពៀរទ្បើយ ពៀរតែងរម្ងាប់បាន ដោយការមិនចងពៀរ គឺមេត្តា នេះជាធម៌នៃបោរាណបណ្ឌិត ។

អក្កោធេន ជិនេ ក្កោធំ អសាធុំ សាធុនា ជិនេ

ដ៉ៃ ឥឥ៉ៃ ឧាឃៃ សៃ ឧាល៉ឥ៉ៃ ។

ឥតោ (បណ្ឌ៉ាតេហ៉ា បដ៉ិបជ្ជនតោ) សម្ម៉ន្ត៉ិ មេធតា ។

បុត្តលឈ្នះមនុស្សក្រោធ ដោយមិនក្រោធតប, ឈ្នះមនុស្ស អសប្ប្យរស ដោយប្រព្រឹត្តសប្ប្យរសរក, ឈ្នះមនុស្សកំណាញ់ស្ទិត ដោយ អំណោយ, ឈ្នះមនុស្សកុហកដោយពាក្យសត្យ ។ (ជំលោះពំនឡាយ រមែងស្ទប់ពៅបាន ព្រោះការប្រតិបត្តិតាមញ្ញកបណ្ឌិតនោះ) ។

ជយំ រ៉ៃ បសវ៉ត៉ិ ឧក្ឃ៉ំ សេត៉ិ បរាជ៉ិតោ

ឧបសន្តោ សុឧំ សេត៉ិ ហ៉ិត្វា ជយបរាជយំ

អ្នកឈ្នះរមែងសោយពៀរ, អ្នកចាញ់រមែងដេកកើតទុក្ខ, អ្នកលះ បង់ពំនាការឈ្នះនឹងការចាញ់ រមែងដេកនៅជាសុខ ។

យោ បរំ ឧបយាតេត៉ិ សោ បដ៉ិ ឧបយាតឧំ

បដ៉ិលភ៉ត៉ិ ជយំ អ. រជ៉ិយត៉ិ ជយាជយំ

បជហ៉ត៉ិ ឌ៉ីរោ ។

អ្នកសម្ទាប់គេ តែងត្រូវគេសម្ទាប់វិញ; អ្នកឈ្នះគេ តែងត្រូវគេ ឈ្នះវិញ; អ្នកប្រាជ្ញតែងលះបង់ទូវជំនះនឹងបំណាញ់ ។

យេ មេ ឧក្ឃ៉ំ ឧបហ៉ន្ត៉ិ យេ ច ឧេន្ត៉ិ មម សុឧំ

សព្វេសំ សមតោ ហោត៉ិ ឧយា តោតោ ឧវ៉ជ្ជត៉ិ ។

សុឧឧក្ឃ៉ា តុលាភ្ទតោ យសេសុ អយសេសុ ច

សព្វត្ត សមតោ ហោម៉ិ ឯសា មេ ឧបេក្ឃា ចារម៉ី ។

អ្នកណាធ្វើទុក្ខតថាគត អ្នកណាឲ្យសុខតថាគត តថាគតបិតនៅក្នុង

ទបេក្ខាចំពោះអ្នកនោះដូចគ្នា តថាគតមិនលំអៀង តថាគតមិនចងពៀរ
តថាគតបិតនៅក្នុងទបេក្ខាចំពោះសុខនឹងទុក្ខ តថាគតបិតនៅក្នុងទបេក្ខា
ចំពោះយសនឹងឥតយសដូចគ្នា នេះហើយជាទបេក្ខាបារមីរបស់តថាគត ។

ឥទំ ខោ បន ភិក្ខវេ ទុក្ខំ អរ៉យសច្ចំ ជាតិបិ ទុក្ខា
ជរាបិ ទុក្ខា មរណម្ប៉ ទុក្ខំ បិយេហិ វិប្ប យោគោ ទុក្ខោ ។

ឥទំ ខោ បន ភិក្ខវេ ទុក្ខសមុទយោ អរ៉យសច្ចំ
ភាមតណ្ហា ភវតណ្ហា វិភវតណ្ហា ។

ឥទំ ខោ បន ភិក្ខវេ ទុក្ខនិរោធោ អរ៉យសច្ចំ យោ
តស្សាយេវ តណ្ហាយ អសេសវិរាគនិរោធោ ចាគោ
បដិនិស្សគ្គោ មុត្តិ អនាលយោតិ ភតរា អនេសេសិ ។

ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា: ម្នាលភិក្ខុទាំងឡាយ! នេះទុក្ខអរ៉យ-
សច្ច គឺជាតិទុក្ខ ជរាទុក្ខ មរណទុក្ខ ការព្រាត់ប្រាសចាកសត្វនឹងសង្ខារ
ជាទីស្រឡាញ់ក៏ជាទុក្ខ ។ នេះទុក្ខ សមុទយអរ៉យសច្ច គឺកាមតណ្ហា
ភវតណ្ហា វិភវតណ្ហា ។ នេះទុក្ខនិរោធអរ៉យច្ច គឺការអស់ទៅនៃតណ្ហា
គឺការរំលត់មិនសេសសល់នៃតណ្ហាទាំងនោះ ។

ឱ្យុព្រះករុណា-ឱ្យុ សុំយកព្រះពុទ្ធកាសិតមួយទៀតមកសំដែងក្នុងទី
នេះ មានសេចក្តីថា

សុខកាមានិ ភូតានិ យោ ទណ្ឌេន វិហឺសតិ
អត្តនោ សុខមេសានោ បេច្ច សោ ន លភតេ សុខំ ។
សុខកាមានិ ភូតានិ យោ ទណ្ឌេន ន ហឺសតិ

អត្តជោ សុខមេសាជោ . បេច្ច សោ លភតេ សុខំ ។

សត្វតំណឡាយសុទ្ធតែប្រាថ្នាសេចក្តីសុខ អ្នកណាស្វែងរកសុខ ដើម្បីខ្លួន ហើយបៀតបៀនគេដោយអាជ្ញា គឺប្រើកម្ចាំង ប្រើយសស័ក្តិ សម្បត្តិ ឬអាវុធ អ្នកនោះរមែងមិនបានសុខទៅមុខទេ ។ សត្វតំណ-ឡាយសុទ្ធតែប្រាថ្នាសេចក្តីសុខ អ្នកណាស្វែងរកសុខដើម្បីខ្លួន ហើយ មិនបៀតបៀនគេដោយអាជ្ញាទេ អ្នកនោះតែងបានសុខទៅមុខប្រាកដ ។

មានប្រទេសជាច្រើន នៅក្នុងសកលលោក ដែលប្រកបដោយ លោភៈទោសៈមោហៈ គឺបានធ្វើបំពារបំពាន់ពុទ្ធោវាទដ៏ល្អសំខាន់តំណនេះ ដែលប្រទេសកម្ពុជាបានខិតខំប្រព្រឹត្តកាន់តាមយ៉ាងមាំមួន ។

កាលពីសម័យមុន ប្រទេសកម្ពុជាបានរងគ្រោះ ដោយសារតែកាន់ ចិត្តអត់ឧនប្រាសចាកសេចក្តីប្រាថ្នា ហើយយកអាសាក្នុងការរិះរកសន្តិ-សុខ ជូនលោកសន្ទិវាស ។ សព្វថ្ងៃនេះទៀត ប្រទេសយើងបានពើប ប្រទះនឹងការប្រលោមលោកមកជ្រៀតបៀត តំណាងក្នុង តំណាងក្រៅ ដែនស័មាដែរ ។

ត្បូរឲ្យវេទនាចិត្តណាស់ ពីព្រោះក្នុងបច្ចុប្បន្នកាលនេះ មានមារមក ជ្រៀតជ្រែកពិភពលោក បណ្តាលឲ្យអ្នកត្រួតត្រាប្រទេសខ្ចះលែងស្គាល់ផ្ទូវ ល្អ ហើយនឹងអាចធ្វើឲ្យសត្វលោកទទួលរងទុក្ខទោសពុំខាន ។

សូមឬទ្ធានុភាពនៃព្រះពុទ្ធសាសនា ដែលមានអាយុបាន ២៥០០ វស្សាហើយ នឹងសេចក្តីជ្រះថ្លារបស់ពពួកពុទ្ធបរិស័ទរាប់រយលាននាក់ ជួយតម្រង់ចិត្តលោក . អ្នកទទួលខុសត្រូវក្នុងការគ្រប់គ្រងប្រជាពលរដ្ឋឲ្យ

ស្គាល់ការណ៉ៃយកិច្ចនៃមនុស្ស ដើម្បីសន្តិសុខ ។

សូមឥទ្ធានុភាពនៃព្រះពុទ្ធសាសនា នឹងសេចក្តីជ្រះថ្លាបេស់ពុទ្ធបរិស័ទទាំងអស់ ជួយកំចាត់បំបាត់សេចក្តីលោភ ឲ្យអស់ពីខន្ធសន្តាននៃសត្វលោក ។

សូមព្រះគេជានុភាពនៃព្រះកតវន្តមុនីសា ស្តាមេត្តាជួយស្រោចស្រង់តម្រង់ចិត្តមនុស្សសត្វទាំងឡាយ ឲ្យគោរពប្រតិបត្តិតាមគន្ធងព្រះសុធម្ម ហើយជួយសួយលោកសន្ធិវាសឲ្យបានជួបប្រទះតែនឹងសេចក្តីសុខ នឹងសេចក្តីចំរើនជានិច្ចនៅនាអនាគតកាល ។

សម្តេចព្រះទបយុវរាជទ្រង់ថ្វែងព្រះរាជសុន្ធរកថាចប់ ពួកមន្ត្រីធំតូចទបាសក-ទបាសិកា ក្នេងចាស់ទះដៃអរសាទរជាយ៉ាងក្រៃលែង ។

រួចទើបគណៈប្រតិភូបរទេស បានថ្វែងនូវសារលិខិតម្នាក់ម្តង ៥ នាទីម្នាក់ ជូចរៀបរាប់តទៅនេះ:

ទី ១ ប្រតិភូប្រទេសអូស្ត្រាលី

ទី ២ " " ភូមា

ទី ៣ " " សេរីលង្កា

ទី ៤ " " អាមេរិក

ទី ៥ " " បាកំង

ទី ៦ " " អង់គ្លេស

ទី ៧ " " ឥណ្ឌៀ

ទី ៨ " " ជប៉ុន

ទី ៩ " " លាវ

ទី ១០ " " ម៉ាឡេស៊ី

ទី ១១ " " ថៃឡង់

ទី ១២ " " វៀតណាមខាងជើង

ទី ១៣ " " វៀតណាមខាងត្បូង ។

សូមស្រង់យកសារលិខិតនៃគណៈប្រតិភូប្រទេសទាំងនោះមកចុះជូនលោក-អ្នកអានដូចតទៅនេះ ៖-

សារលិខិតនៃប្រតិភូរដ្ឋភិបាលកុម្ម៉ង់ទ៉ាល់អូស្ត្រាលី

សូមក្រាបបង្គំទូលព្រះករុណាជាអម្ចាស់ជីវិតលើត្បូង !

សូមក្រាបថ្វាយបង្គំសម្តេច ឧត្តមព្រះថេរានុត្តរៈទាំងឡាយ,

សូមទូលទ្រង់ សូមជំរាបឯកឧត្តមអស់លោកអ្នកទាំងឡាយ !

ថ្ងៃនេះខ្ញុំមានបុព្វសិទ្ធិដ៏ធំ ឧត្តមកិត្តិយស ក្នុងឋានៈជាប្រតិភូនៃរដ្ឋាភិបាលកុម្ម៉ង់ទ៉ាល់ប្រទេសអូស្ត្រាលី ចូលរួមក្នុងពិធីបុណ្យ ព.ស. គម្រប់ ២៥០០ ព្រះវស្សា ។ ដូចសេចក្តីខ្ញុំទូលព្រះបង្គំមានកិច្ចការណ៍ជាកិច្ចដំបូង ត្រូវថ្វាយចំពោះព្រះករុណាជាអម្ចាស់ជីវិតលើត្បូងឧត្តមសម្តេចព្រះមហាក្សត្រិយានី ចំពោះសម្តេចព្រះនរោត្តមសីហនុ ចំពោះរាជរដ្ឋាភិបាលឧត្តមថ្វាយជូនប្រជារាស្ត្រប្រទេសកម្ពុជានូវពរសព្វសាធុការ ដ៏ជាទីគាប់ក្តៅដែលរដ្ឋាភិបាលឧត្តមប្រជារាស្ត្រប្រទេសអូស្ត្រាលីប្រសិទ្ធិឡើង ដើម្បីឲ្យពិធីបុណ្យដ៏ខ្ពង់ខ្ពស់នេះជួបប្រទះនឹងជោគជ័យដ៏ប្រសើរពេញលេញ ។

សម្តេចបានទ្រង់ស្រាប់ហើយថា ប្រទេសអូស្ត្រាលីមិនមែនជាប្រទេសកាន់ព្រះពុទ្ធសាសនាតាំងអស់ទេ ។ តួនប្រទេសរបស់យើងខ្ញុំព្រះអង្គ មានអ្នកកាន់ព្រះពុទ្ធសាសនាស្ទួចស្តើងណាស់ ។

សេចក្តីអញ្ជើញដ៏ជាទីគោរពរបស់ព្រះអង្គចំពោះប្រទេសអូស្ត្រាលីសុំឲ្យបញ្ជូនអ្នកតំណាងមកកាន់តាំងពិធីបុណ្យនេះ ហើយនឹងគាទទួលដោយប្រញាប់ប្រញាល់នៃយើងខ្ញុំទូលបង្គំ មិនមែនបណ្តាលមកតែពីដំនឿខាងព្រះពុទ្ធសាសនាទេ គឺបណ្តាលមកពីមិត្តភាពដ៏ជ្រាលជ្រៅ នឹងសេចក្តីគោរពគ្នាសឹងវិញទៅមក ដែលកំពុងកើតមានរវាងប្រទេសឯកពន្ធដ៏ពិតប្រាកដទាំងពីរ ព្រមទាំងជាប្រទេសដែលស៊ូបូរនឹងបោគុំនៃសេរីភាពសម្រាប់ប្រតិបត្តិការអន្តរជាតិ សន្តិភាពនឹងយុត្តិធម៌ផង ។

គឺដោយអាស្រ័យគំនិតទាំងនេះហើយទើបប្រទេសអូស្ត្រាលី មានសេចក្តីក្តែងក្តួលដ៏ជ្រាលជ្រៅចូលមករួមរួមក្នុងពិធីបុណ្យនេះ ដែលមានន័យខាងសាសនាដ៏យ៉ាងខ្លាំងស់ ចំពោះព្រះពុទ្ធសាសនិកជនក្រុមតូចក្នុងប្រទេសជាមិត្តដ៏ខ្ពង់ខ្ពស់ទាំងឡាយនៃយើងខ្ញុំទូលបង្គំ ក្នុងខ្លួនអាស៊ីហើយជាពិធីបុណ្យដែលទាក់ទងអាត្មាដ៏ជិតស្និទ្ធដល់ដីតែប្រយោគស្តួចស្តើង ។ តាមរយៈអាស្រ័យគំនិតដ៏ល្អយើញយ៉ាងដូច្នេះដែរ ទើបយើងខ្ញុំទូលបង្គំសូមប្រសិទ្ធិពរក្នុងថ្ងៃនេះ នូវព្រះសព្វញ្ញុតាធុតាដើម្បីឲ្យគាត់ជួយជំរុញទ្រទ្រង់ដល់ការចម្រើនដ៏ល្អប្រសើរនៃពិធីបុណ្យនេះ ទាំងដើម្បីសេចក្តីថ្កើងថ្កានឹងវឌ្ឍនភាព ទាំងខាងផ្លូវចិត្ត ទាំងខាងសម្ភារៈដល់ព្រះពុទ្ធសាសនិកជនក្រុមតូចក្នុងប្រទេសនេះ ។

× × ×

សារលិខិតនៃលោក ឌុ-ឌាក-ស

រដ្ឋមន្ត្រីក្រសួងធម្មការប្រតិភូនៃប្រទេសភូមា

សូមពិតពុទ្ធដីកាសម្តេចសង្ឆនាយកទាំងពីរព្រះអង្គ និងព្រះថេរានុ-ត្ថេរៈទាំងឡាយ,

សូមទូលព្រះករុណាទាំងពីរព្រះអង្គ និងសម្តេចព្រះឧបយុវរាជ,

សូមជំរាបនាមឹនសព្ទមុខមន្ត្រី និងប្រជាជនវ៉ខ្មរត្រប់រូប,

សូមទានជ្រាប សូមជ្រាប ។

បុណ្យពុទ្ធជយន្តិ ២៥០០ ព្រះវស្សាដីឧឡារិកនេះ មានសម្តេចសង្ឆនាយកទាំងពីរព្រះអង្គ, ព្រះករុណាទាំងពីរព្រះអង្គ, សម្តេចព្រះឧបយុវរាជ, នាមឹនសព្ទមុខមន្ត្រី និងលោកអ្នកសាធុសប្ប្ញរសទាំងឡាយ ព្រមទាំងតណៈប្រតិភូជាច្រើនប្រទេសបានមកជួបជុំក្នុងទីនេះទាំងអស់ ។ ពេលនេះ ខ្ញុំព្រះករុណាទូលបង្គំ ខ្ញុំបាទ ជាតំណាងនៃប្រទេសសហភាពភូមា មានសេចក្តីត្រេកអរយ៉ាងក្រៃលែង ដោយបានមកជួបជុំក្នុងទីនេះ និងសូមថ្វែងសុន្ទរកថា ដូចមានតទៅនេះ:

បុណ្យពុទ្ធជយន្តិ ព្រមទាំងកិច្ចធ្វើធដ្ឋសង្ឋាយនា ប្រទេសភូមាបានរៀបចំធ្វើរួចចប់សព្ទត្រប់អស់ហើយ យើងខ្ញុំជឿជាក់ថា តទៅអនាគតព្រះពុទ្ធសាសនានឹងរុងរឿងផ្សាយចេញាទៅ កាន់ប្រទេសក្នុងលោកទាំងមូល និងបិតនៅអស់កាលជាយូរឆ្នាំមិនខាន ។

នៅពេលបុណ្យពុទ្ធជយន្តិនេះ រដ្ឋាភិបាលភូមាសូមថ្វាយនូវព្រះត្រៃបិដកមួយចប់ដ៏ពិសេសដែលបានជ្រះពុម្ពជាថ្មីក្នុងសម័យធដ្ឋសង្ឋាយនានោះ

ចំពោះព្រះកុណាព្រះមហាក្សត្រិយ៍នៃប្រទេសកម្ពុជា ។

ប្រទេសកម្ពុជានឹងប្រទេសភូមា ពិតមែននៅឆ្ងាយដាច់ដោយឡែកពីគ្នា ប៉ុន្តែប្រទេសទាំងពីរនេះគាន់ព្រះពុទ្ធសាសនាផ្នែកខាងថេរវាទដូចគ្នា បានបងស្ថានមេត្រីជាមួយគ្នាយ៉ាងមាំមួន ហាក់ដូចជាបងប្អូនបង្កើត ថែមទាំងអារ្យធម៌ សីលធម៌ ក៏ដូចគ្នាច្រើនណាស់ ។

ប្រជាជននៅប្រទេសកម្ពុជាទាំងមូលជាអ្នកជឿគាន់ដោយខ្លាប់ខ្ជួនខ្ជូនព្រះពុទ្ធសាសនា ដែលគេតាប់ថាជាសាសនារបស់រដ្ឋ ។ អាស្រ័យហេតុនេះ, ប្រទេសភូមា នឹងប្រទេសកម្ពុជា មានសេចក្តីភក្តីគាន់ស្រឡាញ់គ្នាទៅវិញទៅមក ជាមិត្តដ៏ខ្ជិតខ្ជាប់ស្រុកថ្លោះធម៌ ។

សម័យបុណ្យទង្គស្តាយនាទៅប្រទេសភូមា សម្តេចព្រះមហាសុមេធាធិបតី នឹងព្រះថេរាខុនត្តរ សម្តេចព្រះឧបយុរាជគាលទ្រង់នៅគ្រងរាជ្យទៅឡើយ នាយករដ្ឋមន្ត្រី ព្រមទាំងទាហានទាសកទាសិកាជាតិខ្មែរជាច្រើនរូប បានឧទ្ទិសកុសលយាន បានអញ្ជើញទៅជួបជុំដង្ហែរបត្តមួដើម្បីឱ្យតំណពូជបុណ្យនោះបានរុងរឿងជានិច្ចតរៀងទៅ ។ ពេលនេះ ដល់បុណ្យពុទ្ធជយន្តី ២៥០០ ក្រោយស្លាប់នៅប្រទេសកម្ពុជា ប្រទេសសហការតម្លាក់បានបញ្ជូនតំណាងប្រតិភូមួយក្រុម ព្រមទាំងរូបថ្មីក្រនេះ ចូលរួមធ្វើពិធីនេះមកដង្ហែជុំវិញតែដើម្បីបុណ្យ នៅឱ្យបានថ្កុំថ្កើងដ៏ធំធេងតរៀងទៅ ។

ប្រទេសភូមា នឹងប្រទេសកម្ពុជា ដែលតាប់ថ្លែងទង្គស្តាយនាទឹងបុណ្យពុទ្ធជយន្តីឆ្នាំ[illegible]

ប្រសិនបើយើងមិនបានទាន់ព្រះពុទ្ធសាសនា យើងក៏មិនអាចធ្លីមធ្វើបុណ្យ
ទាំងពីរបែបនេះបានឡើយ ។ បុគ្គលទាំងឡាយដែលបានជួបធ្វើបុណ្យ
ទាំងពីរបែបនេះ ឈ្មោះថាមានកុសលមានបារមីដែលបានបំពេញមក
ជាច្រើនឆ្នាំគ្រប់ៗគ្នា ។ បុណ្យកុសលផ្នែកខាងព្រះពុទ្ធសាសនានឹង
ពាហិរសាសនាអាចទទួលលទ្ធផលផ្សេងពីគ្នា, បុណ្យកុសលខាងព្រះពុទ្ធ
សាសនាអាចទទួលផលដ៏ច្រើន ប្រៀបដូចជាបុគ្គលធ្វើស្រែនឹងដាំដំណាំ
លើដីដែលមានជីជាតិល្អ ។

ព្រោះហេតុនេះ កាលបើយើងធ្វើកាន់រាប់អានព្រះពុទ្ធសាសនា
ជូច្នេះហើយ យើងកុំភ្លេច ហើយកុំធ្វេសប្រហែស ត្រូវតែព្យាយាមប្រតិបត្តិ
ធ្វើទាន-សីល-ភាវនា ឲ្យបានជាប់ជានិច្ច ដើម្បីឲ្យបានសម្រេចមគ្គផល
ហូតផល់ព្រះនិព្វានគ្រប់ ៗ គ្នា ។

នៅទីបំផុតនេះ សូមឲ្យប្រទេសកម្ពុជា នឹងប្រទេសភូមាមានមិត្តកាព
យាំងមាំមួន ប្រកបដោយសម្បុណ៌កាព នឹងសូមឲ្យព្រះពុទ្ធសាសនា
បានរុងរឿងផ្សាយចេញទៅប្រទេសក្នុងសកលលោក មានរស្មីភ្លឺជូចជា
ព្រះអាទិត្យនឹងព្រះចន្ទ ជាយូរអង្វែងតទៅ កុំបីឃ្លៀងឃ្លាតឡើយ ។

× × ×

សង្ក្ថានៃប្រតិភូប្រទេសសេរីលង្ក្ថា

ខ្ញុំមានសេចក្តីរីកាយជាអនេក នឹងបញ្ជូនសារភាតរភាពនឹងសុធន្ទ:

នេះ ចំពោះពុទ្ធសាសនិកជនទៃប្រទេសកម្ពុជា នៅអស់លក្ខិតសម័យនៃពិធីបុណ្យ គម្រប់ ២.៥០០ព្រះវស្សានៃព្រះពុទ្ធសាសនា ។

នៅឯគោះសេរីលង្កា យើងយកនៃ១សកា ១៩៥៦ - នៃ១សកា ១៩៥៧ ពុកជាឆ្នាំនៃពុទ្ធជយន្តិ ហើយយើងបានមានកិត្តិយសធំណាស់ដោយគាលពីក្នុងខែកុម្ភៈ ១៩៥៧ បានតណៈប្រតិភូនៃប្រទេសកម្ពុជាដែលមានសម្តេច ព្រះនរោត្តម សីហនុ ជារដ្ឋមន្ត្រីទី ១ របស់លោក-អ្នកស្តេចយាងមកចូលរួមជាមួយនឹងយើងនោះ ។

ពេលនោះ មិនត្រឹមតែបាត់ពុកជាឧកាសបុណ្យប៉ុណ្ណោះទេ គឺបាត់ពុកជាឧកាសធ្វើឲ្យចំរើនបម្លែងនូវមណ្ឌលបណ្តាលដល់ដួងវិញ្ញាណរបស់យើងទាំងឡាយទៀតទាងផ្លូវសាសនា ទូរមហាឧត្តមគតិ ដែលព្រះបរមគ្រូសម្តេចរបស់យើងបានទ្រង់ប្រៀនប្រដៅដល់យើងទាំងឡាយនោះ ។ ក្តៅម៉ត់ក៏ដំណាអនេកដែលព្រះសម្តេចបានទ្រង់ប្រទានមកនេះ បាត់ពុកជាព្រះឱវាទដែលសព្វថ្ងៃនេះមានប្រជាពស្ត្រទាំងឡាយក្នុងលោកសន្និវាសទាំងទាងបូពាទិសទាំងទាងបស្ចិមទិសកំពុងប្រតិបត្តិតាម ។

ប្រសិនបើគេចោលក្នែកក្រៃឡែកមើលទៅពិភពលោកសម័យនេះគេនឹងឃើញច្បាស់ថាបណ្តាវឌ្ឍនភាពនៃវិទ្យាសាស្ត្រ ទំនាក់ទងគ្នាយើញវិជ្ជាសម័យពិភពលោកកំពុងស្ថិតនៅក្នុងការប៉ះគ្នាទំនងសេចក្តីតានតឹង; ការប្រៀនប្រដៅដួងវិញ្ញាណ ឲ្យបានប្រសើរជួចជាការប្រៀនប្រដៅនៃសម្តេចព្រះបរមគ្រូសម្តេច អាចទំនងឲ្យមានការរំដោះពុកផ្លូវស្រាលដល់ប្រជាពស្ត្រទាំងឡាយ ដែលសព្វថ្ងៃកំពុងស្ថិតនៅក្នុងសេចក្តីទុក្ខនោះបាន ។

ការប្រៀនប្រដៅឲ្យមានសមានចិត្តខ្ពស់ឲ្យមានមិត្តភាព, ការប្រៀនប្រដៅឲ្យមានការស្អាប់គ្នាទន់រយោតរយល់គ្នាទៅវិញទៅមក ឯទាត់ទុកជាទក្ខមគតិដ៏ប្រសើរក្លាស់ខ្ពស់ ដែលព្រះសម្ពុទ្ធបានទ្រង់ប្រទានប្រៀនប្រដៅពុកមកចំនួន ២.៥០០ឆ្នាំ ហើយនេះ ។

មែនពិត, ដែលយើងជួបប្រទះនឹងស្ថានការណ៍ដ៏តានតឹងនៅបច្ចុប្បន្នកាលនេះ មិនមែនបណ្តាលមកពីសេចក្តីកន្តប្រឡំនៃព្រះពុទ្ធសាសនានោះទេ តែមកតែពីការក្វេងប្រតិបត្តិតាមព្រះធម្មវិន័យតែប៉ុណ្ណោះឯង ។

ដូច្នេះ នៅឱកាសដែលយើងធ្វើបុណ្យត្រង់គ្នានេះ គួរតែយើងរំលឹកឡើងវិញនូវទក្ខមគតិដ៏ប្រសើរបស់ព្រះបរមគ្រូសម្ពុទ្ធយើង គួរតែយើងសម្រេចចិត្តថា ត្រូវតែអបរំ "អត្តា" ដើម្បីទូន្មានចិត្តរបស់យើង ។ ដែលពួកមាមីកជនទាំងឡាយ ក្នុងព័ត៌មានណាគាំងអូសបានធ្វើបុណ្យពុទ្ធជយន្តិនេះ គឺដើម្បីសំដែងកតវេទិតាធម៌ ហើយនឹងកិត្តិយសចំពោះព្រះបរមគ្រូសម្ពុទ្ធ ។

បុណ្យនេះ នឹងពន្យារពេលតទៅអនាគត ឲ្យតម្កល់ពុទ្ធសាសនាដែលត្រូវសម្រេចដ៏ពិតប្រាកដ ដោយការរួបរួមយ៉ាងជាក់ច្បាស់នៃសាសនានេះជាមួយនឹងជីវភាពនៃមនុស្សលោកដោយពិត ។ ពិធីបុណ្យនេះ ជាសេចក្តីគោរពយ៉ាងប្រសើរបំផុត ដែលយើងបូជាចំពោះព្រះបរមគ្រូសម្ពុទ្ធរបស់យើង ។ ព្រះអង្គបានទ្រង់ទេសនាថា ការប្រតិបត្តិព្រះពុទ្ធសាសនាគឺជាកតវេទិតាដ៏ខ្ពង់ខ្ពស់បំផុត ដែលពួកពុទ្ធបរិស័ទសំដែងចំពោះព្រះអង្គ ។

ព្រះពុទ្ធសាសនាទុកជាវត្ថុពិសេសដែលចង់ប្រទេសយើងតាំងពីឲ្យ

ប្រមូគ្នា ហើយប្រវត្តិសាស្ត្រក៏ចាត់ទុកនូវកាលបរិច្ឆេទនៃការឆ្លើងដំណើរ នៃសមណទូតរាល់ប្រទេសយើងទាំងពីរផង ។ ខ្ញុំជឿជាក់ថា ការឆ្លើងពិធីពុទ្ធជយន្តិនេះ នឹងបន្ថែមកំភ្លាំងរៃលើសុឆន្ទៈនៃប្រជាពលរដ្ឋយើងទាំងពីរ ហើយនឹងបណ្តុះបណ្តាលឲ្យកាន់តែចំរើនឡើងនូវមិត្តភាពដែលយើងបានចិញ្ចឹមទុកក្នុងដួងចិត្ត របស់យើងទាំងអស់គ្នានោះ ។

× × ×

សារលិខិតនៃលោក ក.វ.ស្រ្តែម ឯកអគ្គរដ្ឋទូត នៃស.ស.អា. ប្រចាំប្រទេសកម្ពុជា ជូនព្រះមហាក្សត្រ ទឹងព្រះមហាក្សត្រិយានី នៃប្រទេសកម្ពុជា

សូមក្រាបថ្វាយបង្គំក្រាមល្អដងព្រះបាទ ដោយទូលព្រះបង្គំបានឃើញច្បាស់ទឹងក្តែកនូវន័យដ៏ជ្រាលជ្រៅខាងផ្លូវសាសនា នៃពិធីទាំងឡាយដែលមានធ្វើក្នុងបុណ្យនេះ, ទូលព្រះបង្គំសូមនមស្សការសើរចំពោះព្រះកុណាទាំងពីរព្រះអង្គទឹងព្រះពាជបុត្រដ៏ឆ្នើមរបស់ព្រះអង្គទៀតគឺសម្តេចព្រះបរមឃុវពាជនពោធិមស័ហនុនាយកវង្សមន្ត្រី ដែលជាអ្នកទទួលភារកិច្ចពិធីបុណ្យនេះឲ្យបានសម្រេចត្រប់យ៉ាង ។ ពិធីទាំងនេះប្រាកដជាបានលើកបុប្ផាតិត្តិនាមនៃប្រទេសកម្ពុជាបានយ៉ាងខ្ពស់កងពិភពលោក ដោយបានបង្ហាញឲ្យឃើញយ៉ាងជាក់ច្បាស់ នូវគុណសម្បត្តិខាងពុទ្ធសាសនានៃប្រទេសនេះ ទឹងការស្រឡាញ់ប្រតិព័ទ្ធដ៏ស្មោះស្ម័គ្រនៃប្រទេសនេះ ចំពោះសន្តិភាពពិភពលោកជួបយើងខ្ញុំត្រប់ៗគ្នាដែរ ។

× × ×

សារលិខិតនៃលោកពីយែរគស្ប្ស ឯកអគ្គរដ្ឋទូត
នៃប្រទេសបារាំងប្រចាំប្រទេសកម្ពុជា

ដោយរដ្ឋាភិបាលសាធារណរដ្ឋបានតាត់តាំង ដើម្បីតំណាងរដ្ឋនេះក្នុងពិធីបុណ្យ ព.ស.២.៥០០ ជាមួយនឹងលោកហ៊ូស្ស៊ីយ៉ូហ្គត់, សង្ឃាធិការនៃអនុវិទ្យាល័យប្រទេសបារាំង ខ្ញុំព្រះករុណា, ខ្ញុំបាទសូមបញ្ជាក់ថា ប្រទេសបារាំងសូមចូលមករួបរួមជាមួយមុំងមាត់ដោយមេត្រីភាព នឹងព្រះតេជព្រះគុណ, ទ្រង់, លោកអ្នកដែលកំពុងធ្វើពិធីបុណ្យ ព.ស.២.៥០០ ក្នុងថ្ងៃនេះ, ព្រមទាំងមានបំណងចង់បង្ហាញឲ្យឃើញជាក់ស្តែងនូវសេចក្តីសន្តោសសប្បុរសធម៌ នឹងសន្តិភាពដែលជាលំនៅគោលនៃព្រះពុទ្ធសាសនានោះ ។

ក្នុងពេលដែលជីវភាពសកលលោកមានមធ្យោបាយប្រកបដោយវិនាសកម្មកាន់តែមានសភាពខ្លាំងក្លាឡើង អាចធ្វើឲ្យដំណើរមនុស្សជាតិឆ្ពោះទៅក្នុងភាពងងឹតយ៉ាងច្រើនមហិមា, យើងប្រាថ្នាត្រូវបង្ហាញជាយ៉ាងខ្លាំងនូវដំណឹងដែលប្រជាជនដោយភាគច្រើន បានឥតឈប់ឈរកក្អកដោយខ្លាចញាប់ញ័រ នូវគុណធម៌របស់មនុស្សជាតិដ៏ប្រពៃ ។

ពីអតីតកាលមានចិត្តបុរសជាតិបានកំណត់ថានោះគឺថា វិជ្ជាគ្មានសម្បជញ្ញៈនាំឲ្យវិនាសដល់ខ្លួនទេ ។ តាំពីអតីតកាល ប្រទេសបារាំងនេះឯងដែលគេទុកជាកន្លែងស្តុតាងជាយ៉ាងជាក់ស្តែងនៃតម្លៃក្នុងការតស៊ូ នឹងកំឡាំងជំរុញដ៏ខ្លាំងក្លាដើម្បីជាទីគោរពដល់បុគ្គលិកលក្ខណៈមនុស្សជាតិ នឹងសន្តិភាព ។ សេចក្តីថ្លៃថ្នូរដ៏ប្រសើរនៃមនុស្ស ជាមូលដ្ឋានរបស់ចិត្ត

សប្បុរស បញ្ជាក់ថាត្រូវគេលះបង់នូវលទ្ធិដែលធ្វើបុគ្គលឲ្យទៅជាបរិមាណ
មួយប្រកបដោយអនាមិកបុរ ស្ថិតនៅក្នុងមណ្ឌលសង្គមមានសភាពភាព
សាហាវ អាចបំផ្លាញនូវមនុស្សធម៌ឲ្យសាបសូន្យព្រមទាំងធ្វើឲ្យអន្តរាយ
នូវសេរីភាពក្នុងលោក ។ ប្រទេសខ្ញុំព្រះករុណា ខ្ញុលបង្គំ, ខ្ញុំបាទយល់
ឃើញ តាមសភាពផ្ទុយទៅវិញថា អង្គការនយោបាយ ត្រូវតែស្រោច
ស្រង់នូវការចម្រើនប្រកាន់ទំនៀមទំលាប់ជាតិ, បុរសស្ត្រី គឺជាមនុស្ស
ទីមួយៗមានសិទ្ធិស្រើសរើសផ្លូវសព្វៗខ្លួនដោយសេរី ហើយបុគ្គលិក-
លក្ខណៈទីមួយៗត្រូវហាមជាដាច់ខាតកុំឲ្យប៉ះពាល់សោះឡើយ ដោយ
មានលក្ខណៈជាមូលដ្ឋានសម្រាប់ទ្រទ្រង់នូវបុគ្គលិកលក្ខណៈនេះ ។ ប្រទេស
ជាតិ ដោយយកគោលការណ៍ទាំងនោះជាមូលដ្ឋាន, មានបំណងចង់
ធ្វើសហការនឹងប្រជាជាតិទាំងអស់ដែលមានឆន្ទៈដ៏ល្អ ដើម្បីនឹងស្ថាបនា
លោកមួយដែលជាអសមគតិសង្គម នឹងការសន្ត្រាមចំពោះបងប្អូនសាច់
ឈាមជាមួយគ្នា ត្រូវតែបំផ្លាញឲ្យអស់កុំឲ្យមានសេសសល់ឡើយ ។

ក្រោះហេតុដូច្នេះ ខ្ញុំព្រះករុណា,ខ្ញុលបង្គំខ្ញុំបាទមានចិត្តសោមនស្ស
ជាយ៉ាងក្រៃលែង ក្នុងការនាំដំណឹងមកជំរាបប្រជាពលរដ្ឋខ្មែរដែលកំពុងធ្វើពិធីបុណ្យ
ជាមហាមង្គលទេសន៍ខាងទត្តមប្រាជ្ញាមួយនៃមនុស្សជាតិ ដោយការគោរពព្រមទាំងសេចក្តីជាប់អាន
ប្រជាពលរដ្ឋជាកំពង់ ប្រកបដោយការគោរពដ៏ប្រសើរចំពោះប្រជាពលរដ្ឋខ្មែរ
ដោយមានដំណឹងដ៏ជាមុនមុតចំពោះព្រះបរមគ្រូសម្ពុទ្ធជាម្ចាស់ ព្រមទាំង
បញ្ជាក់នូវសេចក្តីស្នេហាចំពោះសេចក្តីយុត្តិធម៌នឹងសេរីភាព ជាអាសាន ។

x x x

សង្គហលោកប្រាំង ឯកអគ្គរាជទូត
នៃប្រទេសឡាក្រង់ប្រឹតាញប្រចាំប្រទេសកម្ពុជា

ជាសុភមង្គលព្រមទាំងសេចក្តីសោមនស្សដ៏ប្រសើរចំពោះខ្ញុំព្រះ
ករុណា, ទូលបង្ទំ, ខ្ញុំបាទ, ដោយសូមថ្វែងនូវសង្គថា ក្នុងហានៈ ជា
តំណាងផ្ទូវការនៃរាជរដ្ឋាភិបាលព្រះរាជិនីប្រទេសឡាក្រង់ប្រឹតាញ, ក្នុង
ពិធីបុណ្យដ៏ឡាវិកវំលឹកដល់ ព.ស. ២៥០០ ក្រោយដែលព្រះបរមសម្ពុទ្ធ
ចូលកាន់មហាបរិនិព្វានទៅ ដែលជាថ្ងៃគួរចារិកទុកក្នុងប្រវត្តិសាស្ត្រ ។

ព្រះពុទ្ធសាសនាដែលស្រែកអំពាវនាវទៅកាន់ប្រជារាស្ត្រទាំងឡាយ
មិនត្រឹមតែទ្វីបអាស៊ីទេ ថែមទាំងប្រទេសទាំងអស់ក្នុងសកលលោក
ទៀត, បានផ្សាយអានុភាពដ៏សំខាន់ចំពោះជីវភាពរបស់យើងសព្វៗខ្ជួន ។
អានុភាពនោះអាចជួយផ្តល់នូវកំឡាំងដ៏សំខាន់ចំពោះការដោះស្រាយបញ្ហា
នៃលោកសន្និវាស, ក្នុងសម័យបច្ចប្បន្ន ដូចជាព្រះពុទ្ធសាសនាបាន
កំណត់ទុកជាមុននូវតោលការណ៍សន្តិភាពនឹងមហាសប្បុរិសធម៌ជូច្នោះ ។

ការគោរពប្រជារាស្ត្រខ្មែរចំពោះព្រះពុទ្ធសាសនា, គេធ្លាប់បាន
ដឹងបានព្មមកជាយូរអង្វែងណាស់មកហើយ ។ ការសំដែងសាទរភាពក្នុង
ពិធីបុណ្យនេះជាភស្តុតាងជាក់ស្តែងមួយនៃការគោរពនោះ ។ សាទរ-
ភាពក្នុងពិធីបុណ្យនេះ, មនុស្សគ្រប់ជាតិ គ្រប់ពណ៌បានមកក្រេបយក
នូវអត្ថរសគ្រប់ ៗ ត្នា ។ គេបានដឹងថាប្រជារាស្ត្រទាំងអស់នៃប្រទេស
ឡាក្រង់ប្រឹតាញ ដោយភាគច្រើនមានកាន់ត្រិស្តសាសនា ។ តែដោយ
សារគោលការណ៍សន្តោសពេញលក្ខណៈ ចំពោះកិច្ចការខាងសាសនា

ដែលប្រទេសខ្ញុំព្រះករុណា, ខ្ញុំលបង្គំ ខ្ញុំបានបានប្រតិបត្តិតាម, ដូចជា
ពួកពុទ្ធសាសនិកជននៅប្រទេសកម្ពុជា បានប្រព្រឹត្តដែរ, ព្រះពុទ្ធ-
សាសនាក៏បានស្ថិតនៅឯប្រទេសឡាក្រង់ប្រឹតាញជាយ៉ាងមាំមួន ។ មាន
មិត្តភក្តីខ្ញុំព្រះករុណា, ខ្ញុំលបង្គំ, ខ្ញុំបានជាច្រើនគ្នាបាននិយមកាន់ព្រះ
ពុទ្ធសាសនា ហើយនៅពាជនាទីឡុងជ្រ៉ូ, មានសមាគមពុទ្ធសាសនា
មួយមានសកាពជាយ៉ាងធំបំផុត ដែលមានការគេមនាគមន៍ជាយ៉ាងជិតស្និទ្ធ
នៅទីធំអគ្គការពុទ្ធសាសនាទាំងឡាយ នៅអាស៊ីទូបទាំងភូមិភាគឯទៀតនា
ពិភពលោក ។ ក្រោយដែលបានរកឃើញខ្ញុំអក្សរសាស្ត្រភាសាបាលី
ជាវត្ថុសំខាន់ក្នុងបរមសតវត្សទី ១៩ លោកសង្ស្កាចារ្យ ហ្វ្រ៊ស-ដាវីត្ស
រ៉ៃ្សជនអង់គ្លេស ដែលបានសិក្សាព្រះពុទ្ធសាសនានៅប្រទេសស៊ីឡង់
ក៏បានស្ថាបនាសមាគមអក្ខរបទក្នុងលីមួយឯពាជនាទី ឡុងជ្រ៉ូ គ.ស.
១៨៨១, ហើយសមាគមនេះ ក្នុងសម័យបច្ចុប្បន្ន ក៏ស្ថិតនៅជាមជ្ឈ-
មណ្ឌលដ៏សំខាន់ សម្រាប់ឃោសនាផ្សាយចំពោះការស្វែងរកនូវន័យការ
សិក្សាព្រះពុទ្ធសាសនា ។

ខ្ញុំព្រះករុណា, ខ្ញុំលបង្គំ, ខ្ញុំបានមានចិត្តរីករាយមនស្សជាយ៉ាងក្រៃ
លែង, ដោយសូមប្រគេន នូវថ្វាយដូនដំណឹងថាពាជរដ្ឋាភិបាលប្រទេស
ឡាក្រង់ប្រឹតាញបានតំណាត់ទុកជាមុន, ថាក្នុងទសាសដ៏ខ្លីតែនេះនូវ
ឱ្យជាទេយ្យទានមួយចំពោះប្រទេសកម្ពុជានូវសៀវភៅទាំងឡាយ ដែល
សមាគមដូចមានឈ្មោះលើបានបោះពុម្ពផ្សាយ ។

មុននឹងបញ្ចប់ខ្ញុំសង្កត់ថានេះ, ខ្ញុំព្រះករុណា, ខ្ញុំលបង្គំ ខ្ញុំបានមាន

បំណងកន្លងមកខ្ញុំព្រះករុណា, ខ្ញុំសូមថ្កើង, ខ្ញុំបានទំនុកក្តីនឹងមកដល់ឯកឧត្តម, ព្រមទាំងកន្លងមកប្រជាពលរដ្ឋប្រិតទ្ធិក, ទឹងថ្លែងចំពោះពួកដល់ឯកឧត្តមខ្មែរ ទឹងប្រជាពលរដ្ឋខ្មែរ, ខ្ញុំមានសេចក្តីនាប្រកបដោយសមានចិត្តជាយ៉ាងជ្រាលជ្រៅ ទឹងសេចក្តីសរសើរដោយចិត្តស្មោះត្រង់, កន្លងមកសព្វថ្ងៃពិធីបុណ្យរំលឹក ព.ស. ២៤០០ នៃមហាមិនាព្រះបរមសម្តេចជាម្ចាស់, ពិធីបុណ្យដែលជាព្រឹត្តិការណ៍មួយ- ដ៏រុងរឿងក្នុងដីវភាពប្រាជ្ញានៃប្រទេសកម្ពុជាទឹងនាប្រទេសដែលកាន់ព្រះពុទ្ធសាសនាក្នុងសកលលោក ។

× × ×

សារលិខិតនៃបណ្ឌិតគ្រិស្តាន់
ជាអគ្គប្រធានាធិបតីនៃសាធារណរដ្ឋឥណ្ឌៀ

លំភូខ្ញុំណា ប្រកបដោយគ្រោះថ្នាក់ ដែលពិភពលោកស្ថិតនៅខាងក្នុងសព្វថ្ងៃនេះ អាចនឹងផ្តួលឡើងបាន ប្រសិនបើគេមិនណាមួយប្រព្រឹត្តទៅតាមអំពើចិត្ត ដូច្នេះជាការចាំបាច់ យើងត្រូវត្រៀមរឹងជាប្តូរឡើងវិញចំពោះយោបល់ប្រកបដោយសារៈរបស់យើង ។ យោបល់នេះពុំមែនជាបញ្ហាខាងផ្នែកយោធាយេ ដែលជាការរបស់រដ្ឋបុរសយើង អាចដោះស្រាយបានតាមការធ្វើកតិកាសញ្ញាទឹងសម្ព័ន្ធភាព ។

សព្វថ្ងៃនេះ យើងស្ថិតនៅចំពោះមុខវិបត្តិខាងសីលធម៌ ជាវិបត្តិដែលទឹងអាចធ្ងន់ធ្ងរ តែដោយការរំលឹកទឹងការធ្វើឲ្យកើតពិតប្រាកដ ខ្ញុំ

ទុក្ខនៃព្រះសម្ពុទ្ធដែលប្រដៅយើងកល់ភ្នាថា ជ័យជំនះជាហេតុបង្កើតឲ្យ
មានការគំនុំ អ្នកចាញ់តាំងខ្លាយ រមែងរបៀនៅកងសេចក្តីទុក្ខសោក
ហើយថាការបង្រួបបង្រួមគ្នាទុកជាមហាសម្បត្តិដ៏លើសលុប ។ ក្នុងទុកាស
ជាតិនេះ យើងសូមរំលឹកឲ្យដឹងថាមានតែព្រះពុទ្ធជាម្ចាស់ទេ
ដែលព្រះអង្គបានទ្រង់ធ្វើឲ្យមានកើតចិត្តធម៌នៅកងរបូបយើងតាំងខ្លាយទើង
ទ្រង់បានធ្វើនៅជាកោតខាងសាសនា ដែលជាគ្រឿងតាក់ចិត្តដើម្បីបើក
ទុកាសឲ្យយើងអាចធ្វើការប្រយុទ្ធក្នុងជីវិតាតមួយអង្គ ដោយផល
ប្រយោជន៍ថ្នឹងសេចក្តីក្រពយថ្នីបាន ។

×

× ×

សុន្ទរកថានៃអ្នកតំណាងប្រទេសជប៉ុន

សូមក្រាបបង្គំទូលព្រះកុណាងអម្ចាស់ជីវិតលើត្បូង,

សូមក្រាបបង្គំទូលទ្រង់ទើងសូរជំកបងកទុតម អស់លោកតាំងខ្លាយ!

ថ្ងៃនេះខ្ញុំទទួលកិត្តិយសជាតំណែងបំផុត ដើម្បីចូលរួមក្នុងពិធីបុណ្យ
ដ៏ទទ្លាក់នៃព.ស.គម្រប់ ២៩០០ ព្រះវស្សានេះ ។ នៅប្រទេសជប៉ុន
គាលពីកងខែធ្នូតាំងពីមួយ កងទុកាសព្រះពុទ្ធសាសនាការ នៃសម្តេច
ព្រះនរោត្តម សីហនុ ជាវង្សក្ត្រីទី ១ ដូចអស់លោក-អ្នកបានជ្រាបស្រាប់
ហើយ គឺមានសន្ធិសញ្ញាមិត្តភាពមួយបានសម្រេចកើតមានរវាងប្រទេស
ជប៉ុនងឺងប្រទេសកម្ពុជា ។ ចាប់តាំងពីពេលនោះមក ប្រជាជាតិរបស់យើង
តាំងពីរ បានរៀបចំប្តូរសម្ភារៈជីតស្និទ្ធ ដោយបំណងគឺការគោរព

នឹងសំដែងមិត្តភាពទៅវិញទៅមក ។

ខ្ញុំយល់ថា មិត្តភាពដ៏យ៉ាងប្រសើរបំផុត ដែលប្រជាពស្ត្រជប៉ុនបានមានចំពោះប្រជាពស្ត្រខ្មែរ បណ្តាលមកពីហេតុពីរយ៉ាងដូចតទៅនេះ ៖

ទី១ ត្រូវស្រង់ឲ្យដឹងឡើងវិញនូវសេចក្តីពប់អានខ្ទះ ដែលបានកើតមានរវាងប្រជាពស្ត្រទាំងពីរ តាមលំអានវិនព្រះពុទ្ធសាសនា ។ ជ្យិតថាមានជនជាតិជប៉ុនជាចំនួនយ៉ាងច្រើនក្រៃលែង សុទ្ធសឹងជាអ្នកកាន់សាសនានេះ, ហើយដោយអាស្រ័យហេតុនេះ ទើបយើងមានសេចក្តីស្នេហាដ៏ខ្ទាំងក្លាក្រៃលែងមកលើប្រជាពស្ត្រខ្មែរ ដែលជាមិត្តអ្នកកាន់ព្រះពុទ្ធសាសនាដូចគ្នា ។

ខ្ញុំសូមឧកាសនឹងជំរាបអស់លោកអ្នក ជាលើកទីពីរនូវមនោ-សញ្ចេតនាខាងការគោរព ដែលប្រជាពស្ត្រជប៉ុនបានមានចំពោះព្រះករុណាជាម្ចាស់ជីវិតលើត្សូង នឹងសម្តេចព្រះមហាក្សត្រិយានី ព្រមទាំងសម្តេចព្រះនរោម្តមសីហនុឧបយុវរាជទៀត ។

មនោសញ្ចេតនាទាំងនេះ រមែងប្រពឹត្តទៅជាពិសេសចំពោះសម្តេចព្រះឧបយុវរាជ ដែលព្រះអង្គបានទ្រង់សព្វព្រះរាជហប្ចទ័យស្តេចយាងទៅទស្សនាប្រទេសយើងជាច្រើនដង ក្រៅផ្លូវការក៏មានតាមផ្លូវការក៏មាន ។

មហាបុរសរដ្ឋដ៏ប្រសើរ ដែលមានមនោសញ្ចេតនាប្រកបដោយសេចក្តីស្នេហាមាតុភូមិនេះ បានបណ្តាលធ្វើឲ្យយើងត្រប់គ្នាមានចិត្តសោមនស្សយ៉ាងខ្ទាំងក្រៃលែង ។ យើងទុកព្រះអង្គជាមេដឹកនាំមួយដ៏យ៉ាងប្រសើរបំផុតក្នុងទ្វីបអាស៊ី ថែមទាំងក្នុងពិភពលោកទាំងមូលផង ។ យើង

សូមគោរពចំពោះព្រះអង្គ ដោយមនោសញ្ចេតនាដ៏យ៉ាងជ្រាលជ្រៅ ។

ការណ៍ទាំងនេះហើយ ដែលនាំឲ្យយើងមានមនោសញ្ចេតនាប្រកបដោយមិត្តភាពដ៏ស្មោះត្រង់ក្រៃលែង ចំពោះប្រជាពស្តុខ្មែរទាំងអស់នោះ ។

ខ្ញុំសូមជម្រាបថា សភាពថ្ងៃថ្លាដែលកំពុងប្រព្រឹត្តទៅក្នុងថ្ងៃនេះនៅទីនេះ ជាតំណាងនិមិត្តរូបនៃការរីកចំរើនហើយនឹងវឌ្ឍនភាពទៅអនាគតនៃអធិប្រទេសជប៉ុន ។

ក្នុងកាលដ៏យ៉ាងរីករាយនេះ ក្នុងនាមនៃរដ្ឋាភិបាលជប៉ុន ទឹងក្នុងនាមនៃប្រជាពស្តុជប៉ុន ខ្ញុំសូមប្រសិទ្ធិពរជ័យសិរីសួស្តីជូនចំពោះសព្វសាធុការដ៏យ៉ាងស្មោះស្ម័គ្រក្រៃលែងរបស់យើង សូមឲ្យតិចប្រស្រ័យយ៉ាងខ្លាំងមិត្តភាពរវាងប្រទេសយើងទាំងពីរបានជិតស្និទ្ធជាតំណើរការតទៅ ។

× × ×

សារលិខិតអ្នកអង្គម្ចាស់សុវណ្ណភូមា
រដ្ឋមន្ត្រីទី ១ នៃរដ្ឋាភិបាលប្រទេសលាវ

បងប្អូនខ្មែរជាមិត្តដ៏ថ្លៃថ្លាទាំងឡាយ ! នៅក្នុងសតិវត្សរ៍ ព.ស. ២៥០០ ព្រះពុទ្ធសាសនា ដែលប្រជាពស្តុខ្មែរបានធ្លាប់ដឹងគុណយ៉ាងក្រៃលែងក្នុងថ្ងៃនេះ, ក្នុងហានៈជាប្រមុខពរជ័យតំណាងប្រទេសលាវ ខ្ញុំមានសេចក្តីរីករាយដ៏ធំអនេកនន្តក្នុងថ្ងៃដ៏ឧត្តមនេះ ខ្ញុំសូមលើកឡើងដ៏ស្មោះស្ម័គ្រ ចំពោះពរជ័យតំណាងរាស្ត្រប្រទេសកម្ពុជា ដែលបានមានសោមនស្សចេតនាអញ្ជើញប្រទេសលាវដើម្បីមកចូលរួមក្នុងពិធីបុណ្យនេះផង ។

ក្នុងនាមនៃប្រជាពស្ត្រលាវ ខ្ញុំសូមថ្វៃងសមានចិត្តទាំងស្រុងរបស់ ខ្ញុំចំពោះប្រជាពស្ត្រខ្មែរដែលជាអ្នកកាន់ព្រះពុទ្ធសាសនាដ៏យ៉ាងហ្មត់ចត់ ហ៊ីយក្នុងឧកាសនេះខ្ញុំសូមនាំយកនូវក៉ស្តតាង គឺសេចក្តីរីកចាយដ៏ខ្ចាំងក្លាក្រៃលែង ដែលប្រជាពស្ត្រលាវកើតមាន ដើម្បីចូលរួមជាមួយនឹងសេចក្តីរីកចាយដែលប្រជាពស្ត្រខ្មែរបានមាន នៅឧកាសធ្វើមហាពីធីបុណ្យនេះ ព្រោះជនជាតិខ្មែរ នឹងជនជាតិលាវ មានវប្បធម៌ នឹងសាសនាដូចគ្នា។

ប្រវត្តិសាស្ត្រនឹងចារិកផ្សេង ។ បង្ហាញក៉ស្តុតាងយ៉ាងជាក់ច្បាស់ថាព្រះពុទ្ធសាសនាដែលអប់រំដួងវិញ្ញាណនៃប្រជាស្ត្រលាវបានផ្សាយចូលទៅប្រទេសលាវតាមប្រទេសកម្ពុជា ។

បុរាណប្រាសាទនៅវត្តភូ (ចំប៉ាសាក់) នឹងនៅសៃហ្វុ៉ង (រ៉ៀងច័ន្ទន៍) បង្ហាញក៉ស្តតាងយ៉ាងពិតប្រាដកថា ព្រះពុទ្ធសាសនាសាវ្យធម៌នឹងសិល្បៈបានផ្សាយចូលទៅក្នុងប្រទេសលាវតាមរយៈនៃប្រទេសខ្មែរ ។

ថ្ងៃវិសាខនេះ ជាឧកាសដែលពុទ្ធបរិស័ទទាំងឡាយនៃប្រទេសទាំងអស់ក្នុងពិភពលោក នាំគ្នាសូត្រធម៌ដើម្បីរំលឹក នូវមហាឧបការគុណនៃព្រះបរមគ្រូសម្ពុទ្ធ ខ្ញុំសូមប្រសិទ្ធិតាងនាមនៃប្រជាពស្ត្រលាវ នូវពរសព្ទសាធុការដ៏ជាការកក់ក្តៅក្រៃលែង សូមព្រះពុទ្ធសាសនាផ្សាយពន្ធឹរស្មីដ៏យ៉ាងរុងរឿងទៅគ្រប់ទិស សូមអានុភាពនៃព្រះត្រៃរតន៍គឺព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឆជួយនាំចិត្តគំនិតនឹងធ្វើឲ្យចំរើនកើតមាននូវសេចក្តីសាមគ្គី នៃមនុស្សទាំងអស់ ព្រមទាំងធ្វើឲ្យចំរើនដល់មនុស្សទាំងឡាយនោះ នូវសេចក្តីសុខចំរើន ដែលផ្សាយចេញមកពីសន្តិភាពក្នុងពិភពលោក ។

× × ×

សារនៃឯកឧត្តមសេនាប្រមុខ

ពិបុលសង្គ្រាម នាយករដ្ឋមន្ត្រីប្រទេសថៃ

នៅឧកាសនៃពិធីបុណ្យ ព.ស.២៥០០ វស្សា ដែលប្រព្រឹត្តទៅ
នៅប្រទេសកម្ពុជា ចាប់ពីថ្ងៃទី ១២ ទៅថ្ងៃទី ១៨ ខែឧសភានោះ ខ្ញុំមាន
សេចក្តីរីករាយពិសេស សូមថ្វែងសេចក្តីគោរពចំពោះបាតុភម្មខាងដំខ្ញី
រដ្ឋាភិបាលប្រជាពស្ត្រនៃប្រទេសកម្ពុជា ក្នុងនាមនៃរដ្ឋាភិបាលនឹងប្រជា
ពស្ត្រថៃ ដែលកំពុងតែធ្វើពិធីនេះក្នុងរយៈពេល ៨ ថ្ងៃជួបគ្នានោះ ។

យើងភាំងអស់គ្នានៅក្នុងប្រទេសថៃតែងបានរក្សាទុកនូវចំណង
ដ៏តាប់ប្រសើរ នឹងមិត្តភាពដ៏ស្មោះស្ម័គ្រគ្រៃលែង ចំពោះជនជាតិខ្មែរជា
បងប្អូនយើង នឹងជាអ្នកកាន់ព្រះពុទ្ធសាសនានៅជិតខាងគ្នា ។ ក្នុង
ឧកាសប្រកបដោយសេរីសួស្តីជាឱឡារិកនេះ ប្រទេសថៃនឹងប្រទេស
កម្ពុជាកំពុងធ្វើពិធីបុណ្យជួបគ្នា ជាតិប្រទេសទាំងពីរមានជំនឿជួបគ្នា ។

ជូនចុះ ខ្ញុំសូមធ្វើតក្នុងឧកាសនេះ ថ្វែងសេចក្តីគោរពជូនពរដ៏
ឃាំងប្រណីតរបស់ខ្ញុំ ចំពោះរដ្ឋាភិបាលនឹងប្រជាពស្ត្រខ្មែរ ។

សូមបុណ្យនៃ ព.ស.គម្រប់ ២៥០០ វស្សា ប្រព្រឹត្តទៅយ៉ាងសុខ
ស្រួលគ្រៃលែង ក្នុងព្រះពុទ្ធចក្រកម្ពុជា ។ សូមព្រះគុណជា
អម្ចាស់ជីវិតលើតួង ប្រទេសកម្ពុជា សូមរដ្ឋាភិបាល នឹងប្រជាពស្ត្ររបស់
ព្រះអង្គ ជួបប្រទះតែនឹងសេចក្តីសុខចំរើនយ៉ាងធំជានិរន្តរ៍ ដែលនឹងធ្វើ
ឱ្យប្រព្រឹត្តទៅបានដោយ ក្នុងគោលវិស័យតែមួយដែន ដល់ការថែរក្សាចំពោះ
ព្រះពុទ្ធសាសនា ដែលជាសាសនារបស់យើងរួមគ្នានោះ ។

x x x

សារលិខិតនៃឯកឧត្តម ផាំ ឃ្ពុំងជុង

ជារដ្ឋមន្ត្រីទី១នៃសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម

ភ្នំពេញ នៅឧកាសពិធីបុណ្យតម្រប់ ២៥០០ វស្សា នៃព្រះពុទ្ធ-សាសនា ឯកឧត្តមផាំ-ឃ្ពុំងជុង ជារដ្ឋមន្ត្រីទី១នឹងជារដ្ឋមន្ត្រីក្រសួងការបរទេសនៃសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម បានផ្ញើមកថ្វាយសម្តេចនាយករដ្ឋមន្ត្រីនូវសារ ដូចតទៅនេះ ៖

" នៅឧកាសពិធីបុណ្យតម្រប់ ២៥០០វស្សា នៃព្រះពុទ្ធសាសនា, ក្នុងនាមរដ្ឋាភិបាលសាធារណប្រជាធិបតេយ្យវៀតណាម និងប្រជាកស្ត្រវៀតណាម ហ៊ីយនឹងក្នុងនាមផ្ទាល់នៃទូលព្រះបង្គំ សូមថ្វៃងចំពោះព្រះអង្គព្រមទាំងប្រជាកស្ត្រខ្មែរ នូវអំណរសេចក្តីសរសើរដ៏ជាទីកក់ក្តៅ ។

ទូលព្រះបង្គំសូមឲ្យពិធីបុណ្យដ៏ឧឡារិកនេះ បានដល់នូវជោគ-ជ័យយ៉ាងពេញលេញ ។ សូមឲ្យប្រជាកស្ត្រខ្មែរដែលស្ថិតនៅក្រោមការដឹកនាំរបស់ព្រះអង្គ បានទទួលនូវលទ្ធផលដ៏ប្រសើរ ក្នុងការអនុវត្តន៍នយោបាយសន្តិភាព និងអព្យាក្រឹត ដែលប្រទេសខ្មែរមានសេចក្តីរុងរឿងជាកល់ថ្ងៃតទៅ" ។

ហត្ថលេខា ផាំ-ឃ្ពុំងជុង

ព្រះរាជិបន្ទូលផ្លើយតបនៃសម្តេចព្រះឧបយុវរាជ

ខ្ញុំមានសេចក្តីរកើបយ៉ាងជ្រាលជ្រៅ ចំពោះសារទូរលេខថ្ងៃងអំណរសរសើរនឹងពរសាពួសាធុការនៃឯកឧត្តម នៅឧកាសពិធីបុណ្យតម្រប ២៥០០វស្សា នៃព្រះពុទ្ធសាសនា ។ ខ្ញុំសូមឯកឧត្តមទទួលនូវសេចក្តី

កតញ្ញូយាំងខ្ចាំងក្នាងនៃរដ្ឋាភិបាលនឹងប្រជាពស្តុទ្ធៃ ។ ខ្ញុំសុំឲ្យពិធីបុណ្យ
នេះ នាំមកនូវសេចក្តីសុខនឹងសេចក្តីចំរើនរុងរឿងដល់ប្រជាពស្ត្រវៀត-
ណាម ។ សុំឲ្យលោកទទួលនូវសេចក្តីរាប់អានដ៏ខ្ពង់ខ្ពស់របស់ខ្ញុំ ។

ព្រះហត្ថលេខា: នរោត្តម សិហនុ

× + ×

សារទូរលេខនៃលោក ជាំ យ៉ាំងជុង រដ្ឋមន្ត្រីទី ១ នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រទេសព្យ៉ាតណាមទាងជើង

ក្នុំពេញ លោក ជាំ - យ៉ាំងជុង រដ្ឋមន្ត្រីទី ១ នៃរដ្ឋាភិបាលសាធា-
រណរដ្ឋប្រជាធិបតេយ្យវៀតណាម បានផ្ញើសារទូរលេខមួយច្បាប់ថ្វាយ
ចំពោះសម្តេចព្រះទបយុវរាជ នាយករដ្ឋមន្ត្រី ដើម្បីថ្វែងអំណរគុណចំពោះ
ព្រះរាជរដ្ឋាភិបាល អំពីបដិសណ្ឋារកិច្ចដ៏ធាទីកក់ក្តៅដែលរាជរដ្ឋាភិបាល
បានផ្ទើចំពោះគណៈប្រតិភូ ទាងពុទ្ធសាសនាវៀតណាម ក្នុងរយៈការ
សំណ្ឋាក់អាស្រ័យនៃគណៈប្រតិភូនេះ ក្នុងប្រទេសយើង នៅទីកាស
បុណ្យពុទ្ធជយន្តិ ដូចសេចក្តីទាងក្រោមនេះ ៖-

"ក្នុងនាមនៃរដ្ឋាភិបាលសាធារណរដ្ឋ ប្រជាធិបតេយ្យវៀតណាម
នឹងក្នុងនាមផ្ទាល់របស់ទូលព្រះបង្គំ, ទូលព្រះបង្គំសូមថ្វែងចំពោះសម្តេច
ព្រមទាំងសមាជិកនៃរាជរដ្ឋាភិបាល នូវអំណរគុណដ៏ស្មោះស្ម័ត្រនៃ
ទូលព្រះបង្គំ អំពីបដិសណ្ឋារកិច្ចដ៏ធាទីកក់ក្តៅដែលរាជរដ្ឋាភិបាលបាន
ផ្ទើចំពោះគណៈប្រតិភូទាងពុទ្ធសាសនា នៃសាធារណរដ្ឋប្រជាធិបតេយ្យ

រៀតណាម ក្នុងរយៈសំណាក់អាស្រ័យនៃគណៈប្រតិភូនេះ ក្នុងប្រទេសរបស់ព្រះអង្ត នៅទីកាសពិធីបុណ្យ ព.ស.៦៥០០រស្យា ។

សូមសម្តេច ទ្រង់ព្រះមេត្តាប្រោស ទទួលសេចក្តីគោរពរាប់អានដ៏ខ្ពង់ខ្ពស់ក្រៃលែងនៃទូលព្រះបង្គំ ។

ហត្ថលេខា : ឆាំ-ឃ្យាំងឆុង

សេចក្តីផ្លើយតបនៃសម្តេចព្រះឧបយុវរាជ

ខ្ញុំសូមថ្វែងអំណរគុណចំពោះឯកឧត្តម អំពីសារទូលេខប្រកបដោយសេចក្តីសប្បុរសរបស់ឯកឧត្តម យើងខ្ញុំសូមឯកឧត្តម ព្រមទាំងរដ្ឋាភិបាលឯកឧត្តម ហើយនឹងប្រតិភូប្រទេសរៀតណាមដែលអញ្ជើញមកក្នុងពិធីពុទ្ធជយន្តិរបស់យើង ទទួលនូវមនោសញ្ចេតនាប្រកបដោយសេចក្តីកតញ្ញូនៃប្រជាជាតិវៀត្ន អំពីជំនួយដ៏សំខាន់នៃប្រទេសឯកឧត្តម ចំពោះជោគជ័យនៃពិធីបុណ្យ ព.ស. គម្រប់ ៦.៥០០ រស្យា ក្នុងប្រទេសរបស់យើងនេះ ។

សូមឯកឧត្តមទទួលនូវសេចក្តីរាប់អានដ៏ខ្ពង់ខ្ពស់ក្រៃលែងរបស់ខ្ញុំ ។

ព្រះហស្តលេខា : នរោត្តម.សីហនុ

×

× ×

មោង ១០ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង សម្តេចព្រះមហាក្សត្រិយានី, សម្តេចព្រះឧបយុវរាជ, សម្តេចវាំងវរៈវ៉ៀងជ័យសមាជិកឧត្តមប្រឹក្សាព្រះរាជា, សមាជិកវង្ផាកិបាល, សមាជិកការទូត មន្ត្រីធំតូចទ្រង់ស្តេចយាង បានអញ្ជើញទៅកាន់មហាវេងទាងកើតបុស្ស្ពក ដើម្បីដាក់បាត្រព្រះសង្ឆ ១០០ អង្ត ។

ពេលនោះ សម្តេចព្រះរាជកណ្ដាវស្ទ្ងីសោភ័ន បានទ្រង់ដាក់បាត្រព្រះសង្ឆ ១០០ អង្តដែរ ។

ទាងកើតមហាវេង, ចាប់តាំងពីមោ៉ង ៧ ព្រឹកទៅ គេបានឃើញពួកពុទ្ធសាសនិកជនបុរសស្ត្រីក្មេង ចាស់ប្រុងប្រៀបយកចង្ហាន់រៀងៗ ទ្ធូនទៅដាក់ជំកល់តាមទីកន្ទែងដែលទ្ធូនបានកំណត់ទុកជាមុន ដោយសេចក្តីអនុគ្រោះអំពីតណៈកម្មការទាងពិធីដាក់បាត្រ ដែលមានលោកទេស-យ៉ង់ជាប្រធាន ។ លោកទេស-យ៉ង់បានរៀបចំទីកន្ទែងដាក់បាត្រ ដោយចាត់មេមួយ ។ មានកាន់ស្ទាកមួយពីលេខ ១ ដល់លេខ ៦៩ ចំពោះព្រះសង្ឆ ៦៩០០ អង្ត ។ មេដាក់បាត្រកាន់ស្ទាកលេខ ១ ដាក់បាត្របានចំពោះតែព្រះសង្ឆ ១០០ អង្តដែលកាន់ស្ទាកលេខ ១ ដូចគ្នា ។ មេដាក់បាត្រកាន់ស្ទាកលេខ ៦ ដាក់បាត្របានចំពោះតែព្រះសង្ឆ ១០០ អង្តដែលកាន់ស្ទាកលេខ ៦ ជាលំដាប់តាមលេខរហូតដល់លេខ ៦៩ ។ តែក្នុងពេលនោះ ពួកឧបាសក-ឧបាសិកាមានប្រើនហួសប្រមាណកកកុញពាសពេញណែនណាន់តាន់តាប់ជ្រៀតគ្នាមិនចុះ ហើយចូលទៅកាន់ទីដាក់បាត្រនីមួយ ។ ដូចជារលកវាយប្រាំងផ្ទប់យ៉ាងទ្ធាំង, ម្ទោ៉ះហើយមេដាក់បាត្រ

ទៅជាកូនដាក់ជាត្រចៀវិញ ព្រោះកូនមានចំនួនច្រើនជាងមេរកតណា
ត្រាកប់តុំបាន ។

ទុជាសក.ទុជាសិកាដែលឯកចង្ក្រានមកដាក់ជាត្រព្រះសង្ឃនោះមាន
ខ្វះមិនបានដាក់នំដែរ ព្រោះព្រះសង្ឃមានចំនួនតែ ៦៥០០ អង្គ
ពួកភ្ញៀវសាសនិកជនមានដល់ទៅ ៧០០០នាក់ ឬ ១០.០០០ នាក់; ម្ល៉ោះ
ហើយពួកពុទ្ធបរិស័ទណាដែលអញ្ជើញមកដល់ក្រោយគេ ខានដាក់ជាត្រ
ហើយឯកចង្ក្រានវិលត្រឡប់ទៅវិញ ។ សម្តេចព្រះមហាសុមេធាធិបតី
សង្ឃនាយកគណៈមហានិកាយបានប្រាប់រឿងនេះកំផ្លុកយតាមវិន្យទេគ្ឃ-
សនសត្តថា ចាប់ពីព្រឹកស្អែកទៅ សូមឲ្យពុទ្ធបរិស័ទនិមន្តព្រះសង្ឃ
៤០០០អង្គ ឬ ៧០០០អង្គ ឬក៏១០០០០អង្គ មកបិណ្ឌបាតដោយសេរី ។

ពេលរសៀល ម៉ោង ១៦,០០; ឯកទត្តមព្រាក់ប្រាប្រឹង
ទីប្រឹក្សាក្រសួងមហាផ្ទៃអញ្ជើញមកដល់ បានទទួលភ្ជួងបុប្ផាអំពីនារីម្នាក់
យកទៅបូជាព្រះបរមសារីរិកធាតុដែលដំកល់លើបុស្បក ។ លុះដាច់តមក
ឯកទត្តមបានឆ្លើយទៅលើវេទិកាពិសេសថ្វាយសុន្ទរកថាមួយ សំដែង
សេចក្តីគោរពចំពោះព្រះបរមសារីរិកធាតុ មានសេចក្តីដូចតទៅនេះ៖-

សូមថ្វាយបង្គំព្រះសម្ពុទ្ធជាម្ចាស់

ក្នុងឱកាសពិធីបុណ្យរំលឹកពុទ្ធសកាជ ២៥០០ ព្រះវស្សានេះ ខ្ញុំព្រះ
អង្គសូមបង្ហាញកាយវាចាចិត្តគោរពជាទុក្ខាកែ ចំពោះព្រះបរមសារីរិក-
ធាតុនៃព្រះអង្គ ។

ពិធីបុណ្យដ៏ធំអស្ចារ្យនេះ យើងខ្ញុំព្រះអង្គធ្លើឡើង ដោយការខិត

យើញព្រះគុណសម្បត្តិ ៣ យ៉ាង របស់ព្រះអង្គដែលផ្សាយគ្រប់ជុំជាប់
ស្រោចស្រង់មកលើយើងខ្ញុំជាជាតិខ្មែរទាំងប្រទេស ។

ព្រះគុណសម្បត្តិ ៣ ប្រការនោះ គឺ

- ព្រះបញ្ញាគុណ ១
- ព្រះវិសុទ្ធិគុណ ១
- ព្រះករុណាគុណ ១ ។

បពិត្រព្រះសម្មាសម្ពុទ្ធជាបរមគ្រូ

យើងខ្ញុំព្រះអង្គ ដោយឃ្លានលើកយើញនូវមហាគុណទាំងបីនេះ
ហើយគ្រាំពុំបាន ទើបថ្វែងនូវសេចក្តីគោរពចំពោះព្រះអង្គ ដោយបទ្ធី
ភ្ជាប់ឈ្មោះក្នុងខ្លួនយ៉ាងនេះ ។

ព្រះគុណសម្បត្តិទាំង ៣ នោះ យើងខ្ញុំបានដឹងច្បាស់ថា ព្រះអង្គ
បានសម្រេចដោយសារសេចក្តីព្យាយាមដ៏បញ្ញាធិក តាលអំពីអតីតជាតិ-
ដែលបានសេចក្តីលំបាកយ៉ាងខ្លាំងក្រៃលែង រាប់ដោយកប្បអស់ ៤ អសំ
ខេយ្យ ១ សែនកប្ប ។ កាលតែព្រះជាតិ ព្រះអង្គយកព្រះទ័យប្តូរនឹង
សម្ពោធិញ្ញាណមិនមានរួញរា តែព្រះជាតិខ្លះ ហានលះពរសម្បត្តិទៅ
ទ្រង់ព្រះផ្នួសជាតាបស ព្រះជាតិខ្លះលះបុត្តភរិយាឲ្យជាទានដល់សូមយា-
ចក ព្រះជាតិខ្លះហានតុះក្រូចយកថ្លើមជាក់ទានដល់អ្នកត្រូវការ សុំឲ្យ
តែសម្រេចពោធិញ្ញាណ ។ ដល់មកបច្ចុប្បន្នជាតិ ព្រះអង្គលះសម្បត្តិ
ស្តេចចក្រ ដែលនៅតែ ៧ ថ្ងៃទៀតនឹងបាន មិនមានព្រះទ័យស្តាយ ទ្រង់
ចេញចោលព្រះពរកំដរទៅទ្រង់ព្រះផ្នួស ហើយធ្វើទុក្ករកិរិយារហូតពាល់

តែជួលលើផែនដី ហើយប្រែផ្លាស់ព្រះទ័យមកចំរើនអានាបាណស្សតិ-កម្មដ្ឋានក៏បានសម្រេចព្រះពោធិញ្ញាណ ។ តមក ទ្រង់មិនខ្មៅស្មៀមទ្រង់ស្តេចទៅមន្តខេសនាខ្ញុំនាងដឹកនាំសត្វឲ្យបានសម្បត្តិសុខ ៣ ប្រការ គឺសុខកាមមនុស្សលោក ១ កាន់ទេវលោក ១ កាន់ព្រះនិព្វាន ១ ។

បពិត្រព្រះសក្យមុនីគោតម

អាស្រ័យហេតុដែលព្រះអង្គ មានព្រះមហាឧបការគុណដ៏ធ្ងន់ចំពោះបរិស័ទដូចថ្ងៃនេះ ទើបយើងខ្ញុំធ្វើនូវបុណ្យដ៏ឧត្តុង្គនេះ ដើម្បីសំដែងនូវកតញ្ញូកតវេទីភាពចំពោះព្រះអង្គ ។

ដោយអំណាចបុញ្ញាភិសេកនេះ សូមពួកទេវតាដែលមានវិញ្ញាណគ្រប់គ្រងនូវទីសក្តិសិទ្ធិកន្លងសកលលោកជួយអភិបាលព្រះពុទ្ធសាសនា ឲ្យបានរុងរឿងដរាបតរៀងទៅ ព្រមទាំងជួយអភិបាលព្រះករុណាជាអម្ចាស់ជីវិតលើត្បូង សម្តេចព្រះមហាក្សត្រិយានី សម្តេចព្រះឧបយុវរាជ ជាព្រះបិតាឯករាជ្យជាតិ ព្រមទាំងប្រជាជាតិខ្មែរទាំងមូល សូមព្រះអង្គទ្រង់អស់លោក បានជួបប្រសព្វនូវរិបុលសុខដរាបដល់ព្រះនិព្វានជាអវសាន ។

លំដាប់តមក អ្នកតំណាងសមាគមពុទ្ធសាសនាបរទេស ទាំងប្រទេសខ្មែរ ឡើងលើវេទិកាពិសេសអានសារលិខិត ៥ ច្បាប់ម្នាក់ គឺ

១ - អ្នកតំណាងពុទ្ធិកសមាគមប្រទេសភូមា,

២ - „ „ ប្រទេសអាមេរិក,

៣ - „ „ ប្រទេសមាលាំយូ,

៤ - „ មហាពោធិសមាគមប្រទេសឥណ្ឌា,

๕- អ្នកតំណាង ពុទ្ធិកសមាគមប្រទេសថៃ,

๖- " ពុទ្ធិកសមាគមប្រទេសជប៉ុន,

๗- " ពុទ្ធិកសមាគមសហភាពរុស្ស៊ី,

๘- " ប្រធានពុទ្ធិកសមាគមកម្ពុជរដ្ឋ,

๙- " សមាគមគិលានសង្គ្រោះព្រះសង្ឃវ្ទៃរ,

๑๐- " សមាគមមិត្តពុទ្ធិកវិទ្យាល័យប្រទេសកម្ពុជា,

๑๑- អ្នកតំណាងនៃមូលនិធិអាស៊ី,

๑๒- អ្នកតំណាងពុទ្ធសាសនាសាធារណរដ្ឋប្រជាមានិតចិន,

๑๓- អ្នកតំណាងពុទ្ធសាសនាប្រទេសវៀតណាមសេរី ។

តអំពីនេះ សូមស្រង់យកសារលិខិតនៃពុទ្ធិកសមាគមនៃប្រទេសទាំងនោះមកចុះជូនអានជូចតទៅនេះ ៖

សារក្រុមប្រឹក្សាខាងព្រះពុទ្ធសាសនានៃសហភាពភូមា

យើងជាសមាជិកទាំងឡាយនៃក្រុមប្រឹក្សាខាងព្រះពុទ្ធសាសនា នៅសហភាពភូមា សូមធ្វើដោយសេចក្តីគោរពយាំងក្រៃលែងនូវសារគឺតារវ-កិច្ច ជាមិត្តភាពនេះនៅឧកាសនៃពិធីបុណ្យដែលបានកើតមាននៅប្រទេសកម្ពុជា ដើម្បីកំណត់នូវ ព. ស. ២៥០០ វស្សានៃពុទ្ធជយន្តិ ។

យើងបានសង្កេតឃើញថា ក្រោយសម័យដ៏យូរអង្វែងមក អាចធ្វើសង្គាយនាមួយ ដើម្បីផ្ទៀងផ្ទាត់ឡើងវិញនូវអត្ថបទទាំងឡាយនៃព្រះត្រៃបិដក ហើយក្នុងរយៈកាល ២៥០០ ឆ្នាំ មានសង្គាយនាតែត្រឹម ៦ លើកប៉ុ ៖ ។

យើងមានចិត្តស្នេហារួបរួម ដោយធ្វើធម្មសង្គាយនារួមគ្នានេះ ។ ប្រ-
ទេសវៀតមួយនឹងមិនអាចធ្វើសង្គាយនា ផ្ទៀងផ្ទាត់ធម៌វិន័យនេះបានឡើយ
ហេតុដូច្នេះ ការផ្ទៀងផ្ទាត់ធម៌វិន័យនេះ ទុកជាស្នាដៃរួបរួមកំឡាំងគ្នា
នៃប្រទេសកាន់ព្រះពុទ្ធសាសនាទាំង ៦ ។ មុខងារនៃប្រទេសកម្ពុជាដឹ
ល្បីល្បាញខាងគុណធម៌ នឹងចំណេះវិជ្ជាដឹខ្ពង់ខ្ពស់របស់គិក្ខុទាំងឡាយ
ជាតិវ្មែរ បានទទួលនូវសេចក្តីគោតសរសើរដឹយ៉ាងធំក្រៃលែង ។

ព្រះត្រៃបិដកមួយចប់ ដែលសម្តេចសង្ឃនាយកប្រទេសកម្ពុជា បាន
ប្រតេនដល់ប្រទេសភូមា ជាព្រះត្រៃបិដកដែលបានកើតឡើងដោយព្រះ
អង្គឯងហើយដែលនឹងចេញផ្សាយទៅអនាគតនោះ គឺជាតំស្ពុតាងមួយដឹធំ
ខាងសហប្រតិបត្តិការ នៃប្រទេសកម្ពុជា ជាមួយប្រទេសអ្នកកាន់ព្រះពុទ្ធ-
សាសនាទាំងឡាយដទៃ ក្នុងករណីយកិច្ចគឺការកសាងស្នាដៃមួយដឹយ៉ាង
មាំគឺធម្មសង្គាយនា ដែលជាទទាហរណ៍មួយ ក្នុងបណ្តាទទាហណ៍ទាំង
ឡាយដទៃជាច្រើននោះ ។ យើងចាំបានជានិច្ចថា ក្នុងរយៈសម័យ ៥ លើក
នៃធម្មសង្គាយនាចំនួនពីរឆ្នាំមកហើយ ប្រទេសកម្ពុជាបានចូលរួមក្នុងពេល
ប្រជុំទាំងឡាយចាប់តាំងពីដើមរហូតដល់ចុង ហើយជាសម័យលើកទី ៣
ធម្មសង្គាយនា បានស្ថិតនៅក្រោមការទបត្ថម្ភនៃប្រទេសកម្ពុជានឹងប្រទេស
លាវ ជាសម័យដែលមាននាមថាសម័យកម្ពុជាលាវនៃធម្មសង្គាយនា ។

សូមប្រទេសកម្ពុជា នឹងប្រទេសភូមាដែលមានជាតិភូមិសាស្ត្រវប្ប-
ធម៌ នឹងសាសនាលាំ ។ ត្នា អាចចាត់ចែងការក្នុងលោកនឹងក្នុងបរលោក
ដោយសេចក្តីស្នេហាស្មើគ្នាចំពោះអ្នកជិតខាង ហើយនឹងអាចធ្វើសហ-

ប្រតិបត្តិការរួមគ្នាបានសម្រេចចាប់តាំងពីថ្ងៃនេះតទៅ ។

× × ×

សារលិខិតអំពីទីបាត់ការធំនៃវត្តពុទ្ធសាសនា
ទាំងឡាយនៅស.រ.អា.ថ្វាយបំពោះព្រះករុណា
នឹងព្រះមហាក្សត្រិយានី នៃប្រទេសកម្ពុជា

ទីបាត់ការធំនៃវត្តពុទ្ធសាសនាទាំងឡាយនៃស.រ.អា. ក្នុងនាមនៃពុទ្ធបរិស័ទទាំងអស់នៅ ស.រ.អា. សូមថ្វាយពរសព្ធសាធុការដ៏ស្មោះស្ម័ត្រនឹងជ្រាលជ្រៅបេស់ខ្ជួន បំពោះព្រះមហាក្សត្រនឹងព្រះមហាក្សត្រិយានីនៃប្រទេសកម្ពុជា ព្រមទាំងពុទ្ធបរិស័ទទាំងអស់នៅកម្ពុជរដ្ឋក្នុងឧកាសបុណ្យ ២៥០០វស្សានៃព្រះពុទ្ធសាសនា ។ យើងខ្ញុំទូលព្រះបង្គំសូមបួងសួងថ្វាយព្រះករុណានឹងព្រះមហាក្សត្រិយានី សូមឲ្យពិធីបុណ្យដែលធ្វើឡើងយាំងអធិកអធ័ម នឹងជាប្រវត្តិសាស្ត្រនេះបានប្រកបដោតជ័យដ៏បរិបូណិ ។

ហត្ថលេខាទីបាត់ការធំនៃវត្តពុទ្ធសាសនាទាំងឡាយនៅ ស.រ.អា

× × ×

សារលិខិតនៃក្រុមពុទ្ធសាសនិកជាតិអាមេរិក

ក្នុងបច្ចុប្បន្នកាលនេះ ប្រជាពស្ត្រទាំងឡាយ នៃប្រទេសទាំងអស់ក្នុងពិភពលោក ដែលកំពុងប្រកបដោយកលិយុគនេះរមែងទាមទារនូវសន្តិភាព ។ ប្រជ្ញូលដ៏អាក្រក់នៃសង្ត្រាមបរមាណូ ដែលកំហែងដើម្បីបំផ្ទេចបំផ្ទាញ ឲ្យវិនាសមនុស្សលោកទាំងអស់នោះ កំពុងបាំងស្រមោល

ឲ្យឃើញព្រាន។ឯដើនមេយ គឺថាមានវដ្ដបហារខ្ទះ ឬសេចក្តីអុកឡុក ឲ្យដឹងាន៥ក្នុងប្រទេសជាច្រើនបានសេចមានមកហើយ ។ ក្នុងសម័យ ប្រវត្តិសាស្ត្រ នៃមនុស្សប្រកបដោយការវិកវរនេះ មានមនុស្សប្រកប ដោយសុធន្ទៈជាច្រើន, ឯប្រជាជាតិទាំងអស់ ចង់ដឹងថាតើមនុស្សលោក ត្រូវប្រតិបត្តិកំឡាំងសីលធម៉ិឬកំឡាំងសាសនាណា ដើម្បីបញ្ជៀសទឹក ជំនន់ដែលបំរុងនឹងឡើងហូរមកពន្ធិចយើងនេះ ។ អំពីកិច្ចពិភាក្សាចំពោះ ស្រមោល ដឹងនឹតឈ្ងប់នេះ ជាការចាំបាច់នោះ គឺត្រូវតែទៅជ្រកក្នុង ម្ងប់ព្រះត្រៃរតន៍ គឺព្រះពុទ្ធព្រះធម៉ិនឹងព្រះសង្ឆនេះឯង ។

សច្ចធម៉ិដែលព្រះសម្ពុទ្ធបានទ្រង់ទេសនាមកហើយនោះ ពុំបានអាប់ ពន្ធឹរស្មីទៅតាមពេលវេលាឡើយ ។ ក្នុងសម័យបច្ចប្បន្ទនេះ ព្រះពុទ្ធ-សាសនាមានមុខងារដឹយ៉ាងធំក្នុងការប្រដៅមនុស្សលោក ។ ក្នុងថ្ងៃទាំង ឡាយទៅអនាគតពុទ្ធសាសនិកទាំងឡាយនៃប្រជាជាតិទាំងអស់ ត្លូវតែ ខំប្រឹងបន្ថែមកំឡាំង ជាទ្ងឡើងទៅលើសន្តិភាព ដោយពិធីពន្រីកលទ្ធិ-ពុទ្ធសាសនាដែលជាសាសនាប្រដៅឲ្យមានសេចក្តីមេត្តាសកល ឲ្យមាន ការអត់ទនគ្នានឹងឲ្យអហឹង្សាធម៉ិ គឺការមិនបៀតបៀននេះឯង ។ ប្រសិន បើពុទ្ធសាសនិកមានចំនួន ៥ រយលាននាក់ ក្នុងពិភពលោករួបរួមចងបាច់ ធន្ទៈគ្នា ដើម្បីស្ងងរកសន្តិភាពជូនពិភពលោក ដោយការប្រព្រឹត្តិតាម គោលប្បាប់ព្រះពុទ្ធសាសនាគឺតតិបណ្ឌិត សេចក្តីមេត្តាករុណា នោះ កំឡាំងខាងផ្ទូវចិត្តនេះប្រវហលជានឹងអាចមានជ័យជំនះបាន ។

សន្តិភាពក្នុងពិភពលោកដឹពិតប្រាកដនឹងស្ថាពរ អាចកើតមានបាន

ដោយសារតែការប្រតិបត្តិតាមព្រះឧរាទនៃព្រះសម្ពុទ្ធ គឺបាអ្វីពំនអស់ដែលទាក់ទន ព្រមព្រៀនជាមួយការពិសោធន៍របស់លោក-អ្នកដែលបានធ្វើពេញទៅដោយសតិសម្បជញ្ញៈ អ្វីពំនអស់ដែលត្រឹមត្រូវហើយ នាំឲ្យអស់លោកអ្នកបានសេចក្តីសុខចំរើន ជល់ខ្ជួនអស់លោក-អ្នក នឹងជល់សត្វមានជីវិតពំនអស់នោះ របស់ពំនអស់នោះ ត្រូវតែទទួលទុកជាការពិត សូមអស់លោក-អ្នកញ្ញុំនជីវភាព របស់អស់លោក-អ្នកឲ្យប្រព្រឹត្តទៅតាមការពិតនោះចុះ ។

សេចក្តីគោរពពិធីពុទ្ធជយន្តិ ក្នុនពិភពលោកទុកជាគោលការរួបរួមពុទ្ធសាសនិកពំនអស់ ដើម្បីបង្ហាញឲ្យឃើញនូវសេចក្តីសម្រេចចិត្តរបស់ខ្ជួនថា នឹងប្រយុទ្ធកំចាត់បង្ហាមិត្តនៃមនុស្សជាតិបោលបេញតឹសត្ត្រាមនឹងសេចក្តីទុក្ខសោកនេះឯន ។

សេចក្តីគោរពពុទ្ធជយន្តិនេះ សម្រាប់ប្រកាសពិភពលោកឲ្យដឹងនូវគោលច្បាប់ដឹទៀនទាត់នៃសន្តិភាព ហើយនឹងត្រៀនរំលត់សេចក្តីទុក្ខសោក, ពិធីបុណ្យផ្សន។ ពំនឲ្យាយដែលនឹងប្រព្រឹត្តទៅចំពោះពុទ្ធជយន្តិ ក៏ត្រូវប្រើសម្រាប់រំលឹកស្ថានតីនៃពិភពលោក អំពីជំនួយដឹធំទូលាយនៃមហាសាសនាយើន ជាសាសនាប្រព្រឹត្តទៅបាន ៦៥ សតវត្សមកហើយ ដើម្បីវឌ្ឍនភាពខាងផ្លូវចិត្តនឹងខាងវប្បធមិនៃមនុស្សជាតិ ការធ្វើពិធីដឹមហោឡារិកនៃពុទ្ធជយន្តិ ដែលប្រព្រឹត្តទៅនៅប្រទេសកម្ពុជា គឺជាសញ្ញាមួយនៃសេចក្តីគាប់ប្រសើរបំផុត ព្រោះប្រទេសកម្ពុជា ជាកន្ទែងមួយដែលសំបូណិយាំនក្រៃលែន ដោយវិជ្ជាពុទ្ធសាសនា ។ ដោយ

ស្ថិតនៅក្រោមមគ្គុទ្ទេស ដ៏ប្រកបដោយចិត្តអាស្សរករុណា នឹងជំនួយនៃ
រដ្ឋាភិបាលប្រទេកម្ពុជា សហជីវិនពុទ្ធសាសនិកតំងឡាយនៃពិភពលោក
តំងមូល អាចសង្ឃឹមថា មានជំនួយដ៏ស័ក្តិសិទ្ធដល់សន្តិភាពក្នុងពិភព
លោក នឹងដល់វឌ្ឍនភាពខាងផ្លូវចិត្តនៃពុទ្ធសាសនិកតំងឡាយ នៅ
ប្រទេសកម្ពុជា ។

នៅឧកាសដ៏គាប់ប្រសើរនៃពុទ្ធជយន្តិនៅប្រទេសកម្ពុជានេះ យើង
មានកិត្តិយសដ៏ធំ ព្រមតំងមានសេចក្តីរីករាយនឹងថ្វែងក្នុងនាមនៃពុទ្ធ-
សាសនិកជាតិអាមេរិកតំងឡាយ នូវអំណរសេចក្តីសរសើរនឹងពរសាពួ
សាធុការដ៏យ៉ាងប្រណីតរបស់យើងចំពោះជនតំងឡាយតំងអស់ ដែល
ចូលរួមក្នុងព្រិត្តិការណ៍ដ៏ធំ ខាងប្រវត្តិសាស្ត្រនេះ ។

ហត្ថលេខា: ធីស្តុប-អេរីយូ-ស្តីសីភូតី

× × ×

សារនៃពុទ្ធសាសនិកជាតិម៉ាឡាយូ

ជាមហាបុព្វសិទ្ធិដ៏ពិតប្រាកដ នឹងជាកិត្តិយស ដែលយើងខ្ញុំបានមក
សំដែងខ្ជូនក្នុងឧកាសដ៏មហោឡារិកនៃបុណ្យ ព.ស. ២៥០០ វស្សា
នៅព្រះរាជអាណាចក្រកម្ពុជា ហើយបានធ្វើជាអ្នកនាំសារ ជាភាតរភាព
នឹងប្រកបដោយសុធនូ: នៃក្រុមពុទ្ធសាសនិករបស់សហពន្ធម៉ាឡាយូមក
ចូលនឹងសហជីវិនតំងឡាយរបស់យើងនៃប្រទេសកម្ពុជានេះ ។ យើង
មិនត្រឹមតែនាំយកនូវពរសពួសាធុការ ដ៏គាប់ប្រសើរនៃពុទ្ធសាសនិកជាតិ
ម៉ាឡាយូដើម្បីឲ្យពិធីបុណ្យខាងសាសនាដ៏ឡារិកនេះ បានប្រកបដោយ

ដោតជ័យតែប៉ុណ្ណោះទេ, តឺយើងនាំយកទាំងពរសព្ទសាធុការដ៏ស្មោះ ស្ម័ត្រសូមឲ្យឧកាសនៃប្រវត្តិសាស្ត្រនេះ ទុកជាសម័យសម្រាប់បណ្តុះ បណ្តាលក្នុងជួងហប៉ូទ័យនៃមនុស្សលោកនូវវឌ្ឍនភាព ដ៏ជាទីតោរពខាង សាសនាតាមឧវាទប្រកបដោយាតតិបណ្ឌិត ហើយមានសភាពដ៏ស្ថិតស្ថេរ នៃព្រះពុទ្ធបរមត្រូជាអម្ចាស់ផង ។

នៅសម័យសព្វថ្ងៃនេះ សេចក្តីលោភ ការមិនទុកចិត្ត មួយអន្ទើ ដោយសេចក្តីតំនុំតុំតួន កំពុងប្រៀតជ្រែកចូលក្នុងពិភពលោក ហើយ មនុស្សលោកតែងតែលុះក្នុងអំណាចដ៏លាមកនៃធម្មជាតិរបស់ខ្ជួន ។

ក្នុងដំណើរដ៏វិលវល់នឹងប្រាសចាកសេចក្តីចំរើនធ្ពោះទៅរកអំណាច នឹងសេចក្តីចំរើនរុងរឿងក្នុងលោកសន្ទ្ធិវាស ដែលមានការប្រែះធានេះ មនុស្សរមែងមើលឆាយ ហើយធ្វើជាមិនដឹងនូវព្រះឧវាទនៃព្រះបរមត្រូ សម្ពុទ្ធ ។ មនុស្សក្ខាយទៅជាងងឹតចំពោះការពិត ដែលជាផ្ទូវនៃសេចក្តី សុខចំរើន នឹងជាផ្ទូវនៃការពង្រីកជីវភាពរបស់ខ្ជួនខាងសាសនា ។

មនុស្សកំពុងតែមានចិត្តប្រាសចាកផែនការខាងសាសនា ម្ហ៉ោះ ហើយសេចក្តីត្រូវការសព្វថ្ងៃចំពោះព្រះធមិរបស់ព្រះអង្ត ជាការចាំបាច់ ដ៏រួសរាន់បំផុត ។

ក្នុងសម័យដែលមនុស្សជាតិកំពុងទទួលកំហែង គឺការបំផ្ទេចបំផ្ទាញ ឲ្យវិនាសដោយពេញទំហឹងដោយវិធីប្រើប្រាសចាកបញ្ញានូវវិទ្យាសាស្ត្រ ទាំងឡាយដែលខ្ជួនបានរកឃើញនោះ, គឺមានសេចក្តីវីកវាយពេញចិត្ត

តេក ដោយសង្កេតឃើញមានព្រះមហាក្សត្រខ្មែរជាច្រើនដែលបានយាងដូចជាព្រះករុណាជាអម្ចាស់ដ៏វិសេសលើសលុនព្រះចៅប្រទេសកម្ពុជា ដែលព្រះអង្គមិនមានព្រះទ័យរួញរាធ្វើការគាត់តែងឲ្យមានទុក្ខាសដ៏មហាឧត្តុង្គដូចជាទុក្ខាសនេះដើម្បីបង្ហាញឲ្យឃើញច្បាស់ថា ការដោះមនុស្សឲ្យផុតពីសេចក្តីទុក្ខ មិនមែនត្រូវការប្រើកំឡាំងយោរយៅឡើយ តែត្រូវការប្រព្រឹត្តតាមព្រះធម៌ដ៏ខ្ពង់ខ្ពស់នៃព្រះសម្មាសម្ពុទ្ធវិញ ។

យើងសូមឲ្យឆ្នាំនៃពុទ្ធជយន្តិនេះ ទុកជាជំនាន់សកលមួយនៃការជួរស្រោលនឹងខាងសន្តិភាព ក្នុងពិភពលោកប្រកបដោយសុខនេះ ហើយសូមឲ្យព្រះធម៌នៃព្រះពុទ្ធជាម្ចាស់ក្នុងរយៈ ២៥ សតវត្សក្នុងនេះ លេចឡើងដូចជាប្រទីប ដ៏មានរំជួលប្រកបដោយពន្លឺរស្មីចាំងភ្លឺក្នុងទីងងឹតចាំងច្បាយ ជួយដឹកនាំមនុស្សលោកទៅកន្លែងត្រូវត្រង់ ព្រមទាំងធ្វើឲ្យពិភពលោកមានសេចក្តីសង្ឃឹមមានសេចក្តីក្សាហាន ព្រមទាំងឲ្យរួចរដោះពីសេចក្តីទុក្ខវេទនាគ្រប់យ៉ាង ។

មិនតែប៉ុណ្ណោះ យើងសូមថ្លែងអំណរគុណដ៏ស្មោះស្ម័គ្រចំពោះសេចក្តីរួមសប្បុរសធម៌ដ៏ខ្ពង់ខ្ពស់ យើងចំពោះពុទ្ធសាសនិកជាតិខ្មែរ ទីឯចំពោះរដ្ឋាភិបាលនៃប្រទេសកម្ពុជាតំណាងពុទ្ធសាសនិកនៃសហព័ន្ធមាឡាយូ ឲ្យមកចូលរួមក្នុងមហាពិធីបុណ្យនៅលើដែនដីខ្មែរនេះ ។

ជយោសន្តិភាព!

× × ×

សារនៃសមាគមមហាពោធិនៃប្រទេសឥណ្ឌា

សមាគមមហាពោធិនៃប្រទេសឥណ្ឌា សូមថ្វៃនូវអំណរសរសើរ ចំពោះរដ្ឋាភិបាល និងប្រជារាស្ត្រទ្វេរនៅឱកាសពិធីបុណ្យ ព.ស. គម្រប់ ២៥០០ វស្សា ។ ថ្ងៃនេះ ប្រទេសឥណ្ឌាទាំងមូលមាន សោមនស្សរីករាយ ចូលរួបរួមជាមួយប្រទេសកម្ពុជា ព្រោះប្រទេសឥណ្ឌា ជាកន្ទែងប្រសូតិនៃព្រះបរមគ្រូសម្ពុទ្ធ ហើយគោលមូលដ្ឋានខាងវប្បធម៌ នៃប្រទេសទាំងពីរបង្ហាញឲ្យឃើញជាក់ច្បាស់នូវនិន្នាការដូចគ្នា ។ ថ្ងៃ វិសាខគម្រប់ ២៥០០ ព្រះវស្សា គឺជាប្រផ្ទូលអនាគតរបស់មនុស្សជាតិ ថា និងមានចិត្តគំនិតលើសជាងសត្វតិរច្ឆាន ទៅរកសភាពដ៏ទៀងទាត់សុចរិត ក្នុងជីវិត ហើយទឹកដីទាំងឡាយរបស់យើង ព្រមទាំងជម្សន់ផ្សេងៗទៀត ក៏បានត្រូវការនូវបំណងដ៏ធំដូចគ្នា ហើយនឹងនូវការស្តាប់គ្នាបាន និងការ រួមគ្នាខាងវត្ថុបំណងជាអវសានដែរ ។

នៅឱកាសដែលគួរកំណត់ទុកក្នុងប្រវត្តិសាស្ត្រនេះ សមាគមមហា ពោធិនៃប្រទេសឥណ្ឌាមានសេចក្តីរីករាយពិសេស ដើម្បីបន្ទែមកម្ចាំង លើបំណងទាំងឡាយរបស់ខ្ងួន លើប្រទេសកម្ពុជា ដែលជាបំណង មានមកហើយតាំងពីយូរយារណាស់នោះ ។ យើងសូមរំលឹកនូវមនោ សណ្ឋានភិច្ឆឯក ដែលបានមកអំពីសំណាក់នៃព្រះករុណាជាអម្ចាស់ជីវិត លើត្សូង ព្រមទាំងអំពីសំណាក់នៃប្រជារាស្ត្រទ្វេរ ចំពោះព្រះសារីរិកធាតុ នៃព្រះអរហន្តសារីបុត្តនឹងមហាមោគ្គល្ខាន តាមសេចក្តីអញ្ជើញនៃរដ្ឋា- ភិបាលប្រទេសកម្ពុជា ។ មនោសញ្ចេតនារួបរួមគ្នាដែលបានដុះដាល

ឡើងនៅទូកាសនេះ រាជធានីប្រទេសឥណ្ឌា និងប្រទេសកម្ពុជា សម្រាប់ប្រើទុកជាចំណងក្នុងកិច្ចប្រស្រ័យទាក់ទងប្រកបដោយភក្តីភាព ដែលធ្លាប់មានមកហើយ ឱ្យរឹងតែតែចំរើនឡើងទៀត រាជធានីប្រទេសទាំងពីរ ។

ចំពោះជនជាប្រជុំ ការខ្វល់ខ្វាយរបស់មនុស្សជាតិតែងតែធ្វើឱ្យមានឧបសគ្គដល់ផ្លូវវិឈ្នានភាព ប៉ុន្តែជនទាំងឡាយណាដែលអាចប្រព្រឹត្តតាមសេចក្តីយល់ដឹងសមរម្យរបស់ខ្លួនតាមគោលធ្លាប់នៃព្រះពុទ្ធជាម្ចាស់ អាចមានដំណើរលឿនទៅមុខតាមផ្លូវស្ថិតបាន ដើម្បីជាប្រយោជន៍ដល់មនុស្សជាតិទាំងមូល ។ ការយល់ត្រូវគឺសម្មាទិដ្ឋិ រមែងបំភ្លឺឱ្យឃើញនូវការពិតមិនមានអាថ៌កំបាំងតទៅមុខទៀត ដែលអាចធ្វើបានដោយងាយអំពីសំណាក់នៃជនដែលប្រព្រឹត្តតាមនូវនៃព្រះសម្មុខឡើយ ។ ប្រវត្តិសាស្ត្របង្ហាញភស្តុតាងនៃរឿងនេះ ដែលប្រទេសកម្ពុជាដូចជាប្រទេសកាន់ព្រះពុទ្ធសាសនាទាំងឡាយដទៃបានរួមរួមដោយចេះស្មោះត្រង់ក្នុងព្រះធម៌ ដើម្បីសុខុមាលភាពដល់ប្រជារាស្ត្រវេស់ខ្លួន ទោះបីមានសេចក្តីលំបាកយ៉ាងណាក៏ដោយ ។

ប្រទេសកម្ពុជាដែលមានសេចក្តីខ្នះខ្នែងក្នុងលទ្ធិនៃព្រះពុទ្ធសាសនាបានជួយឱ្យកូនចៅរបស់ខ្លួនអាចផ្ទុះឆ្កាត់នូវមហន្តរាយបាន ។ ប្រទីបបញ្ញានេះបំភ្លឺក្នុងប្រទេសកម្ពុជា តាំងពីច្រើនសតវត្សណាស់មកហើយ ។ គេរមែងគោតសរសើរជាច្រើន ចំពោះគំនិតខាងពលិកម្មនៃឥស្សរជនជាច្រើនក្នុងប្រទេសនៃអស់លោក-អ្នក ដូច្នេះ ផ្លូវសីលធម៌ធំទុកជាឧទាហរណ៍សម្រាប់ពិភពលោក ព្រោះថានៅទីណាមានប្រទីប គឺព្រះពុទ្ធព្រះធម៌ធំព្រះសង្ឃដើម្បីគ្រាលបំភ្លឺគំនិតនៃមេដឹកនាំតាំងឡាយហើយ

នៅទីនោះសេចក្តីចំរើនរុងរឿងខ្លាំងតែកើតមានដល់ប្រជាពស្ត្រដោយពិតៗ

ទោះបីមានសេចក្តីចំរើនដែលមិនសមយកតំណែងយ៉ាងនេះក៏ដោយចុះ តែនៅមានមនុស្សក្រមខ្លះដែលតាំងនៅក្នុងជង្រៃបនៃសេចក្តីតំនុំតួន ។ មនុស្សជាតិរមែងសំបូរណ៌ទៅដោយការសម្អាត ដែលផ្សាយចេញពីធម្មជាតិដ៏ឃ្មាំងឃ្មាំដើម្បីធ្វើឲ្យនៅសន្ធូរមិត្តភាពនឹងសេចក្តីមេត្តាករុណា ។ សព្វថ្ងៃនេះមនុស្សបានស្ទុះស្ទឹងកន្ទុះសើចភាជនេយ្យាចាយនឹងភាពសង្គម ដែលជាការណ៍លះបង់ចោលនូវក្តីមិតភក្តី តែឯកពជ្ឈរបស់ខ្លួនទៅក្នុងធន្លុះជាអកុសល ដោយបង្ហាញភាជនេយ្យាចាយ តែជាការបំផ្លេចបំផ្លាញ ដើម្បីស្ថាបនានូវសេចក្តីឧត្តុង្គឧត្តមរបស់ខ្លួនលើក្រមមនុស្ស ។

មនុស្សអាចនឹងស្ថាបនាជាថ្មីឡើងវិញបាន នូវសេចក្តីឧត្តុង្គឧត្តមរបស់ខ្លួនដែលអន្តរធានបាត់ទៅក្នុងពិភពលោក ដោយពិធីប្រតិបត្តិព្រះធម៌ព្រះសម្មុខតែប៉ុណ្ណោះ ព្រោះមានតែព្រះធម៌មួយទេ ដែលអាចធ្វើឲ្យមានតំនិតដ៏ពិតប្រាកដខាងឯកពជ្ឈ ដោយរំលឹកមនុស្សនោះឲ្យដឹងនូវការខ្វល់ខ្វាយត្រង់របស់ខ្លួនចំពោះការណ៍ឃាតិក ដើម្បីទំលុះទំលាយនូវចំណងនៃទាសភាព ដែលតែងតែមនុស្សភ្ជាប់ទៅនឹងពិភពលោកខាងការគាថកំចាំង ។ គឺមានតែប្រព្រឹត្តនូវបញ្ញាសីលនេះហើយ ទើបមនុស្សអាចដោះខ្លួនរួចចេញពីការខ្វល់ខ្វាយត្រង់ដ៏មានខម្លង់បាន, ឯបញ្ញាសីលមានអត្ថរស តែសេចក្តីមេត្តាករុណានឹងអហឹង្សា ។ មនុស្សជាតិអាចធ្វើជំណើរឆ្ពោះទៅកាន់ខ្ពង់ខ្ពាគាពបាន លុះណាតែខ្លួនបាត់បង់ចោលនូវការប្រព្រឹត្តិចំពោះប្រយោជន៍ខ្លួនចោលចេញ ។ សូមមេដឹកនាំតាំងឡាយ នៃ

ប្រទេសកាន់ព្រះពុទ្ធសាសនារបស់លោក.អ្នក បង្ហាញប្រជាពស្ត្រឲ្យដឹងនូវព្រះតេជគុណដែលប្រសម្ពុទ្ធបរមគ្រូ បានទ្រង់ប្រទានដល់មនុស្សលោក ចំនួន ២៥០០ វស្សាមកហើយនេះ ។

ដោយថ្លែងនូវអំណរសរសើរ ចំពោះប្រជាពស្ត្រប្រទេសកម្ពុជា សមាគមមហាពោធិ៍នៃប្រទេសឥណ្ឌា សូមថ្លែងនូវបំណងសុំឲ្យប្រទីបតំបញ្ញាទីឯសេចក្តីសុខ-ចំរើន ដែលបានដុះដាលក្នុងប្រទេសរបស់យើងចំនួនជាច្រើនសតវត្សមកហើយនោះ បន្តពន្ធឹជាតិយោគាពទៅទៀតដល់ដួងចិត្តប្រជាពស្ត្រេបស់លោក អ្នក ដើម្បីជាប្រយោជន៍តិសុខុមាលភាពនៃអ្នកទាំងអស់ ហើយទីឯដើម្បីឲ្យមនុស្សលោករួចរោះចេញពីសេចក្តីទុក្ខទាំងឡាយ ។

ហត្ថលេខា: ស្រីទេវប្រិយៈ វិស័ង្ក

× × ×

សារនៃព្រះអង្គម្ចាស់ក្សត្រីជាតំណាងពុទ្ធិកសមាគមប្រទេសថៃ

សូមជំរាបឯកឧត្តម,

សូមក្រាបបង្គំសម្តេចនរោត្តមព្រះថេរាទុត្តរៈទាំងឡាយ,

សូមជំរាបលោកស្រី ទីឯកអស់លោកទាំងឡាយ !

ពុទ្ធិកសមាគមនៃប្រទេសថៃ ដែលស្ថិតនៅក្រោមព្រះរាជូបត្ថម្ភដ៏ខ្ពង់ខ្ពស់នៃព្រះករុណាជាអម្ចាស់ជីវិតលើស្ងួនប្រទេសថៃ បានតាំងខ្ញុំជាតំណាង ដើម្បីថ្លែងក្នុងទីនេះជូនអស់លោកអ្នក នូវអំណរសរសើរដ៏ស្មោះស្ម័គ្រក្រៃលែងរបស់ពុទ្ធិកសមាគមក្នុងឧកាសដ៏មហោឡារិកនេះ ។

សព្វថ្ងៃនេះ ពិភពលោក បានយល់នូវព្រះពុទ្ធសាសនាច្បាស់ត្រាន់បើជាងពេលមុន យើងទាំងអស់គ្នាជាពុទ្ធសាសនិកមានសេចក្តីរីករាយជាអនេក ព្រោះការយល់ច្បាស់នេះ នឹងបើកឧកាសឲ្យយើងរាល់គ្នាអាចជួយផ្សាយព្រះធម៌បានត្រាន់បើ រឿងនេះ គឺប្រព្រឹត្តតាមឧទាហរណ៍ដែលព្រះសម្ពុទ្ធបរមត្រូបានទ្រង់ប្រទាន ក្នុងការដែលព្រះអង្គទេសនាប្រដៅពិភពលោកឲ្យស្គាល់ច្បាស់នូវផ្លូវពិត ដែលនាំទៅរកសេចក្តីសុខចំរើននោះ ។

ព្រះពុទ្ធសាសនាបានបញ្ជាក់នូវដំណៃឲ្យឃើញពិតនឹងភ្នែក អស់រយៈពេលចំនួន ២៥០០ ឆ្នាំហើយ ។

តាំងពីយូរកាលអង្វែងណាស់មកហើយ ប្រទេសកម្ពុជានឹងប្រទេសថៃ បានប្រកាន់យកនូវព្រះពុទ្ធសាសនារួមគ្នា ទុកជាសាសនាសម្រាប់ជាតិ ។ ជូច្នេះ យើងពួតដៃគ្នាប្រឹងខំប្រតិបត្តិតាមព្រះពុទ្ធឧវាទ ដើម នាំមកនូវសន្តិភាពក្នុងពិភពលោក ។

ក្នុងនាមនៃពុទ្ធិកសមាគមនៃប្រទេសថៃ ខ្ញុំសូមជូនពរសព្វសាធុការតសេចក្តីសុខសេចក្តីចំរើន ឲ្យកើតមានជល់អស់លោក-អ្នកដែលបានស្តាប់ច្បាស់នូវឧបការគុណនៃព្រះសម្មាសម្ពុទ្ធជាម្ចាស់នោះ ។

×

× ×

សារនៃសហពន្ធពុទ្ធសាសនិកនៅប្រទេសជប៉ុន

ខ្ញុំមានសេចក្តីរីករាយនឹងកិត្តិយសផ្ទៀតឧកាសនេះ បញ្ជូនសេចក្តីគោរពរបស់ខ្ញុំ ក្នុងនាមនៃពុទ្ធសាសនិកទាំងអស់នៃប្រទេសជប៉ុន មក

ប្រទេសរបស់លោកអ្នក ដែលកំពុងធ្វើពិធីបុណ្យព.ស. ២៥០០ រស្យា ។

ព្រះមហាសក្យមុនី បានទ្រង់លះបង់រាជសម្បត្តិ បានទ្រង់លះបង់ព្រះអត្តមហេសីនឹងព្រះរាជបុត្ត ព្រះអង្គបានទ្រង់ព្រះផ្ទួស ហើយស្វះស្វែងរកសេចក្តីត្រាស់ដឹង ។

មាតាដែលព្រះអង្គ បានជ្រើសយកមានតែមួយ គឺមាតាដែលធ្វើឲ្យបុត្តលនឹងសង្គម បានទ្ទរសេចក្តីសុខ-ចំរើនដ៏ខ្ពង់ខ្ពស់ ហើយមិនអាចវិនាសទៅវិញបាន គឺសន្តិភាពដ៏ស្ថិតស្ថេរនេះឯង ។

ដូច្នេះ ព្រះឥរាទនៃព្រះអង្គបដិសេធទ្ទរមនុស្សទាំងឡាយណា ដែលស្វែងរកទ្ទរសេចក្តីចំរើនផ្ទាល់ខ្ទួនដោយធ្វើឲ្យមនុស្សដទៃបានសេចក្តីទុក្ខ ឬក៏ធ្វើប្រជាជាតិណាមួយឲ្យប្រាសចាកសេចក្តីរុងរឿងរបស់គេ ហើយព្រះអង្គទ្រង់ប្រដៅឲ្យដឹងថា មនុស្សត្រូវតែទូន្មានចិត្តរបស់ខ្ទួនឲ្យមានសេចក្តីមេត្តាករុណា នឹងត្រូវទូន្មានខ្ទួនឲ្យលះបង់ទ្ទរសេចក្តីប្រាថ្នាដែលជាគោលតណ្ហានោះចោលចេញ ។

ព្រះពុទ្ធសាសនាបានផ្សាយចូលមកក្នុងប្រទេសជប៉ុន ចំនួនជាង ១០០០ ឆ្នាំហើយ ។ ប៉ុន្តែមនុស្សដែលបានស្គាល់ច្បាស់ទ្ទរអត្ថរសដ៏ជ្រាលជ្រៅនៃព្រះពុទ្ធសាសនា ហើយដែលទុកព្រះពុទ្ធសាសនាជាមគ្គុទ្ទេសក៍ជាន់ខ្ពស់បំផុតនៃជីវិត ព្រមទាំងជាមគ្គុទ្ទេសក៍ជាន់ខ្ពស់បំផុតនៃប្រជាជាតិ មិនគឺអ្នកណាដទៃក្រៅពីព្រះអង្គម្ចាស់សូតូតូទេ ។ ព្រះអង្គម្ចាស់នេះបានទ្រង់ប្រសូតចំនួន ១៣៨០ ឆ្នាំហើយ ។ ក្នុងរយៈ ៦០ ឆាំ

ទ្រង់បានត្រូតត្រាប្រទេសជប៉ុន ក្នុងហានៈជាអាជ្ញាសិទ្ធិរាជ ហើយទ្រង់បានចាក់ត្រឹសតឺព្រះពុទ្ធសាសនា នេះឲ្យមានរហូតមកដល់សព្វថ្ងៃនេះឯង ។

ព្រោះហេតុនេះហើយ ទើបប្រជាពស្ត្រជប៉ុនតែងគោរពទ្រង់ទុកជាអ្នកបង្កើតព្រះពុទ្ធសាសនានៅប្រទេសជប៉ុន ។ រហូតដល់ទីវង្គតទៅព្រះអង្គម្ចាស់សូតូគូ មិនមែនត្រាន់តែជាពុទ្ធសាសនិកដ៏បរិសុទ្ធប៉ុណ្ណោះទេ គឺព្រះអង្គបានទាំងមានអានុភាពដ៏ធំ ផ្ទើឲ្យព្រះរាជបុត្ររបស់ព្រះអង្គព្រះនាមយ៉ាមីស៊ីរូណអូយ៉ៃអូ កាន់ព្រះពុទ្ធសាសនាជូចព្រះអង្គផង ។ កាលដែលព្រះអង្គម្ចាស់ អូយ៉ៃអូ បានទទួលការប្រហារពីឈ្មោះសូហ្គាណូអ៊ីរុកាជាមេបក្សសម្ពន្ធមួយដ៏មានអំណាចនោះ មិត្តភ័ក្តិរបស់ទ្រង់ជាច្រើន បានទូន្មានទ្រង់ឲ្យប្រយុទ្ធតនឹងឈ្មោះអ៊ីរុកា ប៉ុន្តែទ្រង់មិនព្រមទទួលផ្ទើការប្រយុទ្ធតបទ្បើយ ទ្រង់ពោលថា "អ្នកឈ្នះក្នុងការប្រយុទ្ធ មិនមែនជាមនុស្ស ដែលគេចាត់ទុកថាមានសេចក្តីអង់អាចទេ ។ ឯមនុស្សដែលមានឈ្មោះថាជាអ្នកអង់អាចដ៏ពិតប្រាកដនោះ គឺនរណាដែលចេះពង្រីកសន្តិភាពក្នុងប្រទេសរបស់ខ្ជួនបាន ហើយបំបាត់ឈ្មោះមិនឲ្យអ្នកណាជឹងថែមទៀត" ។

ដោយទ្រង់មិនព្រមផ្ទើសង្គ្រាម ទ្រង់បានបញ្ជូនចុតហ្មាយមួយទៅបច្ចាមិត្តរបស់ព្រះអង្គឈ្មោះសូហ្គាណូអ៊ីរុការ , ក្នុងចុតហ្មាយនោះទ្រង់បានប្រកាសថា: "ខ្ញុំយល់ច្បាស់ថា ខ្ញុំប្រហែលជានឹងមានជ័យជំនះប្រសិនបើខ្ញុំលើកទ័ពមកផ្ទាញ់លោក, ប៉ុន្តែខ្ញុំមិនមានបំណងអ្វីមួយចង់ឲ្យមនុស្សស្ទាប់ ដោយសារតែកំហុសរបស់ខ្ញុំនោះទេ" ។

អំពីនេះឯងហើយដែលជាឧទាហរណ៍ នៃដួងវិញ្ញាណប្រកបដោយ
ករុណាធម៌ដែលគ្រាយទៅជាអ្នកប្រវត្តិទី ១ នៃជីវភាព តាមលំអានព្រះ
ឧវាទនៃសម្តេចព្រះមហាសក្យមុនីរបស់យើង ។

ខ្ញុំយល់យើញថាគឺជាកិត្តិយសមួយដ៏ធំដល់រូបខ្ញុំ ក្នុងការជូនដល់
ប្រទេសរបស់អស់លោកអ្នកក្នុងឧកាសនេះ ក្នុងនាមនៃសហពន្ធពុទ្ធ-
សាសនិកជាតិជប៉ុន នូវព្រះរូបជាវិការៈនៃឈើ នៃព្រះអង្គម្ចាស់សូតូតុ
ដែលខ្ញុំបានពោលរៀបរាប់ហើយខាងលើនេះ ។

× × ×

សារនៃប្រជាងពុទ្ធិកសមាគមសហភាពរុស្សុ
ថ្វាយបំពោះសម្តេចព្រះឧបយុវិរាជនរោត្តមសីហនុ

ក្នុងនាមនៃពុទ្ធសាសនិកជនសហភាពរុស្សុ ព្រមទាំងក្នុងនាមអាត្មា
ភាពៗសូមអភ័យទោសសម្តេច, សូមថ្វែងនូវសេចក្តីសរសើរចំពោះ
សម្តេច នឹងពុទ្ធសាសនិកជនប្រទេសកម្ពុជា ជាកល្យាណមិត្រៈបស់
យើងក្នុងឧកាសពិធីបុណ្យ ២៥០០ វស្សា រំលឹកព្រះបរមសម្មាសម្ពុទ្ធ
ក្រោយដែលព្រះអង្គទ្រង់ចូលបរិនិព្វាន ។

អាត្មាភាព សូមថ្វែងនូវអំណរព្រះតេជះព្រះគុណ ជាយ៉ាងក្រៃលែង
ចំពោះសម្តេច ដោយមានសេចក្តីនិមន្តអាត្មាភាពទៅរួបរួមក្នុងពិធីបុណ្យ
នេះ ។ អាត្មាភាពមិនអាចនឹងចូលមករួបរួមក្នុងពិធីបុណ្យបាន មកពីការ
ទទួលសេចក្តីនិមន្តក្នុងរយៈរវាងដ៏តិចពេក (ថ្ងៃទី ១២ ឧសភា) ។

អាត្មាភាព ក្នុងនាមនៃពួកពុទ្ធសាសនិកជនសហភាពរុស្សុ នឹងក្នុង

នាមអាត្មាភាព, សូមថ្វាយព្រះពរ, សូមព្រះអង្គប្រកបដោយសន្តិភាព, សុភមង្គល, សូមប្រជាពស្ត្រៀឡរប្រកបដោយសន្តិភាព, សុវត្ថិភាព, សម្ឈូណ៌ភាព ។

អត្មាភាព សូមថ្វែងនូវសេចក្តីសោមនស្សជាយ៉ាងក្រៃលែងចំពោះសម្តេច កាលដែលអាត្មាភាពបានជួបសនូនាការជាមួយសម្តេច នៅទីក្រុងមុស្គូ ។

ដោយអាត្មាភាពមានចិត្តស្មោះស្ម័ត្រប្រតិបត្តិតាមព្រះទរាទ នៃព្រះបរមសម្ពុទ្ធជាម្ចាស់, យើងសូមឲ្យសន្តិភាពកើតមានជល់សកលលោក, សុភមង្គលចំពោះប្រជាពស្ត្រទាំងអស់ ។

ហត្ថលេខា: សម្តេចប៉ងហ៊ីទ្ធ-ហ៉មឡូ-ឡាមា៉-អ៊ីកធី ជ៉ីជ៉ ចាភ៉ីប៉ូ

\+ + +

សង្ឆាជាតៃលោក ភ៉ីយ-ល្មុត

អនុប្រជានពុទ្ធិកសមាគមកម្ពុជរដ្ឋ

ព្រះថេរានុត្តរៈទាំងឡាយ !

ទ្រង់ !

អស់លោក-អ្នកទាំងឡាយ !

ថ្ងៃនេះជាថ្ងៃពេញបូណិមី ខែពិសាខ ឆ្នាំរកានពូស៉ក ពុទ្ធសាស-នាយុកាលតម្រប់ ២៥០០ វស្សា ជាថ្ងៃបុណ្យ ព.ស.២៥០០ ជាកាលបរិច្ចេទដែលព្រះសក្យមុនីគោតមសម្មាសម្ពុទ្ធបរមត្រូទ្រង់ប្រសូតផង, ទ្រង់លុះអរហត្តកំចាត់នូវអាសវក្កិលេសបេញអស់ចាកសន្តាន បានឡើងជាព្រះ

សព្វញ្ញុតញ្ញាតុ ត្រាស់ដឹងខ្លួវញ្ញេយ្យធម៌សព្វគ្រប់ផង, ទ្រង់ចូលកាន់ព្រះបរមនិញ្ញាន ជាស្ថានវិសេសក្ខុក្ខផង ។

ខ្ញុំ ព្រះករុណា, ខ្ញុំ បានទទួលអាណត្តិពីសមាជិកទាំងឡាយនៃគណៈកម្មាធិការនាយករបស់ពុទ្ធិកសមាគមកម្ពុជវត្ត ដែលតាងនាមពុទ្ធមាមកៈជាសមាជិកទាំងឡាយ ក្នុងព្រះពុទ្ធអាណាចក្រកម្ពុជា ឲ្យថ្លែងខ្លួវសង្កថានេះ ពីជាកិត្តិយសមួយធំដល់ខ្ញុំព្រះករុណា ខ្ញុំ ក្នុងឧកាសដ៏ទឡ្ហវិកនេះ ។

ជាដំបូង ក្នុងនាមនៃសមាជិកទាំងឡាយ ខ្ញុំព្រះករុណា, ខ្ញុំ សូមបង្ហាញកាយ, វាចា, ចិត្ត គោរពបូជា ចំពោះគុណព្រះរតនត្រ័យ គឺព្រះពុទ្ធ, ព្រះធម៌, សង្ឃ ។

លើជាប់តពីនេះ, ខ្ញុំព្រះករុណា, ខ្ញុំ សូមប្រាប្តជាសង្ខេបបំផុតថា ដោយសេចក្តីណែនាំនៃសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយ (ជួន-ណាត ដោតញ្ញាណោ) នេះខមួយ ខមួយទៀត ដោយព្រះបរមរាជូបត្ថម្ភ នៃព្រះករុណាជាម្ចាស់ជីវិតលើត្បូង ព្រះបាទសម្តេចព្រះនរោត្តម សីហនុវរ្ម័ន ដែលទ្រង់ស្តេចជាបរមរាជាធិបតីផង ហើយដោយពុទ្ធបរិស័ទទាំងឡាយខ្ញុំល្អាងឈ្លួនផង ពុទ្ធិកសមាគមកម្ពុជវត្តនេះបានកើតឡើងនៅប្រទេសកម្ពុជាយើង ក្នុងខែកក្កដា ព.ស. ២៤៩១ (គ.ស.១៩៤៨) ។

ព្រះករុណាទាំងឡាយ !

ទ្រង់ !

អស់លោក.អ្នកទាំងឡាយ !

សមាជិក, សមាជិកា ចាំងឡាយនៃពុទ្ធិកសមាគមកម្ពុជវដ្ឋគ្មានគោលបំណងអ្វីក្រៅពីការរួបរួមគ្នា ដើម្បីទ្រទ្រង់ព្រះពុទ្ធសាសនាឲ្យបានគង់វង្សរីកចំរើនតរៀងទៅ ព្រោះយល់ឃើញថា គ្មានពាក្យប្រៀនប្រដៅគ្រូអាចារ្យណា អាចនាំឲ្យសត្វលោកបានសុខចំរើន ចាំងលោកនេះនឹងទៅបរលោក ដូចពាក្យប្រៀនប្រដៅរបស់ព្រះអង្គទេឡើយ ។

ដោយហេតុនេះ យើងខ្ញុំព្រះករុណា, ខ្ញុំចាំងឡាយ បានប្រមូលផ្តុំគ្នាជាសមាគមជាកម្មាំង ដើម្បី៖

១- ជួយទប្ចូលពួកសមាជិក, សមាជិកា ឲ្យនាំគ្នាយកចិត្តទុកជាក់ប្រតិបត្តិ ឲ្យបានត្រឹមត្រង់តាមពុទ្ធាណត្តិ;

២- ទ្រលំទ្រាយកំប៉ងវិលលក ដើម្បីឲ្យពុទ្ធិកជនទូទៅក្នុងលោកមានឯកភាព, សាមគ្គីភាព ទំនាក់ទាក់ទងគ្នា;

៣- នាំគ្នាជួយធ្យូរយោគ្គវៃអនុត្តរធម៌របស់ព្រះសម្មាសម្ពុទ្ធបរមគ្រូ;

៤- ចាត់ចែងធ្វើសកម្មភាពខាងប្រជាសង្គ្រោះ, ការសិក្សា, វប្បធម៌ទំនាក់ទំនងការដៃទៀតជាមនុស្សធម៌ តាមពាក្យដំបូន្មានព្រះអង្គខាងៗ;

៥- ទំប្រឹងប្រែងធ្វើឲ្យមាន មិនត្រឹមតែ ឯកភាព ទំនុកដុមរ៉ៅងមនុស្សជាតិប៉ុណ្ណោះទេ តែឲ្យមានបុគ្គលចំពោះសត្វលោកទូទៅផងទៀត ដោយរួបរួមគ្នាទំនងអង្គការដៃទៀត ក្នុងកម្ពុជវដ្ដក្នុងពិភពលោកក្តី ដែលមានគោលបំណងដូចគ្នា;

៦- ចាត់ចែងឲ្យសមណៈបូជនីយសក្ការៈ និមន្តធ្វើដំណើរទៅនមស្ការបូជនីយដ្ឋានតាមក្នុងលោក, មិនតែប៉ុណ្ណោះ ចាត់ចែងសង្គ្រោះ

ដល់រវាងទាំងឡាយ ដែលចង់ចេញរៀនសូត្រខាងព្រះពុទ្ធសាសនា ឯ
ប្រទេសក្រៅផងខ្លះ ។

កម្មវិធីដែលរៀបចាប់ជាសង្ខេបប៉ុណ្ណោះ ខ្ញុំព្រះករុណា, ខ្ញុំទាំងឡាយ
បានខ្វល់ខ្វាយតតាមសប្រហែល ឃកចិត្តខុកជាក់ចំពេញតាមកម្លាំង
ដែលអាចធ្វើបានទាំងប៉ុន្មាន ។ តាំងពីពុទ្ធកសមាគមកម្ពុជរដ្ឋនេះ បាន
កើតឡើងមកទល់បច្ចុប្បន្នកាលដ៏អស្ចារ្យ ពោលគឺ ព.ស.២.៥០០ នេះ
សេចក្តីរីកចំរើនតែងមានឡើងជាលំដាប់គួរសង្ឃឹមខុកចិត្តបានថា ទោះបី
យ៉ាងម្តេចក៏ដោយ ព្រះពុទ្ធសាសនា ត្រូវតែមានជ័យជំនះជាជាតិ ព្រោះ
ជាព្រះបដិមាករ, ព្រះពោធិព្រឹក្ស, ព្រះសថូប, ព្រះជិនធាតុ, ព្រះធម៌
៨ ហ្មឺន ៤ពាន់ធម្មក្ខន្ធ, ព្រះអរិយសង្ឃ ទំនឹងព្រះសម្មតិសង្ឃ ដែលសម្តែច
ព្រះសិរីសក្យមុនីសព្វញ្ញុពុទ្ធជាម្ចាស់ ទ្រង់បានប្រតិស្ឋានខុកក្នុងលោក
ហើយ ជាវត្ថុស័ក្តិសិទ្ធិជាក់ស្តែងណាស់ សំពាប់ជាបុញ្ញក្ខេត្តដ៏ប្រសើរបស់
សត្វទាំងឡាយ ។

មួយទៀត កាលព្រះសម្មាសម្ពុទ្ធ ជាអគ្គបុគ្គល ជាឪពុំនៃសត្វ-
លោកបរិនិព្វានទៅហើយ កុលបុត្រ កុលធីតា នៃព្រះអង្គឥតធ្វេស
ប្រហែសសោះឡើយ ... " អប្បមាទោ អមតំ បទំ ... " ដោយបានធ្វើ
សង្គាយនា ជាច្រើនលើកច្រើនគ្រាប្រមូលផ្តុំដង្កាត់ ធម្មវិន័យទាំងឡាយ
ចងក្រងជាច្បាប់ស្តាពរផ្សាយតទៅគ្មាទៅ មានទាហរណ៍ប៉ុណ្ណោះជាដើមតំ
កុងពុទ្ធសតវត្សទី ៣ ព្រះមោគ្គល្លីបុត្តបានជាត់ ព្រះសមណៈប្រសិតជា
ច្រើនអង្គ ឲ្យទៅមិទ្ធផ្សាយព្រះពុទ្ធសាសនា ឲ្យបានជ្រួតជ្រាបខ្លួទៅដល់ក្នុ

ពិតពាលោក ។ ព្រះមហាថេរដែលទ័មន្តមកគាន់សុំណ្ណភូមិ មានពីរអង្គ មាននាមប្រាកដជា ព្រះសោណៈត្ថេរ ខឹងព្រះឧត្តរៈត្ថេរ ។ ប្រទេសកម្ពុជាយើងជាប្រទេសមួយក្នុងចំណោមសុវណ្ណភូមិ ប្រកបដោយព្រះមហាកត្រ័យគ្រប់ព្រះអង្គខឹងពស្ត្រខ្លួនៅ ទ្រង់មាន, មានទុបទ័សព្វ័យ ខឹងព្រះសម្មាសម្ពុទ្ធនោះ ក៏ព្រះពុទ្ធសាសនាបានកែចំរើនឡើងជាតិយ៉ាកាតក័ស្តុតាងគឺថ្ងៃបើកម្ពុជា ជាប្រទេសនៅគេកន្លែងបានឧបត្ថម្ភវិបន: មកសិក្សាប្រតិបត្តិកិតិមែន ប៉ុន្តែអ្នកប្រាជ្ញខឹងអ្នកប្រតិបត្តិជាបញ្ជីតក្តី ជាគ្រហស្តក្តី សញ្ជាតិជាខ្មែរសព្វថ្ងៃនេះ ថាមិនមានរបៀបរៀបរយជាងពុទ្ធសាសនិកនៃប្រទេសនានាក្នុងលោក នោះឥតអង្គឺមានឡើយ ។

ព្រះថេរានុត្ថេរាំងឡាយ !

ទ្រង់ !

អស់លោក-អ្នកាំងឡាយ !

ខ្ញុំព្រះករុណា, ខ្ញុំប្រតិស្ឋអធិស្ឋានសំបូងសម្រួងសូមឱ្យជនាំងឡាយណា អ្នកមានសទ្ធាក្នុងព្រះពុទ្ធសាសនា ដែលបានទ័មន្តអញ្ជើញមកបួមួកក្នុងពិធីបុណ្យនេះក្តី មិនបានទ័មន្តអញ្ជើញមកក្តី មានភិក្ខុ, សាមណេរ, ខឹងអ្នកគាន់សីល ១០, សីល ៨, សីល ៥ ជាដើម, ដែលពាក់ថាជាអ្នកមានលាភធំ សូមឱ្យជនាំងឡាយនោះ បានជាប់ឧបទ័សព្វ័យទៅក្នុងអនាគតតាមកំឡាំងសទ្ធា ខឹងសេចក្តីប្រាថ្នាវៀងខ្លួនតទៅ ។

ជាអាសាន, សូមព្រះករុណាំងឡាយ, ទ្រង់ខឹងអស់លោក-អ្នកាំងឡាយ តាំងនៅក្នុងអប្បមាទធម៌ជាមួយខឹងខ្ញុំព្រះករុណា, ខ្ញុំ!

លំដាប់តពីនេះ, តាងនាមនៃព្រះតេជព្រះគុណ ទាំងឡាយ, ទ្រង់នឹងអស់លោក អ្នកទាំងឡាយ ខ្ញុំព្រះករុណា, ខ្ញុំ សូមអធិដ្ឋានឯកតទៅនេះ ពោលគឺ៖ "អំណើះពីថ្ងៃនេះតទៅអនាគត, ជរាបណាសត្វលោក មានទៅក្នុងភពទាំងបី ខ្ញុំព្រះករុណា, ខ្ញុំ សំបូងសម្រូងសូមឲ្យព្រះពុទ្ធសាសនាថ្ពើងរុងរឿងជរាបនោះកុំបីឃ្សៀងឃ្ងាតឡើយ" ។

× + ×

សេចក្តីថ្លែងលោកឃួន-ណៃ

ប្រធាននៃសមាគមគិលានសង្រ្គោះ

បំពោះព្រះសង្ឆពុទ្ធសាសនិក

សូមព្រះតេជះតំកល់លើត្បូង !

សូមព្រះរាជទានព្រះបរមរាជវរោកាស !

សូមគោរពបំពោះសម្តេចទាំងពីរគណៈ, ព្រះថេរានុត្តរៈ !

ឯ.ឯ.ទីប្រឹក្សាក្រសួងមហាផ្ទៃ !

នឹងអស់លោកអ្នកសប្ឋុរសរួមសាសនាទាំងឡាយ !

ក្នុងកំឡុងមួយឆ្នាំនេះ ពុទ្ធសាសនិកជនក្នុងពិភពលោកបាននាំគ្នាសំដែងសេចក្តីអបអរសាទរបរិច្ចាគធនធានតាមកម្ចាំងសទ្ធា ធ្វើពិធីបុណ្យធ្ងងអាយុកាលនៃព្រះពុទ្ធសាសនាគំរប់ ២៥០០ វស្សា ក្រោមសេចក្តីឯបត្ថម្ភនៃរដ្ឋាភិបាលរៀងរាល់ប្រទេស ។ ជនជាតិយើងក៏បានយកចិត្តទុកដាក់ក្នុងរឿងនេះណាស់ដែរ ទើបកើតជាពិធីបុណ្យដ៏ឯ ឡារឹកអធិកអធមដ៏

ប្រត្យក្សក្នុងពេលនេះទ្បើង ។ ជំណើរនេះធ្ចុះឲ្យឃើញថា ពុទ្ធសាសនិក-
ជន ត្រប់ប្រទេស សុទ្ធសឹងមានបំណងស្របត្នាតែមួយ គឺការត្រេកអរ
សាទរនឹងកត្ថ្ថវាសនារៀងខ្ជួន ដែលកើតមកបានកពប្រសព្ធនឹងព្រះពុទ្ធ-
សាសនា ក្នុងពេលដែលព្រះពុទ្ធសាសនាកំពុងចម្រើនរុងរៀង ហើយ
មានបំណងចង់ឲ្យលទ្ធិជ្ប្រសើរនេះ រឹងរឹតតែចម្រើនរុងរៀងទ្បើងទៀត
ផ្សព្ធផ្សាយទ្ជូទៅត្រប់ទិសទីពាសពេញទាំងសកលលោក ។

សមាគមគិលានសង្រ្គោះចំពោះព្រះសង្ឆពុទ្ធសាសនិក ដែលចាប់
កំណើតកើតមានអាយុមកទល់ពេលនេះ បានចំនួន ៨ ឆ្នាំ ហើយក៏មាន
បំណងមិនខុសពីគោលខាងលើប៉ុន្ធានដែរ គឺ

ចង់ឲ្យព្រះសង្ឆពុទ្ធសាសនិកដែលជាអ្នកប្រព្រឹត្តតាមពាក្យទ្ធវាទ
ផ្ទាល់ ជាអ្នកផ្សាយព្រះពុទ្ធសាសនាមានសុខភាពបរិបូណិ ដើម្បីនឹង
បំពេញការណីយកិច្ចបានល្អប្រសើរ ។ ក្រសួងសុខាភិបាលក៏មិនមែន
ព្រងើយកន្តើយដែរ តែងចាត់ការថែជួនជួចជាសាធារណជនទ្ជូទៅដែរ
ប៉ុន្តែសមាគមចង់ឲ្យព្រះសង្ឆទាំងនោះ នៅកាន់ក្រិត្យវិន័យបរិសុទ្ធម៉ឹត់ចត់
ទោះបីមានជម្ងឺតម្ពាត់ប្រៀតប្រៀនរាងកាយក៏ដោយ មិនចង់ឲ្យមានការ
ប្របូកប្របល់ហួសហេតុពេក ដែលជាជំណើរមិនសមរម្យទាំងជាទំនាស់
នឹងវិន័យបញ្ញត្តិផង ។

ចង់រក្សាកល្យាណ ប្យវេណីនៃពុទ្ធមាមកជនជាបុព្ធបុរសពីបុរាណត្រេង
នាយ ចាប់តាំងពីកាលព្រះសម្ពុទ្ធបរមត្រូទ្រង់គង់ធរមានទៅដរាបមក ។
មានសេចក្តីជំណាលថា ក្នុងសម័យពុទ្ធកាលវេជ្ជបណ្ឌិតឈ្មោះ ជីវកកោ-

មារក័ត្ស ជាទសុំខ្ញុំជាអ្នកឥ្យាបាលរក្សាព្រះពោគនៃព្រះបរមគ្រូធំធំព្រះ
កិកុសន្ធ ។ ព្រះបាទជម្ងាសោកនៅជម្ពូទ្វីប ទំធំព្រះពាជាពុទ្ធសាសនិក
នៅលង្កាទ្វីប ជាទសាងសង់អារោគ្យសាលា គឺមទ្បីរពេទ្យ ព្រមទាំង
ផ្គត់ផ្គង់ថ្នាំសង្ឃវ៉ាគ្រប់បែបគ្រប់យ៉ាងចំពោះព្រះសង្ឃ ។ ព្រះមហាក្សត្រិយ៍
នៃកម្ពុជរដ្ឋសម័យបុរាណ មានព្រះបាទជយវរ្ម័នទី៧ជាដើម កំមាន
សិលាចារឹកជំណាលថា: ខ្ញុំមានព្រះពាជសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនា
បានចាត់ការឲ្យសាងសង់មទ្បីរពេទ្យផ្គត់ផ្គង់ថ្នាំ ការពារពេគសម្រាប់ព្រះ
សង្ឃ ទំធំប្រជាជនខ្ញុំទៅទាំងព្រះពាជអាណាចក្រ ។

ដោយហេតុប្រទេសយើងធ្លាក់ចុះជុំនជាបន្តបន្ទាប់អាទុគាពក្នុងសម័យ
ខ្លះនោះ ទំនៀមទម្លាប់នេះកំបានជាប់ជង់ទៅអស់កាលយូរហើយ ។ ទើប
តែក្នុងរវាង ៨ ឆ្នាំកន្លងមកនេះ ក្រោមព្រះបរមពាជូបត្ថម្ភនៃព្រះករុណាជា
អម្ចាស់ជីវិតលើត្បូង សម្តេចព្រះមហាក្សត្រិយានី ខ្ញុំព្រះករុណាជា-
សេសសម្តេចព្រះទេពយុវពាជ សមាគមគិលានសង្គ្រោះចំពោះព្រះសង្ឃ
ពុទ្ធសាសនិក កំបានចាប់កំណើតឡើង ក្រោយពេលចាប់កំណើតមក
មិនយូរប៉ុន្មាន គ្រឹះស្ថានមួយខ្នងដ៏ធំធេង ជាមទ្បីរពេទ្យសម្រាប់ព្រះសង្ឃ
កំបានផុសចេញជារូបរាងឡើង ដោយសទ្ធាជ្រះថ្លារបស់ពុទ្ធបរិស័ទក្នុង
កម្ពុជរដ្ឋរួបរួមជាមួយនឹងជំនួយនៃព្រះពាជរដ្ឋាភិបាលនឹងជំនួយបរទេស ។
សមាគមគិលានសង្គ្រោះចំពោះព្រះសង្ឃពុទ្ធសាសនិក ពិតមែនតែពុំអាច
ខ្ចួលឥ្យាបាលរក្សាព្រះសង្ឃ ដែលមានពេគាពធាងធំប៉ុន្មានក្នុងកម្ពុជរដ្ឋ
ទាំងមូលដោយមកពីទីកន្លែងនឹងគ្រឿងបរិក្ខារមិនទាន់មានគ្រប់គ្រាន់ កំតង់

អាចទទួលថែទាំបានចំនួនច្រើនហើយដែរ ហើយក្នុងការព្យាបាលនេះ
សោត ក៏មានការផ្តត់ផ្តង់ដោយបច្ច័យ ទាំងបួនចំពោះព្រះសង្ឆតាមពុទ្ធា-
នុញ្ញាតឥតមានទ្វះចន្ទោះ ឃើញថាសមាគមបានបំពេញករណីយកិច្ច
ដែលពុទ្ធសាសនិកជនគប្បីធ្វើចំពោះព្រះសង្ឆដោយសព្វគ្រប់ ល្មមរាប់ថា
ជាអង្គការមួយដែលអាចជួយលើកស្ទួយព្រះពុទ្ធសាសនា ឲ្យបានចម្រើន
ជុះជាលដែរ ។

ក្នុងឧកាសនៃពិធីបុណ្យ ព.ស.២៥០០ នេះ សមាគមតិលាន-
សង្ត្រោះ ចំពោះព្រះសង្ឆពុទ្ធសាសនិក សូមសំដែងនូវគារវកាពដ៏ជ្រាល
ជ្រៅចំពោះព្រះបរមសារីរិកធាតុ ស្នងអង្គព្រះបរមគ្រូជាម្ចាស់ ដែលបម្រុង
ទឹងប្រតិស្ឋាន ក្នុងព្រះសក្យមុនីចេតីយដ៏ជាបូជនីយទស្យនីយដ្ឋានបេស់
ពុទ្ធសាសនិកជនជាតិយើងតទៅអនាគត ។

ដោយអានុភាពនៃសេចក្តីគោរពនេះទឹងកុសលកម្មដែលសមាគមតិ-
លានសង្ត្រោះបានបំពេញហើយ ទាំងបម្រុងទឹងបំពេញទៅអនាគតទៀត
សូមព្រះពុទ្ធសាសនារឹងរឹតតែចម្រើនរុងរឿងផ្សព្វផ្សាយ នូវសេចក្តីសុខ
ស្ងប់ ទាំងផ្ទូវកាយទាំងផ្ទូវចិត្តចំពោះពុទ្ធសាសនិកជនទូទៅ មានព្រះ
ករុណាជាអម្ចាស់ជីវិតលើត្បូង, សម្តេចព្រះមហាក្សត្រិយានី ទឹងទ្រង់
ព្រះករុណាពិសេស សម្តេចព្រះឧបយុវរាជជាប្រមុខ ព្រមទាំងសម្តេច
ទាំងពីរគណៈទឹងប្រជាជនទូទៅគ្រប់ប្រទេសទិសទី ។

សូមព្រះពុទ្ធសាសនាបានទៅជាមធ្យាបាយមួយ ដ៏ប្រត្យ័ក្សដល់

ប្រជាជនគ្រប់ជាតិ ដើម្បីដឹកនាំពិភពលោកទៅរកសន្តិភាពនិងវឌ្ឍនភាព
កុំបីឃ្លៀងឃ្លាត ។

× × ×

សុន្ទរកថា លោក ប៉ាយ-ប៊ុក

ប្រជាជនសមាគមមិត្តពុទ្ធិកវិទ្យាល័យ

សូមនមស្ការ សម្តេចព្រះសង្ឃនាយកខាងគណៈ,

សូមនមស្ការ ព្រះថេរានុត្ថេរៈទាំងឡាយ,

សូមជំរាប ឯកទត្តមទីប្រឹក្សា នៃក្រសួងមហាផ្ទៃ,

សូមជំរាបឯកទត្តមគណៈប្រតិភូទាំងឡាយ!

ខ្ញុំ, អស់លោកអ្នកទាំងឡាយ ខ្ញុំនឹងតាងនាមសមាគមមិត្តពុទ្ធិ-
វិទ្យាល័យ សូមថ្លែងនូវសេចក្តីសោមនស្សយ៉ាងក្រៃលែង ចំពោះព្រះ
ថេរានុត្ថេរៈ ឯកទត្តម គណៈប្រតិភូ ខ្ញុំ ទឹងអស់លោកអ្នកទាំងឡាយ
ដែលបានធ្វើដំណើរមកកាន់ទីនេះ ។

ថ្ងៃនេះ ជាថ្ងៃទុត្តិយកម្មវស្សដែលប្រទេសកម្ពុជា បានរៀបចំធ្វើជាទូទៅ-
កែនូវតែជាធម្មតាបុណ្យ ព.ស. ២.៥០០ យើងទាំងអស់គ្នា ជាពុទ្ធមាមិកជនបាន
មកជួបជុំនៅទីនេះ ដើម្បីទឹងសំដែងនូវសេចក្តីនឹករឭកដល់ព្រះសមណៈគោ-
តមដ៏ប្រសើរជាម្ចាស់ ដែលទ្រង់បរិនិព្វានហើយដោយអនុបាទិសេសនិព្វាន
ធាតុ នៅបន្ទោះដើមសាលព្រឹក្សទាំងគូ ជិតក្រុងកុសិនារកនាំងថ្ងៃទុត្តិ-
យកម្មវស្សាឈ្មោះអនុពុទ្ធ ជាតិចើតញ្ញូបូណ៌មីនៃខែតិសាខឆ្នាំម្សាញ់ ។ ពិតមែន
តែព្រះអង្គបរិនិព្វានទៅ ហើយព្រះបរមរូបរាយទៅជាព្រះបរមសារីរិក-

ធាតុ ឥតព្រះបរមនាមនឹងព្រះគេះត្រូវបស់ព្រះអង្គតង់នៅជានិរន្តរ៍ ធម៌នឹង
វិន័យដែលជាឧវាទរបស់ព្រះអង្គសម្រាប់ឲ្យសត្វលោកប្រតិប័ត្តិតាម ក៏ស្ថិត
នៅរហូតមកសម័យបច្ចុប្បន្ននេះ ទុកបីដូចព្រះអង្គតង់ធរមាននៅឡើយ
សមដូចព្រះភគវន្តមុនីបានត្រាស់ចំពោះព្រះអានន្ទ មុនទ្រង់ចូលកាន់បរិនិ-
ព្វានថា "ធម៌នឹងវិន័យតថាគតនេះឯងជាត្រូបាអាចារ្យរបស់អ្នក ក្រោយ
ដែលតថាគតបរិនិព្វានទៅ" ។ ធម៌នឹងវិន័យព្រះអង្គមានល័ក្ខគោលខាង
សីលធម៌ ទស្សនវិជ្ជា ដែលយកមកអនុវត្តអាចឲ្យសុខក្នុងត្រួសារបាន
រហូតសម្រេចមត្តជលនឹងព្រះនិព្វាន ។ យើងទាំងអស់គ្នាកើតមកនេះ
ពេញជាមានភ័ព្វសំណាង ព្រោះបានឧបត្តិឡើងទាន់ព្រះបរមពុទ្ធោវាទ
ព្រះសក្យមុនីសម្ពុទ្ធជាម្ចាស់ ទាន់ព្រះពុទ្ធរូបព្រះបដិមាកវដែលជាតំណាង
ព្រះអង្គ ទាន់ព្រះបរមសារីរិកធាតុដែលបានយកមកដំកល់នៅបុស្បុក
ចំពោះមុខយើងនេះ ទុកជាបានទាន់ព្រះពុទ្ធអង្គពិតមែន ។

ព្រះពុទ្ធសាសនាយុកាលមកដល់ថ្ងៃនេះត្រប់ ២.៥០០ វស្សា
យើងទាំងអស់គ្នាបានយល់ជាក់ច្បាស់ថា ព្រះសម្មាសម្ពុទ្ធបរមត្រូជាម្ចាស់
ព្រះអង្គមានគុណូបការៈដ៏ជ្រាលជ្រៅពន់ពេក មានបញ្ញាគុណ វិសុទ្ធិគុណ
នឹងករុណាគុណ រកបុគ្គលដទៃឲ្យស្មើគ្មាន បានជាយើងសូមសំដែងក្នុងថ្ងៃ
នេះនូវកតញ្ញូកតវេទីតាចំពោះព្រះអង្គ ដោយបញ្ចេញនូវសច្ចវាចានមស្ស-
ការគោរពព្រះអង្គ ហើយប្រតិបត្តិតាមឧវាទនៃព្រះបរមសាស្តាជាភិយ្យោ-
ភាពតទៅ ។ សម័យនេះជាអភិលក្ខិតសម័យ គឺសម័យដ៏មានជោគជ័យ
មង្គលសិរីសួស្ត៍ ដែលជនជាតិទ្វៃទាំងបុរសស្ត្រី ទាំងត្រហស្ត-បព្វជិត

តាំងក្នុងចាស់ តាំងអ្នកក្រ-អ្នកមានជាដើម ស្រុះស្រួលមូលគំនិតគ្នាធ្វើពិធីបុណ្យ ព.ស. ២៥០០ វស្សាដ៏ឧឡារិកនេះ ជាកិច្ចរំលឹកចំពោះព្រះមហាគុណរបស់ព្រះសម្ពុទ្ធជាម្ចាស់នោះ ។

សមាគមមិត្តពុទ្ធិកវិទ្យាល័យ ជាឧបាសកឧបាសិកាដែលបានយល់ដឹងនូវគុណបការៈដ៏ប្រសើរនេះ ក៏បានជាចំព្យាយាមផ្សាយព្រះពុទ្ធសាសនាទៅគ្រប់ទិសទី តាមដែលមានលទ្ធភាព ដោយការបញ្ជូនសមណនិស្សិតទៅសិក្សារៀនសូត្រនៅប្រទេសក្រៅ ឧបត្ថម្ភអ្នកសិក្សាសាធារណៈដោយគ្រឿងសម្ភារៈនិងសិលធម៌ ថែមទាំងស្នាមនានូវសាខាសមាគម ១៦ ខាងក្នុងក្រៅ ដើម្បីជាមជ្ឈដ្ឋានសម្រាប់ឃោសនាផ្សាយឱ្យពួកពុទ្ធបរិស័ទជ្រួតជ្រាបនូវអត្ថរសនៃព្រះពុទ្ធសាសនា ។ សមាគមនេះមិនមែនមានការណ៍កិច្ចត្រឹមតែទ្រទ្រង់ព្រះពុទ្ធសាសនាប៉ុណ្ណោះទេ ថែមទាំងរបៀបវារៈឬធម៌ជាគំនិតឱ្យបានចំរើនរុងរឿងផងដែរ ។ សមាគមមានសេចក្តីក័ង្ខាទៅអនាគតជាយ៉ាងក្រៃលែង ក្រែងព្រះពុទ្ធសាសនាថយអានុភាព ក៏បានជាចំព្យាយាមយោសនាតឲ្យបំភ្លឺលោកអ្នកជាពុទ្ធបរិស័ទ ឱ្យពេញចិត្តខាងកិច្ចធ្វើការដោយសាមគ្គីភាព ។

ព្រះភគ្គវន្តមុនីបរមសម្ពុទ្ធទ្រង់ត្រាស់ថា "តថាគតគ្រាន់តែជាអ្នកប្រាប់ផ្លូវ" ត្រង់ដើរឬមិនដើរទៅតាមផ្លូវនោះជាការៈលើលោកអ្នកជាពុទ្ធបរិស័ទតាំងខ្លួយ តថាព្រះពុទ្ធាភិដែលទំនងមានផលប្រយោជន៍លុះត្រាតែយើងយកទៅប្រតិបត្តិតាមធ្វើតាម ។

ឯកឧត្តមគណៈប្រតិកូពំធឡាយ ! ក្នុងនាមនៃសមាគមមិត្តពុទ្ធិក-
វិទ្យាល័យ ពួកពុទ្ធមាមកជនប្រទេសកម្ពុជា សូមសំដែងនូវសេចក្តីស្មោះ
ស្ម័ត្រ ចំពោះពុទ្ធសាសនិកជននានាប្រទេស សូមឲ្យរួមកម្ចាំងគ្នាប្រកប
ដោយមេត្រីភាពកាតរភាព ដើម្បីនឹងតស៊ូនូវអយុត្តិធមិនឹងអកុសលត្រប់
យាំងដែលជាហេតុធ្វើឲ្យមហាសង្ត្រាមសកលលោកផុសផុលឆេះឡើងក្នុង
កាលខាងមុខ សូមឲ្យសកលលោកតាំងនៅក្នុងសេចក្តីស្ងប់សន្តិភាពវឌ្ឍ-
ភាពសម្បូរណភាព ។ ការដែលលោកអ្នកអញ្ជើញមករួបរួមក្នុងពិធីបុណ្យ
នេះ មិនមែនត្រាន់តែជាសកម្មភាពប្រព្រឹត្តិទៅត្រឹមតែសម្ភារៈនឹងសីលធមិ
នោះទេ ថែមទាំងបញ្ជាញនូវមិត្តរូបដ៏ជាក់ស្តែង នៃសហការរវាងជាតិ
ដែលជាមូលដ្ឋាននៃការគមនាគមន៍សកលលោក ។ ប៉ើមនុស្សយើង
ស្រឡាញ់រាប់អានគ្នាដ៏ស្មោះស្ម័ត្រ មិនប្រកាន់គ្នាហួសហេតុ ជួយ
ស្រេចស្រង់គ្នាកាន់ធមិអហឹសាមិនបៀតបៀនគ្នានឹងគ្នា ជួយជាស់គឿន
ក្រើនរំលឹកគ្នាទៅវិញទៅមក ម្ចុះសមលោកសន្និវាសនេះទៅជាស្ថានសួត៌
មួយដែលមានតែសេចក្តីសុខតែម្យ៉ាង ។

ក្នុងអវសានកថានេះ សូមប្រមូលកុសលដែលកើតឡើងអំពីពិធីបុណ្យ
នេះ ទ្ធិសផ្សាយជល់ពួកពុទ្ធសាសនិកជនប្រទេសកម្ពុជា នឹងនានាប្រទេស
សូមឲ្យបានសេចក្តីសុខ មានសន្តិភាព តាំងពីថ្ងៃនេះ ជាដើមរៀងទៅ !

សូមសត្វលោកទាំងឡាយកុំចងពៀរនឹងគ្នា សូមសកលលោកប្រកប
ដោយសេចក្តីស្ងប់ សូមព្រះពុទ្ធសាសនាចំរើនរុងរឿងជាកិយ្យាភាព ! ។

×

× ×

សារនៃសោភារ័ស្ចាចាដ

ជាទីប្រឹក្សាពិសេសនៃមួលធិធិអាស៊ី

សូមគ្រាបថ្វាយបង្គំសម្តេច ទេពព្រះថេរពុទ្ធត្រេះទាំងឡាយ !

សូមជំរាបឯកទត្តមទេពពុទ្ធមាមកវនទាំងឡាយ !

ពិធីបុណ្យពុទ្ធជយន្តិនេះ បានផ្តល់ឱកាសគួរឱ្យកំណត់ចុកក្នុងប្រវត្តិសាស្ត្រ ដើម្បីគោរពព្រះសម្ពុទ្ធ ដើម្បីពិនិត្យហើយទទឹងប្រតិបត្តិទៅព្រះធម៌របស់ព្រះសម្ពុទ្ធ ដែលទ្រង់ប្រដៅឱ្យរស់នៅក្នុងសន្តិភាព ចុកដូចជាសមាជិកនៃក្រុមសង្ឃរបស់ព្រះអង្គ ។

ចំពោះយើងមួយរូប ។ ពិធីពុទ្ធជយន្តិនេះ ជាឱកាសមួយនៃប្រវត្តិសាស្ត្រសម្រាប់ការត្រិះរិះពិចារណាផ្ទាល់ខ្លួន ហើយទទឹងការតាំងចិត្តស្មើនស្មាធ៌ហើយទទឹងដើម្បីធ្វើឱ្យមានមិត្តភាពជាមួយអ្នកដែតខាងទាំងឡាយរបស់យើង ។ ចំពោះចំណុចយោបល់ខាងប្រវត្តិសាស្ត្រវិញ ពិធីពុទ្ធជយន្តិនេះ បានរួបរួមមនុស្សទាំងឡាយ នៃបូពាប្រទេសទទឹងបស្ចឹមទិសជាហ៊ាងច្រើនអនេក ឱ្យមានមិត្តភាពខាងសាសនាខាងបញ្ញាទទឹងខាងវប្បធម៌ ។

ដូច្នេះ ពិធីបុណ្យពុទ្ធជយន្តិនៅប្រទេសកម្ពុជាទទឹងនៅទីដែ អាចចាត់ចុកជាសេចក្តីគោរពមួយដ៏ជ្រាលជ្រៅ ជាសាធារណៈចំពោះព្រះសម្ពុទ្ធដែលជាគ្រូលើអស់មនុស្សសត្វនានា ។

ពិធីនេះគឺជាសេចក្តីតតញ្ញូសាធារណៈ ខាងការពិតជាសតិលនៃ*ឥរិយាបថរបស់ព្រះសម្ពុទ្ធ* ដែលចុកជាមគ្គាចារ្យសម្រាប់ការរស់នៅ ។ ព្រះ

ឧកាទនេះបង្ហាញឲ្យយើញនូវជំនឿជាសាធារណៈក្នុងព្រះសង្ឆ ដែលទុកជូបជាឧត្តមគតិរួមគ្នានៃសត្វលោកទាំងមូល ដែលរស់នៅក្នុងកិច្ចប្រស្រ៉យទាក់ទងល្អជីប្រសើរ ហើយចំពោះកិច្ចប្រស្រ៉យទាក់ទងនេះមានព្រះនិព្វានជាកន្ទែងរំលត់ទុក្ខ ជាកន្ទែងរំលត់តណ្ហារបស់យើង ។

ព្រះពុទ្ធសាសនាទៅប្រទេសកម្ពុជា មានព្រះពុទ្ធព្រះធម៌និងព្រះសង្ឆជាគោលនឹងជាទីគាង ។ ក្នុងទីនេះ ព្រះពុទ្ធជាអគ្គបុគ្គលជីជាទីគោរពនឹងសក្ការបូជាជានិច្ចជូបជាគ្រូមួយ ។ ក្នុងទីនេះ ព្រះធម៌ បានត្រូវគេលើកយកមកសំដែងទេសនា ពិនិត្យនឹងបកស្រាយតាមអត្ថរសជីជ្រាលជ្រៅ ។ ក្នុងទីនេះ ព្រះសង្ឆជាសង្គមមួយទាងឧត្តមគតិ សម្រាប់សមូហភាពសកលនៃប្រជាពស្ត្រទាំងអស់ ។ ក្នុងទីនេះ លទ្ធិព្រះពុទ្ធសាសនានឹងការប្រតិបត្តិព្រះពុទ្ធសាសនា, យោបល់នឹងកម្មភាពនៃព្រះពុទ្ធសាសនាបានត្រូវគេបានិកទុកឥតប្រប្រួលនៅឯប្រាសាទអង្គរ ។ ក្នុងទីនេះ ក្រ៉ឺមតិកគឺព្រះពុទ្ធសាសនានៃទ្វីបអាស៊ី បានទទួលការរក្សាយុំគ្រងពីសំណាក់នៃព្រះករុណាជាអម្ចាស់ជីវិតលើត្ឆូងទាំងពីរព្រះអង្គ នឹងសម្តេចព្រះនរោត្តម-ស៊ីហនុ ។

ជូច្នេះ គឺជាឧកាសជីប្រសើរនឹងជាទីរីករាយ ដែលត្រូវតែសូមឲ្យពិធីពុទ្ធជយន្តិតាំងនៅប្រទេសកម្ពុជា ទុកជាឧទាហណ៍មួយជីទ្វាំងក្នានៃព្រះពុទ្ធសាសនាសម្រាប់ប្រជាពស្ត្រទាំងអស់ ។

នៅឯសហរដ្ឋអាមេរិក មានជនជាតិអាមេរិកជាច្រើនកំពុងតែសិក្សាព្រះពុទ្ធសាសនា ដែលជាការចាំបាច់មុននឹងតាំងខ្ទួនជាពុទ្ធសាសនិក ។

កាលបើយើងយល់ច្បាស់ទូវឧវាទនៃព្រះសម្ពុទ្ធហើយ យើងសូមគោរព
ព្រះអង្គដោយមនោសញ្ចេតនាដ៏ស្មោះត្រង់ ។

កាលបើគោរពព្រះពុទ្ធហើយ យើងមុខជានឹងយល់ច្បាស់ដោយ
ខ្ជួនឯង ហើយនឹងមានសតិសម្បជញ្ញៈ ខាងការទាក់ទងរបស់យើង
ចំពោះប្រជារាស្ត្រទាំងឡាយដទៃ ។

ព្រះពុទ្ធបានទ្រង់ប្រទានដល់យើង ទូវឧទាហរណ៍មួយដ៏ជាក់ច្បាស់
អំពីជីវភាពជាសុក្រិត ។ ការប្រៀនប្រដៅរបស់ព្រះអង្គបាត់ទុកជា
មត្តុទ្ទេសមួយខាងបញ្ញា ទឹងបាត់ទុកជាកំឡាំងមួយខាងសីលធម៌ ។
ព្រះសង្ឆបង្ហាញឲ្យយើងដឹងទូវឧត្តមគតិ ហើយយើងកឹខំប្រឹងប្រយុទ្ធ
ដើម្បីសែងរកឧត្តមគតិនេះ ។

ពុទ្ធដយន្តិរបស់ខ្មែរ បានផ្តល់ដល់យើងនៅឧកាសមួយខាងប្រវត្តិ-
សាស្ត្រ ដើម្បីគោរពព្រះពុទ្ធ ទឹងដើម្បីចូលរួបរួមជាមួយអស់លោកអ្នក
ទាំងឡាយ ក្នុងការគោរពនឹងការប្រតិបត្តិតាមព្រះឧវាទ នៃព្រះពុទ្ធ
សម្រាប់ខ្ជួនយើងផង សម្រាប់អ្នកដទៃផងចាប់ពីពេលឥឡូវនេះទៅរហូត
ដល់អវសានកាល ។

យើងសូមអស់លោកថ្ងៃងជាថ្នីទ្រៀតទូវកតរវ៉ៃតាធម៌ដ៏ស្ពួចស្ពើងក្រៃ
លែងរបស់យើង ចំពោះព្រះករុណាជាអម្ចាស់ជីវិតលើត្បូងទាំងពីរព្រះ
អង្គ ចំពោះសម្តេចព្រះឧបយុវាជ ចំពោះព្រះសង្ឆ ទឹងចំពោះ
ប្រជារាស្ត្រនៃប្រទេសកម្ពុជា អំពីសេចក្តីអញ្ជើញដ៏ជាទីស្នេហានៃព្រះ
ករុណាជាអម្ចាស់ជីវិតលើត្បូងទឹងអំពីបាហុនភាពរបស់ព្រះអង្គ ទឹងអំពី

អំពើទាងព្រះពុទ្ធសាសនាដ៏ឃាឹងប្រើនអនេក ដែលពន្យល់ឲ្យមានការ
ស្តាប់ត្នាបានងឹងឲ្យមានសេចក្តីស្នេហារកត្នា ។

×

× ×

សារលិខិតនៃគណៈប្រតិភូពុទ្ធសាសនា
សាធារណរដ្ឋប្រជាមានិតចិន

សូមឲ្យមនោសញ្ចេតនាដូចជាមិត្តរួមឈាមរវាង
ពុទ្ធសាសនិកខ្មែរនឹងចិនរុងរឿងដល់ទៅអវសានកាល.

និពន្ធដោយភិក្ខុ ជឹ-សុង
ជាប្រធានគណៈប្រតិភូពុទ្ធសាសនា
សាធារណរដ្ឋប្រជាមានិតចិន

ដោយសេចក្តីអញ្ជើញជាកិត្តិយសអំពីរាជរដ្ឋាភិបាលប្រទេសកម្ពុជា
រដ្ឋាភិបាលចិនបានបាត់ឲ្យអាត្មាខ្ញុំដឹកនាំនូវគណៈប្រតិភូពុទ្ធសាសនា ១ ក្រុម
មកកាន់ប្រទេសកម្ពុជា ដើម្បីចូលរួមក្នុងមហាសន្និបាតបុណ្យរំលឹក ព ស.
២៥០០ វស្សាឯប្រទេសនេះ ។ ក្នុងឧកាសនេះសោត បានញ្ញាំងឲ្យអាត្មា
ខ្ញុំនឹងសហការីទាំងអស់មានដោតវាស្នា ដោយបានៈចូលគាល់ព្រះករុណា
ទាំងពីរព្រះអង្គ, សម្តេចនាយករដ្ឋមន្ត្រី, សម្តេចសង្ឆនាយកទាំងពីរគណៈ
ព្រមទាំងបានស្គាល់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងធម្មការ, លោកប្រធានពុទ្ធិក-
សមាគមកម្ពុជរដ្ឋ ហើយនឹងអស់លោកមគ្គនាយកឯទៀតទាងពុទ្ធ-
សាសនាជាប្រើនរូបទៀតផង ។

ក្រៅពីនេះ អាត្មាខ្ញុំនឹងសហការីមានភ័ព្ធបានទៅទស្សនាមហាប្រាសាទអង្គរ ហើយនៅក្នុងរយៈកាលដែលអាស្រ័យនៅក្នុងប្រទេសនេះទៀត ក៏បានទទួលនូវកិច្ចបដិសណ្ឋារៈជាទីតាប់ចិត្តពីរាជរដ្ឋាភិបាលទៀតផង ។ ភ័ព្ធវាស្នាដ៏ប្រវៃពនេះ ពុំអាចនឹងបំភ្ចេចបានឡើយ ជាហេតុឲ្យអាត្មាខ្ញុំសូមផ្ទៀតយកឧកាសនេះ ទទួលនូវសព្ទសាធុការពរ នឹងអំណរគុណ យ៉ាងជ្រាលជ្រៅ ថ្វាយចំពោះព្រះមហាវរក្សត្រ៏មហាក្សត្រិយានីសម្តេចនាយករដ្ឋមន្ត្រី សម្តេចសង្ឆនាយកទាំងពីរគណៈ ព្រមទាំងជូនដល់អស់លោកប្រមុខរដ្ឋាភិបាលនឹងវរជនខាងពុទ្ធសាសនាឯទៀតផង ។

ការប្រស្រ័យទាក់ទង រវាងពុទ្ធសាសនិកខ្មែរនឹងចិន បានផ្តើមឡើងតាំងពីជាង ១៦០០ ឆ្នាំមុនម្ទើះ ។ នៅក្នុងសតវត្សទី ៥ (គ.ស.) មានព្រះសង្ឆខ្មែរ ១ អង្គព្រះនាមចនូខៈភឡ (ប្រែតាមអក្សរចិន) បានទិមន្តទៅដល់ប្រទេសចិន, លោកព្យាយាមប្រែធម៌វិន័យអស់រយៈពេលជិត ៦០ ឆ្នាំ, រាជរដ្ឋាភិបាលចិនសម័យនោះ ក៏បានស្ថាបនាអគារ ១ នៅឯក្រុងណានជីង ហៅថា "អគារហ្ជ-ណាន" ទុកជាទីគោរពនឹងភក្តីភាពចំពោះព្រះសង្ឆខ្មែរ ។ ក្នុងសម័យដដែលនោះ មានព្រះសង្ឆចិន ១ អង្គព្រះនាមឡៃ-យីន បានទិមន្តមកប្រទេសខ្មែរ ។ នៅដើមសតវត្សទី ៧ មានព្រះសង្ឆចិន ៣ អង្គ ព្រះនាម យី-ឡាន ១ ជឺអាន ១ នឹងយីសៀន ១ បានទិមន្តមកប្រទេសខ្មែរជាមួយគ្នាទៀតផង ។

ពិរសសជាងនេះទៅទៀត គឺខាងក្រោយពីវរសង្ឆ សៀន-ជួង (គេនិយម ហៅថា ថាង.ចេង) មក នៅមានភិក្ខុសង្ឆដែលមាន

កិត្តិនាម យាំងល្បីល្បាញ ១ អង្គទៀត ព្រះនាម ហ្ជូប-ហៀន- ជានន្ទិមន្តមក ប្រទេសកម្ពុជាដែរ ។

ចណ្តាព្រះសង្ឆ ដែលអាត្មា ខ្ញុំអធិប្បាយជូចខាងលើនេះ លោកស្ថិ ចូជាព្រះកាយពល ក្នុងការប្រស្រ៍យនឹងការស្រាវរកពុទ្ធវចនៈតែប៉ុណ្ណោះ ទេ ថែមទាំងញ្ញាំងឲ្យដំណើរវប្បធម្មនឹងមិត្តភាពរវាងត្នានឹងត្នាមានទកាស ផ្ទាស់ប្តូរ នឹងរួមរិតជាម្ជុងត្នា ហើ ឆត្រាប់ពូជដែលបុព្វបុរសយើងជាន ចណ្ណុះនេះ ក៏ជានជុះជាលតរៀងមក ។

ដោយពលិកម្មដ៏ប្រសើរនេះហើយ ទើបញ្ញាំងឲ្យមនោសញ្ចេតនា-រម្មណ៍ នៃពុទ្ធសាសនិកចិនតែងតែទាក់ចិត្តមកលើពុទ្ធសាសនិកខ្មែរជាដរាប ។

អាត្មាខ្ញុំសង្ឆឹមថា មនោសញ្ចេតនាជូចជាមិត្តរួមឈាមនេះអាចលូត លាស់តទៅមុខជាពុំខាន ហើកាលណាមានការគាំទ្រនឹងសេចក្តីញ្ញាយាម រវាងត្នានឹងត្នា ។

ពុទ្ធសាសនាដែលស្ថិតនៅឯប្រទេសចិនមានវ៉យជិត ៤០០០ ឆ្នាំ ហើយ ។សកម្មភាពនេះនៅតែកម្រើកនឹងពង្រីកនាទីខ្ជូនជានិច្ច ។

ពុទ្ធសាសនានៅឯនេះមានពីរផ្នកគឺ ផ្នកមកពីទិសខាងជើងមាន ប្រែជាអក្សរចិននឹងអក្សរទីបេត៍ ផ្នកមកពីទិសខាងត្បូង មានអក្សរបាលី ជាដើម ។

សព្វថ្ងៃនេះ ប្រទេសចិនមានវត្ត ៥ ម៉ឺន ភិក្ខុសាមណេរប្រហែល ៥០ ម៉ឺនអង្គ រឹឯពុទ្ធបរិស៉ទ តិចណាស់ក៏ប្រហែលជា ១០០ លាននាក់ដែរ ។

ដោយស្ថានភាពរបៀបរស់នៅនឹងលក្ខណៈប្រវត្តិសាស្ត្រ ព្រមទាំង

ការគាន់នៃន័យខ្លះមានសភាពប្លែកពីគ្នាទឹងប្រទេសឯទៀត តែតម្កល់ន័យនឹងដំនឿយើងគឺថាស្របគ្នាគាំងអស់ ។ ឧទាហរណ៍: ដូចជាពុទ្ធឧទ្ទេសវិធីដែលនឹងអាចដឹងអំពីអដ្ឋង្គិកមគ្គ (គឺផ្លូវ ៨ យ៉ាង) អបរិសេសព្រះពុទ្ធឲ្យស្គាល់នូវបញ្ញាសង្ខា សីលសង្ខា ចិត្តសង្ខា ជាតិទុក្ខ ជរាទុក្ខ ព្យាធិទុក្ខ ទឹងមរណៈទុក្ខ ឬ តណ្ហា (គឺកាមតណ្ហា ភវតណ្ហា វិភវតណ្ហា) ព្រះគោតមបរមគ្រូបានញ៉ាំងឲ្យយើងយល់នូវអត្ថន័យ ពុទ្ធនិកេធអាយេសច្ចៈទៀតផង ។ ពុទ្ធសាសនិកចំនួនក៏ដូចជាពុទ្ធសាសនិកខ្មែរគាន់ឆ្លាប់នូវទត្តមតនេះ ។

អាត្មាភាពខ្ញុំជឿជាក់ថា មិត្តភាពដោយមានប្រវត្តិសាស្ត្រដ៏ប្រពៃ ហើយនឹងការប្រស្រ័យចំពោះពុទ្ធវចនៈសន្តិភាព ទឹងមេត្រីភាពរវាងគ្នាទឹងគ្នានេះ នឹងរួមផ្សំជាធ្មុងមួយបាន ដូច្នេះ ដើម្បីគាំទ្រ ទឹងពង្រីកនូវមហាករុណាធម៌ ទឹងសមធម៌នៃព្រះសម្មាសម្ពុទ្ធបរមគ្រូ ហើយទឹងដើម្បីជាកម្លាំងជម្រុញចលនាសន្តិភាពទឹងមេត្រីភាព នាសកលលោកទៀតផង ពុទ្ធសាសនិកចំនួនសូមផ្តល់នូវកម្លាំងគ្រប់ផ្លូវ ទឹងបំពេញសហប្រតិបត្តិការជាមួយទឹងពុទ្ធសាសនិកខ្មែរ ។

សូមឲ្យព្រះពុទ្ធសាសនានៅប្រទេសកម្ពុជាស្ថិតស្ថេរជាស្ថាពរ !

សូមឲ្យកម្ពុជារុងរឿងថ្កុំថ្កើង !

សូមឲ្យប្រជាជនខ្មែរប្រកបដោយសេចក្តីសុខទឹងសេចក្តីចំរើន !

សូមឲ្យមនោសញ្ចេតនាដូចជាមិត្តរួមឈាមរវាងពុទ្ធសាសនិកខ្មែរទឹងចិនល្អគង់ជានិច្ច ។

× × ×

សុន្ទរកថាព្រះមហាពុទ្ធទាស

អនុប្រជានគណៈប្រតិភូប្រទេសវៀតណាមសេរី

សូមនមស្ការសម្តេច !

សូមនមស្ការព្រះមហាថេរានុត្ថេរៈគាំងឡាយ !

សូមចំរើនពរគណៈប្រតិភូបរទេសជាមិត្រទឹងសាធុសប្បុរសគ្រប់ជាតិ !

ក្នុងនាមនៃពុទ្ធិកសមាគមផ្នែកថេរវាទ អាត្មាភាពសូមសម្តែងនូវ
សោមនុស្សចេតនាដ៏ជ្រាលជ្រៅចំពោះពជរដ្ឋកិបាលខ្មែរ មានព្រះករុណា
ជាប្រមុខរដ្ឋ ដែលមានសេចក្តីស្នេហាមេត្រីភាព ពប់អាននស្មោះស្ម័គ្រដល់
ប្រទេសជាមិត្រជិតខាង ទុកជាមង្គលសម័យមួយដើម្បីពុទ្ធសាសនិក
គ្រប់រូបសំដែងទឹកចិត្តដ៏បរិសុទ្ធយ៉ាងខ្ពស់ ប្រកបដោយកតញ្ញូកតវេទិតា
ចំពោះព្រះពុទ្ធសាសនា ទឹងចំពោះព្រះបរមសារីរិកធាតុនៃព្រះសាស្តៃលោក-
នាថ ព្រះអង្គមានព្រះមហាករុណាចំគុណានោះ ។

សង្គ្រាមលោកពីរលើកកន្លងទៅហើយ សត្វលោកឯកូវនេ
យ៉ាងតិចទឹកស្បប់ស្បៃង គ្រោះតែលោភចេតនាគ្មានគោះត្រើយបង្អែរបង្អើត
ឡើង ។ ហេតុនេះ បើត្រូវការសន្តិសុខ បរិស័ទគួរសង្វាតនូវភាតជាំគោល
សាសនៀនលើអព្យាបាទធម៌ ទឹងព្រហ្មវិហារធម៌ បើជាព្រមគ្នាចុះសំរុង
ប្រតិបត្តិតាមធម៌នេះមែន លោកនឹងបានប្រកបដោយសន្តិសុខក្សេមឥត
ឃ្លៀងឃ្លាត ។

ដើម្បីសំដែងមនោសញ្ចេតនា ប្រកបដោយសេចក្តីដឹងគុណ ទឹងតាវ-
កាលយ៉ាងខ្ពស់ចំពោះសាសនារបស់អង្គព្រះជិនស្រី យើងខ្ញុំពុទ្ធបរិស័ទ

ដើងវត្តដេតពន នៅព្រៃនគរ នឹងវត្តមហាមន្ត្រី ភ្នំពេញ សូមចាប់កុសល ក្នុងពិធីបុណ្យសម្ពោធធ្ងងពាក់កណ្តាលព្រះសាសនានេះ ចំនួនទឹកប្រាក់ ៦៥០០ សូមឲ្យភាគផលអានិសង្សនេះ ផ្តល់សេចក្តីសុខសេចក្តីចំរើនដល់ រាជរដ្ឋកិបាលខ្មែរ មានព្រះមហាក្សត្រនឹងព្រះមហាក្សត្រិយានីជាប្រមុខ សព្វទិវារាត្រីកាលជាអាចិន្ត្រៃ រហូតដល់សព្វសត្វក្នុងពិភពលោក មានប្រទេសកម្ពុជាជាដើម ។

ជយោ ពុទ្ធសាសនា

x

x x

សុន្ទរកថាព្រះកាតន្ទេរ

តំណាងប្រទេសវៀតណាមសេរី

បពិត្រព្រះករុណាត្រប់ព្រះអង្គ !

សូមថ្វាយព្រះពរព្រះមហាក្សត្រ នឹងព្រះមហាក្សត្រិយានី !

សូមចំរើនពរទ្រង់, ឯកឧត្តមនឹងអស់លោក-អ្នកទាំងឡាយ !

ក្នុងនាមនៃសង្ឃមណ្ឌលនឹងពុទ្ធសាសនិក សញ្ជាតិវៀត-ណាម អាត្មាភាពសូមថ្វាងមនោសញ្ជាតនា ប្រកបដោយសេចក្តីត្រេកអរយ៉ាងទូលាយចំពោះរាជរដ្ឋាភិបាលខ្មែរ នឹងគណៈប្រតិភូបរទេសជាមិត្រទាំងឡាយ ដែលសន្និបាតក្នុងឧកាសបុណ្យសម្ពោធ ៦៥០០ វស្សា នៃព្រះពុទ្ធសាសនានេះ ដើម្បីសម្ពែងទឹកចិត្តដ៏បរិសុទ្ធិរាប់អានស្មោះស្ម័ត្រព្រះសទ្ធម្មនៃអង្គព្រះជិនស្រី ។

ប្រទេសខ្មែរ នឹងប្រទេសវៀត-ណាម ជាមិត្រនឹងគ្នា មានសាសនា

នឹងអាស្សធមិស្ស៊ីរតែជូចគ្នាជាច្រើនសតវត្សមកហើយ ថែមទាំងនៅ
ពេលជិតនេះ សញ្ញាតិវ៉ៀត-ណាមបានទទួលប្រតិបត្តិតាមសាសនោវាទ
ផ្នែកថេរវាទ ។

ទ្ធកាសនេះ រាជរដ្ឋាភិបាលខ្មែរបានធ្វើពិធីសម្ពោធ បុណ្យពាក់
កណ្តាលព្រះសាសនាដ៏ទទ្បាវឹកភ្ជូកភ្ជឹកយ៉ាងអស្ចារ្យ ក្នុងថ្ងៃនេះហើយ
ដែលព្រះបរមពោធិសត្ត ចាប់បដិសន្ធិ ត្រាសដឹងនឹងចូលព្រះបរមនិព្វាន ។

អាត្មាភាពមានសេចក្តីសង្ឃឹមកក់ក្តៅទុកក្នុងចិត្តថា មិត្តភាពនឹង
សម្ពន្ធភាពទាងផ្ទូវសាសនារវាងប្រទេសខ្មែរ នឹងវ៉ៀត-ណាមកាន់តែ
ស្រឡាញ់រាប់អានគ្នាទ្វេភាគ ។

ដោយអានុភាពនៃបុណ្យធ្ងងពាក់កណ្តាលព្រះសាសនានេះ សូម
សេចក្តីសុខ-ចំរើនកើតមានដល់ព្រះមហាក្សត្រ, ព្រះមហាក្សត្រិយានី
នឹងប្រជាជនខ្មែរទូទៅ ។

ជយោ ពុទ្ធសាសនា

លុះតំណាងពុទ្ធិកសមាគមនានាប្រទេស នឹងប្រទេសយើងបាន
ថ្ងៃងសុន្ទរកថាចប់ហើយ, ទើបមានពិធីប្រគេនទេយ្យទានដល់ព្រះសង្ឃ
បរទេស ។



 

ពេលយប់ មោំង ១៩-មានការតាក់តែងប្រទីបផ្ទាលានៅគ្រប់
វត្តអារាមនឹងគ្រឹះស្ថានរាជការសាធារណៈនឹងឯកជន ។

ម៉ោង ២០ ព្រះករុណា ជាអម្ចាស់ជីវិតលើត្បូង សម្តេចព្រះមហាក្សត្រិ-
យានី សម្តេចព្រះទេបយុវាជ ស្តេចយាងមកដល់ ព្រមទាំងព្រះពជមរិតារ
មានសម្តេចចោហ្វាំងវរៈវៀនដ័យ ប៉ែន-នុត ជាដើម ។

ព្រះករុណា ទាំងពីព្រះអគ្គមហេសីសម្តេចព្រះទេបយុវាជ ទ្រង់ជាន់ជូជា
ភ្ជួងប្តូរចំពោះព្រះបរមសារីរិកធាតុ ដែលតម្កល់លើបុស្បក រួចទ្រង់ជាន
ស្តេចយាងប្រទក្សិណ ៣ ជុំបុស្បក ទ្រង់អុជធូបទៀនបូជាដោយមានពួក
ក្រុមខ្មែរនានាប្រទេសនិងនាម៉ឺនសព្វមុខមន្ត្រីហែតាមផង រួចទ្រង់យាងទៅ
ប្រថាប់លើព្រះសុវណ្ណគោច្ចកន្ត ព្រះពន្ធាតត្តិយសវិភ្ញ ។ បន្ទាប់ពីនោះ
មានភ្ជួនហែក្លែងបូជាព្រះរតនត្រ័យប្រទក្សិណមណ្ឌលបុណ្យ ដោយ
វេយ្យាវច្ចមាលាវិចិត្រដែលតាក់តែងរឿងពុទ្ធប្រវត្តិ អំពីព្រះអគ្គទ្រង់ប្រសូត
អំពីទ្រង់ចរិនិព្វាន ។ល។ ដោយពិធីប្រឡងប្រដែង ។

វេយ្យាវច្ច មាលាវិចិត្រទាំងអស់ចំនួន ២ ០, ជានទ្ធលង្កាន់តាម
លេខ ដូចខាងក្រោម:

លេខ ១– វេយ្យាវច្ចមាលាវិចិត្របង្ហាញពីទីតាំងកំណើតនិងកំណត់ខេមរៈភូមិន្ទ
ដែលតែងអំពីខេត្តភូត ;

លេខ ២– វេយ្យាវច្ចមាលាវិចិត្របង្ហាញពីវរៈសេនាភូមិ ឆ្នាំ ១៩ (B.c.c.)
កំណត់ខេមរៈភូមិន្ទ ដែលតែងអំពីព្រះសម្ពុទ្ធទ្រង់ប្រសូត ;

លេខ ៣– វេយ្យាវច្ចមាលាវិចិត្របង្ហាញពីក្រសួងយោសនាការ ដែល
តែងអំពីព្រះនាងសុជាតាថ្វាយមធុបាយាសចំពោះព្រះអគ្គ ។

ព្រះសង្ឃគណៈមហានិកាយ ២៩០០ អគ្គនមស្ការនៅមហាកេតន ។

ចាស់ក-ចាស់កា នមស្ការដោយមានព្រះគុណ គាំងពីព្រះអគ្គ ទំនង សម្តេចព្រះបយុវពជាប្រមុខ ព្រមគាំងសម្តេចចៅហ្វាំងវរៈវៀងជ័យ សមាជិកឧត្តមប្រឹក្សាព្រះពជា សមាជិកពជវង្សាគិចាល នាម៉ឺនសព្វមុខមន្ត្រី ។

លំដាប់តមក សម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយប្រកាសវិសាខបូជា, រួចព្រះសង្ឃគណៈមហានិកាយ ៦៩ អង្គសូត្រវិសាខបូជា ។

លុះចប់គិច្ចពិសាខបូជា ព្រះគុណ គាំងពីព្រះអគ្គស្តេចយាងវិលត្រឡប់ទៅគាន់ព្រះបរមពជកំនិវិញ ។

ក្នុងពេលនោះ សម្តេចព្រះបយុវពជ សមាជិកឧត្តមប្រឹក្សាព្រះពជា សមាជិកពជវង្សាគិចាល នាម៉ឺនសព្វមុខមន្ត្រីខ្ទង់ស្តេចយាងចូលទៅកន្លែមហាពេន ខ្ទង់ព្រះសណ្តាប់ព្រះធម្មទេសនានៃសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយ ។

ម៉ោង ២ មានពិធីចាត់គាំងព្រះនាងសុជាតា (ព្រមគាំងនារីកិត្តិយស ២ នាក់) ដោយពិធីប្រឡងរួប ព្រមគាំងពិធីប្រឡងប្រជែងកម្រងបុប្ផាដែលនាងកញ្ញាគាន់ ។

មានបេក្ខនារីចំនួន ៩៩ នាក់ចូលមកប្រឡង ។ ក្នុងចំនួននេះត្រូវជ្រើសយកតែនាងកញ្ញា ៣០ នាក់, ហើយយកនាងកញ្ញា ៣០ នាក់នោះមកជ្រើសយកតែនាងកញ្ញា ១៥ នាក់; យកនាងកញ្ញា ១៥ នាក់នោះមកជ្រើសយកតែ ៣ នាក់ ជានាងកញ្ញាជ័យលាភី គឺមួយនាក់ ជា

នាងកញ្ញាកិត្តិយសគឺជាតួនាងសុជាតា, ២ នាក់ទៀត អមដួង.ស្តាំនៃ
នាងសុជាតា ។

នាងកញ្ញាទាំងអស់នោះសុទ្ធតែមានរូបឆោមលោមពណ៌ស្រស់ប្រិម-
ប្រិយ, ស្បែកសំពត់ពណ៌ផ្សែង ។ ខ្លះស្បែកសំពត់សារបាប់មានរស្មីភ្លឺ
ផ្លេក ។ តាក់តែវពណ៌ត្រប់ឃ្នាងតាមរបៀបសម័យថ្នាក់ក្តួនបុរាណ ។

នាងកញ្ញាឯកដែលបានជាប់ជាតំណាងនាងសុជាតាក្នុងពេលនោះគឺ
នាងកញ្ញា លី_សាវ៉ែត សាលាសុធាវេ ។

លំដាប់តមក មានការប្រឡងប្រជែងសូត្រធម៌បទផ្សែង ។ ដោយ
បែងចែកនារីជាប្រាំមួយក្រុម ក្នុងមួយក្រុម ។ មាននារីសូត្របន្ទាប់
តាក់តែងរយៈពេល ៥ នាទី ។ នារីដែលបានជាប់គឺទ្វេនោះ គឺ

១. នាង ខែត-សុីម (ខែត្រតាកែវ)

២. „ ពស់-ដាំម (ខែត្រកំពត)

៣. „ តែម-សេង (ខែត្រតាកែវ) ។

ម៉ោង ៤, ៣០ រៀបភ្លឺ ព្រះគណៈទាំង ២ ព្រះអង្គធំនិងសម្តេច
ព្រះទេបយុវរាជ ស្តេចយាងមកដល់ ។

ក្រោយដែលព្រះសង្ឃទេ.ថា-សកទេ.ថាសិកា ធ្វើពិធីមង្គលព្រះ
រត្នត្រ័យ មានធ្វើពិធីរំលឹកដល់ពេលដែលព្រះអង្គបានត្រាស់ដឹងនូវអនុត្តរ-
សម្មាសម្ពោធិញ្ញាណ ដោយអុជតាំង្រួចបន្ទោញធូបណ្តារធ្យីផ្សែង ។ រួច
ហើយនាងកញ្ញាឯកតំណាងនាងសុជាតាខួលកិត្តិយសបើកពិធី ។ នៅ
លើស្តានីយ៍ពដអាយស្ទុយយាន មានបន្ទោញរូបភាពនៃព្រះភ្នែ ភ្នំសន្ទោ

សន្ទៅ ក្នុងពេលកំជ្ជួបធេះបន្ត ៗ ត្នា ។

ក្នុងពេលនោះ អាចារ្យគណៈមហានិកាយ ១ នាក់ នៅប្រចាំការ សម្រាប់នាំផ្ទើនៅមហាវេង, ព្រះសង្ឆគណៈមហានិកាយជាង ៦៥០ អង្គនមស្ការព្រះរត្នត្រ័យ, រួបពួកទបាសក-ទបាសិកានមស្ការ ដោយមាន ព្រះករុណាទាំងពីរព្រះអង្គ និងសម្តេចព្រះទបយុវរាជជាប្រមុ ។

ឧណៈនោះ សម្តេចព្រះមហាសុមេធាធិបតីសង្ឆនាយកគណៈ មហានិកាយ នាំពុទ្ធបរិស័ទ ឲ្យស្រែកថ្វាយព្រះពរជ័យ ៣ ជងថា

សម្មាសម្ពុទ្ធស្ស ជយោ ព្រះសម្មាសម្ពុទ្ធមានជ័យជំនះហើយ,
មារស្ស បរាជយោ មារបាញ់ព្រះហើយ,

លំដាប់តមក មានព្រះសង្ឆគណៈមហានិកាយចំនួនជាង ៦៥០ អង្គ ស្វាធ្យាយធមិបដិច្ចសមុប្បាទ, អនេកជាតិសំសារំ, យទាហារ បាតុកវន្ទិ ធម្មា ជាដើម ។

ថ្ងៃទី ៣

គឺថ្ងៃអង្គារ ១ រោច ខែពិសាខ ព.ស. ២៥០

(១៤ ឧសភា ១៩៥៣)

ថ្ងៃនេះ ជាថ្ងៃវិសាខបូជា តាមវិធីបក្សនៃគណៈធម្មយុត្ត ។

ពេលព្រឹក មោ៉ង ៦ ក្រឹ. ព្រះករុណាទាំង ២ ព្រះអង្គនឹងសម្តេចព្រះទបយុវរាជទ្រង់យាងត្រឡប់ ។

ក្នុងពេលនោះ, មានការរៀបក្ឈួនជូនដំណើរ គណៈប្រតិភូនានា ប្រទេសទៅទស្សនាប្រាសាទនគរវត្ត ដល់ថ្ងៃទី ១៤ ឧសភា ពេលព្រឹក ទើបវិលមកវិញ ។

មោង ៩ ព្រឹក, លោកប្រធានរដ្ឋសភាអញ្ជើញដល់អគារកិត្តិយស, បានទទួលកម្រងបុប្ផាពីកញ្ញាមួយនាក់ ទៅបូជាព្រះបរមសារីរិកធាតុ ។ បន្ទាប់មក លោកប្រធានបានអញ្ជើញឡើងលើវេទិកាកិត្តិយសសូត្រ សេចក្តីថ្វាយការណ៍ជាបដិសណ្ឋារកិច្ច ចំពោះព្រះបរមសារីរិកធាតុថា:-

សូមនមស្សការចំពោះព្រះអរហន្តសម្មាសម្ពុទ្ធ

សុភវារតិថី ថ្ងៃនេះ បានធ្វងផុតពាក់កណ្តាលនៃព្រះពុទ្ធសាសនា ហើយ បើខ្ញុំព្រះអង្គរំពឹងនឹកទៅអតីតកាល ចាប់តាំងពីថ្ងៃអង្គារដប់ប្រាំកើត ខែវិសាខឆ្នាំម្សាញ់បញ្ចស័ក ជាកាលបវិច្ឆេទដែលព្រះអង្គទ្រង់ចូលកាន់ ព្រះបរមនិព្វានមកនោះ នឹងឃើញថា អាយុកាលនៃព្រះពុទ្ធសាសនា កន្ធងមកជាយូរអង្វែងហើយ ជាង ២៥ សតវត្សនៃពុទ្ធសករាជ ។ ប៉ុន្តែ ព្រះនវអរហាទិគុណ ដែលរួមចុះមកមានត្រឹម ៣ គឺព្រះវិសុទ្ធិគុណ, ព្រះ បញ្ញាគុណនឹងព្រះករុណាគុណ ព្រមទាំងព្រះធម្មវិន័យជាសាសនធម៌ របស់ព្រះអង្គ បានស្ថិតនៅដ៏ខ្ជាប់ខ្ជួនក្នុងដួងហឫទ័យខ្ញុំព្រះអង្គ ព្រមទាំង ប្រជាជាតិខ្មែរទាំងឡាយ ដូចជាព្រះអង្គទ្រង់គង់ព្រះជន្មនៅឡើយ ។

បពិត្រព្រះមានព្រះភាគ

សាសនធម៌របស់ព្រះអង្គ ក្រោយដែលព្រះអង្គទ្រង់មរិនិព្វានទៅជា

យូរឆ្នាំ ទើបបានផ្សាយជ្រួតជ្រាបចូលមកប្រទេសកម្ពុជា ។ តាមព្រះពុទ្ធសាសនាវិស្វាសថា ព្រះមហាក្សត្រិយ៍ខ្មែរបុរាណ បានទទួលយកយក ព្រះពុទ្ធសាសនាមកប្រតិបត្តិ តាំងពីសតវត្សទី ១ នៃព្រះពុទ្ធសករាជ គិតទៅក្នុងឆ្នាំជាង ៤៥ សតវត្សមកហើយ ។ សាសនាធម៌ របស់ព្រះអង្គនេះ បានធ្វើឲ្យប្រជាជាតិខ្មែរប្រកបដោយសីលធម៌ ស្នេហា សន្តិភាព ទឹងមានវប្បធម៌ សង្គមកិច្ច ព្រមទាំងសេដ្ឋកិច្ច ថែមទៀត ។

ប្រជាជាតិខ្មែរបានយល់ដាក់ច្បាស់ថា សច្ចធម៌ ៤ ប្រការ ហៅថា ចតុរារិយសច្ច គឺទុក្ខ, សមុទ័យ, និរោធ និងមគ្គ ដែលព្រះអង្គទ្រង់ប្រកាសជាទីពីរ ហើយជាដំបូងបំផុតនៃព្រះធម៌ទេសនា កន្លះអាងចំពោះព្រះបញ្ចវគ្គិយថា សច្ចធម៌នេះ ព្រះអង្គពុំដែលបានស្តាប់បានឮអំពីមុនមកទេ សច្ចធម៌នេះពិតជាធម៌ដឹកនាំសត្វលោកអ្នកប្រតិបត្តិតាមឲ្យនិរាសចាកទុក្ខ បានដល់នូវសន្តិសុខ ដែលជាបរមសុខយ៉ាងជាក់ស្តែង ។ ប្រជាជាតិខ្មែរយល់ថែមទៀតថា សច្ចធម៌នេះសាស្តាដទៃពុំអាចរកឃើញបានដោយដាច់ខាត ហើយពួកបណ្ឌិតវេទន ឬអ្នកនយោបាយណាមួយក៏ពុំអាចរិះគន់ ដោយសុក្រឹតនិច្ច័យបានដែរ ។

អាស្រ័យហេតុនេះ បានជាប្រជាជាតិខ្មែរ ខំប្រឹងប្រែងរក្សាទុកនូវសាសនធម៌របស់ព្រះអង្គ ជាង ១ សតវត្សមកហើយ ហើយបានតាំងចិត្តថានឹងរក្សាទុកនូវសាសនធម៌នេះ ជាប់ជាប់ដល់អវសានកាលនៃព្រះពុទ្ធសាសនា ។

បពិត្រព្រះបរមត្រូ

ក្នុងនាមនៃសមាជិកវដ្ឋសភា ជាតំណាងប្រជាជាតិវៀត្ន នឹងក្នុងនាមផ្ទាល់ខ្លួនខ្ញុំព្រះអង្គ សូមបួងសួងបំពោះព្រះគុណព្រះអង្គ ព្រះធម៌នឹងព្រះសង្ឃព្រមទាំងវត្ថុសក្តិសិទ្ធិក្នុងសកលលោក ជួយអភិបាលប្រជាជាតិវៀត្ន នឹងប្រទេសវៀត្ន ឲ្យបានទទួលនូវសន្តិសុខប្រកបដោយវឌ្ឍនធម៌ជាភិយ្យោភាព អស់កាលជាអង្វែងតរៀងទៅ ។

មួយទៀត សូមជួយអភិបាលសកលលោកឲ្យបាននូវសន្តិភាពប្រាសចាកភ័យអន្តរាយ សព្វទិវារាត្រី កុំបីឃ្លៀងឃ្លាតឡើយ ។

× × ×

លំដាប់តមក មានធ្វើពិធីសមាទានសីលបែបធម្មយុត្ត ជាឧឡារិកមានសម្តេចព្រះសុធម្មាធិបតី កុល-ទេស ឥន្ទញ្ញាណោ សង្ឃនាយកគណៈធម្មយុត្ត ប្រទានសីលជាឧឡារិកលើវេទិកាពិសេស ។

ពេលម៉ោង ១០ សម្តេចព្រះមហាក្សត្រិយានី សម្តេចព្រះឧបយុវរាជ, សម្តេចព្រះរាជកនិដ្ឋារស្មីសោភ័ណ, សម្តេចក្រុមព្រះស៊ីសុវត្ថិមុនីរ៉ែត ស្តេចយាងមកដល់ព្រមទាំងព្រះរាជបរិពារ ។ ក្រោយដែលព្រះអង្គទាំងពីរទ្រង់យកកួងផ្កាទៅបូជាព្រះបរមសារីរិកធាតុ, ទ្រង់ស្តេចយាងចូលទៅកាន់មហារាង, កាលស្តេចដល់មាត់ទ្វារមហារាង វង់ក្វេងបានបន្ទឹបទនគររាជថ្វាយជាព្រះរាជកិត្តិយស ។

ពេលម៉ោង ១០, ១៥នាទី, សម្តេចព្រះមហាក្សត្រិយានី សម្តេចព្រះឧបយុវរាជនឹងសម្តេចព្រះរាជកនិដ្ឋារស្មីសោភ័ណ ទ្រង់ដាក់បាត្រព្រះសង្ឃ

១០០ អង្គ ។ សម្តេចវៀហ្វាកំដរវៀងដ៏យអធិបតីស្រីផ្ការ ប៉ែន-ឌុត, សមាជិករដ្ឋាភិបាល, មន្ត្រីជំនួប បានទៅរួមដាក់ចាត្រជាមួយព្រះអង្គផង ។

ពេលរសៀល ម៉ោង ១៦ លោកប្រធានក្រុមប្រឹក្សាព្រះរាជាណាចក្រអញ្ជើញទៅដល់ ដោយមានពិធីទទួលអាវុធផ្លូវ ។ ក្រោយដែលលោកប្រធានបានយកកូនបុប្ផាទៅបូជាព្រះបរមសារីរិកធាតុ លោកបានអញ្ជើញទៅលើវេទិកាតំណែងថ្ងៃឯបដិសណ្ឋារ មានសេចក្តីដូចតទៅនេះ៖

សូមនមស្សការព្រះសមណគោតម បរមគ្រូជាម្ចាស់!

ថ្ងៃនេះ ជាតិថ្មគ្គលមួយ ហាន់ទុឡាកជាទំព័រ ដែលគួរចារកុកថា ជាអនុស្សរណៈកាលដ៏ប្រសើរ ក្នុងប្រវត្តិសាស្ត្រនៃព្រះពុទ្ធសាសនា ។

បពិត្រព្រះមានបុណ្យ

ព្រះពុទ្ធសាសនា របស់ព្រះអង្គនេះ ចាប់ចាប់ដើមតាំពីថ្ងៃអង្គារ ដប់ថ្ងៃកើត ខែវិសាខ ឆ្នាំម្សាញ់បញ្ចស័ក ជាតិថ្មគ្គលល្អដែលព្រះអង្គទ្រង់ស្តេចយាងចូលកាន់ព្រះបរមនិព្វានទៅ មកទល់ទីនថ្ងៃជាបច្ចុប្បន្ននេះ ឃើញថាមានអាយុកាលកន្លងទៅ ២៥០០ ឆ្នាំហើយ ។

បពិត្រព្រះមានជោគ

ពិតមែនតែអាយុកាលនៃព្រះពុទ្ធសាសនារបស់ព្រះអង្គ បានកន្លងទៅជាយូរអង្វែង ក៏ប៉ុន្តែ ព្រះគុណទាំងអស់របស់ព្រះអង្គ ព្រមទាំង

សាសនធម៌របស់ព្រះអង្គ ប្រទេសថ្មីតនៅតជាំវិញអស់ ស្ទើរតែគ្មានខ្លះ អក្សរឬបទប្បព្រះគាថាណាមួយទេឡើយ ។

បពិត្រព្រះមានព្រះភាគ

សាសនធម៌ដ៏បវរបស់ព្រះអង្គនេះ ប្រទេសមកប្រតិស្ឋានក្នុងប្រទេសខ្មែរ អស់រយៈកាលជាយូរអង្វែងហើយ គាំងពីសតវត្សទី១០នៃព្រះពុទ្ធសករាជ តតៅជាង ១០០០ ឆ្នាំហើយ ។

ដោយអាស្រ័យការឧត្តឧត្តការគោរពប្រតិបត្តិយ៉ាងមុតមាំ នៃព្រះមហាក្សត្រខ្មែរគ្រាំងគ្រាយៗផង ទឹងប្រជាជនខ្មែរគ្រាំងអស់ធន កំព្រះពុទ្ធសាសនារបស់ព្រះអង្គនោះ មានថ្ងៃរកាពនឹងរលាយនាស រុងរឿងជាងទីបំផុតហាក់ដូចព្រះអង្គតង់ព្រះដន្ទៅឡើយដែរ ។

ក្នុងបច្ចុប្បន្នេះសោត ព្រះមហាក្សត្រខ្មែរ ទឹងប្រជាជនខ្មែរគ្រាំងអស់ នៅតែមានជំនឿ ទឹងគោរពប្រតិបត្តិ លើកតំកើងបូជាព្រះពុទ្ធសាសនានេះ ឲ្យតង់រង្វាស ឲ្យរុងរឿងនៅជាដដែល ហើយទៅអនាគតខៀត កំប្រទេសខ្មែរគ្រាំងមូលបានតាំងចិត្តថា ទឹងរក្សាសាសនធម៌របស់ព្រះអង្គ ជាប់ជាប់អស់កាលនៃព្រះពុទ្ធសាសនា ។

បពិត្រព្រះអរហន្តសម្មាសម្ពុទ្ធ

ក្នុងព្រះបរមនាមនៃព្រះមហាក្សត្រគ្រាំងពីព្រះអង្គ ក្នុងនាមនៃប្រជាជនខ្មែរគ្រាំងអស់ ក្នុងនាមនៃសមាជិកក្រុមប្រឹក្សាព្រះពុទ្ធសាសនាចក្រគ្រាំងមូលទឹងក្នុងនាមផ្ទាល់ខ្លួនខ្ញុំព្រះអង្គ សូមបួងសួងចំពោះព្រះគុណព្រះអង្គ ព្រះធម៌ទឹងសង្ឃ ព្រមគ្រាំងវត្ថុសក្តិសិទ្ធិក្នុងលោក សូមជួយអភិបាលរក្សា

ព្រះប្រិយមហាក្សត្រប្រជាជនប្រទេសវ្ទៃ ឲ្យបានឲ្យវសេចក្តីសុខប្រកប
ដោយសេចក្តីចំរើនរុងរឿង ជាកិយ្យោភាពអស់កាលអវ្ងូងតរៀងទៅ ។

មួយទៀត សូមជួយអកិបាលរក្សាពិភពលោកទាំងមូលឲ្យមានសន្តិ-
ភាពប្រាសចាកសិកសង្ត្រាមត្រប់ពេលវេលាកុំបីឃ្ជៀងឃ្ជាតឡើយ ។

× × ×

បន្ទាប់មក ទបាសក-ទបាសិកា នមស្ការ, សម្តេចព្រះសុធម្មាធិបតី
សង្ឆនាយកគណៈធម្មយុត្តប្រទានសីលជាទឡាវិក លើវេទិកាធិសេស ។

លោកប្រធានក្រុមប្រឹក្សាព្រះរាជអាណាចក្រ បានវិលត្រឡប់ទៅវិញ
នៅវេលាម៉ោង ១៦,៤០ នាទី ។

ពេលយប់ ម៉ោង ១៩,៣០នាទី, មានការជួបជុំព្រះសង្ឆគណៈ
ធម្មយុត្តិកនិកាយ មានសម្តេចព្រះសុធម្មាធិបតីជាប្រធាន ។

នៅវេលាម៉ោង ៦០ ព្រះករុណាជាអម្ចាស់ជីវិតលើត្ឆូង សម្តេចព្រះ
មហាក្សត្រិយានី, សម្តេចព្រះទបយុវរាជ ស្តេចយាងមកជល់ព្រមទាំងព្រះ
រាជបរិពារ ។

ក្រោយដែលព្រះករុណាទាំងពីរព្រះអង្ត ព្រមទាំងសម្តេចព្រះ-
ទបយុវរាជ ទ្រង់បានយកកូងបុប្ជាបូជាចំពោះព្រះបរមសារីរិកធាតុទ្រង់ស្តេច
យាងប្រទក្សិណបុស្ឆុកជាទីជំកល់ព្រះបរមសារីរិកធាតុ ជាទក្ខិណាវដ្ត ៣
ជុំ បន្ទាប់ពីនោះមក មានការសំដែងគាវរកាពចំពោះក្ងូងជាតិ ។

រួចហើយកាំជ្ជួចរន្ទាក្ត្រីទៀនក៏បានផ្ទុះឡើងពុសូរគគ្រឹកគគ្រេងលាយ
ដោយសំឡេងពួកពុទ្ធសាសនិកជនជាប្រើនពាន់នាក់ ហើយនៅពេល

នោះ មានវត្តពីរសេសមួយ នៅលើដំបូលស្ថានីយ៍ពដអយស្ទុយយោន ចានបញ្ចេញពណ៌ដាវស្មើ ៦ ពណ៌ ទំនឹបញ្ចេញជាព្រះពុទ្ធរូបប្រាសន្តៅ នៅទីនោះ ។

លំដាប់តមក ព្រះករុណាជាអម្ចាស់ដ៏វិតលើក្បាល, សម្តេចព្រះមហាក្សត្រិយានី, សម្តេចព្រះឧបយុវរាជ ទ្រង់ស្តេចយាងទៅគាន់មហាពេធដើម្បីគោរពនមស្ការព្រះរត្នត្រ័យ ព្រមទាំងសម្តេចព្រះពដកនិដ្ឋាវស្មើសោភ័ណ, សម្តេចក្រុមព្រះស៊ីសុវត្ថិមុនីរតន, សម្តេចកំធរវរៈវឿនជ័យ, សមាជិកឧត្តមប្រឹក្សាអមព្រះរាជា, សមាជិករដ្ឋាភិបាល, មន្ត្រីធំ-តូច ហែហមជាព្រះពដបរិពារ រួចទ្រង់ស្តេចយាងវិលត្រឡប់មកគាន់ព្រះពន្ធាភិក្តិយសដើម្បីទំនឹទ្រង់ព្រះសណ្តាប់ធូរព្រះសង្ឃធ្វើវិសាខបូជា ។

ព្រះសង្ឃគណៈធម្មយុត្តចំនួន ២៥ អង្គ សូត្រវិសាខបូជា សម្តេចព្រះសង្ឃនាយកគណៈធម្មយុត្តសំដែងព្រះធម្មទេសនា ។

លំដាប់តមក ក្រោយដែលព្រះករុណាទាំងពីរព្រះអង្គសម្តេចព្រះឧបយុវរាជ ទ្រង់ស្តេចយាងវិលត្រឡប់ព្រះបរមពដកំធរវិញ មានព្រះធម្មកថិកគណៈធម្មយុត្ត ២ អង្គទេសនាវឿនពុទ្ធប្រវត្តិ ២ លើក ក្នុងមួយលើកកន្លះមោង ។

លើកទី ១ មោង ២២ ព្រះមហា មៅ-ខាន់ វត្តបទុមវតី ទេសនាវឿនទុក្ករកិរិយាបរិច្ឆេទី ៨ ពុទ្ធបូជាបរិច្ឆេទី ៩ ។

លើកទី ២ មោង ២២,៣០ ព្រះបាឡាត់បទុមវង្ស ហ៊ីន-កេង វត្តបទុមវតី សំដែងវឿនមារវិជ័យបរិច្ឆេទី ១០, អភិសម្ពោធិបរិច្ឆេទី ១១ ។

ក្នុងទាសនោះ ពុទ្ធសាសនបណ្ឌិត្យ បានចែកសៀវភៅពុទ្ធសាសនា ៦៥០០ ចំនួន ៥០០ ក្សាល ។

ថ្ងៃទី ៤

គឺថ្ងៃពុធ ២ ចេបខែពិសាខ្ទ ព.ស.២៥០០

(១៥ឧសភា ១៩៥៣)

ថ្ងៃនេះជាថ្ងៃនខត្តប្ចក្សមួយដ៏ប្រកបដោយជោគជ័យមង្គលសិរីសួស្តីគឺ ថ្ងៃរំលឹកដល់ព្រះមានព្រះកាគសម្ពុទ្ធបរមគ្រូទ្រង់សំដែងធម្មចក្រ ។

ពេលព្រឹក មោ៉ង ៧.៥៥ លោកទេសរដ្ឋមន្ត្រីក្រសួងធម្មការ និងសន្តិសុខជាតិអញ្ជើញមកដល់ ។ ក្នុងពេលនោះ ពួកពុទ្ធសាស-និកជនជាច្រើនពាន់នាក់ បានអញ្ជើញមកទស្សនាពិធីបុណ្យនេះមីដេរ ជាសប្រជ្រៀតគ្នាដើរស្ទើរមិនរួច ។ ក្រឡេកទៅឃើញពិណ លឿង អណ្តែតគ្រសែតកណ្តាលពណិសគឺពួកពុទ្ធសាសនិកជនជាភេទបព្ចជិតនឹង គ្រហស្ថអ្នកកាន់សីល ១០ ទៅលាយចម្រុះ និងមហាជនប្រុសស្រីពណ គ្រប់យ៉ាង ។

ក្រោយដែលលោកទេសរដ្ឋមន្ត្រី បានយកកូងបុប្ជាទៅបូជាព្រះ បរមសារីរិកធាតុ លោកបានអញ្ជើញទៅលើវេទិកាកិត្តិយស ថ្ងៃងសង្កបា ជាបដិសណ្ឋារកិច្ចចំពោះព្រះបរមសារីរិកធាតុ មានសេចក្តីដូចតទៅនេះ:

សូមថ្វាយបង្គំព្រះសម្មាសម្ពុទ្ធ

ក្នុងទាសពិធីបុណ្យរំលឹកពុទ្ធសកាជ ៦.៥០០ រស្យានេះ យើងខ្ញុំព្រះ

អង្គទាំងឡាយជាពុទ្ធបរិស័ទទាំងបព្វជិតទាំងគ្រហស្ថ សូមបង្អោនដោយ
គោរពដឹងឡាវិកនូវកាយវាចាចិត្ត ចំពោះព្រះបរមសារីកធាតុនៃព្រះអង្គ ។

ពិធីបុណ្យដឹមហោឡាវិកនេះ នៅប្រទេសកម្ពុជាយើង ទើបនឹងមាន
ម្តងនេះទេ ជាបុណ្យដែលត្រូវកត់ត្រាចុះទុកក្នុងប្រវត្តិសាស្ត្រនៃប្រទេស
កម្ពុជាតទៅ ។ យើងខ្ញុំព្រះអង្គជាពុទ្ធបរិស័ទ បានចាត់ចែងធ្វើបុណ្យតាម
ផ្លូវការនេះ ដើម្បីឲ្យសមគួរដល់កិត្តិយសនៃព្រះអង្គដែលជាអគ្គសាស្ត្ត
ក្នុងលោក ដោយខ្ញុំព្រះអង្គទាំងឡាយនឹករលឹកចំពោះព្រះអង្គដែលបរិ-
បូណ៌ដោយគុណជាច្រើនប្រការ លើមនុស្សសត្វក្នុងសកលលោក សូម្បី
ព្រះអង្គបរិនិព្វានកន្ធងទៅអស់ ២៥០០ ឆ្នាំហើយពិតមែន ប៉ុន្តែព្រះ
កិត្តិនាមរបស់ព្រះអង្គនឹងព្រះសាសនារបស់ព្រះអង្គ ឯតនៅស្ថាពរជូច
កាលព្រះអង្គតង់ព្រះជន្មនៅឡើយ ដោយហេតុសាសនារបស់ព្រះអង្គមាន
សារៈគុណដឹប្រសើរបំផុត ដែលមហាជនក្នុងសកលលោក តែងដឹងព្ធ
ទទួលស្គាល់ ។

ព្រះបរមគ្រូសម្មាសម្ពុទ្ធ មានគុណដឹធំទូលាយច្រើនប្រការពុំអាច
ពណ៌នាឲ្យអស់បានឡើយ ប៉ុន្តែព្រះគុណនៃព្រះអង្គនោះ បើនិយាយ
ដោយរួបរួមយាំងខ្លី មានពីរប្រការគឺ

១- **អត្ថហិតគុណ** គុណដោយព្រះអង្គបានត្រាស់ដឹងញ្ញាយ្យធម៌
ទាំងពួងមានអរិយសច្ច ៤ ប្រការជាដើម ព្រមទាំងបរិសុទ្ធផូរផង់ ចាក
កិលេសគ្រឿងសៅហ្មងគ្រប់យ៉ាងដែលជាប្រយោជន៍ចំពោះព្រះអង្គ ។

២- បរហិតគុណ គុណដោយព្រះអង្គ ប្រកបដោយព្រះមហាករុណាចំពោះមនុស្សសត្វទាំងអស់ក្នុងលោកគ្រប់ទិសទាំង ១០ ដោយទ្រង់និមន្តគ្រាប់រង្គាត់សំដែងធម៌ទេសនា ប្រោសសត្វជាសាធារណៈ ឥតប្រកាន់ត្រកូលរើសជាតិ រើសវណ្ណៈ ចង់ឲ្យតែពពួកសត្វប្រព្រឹត្តល្អតាមព្រះអង្គ ដើម្បីឲ្យបានទទួលសេចក្តីសុខ-ចំរើនតាមសមគួរដល់ទបនិស្ស័យវាសនារៀងៗខ្លួន ។

បពិត្រព្រះសម្មាសម្ពុទ្ធ

សាសនារបស់ព្រះអង្គបរិបូណ៌ដោយគោលធម៌ដោយអត្ថបទ ដោយទ្រឹស្តីដែលល្អៗ ជាច្រើនណាស់ ជាសាសនាប្រព្រឹត្តទៅដើម្បីសន្តិភាព ។ លទ្ធផលរបស់ពុទ្ធបរិស័ទអ្នកប្រព្រឹត្តប្រតិបត្តិគឺ មគ្គផលនិព្វាន ដែលជាគុណដ៏ប្រសើរបំផុតរបស់ពុទ្ធសាសនា ។ ព្រះសម្មាសម្ពុទ្ធ ព្រះអង្គបានដល់នូវត្រើយសម្មាសម្ពោធិញ្ញាណ ដូចគោលបំណងរបស់ព្រះអង្គនេះ ដោយអានុភាពនៃពុទ្ធការកធម៌ឬ បារមីទាំង ១០ យ៉ាង មានទាន-បារមីជាដើម ។ ក្នុងកាលដែលទ្រង់កសាងបារមីធម៌នេះ មានសេចក្តីលំបាកជាយ៉ាងក្រៃលែង ទ្រង់ទំបំពេញដោយព្យាយាមដ៏លើសលប់ តស៊ូនឹងទបស័ត្តដោយឥតរួញា អស់រយៈកាល ៤ អសង្ខេយ្យ នឹង ១សែនកប្ប ព្រះអង្គទំបំពេញបារមីរៀងរាល់ជាតិដើម្បីត្រាស់ដឹង, ព្រះអង្គបង្រៀនព្រះទ័យព្រះអង្គឲ្យហ៊ានលះហ៊ានបត្ថូ សូម្បីរាជសម្បត្តិនឹងបុត្រភរិយាព្រមទាំងជីវិតរាងកាយរបស់ព្រះអង្គក៏ព្រះអង្គអាចហ៊ានលះ ហ៊ានបរិច្ចាគឲ្យទៅជាទានដល់អ្នកដទៃ ដើម្បីប្តូរយកការត្រាស់ដឹងផង ទុកជាទិដ្ឋានុគតិ

ដល់មហាជនជាន់ក្រោយផង ដូចយ៉ាងកាលទ្រង់ចេញចោលរាជកំណ ទ្រង់ព្រះផ្នួសហើយបំពេញពុទ្ធកិរិយាស្ទាំងស្គមកាលតែដួលលើផែនដី តមកទ្រង់ផ្ទាស់ប្តូរសេចក្តីប្រតិបត្តិជាថ្នីដរាបកាលតែបានត្រាស់ដឹង ។ លុះព្រះអង្គត្រាស់ដឹងហើយ ទ្រង់មិនមើលបំណាំសត្វលោក ទ្រង់និមន្តទៅកាន់ស្រុកតូចធំ ដើម្បីសំដែងធម៌ទេសនាប្រោសសត្វ ដើម្បីបំភ្លឺប្រយោជន៍បច្ចុប្បន្ន ប្រយោជន៍ក្នុងបរលោកនិងប្រយោជន៍ក្នុងព្រះនិព្វាន ។ ទ្រង់បានបំពេញពុទ្ធកិច្ច រាប់តាំងអំពីថ្ងៃដែលបានត្រាស់រហូតដល់ថ្ងៃទ្រង់បរិនិព្វាន គ្រប់ជា ៤៥ ឆ្នាំ ។

បពិត្រព្រះសក្យមុនីគោតម

ព្រះមហាករុណាគុណធម៌ដែលមានក្នុងព្រះអង្គផង មានចំពោះសត្វលោកផង ដូចបានរៀបរាប់មកដោយសង្ខេបប៉ុណ្ណោះ ។ អាស្រ័យដំណើរនេះហើយ ទើបយើងខ្ញុំព្រះអង្គ ជាប្រជាតិខ្មែរគ្រប់ហាន: ព្រមទាំងជនបរទេសដែលនៅក្នុងប្រទេសកម្ពុជា មានសាមគ្គីធម៌ផ្តើមចាត់ការបុណ្យដ៏មហោឡារិកនេះឡើង ដើម្បីសំដែងកតវេទិតាធម៌ ការប្រកាសគុណឲ្យប្រាកដចំពោះព្រះអង្គ ។

ដោយអំណាចបុញ្ញាភិសេកនេះ សូមពួកទេវតាដែលមានឥទ្ធានុភាពស័ក្តិសិទ្ធិក្នុងលោកជួយអភិបាលរក្សា ប្រជាជាតិខ្មែរ ទឹនប្រទេសខ្មែរទាំងមូលឲ្យបានតប់ប្រសព្វចំពោះសេចក្តីសុខសេចក្តីចំរើន ថ្កើងរុងរឿងដូចសម័យអង្គរកុំបីអាក់ខាន ! ទាំងសូមជួយជោះស្រាយបញ្ហាតានតឹងក្នុងសកលលោកឲ្យបានធូរស្រាលស្បើយល្អើយ ពាក្យទុក្ខសោកពេតភ័យ

ទបច្រូតចង្រៃត្រប់យ៉ាង ឲ្យទៅជាសុកលលោកបានទទួលសុខក្សេមក្សាន្ត
និរុក្ខទុក្ខនិរភ័យ សន្តិភាព ជាស្ថាពរ តាំងអំពីថ្ងៃនេះតរៀងទៅ!

ដល់ចប់សង្កថានៃលោករដ្ឋមន្ត្រី មានស្នាខែដែលាន់ឮពីពន្លឺរឡើង
ជាយ៉ាងក្រៃលែង ។ រួចលោកទេសរដ្ឋមន្ត្រីថ្វាយបង្គំព្រះបរមសារីរិកធាតុ
ហើយអញ្ជើញចុះពីវេទិកាពិសេសមកអង្គុយកន្លែងព្រះពន្ធាកិត្តិយសវិញ ។

លំដាប់តមក មានធ្វើពិធីនមស្ការព្រះរតនត្រ័យ ។ សម្តេចព្រះសង្ឃ
នាយកគណៈមហានិកាយបានឱមន្តទៅតន់លើវេទិកាពិសេសប្រទានសីល
ប្រាំជាទូទៅ រួចសម្តេចប្រទានទុកថា: "សូមពុទ្ធសាសនិកជន
ទូទៅទំយកចិត្តទុកដាក់រក្សាសីលឲ្យបានហ្មត់ចត់ ព្រោះថា បើអ្នកណា
មួយមិនទំប្រព្រឹត្តតាន់សីល ៥ ។ ល ។ ឲ្យបានត្រឹមត្រូវតាមពុទ្ធាភ្ញាទេ
អ្នកនោះឈ្មោះថាដឹកឋសតល់របស់ខ្លួនឲ្យវិនាស អ្នកណាបានប្រព្រឹត្ត
សីលប្រាំជាដើមឲ្យបានស្អាតផូរផង់ អ្នកនោះឈ្មោះថាបានធ្វើខ្លួនឲ្យរួច
ចាកទុក្ខភាំងលោកនេះ នឹងលោកខាងមុខ.... ល ...." ។

ម៉ោង ៩.០០ មានការធ្វើពិធីតាវៃកិច្ចនៃកឋិនបដតម្រួតកឋិនជាវិតលនឹង
នាំគ្នាហានចំពោះព្រះបរមសារីរិកធាតុជាយ៉ាងទូទៅ ។ ក្នុងពេលនោះ
ឯកទុតមប្រាក់ប្រាត្រឿងសមាជិកទុតមប្រឹក្សាអមព្រះរាជា ជាព្រះរាជ-
តំណាងនៃព្រះករុណា ចាំងពីព្រះអង្គអញ្ជើញមកដល់ ។

ម៉ោង ១០.០០ ឯកទុតមព្រះរាជតំណាងសមាជិករដ្ឋាភិបាល នាម៉ឺន
សព្វមុខន្ត្រីបានអញ្ជើញទៅដាក់ជាត្រៀមក្នុងមហាពេធ ចំពោះព្រះសង្ឃ
ចាំងពីគណៈ ១៩០ អង្គ ផ្នែកខាងព្រះករុណាចាំងពីព្រះអង្គដែលទ្រង់

សព្វព្រះរាជហឬទ័យ ចំណាយទ្រព្យផ្ទាល់ព្រះអង្គធ្វើចង្ហាន់ជាក់ឋាត្រ ។ មួយក្រុមទៀត មានព្រះសង្ឆ ១០០ អង្គរួមតាំងពីរគណៈ ជាក្រុមសម្តេចព្រះរាជកនិដ្ឋានរស្មីៈសាគ័ណ ដែលសព្វព្រះទ័យចំណាយព្រះរាជទ្រព្យធ្វើចង្ហាន់ជាក់ឋាត្រ ។ មួយក្រុមទៀត មានព្រះសង្ឆ ១០០ អង្គរួមតាំងពីរគណៈ ជាក្រុមសម្តេចពិនតារាសុតារ៉ត ដែលទ្រង់សព្វព្រះទ័យចំណាយព្រះរាជទ្រព្យធ្វើចង្ហាន់ជាក់ឋាត្រ ។

ខាងកើតមហាវេង, មានពួកពុទ្ធបរិស័ទជាច្រើនឋាននាំយកចង្ហាន់មកជាក់ឋាត្រព្រះសង្ឆឥតមានកំណត់ចំនួន ។ មានពួកក្រុមតាហានខាងខេមរៈភូមិន្ទ ឋានយករថយន្តតាហានទៅដឹកព្រះសង្ឆអំពីវត្តផ្សេង ។ ឲ្យនិមន្តមកបិណ្ឌឋានទៅមណ្ឌលបុណ្យ ហើកដឹកនាំព្រះសង្ឆនោះត្រឲ្យប់ទៅកាន់វត្តវិញឲ្យឋានតាន់ពេលឆាន់ ។

ពេលរសៀល. មោ៉ង ១៦ លោករដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចជាតិអញ្ជើញមកដល់ ។

ក្រោយដែលយកភួងផ្ការទៅបូជាព្រះបរមសារីរិកធាតុ លោកឋានអញ្ជើញទៅកាន់រវិកាពិសេស ធ្វើសេចក្តីថ្វែងការណ៍ជាបដិសណ្ឋារកិច្ចចំពោះព្រះបរមសារីរិកធាតុមានសេចក្តីដូចខាងក្រោមនេះ:

សូមថ្វាយបង្គំព្រះសម្ពុទ្ធជាម្ចាស់ ក្នុងឧកាសពិធីបុណ្យតំរប់ ២៥០០ ព្រះវស្សានេះ យើងខ្ញុំព្រះអង្គតាំងឡាយសូមបង្ហានកាយវាចាចិត្តគោរពជាឧឡារិកចំពោះព្រះបរមសារីរិកធាតុនៃព្រះអង្គ ។

ពិធីបុណ្យដ៏ធំអស្ចារ្យនេះ យើងខ្ញុំព្រះអង្គធ្វើឡើង ដោយការនឹកឃើញព្រះគុណសម្បត្តិ ៣ យ៉ាង របស់ព្រះអង្គដែលផ្សាយគ្រប់ជ្រាប់ស្រោចស្រប់លើយើងខ្ញុំប្រជាជាតិខ្មែរទាំងប្រទេស ។

ព្រះគុណសម្បត្តិ ៣ ប្រការនោះគឺ

១- ព្រះបញ្ញាគុណ គុណត្រង់ដែលព្រះអង្គត្រាស់ដឹងនូវធម៌ពិត ៤ ប្រការមុនសាស្តាទាំងអស់ក្នុងលោក ហើយប្រកាសប្រាប់សត្វឲ្យដឹងផង គឺព្រះអង្គត្រាស់ដឹងនូវ៖

ក- ទុក្ខសច្ច សេចក្តីទុក្ខ ជាបរមសច្ចពិត,

ខ- សមុទយសច្ច ហេតុនាំឲ្យកើតទុក្ខ ជាបរមសច្ចពិត,

គ- និរោធសច្ច ការរំលត់ទុក្ខ ជាបរមសច្ចពិត,

ឃ- មគ្គសច្ច ផ្លូវនៃសេចក្តីប្រដិបត្តិដើម្បីរំលត់ទុក្ខ ជាបរមសច្ចពិត ។

២- ព្រះវិសុទ្ធិគុណ គុណត្រង់ដែលព្រះអង្គបរិសុទ្ធស្អាត គ្មានកំហុសជាគ្រឿងមន្ទិលសៅហ្មងក្នុងព្រះទ័យ ចាត់ជាព្រះអរិយបុគ្គលជាន់ខ្ពស់បំផុត ដែលពួកសត្វលោកគួរយកតម្រាប់ព្រះអង្គ ។

៣- ព្រះការុណ្យគុណ គុណត្រង់ដែលព្រះអង្គ មានព្រះទ័យមេត្តាករុណា ចំពោះសត្វសត្វទាំងអស់គ្មានលើសមុខ ។

ដោយហេតុព្រះអង្គមានព្រះករុណាគុណនេះហើយ ទើបកាលព្រះអង្គគង់នៅឡើយ ទ្រង់ស្វះស្វែងប្រោសសត្វឥតតិតជល់ការលំបាកព្រះអង្គ ព្រមទាំងប្រតិស្ឋានសាសនា ទុកតមកដល់វេលានេះ ។

ឋតិត្រព្រះសម្មាសម្ពុទ្ធបរមគ្រូជាម្ចាស់

យើងខ្ញុំព្រះអង្គ ដោយបានឃើញនូវមហាគុណទាំង ៣ នេះ ហើយ ទ្រាំពុំបានទើបថ្វែងនូវសេចក្តីគោរពចំពោះព្រះអង្គដោយបន្ទឹកចាដ៏លាន់ឮខ្ទរខ្ទារយ៉ាងនេះ ។ ព្រះគុណសម្បត្តិទាំង ៣ នោះយើងខ្ញុំបានដឹងច្បាស់ថាព្រះអង្គបានសម្រេចដោយសារសេចក្តីព្យាយាមជាបញ្ញាធិកកាលអំពីអតីតជាតិ ដែលមានសេចក្តីលំបាកជាយ៉ាងខ្លាំងក្រៃលែង ពាប់ដោយកប្បតស់ ៤ អសំខេយ្យ ១សែនកប្ប ។ ពាល់តែព្រះជាតិ ព្រះអង្គយកព្រះទ័យប្តូរនឹងព្រះសម្ពោធិញ្ញាណមិនមានខ្ជិលច្រអូស គឺ

- ព្រះជាតិខ្លះហ៊ានលះរាជសម្បត្តិដោយទ្រង់ផ្ទួនជាតាបស,
- ព្រះជាតិខ្លះលះបុត្តភរិយាឲ្យជាទានដល់សមយាចក,
- ព្រះជាតិខ្លះហ៊ានពុះទ្រូងរួងយកថ្លើមដាក់ទានដល់អ្នកត្រូវការ ។

កិច្ចទាំងអម្បាលនេះទ្រង់ប្រាថ្នាសុំឲ្យតែសម្រេចពោធិញ្ញាណ ។ ដល់ម្ករបច្ឆិមជាតិ ព្រះអង្គលះបង់សម្បត្តិស្តេចចក្រ ដែលនៅតែ ៧ ថ្ងៃទៀតវិវឌ្ឍបាន មិនមានព្រះទ័យស្តាយ ។ ទ្រង់ចេញចោលពាជកំដាក់ទៅទ្រង់ព្រះសង្វេហើយធ្វើទុក្ករកិរិយារហតល់តែផ្ទួលលើផែនដី ហើយប្រែផ្លាស់ព្រះទ័យមកចំរើនអានាបាណស្សតិកម្មដ្ឋាន ក៏បានសម្រេចព្រះពោធិញ្ញាណ ។

តមក ទ្រង់មិនទៅសុខទ្រង់ស្តេចនិមន្តទេសនាទូន្មានដឹកនាំសត្វឲ្យបានសម្បត្តិសុខ ៣ ប្រការ គឺសុខក្នុងមនុស្សលោក ១ ក្នុងទេវលោក ១ ក្នុងព្រះនិព្វាន ១ ។

បពិត្រព្រះសក្យមុនីគោតម

អាស្រ័យហេតុដែលព្រះអង្គ មានព្រះមហាទបការគុណដ៏ធ្ងន់ចំពោះពុទ្ធបរិស័ទដូចថ្ងៃនមកនេះ ទើបយើងខ្ញុំធ្វើបុណ្យដ៏ទឡារិកនេះ ដើម្បីសំដែងនូវកតញ្ញូកតវេទិតាធម៌ចំពោះព្រះអង្គ ។

ដោយអំណាចបុញ្ញកសីនេះ សូមពពួកទេវតាដែលមានវិទ្ធានុភាពនឹងសូមឲ្យវត្ថុស័ក្តិសិទ្ធិក្នុងសកលលោកទាំងមូល ជួយអភិបាលប្រជាជាតិប្រទេសខ្មែរឲ្យបានជួបប្រសប់តែនឹងវិបុលសុខ ដោយផ្តល់ផលិតផលឲ្យសម្បូណិហូរហៀ តាំពារឲ្យមាំមួន ជួបជួននូវការថ្កើងរុងរឿង ជួចសម័យអង្គរកុំបីអាក់ខាន ហើយជួយអភិបាលសម្រាលការតានតឹងក្នុងសកលលោកឲ្យបានធូរស្បើយចាប់តាំងពីពេលនេះតរៀងទៅ ។

ជយោព្រះពុទ្ធសាសនា ។

នៅវេលាដែលលោកវជ្ជមន្ត្រីក្រសួងសេដ្ឋកិច្ចថ្ងៃនសន្ទាបានេះចប់ក្ខាម គេឌ្ឋសូរសម្ងៃងទៃដៃផ្ទុះចញពីចំណោមពុទ្ធបរិស័ទសំដែងសេចក្តីសាទរចំពោះសន្ទាបារបស់លោក ។

លុះចប់សុនូរកថាហើយ, លោកវជ្ជមន្ត្រីក្រសួងសេដ្ឋកិច្ចជាតិ ក៏ចុះពីលើវេទិកាមកកាន់ព្រះពន្ធាកិត្តិយសវិញ ។ លំដាប់តមក ពួកពុទ្ធសាសនិកជនទាំងបុរសស្ត្រី នមស្ការថ្វាយបង្គំព្រះរតនត្រ័យ រួចសម្តេចព្រះសង្ឆនាយកគណៈមហានិកាយប្រទានបញ្ចសីលជាទឡារិកលើវេទិកាពិសេស ព្រមទាំងឲ្យទៅទជល់ពួកពុទ្ធបរិស័ទ, ពន្យល់បំភ្ងឹអំពីការកាន់បញ្ចសីលរមែងមានផលប្រយោជន៍ក្នុងលោកនេះនឹងលោកខាងមុខ, មាន

អត្ថន័យដ៏ពីរោះអស់រយៈ រៀល ៣០ នាទីទើបចប់ ។

ពេលយប់ មោ៉ង ១៩,០០ មានជួបជុំពួកពុទ្ធបរិស័ទជាច្រើនរាប់ម៉ឺននាក់នមស្ការព្រះរតនត្រ័យ ។ បន្ទាប់មក មានព្រះសង្ឆគណៈមហានិកាយ ៤៥០០ អង្គ ស្វាធ្យាយព្រះធម្មចក្កប្បវត្តនសូត្រ ។

រួចព្រះធម្មកថិកគណៈមហានិកាយ ៤ អង្គ ទេសនារឿងពុទ្ធប្រវត្តិ ៤ លើក ក្នុង ១ លើកកន្ទះមោ៉ង :

លើកទី ១ មោ៉ង ៤៤ ព្រះមុនីកោសល សោម-ឈុន វត្តនិរោធរង្សី សំដែងរឿងពោធិសត្វញ្ញាបរិច្ចេទទី ១៤ ព្រហ្មជ្ឈសនបរិច្ចេទទី ១៣ ធម្មចក្កបរិច្ចេទទី ១៤ ។

លើកទី ៤ មោ៉ង ៤៤,៣០ នាទី ព្រះបាឡាត់ អ៊ុម ស៊ុម វត្តកែវព្រះគ្រើង សំដែងរឿងយសបព្វជ្ជាបរិច្ចេទទី ១៥ ឧរុវេលគមនបរិច្ចេទទី ១៦ អគ្គសាវកបរិច្ចេទទី ១៧ ។

មោ៉ង ៤៣ គឺមោ៉ង ១១ យប់, មានការប្រកួតប្រដែងអត្ថបទស្តីអំពីពុទ្ធោវាទជាសារវន្តដែលមានលទ្ធផលជូចខាងក្រោម :

លេខ ១ ប៊ូ-ប៉ូ ក្រូវបានរង្វាន់ ៣៥០០៤០០ នឹងព្រះពុទ្ធរូប ១ អង្គ

លេខ ៤ គុយ-សូត្រ :	៤៥០០៤០០	
លេខ ៣ ទ្រិញ-ភ៉ាញ :	១៥០០៤០០	
លេខ ៤ លីធាម-គេង :	១០០០៤០០	(ជារង្វាន់ល្ងងចិត្ត)
លេខ ៥ ស្រ៊ី-អ៊ូ :	១០០០៤០០	—
លេខ ៦ តូច-សឃ្ឃិន :	១០០០៤០០	— ។

ថ្ងៃទី ៥

គឺថ្ងៃព្រហស្បត៍ ៣ រោច ខែពិសាខ ព.ស.២៥០០

(១៦ ឧសភា ១៩៥៦)

ពេលព្រឹក មោង ៧,៥៩ លោករដ្ឋមន្ត្រីក្រសួងការពារប្រទេស ទទឹងយោសនាការអញ្ជើញមកដល់ ។ ក្រោយដែលបានធ្វើពិធីគោរពទង់ជាតិ ទទឹងខ្លួនតាវៀតចូលក្រុមក្មេងទទឹងក្រុមខាហានរួចហើយ ក៏បានចាត់ពិធីឲ្យហាយត្រាជោយមានលោកវរសេនីយ៍ឯក ង៉ោ.ហ៊ូ ដែលមានលោកវរសេនីយ៍ត្រី ភូក.ប៊ុតអមដំណើរផង ។ រួចលោករដ្ឋមន្ត្រីខ្លួលយកក្តួនបុប្ផាអំពីកញ្ជើម្នាក់ទៅបូជាព្រះបរមសារីរិកធាតុដែលតម្កល់នៅបុស្បក ។

លំដាប់តមក, លោករដ្ឋមន្ត្រីបានអញ្ជើញទៅលើវេទិកាពិសេសថ្វាយសេចក្តីជាបដិសណ្ឋារកិច្ចចំពោះព្រះបរមសារីរិកធាតុ ព្រះសម្ពុទ្ធបរមគ្រូជាម្ចាស់ដូចមានសេចក្តីតទៅនេះ ៖

សូមថ្វាយបង្គំព្រះសម្ពុទ្ធជាម្ចាស់

ក្នុងឱកាសពិធីបុណ្យរំលឹកពុទ្ធស័កពាជ២៥០០ វស្សានេះ យើងខ្ញុំព្រះអង្គដែលជាក្រុមកងរយោធពលខេមរៈភូមិន្ទពាំងឡាយ សូមបង្ហាញការយកចិត្តគោរពជាខ្លាំងក្លា ចំពោះព្រះបរមសារីរិកធាតុនៃព្រះអង្គ ។

ពិធីបុណ្យដ៏ធំអស្ចារ្យនេះ យើងខ្ញុំព្រះអង្គធ្វើឡើង ដោយនឹកឃើញព្រះគុណសម្បត្តិឥឡូវនេះរបស់ព្រះអង្គ ដែលផ្សាយគ្របដណ្តប់ស្រោចស្រង់មកលើយើងខ្ញុំជាជាតិខ្មែរពាំងប្រទេស ។

ព្រះគុណសម្បត្តិ៣ប្រការនោះគឺ

១-ព្រះបញ្ញាគុណ គុណត្រង់ដែលព្រះអង្គត្រាស់ដឹង នូវធម៌ពិត ៤ប្រការមុនសាស្តាទាំងអស់ក្នុងលោក ហើយប្រកាសប្រាប់សត្វឲ្យដឹងផង គឺព្រះអង្គត្រាស់ដឹងនូវ៖

ក- ទុក្ខសច្ច សេចក្តីទុក្ខ ជារបស់ពិត,

ខ- សមុទយសច្ច ហេតុនាំឲ្យកើតទុក្ខ ជារបស់ពិត,

គ- និរោធសច្ច ការរំលត់ទុក្ខ ជារបស់ពិត,

ឃ- មគ្គសច្ច ផ្លូវនៃសេចក្តីប្រតិបត្តិដើម្បីរំលត់ទុក្ខ ជារបស់ពិត ។

២-ព្រះវិសុទ្ធិគុណ គុណត្រង់ដែលព្រះអង្គបរិសុទ្ធស្អាត ត្មានកិលេសជាគ្រឿងមន្ទិលក្នុងព្រះទ័យ ចាត់ជាព្រះអរិយបុគ្គលជាន់ខ្ពស់បំផុត ដែលពួកសត្វគួរយកតម្រាប់តាមព្រះអង្គ ។

៣-ព្រះករុណាគុណ គុណត្រង់ដែលព្រះអង្គមានព្រះទ័យ មេត្តាករុណាចំពោះសព្វសត្វឥតរើសមុខ ។

មួយទៀតយើងខ្ញុំព្រះអង្គជាកងយោធពលទេមរៈភូមិន្ទ ជាន់ដឹងច្បាស់ថា ដែលព្រះអង្គជាន្រាស់ដឹងជាព្រះសម្ពុទ្ធនោះ ដោយអំណាចបុញ្ញាភិនិហារ ដែលព្រះអង្គខំប្រឹងកសាងបំពេញជារមីធម៌ មានទានជារមីជាដើម អស់បួនអសង្ខេយ្យនឹងមួយសែនកប្ប ដោយសេចក្តីព្យាយាមខ្ជាប់ខ្ជួន ទោះបីមានទុបសគ្គយ៉ាងណាក៏ព្រះអង្គហ៊ានពុះពារតស៊ូប្តូរយកសម្មាសម្ពោធិញាណ ទាល់តែជានសម្រេចដូចបំណង ។ ព្រះអង្គជានទទួលហានៈ

ដ៏ខ្ពង់ខ្ពស់បំផុត ត្រង់ដែលបានត្រាស់ជាព្រះសម្មាសម្ពុទ្ធប្រាកដក្នុងលោក ដោយអំណាចនៃគុណសេចក្តីព្យាយាមប្រឹងប្រែងអាចហ៊ានលះ ហ៊ានកាត់សេចក្តីសង្ស័យរួញរា ឥតខ្លាចខ្លឹយហត់ ឥតថ្នមព្រះកាយពលឥតតំអក់ធុញទ្រាន់ក្នុងការបំពេញការណ៍កិច្ចរបស់ព្រះអង្គឡើយ ។ ក្នុងកាលបច្ចុប្បន្នជាតិ ដែលព្រះអង្គសោយព្រះជាតិជាក្សត្រសម្បូណ៌ដោយព្រះពជ្រៈត្បូងគ្រប់យ៉ាង ក៏ព្រះអង្គហ៊ានលះបង់ដោយដៃស្រឡះ ចេញទៅទ្រង់ព្រះផ្នួស ខុកជាក់ទូរព្រះអង្គដូចជាមនុស្សធម្មតា ប្រព្រឹត្តខ្មក់កំរើយស្ទាំងស្គមព្រះកាយពល ដើម្បីប៉ុនប៉ងចំពោះសម្ពោធិញ្ញាណ-ការត្រាស់ដឹង-ទឹងបានសំដែងធម៌ទេសនាប្រោសសត្វ ដោះស្រាយបញ្ហាសេចក្តីខ្វក់ក្នុងវដ្តសង្សារ បម្ងឹងសត្វលោកឲ្យរួចចាកទុក្ខភ័យខាងមួង ដោយទ្រង់សំដែងធម៌តឲ្យលំហោតុផលក្នុងការប្រតិបត្តិដោយសេរីឥតបង្ខំ ខាងប្រយោជន៍បច្ចុប្បន្នទឹងបរលោកព្រមទាំងមគ្គផលព្រះនិព្វាន ក៏ព្រះអង្គលាតត្រដាងខ្លួនមកហើយ ។

យើងខ្ញុំព្រះអង្គដែលជាក្រុមយោធពលទេមរៈកូមិន្ទខាងឡាយ ដោយយល់ឃើញពិតប្រាកដនូវមហាគុណខាងនេះហើយ ទើបនាំគ្នាយកនូវទង់ជ័យនៃទេមរៈកូមិន្ទមកប្រជុំនៅទីនេះ ដើម្បីថ្វែងនូវសេចក្តីគោរពចំពោះព្រះអង្គ ដោយបន្ទឹកចាដ៏លាន់ឮខ្ទរខ្ទារយ៉ាងនេះ ។ យើងខ្ញុំព្រះអង្គក្រុមយោធពលទេមរៈកូមិន្ទ ដែលជាពុទ្ធបរិស័ទសូមនឹងខ្ញុំសូមយកម្ងាំងកាយកម្ងាំងវាចា ឧឡារកម្ងាំងចិត្ត នៃយើងខ្ញុំខាងឡាយចំពោះព្រះអង្គ ដើម្បីការពារ ដើម្បីលើកស្ទួយសាសនាព្រះអង្គដែលបានបំភ្លឺ

សត្វលោកឲ្យមានពន្ធឺក្ខឺស្ទាងចំនួន ៤៥០០ វស្សាមកហើយនោះ ឲ្យ
រឹងរិតតែមានពន្ធឺរស្មីចែងចាំងរីកធំទូលាយអស់កាលជាងច្ច ។

វត្តប្រតិបត្តិ ដែលយើងខ្ញុំព្រះអង្គជាក្រុមយោធពលខេមរៈកូមិន្ទបាន
ប្រព្រឹត្តរៀងរាបជរាបមកដល់ថ្ងៃនេះ គឺយើងខ្ញុំព្រះអង្គប្រព្រឹត្តតាមលំអាន
រ៉ែងយរបស់ព្រះអង្គ ដែលបានបញ្ញត្តិទុកមក តួយ៉ាងដូចជាការរស់នៅ
ដោយពួក ដោយក្រុមមិនឲ្យប្រឲ្យកប្រឲ្យំនឹងជនដទៃ នឹងមានកិច្ចធុរៈដែល
ត្រូវធ្វើទៅតាមជាន់តាមថ្នាក់ ត្រូវត្នានឹងពុទ្ធបញ្ញត្តិពុទ្ធានុញ្ញាតសម្រាប់ភិក្ខុ
សង្ឆនៅក្នុងអាវាស តួយ៉ាងដូចជាយើងខ្ញុំព្រះអង្គទទួលស្តាប់បង្គាប់នាយ
ចៅហ្វាយដោយស្មោះត្រង់ ត្រូវត្នានឹងព្រះរ៉ែងយរបស់ព្រះអង្គទ្រង់បញ្ញត្តិ
ឲ្យភិក្ខុតូចជាងឬមានវស្សាខ្ចីជាង ឲ្យគោរពដល់ភិក្ខុធំជាងឬមានវស្សាចាស់
ជាង ដូចជាការបញ្ញត្តិក្នុងផ្ទូវកាន់ឥរិយាបថទាំង ៤ គឺដេក ដើរ ឈរ អង្គុយ
ឲ្យមានរបៀបរៀបរយថ្ងូថ្ងូរសមរម្យនឹងក្នុកអ្នកដទៃ, ខន្តីធម៌ ដែល
ព្រះអង្គទ្រង់ត្រាស់សំដែងទុកមកហើយនោះ យើងខ្ញុំព្រះអង្គក៏ប្រព្រឹត្ត
ប្រតិបត្តិតាមឥតមានស្អៀង គឺយើងខ្ញុំព្រះអង្គរក្សាអំណត់អត់ធន់ ទ្រាំ
តស៊ូនឹងសេចក្តីនឿយព្រួយលំបាកត្រប់យ៉ាងឥតក្អូញត្រូរ ដរាបដល់បាន
ទទួលលទ្ធផលយ៉ាងជាក់ស្តែង ។ ការណ៍ទាំងនេះមកអំពីយើងខ្ញុំព្រះអង្គ
មានសទ្ធាជឿចំពោះព្រះពុទ្ធសាសនា ។

បពិត្រព្រះសក្យមុនីគោតម

អាស្រ័យហេតុដែលព្រះអង្គមានមហាឧបការគុណដ៏ធ្ងន់ ចំពោះ
ពុទបរិស័ទជូចថ្ងៃនមកនេះ ទើបយើងខ្ញុំព្រះអង្គធ្វើពិធីបុណ្យដ៏ឧឡារិកនេះ

ដើម្បីប្រកាសនូវកតញ្ញូកតវេទិតាធម៌ចំពោះព្រះអង្គ ។ ដោយអំ-
ណាចកុសលបុញ្ញរាស៊ីនេះ យើងខ្ញុំព្រះអង្គដែលជាក្រុមកងយោធពល
ខេមរៈភូមិន្ទ សូមតោរពសូមទនកាយថ្វាយបង្គំ សូមពរដឹស៊ក្តិសិទ្ធិអំពីព្រះ
អង្គ សូមឲ្យយើងខ្ញុំព្រះអង្គមានអំណាចតេជានុភាពឈ្នះមារសត្រូវទាំង
ឡាយគ្រប់យ៉ាង ជូចកាលដែលព្រះអង្គទ្រង់ឈ្នះនូវបច្ចាមិត្តទាំងឡាយ
មានមារ ព្រមទាំងពួកពលសេនានៃមារជាដើម ។

នៅក្នុងឧកាសពិធីបុណ្យ ២៥០០ ព្រះវស្សា ដឹមហស្ថារ្យទឡាវិក
អធិកអធមនេះ សូមពួកទេព្តាដែលមានវិទ្ធានុភាព នឹងសូមឲ្យវត្ថុស៊ក្តិ-
សិទ្ធិក្នុងសកលលោកជួយអភិបាលទ្រទ្រង់ព្រះករុណាជាម្ចាស់ជិវិតលើត្សូង
ទាំងពីរព្រះអង្គនឹងសម្តេចព្រះឧបយុវរាជ ជាព្រះបិតាឯករាជ្យ ដែលជា
ប្រមុខនៃពិធីបុណ្យដឹអស្ចារ្យនេះ សូមឲ្យព្រះករុណាទាំងពីរព្រះអង្គ នឹង
សម្តេចព្រះឧបយុវរាជជួបប្រសប់តែនឹងសុភមង្គលវិបុលសុខ គ្រប់ទិវារាត្រី
ដើម្បីនឹងបានទំនុកបម្រុងឧបត្ថម្ភព្រះពុទ្ធសាសនា ឲ្យមានពន្ធឹរស្ម៉ីជ្ជ្ជត
ជ្រាបផ្សាយទូទៅពេញទាំងសកលលោក នឹងដើម្បីជឹកនាំប្រជាជាតិខ្មែរនឹង
ប្រទេសខ្មែរ ឲ្យបានសម្ស្ថរសប្បាយថ្ពុំថ្ពើងរុងរឿងជូចសម័យអង្គរ ។

ម្យ៉ាងទៀត យើងខ្ញុំទាំងឡាយដែលជាក្រុមកងយោធពលខេមរៈ-
ភូមិន្ទ សូមបែងជូននូវកុសលផលបុណ្យនេះ ចំពោះដល់អស់លោកអ្នក
ដែលបានអញ្ជើញមកប្រជុំក្នុងមណ្ឌលបុណ្យនេះ សូមឲ្យបានសម្រេច
សេចក្តីសុខ-ចំរើន តាំងអំពីពេលនេះដរាបដល់ព្រះនិព្វានជាអវសាន ។

× × ×

លុះចប់សុទ្ធរកថាហើយ មានការធ្វើពិធីនមស្ការ រួចហើយសម្តេចព្រះសង្ឃនាយកគណៈធម្មយុត្តប្រទានសីល ៥ ជាទ្បាវែក ។

លំដាប់តមក, លោកវន្តមន្ត្រីទទឹងលោកតំណាងទត្តមសេនិយអគ្គសេនាធិការយោធា ថ្វាយតង្បើញពីរូបភៀទិមន្តសម្តេចព្រះសង្ឃនាយកពីរគណៈឲ្យស្វាធ្យាយទិភ្ជមន្តប្រុះទឹកលើធ្លីជ័យកន្លេមរៈកូមិន្ទ ដើម្បីឲ្យមានសុវត្ថិជ័យមង្គលសិរីសួស្តីត្រប់ហាំង ។

ម៉ោង ៩ មានធ្វើពិធីហែក្បួនធ្វើតាវកិច្ចនៃកន្លេយោធពលខេមរៈកូមិន្ទចំពោះព្រះបរមសារីរិកធាតុ ជាយ៉ាងទ្បាវែកដើម្បីបំពេញការណីយកិច្ចគោរពចំពោះបាវចនា: ជាតិ, សាសនា, មហាក្សត្រិយ៍ ។ យើងសង្កេតឃើញ ការហែក្បួនទេះចាប់ផ្តើមពីទិសខាងជើងមណ្ឌលបុណ្យទៅកាន់ទិសខាងក្បូង, កន្លែងជើងគោតមិនទាន់មកដល់ចំមុខបុស្បូរដែលតម្កល់ព្រះបរមសារីរិកធាតុផង ស្រាប់តែមានអាកាសយានខាងកន្លែងអាកាសហោះមកដល់មណ្ឌលបុណ្យមុន ។ អាកាសយាននោះហោះមកតាម ៣ សំដែងសេចក្តីគោរពព្រះបរមសារីរិកធាតុ ។

កន្លែងនោះ ការិយាល័យឡាយនៃនាយកាហានទីនាយកាហានវេង ថ្វាយកទៀនធូបភ្លើងមកបូជាព្រះបរមសារីរិកធាតុនមស្ការថ្វាយបង្គំដោយគោរព ។

លំដាប់តមក មានពិធីដាក់ថ្វាយត្រព្រះសង្ឃនៅមហាពេធ សម្រាប់ព្រះកុណាលាំងពីរព្រះអង្គ, សម្តេចព្រះឧបយុវរាជ, សម្តេចព្រះពោធគន្ធាវស្ថីសោភ័ណ ។

ក្នុងពេលនោះ, ណេកវដ្ឋម្ត្រីក្រសួងការពារប្រទេសនឹងឃោស-
នាការព្រមទាំងសមាជិកវដ្ឋាកិបាល, មេទាហាន, មេទាហានវង, នា
ម៉ឺនសព្វមុខមន្ត្រី បានអញ្ជើញទៅដាក់បាត្រផង ។ នៅជិតកន្ទែង
ដាក់បាត្ររបស់ព្រះករុណាទាំងពីរព្រះអង្ត មានកន្ទែងមួយទៀតសម្រាប់
ក្រុមសម្តេចព្រះរាជកនិដ្ឋារស្មីសោភ័ណដាក់បាត្រព្រះសង្ឆ មានក្រុម
ព្រះរាជវង្សានុវង្ស ភរិយានាម៉ឺនធំតូចជាដើម បានអញ្ជើញមករួបរួមក្នុង
ពិធីដាក់បាត្រនេះ ។

ទាងកើតមហារាង, មានពួកពុទ្ធបរិស័ទទាំងបុរសស្ត្រីជាច្រើនម៉ឺន
នាក់ឈរតម្រៀបជាជួរហែតាមបង្ហាដាក់បាត្រ ចាំដាក់បាត្រព្រះសង្ឆ
ដែលនិមន្តទាងមុខបង្ហា ។ ឥតមនុស្សអ្នកដាក់បាត្រនោះ មានចំនួន
ច្រើនហួសប្រមាណកកកុញមីដេរដាសពាសពេញដូចទឹកជំនន់ហៀបេញ
ពីស្ទឹងទន្ទេលចរាលត្រៀមក ។ ក្រឡេកទៅទឹកមុខបុរសស្ត្រីទាំងនោះ
ឃើញញញឹមញញែមដូចផ្កាកុឡាបរីកពេលព្រឹក, សឲ្យឃើញថាអ្នក
ទាំងនោះ មានចិត្តជ្រះថ្លាជាយ៉ាងក្រៃលែងចំពោះពិធីបុណ្យដាក់បាត្រ
ក្នុងពេលនោះ ។

ពេលរសៀល មោង ១៤: មានការប្រកួតប្រដែងរថយន្តមាលា
រិចិត្ររបនាតាមផ្លូវឿងពុទ្ធប្រវត្តិ ។ រថយន្តមាលាវិចិត្រចំនួន ៤៥
ត្រឿងប្រដាប់តុបតែងដោយបុប្ជាក្រងជាក្បាច់សិល្ប: ផ្សង ។ ស្ទឹករុក-
ជាតិពេនព័ទ្ធទៀវស្រងាត់ ប្រកបដោយសោភណភាពជាយ៉ាងក្រៃលែង
ព្រមទាំងតំនូវរូបភាពជាសត្ត មនុស្សប្រុសស្រី បព្វជិតឬត្រហស្ត, នៅ

ក្នុងក្រុបខ័ណ្ឌរឿងតាំងពីព្រះសម្មាសម្ពុទ្ធប្រសូតរហូតដល់ទ្រង់បរិនិព្វាន
របស់រដ្ឋសភា, ក្រុមប្រឹក្សាព្រះរាជអាណាចក្រ, ក្រសួងនានា, ពួក
ពាណិជ្ជ . . . . . ល . . . . . ។

គណៈកម្មការពិនិត្យការប្រឡងប្រជែងរថយន្តមាលាវិចិត្រ បាន
តាំងនៅខាងលិចធ្វើងខាងត្បូងនៃពន្ធាព្រះសង្ឃ ។ គណៈកម្មការនោះ
មានសមាសភាពដូច្នេះ

- ឯកឧត្តមញឹក-នូមហាមន្ត្រី ប្រធាន
- លោកមៅ-គាអុន នាយការិយាល័យក្រសួងធម្មការ សមាជិក
- „ ហ៉ន់-មោលីហ៉ន់ និម្មាបនិកក្រសួងសាធារណការ -"-
- ព្រះពោធិវ័ង្ស ហួត-តាត អ្នកសង្កេតការ
- លោកត្រូ បាឡាត់តន់ -"- ។

គណៈកម្មការសម្រាប់ឲ្យពិន្ទុ បានសម្រេចឲ្យពិន្ទុដល់រថយន្ត
មាលាវិចិត្រដូចខាងក្រោម:

លេ១-១ រថយន្តមាលាវិចិត្រ របស់ក្រុមកសិកម្មនៃក្រសួងសេដ្ឋកិច្ច
ជាតិ ដែលតែងត្រង់រឿងព្រះឥន្ទូនិមិត្តជាជូជកមកសុំព្រះនាងមត្រី ;

លេ១-២ បានដល់រថយន្តមាលាវិចិត្ររបស់ក្រសួងការងារ នឹងសង្គម-
កិច្ច ដែលតែងត្រង់រឿងរាជសីហ៍ ទ្ធាធំ ទ្ធាជំបងមករាំងផ្ទូវព្រះនាងមត្រី;

លេ១-៣ បានដល់រថយន្តមាលាវិចិត្រ របស់ក្រុមសុរិយោដី នឹង
កូមិបាលនៃក្រសួងសេដ្ឋកិច្ចជាតិ ដែលតែងត្រង់រឿងព្រះវេស្សន្តរទាញ
ធ្នូកំហែងជូជក ;

លេខ-៤ ជាន់ជល់រថយន្តមាលាវិចិត្រ របស់ក្រសួងសាធារណ-
សិក្សាធិការជាតិ ដែលតែងត្រង់រឿងព្រះសិទ្ធត្ថទតនិម្មិតទាំង ៤ យ៉ាង;

លេខ-៥ ជាន់ជល់រថយន្តមាលាវិចិត្រពីរគ្រឿង គឺ ១) រថយន្តមា-
លាវិចិត្រ របស់ក្រសួងសាធារណការ ដែលតែងត្រង់រឿងព្រះអង្គទ្រង់
ប្រសូត; ២)-រថយន្តមាលាវិចិត្ររបស់សាលាក្រុងភ្នំពេញ ដែលតែង
ត្រង់ព្រះអង្គទ្រង់កាត់ព្រះកេសា ។

ម៉ោង ១៥ មានពុទ្ធបរិស័ទជាតិរៀតណាម កាន់ព្រះពុទ្ធសាសនា
ទាងមហាយានចូលទៅសូត្រធមិថ្ថាយបង្គំ គោរពព្រះបរមសារីរិកធាតុ,
គណៈប្រតិភូចិនប្រជាមានិតជាន់ជូនចំពោះគណៈកម្មាធិការនាយក នៃពិធី
បុណ្យ ព.ស.២៥០០ នូវអំណោយ :

- ព្រះពុទ្ធរូបមួយអង្គ,

- ព្រះត្រៃបិដក ១៦ ក្សាល ដែលថាជាន់រៀបចំចំនួន ១០០០ ឆ្នាំ
មកហ៊ីយ,

- ថូផ្ការ៦,

- ទ្យែកុន ១៦ និយាយពីព្រះពុទ្ធសាសនានៅប្រទេសចិន ។

គណៈប្រតិភូចិនប្រជាមានិតជាន់បញ្ជាក់ថា ការជូននេះសុំឲ្យយកទៅ
ជំកល់ទុកនៅក្រសួងធម្មការ ទុកជាសម្បត្តិសាសនា ។

ក្នុងពេលនោះ គណៈកម្មាធិការនាយកមានបីតិជាមោជ្ជៈជាយ៉ាង
ក្រៃលែង, ជាន់ថ្ងៃងសេចក្តីអរគុណតបទៅគណៈប្រតិភូវិញ ។

ម៉ោង ១៥,៥០ ទាងផ្នែកបព្ចជិត សម្តេចព្រះមហាសុមេធាធិបតីសង្ឆ-

នាយកគណៈមហានិកាយ, ព្រះពោធិវង្ស ហួត-តាត ព្រះវិនយតន្ត អ៊ុំ
-ទួតជាដើម, ផ្នែកខាងគ្រហស្ថ លោកមៅ-ចយ, លោកគ្រឿង-កាង,
លោកអនុប្រធានពុទ្ធិកសមាគម, លោកប្រធានសមាគមគិលានសង្គ្រោះ
សម្រាប់ព្រះសង្ឃខ្មែរ, លោកប្រធានសមាគមមិត្តពុទ្ធិកវិទ្យាល័យ ជានាំ
គណៈប្រតិភូនានាប្រទេសចាំឯបព្វជិត - គ្រហស្ថទៅទស្សនាអគារតាំងតុ
ក្នុងមណ្ឌលបុណ្យតឹ

អគារសម្តែងសង្ឃនាយកគណៈមហានិកាយ មានតាំងធ្វើ
ជាក្តីតជ្ឈកូដជិតក្រុងពជ្រគិរីមានរូបទេវទត្តប្រមៀលថ្មពីលើខ្នងភ្នំមកចំព្រះ
ជាតព្រះបរមសម្ពុទ្ធជាម្ចាស់ ចេញឈាមបទ្ទិចបន្ទូច, រូបបេតវិស័យ, កុដិ
ព្រះជាតពិម្ពិសារ, សុបិនទិមិត្តព្រះនាងមហាមាយាទើរជាដំរីសបុះមកកាន់
ទន្តរជាដើម ។

អគារបាត់ជិបង រូបតំនូរព្រះអគ្គីប្រសូតជាដើម ។

អគារតាកែវ រូបតំនូរអគ្គីលិមាលដេញតាមក្រោយព្រះអង្គ,
ជំរីនាឡាគីរី, ព្រះអង្គប្រសូតជាដើម ។

អគារកំពត ព្រះពុទ្ធរូបព្រមគាំនាក្យស្មោកថា "សូមឲ្យព្រះ
ពុទ្ធសាសនាចម្រើន" ជាដើម ។

អគារស្វាយរៀង រូបតំនូរព្រះអង្គកាត់ព្រះកេសា ។

អគារសៀមរាប រូបតំនូរព្រះអង្គធ្វើទុក្កករកិរិយាមានព្រះរូបស្គម
កំព្រឹង ព្រះមាតាបុះពីស្ថានតុសិតមកដេញពិណថ្វាយជាដើម ។

អគារក្របេះ រូបគំនូរសម្តេចព្រះឧបយុវរាជ នឹងតាំងព្រះចន្ទូមកែវ ជាដើម ។

អគារពោធិសត្ត រូបគំនូរនាងកគី, រាគា, តណ្ហាប្រលោមលួង លោមព្រះអង្គ មុនព្រះអង្គនឹងបានត្រាស់សម្មាសម្ពោធិញាណជាដើម ។

អគារកំពង់ឆ្នាំង រូបគំនូរព្រះអង្គត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញាណជាដើម ។

អគារកំពង់ស្ពឺ រូបគំនូរព្រះអង្គសំដែងធម្មចក្រ, ព្រះអង្គអធិដ្ឋានកាជន៍មាសបោះទៅលើទ្សេទឹកស្ទឹងនេរញ្ជរា ។

-អគារកំពង់ធំ រូបគំនូរព្រះអង្គស្តេចយាងទៅប្រោសពុទ្ធបិតានឹងព្រះនាងពិម្ពាយសោធរាជាដើម, ។

-អគារព្រៃវែង: រូបគំនូរព្រះអង្គស្តេចយាងទៅប្រោសព្រះពុទ្ធមាតា នៅស្ថានត្រៃត្រឹង្ស ។

-អគារកណ្ណាល រូបគំនូរមុចូលិនូស្រះ, ព្រះពុទ្ធនិញានជាដើម ។

-អគារសម្ពេចសង្ឆនាយកគណៈធម្មយុត្ត រូបគំនូរព្រះសម្ពុទ្ធស្តេចយាងទៅប្រោសបញ្ចវគ្គីយកិត្ថុ, ព្រះពុទ្ធរូបលង្ហីនកំពស់ ៦ មែត្រព្រះកែន ១ មុ៨០ - ។

-អគារសមាគមមិត្តពុទ្ធកវិទ្យាល័យ រូបគំនូរកាលព្រះបាទអសោកទ្រង់ចាត់កិត្ថុទៅផ្សាយព្រះពុទ្ធសាសនានៅនានាប្រទេស, សម្ពេចព្រះឧបយុវរាជកាលទ្រង់ជាព្រះមហាក្សត្រិយនៅទ្យីយ ទ្រង់បានប្រគេន

ព្រហ្មទាននៅពុទ្ធិកវិទ្យាល័យព្រះសុវាម្រឹត, ភិក្ខុ ៤ អង្គ និមន្តទៅរៀន
នៅមហាវិទ្យាល័យនាលន្ទា, ព្រះអស្សិជតត្រូវជ្រាសព្រះមោគ្គល្ឆានទឹង
ព្រះសារីបុត្រ, នាងសុជាតាយកមធុបាយាសទៅថ្វាយព្រះអង្គជាដើម ។

-អគារពុទ្ធិកសមាគម រូបគំនូរព្រះសិទ្ធត្ថយាងទៅទ្រង់ព្រះផ្នួស
ជាដើម ។

-អគារសមាគមគិលានសង្ត្រោះព្រះសង្ឃខ្មែរ: រូបគំនូ
មន្ទីរព្យាបាលរោគព្រះសង្ឃព្រមទាំងសកម្មភាពនៃមន្ទីរពេទ្យនេះជាដើម។

-អគារព្រះសង្ឃមហាយាន រូបព្រះពោធិសត្វអវលោកិតេស្វរ:

-អគារក្រសួងសិក្សាធិការនឹងខ្មែរកម្ពុជាក្រោម: ពាក្យសុភា-
សិត, ពាក្យស្វាក, រូបគំនូរជាច្រើន, ព្រះពុទ្ធរូបត្រប់សម័យជាដើម ។

លុះចប់ការទស្សនាន្ទូវអគារទាំងឡាយនៃមណ្ឌលបុណ្យ គណ:
ប្រតិភូនានាប្រទេស ក៏បានអញ្ជើញមកថ្វាយបង្គំដោយគោរពចំពីមុ ១
ព្រះសក្យមុនីបេតិយ ។

ពេលយប់ មោ៉ង ១៩ មានការបូជាប្រទីបជ្វាលា, កាំជ្ជូចរន្ទា, ភ្ជ
ទៀនទឹងពិធីលឹកព្រះពុទ្ធអង្គកាលយាងចុះពីស្ថានត្រៃត្រឹង្ស ។

រួចព្រះថេរ:គណ:ធម្មយុត្ត ១ អង្គឲ្យស៊ីល ៥ ព្រះសង្ឃគណ:ធម្ម
យុត្ត ២៥០ អង្គចំរើនព្រះបរិត្ត ។

មោ៉ង ២២: ព្រះធម្មកថិកគណ:ធម្មយុត្ត ២ អង្គទេសនារឿងពុទ្ធ-
ប្រវត្ត ២ លើក, ក្នុង ១ លើកកន្ទះមោ៉ង:

– លើកទី ១ ព្រះបាទ្យាត់ធម្មវរោត្តម ទ្យេន-ពម វត្តស្វាយពាព សំដែងរឿងកបិលវត្ថុគមនបរិច្ចេទទី ១៨, ពិម្ពាកិលាបបរិច្ចេទទី ១៩ ។

– លើកទី ២ ព្រះមហាឃ្ឌន-សឿ វត្តប្រយូរវង្ស សំដែងរឿងសក្ស-បព្ទជ្ជាបរិច្ចេទទី ២០ មេត្តេយ្យបរិច្ចេទ ២១ ។

ក្នុងពេលនោះ មានការលឿងកោជនាហារនៅព្រះបរមរាជរាំងនឹងលេងល្ខោនព្រះរាជទ្រព្យជូនក្សៀវបរទេសមើលជាកិត្តិយស ។

ថ្ងៃទី ៦

គឺថ្ងៃសុក្រ ៤ រោច ខែវិសាខ ព.ស. ២៥០០

(១៣ ឧសភា ១៩៥៣)

ថ្ងៃនេះ ជាថ្ងៃរំលឹកជល់ព្រះពុទ្ធអង្គបរមគ្រូជាម្ចាស់ទ្រង់ចូលកាន់ព្រះបរិនិព្វាន ជាថ្ងៃដ៏មានជោគជ័យមង្គលដ៏ប្រសើរពន់ពេក ។

ពេលព្រឹក មោ៉ង ៧,៥៥, លោករដ្ឋមន្ត្រីក្រសួងសិក្សាធិការ, យុវកាពសង្គមនឹងការសំអាតទ្ធូទៅបានអញ្ជើញមកជល់ ។ ក្រុមទាហានទេមរៈកូមិន្ទូទាហានត្រៃ បានលើកអាវុធវន្ទានឹងបន្ទឹបទចរលីលាជូនជាកិត្តិយស, ចំណែកកូនសិស្សវិទ្យាល័យស៊ីសុវត្ថិ, ឥរុវិជ្ជា នឹងក្រុមកាយរឹទ្ធិ ទាំងប្រុសស្រី ព្រមទាំងឥស្សរជនទ្ទះដែលនៅទីនោះ ក៏បង្អោនកាយសំដែងនូវសេចក្តីគោរពចំពោះលោករដ្ឋមន្ត្រី ។

ក្រោយដែលបានទទួលកម្លងបុប្ផាព័ន្ធាងកញ្ចាម្ចាក់ លោកវដ្ដមន្ត្រីក៏បានយកកម្លងបុប្ផានោះទៅបូជាព្រះបរមសារីរិកធាតុ រួចអញ្ជើញទៅតាន់វេទិកាកិត្តិយស ធ្វើសេចក្តីថ្លែងការណ៍ជាបដិសណ្ឋារកិច្ច ចំពោះព្រះបរម-សារីរិកធាតុ ដូចខាងក្រោម:

សូមថ្វាយបង្គំព្រះសម្ពុទ្ធជាម្ចាស់

ក្នុងទិវាសពិធីបុណ្យរំលឹកពុទ្ធសករាជ ២៥០០ វិស្សានេះ យើងខ្ញុំព្រះអង្គខាំងខ្សាយ សូមបង្ហាញកាយវាចាចិត្តគោរពជាទុក្ខារកិច្ចចំពោះព្រះបរមសារីរិកធាតុនៃព្រះអង្គ ។

ពិធីបុណ្យដ៏ឧត្តុង្គឧត្តមនេះ យើងខ្ញុំព្រះអង្គធ្វើឡើងដោយការនឹកឃើញព្រះគុណសម្បត្តិ ៣ យ៉ាងរបស់ព្រះអង្គ ដែលផ្សាយគ្រប់ដណ្តប់ស្រោចស្រង់មកលើយើងខ្ញុំជាជាតិខ្មែរទាំងប្រទេស ។

ព្រះគុណសម្បត្តិ ៣ ប្រការនោះគឺ

១- ព្រះបញ្ញាគុណ គុណគ្រប់ដែលព្រះអង្គត្រាស់ដឹងនូវធម្មតិត ៤ ប្រការ មុនសាស្តាទាំងអស់កន្លងលោក ហើយប្រកាសប្រាប់សត្វឲ្យដឹងផង គឺព្រះអង្គត្រាស់ដឹងនូវ:

ក- ទុក្ខសច្ច សេចក្តីទុក្ខ ជារបស់ពិត,

ខ- សមុទយសច្ច ហេតុនាំឲ្យកើតទុក្ខ ជារបស់ពិត,

គ- និរោធសច្ច ការរំលត់ទុក្ខ ជារបស់ពិត,

ឃ- មគ្គសច្ច ផ្លូវនៃសេចក្តីប្រតិបត្តិដើម្បីរំលត់ទុក្ខ ជារបស់ពិត ។

๒- ព្រះវិសុទ្ធិគុណ គុណត្រង់ដែលព្រះអង្គបរិសុទ្ធស្អាតគ្មានកំលេសជាគ្រឿងមន្ទិលសៅហ្មងក្នុងព្រះទ័យ ជាត់ជាព្រះអរិយបុគ្គលជាន់ខ្ពស់បំផុត ដែលពួកសត្វគួរយកតម្រាប់តាមព្រះអង្គ ។

๓- ព្រះករុណាគុណ គុណត្រង់ដែលព្រះអង្គមានព្រះទ័យមេត្តាករុណាចំពោះសព្វសត្វឥតរើសមុខ ។ ដោយហេតុព្រះអង្គមានព្រះករុណាគុណនេះហើយ ទើបការលព្រះអង្គតន់ធរមាន៣ ទ្រង់សង្រះសង្រែងជ្រោសសត្វ ឥតគិតដល់ការលំបាកព្រះអង្គ ព្រមទាំងប្រតិស្ឋានសាសនាពុកមកដល់វេលានេះ ។ ម្យ៉ាងទៀត ដោយអំណាចរស្មីព្រះពុទ្ធបរមគ្រូព្រះពុទ្ធសាសនាបានមកស្ថិតនៅលើប្រទេសកម្ពុជា ហើយបានចំរើនរុងរឿងជាទីបំផុត ហើយដោយអំណាចព្រះពុទ្ធសាសនានេះ ពុទ្ធបរិស័ទជាតិខ្មែរបានទទួលការពេញដំនឹងនូវវិជ្ជាផ្លូវលោកនឹងផ្លូវធម៌ ព្រោះក្នុងវត្តអារាមនីមួយ ។ តាំងពីបុរាណកាលមក ព្រះសង្ឃជាអ្នកអប់រំបង្រៀនកុលបុត្រខ្មែរខ្លួនឯង មានព្រះពាជបុត្រព្រះមហាក្សត្រ នឹងក្រុមព្រះពាជវង្សានុវង្ស រហូតដល់កូនមន្ត្រីនឹងប្រជាសាមញ្ញ ។ នៅសម័យដែលក្រសួងសិក្សាជាតិមិនទាន់កែចំរើនធំ វត្តអារាមជាប្រភពនៃចំណេះវិជ្ជាគ្រប់ចំពូកមានវិជ្ជាខាងផ្លូវព្រះពុទ្ធសាសនា តំបន់ត្រៀនធម៌អាចតាមក្បួនព្រះពុទ្ធសាសនា នឹងវិជ្ជាខាងផ្លូវលោកគឺ

๑. ភាសានឹងអក្សរសាស្ត្រ,

๒. ពុទ្ធសាស្ត្រ,

៣- សិល្ស:,

៤- វិជ្ជាជីវ: ត្រប់ប្រភេទចាប់តាំងពីត្រឿងឈើ ត្រឿងដែក ចំឡាក់ តំនូរ ស្មិត ឆ្នុកឡើងទៅ ។

៥- ការអប់រំបណ្តាជនឲ្យចេះស្រឡាញ់រាប់អានគ្នា ឲ្យចេះរួបរួម ធ្វើឲ្យមានប្រយោជន៍ដល់សង្គមជាតិ ដូចជាការជីកអណ្តូង - ស្រះ សង់ស្ពាន-លើកថ្នល់ ។ល។ តឹវត្តអារាមនោះហើយដែលបណ្តាជនខ្មែរ តែងតែពឹងពាក់អាស្រ័យនៅត្រាក្សេមក្សាន្ត នឹងត្រាមានទុក្ខព្រួយ ។ មនុស្សគ្មានទីពឹង, មនុស្សជរាពិការ, អ្នកដំណើរគ្មានទីសំណាក់, អ្នក មានទុក្ខព្រួយតែងតែរត់ទៅជ្រកនឹងព្រះសង្ឆ ។ ហេតុនេះហើយបាន ជាព្រះសង្ឆក្នុងពុទ្ធសាសនាជាទីគោរពរបស់ប្រជាជនខ្មែរត្រប់រូប ។

សង្ខេបសេចក្តីទៅឃើញថា ព្រះសង្ឆមិនត្រាន់តែជាអ្នកដឹកនាំពុទ្ធ-បរិស័ទឲ្យដើរផ្ទូវទៅរកព្រះនិព្វានដែលជាឋានបរមសុខទេ តឹជាអ្នកដឹកនាំ សង្គមខ្មែរទៀតផង ។

ក្នុង គ.ស. ១៩៦៤ ពេលដែលក្រសួងសិក្សាធិការជាតិបានរីកធំឡើង ព្រះរាជរដ្ឋាភិបាលបានរៀបចំការសិក្សានៅតាមវត្តអារាមទាំងឡាយឲ្យមាន របៀបរៀបរយតាមសម័យនិយម ហើយសព្វថ្ងៃនេះ ព្រះសង្ឆក៏ នៅតែជួយ ឧបត្ថម្ភក្នុងការសិក្សាជាតិជានិច្ច តឹព្រះសង្ឆនេះហើយជាអ្នក សង់អគារសិក្សា ផ្តល់ត្រឿងសម្ភារ: ធ្វើជាគ្រូបង្រៀនដោយគ្មានតិត ដល់បៀវត្ស ។

បពិត្រព្រះសក្យមុនីគោតម

អាស្រ័យហេតុដែលព្រះអង្គមានព្រះមហាឧបការគុណដ៏ធ្ងន់ចំពោះពុទ្ធបរិស័ទ ទើបយើងខ្ញុំធ្វើនូវបុណ្យដ៏ទឡ្ហាកៃនេះ ដើម្បីសំដែងនូវកតញ្ញូកតវេទីភាពចំពោះព្រះអង្គ ។

ដោយអំណាចបុញ្ញកម្មនេះ សូមពួកទេវតាដែលមានវិញ្ញាណធាតុកាពនីធ សូមឱ្យវត្ថុស័ក្តិសិទ្ធិក្នុងសកលលោក ជួយគ្រប់គ្រងព្រះករុណាជាអម្ចាស់ជីវិតលើតួង ព្រមទាំងសម្តេចព្រះមហាក្សត្រិយានី ទឹងសម្តេចព្រះបយុវរាជ សូមគ្រប់ប្រកបដោយសេចក្តីសុខ-ចំរើនគ្រប់ប្រការ ហើយសូមជួយអភិបាលប្រជាជាតិខ្មែរនឹងប្រទេសខ្មែរឱ្យបានជួបប្រសប់នូវបុលសុខ ឱ្យបានថ្កើងរុងរឿង ជួចសម័យអង្គរកុំបីអាក់ខាន ។ មួយទៀត សូមជួយអភិបាលសម្រាលការគាន់តឹងក្នុងសកលលោកឱ្យបានធូរស្បើយ ចាប់តាំងពីពេលនេះតទៅ ។

×

× ×

លំដាប់តមក, មានពិធីសមាទានសីល ៥ ជាទឡ្ហាកៃដែលមានព្រះសង្ឃជាតំណាងមួយរូបជាអ្នកឱ្យសីល ។ ក្រោយពីនេះបន្តិចមក ក្រុមសិស្សវិទ្យាល័យព្រះស៊ីសុវត្ថិ, តាវ៉ៃជ្ញា នឹងអនុវិទ្យាល័យ ក្រុមកាយវិទ្ធិនពេត្តមប្រុសស្រី ក៏បានបង្ហើនកាយគោរពចំពោះព្រះបរមសារីរិកធាតុ ។

រួចទើបលោកវង្គមន្ត្រីបានអញ្ជើញទៅដាក់ជាត្រព្រះសង្ឃ ចំនួនជាង ៩,០០០ អង្គជាមួយនឹងពួកពុទ្ធបរិស័ទ ។

លំដាប់តមក មោង ៧,៥០ សម្តេចហ្ការាកំងវរៈវ្រៀងជ័យអធិបតី ស្រឹង្ការ ប៉ែន.ទុត បានអញ្ជើញមកដល់ ។ ដើម្បីដាក់បាត្រចំពោះ ព្រះសង្ឆ ១០០ អង្ត ក្នុងហានៈជាព្រះរាជតំណាងព្រះករុណា ទាំងពីរព្រះ អង្ត ។ សម្តេចហ្ការាកំងក៏បានអញ្ជើញទៅកាន់មហាវាង ព្រមទាំង សមាជិករដ្ឋាភិបាល, នាម៉ឺនធំតូច ។ នៅជិតនោះ ក្នុងមហាវាង សម្តេច ព្រះរាជកនិដ្ឋារស្មីសោភ័ណទ្រង់បានដាក់បាត្រព្រះសង្ឆ ១០០ អង្ត ព្រម ទាំងភរិយារដ្ឋមន្ត្រីនឹងនាម៉ឺនធំតូច ។

ពេលរសៀល មោង ១៥,៤០ មានក្រៀងប្រឹះ។ បង្អុរចុះតែត្រង់ មណ្ឌលបុណ្យ, ហើយមានអសនីធ្លាក់ចុះត្រង់ហោជាងទាងលិចនៃមហា វាង តែឥតធ្វើឲ្យមានគ្រោះថ្នាក់អ្វីទេ គ្រាន់តែឲ្យឃើញជាស្នាមឡៅនៅ កំពូលទាងលើនឹងជើងទាងគ្រោមនៃហោជាងប៉ុណ្ណោះ។ នេះជាការអស្ចារ្យ មួយយ៉ាងដែលនាំឲ្យអ្នកធងសំគាល់ថាជាសញ្ញាប្រសិទ្ធិពររបស់ទេវតា ។

មោង ១៦ លោករដ្ឋមន្ត្រីក្រសួងយុត្តិធម៌អញ្ជើញមកដល់ ។ ក្រោយ ដែលលោករដ្ឋមន្ត្រីយកកូងបុប្ជាទៅបូជាព្រះបរមសារីរិកធាតុ លោក រដ្ឋមន្ត្រីក៏បានអញ្ជើញទៅលើវេទិកាកិត្តិយស ដើម្បីនឹងឲ្យឧវាទចំពោះ មនុស្សទោសដែលនឹងដោះលែងក្នុងពេលនោះ ។ ឧវាទនោះមាន សេចក្តីដូចតទៅនេះ ៖

សូមពិតទូលព្រះមហាថេរានុត្តេរៈទាំងឡាយ មានសម្តេចព្រះសង្ឆ-នាយកទាំងពីរគណៈ ជាដើម !

សូមក្រាបបន្ទំទូលទ្រង់-សូមជំរាបឯកទត្តម ព្រមទាំងអស់លោកពុទ្ធ-
បរិស័ទទូទៅ !

ថ្ងៃនេះ ខ្ញុំព្រះករុណាទូលបន្ទំ ខ្ញុំ មានកិត្តិយសមកថ្វៃងសុនួរកថា
ក្នុងនាមរាជរដ្ឋាភិបាលនឹងក្នុងនាមខ្លួនខ្ញុំជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌ សូមទន
កាយគោរពបំពោះព្រះតម្ពែងសង្ឆព្រមទាំងសរសើរបំពោះទ្រង់ ឯកទត្តម
លោកស្រី ហើយនឹងអស់លោកអ្នកពុទ្ធបរិស័ទទាំងឡាយ ដែលមាន
រាសនាល្អកើតទាន់ពេលធ្វើបុណ្យ ព.ស. ២.៥០០ រស្សា ក្នុងរដ្ឋកាលនៃ
ព្រះករុណាជាអម្ចាស់ជីវិតលើតួន និងសម្តេចព្រះមហាក្សត្រីយានី ដែល
ទ្រង់ប្រកបដោយទសពិធរាជធម៌ ទ្រង់ប្រោសព្រះរាជទានឲ្យលើកលែង
ទោសខ្ទះ ឲ្យបន្ទយទោសខ្ទះជល់មនុស្សទាំងឡាយ ដែលកំពុងទទួល
ទោសក្នុងព្រះរាជអាណាចក្រនៅពេលធ្វើបុណ្យ ព.ស.២៥០០ រស្សានេះ

ទោសដែលលើកលែងមានពីរយ៉ាង ៖

១- លើកលែងទោសជាអាជ្ញា,

២- លើកលែងទោសខាងបទល្មើស ។

លើកលែងទោសជាអាជ្ញា គឺបំពោះជនជាប់ទោសដែលបាន
ប្រព្រឹត្តបទល្មើសនោះមុនថ្ងៃ ១ ទសភា ១៩៥៧ ជាទោសពិន័យទោសតុក
ឬទោសត្រាន់តែពិន័យ ឬត្រាន់តែដាក់គុក ក្នុងបទល្មើស លហុ ឬបទ
មជ្ឈិមក្តី មានសាលក្រមសំរេចជាដាច់ស្រេច ដំរូវឲ្យបង់ឲ្យទទួលរងទោស
ឬបង្អង់មិនទាន់ឲ្យសំរេចទោសក្តី ទោសទាំងនេះ នឹងលើកលែងឲ្យរួច
ខ្លួនតាមមាត្រាដូចមានរាយក្នុងព្រះរាជក្រមនេះស្រាប់ ។

លើកលែងទោសបទល្មើស គឺបទល្មើសជាលហុ និងបទ
ល្មើស ជាមជ្ឈិម ដែលបានប្រព្រឹត្តមកពីថ្ងៃ ១ ឯសភា ១៩៥៧ ហើយ
អ្នកប្រព្រឹត្តបទល្មើស ត្រូវជាប់នៅក្នុងការអង្គតស៊ើបស្បូវ ឬនឹងត្រូវជំនុំជំរះ
កាត់សេចក្ត៖ ។ បទល្មើសទាំងនេះ និងត្រូវលុបលាងតែក្នុងល័ក្ខខ័ណ្ឌ
ដែលបានទាក់ទងទៅនឹងអំពើទាំងឡាយ ដែលបានប្រព្រឹត្តមុនថ្ងៃដែល
ព្រះករុណា ទ្រង់ព្រះមេត្តាប្រោសឡាយព្រះហស្តលេខា ប្រកាសឲ្យប្រើ
ព្រះរាជក្រមនេះ ។ មានបទល្មើសជាលហុ និងបទល្មើសជាមជ្ឈិម
ដែលមានបញ្ញត្តិតាមមាត្រានៃក្រមព្រហ្មទណ្ឌ និងក្រុមតុលាការសឹក បទ
ល្មើសលហុនឹងមជ្ឈិមដែលចូលក្នុងរឿងតយនឹងផ្លាការ បទល្មើសពីរឿង
ប្ពូរប្រាក់ បទបញ្ញត្តិពីសេដ្ឋកិច្ច បទបញ្ញត្តិពីឲ្យឈ្នួលផ្ទះបុដីនឹងកំ
ណែន បទបញ្ញត្តិអំពីរបរបាញ់ អំពីរព្រៃឈើ និងនេសាទ ចរាចរតាម
ផ្លូវថ្នល់រថភ្លើង អំពីអាកៀននឹងជាតិពុល ។

ចំណែកមនុស្សទោសឯណា ដែលមានសាលក្រមកាត់ទោស
ចំពោះបទល្មើស ដែលពុំមានចង្អុលក្នុងមាត្រានៃព្រះរាជក្រមនេះទេ
ហើយត្រូវទទួលនៅឡើយ ត្រូវបានទទួលផលតាមល័ក្ខខ័ណ្ឌ ដូចមាន
បញ្ញត្តិក្នុងព្រះរាជក្រមនេះស្រាប់ ។

បើត្រូវទោសទក្រឹដ្ឋថ្នាក់ទី ៣ (ប្រហារជីវិត) ត្រូវបន្ធយឲ្យមកជា
ទោសទក្រឹដ្ឋថ្នាក់ទី ៦ គឺទោសគុកឲ្យធ្វើការជាទម្ងន់អស់មួយជីវិតវិញ ។

បើត្រូវទោសទក្រិដ្ឋថ្នាក់ទី ៦ (ទោសគុកឲ្យធ្វើការជាទម្ងន់អស់
មួយជីវិត) ត្រូវបន្ធយមកត្រឹមទោសទក្រឹដ្ឋថ្នាក់ទី ១ វិញ គឺទោសគុកឲ្យ

ធ្វើការជាទម្ងន់កំណត់ ៤០ ឆ្នាំ ។

បើត្រូវទោសទក្រិដ្ឋថ្នាក់ទី ១ គឺទោសគុកបង្ខំឲ្យធ្វើការជាទម្ងន់មានកំណត់ ហើយបើពុំបានសំរេចញ្ជូរទោសទេ ត្រូវបន្ថយមកត្រឹម ១ កាត ៤ នៃកំណត់ពេលដែលនៅសល់កំពុងរងទុក្ខ ។

នែ! អ្នកទាំងឡាយ ដែលមានវាសនាត្រូវបានរួចទោសក្តី ត្រូវបានបន្ធូរបន្ថយទោសក្តី ចូលមានចិត្តស្វាមីភក្តីចំពោះព្រះនរបតីនៃយើងតទៅកុំបីភ្លេចឡើយ ។

ខ្ញុំសុំរំឭកមួយយ៉ាងទៀត សុំឲ្យអ្នកទាំងឡាយចាប់តាំងពីថ្ងៃបានរួចខ្លួនជាជនសាម៉ញ្ញតទៅ ខំតាំងចិត្តប្រកបការចិញ្ចឹមជីវិតដោយសុចរិត ត្រូវប្រកាន់ឲ្យខ្ជាប់នូវសេចក្តីថ្ងៃថ្នូរ មានការប្រស្រ៍យគ្នាជាដើម ហើយខំយកចិត្តទុកដាក់ប្រឹងប្រែង កុំខ្ជាចនឿយហត់ក្នុងការចិញ្ចឹមជីវិត ដើម្បីលើកហានៈឲ្យសមជាពលរដ្ឋប្រទេសកម្ពុជាឯករាជ្យ ត្រូវបំភ្លេចចោលនូវគំនិតណាដែលនាំឲ្យថោកថយដល់ជាតិ មានការប្រព្រឹត្តិអំពើល្មើសដែលទើបនឹងមានព្រះរាជក្រមលើកលែងមកនេះ ជាទទាហរណ៍ស្រាប់ ។

កាលបើអ្នកទាំងឡាយបានទៅកាន់ទីលំនៅដួបជុំនឹងគ្រួសារហើយ ចូរកុំភ្លេចនូវការណីយកិច្ចរបស់ខ្លួន ដែលជាពលរដ្ឋសំរាប់ប្រទេសឯករាជ្យ ដែលបានមកដោយថ្ងីព្រះហស្តនៃព្រះបាទសម្តេចសហជីវិន ព្រះបិតាឯករាជ្យនៃយើង ។

សារុបសេចក្តីយ៉ាងខ្ងី គឺត្រូវតាំងចិត្តឲ្យមុតមាំបំរើព្រះមហាក្សត្រ

នឹងមាតុប្រទេស ដោយស្មោះស្ម័ត្រហើយសុំឲ្យប្រព្រឹត្តតាមព្រះពុទ្ធឧវាទ ដូចតទៅ ៖

១- កុំធ្វើអំពើបាប

២- ឲ្យធ្វើតែអំពើល្អ

៣- ត្រូវញ្ចាំងចិត្តខ្ជួនឲ្យសុចរិត ។

បពិត្រព្រះគម្ពែងសង្ស, ទ្រង់, លោកស្រី, អស់លោកពុទ្ធបរិស័ទ ទាំងឡាយ មុននឹងបញ្ចប់នូវសុន្ទរកថានេះ ខ្ញុំព្រះករុណាទូលបង្គំ ខ្ញុំ សូម ឧនកាយគោរព ចំពោះគុណព្រះរតនត្រ័យ ដោយតេជានុភាពនៃបុញ្ញវាសី ដែលអស់លោកបាននិមន្ត យាង អញ្ជើញមកធ្វើបុណ្យ ព.ស. ២៥០០ វស្សានេះ សូមឲ្យបានប្រកបនូវសេចក្តីសុខចំរើនគ្រប់ប្រការ សូម ឲ្យព្រះពុទ្ធសាសនាបានរុងរឿងជាដរាបតទៅ ។

×

+ +

ម្រោង ១៦, ៣៥ នាទី, សម្តេចព្រះទបយុវរាជ ទ្រង់ស្តេចយាងមក ដល់ព្រមទាំងសម្តេចហ្ចើរាំងវរៈរៀងជ័យអធិបតីស្រឹង្គា ប៉ែន-នុត, ឯក ឧត្តមប្រាក់ប្រាព្រឿងសមាជិកឧត្តមប្រឹក្សាព្រះរាជា លោកវរសេនីយ៍ ទោ មាស-ហ៊ុល ជាព្រះរាជបរិពារបានហែហមព្រះអង្គមកផង ។

ក្នុងពេលនោះ មាននាងកញ្ញាម្នាក់ស្ងៀកសំពត់ផាមួងបៃតងមានរូប កាយល្អធើត មុខស្រស់ញញឹមប្រិមប្រីយ បានយកកួងបុប្ផាទៅថ្វាយ សម្តេចព្រះមិតាឯករាជ្យ, ព្រះអង្គទ្រង់ទទួលយកកួងបុបានោះទៅបូជា

ចំពោះព្រះបរមសារីរិកធាតុ; រួចទ្រង់ស្តេចយាងទៅកាន់រៀងកាកិត្តិយស ដើម្បីប្រទានឧវាទដល់ពួកមនុស្សទោសដែលនឹងត្រូវដោះលែងខាងមុខ នេះថា:

"កូនចៅទាំងអស់គ្នាដែលរួចចាក់ការឃុំឃាំង ក្នុងឧកាសពិធីបុណ្យ ព.ស ២៥០០ នេះ ដោយសារសេចក្តីប្រោសប្រណីនៃព្រះមហាក្សត្រិយ៍ទាំងពីរ ជាព្រះវរបិតាមាតារបស់អ្នក ហេតុនេះ ត្រូវឲ្យអ្នកទាំងអស់គ្នាភ្ជាក់រលឹក ហើយចាំជាក់តាំងពីថ្ងៃនេះទៅ:

"បើយើងធ្វើអាក្រក់ យើងត្រូវទទួលផលអាក្រក់វិញ បើយើងធ្វើល្អ យើងត្រូវទទួលផលល្អវិញ ក្នុងកាលជាអនាគតមិនខាន" ។

សម្តេចមានព្រះបន្ទូលតទៅទៀតថា:

"នេះគឺជាឧកាសតែមួយហើយជាសម័យដ៏ប្រសើរចំពោះអ្នកដែលបានរស់នៅមកដល់ពាក់កណ្តាលព្រះពុទ្ធសាសនា ។ អ្នកត្រូវប្រែកិរិយាមារយាទ ឲ្យទៅជាអ្នកសប្បុរស រួបរួមធ្វើការក្នុងសង្គមជាតិ ប្រព្រឹត្តប្រតិ-បត្តិតាមធម៌ព្រះបរមសម្មាសម្ពុទ្ធជាម្ចាស់ ដើម្បីនឹងតាំងខ្ជួនជាពលរដ្ឋមួយសមទៅតាមប្រទេសឯករាជ្យ ព្រមទាំងនិយមកាន់ព្រះពុទ្ធសាសនា" ។

លុះចប់ព្រះរាជសង្គថានៃសម្តេចព្រះឧបយុវរាជ សំឡេងទះដៃទទួលអំណរក៏លាន់ឮបេញពីប្រជុំជនយ៉ាងគឹកកងរំពង ។ តមក គេក៏ចាត់ឲ្យលែងមនុស្សទោសទាំងបុរសស្ត្រី ដែលមកអង្គុយត្រៀបត្រាខាងមុខមហារោង, នឹងរៀងកាកិត្តិយស ។ ពួកមនុស្សទោសថ្វាយបង្គំសម្តេចព្រះបិតាឯករាជ្យដោយគោរព ហើយក៏ដើរទៅតាមលំដាប់គ្នាមុនក្រោយ

ដោយមានចិត្តសោមនស្សវិតក្កប្បមាអំពីការណ៍ដែលខ្ញុំបានរួចផុតការ
ឃុំឃាំង ដូចបក្សាជាប់ទ្រុងដែលគេលែងចេញពីទ្រុងហើរសប្បាយទៅ
លើនភាល័យដូច្នោះ ។ ពួកមនុស្សទោស ដែលរួចអំពីឃុំឃាំងទាំងនោះ
បានប្រសិទ្ធពរជោគជ័យមង្គលសិរីសួស្តីថ្វាយសម្តេចព្រះនរោត្តម សូម
ឲ្យទ្រង់ប្រកបដោយអាយុវណ្ណៈសុខៈពលៈ, បដិភាណ ជានិច្ចនិរន្តរ៍តរៀងទៅ
កុំបីឃ្លៀងឃ្លាតឡើយ ។

លំដាប់តមក, មានការសមាទានសីល ៥ ជាទម្លាប់ ។

ម៉ោង ១៧,៤០ មានពិធីទូលព្រះត្រៃយបិដក ៨ ចប់ ចំពោះវត្ត
នៅប្រទេសថៃរដែលបានទៅជួយទូបតម្ពមកនិពន្ធដ្ឋសង្គាយនាកាលពីឆ្នាំ
១៩៥៤ ដោយលោករដ្ឋមន្ត្រីក្រសួងធម្មការប្រទេសកូមាប្រគេនផ្ទាល់ដៃ
លោក, ទីឯសញ្ញាប័ត្រ "អ្នកពិធជិមបារដ្ឋិគ្រូ" ដែលរដ្ឋាភិបាលកូមា
បានទាំយកមកប្រគេនសម្តេចព្រះមហាសុមេធាធិបតី ជ្លួង-ណាត ជោត-
ញ្ញាណ សង្ឃនាយកគណៈមហានិកាយប្រទេសកម្ពុជា ។

តំបូងឯកឧត្តម អ៊ូ-ចាក-ស រដ្ឋមន្ត្រីក្រសួងធម្មការ បានថ្លែងសុន្ទរ-
កថាមួយជាភាសាកូមា, លោកភាង-សឿង លេខាធិការក្រុមពុទ្ធ-
សាសនបណ្ឌិត្យជាអ្នកប្រែមកជាភាសាខ្មែរ មានសេចក្តីដូចតទៅនេះ៖

ចិរំ តិដ្ឋតុ សទ្ធម្មោ

"សូមឲ្យព្រះសទ្ធម្ម ឋិតនៅអស់កាលជាយូរអង្វែង" ។

ខ្ញុំព្រះករុណា ជាតំណាងរដ្ឋាភិបាលសហភាពកូមា សូមថ្លែងដោយ

សេចក្តីគោរពចំពោះព្រះថេរានុត្ថេរៈគាំងឡាយ មានសម្តេចព្រះមហាសុ-
មេធាធិបតី សង្ឃនាយកនៃព្រះពុទ្ធសាសនាចក្រកម្ពុជាជាប្រធាន
សូមមានជ័យ ។

ខ្ញុំព្រះករុណា មានសេចក្តីត្រេកអរដ៏ក្រៃលែង ដោយបានមកថ្វាយ
បង្គំព្រះថេរានុត្ថេរៈគាំងឡាយ នៃប្រទេសកម្ពុជា មានសម្តេចព្រះសុមេ-
ធាធិបតីជាប្រធាន តាមលំអានព្រះពុទ្ធដីកាដែលព្រះបរមគ្រូសម្មាសម្ពុទ្ធ
បានត្រាស់សំដែងទុកមកថា " សមណានញ្ច ឧស្សុំ " ។

វេលានេះ ពិធីបុណ្យដែលបានផ្តើមឡើងកន្លងទីនេះឲ្យឈ្មោះថាការ
ប្រគេនសញ្ញាប័ត្របេះរដ្ឋាភិបាលសហគាមភូមា ។

ឯការប្រគេនសញ្ញាប័ត្រក្នុងវេលានេះ មិនមែនធ្លាប់ឡើងតាមប្រវេ-
ណីទេ បើពិនិត្យតាមប្បាប់ព្រះពុទ្ធសាសនា ជាការធ្លាប់មានមកប្រមាណ
២.៥០០ ព្រះវស្សានៃព្រះពុទ្ធសកពជកន្ធឆមកហើយ ។ រីឯការប្រគេន
សញ្ញាប័ត្រនេះ មិនមែនចេះតែប្រគេនចំពោះសាមញ្ញបុគ្គលនោះទេ គឺ
ប្រគេនចំពោះតែបុគ្គលដែលមានគុណសម្បត្តិដ៏ពិសេស ។

បណ្តាអរិយសង្ឃក្នុងព្រះពុទ្ធសាសនា ដែលបានប្រកបដោយ
គុណគាំងឡាយ មានសីលគុណ សមាធិគុណ បញ្ញាគុណ ទីឆ៍សិក្ខា-
កាមគុណជាដើម ព្រះបរមគ្រូសម្មាសម្ពុទ្ធគួព្រះអង្គឯង បានទទួលនាម
ថាជាឯតទគ្គបុគ្គល ក្នុងចំណោមបរិស័ទគាំង ៤ ។

ព្រះមានព្រះភាគគួព្រះអង្គឯង បានលើកតម្កើងសរសើរឲ្យព្រះនាម
ព្រះសារីបុត្តត្ថេរ ដែលមានប្រាជ្ញាឈ្វាស់វៃជាងគេថា ជាឯតទគ្គបុគ្គល

ជាពិសេសខាងបញ្ញា,បានលើកតម្កើងសរសើរឲ្យព្រះនាម ព្រះមហាមោគ្គល្លានត្ថេរដែលមានតេជៈ មានឥទ្ធានុភាពពូកែជាងគេថាជាឯតទគ្គបុគ្គលជាពិសេសខាងតេជៈទិព្វឥទ្ធានុភាព, បានលើកតម្កើងសរសើរឲ្យព្រះនាមព្រះពហុល ដែលប្រកបដោយសទ្ធាកាម ថាជាឯតទគ្គបុគ្គលខាងសទ្ធាកាម ។

ដោយហេតុតែព្រះបរមគ្រូរបស់យើងខ្ញុំបាទតែបានធ្វើតាំងពីដើមមកដូច្នេះ បានជាព្រះមហាក្សត្រនៃប្រទេសកម្ពុជាលំដាប់តរៀងមក បានសព្វព្រះពុទ្ធហឫទ័យក្នុងការប្រគេនសញ្ញាប័ត្រ ចំពោះព្រះសង្ឃជាមហាថេរដ៏ពិសេសតាំងពីបុរាណមកម្ល៉ះ តាំងដល់ឆ្នាំរសញ្ញាប័ត្រ សង្ឃនាយកសញ្ញាប័ត្រ ពុទ្ធសញ្ញាបត្រជាដើម ។

ដោយហេតុ តែព្រះមហាក្សត្រនៃប្រទេសកម្ពុជាបានធ្វើមកតាំងពីដើមរៀងមកដូច្នេះហើយ បានជារដ្ឋាភិបាលសហការកម្ពុជា មានសេចក្តីពេញចិត្តរក្សាទុកនូវទំនៀមទំលាប់នេះមិនឲ្យដាច់ ក៏មានការធ្វើពិធីប្រគេនសញ្ញាប័ត្រ អ្នគ្គមហាបណ្ឌិត្យ ទិន្នសញ្ញាប័ត្រ អភិធជមហារដ្ឋគុរុ ចំពោះព្រះមហាថេរ ដែលប្រកបដោយគុណសម្បត្តិដ៏ប្រសើរជារឿយ ។ មកដែរ ។

រីឯកន្លែង ដោតញ្ញាណ សម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយ ដែលគង់នៅវត្ត ណាគោមក្រុងភ្នំពេញប្រទេសកម្ពុជានេះ ព្រះអង្គជាមហាថេរមួយព្រះអង្គជាសីលវន្ត- សទ្ធាកាម

ធំដ៏បវរយត្តិ វិសារទបុគ្គល ។ ម្យ៉ាងទៀត កិត្តិសព្ទរបស់ព្រះអង្គអាច
ពាប់បញ្ចូលកងប្រវត្តិសាស្ត្រសកលលោក ធំដ៏ប្រវត្តិសាស្ត្រខាងសាសនា
ជាន ដោយសម្តេចបានចំពេញកិច្ចជួយទប្តម្ភធជ្ជសង្គាយនា គ្រប់
ពេលសន្និបាតទាំង ៥ គ្រា មិនត្រឹមតែប៉ុណ្ណោះ សម្តេចបានទិមន្តភៀវគាន់
សហភាពភូមាដោយព្រះអង្គឯងទៀត ដើម្បីធ្វើជាប្រធាននៃតតិយសន្និ-
បាតដែលមាននាមថា កម្ពុជា-លវសន្និបាត ប្រៀបដូចជាព្រះមហា-
កស្សបត្ថេរដែលធ្វើជាប្រធាននៃបឋមសង្គាយនា ។ ដើម្បីនឹងតបស្នង
ព្រះគុណចំពោះសម្តេច, រដ្ឋាភិបាលសហភាពភូមា បានមូលមតិគ្នា
ប្រគេនឋានន្តរៈសម្តេចជា អ្គ្គមហាឧបដ្ឋាយក ដែលជាឋានន្តរដ៏
ខ្ពង់ខ្ពស់បំផុតក្នុងសហភាពភូមា ធំដ៏ប្រគេនសញ្ញាប័ត្រជ័យប្រសើរជា
សាសនធ្វជ ចំពោះព្រះសង្ឃជាមេគណៈប្រតិភូ ធំដ៏ព្រះសង្ឃជាសន្តិ-
តិការតិខ្មែរទាំងឡាយ ដែលបានទិមន្តភៀវគាន់ទីប្រជុំក្នុងមហាបាសា-
ណគុហា នៃឆដ្ឋសង្គាយនា ។

ព្រះសង្ឃដែលបានទិមន្តភៀវគាន់ទីប្រជុំនោះ មានច្រើនរូបណាស់ ។
ដើម្បីឲ្យងាយស្រួលដល់ការប្រើប្រាស់តភៀ សមាគមសហភាពភូមា សូម
ប្រគេនគ្រប់វត្តទាំង ៨ នូវបិដកមួយចប់មួយវត្ត ទុកជាធម្មបណ្ណាការ ។

នៅទីបំផុត ខ្ញុំព្រះករុណាជាតំណាងនៃរដ្ឋាភិបាលសហភាពភូមា
សូមបួងសួងឲ្យប្រជាជនខ្មែរ-ភូមាទាំងពីរប្រទេស បានសម្រេចនូវព្រះ
និព្វានសម្បត្តិគ្រប់ៗគ្នា ដោយអានុភាពនៃកុសលដែលបានប្រគេនសញ្ញា-
ប័ត្រធំធ្ងន់នេះ ។

បន្ទាប់មក មានការប្រគេនសៀវភៅព្រះត្រៃបិដកអក្សរកូមាចំពោះ
ព្រះសង្ឃប្រចេសខ្មែ ៩ វត្ត ក្នុងមួយវត្តមួយចប់ ដូចតទៅ:

១	វត្តនិភេធ (កណ្តាល)	១ចប់
២	„ ទេពធិតាភម (កំពង់ឆ្នាំង)	„
៣	„ កែវព្រះភ្លើង (កំពត)	„
៤	„ មហាមន្ត្រី (កំពត)	„
៥	„ លង្កា (កំពត)	„
៦	„ បទុមវតី (កំពត)	„
៧	„ សាកម៉ែនតេជោ (កំពត)	„
៨	„ ជោតនាភម (កំពត	„

បូកសរុបសៀវភៅទាំងអស់ ២៧៧ ក្បាល ។

រួចលោកប្រធានពុទ្ធសាសនសិក្សាកូមាថ្លែងរៀបរាប់អំពីដីវប្រវត្តិ
របស់សម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយក គណៈមហានិកាយ
ជាភាសាកូមា, លោកញូង-សឿង ជាអ្នកសូត្រជាភាសាខ្មែរ ដែលខ្ញុំនឹង
ចុះផ្សាយនៅខាងក្រោមនេះ ;-

សម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយក គណៈមហានិកាយ
ព្រះនាម ជួង-ណាត (ជោតញ្ញាណោ) ប្រសូតនៅថ្ងៃអង្គារ ១១ កេច
ខែផល្គុន ឆ្នាំវកធស័ក ព. ស. ២៤២៦ គ. ស. ១៨៨៣ នៅភូមិកំរៀង
ឃុំតាគោះ ស្រុកគងពិសី ខែត្រកំពង់ស្ពឺ បិតានាម ជួន មាតានាម យក់ ។

កាលដែលនៅជាកុមារ ចូលសិក្សាអក្សរសាស្ត្រ ហើយបួសជាសាមណេរ នៅវត្តពោធិព្រឹក្ស (ហៅវត្តពោលរំ) ឃុំរលាំងកែន ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។ ព.ស.២៤៦២ គ.ស.១៨៩៩ ជន្មាយុ ១៦ ឆ្នាំ សាមណេរ ជួន-ណាត ចូលមករៀនសូត្រព្រះបរិយត្តិធម៌ នៅវត្តទុណ្ណាលោម ក្រុងកំពង់ត្រាញ; ជន្មាយុគំរប់ ២១ ឆ្នាំ សូមឧបសម្បទាជាភិក្ខុការៈ នៅវត្តពោធិព្រឹក្ស មានទាមនាយាជា ជោតញ្ញាណោ ហើយត្រឡប់មកនៅវត្តទុណ្ណាលោមវិញ ។ ព.ស.២៤៥៦ គ.ស.១៩១៣ ភិក្ខុជោតញ្ញាណោ ចូលជេញប្រយោគក្នុងព្រះរាជាសថវតនារាម (ហៅព្រះវែកមកិត) ក្រុងកំពង់ត្រាញ ចូលប្រយោគ ៤ ។ គ.ស.១៩១៥ ភិក្ខុជោតញ្ញាណោ ចូលប្រឡងជាប់ខ្ពស់លនាទីជាសាស្ត្រាចារ្យសាលាចូលីជាន់ខ្ពស់ ។ ព.ស.២៤៦៩-២៤៦១, គ.ស.១៩២៦ ១៩២៣ ចូលទៅបំពេញវិជ្ជាការសិក្សាទឹងអក្សរឋ្មបុរាណជាដើម នៅក្រុងហាណូយ ។ គ.ស.១៩៣០ ចូលឡើងជាចាងហ្វាងរងសាលាចូលីជាន់ខ្ពស់ ។ គ.ស.១៩៤២ ចូលឡើងជាចាងហ្វាងសាលាចូលីជាន់ខ្ពស់ ។ គ.ស.១៩៤៣ ចូលឡើងជាចៅអធិការវត្តទុណ្ណាលោម ។ គ.ស.១៩៤៤ ចូលទទួលនាទីជាអធិបតីចៅសភា ។ គ.ស.១៩៤៧ ចូលធ្វើជាអនុប្រធានគណៈកម្មការវិបស្សនាធម៌ ។

សម្តេចចូលទទួលសមណសក្តិតាមលំដាប់ គឺជាគ្រូចូលាត់សាក្យបុត្តិយ៍ គ.ស.១៩១០, ជាព្រះគ្រូសង្ឃសត្តា គ.ស.១៩១២, ជាព្រះ

សាសនាសោភ័ណ គ.ស.១៩៣១ ជាព្រះពុទ្ធឃោសាចារ្យ គ.ស.១៩៤០, ជាព្រះគោធិវង្ស គ.ស. ១៩៤៤, ហើយបានឡើងសមណស័ក្តិជាខ្ពស់បំផុត ជា ព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយ គ.ស.១៩៤៨, លុះមកដល់ថ្ងៃទី១៨ មេសា ១៩៥០ ព្រះករុណាជាម្ចាស់ជីវិតទ្រង់ព្រះបរមរាជានុសមណស័ក្តិ ឲ្យបានឡើងជា សម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយ ។

សម្តេចមានសមត្ថភាពអាចប្រាស្រ័យ អាន សរសេរភាសាចំនួន, សៀម, លាវ, ខ្មែរអក្សរមន, កូមា, លង្កា ជាភាសាចាស់ ។ មិនតែប៉ុណ្ណោះ សម្តេចអាចធ្វើចាប៉កថា ឬ ខេសនាជាភាសាចាស់ សំស្ក្រឹតបានដោយឥតខ្វេសខាត់ ។ សម្តេចបានទទួលហានន្តរស័ក្តិជា អ្នគ្គមហាបណ្ឌិត ដែលរដ្ឋាភិបាលសហភាពភូមា បានប្រគេនកុង ព.ស.២៤៨៧ (ថ្ងៃ ២២ ឧសភា គ.ស.១៩៥៤)

សម្តេចជាក្រមដំខុំតែងវចនានុក្រមខ្មែរ បានបង្ហើយការនោះតែមួយព្រះអង្គឯងដ៏ពេជដល់ចប់ បានរៀបរៀងកថាយនូបត្ថម្ភកចាស៎, តិហ៎ជដិបត្តិ, សាមណេរវិនិយ, តិកុបសម្បាតិមោក្ខសង្ខេប, នាគោបមាទិកថា, មហាបុរិសលក្ខណៈ, នាមប្បញ្ញត្តិ, បព្វជ្ជបសម្បទា ព្រមទាំងសៀវភៅពាយវនធម៌កិច្ចការឯទៀតៗ ជាច្រើន ។

អាស្រ័យដោយគុណ គឺសីលគុណ សមាធិគុណ ឧត្តមបញ្ញាគុណ ដែលសម្តេចបានបំពេញខុកកុងព្រះពុទ្ធសាសនាមក អស់កាលដ៏យូរ

កំបណ្តាលឱ្យរង្គើកិត្តិសព្ទសហការភូមា, មួយអន្លើដោយប្រជាជនគ្រប់ទ្រង់ប្រទេស ជាពិសេសជាមួយនឹងព្រះសង្ឃដ៏ខ្ពង់ខ្ពស់បំផុតចំពោះអគ្គមហាបណ្ឌិតកម្ពុជ សម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយឱ្យទៅធ្វើជា អគ្គមហាឧបាសិកា ដែលជាមហាសក្តិ ថ្នាក់ខ្ពស់បំផុតក្នុងប្រទេសភូមាថែមទៀត កាលពីថ្ងៃទី ១៧ - ៥ ត.ស. ១៩៥៧ ដោយសេចក្តីគោរពយ៉ាងខ្ពស់ ។

ទីបំផុត ដោយសោមនស្សចិត្តដ៏បរិសុទ្ធនេះ សូមសម្តេចជូនប្រកបដោយសេចក្តីសុខ-ចំរើន មានព្រះជន្មវស្សាវែងឆ្ងាយដើម្បីជាទីពំនាក់នៃពុទ្ធបរិស័ទតទៅ ធំធេងដើម្បីជួយភ្ជាប់ព្រះពុទ្ធសាសនាឱ្យជានុឆេរឿងជាស្ថាពរទៅកាលលោកទាំងមូល ។

សូមព្រះពុទ្ធសាសនារុងរឹងអស់កាលជានិច្ចនិរន្តរ៍ !

× × ×

លំដាប់មក មានពិធីប្រគេនសញ្ញាប័ត្រ "អគ្គមហាឧបាសិកា" ចំពោះសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយកទៀត ។ លុះចប់ពិធីនេះហើយសម្តេចជានិមន្តមានបន្ទូលតាម តាមរបៀបភាសាភូមា ។ រួចគណៈប្រតិភូភូមាក៏ជានិមន្តបាន្ទូលតាងកិច្ចបញ្ចប់ពិធីក្នុងពេលនោះ ។

ក្នុងឱកាសពិធីនេះ សម្តេចព្រះទបយុវាជដ្រង់ស្តេចយាងមកឈរប្រថាប់រួបរួមក្នុងពិធី ព្រមទាំងសម្តេចចៅហ្វាំងវ័រវឿងជ័យសមាជិកវង្ស-កិត្តិយស ។

សម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយក ចូលទៅថ្វាយព្រះពរជ័យសួស
ចំពោះសម្តេចព្រះទេពុយវរាជនិន្នសមាធិភវន្តាតិថ្កាលនឹងប្រជាជនទាំងអស់។

ពេលរសៀល ម៉ោង ១២, ៣០ អ្នកតំណាងព្រះសង្ឃតិច្ចការ
បរទេស, ប្រធានគណៈកម្មការប្រតិបត្តិការខាងពិធីពុទ្ធសាសនា ចូល
ទាំងគណៈប្រតិភូនានាប្រទេសទៅទទួលស្វាគមន៍ប្រជុំក្នុងវិហារព្រះវែកវមរកត នឹង
មណ្ឌបព្រះថ្កាន ។ ពួកភ្ញៀវបរទេស ត្រាមដែលចូលទៅតាំងព្រះ
វែកវមរកត មានមនោសញ្ចេតនាវែកឆ្ងាយ៉ាងក្រៃលែង ។

ពេលយប់ ម៉ោង ១៩: មានការបូជាប្រទីបផ្កាសា,អុជកាំជ្រួចខ្ទា
ភ្លឺច្រាលសន្ធោសន្ធាវពេញទាំងយ ។

លំដាប់តមក ព្រះថេរៈគណៈមហានិកាយ ១ អង្គឡើងប្រាំ; ព្រះ
សង្ឃគណៈមហានិកាយ ២៥០ អង្គ ស្វាធ្យាយអាទិភ្គបរំយោយសូត្រ ព្រះ
ធម្មកថិកគណៈមហានិកាយ ៦ អង្គ ទេសនារឿងពុទ្ធប្រវត្តិ ២ លើក, ក្នុ
មួយលើកក្នុងម៉ោង :

លើកទី ១ ម៉ោង ២២ ព្រះមហា ដួរ-សុទ្ធ វត្តសង្កា ទេសនារឿងពុទ្ធ
បិតុបវាទិញ្ញាទបរិច្ឆេទទី ២២ ។

លើកទី ២ ម៉ោង ២២, ៣០ នាទី មហា ធន់ ភ័ន់ វត្តទណ្ឌាសោះ
ទេសនារឿងពុទ្ធបវាទិញ្ញាទ បរិច្ឆេទទី ២៣ ។

ក្នុងពេលនោះ មានពិធីសំដែងនូវចក្តីសោកស្តាយ ចំពោះព្រះ
សម្ពុទ្ធបរមគ្រូជាម្ចាស់ ។

ថ្ងៃទី ៧

គឺថ្ងៃសៅរ៍ ៥រោច វិសាខ ព.ស. ២.៥០០ (១៨ឧសភា ១៩៥៧)

ថ្ងៃនេះ ជាថ្ងៃប្រតិស្ឋានព្រះបរមសារីរិកធាតុក្នុងព្រះសក្យមុនីចេតិយ ។

ពេលព្រឹក គេក្រេឡកទៅឃើញពួកពុទ្ធសាសនិកជនភាំងបុរសស្ត្រីអង្គើញមកកាន់មណ្ឌលបុណ្យមានចំនួនច្រើនអនេក ។ តាមបន្ទាះអគារផ្សេង ។ គេឃើញពួកទេវតាសក្កទេវតាសិកា អ្នកកាន់អតិរេកសីលគោរក្សាសីលស្ងៀកពាក់ស, មុនប្រុសចង់ត្រាច់ទៅតាមប្រក្រតីភាព គេមើលពីចម្ងាយឃើញដូចពស់នាគពណ្ណរាយបួនកណ្តាលព្រៃ មានរុក្ខជាតិព័ណ៌លឿង គឺព្រះសង្ឃនិមន្តកណ្តាលមហាជនប្រុសស្រីដែលស្ងៀកសំពត់ហូលផាមួងពណ៌ត្រប់ហ៊ាង ណាយចំរុះគ្នា ជាទិដ្ឋភាពប្រកបដោយសោភណរូប គួរឲ្យរមិលមើលពន់ពេក ។

ចំណែកឯអគារតាំងប៉ុន្មានេះឃើញដូចជាប្រាសាទប្រាំមានផ្ទុះចេញពីក្រឡាប្រថពី សន្ធោសន្ធៅប្រាំលន្ធៅចោលស្មើផ្ទៃក ។ ទៅត្រប់ទិសទី ។

មហាជនក្នុងពេលនោះ ខ្លះកាន់ចង្ហាន់សម្រាប់ជាតំណាក់ថ្វាយព្រះសង្ឃ មានផ្តិលជានស្រាក់ ខ្លះទូលកន្ទោចុងយួរបូបំណី ខ្លះយកខ្នើតជូបភ័ក្ត្រាមកបូជាព្រះសក្យមុនីចេតិយ ឬព្រះបរមសារីរិកធាតុដែលតម្កល់នៅបុស្សក្រ ខ្លះដៃកគ្នាថាយើងមានកត្តព្វសំណាងល្អ ថ្ងៃនេះតាន់ពាក់កណ្តាលព្រះពុទ្ធសាសនា ខ្ញុំបានឮពួកជនបរទេសពោលថា ពិធីបុណ្យព.ស.២៥០០

នៅប្រទេសកម្ពុជា មានបាតព្ជាំថ្ពើងរុងរឿងជាងប្រទេសឯទៀត ។

ម៉ោង ៨,ព្រះគុណាភិនីព្រះមង្គលខ័ណ្ឌសម្តេចព្រះទេពយុវរាជ ស្តេចយាងមកដល់ ។ មានកញ្ញាបីនាក់មានរូបឆោមលោមតំណាស្រស់ប៉ិនប្រសប់បានយកកូនបុប្ផាមកថ្វាយព្រះនរបតី ទើសម្តេចព្រះមហាក្សត្រីយានីសម្តេចព្រះទេពយុវរាជ ទ្រង់ស្តេចទទួលកូនបុប្ផានោះយកទៅបូជាព្រះបរមសារីរិកធាតុ ព្រមទាំងសម្តេចក្រុមព្រះស៊ីសុវត្ថិ-មុនីវង្ស ទត្តមសេនីយអគ្គាធិការកងយោធពលខេមរៈភូមិន្ទ ។ កងពលនោះ ក្រុមសិស្សានុសិស្សនៃសាលាគរុវិជ្ជាទើងអនុវិទ្យាល័យជនពត្តមប្រមាណ ១០០ នាក់ស្មៀកពាក់ឯកសណ្ឋាន តាមគេទបុរសទើងគេទស្ត្រីឈរតម្រៀបជាជួរយ៉ាងរៀបរយ ជាបន្ទឺឡើងទូរបទសរភ័ញ្ញព្រមៗគ្នាយ៉ាងព័រពៃក្រៃលែង ។

បន្ទាប់មក ទេវាសកទេវាសិកាមានព្រះគុណាភិនី ២ ព្រះអង្គជាប្រធានធ្វើពិធីទមស្ការ សម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយប្រទានឆ័ល ៥ លើរៀងគាត់សេស ព្រមទាំងថ្វែងសង្គ្រហធម្មន្តព្រះបរមសារីរិកធាតុទៅគាន់ព្រះសក្យមុនីចេតិយ ។

លុះចប់សង្គ្រហធម៌ហើយ លោកទេកញ្ចាមហាមន្ត្រីចាងហ្វាងពិធីការនៃព្រះបរមកជកំនត់ ឡើងទៅលើបុស្បកចាប់កំលៀងព្រះបរមសារីរិកធាតុប្រគេនសម្តេចព្រះសង្ឃនាយកគណៈមហានិកាយ , សម្តេចបានទាំព្រះបរមសារីរិកធាតុ ពីកបុស្បកដល់ខាងក្រោមដណ្តើរថ្នាក់ទី ១ ទើបថ្វាយទៅព្រះគុណាភិនីអង្គាស់ដំរីតែលើកូនដ៏ ព្រះមង្គលខ័ណ្ឌទ្រង់ទ្រសួយព្រះបរមសារីរិកធាតុនោះ ស្តេចយាងទៅគាន់ព្រះសក្យមុនីចេតិយ ដោយមាន

សម្តេចព្រះមហាកស្សត្រិយានី, សម្តេចព្រះទេបយុវរាជ, សម្តេចក្រុមព្រះ
ស៊ីសុវត្ថិមុនីរ៉ែត, សម្តេចចៅហ្វាភ័ណវរៈវៀនដ៏យ, សមាជិកទត្តមប្រឹក្សាព្រះ
រាជា, សមាជិករដ្ឋាភិបាល, សមាជិកការទូត, គណៈប្រតិភូនានាប្រទេស,
ប្រជានពុទ្ធិកសិមាតមកពីទូទៅ, ប្រជានសមាគមតំណាងសង្គ្រោះសម្រាប់
ព្រះសង្ឃខ្មែរ, ប្រជានសមាគមមិត្តពុទ្ធិកវិទ្យាល័យ នាមុនធំតូចជាព្រះរាជ-
បរិពារហែតាមពីក្រោយព្រះអង្គ ។ ក្នុងពេលនោះ មានសមាជិកាពីនាក់
នៃសមាគមមាតាពុទ្ធសាសនាប្រទេសកម្ពុជា បានបែកផ្កាក្រជាសគ្រប់តណ
ជូនពួកក្មេកែតិយសកាន់បៃ ។

ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ទ្រង់ស្តេចយាងប្រទក្សិណព្រះ
សក្យមុនីចេតិយ ៣ ជុំ ជាទង្គុំណាត់តិ ព្រមទាំងព្រះរាជបរិពារ ។

ចំណែកសម្តេចព្រះសង្ឃនាយកទាំងពីរគណៈ ព្រមទាំងព្រះសង្ឃ
ជារច្រើនតាន់អង្គតន់ឯពីទ្វារព្រះសង្ឃ បានស្វាធ្យាយធម៌ជយន្តោ លាន់ឮ
ខ្ទរខ្ទារនៅពេលដែលព្រះនរបតី ទ្រង់ស្តេចយាងប្រទក្សិណព្រះសក្យមុនី-
ចេតិយ។ ឯក្រុមគហានក្សព្រះអង្គ ក្រុមគហានកដ៏ទេមរៈភូមិន្ទ ដែល
ឈរតម្រៀបជាជួរកំផ្លើតាវែកិច្ច ដោយលើកគាវុធវិន្ធាជាយ៉ាងផ្ងតផ្ងង់ ។

នៅពេលចប់ការហែប្រទក្សិណ, ក្រុមសិស្សានុសិស្សនៃសាលា
តរុវិជ្ជាធីដ៏អនុវិទ្យាល័យនារី បានបន្ទឺចសរសើរញ្ញាមួយលើកទៀត ថ្វាយ
ចំពោះព្រះចរមសារីរិកធាតុ ដោយសំឡេងលាន់ឮពីពេះអស្ចារ្យ គួរឲ្យ
ចង់សរសើរាពន់ពេក ។

ព្រះនរបតី ទ្រង់ឈរប្រថាប់នៅមុខព្រះសក្យមុនីចេតិយ ព្រមទាំង

ព្រះពជបរិពារ ទ្រង់ថ្វាយព្រះបរមសារីរិកធាតុទៅសម្តេចព្រះទេបយុ-វាជ។ ទ្រង់បាន់ស្តេចយាងតាមផ្លូវខ្ពស់ ទៅខាងលើព្រះសក្យមុនីចេតិយ ហើយទ្រង់ឃុកព្រះបរមសារីរិកធាតុ ទៅតម្កល់ក្នុងព្រះសក្យមុនីចេតិយ នោះ ។

ខេវពេលនោះ មេឃងងឹតជិតនឹងភ្លៀង ហើយព្រះពាយុបក់រំភើយៗ បញ្ចេញអាការស្រងាក់ល្មម ដូចជាទេវតាថ្វាយពរជោគជ័យ ចំពោះព្រះមហាក្សត្រ័យ៍ទាំងពីរព្រះអង្គ ដែលទ្រង់កំពុងខ្វល់ខ្វាយក្នុងពិធីបុណ្យដ៏ខ្ពង់ខ្ពស់នេះ ។ ខ្ញុំដូចជាមានជម្ងឺជាតិទាំងមូលក្នុងព្រះពជជានីក៏បញ្ចេញខ្យល់ស្រួចក្តៅសោមនស្សព្រឺខ្លាចតក ។

លំដាប់តមក ព្រះសុណាគាំងពីរព្រះអង្គ សម្តេចព្រះទេបយុវាជ ទ្រង់ស្តេចយាងរួចត្រឡប់មកគង់ប្រថាប់នៅព្រះពន្លាកិត្តិយសវិញ ព្រមទាំងព្រះពជបរិពារ ។ ក្នុងពេលនោះ មានប្រតិកូប្រទេសឥណ្ឌាបាននាំយកព្រះពុទ្ធរូបមួយព្រះអង្គ ឧទ្ទិសថ្វាយព្រះសាស្តាដែលបានយកមកពីពុទ្ធគយា កន្លែងដែលព្រះអង្គត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណមកថ្វាយព្រះនរបតី, ព្រះអង្គម្ចាស់ក្សត្រ័យាតិវង្សមួយអង្គទ្រង់ក៏បាននាំយកសៀវភៅមកថ្វាយព្រះមហាក្សត្រ័យ ។

លុះដល់ម៉ោង ៩, ១៩ នាទី ព្រះសុណាគាំងពីរព្រះអង្គ, សម្តេចព្រះទេបយុវាជ, បានស្តេចយាងទៅកាន់មហាពេជ្ឈាមួយទឹងក្បែរបរិវេណព្រមទាំងព្រះពជបរិពារដើម្បីដាក់ចាក្រព្រះសង្ឃ ១០០ អង្គ ។ ទៅដល់កន្លែងដាក់ចាក្រនៃព្រះពជា មានកន្លែងពីរទៀត ១_សម្រាប់សម្តេចព្រះ

ពជកនិដ្ឋារស្នើសោតណាដាក់ជាត្រព្រះសង្ឃ ១០០ អង្គ ២- សម្រាប់
សម្តេចពិនតាពសូតរតើដាក់ជាត្រព្រះសង្ឃ ១០០ អង្គ ។

ឯណេតមហាកេង, មានឮតតុទ្ទបសែទាបម៉ឺននាក់កំពុងដញ្ជូន
បង្ហាន់សម្រាប់ដាក់ជាត្រតាមបង្ហាវែង កកកុញតឹកកងរំពងពាសពេញ ។
គេក្រឡេកទៅឃើញពណ៌លឿងលាយចម្រុះនឹងពណ៌ក្រហម, បៃតង,
ខៀវ . . . ល . . . ពាយដេរជាសម្រួចពី ហើយខ្ពស់ស្មើព្រះសុរិយោ
ចំណែងមក, ធ្វើឲ្យឃើញដូចជារូបភំនូរមួយដ៏រំពិត្រដែលជាងជំនាញ
បានទ្វាក់យ៉ាងល្អអស្ចារ្យ ។

ពេលរសៀល ម៉ោង ១៤ មានធ្វើពិធីទេសនាសង្គាយនាដោយ
ព្រះធម្មកថិក ៣ អង្គ គឺគណៈមហានិកាយ ២ អង្គ ធម្មយុត្ត ១ អង្គ :

១- គណៈមហានិកាយ : ព្រះយោសធម្ម ម៉ឺង-សែស ចៅអធិការ
វត្តមហាមន្ត្រី ជាព្រះគស្សប;

២ គណៈមហានិកាយ: ព្រះញាណកោសល ញាណ-ឈឹន វត្ត
លង្កា ក្រុមជំទុំព្រះត្រៃបិដក ជាព្រះទុតិយ;

៣- គណៈធម្មយុត្ត: ព្រះញាណវីរិយៈ ភ័ន់-សាខុំ វត្តខ្នួនមណី-
កម, ក្រុមជំទុំព្រះត្រៃយបិដក ជាព្រះតេនទ្ធ ។

ព្រះយោសធម្ម ម៉ឺង-សែស ជាអ្នកសួរធម្មវិន័យ, ព្រះញាណកោ
សល ញាណ-ឈឹន ជាអ្នកឆ្លើយព្រះវិន័យ; ព្រះញាណវីរិយៈ ភ័ន់-
សាខុំ ជាអ្នកឆ្លើយព្រះធម៌ ។ ទេសនានេះ មានរៀបរៀងដូចចម្ម-
សង្គាយនាក្នុងគ្រាដែលព្រះអនាវរណញាណ ទ្រង់ចារនិព្វានទៅថ្មី ។ ។

ចំណែកឯលោកសង្ឃហត្ថបាសដែលគង់នៅមហាវេន គឺលាយចម្រុះទាំងពីរគណៈ គឺ គណៈមហានិកាយ ២០០០ អង្គ ធម្មយុត្តិ ៥០០ អង្គ រួមជា ២៥០០ អង្គ ថែមទាំងព្រះសង្ឃបរទេស ២០ អង្គទៀត ។

រួចទើបមានពិធីប្រគេនទេយ្យទានដល់ព្រះសង្ឃសង្គាយនា ។

ម៉ោង ១៦,ព្រះករុណាជាអម្ចាស់ជីវិតលើត្ឃូងទាំងពីរព្រះអង្គ, សម្តេចព្រះទបយុវរាជស្តេចយាងមកដល់ ព្រមទាំងព្រះរាជបរិពារ ។ ក្រោយដែលទ្រង់បានយកភ្លងបុប្ជាទៅថ្វាយព្រះបរមសារីរិកធាតុ, ទ្រង់ក៏យាងទៅប្រថាប់ឯព្រះពន្ធាកិត្តិយស ដើម្បីទ្រង់ព្រះសណ្តាប់នូវព្រះសង្ឃទេសនាសង្គាយនា, ពិធីនេះផ្ទីរហូតដល់ម៉ោង ១៦.៣០ នាទីទើបចប់ ។

លំដាប់តមក មានព្រះសង្ឃជាតិចិនខាងទីបេត៍ ២ រូបបាននាំយកដង្វាយដ៏ប្រណីតមកថ្វាយព្រះនរបតី ។ ក៏ទ្រង់បានប្រគេនព្រះពុទ្ធរូបដែលសាងអំពីជ្រាក់ ដល់ព្រះសង្ឃបរទេសជាច្រើនអង្គដែរ ។

លុះដល់ម៉ោង ១៦.៤៥ សម្តេចព្រះទបយុវរាជ ស្តេចយាងទៅលើវេទិកាពិសេស ថ្ងៃននូវសេចក្តីរាយការណ៍នៃពិធីបុណ្យនេះ ថ្វាយព្រះករុណាជាអម្ចាស់ជីវិតលើត្ឃូង ដូចតទៅនេះ:

សូមព្រះតេជះដំកល់លើត្ឃូង

សូមព្រះរាជទានក្រាបបង្គំទូល ព្រះករុណាជាអម្ចាស់ជីវិតលើត្ឃូង

សូមទ្រង់ជ្រាប ក្រោមល្អងធូលីព្រះបាទ ។

សូមពិតពុទ្ធដីកាសម្តេចព្រះសង្ឃនាយក, ព្រះថេរានុត្ថេរៈ,

សូមជំរាបលោកអ្នកតំណាងប្រទេសនានា និងមិត្តរួមជាតិទាំងឡាយ,

មហាកុសល ដែលយើងបាននាំគ្នាកសាងក្នុងឧកាសពិធីបុណ្យ ព.ស. ២៥០០ ចំនួនមួយសន្ធាហ:នោះ នឹងចប់នៅថ្ងៃនេះហើយ ។

បុញ្ញកិរិយានេះ យើងទាំងអស់គ្នាមុខជាទទួលគ្មានក្ងេចក្ងាចដូចហឫទ័យទៅតែម្តង ។

ខ្ញុំព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំ សូមថ្វាយអំណរដ៏ជ្រាលជ្រៅចំពោះព្រះមហាករុណាគុណនៃព្រះករុណាជាម្ចាស់ជីវិតលើស្ងួន ដែលទ្រង់បានជួយឧបត្ថម្ភធ្វើឲ្យពិធីបុណ្យនេះ បានអាចកសាងជាហេតុឲ្យពលរដ្ឋខ្ញុំទៅសំគាល់បានថាព្រះអង្គជាព្រះពុទ្ធបរិស័ទមួយដ៏ឧត្តម ដែលមានព្រះហឫទ័យជ្រះថ្លាគោរពបូជាព្រះពុទ្ធជាអម្ចាស់ ។

ខ្ញុំព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំ មានចិត្តរីករាយជាទីបំផុត ដោយបានឃើញអស់លោកតំណាងប្រទេសដែលជាមិត្ត ហើយដែលយើងទុកដូចជាបងប្អូនរួមសោហិត អញ្ជើញមករួមសាងកុសលដ៏ប្រសើរថ្ងៃនេះជាមួយនឹងព្រះមហាក្សត្រិយ៍ព្រះមហាក្សត្រិយានី ព្រះកិត្តិសង្ឃ.ភាយក.ភាយិកា បណ្តាពស្ត្រគាំងមូលនៃប្រទេសកម្ពុជា ដើម្បីថ្វាយសេចក្តីគារវ.ភាពចំពោះសម្តេចព្រះដ៏នស្រីសម្ងាសម្ពុទ្ធទេសតលញ្ញាណ ដែលមានគុណលើសគ្រូលោកគេចំបំផុតគ្មាន ។ នៅវេលាដែលអញ្ជើញទៅកាន់ប្រទេសនឹងគេហស្ថានវិញ លោកអ្នកតំណាងរដ្ឋដែលជាមិត្តភាពជំពប់រង្គាកិច្ចលនឹងជនរួមជាតិអស់លោកបានថា ពុទ្ធបរិស័ទនៅប្រទេសកម្ពុជា មានចិត្តសទ្ធាជ្រះថ្លាជឿជាក់ដល់ព្រះសុធម្មាំងឡាយ ដែលព្រះដ៏មានព្រះភាគបានត្រាស់សំដែងទុកឲ្យមនុស្សលោក ។

ខ្ញុំសូមថ្វាយនមស្សការ ខ្ញុំ សូមថ្វែងអំណរគុណដ៏ស្មោះស្ម័គ្រ ដល់ជនរួមជាតិទាំងអស់ មានព្រះសង្ឃនិងពួកឧបាសក ឧបាសិកា ជាដើម ដែលបានចំណាយកំឡាំងកាយចាចិត្ត ទឹងកំឡាំងទ្រព្យអស់ ជាច្រើន ដើម្បីធ្វើឲ្យតិដ៏បុណ្យនេះបានប្តូរឆ្លងយ៉ាងឧឡារិកទឹងសំដែង ឲ្យយើញជាយថាតែថ្ងៃថ្នូរថា ប្រជាពលរដ្ឋខ្មែរទាំងមូលបានយកព្រះពុទ្ធ ព្រះធម្មព្រះសង្ឃជាទីពឹងទីរឭករបស់ខ្លួនជាដរាប ។

ខ្ញុំព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំសូមឲ្យលោកសប្បុរសទាំងអស់មេត្តា អត័យទោសដល់សេចក្តីខុសខ្វាំងគ្នងទឹងការខ្វះខាតដែលកើតមានឡើង ក្នុង ឧកាសរៀបចំពិធីបុណ្យនេះ ។ ដូចអស់លោកអ្នកសប្បុរសបានជ្រាប ស្រាប់ហើយ យើងសព្វថ្ងៃនេះមានជនជាន់ទឹងមរណ្យយ ភាយ ស្តួចស្តើង នៅឡើយ ។ ប៉ុន្តែលោកអ្នកទាំងអស់គ្នាមុខជាសំគាល់បានថា ពិត មែនតែប្រទេសនេះពុំសូវបរិបូណ៌ដោយកោគទ្រព្យ តែប្រជាពស្ត្រជាតិខ្មែរ ទាំងមូលមានធន្ធះយ៉ាងធំ ហើយល្អបំផុតក្នុងការខ្នះខ្នែងខួលក្បៀវៃប្រ- ទេស ដែលអញ្ជើញមកកាន់ពីនេះ ព្រមទាំងមានចិត្តសប្បាយរីកយ យ៉ាងស្មោះដល់ការកុសលទឹងចិត្តជ្រះថ្លាចំពោះព្រះរតនត្រ័យ ។

មុនទឹងយើងបែកគ្នា ទៅកាន់គេហស្ថានពល់រៀងខ្លួន ខ្ញុំព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំ សូមថ្វាយ សូមជូនសព្វសាធុការពរ របស់ខ្ញុំព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំ ព្រមទាំងរបស់អស់លោកអ្នកសប្បុរស ដែលបានខិតខំ ព្យាយាមគុបតែងតិ៍បុណ្យ ព.ស.២៥០០នេះ ដល់ជនរួមជាតិយើងទាំង អស់ ដល់លោកអ្នកតំណាងប្រទេសនានា តំណាងរដ្ឋជាមិត្តទាំង

ឡាយ ដែលបានអញ្ជើញមកកាន់ពិធីបុណ្យនេះ ដើម្បីធ្វើសក្ការបូជា
ចំពោះព្រះសុគតសព្វញ្ញូជាគ្រូសត្វលោកក្នុងត្រៃភព សូមឲ្យបានប្រកប
តែនឹងសេចក្តីសុខសេចក្តីចំរើនជានិច្ច ។

ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំ សូមបួងសួងដល់ព្រះតេជានុភាព
នៃព្រះពុទ្ធគ្រប់ព្រះអង្គនឹងព្រះសុធមិទាំងឡាយ សូមមេត្តាដឹកនាំយើងខ្ញុំ
ទាំងអស់គ្នានឹងពិភពលោកទាំងមូលឲ្យបានផុតអំពីទុក្ខវេទនា ទៅកាន់
សេចក្តីសុខ មានព្រះនិព្វានជាទីបំផុតឲ្យបានដូចព្រះពុទ្ធដីកាតទៅនេះ ៖

សព្វេ ចទេសា សព្វេសំ បាណីនំ ទុក្ខំ នីហរន្តុ វិនាសេន្តុ ។ យេ
សត្តា សកលលោកស្ស ទសសុ ទិសាសុ ឋិតា ទុព្ទលា ហោន្តិ តិលា.
នា អនាវរណា តេ អត្តនោ អត្តនោ ទុក្ខវិបាកា បមុច្ចន្តុ ។

យេ សត្តា ទណ្ឌកម្មំ អនុភោន្តិ តេ ទណ្ឌកម្មា បមុញ្ចន្តុ ។

យេ សត្តា មរណសង្គាមេន អភិភូតា ហោន្តិ តេ អាយតឹ ជីវន្តុ ។
យេ ច សត្តា ទុក្ខភយប្បត្តា ហោន្តិ ។ តេ សព្វទុក្ខភយេហិ វិនិមុត្តា
ហោន្តិ ។ យេ សត្តា បិបាសិតា ជិយច្ឆិតា ហោន្តិ តេ មនុញ្ញាំ បវិបុណ្ណំ
ភោជនភេសជ្ជំ លភន្តុ ។ យេ សត្តា អន្ធចក្ខុកា ហោន្តិ តេ ទស្សនំ
បដិលភន្តុ ពធិរា សវនំ បដិលភន្តុ ។ យា ឥត្ថី គព្ភិនី ហោន្តិ តា សុខេន
វិជាយន្តុ ។ សកលលោកស្ស សព្វកណ្ណេសុ ទុក្ខោ សព្វោ មា និច្ឆរតុ ។
សព្វេ សត្តា បដិសន្ធិគ្គហណេ អកុសលស្ស បថំ បវិវិវជ្ជន្តុ ។

សព្វេ សត្តា និរយសង្ខាតេ អន្ធលោកេ វិបច្ចន្តិ តេ សព្វទុក្ខសោ.
កេហិ វូបសម្មន្តុ ។

លោកេ ឯវំ ទុក្ខំ វេទនំ វេទិយន្តេ យេ សប្បុរិសា មេត្តា ការុណិកា ហោន្តិ តេ បមោទនេន ថាតុំ ន សក្កោន្តិ យេវ ។

សព្វេ សត្តា សន្តិកាវេន សមន្ឋិកា ហោន្តុ ។

សូមប្រទេសទាំងអស់ បំបាត់នូវសេចក្តីទុក្ខនៃសព្វសត្វទាំងឡាយ។ សូមសត្វទាំងឡាយដែលបិតនៅក្នុងទិសទាំង ១០ នៃពិភពលោក ដែលឲ្យត់ឲ្យាយ ដែលឈឺថ្កាត់ ដែលឥតមានត្រឿងការពារឲ្យរួចផុតពីផលនៃអំពើអាក្រក់របស់ខ្ជួនៗ ។ សត្វដែលត្រូវទណ្ឌកម្ម សូមឲ្យរួចពីទណ្ឌកម្ម។ សត្វដែលត្រូវមរណសង្ត្រាមកម្រាមហើយ សូមឲ្យមានជីវិតរស់នៅតទៅ ។ ឯសត្វណាដែលមានសេចក្តីស្រេកឃ្ងាន សូមឲ្យបានទទួលនូវភោជនាហារនឹងភេសជ្ជៈជ៏បរិបូណិ ។ សត្វដែលមានក្នែកខ្ងាក់ សូមឲ្យមើលឃើញឡើងវិញ ដែលថ្ងង់ សូមឲ្យស្តាប់ព្ទឡើយវិញ ។ ស្ត្រីមានតភិ សូមឲ្យប្រសូតបុត្ត ដោយសុខសប្បាយ ។ ត្រប់ជ្រុងពិភពលោកទាំងមូល សូមកុំឲ្យលេចព្ទសំឡេងដែលប្រកបដោយទុក្ខ ។

សូមសត្វទាំងឡាយវៀរបង់នូវតន្ធងអកុសល ក្នុងការបដិសន្ធិ ។ សូមឲ្យសព្វសត្វដែលបិតនៅក្នុងលោកងងិតគឺនរក បានផ្ទស្រាលចាកទុក្ខសោកត្រប់ប្រការ ។ "ល្ងិកណាសត្វនៅទទួលទុក្ខនោះ លោកអ្នកសប្បុរសដែលមានចិត្តប្រកបដោយមេត្តាតរុណា មិនអាចនឹងមានសេចក្តីរីករាយសប្បាយបានទេ" ។

សូមសព្វសត្វទាំងឡាយបានប្រកបដោយសន្តិភាព ។

×

× ×

លំដាប់តមក នៅពេលម៉ោង ១៧ ព្រះនរបតីទ្រង់ស្តេចយាងទៅកាន់រៃគាកិត្តិយស ថ្វៃនន្ទូវព្រះរាជសុន្ទូរកថាបិទពិធីបុណ្យដែលមានសេចក្តីដូចតទៅនេះ :

ព្រះរាជសុន្ទូរកថា

សូមពិតពុទ្ធដីកាព្រះថេរានុត្តរ:,

សូមទូលទ្រង់,

ជំរាបឯកឧត្តម លោកអ្នកតំណាងប្រទេសជាមិត្ត និងអស់លោកអ្នកជាពុទ្ធមាមក:ទាំងឡាយ!

កាលពីថ្ងៃទី ១៦ ឧសភាមុននេះ ខ្ញុំព្រះករុណា, ខ្ញុំ បានថ្ងៃនរៀបរាប់ចង្អុល អំពីហេតុដែលនាំឲ្យយើងជ្រះថ្ងាន្ទបន្ទមតាក់តែងមហាពិធីដែលត្រូវបង្ហើយនៅពេលនេះ ។ មុននឹងបញ្ចប់ពិធីបុណ្យ ខ្ញុំព្រះករុណា, ខ្ញុំសុំថ្ងៃនអំណរគុណ ចំពោះព្រះថេរានុត្តរ: -ទ្រង់ ឯកឧត្តម ព្រមទាំងអស់លោកតណ:ប្រតិភូនៃប្រទេសជាមិត្ត និងពុទ្ធបរិស័ទទូទៅដែលមានសទ្ធាជ្រះថ្ងាលះក្តីកង្ខល់ ហើយនិមន្ត យាង អញ្ជើញយ៉ាងកុះករមកន្ទបន្ទមក្នុងមហាពិធីនេះជាមួយនឹងយើង ទាល់តែកើតបានជាឧឡារិកដ៏មហិមា ។

អំពើកុសលដែលកើតឡើងពីសាមគ្គីធមិ និងសទ្ធាជ្រះថ្ងារបស់យើង ចំពោះសាសនា នៃព្រះសក្យមុនីគោតមបរមគ្រូតាំងពីថ្ងៃទី ១ រហូតមកដល់ថ្ងៃនេះ ដែលជាថ្ងៃបង្ហើយពិធីបុណ្យ មានការសមាទានសីលទូទៅពេញព្រះរាជអាណាចក្រ ។ ការប្រគេនចង្ហាន់បិណ្ឌបាតចំពោះព្រះសង្ឆ ត្លូរចាត់ទុកជាអកិលក្ខិតកាលមួយ ដិតជាប់ក្នុងថ្ងើមប្រាមាត់របស់

យើងរាល់គ្នា ដែលជាអ្នកកាន់ព្រះពុទ្ធសាសនា ។ ឆ្លរសំតាល់ថាដោយ
អំណាចគុណ ព្រះរតនត្រ័យនឹងទេវតារក្សរៈលោកធាតុយើងនេះ ពិធីបុណ្យ
របស់យើង ចាន ប្រព្រឹត្តទៅក្នុងបរិយាកាសមួយយ៉ាងរីករាយបំផុត ព្រម
ទាំងគ្មានជួបប្រទះនឹងទបស័ត្តអ្វីសោះ ។

មុននឹងប្រកាសបិទពិធីនេះ ខ្ញុំករុណាខ្ញុំ សុំព្រះអង្គ ទ្រង់ ឯកទត្តម
ព្រមទាំងអស់លោកគណៈប្រតិភូនៃប្រទេសជាមិត្ត នឹងអស់លោកអ្នកជា
ពុទ្ធបរិស័ទ ទទួលនូវ ចំណែកកុសល ដែលកើតអំពីបុណ្យនេះស្មើរ ។ ត្នា
ហើយជាអវសានកថានេះ ខ្ញុំករុណា, ខ្ញុំ សូមព្រះធមិនៃព្រះពុទ្ធដ៏ត្រជាក់
ជូចជាទឹកអម្រឹត ផ្សាយស្រោចស្រប់លើជួងហម្ទ័យ នៃអស់លោកជាមេ
ដឹកនាំប្រទេសទាំងឡាយក្នុងសកលលោក សូមមេដឹកនាំទាំងនោះតាំងនៅ
ក្នុងធមិមេត្តារកត្នាចាប់តាំងពីពេលនេះតទៅ ហើយសូមឲ្យសន្តិភាពមាន
ជ័យជំនះជាស្ថាពរនៅក្នុងពិភពលោក ។

ជយោ ជយោសន្តិភាព ।

សំឡេងស៊ីវ៉ៃនឹលាន់ពុឡើងពេញព្រះរាជធានី ជាសញ្ញានៃការ
ចប់ពិធីបុណ្យនេះ ។

បន្ទាប់ពីសេបក្តីថ្វៃងបិទពិធីបុណ្យនេះមក ព្រះករុណាទាំងពីរព្រះអង្គ
ទ្រង់ស្តេចយាងទតមន្ទីរតាំងតុនានា ដែលមានទាំងគ្រឿបរទេសនឹង
ឥស្សរជនវ្មៃរជាន់ខ្ពស់នឹងព្រះរាជបរិពារជដែល តាមជដ្ឋីព្រះរាជាផង ។

ដំបូងទ្រង់ទតតុនៃសម្តេចព្រះសង្ឃនាយកគណមហានិកាយដែល
មានសម្តេចព្រះសង្ឃនាយក ចាន នាំព្រះប្រមុខរដ្ឋឲ្យទ្រង់ទតវត្ថុផ្សេង ។

ហើយបន្ទាប់បន្តទៅទ្រង់ទតតុតំណាងខែត្រទាំង ១៤ នៃព្រះពុទ្ធសាសនា. ចក្រដែលតាក់តែងតាំងឡើង ដោយរួមលោកចៅហ្វាយខែត្រ, ចៅហ្វាយស្រុក, លោកគ្រូមេគណ អនុគណនៃខែត្រនីមួយ ។ តពីតុ នៃខែត្រទាំង ១៤ ព្រះពុទ្ធ ទ្រង់ទតតុសម្តេចព្រះសង្ឃនាយកគណៈ ធម្មយុត្តិ ហើយទ្រង់យាងទៅទតតុនៃសមាគមអ្នកតម្កល់ក្រោម, ក្រសួងសិក្សាធិការ, តុះប្រជាជាតិចិន, តុសមាគមគិលានសង្គ្រោះចំពោះព្រះសង្ឃ, តុសមាគមមជ្ឈមណ្ឌលកម្ពុជវេជ្ជនិធិតុសមាគមមិត្ត ពុទ្ធិកវិទ្យាល័យ ។

ពិធីបុណ្យនេះបានចប់នៅវេលាម៉ោង ១៨,១៥នាទី ដោយមានពាក្យអាណត្តិសញ្ញា ប្រាប់គាំក្លើង ២៥ ណាត់ ជាសញ្ញាបិទពិធីបុណ្យ ក្រោយដែលព្រះករុណាទាំងពីរព្រះអង្គបានស្តេចយាងត្រឡប់ចូលព្រះបរមរាជវាំងវិញ ។ ការពីម៉ោង ១៨ មានពុទ្ធបរិស័ទប្រជុំនាក់បានទាំគ្នាដង្ហែព្រះពុទ្ធរូបជាច្រើនអង្គដែលជនរួមជាតិខ្លួនៅ បានសាងឡើងពីប្រាក់ ឬកែវ លង្កិន ឬកែវ ហើយដែលបានយកមកចូលជាកុសលកម្មនិពិធីបុណ្យនេះ ដើម្បីនឹងយកទៅតម្កល់ទុកនៅក្នុងព្រះសក្យមុនីចេតិយ ត្រង់ថ្នាក់ខាងក្រោម ជាកិច្ចបង្ហើយបុណ្យ ។

ឯការយន្តសហវដ្ដអាមេរិកក៏បញ្ចេញអាទុការ ដ៏តស្ងាន់អឺងឺយ. យាន ពាល់ពាក្យឲ្យប្រជាជនទស្សនាតាមបំណង មានបញ្ជាំងពីរឿងព្រះពុទ្ធសាសនានៅប្រទេសកម្ពុជា, ប្រទេសលាវ, ប្រទេសថៃឡង់ដ៏ជាដើម ។

ពិតមែនតែពិធីបុណ្យ ព. ស. ២៥០០ បានបញ្ចប់កន្លងពេលនោះតែប្រជាជនប្រុស-ស្រី, ក្មេងចាស់, ពួកពុទ្ធសាសនិកជនទាំងបព្វជិតនឹង

គ្រហស្ថកំនៅតែនិមន្តទំនឹងអញ្ជើញទៅតាន់មណ្ឌលបុណ្យ ណែនណាន់តាន់តាប់នៅឡើយ ។ ពិតមែនតែអគារតាំងគុតេជាន សាជញ្ជួនសាវត្ថិបន្តិចម្តង ។ ខ្លះទៅហើយ ក៏ពួកពុទ្ធមាមកជនកំនៅតែគ្រាប់ដង្ហើតតាមអគារនោះ ។ ដើម្បីទំនឹងទស្សនាខ្លួវពីផ្សេង ។ ក្នុកមើលមិនឆ្អែត, គ្រប់ក៏នៅតែចង់ស្តាប់ខ្លួវសូត្រសំឡេងបុណ្យ, សំណូរព្រះសង្ឃប្រជានសីល, សំដែងព្រះសទ្ធម្មវិសេសទេសនា, សូត្រធម៌, ចិត្តនៅតែចង់ក្រេបអារម្មណ៍នានា, នៅតែស្តាយ សែនស្តាយ មិនអស់មិនហើយ នៅតែកខ្វះចិត្ត . . . ។ មានខ្លះពោលថា: "អគារភាំងប៉ុន្មានដែលសាងសង់ល្អដូច្នេះមិនសមទំនាប់រុះរើ មិនសមទំនឹងឱ្យបាត់ពីទីនេះទេ" ខ្លះថា: "ពិធីបុណ្យ ព.ស. ២៥០០ នៅប្រទេសយើងប្រសើរថ្លៃថ្លាជាងពិធីបុណ្យពុទ្ធជយន្តិប្រទេសឥណ្ឌា, ប្រទេសថៃឡង់ ប្រទេសសេរីលង្កា" ខ្លះថា: "គួរតែធ្វើបានមួយរៃទើបសម" ។

× × ×

ពិធីដង្ហែរសៀងក្រយោហារ
បំពោះប្រតិភូពុទ្ធសាសនាប្រទេសឥណ្ឌៀ
នឹងប្រទេសបិនប្រជាមានិត

កាលពីថ្ងៃសៅរ៍ទី ២៥ សីហា ១៩៥៧ មានពិធីដង្ហែរសៀងក្រយោហារ បំពោះប្រតិភូពុទ្ធសាសនាប្រទេសឥណ្ឌៀ នឹងប្រទេសបិនប្រជាមានិត នៅគោដនាគារ "ថៃសាន" របស់ពុទ្ធសមាគមទាំង ៣ គឺ ពុទ្ធិកសមាគម កម្ពុជរដ្ឋ, សមាគមគិលានសង្គ្រោះសម្រាប់ព្រះសង្ឃវិញ, សមាគមមិត្ត

ពេលម៉ោង ១០,៣០ នាទី, គណៈប្រតិភូខាងពុទ្ធសាសនាចិន ប្រជាមានិត នឹងលោកវ៉ាលីស៊ុនហា តំណាងមហាពោធិសមាគមប្រទេសឥណ្ឌា ចូលមកដល់ ។

ក្រោយដែលបានធ្វើការកិច្ចតាមប្រពៃណី, គណៈប្រតិភូចិនប្រជាមានិតបានជូនចំពោះលោកប្រធានពុទ្ធិកសមាគម នូវពុទ្ធរូបមួយអង្គ, សៀវភៅ "ប្រទេសចិន" ជាភាសាអង់គ្លេស, តែយ៉ាងណាមួយកំប៉ុន្តែសំពត់មានបារាំងអក្សរចិន ១ ផ្ទាំងគូប ។

ម៉ោង ១០,៤០ នាទី, មានការលៀងក្រយាហារ នឹងកិច្ចសន្ទនាដោយមេត្រីភាព ។

ម៉ោង ១១,៤០ នាទី, រួចពីការដាប់លៀងក្រយាហារ លោក សម·ញាណ ប្រធានពុទ្ធិកសមាគមកម្ពុជរដ្ឋ ក្នុងឋានៈជាអ្នកតំណាងសមាគមពុទ្ធសាសនាទាំងបី បានថ្លែងសុន្ទរកថាមួយ ដូចសេចក្តីខាងក្រោមនេះ៖

ព្រះតេជព្រះគុណ,

អស់លោកអ្នកភាំងឡាយ!

ពេលនេះ ខ្ញុំព្រះករុណា ខ្ញុំមានកិត្តិយសដ៏ប្រពៃ ដោយបានទទួលអាណត្តិពីសមាជិក-សមាជិកាគណៈកម្មាធិការនាយក នៃពុទ្ធសមាគមទាំងបីគឺពុទ្ធិកសមាគមកម្ពុជរដ្ឋ ១ សមាគមមិត្តពុទ្ធិកវិទ្យាល័យ ១ សមាគមតំណាងសង្គ្រោះចំពោះព្រះសង្ឃពុទ្ធសាសនិក ១ ។

ជាដំបូង ខ្ញុំព្រះករុណា ខ្ញុំ ជាប្រធានពុទ្ធិកសមាគម តាងនាមពុទ្ធសមាគមទាំងបីនេះ សូមថ្វាយបង្គំចំពោះព្រះមហាវេរភន្តុត្តេរៈទាំងឡាយ

ហើយសូមសំដែងនូវសេចក្តីគំនាប់គាប់ឆ្លរដឹស្មោះត្រង់ព្រមទាំងមានអំណរ
ចំពោះអស់លោក សមាជិកគណៈប្រតិភូខាងព្រះពុទ្ធសាសនានៃប្រទេស
ទាំងឡាយ មានប្រទេសចិនប្រជាមានិត នឹងប្រទេសឥណ្ឌាជាដើម
ដែលបាននៃមន្ត អញ្ជើញ មករួបរួមធ្វើបុណ្យរំលឹក ព.ស. ២៥០០
នៅប្រទេសកម្ពុជានេះ ។

អរផ្ទួនថែមមួយសាទៀត ដោយអស់លោកធ្វៀតនៃមន្តអញ្ជើញមក
ក្នុងការជប់លៀងនេះ ជាហេតុនាំឲ្យយើញថាយើងជាពុទ្ធសមាគម មាន
សាមគ្គីរួបរួមគ្នាជាមិត្តមេត្រីភាពដោយពិត ។ ។

យើងខ្ញុំស្តាយណាស់ ព្រោះគណៈប្រតិភូខាងព្រះពុទ្ធសាសនានៃ
ប្រទេសជិត បាននៃមន្ត-អញ្ជើញត្រឡប់ទៅវិញ ពុំបានមកក្នុងពេលជប់
លៀងនេះ មកពីខាងយើងខ្ញុំនេះមានកិច្ចផ្សង ។ សុទ្ធជាការបន្ទាន់ក្នុង
ពេលបុណ្យ ពុំអាចរកនកាសនៃមន្ត-អញ្ជើញមុនពេលនេះបានឡើយ ។

ពិធីបុណ្យដ៏ឡាវិកដែលទើបធ្វើហើយនេះ មាន៣យ៉ាង:

១- បុណ្យរំលឹក ព.ស. ២៥០០,

២- បុណ្យវិសាខបូជា,

៣- បុណ្យធ្វងព្រះសក្យមុនីចេតិយ

បានធ្វើរួមគ្នា នៃក្នុងសប្តាហៈមួយនៅប្រទេសកម្ពុជានាសម័យនេះ ។

ប្រជាជនរាប់សែននាក់ ដែលមករួបរួមធ្វើបុណ្យនេះ មានជនជាតិ
ខ្មែរកម្ពុជាក្រោម "ដែនកូសាំងស៊ីន" រាប់ពាន់នាក់ បានមករួមកម្ចាំងធ្វើ
ជាមួយផងដែរ ។ ចំពោះបុណ្យទី ១ នឹងទី ២ មិនធ្វើត្រឹមតែក្នុងព្រះរាជធានី

ភ្នំពេញនេះទេ នៅវត្តលោកសង្ឆពំងឡាយទ្ធទៅ ក្នុងព្រះរាជ-
អាណាចក្រចំនួន ២.៨២០ វត្ត ហើយនឹងវត្តលោកសង្ឆពុទ្ធសាសនានៅ
កម្ពុជាក្រោម ដែនកូសាំងស៊ុន ជាង ៥០០ វត្ត ក៏បានធ្វើយ៉ាងអធឹកអ-
ធមនៅថ្ងៃជាមួយគ្នាដែរ ។

ព្រះតេជព្រះគុណ!

អស់លោកអ្នកពំងឡាយ!

ពិធីបុណ្យទាងលើនេះ បានធ្វើហើយក្នុងពេលដឹទ្ធ គណៈកម្មាធិការ
ចាត់ការបុណ្យ បានប្រឹងប្រែងពេញកម្ទាំងក៏ពិតមែន តែប្រហែលមានកិច្ច
ការទ្ទះទ្ទះចន្ទោះ នាំឲ្យព្រះតេជព្រះគុណ អស់លោកអ្នកពំងឡាយ មិន
សូវបានសុខស្រួល នោះសូមមេត្តាអភ័យទោសជងចុះ ព្រោះបាកិច្ចទ្ទះ
នោះបើមានមែន គឺប្រាជកជាមិនមែនដោយចេតនាសោះឡើយ ។

ជាអវសាន ទ្ធំព្រះករុណា ទ្ធំ ទ្ធនកាយបួងសួង សូមតេជានុភាពនៃព្រះ
បរមសារីរិកធាតុ ជួយអភិបាលរក្សាព្រះតេជព្រះគុណ នឹងអស់លោក-អ្នក
ពំងឡាយ ព្រមពំងជួយអភិបាលរក្សាចំពោះរដ្ឋាភិបាលនឹងប្រជាជននៃ
មហាប្រទេសចិនប្រជាមានិត នឹងមហាប្រទេសឥណ្ឌ ជាដើម សូម
កុសលរាសីដែលកើតអំពីធ្វើបុណ្យព. ស. ២៥០០ ជួយឲ្យបានប្រកបនូវ
សេចក្តីសុខ.ចំរើនគ្រប់ប្រការ ហើយសូមឲ្យកើតមានសាមគ្គីរវាងគ្នានឹងគ្នា
ព្រួតកម្ទាំងផ្សាយព្រះពុទ្ធសាសនា ឲ្យបានជ្ជួតជ្រាបទ្ធទៅក្នុងសកលលោក
ដើម្បីសេចក្តីស្ងប់ ជាហេតុនាំឲ្យពិភពលោកពំងមូល បានន្ទូវសេចក្តីសុខ
សន្តិភាព សូមឲ្យដំណើរនៃអស់លោកដែលនឹងនិមន្ត.អញ្ជើញទៅកាន់

ប្រទេសអស់លោកវិញ ចាន់សុខស្រួលដោយសុវត្ថិភាព សូមឲ្យសត្វលោកចាន់ប្រកបដោយអាយុ: វណ្ណ: សុខ ពល: ទីឆ័ជាតិណា ប៉ើសត្វលោកវស់នៅដែនជាតិណា សូមឲ្យព្រះពុទ្ធសាសនាចាន់វស់នៅហើយរុងរឿងដែនជាតិនោះ កុំបីឃ្លៀងឃ្លាតឡើយ ។

× × ×

ចុះចប់សុន្ទរកថានៃលោក សម ញ៉ាណប្រធានពុទ្ធិកសមាគម អ្នកតំណាងនៃគណៈប្រតិភូពុទ្ធសាសនាចិនប្រជាមានិត ចាន់ថ្លែងន្យវសង្ឃថាជាភាសាចិន, មានចិនម្នាក់ជាអ្នកប្រែភាសាខ្មែរដូចតទៅនេះ:

ខ្ញុំសូមថ្លែងអំណរជាយ៉ាងក្រៃលែង ដោយខ្ញុំចាន់មកជួបលោកប្រធានពុទ្ធិកសមាគម, សមាគមគំលាងសង្គ្រោះសម្រាប់ព្រះសង្ឃខ្មែរ, សមាគមមិត្តពុទ្ធិកវិទ្យាល័យនៅទីនេះ, ទុកជាកិត្តិយសដ៏ប្រសើរចំពោះអាត្មា ។ កិត្តិយសមួយទៀត គឺអាត្មាចាន់មកប្រជុំរួមជាមួយអស់លោក ក្នុងពិធីបុណ្យ ព.ស. ២៥០០ នៃប្រទេសកម្ពុជា ។ អាត្មាមានចិត្តស្កាយពន់ពេកដោយអាត្មាចាន់ទំមន្តមកដល់កំពុងព្រ ពិធីបុណ្យនេះចាន់ធ្វើអស់រយៈវេលាពីរថ្ងៃមកហើយ ។ តែអាត្មាមានចិត្តសោមនស្សជាយ៉ាងក្រៃលែង ដោយមានភ័ព្វចាន់មកគប់ប្រសប់ទំនឹងពួកពុទ្ធសាសនិកជនប្រទេសកម្ពុជា ដែលចាន់ទទួលអាត្មាត្រមទាំងគណៈប្រតិភូចិនប្រជាមានិតដោយសេចក្តីជ្រះថ្លា គោរពគប់អានស្មោះចំពោះ; ការណ៍ដែលអាត្មាចាន់ទទួលបដិសណ្ឋារៈដ៏ប្រសើរនេះ អាត្មាពាំកុំកុងដួងហទយវត្ថុអាត្មាចាំមិនភ្លេច ហើយអាត្មាទឹងយកពណ៌មានដ៏ល្អនេះ ទៅផ្សាយ

ឲ្យពួកពុទ្ធបរិស័ទប្រទេសអាត្មាបានដឹងត្រប់ ។ ត្មា ។

អាត្មាសូមជំរាបលោកប្រជានថា: ប្រទេសចិននឹងប្រទេសកម្ពុជាមិនមែនទើបនឹងស្គាល់ត្មា ក្នុងសមយបច្ចុប្ប្ជន្នេះទេ គឺមានការគមនាគមន៍តាំងពីបុរាណកាល ; ព្រះសង្ឆរ៉ាឡរបានទិមន្តទៅប្រទេសចិនពីសម័យហ្ហូណង់ ចិនឡា ហើយលោកបានប្រែគម្ពីរព្រះត្រ័យបិដកទុកឲ្យជនជាតិចិនសិក្សារៀនសូត្រលុះសព្វថ្ងៃ ។ ប្រទេសចិនក៏បានចាត់លោកជូ-តា-ត្ជូន មកទស្សនាប្រទេសកម្ពុជាពីសម័យ ហ្ហូណង់; លោក ជ-តា-ត្ជូន ក៏បានតែងសៀវភៅមួយទុកជាកស្តុតាងស្រាប់អំពីរឿងនេះ ។ ឥឡូវអាត្មានឹងតណ:ប្រតិកូចិនប្រជាមានិត បានទិមន្តនឹងអញ្ជើញមកកាន់ទីនេះ ដើម្បីធ្វើការប្រាស្រ័យជាថ្មីតទៅទៀត ។

អាត្មាបានទៅមើលប្រាសាទអង្គរ បានយល់អានុភាពឡៃតីសម័យ-អតីត: ។ ក្បាច់ចំឡាក់សិល្ប:មានសភាពសម្បើមអស្ចារ្យ; អាត្មាត្រាន់តែបានឃើញប្រាសាទអង្គរនេះ អាត្មាក៏បានយល់ជាក់ច្បាស់នូវព្រះរាជ-តេជានុភាពព្រះមហាក្សត្រិយ៍ឡៃតុងសម័យនោះ;

អាត្មាតាងនាមពួកពុទ្ធសាសនិកជនប្រទេសចិនប្រជាមានិត សូមសំដែងក្នុងពេលនេះនូវមេត្រីភាពចំពោះពួកពុទ្ធសាសនិកជនប្រទេសកម្ពុជាសូមកាន់ដៃត្មាទៅវិញទៅមករាប់អានត្មាជូចបងប្អូនរួមសាច់ឈាមជាមួយ, ដើម្បីនឹងរចនាព្រះពុទ្ធសាសនា ឲ្យមានវឌ្ឍនភាពមិនត្រឹមទ្វីបអាស៊ីរហូតដល់ទ្វីបអឺរ៉ុប, អាមេរិកនឹងលោកសន្និវាសទាំងមូល ។

អវសាន, អាត្មាសូមជ្យាយកុសលរាស៊ីដែលកើតឡើងពីបុណ្យនេះ

ទុកជាព្រះរាជកុសលថ្ចាយទៅព្រះករុណាជាអម្ចាស់ជីវិតលើត្បូង, សម្តេចព្រះមហាក្សត្រីយានី នឹងសម្តេចព្រះ១បយុវរាជ សូមទ្រង់គង់ជាសុខប្រកបដោយសុវត្ថិជ័យមង្គលត្រប់យ៉ាង, សូមឲ្យលោកប្រធានពុទ្ធិកសមាគម, សមាគមតិលានសង្ត្រោះសម្រាប់ព្រះសង្ឆវ្ទ្ធរ, សមាគមមិត្តពុទ្ធិកវិទ្យាល័យ. សមាជិកសមាជិកា គណៈកម្មាធិការនាយក សមាគមទាំងបី, ពួកពុទ្ធសាសនិកជនទាំងបុរស-ស្ត្រី, ទាំងបព្ចជិតត្រហស្ថបានប្រកបដោយអាយុវណ្ណៈ សុខៈ ពលៈ សូមព្រះពុទ្ធសាសនារីកពេញសកលលោក ។

សង្ក្ថាវិនៃលោកជុវលិសិង្ហៈ

លំដាប់គមក, លោកជុវលិសីង្ហៈអគ្គលេខាធិការមហាពោធិសមាគមប្រទេសឥណ្ឌាតំណាងសមាគមនេះ, បានថ្វែងនូវសង្ក្ថាមួយជាភាសាអង់គ្លេស ខ្មែរម្នាក់ជាអ្នកប្រែពីភាសាអង់គ្លេសមកជាភាសាខ្មែរថា:

ខ្ញុំមានចិត្តសោមស្សជាយ៉ាងក្រៃលែងដោយខ្ញុំបានមកជួបក្នុងពេលនេះ នូវលោកប្រធានពុទ្ធិកសមាគម, សមាគមតិលានសង្ត្រោះសម្រាប់ព្រះសង្ឆវ្ទ្ធរ, សមាគមមិត្តពុទ្ធិកវិទ្យាល័យ ។

មួយទៀត ខ្ញុំត្រេកអរដោយខ្ញុំបានជួបលោកសមញ្ញាណ, លោកវ៉ាយ-ប៊ុក ដែលខ្ញុំបានកប់ប្រសប់ពីកាលបុណ្យឆ្ពុទ្ធជយន្តិប្រទេសឥណ្ឌាពីឆ្នាំមុន ។ ត្រេកអរទីបី គឺខ្ញុំបានចូលមករួបរួមក្នុងពិធីបុណ្យរំលឹក ២៥០០ ព្រះវស្សានៃបរិនិព្ចានព្រះបរមសម្ពុទ្ធ ជាមួយនឹងអស់លោករាល់គ្នា ។

– មួយទៀត, ខ្ញុំបានទៅទស្សនាប្រាសាទអង្គរធំ នឹងអង្គរវត្ត ខ្ញុំមានចិត្តស្រប់ស្រង្គពន់ពេក ចំពោះក្សាច់សិល្ឆៈដ៏វិចិត្រនៃប្រាសាទទាំង

នោះ ហើយទ្ចុំតិតថា សម័យអង្គរប្រទេសកម្ពុជាថ្ពុំថ្ពើងណាស់ ។

- ប្រទេសសេរីលង្ការបានទាយថា "តាំងពី ព. ស.២៥០០ ទៅ, ព្រះពុទ្ធសាសនានឹងចម្រើនរុងរឿងរីកពេញសកលលោក" ។ ប្រទេសវៀណ្ណ្ឌមានអ្នកកាន់ព្រះពុទ្ធសាសនាតែ ៣០០.០០០ នាក់ ក្នុងចំណោមប្រជាជនវៀណ្ណ្ឌ ៤០០ លាននាក់ ។ ពីសម័យព្រះបាទអសោក, ព្រះបាទកនិស្ក:, ប្រទេសវៀណ្ណ្ឌ បាននិយមកាន់ព្រះពុទ្ធសាសនាដោយកាតប្រើន ។ តឹនៅរជ្ជកាលព្រះបាទអសោក, ព្រះអង្គទ្រង់បានចាត់ព្រះភិក្ខុសង្ឆឲ្យនិមន្តទៅផ្សាយព្រះពុទ្ធសាសនាគ្រប់ទិសជំបន់ ។ តាំងពីព្រះបាទកនិស្ក:តមក, ព្រះពុទ្ធសាសនានៅប្រទេសវៀណ្ណ្ឌ ក៏ទុព្វលកាពតាមលំ.ជាប់ដោយមានសង្ត្រាម នឹងពួកមហាម៉តជាប្រើនលើកប្រើនគ្រា ។ នៅប្រ-ទេសនោះសព្វថ្ងៃព្រះពុទ្ធសាសនាបានស្ថិតនៅតែត្រង់លុម្ពិនី, ពុទ្ធគយា, សញ្ជី, បង្គ័ល, សារណាត់ ។ មហាពោធិសមាគមបានទបត្តិទ្បើងជាង ៦០ ឆ្នាំមកហើយ, បានព្យាយាមប្រឹងប្រែងផ្សាយព្រះពុទ្ធសាសនាគ្រប់ដ្ឋនិតមជនបទ ។ ទើបមកដល់សម័យបច្ចុប្បន្ន, ដ្ឋាភិបាលប្រទេសវៀណ្ណ្ឌ បានចាត់ក្រុមបុរាណវត្ថុ ឲ្យទៅជីកគាស់កកាយរកកេរ្តឹតំណែលព្រះពុទ្ធសា-សនា ។ ទើបចាត់ឲ្យមានមនុស្សទៅស្ថិតនៅថែរក្សាកេរ្តឹតំណែលទាំងនោះ ឲ្យគង់រង់តទៅអនាគត បានជាប្រទេសវៀណ្ណ្ឌ ធ្វើបុណ្យពុទ្ធជយន្តិ តាំងពីខែទសកា ១៩៥៦ រហូតមកដល់ខែទសកា ១៩៥៧ ។ មានជុកទ័រមួយជាពួកសុទ្រះនាម អម៉ឃេកា បានបួសក្នុងពុទ្ធសាសនា ហើយមានសូទ្រះដទៀតកន្ទះលាននាក់ បានបួលមកបួសតាមលោកជុកទ័រនេះដែរ ។

– ការប្រាស្រ័យទាក់ទងរវាងប្រទេសឥណ្ឌានឹងប្រទេសកម្ពុជា តើតមានឡើងតាំងពីសម័យបុរាណ ។ ក្នុងរវាង ២ ឬ ៣ ឆ្នាំនេះ ប្រទេសទាំងពីរក៏មានការគមនាគមន៍ជាញឹកញាយ មានការបញ្ជូនព្រះបរមសារីរិកធាតុមកធ្វើបុណ្យជាច្រើនឡើងវិញ នៅក្នុងព្រះ ដោយការទទួលគ្គមមហាពោធិសមាគមប្រទេសឥណ្ឌា ព្រះពាជដំណើរសម្តេចព្រះទេបយុវរាជពីរលើកដំណើរតណៈប្រតិភូប្រទេសកម្ពុជាទៅកាន់បុណ្យពុទ្ធជយន្តិ, ដំណើរបណ្ឌិតនេហ៍រូមកកាន់ប្រទេសកម្ពុជាជាដើម ។ ពេលនេះ ខ្ញុំបានមកចូលរួមក្នុងពិធីបុណ្យ ព.ស. ២៥០០ នៃប្រទេសកម្ពុជា ដើម្បីទំនាក់ទំនងមេត្រីភាពឲ្យកាន់តែមាំមួនឡើង ។

– ខ្ញុំអាចយល់បានថា: ដល់ពុទ្ធសាសនាឃុំកាលត្រប់ ៥០០០ ព្រះវស្សា, មុខជាព្រះពុទ្ធសាសនាមានវឌ្ឍនភាពជាយ៉ាងក្រៃពេកហើយប្រទេសនានាក្នុងសកលជម្ពូទ្វីប នឹងនិយមកាន់ព្រះពុទ្ធសាសនា ។ ដល់ពេលនោះ មុខជាគ្រប់ប្រទេសនឹងធ្វើពិធីបុណ្យ ព.ស. ៥០០០ ។ ប្រទេសកម្ពុជានឹងធ្វើបុណ្យនេះដែរ ។ តែដល់ពេលនោះ, ខ្ញុំអនិច្ចកម្មមិនដឹងជាប៉ុន្មានដង ។ បើខ្ញុំរស់នៅប្រទេសណា ខ្ញុំសុំឲ្យប្រទេសកម្ពុជាអញ្ជើញខ្ញុំមកកាន់ពិធីបុណ្យ ព. ស. ៥០០០ នៅភ្នំពេញម្តងទៀត ។

ជាអវសាន, ខ្ញុំសូមប្រមូលកុសលដែលកើតឡើងអំពីពិធីបុណ្យ ព. ស. ២៥០០ នឹងបុញ្ញភាគីដែលមហាពោធិសមាគមប្រទេសឥណ្ឌាបានធ្វើចំពោះព្រះពុទ្ធសាសនា ថ្វាយទៅព្រះករុណាជាអម្ចាស់ជីវិតលើក្បាល, សម្តេចព្រះមហាក្សត្រីយានី, សម្តេចព្រះទេបយុវរាជ សូមទ្រង់បាន

ប្រកបដោយសម្សូណិភាព, សន្តិភាពអស់កាលជាយូរអង្វែង សូមលោកប្រធានពុទ្ធិកសមាគម, សមាគមគិលានសង្គ្រោះសម្រាប់ព្រះសង្ឆវិទ្ធរ, មិត្តពុទ្ធិកវិទ្យាល័យ លោកស្រី-អ្នកស្រីជាក្រុមអភិបាលសមាគមទាំងបី សូមឲ្យមានជោគជ័យសិរីសួស្តីគ្រប់យ៉ាង, សូមពុទ្ធសាសនិកជនទាំងបព្វជិតគ្រហស្តនៅប្រទេសកម្ពុជាបានសេចក្តីសុខ-ចម្រើន, សូមព្រះពុទ្ធ-សាសនាផ្សាយទូទៅពេញសកលលោក . . . . ។

លុះចប់សង្តថាហើយ ពុទ្ធិកសមាគមបានប្រគេនទៅព្រះសង្ឆតំណាងពុទ្ធសមាគមចិនប្រជាមានិត នូវពិភានហូលមួយដែលមានចារិកពុទ្ធប្រវត្តិ និងសៀវភៅធមិផ្សេង ។; សមាគមមិត្តពុទ្ធិកវិទ្យាល័យបានជូនទៅក្រៀវកិត្តិយសពុទ្ធសមាគមចិនប្រជាមានិត នូវសៀវភៅសាមគ្គីធមិ ២០ ក្សាល ។

ពិធីជប់លៀងក្រយាហ៉ារបានបញ្ចប់នៅម៉ោង ១៣.៣០ នាទី ។

×

× +

រឿងផ្សេងៗនៃពិធីបុណ្យ ព.ស. ២៥០០

កាលពីថ្ងៃទី ១៤-ឧសភា គណៈប្រតិភូនានាប្រទេសបានអញ្ជើញទៅទស្សនាប្រាសាទអង្គរធំ, អង្គរវត្ត, ស្រះស្រង់ បាកយ, តាមវង់ធំ, វង់តូច ។ លោកក្រេងនីលអនុព័ន្ធពតិមាននៃក្រសួងការពារប្រទេសបានទទួលការៈជាអ្នកនាំនូវគណៈប្រតិភូទាំង ១៦ ប្រទេសទៅកាន់ប្រាសាទទាំងនោះ ។ មានការរៀបចំទទួលក្រៀវកិត្តិយសនោះជាយ៉ាងឧឡារិកនៅបាក៉យដែលស្ថិតនៅ ១៦ គីឡូម៉ែត្រពីវិទត្រសៀមរាប ។ គណៈ

កម្មការប្រតិបត្តិការបុណ្យ ចាត់ឲ្យលេងល្ខោនមានតាំងសម័យបុរាណ
និងសម័យថ្មីទើប ហើយពួកនាងនាដការស្លៀកពាក់សំពត់មានពិណក្នុ
ផ្ទៃក្រលើបរលង់, ចំកម្មុខស្រស់ប៉ែប្រែបានកំដរក្បាច់គួរឲ្យពិតពិលរមិល
មើល ដោយមានក្រមខ័ណ្ឌអគ្គិ ប្រកបដោយលំអដាយ៉ាងវិក្រលែង
ព្រមទាំងគោមក្ងើងអគ្គិសនីបញ្ចេញពិណគ្រប់យ៉ាង កណ្តាលកត្រៃដែល
មានព្រះចន្ទភ្លឺចាំងចែងលើនកាល័យ ឈើត្រៃមានស្លឹកខៀវខ្ចីស្រងាត់
ធ្វើឲ្យនាំតាំងនោះ មានសម្រស់ ព្រមទាំងលំអដូចជានាងទេវធីតាចុះពី
សួគាល័យ ។

លុះដល់ថ្ងៃទី ១៥ ខែសីហា, ក្មេវិកត្តិយសបានធ្វើដំណើរទៅកាន់
ប្រាសាទបន្ទាយស្រី ។ ក្នុងពេលនោះ គណៈប្រតិភូប្រទេសម៉ាលែស៊ី
ដោយបានក្រឡេកទៅឃើញប្រាសាទសន្ធោសន្ធៅផុះចេញពីព្រៃ មាន
ព្រឹក្សាលតាវល្លិ៍ស្លឹកខៀវស្រស់ ដូចជាមានទេវតានិម្មិតចេញពីនគរ
គោកធ្លកក៏លាន់មាត់ថា ឧជាអព្ភូតហេតុដ៏ស្ងប់ស្ងែងដោយមានសម្រស់
គួរឲ្យចាប់ចិត្តថែមទាំងមានតលភាពទៀត ។

ល្ងាចដល់ថ្ងៃទី ១៦ ខែសីហា, ក្មេវិកត្តិយសនោះ ក៏លែងត្រឡប់មក
កាន់ពាជធានីភ្នំពេញវិញ ដែលបានទទួលនូវការដង្ហែលៀងក្រយោហារ
ព្រមទាំងកិច្ចទស្សនាល្ខោនព្រះពាជទ្រព្យនៅវិមានចន្ទ្រាយ ។

ដល់ថ្ងៃ ១៧ ខែសីហា, ពាជរដ្ឋាភិបាលបានអញ្ជើញក្មេវិកត្តិយសនោះ
ទៅទស្សនាតាមទន្លេធំដោយក. ណ្តាត តម្រង់ទៅតាមមជ្ឈមណ្ឌលកសិកម្ម

ព្រេកលាភស្ថិតនៅទាងមាត់ទន្ទេឯស្ពាំ ចម្ងាយ ៣០ គីឡូម៉ែត្រពីរាជ-ធានីភ្នំពេញ ។

\+ × ×

អរិសាងកថា

ពិធីបុណ្យ ព.ស.២៥០០ ធ្វើឲ្យពួកពុទ្ធបរិស័ទទាំងបុរស-ស្ត្រី ទាំងត្រហស្ត.បព្វជិត ទាំងជនបរទេសនឹងជនជែលស្ថិតនៅក្នុងប្រទេស មានមនោសញ្ចេតនាដ៏សាមនស្សពន់ពេក ។ សេចក្តីសាមនស្សនោះកើតមានឡើងតាំងពីថ្ងៃបបមនៃពិធីបុណ្យរហូតដល់ថ្ងៃបង្ហើយពិធីបុណ្យដោយនឹកឃើញថា :

ឃើងពេញជាមានក័ព្វសំណាង ដែលបានកើតទាន់ពិធីបុណ្យ ព.ស.២៥០០ ; ដោយឃើងមានការចាប់អារម្មណ៍ ៦ យ៉ាង :

ក) សំណង់នឹងបុស្សុកនឹងអគារនៃពិធីបុណ្យ មានសម្រស់ល្អគួរជាទីទស្សនាពន់ពេក ;

ខ) ព្រះសង្ឆបួសថ្មី នឹងឧបាសកឧបាសិកាអ្នកកាន់អតិរេកសីលរាប់មឺននាក់ មានពណិលឿងលាយចំរុះនឹងពិណសត្រាច់ព្រោងព្រាតក្នុងមណ្ឌលបុណ្យ :

គ) ទាយកទាយិកាបានធ្វើទេយ្យទានចង្ហាន់បិណ្ឌបាត មានសកាពដ៏បរិបូណ៌ហួសប្រមាំណដោយសទ្ធាដ៏ខ្ជាំងក្លា ;

ឃ) គេឃើញជាយ៉ាងជាក់ស្តែង ថាព្រះករុណាជាអម្ចាស់ជីវិត

លើត្សង និងសម្តេចព្រះមហាក្សត្រិយានី ទ្រង់ជាព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៍ជ៉ពិត ។ ហើយសមនឹងព្រះរាជកិត្តិយសដោយមានផ្នែងខាងបព្វជិត មានសម្តេចសង្ឆនាយកទាំងពីរគណៈ រាជាគណៈហានានុក្រម ព្រះថេរានុត្តរៈទាំងឡាយ; ខាងគ្រហស្ត មានសម្តេចព្រះទបយុវរាជ សម្តេចព្រះរាជកនិដ្ឋារស្មីសោភ័ណ សម្តេចក្រុមព្រះស៊ីសុវត្ថីមុនីរ៉ៃត សម្តេចចៅហ្វាយរាំងវរៈវ៉ៃងជ័យ សមាជិកទត្តមក្រុមប្រឹក្សាអមព្រះរាជា, សមាជិករដ្ឋាភិបាល នាមុឹនសព្វមុខមន្ត្រីធំតូច ហែហមព្រះអង្គជាព្រះរាជបរិពារទៅកាន់ព្រះពន្ធាកិត្តិយស ;.

ង) គេឃើញគ្រឿវបរទេស ដែលមកពីប្រទេសនានាក្នុងពិភពលោក, ស្លៀកពាក់តាមប្រពៃណីជាតិ ពោលភាសាជាតិ;

ច) គេឃើញក្ឆួនរថយន្ត មាលាវិចិត្តរចនាដោយកម្រងផ្កា មានរំយោលក្បាច់សិល្បៈគ្រប់យ៉ាងគ្រប់ពណ៌ តុបតែងទៅជារឿងពុទ្ធប្រវត្តិ តាំងពីព្រះអង្គទ្រង់ប្រសូតនៅលម្ពិនី រហូតដល់ព្រះអង្គទ្រង់ចូលកាន់បរិនិព្វាន; រថយន្តខ្ទះយកបុជ្ជាមករចនាជារូបប្រុសស្រីតាមរឿងពុទ្ធប្រវត្តិនោះ, រថយន្តខ្ទះមានរូបតំនូរគ្រប់យ៉ាង បង្ហាញឲ្យឃើញជាក់ស្តែងនូវព្រិត្តិការណ៍ផ្សងៗ ដែលមានមកក្នុងរឿងនោះ ។

ក្រៅពីនេះ នៅមានល្ខោនជាតិរួបរួមនឹងល្ខោនព្រះរាជទ្រព្យលេងរឿងពុទ្ធប្រវត្តិ, មានការចែកសៀវភៅធមិ ដោយក្រសួង ដោយក្រុមសមាគម ឬបុគ្គលជាសាមិទាន ជាច្រើនមុឹនក្បាល សម្រាប់បូជាចំពោះបុណ្យ ព.ស ២.៥០០ ;

ពិធីបុណ្យនេះប្រៀបដូចជាស្ពានខ្ពង់ជាស់សតិសម្បជញ្ញៈពួកពុទ្ធសាស-
និកជនគ្រប់ប្រភេទឲ្យនឹកលើក ថាខ្លួនកើតមកជាមនុស្ស ត្រូវប្រព្រឹត្ត
ធម៌ជាកុសល ដែលនាំមនុស្សឲ្យតាំងនៅក្នុងមនុស្សធម៌ ។

ក្រៅពីនេះ, ពិធីបុណ្យអាចញុំាងប្រជាជនគ្រប់នានាប្រទេសក្នុង
សកលលោក ដែលចូនមកប្រមូលក្នុងបុណ្យ ឲ្យយល់តម្លៃភាតភាព
សេរីភាព សាមគ្គីភាព ដែលជាហេតុធ្វើលោកឲ្យមានសន្តិភាព ។

ការដែលចាប់អារម្មណ៍មួយទៀត គឺព្រះករុណាជាអម្ចាស់ដ៏ថ្កៅលើ
ត្បូង ទ្រង់សម្តេចព្រះមហាក្សត្រិយានីទ្រង់ស្តេចយាងមកគាន់ពិធីបុណ្យ
នេះ ដោយព្រះកដហឫទ័យសោមនស្សពន់ពេក ទ្រង់ជាក់ជាក្រាលថ្ងៃ,
បំពេញព្រះរាជកុសលគ្រប់យ៉ាង ទុកជាបុញ្ញាលាភដ៏ប្រសើរចំពោះ
ប្រទេសកម្ពុជា ។

មួយទៀតចាប់អារម្មណ៍ចំពោះក្បួនរថយន្តមាលវិចិត្រចូនរៀ
ប្រទក្សិណមណ្ឌលបុណ្យជាយ៉ាងទន្ទឹកកែ គួរឲ្យពេចពិលរមិលមើល
ពន់ពេក ព្រោះរថយន្តគាំងនោះ ចូនបញ្ចេញនូវកម្លាំងសិល្ប:
ត្រប់យ៉ាង មានរំយោលបុប្ផាក្រងរំលេចពណ៌ក្រហមខៀវ-លឿង-បៃតង
ហើយមានរូបគំនូរស្តីអំពីពុទ្ធប្រវត្តិបង្ហាញឃើញជាក់ស្តែង នូវដីវភាពនៃ
ព្រះបរមសម្មាសម្ពុទ្ធជាម្ចាស់ ដូចជាយើងចូនឃើញព្រះបរមរូបព្រះអង្គ
គង់ជាមានៅឡើយ ។ ទេសយប់ ល្ងាចជាតិបូរមនឹងល្ងាចព្រះ
រាជទ្រព្យចូនពាំរឿងពុទ្ធប្រវត្តិថែមទៀតនៅក្នុងឆាកដែលមានភ្លើងអគ្គិសនី
គ្រប់ពណ៌បញ្ចាំងឲ្យឃើញទិដ្ឋភាពធម្មជាតិ, មនុស្សសត្វទេវតាលាយចំរុះ

ឆ្នា មាននាឥនាជកាប្រកបដោយរូបធោមលោមពណិល្ហស្រស់ប្រិមប្រិយ
បញ្ចេញសំឡេឥពិរោះអស្ចារ្យ ឆ្លូវឲ្យសវនាពន់ពេក មានគ្រូឥឆ្លូវ្យតន្ត្រី
ដ៏ពីរោះ ធ្វើឲ្យធាកនោះហាក់ជាស្ថានសួគ៌មួយនៅក្នុឥលោកនេះ ។
លំជាប់តមកយើឥចាប់អារម្មណ៍ ចំពោះការចែកសៀវភៅធម៌ជាច្រើនមុឺន
ក្សាលសឲ្យយើញថាបុគ្គលសាមីទាន ហ៊ានចាយទ្រព្យច្រើន ដើម្បី
យកសៀវភៅនោះមកចែកជាធម្មទានជាការប្រពៃណាស់ ។

ការចាប់អារម្មណ៍ជាអវសាន ចំពោះការប្រកួតប្រជែឥព្រះនាឥសុជាតា
ដែលមាននាឥកញ្ញាកាន់ក្លឥបុប្ជាឈរជាជួរហែរត្រាច់លើវេទិកា ចំពោះ
មុខតណៈកម្មាធិការពិនិត្យឲ្យពិន្ទុ, នាឥខ្ទះស្ទ្រិកសំពត់ជាមួឥបៃតឥ ខ្ទះ
ស្ទ្រិកចារបាប់ត្រប់ពណ៌តាមសម៉យថ្មី ខ្ទះពាក់អាវពណ៌ក្រហមធេះ ខ្ទះ
ពានាកាម៉ាស៊ីនួនខ្ចី ភក្ត្រញញឹមស្រស់ ជំណើរទន់ល្ទន់ល្ទាសឆ្លូ
ឲ្យភិសម៉យ ឯក្លឥបុប្ជានោះមានខ្ទះរចនាជាសីល្យៈដ៏វិចិត្រខ្ទះ ជាផ្ទិតមាន
រំលេចពណ៌ត្រប់យ៉ាឥ ខ្ទះជាសត្វលាយបុប្ជានឹឥស្ទឹកព្រឹក្សជាតិនៅជា
ក្សាច់រូបសត្វឆ្លូវឲ្យពិចពិលរមិលមើល ។

ការធ្វើបុណ្យក្នុឥព្រះពុទ្ធសាសនា មានការធ្វើមាយបូជា, វិសាខ
បូជាជាដើម ក៏ជាកិច្ចមួយដើម្បីឲ្យពួកពុទ្ធសាសនិកជនឹករលឹកជល់
ព្រះបរមសម្ពុទ្ធជាម្ចាស់ដែលទ្រឥ់ព្រះរាជទានឧរាទ ដើម្បីឲ្យសត្វប្រព្រឹត្ត
ប្រតិបត្តិតាមយកបុណ្យកុសលត្រប់យ៉ាឥ ព្រមទាំឥមានសទ្ធាជ្រះថ្លាចំពោះ
គុណព្រះពុទ្ធព្រះធម៌ព្រះសង្ឆ ដែលដឹកនាំសត្វទៅកាន់ត្រើយនាយ
ឥព្រះនិព្វាន ជាស្ថានលះបឥ់នៅអាសវកិលេស សង្សារចក្រ, តណ្ហា,

អកុសលត្រប់យាំង ។ មធ្យាបាយមួយទៀត គឺកិច្ចការសាងសង់វត្តអារាម, ព្រះវិហារកុដិ, សាលាបាលីជាដើម ក៏ជាកងការកុសលសម្រាប់ឲ្យមនុស្ស សត្វបរិច្ចាគទ្រព្យសម្បត្តិលះបង់នូវសេចក្តីកំណាញ់ចេញ ។

មធ្យាបាយក្រៅពីខាងលើនេះ, មានការស្ថាបនានូវសមាគមពុទ្ធ-សាសនា ដូចពុទ្ធិកសមាគម, សមាគមមិត្តពុទ្ធិកវិទ្យាល័យ, សមាគមគិលានសង្គ្រោះសម្រាប់ព្រះសង្ឆវិទ្ធ ដែលមានគណៈកម្មាធិការនាយក ប្រជុំតាមកាលៈទេសៈ ដើម្បីនឹងប្តូរយោបល់គ្នា ដើម្បីនឹងរចនាព្រះ ពុទ្ធសាសនាឲ្យមានវឌ្ឍនភាពតទៅអនាគត ។

មធ្យាបាយឯទៀត មានជាអនេកប្បការ មានការគមនាគមន៍នឹង សមាគមពុទ្ធសាសនានានាប្រទេស, សាលាពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត, ពុទ្ធសាសនបណ្ឌិត្យ, ក្រុមជំនុំព្រះត្រ័យបិដក, ពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ ការបោះពុម្ពផ្សាយសៀវភៅធម៌, ទស្សនាវដ្តីជាដើម ក៏ជាហេតុឲ្យព្រះពុទ្ធសាសនាចម្រើនរុងរឿងតទៅមុខបាន ។

×

× ×

ប្រកាសតាំងគណៈកម្មាធិការនាយកសម្រាប់ចាត់ពិធីបុណ្យ ព.ស.២៥០០

ប្រកាសលេខ ១១៨-៤១៩ ចុះថ្ងៃទី ១៨ មករា-៧ កុម្ភៈ១៩៥៧ តែងតាំងគណៈកម្មាធិការនាយក សម្រាប់ទទួលការៈចាត់ការបុណ្យ ព.ស. ២.៥០០ របស់ប្រុទេសកម្ពុជា ដូចមាននាមខាងក្រោម:

១-	អ្នកទកញ៉ាំទេសរដ្ឋមន្ត្រី ទទួលបន្ទុកខាងសន្តិសុខជាតិ	
	និងធម្មការ	ប្រធាន
២-	សម្តេចសង្ឃនាយកគណៈមហានិកាយ	ប្រធានកិត្តិយស
៣-	សម្តេចសង្ឃនាយកគណៈធម្មយុត្ត	-ដ-
៤-	អ្នកទកញ៉ារដ្ឋមន្ត្រីក្រសួងយុត្តិធម៌	សមាជិក
៥-	" ក្រសួងដែនការកសិកម្ម និងឧស្សាហូបនិយកម្ម	"
៦-	អ្នកទកញ៉ារដ្ឋលេខាធិការ ក្រសួងយោសនាការ	
	និងការងារ	"
៧-	" ក្រសួងសិក្សាធិការជាតិ,កីឡាយុវជននិងសិល្បការ	"
៨-	" រដ្ឋលេខាធិការក្រសួងសាធារណសុខាភិបាល	
	និងសង្គមកិច្ច	"
៩	" រដ្ឋលេខាធិការក្រសួងកិច្ចការសេដ្ឋកិច្ច	"
១០-	" ក្រសួងចរិកាជាតិ	"
១១-	" ការពារប្រទេស	"
១២-	" សាធារណការនិងទូរគមនាគមន៍ . . .	"
១៣-	" អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ . . .	"
១៤-	" អគ្គលេខាធិការក្រសួងការបរទេស	"
១៥-	លោកអធិបតី សមាគមមិត្តពុទ្ធិកវិទ្យាល័យ . .	"
១៦-	" អធិបតីពុទ្ធិកសមាគមកម្ពុជរដ្ឋ	"

១៧. លោក អធិបតីសមាគមតិលានសង្គ្រោះបំពោះ

ព្រះសង្ឆ . . . . . សមាជិក

១៨. លោកតំណាងក្រុមប្រឹក្សាព្រះកជអាណាចក្រ "

១៩. " តំណាងរដ្ឋសភា . . . . . "

២០ " តំណាងក្រសួងព្រះបរមកជវាំង លេខាធិការ

២១. លោក មៅ-ភាអុន.នាយការិយាល័យក្រសួងធម្មការ "

២២. លោក មែ-ជ៉ាន់ យោក្ស័ត្រក្រសួងធម្មការ អនុលេខាធិការ

២៣. លោក ឌី-រ៉ង យោក្សាត់ក្រសួងធម្មការ អនុលេខាធិការ

×

× ×

ប្រកាសតាំងគណៈកម្មាធិការប្រតិបត្តិការបុណ្យ

ព.ស. ២៥០០

ប្រកាសនៃអ្នកទកញ៉ាទេសរដ្ឋមន្ត្រីទទួលបន្ទុកខាងសន្តិសុខជាតិនឹងធម្មការ ប្រធាននៃគណៈកម្មាធិការនាយកពិធីបុណ្យ ព.ស. ២.៥០០ ទៃងតាំងគណៈកម្មាធិការប្រតិបត្តិការខាងសេចក្តីសម្រេចគណៈកម្មាធិការនាយកពិធីបុណ្យ ព.ស ២.៥០០ ដូចខាងក្រោមនេះ:

ប្រធាន: លោកមៀច.គន្ធ ចៅហ្វាយក្រុងភ្នំពេញ;

អនុប្រធាន: លោកសាវិន.ធាក នាយកការិយាល័យតំណាងក្រសួងមហាផ្ទៃ:

អនុប្រធាន: លោក ប៉ុក-សំអាន វរសេនិយត្រី មេបញ្ជាការកងវរសេនា
ធំទាងរថក្រោះ នៃកងសេន្យានុភាពទេមរភូមិន្ទ;
សមាជិក: លោក យ៉ែម-ឃុត នាយកការិយាល័យ តំណាងក្រសួងធម្មការ;
" លោកជា-អ៊ុន នាយកវងនៃក្រុមព្រះរាជពិធីសារ តំណាង
អគ្គនាយកមន្ទីរព្រះបរមរាជវាំង;
" លោក វ៉ាយ-ស្មុត នាយកក្រុមប្រៃសណីយទូរលេខទូរសព្ទ
តំណាងសមាគមទាងពុទ្ធសាសនា;
" លោក ពៅ-វ៉ា វិស្វករនាយកក្រុមសាធារណការ តំណាង
លោកចៅហ្វាយក្រុង ភ្នំពេញ;
" លោក យ៉ឿន-ចឹម អគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ
តំណាងក្រុមពុទ្ធសាសនបណ្ឌិត្យ;
" លោក សាន-ណាក នាយកវងយោសនាការ តំណាង
ក្រសួងយោសនាការ;
" លោក ទេស-យ៉ង់, ទីប្រឹក្សាសាលាទទរណ៍ តំណាង
សមាគមពុទ្ធសាសនា;
" លោក អ៊ុង-ជីវ-អាន អធិការផែនការណ៍ តំណាងក្រសួង
ផែនការណ៍;
" លោក ពេជ្រ-ហេង នាយការិយាល័យ តំណាងក្រសួង
កិច្ចការបរទេស;

សមាជិក លោក ជា-អួម នាយកនៃសាជារណ សិក្សាធិការតំណាន
ក្រសួងសិក្សាធិការ;

" លោក ផែន-កន្ធែល មន្ត្រីសុខាភិបាលតំណាងក្រសួង
សាជារណសុខាភិបាល;

" លោក ហិន-ឌី នាយទុទ្ធកាល័យ តំណាងក្រសួងសេដ្ឋ-
កិច្ចជាតិ;

" លោក លឿង-ណាល់ នាយសេនាធិការការពារលើផ្ទៃផែនដី
តំណាងក្រសួងសន្តិសុខជាតិ;

×

× ×

វិធីនមស្ការព្រះរត្នត្រ័យ

ក្នុងទុកាសបុណ្យ ព.ស. ២៥០០

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស (៣ដង)

"សូមនមស្ការ ចំពោះព្រះភគវន្តមុនី អរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ";

(ក្រាបថ្វាយបង្គំម្តង)

សម្មាសម្ពុទ្ធោ វត សោ ភគវា, យោ សព្ទទុក្ខស្ស
បហានាយ ធម្មំ ទេសេតិ, តំ សម្មាសម្ពុទ្ធំ អាទរេន

ឧមស្ឈាម(១) "ព្រះកតវន្តមុនីអង្គណា ទ្រង់ត្រាស់សំដែងនូវធម៌ ដើម្បីកំចាត់បង់ នូវសេចក្តីទុក្ខទាំងពួង, ព្រះកតវន្តមុនីអង្គនោះ ជាព្រះសម្មាសម្ពុទ្ធពិតមែន, យើងខ្ញុំព្រះអង្គ(២) សូមថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធអង្គនោះ ដោយគោរព"

(ក្រាបថ្វាយបង្គំម្តង) ។

ឧយ្យានិកោ វត សោ ឆម្មោ, យោ សព្វទុក្ខស្ស បហានាយ ស្វាក្ខាតោ តេន កតវតា, តំ ឆម្មំ អាទរេន ឧមស្ឈាម "ព្រះធម៌ណា ដែលព្រះកតវន្តមុនីអង្គនោះ ទ្រង់ត្រាស់សំដែងហើយ ដោយប្រៃព ដើម្បីកំចាត់បង់នូវសេចក្តីទុក្ខទាំងពួង, ព្រះធម៌នោះ ជាធម៌ស្រោចស្រង់សត្វពិតមែន, យើងខ្ញុំព្រះអង្គសូមថ្វាយបង្គំនូវព្រះធម៌នោះ ដោយគោរព";

(ក្រាបថ្វាយបង្គំម្តង)

សុប្បដិបន្នោ វត តស្ស កតវតោ សោ សាវកាសង្ឃោ, យោ សព្វទុក្ខស្ស បហានាយ បដិបន្នោ, តំ សង្ឃំ អាទរេន ឧមស្ឈាម "ព្រះអរិយសង្ឃណា លោកប្រតិបត្តិដើម្បីកំចាត់បង់ នូវសេចក្តីទុក្ខទាំងពួង, ព្រះអរិយសង្ឃនោះ ជាសង្ឃ-

---

១-២ សម្រាប់ឆ្នាប្រើនតាំងពីពីរនាក់ឡើងទៅ; បើតែម្នាក់ឯងត្រូវថា "ឧមស្ឈាមិ" ថា "ខ្ញុំព្រះអង្គ": បើសុទ្ធតែស្ត្រី ឆ្នាប្រើន ត្រូវប្រើពាក្យថា "យើងខ្ញុំម្ចាស់" ស្ត្រីតែម្នាក់ ត្រូវប្រើពាក្យថា "ខ្ញុំម្ចាស់" ។ ទាំងបាស៊ីទាំងសម្រាយ ទាងព្រះធម៌ទឹងព្រះសង្ឃ ក៏មានន័យដូចនេះដែរ ។

សាវ៉ក នៃព្រះកគវន្តមុនីអង្គនោះ លោកប្រតិបត្តិដោយប្រពៃពិតមែន, យើងខ្ញុំព្រះអង្គសូមថ្វាយបង្គំ នូវព្រះអរិយសង្ឆនោះ ដោយគោរព"

(ក្រាបថ្វាយបង្គំម្តង)

× × ×

នមស្ការព្រះបរមសារ៉រិកធាតុ

ក្នុងឧកាសបុណ្យ ព.ស.២៥០០

មាយវស្ឆាន៉ សម្ពុទ្ធោ កកវា យោ តថាគតោ
សមស៉ត្យាយុកកាលេ បរិន៉ព្វាយ៉ សោ មុន៉
តស្ឆ សារ៉រិកា ធាតុ អម្ហាកំ បមុទេ ឋិតា
ឥធាគតោ ច សោ សត្ថា ធរមានោវ តិដ្ឋតិ
សក្ការេហាកិមូជេម តំ នមស្ឆាម សាធរំ
សាធុ នោ កកវា នាថោ សព្វញ្ញូ សន្ត៉ធាយកោ
ឥមេ ធល៉ធូសក្ការេ អនុកម្ឆាយ កណ្ហាតុ
ធីយរត្តំ ហ៉ិតាយេវ សុទាយម្ហាកក សព្វធា ។

"ព្រះតថាគត កគវន្តមុនី អង្គណា ទ្រង់បានត្រាស់ហើយ (ឋិតនៅ) អស់កាល ៤៥ ឆ្នាំ, ព្រះតថាគតអង្គនោះ ព្រះអង្គជាមហាមុនី ទ្រង់បរិនិព្វានហើយ ក្នុងកាលដែលព្រះអង្គមានព្រះជន្មាយុ ៨០ ឆ្នាំគត់; (ឥឡូវ) ព្រះបរមសារ៉ រិកធាតុនៃព្រះអង្គមកប្រតិស្ឋាន ក្នុងទីបំពោះមុខនៃយើងខ្ញុំព្រះអង្គ ហាក់ដូចជាព្រះបរមសាស្តាអង្គនោះទ្រង់គង់ព្រះធរមាន

នៅឡើយ ស្តេចយាងមកគង់ក្នុងទីនេះ; យើងខ្ញុំ សូមបូជាចំពោះព្រះអង្គ ដោយគ្រឿងសក្ការៈទាំងឡាយ សូមនមស្ការព្រះអង្គ ដោយគោរព; សូមព្រះកគវន្តមុនី សព្វញ្ញុព្ធ បរមលោកនាថ ដែលតែងតែប្រោសប្រទានសន្តិសុខដល់សត្វលោក ទ្រង់ព្រះមេត្តាប្រោសទទួលនូវគ្រឿងសក្ការៈទាំងឡាយរបស់យើងខ្ញុំព្រះអង្គ ដែលជាសក្ការបូជារបស់អ្នកកំសត់ទុគិតនេះ ដើម្បីអនុគ្រោះយើងខ្ញុំព្រះអង្គ ឲ្យបានហិតៈប្រយោជន៍នឹងសេចក្តីសុខ សព្វកាលវេលា យូរអង្វែងរៀងទៅហោង!"

(ក្រាបថ្វាយបង្គំ ៣ ដង)



ទស្សនាវដ្តី ផ្សាយជំណឹងខាងសាសនា និងអក្សរសាស្ត្រ

លេខពិសេស

ពិធីបុណ្យ



ឆ្នាំទី ២៩ លេខ ៦ ខែមិថុនា ព.ស. ២៥០០ គ.ស. ១៩៥៦





ទស្សនាវដ្តី ផ្សាយជំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បញ្ជីរឿង	ទំព័រ
– អរិយសច្ចកថា	ព្រះឧបាលីវង្ស សូរ.ហាយ	៥០៣
– សុទ្ធិកថា	ព្រះមហា មួល-អ៊ុំ	៥២៥

ផ្នែកអក្សរសាស្ត្រ		
– ការអប់រំក្មេងតូចអប់រំនៅផ្ទះ ឬនៅសាលារៀន	ឃុនអត្ថកោវិទ ជា.ឃួ.	៥៣៣
– រឿងវេវនូរបស់អម្រឹតស្បែត្រង៉ុក .... (តមក)	លោក ញ៉ុក-ថែម ពិនិត្យ	៥៤៦
– រឿងសាមកុក (តមក)	ឧកញ៉ា ន្ហូ-កន ប្រែ	៥៥៥
– រឿងហ្សាតិក (តមក)	លោក ព័យ - ប៊ុក ប្រែ	៥៥៩
– រឿងបុរសពីរនាក់ស្លាប់ឆន្ទៈដូចគ្នា	លោក ផេង-ន្ត្រីវ ប្រែ	៥៦៤

កំណាត់ទំនៃប្រវត្តិសាស្ត្រ		
– ព័ត៌មានសំខាន់ៗមហាសន្និបាតទី ១៣ នៃព្រះសង្ឃ	លោក ឯក-ប៊ង់	៥៧៤
– បុណ្យជាដង្កៀងអភិសេកព្រះពុទ្ធរូបសម្រឹទ្ធ	លោក អឿ-ភូសុខ	៥៨៨
– វចនានុក្រមសំស្ក្រឹត-ខ្មែរ . (តមក)	ព្រះ ភិក្ខុ ជាំង-ខាត់	៦០០

មួយឆ្នាំមាន ១២ សៀវភៅ–ដំឡៃដាវ ៤៣០រៀល

KAMBUJASURIYA

Revue religieuse et littéraire éditée par
l'Institut Bouddhique

TABLE DES MATIÉRES

PARTIE RELIGIEUSE:

-Ariyasaccakatha . . . . . par vén. *SOR-HAY.* 503
-Sudhikatha . . . . . par Vén. *MOUL-OU* 525

PARTIE LITTERAIRE:

-Education de l'enfants . . . . . par *M. CHEA-YOU* . 533
-Histoire de Devanda de *M. MOK,*
revue et corrigée (suite) par *M. NHOC-THEM* 546
-Histoire de Samkok (suite) . . . . . traduit par *M. NOU-KAN* . . 555
-Histoire de Zadig . (suite) . . . . . traduit par *M. RAY-BUC* . . . 559
-Histoire de deux amis . . . . traduit par *M. PHENG-CHRIV* . 564

NOTES ET CHRONIQUES:

-Treizième réunion des dignitaires
bouddhiques . . . . . par *M. EN-PANG* . 574
-Fête de consécration d'une statue de Bouddha
en bronze . . . . . par *M. ŒUR-TOLUCH* . . 588
-Dictionnaire Samskrit - Khmèr (suite) . . . par vén. *PANG-KHAT* . . . 600

Prix d'abonnement annuel (comprenant 12 numéros): 230$00

ផ្នែកសាសនា

អរិយសិប្ចកថា

ព្រះឧទាលិវង្ស សូរ-ហាយ

រៀបរៀង

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

ទុក្ខមេវ ហិ ន កោបិ ទុក្ខិតោ ការកោ ន កិរិយា វិវិជ្ជតិ

អត្ថិ និព្ពុតិ ន និព្ពុតោ បុមា មគ្គមត្ថិ គមកោ ន វិជ្ជតិ ។

ចាលីនេះ ជាសច្ចនិទ្ទេស ជាតោលនៃអរិយសច្ចធម៌ ៤ ប្រការ ។

អាត្មាភាព សូមសំដែងផ្សាយតាមវិឡុទគ្សោសនសព្ទ នូវអរិយ-សច្ចដែលព្រះសម្មាសម្ពុទ្ធទ្រង់សំដែងទុកហើយ ដោយន័យជាប្រើនយ៉ាងសឹងមានអាតតជ្ជាន ក្នុងតម្ពីរវិសុទ្ធិមគ្គ ត្រង់ឥន្ទ្រិយសច្ចនិទ្ទេស នឹងតម្ពីរបដិសម្ភិទាមហានិទ្ទេសនៃទុទ្ធកនិកាយ ដូចសេចក្តីអធិប្បាយតទៅនេះ ។

អរិយសច្ចធម៌ លោកបាត់ថាជាសាមុក្កំសិកាទេសនា គឺជាទេសនាដែលព្រះសម្ពុទ្ធលើកឡើងសំដែងដោយព្រះអង្គឯង ។ អរិយសច្ចធម៌នេះ ជាធម៌ដែលព្រះអង្គសំដែងជាញឹកញាយ ដើម្បីញ៉ាំងមនុស្សទេពតាក្នុងលោក ឲ្យកើតប្រាជ្ញាស្មារតី ក្នុងការកំណត់ពិចារណាកេហេតុផល, ក្នុងការលះនូវកិលេស មានអវិជ្ជាតណ្ហាជាដើម ។

អរិយសច្ច ប្រែថា "សេចក្តីពិតដ៏ប្រសើរ" ឬថា "សេចក្តីពិត

របស់អរិយ:ទាំងឡាយមានព្រះសម្ពុទ្ធជាដើម" មួយទៀត សេចក្តីពិត
នេះឯងតែងបិតនោប្រចាំលោក ជាធមិដែលអរិយ:មានព្រះសម្ពុទ្ធជាដើម
ស្វែងរកឃើញដោយជាក់ច្បាស់ ជាធមិមានអត្ថតម្ក័រកាព ។ ធមិនេះ
ជាសការ:ពិតមែន មិនប្រប្រួលឃ្យៀងឃ្ជាត, ជាសារធមិមួយក្នុងព្រះ
ពុទ្ធសាសនា កាលដែលព្រះអង្គសំដែងប្រោសបញ្ជាវត្តិយកិក្ខុឲ្យបាន
សម្រេចមត្តផល ក៏មានជាប់ទាក់ទងដោយអរិយសច្ចធមិនេះដោយ
ពិស្តារ ។

អរិយសច្ចមាន ៤ យ៉ាង:

១. ទុក្ខអរិយសច្ច សេចក្តីទុក្ខជាអរិយសច្ច ដែលគួរកំណត់,

២. សមុទយអរិយសច្ច ហេតុនាំឲ្យកើតទុក្ខជាអរិយសច្ច ដែលគួរលះបង់,

៣. និរោធអរិយសច្ច ការរលត់ទុក្ខជាអរិយសច្ច ដែលគួរធ្វើ
ឲ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ឧត្តម,

៤. មគ្គអរិយសច្ច ផ្លូវប្រតិបត្តិជាអរិយសច្ច ដែលគួរចំរើន ។
អរិយសច្ច ៤ យ៉ាងនេះ ជាអតិញ្ញាទេសិតធមិ គឺធមិដែលព្រះអង្គសំដែង
ដើម្បីត្រាស់ដឹង ជាធមិដែលព្រះសម្ពុទ្ធ ទ្រង់សំដែងធ្វើបដិវត្ត (ពវរក)
ដោយព្រះអង្គឯង ដែលទេវតា មារ ព្រហ្ម ពុំអាចធ្វើបដិវត្តបាន ដូច
ព្រះអង្គទ្បើយ ។

បាលីសច្ចនិទ្ទេស ដែលតាំងទុកខាងលើនេះ សេចក្តីថា:

"ពិតណាស់ សេបក្តីទុក្ខតែងមាននៅ ប៉ុន្តែអ្នក
ណាម្ខយដល់នូវទុក្ខមិនមាន, ជាងផ្ទះគឺតណ្ហារមែង
មាន ប៉ុន្តែសេបក្តីប្រតិបត្តិក្នុងការលះតណ្ហាមិនមាន,
សេបក្តីរំលត់ទុក្ខរមែងមាន ប៉ុន្តែបុគ្គលអ្នករំលត់
ទុក្ខមិនមាន. ផ្លូវសម្រាប់ដើររមែងមាន ប៉ុន្តែអ្នក
ដើរមិនមាន" ។

ត្រង់ពាក្យថា "អ្នកណាម្ខយដល់នូវទុក្ខមិនមាន" នោះបាន
សេបក្តីថា មនុស្សសត្វក្នុងលោកសុទ្ធតែបានឈ្មោះដោយសម្មតិសច្ច
មិនមែនដោយបរមត្ថសច្ចទ្បើយ ទាំងប្រាជ្ញាពិចារណាឃើញកងទុក្ខ ក៏
មិនសូវមាន ប្រើនតែព្រមទទ្ធលរងទុក្ខរៃទនា ព្រមទ្យសេបក្តីទុក្ខត្រប
សង្កត់ តាមយថាហេតុ ពុំអាចរកឧបាយដោះស្រាយបញ្ហានៃសេបក្តីទុក្ខ
បានទ្បើយ ។

ត្រង់ពាក្យថា " សេបក្តីប្រតិបត្តិក្នុងការលះតណ្ហាមិនមាន "
នោះ សេបក្តីថា មនុស្សក្នុងលោក សុទ្ធតែបិតនៅក្នុងទាសកាពនៃតណ្ហា
ព្រមនៅក្នុងបំណុះតណ្ហាទាំងអស់ ពុំសូវមាន្ធរណាម្ខយ គិតរើខ្ជួនចេញ
ចាកតណ្ហា លះបង់តណ្ហាទេ ។

ត្រង់ពាក្យថា "បុគ្គលអ្នករលត់ទុក្ខមិនមាន" នោះ សេបក្តីថា
មនុស្សក្នុងលោក មិនមែនឈ្មោះដោយបរមត្ថសច្ចទេ ប៉ុន្តែលោកសន្មត
យកសម្មតិសច្ចមកប្រើប៉ុណ្ណោះដើម្បីទ្យងាយយល់ ។ កាលបើមិនមាន

ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ឬសាវកពុទ្ធ ត្រាស់ដឹងក្នុងលោក ក៏ពុំមានន
ណាមួយអាចរកមធ្យាបាយ ឲ្យដល់នូវព្រះនិព្វាន ដែលជាតុណជាត
រំលត់ទុក្ខនោះឡើយ ។

ត្រង់ពាក្យថា "ផ្លូវមាន អ្នកដើរមិនមាន" នោះ សេចក្តីថា ក្នុង
កាលលង្វែកដែលមិនមានព្រះសម្ពុទ្ធ ឬ សាសនារបស់ព្រះសម្ពុទ្ធ ពុំ
សូវមានបុរសស្ត្រីប្រតិបត្តិតាមអដ្ឋង្គិកមត្ត (ផ្លូវប្រកបដោយអង្គ ៨) នោះ
ឡើយ ។

អធិប្បាយទុក្ខអរិយសច្ច

ពាក្យថា "ទុក្ខ" នេះ ប្រែថា "ការអត់ធ្មត់បានដោយក្រ, ការដីក
តាស់រំលើងបញ្ចបានដោយក្រ, សេចក្តីលំបាក, សេចក្តីតានតឹង ឬថា
សេចក្តីបង្ស៊ាតចង្អល់ទង្គឹះផ្អូកផ្អីះត្រាំនៅទាំងត្រជរ" ។

សេចក្តីទុក្ខនេះ មានប្រើនកងគឺ ទុក្ខ ៤ កងក៏មាន, ទុក្ខ ៧ កងក៏មាន,
ទុក្ខ ១៦ កងក៏មាន ។

ទុក្ខ ៤ កងនោះគឺ

១- ជាតិទុក្ខ សេចក្តីលំបាកព្រោះការកើតនៃបញ្ចក្ខន្ធ,

២- ជរាទុក្ខ សេចក្តីលំបាកព្រោះការចាស់ត្រាំត្រា,

៣- ព្យាធិទុក្ខ សេចក្តីលំបាកព្រោះការឈឺចាប់,

៤ មរណាទុក្ខ សេចក្តីលំបាកព្រោះមរណៈ ។

ទុក្ខ ៣ កង៖ គោះគឺ

១-	ទុក្ខទុក្ខ	ទុក្ខត្រូតលើទុក្ខ,
២-	វិបរិណាមទុក្ខ	ទុក្ខព្រោះការប្រែប្រួលឬព្រាត់ប្រាស,
៣-	សង្ខារទុក្ខ	ទុក្ខប្រចាំសង្ខារ,
៤-	បដិប្ជន្ទទុក្ខ	ទុក្ខដែលនោបិទបាំង,
៥-	អប្បដិប្ជន្ទទុក្ខ	ទុក្ខដែលមិនបិទបាំង,
៦-	បរិយាយទុក្ខ	ទុក្ខតាស្រ័យហេតុ,
៧-	និប្បរិយាយទុក្ខ	ទុក្ខដោយហ្ជសហេតុ ។

ទុក្ខ ១២ កង៖ គោះគឺ

១.	ជាតិទុក្ខ	ទុក្ខព្រោះការកើត,
២.	ជរាទុក្ខ	ទុក្ខព្រោះចាស់ត្រាំត្រា,
៣.	មរណទុក្ខ	ទុក្ខព្រោះសេចក្តីស្លាប់,
៤.	សោកទុក្ខ	ទុក្ខគឺការស្ជូតស្ជប់ចិត្ត,
៥.	បរិទេវិទុក្ខ	ទុក្ខគឺការឲ្យឹកឲ្យលសន្រែងសន្រែ,
៦.	ទុក្ខទុក្ខ	ទុក្ខគឺសេចក្តីលំបាកកាយដែលត្រូតលើទុក្ខ,
៧.	ទោមនស្សទុក្ខ	ទុក្ខគឺសេចក្តីលំបាកចិត្ត,
៨.	ឧបាយាសទុក្ខ	ទុក្ខគឺសេចក្តីចង្អៀតចង្អល់ចិត្ត,

៩. អប្បិយសម្បយោគទុក្ខ, ទុក្ខព្រោះការបានទៀសត្វនឹងសង្ឆារមិនជាទីស្រឡាញ់,

១០. បិយវិប្បយោគទុក្ខ, ទុក្ខព្រោះការព្រាត់ប្រាសចាកសត្វនឹងសង្ឆារជាទីស្រឡាញ់,

១១. យម្បម្ជំ ន លភតិ តម្ម ទុក្ខ, ទុក្ខគឺបុគ្គលប្រាថ្នារបស់ណាមិនបានដូចប្រាថ្នា ការមិនបានដូចប្រាថ្នានោះនាំមកនូវទុក្ខ

១២. សង្ខិត្តបញ្ចុបាទានក្ខន្ធទុក្ខ ដោយរួបរួម គឺទុក្ខព្រោះឧបាទានក្ខន្ធទាំងប្រាំ មានរូបូបាទានក្ខន្ធជាដើម ។

បណ្តាសេចក្តីទុក្ខទាំងអស់ សូមអធិប្បាយចំពោះទុក្ខទាំង ៧ កង ដើម្បីឲ្យពុទ្ធបរិស័ទត្រិះរិះពិចារណាតាមក្រសែនៃវិបស្សនា ដើម្បីស្គាល់សមុដ្ឋាននៃទុក្ខ ជាហេតុឲ្យកើតសេចក្តីសង្វេត ទ្រឿយណាយចាកកងទុក្ខនឹងរកឧបាយចេញចាកទុក្ខ ដូចសេចក្តីអធិប្បាយចំពោះសេចក្តីទុក្ខមួយ ៗ តាមលំដាប់តទៅនេះ ៖

១. ទុក្ខទុក្ខ=ទុក្ខត្រួតលើទុក្ខ ។ សេចក្តីទុក្ខនេះ សំដៅយកការទាក់ទងគ្នាទៅវិញទៅមក ក្នុងរវាងមាតាបិតានឹងបុត្រធីតារវាងតរិយានឹងស្វាមីដែលមានការទើសទាស់ខុសអធ្យាស្រ័យមានការឈ្លោះប្រកែកជាដើមក៏មាន, សេចក្តីទុក្ខចំពោះមាតាបិតា ជារបច្ច័យនាំឲ្យរាលដាលដល់បុត្រធីតា ឬសេចក្តីទុក្ខចំពោះបុត្រធីតាជាបច្ច័យនាំឲ្យរាលដាលដល់មាតាបិតាក៏មាន ប៉ុណ្ណោះជាដើម ។

២. វិបរិណាមទុក្ខ=ទុក្ខព្រោះការប្រែប្រួលឬត្រាត់ប្រាស ។ ការប្រែប្រួលត្រាត់ប្រាសនេះ លោកពន្យល់ថាជាទុក្ខ ដោយហេតុតែសេចក្តីស្រឡាញ់ជាប់ចិត្ត ដូចមាតាបិតាជាទីស្រឡាញ់របស់កូន តាំងកូនក៏ជាទីស្រឡាញ់របស់មាតាបិតា, ភរិយាជាទីស្រឡាញ់របស់ស្វាមី តាំងស្វាមីក៏ជាទីស្រឡាញ់របស់ភរិយា ។ បុគ្គលតាំងនេះ កាលបើមានចិត្តស្នេហាប្រតិព័ទ្ធដោយការសន្សឹមកក់ក្តៅទុកចិត្តគ្នាទៅវិញទៅមកក្តី ដោយការគោរពប្រាស្រ័យស្និទ្ធស្នាលស្មោះត្រង់ទឹងឆ្នាំក្តី ហើយស្រាប់តែបុគ្គលណាមួយដល់នូវមរណភាព ចែកឋានទៅគាប់របរលោកជាតិបន្ទាប់ឬឆ្ងាយឆ្ងាយទៅ។ សេចក្តីទុក្ខព្រោះការត្រាត់ប្រាសនេះ រមែងកើតខ្លាំងដល់បុគ្គលអ្នកនៅ ជាហេតុញាំងអ្នកនៅ ឲ្យមានសេចក្តីក្រៀមក្រំ ជាលំដាប់ យំសោកសង្រេងសង្រៃ តានតឹង ខ្ជិលច្រអូសច្រអើម ក្នុងចិត្ត, ជួនកាលអ្នកដែលមានប្រាជ្ញាស្មារតីខ្លាំង ត្រូវវិបរិណាមទុក្ខត្រូបសង្កត់ជាហេតុនាំបណ្តាលឲ្យឈឺចិត្ត ដល់នូវការកើតលិចតែ ដូចនាឯបដាចាកកំមាន ជួនកាលអ្នកខ្លះកើតសេចក្តីទុក្ខ ព្រោះការត្រាត់ប្រាសចាកវត្ថុស្តៅរងើងរផ្ងាន់ការគំនិតគិតអ្វីពុំឃើញ បណ្តាលឲ្យមម្ចាស់ខ្លួនឯងក៏មាន ឲ្យឈឺចាប់ខ្លួនឯងខ្លៅតក៏មាន ។

៣- សង្ខារទុក្ខ=ទុក្ខប្រចាំសង្ខារ ។ ពាក្យថា "សង្ខារទុក្ខ" នេះសំដៅយកសេចក្តីទុក្ខ ដែលកើតឡើងព្រោះសង្ខារជាបច្ច័យ ។ សង្ខារក្នុងន័យនេះ សំដៅយកទាំងសង្ខារ គឺសង្ខារ ដែលមានធាតុ

ទាំង ៤ មានវិញ្ញាណជ្រកកោនអាស្រ័យនៅ ។ សង្ខារពន្ធកាយ
របស់សត្វលោកនេះ មានទុក្ខច្រើន មានពេលច្រើនណាស់ ។ សេចក្តី
ទុក្ខ សោក ពេគ ភ័យ ឧបទ្រព ៦យ៉ាងទាំងអស់ តែងកើតឡើង
តែក្នុងសង្ខារពន្ធកាយ មិនមែនពេគតាធកើតនៅលើអាកាសទេ ។
គ្រោងកាយនេះ ជាសម្បុដនៃទុក្ខ សោក ពេគ ភ័យ ទាំងអស់ ។
ពន្ធកាយរបស់បុរសស្ត្រីឯណា ដែលមានបុញ្ញាភិសង្ខារស្តុបស្តើង ដែល
ជាប់ដោយផលនៃអកុសលកម្ម មានការសម្លាប់ប្តូរបៀតបៀនសត្វជាដើម,
បុរសស្ត្រីខោះ ក៏មានពេគតាធកើតនៅជានិច្ចក្នុងពន្ធកាយ មានពេគ
ស្តាំនស្តមនែរៃពុនទុក ភ្លុំរ៉ៃ ក្តៅក្រហាយ ភាយចិត្ត ចុកចាប់ជានិច្ចឥត
ស្រាក ។ ពេគតាធទាំងអស់ មានពន្ធកាយជាប្រភពគឺជាដែនកើតនៃ
ពេគ ដូចពេគតាធដែលមានមកក្នុងគំរីមានខ្ញុសត្រូថា ឥមស្មឹ កាយេ
អវិជ្ជា អាសវា ខុប្បជ្ជន្តិ ដម្ងីដម្ងាត់ទាំងឡាយផ្សេងៗមានកើត
ឡើងក្នុងកាយនេះគឺ បក្ខីរោគោ ពេគក្នុងស្លែក សោតរោគោ
ពេគក្នុងត្រចៀក ឃានរោគោ ពេគក្នុងច្រមុះ ជិវ្ហារោគោ ពេគក្នុង
អណ្តាត កាយរោគោ ពេគក្នុងកាយ សីសរោគោ ពេគក្នុងក្បាល
កណ្ណរោគោ ពេគត្រង់ស្ងឹកត្រចៀក មុខរោគោ ពេគក្នុងមាត់ ទន្ត
រោគោ ពេគត្រង់គល់ធ្មេញ កាសោ ពេគក្អួក សាសោ ពេគហឺត
បិនាសោ ពេគខាងក្រៅច្រមុះ ឌុប្បោ ពេគក្តៅក្រហាយ ជរោ ពេគ
ស្តាំនស្តម កុប្បិរោគោ ពេគក្នុងដៃ ម្តុំប្តូ ពេគឡស់ចាប់ពីលើមុខ បក្ខុ

ឆ្នូកា ពេតឆ្នាក់ឈាម សុលា ពេតបុកសៀត វិសូបិកា ពេតស្រែន សោសោ ពេតរ៉ែងវែ អបមារោ ពេតឆ្កួតជ្រូក ទុទ្ទុ ពេតដំខួចតិស កណ្តុ ពេតមាស់ កប្ប ពេតកមក្រែន រខសា ពេតកន្ត្រើល វិតប្បិកា ពេតកមលោយ លោហិតំ ពេតឈាម បិត្តំ ពេតប្រមាត់ មធុមេហោ ពេតទឹកឃ្មោមផ្អែម អំសា ពេតឫសដូនចាតដុះដុំពៃញ្វាធំ បិឡកា ពេតលេកកែវ ភគណ្ឌលា ពេតឫសដូនចាតដុះខាងក្នុង បិត្តសម្ដុនា អាពាធ អាពាធកើតអំពីប្រមាត់ សេម្ហសម្ដុនា អាពាធ អាពាធកើតអំពីស្លេស្ម វាតសម្ដុនា អាពាធ អាពាធកើតអំពីខ្យល់ សន្និបាតិកា អាពាធ អាពាធកើតអំពីសន្និបាត ឥរិយាបថ ប្រមាត់ ស្លេស្ម ខ្យល់ប្រជុំគ្នា ឧតុបរិណាមជា អាពាធ អាពាធកើតអំពីការប្រែប្រួលរដូវ វិសមបរិហារជា អាពាធ អាពាធកើតអំពីការថ្នាស់ថ្នូរមិនស្មើគ្នា ឱបក្កមិកា អាពាធ អាពាធកើតអំពីសេចក្តីព្យាយាម (បើស់អ្នកឯទៀត មានចាប់ចងក៏ឃើញដាប់ដាដើម) កម្មវិបាកជា អាពាធ អាពាធកើតអំពីផលកម្ម សីតំ អាពាធកើតអំពីត្រជាក់ ឧណ្ហំ អាពាធកើតអំពីកំដៅ ជិឃច្ឆា អាពាធកើតអំពីសេចក្តីឃ្លាន បិបាសា អាពាធកើតអំពីសេចក្តីស្រេក ឧច្ចារោ អាពាធកើតអំពីទល់ឧ: បស្សាវោ អាពាធកើតអំពីបស្សាវៈ" សេចក្តីទុក្ខទាំងអស់ក៏ឈ្មោះថាជារបស់ក្តៅ កាលបើតែក្តៅមាន តែត្រជាក់សម្រាប់

លត់កំដៅក៏មាន ។ នេះជាញាណទស្សនៈនៃបណ្ឌិតពំនឲ្យាយមាន ព្រះពោធិសត្វជាដើម ។

រោតាពាធពំនអស់ តែនកើតប្រជុំកុះនៅតែក្នុនរាងកាយ មានរាងកាយជាប្រភព ឬ ជាសមុដ្ឋាន ។ រាងកាយមានការៈដ៏ធ្ងន់ក្រៃលែន លំបាកក្នុនការចិញ្ចឹមថែទំដោយត្រឿនស្ទៀកពាក់, ដោយអាហារបរិភោគ, ដោយទីនៅសម្រាប់ជ្រកកោន, ដោយកេសជ្ជ: គឺថ្នាំសម្រាប់កែរោគរបស់រាងកាយ ។

រាងកាយនេះ មានអាការៈគ្ឆរឆ្ពីមរអើម កាលបើមានវិញ្ញាណឃ្លាតចេញហើយ នឹនដេកស្ពូកស្ពឹនដូចជាអង្គត់អុស ។ សមដូចជាព្រះពុទ្ធដីកាក្នុនចាតុម្មសូត្រថា ជើតុ ឬ រិតាយំ ភិក្ខវេ កាយោ សកលោ ទុគ្គន្ធោ អាហារប្បដិកូលសញ្ញាយ អភិណ្ហំ បច្ចវេក្ខិតព្ធោ ប៉ុណ្ណោះជាដើម សេចក្តីថា "ម្នាលភិក្ខុពំនឲ្យាយ កាយនេះ មានអាការៈគ្ឆរឆ្ពីមរអើម មានក្ខិនស្អុយពំនមូលដោយពិត ដែលអ្នកពំនឲ្យាយគប្បីពិចារណាឲ្យរឿយ ។ ដោយអាហារប្បដិកូលសញ្ញា" ។ កាលបុគ្គលពិចារណារាងកាយយើញដោយប្រាជ្ញាហើយ ចិត្តក៏រមែនរ្ឆាថយចាករាងកាយ ជាចិត្តធុញត្រាន់ ឿយណាយមិនក្រាប មិនក្រាញនៅក្នុនរាងកាយនេះ ដោយកក់ក្តៅឡើយ ។

រាងកាយដែលប្រជាប់ដោយស្បែកសាច់សរសៃ លាបប្រឲ្យាក់ដោយឈាមរំអិល ក៏សុទ្ធតែជារបស់មិនស្អាត សូម្បីអាហារជាគោកជាដុំ ដែល

គេចំអិនឲ្យឆ្អិនដោយក្តៃន ដែលជាអាហារមានរសជាតិឆ្ងាញ់ ឬ ផ្អែម, កាលបើបុគ្គលបរិភោគលេបចូលទៅក្នុងពោះ ពុំបានយូរប៉ុន្មាន ស្រាប់តែបន្ទោបង់ជ្ងាក់ចេញមកវិញ ក៏ត្រឲ្យប់ជាមានក្លិនស្អុយដ៉ាង ឆ្លរស្អប់ខ្ពើមជ្មាត្រាន់ជាយ៉ាងក្រៃពេក ។ អាហារច្រើនមុខមានរសជាតិផ្សងៗគ្នាពុកផូចជាស្ទូលរាងកាយ ទាំងស្ងោររំងាស់ចំអិនក៏ឆ្អិនសព្វទាំងអស់ពិតមែនប៉ុន្តែកាលបើចូលទៅក្នុងពោះ អាហារទាំងនោះក៏ស្រាប់តែត្រឲ្យប់ក្លាយទៅជាស្អុយវិញទាំងអស់ ឃើញថាផ្ទុយស្រឲ្យះពីស្ទូលនំធម្មតា ។ ចំណែកខាងភេសជ្ជៈដែលជាទឹកវាវ៉ា មានរសជាតិផ្សងគ្នា កាលបើផឹកចូលទៅក្នុងពោះពុំយូរប៉ុន្មាន ក៏ស្រាប់តែបន្ទោបង់ទឹកមូត្រមក មានក្លិនផ្អេះឲ្យប់ម្ជុយរំពេចសូម្បីឲ្យល់របស់រាងកាយក៏មានក្លិនអាក្រក់ខុសពីឲ្យល់ប្រក្រតី ។

<u>៤-បដិច្ចត្ថទុក្ខ=ទុក្ខដែលនៅកំបាំង ។</u> សំដៅសេចក្ដីទុក្ខដែលកើតក្នុងកាយក្ដីក្នុងចិត្តក្ដីរបស់បុគ្គលណាម្ជុយ នៅពុំទាន់ប្រាកដជាក់ស្តែងជាទុក្ខនៅទន់ភ្សាយនៅឡើយ ។ សេចក្ដីទុក្ខតែងមាននៅក្នុងកាយដោយពិត ប៉ុន្តែមិនទាន់លេចមកខាងក្រៅ ដែលអ្នកដទៃមិនអាចមើលឃើញបានទេ, សេចក្ដីទុក្ខនេះ លោកហៅថា ទុក្ខនៅកំបាំង ។ ម្ជុយទៀតបេតសិកទុក្ខ គឺសេចក្ដីទុក្ខក្នុងផ្លូវចិត្តដោយហេតុការណ៍ណាម្ជុយ ដែលអាចដឹងបានចំពោះតែសាមិខ្លួន អ្នកដទៃមើលពុំឃើញ នេះឯងហៅថាទុក្ខដែលកំបាំង ។ ម្ជុយវិញទៀត សេចក្ដីទុក្ខទាំងអស់ដែលមាននៅក្នុងរាងកាយរបស់បុគ្គលណាម្ជុយ តែសេចក្ដីទុក្ខនោះជាទុក្ខធូរស្រាលនៅឡើយ ។ បុគ្គលនៅមិទាន់មានសេចក្ដីទុក្ខធ្ងន់ត្របសង្កត់ ឬថាមិនទាន់ជ្ជបប្រទះនឹង

សេចក្តីទុក្ខជ្រួនៅខ្លួយ តែថាជាទុក្ខដែលនៅសឹកសៀតមិនខាន់សេច ចេញជាក់លាក់ម៉កខាងក្រៅ ដូច្នេះលោក ហៅថា បដិច្ចទុក្ខ តែទុក្ខដែលនៅកំបុំនៅខ្លួយ ។

៥- អប្បដិច្ចទុក្ខ = ទុក្ខដែលមិនកំបុំបង ។ ទុក្ខណាមួយ គោះបីកាយិកទុក្ខ តែទុក្ខកងកាយក្តី ចេតសិកទុក្ខ តែទុក្ខកងចិត្តក្តី ដែលកើតខ្លួនច្រាកដយើញជាក់ស្តែងជាទុក្ខជ្រួន បើកបង្ហាញឲ្យយើញជាក់ច្បាស់ដល់ខ្លួនឯងនិងអ្នកដទៃ ។ សេចក្តីទុក្ខដែលបុគ្គលបានជួបប្រទះដោយផ្លាល់ខ្លួនដូច្នេះ លោកហៅថា អប្បដិច្ចទុក្ខ ទុក្ខដែលមិនកំបុំបង ។ អប្បដិច្ចទុក្ខនេះ ផ្ទុយគ្នានឹងបដិច្ចទុក្ខ មិនបាច់អធិប្បាយឲ្យពិស្តារទេ បណ្តិតគប្បីសន្និដ្ឋានចុះ ។

៦- បរិយាយទុក្ខ = ទុក្ខអាស្រ័យហេតុ។ ពាក្យថា "ទុក្ខអាស្រ័យហេតុ" នេះ សំដៅយក ជាតិ គឺការកើតខ្លួនជាហេតុ ១, ជរា សេចក្តីចាស់គ្រាំគ្រាជាហេតុ ១, ព្យាធិ សេចក្តីឃើចាប់ខាត់ជាតជាហេតុ ១ប៉ុណ្ណេះជាដើម ហៅថា ទុក្ខអាស្រ័យហេតុ ។ មួយទៀត សេចក្តីទុក្ខដែលធ្លុះស្រាលតែងកើតខ្លួនក្នុងកងកាយ ដោយអំណាចហេតុខាងក្រៅ មានអាហារ ចំណី មិនល្អ ឬដោយរដូវជាតុអាកាសប្រែប្រួល បណ្តាលឲ្យមានទុក្ខដល់កងកាយ មានទាំងរោគតេគស្រែះស្រៃ ញាស្រកាញ់ស្រកើឬផ្តាសាយគ្រុនរងាជាដើម ។ សេចក្តីទុក្ខណាមួយដែលប្រកបដោយហេតុនៅធ្លុះស្រាលល្មមមើលញាក់ញ៉ាលរក្សាបានដូច្នេះ លោកហៅថា

បរិយាយទុក្ខ ទុក្ខអាស្រ័យហេតុខាងក្រៅ ។

៣_ ឥប្សរិយាយទុក្ខ = ទុក្ខដោយហ្លសហេតុ ។ ពាក្យថា "ទុក្ខដោយហ្លសហេតុ" នេះ លោកមិនបានសំដៅយកជាតិ ជរា ព្យាធិ មកជាប្រមាណឡើយ ទាំងហេតុខាងក្រៅ មានអាហារ បំណី ឬរដូវ ធាតុអាកាសប្រែប្រួល ក៏មិនបាច់រាប់យកថាជាហេតុទេ ព្រោះថាឥប្សរិយាយ-ទុក្ខនេះ សំដៅតែត្រង់សេចក្តីទុក្ខដ៏ធ្ងន់បំផុត ដែលជាទុក្ខកើតមកអំពីផលនៃអកុសលកម្មរបស់ខ្លួន ដែលជាប់តាមមកតាំងពីអតីតកាល ។ មួយទៀត សេចក្តីទុក្ខផ្ទាល់ខ្លួន ដោយមរណៈ ឥតមាន្ទរណាដ៏ងមុនឡើយ តឹសុទ្ធតែរស់នៅដោយស្មាន ។ ព្រាវ ។ ផ្សងព្រេងទាំងអស់ ឬសេចក្តីទុក្ខរបស់ញាតិមិត្ត ដែលជាទុក្ខធ្ងន់ក្រៃលែងហ្លសវិស័យក្នុងការព្យាបាលដោយថ្នាំកែរោគក្តី ដោយត្រូពេទ្យពិនិត្យមើលក្តី តាមយថាកម្ម ទោះបីយើងជាមនុស្ស ឬវ៉ន្តែជូចសត្វមាន់ ដែលឥតដ៏ងពេលមរណៈ នេះលោកហៅថា ឥប្សរិយាយទុក្ខ, មួយវិញទៀត សេចក្តីទុក្ខរបស់បុគ្គលដែលមានបាបកម្ម ត្រូវទទួលមរណៈដោយត្រោះថ្នាក់ធំ ។ ដែលមិនអាចនរណាមួយជួយកែព្យាបាលទាន់ ជាសេចក្តីទុក្ខដល់នូវកាលកិរិយា ដោយអំណាចទោសរបស់ផលបាបកម្ម ដូច្នេះ ហៅថា ឥប្សរិយាយទុក្ខ ។

សេចក្តីទុក្ខទាំងអស់ចាត់ជាបរិញ្ញេយ្យកិច្ច តឹកិច្ចដែលត្លរកំណត់ដ៏ង, សេចក្តីទុក្ខលោកចាត់ថាជាផលដែលកើតអំពី ហេតុតឹសមុទយៈ កាលបើយោតាវបរធុញទ្រាន់ទឹងផលជាទុក្ខ ត្រូរស្រាវជ្រាវរកហេតុនៃទុក្ខតទៅ ។ សេចក្តីទុក្ខលោកចាត់ជាកុសលក៏មានជាអកុសលក៏មាន ជាអព្យាត្រឹតក៏

មាន ។ សេចក្តីទុក្ខក្នុងកាយឬក្នុងចិត្តរបស់បុគ្គលដែលប្រកបព្យាយាមដើម្ប
បំពេញកុសល មានការឲ្យទានរក្សាសីលជាដើម ហៅថា ទុក្ខជាកុសល ។
សេចក្តីទុក្ខក្នុងកាយឬក្នុងចិត្តរបស់បុគ្គលដែលតែងមានជាធម្មតា ដូចយ៉ាង
សេចក្តីទុក្ខកើតអំពីជរាព្យាធិ ឬកើតអំពីការស្រេកឃ្ងាន ក្តៅត្រជាក់ឬកំកើត
អំពីរាមនស្ស ដោយឧសបំណងក្នុងផ្ទូវចិត្ត ហៅថាទុក្ខជាអព្យាក្រឹត ។

អធិប្បាយសមុទយអរិយសច្ច

ពាក្យថា "សមុទយ:" ប្រែថា ហេតុជាទីកើត, ហេតុជាទីប្រជុំ
កើតឡើងព្រម, ហេតុជាគ្រឿងបណ្តាលនាំឲ្យកើត" សំដៅយក
ជលំកិលេសធម៌ មានតណ្ហាជាដើម ដូចបាលីដែលលោកសំដែងថា
អវិជ្ជាតណ្ហាយ កាយសម្ភវោ សម្ភវតិ សេចក្តីថា "ការកើត
ឡើងនៃកាយ រមែងកើតឡើងបាន ព្រោះអវិជ្ជានឹងតណ្ហា" ។ អវិជ្ជា
នឹងតណ្ហានេះ ចាត់ជាប្រភពនៃរូបកាយ គឺជាដែនកើត ឬ ជាមូលហេតុ
នៃរូបកាយ ។ កិលេសជាតិដែលនាំចិត្តមនុស្សសត្វឲ្យធ្វើនូវអំពើទុច្ចរិត
មានកាយទុច្ចរិតជាដើម ហៅថា អវិជ្ជា ។ កិលេសជាតិ ដែលញ្ចាំង
មនុស្សសត្វឲ្យចង់បាននូវរបស់ដែលមិនគួរបាន មានអបាយភូមិជាដើម
ហៅថា អវិជ្ជា ។ មួយទៀត កិលេសជាតិដែលនាំមនុស្សសត្វឲ្យវង្វេង
វង្វាន់ឲ្យយល់ផ្ទុយពីវិជ្ជា ហៅថា អវិជ្ជា ។ មួយវិញទៀត កិលេស
ជាតិដែលបិទបាំងមនុស្សសត្វ មិនឲ្យឃើញកងទុក្ខ, ដែលញ្ចាំងសត្វ
ឲ្យអន្ទោលទៅក្នុងសង្សារវដ្ត ហៅថា អវិជ្ជា ។ អវិជ្ជានឹងតណ្ហានេះ
លោកចាត់ជាមូលហេតុនៃសេចក្តីទុក្ខទាំងអស់ ។

ពាក្យថា "តណ្ហា" មានអត្ថដែលគួរប្រែថាន ច្រើនយ៉ាង ដូច
បាលីក្នុងគម្ពីរបដិសម្ភិទាមហានិទ្ទេសថា យាយំ តណ្ហា ជោនោព្ភ.
វិកា ឧន្នីរគសហគតា តត្រ តត្រាភិនន្ទិនី សេយ្យថីទំ កាម.
តណ្ហា ភវតណ្ហា វិភវតណ្ហា វិសត្តិកា វិសជា ជដិតា តណ្ហា
សិនេហោ តណ្ហាយនា តណ្ហាយិតត្តំ សប្បនា អាសប្បនា
ជប្បា បរិជប្បា អយំ វុច្ចតិ តណ្ហា ប្រែថា "កិលេសជាតិណា
ដែលឈ្មោះថាតណ្ហានេះ តែងនាំសត្វឲ្យឈម:ទៅកាន់កំណើតថ្មីទៀត ដែល
ប្រឡូកប្រឡាំដោយនន្ទិរាគ ត្រេកត្រអាលទៅក្នុងអត្តភាពនោះ។ គឺកាម.
តណ្ហា ១ ភវតណ្ហា ១ វិភវតណ្ហា ១ កិលេសជាតិ គឺ តណ្ហាដែលជាប់
នៅក្នុងអារម្មណ៍ផ្សេង ៗ, ដែលផ្អួយទៅ, ដែលចាក់ស្រែះ, សាំញាំ,
ជាប់ស្អិត, ជាទីនឹកនា, ជាទីញាំងសត្វឲ្យអន្ទះសា, ភាពនៃការសង្ឃឹម
សង្ឃា, ការកេងេសកង្វាស, ខ្ទួចខ្ទៃលោភៈ, អន្ទោកអន្ទោល
នេះលោកហៅថា តណ្ហា ។

ពាក្យថា តណ្ហា នេះ ជាឈ្មោះនៃកិលេសដែលដឹកនាំសត្វ ឲ្យ
ជាប់ស្អិត នៅក្នុងភពទាំង ៣ ដោយសេចក្តីអធិប្បាយថា សត្វសត្វទាំង
អស់ដែលត្រេកត្រអាលអន្ទោលយោនយកកំណើត ដោយការប្រណាំង
ប្រជែងដេញដើរតាមចាប់កំណើត ឬ ដេញដើរគ្នា ដើម្បីស្វែងរកកំណើត
ក៏ព្រោះហេតុតែតណ្ហាហ្នឹងឯង ។ តណ្ហានេះ ទុកដូចជាស្នេហ៍មួយ
ដែលអាចបញ្ចោះបញ្ចូលតពួកសត្វ ឲ្យមានការជាប់ជំពាក់ស្រឡាញ់

ក្លួចកាន់នៅក្នុងឥតខ្លួន ដឹកនាំសត្វឲ្យសំដែងអាការច្រួលច្រាល់នូនវនាទ
ក់ទាញ ឥតស្រាកស្រាន្ត ។

តណ្ហា ចាត់ជាបហាតភូតកិច្ច គឺកិច្ចដែលត្រូវលះបង់ ។ តណ្ហា
ចាត់ជាអកុសលតែម្យ៉ាង ដោយហេតុថាតណ្ហាជាកិលេសជាតិ ជាធម្ម
ជាអកុសល ពុំមែនជាបុណ្យ កុសលឡើយ ព្រោះថាតណ្ហានេះមិន
មែនជាបដិបទាដឹកនាំសត្វទៅរកមគ្គផលនិព្វានទេ, តណ្ហានេះ ជាកិលេស
ជាតិ បង្អួនជាន់ឲ្យឃ្លាតពីព្រះនិព្វាន ។

តណ្ហាមានធម៌ជាឫសគល់ ៩ យ៉ាង:

១. តណ្ហំ បដិច្ច បរិយេសនា អាស្រ័យតណ្ហា ទើបមានការ
ស្វែងរកទ្រព្យសម្បត្តិ ដែលជាហេតុនាំឲ្យទើសទាស់ប៉ះពាល់ដល់គ្នា ។

២. បរិយេសនំ បដិច្ច លាភោ អាស្រ័យការស្វែងរក ទើប
កើតលាភ គឺការបាន ជាហេតុនាំឲ្យជាប់ចិត្ត ឲ្យញ៉ាំមក្នុងការស្វែងរក ។

៣. លាភំ បដិច្ច វិនិច្ឆយោ អាស្រ័យលាភ ទើបកើតសេច
ក្តីត្រិះរិះលៃលក មិនមានទីបំផុត ។

៤. វិនិច្ឆយំ បដិច្ច ឆន្ទរាគោ អាស្រ័យសេចក្តីត្រិះរិះ ទើប
កើតឆន្ទរាគ គឺតម្រេកដ៏ខ្លាំងក្លា ។

៥.ឆន្ទរាគំ បដិច្ច អជ្ឈោសានំ អាស្រ័យឆន្ទរាគទើបកើត
សេចក្តីស្ទឹះចិត្តសិប់ ជាហេតុនាំឲ្យមានសេចក្តីប្រកាន់មាំ ។

៦.អជ្ឈោសានំ បដិច្ច បរិគ្គហោ អាស្រ័យដំនៀបុះចិត្តសិប់ ទើបកើតការហួងហែងទុក ។

៧.បរិគ្គហំ បដិច្ច មច្ឆរិយំ អាស្រ័យការហួងហែង ទើបកើតសេចក្តីកំណាញ់ស្ងិតស្ងាញ ។

៨.មច្ឆរិយំ បដិច្ច អារក្ខោ អាស្រ័យសេចក្តីកំណាញ់ស្ងិតស្ងាញ ទើបកើតការរក្សាទុក ។

៩.អារក្ខាធិការណំ បដិច្ច ទណ្ឌាទានាទិកា បាបកា អកុសលាធម្មា អាស្រ័យការរក្សាទុកជាហេតុ ទើបកើតអកុសលធម៌ដ៏លាមក មានន៉ិយាយកុហកញុះញង់ទាស់ទែង មានការកាន់ដំបងជាដើម ។

តណ្ហាដែលលោកចាត់ថាជាសមុទយៈនោះ ព្រោះថាតណ្ហាជាប្រភព គឺជាដែនកើតនៃទុក្ខទាំងពួង មានជាតិទុក្ខជាដើម ទាំងជាហេតុនៃការឈ្លោះប្រកែក ចោទប្រកាន់ដល់ឆ្នាន៉ឆ្នា រហូតដល់ការប្រកាសសង្ត្រាម ។

អធិប្ប្បាយនិរោធអរិយសច្ច

ពាក្យថា "និរោធៈ" នេះ ជាឈ្មោះនៃព្រះនិព្វាន ។ និរោធៈ ប្រែថា "ការរំលត់កិលេសម្ចរំលត់ទុក្ខ" ។ និរោធៈនេះជាវៀចនស័ព្ទនៃពាក្យថា "និព្វាន" សមដូចបាលីថា "យោ ឥស្សាយេវ ឥណ្ហាយ អសេសវិរាគនិរោធោ បាគោ បដិនិស្សគ្គោ មុត្តិ អនាលយោ

ធិញ្ជាធំ" ប្រែថា "ការលែងដោយអរិយមគ្គ ឥតមានសេសសល់នៃតណ្ហានោះឯង ការលះបង់ ការរលាស់ចោល ការរួចស្រឡះ ការមិនមានអាល័យ (ដោយតណ្ហា) ហៅថា "និញ្ជាន" ។ មួយទៀត ពាក្យថា "និញ្ជាន" នេះប្រែថា "ការរួចចាកគ្រឿងចាក់ស្រែះឬគ្រឿងរួបរឹត" ព្រោះមានឫសគល់វិគ្រោះថា បញ្ជ្រុគពីវានេធ វានសញ្ញិតាយ តណ្ហាយ និក្ខន្តតា និញ្ជាធំ ប្រែថា "គុណជាតឈ្មោះថានិញ្ជាន ព្រោះចេញចាកតណ្ហាដោយភាពដែលអាចដឹងហើយថា ជាគ្រឿងចាក់ស្រែះដោយការចងរួបរឹតទុកខ្លួនតតិភាំង ៥ មានមរយតតិ តីដំណើរទៅខាងដើម" ។

និញ្ជានមានន័យយ៉ាងគឺ សង្ខាទិសេសនិញ្ជាន ការរលត់កិលេស ឬការរួចស្រឡះចាកគ្រឿងរួបរឹតរបស់ព្រះអរហន្ត ដែលមានខន្ធ ៥ នៅសល់ ១, អនុបាទិសេសនិញ្ជាន ការរលត់កិលេស ឬការរួចស្រឡះចាកគ្រឿងរួបរឹតរបស់ព្រះអរហន្ត ដែលមិនមានខន្ធទ្រាំ ១ ។ ពាក្យថា "និញ្ជាន" នេះ ប្រែថា "មានគ្រឿងចាក់ស្រែះគឺតណ្ហានាំចេញហើយ" ក៏បាន, ថា "អស់គ្រឿងរួបរឹត" ក៏បាន, ថា "រលត់ទុក្ខ" ក៏បាន សម្រួលតាមវិគ្រោះដោ តាពិភវំ វិនេនតោ សំសិព្វនតោ វានសង្ខាតាយ តណ្ហាយ និក្ខន្តិ និញ្ជាធំ ប្រែថា "ធម្មជាតណាដែលនាំចេញហើយចាកតណ្ហា គឺគ្រឿងចាក់ស្រែះ ព្រោះកំរិយាទន់ខ្សោយ កំរិយារួបរឹតទុក ខ្លួកពតួចនឹងតតធំ ធម្មជាតនោះ ឈ្មោះថា "និញ្ជាន" ។

ដែលប្រែថា "រលត់" នោះ ដូចបាលីវិគ្រោះថា "និញ្ជាតិ ឯតេន រាគគ្គិអាទិកោតិ និញ្ជានំ" ប្រែថា "ភ្លើងមានរាគៈ ជាដើម រមែងរលត់ទៅដោយអរិយមគ្គនេះ ព្រោះហេតុនោះទើបឈ្មោះថា "និញ្ជាន" ។

និរោធ គឺនិញ្ជាននេះជាសច្ចិកាតព្វកិច្ច គឺកិច្ចដែលត្រូវធ្វើឲ្យជាក់ច្បាស់ ។ និរោធធម៌នេះ ចាត់ជាអព្យាក្រឹត គឺជាគុណជាតមិនច្រឡំដោយទុក្ខ មិនទាក់ទងចូលទៅខាងសាមិសសុខ, ជាលទ្ធផលដ៏ប្រសើរបំផុតនៃព្រះពុទ្ធសាសនា ជាសន្តិវរបទ គឺជាផ្លូវសន្តិសុខ ដ៏ប្រសើរខ្ពង់ខ្ពស់ជាងសេចក្តីសុខក្នុងលោកទាំងពួង ។

អធិប្បាយមគ្គអរិយសច្ច

ពាក្យថា "មគ្គ" ប្រែថា "ផ្លូវ ឬទបាយចេញចាកទុក្ខ" សំដៅយកផ្លូវប្រតិបត្តិ ដើម្បីទូន្មានកាយវាចាចិត្តឲ្យបរិសុទ្ធ ដឹងបានដោយស្រាយបញ្ហានៃទុក្ខទាំងពួង ។ ផ្លូវប្រតិបត្តិរបស់មនុស្សក្នុងលោកមានច្រើនយ៉ាង ប៉ុន្តែបើបំប្រួញដោយខ្លីមានពាយ៉ាងគឺ កាមសុខល្លិកប្បដិបទា សេចក្តីប្រតិបត្តិបន្ទូរបន្ទយ ដោយការបណ្តោយចិត្តឲ្យធ្លន់ទៅរកកាមគុណ ១ អត្តកិលមថប្បដិបទា សេចក្តីប្រតិបត្តិដោយការប្រព្រឹត្តិតឹងរ៉ឹង ធ្វើខ្លួនឲ្យលំបាកហួសហេតុ ១ មជ្ឈិមាបដិបទា សេចក្តីប្រតិបត្តិយ៉ាងកណ្តាល ១ ។

សេចក្តីប្រតិបត្តិពីរខាងដើម ព្រះសម្មាសម្ពុទ្ធទ្រង់បដិសេធថាជា កុមគ្គប្បដិបទា គឺជាផ្លូវប្រតិបត្តិខុស ឬ ផ្លូវប្រតិបត្តិដែលគួរខ្ពើម, ជាបដិបទាថោកទាប ជារបស់អ្នកស្រុកធម្មតា ជារបស់បុថុជ្ជន មិនមែនជា

របស់អរិយ: មិនប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីត្រាស់ដឹងនូវមគ្គផល ដើម្បីព្រះនិព្វានឡើយ ។ ព្រះសម្មាសម្ពុទ្ធទ្រង់បញ្ញត្តវិនយសំដែងធម៌ចំពោះកិកូទាំងឡាយថា "ម្នាលកិកូទាំងឡាយ បពូជិតមិនគប្បីសេពគប់នូវបដិបទាពីរយ៉ាងនោះឡើយ" ។ ព្រះអង្គសំដែងសរសើរអំពីមជ្ឈិមាបដិបទា គឺសេចក្តីប្រតិបត្តិធម៌យ៉ាងកណ្តាល ជាផ្លូវកាត់ត្រង់ទៅព្រះនិព្វាន ។ មជ្ឈិមាបដិបទានេះ លោកហៅថា អដ្ឋង្គិកមគ្គ (ផ្លូវមានអង្គ ៨ ឬ ផ្លូវប្រកបដោយសាខា ៨) ។ អដ្ឋង្គិកមគ្គនេះ ជាផ្លូវពិតរបស់អរិយ:ទាំងឡាយមានព្រះសម្ពុទ្ធជាដើម, ជាឧបាយដឹប្រពៃសម្រាប់រើខ្ទួនឲ្យរួចបាកទុក្ខ ប្រព្រឹត្តទៅដើម្បីដឹកនាំសត្វឲ្យត្រាស់ដឹងមគ្គ-ផល ដើម្បីព្រះនិព្វានដោយពិត ។

អដ្ឋង្គិកមគ្គ (ផ្លូវមានអង្គ ៨) គឺ

១. សម្មាទិដ្ឋិ ការយល់ឃើញត្រូវ,

២. សម្មាសង្កប្បោ ការត្រិះរិះត្រូវ,

៣. សម្មាវាចា ការពោលពាក្យត្រូវ,

៤. សម្មាកម្មន្តោ ការធ្វើការងារត្រូវ,

៥. សម្មាអាជីវោ ការចិញ្ចឹមជីវិតត្រូវ,

៦. សម្មាវាយាមោ ការព្យាយាមត្រូវ,

៧. សម្មាសតិ ការនឹករឲ្យកត្រូវ,

៨. សម្មាសមាធិ ការដំកល់ចិត្តត្រូវ ។

មគ្គមានអង្គ ៨ នេះ ហៅថា "មគ្គអរិយសច្ច" ពាក់ជាការពិតពួកគ្នា គឺកិច្ចដែលគួរចំរើន ឬគួរប្រតិបត្តិធ្វើឲ្យកើតមានឡើង ដើម្បីដោះស្រាយបញ្ហានៃសេចក្តីទុក្ខឲ្យរួចស្រឡះ ។ មគ្គអរិយសច្ចនេះពាក់ជាកុសលសុទ្ធ ឥតពាក់ព័ន្ធលាយច្រឡំដោយអកុសល ឬអព្យាក្រឹតឡើយ ។

សេចក្តីប្រៀបអរិយសច្ចដោយឧបមា

ទុក្ខសច្ច ដូចជាការៈដ៏ធ្ងន់, សមុទយសច្ច ដូចជាការៈដែលយកទៅការៈធ្ងន់, និរោធសច្ច ដូចជាការៈដែលទម្លាក់ចោលនូវការៈធ្ងន់, មគ្គសច្ច ដូចជាឧបាយដើម្បីទំលាក់ចោលនូវការៈ ។ មួយទៀត ទុក្ខសច្ច ដៀបដូចជាភ្នែក, សមុទយសច្ច ប្រៀបដូចជាមូលហេតុដែលនាំឲ្យកើតភ្នែក, និរោធសច្ច ដូចជាការសះស្បើយចាកភ្នែក, មគ្គសច្ច ដូចជាគេសង្ឃៈសម្រាប់អោបភ្នែក ។

សេចក្តីទុក្ខគាំងអស់ ពាក់ជាផលកើតអំពីជម្ងឺជម្ងាត់ ឬ អំពីសត្រូវបៀតបៀនជាដើម តែងគ្របសង្កត់ប៉ះពាល់កាយចិត្តរបស់មនុស្សសត្វគ្រប់ ។ គ្នា, សេចក្តីទុក្ខ ជាគ្រឿងធ្ងន់បំផុតដែលយើងគួរកំណត់ចំណាំតទៅ ។

តិរេសគាំងឡាយ មានអវិជ្ជាតណ្ហាជាដើម ពាក់ជាហេតុ ទុក្ខដូចជាគ្រឿងបឺតជប់ នូវសេចក្តីទុក្ខមានជាតិទុក្ខជាដើម ។ មនុស្សសត្វកន់លោកនេះ កាលបើនៅមានតិរេសជាបច្ច័យ, ការខ្ជួលកំណើត

ក្នុងភពថ្មីៈ៣តរបស់មនុស្សក៏រមែងមាន ដរាបនោះ(*) ។

គុណជាតិដ៏ឧត្តមបំផុតនៃព្រះពុទ្ធសាសនានោះ គឺព្រះនិព្វាន ដែលអាចកំចាត់បង់ទូ កិលេសទាំងអស់ចាន, ទំលាក់ចេញនូវការៈដ៏ធ្ងន់ ហានការៈគឺទន្ទ ៥ ជាដើម ចាត់ជាផលនៃបរមសុទ ។ និព្វាននេះ ចាត់ជាកិច្ច ដែលយោគាវចរគួរផ្ចើឲ្យជាក់ច្បាស់ ។

ផ្លូវប្រតិបត្តិ ដើរឆ្ពោះទៅរកព្រះនិព្វាននោះ គឺអដ្ឋង្គិកមគ្គ ចាត់ជាហតុ ជាឧបាយដ៏ប្រសើរបំផុត, ដែលគួរចំរើនគួរប្រតិបត្តិតាម ដូចពណិនាមកនេះឯង ។

ចប់អរិយសច្ចកថាសង្ខេប ប៉ុណ្ណោះ ។

---

*អង្គការរបស់រដ្ឋបានបង្កើតរៃដ្ឋសាស្ត្រ, មន្ទីរពេទ្យ, វិដ្ឋាផ្សំទសចសម្រាប់ព្យាបាលរោគរបស់មហាជនឲ្យមានសុទភាពរាងកាយ ដើម្បីដោះស្រាយបញ្ហានៃសេចក្តីទុក្ខដែលកើតអំពីរោគាពាធផ្សេង ។ ដ្ឋចយ៉ាងមន្ទីរពេទ្យព្រះសង្ឃដែលកើតៈឡើងអំពីតំនិតដ៏ត្រាលដ្រៅនៃពុទ្ធ-បរិស័ទទាំងបព្វជិតទាំងគ្រហស្ថមានឯកទត្តម ឃួន-ណៃ ជាប្រធាននៃសមាគមតិណាន សង្ត្រោះជាដើម ។



សុទ្ធិកថា

ព្រះមហាមូល-អ្ចិវត្ថមហាមន្ត្រី

រៀបរៀង

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស (ពាដិង) ។

សូមនមស្ការបំពោះព្រះមានព្រះកាត ជាព្រះអរហន្តសម្មាសម្ពុទ្ធកន្តនោះ (ព្រមទាំងព្រះធម៌ នឹងព្រះអរិយសង្ឆ ដោយសេចក្តីគោរព) ។

រៀលានេះ អាត្មាកាពសូមសំដែងធម៌តាមសមគួរជល់កាលរៀលា, ធម៌ដែលត្រូវសំដែងក្នុងពាសនេះ គឺសំដែងអំពីបាលីមួយមាំត់ថា សុទ្ធិ ។ សុទ្ធិ-ស័ព្ទនេះ ប្រែថា សេចក្តីបរិសុទ្ធិ គឺស្អាតបាតជ្រះស្រឡះ ឥតមានមន្ទិលសៅហ្មង ។

ឯសុទ្ធិនេះ ចែកជាប្រភេទមាន ៣ គឺ កាយសុទ្ធិ សេចក្តីបរិសុទ្ធិកាយ ១, ភាបាសុទ្ធិ សេចក្តីបរិសុទ្ធិវាចា ១, មនោសុទ្ធិ សេចក្តីបរិសុទ្ធិចិត្ត ១ ។

កាយសុទ្ធិ សេចក្តីបរិសុទ្ធិគឺសេចក្តីស្អាតកាយនោះ បានជល់ការស្អាតក្នុងឥរិយាបថទាំង ៤ គឺដេកស្អាត ដើរល្អ ឈរសមរម្ស អង្គុយត្រឹមត្រូវ មានរបៀបរៀបរយមិនឲ្យទាស់ក្នែកទើសចិត្តគំនិតអ្នកដទៃ ។

ដេកស្អាត គឺទីកន្ទែងដេកត្រូវបោសប្រាសត្រវសឲ្យស្អាតបាតត្រូវសំអាតត្រែ-កន្ទេល-ពូក-ទ្នើយ-មុងឲ្យស្អាតជានិច្ច; ហើយដេកដោយមានស្មារតីប្រុងប្រយ័ត្ន កុំឲ្យទូចបរិយារបស់មនុស្ស, ការដេកនោះ

ត្រូវដេកក្នុងទីដ៏សមគួរ គឺទីកន្ទែងមានរនាំងសន្ទិយាសម្រាប់បិទបាំងនឹង
បន្ទប់មានទ្វារបិទបើកបានជាដើម, ត្រូវកំណត់ពេលដេកនឹងពេលក្រោក
ត្រូវដេកឲ្យសមរម្យកុំដេកច្រដេងច្រដាងឥតសណ្ឋាប់ធ្នាប់ ។ ការដេកល្ម
រៀរចាកទោសអាក្រក់ដូចបានពោលមកនេះ ហៅថា ដេកស្អាត ។

ដើរល្អ គឺការដើរត្រឹមត្រូវផុតអំពីទោសផ្សេង ។ ដូចតទៅ ៖ គឺការ
ដើរមិនថ្នមដើងក្នុងទីដែលគួរថ្នម, ដើរជាក់ដើងទ្ចាំងពេក ជាទំនាស់ដល់
ត្រចៀកអ្នកដទៃ, ដើរខុសពេលវេលា នាំឲ្យគេរង្គៀសប្រកាន់ថាដើរ
ល្ឆបប្ចន់គេ, ដើរជាន់ដំណាំគេមានពោតសណ្ឋោកជាដើម, ដើរលុក
លុយស្ឆនប្ឆារគេជាដើម, ដើរលេងឥតប្រយោជន៍ខាតការងារខាតការ
រៀនសូត្រជាដើម ។ ការដើររៀរចាកទោសដូច្នេះជាដើម ហៅថា
ដើរល្អ ។

ឈរសមរម្យ គឺឈរក្នុងទីដែលគួរឈរ មិនឈរកណ្ឋាលមាត់
ទ្វារ នឹងផ្ទូវធ្វា ផ្ទូវថ្នល់ជាដើម មិនឈរឲ្យទាស់ត្នែកទាស់ការងារគេ,
ឈរដោយគោរពដល់បុគ្គលដែលគួរគោរព, មិនឈរឲ្យមានគ្រោះថ្នាក់
ព្រោះការឈរ ដូច្នេះជាដើមហៅថា ឈរសមរម្យ ។

អង្គុយត្រឹមត្រូវ គឺអង្គុយក្នុងទីដែលគួរអង្គុយ, អង្គុយគោរព
ដល់បុគ្គលដែលគួរគោរព, មិនអង្គុយត្រង់កន្ទែងដែលត្រូវគេដេញចេញ,
មិនអង្គុយទាងលើប្ចទាងមុខ នៃបុគ្គលដែលមានគុណធមិ គុណសម្បត្តិខ្ពស់
ជាងខ្ឆន, មិនអង្គុយក្នុងទីប្រកបដោយគ្រោះថ្នាក់, មិនអង្គុយនាំឲ្យទាស់

ចិត្តទាស់ក្នែកទាស់ការសារតេ, អង្គុយតាមលំដាប់ធំ-តូចឬចាស់ខ្ចី, អង្គុយ
សមរម្យតាមកាលៈទេសៈ, ដូច្នេះជាដើមហៅថា អង្គុយត្រឹមត្រូវ ។ ឥរ-
យាបថទាំង ៤ គឺការដេក-ដើរ-ឈរ-អង្គុយ ស្អាតបាតល្អសមរម្យត្រឹមត្រូវ
ដូចបានសំដែងមកនេះ ហៅថា កាយសុទ្ធិ សេចក្តីបរិសុទ្ធិកាយ ។

ការសារដែលធ្វើដោយកាយរបស់មនុស្សទាំងឡាយក្នុងលោក ជា
ស្នាដៃរបស់ជាងធ្សេងៗ គឺជាងស្ងិទ្ធ ជាងឥដ្ឋកំបោរ ជាងឈើ ជាងមាស
ប្រាក់ ជាងក្អមធ្នាំង ជាងក្បាច់រចនា ជាងតំនូរតូរវាស ជាដើម ដែល
មានស្នាដៃល្អស្អាតត្រឹមត្រូវសមរម្យ ពួកសាមញ្ញជនឃើញហើយ តួ
ស្រឡាញ់ចូលចិត្ត, ដូចប្រាសាទអង្គរវត្តដែលជាកេរ្តឺដំណែលរបស់បុព្ធ-
បុរសយើងបានសាងទុកមកជាយូរអង្វែងហើយ មហាជនច្រើនប្រទេស
តែងនាំគ្នាមកមើលសព្វថ្ងៃ តែងកោតសរសើរថា ល្អស្អាតត្រឹមត្រូវ
អស្ចារ្យ ។ អំពើរបស់ជាងបែបនេះ ក៏ហៅថា កាយសុទ្ធិ សេចក្តីបរិសុទ្ធិ
កាយ ដោយបរិយាយ ។

១ ទៀត សេចក្តីទូល់ទ្វាយដោយកាយ ក្នុងកុសលកម្ម ក៏ចាត់ជា
កាយសុទ្ធិ សេចក្តីបរិសុទ្ធិកាយដែរ ដូចជាបុគ្គលណាមួយ មិនមានទ្រព្យ
សម្បត្តិនឹងធ្វើទាន មានតែកម្ទាំងកាយជួយតេ ក្នុងការបុណ្យកុសល គឺ
ជួយចាត់ចែងទេយ្យវត្ថុមានចីវរជាដើម ឬជួយចាត់ចែងចង្ហាន់បិណ្ឌបាត
ដូចជាដងទឹក ពុះអុសដណ្តាំស្ទូជាដើម ឬ ជួយបម្រើសង្ឆដោយតោរព
ឬ ជួយធ្វើសេនាសនៈដោយកម្ទាំងកាយដូច្នេះជាដើម ក៏ហៅថា កាយសុទ្ធិ

សេចក្តីបរិសុទ្ធិកាយវៃរៈ ។

ការមិនបៀតបៀនសត្វ គឺមិនធ្វើពុក្ខធ្វើបាបដោយឥតមេត្តា, មិនវាយសំពងដោយដំបងព្រងនឹងជាដើម, មិនកាប់ចាក់ដោយគ្រឿងសាស្ត្រាវុធមិនប្រហារជីវិតបង់១, ការមិនបំបិទបំបាំងនៃបន្ទុំយកទ្រព្យគេ មិនបំបាត់ប្រព្រែន្ទ័យកទ្រព្យគេ មិនលបលួចប្លន់កំហែងជណ្តើមធក់យកទ្រព្យគេ១ ការមិនផ្តើមបរាកម្ម គឺមិនប្រព្រឹត្តអសទ្ធម្មនឹងប្រពន្ធគូនគេ ដែលជាអំពើធ្វើគេឲ្យអាប់កេរ្តិ៍ឈ្មោះ កើតសេចក្តីអៀនខ្មាសតូចចិត្តខ្លាំង ក្រៃមុខក្រំដើមទ្រូង១, គឺង ៣ នេះហៅថា កាយសុទ្ធិ សេចក្តីបរិសុទ្ធិកាយវៃរៈ ។

វិបាសុទ្ធិ សេចក្តីបរិសុទ្ធិវាចានោះ គឺការពោលពាក្យសំដីដែលពិតត្រូកដ មិនកុហកបោកបញ្ឆោតបំភ័ន្តអ្នកដទៃហៅថាពាក្យសច្ចៈ, សច្ចៈនេះជាចារមីធម៌ របស់ព្រះពោធិសត្វគឺង ឲ្យ ជាធម្មជាតខ្ជែងពាត់ ប្រៀបដូចផ្កាយព្រឹក តែងរះឡើងក្នុងវេលាមុនព្រឹកបន្តិច ខ្ជែងពាត់ពាល់ថ្ងៃមិនប្រែប្រួល មនុស្សលោកអាចយកជាគតិបាន វេលាយប់ម៉ែកាលណាឃើញផ្កាយព្រឹករះឡើងហើយ គេយល់ជាក់ថា ជិតភ្លឺហើយ, ពាក្យសច្ចៈនោះប្រៀបដូចជាផ្កាយព្រឹកនោះឯង; ពាក្យសច្ចៈនេះហៅថា វាចាសុទ្ធិ សេចក្តីបរិសុទ្ធិវាចា ។

ពាក្យសំដីផ្សេងប្រមុំប្រមូលឲ្យកើតសាមគ្គីសេចក្តីត្រមត្រៃង, ការមិននិយាយសីកសៀតញុះញង់ឲ្យគេឈ្លោះបែកគ្នា, ការនិយាយផ្សះផ្សារពាងជនដែលកើតវិវាទឲ្យសង្គាយខែងគ្នា ឲ្យជានឹងគ្នាវិញ, ការ

និយាយបវិនូមកម្ចាំងនាំឲ្យពួកជនដែលកប់អានគ្នាហើយ ឲ្យរឹងរិតតែកប់អានគ្នា ស្រឡាញ់គ្នាខ្ចាំងជាងមុនទៅទៀត, ពាក្យសំដីដូច្នេះជាដើម ក៏ហៅថា វាចាសុទ្ធិ សេចក្តីបរិសុទ្ធិវាចា ។

ការនិយាយពាក្យទន់ផ្អមពីរោះ ជាទីគាប់ត្រចៀកត្រូវចិត្តអ្នកជទៃ, ការមិននិយាយពាក្យទ្រគោះចាក់ដោតបញ្ជឹកិត្តគេ, មិនដេរប្រទេចឲ្យអាស្រូវកាសជល់ត្រចៀកនឹងចិត្តអ្នកជទៃ, ការនិយាយពាក្យដូច្នេះជាដើម ក៏ហៅថា វាចាសុទ្ធិ សេចក្តីបរិសុទ្ធិវាចា ។

ការនិយាយអំពីប្រយោជន៍ នឹងសេចក្តីចំរើនទាំង៦ប្រការ គឺផ្ទូវលោក១ ផ្ទូវធម៌១, មិននិយាយពាក្យកេយកយផតប្រយោជន៍, មិននិយាយពាក្យតូកកំផ្ទងលេងសើចផតប្រយោជន៍ផតអំពើ នេះក៏ហៅថា វាចាសុទ្ធដែរ ។

ការនិយាយផ្ទូវលោកនោះ គឺនិយាយពីវិជ្ជា ការបេះដឹងនឹងការងារដែលផតទោស នាំឲ្យចំរើនធនធានចំរើនអាជីវកម្ម ចំរើនសេចក្តីសុខ ផតមានទោសសត្រូវ ។

ក៏ឯការនិយាយផ្ទូវធម៌នោះ គឺការរៀរចាកតិរច្ឆានកថាទាំង ៣៦ ហើយនិយាយអំពីកថាវត្ថុ ១០ ប្រការជាដើម, កថាវត្ថុ ១០ ប្រការនោះគឺ អប្ឈិច្ឆតាកថា និយាយអំពីសេចក្តីប្រាថ្នាតិច១, សន្ថុដ្ឋិកថា និយាយអំពីសេចក្តីសន្តោសគឺត្រេកអរតាមបានតាមមាន១, បវិវេកកថា និយាយអំពីសេចក្តីស្ងាត់ចាកពួកគណៈ១, អសំសគ្គកថា និយាយអំពីការមិនច្របូកច្របល់ ដោយគ្រហស្ថ (នៃបព្វជិត) ១, វីរិយារម្ភកថា

និយាយអំពីការប្រាវត្ថនូវព្យាយាម ១, សីលកថា និយាយអំពីសីល ១, សមាធិកថា និយាយពីសមាធិ ១, បញ្ញាកថា និយាយអំពីវិបស្សនា ១, វិមុត្តិកថា និយាយអំពីអរហត្តផល ១ វិមុត្តិញ្ញាណទស្សនកថា និយាយអំពីការដឹងការឃើញច្បាស់នូវអរហត្តផលដែលខ្ជនបានហើយ ១; ការនិយាយពាក្យមានប្រយោជន៍ទាំងផ្ទូវលោកផ្ទូវធម៌ ដូចបានពោលមកនេះក៏ហៅថា ក់ចាសុទ្ធិ សេចក្តីបរិសុទ្ធិក់ចាដែរ ។

ម្យាំងទៀត ក់ចាជាសុភាសិត គឺពាក្យដែលល្អមានប្រយោជន៍ក៏ពប់ថាជាក់ចាសុទ្ធិដែរ, ឯក់ចាជាសុភាសិតនេះ ប្រកបដោយអង្គ៥ ដូចតទៅនេះ ៖

១. កាលេន ច ភាសិតា ហោតិ និយាយក្នុងកាលគួរគឺកាលគួរនិយាយទើបនិយាយ បើមិនគួរទេក៏មិននិយាយ ។

២. សច្ចា ច ភាសិតា ហោតិ និយាយពាក្យពិតប្រាកដទៀងទាត់មិនកុហក ។

៣. សណ្ហា ច ភាសិតា ហោតិ និយាយពាក្យល្អិតល្អទន់ផ្អមពីរោះជាទីតាប់ចិត្តនៃជនទាំងឡាយ ។

៤. អត្ថសញ្ហិតា ច ភាសិតា ហោតិ និយាយពាក្យប្រកបដោយប្រយោជន៍ក្នុងលោកនេះនឹងលោកខាងមុខ ។

៥. មេត្តចិត្តេន ច ភាសិតា ហោតិ ពាក្យនិយាយ

ប្រកបដោយមេត្តាចិត្តពិត ។ មិនទិយាយពាក្យប្រកបដោយពោសៈស្អប់ខ្ពើមឡើយ ។

ភាជាសុភាសិតប្រកបដោយអង្គ ៤ ដូច្នេះ ក៏ហៅថា ភាសុទ្ធិ សេចក្តីបរិសុទ្ធិភាព ។

មនោសុទ្ធិ សេចក្តីបរិសុទ្ធិចិត្តនោះ គឺគំនិតរបស់មនុស្សទើមួយ ។ ដែលជាអ្នកស្រឡាញ់សុចរិត តែងប្រើគំនិតល្អដូចតទៅនេះ៖

១- គំនិតឈមទៅ ខេះទៅ ជ្រេះទៅ ផ្លឿងទៅ រមែលទៅរកសេចក្តីប្រាថ្នាតិច បន្ថយសេចក្តីលោភឲ្យស្រាលស្តើងទៅដោយលំដាប់, គំនិតប្រកបដោយសេចក្តីសន្តោសត្រេកអរតាមបានតាមមាន, គំនិតប្រកបដោយហិរោត្តប្បៈ សេចក្តីខ្មាស់បាបខ្លាចបាប, គំនិតលះបង់អំពើចង់បានឥតខ្មាស់, គំនិតស្មោះត្រង់មិនត្រូវការនឹងយកទ្រព្យគេមកធ្វើជាទ្រព្យខ្លួន, សេចក្តីត្រិះរិះកន្លងការចេញចាកកាម ។

២- គំនិតប្រកបដោយមេត្តាគឺការស្រឡាញ់សត្វខ្លួនទៅ ដូចមាតាស្រឡាញ់បុត្រ មិនមានភ្លាចដល់ដនណាមួយឡើយ ប្រកបដោយការុណា គឺសេចក្តីអាណិតអាសូរសត្វខ្លួនទៅដែលបានសេចក្តីទុក្ខ ចង់ឲ្យសត្វបានរួចចេញអំពីទុក្ខ, គំនិតមិនត្រូវការនឹងបៀតបៀនសត្វណាមួយឲ្យបានសេចក្តីទុក្ខលំបាកឡើយ ។

៣- គំនិតយល់ត្រូវល្អ មិនខុសជាកសិការធម៌ ស្គាល់សេចក្តីទុក្ខព្រឹនប្រការ គឺដឹងច្បាស់ថា សេចក្តីទុក្ខគឺឆន្ទរាគៈយ៉ាងណាខ្លះ មិនស្ទើ

សេចទុក្ខព្រោះនឹងខន្ធ៥ឡើយ ខន្ធ៥ជាសភាវៈនាំមកនូវសេចក្តីទុក្ខវិក្រៃ
លែង; ដឹងច្បាស់នូវតណ្ហា គឺសេចក្តីប្រាថ្នាស្រឡាញ់រាប់អាននូវអា-
រម្មណ៍ទាំង៥ គឺរូប, សំឡេង, ក្លិន, រស, ឥដ្ឋព្ធ ថាជាហេតុបណ្តាល
ឲ្យកើតកងទុក្ខត្រប់ប្រការ; ដឹងច្បាស់នូវនិរោធគឺព្រះនិព្វានថាជាសភាវ
រំលត់នូវទុក្ខនឹងតណ្ហាបានសព្វត្រប់; ដឹងច្បាស់នូវមគ្គប្រកបដោយអង្គ៨
ថាជាផ្លូសំរាប់ដើរទៅកាន់និរោធគឺព្រះនិព្វានជាហានបរមសុខ; គំនិតល្អ
ទាំង ៣ យ៉ាងនេះហៅថា មនោសុទ្ធិ សេចក្តីបរិសុទ្ធចិត្ត ។

អាត្មាភាពពណិនាមកក្នុងសុទ្ធិកថាក៏ល្មមដល់ការបញ្ចប់ហើយ ។

ទីបំផុតនៃធម្មទេសនានេះ សូមថ្វាយព្រះរាជកុសលចំពោះព្រះករុណា
ជាអម្ចាស់ជីវិតទាំងពីរព្រះអង្គ នឹងសម្តេចព្រះទបយុវរាជព្រមទាំងព្រះរាជ-
វង្សានុវង្ស សូមផ្ទនបុណ្យកុសលដល់អស់លោក-អ្នករាជការត្រប់តំណែង
នឹងអស់ប្រជាជនក្នុងកម្ពុជរដ្ឋទាំងមូល សូមឲ្យបានសមប្រកបដោយ
សេចក្តីសុខចំរើនក្នុងលោកនេះ សូមឲ្យបានសម្រេចឥដ្ឋមនុញ្ញផលវិបុល-
សុខត្រប់ប្រការក្នុងបរលោក ទីបំផុតសូមឲ្យបានសម្រេចព្រះនិព្វាន ។

ឯវំ សង្ខេបេន សម្មតា ធមិទេសនាក៏ចប់ដោយសង្ខេបតែប៉ុណ្ណេះ ។

ផ្នែកអក្សរសាស្ត្រ

ការអប់រំក្មេងគួរអប់រំនៅផ្ទះឬនៅសាលារៀន ?

ឃុនអត្តកោវិ, ជា - ឃួរ - រៀបរៀង

ការអប់រំបានដល់ការហាត់ចិត្ត ឬបង្ខឹកចិត្តឲ្យផ្ទួតជ្រាបចូលទៅជាប់ជាទបនិស្ស័យ; ពោលដោយសង្ខេប បានដល់ការរៀន, ការតិតនឹងការប្រតិបត្តិ ទាំង ៣ យ៉ាងនេះ សុទ្ធតែជាគ្រឿងសម្រាប់អប់រំកាយវាចា ចិត្តឲ្យផុះជាប់ជាទបនិស្ស័យ បានយ៉ាងល្អ ។

សាលារៀនជាស្ថានសម្រាប់អប់រំកុមាកកុមារី ឲ្យមានបំណោះវិជ្ជាបានយ៉ាងមុតមាំ រាប់ថាជាកន្ទែងសម្រាប់បណ្តុះបណ្តាលសេចក្តីចំរើនដល់ពួកក្មេងបានយ៉ាងសំខាន់ តែនៅផ្ទះក៏ជាទីអប់រំពួកក្មេងបានយ៉ាងល្អណាស់ដែរ ព្រោះផ្ទះជាទីកើតរបស់ក្មេង ក្មេងបានទទួលការចិញ្ចឹមនឹងការអប់រំសិក្សាអំពីបុព្វាចារ្យ គឺមាតាបិតាជាប់ជាទបនិស្ស័យមកមុនគេ ។ ដោយន័យនេះ ក្មេងនឹងល្អឬអាក្រក់ តែងជាប់ទបនិស្ស័យមកអំពីផ្ទះប្រើនជាងសាលារៀន ប៉ើសាលារៀនដែលមានវិន័យតឹងរឹង នឹងមានការសិក្សាល្អផងហើយ ក្មេងឈ្មោះថាធ្ងាក់នៅក្នុងក្រុមចណ្ឌ៉ដ៏ល្អយ៉ាងឯកសូម្បីខាងសាលារៀននឹងមានគ្រឿងដឹកនាំផ្ទងចិត្ត ឬគ្រឿងទបការណ៍ផ្សេង ។ ដែលអាចទាញចិត្តក្មេងឲ្យវិលទៅតាមក៏ដោយ ក៏នៅតែត្រូវ

គាស្រ័យឥទ្ធិពលខាងផ្លូវជួយផងដែរ ព្រោះឥទ្ធិពលខាងផ្លូវ ជាគ្រឿងដែលធាប់ជ្រួតជ្រាបទៅក្នុងដួងចិត្តរបស់ក្មេង ដូចមាតាបិតាបានពោលប្រដៅពាក្យបន្តិចបន្តួចដល់កូន សូម្បីជាពាក្យដែលមិនសូវមានសារៈ កូនក៏ច្រើនតែកួចកាន់ចាំពុកក្នុងដួងចិត្ត ។ ក្មេងខ្លះនិយាយប្រាប់គ្នាថា ម្ពាយខ្ញុំថាដូច្នោះ ឪពុកខ្ញុំថាដូច្នេះ បើអ្នកជាខែត្រៀតតែមាតាបិតាស្តីប្រដៅ តែមិនសូវយកចិត្តទុកដាក់ ដោយគិតថាមិនមែនជាមែទីអាត្មាអញ ។ ហេតុនោះទើបឃើញថា ឥទ្ធិពលខាងផ្លូវអាចបណ្តាលពួកក្មេងឲ្យប្រព្រឹត្តទៅបានទាំងផ្លូវល្អផ្លូវអាក្រក់ផ្លូវចំរើនវិនាស ស្រេចតែឥទ្ធិពលទឹងការអប់រំខាងផ្លូវបណ្តាលឲ្យប្រព្រឹត្តទៅ ។ ផ្លូវណាមានការប្រព្រឹត្តរៀបរយ មានសុខភាពសមគួរតាមហានៈនៃអ្នកគ្រប់គ្រងផ្លូវមានគុណធម៌គួរឲ្យទុកចិត្តអាន ជីវិតរបស់គ្រួសារក្នុងផ្លូវនោះ គួរជាទីត្រេកអរពេកយ, តែបើផ្លូវណាមានការប្រព្រឹត្តផ្ទុយគ្នា (គឺប្រព្រឹត្តអាក្រក់) ជីវិតរបស់គ្រួសារក្នុងផ្លូវនោះមានតែការផ្សារផ្ទុមសៅហ្មង ទីនោះពេញទៅដោយសេចក្តីទុក្ខ ដែលជាគ្រឿងបន្ទុយកំឡាំងមញ្ញារបស់ក្មេង ។

មនុស្សសំខាន់ប្លែមនុស្សបានការក្នុងប្រទេសមួយ ។ ដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញក្នុងលោក លោកចាំនោះច្រើនតែកើតក្នុងគ្រួសារដែលមានអារម្មណ៍ដ៏ល្អ មានការសិក្សាអប់រំទឹងត្រឹងទបករណ៍ ដែលជាគ្រឿងបង្វិលដួងចិត្តឲ្យទៅកាន់សេចក្តីចំរើនបានយ៉ាងរហ័សរហួន, ចំណែកពួកចោរអន្ធពាលដែលប្រព្រឹត្តអាក្រក់ ត្រូវគេចាប់យកទៅធ្វើទោសទណ្ឌកម្មមានជាក់ច្បាស់ជាជើម ព្រោះច្រកបកវត្ថុដែលបង្កឲ្យចលចល

ធ្វើឲ្យក្តៅក្រហាយដល់ប្រជាជនក្នុងសង្គម ក៏មកពីមានការអប់រំសេចក្តីល្អ
បែកខាងផ្ទះមិនគ្រប់គ្រាន់ ហេតុនេះទើបឃើញថា ផ្ទះជាទីកើតនៃសេចក្តីល្អ
អាក្រក់ ចរិយា ការប្រព្រឹត្តិសីលធម៌អនាម័យ ឲ្យមានច្បាប់ទម្លាប់ល្អអាក្រក់
រួមទាំងការខំខ្នុកបំរុងកូនឲ្យល្អអាក្រក់ ទាំងកូនឲ្យរៀនសូត្រឬបុនរកបាន
តាំងអស់ស្រេចតែមេឬគ្រូសារ, ហើយគ្រូសាររបស់ខ្លួនមានសភាពយ៉ាងណា ពួកកូនក្នុងគ្រូសារក៏ងាករេះភាយ៉ាងនោះដែរ កាលបើឃើញថា
បែកខាងផ្ទះមានការសំខាន់ដូចបានពោលមកនេះ ការអប់រំកូនដែលបន្ទៅ
ក្នុងផ្ទះទើបជាកិច្ចមួយដែលមេផ្ទះត្រូវគួរយកចិត្តទុកដាក់ដោយមុតមាំ ។

តាមសាលារៀន យើងនឹងឃើញកូនដែលមានចរិយា អនាម័យនឹង
ការិយាដទៃទៀតជារបើន ។ កូនខ្លះមានចរិយាល្អ គាំងមានយោគ្គជ្រះថា
យើងគាបភាយបានពេញទ្រព័ងមាត់ថា កូនខ្លះមកពីផ្ទះដែលមានការ
អប់រំល្អ អាជីពក្នុងផ្ទះមានសុភាពល្អ កូនខ្លះមានកិរិយាក្រញាំងក្រញ៉ូត
ធាប់ខឹងគ្មានមូលហេតុអត់ធន់ ចរិយាថោក យើងភាយបានថាអាជីពនឹងការ
អប់រំសម្រាប់ផ្ទះនោះមានអាការក្រាស់ក្រាក ។ ការដែលគ្រូសារមានអាជីព
នឹងចរិយាផ្សេងៗគ្នាបែបនេះ ជាកត្តាដ៏ធ្ងន់សម្រាប់សាលារៀនក្រោះ
សាលារៀនត្រូវតែអប់រំប្រៀនប្រែងកូន ដែលមកពីគ្រូសារមានចរិយា
ផ្សេងៗគ្នាឲ្យបានបទល្អ តាមគោលប្រថាននិយម ។ ការដែលសាលារៀន
ត្រូវទទួលតាមរយៈអំពីផ្ទះផ្សេងៗដូច្នេះ ឈ្មោះថាធ្វើការអប់រំពុនដែរ ។
ការអប់រំដូច្នេះមិនសូវបានផលល្អណាប៉ុន្មានទេ ព្រោះកូនមានគោលនៅក្នុង
សាលារៀនតិចនោះប្រការ១ ប្រការមួយទៀតកូនខ្លះមានមារយាទអាក្រក់

មកពីផ្ទះ ទាល់តែហ្លួសកំឡាំងសាលារៀនទឹងប្រៀនប្រដៅទៅហ៊ីយ
ទាំងប្រាកដថាក្មេងចំពូកនេះមានចំនួនប្រើនណាស់ផង ។ វត្ថុបំណង
ដែលនឹងពត់ក្មេងឲ្យជាមនុស្សល្អសម្រាប់ប្រទេសជាតិក្នុងអនាគតនោះជា
បញ្ហាមួយដ៏ធំ ព្រោះហេតុនោះ ទើបត្រូវកែទៃសេចក្តីផ្សេងៗ ដែលជា
មូលហេតុនាំឲ្យក្មេងប្រព្រឹត្តល្អអាក្រក់មុនសិន ។

ដួងហ្ម្ចុទ័យរបស់ក្មេង ដែលកើតមកក្នុងលោក ប្រៀបដូចសំពត់ដែល
សស្អាត ដែលយើងអាចជ្រលក់ជាពណ៌អ្វីក៏បាន ស្រេចតែអ្នកជ្រលក់,
ប៉ើអ្នកជ្រលក់ជាអ្នកដឹងរបៀបនៃការជ្រលក់ ទាំងជំនាញក្នុងការជ្រលក់,
សំពត់ដែលជ្រលក់នឹងមានពណ៌ស្រស់ល្អ ត្មានធ្ងកជាមពពាលពព្រុះ តែ
ការជ្រលក់ឲ្យមានពណ៌ល្អនោះ មិនមែនមកពីការជ្រលក់តែម្យាំងនោះទេ
កាជន៍ដែលប្រើក្នុងការជ្រលក់ ក៏ជាគ្រឿងឧបករណ៍ដ៏សំខាន់ម្យាំង
ទៀតដែរ ឥអាចធ្វើសំពត់ដែលជ្រលក់ឲ្យប្រឡាក់ប្រឡូសឬឲ្យស្អាត
បាតយ៉ាងពិតប្រាកដ អ្នកជ្រលក់ប្រៀបដូចអ្នកគ្រប់គ្រងផ្ទះ កាជន៍ដែល
ប្រើជ្រលក់ ប្រៀបដូចដំណើរការរស់នៅក្នុងផ្ទះ (ឬអាជីពក្នុងផ្ទះ)
ការល្អអាក្រក់នឹងមានប្រើនឬតិច ក៏មកពីការទាក់ទងនៃវត្ថុទាំងពីរ ឥ
អ្នកគ្រប់គ្រងនឹងអាជីពក្នុងផ្ទះអ្នកគ្រប់គ្រងផ្ទះ ខ្ទះបណ្តោយឲ្យអាជីពក្នុង
ផ្ទះប្រព្រឹត្តទៅតាមយថាកម្មស្ទើរតែមិនយកចិត្តទុកដាក់ក្នុងកិច្ចការផ្ទះសោះ
ឡើយ ផ្ទះសម្បែស្មុកស្មាញពេញទៅដោយសម្រាម ទុកដាក់វត្ថុប្រើ
ប្រាសត្មានរបៀបរៀបរយ មិនតែបុំណ្ណោះសោត អ្នកខ្ទះក៏បណ្តោយឲ្យ
អបាយមុខចូលកាន់ត្រួសារមួយកាតទៅទៀត ដូចការដើរលងស្ទើរតែ

មិនដែលនៅផ្ទះ ជាអ្នកលេងការក្នាល់ ជាអ្នកប្រមឹកផឹកស្រវឹងឯបផ្ទះច្នះ
ជាដើម យើងត្រូវដឹងថាចុះបើអាជីពរបស់មេផ្ទះពេញនៅដោយអបាយមុខ
ម្ទ៉ះទៅហើយ គេនឹងមានពេលឯណាមកអប់រំកូនបៅឲ្យល្អទៅបាន តែ
ចំណែកខ្ជូនគេកឹយោងតែអាត្មាមិនរួចទៅហើយ នឹងបែរមុខមកប្រដៅអ្នក
ដទៃឲ្យល្អដូចម្តេចកើត គេមិនមែនខូចត្រឹមតែខ្ជូនគប៉ុណ្ណោះទេ ថែមទាំង
ជ្រលក់ក្មេងដែលនៅក្នុងផ្ទះឲ្យមានពណ៌ធ្ងកជាមពពាលពព្រុះខូចអស់ទៅ
ផង នេះជាការទាស់ខុសថោកទាបមួយយ៉ាង ដែលជាហេតុញ៉ាំងក្មេង
យើងឲ្យទាស់ខុសថោកទាបទៅតាម មកពីការគ្រប់គ្រងនឹងអាជីពគ្រួសារ
មិនល្អ ។

មួយវិញទៀត យើងឃើញថា តាមគ្រួសារផ្សេងៗ ច្រើនបណ្តោយ
ក្មេងឲ្យប្រព្រឹត្តទៅតាមអំពើចិត្ត បើជាកូនអ្នកមានភោគសម្បត្តិ ក៏មាន
ពីលៀងមេដោះជួយបីព ថ្នមយកចិត្តទាល់តែហួសសេចក្តីត្រូវការ ជា
ការសាងនិស្ស័យក្មេងឲ្យបានចិត្តរឹងត្អឹង, ឆាកមកម្ចាងទៀត យើងនឹង
យើញកូនអ្នកទាល់ក្រៈហេមរហាម រកស៊ីបានព្រឹកបាត់ល្ងាច; អាជីព
គ្រួសាររបស់បុគ្គលទាំងនេះ គួរឲ្យអាណោចអាធ័ម, ការទាល់ក្រនឹងការ
ចាំបាច់ របស់គ្រួសារទាំងនេះធ្វើឲ្យម្តាយឪពុករបស់ក្មេង ត្រូវចេញ
ទៅរកទទួលទាន អស់ពេលមួយថ្ងៃវាល់ល្ងាចគ្មានពេលមកមើលថែ
រក្សាកូនទៅ នឹងគ្មានពេលមកមើលផ្ទះសម្បែង បណ្តោយឲ្យប្រព្រឹត្តទៅ
តាមយថាកម្ម ក្មេងក៏នៅកណ្តែងកណ្តោច ចិត្តថ្ងីមក៏ចេះតែស្រៀវទ្ងាច
រួញរា ខ្ទះការគិតនឹកទៅខាងផ្ទូវល្អ ដែលជាហេតុឲ្យកើតបញ្ញា ។

ការថែរក្សាយកចិត្តទុកដាក់ឲ្យនៅជាប់ជានិច្ចនូវការងារដែលខ្លួនបានធ្វើ ឬនិយាយ ឬគិតរួចមកហើយនោះ ដើម្បីមិនឲ្យមានការភ្លេចភ្លាំងឡើយ ។ ការដែលមានចិត្តនឹកឃើញដូចនេះ ហៅថាសតិ ។ ការដែលមានចិត្តដឹងច្បាស់ក្នុងការងារដែលខ្លួនធ្វើ ឬនិយាយ ឬគិតរួចមកហើយនោះ ហៅថាសម្បជញ្ញៈ ។ ការដែលមានចិត្តនឹកឃើញ និងដឹងច្បាស់ក្នុងការងារដែលខ្លួនធ្វើ ឬនិយាយ ឬគិតរួចមកហើយនោះ ហៅថាសតិសម្បជញ្ញៈ ។ ការដែលមានសតិសម្បជញ្ញៈនេះ ជាគុណធម៌ដ៏ប្រសើរក្រៃលែង ដែលមានសេចក្តីប្រយោជន៍ច្រើនយ៉ាងណាស់ ។ ដូចជាការដែលមានសតិសម្បជញ្ញៈ ក្នុងការដែលនឹងទៅ ឬមក ឬឈរ ឬអង្គុយ ឬដេក ឬភ្ញាក់ ឬនិយាយ ឬនៅស្ងៀម ឬបត់ ឬលាតដៃជើង ឬបិទភ្នែក ឬបើកភ្នែក ឬស្លៀកពាក់ ឬបរិភោគ ឬបន្ទោបង់ ឬដើរ ឬឈប់ ឬគេង ឬភ្ញាក់ ឬនិយាយ ឬនៅស្ងៀម ជាដើម ។ ការដែលមានសតិសម្បជញ្ញៈក្នុងការងារទាំងនេះ ហៅថាសតិសម្បជញ្ញៈ ។ ការដែលមានសតិសម្បជញ្ញៈ

ក្មេងដែលមានធម្មជាតិចូលចិត្តយកតម្រាប់ នឹងដាកនេវៀកក្នុងផ្ទូវ
ណាក៏បានដោយដាយ បើផ្ទូវនោះមានអ្នកធំដឹកនាំផងហើយ ក្មេងតែង
ធ្វើទុកក្នុងចិត្ត ហើយធាប់ចាំបានយ៉ាងល្អបំផុត សេចក្តីកាំងក្ទាត់នឹង
ការទាស់ទុសបន្ទិចបន្ទួច ដែលអ្នកធំបានធ្វើហើយនោះ ក្មេងប្រើនយក
ជាតួយ៉ាង ព្រោះដូច្នោះត្រឹត្តិការណ៍ត្រប់យ៉ាងក្នុងផ្ទះ ទើបជាមេពុម្ពរបស់
ក្មេងយ៉ាងសំខាន់ម្យ៉ាងដែរ ។ ក្មេងមានជីវិតរស់នៅក្នុងផ្ទះចំរើនវ័យមួយថ្ងៃ
បន្ទិចមួយថ្ងៃបន្ទិច ការគឹតនឹក កិរិយាមារយាទ សីលធម៌ ការសមាគម
ក៏ចំរើនម្តងបន្ទិចម្តងបន្ទិច ហើយដុះជាទបនិស្សយជាប់នៅនឹងចិត្តសន្ទាន
ជ្រាកដទ្បើង, កិរិយាមារយាទទាំងនោះជាប់ជិតនៅនឹងរូបរាងកាយរបស់
ក្មេងរហូតទៅ, បើក្មេងណាមានកិរិយាអាក្រក់ជាប់មកពីផ្ទះ កាលមកកាន់
ប្រជាគមគឺសាលារៀន ក៏នឹងនាំកិរិយាអាក្រក់ទាំងនោះមកព្រោះសាប
នៅសាលារៀន ដូចរុយនឹងកណ្ពុរដែលនាំមេរោគមកព្រោះសាបក្នុងខ្ទួន
មនុស្ស ។ រឿងនេះបើអំណាចត្រៀងជ្រាបជ្រាមទាងសាលារៀនមានត្រប់
ត្រាន់ក៏មិនសូវជាការអ្វីណាស់ទេ តែបើអំណាចទាងសាលារៀនជ្រាបជ្រាម
មិនបានហើយ ក៏ពិបាកនឹងរកថ្នាំបន្សាបរោគចិញកនេះ ។ រោគចំបួរដែល
ត្របសង្កត់ក្មេងជ្រុលមកពីផ្ទះហើយនោះ ជាជម្ងឺធ្ងងដល់ក្មេងដទៃរហូត
ដល់សាលារៀនដទៃទៀតផង ចួនកាលទំរាំយើងដឹងខ្ទួនអាការរោគក៏ធ្ងន់
ពេញទំហឹងរកថ្នាំកែទៃមិនត្រូវ ។

លោកអ្នកត្រប់ត្រងក្មេងខ្ទះ តែងគិតថា កាលបានយកកូនទៅទុក
នៅសាលារៀនហើយ ការៈតទៅជានាទីរបស់សាលារៀន ។ ការគិត

ដូច្នេះជាការខុសស្រឡះក្រោះចំពោះតែសាលារៀន ខ្ញុំធ្វើនាទីជាំនងបង្ហាត់បង្ហាញវិញ្ញា ជាំនអប់រំក្មេងឲ្យបានល្អយ៉ាងពិតប្រាកដដោយមិនបានខ្វល់ការប្រៀនប្រដៅអំពីម្ដាយឪពុកសោះឡើយនោះ ជាការពិបាកយ៉ាង. ក្រៃលែង ព្រោះសាលារៀននោះសោត មិនមែនជាមន្ទីរពេទ្យដែលមានគ្រូពេទ្យជំនាញ ដែលអាចបំបាត់រោគចំប្លែរបស់ក្មេងដែលជាប់មកអំពីផ្ទះ ឲ្យបាត់ដូចគេប្ដូរគ្រាប់ចោលទៅអស់នោះទេ ចួនកាលរោគកំណាចនោះបូលស៊ីក្មេងទាល់តែហួសសាលារៀនតែម្ដងក៏មាន ។ ការបំបាត់រោគផ្សេង ។ នោះចាំគ្រូពេទ្យដ៏ជំនាញក៏ត្រូវពិសោធមើលសម្គាល់នៃរោគនោះដែរ; ។ ខ្ញុំដូចម្ដេចមិញ ការដែលយើងខ្ញុំបំបាត់រោគ គឺការប្រព្រឹត្តអាក្រក់, ការគាស់ខុស, ការទ្វិលច្រអូសរបស់ក្មេងនោះ ហើយបណ្ដុះបណ្ដាលសេចក្ដីល្អ ឲ្យជ្រុះជាលក់លតុម្ពដល់ក្មេងនោះ ក៏ត្រូវពិសោធមើលសម្គាល់ដើមរបស់ក្មេងគឺផ្ទះដូច្នេះដែរ ។

មេបាំនៃផ្ទះតប្បីធ្វើខ្លួនឲ្យដូចជាកញ្ចក់ថ្នុះស្រមោលដ៏ល្អ ដែលគួរខុកជាគួយ៉ាងដល់ក្មេងនៅផ្ទះ ដូចពួកគ្រូបាំនឡាយដែលបានធ្វើខ្លួនឲ្យដូចជាកញ្ចក់ថ្នុះស្រមោលដ៏ល្អខុកជាគួយាំន ដល់ពួកសិស្សសាលា ។ មេបាំនៃផ្ទះតប្បីយកចិត្តខុកជាក់ក្នុងការអប់រំក្មេងរបស់ខ្លួន ឲ្យប្រហែលប្ដូច្រូនជាងរបស់សំខាន់ដទៃ ព្រោះក្មេងពាំនេះកាលចំរើនឡើងហើយ ខ្ញុំបានជាគោលចាក់សំពាប់តវង្ស្រគូលឲ្យថតចេះចំរើនតទៅ ព្រោះដូច្នោះការកែទំនុកបំរុងក្មេងគ្រប់ផ្លូវប្ដូគ្រប់ប្រក ដើម្បីបណ្ដុះបណ្ដាលសេចក្ដីចំរើនខ្ញុំនការសម្បូណ៌ នោះជាកិច្ចដែលគួរបំពេញដោយ

ខាងមិនបាន ព្រោះយើងត្រូវបណ្តុះបណ្តាលដូចការដាំដើមឈើ មិនមែន
ធ្វើដូចការសង់ផ្ទះឥដ្ឋ ឬផ្ទះថ្មនោះទេ ព្រោះក្មេងជាសភាពដែលមានជីវិត
ចិត្តថ្លើម ។ ការអប់រំប្រៀនប្រដៅក្មេង ទើបត្រូវផ្តើមធ្វើសភាលះក្មេងនៅ
មានសភាពជាឈើលំពង់ទើតឹកក្នងបថមវ័យនៅផ្ទះជាមុនសិន ។ ផ្ទះជាទ្រនាប់
ជើសំខាន់នៃជីវិតរបស់ក្មេង ខាងផ្ទះត្រូវធ្វើទ្រនាប់នេះឲ្យមាំ ហើយបញ្ជូន
តាមរយៈទៅសាលារៀន ដើម្បីឲ្យសាលារៀនជួយតួតដៃតាក់តែង សាង
រចនាទ្រនាប់នេះ ឲ្យមាំមួនទើងប្រណិតបញ្ចង់ឡើង ។ អ្នកគ្រប់គ្រងផ្ទះត្រូវ
ធ្វើផ្ទះឲ្យជាមូលដ្ឋាក់ជាទីសុខសប្បាយរីករាយដល់ក្មេង ឲ្យចាន់យ៉ាងល្អ
បំផុត ដូចម្ហូបពោជ្ឈ ម្ហូបដែរ ដែលឲ្យសេចក្តីសុខដល់បណ្តាសត្វទើង
បណ្តាជនទូទៅយ៉ាងនោះដែរ ។ អ្នកគ្រប់គ្រងផ្ទះត្រូវប្រព្រឹត្តបែបបទហ៊ាងល្អ
ក្នុងការនិយាយការប្រព្រឹត្តគំនិតមារយាទគុណធម៌ ដែលជាគ្រឿងទិយម
ពាប់អានផ្សេង ។ ត្រូវឲ្យមានមេត្តា ករុណា ការអើពើមេត្រីភាពនឹងវប្បន-
ធម៌ដទៃទៀត ដែលជាគ្រឿងជីកទាំងដួងចិត្តក្មេង ឲ្យបង្ហាញនៅរកសេចក្តី
ល្អប្រពៃពាំងពួង ហើយត្រូវទុកឲ្យហាស់ភ្ញៀនក្រើនរំលឹកក្មេងឲ្យមាន
មានអត់ធ្មត់ទុកឲ្យហ៊ានសួរគ្រូរៀន ព្រមទាំងការហាត់ប្រាណចេះអត់ធន់ក្តៅ
ត្រជាក់ស្រេកឃ្លាន ធ្វើខ្លួនឲ្យរឹងប៉ឹង ឲ្យជាទីពឹងរបស់ខ្លួនបាន ព្រមទាំង
ចេះអត់ធន់ចំពោះអនិដ្ឋារម្មណ៍ មានត្រូវតែដោះពោលរកបែបត់ប្រមាថមើល
ងាយជាដើម ហើយត្រូវចេះស្រឡាញ់ការយុត្តិធម៌ ស្រឡាញ់បងប្អូនត្រួ-
សារ ឬហាប្រទេសជាតិ ឲ្យចេះធ្វើប្រយោជន៍ខ្លួនទើងប្រយោជន៍អ្នកដទៃ ។

អាជីពតឺការរស់នៅរបស់ជនជាតិយើងកន្ងសម័យនេះ មិនទាន់មាន

ការគ្រប់គ្រងក្មេងក្នុងការអប់រំសិក្សាឱ្យល្អគ្រប់គ្រាន់ទេ ព្រោះមេបាគ្រូសារខ្លះដែលចង់ឱ្យកូនៗទៅមានមុខមាត់ធំធាត់គេ ច្រើនបញ្ជូនកូនៗទៅឱ្យទៅសាលារៀនជាន់ខ្ពស់ច្រើនជាង; អ្នកដែលចេះវែសសាលារៀនដែលមានការអប់រំល្អ មានរបៀបរៀបចំយ៉ាងគួរឱ្យចម ក្មេងក៏ចំណេះជាន់ខ្ពស់ តែខ្លះចំណេះដែលជាគ្រឿងយកកូនបួច ហើយសភាពរបស់គ្រួសារខ្លះ ខ្លះការស្រឡាញ់ពាក់ព័ន្ធគ្នា ច្រើនមានតែជម្លោះប្រកែក យកឈ្នះយកប្រៀប គាលបើជួបនឹងអាជីពក្នុងជីវិតមានសេចក្តីសុខដូចម្តេចបាន ទំនងមានតែការអាក់អន់ស្រពន់ចិត្តដល់គ្នាទៅវិញទៅមក តាំងចិត្តថ្មើមក្មេងក៏ត្រូវខោសតំយប្រឡូសក៏ឃញ្ជ ឃ្យាដាហេតុឱ្យស្រីវិទ្យាចរញ្ជ្រាក ប្រាសជាកយោនិសេមនសិការៈដ៏ល្អប្រពៃ, មេបាគ្រូសារខ្លះទៀតបានបណ្តាយក្មេងឱ្យប្រព្រឹត្តក្នុងផ្លូវអបាយមុខ ដូចបណ្តាយឱ្យគប់បាចមិត្តដែលនាំឱ្យចេះលេងល្បែងបៀ ល្បែងស្រីញី លេងសុក មើលកុនល្ងាន ពាល់ថ្នាំដក់ជាដើម ដូច្នេះជាដើម មេបាគ្រូសារបណ្តាយខាលតែជាប់ជាទម្លាប់ ខាងក្នុងចិត្តសន្ធានដោយមិនបានដេរពោលពេលពត់ប្តូរយ៉ាងដំណើរតាក់តែ ឱ្យពេលចាលដើម្បីលះការប្រព្រឹត្តិតាក្រក់ចោលចេញ គួរនឹកដល់សុភាសិតមួយបទថា "បើមិនហ៊ានដេរពេលកូនទេ ក៏ត្រូវបណ្តាយកូនឱ្យខូចប៉ាំឡៃ" ។ ការវាយកូនគួរយ៉ាងមេត្តា កុំវាយដោយខោស: បើវាយដោយខោស:ទើមានអន្តរាយដល់អវៈយវៈកូន ដូចបុគ្គលវាយគ្មានឱ្យកើតជាជញ្ជាំង វាយដំឱ្យកើតជាទាំង, បើវាយដោយខោស:ខូចជញ្ជាំងខូចទាំង មួយវិញទៀត ការខាស់ខុសផ្សេងៗ ច្រើន

ជាប់មកព័ន្ធកធំដែលជាមេជាបា ព្រោះដូច្នោះលោកគេបឲ្យកែទៃដោយ
ការសិក្សាការអប់រំ ដោយសីលធម៌ដ៏ល្អប្រពៃ អប់រំឲ្យដឹងសិទ្ធិនឹងនាទី
របស់ពលរដ្ឋ ទាំងឲ្យចូលចិត្តក្នុងការគ្រប់គ្រងប្រទេសជាតិជាដើម ។

ចំណែកក្មេងដែលមានការអប់រំនឹងអាជីពក្នុងគ្រួសារមិនសូវល្អ ក៏
ជានាទីទាងសាលារៀនដែលត្រូវជួយអប់រំប្រៀនប្រដៅ ពត់បំបាក់ឲ្យបាន
បទក្នុងសីលធម៌នឹងយុវចរិយា ព្យាយាមដឹកនាំចិត្តក្មេងឲ្យស្រឡាញ់
សាលារៀនស្នេហាកល្យាណមិត្ត ហើយជុះទាត់សេចក្តីអាក្រក់ផ្សេង ។
ដែលជាប់មកព័ជុះ ឲ្យអស់ទៅបន្ទិចម្តង ។ នឹងដឹកនាំសេចក្តីល្អទៅក្លាប់ក្នុង
សន្ទានចិត្តជំនួសសេចក្តីអាក្រក់; មួយវិញទៀតការកាយវិទ្ធ ការកីឡា នឹង
ការអនាម័យទាំងនេះ សុទ្ធសឹងតែជាការដែលជួយ ឧបត្ថម្ភតាំពាវចំណេះ
វិជ្ជារបស់ក្មេងឲ្យបានចំរើនកើតឡើងណាស់ដែរ ហេតុនេះគេបយើញ
ថា គួរដឹកនាំក្មេងឲ្យស្រឡាញ់ការកាយវិទ្ធ ចូលចិត្តក្នុងលៀងកីឡា
ផ្សេង ។ នឹងបំពេញប្រយោជន៍ដល់អ្នកដទៃ តាមគន្ធង ឧត្តមគតិនៃ
អនាម័យ ព្រឹត្តិការណ៍ទាំងនេះជាហេតុញ៉ាំងគុណធម៌ដ៏ល្អផ្សេង ។ ឲ្យជុស
ឡើងក្នុងសន្ទានចិត្តរបស់ក្មេង យើងនឹងយើញបានក្នុងកាលមិនយូរ ។

ជំណើរការណ៍ទាំងនេះ មានសេចក្តីសំខាន់ទៅត្រង់ការពួតដៃគ្នា
រវាងគ្រួសារនឹងសាលារៀន ក្នុងកិច្ចដែលនឹងជួយគ្នាសាងឬពត់មនុស្សឲ្យ
ល្អសំរាបជាតិរបស់យើង, គ្រួសារនឹងសាលារៀនត្រូវមានអាជីពប្រព្រឹត្ត
ទៅដោយការផ្សារសាមគ្គីគ្នាយាំងជិតជិតស្និតស្នាល នឹងចងព័ន្ធទាក់ទង
គ្នាជូចវឲ្យប្រវាក់ ។ មេបាគ្រួសារគួរធ្វើជុះឲ្យជាទីស្រណុកសុខសប្បាយ គួរ

ជាទីស្រឡាំងកាំងរីករាយ មានវត្តមានក្នុងគ្រប់ក្នុងផ្ទះ ឲ្យជារបស់មានដ៏វិសេសវិសាលក្លិនតាស់ពាល់ថ្ងៃមិនស្ងួតស្រស់ពោរពេញ ឲ្យតួយ៉ាងដ៏ល្អដល់ក្មេង, ត្រមាំងការពិត មានធ្វើពិតនឹងរៀនពិតជាដើម, ការស្អាតការរៀនត្រង់មានរៀងពេលមោងជាដើម, ការមានរបៀបនឹងការគោរពចំពោះអ្នកធំ បណ្តុះបណ្តាលក្មេងឲ្យមានសេចក្តីអត់ធ្មត់ រឹងមុឺងគួរាមានឲ្យស្នេហាការរៀនសូត្រស្ងប់ជ្រះ, ការសំខាន់បំផុតគឺការធ្វើប្រយោជន៍ចំពោះភាគរួមនៃជាតិព្រោះមានការស្នេហាជាតិ ពោលដោយខ្លីថា គួរធ្វើផ្ទះរបស់លោកឲ្យបីថ្លូចជាអណ្តូងមាស ដែលជាទីកន្លែងត្រជាក់ព្រះចន្ទខ្សែសង្ខ ។ ការចាត់របៀបត្រួសារឲ្យបានរៀបរយល្អ ដូចបានពោលមកហើយខាងមុខ មានប្រើនទៀងត្រឹមណា ក្មេងរបស់យើងក៏នឹងមានស្មើភ្នែថា ល្អល្អះទៀងត្រឹមណោះដែរ ។ របៀបដ៏ល្អប្រពៃនេះ នឹងជាដ៏ដ៏វិសេស ដែលអាចជួយឲ្យប្រពៃក្សរបស់ជាតិយើងឲ្យតាប់ល្អតាស់បែកមែកបែកធាង ចេញផ្កាចេញផ្លែដ៏មានឧជារសផ្អែមឆ្ងាញ់ពិសា ។ ត្រួសារដែលមានការអប់រំល្អនឹងបរិបូណ៌ដោយគុណធម៌ រមែងមានជម្លៀងថ្លូវដល់ការសិក្សា នឹង ជួយគាំទ្រនូវទ្រនាប់ប្រទេសជាតិ ឲ្យដល់នូវការវិឌ្ឍនាថាវរៈ មាំមួន នឹងមានកំពូយស ។ កាលបើត្រួសារបស់យើងត្រប់ៗ គ្នាចំរើនល្អហើយ នឹងបាច់ព្រួយបារម្ភទៅថ្ងៃដល់ការចំរើននឹងការថាវរៈរបស់ប្រទេសជាតិ ។ ព្រោះដូច្នោះអ្នកស្នេហាជាតិដ៏ពិតប្រាកដ ទើបមិនធ្វេសប្រហែសក្នុងការអប់រំក្មេងដែលមានជីវិតរស់នៅក្នុងត្រួសារបស់ខ្លួន ដែលមានខ្លួនជាអ្នកគាន់ចងក្រ ហើយគប្បីគិតថា ការទុកតម្លៃអាជីវកម្មក្នុងត្រួសារយើង

ដែលមានការគាស់ខុសខ្ទះខាតផ្សេង ។ ដើម្បីឲ្យល្អប្រពៃនឹងបរិបូណ៌ ឡើងនោះមិនមានអ្វីក្រៅពីការទំនុកបំរុង ទំសាងបំពោរបំពេញជីវិតរបស់ជាតិតឹសាលារៀនដែលជាបច្ចយអំណោយដល់ការត្រប់ត្រងពាណិជ្ជការនឹងមានសង្ហាកស៊ ចំរើនរុងរឿងដល់ប្រទេសជាតិយើងក្នុងអនាគត ។

មុននឹងបញ្ចប់រឿងនេះ ខ្ញុំសូមផ្ញើសុកាសិតរបស់បោរាណកបណ្ឌិតមួយបទថា "បើប្រទេសពេញទៅដោយត្រូសារដឹចំរើនរុងរឿង ក៏ដូចនគរដែលពេញទៅដោយផ្ទះវដ្ដផ្ទះថ្មដឹចិញ្ចៅចិញ្ចាច" ។



ការសិក្សាស្ទង់

លោកអម្ចូតក្សត្រី ម៉ុក រៀបរៀង

ក្នុងឱកាសព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម

លោក ញ៉ុក.បែម ពិនិត្យ

(តពីលេខ ៤មក)

ជកតរត្រឡាត់ ត្រឡក់កំចាត់ ត្រសៀកកុំចាយ សម័សម្ងួល
ភក្ងួលតពាយ តាសេលវល្ងីវាយ ឆ្នាច្នន់តង្រែ ។ សណ្តាសណ្តាន់
សណ្តែកលំពាន់ លិះកោះលំពៃ លំពូច្រកូង ច្រមុនច្រ-ម ច្រមូចក្រូចក្រ
សម្ងួតៗគ្រៅ ។ ជកតាយចារចំនួន សំពោធថ្លាន់ សម្រកស្រែឡៅ
សម្រងសៀបលោត កែវកោងដ្ឋអំពៅ អំពិលបង្គៀ បង្គារសៀកាយ ។
ពោចចែំនមង្ករ សាមាំរាពោនតុ- ត្រាត្រាចស្ងាតស្ងាយ តុយល្ងាតស្តី-
ស្តង់ គ្រើលក្រូងរៃយ្ងាយ ខ្លូតខ្លុងក្រូចក្រាយ ត្រីនត្រុះសំរាន់ ។
ដើមដុះជិតគ្នា ច្រង់ផលបុប្ផា រយោងរយាន ព្រះរាជកុមារ ថ្ងៃថ្លាបេះបាន
សេពសោយប្រគាន អនុជស្នេហ៍ស្និទ្ធ ។ ចុម្ងាចម្ប៉ី ក្តាំងជាស្រឡី
ខ្លួនស្រើស្រឡែត ក្តុលផ្កាមហាហង្ស ក្រយង់ដុះជិត ជុះជាសប្រកិត
ប្រកបក្តិនត្រៃប់ ។ ចេកទេសមន្ទារ— បុស្សផ្កាម្ងំលា ម្ងំរួតឈ្ងុយឈ្ងប់
ការកេសតើដោរ គន្ធសាយសព្ទ ប៊ីដូចអ្នកអប់ ត្រឡប់ក្តិនសាយ ។
ត្រីរាជកុមារ បេះឲ្យអនុជា ក្រតំសេងសប្បាយ បង្ហាញមើលសត្វ
ទ្វៀលទ្វាត់ព្រោងព្រាយ ចំហើយនិយាយ ស្ងួរសព្ទក្រអៅ ។ សេកសោម-

សេកយ៉ាវ ខ្លូសារិកា ដោយហ្វូងហ៊ោរៅ សត្វសត្វថ្លែក ។ អនេកមាន
នៅ ក្នុងព្រៃព្រៃជ្រៅ គណនាពុំបាន ។ មានស្រះជ្រះថ្លា កំពង់តង្គ្រា
សឹងខ្ចប់ក្បែមក្បាន្ត មច្ឆាមច្ឆា គ្រប់ពណ៌សឹងមាន ច្រើនពៃក្រៃលើស-
លាន លោតលេងលលាំ ។ លំពង់ទ្រង់ផ្កា មានក្រមុំតា គ្រប់
ពណ៌តាំងជ្រុំ ស្ទឹកស្ទាមភ្នាញ់ខ្មៅ មើលទៅដូចងាំ រក្សាថែតាំ
ខ្ទុះកែកយកយ ។ ទៅខ្នងថ្មថ្ងា នាំព្រះអនុជា ចុះស្រង់សប្បាយ បន្ទះ
ញើសខ្លូវ ក្តីក្តៅក្រហាយ ជម្រះព្រះកាយ ប្រកបដោយ ។ ខ្លូកសោក
ជានស្បើយ លីលាឡើងហើយ សម្រាន្តកាយា ផ្ទឹមផ្ទំស្អាបស្អល់
ក្រោមម្លប់ក្តារ សេះតាំក្បាល តាំងតំព្រះអង្គ ។ រសៀលសូរ្យា
តាំងតំកុមារ តើនទៅស្រេចស្រង់ ទៅទឹកជនស្រះ ជម្រះព្រះអង្គ
លីលាឡើងទ្រង់ ត្រៀងត្រប់តណ្ឌកាយ ។ និរភ្ញឹកព្រឹក្សា រូបជសីហ
តតាតកែក្រាយ បេះអស់ផលា រុក្ខាតាំងឡាយ រើចជាសំតាយ
ខុកថ្មើមតា ។ លីលាឡើងតង់ លើអង្គអស្សពន្ធ នាំពាជកុមារ ត្រ
សាលទន្លាន ក្បែមក្បាន្តចិត្តា សេះនាំយាត្រា តំនោះខៀតទៅ ។
ជានមួយយោជន៍ត្រប់ សេះឱ្យការពាប់ ព្រះទ័នខុកទៅ ហើយរំលងវិធីដល់
មណ្ឌលត្តិទ្ធ ផ្ទៅ នាំផលផងទៅ ថ្វាត់ក្បាយមាតា ។ នាងនាថបវរ
ខ្លូលត្រេកអរ ថ្នមថើបបុត្រក្សា បពោសអស់អង្គ ហើយទ្រង់សួរថា អ្នក
លេងព្រឹក្សា សប្បាយឬទេ ។ កុមារខ្លូលថ្លាន បពិត្រទន្លាន សប្បាយ
ឥតឯ ឱនតិតគណនា រុក្ខាផ្កាផ្លែ សូមប្រោសតាំងតែ តំថ្ងៃនេះទៅ ។
សូមលាទៅលេង សត្វថ្ងៃផ្សារល្បែង ល្ងាចរំលងទៅ សូមតានុតែធ្វាយ

រៀបស្ពាយយកទៅ ដល់ដងព្រៃជ្រៅ នាំគ្នាភោក្តា ។ នាងត្រាស់ហៅ
ស្ងួន ស្ងើច្ចើមស្ងើខ្ងួន អាសូរម្តាយកំ ម្តាយចង់សុំយាត់ កូនរត្នស្នេហា
សព្វថ្ងៃមាតា ថប់ឥតថ្ងឹងថ្ងៃន ។ ថប់មួយក្រែងសត្វ ពាលពឹងព្រៃស្ងាត់
ថប់មួយម្តាយក្រែង កូនស្ងួនត្រាណត្រើយ ទៅហើយវង្វេង សមម្តាយ
ចំបែង បែកទ្រូងមរណា ។ កុមារស្តាប់ដាក់ ខ្សឹកខ្ស្ងលអួលអាក់
អាសូរមាតា ភក្ត្រាសញ្ជប់ ខំទប់ទូលថា កុំឲ្យមាតា ព្រួយព្រះហ្ជ្ជុទ័យ ។
ខ្ញុំលេងទាល់ល្ងាច ទិលវឹងកាន់រាជ-មន្ទីរថ្ងាថ្ងៃ នាងយល់បុត្រដាក់
ព្រះភក្ត្រក្រៀមក្រៃ ហេតុតែព្រះទ័យ អាសូរករុណា ។ ហើយនាង
បណ្តោយ ព្រមត្រាស់បើកឲ្យ ទៅតាមចិត្តា កុមារបង្គំ ប្រណម្យលុតលា
ផ្ទុំមួយអនុជា ក្នុងទិទិព្វហាន ។

លង់លុះព្រឹកព្រាង ស្អាងអង្គយាសហាង ចរចូលទៅថ្ពាន យក្ស
ហើយវន្ទា ទូលថាសូមទាន ខ្ញុំទៅទទ្យាន សប្បាយពន់ពេក ។
មើលព្រៃដោយដង ព្រៃព្រឹក្សសត្វដង ច្រើនៗប្ងែកៗ មើលមិន
ឆ្អែតឆ្អន់ អនន្តអនេក ថ្ងៃនេះថ្ងៃស្អែក សព្វទិនទិវា ។ សូមលាក្សត្រថ្ងៃ
ទៅលេងសព្វថ្ងៃ សូមទ្រង់មេត្តា យក្សថាបើច្នោះ ទៅចុះស្ងួនភ្ងា
តាមចិត្តចិន្តា អញមិនឃាត់ទៅ ។ កុមារទាំងពីរ អរទនព្រះសិរ
បង្គំលាទៅ អភិវាទលាកលា មាតាយកនូវ អាហារចុះទៅ
កាន់រាងអស្សយាន ។ ឥង់សេះចញទៅ ដោយដងព្រៃជ្រៅ
ពីរយោជន៍ទិលថ្ពាន ប្រាសាទថ្ពល់ថ្ពើង ព្រឹកទ្បើងទៅបាន បួន
យោជន៍ដោយក្សាន្ត ទិលវឹងមណ្ឌាល ។ ឥតងទៅសព្វថ្ងៃ កប់បាយ

ដោយវិត្រ ជាបល់ដល់ មួយរយៈយោជន៍គត់ កំណត់សេសសល់ ប្រដូចនូវឱ្យល់ លឿនដូចកំណត់ ។ សេះសោតទូលថា បពិត្រកុមារ យើងនឹងល្មមត់ កំឡាំងខ្ញុំមាន ប្រៃប្រាណធំធាត់ មួយរយយោជន៍គត់ ៗវិលល្ងាចបាន ។ មួយកុំចរចា ប្រាយប្រាប់អ្នកណា ក្រែងក្រខូចខាន តាំងព្រះមាតា ជាតិជាប្រពន្ធ កុំបីឱ្យអាន បន្ទូលប្រាប់ក្រោយ ។ បើឱ្យ ជ្រាបហើយ សមសោះពុំស្បើយ នឹងស្ងាប់អន្តរាយ បិទកុំឱ្យប្រុះ ហេតុ នេះមិនរឹងយ ឮលេចសុះសាយ សោតសមុទ្រស្ងាប់ ។ ម្តេចម្តាប្រុងប្រាណ យប់នេះឱ្យបាន រត់ប្លែចេញឆាប់ កុំតិតព្រះមេ តង់តែក្រឡាប់ វិលវិញសម្លាប់ យក្សយកស្រុកទៅ ។ បុណ្យម្ចាស់សោតមាន តែតូចណាស់បាន ជាខ្ញុំទាំងៅ ក្រែងបុណ្យម្ចាស់បាន អ្នកមានបុណ្យទៅ ប្តូរនឹងទៅ យកតែមកចង្កាំង ។ ថ្លូហ្នឹងប៉ុណ្ណោះ ក៏ហើយទៅចុះ នេះហេតុវើ អកុសលៈ អង្គអនិច្ច ពាល់រូបមានតាំង អស់ឱ្យដូចគ្នា ។ នឹងតែថ្លើម្តេច ឱ្យបានរំពេច ដូចព្រះចិន្តា ពង្សព្រះញាណ នោះគ្មានអ្នកណា នឹងតាំងប្រាថ្នា ឱ្យបានរំពេច ។ វេលាកន្លងយប់ នេះសូមបានខប់ សំណោកម្តេចៗ ចាំចរចេញទៅ ដល់ស្រែស្រុកស្រេច ស្តាយម្តេចសឹមស្តេច សោកតាមចិត្តចុះ ។

កុមារស្តាប់សេះ ដូចនឹងរបេះ ថ្លើមថ្នាយថ្នាក់ធ្លុះ ព្រឺក្រាណត្រួចៗ ក្រលួចតង់ពោះ ជាពន្លកនោះ ហៀរហូរលិចឆ្លិច ។ ការតែវិការយោ ខន់ខល់ខ្លុកខ្លោ- មនស្សាអាល័យ ស្រណោនស្រពន់ អួលអន់ហប្ចាយ ព្រះកត្តញ្ញូក្រៀមក្រៃ ស្ទើអ័ពួអន់ ។ ហាក់ព្រះច័ន្ទ្រចរ ចែងចាំងអម្ពរ

ស្រឡះសោកណ៌ ពហូអស្ចារ្យ រស្មីមានម- ន្ទិលភៅចាប់ចំន្រូ
អ័ព្ភអន្ធការ ។ ទះទំពល់ទប់ ញាប់ញ័រសោយសព្ទ អស់អង្គកាយា
សេះនាំមកដល់ មណ្ឌលច្រាង្គច្រា- សាទស្តេចលីលា ចូលកាន់វែនឌី ។
ចូលភៅវាំង្ហា ព្រះវរមាតា ក្សត្រីណានោះទេវី ឃង់យល់កន្ត្រកបុត្រ
ពិសុទ្ធគាំនឹទ្ធ អ័ព្ភអន់ពេកតី- កាល់ភ័យសួរថា ។

មាសមិត្រអ័ព្ភទន អ័ព្ភអន់ស្រោចន ស្រេចាប់កន្ត្រា មាសមាន
បើអាក់ ថ្នាំនថ្នាក់ចិន្តា ឬមានប្រការ ដូចម្តេចមាសថ្លៃ ។ កុមារច្រាប់
ច្រាយ ខឿនខូលដោះស្រាយ ដោយច្រាជ្ញាវៃ យើនខ្ញុំស្ទះស្ទឹង
ភៅសេនដោយព្រៃ ហត់ហើយហាលថ្ងៃ សព្ទ ។ វេលា ។ មិនមាន
ខុក្ខខេ កុំបីព្រះមេ សន្ទុះសង្កា មួយមិនអន់អាក់ ថ្នាំនថ្នាក់ចិន្តា ទឹនឹ
អ្នកឯណា ឯខឿតដែរ ។ នាងថើបសិរសា ត្រាស់សួរខឿតថា មិត្រ
មាសថ្មើមថ្លៃ អ្នកនាំប្អូនភៅ ចេញភៅសេនព្រៃ មកវិញសព្ទថ្ងៃ
ម្លាយយល់កន្ត្រា ។ មិនដែលដូច្នេះ មាសមកម្តងនេះ ប្លែកនឹងសព្ទ
ត្រា ម្តាយយល់ស្នូនតន់ អ័ព្ភអន់កន្ត្រា ច្រូនម្តាយឈឺផ្សា ហាក់ទឹង
ធ្លុះថ្លាយ ។ ចូរអ្នកមាសមិត្រ ច្រាបច្រាប់ជាយពិត កុំកែវលាក់
លាយ ភូតភរវៀចវេះ ជម្រិះច្រាជ្ញច្រាយ កុមារថ្នាត់ថ្នាយ បង្គំទូលថ្លាន ។ បពិត្រចាន់ជា ស្រេចាប់កន្ត្រា ព្រោះព្រួយខ្លួនឃ្លាន ពី
ព្រឹកចេះចរ ភៅខួលខាន ពិតពុំសូវបាន ដូរតែថ្ងៃខ្លួន ។ នាង
នាងកប្បាណ ឮថាបុត្រឃ្លាន ដឿងាក់តែកាយ ហៅទ្បើលើកអស់
កោដន៍ភ័ស្តុគាំនឹឡាយ យកមកថ្នាត់ថ្នាយ ពាដបុត្រគាំនឹពីរ ។ នាង

នាថសោតសោយ មូលមួយផងដោយ ពដបុត្រសោភ័ តន់តិតក្រ
ត្រប់ ញ៉ាសេតុតន្ត្រីយ៍ អស់ដលជាវ៉ ហៅរហូវល្អនវិល្ហ ។ ទឹកពាក្យ
សេះស្រេច ជូតចេញរំពេច មិនឲ្យសន្សំយ នាងយល់បុត្រសោភ
ស្តួរមកថាហៃ មាសមិត្រថ្នីមថ្ងៃ ហេតុអ្វីកំយំ ។ ព្រះពដកុមារ ខ្ញុល
ពាស់ដោះសា បពិត្រអញ្ញ៉ា តានមួសមួយណា ចានជាវ៉ូយំ ខ្ញុល
ស្រេចបន្តិ លីលាចូលទៅ ។ កាន់ទីបន្តិ តក្តោក្រៀមក្រំ ប្រែប្រាស់
ផ្សំនៅ ទើសពាស់តួចចិត្ត ធើតែក្តាត់ក្តៅ ផាំពក្រើជ្រៅ ខនិដចរយោត្រា ។

ទ្រង់ព្រះកន្សែង ពិលាបខ្ញុញថ្លែង នុះទុមាតា អ្នកធ្លាប់ចិបម ថ្នាក់
ថ្នមរក្សា ឥរ្យាខនិដ្ឋា ខនិដ្ឋាតអ្នកទៅ ។ ដោយព្រៃសូន្យឈឹង ឯក
តតទីពឹង ហើយហាលថ្ងៃក្តៅ យកតអ្នកទៅផង ដោយដងព្រៃជ្រៅ ក្រែង
ក្រមួយនៅ កូនដៃយក្សា ។ នុះទុតួរតិត តួរកូនតាណិត ព្រះវរមាតា តុំ
ដឹងដោយដាន ស្មោះស្មានថាជា បិតាក្សត្រា-ធិពដស្តេចនៅ ។ ទុតួរ
ស្តាយពួជ ស្តាយតង្ស្រពណិដូច មាសមែង្គនផ្តៅ កម្មអ្វីតដោយ អង្គឲ្យ
តាសៅ អះសាច៏សូន្យរហៅ ដួជាតិសាមាន្យ ។ ទុតួរស្តាយក្រិត ស្តាយ
ក្រំចរិត កបកែកែលក្សា-ណាំនឹងរកស្រី ដរៃដួមគ្មាន កម្មអ្វីមកទាន ដកស្ម
យធំមោហា ។ នុះទុព្រះគុណា គុណាតាប់មហាជួន់ តតឯទបមា តាល់កូន
ធំក្រៃល មិនដែលក្រែងា យកព្រះហត្ថា ខះតិចតួចឡើយ ។ មិនដែលស
តោលដេរ តាន់កូនតាល់តែ ធំប៉ុណ្ណេះហើយ មិនដែលឲ្យតាក់ ត្រណាក់
ចិត្តឡើយ ទុព្រះគុណាអើយ តែនទ្រង់មេត្តា ។ កូនទៅណាដោយ ព្រម
អ្ហ្វាសបើកឲ្យ ទៅតាមប្រាថ្នា មិនហ៊ានពារឆ្ងិ ខទីឆ្ងិចិត្តា បន្ទោសបន្ទា

ខ្ញុំឯងទាំងឃាត់ ។ កូនធ្លាប់សាន្តសុខ នឹរណាយទោសទុក្ខ ឥតច្រោស
ឥតក្រាត់ ធ្លាប់បួចធ្លាប់ជួន ធ្លាប់ស្ងួនប្រតិព័ទ្ធ ឥឡូវនឹងចាត់ ខ្ញុំឯបង់
មាតា ។ ចោលអ្នកនៅអាយ តែអង្គឯកាយ ឯកអនាថា វែងតែឯទុក្ខ
ខ្លៅ ពុំយល់តក្រោ យើងពីរអង្គា អង្គកាយរឹងវៃ ។ ឧហេតុព្រះគុណ
ប្រកបដោយបុណ្យ ដោយចារមីថ្ងៃ ខ្ញុំទៅសុំបាន អ្នកមានផោតដ៏យ
ភ្នំរៀងរំពៃក្រៃ មូលមកនៅឥឯង ។ ខ្ញុំឯយកចំពមក ប្រយុទ្ធ
យកតយក រម្យដ្ឋសូមសង ឈាមព្រះបិតា ដូចដាបំណង
បំណាច់ខ្ញុំប៉ុង ខ្ញុំពុំភ្លេចភ្លាត់ ។ សូមអស់ទេវតា រក្សាវង្ស
ខ្ញុំសូតប្តូត្រ ក្រែងកើតទុក្ខសោក សូមលោកចំបាត់ បំបង់វៃឆ្ងាំង
វេរឥមាតា ។ មួយកុំឲ្យឃ្លាត ដូចាតិអបលក្ខណ៍ មៀតមៀនចំណា
ឲ្យខ្ញុំត្បៅនៅបាន រក្សាមក្សាខ្ញុសុខា ពាល់តែគាលណា យើងខ្ញុំ
រំលៃវាញ ។ ខៀនខ្លួញសព្វ ។ ញាប់ញ័ចំប្រាប់ ព្រះនេត្រសឹង
គេញ ទឹកនេត្រហាម លង់លាមហូរចេញ ព្រះឧកមិញ ទុក្ខ
គោមនស្សា ។ លុះអាត្រាត្រហើយ ព្រលឹងបង់អើយ យើង
ស្មមយាត្រា ស្រេចរៀបប្រដាប់ សម្រាប់តាយា ព្រះព័ស្តុផង់អ-
ពុធរៀនសៀតសឹក ។ ស្រេចចាប់ដឹកដៃ អនុជថ្ងាថ្ងៃ យាសយាង
ចេញមក ត្រាបថ្ងាយបង្គំ ចែរចំតក្រែក មាតាហើយសោក
ខៀនខ្លួញលាថា ។

បពិត្រអើយខ្ញុំ សូមលាអង្គអ- ម្ចាស់បយោត្រា មិនបាន
ឃើរខេ តង់តែលីលា រៀលវែងវាញ សម្តេចជនន៍ ។ ស្តេចយាង

ព្រះចុង ដល់ខ្នាក្រោសាទ ព្រះពដមន្ទីរ តក្រាក្រៀមក្រំ ចិត្ត
ពុំជាប់ពី សម្តេចជនន៏ ចន៏យល់តក្រា ។ ទីឆ៏យតម្លួនទៅ ក្រែង
យំយែកនៅ ដោយយល់មាតា ស្តេចតតែងខ្លោះសោត បញ្ជោតអនុជា
ទៅតម្លួនស្នេហា នៅនេះក្សិណទៅ ។ ចាំបង់រំពេច ដ្បិតបង់ភ្នាំង
ក្តេច តែតត់មួយនៅ បង្គិមាលមាស ទុកាលន្លែងផ្តៅ ចូរបងចាំ
នៅ កុំកែវយោសយំ ។ ផ្តាំអនុជនៅ ហើយយាងយាសទៅ
យល់មាតាផ្ទំ ទីឆ៏យក្សត្តិតគូរ ដូច ។ ទីឆ៏សំ ពងិពិតៈរំ
ខប់ពញចិត្តជាប់ ។ ទុខអង្គវន្ធា ទៀបភ្នាក់មាតា ព្រះរត្តិ៍ក
ញ្ជាប់ ត្បាអង្គតន្ត្រែយ៍ ព្រះសិរផ្ទាល់ផ្ទាប់ ព្រះក្រាលស្រកាប់
ស្រោនតក្រា ។ សលសែនអាល័យ ខំកាត់ព្រះទ័យ ពុំធ្រេង
សោកា ចរចាកចេញបរ ឈប់ឈរពេក ពុំចង់ឃាត្រា ហេតុ
ក្តីអាល័យ ។ តិតក្រែងម្លួនយំ រត់រកហើយខំ សង្កត់ហាទ័យ
ចេញទៅដល់ខ្នារ យើញអនុជថ្ងៃ ព្រះករចាប់ដៃ អនុជកក្រាណ ។
លីលាចុះចាក ចុះចរលេះលាក ប្រាង្គប្រាសាទភាន ស្តាយទ័មណ្ឌល
សកលតិមាន ទំយាងបាទទាន ដល់ពេងអស្សាហ៏ ។ ទត
ប្រាសាទសព្វ ពុំអាចទល់ទប់ ទៀងទើបទូញថា ទុហាទឹតថៅ
ព្រះកេរ្តិ៍បិតា ព្រះតិតប្រជា ប្រជាប់ទ្បែគាន ។ ឥឡូរកូមឃ្លាត
កូនឃ្លាប្រាសាទ ប្រុសើរថ្កើងថ្កាន ថ្កើងថ្កែងយល់ ថ្កើង
ថ្កល់រូហាន ប្រាង្គប្រាសាទហាន នៃព្រះឥន្ទ្រា ។ ឃ្លាតទ័មទ្ទូ
ឃ្លាតស្រីព្រះស្នំ ឃ្លាតភាំងមាតា ឃ្លាតមុខមន្ត្រី សេនីសេនា

ឃ្លាតញាតិកា ខ្លួវពស្ត្រសត្វច្រាណ ។ ទៅយកពសុធា ជាទីក្រឡា
ចន្ទំចិញ្ចហាន យកអាកាសា ជាតិជាពិតាន ឃ្លាតខ្ទ័យមាសមាន
ផែលដៃតល់តើយ ។ ឃ្លាតក្លេងតែងស្តាប់ ទីឯយកសត្វស័ព្ទ សត្វស្ងួរ
ស្ងែងស្ងើយ យាសយំដោយព្រៃ ចន្ទីឆ្លាសខ្ទើយ ជាក្លេងលំហើយ
លំវៃគាយា ។ ស្តេចសោកវន្ទត់ ញ័រកាយាស្ងុត ខន់ព្រះជង្ឃា ជាប
ដល់ដីហើយ តុំសេរ្យីយសោតា សេះខូលគឿនថា បតិត្រម្ងាស់ថ្ងៃ ។
ពេលនេះល្មមហើយ កុំសោកពេកឡើយ ក្រុងយក្សចម្រៃ ចិត្ត
ចោរកំដឹង សមទឹងក្សិណក្សីយ អញ្ជើញដេរស្ងួយ ធាប់ ។ ម្ន៎ម្ន ។
ស្តេចឮសេះជាក់ គ្រាន់ចាន់ក្សាក្សាក់ នៃព្រះចិន្តា ខ្លះខំច្រាណប្រុង
លើតអង្គអនុជា ជាក់លើអស្សពាហ៍ ឋរិមូណិតាលណោះ ។ ស្តេចរៀប
ផែលឡើង ស្រយុតខន់ជើង ដាលដល់ដួលចុះ សេះសោតយង់យល់
ស្តេចដួលដូច្នោះ ខន់ទាបលុតចុះ ទិនឲ្យស្តេចឈាន ។ ស្តេចឡើងដំរ
ជាប់ អស្សពាហ៍ច្រាយច្រាប់ ប្រើព្រះប្រុងច្រាណ សេះនាំយាត្រា
លីលាចាកហាន ហួសតំពែងចាន ដល់ក្រៅសីមា ។ សម្តេចទេវន្ធ
ប្រសើរសោភ័ណ តួដតន្ត្រីពុទ្ធា ពាក្យបណ្តាល ត្រួយត្រួលសាស្តា
ខ្លួវព្រះអនុជា តន់ពាជីចរ ។ រ៉ូព្រះសូរ្យា ឯឮនភា រុងរឿងថ្លៃឆ្លាវ
ត្រចះយេលយង់ គួរតន់អស្សតរ ចេញចាកនគរ ដើរដោយព្រឹក្ស ។
សេះនាំចេញចរ ចាកចោលនគរ ឆ្ងាយព្រៃមហិមា ទើបក្សត្រទ្រង់
ល័ក្ខណ៍ ក្សាក្សាក់ស្មោះស្មារ តិដំនឹងជាក់ដា ខ្លួរកេដង្ហាន ។

(មានត)

រឿងសាមកុក

ទកញ៉ាវិបុលភដសេនា ឆ្ន កន ប្រែរៀបរៀង

(គពីកម្ពុ. លេខ ៤)

រឿងសាមកុកទុកជាយទ្ធសាស្ត្រ
អ្នកវាងវៃឆ្លាសបើបានអាន
នឹងបេះទុបាយកលបំណាន
ទាំងមានសន្ទានស្នេហាជាតិ ។

សាមកុកកំណ្ឌទី ២៨

ពាំងពីចូឆ្ងយកសំបុត្រនាយទាហានមកពិចារណា រិះគិតតែក្នុងចិត្តមិនយកទោស ជុតសំបុត្រនោះចោល រហ្ហតដាល់ចូឆ្ងលើកទ័ពទៅវាយយកស្រុកគីដីវ ទៅដាល់មាត់ទន្ទេហងហោកឹពាំងបន្ទាយនៅទីនោះ ។

ចូឆ្ងដឹងដូច្នោះក៏នឹកតែក្នុងចិត្តថា បើពិចារណាតាមសំបុត្រនេះ ក៏គង់នឹងរកខ្ជនយើញ តែបណ្ណាអ្នកដែលមានខ្ជននោះ ក៏គង់នឹងក្លែងធ្វើយដោះសាថាមិនដឹងមិនយើញ, បើយើងដេញដោលឲ្យបែកការណ៍ទ្បើងទាហានទាំងពួងក៏គង់នឹងភ្ជាក់ផ្អើលវឹកវរមិនខាន នាំមានពាក្យនិយាយថាយើងពិចារណាស្ងរដេញដោលនោះមិនគួរ ព្រោះនាយទាហានទាំងអម្បាលនោះនឹងបានគិតប្រទូសក៉យដល់យើងវិញក៏ទេ ដែលបានជាគិតដូច្នោះព្រោះក្រែងអ្ជិនសៀវមានជ័យជំនះ ដោយហេតុអ្ជិនសៀវមានទាហានច្រើនជាង ខ្ជាចខាងយើងនឹងភ្ជាត់ចំណាប់បរាជ័យ ទើបនាំគ្នា

និយាយទៅគេអ្នកនៅសៀវ ដើម្បីនឹងផ្ញើខ្លួនប្រាណខុសជាមុន រឿងនេះ
បើយើងពិចារណាយកគោលកំហុសដល់រូបនីមួយៗ ក៏មិនគួរ សូម្បីខ្លួន
យើងវិញ បើមកនៅក្នុងចំណោមសិតនេនោះ ក៏តង់មានសេចក្តីភ័យ
ជាមួណ៌ដូចគ្នា" ចូរគិតហើយក៏យកសំបុត្រនោះដុតអស់ក្នុងភ្លើងទៅ ។

ខណៈកាលដែលអ្នកនៅសៀវបែកចិត្តទៅនោះ ឥឡូវចូរគូរ
ចូលទៅក្នុងបន្ទាយឃើញចស៊ីត្រូវឃុំក្នុងគុក ក៏នាំខ្លួនទៅឲ្យចូរក្រឡែក
ឃើញឥឡូវនាំចស៊ីមក ក៏បង្គាប់ឲ្យដោះចំណងចេញ ហើយនិយាយ
ថា យើងនឹងចស៊ីវែនឯងល្អាប់ស្គាល់ភាប់តាមគ្នាមកពីដើម ។ ចស៊ី
វ៉ែញចូរគូរឆ្លើយថា កំដឹងក្តីមថាចូរនឹងលួងលោមយកខ្លួនខុក
ទើបស្រែកថា អាចូរ អាឯងកុំមកលួងលោមអញឲ្យសោះ អញមិន
ចាន់អង្វរលន់តួរគោសខ្លួចអាឯងទេ ។

ចូរឃាតឮសំដីចស៊ីនិយាយទ្រនានៈមើលងាយដូច្នោះ ក៏មិនមាន
សេចក្តីនឹងឲ្យយ ទើបយកមាសប្រាក់នឹងគ្រឿងសំលៀកបំពាក់មកឲ្យ
ចស៊ីវហើយថា អ្នកនៅសៀវនោះជាមនុស្សល្អងល្ងើគ្មានសតិបញ្ញាអ្វីសោះ
ចានជាមិនចិញ្ចឹមខំខុកបំរើអ្នកឲ្យដល់ខ្នាត ប្រសិនបើយើងចានអ្នកមក
ខុកជាគ្នាហើយ យើងនឹងរិះគិតការកំចាត់អ្នកនៅសៀវចេញចានដោយងាយ
ណាស់ ហេតុម្តេចអ្នកនៅតែពាប់អានស្រឡាញ់អ្នកនៅសៀវធ្វើអ្វីទៀត ។
ចស៊ីវនៅស្ងៀមមិនឆ្លើយតបថាអ្វីសោះ ចូរក៏ឲ្យរៀបតុលៀងគោជនាហារ
ឲ្យចស៊ីវបរិភោគ ។

លុះដល់ពេលកណ្តាលអធ្រាត្រយប់ស្ងាត់ ចស៊ីវក៏លបចេញទៅ

លួចយកបានចាំងសេះ ១ ផង ដំរេះទៅដើម្បីនឹងទៅកអ្នកសៀវភៅ ។
ឯហានចូរួដែលយាមល្បាតកំចាប់ខ្លួនបស៊ីវបាន ហើយនាំខ្លួនទៅឲ្យចូរួ
កំថា "បស៊ីវបើមិនព្រមចូលចិត្តនៅធ្វើកដការជាមួយនឹងយើងកំវាហើទៅ
ចុះ" ហើយកំបង្គាប់ឲ្យហានទាំយកខ្លួនបស៊ីវទៅសម្លាប់ក្នុងវេលានោះ
តែចូរួត្រឡប់ចិត្តគិតឃើញក្តាមមួយរំពេចនោះថា "យើងឲ្យសម្លាប់បស៊ី
ដែលជាមនុស្សមានចិត្តស័ត្យខ្ជឹងត្រង់ស្រឡាញ់ចៅហ្វាយនាយនោះ មិន
គួរសោះ" ទើបឲ្យគាក់តែងការសពនាំទៅបញ្ចុះទុកនៅមាត់ទន្លេហង៍ហោ
ហើយទ្បាយកថ្មមកចារតែអក្សរទុកជាអនុស្សាវរីយ៍ថា "បស៊ីវនេះមានចិត្ត
ស័ត្យខ្ជឹងត្រង់ស្រឡាញ់ចៅហ្វាយនាយគាល់តែស្លាប់ដីវិត នរណាទំង
ធ្វើការអៅមុខ ចូរមើលតួយ៉ាងបស៊ីវទុកជាតម្រាប់ចុះ" ហើយចូរួក៏
រៀបចំលើកពហានទូងទន្លេហង៍ហោចេញទៅ ប្រាថ្នាទំងតាមទៅឲ្យទាន់
អ្នកសៀវ ។ ខណៈនោះ អ្នកសៀវទំងពហាន ៨០០ ប្លាយ កំលើការត់
ទៅដល់ដែនស្រុកលីយ៉ុង ។

ឯជៀវធីដែលអ្នកសៀវឲ្យទៅក្បាស្រុកលីយ៉ុងនោះ ខ្លាចក្រែងចូរួ
ទំងលើកទ័ពមកធ្វើអន្តរាយ ទើបកេណ្តាពហានចេញមកតាំងបន្ទាយ
នៅក្រៅស្រុក លុះដឹងថាអ្នកសៀវពាក្យទ័ពចូរួតាមមកដល់ដែនស្រុក
លីយ៉ុងដូច្នោះ កំចេញទៅទទួលអ្នកសៀវហើយអញ្ជើញចូលទៅក្នុង
បន្ទាយ អ្នកសៀវកំពណានារឿងកំឲ្យជៀវធីស្តាប់ត្រប់ប្រការ ហើយ
អ្នកសៀវទំងជៀវធីកំទៅក្នុងបន្ទាយនោះ ។

ឯពហានអ្នកសៀវដែលបែកទ័ពទំងចូរួតាមក លុះដឹងដំណឹងថា

អ្នកនៅចូលទៅនៅក្នុងបន្ទប់ឃើញលើយុំងក៏មានសេចក្តីត្រេកអរ ទើបបបួលគ្នាចូលទៅកអ្នកនៅ។ ឯាហានចូលមកជាច្រើនក៏តតាំងលើកខ្លួនទៅឲ្យឈ្នះតែងចូលខ្លួនទៅ ទើបលើកខ្លួនចេញចាកបន្ទប់ឃើញសំដៅនឹងទៅស្រុកតីជាវ លុះទៅដល់កណ្តាលផ្លូវត្រូវពេលយប់ អ្នកនៅក៏ឈប់ឯាហានកងខ្លួនៅក្បែរដើមកុំមួយ រួចនៅក៏នៅក្នុងខ្លួនោះ ស្រាប់តែឮសូរសំឡេងមាត់មនុស្សយំខ្លាំងក្រៃ អ្នកនៅក៏ទឹកសង្ស័យទើបក្រោកចេញទៅលបស្តាប់ឮសំឡេង ឯាហានឲ្យយំអាលោះអាល័យបងប្អូនដែលស្លាប់ ពាក់រឿបថា បើប្រសិនជាចៅហ្វាយយើងស្តាប់ពាក្យខៀនហងនិយាយរំលឹកហើយ កាលណាឡើយយើងនឹងបានសេចក្តីក្តៅក្រហាយយ៉ាងនេះ។

អ្នកនៅបានឮដូច្នោះក៏តិតថា បើយើងស្តាប់ពាក្យខៀនហងហាមឃាត់ ឯាហានក៏មិនមានអន្តរាយ, ដែលយើងត្រឡប់ខ្លួនទៅស្រុកតីជាវវិញនោះ ក៏ឃើញថាខ្មាសខៀនហងខ្លាំងណាស់ តែត្រូវទៅឲ្យដល់សិនចុះទើបបានតតាំងសឹកចូលវិញ។ លុះវេលាព្រឹកឡើងអ្នកនៅក៏លើកឯាហានចេញទៅ ទទួលប្រទះនឹងហងគីដែលជាទីប្រឹក្សាដ៏ប្រសើរនាំឯាហានមកជល់ អ្នកនៅនិយាយនឹងហងគីថា យើងទៅធ្វើសឹកសង្គ្រាមគ្រានេះថ្មីសិនាតើងចូលទើបវិលមកវិញ ព្រោះយើងមិនព្រមស្តាប់ពាក្យខៀនហងឃាត់ហាម ដែលយើងនឹងលើកខ្លួនត្រឡប់ទៅស្រុកក្នុងវេលានេះ គឺយើងទៅចាំងអៀនខ្មាសខៀនហងពេកណាស់។

(មានត)

ឃ្យាងហ្ឍាឌ្ឋិត

លោកវុលតែរ គិពន្ធ

លោក រ៉ាយបុិក រៀបរៀង

ពពីកម្ពុ.លេ១ ៤ មក

លោកហ្ឍាឌ្ឋិតតបថា: "លោក, សុនខនោះជាសុនខញ្ញ មិនមែន សុនខឈ្មោលទេ" ។

នាហ្ឋឹនកំរៀវឆ្ងែយទ្បើនថា: "អ្នកថានោះត្រូវហើយ" ។

លោកហ្ឍាឌ្ឋិតក៏ពោលបន្ថែមថា "សុនខនោះជាពូជ អេបាំញ្ញែល (épagneul) ជាពូជឆ្កែមានរោមវែន, ត្រចៀកជ្ងាក់ បានមកពីប្រទេស អែស្ស្ញា សុនខនេះទើបតែនឹងមានកូន ហើយខ្ចកជើងឆ្ងែងខាងមុខ, មានស្ងឹកត្រចៀកវែងណាស់" ។

នាហ្ឋឹនកំរៀវនោះសួរលោកថា "លោកឃើញឬ?" ។

លោកហ្ឍាឌ្ឋិតតបថា: "ទេ, ខ្ញុំមិនដែលឃើញសុនខញ្ញីនោះទេ, ហើយខ្ញុំមិនបានដឹងថាព្រះអត្តមហេស៊ី មានសុនខញ្ញីនោះដងទេ" ។

ពិតមែន, ក្នុងពេលនោះ មិនដឹងជាទេសកាលអ្ងី, ស្រាប់តែមានពាជីម្ជុយយ៉ាងល្អរត់ចេញពីរាជអស្ស ស្ថានទៅវាលបាប៊ីឡោន ។ ទត្តមសេនាព្រះមហាក្សត្រិយ៍ខាងការបរបាញ់ នឹងពួកនាយទាហានបានរត់ដេញពាជីនោះមកជិតលោកហ្ឍាឌ្ឋិត ដោយមានទឹកមុខព្រួយជាខ្ងាំង ជូបត្នានឹងទត្តមសេនាកំរៀវរត់តាមសុនខញ្ញីដែរ ។ ទត្តមសេនាខាងការបរបាញ់

នោះក៏សួរទៅលោកហ្សាឌិតថា "លោកបានឃើញភាពជាវត់មកត្រង់ចំនេះឬ ? " ។

លោកហ្សាឌិតឆ្លើយតបទៅវិញថា: "ភាពជាដែលជាយល្អជានិតនោះឬ ? ភាពជានោះកំពស់ ៥ ជើង (១ ជើង ០ម,៣២៤៨; ៥ ជើង: ០ម,៣ ២៤៨×៥=១ម៦២៤០), ក្រចករជើងក៏គួចណាស់ហើយមានកន្ទុយវែង ៣ ជើងកន្លះ, ដែកបន្ទូរមានលាមមាសម្តែបក្រាត់, ដែកបង្គាំមាត់មានលាមច្រាក់ខមួន់ ១១ ដឺនីញ (១ដឺនីញ ៥ សង់ទីក្រាម; ១១ ដឺនីញ: ០,០៥×១១=០ក្រ,៥៥) ។

ខត្តមសេនានៃការបរបាញ់ សួរលោកហ្សាឌិតទៀតថា: "ចុះភាពជានោះ វាវត់ទៅតាមផ្លូវណា ? វានៅឯណាឥឡូវនេះ ? ។

លោកហ្សាឌិតក៏តបទៅវិញថា: "ខ្ញុំមិនបានឃើញខ្លួនវាភាពជានោះទេ សូម្បីតែឮគេនិយាយក៏មិនដែលឮផង ។

ខត្តមសេនានៃការបរបាញ់ទីដ ខត្តមសេនាកំរៀវ កំសន្សំយពន់ពេកថា លោកហ្សាឌិតប្រហែលជាលួចភាពជាវបស់មហាក្សត្រីជាតិជាសុខរបស់ព្រះអគ្គមហេសី, ដូច្នេះហើយទើបក៏នាំលោកហ្សាឌិតយកមកប្រគល់ទ្បើមហាសក្ក(សក្កាដែស្តេរហាម) ។ ក៏បានតិនិត្យរឿងនេះ ហើយបានសម្រេចកាត់ទោសឲ្យគេដាក់ឃុំនឹងពាក់ស្បែក ដែលមានដុំដែករៀបពុំនឹងពាក់ត្រមាំងនិងរទេះសៀប្រទេសស៊ីបេរី ។ ក្រោយដែលមហាសក្កកាត់ទោសលោកហ្សាឌិតរួច ស្រាប់តែគេរកឃើញភាពជានិងជាសុខរនោះ ។ ភ្លាមៗទៅក្រមាំងប៉ុន្មានក៏ត្រូវរើជំនុំដំរេរឿងនោះជាថ្មី សម្រេចតាមយោក

ហ្សុងឆិតជាមាសទម្ងន់៤០០អុងសូ (១អុងសូ២៨ក្រាម៣៥; ២៨ ក្រ. ៣៥×៤០០=១១៣៤០ក្រាម) ដោយហេតុថាលោកគោលន្ធវៃគ្នាដែលលោកមិនចុះយើញ ។ លំដាប់តមក, មហាសភាបានអនុញ្ញាតឲ្យលោកហ្សាងឆីនថ្វាយការពន្យល់ចំពោះមហាសភាអំពីរឿងនោះ ។

ឧកាយុត្តិធម៌, អនុធម៌វិន័យសាស្ត្រ, កញ្ចក់សច្ចធម៌, លោកដែលមានទម្ងន់ធ្ងន់ដូចសំណរ, សភាពដែលដូចដែក, ពន្ធឹស្មើពេជ្រ, ពេញចិត្តខ្លាំងមាស! មើលោកអនុញ្ញាតខ្ញុំឲ្យខ្ញុំថ្វាយការណ៍ ចំពោះមុខមហាសភានេះ ខ្ញុំសូមថ្វាយសច្ចប្រណិធានចំពោះមហាពាជអ្ហួស្មាតថា ខ្ញុំមិនដែលយើញពាជសុនខញ៉ាំនៃអគ្គមហេសី ឧដ្ឋកជញាដ៏នៃព្រះហ៊ាអតិពាជសោះឡើយ ។ ខ្ញុំកំពុងដើរលេងតម្រង់ទៅគុម្ពោតព្រៃតូចមួយ ក៏ស្រាប់តែខ្ញុំយើញសេះខ្លាច់ ខ្លួសាមសតូច្រមៃលជាកូនសុនខ ។ មានស្នាមចង្កឹជាច់ធំធំខ្លាច់ពក់ ។ ហើយវែង ធ្វើឲ្យខ្ញុំដឹងច្បាស់ថា ជាសុនខញ៉ាំដែលមានះដាះវែង ។ ទៅក្រោម ហើយដែលខ្ទើបធំមានកូនថ្មី ។ មានស្នាមផ្លូវខ្មៅតមកពីចិសផ្លែង ហើយស្នាមនោះពិតជាប៉ាសខ្លាច់ពក់ ។ បន្ទើ ។ ជិតដើងមុខ ធ្វើឲ្យខ្ញុំដឹងច្បាស់ថាសុនខញ៉ានោះមានត្រចៀកវែងណាស់ ។ ហើយដោយខ្ញុំបានពិនិត្យថានៅលើខ្លាច់មានស្នាមដើងមួយពក់ ។ ជាងស្នាមដើងថ្មីដែលសុភាពស្រីនៅក្នុងខ្លាច់ខ្ញុំយល់ថាសុនខញ៉ានៃព្រះអគ្គមហេសីរបស់យើង ប្រហែលជាមានដើងមួយដើរចុះកេះច្រឹច ។

ចំពោះពាជញាដ៏នៃព្រះមហាក្សត្រិយ៍នោះ ខ្ញុំកំពុងដើរលេងតាមថ្នល់

ជិតតុម្ពោតព្រៃនោះ ខ្ញុំបានឃើញស្នាមជើងភាជីនោះនៅលើរាបថ្ម ស្ថិតនៅរវាងគ្នាទំនឹងគ្នាមានប្រវែងប៉ុនគ្នា ប៉ាន់ជាខ្ញុំថាភាជីនេះចេះជាយន្តវិស្សរសើរ, ផង់ធូលីនៅលើស្នឹកឈើនៅតាមផ្លូវចង្រៃត មានទំងន់ ៧ ដើង ជ្រុសរុសកាយបន្ទិចត្រង់នេះ បន្ទិចត្រង់នោះ ខាងស្តាំខាងធ្វេង, ចម្ងាយ ៣ ដើង ១/២ ពីកណ្តាលផ្លូវ ។ ខ្ញុំយល់ថាភាជីនោះមានកន្ទុយវែង ៣ ដើង ១/២ ហើយកន្ទុយនោះបានប៉ាស់ផង់ធូលីនៅលើស្នឹកឈើចាស់បន្ទិច ។ ។ នៅក្រោមរុក្ខជាតិដែលមានស្នឹកត្រសុំត្រសាយកំពស់ ៩ ដើង, ខ្ញុំបានឃើញស្នឹកឈើមើលទំងន់ធ្ងាក់ថ្នឹ ។ ហើយខ្ញុំដឹងថាភាជីនោះបានប៉ាស់ស្នឹកឈើនោះ ។ ចំពោះដែកបង្ក្រៀ, ដែកនេះប្រវែងជាលាបជាយមាសមានទម្ងន់ ២ ក្រាក់ ព្រោះភាជីនោះបានត្រដុសជាប់មាសនៅលើថ្មមួយដែលខ្ញុំបានយកមកពិនិត្យឃើញជាក់ច្បាស់ ។ អាស្រ័យខ្ញុំបានពិនិត្យស្នាមជើងភាជី, ខ្ញុំយល់ថាដែកក្រចកភាជីនោះប្រាកដជាលាបប្រាក់មានទម្ងន់១១ដីនីញ្ញរ.....” ។

លោកចៅក្រមទាំងអស់ គោតសរសើរស្ទប់ស្ងែនឮវាគាវតិចារណារបស់លោកហ្វាឌិតដោយជ្រាលជ្រៅ ព្រមទាំងប្រាជ្ញាដ៏មុះមុត ។ ដំណឹងនោះកំរ្រាបដល់ព្រះមហាក្សត្រីយ៍ ទឹងព្រះកដិនី ។ គេពោលតែពីលោកហ្វាឌិតនៅក្នុងក្រឡាព្រះបន្ទូល, ព្រះកដមនីរ, បន្ទូបត្រប់ទិសទី ។ ហើយពិតមែនតែមានហាកខ្លះពោលថា ត្រូវយកលោកទៅធ្វើខណ្ឌកម្មដោយការដុតក្នុងភ្លើង ព្រះមហាក្សត្រីយ៍ត្រឡប់ជាទ្រង់ត្រាស់បង្គាប់ថា ត្រូវប្រគល់ជូនលោកវិញនូវប្រាក់ពិន័យ ៤០០ អុង្ស

មាស ដែលតុលាការបង្គាប់ឲ្យបង់ ។ អាជ្ញាសាលានឹងព្រះរាជអាជ្ញាបាន
នាំយកប្រាក់ ៤០០ អុស្សមាសមកជូនវិញ ។ តែពួកនេះបានយកប្រាក់
នោះ ចំនួន ៤៩៨ អុស្សជាសោហ៊ុយតុលាការ ហើយពួកទាសាកឹទារ
ប្រាក់ឈ្នួលថែមទៀតផង ។ លោកហ្សាឌិតបានយល់ច្បាស់ថា ធ្វើជា
អ្នកបេះដឹងប្រើន, អួតខ្ជូនថាជាបណ្ឌិត នាំឲ្យតែលំបាកខ្ជូន ហើយ
ក៏ប្តេជ្ញាក្នុងចិត្តថាតាំងពីថ្ងៃនេះតទៅ អញលែងពោលចំពោះរបស់ដែល
អញយើញហើយ ។ ពេលឧកាសនោះក៏មកដល់ក្ខាម ។ មានមនុស្សទោស
ម្នាក់រត់រួចចេញពីពន្ធនាគារ ទៅតាមក្រោមបង្ហួចគេហដ្ឋានរបស់លោក ។

គេបានសាកស្ទរលោកហ្សាឌិត ។ មិនធ្វើយ ; តែគេបានស្ទរបញ្ជាក់
ថា តើលោកបានមើលតាមបង្ហួចឬទេ ។ លោកតបថាបានមើល ។
គេក៏បានកាត់ទោសលោកឲ្យបង់ប្រាក់ ៥០០ អុស្សមាស អំពីការប្រព្រឹត្តិបទ
ឧក្រិដ្ឋនេះ ។ លោកក៏បានថ្ងៃងសរសើរថៅក្រមទាំងនោះអ្នំពីការ
សន្តោសទោសត្រាប្រណីចំពោះលោក, ហើតិតតាមទំនៀមទម្ងាប់ទីក្រុង
បាប៉ីឡោន ។

លោកពោលពីខ្ជូនលោកថា ឧត្ថរឲ្យអនិច្ចាពន់ពេក ហើត្រាន់តែ
អាត្មាអញដើរលងតាមព្រៃដែលមានសុនខញ៉ីព្រះអត្តមហេស៊ី ឬរាជពាជី
ព្រះមហាក្សត្រិយ៍បានត្រាច់ទៅតាមទីនោះ ទៅជាមានរឿងរ៉ាវទៅកើត,
ត្រាន់តែអត្តុយជិតបង្ហួច, ក៏មានទោសក្ខាម, ឧទៅក្នុងជីវកាពនេះ សេចក្ត
សុខគេលំបាកនឹងរកបានពន់ពេក ។

(មានរ)

រឿងបុរសពីរនាក់ភ្លក់ឧកញ៉ាំងឆ្ងាញ់

លោកផើង-ជ្រីវ នៅក្រសួងយោសនាការជាតិ

ប្រែចាកសៀវភៅ ពុងអេឡេសង់ដ៏ធំរ៉ូម៉ានី
(Contes et Legendes de Romanie)

សេចក្តីដំណាលថា មានបុរសពីរនាក់ពុនការនុំមួយម្នាក់ ដើរមកជួបគ្នានៅផ្លូវបំបែកមួយ ។ ក្នុងការនុំរបស់ឈ្មោះ ចាំកាឡា មានសុទ្ធតែស្វែ, ចំណែកក្នុងការនុំរបស់ឈ្មោះ តន្ទាឡា មានសុទ្ធតែត្រាប់ចំបក់ ។ ចាំកាឡាជំពប់សួរថា: ទិវាសួស្តី សំឡាញ់! ។ តន្ទាឡាទ្វើយតបថា: អរគុណច្រើន សំឡាញ់! ។ – គាកឿន! ឯងមានអ្វីក្នុងការុនហ្នឹង? ។ – ពេមចៀម សំឡាញ់! យកទៅលក់ឯផ្សារ ចុះអ្វីដែរ ក្នុងការុនឯងនុ៎ះ? ។ – ផ្លែស្វា សំឡាញ់! យកទៅលក់ឯផ្សារដែរ ។

ជនទាំងពីរដើរដេញដែនគិតរឿងខ្លួនមួយស្របចក់ ដោយស្រឡាំងស្ងាត់ រួចទើប ចាំកាឡា ផ្តើមសួរថា: អាកឿន! តើឯងដឹងថាអញកំពុងគិតអ្វីឬទេ? ។ – អញមិនដឹងជាឯងគិតអ្វីទេ ។ – ចុះប្រសិនបើយើងប្តូរការុនគ្នា ជាឧឬទេ? ។ – ចុះមានជាអ្វី ប៉ុន្តែមិនត្រូវបើកការុនមើលទេ ។

បុរសទាំងពីរប្តូរការុនគ្នា រួចបែកចេញពីគ្នា ដើរយ៉ាងរហ័សទៅផ្លូវម្ខាងម្នាក់ ដើម្បីគេចចេញដោយឆ្ងាយពីគេ: ហឺ! ហឺ! អញបានភ្លក្សអាន៎ះជាន ។ លុះដល់ទីស្ងាត់ ជនទាំងពីរលួចបើកការុនមើលរឿងខ្លួន ។ ចាំកាឡា ឃើញត្រាប់ចំបក់, តន្ទាឡា ឃើញស្វាខ្លួនតែស្វែ ។

ចូរមើលចុះ អាទីលទាំងពីរត់សាជានរឿងខ្លួនមកវិញ ។

– អេះ! ឯងបានឱយយីងថ្លៃស្លាអញ! ហេតុអ្វីកំកុហកអញ?។ – ចុះឯង! ឯងបានទ្រាប់អញថាកេមះបៀមមែនឬ? ហេតុអ្វីកំយកស្លែមកឱ្យអញ?

ឮសេចក្តីតតាំងតែជេរគ្នាគេញចំហឆាងទៅវិញទៅមក លុះអន់ចិត្តគេនិយាយគ្នាថា: ល្អើយសំឡាញ់! ចូរយើងយកគ្នាធ្វើជាក្តីគេ។ – មែនហើយ! យើងជាមនុស្សត្រូវស្តាប់គ្នា។

ជនទាំងពីរប្តូរឈាមគ្នា ស្បថស្បែរស្បើស្លាប់ ស៊ូរស់ទីងគ្នា ហើយត្រូវប់ធ្វើដំណើរចេញទៅជាមួយគ្នា ជារបៀបបងប្អូនបង្កើត។ កំពុងតែដើរ គេបានជួបនឹងបព្វជិតមៅត្តមួយអង្គដំរេះមក បព្វជិតនេះសួរថា: – នែ! អានាងទាំងពីរនាក់ ឯងនាំគ្នាទៅណាមកណា?។ – ទៅរកការធ្វើទៅកន្លែងណាមួយដែលយើងខ្ញុំសុំណាអាចរកបាន លោកគ្រូ!។ – អានាងឯងចង់ទៅធ្វើការនឹងយើងឬទេ?។ – ចុះមានខាស់អ្វី លោកគ្រូ!។ – បើដូច្នេះ អានាងឯងត្រូវការបៀវត្សប៉ុន្មាន?។ – មាសបីរយឡើ(១) ប៉ុន្តែលោកគ្រូឱ្យយើងធ្វើអ្វីខ្លះ?។ – អានាង! គ្នាមានមេគោមួយ ក៏ដើរស៊ីស្មៅក្នុងមួយថ្ងៃប្រាំមួយតង្លាម៉ែត្រ ហើយអាចម៍ប្រាំមួយរះ កិច្ចដែលអានាងឯងត្រូវធ្វើ គឺម្នាក់ដឹកក្បាលស៊ីស្មៅ ម្នាក់ទៀតសំអាតក្រោល តើយល់ត្រមឬទេ?។ – អានយល់ត្រម, យើងគ្រាន់បើជាជាងលើកមុន, នៅទីងដូរម្តាយយើងក៏មិនបានប៉ុណ្ណឹងដែរ! ហើយបុរសទាំងពីរត្រមចុះកិច្ចសន្យាជាស្រេច។ ប៉ាកាឡាជាម្ចាស់ឃ្លាលមេគោ

(១) ប្រាក់រៀលប្រទេសម៉ារ៉ុក

ដឹកទៅលើកូនក្នុងលង្ហៀសុីស្នៅ ។ គន្ធាឡានៅសំអាតគ្រោល ។

ឧត្ថុរឲ្យអនិច្ចាអ្នកទៅលើក្នុំពេក មេតោសុីស្នៅតែមួយមាត់ដើរធ្ងន់ជាបលើខ្នងក្នុំមួយទៀត រួបកាត់ទៅរកក្នុំផ្សេងទៀត ហើយវត្រឡប់មកផ្ទះក្នុងពេលល្ងាច លុះណាតែវាបានដើរពេញសព្វពាំងប្រាំមួយតីឡូមែត្រនោះ ។ ដើងរបស់ប៉ាកាឡាស្ពាល់សព្វគ្មានសល់អ្វី ។

ចំណែកគន្ធាឡា សំអាតភក់ជ្រាំពាំងប្រាំមួយរទេះដែលមាននៅក្នុងគ្រោល ប៉ុន្តែមិនត្រូវឲ្យប៉ែលប្ដូចបទើសដីឡើយ បើត្រាន់តែប្រផិត, ផូង ! ត្រូវកំផ្ទៀងរបស់លោកត្រូ ។

លុះល្ងាចគូកនពាំងពីរនាក់មកចួបគ្នា ។

—ដូចម្តេចទៅ អាភ្ជឿន កិច្ចការឯងនៅឯគ្រោល?

—ហ្ម៉ុ! ស្រួលដូចជាគេនៅក្នុងប្រាសាទស្ថានសួគិរបស់ព្រះឥន្ទ្រ ។ គេលើកអាចម៍គោតែនឹងកូនប៉ែល ហើយលោកត្រូឲ្យនំសុីត្រប់តែប៉ែល ហើយតែបែបយ៉ាងដូច្នេះជាដរាប មួយកូនប៉ែលនំមួយ.....ចុះចំណែកអាភ្ជឿននៅលើខ្នងក្នុំ ដូចម្តេចទៅ ?

– ហេ! ហេ! អញដូចជាត្រាន់បើជាងអាភ្ជឿន! មេតោនេះជាតិស្ងូតស្ងូតដូចរូបតំនូរ វាដើរតាមតែអញ ។ បើកាលណាអញឃើញវានៅឈរស្ងៀមមួយកន្ទែង អញយកស្បែកចៀមមកគ្រាលដេក បើអញមិនដេក ត្រាន់តែផ្ទាស់កន្ទែងបន្តិចបន្ទួចម្តងម្តាល ក្នុងពេលដែលវាអស់ស្នៅនៅជុំវិញខ្ទួនវាប៉ុណ្ណោះ ។

រួបការស្ងៀមស្ងាត់កើតមានមួយស្របក់ ទើបប៉ាកាឡានិយាយថា

– នែអាកឿន! ឯងដឹងឬទេ ឆ្នាមានរោគម្យ៉ាង កាលណាបើអង្គុយ
យូរពេក, ស្អែកយើងតិតប្ពូរឆ្នាម្ពងណា+ អញនៅធ្វើការឯក្រោល ឯង
ទៅមើលគោ ។

តន្ធាឡាសប្សាយចិត្ត ធ្វើយថា: ចុះមានអី យល់ព្រម! ។
មើលចុះ តន្ធាឡាចេញទៅលើឧងកុំ លីក្តារឡារមួយសន្ធឹកសម្រាប់ដេក
នឹងកាន់ដើងតាំងមួយសម្រាប់អង្គុយយកទៅផង ។ តើសម្រាកដូចម្តេច?
ហា! ឆួរអនិច្ចាពេក! មេគោដើរស៊ីពេញតាំងប្រាំមួយតីឡូរហូតដល់ល្ងាច
ហើយចំណែកឆ្នាតិតតែរត់តាមមេគោឆ្ងាក់អណ្ណាត ណាលីក្តារឡារផង
ណាកាន់ដើងតាំងផង ។ ប៉ុន្តែប៉ាកាឡាវិញ នៅឯក្រោល ចាន
ទទួលសាមសិបប្រាំមួយកំផ្នៀងរបស់លោកគ្រូ ដំនួសនំដែលថាមួយបើល
ឲ្យនំមួយនោះ ។

លុះល្ងាច ប៉ាកាឡាសួរតន្ធាឡាថា: ហេ! អាកឿន ឯងថាបើល
តូចៗហើយចានទំស៊ីផង ឥឡូវសុទ្ធតែកំក្នៀងគ្រប់បើល ហេតុអ្វីក៏មិន
ដូចឯងនិយាយប្រាប់ ។ មែន! ស្តាប់ចាន! ចុះចំណែកអាកឿនដែល
ធ្វើឲ្យអញស្ទើរៀបលោងម្ចាងព្រោះតែដំណើរវិនមេគោចវិត្រ ស្រួល
កែរុញទៅឲ្យចចក ... នោះដូចម្តេចវិញ ។

ជនតាំងពីរស្តីបន្ទោសឆ្នា ដេរឆ្នាទៅវិញទៅមក រួចហើយគេក៏ជា
ឆ្នាឡើងវិញ ។ លុះយប់ អាឧីលតាំងពីរដំនុំតិតឆ្នាថា: "អាកឿន យើង
តិតទៅលបស្តាប់នៅក្សែរបង្អួច តើលោកគ្រូមាននិយាយអ្វីពីយើងឬទេ?

ប៉ាកាឡា ចិត្តស្ទុយ ទៅលបស្តាប់ តើវាត្មលោកគ្រូនិយាយថាអ្វី

ខ្ទះ? លោកគ្រូហៅប្រពន្ធមកប្រាប់ថា: "គេហ៍ គេហ៍ ចូរឯងទៅមើល
គើអាចត្រៃពីរនាក់ដេកលក់ឬនៅ? ថ្ងៃនេះ ប្រសិនបើអាឡាំកាឡារុញ
ប៉ែលឲ្យជ្រៅបន្ថិចទៀត ត្រង់ក្បែសសរខាងកើតផ្ទះ មុខជាប៉ះនឹងតែម
ឆ្នាំងដែលជាក់កំណប់នៅនោះ ។

ឡាំកាឡានឹកថា: ហ៉ា! អីចឹងគើលោកគ្រូ ឥានជាមិនចង់ឲ្យអញចូក
ខ្ទាំង! ហើយវារត់ត្រឡប់មកវិញប្រាប់តន្ទាឡាថា: ធាប់ៗ! យើងដេកក្នុង
ទ្រុងស្មៅ ហើយធ្វើជាស្រមុក ធាប់ៗ! ។

ប្រពន្ធលោកគ្រូឃើញអាចោរខឹលដេក ក៏ត្រឡប់ចូលទៅផ្ទះវិញ ។
រួចឡាំកាឡាក្រោកឡើង ដើរតាមក្រោយលបៗ ទៅស្តាប់ការណ៍នៅត្រង់
បង្ហួចទៀត ។ លោកគ្រូសួរថា: ជូចម្តេចទៅ? ។ - វាដេកលក់អស់ហើយ
ឃើកសែងយកទៅចោលឯណា ក៏មិនរលឹកផង ។ - កុំព្រួយមិនអ្វីទេ ។

ខណៈនោះ ឡាំកាឡាត្រឡប់រត់មករកតន្ទាឡាវិញ ហើយប្រាប់ថា:
ទែអាគឿន! ឯងដឹងឬទេ? មានឆ្នាំងមួយជាក់ប្រាក់ពេញកប់នៅក្បែ
សសរ, មកយើងទៅតាស់យក ។

វានាំគ្នាជីក មិនឥានជាជ្រៅប៉ុន្មាន ស្រាប់តែជល់នឹងឆ្នាំង នាំ
គ្នាកាយយកចេញ ជាក់សត្រែកប្រហកស្នែងសែងចេញទៅ ធ្វើការតែ
ពីរថ្ងៃឥានប្រាក់សន្ធឹក ។ ជនទាំងពីរដើរៗទៅ ឥានជល់ព្រៃរបោះ
មួយនៅកណ្តាលព្រៃធំអស់កំឡាំងពេក ក៏នាំគ្នាលេប់សម្រាក ជាក់
ឆ្នាំងកំណប់ក្បែរខ្ទូន ។ តន្ទាឡាដេក ហើយឲ្យឡាំកាឡារកចៃឲ្យ ។
គេតែងដឹងគ្រប់ៗ គ្នាមកហើយថា របៀបនេះជាមធ្យាឥាយនាំឲ្យដេក

លក់ស្រូល ។ ហើយតន្ត្រាឮគិតដេកលក់ទៅ ។ លុះយើញដូច្នោះ ប៉ាកាឮនឹកថាខេត្តាជួយអញតើ! ឆ្នាំនេះកណប់ត្រូវបានអញតែម្នាក់ឯង ។ រួចប៉ាកាឮក្រោកឡើងសឹម ។ ជាក់ស្តែងតន្ត្រាឮកំពុងដេកលើមួកលើតពុនឆ្នាំនេះនឹងស្មែន ហើយលួចចេញដើរកាត់ព្រៃទៅ ។

អាចារឿលយកបានមែន តែប្រយ័ត្ន! តន្ត្រាឮភ្ញាក់ឡើងមិនឃើញប៉ាកាឮ មិនឃើញឆ្នាំនេះ តើវាគិតដូចម្តេច ?

វាចូលទៅកន្លែងគុម្ពកំរឹមានមែកស្អុយ វាចាប់បានមែកមួយស្រួលបួច យកសំបកចេញធ្វើជារំពាត់ហើយត្រឡប់ផ្ទះ ភ្លក់ផង រួចចេញដើរហើយស្រែកដូចអ្នករះខេះតាមរកគោថា "យើអាខោរ អាឯង់ទៅណា រួចតែងអញ!" ។ ដើរកមួយស្របក់ ស្រាប់តែគាន់ ស្រែកថា ហេ! អាកើន, មានការណ៍អ្វីអា? ឈប់មើល? ។ ខណៈនោះ តន្ត្រាឮតាំងស្រែកទៀតថា "ហេ;ហេ" ហើយឈរនៅស្ងៀមតែមួយកន្លែង ។ ប៉ាកាឮទ្រាំមិនបាន ក៏ចេញពីព្រៃគុម្ពតមក ព្រមទាំងឆ្នាំនេះកណប់ហើយនោលថា: «ហៅ អាខ្មោច! អាកើនៈខ? ហេតុម្តេចក៏ធ្វើដូច្នេះ? ។ ឯងចង់ទៅណាជាមួយនឹងឆ្នាំនេះ ខោលអញ? ។

ដូច្នេះ ប៉ាកាឮគោងតែយល់ព្រមជាមួយតន្ត្រាឮវិញ ។ រួចអាខោទើលកបំបែកច្រាក់គ្នា មួយឯង មួយអញ... ។ អ្នកទាំងពីរទៅបែកប្រឹងប្រែងខ្លាចក្រែងលើសទៅលើមាន ។ ប៉ុន្តែកន្លែងបំផុត ប៉ាកាឮបន្ទុំយកលើសបានតាសតីរ ។ លុះចែករួចហើយ គេនាំគ្នាត្រឡប់ទៅផ្ទះវិញ ព្រោះគេមានប្រពន្ធ រៀងខ្លួន ។ ប៉ុន្តែប្រពន្ធតន្ត្រាឮ មិនឈប់ស្តី

ទាមទារកាសពីរពីបុ៉ាកាឡាសោះ ។

—ឲ្យកាសពីរនោះមកខ្ញុំ ឲ្យខ្ញុំមក កាសពីរនោះ ។ ហើយតន្ទាឡាក៏ជួយផងដែរ ។

ប៉ាកាឡានិយាយថា: កុំមាត់ ចាំខ្ញុំឲ្យ ចុះកាលណាឲ្យ? ចាំថ្ងៃនេះ ។

ពាក្យថា "ចាំថ្ងៃនេះ"មិនចេះមកដល់សោះ ចំណែកតន្ទាឡាមិនព្រមដើរចេញពីផ្ទះប៉ាកាឡា នៅតែទទួចទាមទារ ។

មិនដឹងមានគំនិតជួចម្តេច ថ្ងៃមួយប៉ាកាឡានិយាយនឹងប្រពន្ធថា:

— គេហ៍អើយ! អញមិនដឹងធ្វើម្តេចនឹងដោះខ្ជនចេញពីអាតន្ទាឡាសោះ ។ ជួច្នេះ អញធ្វើជាស្ងាប់ ហើយឲ្យឯងនាំអញទៅទុកឯវត្តលោក ។

ថាភ្ងាម ធ្វើភ្ងាម ។ គេដាក់ឥក្នុងក្តារម្ជូសនាំយកទៅជម្ពល់ទុកក្នុងវត្ត ហើយប្រពន្ធត្រឡប់មកផ្ទះវិញ ។ ត្រាន់តែនាងនេះមកដល់ស្រាប់តែឡពាក្យស្ងរនៅមុខផ្ទះថា : ហេ! អ្នក! ហេ! អាគ្រឿននៅហ្នឹងទេម្ត? ។

នាងប្រពន្ធធ្វើយទៅវិញទាំងយំថា: "ទត្ថរឲ្យកំសត់ពេក គាត់ស្ងាប់ហើយ! ខ្ញុំទើបនឹងនាំគាត់ទៅជំកល់ទុកឯវត្តអម្បាញ់មិញ ។ =អីចឹង! ខ្ញុំជួចជាមិនដឿ! ខ្ញុំទៅពិនិត្យមើល! ។

តន្ទាឡាទៅឯព្រះវិហារ ហើយលបចាំឃ្ងាំមើលនៅខាងក្រោយឡារដោយនឹកថា: "ប៉ើវានៅរស់ វមុខជានឹងចេញមកជាមិនខាន" ។

ប៉ុន្តែស្រាប់តែមានហេតុដឹស្មុកស្មាញដវិទទៀតកើតមានឡើង ។

មានអ្នកស៊ីឈ្នួលព្រះវិហារម្នាក់ទៀបចូលដៃដាមួយនឹងអាពួកចោរដែលទៅលួចប្លន់គេតែពាលវិញ ។ គ្នាវាទាំងអស់ជាប់មួយនាក់ ជាប់ពីទាំងអានៅក្នុងព្រះវិហារ ។ ម្ដងនេះ ពួកអាចោរខឹងនឹងមកពីប្លន់បានមាសយ៉ាងច្រើនហើយជាពេលដែលត្រូវចែកមាសគ្នា អាចោរតួនិយាយថា :

ត្រូវតែយើងទៅឯព្រះវិហារ តែនៅពីនោះយើងអាចចែកបានដោយសេរី ហើយត្រឹមត្រូវផង ។ – យល់ព្រម ។ អាចោរទាំងគ្នាទៅពីនោះចែកមាសជាចំណែកជាប់ពីរដោយឮសូរនឹងក្ដីចាំងវែកៗ ផង ។ លុះឃើញមាសដូច្នោះ គន្លាឮដែលនោអន្ទឹយជិតភ្លាវ តាំងខ្ទ្រាំដី ហើយស្រែកយ៉ាងអស់ចំហាំងថា: ខ្មោចក្រោកឈរឡើង ! ចោរ! ចោរ! ស្លាប់ ! ខ្មោចក្រោកឈរឡើង ! ចោរ ! ចោរ ! ស្លាប់ ! ។ មួយរំពេចនោះ ចាំកាឮសូរលោតមកចាំងក្ដារម្ជុសទៅរកចោរ ចោរភ័យខ្លាចខ្មោចឈប់តែតមាស ទំនុះតែប្រណាំងគ្នាចាចរាចប្រាសអាយុ ចាចដើងសព្រាត តែរៀងខ្លួន ។ ខណៈនោះ ចាំកាឮមុះមកសង្ត្រួចមាសឯគន្លាឮក៏តែមកដល់ស្មើគ្នា ។ – អាកឿន ! ឯងឃើញឬទេ? ចើអញមិនខ្វើជាងាប់ តើអាកឿនឯងអាចបានសម្បត្តិដ៏ច្រើនដូច្នេះឬ? ។ –នែ អាកឿន ! តើឯងបានមាសនេះឬ បើកុំតែអញមកនៅក្បែរទ្វារព្រះវិហារហើយស្រែកបំភ័យផង ? ។

រួចគូកនទាំងពីរនាក់ ក៏យកប្រាំមួយចំណែកម្នាក់ ។ ហើយគន្លាឮសួរថា: ឥឡូវនេះ ចូរឯងឲ្យគាសពីមេកអញ ដ្បិតឯងបានមាសហើយ ។ -អ៊ីចឹងមែន ! មិនដែលឮ ! ។

រួចអាខឹលទាំងពីរមានរឿងរាំវនឹងគ្នាទៀត ដដែកគ្នាមួយជាពីរ ពីរជា
ប៉ី រហូតដល់ដាល់គ្នាកណ្ដាលព្រះវិហារជូចជាអ្នកលក់នៅផ្សារ ។

និយាយពីពួកអាចោរវិញ លុះអន់ភ័យ ត្រឡប់មករួមគ្នា ។ ខណៈ
នោះ អាមេចោរនិយាយថា: "យើងប្រាកដជាបានឃើញតែស្រមោល
ស្រពេចស្រពិលទេ! គឺមិនទំនងជាមានឆ្នាចស្ទាប់ហើយ។ រស់ឡើងវិញ
នៅកណ្ដាលព្រះវិហារដូច្នេះ" ។ រួចវានិយាយទៅកាន់គ្នាវាថា: "ចូរទៅ
ពិនិត្យឲ្យប្រាកដម្តងទៀត ។ ប្រសិនបើគ្មានន្ទរណាទេ គួរឲ្យគ្តៅ
ក្រហាយណាស់ ដែលនាំឲ្យវិនាសមាសរបស់យើងនេះ ។ ហើយម្យ៉ាង
ទៀត ការណ៍អ្វី ត្រូវតែដឹងឲ្យច្បាស់លាស់" ។ មានអាចោរម្នាក់ចិត្តស្មឹត្រ
ហ៊ានទៅលបមើលក្បែរទ្វារព្រះវិហារ ។ ឯអាចោរខឹលឈប់
ប្រវាយគ្នាហើយ នៅត្រាន់តែដដែកឈ្ទោះគ្នាអំពីរឿងកាសពីរបុំណ្ណោះ ។
លុះបានឃើញដូច្នោះ អាចោរនោះរត់ទៅសំណាក់មេចោរហើយប្រាប់
ថា: "លោកនាយ! មានឆ្នាចច្រើនណាស់ មាសយើងទាំងបុំន្មាន
មិនត្រប់ត្រាន់ដល់គ្នាវាទេ វាកំពុងតែប្រឈ្ទោះគ្នាដូចជាមនុស្សតម្ងន់
ដណ្ដើមកាសពីរ" ។ អាមេចោរឆ្ងើយថា: ចូរទៅមើលម្តងទៀត
អាឯងប្រឡំទេដឹង ។ អាចោរឆ្ងើយថា: បើលោកនាយមិនជឿ សូម
អញ្ជើញទៅមើលឲ្យច្បាស់នឹងភ្នែករបស់លោកចុះ ។ អាមេចោរក៏ទៅ
មែន អើតក្សាលតាមទ្វារ ដើម្បីមើលឲ្យច្បាស់ ។ អើ! តើអាមេ
ចោរឃើញអ្វី? ។

ប៉ាកាឡានឹងតន្ទាឡានៅតែដដែកគ្នាតឹងដើមក មុខក្រហមរឿង

ឲ្ជ ស្រែកញ្ជយ៉ាងឱ្ចាំង ហាក់ដូចជាក្នុងព្រះវិហារមានសុទ្ធតែមនុស្ស។

លុះអាមេចារចេះតែអើតក្សាលសឹមៗចូលទៅ ជ៉ាកាឡា ហុប! ធក់ម្ជកក្ងៃតពីក្សាលអាមេចារ ហើយស្រែកជ្រាប់ទៅតន្ជាឡាថា: ហ៉ា! យកទៅ ; នេះនែកាសពីរបស់អាឯង!

អាមេចារក៉យសូន់ ស្ជុះរត់ទៅតែក្សាលទទេ ឥតដាកក្រោយហើយលែងហ៉ានត្រឡប់មកមើលទៀត ។

ចំណែកជ៉ាកាឡានឹងតន្ជាឡា ជានឹងគ្នាវិញ ត្រឡម់ពប់អានគ្នាដូចដើម ហើយចិញ្ចឹមជីវិតដោយផលនៃការរួមគ្នាជាភាតរភាព ប៉ុន្តែតង់ថ្ងៃណាមួយ អាចារទឹលនឹងត្រូវទទួលទណ្ឌកម្មពីទេញ្ពាវិញជាមិនខាន ។

ចប់



កំណត់ទឹតប្រវត្តិការណ៍

ពិធីអនុសំវច្ឆរមហាសន្ទិចាតធី ១៣ ឱនព្រះសង្ឆ

របស់លោក ឯន_ប៉ង

កាលពីថ្ងៃអង្គារទី ១៥ មករា ១៩៥៧ រំលាម៉ោង ១៤, ៣០ នាទី នៅព្រះវិហារក្នុងវត្តបទុមវតី មានធ្វើពិធីប្រជុំមន្ត្រីព្រះសង្ឆនឹងចៅអធិការវត្ត គណៈធម្មយុត្តិ ក្រោមអធិបតីភាពនៃលោករដ្ឋមន្ត្រីក្រសួងធម្មការ ។

រំលាម៉ោង ១៥ នៅព្រះវិហារក្នុងវត្តទណ្ណាលាម មានធ្វើពិធីប្រជុំព្រះសង្ឆមេគណ, អនុគណ នឹងចៅអធិការ គណៈមហានិកាយ ក្រោមអធិបតីភាពនៃលោករដ្ឋមន្ត្រីក្រសួងធម្មការដែរ ។

កាលលោករដ្ឋមន្ត្រីក្រសួងធម្មការអញ្ជើញមកដល់ហើយ បានបើកពេលប្រជុំ ហើយបានថ្លែងអំពីសេចក្តីប្រតិបត្តិធម្មវិន័យ នឹងការបោសសំអាតទាងផ្ទូវព្រះពុទ្ធសាសនា ។ បន្ទាប់មក សម្តេចព្រះមហាសុមេធាធិបតីសង្ឆនាយក គណៈមហានិកាយ ជ្ឆិន.ណាត ថ្លែងរំលឹកអំពីកិច្ចសិក្សានឹងការគោរពព្រះពុទ្ធសាសនា ។

នៅថ្ងៃពុធទី ១៦ មករា ១៩៥៧ រំលាម៉ោង ៧ ព្រះសង្ឆទាំងឡាយ មានសម្តេចព្រះមហាសុមេធាធិបតីសង្ឆនាយក គណៈមហានិកាយ ជ្ឆិន.ណាត នឹងព្រះសុធម្មាធិបតីសង្ឆនាយក ស្ពីទី គណៈធម្មយុត្តិ

ភ្លុល.ទ្វេស ជាប្រធាន ចានទឹមន្តៅចំរើនសត្តប្បការណ៍នាព្រះចេតិយ
តាំងតូ ក្នុងវត្តព្រះកែវមករត ដើម្បីទុទ្ទិសថ្វាយព្រះពាជកុសលចំពោះព្រះ
បិតា រួចហើយទឹមន្តៅជួបជុំនៅតុទ្ធិកវិទ្យាល័យព្រះសុកម្រឹត ។

ក្នុងទុកាសនោះ យើងសង្កេតឃើញការយាងទំងការអញ្ជើញមកនៃ
ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង, សម្តេចវៀហ្វាកំងវ៉ាអឿងជ័យអធិបតី
ស្រីគ្នាវ៉ៃខ-ទុត, ឯកទត្តម សម-សារី, ឯកទត្តម ប្រាក់-ប្រាត្រឿង,
លោកសុំម-កំ ប្រធានក្រុមប្រឹក្សាព្រះពាជអាណាចក្រ, លោកឯក-យីអ៊ុន
ប្រធានវេជ្ជសាស្ត្រ ព្រមទាំងសមាជិក សមាជិកវេជ្ជកិច្ចាលទំងអស់លោក
ឯទៀតជាច្រើន ដែលយើងសូមអភ័យទោសដោយមិនបានពាប់នាមក្នុង
ទីនេះ ។

ទាងក្រោយអំពីការជួបជុំនៃមន្ត្រីសង្ឃទំងគ្រហស្ថទាំងឡាយ, ព្រះ
ករុណាជាអម្ចាស់ជីវិតលើត្បូង ទ្រង់ថ្លែងសង្កត់ថាមួយយ៉ាងខ្លីដោយឥត
ព្រាងទុកជាមុនថា ខ្ញុំករុណាមានសេចក្តីត្រេកអរជាពន្លឹកចំពោះព្រះករុ-
ណាត្រប់ព្រះអង្គដែលបានទឹមន្តមក ដើម្បីបើកអនុសាវ៉ៃយមហាសន្និបាត
ក្នុងទីនេះ, សូមព្រះករុណាជុំសទាត់ព្រះពុទ្ធសាសនាឲ្យតែតែលូវឡើង
ក្នុងអនាគត, ខ្ញុំករុណាទុកជាឫទ្ធយថាជាប្រយោជន៍ដល់ព្រះពុទ្ធ-
សាសនា ។ សូមព្រះករុណាត្រប់ព្រះអង្គទទួលនូវសេចក្តីគោរពដ៏
ជ្រាលជ្រៅអំពីខ្ញុំករុណា ។

បន្ទាប់មក លោកវេជ្ជមន្ត្រីក្រសួងធម្មការ សំដែងសុន្ទរកថា រួចហើយ
ព្រះតេជព្រះគុណពុត-ភេត ចាត្បាត់មេគណវៃត្រកំពង់ធ្នំឆ្នាំង តំណាង

ព្រះសង្ឆត្រប់អង្ត បានវិថូងសុន្ទរកថាធ្វើយតបវិញ ។ តមកទៀតព្រះ
សង្ឆស្ទាធ្យាយធម៌ ជយន្តោ ថ្វាយព្រះពរចំពោះព្រះករុណាជាអម្ចាស់
ជីវិតលើត្ឆូង ។ លុះចប់ហើយ ព្រះមហាក្សត្រទ្រង់ស្តេចថ្វាយបង្គំលា
ព្រះសង្ឆ ស្តេចយាងចូលព្រះបរមរាជវាំងវិញ ។

ដល់ម៉ោង ១០,៣០ នាទី ព្រះសង្ឆទាំងនោះ បាននិមន្តទៅទទួល
ចង្ហាន់ក្នុងមហាកុដិវត្តទណ្ណាលោម ដោយការចាត់ចែងនៃលោករដ្ឋមន្ត្រី
ក្រសួងធម្មការ និងទបាសកទបាសិកាទាំងឡាយ ក្នុងព្រះបរមនាម
នៃព្រះករុណាជាអម្ចាស់ជីវិតលើត្ឆូង ។

ដល់ថ្ងៃព្រហស្បតិ៍ទី ១៧ រំលាម៉ោង ៨ មានការប្រជុំមន្ត្រីសង្ឆខាង
គណៈមហានិកាយ នៅមហាកុដិវត្តទណ្ណាលោម ។ ដល់ម៉ោង ១៦ ព្រះ
សង្ឆទាំងនោះបានមកជួបជុំនៅមហាកុដិទៀត ហើយឡើងរថយន្តទៅ
ប្រជុំឯមន្ទីរពេទ្យព្រះសង្ឆ ។

ពិធីនេះចប់តែប៉ុណ្ណោះ ។

\+ \+ \+

យើងសូមស្រង់យក សុន្ទរកថា លោករដ្ឋមន្ត្រីក្រសួងធម្មការ និង
សុន្ទរកថា ព្រះតេជព្រះគុណពុត-កេត បាឡាត់មេគណ វិទត្រកំពង់
ឆ្នាំង មកចុះជូនអានជូចតទៅនេះ ៖

សុន្ទរកថា

នៃលោកទេសរដ្ឋមន្ត្រីទទួលបន្ទុកខាងក្រសួងធម្មការ

ថ្ងៃងនៅថ្ងៃទី ១៦ មករា ១៩៥៧

សូមព្រះតេជះដំកល់លើត្បូង!

សូមព្រះរាជទានក្រាបបង្គំទូលព្រះករុណាជាអម្ចាស់ជីវិត

សូមទ្រង់ជ្រាប ក្រោមល្អងធូលីព្រះបាទ ។

ទូលព្រះបង្គំជាខ្ញុំ សូមព្រះរាជទានទទួលនូវអំណរព្រះករុណាទិ-គុណដ៏ក្រៃលែង ចំពោះព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ដែលព្រះអង្គបានស្តេចយាងមកជាព្រះរាជាធិបតី ក្នុងពិធីបុណ្យអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឆ ទី ១៣ សម្រាប់ឆ្នាំវក ព.ស.២៤៩៩ គ.ស.១៩៥៧នេះ ។

ទូលព្រះបង្គំជាខ្ញុំសូមព្រះបរមរាជានុញ្ញាត ដើម្បីប្រស្រ័យជាមួយនឹងព្រះថេរានុត្តរ ទាំងឡាយ ដោយមានបំណងចង់ឲ្យព្រះសង្ឆបានជ្រាបនូវដំណើរកិច្ចការខ្ទះ ទាំងពុទ្ធចក្រនឹងអាណាចក្រ ដែលបានប្រព្រឹត្តទៅក្នុងបច្ចុប្បន្នកាលនេះ ក្រោមព្រះរាជាធិបតីភាព នៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ។

សូមក្រាបថ្វាយបង្គំសម្តេចនឹងព្រះថេរានុត្តរៈគ្រប់ព្រះអង្គ!

ខ្ញុំព្រះករុណា មានសេចក្តីរករាយជាទីបំផុត ចំពោះព្រះថេរានុត្តរៈគ្រប់ព្រះអង្គ មានសម្តេចជាដើម ដែលបាននិមន្តមកកាន់ទីសន្និបាតនេះ ។

សម្តេច ;

ព្រះករុណាគ្រប់ព្រះអង្គ ;

ឱកាសនេះ ទុកជានក្ខត្តបុក្ខដ៏ប្រសើរបស់ខ្ញុំព្រះករុណា ដែលបានមករួបរួម ជួបព្រះកក្ត្រ នៃព្រះតេជព្រះគុណគ្រប់ព្រះអង្គ ក្នុងវេលាដែលខ្ញុំព្រះករុណា ទទួលកាន់ការជារដ្ឋមន្ត្រីក្រសួងធម្មការ ។ ការជួប

នេះអាចចាត់ទុកថាទស្សនានុត្តរិយៈម្ជយដ៏ទត្តម ដើម្បីបានពិតទូលព្រះ
ករុណាត្រប់ព្រះអង្គ ឲ្យបានជ្រាបនូវដំណើរការណ៍ទាំងពួងរបស់ប្រទេស
យើង ដែលកំពុងចាត់ការសព្វថ្ងៃនេះ តាមតម្រាយនៃសម្តេចព្រះទបយុវ-
រាជ ដែលព្រះអង្គបានត្រាយឲ្យដើរ, តែកិច្ចការទាំងអស់ដែលខ្ញុំព្រះ
ករុណាបានចាត់ធ្វើមកក្នុងរវាងប៉ុន្មានខែនេះ ពុំដឹងជាសមតាមបំណងនៃ
ព្រះករុណាត្រប់ព្រះអង្គប្ដយ៉ាងណាទេ, ប៉ុន្តែទោះបីសេចក្តីគ្នាំងគ្នងខ្ទះក្នុង
កិច្ចប្រតិបត្តិការដែលកន្ទងទៅហើយក្តី នឹងទៅអនាគតក្តី សូមព្រះករុណា
ណាត្រប់ព្រះអង្គមេត្តាអភ័យទោសជួយបំភ្ងឹផង ដើម្បីលើកស្ទួយប្រទេស-
ជាតិ នឹងព្រះពុទ្ធសាសនាឲ្យបានជល់នូវវឌ្ឍនភាពតទៅអនាគត ។

ខ្ញុំព្រះករុណា សូមផ្ញើសេចក្តីសង្ឃឹមលើព្រះករុណាត្រប់ព្រះអង្គជា
មេគណ-អនុគណ ថានឹងជួយរិះរកមធ្យោបាយសម្រួលកិច្ចការទាំងពួង
មានអធិការណ៍សង្ឃជាដើម កុំឲ្យកើតមានក្នុងស្រុកខែត្រប្រើនពេក
តឹថាអធិការណ៍ណាដែលកើតមានឡើង ក្នុងស្រុក-ខែត្រ ហើយព្រះ
គេជព្រះគុណអាចនឹងសម្រុបសម្រួលបាន ក៏សុំឲ្យរិះរកមធ្យោបាយកែ
សម្រួលអធិការណ៍នោះ កុំឲ្យបណ្តាលវីកវាលធំឡើងបាន នាំឲ្យរវល់ជល់
ព្រះរាជរដ្ឋាភិបាល ព្រោះខ្ញុំព្រះករុណាបានសង្កេតឃើញថា អធិការណ៍ខ្ទះ
កើតឡើងជាការណ៍បន្តិចបន្ទួច ល្មមព្រះគេជព្រះគុណ មេគណ អនុគណ
អាចសម្រុបសម្រួលបានដោយត្រប់ត្រាន់ តែអធិការណ៍នោះត្រឲ្យប់
ទៅជារីកធំជល់ទៅព្រះរាជរដ្ឋាភិបាល ដែលពុំអាចនឹងរម្ងាប់បានដោយ
ងាយទៅវិញ ។ ត្រង់នេះ ជានិមិត្តរូបឲ្យឃើញថា អធិការណ៍ដែល

កើតឡើងតាំងពីបុព្វាទបណ្តាលមកតែពីរឿងហេតុបន្តិចបន្តួចប៉ុណ្ណោះ ។
បើរឿងហេតុបន្តិចបន្តួចមានកើតឡើងក្នុងអាកាសណា សូមព្រះតេជព្រះគុណមេត្តាករុណាធ្វើការបំភ្លេចរឿងហេតុក្នុងអាកាសនោះភ្លាម ។ ឲ្យស្រាច់តែម្តង ដើម្បីចៀសវាងកុំឲ្យកើតទៅជាអធិករណ៍ធំទូលាយបានឡើយ ។

ព្រះករុណាគ្រប់ព្រះអង្គ !

យើងមានភ័ព្វល្អណាស់ ដែលមានព្រះពុទ្ធសាសនាប្រតិស្ឋានទៅក្នុងប្រទេសយើងនេះ ព្រោះព្រះពុទ្ធសាសនានាំសត្វឲ្យដើរទៅរកសេចក្តីស្ងប់ គឺសន្តិភាព មិនឲ្យមនុស្សរំលោភលើមនុស្ស ដឹកនាំសត្វឲ្យគ្រឿកម្មនិងផលនៃកម្ម ដូចព្រះតេជព្រះគុណគ្រប់ព្រះអង្គជ្រាបស្រាប់ហើយ ។
ខ្ញុំព្រះករុណាសង្ឃឹមថាព្រះសង្ឃជាសិស្សផ្ទាល់របស់ព្រះពុទ្ធបរមគ្រូនឹងយកផ្លូវស្ងប់តាមគម្រោងរបស់ព្រះពុទ្ធអង្គដោយពិត ។

យើងមានភ័ព្វម្យ៉ាងទៀត ដោយបានព្រះមហាក្សត្រយើង នឹងសម្តេចព្រះបរមនាថរាជ ដែលព្រះអង្គទ្រង់នាំប្រទេសទៅរកវឌ្ឍនភាពនៅបច្ចុប្បន្ននេះ ព្រមទាំងព្រះអង្គជាអគ្គពុទ្ធសាសនូបត្ថម្ភក៍គឺព្រះអង្គជាក្សត្រខ្នុកបំរុងព្រះពុទ្ធសាសនា ដោយព្រះវិរិយភ្ជ្រាជ្ញាដ៏មហិមាសុខុំ ដូចជាក្នុងពិធីបុណ្យអនុស្សាវរីយ៍មហាសន្និបាតរៀងរាល់ឆ្នាំមក ព្រះអង្គតែងមានព្រះបន្ទូលដោយព្រះឋសាទរសព្ទាទូរថវិកាសម្រាប់ព្រះពុទ្ធច្រើន ៧.៨ ពាន់រៀលរាល់ឆ្នាំ ។ ឯក្នុងឆ្នាំនេះ ព្រះអង្គទ្រង់បរិច្ចាគ ១ ម៉ឺនរៀល ដើម្បីចាត់ថ្វៃកត្តប្រទេនព្រះករុណាគ្រប់អង្គ ដែលនិមន្តមកកាន់ទីមហាសន្និបាតនេះ ។

ព្រះតេជព្រះគុណគ្រប់ព្រះអង្គ !

ព្រះពុទ្ធសាសនានៅប្រទេសយើង ពិតមែនតែជាប្រទេសតូច មានពលរដ្ឋតិច ប៉ុន្តែប្រទេសតំណាយ ដែលជាពុទ្ធសាសនិកដូចគ្នា ចាន់ខ្លួលស្គាល់ថាជាប្រទេសកាន់ព្រះពុទ្ធសាសនាយ៉ាងហ្មត់ចត់ ត្រឹមត្រូវតាមពុទ្ធាវាទ មានពុទ្ធសាសនិក ៩៩ ភាគរយ ។ តិត្តិគុណដ៏ល្អនេះ កើតឡើងដោយសារព្រះពជរដ្ឋាភិបាលខំធ្វើការ ប្រស្រ័យទាក់ទងជាមួយប្រទេសឯទៀតដ៏ច្រើនដែលកាន់ព្រះពុទ្ធសាសនា ដោយមានព្រះមហាក្សត្រយើងជាព្រះអគ្គសាសនូបត្ថម្ភក៍ គួយ៉ាងដូចកាលពីកន្លងបុងឆ្នាំ ១៩៥៩ ដែលរដ្ឋាភិបាលសង្គមបានចាប់ផ្តើមទំនាក់ទំនងហើយនោះ បានចាត់ព្រះតេជព្រះគុណព្រះពោធិវង្ស អគ្គធិការនៃក្រុមពិនិត្យត្រួតត្រាគ្រឹះស្ថានបាលី ទីឆ្ងល ឃីមវ៉ែន ទីប្រឹក្សាបច្ចេកទេសឲ្យចេញទៅកាន់ប្រទេសថៃ ដើម្បីទិញយកមកវៀបចំការសិក្សានៅប្រទេសយើង ឲ្យបានខ្លួលយូរចំរើនឡើងគង់វង្សតាលសម័យ ។ គ្រាកាលព្រះតេជព្រះគុណព្រះពោធិវង្ស និមន្តត្រឡប់មកដល់ប្រទេសយើងវិញ ព្រះពជរដ្ឋាភិបាលតែប្រែកម្មវិធី ត្រមពាំងនាមសាលាបាលីជាន់ខ្ពស់ ឲ្យទៅជាពុទ្ធិកមជ្ឈមសិក្សាមាននាមថា ពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត ដើម្បីឲ្យសមតាមទិស្សន៍នៃពុទ្ធិកវិទ្យាល័យនេះ អាចបន្តវិវឌ្ឍនៅ ពុទ្ធិកមហាវិទ្យាល័ព្រះសីហនុរាជ នៅខៀតបាន ។

បន្ទាប់មកទៀត ព្រះពជរដ្ឋាភិបាល បានចាត់ព្រះតេជព្រះគុណព្រះពោធិវង្ស ឲ្យនិមន្តទៅបំពេញបេសកកម្មអស់រយៈពេល ២ ឬ ៣ ខែនៅសហរដ្ឋអាមេរិក តាមសេចក្តីស្នើសុំរបស់ស្ថានឯកអគ្គរដ្ឋទូតអាមេរិកប្រចាំ

ប្រទេសកម្ពុជា ដើម្បីនឹងពិនិត្យនូវការសិក្សា ដែលជាផ្នែក ១ ខាងវប្បធម៌
ក្នុងប្រទេសនោះ ។

អំពីពិធីបុណ្យពុទ្ធជយន្ត៌ គឺបុណ្យសម្ពោធពុទ្ធសតវត្សទី ២៥ ពាក់
កណ្តាលព្រះពុទ្ធសាសនា នៅប្រទេសឥណ្ឌា នៅក្នុងវិទិច្ចិកា ១៩៥៦
ព្រះរាជវង្ឋាកិបាលបានអនុញ្ញាតជល់ព្រះសង្ឆ នឹងត្រហស្ថចំនួន ៣០ រូប
ឲ្យទៅកាន់ពិធីបុណ្យនោះ ដោយចេញប្រាក់ជួលំខ្ជូន ព្រមទាំងបាន
អនុញ្ញាតឲ្យប្ពូរូបិយប័ណ្ណផង ។ ព្រះរាជវង្ឋាកិបាលបានទាំងចាត់ឲ្យនាំយក
វត្ថុជាប្រើនទៅតាំងក្នុងបុណ្យនោះ ដោយប្រទេសឥណ្ឌាមានធ្វើពិធី
បុណ្យពិព័ណិអន្តរជាតិ ក្នុងរយៈកាលនៃពិធីបុណ្យនោះផង ។ សម្តេចព្រះ
ឧបយុវរាជព្រះអង្គក៏បានស្តេចយាងទៅរួមប្រជុំក្នុងពិធីបុណ្យនោះដែរ ។

អំពីពិធីបុណ្យពាក់កណ្តាលព្រះពុទ្ធសាសនា នៅមហាវិទ្យាល័យ
យ៉ាល់ សហរដ្ឋអាមេរិក ក្នុងរាងវិទធ្ទូមុននេះ រាជវង្ឋាកិបាលបានចាត់
បញ្ជូនសៀវភៅ ស្រឿងពុទ្ធសាសនា ពុទ្ធប្រវត្តិ ព្រមទាំងព្រះបត់ ដើម្បី
តាំងក្នុងបណ្ណាល័យនៃមហាវិទ្យាល័យយ៉ាល់ ។ ព្រះករុណាជាអម្ចាស់ជីវិត
លើត្សូង ទ្រង់សព្វព្រះរាជហប្ជ៉ូយឲ្យចាត់ធ្វើព្រះរាជសាសន៍ម្ជុយច្បាប់
ដើម្បីយកទៅថ្ងៃងក្នុងពិធីបុណ្យនោះផង ។

ចំណែកខាងបុណ្យពាក់កណ្តាលព្រះពុទ្ធសាសនា នៅកដ្ឋមណ្ឌូ
ប្រទេសនេបាល់ ពីក្នុងវិទសកា ១៩៥៦ ព្រះរាជវង្ឋាកិបាល បានបញ្ជូន
វត្ថុផ្សេងៗ មានបែបផែនអក្សរប្រៀង អក្សរមូលអក្សរទមជាដើម សម្រាប់
តាំងក្នុងពិធីបុណ្យពិព័ណ៌អន្តរជាតិ ដែលបានធ្វើក្នុងប្រទេសនោះ ។

នៅកុងវិទ្ធ ១៩៥៦ ព្រះរាជរដ្ឋាភិបាលបានចាត់ព្រះសង្ឆ៦អង្គឲ្យ
និមន្តទៅរួបរួមប្រជុំជាលើកទី ៤ កុងពិធីធដ្ឋសង្គាយនា ប្រទេសភូមា
នាក្រុងរង្គូន ។ នៅពេលបញ្ចប់ពិធីធដ្ឋសង្គាយនា រដ្ឋាភិបាលភូមា បាន
ប្រគេនហានន្តរវិនសមណស័ក្តិ ចំពោះសម្តេចព្រះមហាសុមេធាធិបតី-
សង្ឆនាយក គណៈមហានិកាយ ជា អភិធជិមហារដ្ឋគុរុ គឺឲ្យគ្រឿង
សមណស័ក្តិថ្នាក់ខ្ពស់បំផុតជាងសមណស័ក្តិទីអគ្គមហាបណ្ឌិត ដែល
សម្តេចព្រះសុមេធាធិបតីបានទទួលរួចហើយនោះ ។

កាលពីកុងវិទមីនា ១៩៥៦ ព្រះរាជរដ្ឋាភិបាលបានចាត់ លោកព្រះ
ត្រូសង្ឆសត្ថា បុណ្ណា-សម្ភាជិសាស្ត្រាចារ្យនៅពុទ្ធិកវិទ្យាល័ព្រះសុរាម្រឹត
ឲ្យនិមន្តទៅរួមប្រជុំកុងគណៈកម្មការទីប្រឹក្សានៅពុទ្ធគយាប្រទេសឥណ្ឌា ។

រដ្ឋាភិបាលឥណ្ឌា មានបំណងនឹងចែកដីមួយកន្លែងនៅពុទ្ធគយា
គឺត្រង់ទីជិតកន្លែងដែលព្រះត្រាស់ ជាផ្នែក។ ឲ្យដល់ប្រទេសដែល
កាន់ព្រះពុទ្ធសាសនា ដើម្បីសាងសេនាសនៈ មានព្រះវិហារជាដើម ។
ចំពោះភាគដី ដែលនឹងត្រូវបានមកប្រទេសកម្ពុជា ព្រះរាជរដ្ឋាភិបាល
កំពុងធ្វើការប្រស្រ៊ីយទាក់ទងនឹងប្រទេសឥណ្ឌា សព្វវិថ្ងៃនេះ តែពុំទាន់
សម្រេចលទ្ធផលប្រាកដនៅឡើយ ។

ព្រះករុណាត្រប់ព្រះអង្គ, ពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ ដែល
បានចាប់បដិសន្ធិកុងត ស. ១៩៥៥នោះ បានកើតត្រឹះស្ថាន ៦ ខ្នងរួច
ហើយ កុងមួយខ្នងមាន ៦ ថ្នាក់ ។ ឯការសិក្សានៅមហាវិទ្យាល័យនេះ
ប្រហែលជានឹងបានសម្រេចផលកុងរយៈកាល ៦ ឆ្នាំខាងមុខនេះ ព្រោះ

គណៈកម្មការមួយក្រុម កំពុងរំប្រឹងរៀបចំស្នាដៃចប្បាប់សម្រាប់បង្រៀន ដែលបានប្រែពីភាសាបរទេសមកជាខ្មែរភាសា ឲ្យបានទាន់ការវេលាដែលត្រូវបើកឲ្យសមណនិស្សិតចូលរៀន ដោយបច្ចុប្បន្នសម័យនេះ សមណនិស្សិតដែលត្រូវរៀនតាមកម្មវិធីថ្មីនៃពុទ្ធិកវិទ្យាល័យព្រះសុពាម្រឹត បានឡើងដល់ថ្នាក់ទី ២ ហើយ ។

ក្នុងឆ្នាំ ១៩៥៦ ពុទ្ធិកមហាវិទ្យាល័យបានទទួលអំណោយពីព្រះសង្ឃខេត្តពួកខ្មែរក្រោមប្រទេសថៃ ទូវព្រះត្រៃបិដកមិនទាន់ ១ ព្រះធ្មកំពាលតៅស៊ូ ៣ សៀវភៅធម៌ខ្លីសៀវភៅស្នាដៃផ្សេង ។ ១០៣៩ ក្បាល គម្ពីព្រះអភិធម្មស្លឹកតែ ១ គម្ពីរ ដើម្បីទុកជាសម្ភតិសម្រាប់ពុទ្ធិកមហាវិទ្យាល័យ ។

បន្ទាប់មកទៀត លោក មី.ផ្លរីសីហ៍ អតីតរដ្ឋមន្ត្រីក្រសួងធម្មការ បានបរិច្ចាគប្រាក់ផ្ទាល់ខ្លួនលោក ធ្វើអំណោយដល់ពុទ្ធិកមហាវិទ្យាល័យនេះទូវសម្ភារៈគ្រប់ប្រភេទ គឺតុសម្រាប់គ្រូ ដើងម៉ាសម្រាប់សិស្សរៀន ខ្នើនូវដើម តម្លៃប្រាក់ ៨១២០រៀល ។

កាលកន្លងទៅមិនា ១៩៥៦ សម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយក គណៈមហានិកាយ ខ្លឹង លោកគ្រូព្រះពោធិវង្ស ធ្វើទស្សនាចរទៅកាន់ទីវត្តកន្លងទៅគ្រប់នាមា ដើម្បីពន្យល់ពុទ្ធបរិស័ទឲ្យយល់ច្បាស់អំពីផ្លូវព្រះពុទ្ធសាសនា ខ្លឹងប្រយោជន៍នៃសាសនសិក្សា ។ ប៉ុន្តែចំណែកខាងទស្សនាចរ នៃសម្តេចព្រះសង្ឃនាយកនៅតុំពាន់ប្លាន់គ្រប់នៃត្រនៅឡើយ

ការនេះមុខជានឹងមានតទៅទៀត ។

បពិត្រព្រះករុណាគ្រប់ព្រះអង្គ, អំពីចលនានៃព្រះពុទ្ធសាសនា ដែលខ្ញុំព្រះករុណាបានរៀបរាប់មកដោយសង្ខេបខាងលើនេះ សូមព្រះករុណាគ្រប់ព្រះអង្គបានជ្រាបច្បាស់ថា ព្រះពជរដ្ឋាភិបាលសង្គមកស្ត្រីយមដែលមានសម្តេចព្រះ។បយុវរាជជាប្រធាន ពុំមែនក្រឡេកមើលតែខាងកិច្ចការខាងអាណាចក្រទេ គឺក្រឡេកមើលឃើញច្បាស់នូវពុទ្ធចក្រផង ព្រោះប្រទេសកម្ពុជាយើងនេះ ជាប្រទេសកាន់ព្រះពុទ្ធសាសនាសុទ្ធសាធ ពុកផ្តូចជារៀមានចក្រ ២ លុះណាតែបង្វិលចក្រទាំង ២ ឲ្យរៀលៅមានលក្ខ្ឍន្តស្មើគ្នា ទើបសេចក្តីចំរើនកើតមានឡើងដល់ប្រទេសជាតិរបស់យើង ។

ហេតុនេះ ខ្ញុំព្រះករុណាសូមផ្ញើរសេចក្តីសង្ឃឹមពុកចិត្តលើព្រះករុណាដែលជាមន្ត្រីសង្ឃមានមេគណ-អនុគណជាដើម គ្រប់ខែត្រ-ស្រុក សូមព្រះករុណាគ្រប់ព្រះអង្គយកព្រះទ័យពុកជាក់ ជាស់តឿនក្រើនរំលឹកដល់លោកគ្រូចៅអធិការគ្រប់វត្ត ឲ្យរៀបស់កិច្ច-សាមណេរទាំងអស់ត្រមទាំងពុទ្ធបរិស័ទគ្រប់ថ្នាក់ឲ្យប្រតិបត្តិតាមឱវាទនៃព្រះពុទ្ធបរមគ្រូយើង ដែលព្រះអង្គទ្រង់នាំយមយកការចេះដឹងនឹងធម៌ជាគោលនៃសេចក្តីប្រតិបត្តិ ។

ទីបំផុតនៃសុន្ទរកថានេះ ខ្ញុំលព្រះបន្ទូលជាខ្ញុំ សូមបង្ហើនព្រះពជកុសលថ្វាយចំពោះព្រះករុណាជាអម្ចាស់ជីវិតលើស្ងួន សម្តេចព្រះមហាក្សត្រិយានី សូមព្រះអង្គស្ថិតនៅជាសុខ ក្នុងសិរីពជសម្បត្តិអស់កាលជាអង្វែងតទៅ ! ត្រមទាំងសូមថ្វាយព្រះពជកុសលចំពោះសម្តេចព្រះ។បយុវរាជ សូមព្រះ

អគ្គិបានប្រកបដោយសិរីសួស្តី ជោគជ័យមង្គលគ្រប់ក្រោរ កំចាត់បង់ទុក្ខ
ឧបសគ្គចាំងឡាយកុំឲ្យកើតមានដល់ព្រះអគ្គ ដើម្បីបានទ្រង់ដឹកនាំ
ប្រទេសជាតិ ទឹងព្រះពុទ្ធសាសនា ឲ្យដើរឆ្ពោះទៅរកសន្តិភាពទឹងវិឌ្ឍន
ភាពជាខ្លួនរៀងតទៅ ។

* * *

សេចក្តីផ្តើយរបស់តំណាងសង្ឃ
តបបំពោះសុន្ទរកថានៃលោករដ្ឋមន្ត្រី ក្រសួងធម្មការ

សូមថ្វាយព្រះពរព្រះកុណាជាតម្ងាស់ដ៏វិត
ព្រះបរមបពិត្រ សូមទ្រង់ជ្រាប ។

តាមរយៈបញ្ហានៃសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយក អាត្ម
ភាពសូមព្រះរាជទានព្រះបរមានុញ្ញាត ថ្លែងតបសុន្ទរកថានៃលោក
រដ្ឋមន្ត្រីក្រសួងធម្មការ ជាសេចក្តីសង្ខេបដូចតទៅនេះ :

ក្នុងនាមនៃព្រះសង្ឃក្នុងព្រះរាជអាណាចក្រ អាត្មភាពសូមថ្លែងនូវ
អំណរជើលើសលុប ចំពោះកិច្ចការងារដ៏ប្រសើរដែលព្រះពុទ្ធសាសនា
កម្ពុជក្នុងសម័យនេះ បានបំពេញទៅក្រោមព្រះបរមរាជូបត្ថម្ភដោយព្រះករុ-
ណាធិគុណដ៏ផូរផង់ល្អបំសុខ្លួនៃព្រះករុណាជាម្ចាស់ជីវិត សម្តេចព្រះមហា-
ក្សត្រិយានី ទឹងទ្រង់ព្រះករុណាថ្លៃវិសេសសម្តេចព្រះនរោត្តមផង ព្រម
ទាំងការឈឺឆ្អាលខ្វល់ខ្វាយរបស់លោករដ្ឋមន្ត្រីជាប្រក្រសួងទាំងពួងក្រ
ដែលជ្រាបមានកិត្តិសព្ទឋាជាដ្ឋប្បុរសខ្លួបអកយកចិត្តទុកដាក់យ៉ាងម៉ឺងម៉ាត់
ចំពោះព្រះពុទ្ធសាសនា ។

សូមជំពាក់លោករដ្ឋមន្ត្រី!

តំបូងការដែលរដ្ឋមន្ត្រីបានត្រួសត្រាយតាមលំអានមាគ៌ានៃព្រះគុណាថ្លៃវិសេសសមេ្តចព្រះទេមយុវាជ ក្នុងរាត្រីប៉ុន្មានខែ ដែលលោករដ្ឋមន្ត្រីបានអញ្ជើញមកកាន់ក្រសួងធម្មការ តាមយោបល់របស់អាត្មាភាព សឹងជាទឹកចិត្តនៃព្រះសង្ឃខ្លះៗ ព្រោះសុទ្ធតែជាគោលដែលនាំឲ្យព្រះពុទ្ធសាសនា ប្រទេសយើងឈរមុខទៅរកសេចក្តីចំរើនថ្កើងថ្កាន ប៉ុន្តែតាមការសង្កេតផ្ទាល់របស់អាត្មាភាព នៅតំបន់ខ្លះកំពុងអន្ទុះត្អូញត្អែទៅបានដោយប្រួស នៅកន្លែងខ្លះគង់មានការរអាក់រអួលដែរតាមយោបល់របស់អាត្មាភាព ជំណើរនេះ មកអំពីព្រះថេរៈជាអ្នកកាន់ការ អង្គខ្លះគឺមានសមត្ថភាពគ្រប់គ្រាន់ អង្គខ្លះនោះពុំសូវមានសមត្ថភាពប៉ុណ្ណា ឧទាហរណ៍ដូចជាអធិការណ៍ក្នុងសង្ឃមណ្ឌលជាដើម នៅនៃត្រណាដែលលោកអ្នកគ្រប់គ្រងប្រកបដោយសមត្ថភាពគ្រប់គ្រាន់ នៅនៃត្រនោះ អធិការណ៍ដែលកើតមានឡើងគាំងប៉ុន្មានសឹងសូប៉ម្លាប់ទៅវិញស្ទើរ។ ស្ទើរតែគ្មានដែលលេចឡើងនាំឲ្យរំលស់អំពល់ដល់ក្រសួងធម្មការនឹងក្រសួងព្រះសង្ឃនាយកសោះ ។ ករណីនេះ ប្រសិនបើបានសម្តេចសង្ឃនាយក ឬបានលោករដ្ឋមន្ត្រីទិមន្តអញ្ជើញទៅបំពេញទស្សនាចរណ៍រៀងរាំមដ្ឋាត់បង្ហាញមេ្លាជាយមន្ត្រីសង្ឃអ្នកកាន់ការដល់ទីកន្លែងរឿយៗ បន្ថែមលើអនុសាវនមហាសន្និបាត ដែលតែងតែមានរាល់ឆ្នាំផងនោះ អាត្មាភាពយល់ឃើញថា ប្រហែលជានឹងរកសេចក្តីសូប៉ត៌សន្តិភាពនឹងវឌ្ឍនភាពបានដោយងាយ ហើយនាំឲ្យមានការប្រុងប្រយ័ដ៏ជិតស្និទ្ធ

ស្រណុកឥតការផង ។

ក្នុងសម័យនេះ ប្រទេសយើងមានកេរ្តិ៍ឈ្មោះប្រសើរខាងព្រះពុទ្ធសាសនាល្បីល្បាញផ្សព្វផ្សាយទូទៅក្នុងពិភពលោកដោយសារបេសកកម្មផ្សេង ។ ខាងព្រះពុទ្ធសាសនា ដូចលោកវដ្ដមន្ត្រីបានរៀបរាប់ក៏មែនហើយ ប៉ុន្តែតាមពិតនៅចឹកខ្វែងខ្លះ ហាក់ដូចនៅពុំទាន់សមស័ក្តិនឹងកិត្តិយសនេះនៅឡើយ ពាំនាំងាងការសិក្សា ពាំនាំងចរិយោសណ្តាប់ធ្នាប់ផ្លូវប្រតិបត្តិ ។ អាត្មាភាពសង្ឃឹមថាព្រះថេរានុត្ថេរៈពាំនាំអស់ទីធំប្រឹងយកព្រះទ័យទុកដាក់តាមសេចក្តីដើទំនុកទុកចិត្តរបស់លោកវដ្ដមន្ត្រីពុំខាន ប៉ុន្តែការណ៍នេះទើសម្រេចទៅបាន លុះត្រាតែមានជំនួយហ៊ានមាំអំពីលោកវដ្ដមន្ត្រីក្រោមព្រះបារមីជូបត្ថម្ភនៃព្រះករុណាជាម្ចាស់ដីតែ សម្តេចព្រះមហាក្សត្រិយានីនឹងព្រះករុណាក្លែរសេសសម្តេចព្រះទេបយុវរាជ។

នៅទីបំផុត ដោយព្រះពុទ្ធសាសនាជ្រះថ្លាដ៏មោះមុតក្នុងព្រះពុទ្ធសាសនា សូមគុណព្រះត្រៃរត្នអភិបាលរក្សាព្រះមហាបពិត្រនឹងសម្តេចព្រះមហាក្សត្រិយានី សម្តេចព្រះទេបយុវរាជនឹងព្រះពរជាផ្លូវកិច្ចលើដែលមានលោកវដ្ដមន្ត្រីជាចៅក្រសួងខាងព្រះពុទ្ធសាសនា សូមទ្រង់ប្រកប សូមបានប្រកបដួចតែនឹងបរមសុខនិងសព្វកាលទុកជានិច្ចតរៀងទៅ ដើម្បីសេចក្តីចំរើននៃព្រះពុទ្ធសាសនាកម្ពុជរដ្ឋក្នុងសម័យសតវត្សទី២៥ គឺពុទ្ធសករាជគំរប់២៥១០ វស្សា ជានិច្ចនិរន្តរ៍តរៀងទៅ។

សូមថ្វាយព្រះពរ ។

ចប់

បុណ្យដង្ហែនឹងអគ្គសេកព្រះពុទ្ធរូបសម្រេច

លោក អឿ តួលុប

ខេត្តក្រុងកំពត កាលពីថ្ងៃទី ១៩-១៦-១៧ មីនា គ.ស. ១៩៥៧ មានពិធីបុណ្យ ១ យ៉ាងខ្លាំងអធិកអធំ គឺបុណ្យដង្ហែនឹងអគ្គសេកព្រះពុទ្ធរូបសម្រេចអគ្គធំ ១ ព្រះអង្គ ដ៏មានលំអដ៏តធាយភ្នែរលោនជួចខ្លា មានកំពស់ ៦ ម៉ែ ០០ ព្រះភ្លៃនទ្រ ១ ម៉ែ ៨០ ខម្ងន់ ១ តោន ៦០០ គីឡូ គឺព្រះពុទ្ធរូបខម្ងន់ ១.៤០០ បល្ល័ង្កដែក ៤០០ គីឡូក្រាម ។ ចំពោះព្រះពុទ្ធរូប មានលាបមាស ៣ គីឡូក្រាម សាច់ប្រាក់ ២៨ គីឡូក្រាម ស្ពាន់ ១ ដង្កៀលសម្រេច ទឹងដែក ១.១៦៨ គីឡូក្រាម ចូករួមទាំងអស់ ខម្ងន់ ១.៤០០ គីឡូក្រាម, ព្រះមោលី រៃត្រដោយត្បូង ស ៤ ៣ ៨ គ្រាប់, ព្រះនេត្រដាំត្បូងមរកត មានដាក់អំពូលអគ្គិសនីតាងក្នុងព្រះសរ សម្រាប់ចេកបញ្ចាំងភ្លើងជាព្រះពុទ្ធប្បដិមាកវែលសិតសាងឡើងដំបូង ដោយស្នាដៃជាងជាតិខ្មែរសម័យឯកពេជ្ជ រៀងពាក់កណ្តាលពុទ្ធសាសនា ។ ពិធីបុណ្យនោះ មានកម្មវិធីដូចរៀបរាប់ដោយសង្ខេបតាមនេះ :

ទី ១ ថ្ងៃ ១៤ កើត ខែផល្គុន ឆ្នាំកុរអដ្ឋស័ក

ព.ស. ២៤៩៩ (១៤ មីនា គ.ស. ១៩៥៧)

– ម៉ោង ១៤ រសៀល ជង្ហែដោយក្បួនពុទ្ធបរិស័ទប្រជុំគ្នាចេញពីផ្ទះលេខ ១៨៧ ខាងកើតភពលាសង្កាត់លេខ ៥ តាមក្រុងថៃព្រះចាន-សីហនុ បត់តាមមហាវិថីព្រះចាខមុខវែង ឆ្ពោះទៅកាន់វត្តមណីរតនារាម (ឬលភាពួង) សង្កាត់លេខ ៥ ក្រុង កំពត ;

-មោង ១៩ យប់ ចំរើនព្រះបរិត្តនៅទីវត្តឧលតាពូន;

-មោង ៦០ យប់ និមន្តសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយក ជួន-ណាត គណៈមហានិកាយ សំរំជនធមិ ។

ទី ២ ថ្ងៃ ១ ភេប ផល្គុន (១៦មីនា):

-មោង ៧ ព្រឹក ប្រគេនយាគូ;

-មោង ៨ ព្រឹក ទេសនាជាតកទល់ល្ងាច;

ទី ៣ ថ្ងៃ ២ ភេប ផល្គុន (១៦មីនា):

-មោង ៧ ព្រឹក ប្រគេនយាគូ;

-មោង ១០ ព្រឹក ប្រគេនកត្តជល់ព្រះសង្ឃ ៧ វត្ត;

-មោង ៦០ យប់ ទេសនាបឋមត្រាស់នឹងធ្វើកិច្ចពុទ្ធាភិសេកទល់ភ្ជឹ ។

ទី ៤ ថ្ងៃ ៣ ភេប ផល្គុន (១៨មីនា):

-មោង ៨ ព្រឹក ជារធ្វន;

-មោង ១៥ រសៀល ទេសនាបឋមសន្ត្តាយនាធ្វនបុណ្យ ។

នាមអ្នកផ្ទើមកសាង

១- លោក ណាក-តានុច ក្រសួងហិរញ្ញវត្ថុ;

៦- លោក សៅ-ជន តម្រួតក្រុមព្រះនគរបាលក្រុមមឿន;

៣- លោក ឌឿ-តូលុច សាលាក្រុងភ្នំពេញ;

៤- លោក ណាវ-យុន និងក្រុមជាងរាជកយស្ម៉ីយយាន;

៥- លោក ជន-គន់ និងកម្មករទស្សាហកម្ម;

៦_ លោក អៀន-កៀន នឹងក្រុមជាងនាវាចរក្រសួងសាធារណការ;

៧_ លោក ខ្ចៅ-ពូន ជាងសាងពុម្ពនឹងសិត ។

× × ×

សុន្ទរកថា

លោក អៀ-ភូលុច

វេលាយប់ទី ១ ខ្ចុំ (អៀ-ភូលុច) បានថ្វៃងជូនទីប្រជុំស្តាប់នូវសុន្ទរកថា រៀបរាប់ពីអំពីប្រវត្តិហេតុនៃការសាងព្រះពុទ្ធរូប នឹងពិធីបុណ្យពុទ្ធាភិសេក មានសេចក្តីជូចតទៅនេះ ៖

សូមគ្រាបបង្គំទូលទ្រង់!

សូមជំរាបអស់លោក-អ្នក ពុទ្ធបរិស័ទជាទីគោរពទាំងឡាយ!

សូមទ្រង់ជ្រាប សូមទានជ្រាប ។

ទូលព្រះបង្គំ ខ្ចុំបាទ សូមសំដែងអំណរយ៉ាងជ្រាលជ្រៅ ចំពោះគុណដ៏ខ្ពង់ខ្ពស់របស់ទ្រង់ នឹងអស់លោក-អ្នកពុទ្ធបរិស័ទទាំងឆ្នែរ ចិនយួន ដែលបានស្តេច បានអញ្ជើញមកជួយដឹង្ហព្រះពុទ្ធប្បដិមាការនេះ, ដែលជាការមួយសឲ្យឃើញថាទ្រង់នឹងអស់លោក-អ្នក ប្រាកដជាមានសទ្ធាជ្រះថ្លាចំពោះព្រះពុទ្ធសាសនាមែន ហើយជាការលើកដំកើងកិត្តិយសនៃព្រះពុទ្ធប្បដិមាការសម្រឹទ្ធនេះ ដែលសាងឡើងជាលើកដំបូងនៃស្នាដៃជាងឆ្នែរ ក្នុង ព.ស. ២៥០០ នេះផង ។

ក្នុងវេលាដ៏ខ្លីនេះ ទូលព្រះបង្គំ ខ្ចុំបាទ សូមឈ្វៀតឧកាសទូលទ្រង់ នឹងជំរាបអស់លោក-អ្នក នូវដំណឹងព្រឹត្តិការណ៍នៃការចាប់ផ្តើម

កសាងព្រះពុទ្ធប្បដិមាកវនេះ ដោយសង្ខេបដូចតទៅ :

កាលពី ត. ស. ១៩៥៦ លោក ណាក-តានុច ធ្វើការនៅ ក្រសួងហិរញ្ញវត្ថុ ទីលំនៅ ៗ ផ្ទះលេខ ១៨៧ រុក្ខវិថីព្រះបាទ ន.សីហនុ ខាងកើតសាលាសង្ការត់លេខ ៥ ក្រុងភ្នំពេញ ដែលជាពុទ្ធសាសនិកជន ១ រូបតែងតែមានសទ្ធាជ្រះថ្លាក្នុងការកុសលផ្សេង ៗ បានបបួលលោក សៅ-ជន តម្រួតក្រុមព្រះនគរបាលក្រុមម្យឹង ដែលមានសញ្ញាប័ត្រ សាលាដែក ហើយជាអ្នកធ្លាប់ស្គាល់ពួកជាងនឹងញាតិមិត្តជិតខាងច្រើន ៗ ដោយអំណាចគុណានុភាពនៃព្រះរតនត្រ័យជួយទ្រទ្រង់ ក៏បណ្តាលឲ្យអ្នក ទាំង ៦ នេះ សាមគ្គីគ្នាយ៉ាងជិតស្និទ្ធ ដើរកពួកជាងបេះធ្វើពុម្ពសិត ដើម្បីសិតព្រះពុទ្ធរូបសម្រិទ្ធកំពស់ ៦ ម៉ែត្រ ព្រះក្នែន ១ ម៉ែត្រ ៨០ តែរកពុំបានសោះ ព្រោះគេពុំហ៊ានទទួលដោយក្រែងធ្វើពុំកើត ជ្យិតព្រះ ពុទ្ធរូបអង្គធំពេក ៗ អ្នកទាំង ៦ ព្យាយាមរកអស់រយៈវេលា ១ ឆ្នាំទើប បានជួបនឹងលោក ឡៅ-ពូន ដែលមានសញ្ញាប័ត្រសាលាវិចិត្រសិល្បៈ ទេមរៈ ជាអ្នកធ្លាប់ប្រកបជីវភាពដោយរបរធ្វើព្រះពុទ្ធរូប ៗ ពេល នោះ លោក ឡៅ-ពូន ពិតមែនតែធ្លាប់ធ្វើជាងស្មិត តែពុំធ្លាប់ធ្វើព្រះ ពុទ្ធរូបអង្គធំយ៉ាងនេះទេ ស្ទើរតែពុំហ៊ានទទួលធ្វើ, ប៉ុន្តែដោយសេចក្តី បង្ខំអំពីអ្នកដ្តើមកសាងទាំង ៦ រូប នឹងដោយសេចក្តីទ័លក្រ ព្រោះគ្មាន នរណាទំនុកបម្រុងឲ្យមាំមួន ក៏ប្រថុយធ្វើទៅ ហើយបានដ្តើមធ្វើពុម្ព ទ្បើង ៗ ដោយសេចក្តីមានះ នឹងសេចក្តីព្យាយាមរបស់អ្នកទាំង ៦ រូប អស់រយៈវេលាជិត ៦ ឆ្នាំ ទើបពុម្ពនោះកើតបានជារូបរាង អវយវៈ ១៦

ផ្នែកនៃព្រះពុទ្ធរូប ។

ដោយហេតុការសិតព្រះពុទ្ធរូបសម្រាប់អង្គធំនេះ ជាការពិសោធន៍លើកដំបូងរបស់ជាងខ្មែរសម័យបច្ចុប្បន្ន ក៏បណ្តាលឲ្យយើតយូរ តី

១. មកអំពីការពិសោធន៍ធ្វើពុម្ពសិតជាលើកដំបូង ដែលនាំឲ្យអ្នកជំនាញមើលងាយថា ធ្វើពុំកើតទេ ពុកជាកើតក៏មិនល្អមិនសម, អ្នកខ្លះមើលងាយដល់ទៅតិះដៀលកំទេចពុម្ពនោះចោល, ម្ល៉ោះហើយអ្នកផ្តើមការក៏ផ្អាកធ្វើម្តងទៅ ។ ថ្ងៃក្រោយ ទើបបានចាប់បន្តសកម្មភាពសារជាថ្មី ក្រែតែបានសម្រេចជាពុម្ពឡើង ;

២. មកអំពីការខ្វះខាតថវិកាដែលនាំឲ្យចាត់ការឲ្យបានឆាប់រួសពន់ពុំបាន សន្សឹមតែលើប្រាក់បៀវត្ស ធំធៀលឹក ដែលកើតអំពីការងាយស្រួលនៃអ្នកផ្តើមការប៉ុណ្ណោះ មិនហ៊ានខ្វល់ការចាប់កុសលរបស់អ្នកជំនួសោះ ព្រោះខ្លាចក្រែងធ្វើពុំកើត ម្ល៉ោះហើយក៏ខ្ជិតខ្ជាយប្រាក់ចាត់ការទិញប្រដាប់សម្រាប់ធ្វើនឹងថ្ងៃឈ្នួល ។

ខ្ញុំព្រះបង្គំ ខ្ញុំបាទ មិនចង់ក្រាបទូលជំពាក់ឲ្យអស់សេចក្តីទេ ព្រោះខ្លាចក្រែងអ្នកផ្តើមការនឿយខ្ចាស តែសូមគោលចន្ទិចទៅចុះថា អ្នកផ្តើមការជួនកាលចំពាក់ឈ្នួលជាងដល់ទៅបណ្តាក់អង្គរគេមកឲ្យជាងកំមាន ឯជាងសោកតំណេះតែសុទ្ធតែប្រាំដោយចេចង់ចាន់ក្តីរណ្តៅនឹងចង់ឲ្យកើតជាអង្គព្រះពុទ្ធប្បដិមាការឡើង ។

របៀបធ្វើពុម្ព.— មុនដំបូង គេពូនដីជារូបពន្លះតាមទំហំនឹង

កំពស់ ឲ្យសមតាមបំណងរបស់គេ រួចគេយកក្រមួនសុទ្ធមកចំទ្រនាប
ពីលើ ហើយខាត់ដំឲ្យរាបស្មើយ៉ាងរលោង ទើបគេចំទដាយអង្កាមពី
លើទៀត ជាន់គេតាត់អាយ៉ះជា ១៤ ផ្នែក ។ ក្រមួនសុទ្ធដែលគេត្រូវការ
ប្រើនោះ មានទម្ងន់ ៥៦ គីឡូក្រាម ។ ឯប្រាក់ដែលចំណាយក្នុងការផ្តើម
ធ្វើពុម្ពនោះ អស់ចំនួន ៥៣.០០០'០០ ។

ក្រោយពេលដែលសាងពុម្ពនោះរួចហើយ, អ្នកផ្តើមការសាងទាំង ២ រូប
មានសទ្ធាមួយថា ខ្ញុំនឹងក្លែកក ទើបជាន់ជាំគ្នាធ្វើបុណ្យរំលាយស្ពាន់
សិតព្រះ នៅថ្ងៃទី ៨ ខែមេសា គ.ស ១៩៥៥ ក្នុងបរិវេណវត្តខ្លួល
ភាពូនេះ ។ មុនថ្ងៃធ្វើបុណ្យជាន់អំពាវនាវតាមវិទ្យុជន តាមប្រកាស
ជូនដំណឹង (ជាច្រើនក្រាម) ជន ដើម្បីទ្រង់ទឹងអស់លោក-អ្នកចូលចាប់
កុសលតាមសទ្ធាជ្រះថ្លានោះជាបច្ច័យឬជាមាសប្រាក់ស្ពាន់ខ្ចប់ដែនក្តី យក
មករំលាយចាក់ពុម្ពជាអាយ៉ះព្រះពុទ្ធរូប ១៤ ផ្នែក នៅចំពោះមុខអស់លោក-
អ្នកដ៏មានសទ្ធា ជួបទ្រង់ទឹងអស់លោក-អ្នកជាន់ទស្សនាកន្លះវេលាធ្វើ
បុណ្យសិតព្រះពុទ្ធរូបនោះស្រាប់ហើយ ។

ការរំលាយស្ពាន់ចាក់ពុម្ព:- មានឃ្ល ១ ដុតឆ្ងាំង ១ មានយន្តកង្ហារធំបក់បញ្ចេញខ្យល់ឲ្យមានកម្លាំងក្តៅខ្លាំង ឆេះសន្ធោសន្ធៅ, អណ្តាតភ្លើងកំពស់ ៣-៤ ម៉ែត្រតាមកាន់ឃ្ល, ទើបគេថ្លឹង ស្ពាន់ ប្រាក់ មាស ខ្ទាស ខ្ចប់ដែន សម្រិទ្ធ ដែក ឲ្យត្រប់ភោជាតុ ៧ ប្រភេទតាមកម្លាំងពុម្ព រួចយកទៅចាក់កន្លះ ឲ្យរលាយទៅជាទឹក ទើបគេយកមកចាក់ក្នុងពុម្ព ដែលកំពុងឆេះភ្លើងឃ្លាំងខ្លាំងនោះ ម៉ោលទៅតួនឲ្យស្ទើចាក្រែលងចំពោះ

ការតស្សិរបស់ក្រុមជាងស្ងិតវ្ទារនោះ ព្រោះទូលព្រះបង្គំ ខ្ញុំបាទ ពុំដែលឃើញនរណាហ៉ាននៅជិតក្នុក់ត្រីងកំពុងធេះក្តៅ ដូចក្រុមជាងទាំងនោះសោះឡើយ ។

ឯពួកជាងទាំងនោះមាន ៤ ក្រុម គឺ

១- ក្រុមជាងរំលាយស្ពាន់ មកពីក្រុមរាជអយស្ម័យយាន មានលោកណាវ-យុង ជាអ្នកនាំ;

២- ក្រុមជាង អតីតសិស្សសាលាវិចិត្រសិល្បៈខេមរៈ មានលោកឡៅ-ពូន ជាអ្នកនាំ;

៣- ក្រុមជាងផ្សានឹងខាត់ មានលោក ជង់-គង់ ជាអ្នកនាំ ;

៤- ក្រុមជាងដែក មកពីក្រុមនាវាចរ ត្រស្ងងធារណាការ មានលោក សៀង-ភៀង ជាមេដឹកនាំ ។ សរុបទាំងអស់ ៨៩ នាក់ ។

សូមអភ័យទោស ដោយក្នុងទីនេះទូលព្រះបង្គំ ខ្ញុំបាទ ពុំបានរាយនាមអស់លោកអ្នកសព្វត្រប់ ដែលមានសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសានាបានចេញមុខជួយជាកម្លាំងកសាងព្រះពុទ្ធរូប ដោយមិនខ្ជាចក្តៅ មិនខ្ជាចនឿយហត់ មិនខ្ជាចខាតពេលធ្វើការជាប្រយោជន៍ខ្ជូនសោះ ។

ការនេះតួរតែចារឹកនាមជាងទាំងនោះ ក្នុងដែងលាប្ចជ្ជាំងស្ពាន់មួយជ្ជាំងទុកជាភស្តុតាងតទៅ ដើម្បីបង្ហាញយុវជនវ្ទារ ក្នុងអនាគត ឲ្យចេះស្រឡាញ់ឯស្សាហកម្ម ។

អាស្រ័យដោយការចាប់កុសលពេលនោះ ដូចជាមាស ប្រាក់ ស្ពាន់ ទង្វា លង្ហិន សម្រឹទ្ធ ដែលហូរចេញអំពីជួងចិត្តរបស់ពុទ្ធបរិស័ទទាំង

ឡាយ ទើបកើតឡើងជាព្រះពុទ្ធរូបនេះបាន ហើយស្ពាន់ដែលមាន
សល់ខ្ទះនោះ លោកត្រូបៅអធិការវត្តនេះ បានយកខ្ទះទៅចូលធ្វើព្រះ
សក្យមុនីស្ពូបវតន៍ដំកល់ព្រះបរមសារីរិកធាតុ ។

ឯប្រាក់ចំណូលក្នុងពេលបុណ្យសិត គាំងខាងអ្នកផ្តើមសាង
គាំងខាងសប្ប្យុរស រួមគាំងអស់បាន ៤៩.៣៩៦រ.៩០, ចំណាយក្នុង
ការបុណ្យនោះអស់ ៤៦.៤៦៣រ.០០ នៅសល់ ៨៣៣រ.៩០ អ្នក
ផ្តើមបុណ្យ បានយកប្រាក់ដែលនៅសល់នោះទៅប្រគេនលោកត្រូ
បៅអធិការវត្តទួលតាពូងឲ្យសាងព្រះវិហារវត្តនេះ តាំងពីពេលបុណ្យនោះ
ហើយ ។

ការផ្សាភ្ជាប់ជាតួអង្គព្រះ.-

ដើម្បីបៀសវាងពាក្យអកុសល
នឹងការធ្វាយពីទីលំនៅអ្នកធ្វើការនោះ លោក ជង់.ឆង់ បានយក
ផ្នែកអវយវៈព្រះពុទ្ធរូបគាំងអស់ទៅផ្សាឯផ្ទះលោក នៅខាងជើងផ្សារ
ស្ទូនថ្មី ចម្ងាយ ៣០០ ម៉ែត្រពីផ្សារ ។ ពេលដែលផ្សាភ្ជាប់តួព្រះអង្គ
ចេះតែមានទបសត្តប្រែដោរ នាំឲ្យកាត់ចោលហើយផ្សាបំពេញជាថ្មីឡើង
វិញ ពីព្រោះជាការពិសោធន៍ លើកដំបូងរបស់ពួកជាងខ្មែរសម័យនេះ
ដែលនាំឲ្យការនោះយឺតយូរ ក្រាមគាំងពុំមានថវិកាផ្ទាល់ខ្ទួនបរិបូណ៌
ជង ដ្ឋិតត្រូវការទិញទឹកបន្សាប្រើនជង ទិញម្តង ។ អស់តម្លៃដល់មឺន
រៀល ។ សេចក្តីខ្ទះខាតថវិកានេះហើយជាទបសត្តធំនាំឲ្យយឺតយូរពេល
អស់រយៈជិត ៦ ឆ្នាំទាល់ជិតដល់ពាក់កណ្តាលសាសនាទើបបានធ្វើហើយ
ស្រេច ។ ឯការពិសោធន៍នោះក៏យើញច្បាស់ជាធ្វើកើតបានដូចប្រាថ្នា

មែន ហើយដុសខាត់ឡើងរលោងភ្លឺថ្លាដូចគ្នា ដូចព្រះធំ ធំឥតស់
លោកអ្នកសប្បុរសចូរនាំគ្នាមកសក្ការៈនេះ ។

តួនឿងឆ្ងល់ដែរតាលដែលផ្តើមផ្សាពុម្ពនោះ ប្រហែលជាមានវត្ថុសក្តិ
សិទ្ធិអ្វីមួយមកបណ្តាលទេដឹង ? ចានជាវកែតាត់សោះនៅពុម្ពនោះ
ភ្ញាក់ឃើញឆាប់ បន្ទាយពេលទុកឲ្យចានយូរមកដល់ពាក់កណ្តាលសាសនា
នេះ ទើបឲ្យត្រូវកើត ។ តាមពិត ការយឺតយូរទាំងនេះ មិនមែនមកពី
ពួកអ្នកផ្តើមសាងឯ ឬក្រុមជាងមានតំនិតគ្រប់បន្ទាយពេលទុកឲ្យយឺតយូរ
ដូចតាក្យចចាមតាំម ដែលថា ពួកអ្នកផ្តើមកសាងធ្វើឲ្យយឺតយូរ
ដើម្បីឃោសនាវេចប្រឡោជន៍ខ្លួនខោះទេ, ព្រោះតែបៀសអត់តាក្យចចាម
អាំមនេះហើយចានជាសាងរហ័យក្លាម ប្រញាប់ប្រញាល់ធ្វើពុណ្យ
អតិសេកក្លាម មិនចាំដល់ពុណ្យពាក់កណ្តាលសាសនា ដើម្បីថ្វាយព្រះធំ
ដូចអស់លោក-អ្នកដែលចានចាប់កុសលខោះបីប្រព័ន្ធតិច អនុមោទនា
យកផលានិសង្សរឿងអង្គរឿងខ្លួន ។

ខ្ញុំព្រះបង្គំខ្ញុំចាទសូមប្រកាសដឹងឮរាំកជាថ្មីទៀតថាប្រាក់ ឆាស
សាច់ប្រាក់ ស្អាត ដែលព្រះធំធំឥតស់លោក-អ្នកចានចូលក្នុងការកសាង
ព្រះពុទ្ធរូបនេះ:ឥឡូវនេះមុនអ្នកចូល ក្នុងពេលពុណ្យរំលាយស្តាត់ពាក់ព័ន្ធ
ពីថ្ងៃទី ៤ ដល់១៣ មេសា ១៩៥៥ ក្នុងរយៈពេល ៩ថ្ងៃ ៦យប់នៅ
ទីវត្តចូលតាតូនេះម្តង, ចូលក្នុងការធ្វើពុណ្យដាច់ពុណ្យខែមន្តលោក
ឆាន់ម្តង, ហើយនិងចូលផ្តាល់ចំពោះអ្នកផ្តើមសាងនោះ ក្រែកដាចានយក
មកសាងជាព្រះពុទ្ធរូបនេះមែន, ក្រៅពីនេះចូលព្រះបង្គំ ខ្ញុំចាទ និង

អ្នកផ្តើមកសាងឥតបានទទួលទេ, ចំណែកខាងទ្រង់ នឹងអស់លោក-អ្នក
ដែលបានចូលខាងលោកត្រូវៀមធិការវត្ត នោះលោកបានចូលផ្ទើតេព្រះ
មោលីខ្ទះទេ ក្រៅពីនេះ លោកដាក់ទៅក្នុងការកសាងព្រះវិហារវត្តនេះ
ទៅហើយ ដូចទ្រង់នឹងអស់លោក អ្នកយើញកស្ពុតាងស្រាប់, តែសូម
ជ្រាបថា បើទុកជាមិនបានសាមតាមបំណងខ្ទះក្តី ក៏ទូលព្រះបង្គំ ខ្ញុំបាទ
សូមទុកការជ្រះថ្លាវបស់ទ្រង់ នឹងអស់លោក-អ្នកថាបានកសាងព្រះពុទ្ធរូប
នេះជាមួយគ្នាដែរ សូមឲ្យបានជលានិសង្សដូចគ្នា សូមទទួលអនុមោទនា!

ត្រឿងទូបការណ៍នឹងបំណាយសរុប.- ព្រះពុទ្ធប្បដិមាការនេះ
មានកំពស់ ៤ម៉ែត្រ, ព្រះក្នែន ១ ម៉ែត្រ ៨០ សង្ទីម៉ែត្រ, ព្រះមោលីជាំក្សូន
ស ៤៣៨ គ្រាប់, ព្រះនេត្រជាំក្សូនមកិត, ដាក់អំពូលអគ្គីសនីក្នុងព្រះ
សីរបញ្ជាំងក្នើងពីខាងក្នុង ។ កាលដែលរំលាយលោហធាតុចាក់ពុម្ពសិត
ព្រះពុទ្ធរូបនេះ មានលាយមាស ៣ ភីឡូក្រាម សាប់ប្រាក់ ៤៨ ភីឡូក្រាម
ស្ពាន់ ទង់ដែង លង្ហិន សម្រឹទ្ធ ១.១៦៩ ភីឡូក្រាម ចូកសូមជា ១.២០០
ភីឡូក្រាម ។

ប្រាក់ចំណាយកសាងចូកសូមទាំងអស់តាំងពីចាប់ផ្តើមផ្ទើពុម្ព រហូត
ដល់សិតបានជាតួអង្គព្រះពុទ្ធប្បដិមាការនោះឡើង អស់ចំនួន ១៧១.
៤៣៨៤៥០ មិនគិតថ្ងៃមាសប្រាក់ស្ពាន់ទេ ។

អ្នកផ្តើមកសាង ព្រមទាំងទូលព្រះបង្គំ ខ្ញុំបាទ មានយោបល់
យល់យើញរួមគ្នា សូមថ្វាយព្រះពុទ្ធប្បដិមាការនេះ នឹងសូមព្រះបរម.
តាមព្រះករុណាជាអម្ចាស់ជីតិះលីក្ស្ឌ, សម្តេចព្រះមហាក្សត្រិយានី

ទីធ៌សម្តេចព្រះទេបឃុវាង ចិតាឯកពាជ្យជាតិ ដើម្បីចារឹកនៅជាយសន្ធាដ៏
ព្រះពុទ្ធរូបនេះ ទុកជាអនុស្សាវរីយ៍តបស្នងសងព្រះមហាករុណាគុណ
ក្នុងរជ្ជកាលរបស់ព្រះអង្គ ជាទីគោរព ទីធ៌ជាទីស្រឡាញ់របស់ពលរដ្ឋ
គ្រប់គ្នា ។ ព្រះករុណាទាំងពីរព្រះអង្គបានទ្រង់ព្រះពាជាទុញ្ញាតហើយ ។

ខ្ញុំលព្រះបង្គំ ខ្ញុំបាទ សូមសរសើរតវាជាថ្នូរស្នាដៃជាធំខ្មែរ
ដែលបានព្យាយាមពាំរោងសិតសាង ដាបដល់បានសម្រេចជាតួអង្គ
ព្រះពុទ្ធរូបដ៏ខាតវិសិដ្ឋធ្វើតាយនេះឡើង ដែលគួរឲ្យឃុំដែនពលរដ្ឋខ្មែរ
អ្នកស្រឡាញ់សិល្បៈខ្មែរ ទីធ៌ទេសាហកម្មខ្មែរ យកតម្រាប់តាម ។

មួយទៀត មានតាមេរ៉ាង ដែលមិនឲ្យខ្ញុំលព្រះបង្គំខ្ញុំបានបំភ្លេចបាន
គឺការកុសលដែលកើតព័ចិត្តសទ្ធាដ៏ក្លៀវក្លាអធិដ្ឋានរបស់ក្រមការយើង្គព្រះ
ជាតអគ្គចន្ទទី ១ ដែលមានលោក សុខ ជាមេបញ្ជាការ បានអញ្ជើញមក
សង់ពេជ្ឈបុណ្យអតិសេកយ៉ាងធំកន្លងវត្តនេះ ដោយមិនតិតឡើយហត់មិន
ខ្លាចខាតពេលវេលា ទោះបីទុបសគ្គដាយខ្លះខាតយ៉ាងណា ក៏ខំតស៊ូ
ទាល់តែបានសម្រេចជាពេជ្ឈនេះឡើង ក្នុងពេលកំពុងខ្វល់ខ្វាយច្រាក់ចាត់
ការផង, នេះហើយជាអនុស្សរណកុសលមួយដែលគួរឲ្យលព្រះបង្គំ
ខ្ញុំបានទឹកសរសើរពុំក្រេច ព្រមទាំងអរគុណយ៉ាងច្រាលច្រៃផង ។

នៅទីបញ្ចប់នេះតាងនាមក្រុមពុទ្ធបរិស័ទអ្នកឆ្លើមតសាងនិងក្រុមជាង
ចាំងឡាយ លព្រះបង្គំ ខ្ញុំបាទ សូមបង្ហើនកុសលដ៏ប្រសើរដែលកើត
ពីការព្យាយាមសាងព្រះពុទ្ធរូបនេះ ថ្វាយជាព្រះពរកុសលចំរោះព្រះ
ករុណាជាអម្ចាស់ដ៏វិសេសលើសួង, សម្តេចព្រះមហាក្សត្រិយានី, សម្តេចព្រះ

ឧបយុវរាជ សូមបួងសួងគុណ ព្រះរតនត្រ័យ នឹងវត្ថុសក្តិសិទ្ធិក្នុងលោក ជួយអភិបាលរក្សាព្រះករុណាទាំងបីព្រះអង្គ សូមទ្រង់ឆង់នៅជាបរមសុ១ ត្រប់ប្រការ នឹងទ្រង់ប្រកបដោយសិរីសួស្តីដោតជ័យជំនះឈ្នះមារសត្រូវ ត្រប់ទិសានុទិសអស់កាលជានិរន្តរ៍!

សូមជូនកុសលជល់ទ្រង់ នឹងអស់លោក-អ្នកពុទ្ធបរិស័ទដែលមាន សទ្ធាជ្រះថ្លាបានចាប់កុសលក្នុងការសាងព្រះពុទ្ធប្បដិមាការនេះតាំងពីពេល ដំបូងដរាបដល់បានមកដ្ឋីបុណ្យអភិសេកនេះ សូមជលានិសង្សនេះ ជួយ ឧបត្ថម្ភទ្រង់នឹងអស់លោក-អ្នកទាំងឡាយឲ្យបានសេចក្តីសុខចម្រើនត្រប់ ប្រការ នឹងសូមឲ្យបានប្រកបដោយសម្បត្តិមនុស្ស សម្បត្តិសួគិ សម្បត្តិ ព្រះនិព្វាន ដូចសេចក្តីប្រាថ្នា កុំបីឃ្លៀងឃ្លាតឡើយ សូមទទួល អនុមោទនា!

– ឥម៉ន៊ នបុ. "កម្មនៃភ្ជើង" ការបូជាភ្ជើង, ការបូជាអគ្និ ។ – ឥល្យ បុ. កល្យៈ
ដោយភ្ជើង ។ – ឥាយ៌ នបុ. អគ្និការ្យ, ពិធីបូងសូងព្រះអគ្និ ។ – ឥុក្ពុដ បុ. អង្គត់
ឈស, កន្ទុយឈស ។ – ឥុណ្ឌ នបុ. ផើងក្រានភ្ជើង ។ – ឥុមារ បុ. ការឡ្ងាំ ។
– ឥេតុ គុ. ដែលមានភ្ជើងជាទង់ ។ – ឥ្រីឌា ស្ត្រី. អគ្និក្រីឌា, ក៏ឡាភ្ជើង, ការហែភ្ជើង ។
– ឥតិ គុ. ដែលមានភ្ជើងជាគតិ, ។ – ឥតា ស្ត្រី. ឈ្មោះឈើមហាផ្សោតិម្មតី ។
– ឥម្ចុហ នបុ. ផ្ទះភ្ជើង ។ – ចយ បុ. – ចយន នបុ., – ចិតិ ស្ត្រី. – ចិត្យា
ស្ត្រី. ក៏រិយាបម្រើភ្ជើង ។ – ចិត៊ . ដែលបម្រើភ្ជើង ។ – ជ គុ. ដែលកើត
ដោយភ្ជើង, បុ. នាមព្រះវិម្ណុ ។ – ជន្ធ៊ន៊ បុ. អ្នកបង្កើតភ្ជើង, ស្តន្ធជាទេវតាទាងចម្បាំង ។
– ជិវ្ហ គុ. "មានអណ្ណាតជាភ្ជើង" ព្រះអគ្និ, – ជិវ្ហ ស្ត្រី. អណ្ណាតនៃភ្ជើង ។ – ជ្វលិត-
ឥេជន គុ. (សរ) ដែលមានចុងក្រហមដោយភ្ជើង ។ – ជ្វាល បុ. នាមព្រះសិរ
– ជ្វាលា ស្ត្រី. អណ្ណាតនៃភ្ជើង; ដើមឈើដែលមានផ្កាប្រហម ។ – ឥប៊ គុ. ដែល
រីកភយដោយកំដៅនៃភ្ជើង ។ – ឥប្ត គុ. ដែលត្តៅដោយភ្ជើង ។ – ឥេជស៊
ដែលមានភ្ជើងជាគេជៈ ។ – ត្រយ នបុ. ឬ ត្រេតា ស្ត្រី. ប្រជុំបីនៃព្រះអគ្និ គឺ គាហ៊បត្យ,
អាហវនីយ, នឹង ទក្ឌិណៈ ។ – ទ, បុ. "អ្នកឲ្យភ្ជើង" អគ្និភ៊យ ។ – ទត្ត គុ. ដែលធេះ
ហើយដោយភ្ជើង, ដែលធេះហើយលើដើងឡ; បុ. ព្រាហ្មណ៍បិត្ថ្ថសអ្នករក្សាភ្ជើង ។ – ទត្ត
បុ. នាមពួកព្រាហ្មណ៍ ។ – ទមន៊ ស្ត្រី. ឈ្មោះឈើ ។ – ទាហ បុ. ជម្ងឺ;
កំដៅនៃភ្ជើង ។ – ទិត៊ ស្ត្រី. ំ សអគ្នេយ៍ ។ – ទីបន៊ គុ. ដែលធ្វើឲ្យស្រួលប្រពៈ ។
– ទីប្ត គុ. ដែលភ្ជឹដោយភ្ជើង ។